ព្រះគម្ពីរមរមន

ស្បៀវភៅណែនាំការសិក្សា សំរាប់សិស្ស

រៀបចំដោយ
ប្រព័ន្ធអប់រំនៃសាសនាចក្រ

បោះពុម្ពផ្សាយដោយ
សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុងសល្តឡេក, យូថាហ៍

ទំព័រ 84–85, 87, 99, 102, 104, 106, 110, 113, 132–33, 135, 137, 142,
145–46, 149, 151, 158, 202: រូបតាពចេញពី *The Book of Mormon Story*
© 1966 Ronald K. Crosby.

© 2000 ដោយ Intellectual Reserve, Inc.
រក្សាសិទ្ធគ្រប់យ៉ាង
បោះពុម្ពនៅសហរដ្ឋអាមេរិក

អនុម័តជាភាសាអង់គ្លេស: 8/98
អនុម័តឱ្យបកប្រែ: 8/98
ការបកប្រែនៃ *Book of Mormon Student Study Guide*
Cambodian

មាតិកាអត្ថបទ

របៀបប្រើស្បៃវរភោសិក្សានេះ 1
ការសិក្សាព្រះគម្ពីរ 2
តារាង នៃការអានព្រះគម្ពីរមរមន 6
ព្រះគម្ពីរមរមន សូមស្វាគមន៍ 8

ទំព័របុព្វកថា នៃព្រះគម្ពីរមរមន 9
ទំព័រចំណងជើង ហេតុអ្វី និងតាមរបៀបណា ដែលព្រះគម្ពីរមរមនត្រូវបានសរសេរ 9
បុព្វកថា ទិបន្ទាល់ ឬការពន្យល់ខ្លីៗ 9
និងឈ្មោះតាមលំដាប់ស្បៃវរភោ 9

ផ្នាំងទីមួយរបស់នីហៃ 13
នីហៃទី1 1 ព្យាការីលីហៃ ត្រូវបានហៅឱ្យទៅ ព្រមានពួកសាសន៍យូដា 13
នីហៃទី1 2 “ខ្ញុំបានអំពាវនាវដល់ព្រះអម្ចាស់ ហើយសូមមើលចុះ ទ្រង់បានយាងមកជួបនឹងខ្ញុំ” 15
នីហៃទី1 3–4 មានសេចក្តីជំនឿ ព្រះអម្ចាស់នឹងជួយអ្នក 16
នីហៃទី1 5–6 សារៈសំខាន់នៃបញ្ជីប្រវត្តិពិសិដ្ឋ 17
នីហៃទី1 7 អ៊ីសម៉ាអែល ចូលរួមជាមួយលីហៃទៅឯទីរហោស្ថាន 18
នីហៃទី1 8 ការសុបិន្តរបស់លីហៃ 19
នីហៃទី1 9 ផ្នាំងពីរផ្ទៃក 20
នីហៃទី1 10 ការព្យាករណ៍របស់លីហៃ 21
នីហៃទី1 11–12 នីហៃបានរៀនអំពីព្រះគ្រីស្ទ និងបេសកម្មរបស់ទ្រង់ 22
នីហៃទី1 13 ទស្សនៈនិមិត្តសំរាប់សម័យចុងក្រោយ 23
នីហៃទី1 14 ទស្សនៈនិមិត្តរបស់នីហៃ អំពីសាសន៍ដទៃទៅសម័យចុងក្រោយ 25
នីហៃទី1 15 នីហៃបង្រៀនបងប្អូនរបស់គាត់ 26
នីហៃទី1 16 ជុំមូល និងធ្នូបាក់ យ៉ាងចំឡែក 27
នីហៃទី1 17 “ចូរអ្នកសង្ឃឹមសំពោមួយ” 27
នីហៃទី1 18 ការធ្វើដំណើរទៅកាន់ដែនដីសន្យា 29
នីហៃទី1 19 “ដើម្បីបង្ហាញបញ្ជាល ពួកគេឱ្យបានច្រើន ថែមទ្បើត ឱ្យជឿដល់ព្រះអម្ចាស់” 30
នីហៃទី1 20–21 សារដំណឹងមកពីព្យាការីអេសាយ 31
នីហៃទី1 22 ព្រឹត្តិការណ៍នៅថ្ងៃចុងក្រោយ 33

ព្រះគម្ពីរទីពីរនៃនីហៃ 34
នីហៃទី2 1 “ឱកូនប្រុសទាំងឡាយរបស់ឯពុកអើយ ចូរកូនភ្ញាក់ឡើង” 34
នីហៃទី2 2 សេរីភាពដើម្បីជ្រើសរើស ដោយសារតែដង្វាយធួន 36
នីហៃទី2 3 យ៉ូសែប បានព្យាករណ៍អំពី យ៉ូសែបម្នាក់ទ្បើត 38
នីហៃទី2 4 ទំនុកដំកើងរបស់នីហៃ 39
នីហៃទី2 5 គ្រួសារបែកបាក់មួយ 39
នីហៃទី2 6 យ៉ាកុបបានបង្រៀនប្រជាជន ពីការសរសេររបស់ព្យាការីអេសាយ 40
នីហៃទី2 7 ព្រះអម្ចាស់ជួយអស់អ្នកណា ដែលទុកចិត្តទៅលើទ្រង់ 41
នីហៃទី2 8 “សូមគេនទ្បើង សូមគេនទ្បើង!” 42
នីហៃទី2 9 “ឱ ផែនការណ៍នៃព្រះរបស់យើងធំណាស់ន៏!” 42
នីហៃទី2 10 ភាពពេញលេញនៃ សេចក្តីសញ្ញារបស់ព្រះអម្ចាស់ 44
នីហៃទី2 11 សាក្សីទាំងបីនាក់របស់ព្រះយេស៊ូវគ្រីស្ទ 44
នីហៃទី2 12 មកកាន់ភ្នំនៃព្រះអម្ចាស់ 45
នីហៃទី2 13–14 “ពួកកូនស្រីក្រុងស៊ីយ៉ូន” 46
នីហៃទី2 15 អំពើបាបនិងផលនៃអំពើបាប 47
នីហៃទី2 16 លោកអេសាយបានយោបល់ព្រះអម្ចាស់ 48
នីហៃទី2 17–19 ការព្យាករណ៍ពីព្រះមែស៊ី 49
នីហៃទី2 20 សត្វប្រជាជនរបស់ព្រះ នឹងត្រូវកំទេចចោល 50
នីហៃទី2 21–22 ថ្ងៃដ៏អស្ចារ្យរបស់ព្រះអម្ចាស់ 51
នីហៃទី2 23–24 ការធ្លាក់ចុះនៃបាប៊ីឡូន 52
នីហៃទី2 25 “ជឿដល់ព្រះគ្រីស្ទ” 53
នីហៃទី2 26 នីហៃព្យាករអំពីកូនចៅរបស់លោក 54
នីហៃទី2 27 ការលេចចេញមកនៃព្រះគម្ពីរមរមន 55
នីហៃទី2 28 អំពើបាប និងអន្ទាក់នៅថ្ងៃចុងក្រោយ 56
នីហៃទី2 29 “ព្រះគម្ពីរ!ព្រះគម្ពីរ! យើងមានព្រះគម្ពីរមួយហើយ 57
នីហៃទី2 30 អំណាចរបស់ព្រះគម្ពីរមរមន 58
នីហៃទី2 31 គោលលទ្ធិរបស់ព្រះគ្រីស្ទ 59
នីហៃទី2 32 នីហៃបន្តបង្រៀនពីគោលលទ្ធិរបស់ព្រះគ្រីស្ទ 60
នីហៃទី2 33 សក្តិភាពចុងក្រោយរបស់នីហៃ 61

គម្ពីរយ៉ាកុប 62
យ៉ាកុប 1 តួនាទីរបស់ព្យាការី 62
យ៉ាកុបទី 2–3 យ៉ាកុបបង្រៀន ប្រជាជននៅក្នុងព្រះវិហារបរិសុទ្ធ 63
យ៉ាកុប 4 ចូរស្រុះស្រួលនឹងព្រះ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ 64
យ៉ាកុប 5–6 រូបាធិដ្ឋាននៃដើមអូលីវ 65
យ៉ាកុប 7 ចំណេះដឹងរបស់មនុស្ស ទល់នឹងអំណាចរបស់ព្រះ 68

គម្ពីរអេណុស 69
អេណុស1 អំណាចនៃការអត់ឱនទោស 69

គម្ពីរយ៉ារ៉ុម 70
យ៉ារ៉ុម 1 កាន់តាមបទបញ្ជាតទាំងឡាយ នោះនឹងបានចំរើនឡើង 70

គម្ពីរអោមណៃ 71
អោមណៃ 1 សេចក្តីសង្ខេបអំពីស្តេចចាប់ពី អោមណៃទៅ ស្តេចយេនយ៉ាមីន 71

ពាក្យរបស់មរមន 73
ពាក្យសំដីនៃមរមន 1 ពាក្យនៃការពន្យល់ 73

គម្ពីរម៉ូសាយ 74
ម៉ូសាយ 1 សារៈសំខាន់នៃបញ្ជីប្រវត្តិពិសិដ្ឋ 75
ម៉ូសាយ 2 ការបំរើព្រះ 76
ម៉ូសាយ 3 ការព្យាករណ៍អំពីព្រះគ្រីស្ទ 77
ម៉ូសាយ 4 ការទទួល និងការរក្សា ការផ្តាច់បាបរបស់យើង 78
ម៉ូសាយ 5 ការប្រែក្លាយជាកូនចៅនៃព្រះគ្រីស្ទ 79
ម៉ូសាយ 6–7 ប្រជាជនលីមហៃ រស់នៅក្រោមសេវកភាព 80
ម៉ូសាយ 8 តើអ្វីទៅជាអ្នកមើលឆុត? 81
ម៉ូសាយ 9–10 ការចាប់ផ្តើមនៃបញ្ជីប្រវត្តិរបស់សិទ្ធិ 82
ម៉ូសាយ 11–12 ស្តេចទុច្ចរិត ណូអេ និងព្យាការីអ័ប៊ីណាដៃ 83
ម៉ូសាយ 13–14 អ័ប៊ីណាដៃប្រឈមមុខនឹងពួកសង្ឃទុច្ចរិត 84
ម៉ូសាយ 15–16 អ័ប៊ីណាដៃបង្រៀនពីព្រះយេស៊ូវគ្រីស្ទ ហើយពន្យល់ថា ទរណាទនឹងត្រូវបានសង្គ្រោះ 86
ម៉ូសាយ 17–18 អាលម៉ាជឿអ័ប៊ីណាដៃ 88
ម៉ូសាយ 19 ទិបញ្ជាប់របស់ស្តេចទុច្ចរិតណូអេ 90
ម៉ូសាយ 20 ប្រជាជនលីមហៃច្បាំង ដើម្បីការពារគ្រួសាររបស់ពួកគេ 90
ម៉ូសាយ 21–22 សេវកភាព និងការរំដោះ 91
ម៉ូសាយ 23–24 សេវកភាព និងរំដោះសំរាប់ប្រជាជនរបស់អាលម៉ា 92
ម៉ូសាយ 25 អាលម៉ាបានរៀបចំសាសនាចក្ររបស់ព្រះ 94
ម៉ូសាយ 26 ការក្បត់សាសនា ទាំងទាន់មនុស្សដែលកំពុងកើនឡើង 95

ម៉ូសាយ 27 ការផ្លាស់ប្តូរតំនិតរបស់អាលម៉ាជាកូន 96
ម៉ូសាយ 28 ស្តេចម៉ូសាយ ជាអ្នកមើលឆុត 98
ម៉ូសាយ 29 ទីបញ្ចប់នៃស្តេច និងការចាប់ផ្តើមនៃចៅក្រម 99

គម្ពីរអាលម៉ា 100
អាលម៉ា 1 អាលម៉ា និងនីហ្គរ 100
អាលម៉ា 2–3 ការបះបោរនៃពួកសាសន៍អាំលិសៃ 102
អាលម៉ា 4 អាលម៉ាប្រគល់វេទិការដំនុំដំរះ 103
អាលម៉ា 5 មានការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្ត 103
អាលម៉ា 6–7 អាលម៉ាផ្សព្វផ្សាយនៅក្នុងទីក្រុងតេខាន 105
អាលម៉ា 8 អាលម៉ា ជួបអាមូលេក 106
អាលម៉ា 9 អាលម៉ាប្រកាសអំពីការប្រែចិត្ត
ទៅកាន់ប្រជាជននៅដែនដីអាំម៉ូណៃហា 107
អាលម៉ា 10 ទីបន្ទាល់របស់អាមូលេក 108
អាលម៉ា 11 ជំណើរត្រឡប់ទៅវិញ “នឹងបានដល់មនុស្សគ្រប់រូប” 109
អាលម៉ា 12 អាលម៉ាបង្រៀនអំពីផែនការសង្គ្រោះ 110
អាលម៉ា 13 បញ្ហាដិតភាពនៃព្រះ 111
អាលម៉ា 14 សារលិខិតនៃជំណឹងល្អធ្វើឱ្យពួកទុច្ចរិតខឹង 111
អាលម៉ា 15 បេសកកម្មទៅក្នុងដែនដីសៃរ៉ុម 112
អាលម៉ា 16 ទីអវសាន្ត នៃទីក្រុងអាំម៉ូណៃហា 113
អាលម៉ា 17 បេសកកម្មទៅកាន់ពួកសាសន៍លេមិន 114
អាលម៉ា 18 ការផ្លាស់សាសនារបស់ស្តេចឡាម៉ូណៃ 114
អាលម៉ា 19 ព្រះអគ្គមហេសីរបស់ស្តេចឡាម៉ូណៃ និងអ្នកដទៃទៀត
បានផ្លាស់សាសនា 115
អាលម៉ា 20 អាំម៉ូនជួបចិតារបស់ឡាម៉ូណៃ 116
អាលម៉ា 21 អាំម៉ូន និងបងប្អូនរបស់គាត់ បង្រៀនពួកសាសន៍លេមិន 117
អាលម៉ា 22 អើរ៉ុនបង្រៀនដល់ស្តេចរបស់ប្រជាជនឡាម៉ូណៃ 118
អាលម៉ា 23 ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ 119
អាលម៉ា 24 រក្សាសេចក្តីសញ្ញា 119
អាលម៉ា 25 ការព្យាករណ៍ត្រូវបានសំរេច 120
អាលម៉ា 26 “ដោយកម្លាំងរបស់ទ្រង់ ខ្ញុំអាចធ្វើកិច្ចការគ្រប់យ៉ាង” 121
អាលម៉ា 27 ផ្ទះថ្មីសំរាប់ពួកសាសន៍ អាន់តៃ-នីហ្វៃ-លីហៃ 122
អាលម៉ា 28 ពួកសាសន៍នីហ្វៃការពារប្រជាជនរបស់អាំម៉ូន 123
អាលម៉ា 29 “ឱ ខ្ញុំចង់បានទៅជាទេវតាមួយ” 123
អាលម៉ា 30 កូរីហ្គរ ជនដែលទទឹងនឹងព្រះគ្រីស្ទ 124
អាលម៉ា 31 បេសកកម្មទៅដល់ពួកសាសន៍ស៊ូរ៉ាំ 125
អាលម៉ា 32 ធ្វើការពិសោធន៍ដល់ពាក្យសំដី 126
អាលម៉ា 33 ពាក្យទាំងឡាយ ដែលពួកគេគួរតែបណ្តុះឡើង 127
អាលម៉ា 34 ផែនការនៃសេចក្តីក្រាលលោះអស់កល្បជានិច្ច 128
អាលម៉ា 35 ពួកសាសន៍ស៊ូរ៉ាំ ដែលផ្លាស់ប្រែចិត្ត
ស្បថសច្ចូនចូលទៅក្នុងដែនដីយើសុន 129
អាលម៉ា 36 អាលម៉ាបង្រៀនហេលេមិន អំពីការផ្លាស់គំនិតរបស់គាត់ 129
អាលម៉ា 37 “ចូររៀនទៅក្នុងយុវវ័យរបស់កូន” 130
អាលម៉ា 38 អាលម៉ាឱ្យជំបូទ្ធាន ដល់សិបឡុនជាកូនប្រុសរបស់គាត់ 131
អាលម៉ា 39 ប្រភេទនៃអំពើបាបខាងកាមគុណដ៏ធ្ងន់ធ្ងរ 132
អាលម៉ា 40 ពិភពវិញ្ញាណ និងការសាងឡើងវិញ 133
អាលម៉ា 41 “អំពើទុច្ចរិតពុំ ដែលជាសុភមង្គលឡើយ” 134
អាលម៉ា 42 សេចក្តីមេត្តាករុណា និងសេចក្តីយុត្តិធម៌ 134
អាលម៉ា 43 ពួកសាសន៍នីហ្វៃការពារផ្ទះសំបែង សេរីភាព គ្រួសារ
និងសាសនារបស់ពួកគេ 135
អាលម៉ា 44 ជ័យជំនះរបស់សាសន៍នីហ្វៃ 135
អាលម៉ា 45 ក្នុងឱកាសលាគ្នារបស់អាលម៉ា 137
អាលម៉ា 46 ទង់ឥស្សរភាព 138
អាលម៉ា 47 បុរសដែលចង់ធ្វើជាស្តេច 139
អាលម៉ា 48 មេទ័ពម៉ូរ៉ូណៃ បុរសរបស់ព្រះ 139
អាលម៉ា 49 ជ័យជំនះរបស់ពួកសាសន៍នីហ្វៃ 140
អាលម៉ា 50 ព្រះអម្ចាស់ទីងចំរើនដល់កូនចៅស្តាប់បង្គាប់របស់ទ្រង់ 141
អាលម៉ា 51 ការប្រឆាំងជាមួយពួកអ្នកនិយមស្តេច 141
អាលម៉ា 52 ជ័យជំនះរបស់ពួកនីហ្វៃ 142
អាលម៉ា 53 កងពលកំឡោះពីរពាន់ទាក់ 143
អាលម៉ា 54 ការផ្លាស់ប្តូរសំបុត្រ 144
អាលម៉ា 55 ពួកឈ្លើយសង្គ្រាមសាសន៍នីហ្វៃ ត្រូវបានទទួលសេរីភាព 144
អាលម៉ា 56 កងពលកំឡោះពីរពាន់ទាក់នៅក្នុងចម្បាំង 145
អាលម៉ា 57 កងទ័ពកំឡោះពីរពាន់ទាក់រួចផុតពីសេចក្តីស្លាប់ 146
អាលម៉ា 58 ពួកសាសន៍នីហ្វៃ យកបានទីក្រុងម៉ាន់តៃ 146
អាលម៉ា 59 ម៉ូរ៉ូណៃបញ្ជូនកំលាំងដំនួយ 147
អាលម៉ា 60 សំបុត្ររបស់ម៉ូរ៉ូណៃទៅកាន់ពេហូរ៉ាន 147
អាលម៉ា 61 ការឆ្លើយតបរបស់ពេហូរ៉ានទៅម៉ូរ៉ូណៃវិញ 148
អាលម៉ា 62 ម៉ូរ៉ូណៃធ្វើដំណើរទៅជួយពេហូរ៉ាន 148
អាលម៉ា 63 ការផ្លាស់ទីលំនៅរបស់ពួកសាសន៍នីហ្វៃទៅកាន់ដែនដីទំនាងជើង . 149

គម្ពីរហេលេមិន 150
ហេលេមិន 1 សង្គ្រាមនៅក្នុងដែនដីសារ៉ាហិមឡា 151
ហេលេមិន 2 បក្សពួកកាឱអានតុន 151
ហេលេមិន 3 ពេលវេលានៃការចំរុងចំរើន និងការចំរើនឡើង 152
ហេលេមិន 4 អំពើទុច្ចរិត និងផលវិបាក 153
ហេលេមិន 5 នីហ្វៃ និងលីហៃ នៅក្នុងគុក 155
ហេលេមិន 6 ការចំរុងចំរើនទាំងទៅរកអំពើទុច្ចរិត . . . ម្តងទៀត! 155
ហេលេមិន 7 នីហ្វៃប្រកាសពីការប្រែចិត្ត ទៅដល់ប្រជាជនរបស់គាត់ 155
ហេលេមិន 8 ការព្យាករណ៍អំពីឃាតកម្ម 156
ហេលេមិន 9 ឃាតករត្រូវបានរកឃើញ 157
ហេលេមិន 10 នីហ្វៃទទួលបានអំណាចយ៉ាងអស្ចារ្យ 158
ហេលេមិន 11 នីហ្វៃប្រើអំណាចរបស់គាត់ក្នុងទាមទាប្រជាជន 158
ហេលេមិន 12 “ហើយយើងឃើញបែបនេះថា” 159
ហេលេមិន 13 សាំយូអែលជាសាសន៍លេមិន ព្យាករទៅកាន់ពួកសាសន៍នីហ្វៃ . . 160
ហេលេមិន 14 សញ្ញានៃការប្រសូត្រ និងការសុគតរបស់ព្រះគ្រីស្ទ 161
ហេលេមិន 15 “បើអ្នកពុំប្រែចិត្តទេ . . .” 162
ហេលេមិន 16 ប្រតិកម្មចំពោះការប្រកាសរបស់សាំយូអែល 163

នីហ្វៃទីបី គម្ពីរនីហ្វៃ 164
នីហ្វៃទី3 1 “ហើយថ្ងៃស្អែកឡើងយើងនឹងយាងមកឯលោកិយ” 164
នីហ្វៃទី3 2 ការណ៍អស្ចារ្យកំឡុងពេលមានអំពើទុច្ចរិត និងសង្គ្រាម 165
នីហ្វៃទី3 3–4 ចោរកាឱអានតុនតំរាមតំហែងប្រជាជន 165
នីហ្វៃទី3 5 ការពន្យល់ និងទីបន្ទាល់មកពីលោកមរមន 166
នីហ្វៃទី3 6 ពិសុទ្ធរិតទៅ “ទុច្ចរិតដ៏គួរស្អែងខ្លាច” 167
នីហ្វៃទី3 7 ការបំបែកចេញដ៏ធំមួយ 168
នីហ្វៃទី3 8 ការបំផ្លិចបំផ្លាញ និងសេចក្តីងងឹត 169
នីហ្វៃទី3 9–10 សំលេងរបស់ព្រះយេស៊ូវ ចាក់ចូលទៅក្នុងសេចក្តីងងឹត 169
នីហ្វៃទី3 11 ព្រះអង្គសង្គ្រោះទ្រង់លេចមក! 171
នីហ្វៃទី3 12 ទេវទូតថ្លានៅព្រះវិហារបរិសុទ្ធ ផ្នែកទីមួយ 172
នីហ្វៃទី3 13 ទេវទូតថ្លានៅព្រះវិហារ ផ្នែកទីពីរ 173
នីហ្វៃទី3 14 ទេវទូតថ្លានៅឯព្រះវិហារបរិសុទ្ធ ផ្នែកទីបី 174
នីហ្វៃទី3 15–16 ត្រកូវរិទ័យលោកម៉ូសេ និង “ច្បាមដទៃ” 175
នីហ្វៃទី3 17 “សេចក្តីអំណាររបស់យើងបានពោរពេញហើយ” 176
នីហ្វៃទី3 18 ព្រះអង្គសង្គ្រោះណែនាំអំពីពិធីប្រសិទ្ធពរទំប៉ុង និងទឹក 177

នីហ្វៃទី3 19 ព្រះយេស៊ូវអធិស្ឋានជាមួយ និងសំរាប់ប្រជាជន 178
នីហ្វៃទី3 20–22 ការព្យាករណ៍អំពីកូនចៅក្នុងសេចក្តីសញ្ញា 179
នីហ្វៃទី3 23 សារៈសំខាន់នៃការសរសេរពាក្យ 180
នីហ្វៃទី3 24–25 ពាក្យព្យាករណ៍របស់ម៉ាឡាគី 181
នីហ្វៃទី3 26 ការសាកល្បងសំរាប់ប្រជាជនទៅក្នុងថ្ងៃចុងក្រោយ 182
នីហ្វៃទី3 27 “នេះគឺជំណឹងល្អរបស់យើង” 182
នីហ្វៃទី3 28 ចំណងព្រ្តាថ្មាពិសេស របស់ពួកសាវកទាំងដប់ពីរទាក់ 183
នីហ្វៃទី3 29–30 ការព្រមានរបស់លោកមរមន 184

នីហ្វៃទីបួនៈ គម្ពីរនីហ្វៃ 185
នីហ្វៃទី4 1 សន្តិភាពបួនដំទាន់ 185

គម្ពីរមរមន 186
មរមន 1 កំឡោះមរមន 187
មរមន 2 អ្នកដឹកនាំដ៏ខ្លាំងម្នាក់ នៅក្នុងចំណោមសេចក្តីទុច្ចរិត 188
មរមន 3 ឱកាសម្តងទៀត ការបដិសេធម្តងទៀត 188
មរមន 4 “ពួកទុច្ចរិតនឹងត្រូវធ្វើទោសដោយពួកទុច្ចរិត” 189
មរមន 5 គោលបំណង នៃបញ្ជីប្រវត្តិរបស់លោកមរមន 190
មរមន 6 “ការបំផ្លិចបំផ្លាញប្រជាជន” 190
មរមន 7 ទិបន្ទាល់របស់លោកមរមនចំពោះប្រជាជនរបស់លោក 191
មរមន 8 ម៉ូរ៉ូណៃ បានឃើញពីជំនាន់របស់យើង 192
មរមន 9 “ខ្ញុំដឹងថា អ្នករាល់គ្នានឹងឮពាក្យរបស់ខ្ញុំ” 193

គម្ពីរអេធើរ 194
អេធើរ 1 ពួកសាសន៍យ៉ារេឌទៅឯប៉ម នៃក្រុងបាបិល 195
អេធើរ 2 ពួកសាសន៍យ៉ារេឌសង់តេត្រា 195
អេធើរ 3 ទស្សនៈទិមិត្តដ៏ពិសិដ្ឋ 196
អេធើរ 4 ប្រែចិត្ត ហើយមករកព្រះគ្រីស្ទ 197
អេធើរ 5 ការសន្យាមួយ របស់សាក្សីបីទាក់ 198
អេធើរ 6 ពួកសាសន៍យ៉ារេឌឆ្លងកាត់សមុទ្រ 199
អេធើរ 7 កូនប្រុសទាំងឡាយរបស់អ៊ូរីអេហា 199
អេធើរ 8 ការរួមគំនិតស្ងាត់កំបាំងចាប់ផ្តើមមានឡើង 200
អេធើរ 9 ឥទ្ធិពលរបស់អ្នកទាំងឡាយដែលស្វែងរកអំណាច
និងផលប្រយោជន៍ 201
អេធើរ 10 ស្តេចរបស់សាសន៍យ៉ារេឌ 201
អេធើរ 11 ព្យាការី ព្រមានអំពីការបំផ្លិចបំផ្លាញ 202
អេធើរ 12 សារៈសំខាន់នៃសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស 202
អេធើរ 13 ក្រុងយេរូសាឡិមថ្មី 203
អេធើរ 14 ពេលវេលានៃសង្គ្រាម និងការបំផ្លិចបំផ្លាញដ៏ធំ 204
អេធើរ 15 ទិបញ្ចប់របស់សង្គមសាសន៍យ៉ារេឌ 204

គម្ពីរម៉ូរ៉ូណៃ 205
ម៉ូរ៉ូណៃ 1–3 សិទ្ធិអំណាច នៃបព្វជិតភាព 205
ម៉ូរ៉ូណៃ 4–5 ពាក្យអធិដ្ឋានប្រសិទ្ធពរនំប៉័ង និងទឹក 206
ម៉ូរ៉ូណៃ 6 សាសនាចក្រគួរបានរួមប្រជុំគ្នាជាញឹកញាប់ 207
ម៉ូរ៉ូណៃ 7 ព្រះវិញ្ញាណនៃព្រះគ្រីស្ទ នោះត្រូវបានប្រទានដល់មនុស្សគ្រប់រូប 207
ម៉ូរ៉ូណៃ 8 ពិធីបុណ្យជ្រមុជទឹក និងកុមារតូចៗ 208
ម៉ូរ៉ូណៃ 9 សេចក្តីសង្ឃឹមដ៏តិចតួចសំរាប់ពួកសាសន៍នីហ្វៃ 209
ម៉ូរ៉ូណៃ 10 ទិបន្ទាល់នៃព្រះគម្ពីរមរមន 210

ទីកន្លែងដែលអាចរកបាននៅក្នុងព្រះគម្ពីរមរមន
(មានការទាក់ទងជាមួយគ្នាទៅវិញទៅមក) 212

តារាងកាលប្រវត្តិព្រះគម្ពីរមរមន 213

របៀបប្រើសៀវភៅសិក្សានេះ

ដូចដែលចំណងជើងនៃបញ្ជីនេះបានស្នើ នេះគឺជាមគ្គុទ្ទេសក៍ សំរាប់ការសិក្សាព្រះគម្ពីររបស់អ្នក។ មានកណ្ឌជាច្រើន ដើម្បីជួយ បង្កើន ការយល់ដឹងរបស់អ្នក ពីអ្វីដែលអ្នកអាន។



ក្ក

បុព្ចកថា

នៅពីក្រោមក្បាល់រឿងជំពូក ដែលបានបោះពុម្ព នៅលើរូបភាព នៃផ្ទាំងចំណារ លោហៈ គឺជាបុព្ចយោគ នៃព្រះគម្ពីរ ដែលត្រូវបាន ចាត់តាំងអ្នក ឱ្យអាន។ កណ្ឌនេះ ផ្ទុកទៅដោយ ពត៌មានផ្សេងៗ ដែលមានដូចខាងក្រោមនេះ

- ការរៀបចំប្រវត្តិ
- ការពន្យល់ របៀបដែល បណ្ឌុំបទគម្ពីរ ទាក់ទងទៅនឹង ជំពូកមុន ឬជំពូកបន្ទាប់
- សំនួរ និងយោបល់ សំរាប់គិត ពីមុន ឬអំឡុងពេល ដែលអ្នកកំពុងអាន នឹងជួយអ្នក ឱ្យប្រមូល អារម្មណ៍ បានមូល ទៅលើដំណឹងនៃបណ្ឌុំនោះ។

ខ

ការយល់ដឹងអំពីព្រះគម្ពីរ

ផ្នែក "ការយល់ដឹងអំពីព្រះគម្ពីរ" ផ្តល់ការជួយ សំរាប់ពាក្យ និងឃ្លាពិបាកឲ និងការអត្ថាធិប្បាយ ដើម្បីជួយអ្នកអោយយល់ ពីយោបល់ និងគំនិតទាំងឡាយ ដែលមានទៅក្នុងព្រះគម្ពីរ។ សេចក្តីអត្ថាធិប្បាយ ជាញឹកញាប់តែងតែរួមបញ្ជូល ដោយសេចក្តី ថ្លែងពីអ្នកដឹកនាំទូទៅ នៃសាសនាចក្រ។

ក្ត

ការសិក្សាព្រះគម្ពីរ

កណ្ឌនៃ "ការសិក្សាព្រះគម្ពីរ" ផ្ទុកសំនួរ និងសកម្មភាព ដើម្បីជួយអ្នកឱ្យស្វែងរក, គិត, និងអនុវត្ត តាមគោលការណ៍នៃ ដំណឹងល្អ ដែលរកឃើញនៅក្នុងព្រះគម្ពីរ។ ត្មានកន្លែងដើម្បីសរសេរនៅក្នុងសៀវភៅសិក្សានេះទេ ដូច្នេះ អ្នកនឹងត្រូវធ្វើ សកម្មភាពទាំងនេះ នៅក្នុងសៀវភៅសរសេរ ឬនៅក្នុងក្រដាសផ្ទាល់ខ្លួន។

ជំហានទាំងឡាយ ខាងក្រោមនេះ នឹងជួយអ្នក នៅពេលអ្នកសិក្សាព្រះគម្ពីរៈ

- ចាប់ផ្តើមជាមួយនឹងការអធិស្ឋាន។
- អានបុព្ចកថា នៅជំពូកដែលអ្នកនឹងសិក្សា ហើយពិចារណា ជំនាញសិក្សា ផ្សេងទៀត នៅកណ្ឌ "មុនពេលអាន" (សូមមើលទំព័រ 2)។
- អានជំពូក ដែលគេបានចាត់ឱ្យអាន ដោយមើល នៅក្នុងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" ដែលសមរម្យ ដើម្បីរកជំនួយ។ សូមប្រើ ជំនាញសិក្សា ផ្សេងទៀត នៅកណ្ឌ "មុនពេលអាន" (សូមមើលទំព័រ 2)។ សរសេរកំណត់សំគាល់ និងសំនួរទាំងឡាយ នៅក្នុងសៀវភៅសរសេររបស់អ្នក។ សូមសរសេរផងដែរ អំពីអារម្មណ៍ ឬចំណាប់អារម្មណ៍ ទាំងឡាយ ដែលសំខាន់ចំពោះ អ្នក។
- ធ្វើសកម្មភាពទាំងឡាយនៅក្នុង ផ្នែកនៃ "ការសិក្សាពីព្រះគម្ពីរ" សំរាប់ជំពូកដែលអ្នកកំពុងសិក្សា។ ពេលខ្លះ អ្នកត្រូវតែ ជ្រើសរើស សកម្មភាពណាដើម្បីធ្វើ។ ប្រសិនបើអ្នកចង់រៀនបន្ថែម ចូរបំពេញរាល់សកម្មភាពទាំងឡាយ។

កម្មវិធីសិក្សា ថ្នាក់សិក្ខាសិលានៅ តាមផ្ទះ

ប្រសិនបើអ្នក នៅក្នុងកម្មវិធីសិក្សា ថ្នាក់សិក្ខាសិលានៅ តាមផ្ទះ នោះតារាងអាន (នៅលើទំព័រ 6) បង្ហាញដល់អ្នក ពី អ្វីដែលអ្នកគួរតែអាន រាល់សប្តាហ៍ នៅថ្នាក់សិក្ខា សិលា។ ចងចាំថា សិក្ខាសិលា គឺជាកម្មវិធីអប់រំសាសនាប្រចាំថ្ងៃ ថាការអធិស្ឋាន និងការអានព្រះគម្ពីររបស់អ្នក គួរតែបានក្លាយជាការអនុវត្តប្រចាំថ្ងៃ ហើយថា អ្នកនឹង ត្រូវការធ្វើលំហាត់ សិក្ខាសិលា រាល់ថ្ងៃ ដែលអ្នកទៅរៀនទៅសាលា ទោះបីជាអ្នក មិនចូលរួមថ្នាក់សិក្ខាសិលា ជារៀងរាល់ថ្ងៃក៏ដោយ។ ប្រសិនបើអ្នក មានច្រើនជាង ឬក៏តិចជាង សាមសិបប្រាំមួយសប្តាហ៍ នៅក្នុងមួយឆ្នាំនៃថ្នាក់សិក្ខាសិលារបស់អ្នក នោះគ្រូអ្នកនឹង ប្រាប់អ្នក ពីជំពូក ដែលអ្នកនឹង ត្រូវអាន ក្នុងមួយសប្តាហ៍ និងកិច្ចការអ្វី ដែលត្រូវបំពេញ។ ការអានព្រះគម្ពីរ និងការប្រើ សៀវភៅណែនាំ ការសិក្សានេះ គួរតែចំណាយពេល សាមសិប ទៅ សែសិបនាទី រាល់ថ្ងៃរៀន បើអ្នកមិនទៅចូលរួម ថ្នាក់សិក្ខាសិលា។

រាល់សប្តាហ៍អ្នកគួរតែ អោយគ្រូរបស់អ្នកនៅ ទំព័រ ក្នុងសៀវភៅសរសេរ របស់អ្នក ដែលផ្ទុកនូវគំនិតរបស់អ្នកអំពី ព្រះគម្ពីរ និងសកម្មភាព ណែនាំការសិក្សា ដែលអ្នកបំពេញសំរាប់សប្តាហ៍នោះ។ គ្រូរបស់អ្នកនឹងអាន ហើយឆ្លើយតបចំពោះ លំហាត់នោះ ហើយឱ្យសៀវភៅសរសេរ ទៅឱ្យអ្នកវិញ។ អ្នកអាចប្រើសៀវភៅសរសេរ ពីរក្បាលក៏បាន ហើយប្រើសៀវភៅនីមួយៗ ពីរសប្តាហ៍ម្តង។ អ្នកគួរតែសរសេរផងដែរ នៅក្នុងសៀវភៅកង ដែលអាចយកក្រដាស់សៀវភៅ ចេញ ចូលបាន ហើយបើក មើលនៅទំព័រ ដែលអ្នកបានធ្វើនៅក្នុងសប្តាហ៍នោះ។ នៅពេលដែលគ្រូរបស់អ្នក បានប្រគល់ទំព័រនោះ ឱ្យទៅអ្នកវិញ។ ទុកវិញនៅក្នុងសៀវភៅសរសេរ។

កម្មវិធីថ្នាក់សិក្ខាសិលាប្រចាំថ្ងៃ

ប្រសិនបើអ្នកនៅក្នុងកម្មវិធីថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ អ្នកនឹងត្រូវប្រើ សៀវភៅណែនាំនេះ ដូចដែលបានណែនាំដោយ គ្រូបង្រៀនរបស់អ្នក។

ស្បៀវភៅណែនាំការសិក្សានេះ ត្រូវបានរៀបចំដើម្បីជួយអ្នក អាន សិក្សា និងយល់ដឹងពីព្រះគម្ពីរ។ ព្រោះថាការសិក្សាគាត ច្រើនរបស់អ្នក នឹងត្រូវបានចំណាយទៅលើការអាន និងការគិតអំពីព្រះគម្ពីរ កណ្ដឹនេះ ត្រូវបានរួមបញ្ចូល ដើម្បីជួយអ្នក អោយមានប្រសិទ្ធភាពថែមទៀត។

អែលឌើរ ហារើត ជេបិលយូ ហិនថើរ ដែលពេលនោះជាសមាជិក នៃក្រុមសាវ័កទាំងដប់ពីរនាក់ បានអោយសមាជិក សាសនាចក្រ នូវការប្រឹក្សាដ៏មានតំលៃ ស្ដីពីការសិក្សាព្រះគម្ពីរ ដែលបានសង្ខេប ខាងក្រោមនេះ។ អ្នកអាចសរសេរគំនិតរបស់គាត់ ទៅលើកាត មួយ ហើយដាក់កាតនោះ ទៅកន្លែងដែលអ្នកអាចមើលឃើញវា ទៅពេលអ្នកធ្វើការសិក្សា។

- អានដោយប្រុងប្រយ័ត្ន ដើម្បីយល់ពីព្រះគម្ពីរ។
- សិក្សាជារៀងរាល់ថ្ងៃ។
- កំណត់ពេលអោយទៀងទាត់ ទៅពេលដែលអ្នកនឹងសិក្សា។
- សិក្សាទៅកន្លែងដែលអ្នកអាច ផ្ដងអារម្មណ៏ ដោយគ្មានការបន្លប់ ឬការរំខាន។
- សិក្សាសំរាប់រយៈពេលខ្លី ជាជាងការអានពីលេខខ្លះៗ នៃជំពូក ឬទំព័រផ្សេងៗ។
- មានផែនការណ៏ សិក្សា។
  (សូមមើល Conference Report, ខែតុលា 1979, ទំព័រ 91–93 ឬ *Ensign* ខែវិច្ឆិកា 1979, ទំព័រ 64–65។)។

ការប្រើជំនាញសិក្សាបានល្អ នឹងមានប្រយោជន៍ ចំពោះការសិក្សាព្រះគម្ពីររបស់អ្នក។

បទគម្ពីរយោង

បទគម្ពីរយោង គឺជាបទព្រះគម្ពីរ ដែលនឹងដឹកនាំអ្នកទៅនឹង ពតិមានពីស្ពារ ផ្ទៃខាងក្នុង នៅលើប្រធានបទដែលអ្នក កំពុង សិក្សា។

ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ពីព្រះគម្ពីរចីប

ព្រះអម្ចាស់បានបញ្ជា ព្យាការីយ៉ូសែប ស្ម៊ីធ ឱ្យសិក្សាពីព្រះគម្ពីរចីប និងស្វែងរកវិវរណៈ ដើម្បីទទួលបាននូវ ការបកប្រែ ព្រះគម្ពីរ ចីប កាន់តែពេញលេញ និងត្រឹមត្រូវ (សូមមើល គ និង ស 37:1, 45:60, 73:3–4)។ ជាលទ្ធផល ព្យាការី យ៉ូសែប ស្ម៊ីធ បានស្ដារឡើងវិញ នូវសេចក្ដីពិតដ៏សំខាន់ជាច្រើន ហើយបានធ្វើការផ្លាស់ប្ដូរដ៏ណឹង ជាច្រើន នៅក្នុងព្រះគម្ពីរចីប ដែលអាចត្រូវបានបកប្រែខុស, មិនច្បាស់លាស់ ឬមិនពេញលេញ (សូមមើល មាត្រានៃសេចក្ដីជំនឿ 1:8)។ កំណែនេះ ជាមួយនឹង ការផ្លាស់ប្ដូរ ដែលមានការបំផុសគំនិត ត្រូវបានហៅថា "ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ"។

ក្បាល់រឿងជំពូក ក្បាល់រឿងកណ្ដ និងការសង្ខេបខទាំងឡាយ

ក្បាល់រឿងជំពូក ក្បាល់រឿងកណ្ដ និងការសង្ខេបខទាំងឡាយ ឬផ្ដល់ឱ្យ ពតិមានជាប្រវត្តិសាស្ត្រ សំខាន់ៗ ដើម្បីជួយអ្នកឱ្យយល់ ពីអ្វី ដែលអ្នកបានអាន។ ឧទាហរណ៏ តើពតិមានដ៏មានប្រយោជន៍ណាខ្លះ ដែលអ្នកបានទទួល ដោយការអានក្បាល់រឿងកណ្ដ នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា 89?

ការដែលមាន ស្បៀវភៅជំនួយ សិក្សា ដែលអាចរកទៅបាននៅក្នុង គម្ពីរបន្ថែមនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺដូចជា កំរងឯកសារ យោងតូចមួយ ដែលអ្នកអាចរកបាន—ទាំងអស់នៅកន្លែងតែមួយ!

ជំនាញសិក្សាផ្សេងៗ

នីហ្វៃ បានទំាយាយថា យើងគួរតែ "ទទួលទានន្ូវព្រះបន្ទូល នៃព្រះគ្រីស្ទ" (នីហ្វៃទី 2 32:3) ហើយព្រះយេស៊ូវ បានបញ្ជាពួក នីហ្វៃ អោយ "ស្ទង់ [ព្រះគម្ពីរ] ដោយព្យាយាម" (នីហ្វៃទី3 23:1)។ ការសិក្សារបៀបនេះ វាប្រសើរជាង ការគ្រាន់តែអាន យ៉ាងឆាប់ឲ្យ នៅក្នុងព្រះគម្ពីរ។ គំនិត និងជំនាញទាំងឡាយ នៅខាងក្រោម នឹងជួយអ្នកឱ្យយល់ដឹងបានកាន់តែច្រើន ថែមទៀត នៅពេលដែលអ្នកសិក្សា។ ជំនាញសិក្សា ទាំងនេះ ត្រូវបានបំបែក ចេញជាបីផ្នែកខុសគ្នាៈ មុនពេលអាន, ពេលកំពុងអាន និង ក្រោយពេលអាន។

ក មុនពេលអាន

ការអធិស្ឋាន

ព្រះគម្ពីរ ត្រូវសរសេរដោយការបំផុសគំនិត។ ហេតុដូច្នេះ យើងនឹងអាន ព្រះគម្ពីរបាន ប្រសើរបំផុត នៅពេលដែលយើងមានដៃគូរ ជាមួយព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងព្រះគម្ពីរ សញ្ញាចាស់ យើងរៀនអំពី សង្ឃ រ៉ែមសរ៉ា "បានតាំងចិត្ត ស្វែងរក ក្នុងក្រិត្យវិន័យ របស់ព្រះយេហូវ៉ា" (រ៉ែមសរ៉ា 7:10)។ តាំងចិត្ត របស់អ្នក ដើម្បីអានព្រះគម្ពីរ ដោយអធិស្ឋាន រាល់ពេលអ្នកអាន។

រកពតិមានប្រវត្តិសាស្ត្រ

ការយល់ដឹងពីប្រវត្តិព្រះគម្ពីរ នឹងជួយអ្នក ទទួលបានគំនិតកាន់តែច្រើន នៅពេលអ្នកអានៗ ក្បាល់រឿងកណ្ដ នៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ផ្ដល់នូវការពន្យល់ខ្លីៗ នៃប្រវត្តិខាងក្នុងវិវរណៈ។ លិខិតក្រមនៅខាងក្រោយ នៃព្រះគម្ពីរទាំងបី ក៏មានផ្ទុកទៅ ដោយ ពតិមានពីស្ពារសំខាន់ៗ។

ប្រសិនបើអ្នកមានពេល អ្នកក៏អាចរកមើល ស្បៀវភៅដែលសាសនាចក្របាន រៀបចំ និងស្បៀភៅ សិក្សា ដែលមានប្រវត្តិ ស្ដីអំពី ព្រះគម្ពីរដែលអ្នកកំពុងអាន។

សួរសំនួរ

មុនពេលអ្នកអាន វាជាជំនួយដ៏ធំ ដែលអ្នក សួរខ្លួនឯង នូវសំនួរខ្លះដូចជា "តើនរណា សរសេរទំាងនេះ?" "សរសេរទៅ នរណា" "ហេតុអ្វី បានជាការបង្រៀនេះ ត្រូវបានបញ្ចូលមកក្នុង ព្រះគម្ពីរ?" "តើខ្ញុំចង់ដឹង និងរៀនពីអ្វី នៅពេលដែល ខ្ញុំអាននៅថ្ងៃ នេះ?" និង "តើព្រះអម្ចាស់ចង់អោយខ្ញុំរៀនពីអ្វី ពីខគម្ពីរនេះ?" នៅពេលដែលអ្នកអានព្រះគម្ពីរ ចូរ រកមើលចំលើយចំពោះសំនួរ របស់អ្នក។ ចងចាំថា អ្នកក៏អាចប្រើគ្រាស់ ជំនួយសំរាប់ការសិក្សា ដើម្បីរកចំលើយ ពីក្នុងស្បៀវភៅសិក្សា និងឯកសារ ទាំងឡាយ របស់សាសនាចក្រ។

អានក្បាល់រឿងជំពូក និងការសង្ខេប ខ

ក្បាល់រឿងជំពូក និងការសង្ខេបខ គឺជា ការសង្ខេបយ៉ាងសាមញ្ញ នៃគំនិតចំបង នៅ ក្នុងជំពូក ឬ កណ្ដ។ ការអានក្បាល់រឿងជំពូក មុនពេលចាប់ផ្ដើម អានជំពូកមួយ មិនមែន គ្រាន់តែជាទំលាប់សិក្សាល្អប៉ុណ្ណោះទេ ប៉ុន្តែវា នឹងជួយអ្នករៀបចំ ខ្លួនរបស់អ្នក ដើម្បីសួរ សំនួរ និងរកមើលចំលើយរបស់អ្នក នៅពេល អ្នកអាន។

ខ ពេលកំពុងអាន

កុំខ្លាចនឹងឈប់

កំណប់ដ៏មានតំលៃ គឺមិនអាចរកបាន នៅលើផ្ទៃខាងក្រៅនៃផែនដីបានទេ—អ្នកត្រូវតែជីករកកំណប់នោះ។ ការសិក្សាព្រះគម្ពីរ របស់អ្នកនឹងកាន់ តែមានតំលៃ ប្រសិនបើអ្នកនឹង សិក្សាយ៉ាងយឺតឲ ឬក៏ឈប់ ហើយធ្វើសកម្មភាពខ្លះឲ ដូចខាងក្រោមនេះ។

សូមមើលអន្ទន័យពាក្យដែលអ្នកមិនយល់



ប្រើវចនានុក្រម។ ពេលខ្លះ ការមើលពាក្យដែលអ្នកគិតថា អ្នកចេះស្រាប់ហើយ អាចជួយអ្នកយល់ថែមទៀត។ កណ្ឌនៃ "ការយល់ដឹងពីព្រះគម្ពីរ" នៃស្យេភៅសិក្សានេះនឹងជួយអ្នកអោយយល់ពីពាក្យ និងឃ្លាពិបាកឲ។

សូមជ្រាបថា ពេលខ្លះព្រះអម្ចាស់ បានបំផុសគំនិត ព្យាការីរបស់ទ្រង់ ឱ្យបន្ថែមការពន្យល់ និងការសរសេរថែមទៀត ដើម្បីជួយយើង ដឹងពីអត្ថន័យនៃពាក្យ និងឃ្លាទាំងឡាយ។ ឧទាហរណ៍ អានម៉ូសាយ 3:19 ហើយ ស្វែងរក អត្ថន័យ នៃការក្លាយដូចជាកុមារ មានន័យដូចម្តេច តាមបន្ទូល ស្តេចបេនយ៉ាមីន។

ការប្រដូច បទគម្ពីរ

ប្រើឈ្មោះរបស់អ្នកផ្ទាល់ នៅក្នុងខ ដែលអាចធ្វើឱ្យ ការបង្រៀនព្រះគម្ពីររបស់អ្នក មានលក្ខណៈផ្ទាល់ខ្លួន។ ឧទាហរណ៍ តើមានភាពខុសគ្នាអ្វី នៅពេលដែលអ្នកប្រើ ឈ្មោះរបស់អ្នកជំនួសទៅលើពាក្យ "មនុស្ស" នៅក្នុង ម៉ូសេ 1:39?

ការនឹកស្រមៃ

ស្រមើស្រមៃ៉ នៅក្នុងអារម្មណ៍របស់អ្នក ពីអ្វីដែលកើតឡើង។ ឧទាហរណ៍ នៅពេលដែលអ្នកអាន លោកុប្បត្តិ 37 ចូរស្រមើស្រមៃ៉ថា តើអ្នកមានអារម្មណ៍យ៉ាងណា បើអ្នកនៅក្នុងចំណោមបួនប្រុសទាំងនោះ នៅក្នុងគ្រួសារ ហើយបងប្រុសរបស់អ្នកទាំងអស់ ស្អប់អ្នកជាខ្លាំង ឬមានការច្រណែនអ្នក។

ពេលខ្លះ ព្រះគម្ពីរបានប្រាប់យើងឱ្យ នឹកគិតនៅក្នុងចិត្ត។ អាន អាលម៉ា 5:15–18 ហើយឈប់ ហើយធ្វើឱ្យដូចការស្នើរសុំ របស់អាលម៉ា។ ចំណាយពេលខ្លះ ដើម្បីសរសេរ អំពីអារម្មណ៍ ដែលអ្នកមាន នៅពេលដែលអ្នក គិតនៅក្នុងចិត្ត អំពីខគម្ពីរទាំងនេះ។

សូមមើលពាក្យក្នាប់សេចក្តី

ពាក្យក្នាប់សេចក្តី រួមមានដូចជា *និង ប៉ុន្តែ ដោយសារ ហេតុដូច្នេះហើយ និងទោះបីយ៉ាងណាក៏ដោយ។* នៅពេលដែលអ្នកអានពាក្យ

ទាំងនេះ ចូរកត់ចំណាំ អ្វីដែលពាក្យទាំងនេះ បានជួយអ្នកយល់ អំពីគំនិតបន្ថែមទៀត។ នៅពេលខ្លះ ពាក្យទាំងនោះបង្ហាញ រប្យៀប ដែលហេតុការណ៍ពីរ ឬច្រើនជាងនេះ មានលក្ខណៈស្រដៀងគ្នា ឬខុសគ្នា។

ឧទាហរណ៍ ប្រសិនបើអ្នកគិត ពីពាក្យ *ដោយសារ* ថាវាចង្អុលបង្ហាញពីអ្វី នៅក្នុង ម៉ូសាយ 26:2–3 នោះអ្នកអាចរៀនអំពី សេចក្តីពិតដ៏សំខាន់ អំពីការសិក្សាព្រះគម្ពីរ។

> ២ ពួកគេពុំជឿនូវអ្វីៗ ដែលបាននិយាយអំពីដំណើររស់ឡើងវិញនៃមនុស្សស្លាប់ ហើយគេក៏មិនជឿអំពីការយាងមកនៃព្រះគ្រីស្ទដែរ ។
>
> ៣ ហើយឥឡូវនេះ ដោយសារការឥតជំនឿរបស់គេ នោះពួកគេពុំយល់នូវព្រះបន្ទូលនៃព្រះទេ ឯចិត្តគេត្រឡប់ជារឹងរូសទៅវិញ ។

ដោយសារ ចង្អុលបង្ហាញ ពីហេតុនិងផល រវាងការមិនជឿរបស់មនុស្ស និងអសមត្ថភាពរបស់ពួកគេ ក្នុងការយល់ពីព្រះគម្ពីរ និងពាក្យរបស់ព្យាការី។

សូមរកមើលគំរូ

នៅក្នុង នីហ្វៃទី2 31:2, នីហ្វៃបាននិយាយថា គាត់បានចង់សរសេរ ពាក្យបន្តិចបន្តួច អំពីគោលលទ្ធិរបស់ព្រះគ្រីស្ទ។ បន្ទាប់មកនៅខទី 21 គាត់បានថ្លែងសក្ខីភាពរបស់គាត់ថា គាត់ទើបតែពន្យល់ពីគោលលទ្ធិរបស់ព្រះគ្រីស្ទ។ ដោយដឹងថា នីហ្វៃបានបង្រៀន គោលលទ្ធិ នៃព្រះគ្រីស្ទ រវាងខ 2 និង 21 នោះយើងគួរតែត្រឡប់ទៅវិញ ហើយសិក្សាពាក្យរបស់នីហ្វៃ ដើម្បីស្វែងថែមទៀត ដើម្បីរកអ្វី ដែលជាគោលទ្ធិ នៃព្រះគ្រីស្ទ។

ឧទាហរណ៍ ផ្សេងឲទៀត នៃការស្វែងរកគំរូ គឺស្វែងរក ការពន្យល់របស់ព្យាការី អំពីហេតុនិងផល ដោយការមើល ការប្រើប្រាស់របស់គាត់ ចំពោះពាក្យ *ប្រសិនបើ* និង *នោះ*។ នៅក្នុងលេវីវិន័យ 26 ម៉ូសេបានព្យាករ ពីពរជ័យ ឬក៏បណ្តាសា ដែលនឹងមក ចំពោះកូនចៅនៃសាសន៍អ៊ីស្រាអែល។ សូមមើលនៅ ខ 3–4, 18, 23–24, 27–28 និង 40–42 ហើយកត់សំគាល់ថា ម៉ូសេបានប្រើពាក្យ ប្រសិនបើ-នោះ ជាគំរូ នៅពេលដែលគាត់បង្រៀន កូនចៅនៃសាសន៍អ៊ីស្រាអែល អំពីអ្វី ដែលនឹងកើតឡើង ប្រសិនបើពួកគេ បានគោរពតាម ឬមិនបានគោរពតាម បទបញ្ញត្តិ របស់ព្រះអម្ចាស់។

ការនិយាយឡើងវិញ នៃពាក្យ ឬក៏គំនិត គឺជាគំរូផ្សេងទៀត ដើម្បីមើល។ ឧទាហរណ៍ ចូរកត់ចំណាំ តើពាក្យ *ត្រូវបានរកឃើញ* ប៉ុន្មានដងនៅក្នុង នីហ្វៃទី3 11។

រកមើល បញ្ជីនៅក្នុងព្រះគម្ពីរ

បញ្ជី អាចជួយអ្នកឱ្យយល់កាន់តែច្បាស់ ពីអ្វីដែលព្រះអម្ចាស់ និងព្យាការីរបស់ទ្រង់បង្រៀន។ ក្រិត្យវិន័យទាំងដប់ប្រការ គឺជាបញ្ជី (សូមមើល និក្ខមនំ 20)។ ភាពក្សេមក្សាន្ត នៅក្នុង នីហ្វៃទី3 12:3–11 គឺអាចចាត់ទុកជា បញ្ជីមួយ បានយ៉ាងងាយ។ ការស្វែង រក បញ្ជីផ្សេងទៀត ប្រហែលជាគំរូវអោយ ការខិតខំ បន្តិចទៀត។ ឧទាហរណ៍ ធ្វើបញ្ជី ចេញពីគោលលទ្ធិ និងសេចក្តីសញ្ញា 68:25–31 អ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា ឱពុកម្តាយត្រូវបង្រៀនកូនចៅ។

សួរសំនួរ

បន្ទស្ងសំនួរ ដូចដែលបានណែនាំ ធ្វើនៅក្នុងវគ្គ "ពីមុនការអាន"។ នៅពេលអ្នកអាន អ្នកប្រហែលជាជួបឃ្លាសំនួរនោះម្តងទៀត ឬអ្នកបានសួរពីមុនការអាន ឬអ្នកមានសំនួរដែល ខុសពីសំនួរលើកមុន។ ការស្វែងរក ចំលើយសំរាប់សំនួរ គឺជាវិធីមួយដ៏សំខាន់ ដែលយើងបានទទួលការយល់ដឹង ដ៏អស្ចារ្យ មកពីការសិក្សាព្រះគម្ពីរ។ សំនួរសំខាន់ ជាងគេបំផុត ដែលត្រូវសួរ គឺ "ហេតុអ្វី ព្រះអម្ចាស់បំផុសគំនិត អ្នកសរសេរ ឱ្យបញ្ចូល ហេតុការណ៍នេះ ទៅក្នុង ព្រះគម្ពីរ?" ចូរ រកមើលគំរុយច្បាស់លាស់ ដែលអ្នកសរសេរបន្សល់ទុកឱ្យ ពេលដែល អ្នកសរសេរបាន និយាយ "ដោយហេតុដូច្នេះហើយ យើងឃើញថា"។

ឆ្លើយសំនួរ ដែលបានឱ្យ នៅក្នុងព្រះគម្ពីរ

ជាច្រើនដងព្រះអម្ចាស់ សួរ ហើយបន្ទាប់មក ឆ្លើយសំនួរ។ ទ្រង់បានសួរទៅ សាវ័កសាសន៏ នីហ្វៃ "តើគួរអោយអ្នករាល់គ្នា ប្រព្រឹត្តបែបណាទៅ?" បន្ទាប់មកទ្រង់បានឆ្លើយតបថា "ត្រូវអោយបានដូចជាយើង" (នីហ្វៃទី3 27:27)។

ក្នុងឱកាសផ្សេងទៀត សំនួរផ្សេងឲទៀត ត្រូវបានសួរ តែគ្មានចំលើយទេ—ជាទូទៅ អ្នកនិពន្ធគិតថា ចំលើយ គឺបានដឹងទៅហើយ។ ពេលខ្លះ អ្នកសរសេរមិនឱ្យចំលើយទេ ទោះជាយ៉ាងណាក៏ដោយ

ដោយសារសំនួរដែលបានសួរនោះ អាចតំរូវឱ្យ គិតខ្លះៗ ហើយចំលើយមិនមែន ជាការបន្ទាន់ទេ។ ឧទាហរណ៍ អាន អាលម៉ា 5:14–33 ហើយឆ្លើយសំនួរ នៅក្នុងខគម្ពីរទាំងនោះ ហាក់ដូចជាអ្នក បានទៅទីនោះដែរ។

រកមើលប្រភេទ និងអត្ថន័យជានិមិត្តរូប

ព្យាការីតែងតែ ប្រើនិមិត្តរូប និងការប្រៀបធៀប (ប្រភេទផ្សេងៗ) ដើម្បីធ្វើទំនាក់ទំនង នូវ សារដំណឹងរបស់ពួកគាត់ ឱ្យកាន់តែមានអំណាច។ ឧទាហរណ៍ រ្បើងព្រេងគឺជា មធ្យោបាយដើម្បី ប្រាប់ ដំណឹងបានយ៉ាងសាមញ្ញ ហើយក៏ជាវិធី ដែលមានអត្ថន័យដ៏ជ្រាលជ្រៅ។ រ្បើងនៅក្នុង រ្បើង ប្រៀបប្រដូច ធ្វើឱ្យមេរៀន កាន់តែងាយចាំ និងមានអត្ថន័យ។

យោបល់នៅខាងក្រោម អាចជួយអ្នក យល់ពីនិមិត្តរូប នៅក្នុងព្រះគម្ពីរ បាន៖

1. រកមើលការបកស្រាយ នៅក្នុងព្រះគម្ពីរ។ ឧទាហរណ៍ លីហៃ មានការនិមិត្ត នៅក្នុងនីហ្ចៃទី1 8។ នីហ្ចៃ ក្រោយមកមានការនិមិត្ត ពីអ្វី ដែលឱពុកគាត់បានឃើញ ស្របទៅនឹងការបកស្រាយ និមិត្តរូប នៅក្នុងការនិមិត្តរបស់ ឱពុករបស់គាត់ (សូមមើល នីហ្ចៃទី1 11–14)។
2. គិតអំពីបុត្តលិកលក្ខណៈ នៃនិមិត្តរូប និងថា និមិត្តរូប បានបង្រៀនអ្វីខ្លះដល់អ្នក។ អាលម៉ា បាន ប្រើជំនាញរបស់គាត់ក្នុង ការពន្យល់ ត្រីវិស័យ ទៅកូនប្រុសរបស់គាត់ ហេលេមិន (សូមមើល អាលម៉ា 37:38–47)។
3. ចូររកមើលបើសិនជានិមិត្តរូប បានបង្រៀនដល់អ្នក អំពីព្រះអង្គសង្គ្រោះ។ ព្រះអម្ចាស់បានប្រាប់ ទៅ អ័ដាមថា "ត្រប់វត្ថុទាំងអស់ គឺថ្លែងអំពី [ទ្រង់]" (សូមមើល ម៉ូសេ 6:63)។ ឧទាហរណ៍ តើផ្នែកផ្សេងៗ នៅក្នុងរ្បើង នៃការពលីកម្មកូនរបស់អ័ប្រាហាំ ឈ្មោះ អ៊ីសាក ធ្វើទីបន្ទាល់ អំពី ពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទដូចម្តេចខ្លះ? (សូមមើល លោកុប្បត្តិ 22:1–19, យ៉ាកុប 4:5)។

ការសរសេរ

ទុកក្រដាសខ្លះៗ ឬស្បៀវភៅសរសេរ នៅ ជិតដៃ ដើម្បីអ្នកអាចសរសេរ គំនិតយោបល់ ខ្លះៗ ដែលអ្នកចង់ចំណាំទុក ដូចជា បញ្ជី ត្រួតពិនិត្យបុណ្យជ្រមុជទឹករបស់សមាជិកថ្មី ចំណុចពិសេសខាងក្នុង ដែលអ្នកបានទទួល ឬ អារម្មណ៍អ្នកអំពីអ្វី ដែលអ្នកបានអាន។ ដើម្បី ជួយអ្នកអោយចងចាំគំនិត ឬផ្នែកខាងក្នុង ដែលអ្នកអាននៅពេលក្រោយ អ្នកអាច សរសេរគំនិតនេះ នៅក្នុងរឹម ដើមទំព័រ នៃព្រះគម្ពីរផងដែរ។

មនុស្សជាច្រើន ចូលចិត្តគូសចំណាំ ពាក្យ ឬ ឃ្លាសំខាន់ៗ នៅក្នុងព្រះគម្ពីររបស់ពួកគេ។ វាគ្មាន រប្បៀបខុសឬត្រូវទេ ក្នុងការធ្វើដូច្នោះ។ (អ្នកប្រហែលជាមិនចង់ធ្វើដូច្នេះ ទាល់តែសោះ)។ មនុស្សខ្លះ គូររវូង់នៅលេខ ខ ឬ ជាត់ពណិ ឬ គូសបន្ទាត់ខាងក្រោមចំណុច ឬ ឃ្លាសំខាន់ៗ ដែលមានអត្ថន័យ ស៊ីជំរៅទៅខទាំងនោះ។ រប្បៀបមួយទៀត ដើម្បីធ្វើកំណត់សំគាល់លើបទគម្ពីរ គឺសរសេរ យោងបទគម្ពីរ ទៅនឹង បទគម្ពីរផ្សេងទៀត នៅក្នុងរឹមដើមទំព័រ។ ការធ្វើដូច្នេះ ច្រើនខ ដែលស្ថិតនៅក្នុងប្រធានបទដូចៗគ្នា ធ្វើឱ្យខគម្ពីរ របស់អ្នក មានលំដាប់លំដោយ នៅលើប្រធាន បទជាក់លាក់មួយ ដែលអ្នកអាចរក ដោយគ្រាន់តែបើកមើល បទគម្ពីរ នៅក្នុងលំដាប់ណាមួយ។ ការគូសចំណាំព្រះគម្ពីរ អាចជួយអ្នកងាយស្វែងរក ខ សំខាន់ៗឆាប់។

ត ក្រោយការអាន

ពិចារណា

ការពិចារណា គឺជាការគិតអំពីអ្វីមួយ, ដោយសួរសំនួរ និងវាយតំលៃ ទៅលើអ្វីដែលអ្នកបានដឹង និងបានរៀន។ ពេលខ្លះព្រះគម្ពីរ បានហៅរ្បើងទាំងអស់នេះថា "ការសញ្ជឹងគិត" (សូមមើល យ៉ូស្វេ 1:8)។ មានឧទាហរណ៍ជាច្រើនក្នុងព្រះគម្ពីរ ដែលការបើកសំដែងសំខាន់ៗ បានលេចឡើង ជាលទ្ធផលនៃការពិចារណា ជាពិសេសការពិចារណា អំពីបទគម្ពីរ (សូមមើល ត និង ស 76:15–20, 138:1–11)។

ប្រៀបធៀបបទគម្ពីរទាំងអស់ទៅ នឹងខ្លួនអ្នក

ការប្រៀបធៀបបទគម្ពីរ ទៅនឹងខ្លួនអ្នក គឺជាការប្រៀបធៀបបទគម្ពីរទាំងនោះ ទៅនឹងជីវិតរបស់អ្នក។ ដើម្បីប្រៀបធៀប បទគម្ពីរ ទៅនឹងខ្លួន អ្នកត្រូវសួរសំនួរ ដូចជា "តើគោលការណ៍ នៃដំណឹងល្អ នៅក្នុងបទគម្ពីរ ដែលខ្ញុំទើបអាន បង្រៀនអ្វី ខ្លះ ដល់ខ្ញុំ" និង "តើខ្ញុំ បទគម្ពីរទាំងនោះ អាចទាក់ទងទៅនឹងជីវិតរបស់ខ្ញុំ យ៉ាង ដូចម្តេច?" ផ្នែកមួយដ៏សំខាន់ នៃការប្រៀប ធៀប បទគម្ពីរ ទៅនឹងខ្លួនអ្នក គឺត្រូវស្គាប់ ការណែនាំពីព្រះវិញ្ញាណ ដែលព្រះអម្ចាស់បានសន្យា "នឹងនាំ អ្នករាល់គ្នាចូលក្នុង គ្រប់ទាំង សេចក្តីពិត" (យ៉ូហាន 16:13)។

ឧទាហរណ៍ នីហ្ចៃបានប្រៀបធៀបបទគម្ពីរទៅ នឹងខ្លួនគាត់ និងក្រុមគ្រួសារគាត់ ដោយអនុវត្ត គោលការណ៍ខ្លះៗ នៃការបង្រៀន របស់ អេសាយ ទៅនឹងស្ថានភាពរបស់ពួកគេ។ គាត់បាន បង្រៀនប្អូនប្រុសរបស់គាត់ថា ពួកគេដូចជាកូននៃ សាសន៍ អ៊ីស្រាអែល ដែលបានវង្វេងចេញពី ព្រះ—តែព្រះមិនបានវង្វេងចេញ ពីពួកគេទេ។ គាត់ក៏បានបង្រៀនពួកគេដែរថា ប្រសិនបើពួកគេ ប្រែចិត្ត ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណា និងអភ័យទោសអោយពួកគេ។ (សូមមើល នីហ្ចៃទី1 19:24, 21:14–16)។ នីហ្ចៃបាននិយាយថា តាមរយះការប្រៀបធៀប ពាក្យទាំងឡាយ នៃអេសាយ ទៅនឹងខ្លួនគាត់ ជាការជ្បឿរបស់ ប្អូនប្រុសរបស់គាត់ ទៅលើព្រះយេស៊ូវគ្រីស្ទ ថាជា ព្រះប្រោសលោះ បានលេចឡើង (សូមមើល នីហ្ចៃទី1 19:23)។

ការអានសារឡើងវិញ



យើងមិនយល់អ្វីៗទាំងអស់ទេ ពេលយើង បានអានដំណឹង ក្នុងបទគម្ពីរលើកដំបូង។ តាមពិតទៅ វាត្រូវចំណាយពេលមួយជីវិត ដើម្បីសិក្សាអោយយល់ច្បាស់ពីព្រះគម្ពីរ។ ជារ្បើយៗ យើងចាប់ផ្តើមមើលឃើញគំរូ ការស្រមើស្រម៉ៃបានកាន់តែប្រសើរ និង អានព្រះគម្ពីរកាន់តែយល់ស៊ីជំរៅ បន្ទាប់ពី ការអានលើកទីពីរ ទីបី។ អ្នកអាចស្វែងរក ការបង្រៀនថ្មីៗ ឬសួរសំនួរ ប្លែកៗ នៅ ពេលដែលអ្នកអាន ឡើងវិញ។ ការព្យាយាម សរសេរឡើងវិញ នូវរ្បើង មួយ ឬខមួយ ឬពីរ ជាពាក្យរបស់អ្នកផ្ទាល់ អាចជួយអ្នកឱ្យ ដឹងថា តើអ្នកយល់ ឬមិន យល់ អំពីអ្វីដែលអ្នកបានអាន និងជួយអ្នកឱ្យ យល់ព្រះគម្ពីរ កាន់តែច្បាស់។

សរសេរ

ពេលខ្លះមនុស្សរក្សាទុក ស្បៀវភៅ ទិន្នានុប្បវត្តិ ដើម្បីគេអាចសរសេរ អំពីគំនិត សំខាន់ៗ ពីអ្វីដែលគេបានអាន, ពីអារម្មណ៍ ដែល គេមាន អំពីអ្វីដែលគេបានអាន ឬគេ គិតថា អ្វីដែលគេបានអាននោះ អាចអនុវត្ត ទៅក្នុងជីវិតរបស់គេ យ៉ាងដូចម្តេច។ ប្រសិនបើ អ្នកកំពុងប្រើ ស្បៀវភៅនេះ សំរាប់ ការសិក្សាថ្នាក់សិក្ខាសិលានៅតាម ផ្ទះ អ្នកត្រូវរក្សាស្បៀវភៅសរសេរ ដើម្បី ទទួលពិន្ទុ។ ស្បៀវភៅសរសេរនេះ នឹងដូច ជាកំណត់ហេតុ ព្រះគម្ពីរមួយដែរ។

វាក៏ជាការល្អផងដែរ ដែលអ្នកនិយាយជាមួយអ្នកដទៃទៀត ពីអ្វីដែលអ្នកបានអាន។ ការសរសេរទុកំណត់ខ្លះៗ អាចជួយអ្នក ឱ្យចងចាំ ពីអ្វីដែលអ្នកចង់និយាយ និងពិភាក្សាពីអ្វីដែលអ្នកបានរៀន ទីងជួយអ្នកឱ្យយល់ និងចាំបន្ថែមទៀត ពីអ្វីដែលអ្នកអាន។

អនុវត្ត

តំលៃពិត នៃចំណេះវិជ្ជាដែលអ្នកអាចទទួលពីព្រះគម្ពីរ កើតមាន ពេលដែលអ្នករស់នៅតាមអ្វី ដែលអ្នកបានរៀន។ ការខិតកាន់តែ ទៅជិតយ៉ាងអស្ចារ្យ ទៅរកព្រះអម្ចាស់ និងការមានអារម្មណ៍សុខសាន្ត ដែលទ្រង់ប្រទានមក គឺគ្រាន់តែដាពរដ៏ឃ្លាំ មួយចំនួន ប៉ុណ្ណោះ ដែលកើតមកពី ការរស់នៅតាមដំណឹងល្អ។ បន្ថែមពីនេះទៅទៀត ព្រះអម្ចាស់មានព្រះបន្ទូលថា ជនណាដែលរស់នៅតាមអ្វីដែលគេរៀន ជននោះនឹងត្រូវបានឱ្យបន្ថែមទៀត ហើយជនណាដែលមិនរស់នៅតាមអ្វីដែលគេរៀន នឹងត្រូវបាត់បង់ ចំណេះវិជ្ជា ដែលគេមាន (សូមមើល អាលម៉ា 12:9–11)។

> “សូមទទួលទានន្ូវព្រះបន្ទូលនៃព្រះគ្រីស្ទ ត្បិតមើលចុះ ព្រះបន្ទូលនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកន្ូវ គ្រប់អ្វីទាំងអស់ ដែលអ្នកត្រូវ ធ្វើ” (សូមមើល នីហ្វៃទី2 32:3)។

ថ្ងៃទាំងឡាយ ដែលខ្ញុំអាន 10 នាទី ឬ ច្រើនជាងនោះ		ជំពូកដែលបានចាត់តាំង ដែលខ្ញុំអានទៅសប្តាហ៍នេះ
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 1*	“ការសិក្សាពីព្រះគម្ពីរ” “ទំព័រចំណងជើង នៃព្រះគម្ពីរមរមន” “បព្ចកថា ទីបន្ទាល់ ...” នីហ្វៃទី1 1 2
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 2*	នីហ្វៃទី1 3 4 5 6 7 8 9 10
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 3*	នីហ្វៃទី1 11 12 13 14 15 16
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 4*	នីហ្វៃទី1 17 18 19 20 21 22
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 5*	នីហ្វៃទី2 1 2 3 4 5
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 6*	នីហ្វៃទី2 6 7 8 9 10
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 7*	នីហ្វៃទី2 11 12 13 14 15 16 17 18 19 20 21 22 23 24
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 8*	នីហ្វៃទី2 25 26 27 28 29 30
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 9*	នីហ្វៃទី2 31 32 33 យ៉ាកុប 1 2 3 4
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 10*	យ៉ាកុប 5 6 7 អេណុស 1 យ៉ារ៉ុម 1
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 11*	អោមណៃ 1 ពាក្យសំដីនៃមរមន 1 ម៉ូសាយ 1 2 3
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 12*	ម៉ូសាយ 4 5 6 7 8 9 10
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 13*	ម៉ូសាយ 11 12 13 14 15 16 17 18
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 14*	ម៉ូសាយ 19 20 21 22 23 24 25
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 15*	ម៉ូសាយ 26 27 28 29 អាលម៉ា 1
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 16*	អាលម៉ា 2 3 4 5 6 7
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 17*	អាលម៉ា 8 9 10 11 12 13
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 18*	អាលម៉ា 14 15 16 17 18 19 20
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 19*	អាលម៉ា 21 22 23 24 25 26
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 20*	អាលម៉ា 27 28 29 30 31 32 33
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 21*	អាលម៉ា 34 35 36 37 38
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 22*	អាលម៉ា 39 40 41 42 43 44
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 23*	អាលម៉ា 45 46 47 48 49 50
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 24*	អាលម៉ា 51 52 53 54 55 56
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 25*	អាលម៉ា 57 58 59 60 61 62 63
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 26*	ហេលេមិន 1 2 3 4 5 6
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 27*	ហេលេមិន 7 8 9 10 11 12
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 28*	ហេលេមិន 13 14 15 16 នីហ្វៃទី3 1 2
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 29*	នីហ្វៃទី3 3 4 5 6 7 8 9 10
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 30*	នីហ្វៃទី3 11 12 13 14 15 16 17
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 31*	នីហ្វៃទី3 18 19 20 21 22 23 24 25 26
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 32*	នីហ្វៃទី3 27 28 29 30 នីហ្វៃ 4 1 មរមន 1 2
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 33*	មរមន 3 4 5 6 7 8 9
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 34*	អេធើរ 1 2 3 4 5 6 7 8
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 35*	អេធើរ 9 10 11 12 13 14 15
អ ច អ ព ព្រ សុ ស	*សប្តាហ៍ទី 36*	ម៉រ៉ូណៃ 1 2 3 4 5 6 7 8 9 10

ព្រះគម្ពីរមរមន គឺជាសក្ខីបទម្ហយទៀត នៃព្រះយេស៊ូវគ្រីស្ត

អ្នកប្រហែលជាត្រូវបានសួរ ឬក៏ប្រហែលជាបានឆ្ងល់ដោយខ្លួនឯងថា "តើព្រះគម្ពីរមរមន *គឺជាអ្វី*?" ព្រះអម្ចាស់បានប្រកាសថា ព្រះគម្ពីរមរមន មានបញ្ជីប្រវត្តិអំពីប្រជារាស្ត្រដែលបានធ្លាក់ និងភាពពេញលេញនៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ត (សូមមើល គ និង ស 20:9)។ ទ្រង់ក៏បានមានបន្ទូលដែរថា ព្រះគម្ពីរមរមន បានបំភ្លឺថាព្រះគម្ពីរបិ៊ប គឺជាព្រះគម្ពីរពិត ហើយថាព្រះហៅ និងបំផុសគំនិតព្យាការីទាំងឡាយនៅសម័យនេះ ដូចដែលទ្រង់បានធ្វើនៅសម័យបុរាណដែរ (សូមមើល គ និង ស 20:10–12)។

ក្នុងឆ្នាំ 1982 ក្នុងការធ្វើអោយពិភពលោកយល់ថា តើព្រះគម្ពីរមរមន គឺជាអ្វី អែលឌើរ បិយ យេ. ផាកកឺ ជាសមាជិកនៃក្រុមសាវ៉ក ទាំងដប់ពីរ បានប្រកាសថាះ "ដោយការរិះគិតពីមុន របស់បងប្អូនប្រុស ព្រះគម្ពីរមរមន ចាប់ពីពេលនេះតទៅ នឹងថ្លែងជាចំណងជើងថា ព្រះគម្ពីរមរមន ជាម្ហយនិងចំណងជើងរង សក្ខីយបទម្ហយទៀត នៃព្រះយេស៊ូវគ្រីស្ត" (នៅក្នុង Conference Report, ខែតុលា ឆ្នាំ 1982, 75 ឬ *Ensign* ខែវិច្ឆកា ឆ្នាំ 1982, 53)។

ព្រះគម្ពីរមរមន មានតួនាទីយ៉ាងសំខាន់គឺ ទីមួយ "ការបំភាន់នៃ សាសន៍យូដា និងសាសន៍ដទៃ [មនុស្សគ្រប់គ្នា] ថាព្រះយេស៊ូវ គឺជា ព្រះគ្រីស្ត ជាព្រះដ៏អស់កល្បជានិច្ច បានបង្ហាញព្រះកាយ របស់ទ្រង់ ដល់មនុស្សគ្រប់សញ្ជាតិ "(ចំណងជើងទំព័រ នៃ ព្រះគម្ពីរ មរមន)។ គោលដៅទីពីរ របស់ ព្រះគម្ពីរមរមន គឺដើម្បីបំភ្លឺចំពោះពិភពលោកថា យ៉ូសែប ស្មីធ គឺជាព្យាការីពិត របស់ព្រះ ហេតុដូច្នោះហើយ សាសនាចក្រ គឺជា សាសនាចក្រពិត និងព្យាការីដែលមានដោគជ័យ ទាំងឡាយ គឺបាននិយាយ នៅក្នុងព្រះនាម របស់ព្រះ (សូមមើល គ និង ស 20:8–12)។ គោលដៅទីបី គឺ "បញ្ចុះបញ្ចូលមនុស្ស ឱ្យមករកព្រះនៃអ៉ីប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះនៃយ៉ាកុប ហើយបានសង្គ្រោះ" (នីហ្វៃទី1 6:4)។

តើការសិក្សា ព្រះគម្ពីរមរមន អាចធ្វើឱ្យមានអត្ថប្រយោជន៍ អ្នីខ្លះចំពោះខ្ញុំ?

មនុស្សខ្លះបានឆ្ងល់ថា ហេតុអ្វីយើងចាំបាច់មាន ព្រះគម្ពីរមរមន ទៅបន្ថែមលើព្រះគម្ពីរបិ៊ប។ ប្រធានអែសរ៉ា ថាហ្ វ ប៉ែនស៊ីន បន្ទាប់មកក្លាយជាប្រធាន នៃក្រុមសាវ៉កទាំងដប់ពីរ បានបង្រៀនថាះ

"ព្រះគម្ពីរមរមន បញ្ជីប្រវត្តិរបស់យ៉ូសែប ស្មីធ បញ្ជាក់ថា ព្រះគម្ពីរបិ៊ប គឺពិត។ ធ្វើឱ្យថ្មជំពប់ចេញ វាស្តារឡើងវិញ នូវរុក្ខជាតិ និងវត្ថុដ៏សំខាន់ឲ្យ។ យើងសូមថ្លែងថា ប្រសិនបើប្រើ ព្រះគម្ពីរបិ៊ប និងព្រះគម្ពីរមរមនទាំងពីរ បំភ្លឺគោលលទ្ធិខុស ដាក់ចុះនូវការឈ្លោះប្រកែក និងសាងឡើងវិញនូវសេចក្តីសុខសាន្ត (សូមមើល នីហ្វៃទី2 3:12។)

"វាមិនចាំបាច់ដើម្បីបំភ្លឺថា ព្រះគម្ពីរមរមន ពិតទេ។ ព្រោះ ព្រះគម្ពីរមរមនបានបំភ្លឺខ្លួនឯងហើយ។ អ្វីដែលយើងត្រូវធ្វើ គឺគ្រាន់តែអាន និងចែកចាយ! ព្រះគម្ពីរមរមន មិនមែនជាបញ្ហាទេ—មនុស្ស ក្នុងពិពភលោក រួមទាំងសមាជិកនៃសាសនាចក្រ មានបញ្ហា គឺត្រូវធ្វើជាសាក្សីទីពីរ នៃព្រះគ្រីស្ត។

"ខ្ញុំសូមថ្លែងថា ព្រះគម្ពីរមរមន គឺជាព្រះបន្ទូលរបស់ព្រះ ហេតុដូច្នេះហើយ ព្រះយេស៊ូវ គឺជាព្រះគ្រីស្ត, យ៉ូសែប ស្មីធ គឺជាព្យាការី ហើយ សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាសាសនាចក្រពិត ជាម្ហយសិទ្ធអំណាច ដើម្បីបំរើ ធ្វើពិធីការ នៃផែនការណ៍សង្គ្រោះសព្វថ្ងៃនេះ" (នៅក្នុង Conference Report, ខែតុលា ឆ្នាំ 1987, 7 ឬ *Ensign* ខែវិច្ឆិការ ឆ្នាំ 1984, 8)។

ព្រះគម្ពីរមរមន ពិតជា "ព្រះបន្ទូលពិតរបស់ព្រះគ្រីស្ត" (សូមមើល នីហ្វៃទី2 33:10–11, ម៉ូរ៉ៃណៃ 10:26–27)។ នៅពេលដែលអ្នកចាប់ផ្តើមសិក្សាព្រះគម្ពីរនេះ សូមរកមើលពាក្យព្រះអង្គសង្គ្រោះ ហើយសូមទទួលទាននូវបន្ទូលនៃទ្រង់។ អ្នកនឹងរកទ្រង់យើញ នឹងត្រូវបានចិញ្ចឹមបីបាច់យ៉ាងល្អ។ អធិស្ឋាន និងសញ្ជឹងគិត។ អ្នកនឹងទទួលចំលើយទាំងឡាយ ចំពោះសំនួរនិងចំងល់របស់អ្នក វាអាចជាពាក្យបំផុសគំនិត ដែលព្រះវិញ្ញាណ នឹងប្រាប់អ្នកនៅក្នុងអារម្មណ៍របស់អ្នក ឬតាមរយះព្រះវិញ្ញាណ ដោយការអានព្រះគម្ពីរដែលនឹងធ្វើអោយអ្នកនៅក្នុងអារម្មណ៍ល្ងងលោម និងការទទួលវិវរណៈ។

ទទួលយកការសន្យារបស់ម៉ូរ៉ៃណៃ ដែលថា បើសិនអ្នកនឹង "សូមដោយចិត្ត ស្មោះស ដោយចេតនាពិត ដោយមានសេចក្តី ជំនឿដល់ព្រះយេស៊ូវគ្រីស្ត នោះទ្រង់នឹងសម្តែងសេចក្តីពិត នៃការណ៍នេះដល់អ្នក ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។

"ហើយដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នានឹងបានដឹង នូវសេចក្តីពិតនៃការណ៍គ្រប់យ៉ាង" (ម៉ូរ៉ៃណៃ 10:4–5)។

ទំព័របុព្វកថា នៃព្រះគម្ពីរមរមន

ទំព័រចំណងជើង

ហេតុអ្វី និងតាមរបៀបណា ដែលព្រះគម្ពីរមរមន ត្រូវបានសរសេរ

ទំព័រចំណងជើងនៃព្រះគម្ពីរមរមន ត្រូវបានសរសេរដោយម៉ូរ៉ូណៃ ដែលជាកូនរបស់មរមន។ ព្យាការីយ៉ូសែប ស្ម៊ីធ បានពន្យល់ថាៈ “ទំព័រចំណងជើងនៃព្រះគម្ពីរមរមន គឺជាការបកប្រែយ៉ាងត្រឹមត្រូវ គឺត្រូវបានយកចេញពីសន្លឹកចុងក្រោយបង្គស់ នៅផ្នែកខាង ឆ្វេង នៃការប្រមូល ឬស្បៃភៅផ្ទាំងចំណា ដែលមានបញ្ជីប្រវត្តិ ដែលត្រូវបានបកប្រែ ភាសាទាំងមូល គឺដូចជាការសរសេរ ទូទៅ នៃសាសន៍ហេព្រើរ ដែលបានឱយាយថា ទំព័រចំណងជើង មិនមែនជាអត្ថន័យ នៃការសរសេរសម័យថ្មីទេ ទោះជាកម្មសិទ្ធិរបស់ខ្ញុំ ឬ ជាកម្មសិទ្ធិរបស់មនុស្សណាម្នាក់ ដែលបានរស់នៅ ឬកំពុងរស់នៅក្នុងជំនាន់នេះ” (History of the Church 1:71)។

ទំព័រចំណងជើង ត្រូវបានពន្យល់ដោយអំណាច ដែលព្រះគម្ពីរមរមនត្រូវបានសរសេរ និងដោយអំណាច ដែលព្រះគម្ពីរមរមន នឹងមកក្នុងសម័យចុងក្រោយ។ ម៉ូរ៉ូណៃ ក៏បានផ្តល់មូលហេតុជាច្រើន ហេតុអ្វី បញ្ជីប្រវត្តិពិសិដ្ឋនេះ ត្រូវបានសរសេរ នឹងត្រូវបាន រក្សានៅក្នុងសម័យរបស់យើង។

ការយល់ដឹងអំពីព្រះគម្ពីរ

ទំព័រចំណងជើង

ការធ្វើឱ្យខ្លីឡើង—ការបកស្រាយខ្លីៗ

សំណល់—ផ្នែកនៅសល់

បានបំភាន់—បានច្រឡំ

ទំព័រចំណងជើង—តើមានន័យយ៉ាងម៉េចដែរចំពោះពាក្យថា “វង្សនៃអ៊ីស្រាអែល” “ពួកសាសន៍យូដា” និង “សាសន៍ដទៃ”?

យ៉ាកុប ជាកូនប្រុសរបស់អ៊ីសាក និងជាចៅប្រុសរបស់អ័ប្រាហាំ គឺត្រូវបានដាក់ឈ្មោះ *អ៊ីស្រាអែល* ដោយព្រះអម្ចាស់ (សូមមើល លោកុប្បត្តិ 32:28)។ “វង្សនៃអ៊ីស្រាអែល” គឺសំដៅទៅពូជពង្សរបស់អ៊ីស្រាអែល “ពួកសាសន៍យូដា” គឺសំដៅទៅ មនុស្សដែល ជាកុលសម្ព័ន្ធនៃសាសន៍យូដា ប៉ុន្តែក៏មានន័យថា អ្នកដែលមកពីអាណាចក្រនៃ សាសន៍យូដាដែរ ទោះបីជា ពួកគេ មិនមកពីកុលសម្ព័ន្ធយូដាក៏ដោយ “សាសន៍ដទៃ” មានន័យថា “ជនជាតិទាំងឡាយ” និងមានន័យ ចំពោះអ្នកទាំងឡាយណា ដែលមិនមែនជាវង្សនៃអ៊ីស្រាអែល ឬអ្នកទាំងឡាយណាដែលមិនជឿ ទៅលើព្រះនៃអ៊ីស្រាអែល។ ក្នុងព្រះគម្ពីរមរមន ពាក្យថា *“សាសន៍ដទៃ* ក៏អាចសំដៅចំពោះអ្នកដែលបានរស់នៅ ឬអ្នកដែលមកពីក្រៅ ជាតិផ្សេងៗ នៃដែនដីអ៊ីស្រាអែល អាស្រ័យទៅ លើពូជ របស់ពួកគេ។

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក, នៅពេលដែលអ្នក សិក្សាទំព័រចំណងជើងនៃព្រះគម្ពីរមរមន។

គ គោលបំណងនៃការស្វែងរក

នៅក្នុងកថាខ័ណ្ឌទីមួយ នៃទំព័រចំណងជើង ម៉ូរ៉ូណៃបានពន្យល់ថា ព្រះគម្ពីរមរមនគឺ “ត្រូវបានសរសេរដោយបញ្ញត្តិ និងដោយ ព្រះវិញ្ញាណ នៃការព្យាករណ៍ និងវិវរណៈផងដែរ។” នៅក្នុងកថាខ័ណ្ឌទីពីរ គាត់បានផ្តល់គោលបំណងជាច្រើនឡើត ឬជា មូលហេតុដែលព្រះបានបញ្ជាថា បញ្ជីប្រវត្តិនេះត្រូវថែរក្សាទុក។ ស្វែងរកគោលបំណងទាំងនោះ ដូចដែលអ្នក អាចរកទៅបាន ហើយសរសេរ នៅក្នុងស្បៃភៅសរសេររបស់អ្នក។ គូសរង្វង់នូវអ្វី ដែលមានអត្ថន័យ បំផុតសំរាប់អ្នក។

បុព្វកថា ទីបន្ទាល់ ឬការពន្យល់ខ្លីៗ និងឈ្មោះតាមលំដាប់ស្បៃវភៅ

ផ្តើមទំព័រ ទាក់ទងពតិមានជ័មានខ្លឹមសារ ដើម្បីជួយអ្នកអោយយល់ នឹងមានអំណរគុណចំពោះព្រះគម្ពីរមរមន។ កុំរំលងវា។ ទំព័រផ្នែកខាងក្នុងនេះ នឹងទាក់ទង ពតិមាន ដែលអ្នកនឹងត្រូវការ សំរាប់ការយល់ដឹង បញ្ជីប្រវត្តិពិសិដ្ឋ។

ការយល់ដឹងអំពីព្រះគម្ពីរ

សេចក្តីផ្តើម

ការបំភាន់អណ្តាត (កថាខ័ណ្ឌទី 2)—ការបំភាន់ភាសា

សិក្ខាបទ (កថាខ័ណ្ឌទី 6)—បទបញ្ញត្តិ, គោលការណ៍

ទេវភាព (កថាខ័ណ្ឌទី 7–8)—ផ្តើមមកពីព្រះ

សេចក្តីណែនាំ កថាខ័ណ្ឌទី 6—តើសិលាគ្រឹះគឺជាអ្វី?



ព្រះគម្ពីរមរមន គឺជាសិលាគ្រឹះនៃសាសនារបស់យើង។

ព្យាការីយ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា “ព្រះគម្ពីរមរមនគឺជា គម្ពីរដ៏ត្រឹមត្រូវបំផុត ជាងគម្ពីរនានា ទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនារបស់យើង” (*History of the Church,* 4:461)។ ហើយគាត់ក៏បានមានប្រសាសន៍ថាៈ “ដក ចេញ នូវព្រះគម្ពីរមរមន និងវិវរណៈ តើឯណាទៅសាសនារបស់យើង? យើងគ្មានទេ” (*History of the Church,* 2:52)។

ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បានពន្យល់ថាៈ

“សិលាគ្រឹះ ជាថ្មកណ្ដាល។ វាបានទ្រថ្មផ្សេងៗទៀត ឱ្យនៅមួយកន្លែង ហើយបើសិនផ្លាស់ប្ដូរទី ថ្ម និងបែកជាផ្នែកតូចៗ។

“មានវិធីបីយ៉ាង ដែលធ្វើឱ្យព្រះគម្ពីរមរមន ក្លាយជាសិលាគ្រឹះនៃសាសនារបស់យើង។ វាគឺជាសិលាគ្រឹះនៃការធ្វើជាសាក្សី របស់យើង ចំពោះព្រះគ្រីស្ទ។ វាគឺជាសិលាគ្រឹះនៃគោលលទ្ធិរបស់យើង។ វាគឺជាសិលាគ្រឹះនៃទីបន្ទាល់ របស់យើង។

“ព្រះគម្ពីរមរមន គឺជាសិលាគ្រឹះ ក្នុងការធ្វើជាសាក្សីរបស់យើងចំពោះ ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ផ្ទាល់គឺជា ថ្មជ្រុងយ៉ាងឯក នូវគ្រប់អ្វីៗ ទាំងអស់ដែលយើងធ្វើ។ វាថ្លែងជាសាក្សីពីតថភាពពិតរបស់ទ្រង់ អំណាច និងភាពច្បាស់លាស់ . . .។

“ព្រះគម្ពីរមរមន ក៏ជាសិលាគ្រឹះនៃគោលលទ្ធិនៃការរស់ឡើងវិញផងដែរ។ ដូចដែលយើងបានញ្ជាក់ពីមុន ព្រះអម្ចាស់ទ្រង់ផ្ទាល់ បានថ្លែងថា ព្រះគម្ពីរមរមនមាន ‘ភាពពោរពេញនៃដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទ’ (សូមមើល គ និង ស 20ៈ9)។ នោះមិនមានន័យថា វាមានគ្រប់ការបង្រៀន គ្រប់គោលលទ្ធិដែលត្រូវបានសំដែងឱ្យឃើញនោះទេ។ ដូច្នេះ វាមានន័យថា ក្នុង ព្រះគម្ពីរមរមន យើងនឹងស្វែងរកភាពពោរពេញ នៃគោលលទ្ធិទាំងនោះ ដែលត្រូវបានតំរូវសំរាប់ផែនការណ៍សង្គ្រោះរបស់យើង។ ហើយ គោលលទ្ធិទាំងនោះ គឺត្រូវបានបង្រៀនយ៉ាងសាមញ្ញ សូម្បីតែកូនក្មេងតូចៗ ក៏អាចរៀន អំពីផែនការណ៍សង្គ្រោះ និងការលើក ដំកើងបានដែរ។ ព្រះគម្ពីរមរមន បានផ្ដល់ការយល់ដឹងយ៉ាងច្រើនទៅដល់គំនិត អំពីគោលលទ្ធិ នៃផែនការណ៍សង្គ្រោះ។ បើគ្មាន ព្រះគម្ពីរមរមនទេ ការបង្រៀនជាច្រើន នៅក្នុងព្រះគម្ពីរផ្សេងៗទៀត នោះនឹងមិនមានការបង្រៀនយ៉ាងល្អ និងមានតំលៃឡើង។

នៅទីបំផុត ព្រះគម្ពីរមរមន គឺជាសីលាគ្រឹះមូលដ្ឋាននៃសក្ខីភាព។ គឺដូចជាថ្មរាងកោង ត្រូវបានបែកជាផ្នែកតូចៗ ប្រសិន បើមូលដ្ឋាន ត្រូវបាន ផ្លាស់ប្ដូរ ដូច្នេះសាសនាចក្រ អាចឈរ ឬ ធ្លាក់ចុះដោយសារសេចក្ដីពិត ដ៏ពេញលេញ របស់ព្រះគម្ពីរមរមន។ សត្រូវរបស់ សាសនាចក្របានយល់យ៉ាងច្បាស់នូវរឿងនេះ។ នេះជាមូលហេតុដែលពួកគេ ខិតខំធ្វើអ្វីៗ ដើម្បីបំភ្លឺថា ព្រះគម្ពីរមរមនគឺខុស នោះវាអាចបង្ខូច កិត្តិយសថាព្យាការីយ៉ូសែប ស្ម៊ីធ ក៏ខុសដែរ។ ចំពោះការអះអាង របស់យើងទៅ កូនសោនៃបព្វជិតភាព និងវិវរណៈ និងការស្ដារសាសនាចក្រឡើងវិញ។ ប៉ុន្ដែក្នុងរបៀបនេះ បើសិនព្រះគម្ពីរមរមនពិត–ហើយមនុស្ស រាប់លាន ទាក់បានថ្លែងថា ពួកគេមានព្រះវិញ្ញាណជាសាក្សីថា ព្រះគម្ពីរមរមន គឺពិត–បន្ទាប់មកមានអ្នកអះអាង ពីការស្ដារឡើងវិញ និងអ្វីៗដែលទាក់ទង និងព្រះគម្ពីរមរមន” (នៅក្នុង Conference Report, ខែតុលា ឆ្នាំ 1986, 4–5, ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1986, 5–6)។

សេចក្ដីផ្ដើម—ព្យាការីបានថ្លែងពីព្រះគម្ពីរមរមន

ប្រធាន ម៉ារៀន ជី. រ៉ូមនី ដែលធ្លាប់ជាសមាជិក នៃគណៈប្រធានទីមួយ បានមានប្រសាសន៍ថាៈ “បើសិនជាយើង អាចចៀសវាង ពីអំពើអាក្រក់ នៃលោកីយ៍នេះ យើងត្រូវតែស្វែងរក ពីអ្វីដែលនឹងចិញ្ចឹមអារម្មណ៍ យើងប្រចាំថ្ងៃ និងចិញ្ចឹមវិញ្ញាណ យើងផង ដែរ។ ខ្ញុំមិនដឹងថាតើ វិធីណាប្រសើរជាង ការអានព្រះគម្ពីរមរមនប្រចាំថ្ងៃនោះទេ” (នៅក្នុង Conference Report, ខែមេសា ឆ្នាំ 1980, 88, ឬ *Ensign,* ខែឧសភា ឆ្នាំ 1980–66។

ព្យាការីសម័យក្រោយៗ បានថ្លែងពីសារៈសំខាន់ នៃការសិក្សាព្រះគម្ពីរមរមន។ ប្រធាន អែសរ៉ា ថាហ្វ បែនសឹន មានប្រសាសន៍ ថាៈ “អំណាចមាននៅក្នុងព្រះគម្ពីរមរមន ហើយវានឹងចាប់ផ្ដើមហូរ ចូលមកជីវិតរបស់អ្នក នៅពេល ដែលអ្នកសិក្សាព្រះគម្ពីរ មរមន ដោយពិតប្រាកដ។ អ្នកនឹងរកឃើញអំណាចដ៏អស្ចារ្យ ដើម្បីទប់ទល់លើការល្បួង។ អ្នកនឹងរកឃើញ អំណាច ដើម្បីជៀសវាងការបោកបញ្ឆោត។ អ្នកនឹងរកឃើញអំណាច ដើម្បីបន្តធ្វើដំណើរនៅលើផ្លូវតូច និងចង្អៀត។ ព្រះគម្ពីរត្រូវ បានហៅថា ‘ពាក្យនៃជីវិត’ (សូមមើល គ និង ស 84ៈ85) ហើយគ្មានអ្វី ដែលពិតជាងព្រះគម្ពីរមរមនទេ។ នៅពេលដែល អ្នកឃ្លាន ហើយស្រេក រកពាក្យ ទាំងនេះ អ្នកនឹងរកឃើញនូវជីវិតដ៏ប្រសើរ និងភាពសំបូរហូរហៀរ” (នៅក្នុង Conference Report, ខែតុលា ឆ្នាំ 1986, 6, ឬ *Ensign,* ខែវិច្ឆិកា ឆ្នាំ1986, 7)។

ប្រធាន គរដឹន ប៊ី. ហ៊ីងឃ្លី បានមានប្រសាសន៍ថាៈ “ខ្ញុំសូមអញ្ជើញ បុរស និង ស្ត្រី . . . និងរាល់យុវជន យុវនារី ដែលធំល្មម ដើម្បីអាន ព្រះគម្ពីរមរមននៅឆ្នាំថ្មី នេះម្ដងទៀត។ ព្រះគម្ពីរមរមនត្រូវបានសរសេរដើម្បីបញ្ជាក់ ដល់សាសន៍យូដា និងសាសន៍ដទៃថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ។ គ្មានអ្វីសំខាន់បំផុត ដែលយើងគួរធ្វើ ជាងការពង្រឹងជីវិតយើងម្នាក់ៗ និងការមិនភ័យខ្លាច នូវការបញ្ជាក់ថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រាដ៏មានព្រះជន្ម នៃព្រះដ៏មានព្រះជន្ម។ នេះគឺជាគោលបំណង នៃការឆ្លោះ មក របស់ព្រះគម្ពីរដ៏អស្ចារ្យនិងគួរឱ្យកត់សំគាល់។ ខ្ញុំសូមអញ្ជើញអ្នក ឱ្យអានព្រះគម្ពីរមរមនម្ដងទៀត ហើយយកខ្មៅដៃ ពណ៌ក្រហម ហើយគូស ចំណាំ នៅពេលដែលមានពាក្យថា ព្រះយេស៊ូវគ្រីស្ទ នៅក្នុងព្រះគម្ពីរមរមន។ ហើយវានឹងលេចចេញ មកកាន់អ្នកជាមួយនឹង ការបញ្ជាក់យ៉ាងពិតប្រាកដ បើសិនអ្នកធ្វើដូច្នេះ អ្នកគឺជាសាក្សីនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ” (*Teaching of Gorden B. Hinkley* [1997], 44)។

ទីបន្ទាល់នៃពួកសាក្សី បីនាក់

ព្រះគុណនៃព្រះជាព្រះវរបិតា—
អំណោយនៃព្រះ និងអំណាច



អូលីវើរ ខៅឌើរី — *ដាវីឌ វិតមើរ* — *ម៉ាទិន ហារីស*

ទីបន្ទាល់នៃពួកសាក្សីបីនាក់—តើវាមានន័យដូចម្ដេចចំពោះ “កំចាត់សំល្បេកបំពាក់របស់យើង ពីលោហិតនៃមនុស្សទាំងអស់”?

ពាក្យថា លោហិត នៅក្នុងឃ្លានេះ គឺជានិមិត្តរូបនៃអំពើបាប។ ចំពោះអស់អ្នកទាំងឡាយណា ដែលបានទទួលមុខងារពីព្រះអម្ចាស់ ដើម្បីថ្លែងទៅពិភពលោក ដើម្បីបង្រៀន និងថ្លែងដោយស្មោះត្រង់ ដែលថាឱ្យជ្រះស្អាត ពីលោហិតនៃលោកីយ៍។ បើសិនអ្នក ទាំងនោះ មិនស្មោះត្រង់ក្នុងមុខងាររបស់គេទេ ពួកគេនឹងទទួលខុសត្រូវចំពោះអំពើបាប របស់អ្នកដែលពួកគេត្រូវ ជួយឱ្យរៀនពីសេចក្ដីពិត (សូមមើល យ៉ាកុប 1ៈ18–19)។

ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់

បានលើក—បានលើក

ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់—ហេតុអ្វីបានជាព្រះហៅសាក្សីច្រើនម្ល៉េះ?

ព្រះអម្ចាស់បានប្រកាសថា “គ្រប់ការទាំងអស់នឹងបានសំរេច ដោយនូវមាត់ស្មរ បន្ទាល់ ពីរ ឬបីនាក់” (សូមមើល កូរិនថូសទី 2 13ៈ1)។ អែលឌើរ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ក្រោយមកបានក្លាយជា សមាជិកនៃក្រុម សាវកទាំងដប់ពីរនាក់ បានពន្យល់ថាៈ “បន្ទូល [របស់ព្រះ] គឺតែងតែបានប្រកាសដោយមាត់ នៃសាក្សីដែលបាន តែងតាំង យ៉ាងត្រឹមត្រូវ ដែលជាអ្នក ដែលបានតែងតាំង ដើម្បីថ្លែងពីកិច្ចការរបស់ទ្រង់។ ព្រះគម្ពីរមរមន មិនអាចឆ្លោះមក ដោយ វិធីណាផ្សេងក្រៅពីវិធីដែលព្រះគម្ពីរមរមន បានឆ្លោះ មកទេ និងបំពេញតាមច្បាប់។ ព្យាការីបានប្រកាសថា ព្រះអម្ចាស់នឹងហៅ ‘ពួកសាក្សីទាំង ប៉ុន្មានដែលទ្រង់យល់ថាល្អគ្រប់គ្រាន់ សំរាប់ទ្រង់’ [សូមមើល នីហ្វៃទី2 27ៈ12–14] ដើម្បីកសាងកិច្ចការ របស់ទ្រង់” (*The Restoration of All Things* [1945], 107)។

ទីបន្ទាល់របស់ព្យាការី យ៉ូសែប ស្មីធ

ការទូលអង្វរ (ទំព័រ 1 កថាខ័ណ្ឌ 2)—ការសួរ, ការសុំអង្វរ

ទឹកមុខ (ទំព័រ 1 កថាខ័ណ្ឌ 5)—ការបង្ហាញឡើង

អំពីទីកំណើត ដែលពួកគេលេចមក (ទំព័រ 1 កថាខ័ណ្ឌ 7)—កន្លែងអំពីទីកំណើត ដែលពួកគេលេចមក

សញ្ជឹងគិតដល់សេចក្តីប្លែក (ទំព័រ 2 កថាខ័ណ្ឌ 2)—ការគិតពីហេតុការណ៍មិនធម្មតា

សភាពក្រខ្សត់ (ទំព័រ 2 កថាខ័ណ្ឌ 4)—ភាពក្រីក្រ

ពិសោធបានដោយសេចក្តីបញ្ជាក់ពីព្រះ (ទំព័រ 3 កថាខ័ណ្ឌ 8)—ដូចទ្រង់បានមានបន្ទូលថា គង់តែនឹង

ការពន្យល់ដោយសង្ខេបអំពី ព្រះគម្ពីរមរមន

ប្រវត្តិសាស្ត្រលោកិយ (កថាខ័ណ្ឌ 2)—ប្រវត្តិរបស់ស្តេច, សង្គ្រាម, នឹងផ្សេងឲ្យទៀត

សង្ខេប (កថាខ័ណ្ឌ 3)—ទំរង់ខ្លីឲ្យ

ចុងក្រោយបំផុត (កថាខ័ណ្ឌ 8)—នៅទីបំផុត

ការពន្យល់ខ្លីឲ្យ—តើភាពខុសឲ្យគ្នា នៃផ្នែកផ្ទាំងចំណាមាស គំណាងអោយអ្វីខ្លះ នៅក្នុងព្រះគម្ពីរមរមន?

ការពន្យល់នៅទំព័រទី 12 នៃស្សៀភៅសិក្សានេះជាជំនួយពន្យល់ ពីភាពខុសគ្នានៃផ្នែកផ្សេងឲ្យ របស់ផ្ទាំងចំណាមាស និងការផ្តុំចូល គ្នានូវបញ្ជី ប្រវត្តិដើម្បីបង្កើតជា ព្រះគម្ពីរមរមន។ កំណត់ថាវាមានការសរសេរច្រើនជាង ដែលមរមន និង ម៉ូរឹណៃអាចបញ្ចូល ទៅក្នុងផ្ទាំងមាស របស់មរមន (សូមមើល ហេលេមិន 3:14–15, អេធើរ 15:33)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ ចេញពីសកម្មភាពដូចខាងក្រោម (ក–ច)នៅពេលអ្នកសិក្សាពីការណែនាំ និងការពន្យល់ខ្លីឲ្យ។

ក្ត្រ តើសកម្មភាពនេះ មានន័យយ៉ាងដូចម្តេចចំពោះអ្នក?

ការដកស្រង់នូវពាក្យរបស់ព្យាការី យ៉ូសែប ស្មីធ នៅក្នុងកថាខ័ណ្ឌទី 6 នៃសេចក្តីផ្តើម គឺមានខាងក្រោម នូវគោលការណ៍បី អំពីព្រះគម្ពីរមរមន។ នៅក្នុងស្សៀវភៅសរសេររបស់អ្នក ពន្យល់ពីមូលហេតុដែលគោលការណ៍នេះពិត និងតើវាមានន័យ ដូចម្តេចចំពោះអ្នក។ ប្រើពតិមានទៅក្នុងសេចក្តីផ្តើម និងនៅក្នុងកណ្ឌ "ការយល់ដឹងពីព្រះគម្ពីរ" ដើម្បីជួយដល់អ្នក។

1. ព្រះគម្ពីរមរមនគឺជា "ព្រះគម្ពីរដ៏ត្រឹមត្រូវបំផុត ជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ។"
2. ព្រះគម្ពីរមរមនគឺជា "សីលាគ្រឹះនៃសាសនារបស់យើង។"
3. បុគ្គលម្នាក់ឲនឹង "ចូលទៅជិតព្រះបាន ដោយសារ ការធ្វើតាមសិក្ខាបទទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់។"

ខ្ត្រ ធ្វើឱ្យសីលាគ្រឹះមានរាងជាថ្មកោង

ប្រើឈើបន្តឲ្យគ្នា ឬសម្ភារៈសមរម្យផ្សេងទៀត ដើម្បីសាងសង់ថ្មរាងកោង (សូមមើលរូបភាពនៃថ្មរាងកោង នៅទំព័រ 9)។ ដាក់ សញ្ញាសីលាគ្រឹះលើ "ព្រះគម្ពីរមរមន។" យកថ្មរាងកោង ទៅថ្មាក់របស់អ្នកហើយបង្ហាញពីរបៀប ដែលសីលាគ្រឹះ និងថ្មរាងកោង បានទ្រគ្នា ទៅវិញទៅមក។

ត្ត្រ តើធ្វើដូចម្តេច ទើបខ្ញុំដឹងថា ព្រះគម្ពីរមរមនគឺជា ព្រះគម្ពីរពិត?

អានកថាខ័ណ្ឌនៃសេចក្តីផ្តើមពីរចុងក្រោយបំផុត ហើយនៅក្នុងស្សៀវភៅសរសេររបស់អ្នក ពន្យល់ពីអ្វីដែលអ្នកត្រូវតែធ្វើ ដើម្បីទទួល ព្រះវិញ្ញាណជាសាក្សីថា ព្រះគម្ពីរមរមនគឺជាគម្ពីរពិត។

យ្ត្រ តើកថាខ័ណ្ឌចុងក្រោយធ្វើជាសាក្សីឱ្យដល់អ្វី?

1. សរសេរពីអ្វីដែល សាក្សីបីនាក់ បានឃើញនិងបានលឺ និងពីអ្វីដែលសាក្សីប្រាំបីនាក់ បានឃើញនិងបានប៉ះស្ទាប។
2. តើវាមានអត្ថន័យដូចម្តេចចំពោះអ្នក ដែលបុរសទាំងដប់មួយនាក់ បានថ្លែងថា ព្យាការីយ៉ូសែប ស្មីធ គឺពិតជាបាន ទទួលផ្ទាំងចំណាមាស ហើយក្នុងចំណោមពួកគេ មានបីនាក់បានឃើញទេវតា និងបានលឺសំលេងនៃព្រះអម្ចាស់?

ឲ្ត្រ តើអ្វីដែលធ្វើអោយអ្នកស្ងប់ស្ងែង?

បន្ទាប់ពីការអានទីបន្ទាល់របស់ព្យាការីយ៉ូសែប ស្មីធ សរសេរយ៉ាងតិច មួយរឿង ដែលធ្វើឱ្យអ្នកស្ងប់ស្ងែង អំពីទីបន្ទាល់នោះ។

ឳ្ត្រ ព្យាការីបានមានប្រសាសន៍ចេញពីព្រះគម្ពីរមរមន

ធ្វើតារាងដែលមានកូឡោនបួន។ ដាក់សញ្ញាលើកូឡោនទីមួយ "ពរជ័យដែលបានសន្យា" កូឡោនទីពីរ "ចូប្រឹក្សាពីអ្វីដែលអ្នក កំពុងអានព្រះគម្ពីរមរមន" កូឡោនទីបី "តើព្រះគម្ពីរមានទំនាក់ទំនងអ្វីខ្លះ" និងកូឡោនទីបួន "ទីបន្ទាល់ របស់ព្យាការីទាំង ឡាយ។" អាន "តើសីលាគ្រឹះគឺជាអ្វី?" និង "ការថ្លែងទីបន្ទាល់របស់ព្យាការីអំពីព្រះគម្ពីរមរមន" នៅក្នុងកណ្ឌ "ការយល់ដឹងពីព្រះ គម្ពីរ"។ ចូររកមើលសេចក្តីថ្លែងការណ៍ដែលទាក់ទងទៅនឹងកូឡោនមួយក្នុងកូឡោនទាំងបួន ហើយសរសេរសេចក្តីថ្លែងទាំងនោះ នៅក្នុងកូឡោនមួយដែល សមរម្យ។

ប្រភពសំខាន់ៗនៅក្នុងព្រះគម្ពីរមរមន

ប្រភពមួយចំនួនសំរាប់ផ្ទាំងមាសរបស់មរមន	ផ្ទាំងចំណារបស់មរមន ដែលបានឱ្យទៅព្យាការីយ៉ូសែប ស្ម៊ីធ (មិនឆ្លុះបញ្ចាំងជាចំបាច់ចំពោះ លំដាប់លំដោយផ្ទាំងផ្សេងៗ នៃចំណានោះទេ)



ផ្នាំងគីម្ជយរបស់នីហ្វៃ

តើអ្នកបានដឹងអ្វីខ្លះ អំពីការញ្យាការណ៍ របស់ នីហ្វៃ?

អ្នកប្រហែលជាដឹងថា នីហ្វៃ គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នក ដែលសរសេរក្រុះតម្ពីរមរមនជាច្រើនរូបទៀត ប៉ុន្តែតើមានអ្វីខ្លះ ទៀត ដែលអ្នកបានដឹងអំពីគាត់? នៅពេលដែលអ្នកអាន នីហ្វៃទី1 និងទី2 អ្នកនឹងស្វែងយល់ឃើញថា នីហ្វៃក៏ធ្លាប់ជាសិស្ស ម្នាក់ផងដែរ និង ជាអ្នកបរបាញ់ដ៏អស្ចារ្យ ជាជាងដែក ជាជាងសាងសង់សំពៅ ជាអ្នកបើកនាវា ជាជាងមាស ជាអ្នករក្សាបញ្ជី ប្រវត្តិ ជាជនភៀសខ្លួន ជាអ្នកកសាងព្រះវិហារបរិសុទ្ធ ជាស្តេច ជាទាហាន ជាញ្យាការី និងជាអ្នកមើលរុត។ តើអ្នកគិតថា មនុស្ស ដែលមាន បទពិសោធន៍ប្រភេទនេះ អាចបង្រៀនយើងអំពីជីវិតអ្វីខ្លះ?

តើពេលណា ហើយទីកន្លែងណា ដែលនីហ្វៃបានរស់នៅ?

នីហ្វៃបានរស់នៅជិតទីក្រុងយេរូសាឡិម នៅក្នុងអាណាចក្រខាងត្បូង នៃសាសន៍យូដា ប្រហែលជា 600ឆ្នាំ ពីមុនកំណើត ព្រះគ្រីស្ត។ អំណាចដ៏ខ្លាំង នៃសាសន៍បាប៊ីឡូន និងស្រុកអេស៊ីព្ទ គឺកំពុងឈ្លោះគ្នា ដើម្បីគ្រប់គ្រងពិភពលោកប៉ែកនោះ និង អាណាចក្រដ៏តូចរបស់សាសន៍យូដា គឺត្រូវបានចាប់ជាប់នៅចំណុចកណ្តាល។

ដោយសារអំពើទុច្ចរិត អាណាចក្រអ៊ីស្រាអែលខាងជើង ត្រូវច្បាំងគ្នា ហើយមនុស្សត្រូវទទួលទុក្ខវេទនា ដោយសាសន៍ អាសស៊ើរ អស់រយៈពេលជាង 100ឆ្នាំ។ នៅសម័យរបស់នីហ្វៃ មនុស្សទុច្ចរិតមានច្រើន និងសាសន៍យូដា គឺត្រូវបាន ទទួល ឥទ្ធិពលមុនគេ មកពីអំណាចជនបរទេសបន្ទាប់មកគឺសាសន៍ផ្សេងៗទៀត។ ញ្យាការីដូចជា យេរេមា និងឱពុករបស់នីហ្វៃ លីហ្វៃ បានញ្យាករថា អាណាចក្រនៃយូដា និងត្រូវកំទេចចោលផងដែរ ប្រសិនបើពួកគេមិនកែប្រែចិត្ត។ ញ្យាការីអេសេគាល និង ដានីយែល ក៏បានរស់នៅក្នុងអំឡុងពេលនោះដែរ។



ហេតុអ្វីបានជា នីហ្វៃសរសេរផ្នាំងនេះ?

មានសេចក្តីពិតមួយចំនួន ដែលនីហ្វៃសង្ឃឹមថា យើងនឹងបានរៀននៅពេលយើងអានផ្នាំងនេះ។ នៅសេចក្តីផ្តើម បានឱ្យ ការពន្យល់ខ្លីៗ អំពីក្រុមគ្រួសាររបស់នីហ្វៃ និងការធ្វើដំណើរ និងការឈ្លោះប្រកែកគ្នា (សូមមើលកថាខ័ណ្ឌ នៅក្រោមចំណង ជើងស្យែវភៅ ពីមុនជំពូក1)។ នីហ្វៃបានសរសេរថា គាត់នឹងបង្ហាញ "សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយ នៃព្រះអម្ចាស់ មានមកលើផែនដីដល់ជនទាំងអស់ណា ដែលព្រះទ្រង់បានរើស ដោយសារសេចក្តីជំនឿរបស់គេ ដើម្បីធ្វើឱ្យគេខ្លាំងពូកែ ស្មើនឹងអំណាច នៃសេចក្តីរំដោះឱ្យរួច" នីហ្វៃទី1 1ះ20)។ នីហ្វៃក៏បានពន្យល់ផងដែរថា គោលបំណងរបស់គាត់គឺដើម្បី "សរសេរនូវរឿងរបស់ព្រះ" គឺដើម្បី "បញ្ចុះបញ្ចូលមនុស្ស ឱ្យមករកព្រះនៃអ័ប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះនៃយ៉ាកុប ហើយបានសង្គ្រោះ"។ (នីហ្វៃទី1 6ះ3–4, និង យ៉ាកុប 1ះ1–4)។

ហេតុដច្មោះហើយនៅពេលដែលអ្នកអាន នីហ្វៃទី1 ត្រូវយកចិត្តទុកដាក់ថា គាត់កំពុងបង្រៀនយើងឱ្យមកជិតព្រះយេស៊ូវគ្រីស្ត ហើយឱ្យបានសង្គ្រោះ។ នីហ្វៃបានប្រៀបធៀបយើងទៅនឹងបទពិសោធន៍ទាំងឡាយ នៃក្រុមគ្រួសាររបស់គាត់ ដើម្បីបង្ហាញពីអំណាច ដែលព្រះអម្ចាស់បានសង្គ្រោះដល់មនុស្ស ដែលមានសេចក្តីជំនឿ ទាំងក្នុងជីវិតនេះ និងជីវិតក្រោយ។

ព្រឹត្តិការណ៍ នៅក្នុងនីហ្វៃ1 បានចាប់ផ្តើមប្រាំមួយរយឆ្នាំពីមុនកំណើត របស់ព្រះគ្រីស្ត។ នៅពេលនោះ ដោយសារអំពើទុច្ចរិត របស់សាសន៍យូដា បានធ្លាក់ចុះនៅក្រោមការគ្រប់គ្រង នៃអំណាចអាណាចក្ររបស់សាសន៍បាប៊ីឡូន។ ញ្យាការីយេរេមា បានព្រមាន ដល់សាសន៍យូដា ឱ្យទៅបាប៊ីឡូន ឬត្រូវកំទេចចោល (សូមមើល យេរេមា 27ះ12–13)។ ញ្យាការីលីហៃ ក៏ត្រូវបានហៅឱ្យទៅព្រមាន ពួកសាសន៍យូដាឱ្យកែប្រែចិត្តដែរ (សូមមើល នីហ្វៃទី1 1ះ18–19)។ ទោះបីជាយ៉ាងណាក៏ដោយ ពួកសាសន៍យូដា បានជ្រើសរើសស្តាប់តាម ការណែនាំរបស់ញ្យាការីក្លែងក្លាយ ដែលបានញ្យាករថា

បាប៊ីឡូន មិនមែនយូដាទេ ដែលត្រូវកំទេច ចោល (សូមមើល យេរេមា 28:1–4)។ សាសន៍យូដាបានប្រឆាំងនិងបាប៊ីឡូន ហើយនៅក្នុងអំឡុងពេល ប្រហែលឆ្នាំ 586 ម.ត អាណាចក្រ នៃសាសន៍យូដា ហើយទីក្រុង យេរូសាឡិម ត្រូវបានកំទេចចោល ហើយពួកសាសន៍យូដាជាច្រើន ត្រូវ ចាប់ជាឈ្លើយ ទៅបាប៊ីឡូន។



បាប៊ីឡូនច្បាំងនិង ស្រុកអាសស៊ើរ និងបន្ទាប់មកច្បាំង និងសាសន៍អ៊ីស្រាអែល។

តើអ្នកធ្លាប់ឆ្ងល់ទេថា តើព្រះអម្ចាស់ហៅ និងរៀបចំព្យាការីពិតរបស់ទ្រង់ ដោយរបៀបណា? យើងបានរៀនទូវរៀងខ្លះព្ធ នៅក្នុងនីហ្ចៃទី1 1 ដែល នីហ្ចៃបានប្រាប់យើង ពីរបៀបដែលព្រះអម្ចាស់បានហៅឱពុករបស់គាត់ លីហៃ ដើម្បីព្យាករទៅ ដល់សាសន៍យូដា។ នៅពេលដែលអ្នកអានរៀងនេះ កំណត់ចំណាំពីការងាររបស់លីហៃ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ទៅនឹងការងាររបស់ព្យាការីផ្សេងព្ធទៀត។ (ឧទាហរណ៍ សូមមើល អេសាយ 6:1–8, អេសេគាល 1:1–3, 26–28, 2 វិវរណៈ 10:1–2, 8–11, ប្រវត្តិ—យ៉ូសែប ស្មីធ1:15–35)។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្ចៃទី1 1

សេចក្តីអាថិកំបាំងរបស់ព្រះ (ខ 1)—សេចក្តីពិតដែលមិនអាចយល់ ដោយគ្មាន វិវរណៈពីព្រះ

ដ៏ឥតគណនា (ខ 8)—ការប្រជុំដ៏ធំ

រស្មី (ខ 9)—ពន្លឺ

បង្គាប់ (ខ 11)—ស្មើ, បញ្ជា

ទុក្ខវេទនា (ខ 13)—ទុក្ខព្រួយ, សេចក្តីវេទនា

អំពើគួរឱ្យស្អប់ខ្ពើម (ខ 13, 19)—អំពើបាប, គំនិតនិងសកម្មភាពដែលធ្វើឱ្យ ខូចចំពោះព្រះនេត្រព្រះ

ទុក្ខ (ខ 14)—អនុញ្ញាត

ការសង្ខេប (ខ 17)—ទំរង់ខ្លីព្ធ

ការប្រោសលោះនៃពិភពលោក (ខ 19)—ការចែកផ្តល់ដល់ពិភពលោក ចេញ ពីអំពើបាបតាមរយៈការពលិកម្មរបស់ព្រះគ្រីស

នីហ្ចៃទី1 1:2—តើនីហ្ចៃបានសរសេរជាភាសាអ្វីនៅលើផ្ទាំង?

នីហ្ចៃសរសេរជា "ភាសារបស់ឱពុកគាត់" និងជា "ភាសារបស់អេស៊ីព្ធ។" ឆ្ពោះទៅកាន់ទីបញ្ចប់ នៃព្រះគម្ពីរមរមន ម៉ូរ៉ូណៃបាន ពិពណ៌នា ការសរសេររបស់គាត់ និងឱពុករបស់គាត់ថា "បាន សរសេរឡើងជាអក្សរអេស៊ីព្ធ" (មរមន 9:32)។ "យើងពុំដឹងថា នីហ្ចៃ មរមន ឬម៉ូរ៉ូណៃ បាន សរសេរជាអក្សរហេព្រើរ ដែលបញ្ជាក់ន័យជាអក្សរអេស៊ីព្ធ ឬចរិតនៅលើផ្ទាំងរបស់ពួកគាត់ជា អក្សរទាំងពីរប្រភេទ គឺជាភាសាអេស៊ីព្ធ និងជាអក្សរអេស៊ីព្ធ ឬនីហ្ចៃបានសរសេរជាភាសាមួយ ហើយមរមន និងម៉ូរ៉ូណៃ ដែលជាអ្នកបានរស់នៅ ប្រាំបួនរយឆ្នាំក្រោយ បានសរសេរជាភាសាមួយ ទៀត" (នៅក្នុង Danie H. Ludlow, ចោះពុម្ពដោយ *Encyclopedia of Mormonism*, ភាគ 5 [1992] 1:179)។



ជាអក្សរគំរូ ដកស្រង់ចេញពីផ្ទាំងព្រះគម្ពីរមរមន

នៅក្នុងនីហ្ចៃទី1 1:20—តើនីហ្ចៃចង់បង្រៀនយើងអំពីអ្វី?

នៅក្នុងខទី 20 នីហ្ចៃបានប្រាប់ពីមូលហេតុដែលគាត់បានកត់ត្រា ពីប្រវត្តិគ្រួសាររបស់គាត់ (សូម មើលផងដែរថា "ហេតុអ្វីនីហ្ចៃ សរសេរផ្ទាំងនេះ?" នៅទំព័រ 9 នៃស្យែភៅនេះ)។ សូមមើលពី គំរូនៃគោលបំណងនេះ នៅពេលដែលអ្នកអាន នៅផ្ទាំងពីរ ដែលគាត់បានសរសេរ។

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាពពីរដូចខាងក្រោម (ក–គ)នៅពេលដែលអ្នកអាន នីហ្ចៃទី1 1។

ក្ត៉ តើជីវិតរបស់អ្នកដូច នឹងជីវិតនីហ្ចៃ យ៉ាងដូចម្តេច?

ដើម្បីជាការចាប់ផ្តើមកត់ត្រា នីហ្ចៃបានណែនាំខ្លួនរបស់គាត់។

1. អានដោយប្រុងប្រយ័ត្ននៅក្នុង នីហ្ចៃទី1 1:1–3 ហើយស្វែងរកពាក្យ ឬឃ្លាគន្លឹះ ដែលបង្ហាញថា តើជីវិតរបស់នីហ្ចៃ ដូចម្តេច។ អ្នកអាចគូសចំណាំពាក្យនេះនៅក្នុងព្រះគម្ពីររបស់អ្នក។ នៅក្នុង ស្យែវភៅកំណត់ចំណាំរបស់អ្នក សរសេរប្រយោគ ឬការសង្ខេប ពីអ្វី ដែលនីហ្ចៃបានប្រាប់យើង ពីខ្លួនរបស់គាត់។
2. ចូរពន្យល់ពីវិធីមួយដែលជីវិតរបស់អ្នក ស្រដៀងទៅនឹងជីវិតរបស់នីហ្ចៃ។

ខ្ស៉ សៃងរកគំរូ

1. ស្វែងរកនៅក្នុង នីហ្ចៃទី1 1:5–20 ហើយសរសេរចូល ពីអ្វីដែលបានកើតឡើងចំពោះ លីហៃ។ សំនួរខាងក្រោមនឹងជួយ អ្នក ឱ្យស្វែងរកចំណុចសំខាន់ព្ធទាំងនោះ:
   - តើលីហៃបានធ្វើអ្វីតំបូង? (សូមមើល ខ 5)។
   - តើលីហៃបានឃើញអ្វី? (សូមមើល ខ 6–10)។
   - តើលីហៃបានទទួលអ្វី? (សូមមើល ខ 11)។
   - តើលីហៃបានរៀនអំពីអ្វី? (សូមមើល ខ 13–14)។
   - តើលីហៃបានធ្វើដូចម្តេច ចំពោះអ្វីដែលគាត់បានរៀន? (សូមមើល ខ 18)។
   - តើប្រជាជនឆ្លើយតបចំពោះសាររបស់គាត់ដោយរបៀបណា? (សូមមើល ខ 19–20)។
2. អានព្រះគម្ពីរដូចខាងក្រោម ហើយកត់ពាក្យ ឬឃ្លា ដែលបង្ហាញថា ព្យាការីផ្សេងព្ធទៀត បាន មានបទពិសោធន៍ ស្រដៀងនឹងបទពិសោធន៍របស់លីហៃ: អេសេគាល 1:1–3, 26–28, 2, វិវរណៈ 10:1–2, 8–11 ប្រវត្តិ–យ៉ូសែប ស្មីធ 1:15–35។
3. តើព្រះគម្ពីរនេះបានបង្រៀនអ្នក អំពីមុខងាររបស់ព្យាការីយ៉ូសែប ស្មីធយ៉ាងដូចម្តេច?

ត្ត៉ សរសេរសេចក្តីសង្ខេប

នីហ្ចៃបានអានបញ្ជីប្រវត្តិ របស់ឱពុកាត់រួចហើយធ្វើការសង្ខេប ឬជាទំរង់ខ្លីព្ធ នៅលើផ្ទាំងរបស់ គាត់ផ្ទាល់។ ដើម្បីធ្វើ ការសង្ខេប របស់គាត់ នីហ្ចៃបានជ្រើសរើសផ្នែកដែលគាត់គិតថា នឹងអាច

ជួយយើងឱ្យកាន់តែយល់ច្បាស់ពីព្រះអង្គសង្គ្រោះ និងចំណង ក្រាថ្មារបស់ទ្រង់ដើម្បីជួយយើង។ សរសេរការសង្កេតដែលមានភាពស្មុគស្មាញ ពីព្រោះអ្នកដែលនឹងធ្វើការសង្កេត ក៏នឹងត្រូវសំរេចចិត្ត ពីអ្វីដែលគួរបញ្ចូល នឹងអ្វីដែលគួរតែដកចេញដែរ។ សរសេរការសង្កេត នូវខទាំងបីចេញពីនីហ្វៃទី1 1 សង្កេបវាចេញជា ប្រយោគ តែមួយ។ សរសេរវាឱ្យដូចគោលចំណង ដែលនីហ្វៃបានមាន (សូមមើល "តើហេតុអ្វី បានជា នីហ្វៃសរសេរផ្នែកនេះ?" នៅទំព័រ ០០ នៃស្បៃវគ្គនេះ)។



លីហៃមិនមែនជាព្យាការីតែម្នាក់ ដែលត្រូវបានសាសន៍យូដាខឹង ដោយការបង្រៀនសេចក្តីពិតប៉ុណ្ណោះទេ។ ព្យាការីយេរេមា ក៏ត្រូវបាន ធ្លើទុក្ខបុកម្នេញ និងត្រូវបានដាក់គុកនៅកំឡុងពេលប្រហាក់ប្រហែលគ្នាដែរ។ នៅក្នុងនីហ្វៃទី1 2 អ្នកនឹងអាន ពីអ្វីដែលព្រះ អម្ចាស់ បានធ្វើដើម្បីជួយសង្គ្រោះលីហៃ និងក្រុមគ្រួសាររបស់គាត់ មិនត្រឹមតែកំហឹងមកពីសាសន៍យូដាទេ ប៉ុន្តែក៏មកពីការបំផ្លិចបំផ្លាញនៃយេរូសាឡិមដែរ។ តើអ្នកបានរៀនរបៀបខុសគ្នាអ្វីខ្លះ ដែលកូនឲ្យរបស់លីហៃបាន គិតចំពោះអ្វី ដែល ព្រះអម្ចាស់ បានបញ្ជាឱ្យលីហៃធ្វើ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 2

ក្បាលរឹង (ខ 11)—ក្បាលរឹង, អំនួត

រអ៊ូរ (ខ 12)—ការរអ៊ូរទាំ ឬការជំទាស់ដោយសំលេងតិចៗ

បានបំភាន់ពួកគេ (ខ 14)—ធ្វើឱ្យពួកគេច្រឡំហើយមិនអាចមានលទ្ធភាពឆ្លើយបាន

មិនអាចបន្លឺសំលេង (ខ 14)—មិនអាចនិយាយ

មាំមួន (ខ 16)—ទំហំនៃរូបកាយ

រំពាត់ (ខ 24)—ទុក្ខលំបាក, បណ្តាសសារ, ទារុណកម្ម

នីហ្វៃទី1 2:2–6 តើទីរហោស្ថាននៅឯណា?

លីហៃ បានដឹកនាំគ្រួសាររបស់គាត់ចេញពីយេរូសាឡិម ទៅសមុទ្រក្រហម ដែលឈ្លងសមុទ្រអារ៉ាប៊ុយធា។ មានចំងាយប្រហែលជា 180 ម៉ាយ (290 គីឡូម៉ែត្រ)។ នៅទីនោះជាស្រុកដែលស្ងួតហែង ហើយក្តៅ និងមាន ចោរឆ្មក់ចាំលួចអ្នកធ្វើដំណើរដែល មិនបានរៀបចំខ្លួន។ បន្ទាប់ពីបានទៅដល់សមុទ្រក្រហម លីហៃបានត្រលប់ទៅទិសខាងត្បូង ហើយបន្តធ្វើដំណើរចំថ្ងៃឡើត ពីមុនបោះជំរុំទៅច្រកភ្នំទន្លេ។ គ្រួសាររបស់លីហៃ ចំណាយពេលប្រហែលជាដប់បួនថ្ងៃ ដើម្បីធ្វើដំណើរចេញពីទីក្រុងយេរូសាឡិម មកដល់ចំណុចនេះ។ ចូរចងចាំថា រយៈចំងាយគឺ ជាប់ទាក់ទង នៅពេលដែលអ្នកអាន ពីការធ្វើដំណើររបស់ពួកគេ ត្រឡប់ទៅ យេរូសាឡឹមវិញ។

នីហ្វៃទី1 2:11—តើ "មនុស្សរវើរវាយ" គឺជាអ្វី?

លីហៃត្រូវបានហៅថា ជាមនុស្សរវើរវាយ ព្រោះគាត់បានទទួលការនិមិត្ត ជាសុបិន្ត និងវិវរណៈផ្សេងៗទៀត មកពីព្រះ។ មនុស្សជាច្រើនអាចគិតថា វិវរណៈនោះគឺជាការល្អ ប៉ុន្តែ លេមិន និងលេមយួល បែរជាចាត់ទុកថា លីហៃគឺជាអ្នក មានសុបិន្ត រវើរវាយ។

ការសិក្សាព្រះគម្ពីរ

ចូររធ្វើសកម្មភាព ក ឬ ខ ក៏បានបន្តាប់មក ធ្វើសកម្មភាព គ នៅពេលដែលអ្នកអាន នីហ្វៃទី1 2។

ក សរសេររបាយការណ៍សារពតិមាន

សាសន៍យូដាចំអកនិង ខឹងនឹងការថ្លែងសក្ខីភាព ជាសាធារណៈរបស់លីហៃ ដែលជំទាស់នឹងអំពើទុច្ចរិតរបស់ពួកគេ។ សំដែងថា អ្នកគឺជាអ្នកសរសេរសារពតិមានម្នាក់ ដែលនឹងទៅជួបលីហៃ នៅផ្ទះរបស់គាត់ ស្រាប់តែអ្នកឃើញ គ្រួសាររបស់លីហៃ បានចេញ ពាត់អស់។ ហើយនៅពេលដែលអ្នក ធ្វើការសាកសួរអ្នកជិតខាង អ្នកបានទទួលពតិមាន ដូចមាននៅក្នុង នីហ្វៃទី1 2:1–4។ នៅក្នុងស្បៃវគ្គសរសេររបស់អ្នក សរសេររបាយការណ៍សារពតិមាន ដែលពិពណ៌នាពីការបាត់ខ្លួន ភ្លាមៗ របស់លីហៃ និងគ្រួសាររបស់គាត់។

ខ សរសេរកំណត់សំគាល់មួយ

នីហ្វៃបានពិពណ៌នាពី លេមិន និងលេមយួលថាជា "មនុស្សក្បាលរឹង" ព្រោះពួកគេក្បាលរឹងបន្តធ្វើអំពើទុច្ចរិតរបស់ពួកគេ។ ពួកគេមិនជឿថា ឪពុករបស់ពួកគេត្រូវបានបំផុសគំនិតដោយព្រះទេ ហើយពួកគេបានខឹង ព្រោះពួកគេត្រូវរៀបចំដំណើរ និងទ្រព្យ សម្បត្តិនៅឯយេរូសាឡិម ហើយមករងទុក្ខវេទនានៅទីរហោស្ថាន (សូមមើល នីហ្វៃទី1 2:11–13)។ នីហ្វៃ "ព្រួយចិត្តពេក ដោយព្រោះតែភាពរឹងរូស នៃចិត្តរបស់បងខ្ញុំទាំងពីរ ទោះខ្ញុំបានអំពាវនាវដល់ព្រះអម្ចាស់សំរាប់គេ" (ខ 18)។ សរសេរ សំបុត្រទៅកាន់ លេមិននិងលេមយួលអំពីការគោរពឪពុករបស់ខ្លួន និងការបន្ទាបខ្លួន ដើម្បីឱ្យបងប្អូនរបស់គាត់ស្គាល់ពី "អំណាចរបស់ព្រះ ដែលជាអ្នកបង្កើតពួកគេ" (ខ 12)។

គ ប្រៀបធៀបសកម្មភាព និងលទ្ធផល

ប្រតិកម្មរបស់លេមិន និងលេមយួល ចំពោះការសំរេចចិត្តរបស់ឪពុកគាត់ ដើម្បីចាកចេញពីយេរូសាឡិម គឺខុសពីប្រតិកម្ម របស់នីហ្វៃទាំងស្រុង។

1. រំលឹកឡើងវិញ នីហ្វៃទី1 2:11–14 ហើយសរសេរយ៉ាងតិចឱ្យបានមូលហេតុបីដែលលេមមិន និងលេមយួលបានធ្វើការ បះបោរ។
2. រំលឹកឡើងវិញ ខ 16–17 ពីអ្វីដែលនីហ្វៃ បានធ្វើដើម្បីជួយគាត់មិនបះបោរ។
3. ពីអ្វីដែលអ្នកបានរៀន ពីខទាំងនេះ តើមនុស្សត្រូវតែធ្វើអ្វី ដើម្បីមនុស្សមិនបះបោរប្រឆាំង និងព្រះបញ្ជាត្តិរបស់ព្រះ?

នីហ្វៃទី1 3–4

មានសេចក្តីជំនឿ ព្រះអម្ចាស់នឹងជួយអ្នក

បើសិនអ្នកបានព្យាយាមធ្វើការដ៏លំបាកដែលឪពុករបស់អ្នកបានឱ្យអ្នកធ្វើ ហើយអ្នកបានទទួលការបរាជ័យ តើអ្នកគួរតែ សាកល្បងធ្វើ វាម្តងទៀតទេ? បើសិនជាការសាកល្បងនោះ ធ្វើឱ្យអ្នកជិតនឹងស្លាប់ ហើយអ្នកបានព្យាយាមម្តងទៀត តែអ្នកនៅ តែបរាជ័យ តើអ្នកនឹងឈប់ទេ? តើអ្នកនឹងធ្វើយ៉ាងដូចម្តេច បើសិនជាអ្នកដឹងថា ការសាកល្បងនោះ គឺមកពីព្រះវរបិតាសួគ៌ មិនមែនមកពីឪពុកខាង លោកិយរបស់អ្នក? នៅក្នុងនីហ្វៃទី1 3–4 កូនឮប្រុសរបស់លីហៃ បានទទួលការសាកល្បងដូច្នោះ។ កំណត់សំគាល់ថា អ្នកដែល មានជំនឿ ការសាកល្បងនោះនឹងត្រូវបានបំពេញ ហេតុអ្វីគាត់មានជំនឿ។ កំណត់ចំណាំផងដែរថា អ្នកដែលមានជំនឿ មិន មែនថា ការសាកល្បងវាងាយស្រួលទេ គឺគ្រាន់តែគេអាចសំរេចទូរការសាកល្បងនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 3

ប្រវត្តិរបស់បព្វការីជនរបស់ខ្ញុំ និងឈ្មោះរបស់ឪពុករបស់ខ្ញុំ (ខ 3, 12)—ឈ្មោះរបស់ឪពុក និងឈ្មោះរបស់បព្វការីជន របស់ខ្ញុំ

ឆ្លាក់ (ខ 3, 12)—ការឆ្លាក់ ឬ ការសរសេរនៅលើផ្ទាំងលោហៈធាតុ

ក្តីលោភលន់ (ខ 25)—សេចក្តីប៉ងប្រាថ្នាដែលមិនអាចគ្រប់គ្រងបាន, ចំណង់

ត្រូវតែ (ខ 26)—ត្រូវបានបង្ខំ

ភាពទុច្ចរិត (ខ 29)—អំពើបាប

នីហ្វៃទី1 3:11–តើពាក្យថា "ចាប់ឆ្មោត" មានន័យដូចម្តេច?

ការចាប់ឆ្មោតគឺត្រូវបានប្រើ ជាមធ្យោបាយបង្ហាញពីការជ្រើសរើស។ វិធីសាស្ត្រពិតប្រាកដគឺពុំបានស្គាល់ឡើយ ប៉ុន្តែនៅសម័យនេះ គេប្រើការចាប់ឆ្មោតផ្សេងៗ ឬការត្រឡប់កាក់ ក៏ជាវិធីមួយដែរ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សសម័យបុរាណ បានជឿថា ការចាប់ឆ្មោត ត្រូវបានកំណត់ដោយព្រះអម្ចាស់ (សូមមើល សុភាសិត 16:33)។

នីហ្វៃទី1 3:3, 12–13, 23–27, 4:7–9, 12–13, 19–22–តើយើងបានដឹងអ្វីខ្លះ អំពីឡាបាន់?

នៅក្នុងជំពូកនេះ មានអ្នកនិពន្ធម្នាក់ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានលើកឡើងពីចំណុចមួយចំនួនដែលយើងអាចរៀន អំពីឡាបាន់ "យើងបានរៀនរួចទៅហើយថា ឡាបាន់បានបញ្ជាទាហានហាសិបទាក់ ដែលគាត់បានជួប នៅក្នុងពិធីការទាហាន ជាមួយនីហ្វៃ ចាស់ទុំនៃសាសន៍យូដា (នីហ្វៃទី1 4:22)ដើម្បីពិគ្រោះពីការសំងាត់នៅពេលយប់ថា គាត់ត្រូវគ្រប់គ្រងមរតក ដែលឡាបាន់ជាមនុស្សត្រកូលអភិជន ហើយជាប់ខ្សែសាលោហិតជាមួយនីហ្វៃ គាត់ប្រហែលជាធ្វើការងារនេះ ដោយសារដីដូនដីតា របស់គាត់ តំាងពី គាត់តំាងពីបុក ទទួលអ្វី ដែលគាត់សមនិងបានទទួល ផ្ទះរបស់គាត់ផ្ទុកទៅដោយបញ្ជីប្រវត្តិចាស់ៗ គាត់ជាមនុស្ស ដែល មានរូបកាយធំ, ក្មានការអត់ធ្មត់, ឆ្លាត, និងគ្រោះថ្នាក់, ចិត្តកំណាញ់,លោភ, ប្រើហឹង្សា, ខ្ជោយ, និងចូលចិត្តគ្រឿងស្រវឹង"

នីហ្វៃទី1 4

ទៅខាងនេះ និងទៅខាងនោះ (ខ 2)—ទីនេះ និងទីនោះ

កំហឹង (ខ 4)—ខឹងយ៉ាងខ្លាំង

បានបង្ខំ (ខ 10)—បានបញ្ជា, បានបង្ខិតបង្ខំ, បានបង្ខំ

ចុះអន់ថយ (ខ 13)—ការធ្លាក់ចុះ, ក្លាយជាខ្សោយ

មិនមានខ្នះមុខណាឡើយ (ខ 19)—គ្រប់ផ្នែកនៃវត្ថុទាំងអស់

ក្រវ៉ាត់ (ខ 19)—ពាក់

នៅជាមួយ (ខ 35)—ស្នាក់នៅ

នីហ្វៃទី1 4:10–18—ហេតុអ្វីបានជា នីហ្វៃសំលាប់ឡាបាន់?

ព្យាការីយ៉ូសែប ស្ម៊ីធ មានប្រសាសន៍ថា:

"ប្រហែលនោះជាហេតុមួយ ដែលស្ថិតនៅក្នុងកាលៈទេសៈមួយ ហើយជាញឹកញាប់ គឺវាដូច្នោះមែន តែថា ត្រូវ ដែលស្ថិតនៅ ក្នុងកាលៈទេសៈមួយផ្សេងទៀត។

"ព្រះទ្រង់បានមានបន្ទូលថាៈ 'កុំឱ្យសំលាប់មនុស្សឱ្យសោះ' នៅពេលខ្លះទ្រង់បានមានបន្ទូលថា' ឱ្យកុំបំផ្លាញគេ' [ចោទិយកថា 20:17]។ នេះគឺជាគោលការណ៍ ដែលបានដឹកនាំការគ្រប់គ្រងនៅស្ថានសួគ៌—ដោយវិវរណៈយកលំនាំតាមកាលៈទេសៈ ដែល កូនចៅនៃព្រះនឹករ និងត្រូវដាក់។ នៅពេលដែលព្រះតំរូវឱ្យធ្វើអ្វីមួយ មិនថាឡើយតំរូវការនោះជាអ្វីទេ វាគឺជាការត្រឹមត្រូវ ទោះបីជាពេលខ្លះយើងមិនអាចយល់ពីមូលហេតុ ប៉ុន្តែនៅក្រោយពេលហេតុការណ៍នោះកើតឡើង យើងនឹងយល់។ បើសិន ជាយើងស្វែងរកនឹករ របស់ព្រះជាមុនសិន នោះវត្ថុដែលល្អនឹងត្រូវបានផ្តល់ឱ្យ" (*Teaching of the Prophet Joseph Smith,* បានប្រើសរើសដោយ Joseph Fielding Smith [1976], 256)។

© 1966 Ronald K. Crosby

នីហ្វៃទី1 4:30–38—អំណាចនៃសម្បថ នៅក្នុងជំនាន់នីហ្វៃ

"ព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ ហើយត្រាកដដូចជាខ្ញុំនៅមានជីវិត" (នីហ្វៃទី1 4:32) វាគឺជាគំរូនៃសម្បថដ៏ឧឡារិក ហើយត្រូវបានប្រើយ៉ាងពិសិដ្ឋ នៅសម័យដើមនៃទិសកណ្តាលខាងកើត។ "ដើម្បីភ្ជាប់ជាមួយសម្បថ យ៉ាងឧឡារិក គឺត្រូវតែ ធ្វើ ឡើងដោយ *ជីវិត* នៃអ្វីមួយ ទោះបីវាគ្រាន់តែជាស្មៅក៏ដោយ។ សម្បថដែលអាក្រក់ជាងនោះគឺ' ដោយជីវិតរបស់ខ្ញុំ' ឬ(មិនជាទូទៅ) 'ដោយជីវិតដាក់នៅលើក្បាល' គឺ . . . 'ដោយជីវិតនៃព្រះ' ឬ 'ដោយព្រះអម្ចាស់នៅមានព្រះជន្ម'" (Hugh Nibley, *An Approach to the Book of Mormon,* ការរោះពុម្ពជាលើកទីពីរ [1964], 104)។

កំណត់សំគាល់ពីរបៀបដែលសូរ៉ាំ មានចិត្តស្ងប់ដោយពាក្យរបស់នីហ្វៃ (សូមមើល នីហ្វៃទី1 4:35) និងពេលដែលបងប្អូនរបស់នីហ្វៃ បានទុកចិត្តសូរ៉ាំ បន្ទាប់ពីសូរ៉ាំបានសម្បថថានឹងទៅជាមួយពួកគេ (សូមមើល ខ 37)។ នៅក្នុងជំនាន់របស់យើង នៅពេលដែលធ្វើ ការសន្យាវាហាក់ដូចជា ការពិចារណានោះមិនសូវពិសិដ្ឋទេ ជាការគួរឱ្យកត់សំគាល់ណាស់ ចំពោះអ្វីដែល បានកើតឡើងរវាងនីហ្វៃ និងសូរ៉ាំ។ សូមមើលផងដែរ នីហ្វៃទី1 3:15, កន្លែងណា ដែលនីហ្វៃស្បថ ថាពួកគាត់អាចយកផ្ទាំងលង្ហិន។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីក្នុងចំណោមសកម្មភាពទាំងឡាយដូចខាងក្រោមនេះ (ក–គ) នៅពេលដែលអ្នកសិក្សានៅ នីហ្វៃទី1 3–4។

ក ព្រះគម្ពីរចំបង—នីហ្វៃទី1 3:7

1. អាន នីហ្វៃ 1 3:1–8 បន្ទាប់មកអាន នៅក្នុងស្បៃវែងសរសេររបស់អ្នក សរសេរ ខ្ញុំនឹង _____ ហើយ _____ តែខ្ញុំ _____។ រំលឹកឡើងវិញ ខ 7 ហើយសរសេរពាក្យមួយ នៅលើបន្ទាត់ទីមួយៗ។ ពន្យល់ពីប្រយោជន៍នេះ ដោយសង្កេតថា ហេតុអ្វីនីហ្វៃមិនបានរអ៊ូ ដូចបងប្រុសរបស់គាត់។
2. សរសេរឡើងវិញ ខ 7 ហើយប្រើឈ្មោះរបស់អ្នក នៅក្នុងកន្លែងដែលមានពាក្យថា *នីហ្វៃ*។ បន្ទាប់មកយ៉ាងហោចណាស់ សរសេរ មួយម្តង នៅពេលដែលអ្នកមានសេចក្តីជំនឿដូចនីហ្វៃ ហើយក្លាហានហ៊ានធ្វើអ្វីដែលពិបាកដូចជា ព្រះអម្ចាស់ បានប្រើនីហ្វៃឱ្យធ្វើ។
3. សង្កេតអត្ថន័យនៅក្នុង នីហ្វៃទី1 3:7 សរសេរយ៉ាងខ្លី ដែលអ្នកងាយចាំឃ្លានោះ ដូចជា “ពង្រឹងជំហររបស់អ្នក” ឬ “រាល់សមាជិកគឺជាអ្នកផ្សាយសាសនា។”

ខ តើយើងអាចរៀនអ្វីខ្លះអំពី បេសកកម្មរបស់នីហ្វៃ និងបងប្អូនរបស់គាត់?

1. នីហ្វៃនិងបងប្អូនរបស់គាត់ បានព្យាយាមបីដងដើម្បីទៅយកផ្ទាំងលង្ហិន ពីឡាបាន់។ ការទៅយកទាំងពីរលើកតំបូង ត្រូវបានពិពណ៌ នៅក្នុង នីហ្វៃទី1 3:11–27។ នៅក្នុងស្បៃវែងសរសេររបស់អ្នក គូសដែនទីដូចមានខាងក្រោម។ បន្ទាប់ពីអ្នកបានអាន បំពេញនៅក្នុងប្រអប់ ដើម្បីប្រាប់ពីអ្វីដែលបានកើតឡើង នៅក្នុងការទៅយកទាំងពីរលើក ហើយពន្យល់ពីមូលហេតុដែល ត្រូវបរាជ័យនៃការទៅយកនោះ។

	ការទៅយកជាលើកទីមួយ	ការទៅយកជាលើកទីពីរ	ការទៅយកជាលើកទីបី
តើអ្នកណាខ្លះបានទៅ?			
តើពួកគេ ឬគាត់ បានធ្វើអ្វី?			
តើមានរឿងអ្វីកើតឡើង?			
ហេតុអ្វីអ្នកគិតថាវាបរាជ័យ ឬជោគជ័យ?			

2. រំលឹកឡើងវិញ នីហ្វៃទី1 4 រួចបំពេញនៅក្នុងប្រអប់ ការទៅយកជាលើកទីបី ហើយឆ្លើយសំនួរដូចមានខាងក្រោម ដើម្បីជួយអ្នកគិតអំពីអ្វីដែលអ្នកបានសិក្សា:
   ក. តើមានភាពខុសគ្នាអ្វីខ្លះ ដែលអ្នកកត់សំគាល់រវាង ការទៅយកផ្ទាំងទាំងពីរលើក របស់បងប្អូនរបស់នីហ្វៃ ហើយតើនីហ្វៃ ទុកចិត្តទៅលើអ្វី ក្នុងការព្យាយាមជាលើកទីបីរបស់គាត់? (សូមមើល នីហ្វៃទី1 3:11–13, 24 នីហ្វៃទី1 4:5–12)។
   ខ. តើជោគជ័យនៃការទៅយកជាលើកទីបី អាចជួយអ្នករៀនពីជោគជ័យអ្វី នៅពេលដែលអ្នកប្រឈមមុខនឹងឧបសគ្គ?
   គ. ព្រះអម្ចាស់បញ្ជា ឱ្យនីហ្វៃសំលាប់ឡាបាន់ តើអ្នកអាចរៀនអំពីអ្វី ពីពាក្យដែលទ្រង់ បានមានបន្ទូលនៅក្នុង ព្រះគម្ពីរ?
3. អនុវត្តបទពិសោធន៍របស់នីហ្វៃ ទៅនឹងជីវិតរបស់អ្នក។ យ៉ាងហោចណាស់ពន្យល់អំពីការប្រឈមមុខមួយ ដែលអ្នកបានប្រឈម ហើយនៅពេលដែលអ្នកធ្វើតាម គំរូរបស់នីហ្វៃ អាចជួយអ្នកឱ្យជ្រើសរើសផ្លូវត្រូវ។

គ តើអត្ថហេតុអាចបង្កើតជំនឿទេ?

បន្ទាប់ពីការបរាជ័យទាំងពីរលើក លេមិនិងលេមយួល បានបន្ទោសនីហ្វៃ ពីអ្វីដែលបានកើតឡើង ហើយបានវាយនីហ្វៃ និងសាំដោយរំពាត់។

1. រំលឹកឡើងវិញ នីហ្វៃទី1 3:28–31 ហើយពិពណ៌នានៅក្នុងស្បៃវែងសរសេររបស់អ្នក តើមានអ្វីកើតឡើងដើម្បីបញ្ឈប់បង ឮ របស់នីហ្វៃ។
2. ទោះជាមានរឿងអ្វីកើតឡើងក៏ដោយ នៅពេលក្រោយមក បងប្អូនរបស់នីហ្វៃ នៅតែមិនមានជំនឿទៅលើព្រះ ថាទ្រង់មានអំណាចដាច់ឡាបាន់ (សូមមើល ខ 31)។ សរសេរកថាខ័ណ្ឌខ្លីឮ ដែលពន្យល់ពីមូលហេតុ លេមិនិងលេមយួល ប្រឆាំងមិនព្រមជឿ។
3. រំលឹកឡើងវិញ នីហ្វៃទី1 4:1–3 ហើយសរសេរកថាខ័ណ្ឌផ្សេងទៀត ដែលពន្យល់ពីមូលហេតុដែលនីហ្វៃ មានសេចក្តី ជំនឿដ៏ខ្លាំង។

តើព្រះគម្ពីរមានតំលៃយ៉ាងណាទៅ? នៅក្នុងនីហ្វៃទី1 4 នីហ្វៃបានជឿដងថា “មនុស្សម្នាក់វិនាសទៅ គឺប្រសើរជាងសាសន៍ទាំងមូល ទឹងត្រូវចុះអន់ថយ ហើយវិនាសក្នុងការឥតជំនឿ” (ខ 13)។ នៅក្នុងនីហ្វៃទី1 5 គឺពន្យល់ពីតំលៃ នៃមនោសញ្ចេតនា ដែលធ្វើឱ្យ លីហៃ និងសារ៉ាយ សុខចិត្តបញ្ជូនកូនប្រុសរបស់គាត់ ឱ្យត្រឡប់ទៅវិញ ដើម្បីយកផ្ទាំងព្រះគម្ពីរ ដូចដែលលីហៃបានរកឃើញ នៅលើផ្ទាំងទាំងនោះ ដែលបង្ហាញពីការខិតខំ និងការពលិកម្មរបស់ពួកគេ គឺមានសារៈប្រយោជន៍។ នៅក្នុងនីហ្វៃទី1 6 អ្នកនឹងអាន អំពីអារម្មណ៍របស់ នីហ្វៃ ស្តីអំពីព្រះគម្ពីរ នៅពេលដែលគាត់សរសេរព្រះគម្ពីរ។ នៅពេលដែលអ្នកអាន ព្រះគម្ពីរទាំងនេះ គិតពីព្រះគម្ពីរមានតំលៃយ៉ាងណាចំពោះអ្នក។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 5

ទុក្ខសោក (ខ 1)—បានមានទុក្ខព្រួយយ៉ាងខ្លាំង

ចាប់ផ្តើម (ខ 12–13)—ការផ្តើម

ត្រូវបានរក្សាទុក (ខ 14–15)—បានសង្គ្រោះ

នីហ្វៃទី1 6

ល្មមហើយ (ខ 2)—គឺគ្រប់គ្រាន់

បញ្ចុះបញ្ចូល (ខ 4)—ធ្វើឱ្យជឿ

នីហ្វៃទី1 6:3–6 តើហេតុអ្វីបានជានីហ្វៃ រក្សាបញ្ជីប្រវត្តិ?

ផ្នាំងភាគច្រើនគឺត្រូវបានសរសេរដោយទំរង់ បញ្ចុះបញ្ចូល ឬការធ្វើជំណើរ ប៉ុន្តែគោលបំណងដ៏ចំបងគឺដើម្បីធ្វើឱ្យមានការកើនឡើង និងដើម្បីផ្គាប់ចិត្តអ្នកស្តាប់។ នីហ្វៃបានពន្យល់ថា បញ្ជីប្រវត្តិរបស់គាត់គឺមិនបានសរសេរអំពីអ្វី សំរាប់ផ្គាប់ចិត្ត មនុស្សលោក នេះឡើយ ប៉ុន្តែដើម្បីផ្គាប់ចិត្តព្រះ (សូមមើលនីហ្វៃទី1 6:5)។ សំរាប់ពត៌មានបន្ថែមមើលនៅគោលបំណង នៃការសរសេរ របស់នីហ្វៃ សូមមើលនៅនីហ្វៃទី1 9 ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរក្នុងចំណោមសកម្មភាពជាច្រើន (ក–គ) នៅពេលអ្នកសិក្សានីហ្វៃទី 1 5 6។

ក សរសេរកំណត់ហេតុ

1. បន្ទាប់ពីអាននីហ្វៃទី1 5 ចូរសរសេរកំណត់ហេតុ ហាក់ដូចជាអ្នកជាសារ៉ាយ ហើយពន្យល់ថាអ្នកគិតថាសារ៉ាយមានអារម្មណ៍ យ៉ាងដូចម្តេចនៅក្នុងខ 1–9។ រួមបញ្ចូលចំណុចដូចខាងក្រោមៈ
   ក. អ្វីដែលសារ៉ាយបានរៀនទាំ
   ខ. អ្វីដែលលីហៃបានឱយាយទៅកាន់សារ៉ាយ
   គ. អ្វីដែលកើតឡើង ពង្រឹងសក្ខីភាពរបស់សារ៉ាយ
2. សរសេរកថាខ័ណ្ឌ ដែលពន្យល់ពីបទពិសោធន៍ខ្លះៗ ដែលអ្នកមានដើម្បីជួយអ្នកដឹងថាព្រះរក្សាសេចក្តីសន្យារបស់ទ្រង់ និងប្រទានពរដល់អ្នកទាំងឡាយណាដែល ស្រលាញ់និងចំរើទ្រង់។

ខ ធ្វើបញ្ជី

1. ធ្វើបញ្ជីពីអ្វីដែល លីហៃបានរកឃើញ នៅលើផ្នាំងលង្ហិនដោយបំពេញ ទូវប្រយោគដូចខាងក្រោមនៅក្នុងស្បៀវភៅសរសេរ របស់អ្នក (សូមមើលនីហ្វៃទី1 5:10–16)ៈ
   ក. ផ្នាំងទាំងនេះមានត្រាំ _____។
   ខ. ហើយមានបញ្ជីប្រវត្តិរបស់ _____ តាំងពីដើមរហូតដល់ការចាប់ផ្តើមនៃរដ្ឋកាលនៃ _____
   គ. ហើយព្រមទាំងពាក្យព្យាករទាំងឡាយ _____ ព្រមទាំងពាក្យព្យាករទាំងឡាយដែលបានមកពី _____
   ឃ. ព្រមទាំងពង្សាវតារបស _____ ទើបលោកដឹងថា ត្រូវជាពូជពង្សរបស់ _____។
2. រំលឹកឡើងវិញនីហ្វៃទី1 5:17–22 ហើយត្រាប់ពីប្រសិទ្ធភាពនៃការអានព្រះគម្ពីរ ចំពោះលីហៃ។ តើព្រះវិញ្ញាណមាន ប្រសិទ្ធភាពយ៉ាងណាចំពោះអ្នក នៅពេលអ្នកអានព្រះគម្ពីរ?

គ ធ្វើតាមគំរូរបស់នីហ្វៃ

1. ចេញពីអ្វីដែលអ្នកបានអាននៅក្នុងនីហ្វៃទី1 6 តើនីហ្វៃចង់បញ្ចូលអ្វីនៅក្នុង បញ្ជីប្រវត្តិរបស់គាត់? តើមានអ្វីដែលគាត់ដកចេញ? ហេតុអ្វី?
2. ធ្វើតាមគំរូរបស់នីហ្វៃ ធ្វើបញ្ជីពីរឿងត្រាំ ដែលអ្នកប្រហែលជានិយាយ ជាផ្នែកមួយ នៃសក្ខីភាពរបស់អ្នក "សព្វព្រះហឫទ័យដល់ព្រះ ហើយគាប់ចិត្តដល់អស់អ្នកណា ដែលមិនមែនជារបស់ផងលោកិយនោះវិញ" (ខ 5)។

នីហ្វៃនិងបងប្អូនប្រុសរបស់គាត់ ត្រូវបានបញ្ជូនឱ្យ ធ្វើដំណើរត្រឡប់ទៅយេរូសាឡិមវិញ។ លើកនេះពួកគេត្រូវបានបញ្ជូន ឱ្យទៅទាំយក អ៊ីសម៉ាអែលនិងគ្រួសាររបស់គាត់ ឱ្យមកចូលរួមជាមួយពួកគេនៅក្នុងទីរហោស្ថាន។ តើហេតុអ្វីបានជា ព្រះអម្ចាស់បានជ្រើសរើស គ្រួសាររបស់អ៊ីសម៉ាអែល? តើហេតុអ្វីបានជាអ៊ីសម៉ាអែល ត្រូវបានជ្រើសរើសឱ្យចូលរួមជាមួយ លីហៃ? តើលេមិនិងលេមយួលមានសកម្មភាពយ៉ាងដូចម្តេចចំពោះការចាត់តាំងនេះ? នៅពេលដែលអ្នកអាននីហ្វៃទី1 7 ចូររកមើលចំលើយ ដែលមានសំរាប់សំនួរទាំងនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 7

ការណ៍ដែលលោក (ខ 1)—សមរម្យ ឬ ត្រាជ្ញា

ឈប់ (ខ 14)—ឈប់

តស៊ូ (ខ 14)—ធ្វើការប្រឹងប្រែងយ៉ាងខ្លាំង

បង្គាប់ឱ្យ (ខ 15)—បញ្ជា

នីហ្វៃទី1 7:2—តើហេតុអ្វីព្រះអម្ចាស់ជ្រើសរើសគ្រួសាររបស់អ៊ីសម៉ាអែស?

ព្រះអម្ចាស់បានបញ្ជាលីហៃ ឱ្យបញ្ជូនកូនប្រុសឲ្យរបស់គាត់ ឱ្យត្រឡប់ទៅយេរូសាឡិមវិញ ហើយទាំយកអ៊ីសម៉ាអែស និងគ្រួសាររបស់គាត់មកក្នុងទីរហោស្ថាន។ អ៊ីសម៉ាអែសត្រូវបានជ្រើសរើស យ៉ាងហោចណាស់ដាផ្នែកមួយ ពីព្រោះអ៊ីសម៉ាអែស ស្ម័គ្រចិត្តដើម្បីធ្វើតាមព្រះអម្ចាស់។ នីហ្វៃបានសរសេរថាពួកគាត់ "បានឱយាយទៅកាន់អ៊ីសម៉ាអែស ដោយបន្ទូលរបស់ព្រះអម្ចាស់" (នីហ្វៃទី1 7:4) ហើយ "ព្រះអម្ចាស់បានបន្ទន់ចិត្តរបស់ អ៊ីសម៉ាអែស" (ខ 5)។

ការសិក្សាព្រះគម្ពីរ

នៅពេលដែលអ្នកអាននីហ្វៃទី1 7 ចូរធ្វើសកម្មភាព ក ឬ ខ ដូចខាងក្រោម

ក សរសេរពីអ្វីដែលបានកើតឡើង

សរសេរពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងនីហ្វៃទី1 7។ ជាពិសេសនៅក្នុងខ 1, 4–6, 8, 16, 18–19, និង 22។

២ វិភាគនិងអនុវត្តចំពោះ ដែលបានកើតឡើង

1. រំលឹកឡើងវិញនៅក្នុងនីហៃទី1 7:1–5 ហើយពន្យល់មូលហេតុដែល អ្នកគិតថា ព្រះអម្ចាស់ជ្រើសរើសអ៊ីសម៉ាអែល និងគ្រួសាររបស់គាត់ ឱ្យចូលរួមជាមួយលីហៃ នៅឯទីរហោស្ថាន (សូមមើលវគ្គជំនួយបន្ថែមនៃ “ការយល់ដឹងអំពីព្រះគម្ពីរ”)។
2. នៅក្នុង ខ 10–12 នីហៃបានរំលឹកឡើងវិញនូវឃ្លាដដែលៗ ចំដង។ តើឃ្លានោះជាអ្វី? ហេតុអ្វីការភ្លេច គឺជាហេតុផលមួយ សំរាប់ លេមិននិងលេមយួលធ្វើការបះបោរ? សរសេរយ៉ាងតិចណាស់ គំនិតចំ ឬបទពិសោធន៍ពីជីវិតរបស់អ្នក ដែលអាចជួយអ្នក ឱ្យរឹតតែប្រតិបត្តិ នៅពេលដែលអ្នកចងចាំពីគំនិត ឬ បទពិសោធន៍ទាំងនោះ។
3. សរសេរកថាខ័ណ្ឌខ្លីៗ ដែលពិពណ៌នា អំពីនីហៃទី1 7:16–19 ឱ្យខុទាហរណ៍នៃ “សេចក្តីមេត្តាដ៏ទន់ភ្លន់” នីហៃបានសន្យាថា គាត់នឹងបង្ហាញដល់យើង នៅពេលដែលគាត់ចាប់ផ្តើមសរសេរ ផ្ទាំងរបស់គាត់ (សូមមើលនីហៃទី1 1:20)។

ការសុបិនបំផុសគំនិតរបស់លីហៃ គឺជានិមិត្តរូបតំណាងជីវិតរបស់យើង នៃជីវិតដែលរមែងស្លាប់នេះ។ យើងអាចរកតំណាងខ្លួន របស់យើង នៅក្នុងសុបិន្តនោះ។ និងយើងអាចរកឃើញថា ជីវិតយើងទៅជាយ៉ាងណា បើយើងនៅលើផ្លូវដែលតំណាងនោះ។ កំនត់សំគាល់ពីអ្វី ដែលនាំឱ្យលីហៃរីករាយ និងមានទុក្ខព្រួយ។ សូមមើលផងដែរពីអ្វី ដែលកូនៗរបស់លីហៃ បានធ្វើនៅក្នុងសុបិន្ត។ តើហេតុអ្វីបានជាពួកគេមួយចំនួន ស្ថិតនៅក្នុងភាពគ្រោះថ្នាក់? គិតអំពីអ្វីដែលលីហៃមានអារម្មណ៍ នៅពេលដែលគាត់ បានសញ្ជឹងគិត ពីអ្វីដែលព្រះអម្ចាស់បានបើកបង្ហាញដល់គាត់ នៅក្នុងសុបិន្តនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហៃទី1 8

ព្រាប់ឱ្យ (ខ 6)—បានសួរ

បានបោយហោ (ខ 15)—សញ្ជាឱ្យមក

តូច (ខ 20)—ត្រង់ហើយច្បាស់លាស់ (ការប្រើពាក្យពីរ ដែលមានន័យស្រដៀងគ្នា *តូច* ហើយ *ត្រង់* គឺជាទំរង់កំណាព្យ)

ផ្តើម (ខ 22)—ចាប់ផ្តើម

ចំអក (ខ 28)—សើចចំអក, ឡកឡឹយ

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកអានទីហៃទី1 8 ចូរធ្វើសកម្មភាពដូចខាងក្រោម (ក–គ)។

ក ស្វែងរកគន្លឹះ

នៅក្នុងសុបិនរបស់គាត់ លីហៃបានស្ថិតនៅក្នុងភាពងងឹត អស់រយៈពេលជាច្រើនម៉ោង (សូមមើលនីហៃទី1 8:4–9)។ តើលីហៃបានធ្វើអ្វី ដើម្បីចេញពីភាពងងឹតនោះ? តើបទពិសោធន៍ក្នុងភាពងងឹតរបស់លីហៃ ដូចនឹងពិភពលោក ដែលយើងរស់នៅយ៉ាងដូចម្តេចដែរ? តើអ្វីដែលលីហៃបានចេញពីភាពងងឹតនោះ បានជួយអ្នកយ៉ាងដូចម្តេច?

ខ ផ្គូរផ្គងព្រះគម្ពីរនឹងឃ្លា

ការសុបិនរបស់លីហៃ ជួយយើងយល់អំពីគោលការណ៍ សំខាន់អំពីជីវិត និងការខិតខំរបស់យើង ដើម្បីរស់នៅតាមជំណឹងល្អ។ រូបសណ្ឋាន នៅក្នុងសុបិនគឺជានិមិត្តរូប ហើយវាតំណាងឱ្យការប្រឈមមុខពិតប្រាកដ ដែលយើងប្រឈមមុខរាល់ថ្ងៃ។ សរសេរអំពីអ្វីដែលលីហៃបានឃើញដូចដែលមានកត់ត្រានៅខាងក្រោម បន្ទាប់មក ពីការអានរបស់អ្នកនៅក្នុងនីហៃទី1 8 ជ្រើសរើសឃ្លាដែលពិពណ៌នាអំពីរូបសណ្ឋានយ៉ាងល្អបំផុត។

ឃ្លាដែលជ្រើសរើស	តើសេចក្តីថ្លែងមួយណា ដែលជាការពិពណ៌នាល្អបំផុត?
1. “ទីរហោស្ថានដ៏ងងឹត និងអាប់អួរ” (ខ 4)	ក. កន្លែងដែលជាទីពេញចិត្ត ខ. កន្លែងដែលគួរឱ្យខ្លាច
2. “បុរស . . . ស្លៀកពាក់អាវិពណិស” (ខ 5)	ក. ជួយលីហៃឱ្យមានអារម្មណ៍សំអាត ខ. បង្កើនសេចក្តីខ្លាចរបស់លីហៃ
3. “ទីវាលដ៏ធំហើយទូលាំយមួយ” (ខ 9)	ក. ក៏ដាកន្លែងដែលងងឹតហើយអាប់អួរ ខ. កន្លែងអព្យាក្រឹត
4. ដើមឈើមួយ ដែលមានផ្លែដ៏គួរធ្វើឱ្យមនុស្សរីករាយ	ក. ចំនុចកណ្តាលនៃសុបិន ខ. ប្រភពនៃចំងល់របស់លីហៃ
5. “ទន្លេទឹកមួយ” (ខ 13)	ក. គ្រោះថ្នាក់ ខ. ពរជ័យ
6. “ជំបងដែក” (ខ 19)	ក. គូសផ្លូវទៅតាមដើមឈើ ខ. ការពារអ្នកធ្វើដំណើរចេញពីទន្លេ
7. ផ្លូវតូចនិងចង្អៀតនៅជិតទន្លេ (ខ 20)	ក. ងាយស្រួលធ្វើតាម ខ. ពិបាកដើម្បីធ្វើតាម
8. “អាប់នៃសេចក្តីងងឹត” (ខ 23)	ក. ធ្វើឱ្យការធ្វើដំណើរពិបាក ខ. ធ្វើឱ្យមានមនុស្សច្រើន
9. “មានអាគារដ៏ធំហើយទូលាយ” (ខ 26)	ក. ឈរដោយដើមឈើជីវិត ខ. ឈរគ្រាយម្ខាងនៃទន្លេ

៣ សរសេរកិច្ចសំភាសន៍ទាក់ទងពីពតិមាន

លីហៃបានប្រាប់យើងថា ផ្លែនៃដើមឈើជីវិត នៅក្នុងការនិមិត្តរបស់គាត់ "ដ៏គួរធ្វើឱ្យមនុស្សរីករាយ" (នីហ្វៃទី1 8:10) ហើយការភ្លក់ផ្លែឈើ បានធ្វើឱ្យគាត់ពោរពេញទៅដោយ "សេចក្តីអំណរជាអតិបរិមា" (ខ. 12)។ នៅក្នុងការនិមិត្តរបស់គាត់ លីហៃបានឃើញមនុស្សបួនក្រុម ដែលតំណាងឱ្យមនុស្សនៅក្នុងជីវិតនេះ

- អ្នកទាំងឡាយនោះ បានព្យាយាមទៅកាន់ដើមឈើ ប៉ុន្តែត្រូវបានវង្វេង នៅក្នុងអ័ព្ទនៃសេចក្តីងងឹត (សូមមើល ខខ . 21–23)
- អ្នកទាំងឡាយនោះ បានទៅដល់ដើមឈើ ប៉ុន្តែធ្លាក់ចុះ នៅពេលមនុស្សទាំងហ្វូងៗ បានចំអកឡកឡឺយដល់ពួកគេ (សូមមើល ខខ. 24–25, 28)
- អ្នកទាំងឡាយនោះ មានចំណង់ទៅលើអាគារដ៏ធំ ហើយទូលាយនោះ ជាជាងផ្លែនៃដើមជីវិត (សូមមើល ខខ. 26–27, 31–33)
- អ្នកទាំងឡាយនោះ បានទៅដល់ដើមឈើ ហើយមិនមានការខ្មាសអៀន (សូមមើលខ. 30)

1. ចូរនឹកគិតថា អ្នកគឺជាអ្នកការសែតម្នាក់ ហើយអ្នកបានសម្ភាសន៍មនុស្សម្នាក់ ដែលមកពីក្រុមទាំងបួនចេញ។ ចេញពីអ្វី ដែលអ្នកអានអំពីក្រុមនីមួយៗនោះ ចូរសរសេរអំពីអ្វី ដែលអ្នកគិតពីមនុស្សម្នាក់ៗ នឹងឆ្លើយសំនួរខាងក្រោមនេះ

   ក. តើអ្នកកំពុងព្យាយាមទៅណា? *តើហេតុអ្វី?*

   ខ. តើអ្នកបានទៅដល់កន្លែង ដែលអ្នកចង់ទៅហើយឬនៅ? *ហេតុអ្វីបានទៅ ឬ ហេតុអ្វីមិនបានទៅ?*

   គ. តើអ្នកចូលចិត្តកន្លែងដែលអ្នកបានបញ្ចប់ហើយឬនៅ? *ហេតុអ្វី ឬ ហេតុអ្វីមិនចូលចិត្ត?*

2. ឧបមាថា អ្នកអាចសំភាសមនុស្សដូចគ្នានៅក្នុងជីវិតបន្ទាប់។ ចូរសរសេរពី រឿៀបមួយដែលអ្នកគិតថា គេគួរតែឆ្លើយអ្នកយ៉ាងដូចម្តេច នៅសំនួរចុងក្រោយ នៃចំនុចសំភាសន៍នោះ។

នីហ្វៃបានរក្សាផ្ទាំងបញ្ជីប្រវត្តិពីរផ្ទាំង។ មួយផ្ទាំងទៀតគឺជាប្រវត្តិសាស្ត្ររបស់មនុស្ស (ផ្ទាំងធំរបស់នីហ្វៃ) ទីពីរគឺជាបញ្ជីប្រវត្តិពិសិដ្ឋ (ផ្ទាំងតូចរបស់នីហ្វៃ)។ នៅពេលដែលអ្នកអាន នៅនីហ្វៃទី1 9 ចូររកមើលមូលហេតុ ដែលនីហ្វៃបានឱ្យដើម្បី រក្សាប្រវត្តិបញ្ជី ទាំងពីរ។ នៅក្នុងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" អ្នកនឹងរៀនពីអ្វី ដែលយើងដឹងសព្វថ្ងៃនេះ អំពីមូលហេតុមកពីការថែរក្សា ផ្ទាំងទាំងពីររបស់នីហ្វៃ។ ព្រឹត្តិការណ៍នេះបានបង្រៀនយើងថា ព្រះអម្ចាស់មានគំរោងការយកមកគិតពីការបរាជ័យរបស់យើង ឬការជោគជ័យរបស់យើង ផងដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 9

រដ្ឋកាល (ខ 4)—ច្បាប់

ការទាស់ទែង (ខ 4)—ការមិនយល់ព្រមគ្នា, ការឈ្លោះគ្នា

នីហ្វៃទី1 9:3–6–សំរាប់គោលបំណងដ៏ឈ្លាសវៃ

នៅក្នុងឆ្នាំ 1828 ព្យាការីយ៉ូសែប ស្មីធបាន បកប្រែព្រះគម្ពីរមរមន ហើយបានបកប្រែរួចដោយការសរសេរដៃចំនួន 116 ទំព័រ។ ម៉ាទិន ហារិស បានអង្វរយ៉ូសែប ស្មីធជាច្រើនដង ដើម្បីឱ្យគាត់អាចយកការបកប្រែនោះទៅ បង្ហាញក្រុមគ្រួសារ របស់គាត់។ ដំបូងព្រះអម្ចាស់បានមានបន្ទូលថាទេ តែទីបញ្ចប់ទ្រង់ក៏បានអនុញ្ញាត ឱ្យយកការបកប្រែនោះទៅ ប្រសិនបើ ម៉ាទិន ហារិស សន្យាថា នៅពេលដែលយកវាទៅហើយ ត្រូវបង្ហាញតែដល់អ្នកដែលបានជ្រើសរើសពីរបីនាក់តែប៉ុណ្ណោះ។ ម៉ាទិន ហារិស បានក្បត់ពាក្យសន្យារបស់គាត់ ហើយបានធ្វើឱ្យការបកប្រែទាំង 116 ទំព័រនោះ បាត់។ យ៉ូសែបបានអស់ទឹកចិត្ត យ៉ាងខ្លាំង តែតាមរយះបទពិសោធនេះ គាត់អាចរៀន អំពីតំលៃមេរៀននៃការប្រតិបត្តិ និងមនុស្សអាក្រក់ មិនអាចបញ្ឈប់ការងាររបស់ ព្រះវរបិតា (សូមមើល គ & ស 3:1–10)។

© Robert T. Barrett

នៅក្នុងព្រឹត្តិការណ៍នេះ ព្រះអម្ចាស់បានដឹងមុន ពីអ្វីដែល ម៉ាទិន ហារិស នឹងធ្វើ និងបានរៀបគំរោងជាងពីរពាន់ឆ្នាំមុន។ ព្រះអម្ចាស់បានប្រាប់នីហ្វៃ ឱ្យធ្វើបញ្ជីប្រវត្តិពីរ ដែលនិយាយអំពីកំឡុងពេលដូចគ្នា។ មួយគឺផ្ទាំងធំ គឺជាប្រវត្តិសាស្ត្រ នៃប្រ ជាជននីហ្វៃ។ មួយទៀត គឺជាផ្ទាំងតូច ដែលបានសរសេរអំពីប្រវត្តិសាស្ត្រពិសិដ្ឋ។ យ៉ូសែប ស្មីធបានចាប់ផ្តើមការបកប្រែ ចេញពីការសង្ខេបរបស់មរមន នៃផ្ទាំងធំ ដូច្នេះ 116 ទំព័រដែល ម៉ាទិន ហារិស បានធ្វើឱ្យបាត់ គឺការនិយាយអំពីប្រវត្តិសាស្ត្រ របស់មនុស្ស។

ព្រះអម្ចាស់ក៏បានដឹងដែរថា សត្រូវរបស់ព្យាការី នឹងប្តូរការបកប្រែទាំង 116 ទំព័រនោះ ប្រសិនបើ យ៉ូសែប ស្មីធបកប្រែ រឿងដូចគ្នាម្តងទៀត ពួកគេនឹងនិយាយថា យ៉ូសែប ស្មីធមិនមែនជាព្យាការីទេព្រោះគាត់មិនអាចបកប្រែវា ឱ្យដូចគ្នាពីរដងបាន ហើយ (សូមមើល គ និង ស 10:10–19)។ ព្រះអម្ចាស់បានប្រាប់ យ៉ូសែប ស្មីធមិនឱ្យបកប្រែ ផ្នែកនោះម្តងទៀត តែត្រូវបក ប្រែផ្ទាំងតូចនៃនីហ្វៃវិញដែលបានគ្រប់គ្រងកំឡុងពេលដូចគ្នា តែវាគឺជាប្រវត្តិបញ្ជីដ៏ពិសិដ្ឋ (សូមមើល គ និង ស 10:30–45 សូមមើលផងដែរនៅ "ប្រភពដ៏សំខាន់ នៃព្រះគម្ពីរមរមន" ទំព័រ 00)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ ពេលអ្នកសិក្សា នីហ្វៃទី 1 9

៣ ចូរធ្វើកំណត់ចំណាំនៅរឹមដើមទំព័រ

នៅក្នុងនីហ្វៃទី1 9 នីហ្វៃបានប្រើឃ្លា "ផ្ទាំងទាំងនេះ" និង "ផ្ទាំងផ្សេងទៀត" ដែលនិយាយអំពីផ្ទាំងទាំងពីរចំណែក ដែលព្រះអម្ចាស់បានបញ្ជានីហ្វៃឱ្យធ្វើ។ នៅក្នុងរឹមដើមទំព័រ នៃព្រះគម្ពីររបស់អ្នក ចូរសរសេរកំណត់ចំណាំ ដើម្បីជួយអ្នកឱ្យចងចាំ ផ្នែកមួយណានៃផ្ទាំង ដែលនីហ្វៃសំដៅ: *ផ្ទាំងទាំងនេះ = ផ្ទាំងតូច* និង *ផ្ទាំងមួយទៀត = ផ្ទាំងធំ*។

៤ អនុវត្តចំនុចនេះនៅក្នុងជីវិតរបស់អ្នក

នីហ្វៃបានប្រតិបត្តិតាមព្រះអម្ចាស់ ហើយបានធ្វើផ្ទាំងជាពីរផ្នែក ទោះបីជាគាត់មិនត្រូវបានប្រាប់ពីមូលហេតុក៏ដោយ។ តើគំរូនៃសេចក្តីជំនឿ និងការប្រតិបត្តិតាម បំផុសអ្នកអោយរស់នៅតាមព្រះបញ្ញត្តិ ដែលអ្នកមិនអាចយល់ដឹង ពេញលេញដោយរបៀបណា?

នីហ្វៃទី1 10
ការព្យាករណ៍របស់លីហៃ

នៅក្នុងជំពូកទី 1–8 នៃនីហ្វៃទី1 គឺជាការសង្ខេបដ៏ធំរបស់នីហ្វៃ ពីពួកប្រវត្តិរបស់លីហៃ ដែលជាឪពុករបស់គាត់ និងជំពូកទី 9 គឺជាការពន្យល់របស់នីហ្វៃ នៃការរក្សាផ្ទាំងទាំងពីរផ្ទៃករបស់គាត់។ នៅក្នុងនីហ្វៃទី1 10 នីហ្វៃបានចាប់ផ្តើមសរសេរ ពីការបង្រៀន និងបទពិសោធន៍ជីវិតរបស់គាត់ផ្ទាល់ និងការបំរើ (សូមមើលនីហ្វៃទី1 10:1)។ គាត់ក៏បានបញ្ចូល ការព្យាករណ៍របស់ឪពុកគាត់ ដែលនិយាយពីអនាគត ផងដែរ។ នៅពេលដែលអ្នកអានការព្យាករណ៍នេះ កំណត់ចំណាំថា រយៈដែល លីហៃបានទទួលយ៉ាង ពិស្តារតាមរយៈវិវរណៈ ដែលនិយាយអំពីព្រឹត្តិការណ៍អនាគត។ ធ្វើការចំណាំផងដែរ ពីប្រសិទ្ធិភាពនៃពាក្យ របស់លីហៃ ចំពោះនីហ្វៃ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 10

សំដែងព្រះអង្គទ្រង់ (ខ 11)—បង្ហាញរូបទ្រង់



ដែលត្រូវនាំទៅ (ខ 13)—ការរួបរួមគ្នា

សំណល់ (ខ 14)—ផ្នែកដែលនៅសល់

បំបៅ (ខ 14)—បានចូលរួម

គាប់ចិត្ត (ខ 15)—សមរម្យ, ដែលប៉ងព្រាថ្នា

ការសោកល្បួង (ខ 21)—ឧបសគ្គ ឬការសោកល្បួង (មានន័យថា ជីវិតរបស់យើងនៅលើផែនដី)

នីហ្វៃទី1 10:14—ការខ្ចាត់ខ្ចាយ និងការប្រមូលផ្តុំ នៃសាសន៍អ៊ីស្រាអែល



លីហៃបានប្រៀបធៀបវង្សអ៊ីស្រាអែល ទៅនឹងដើមអូលីវ ដែលទីងខ្ចាត់ខ្ចាយពាសពេញពិភពលោក ពីព្រោះមកពីការ ក្មានជំនឿរបស់ពួកគេ។ គាត់បានឃើញក្នុងសាររបស់គាត់ គឺជាផ្នែកនៃការខ្ចាត់ខ្ចាយនោះ។ (សូមមើលនីហ្វៃទី1 10:11–13។)

លីហៃក៏បានព្យាករថា បន្ទាប់ពីដំណឹងល្អត្រូវបានចែកចាយទៅដល់ ពួកសាសន៍ដទៃ ការខ្ចាត់ខ្ចាយនៃមែក របស់វង្សអ៊ីស្រាអែល នឹងត្រូវបានប្រមូលផ្តុំម្តងទៀត។ បន្ទាប់មកលីហៃបានពន្យល់ថា ដើម្បី “បានបំបៅជាប់” នឹងដើមវិញ ដែលតំណាងឱ្យ វង្សនៃ អ៊ីស្រាអែល គឺមានន័យថា “បានជឿអំពីព្រះមែស៊ី” (ខ 14)។ ម្យ៉ាងវិញទៀត មនុស្សម្នាក់ដែល បានក្លាយជាសមាជិកនៃ វង្ស អ៊ីស្រាអែលដ៏ពិតប្រាកដ គឺស្តាប់លើទីង ទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ ដូចខាងក្រោម នៅពេលដែលអ្នកសិក្សានៅក្នុងនីហ្វៃទី1 10។

ក អានសំរាប់ចំលើយ



នៅក្នុងនីហ្វៃទី1 10:4–11 នីហ្វៃបានកត់ត្រាអំពីការពិពណ៌នារបស់លីហៃ ពីព្រឹត្តិការណ៍ ដែលទីងត្រូវកើតឡើងនៅ ក្នុងត្រាំមួយរយឆ្នាំទៀត នៅក្នុងពេលអនាគត។ ចូរអានខទាំងនោះ ដើម្បីជួយអ្នកឆ្លើយទូវសំនួរអំពី ព្រះ ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល។

1. តើហេតុអ្វី យើងត្រូវការព្រះដ៏ប្រោសលោះ?
2. តើមានអ្វីកើតឡើងចំពោះព្រះមែស៊ី?
3. តើពួកសាសន៍ដទៃបានរៀនអ្វីអំពីគ្រីស្ទ?

ខ បំពេញនៅក្នុងចន្លោះ

នៅក្នុងនីហ្វៃទី1 10:17–22 នីហ្វៃបានចែកចាយទីបន្ទាល់របស់គាត់អំពី អំណាចនៃព្រះវិញ្ញាណ គឺដើម្បីជួយយើង ឃល់ពីរឿងរបស់ព្រះ។ សង្ខេប ទីបន្ទាល់របស់នីហ្វៃ ពីអំណាចនៃព្រះវិញ្ញាណ ហើយចូរត្រាប់ថា សក្តិភាពនោះអាច អនុវត្តនៅក្នុងជីវិតរបស់អ្នកយ៉ាងដូចម្តេច។

នីហ្វៃទី1 11–12
នីហ្វៃបានរៀនអំពីព្រះគ្រីស្ទ និងបេសកម្មរបស់ទ្រង់

នៅពេលអ្នកអាន ដំណឹងនៅក្នុងព្រះគម្ពីរ ឬទទួលការណែនាំពីអ្នកដឹកនាំនៃសាសនាចក្រ ហើយអ្នកដឹងថា វាសំខាន់ណាស់ តែអ្នកមិនបានយល់ទេ តើអ្នកនឹងធ្វើដូចម្តេច? នៅក្នុងនីហ្វៃទី1 10:17–19 នីហ្វៃបានថ្លែងថា យើងអាចយល់ឃើងរបស់ព្រះ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ហើយទ្រង់ជួយយើងដឹងអំពីអ្វី ដែលយើងត្រូវធ្វើ។ នីហ្វៃបានមានបំណងចង់ “សូមមើល, ហើយស្តាប់, និងយល់” ខ 17 ពីអ្វីដែលឪពុករបស់គាត់ ត្រូវបានបង្ហាញនៅក្នុងសុបិនដ៏មានការបំផុសគំនិត។

នៅក្នុងនីហ្វៃទី1 10:11–14 គឺត្រូវបានកត់ត្រា អំពីកាលដែលព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងចំណងរបស់នីហ្វៃ ហើយទ្រង់ បានបង្ហាញ នីហ្វៃមិនត្រឹមតែអ្វីដែលលីហៃបានឃើញនោះទេ តែទ្រង់ក៏បានបង្ហាញនីហ្វៃ ពីអត្ថន័យន័យនិមិត្តរូបជាច្រើន។ នៅពេលដែលអ្នកអានជំពូកទី 11 កត់ត្រាពីអ្វីដែលនីហ្វៃបានធ្វើដើម្បីរៀបចំខ្លួនទទួលវិវរណៈ ដ៏អស្ចារ្យ។ នៅក្នុងជំពូកទី 12 ចូរមើលពីវិធីដែលនីហ្វៃ បានប្រៀបធៀបវិវរណៈនេះទៅនឹង ប្រជាជនរបស់គាត់ផ្ទាល់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 11

សណ្ឋិតលើ (ខ 27)—គង់នៅលើ

ចំរើបណ្តាជន (ខ 28, 30)—ការបំរើ, ការផ្តល់នូវអ្វីដែលជាសេចក្តីត្រូវការ

ភាសា (ខ 36)—ភាសា

នីហ្វៃទី1 11:16–36—តើ "ការយាងចុះមកនៃព្រះ" គឺជាអ្វី?

"ការយាងចុះមក ន័យត្រង់ៗ គឺ 'ចុះទៅក្នុងចំណោម។' 'ការយាងចុះមកនៃព្រះគឺត្រូវបានយល់' . . . នៅក្នុងចំណុចពីរ។ ទិដ្ឋភាពទីមួយ ការយាងចុះមកនៃព្រះ ដែលជាព្រះវរបិតា មានន័យថាគឺជា អ៊ីឡូហ៊ីម [សូមមើល នីហ្វៃទី1 11:16–23]។ ការយាងចុះមកនៃព្រះ សំដៅពីទ្រង់ ដែលជាវិញ្ញាណដ៏អស់កល្ប បានចុះមកពី ព្រះបល្ល័ង្កដ៏អស់កល្ប ជានិច្ច ដើម្បីក្លាយជា ព្រះវរបិតានៃបុត្រ "ខាងសាច់ ឈាម បុត្រដែលចាប់កំណើតឯខាងសាច់ឈាម" ([Bruce R. McConkie,] *The Mortal Messiah,* 1:314) . . .។

"ទិដ្ឋភាពទីពីរ នៃការយាងចុះមកនៃព្រះ គឺជាព្រះរាជបុត្រា មានន័យថា ព្រះគ្រីស្ទ [សូមមើល នីហ្វៃទី1 11:24–32]។ ព្រះយេហូវ៉ា—គឺជាព្រះវរបិតានៃស្ថានសួគ៌និងផែនដី គឺជាអ្នកបង្កើតអ្វីៗទាំងអស់ តាំងពីពេលចាប់ផ្តើម ព្រះដ៏ជាព្រះដ៏មហិមា និងព្រះនៃ អ័ប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះនៃយ៉ាកុប—នឹងមកផែនដី ទ្រង់ចាកចេញពីព្រះបល្ល័ង្ករបស់ទ្រង់ ហើយទទួលយក រូប កាយជាសាច់និងឆ្អឹង ហើយបញ្ចូនខ្លួនទ្រង់ ឱ្យធ្លាក់ក្នុងឧបសគ្គនៃសាច់ឈាម ហើយនឹងអំពើយោយៅនៃមនុស្ស ហើយធ្វើ ការងារនៃការសង្គ្រោះរបស់ទ្រង់ ដូចជាមនុស្សធម្មតា ដែលជាគោលលទ្ធិនៃ' ការយាងមករបស់ព្រះ" (Joseph Fielding McConkie និង Robert L. Millet, *Doctrine Commentary on the Book of Mormon,* វ៉ុលទី4 [1987–92], 1:78, 82)។

នីហ្វៃទី1 12

អ៊ីងកង (ខ 4)—ខ្លាំង

ប្រេះបែកចេញ (ខ 4)—បែកជាផ្នែកៗ

ចំហាយ (ខ 5)—អ័ព្ទ ឬ ចុះអ័ព្ទ

ឈូងសមុទ្រ (ខ 18)—ច្រកតូចដ៏ធំ, កន្លែងដែលមានដីរោក្រៅនៅលើលោកិយ

ចុះអន់ថយក្នុងការឥតជំនឿ (ខ 22)—ការធ្លាក់ចុះ ឬ ក្លាយជាខ្សោយដោយការខ្វះជំនឿ

នីហ្វៃទី1 11–12—តើនីហ្វៃបានរៀនអ្វីខ្លះ អំពីសុបិនរបស់លីហៃ?

តារាងសង្ខេបខាងក្រោម គឺជាអ្វីដែលនីហ្វៃ បានរៀនអំពីសុបិនរបស់ឪពុករបស់គាត់ៈ

និមិត្តរូបនៃសុបិនរបស់លីហៃ	ការបកប្រែដែលនីហ្វៃត្រូវបានផ្តល់ឱ្យ
ដើមឈើដែលមានផ្លែពណិស (សូមមើលនីហ្វៃទី1 8:10–11)	សេចក្តីស្រលាញ់របស់ព្រះ ដែលទ្រង់បានបង្ហាញដោយ ការបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះរបស់យើង (សូមមើលនីហ្វៃទី1 11:21–25 ដែលបានហៅថា "ដើមនៃជីវិត" នៅក្នុង នីហ្វៃទី1 15:22)
ទន្លេនៃទឹក (ក្រខ្វក់) (សូមមើលនីហ្វៃ 8:13)	ជំរៅនៃសមុទ្រ ដែលពួកទុច្ចរិតបានធ្លាក់ចុះ (សូមមើល 12:16, ត្រូវបានហៅ "ភាពក្រខ្វក់" នៅក្នុង 15:27)
ជំបងដែក (សូមមើល 8:19)	បន្ទូលរបស់ព្រះ ដែលអាចនាំយើងទៅកាន់ដើមឈើជីវិតដោយសុវត្ថិភាព (សូមមើល 11:25)
អ័ព្ទនៃភាពងងឹត (សូមមើល 8:23)	"ការល្បួងរបស់វិញ្ញាណអាក្រក់" គឺធ្វើឱ្យមនុស្សមិនអាចមើលឃើញ ដើម្បីពួកគេត្រូវវង្វេងផ្លូវ ហើយមិនអាចរកដើមជីវិតឃើញ (សូមមើល 12:17)
អាគារដ៏ធំហើយទូលាយនៅក្នុងអាកាស (សូមមើល 8:26)	គំនិតឥតប្រយោជន៍ និងសេចក្តីឆ្មើងឆ្មៃនៃពិភពលោក (សូមមើល 11:36, 12:18)
មនុស្សដែលនៅលើផ្លូវទៅកាន់ដើមជីវិត តែត្រូវបានវង់វេងនៅក្នុងអ័ព្ទ (សូមមើល 8:21–23)	នៅក្នុងសុបិន នៃចំណោមមនុស្សជីវិតច្រើនឥតគណនានោះ នីហ្វៃមិនបានត្រាប់ថាមនុស្សណាឱ្យបានជាក់លាក់ទេ តែនីហ្វៃបានឃើញ ប្រភេទមនុស្សដូចខាងក្រោមៈ • មនុស្សដែលបានលើអំពីព្រះយេស៊ូវ ហើយ តែ "បណ្តេញទ្រង់ចេញ" (សូមមើល 11:28) • មនុស្សដែលបានឆ្កាងព្រះយេស៊ូវ ទោះបីជាបន្ទាប់ពីទ្រង់បានព្យាបាលអ្នកដំណឹ និងបណ្តេញវិញ្ញាណអាក្រក់ចេញក៏ដោយ (ខ 31–33) • មនុស្សដែលបានប្រមូលផ្តុំគ្នា "នៅក្នុងអាគារដ៏ធំ ហើយទូលាយ" ដើម្បីមកច្បាំងទាស់នឹងពួកសាវកទាំងដប់ពីរ (សូមមើល ខ 34–36) • ពួកនីហ្វៃ និងពួកលេមិនដែល "ប្រមូលគ្នាមកធ្វើចម្បាំង" (សូមមើល 12:1–4, 13–15) • ដោយសារភាពឆ្មើងឆ្មៃ នៃពួកនីហ្វៃ ពួកគេក៏ត្រូវបាន កំទេចចោលដោយពួកលេមិន (សូមមើល ខ 19–23)
ពួកជនដែលបានទៅដល់ដើមជីវិត ដោយកាន់ជំបងដែក តែត្រូវបានធ្លាក់ចេញដោយការសើចចំអក (សូមមើល 8:24–25, 28)	
ពួកជនដែលប៉ងព្រាថ្នាទៅកាន់ អាគារដ៏ធំទូលាយដាងទៅកាន់ដើមជីវិត (សូមមើល 8:26–27, 31–33)	
ពួកជនដែលបានកាន់ជំបងដែក បានដួលចុះទៅឯដើមជីវិត ហើយក៏បរិភោគផ្លែនោះទៅ ពួកគេមិនអើរពើរចំពោះ អ្នកដែលសើចចំអក ហើយក៏ពុំបានដួលចុះដែរ។ (សូមមើល 8:30, 33)	ជនដែលបានទទួល អំណោយទានដ៏មហិមាបំផុតនៃព្រះ—ជីវិតដ៏អស់កល្បជានិច្ច (សូមមើល 15:36)

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងសកម្មភាពពីរផ្សេងទៀត (ខ ឬ គ) នៅពេលដែលអ្នកសិក្សានៅក្នុង នីហ្វៃទី1 11–12

ក ការស្វែងយល់ អំពីអត្ថន័យនៃសុបិន

ដោយការអានរបស់អ្នក នៅក្នុង នីហ្វៃទី1 11 និង 12 ចូរឆ្លើយសំនួរដូចខាងក្រោម ហើយ ពិពណិនាពីអ្វី ដែលនីហ្វៃបានរៀន អំពីសុបិនរបស់ឱពុកគាត់។ បើចាំបាច់ សូមប្រើវ៉ត្ត "ការយល់ដឹងអំពីព្រះគម្ពីរ"។ (អ្នកប្រហែលជាចង់សរសេរ នៅក្នុងស្រៀវភៅ អំពីអត្ថន័យនៃនិមិត្តរូបទាំងឡាយ នៅជាប់នឹងខទាំងឡាយ ដែលមានន័យត្រូវទៅនឹង នីហ្វៃទី1 8។)

1. តើបុគ្គលិកលក្ខណៈ ឬគុណសម្បត្តិអ្វី ដែលធ្វើឱ្យដើមជីវិត និងផ្លែដ៏មានឱជារស មានអនុភាពលើ និមិត្តរូប នៃសេចក្តីស្រលាញ់របស់ព្រះ ចំពោះកូនចៅរបស់ទ្រង់ និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត?
2. តើបន្ទូលរបស់ព្រះ (ព្រះគម្ពីរ និងពាក្យរបស់ព្យាការី) ដូចគ្នានឹងដំបងដែក ដែលលីហៃបាន យើញយ៉ាងដូចម្តេចដែរ?
3. តើបន្ទូលរបស់ព្រះបានជួយអ្នក"ភ្លក់" សេចក្តីរីករាយ ដែលមកពីសេចក្តីស្រលាញ់ របស់ព្រះ យ៉ាងដូចម្តេច?
4. តើការល្បួងដូចគ្នានឹង "អ័ព្ទនៃភាពងងឹត" យ៉ាងដូចម្តេច ហើយតើអ្វី ជាគន្លឹះ ដើម្បីបង្ការមិន ឱ្យងងឹត និងវង្វេង?
5. តើមានភាពខុសគ្នាអ្វី រវាងជនដែលបានទៅដល់ដើមជីវិត ហើយដួលចុះ និងជនដែលទៅដល់ ដើមជីវិត ហើយនៅតែនៅទីនោះ?

ខ ស្វែងរកអ្វី ដែលនីហ្វៃបានរៀនអំពីព្រះយេស៊ូវ



នៅពេលដែលនីហ្វៃបានបង្ហាញពី អត្ថន័យនៃសុបិនរបស់ឱពុកគាត់ នីហ្វៃបានរៀនរៀងជាច្រើន ដែលព្រះយេស៊ូវនឹងធ្វើ ពេលដែលទ្រង់បានយាងមកលើផែនដី ជិត 600 ឆ្នាំ បន្ទាប់មក។

1. រំលឹកឡើងវិញនៅ នីហ្វៃទី1 11–12 ហើយសរសេរយ៉ាងតិច ព្រឹត្តិការណ៍ ប្រាំបី ដែលនីហ្វៃ បានបង្ហាញ អំពីជីវិត នៃព្រះអង្គសង្គ្រោះ។
2. តើការព្យាការណ៍បានបង្រៀនអ្នកអ្វីខ្លះ អំពីភាពត្រឹមត្រូវនៃចំណេះដឹងរបស់ព្រះ ស្តីអំពីអនាគតកាល?

ត ធ្វើសញ្ញាព្រមាន

ធ្វើឌីយ៉ាក្រាម ឬសញ្ញាដែលបង្ហាញពី អាគារដ៏ធំហើយទូលាយ, ដើមជីវិត, និងឈូងសមុទ្រដែល បំបែកពួកគេ (សូមមើលនីហ្វៃទី1 12ះ18)។ ដាក់ផ្លាកសញ្ញានិមិត្តរូបទាំងអស់ ហើយបន្ទាប់មក សរសេរពាក្យស្លោក ឬ សារដែលព្រមាន នៅលើបណ្ណ៉ប្រកាស ដែលអាចជួយ បញ្ចុះបញ្ចូល អ្នកដទៃទៀត ឱ្យផ្សេសរៀងពីអាគារ។ ចូរមានគំនិតឆ្នៃប្រឌិត និងព្យាយាមប្រើគំនិតថ្មីៗ ឬក៏ប្រើ បណ្ណ៉ប្រកាសរបស់អ្នកក៏បាន។

ទស្សនៈនិមិត្តដែលនីហ្វៃបានទទួល ដែលជាចំលើយចំពោះការ "សញ្ជឹងគិត" របស់គាត់អំពី ការសុបិនរបស់ឱពុក របស់គាត់ គឺត្រូវ បានកត់ត្រានៅក្នុង នីហ្វៃទី1 11–14។ ជំពូកទី 11–12 គឺមានការព្យាការណ៍អំពី ការបំរើរបស់ ព្រះយេស៊ូវគ្រីស្ត, ដង្វាយ ធួនរបស់ទ្រង់, និងការយាងមកជួបសាសន៍នីហ្វៃ នៅទ្វីបអាមេរិក។ ការនិមិត្តរបស់នីហ្វៃបន្តរហូតដល់ ជំពូកទី 13 ជាមួយ នឹងការព្យាការណ៍អំពី អ្វីដែលនឹងត្រូវកើតឡើងនៅ ទ្វីបអាមេរិក បន្ទាប់ពីពូជ របស់នីហ្វៃត្រូវបានកំទេចចោល ។ ចូរកត់សំគាល់ ថាតើការព្យាការណ៍នោះ ល្អិតល្អន់ និងត្រឹមត្រូវយ៉ាងណា។ ចូរកត់សំគាល់ផងដែរថា នីហ្វៃបានដឹងពី អនាគត របស់ប្រជាជនរបស់គាត់ នៅលើ ដែនដីសន្យា ពីមុនពេលពួកគេ ចាកចេញ ពីតំបន់ផ្ទុំសមុទ្រក្រហម។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 13

ត្វរខ្ពើមឆ្អើម (ខ 5–6)—ទុច្ចរិត, ពោរពេញដោយការស្អប់

ស្រីពេស្យា (ខ 7–8)—មនុស្សអសីលធមិ ឬ ស្រីខូច

មកសណ្ឌិត (ខ 12)—បានទទួលអនុភាព, បានបំផុសគំនិត

វាយដំកំទេច (ខ 14)—រងទណ្ឌកម្ម, រងទុក្ខព្រួយ

មាតានៃសាសន៍ដទៃ (ខ 17)—ពួក មនុស្ស នៅក្នុងស្រុកដែលគេបានចេញមក

ព្រះគម្ពីរ (ខ 20)—ព្រះគម្ពីរបឹប

បង្ខូច (ខ 27)—ប្តូរឱ្យទៅអាក្រក់

មែនទែន (ខ 30)—ដ៏ពិតប្រាកដ

សំណល់ (ខ 34)—ផ្នែកសេសសល់

សេចក្តីមេត្រី (ខ 37)—ពតិមាន, ដំណឹង

គម្ពីរផ្សេងឲ្យទៀត (ខ 39)—ព្រះគម្ពីរ មរមន និងព្រះគម្ពីរផ្សេងទៀត

ភាសា (ខ 40)—ភាសា

នីហ្វៃទី1 13:3—តើ "ព្រះអាណាចក្ររបស់សាសន៍ដទៃ" ជាអ្វី?

នីហ្វៃបានប្រើពាក្យសាសន៍ដទៃ នៅទីនេះ គឺគាត់ចង់និយាយពីសាសន៍ផ្សេងឲ ដែលនៅក្រៅដែនដីនៃអ៊ីស្រាអែល។

នីហ្វៃទី1 13:5–9–តើវាមានន័យយ៉ាងដូចម្តេច ដែលថា "សាសនាចក្រដ៏ គ្ងរខ្ពើមឆ្អើមបំផុត"?

© Greg K. Olsen

នីហ្វៃបានប្រាប់ថា វាមិនត្រឹមត្រូវទេ ដែលគិតថា ព្រះវិហារខ្លះ ឬនិកាយខ្លះ គឺជា "ព្រះវិហារដ៏គ្ងរខ្ពើមឆ្អើម"។ ក្រុម ដែលធ្វើតាម ផ្លូវរបស់អារក្សសាតាំង គឺជាផ្នែកនៃអាណាចក្រអាក្រក់ និងជាសត្រូវនៃព្រះគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់ (សូមមើលនីហ្វៃទី2 10:16)។ ពួកគេដូចជន ដែលបានរស់នៅក្នុងអាគារដ៏ធំហើយទូលាយ ដែលបានឃើញនៅក្នុងសុបិនរបស់លីហៃនោះ។

នីហ្វៃទី1 13:12—តើនរណាជា "មនុស្សនៅក្នុងចំណោមសាសន៍ដទៃ"?

នីហ្វៃបានឃើញ "មនុស្សម្នាក់ នៅក្នុងចំណោមសាសន៍ដទៃ" ដែលជា "វិញ្ញាណរបស់ព្រះ" ដែលបានបំផុសគំនិតឱ្យទៅ កន្លែងដែល កូនចៅរបស់លីហៃ នឹងនៅលើដែនដីសន្យា។ គ្រីស្ទូហ្វើរ ខូលិមបើស គឺជាមនុស្សដ៏អស្ចារ្យ ដូចដែលមនុស្សដែលនីហ្វៃ បាន ពិពណិនា ខូលិមបើស បាន សរសេរថាះ "តាំងពីនៅក្មេងរហូតដល់ឥឡូវ ខ្ញុំធ្លាប់ជាកម្មករនាវាសមុទ្រ ហើយនៅតែ ធ្វើការនោះ រហូតដល់ឥឡូវ . . .។ *ព្រះអម្ចាស់បានឱ្យខ្ញុំ ដូចសេចក្តីប៉ងប្រាថ្នារបស់ខ្ញុំ ហើយទ្រង់បានបានឱ្យសេចក្តីក្លាហាន និងការយល់ដឹងដល់ខ្ញុំ* ចំណេះដឹងដែលទ្រង់បានឱ្យខ្ញុំ ខាងការដើរក៉ាល់ ទ្រង់បានឱ្យខ្ញុំជាច្រើនក្រៃលែង . . .។ *ព្រះអម្ចាស់របស់យើង មិនបានបិទគំនិត របស់ខ្ញុំ ហើយបោះខ្ញុំ ចោលទៅក្នុងសមុទ្រទេ ហើយឱ្យខ្ញុំនូវកំលាំងដ៏រឹងមាំ សំរាប់សេចក្តីត្រូវការរបស់ខ្ញុំ*។ អស់អ្នកដែលបានលឺ [ការមានគំនិតច្រើន] របស់ខ្ញុំ បានហៅថា ការឆ្ពូតលីលា, បានសើចចំអកខ្ញុំ, ហើយបានសើច។ *តែតើនរណានៅមានចំងល់ តែព្រះ វិញ្ញាណបរិសុទ្ធ បានបំផុសគំនិតខ្ញុំឬ?* (មកពី Jacob Wassermann, *Columbus, Don Quixote of the Seas,* 19–20, 46 ផ្តេកបន្ថែមដកស្រង់នៅក្នុង McConkie and Millet, *Doctrinal Commentary on the Book of Mormon,* 1:91)។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុងនីហ្វៃទី1 13 ធ្វើសកម្មភាពដូចខាងក្រោម (ក–គ)។

ក ធ្វើការប្រៀបធៀប

នៅក្នុងនីហ្វៃទី1 13:1–9 នីហ្វៃបានពិពណិនាថា "ព្រះវិហារដ៏គ្ងរខ្ពើមឆ្អើម" មានគោលដៅដើម្បីកំទេចពួកបរិសុទ្ធរបស់ព្រះ (សូមមើលវគ្គខាងលើ "ការយល់ដឹងអំពីព្រះគម្ពីរ")។

1. នៅពេលដែលអ្នកអាននូវខទាំងនេះ សរសេរពីអ្វីដែលនីហ្វៃបាននិយាយ គឺជាសេចក្តីប៉ងប្រាថ្នារបស់អ្នកទាំងឡាយណា ដែល នៅក្រោម ការដឹកនាំរបស់សាតាំង។ បន្ទាប់មកធ្វើបញ្ជីផ្សេងទៀត ពីពរជ័យខ្លះឲ ដែលសំខាន់សំរាប់ សមាជិកនៃសាសនាចក្រ។
2. សរសេរកថាខ័ណ្ឌខ្លីឲ ដែលពន្យល់ មូលហេតុដែលពរជ័យនៅក្នុងបញ្ជី សំរាប់សមាជិកដែលមាន សេចក្តីជំនឿស្មោះស្ម័ត្រ នឹងនាំ ដល់ពួកគេ នូវសុភមង្គលដ៏អស្ចារ្យ ជាងអ្វីដែលបានសរសេរនៅក្នុងបញ្ជីមួយទៀត។

© 1977 Dan Thornton

ខ ផ្ទូរផ្តងក្សាល់រឿងទៅនឹងខ

នៅក្នុងនីហ្វៃទី1 13:10–19 គឺជាការកត់ត្រាការនិមិត្ត របស់នីហ្វៃ ដែលមាននៅក្នុងទ្វីបអាមេរិក ដោយអ្នកស្រាវជ្រាវក្នុងទ្វីប អ៊ីរ៉ុប។ នីហ្វៃក៏បានឃើញជំលោះដែលអ្នកតាំងភូមិលំនៅជនជាតិអ៊ីរ៉ុប នឹងមានជាមួយកូនចៅរបស់លីហៃ លើភូមិកំណើត របស់ពួកគេ។

1. កត់ក្សាល់រឿងទាំងអស់នៅក្នុងស្សៀវភៅសរសេរ របស់អ្នក។ បន្ទាប់ពីបានសរសេរក្សាលរឿងនីមួយឲ្យរួច ចូរសរសេរលេខ ខចេញពី នីហ្វៃទី1 13:10–19 ដែលនឹងស៊ីគ្នាជាមួយនឹងចំណងជើងះ
   - អ្នកដង្ហែរក្សួនធម្មយាត្រ ធ្វើដំណើរ ទៅពិភពថ្មី សំរាប់សេរីភាពរបស់សាសនា
   - ទោះបីជាទាហានបដិវត្តន៍ ដែលមានចំនួនច្រើន ហើយមានជ័យជំនះ
   - កប៉ាល់ឆ្លងកាត់មហាសមុទ្រអាត្លង់ទិចប្រវែង 4.828 គីឡូម៉ែត្រ
   - ខូលិមបើសធ្វើទូកក្តោងទៅរកពិភពថ្មី
   - ជនជាតិកំណើតរបស់ អាមេរិកត្រូវបានគេបណ្តេញចេញពី ស្រុករបស់ពួកគេ
   - សាសន៍ដទៃធ្វើដំណើរទៅកាន់អាមេរិក
2. តើអ្នកបានដឹងអ្វីខ្លះអំពីប្រវត្តិ ស្រុករបស់អ្នក ដែលបានបង្ហាញព្រះហស្ត របស់ព្រះអម្ចាស់ក្នុងការរៀបចំ ឱ្យស្រុករបស់អ្នក ទទួលជំណឹងល្អ?

៣ សង្ខេបការព្យាករណ៍

នីហ្វៃបានបង្ហាញថា ព្រះគម្ពីរបឹប និងព្រះគម្ពីរមរមន និងគម្ពីរផ្សេងៗទៀត នឹងមកនៅថ្ងៃចុងក្រោយ។ ចូរសង្ខេបពីអ្វីដែលនីហ្វៃ បានឃើញ ដោយឆ្លើយនូវសំនួរដូចខាងក្រោមៈ

1. តើនីហ្វៃបានឃើញអ្វី ដែលនឹងកើតឡើងចំពោះព្រះគម្ពីរបឹប បន្ទាប់ពីបានសរសេរដោយព្យាការី និងសាវ៉ក ដែលនឹងធ្វើឱ្យ ពួកសាសន៍ដទៃ "ញាប់ញ៉រ"? (សូមមើលនីហ្វៃទី1 13:20–29)។
2. តើព្រះអម្ចាស់នឹងធ្វើអ្វីចំពោះពួជ ឬ កូនចៅរបស់នីហ្វៃ នៅពេលដែលសាសន៍ដទៃ មកដល់អាមេរិក? (សូមមើលនីហ្វៃទី1 13:30–31)។
3. តើព្រះអម្ចាស់នឹងធ្វើអ្វី ដើម្បីជួយពួកសាសន៍ដទៃ និងសាសន៍យូដា ដែលជាកូនចៅរបស់លីហៃ និងជាសមាជិក នៃសាសនាចក្ររបស់ទ្រង់ ឱ្យរៀនសេក្តីពិត ពីដំណឹងល្អ? (សូមមើល នីហ្វៃទី1 13:32–41)។
4. តើដំណឹងនៅក្នុងខទី 37 អាចអនុវត្តទៅនឹងខ្លួនអ្នក និងការសំរេចចិត្តរបស់អ្នក នាអនាគតយ៉ាងដូចម្តេច?

ទស្សនៈនិមិត្តរបស់នីហ្វៃ មាននៅក្នុងនីហ្វៃទី1 14។ នៅក្នុងជំពូកនោះនីហ្វៃ បានបង្ហាញពីការប្រយុទ្ធដែលមានចំពោះ សាសនាចក្រនៃកូនចៀមរបស់ព្រះ និងសាសនាចក្រដ៏គួរខ្ពើមឆ្អើម នៃសាសនាចក្រនៃអារក្ស។ ធ្វើការសំគាល់ពីការសន្យា ដែល ព្រះអម្ចាស់ បានធ្វើចំពោះសាសន៍ដទៃ ដែលទទួលដំណឹងល្អនៅសម័យចុងក្រោយ។ ទោះបីជាអ្នក ជាអំបូរអ៊ីស្រាអែលក៏ដោយ បើអ្នកមិនមែនជាសាសន៍យូដា និងជាកូនចៅរបស់លីហៃទេ អ្នកនឹងត្រូវគេរាប់ជាសាសន៍ដទៃ ដូចដែលនីហ្វៃបានសរសេរ។ នៅពេលដែលអ្នកអាននៅជំពូកនេះ ចូរមើលពីតួនាទីរបស់អ្នក នៅក្នុងសម័យចុងក្រោយចំពោះព្រះអម្ចាស់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 14

ត្រូវបានបំភាន់ (ខ 2)—បញ្ចូលជាមួយប្រជាជនដទៃ ដើម្បីឱ្យសញ្ជាតិរបស់ពួកគេមិនអាចប្លែកពីគេ

ដ៏គួរខ្ពើមឆ្អើម (ខ 3)—ទុច្ចរិត, គួរឱ្យស្អប់

បំពេញ (ខ 3—បំពេញ, សរុប

កិច្ចការដ៏ធំហើយអស្ចារ្យ (ខ 7)—គឺជាការសាងឡើងវិញនៃដំណឹងល្អនៃសាសនាចក្រ

ខាងសាច់ឈាម (ខ 7)—ខាងរូបកាយ

ពេស្យា (ខ 10)—ព្រះវិហាររបស់អារក្ស គឺជាពេស្យា ដែលមនុស្សបោះបង់ចោលព្រះ ហើយធ្វើតាមអារក្ស។

អំណាច (ខ 11)—ការទទួលអនុភាពភាពខ្លាំង

នីហ្វៃទី1 14:7–10—តើហេតុអ្វីមានតែ "សាសនាចក្រតែពីរប៉ុណ្ណោះ"?

"សាសនាចក្រនៃអារក្ស" គឺមិនបាននិយាយថា ព្រះវិហារណាមួយពិតប្រាកដទេ តែចំពោះមនុស្សគ្រប់ប្រភេទ, គ្រប់ក្រុម, គ្រប់អង្គការ ឬទស្សនវិជ្ជា ដែលធ្វើការប្រឆាំងជាមួយនឹងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ និងផែនការណ៍សង្គ្រោះ នៃ កូនចៅរបស់ព្រះ។ សេចក្តីពិត និងសេចក្តីល្អអាចរកបាននៅក្រៅ នៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ តែភាពពេញលេញនៃដំណឹងល្អ គឺអាចរកបានតែនៅក្នុង សាសនាចក្រដែលបានសាងឡើងវិញ ហើយសំខាន់ ចំពោះផែនការណ៍ នៃសេចក្តីសង្គ្រោះ ដែលជាសេចក្តីប៉ងប្រាថ្នា របស់ព្រះវរបិតាសួគិ សំរាប់កូនចៅរបស់ទ្រង់។ ដំណឹងល្អ ដែលបាន សាងឡើងវិញគឺជា "កិច្ចការដ៏ធំហើយ . . . អស្ចារ្យ" (នីហ្វៃទី1 14:7) ដូចដែលទេវតា បានប្រាប់នីហ្វៃថា នឹងបំបែកប្រជាជន "ដើម្បីជាការផ្ចាញ់ពួកគេ ដល់សេចក្តីសុខសាន្ត និងជីវិតដ៏នៅអស់កល្បជានិច្ច ឬដើម្បីជាការបណ្តោយ ឱ្យពួកគេ ទៅតាម ភាពរឹងរូសងងល់នៃគំនិតរបស់ពួកគេ រហូតដល់ត្រូវធ្លាក់នៅក្នុងការជាប់ឃុំឃាំង ហើយធ្លាក់នៅក្នុងសេចក្តីបំផ្លិចបំផ្លាញ" (ខ 7)។

អែលឌ៉ ប្រូស អ៉រ. មិកខន់យ៉ ដែលធ្លាប់ជាសមាជិកនៃក្រុមសាវ៉កដប់ពីរនាក់ បានបង្រៀនថាៈ "វាមានតែពន្លឺ និងភាពងងឹត តែប៉ុណ្ណោះ វាគ្មានទៅចន្លោះទេ វាត្រូវតែមានពន្លឺ ឬភាពងងឹត។ បើមនុស្សមិនដើរនៅក្នុងពន្លឺ ឬគេមិនបានសង្គ្រោះឡើយ។ អ្វីឲ្យដែលមិនសក្តិសមចំពោះផែនការសង្គ្រោះ មិនមែនជាផែនការសង្គ្រោះទេ។ វាប្រហែលជាប្រសើរជាង នៅពេលដើរ នៅពេលថ្ងៃជ្រេ ឬមើលឃើញពន្លឺកាំរស្មីពីរបីដំបូង នៃពន្លឺនៅឆ្ងាយ ជាជាងនៅក្នុងភាពងងឹតទាំងស្រុង តែផែនការសង្គ្រោះគឺសំរាប់តែអ្នកដែល ឈានទៅមុខដោយ ពន្លឺចិញ្ចាចឡើង ដូចពន្លឺនៃថ្ងៃត្រង់តែប៉ុណ្ណោះ (*The Millennial Messiah: The Second Coming of the Son of Man* [1982], 54)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពដូចខាងក្រោម (ក–គ) ពេលអ្នកសិក្សានៅក្នុងនីហ្វៃទី1 14។

៣ ស្វែងរកពាក្យសន្យា "បើសិន-បន្ទាប់មក"

នៅក្នុង នីហ្វៃទី1 14:1–3 ទេវតាបានប្រាប់នីហ្វៃអំពីលក្ខខ័ណ្ឌនៃពរជ័យ ដែលអាចមានសំរាប់សាសន៍ដទៃ ដែលសំរាប់ យើងទាំងអស់គ្នាផងដែរ។ ពរជ័យទាំងនេះគឺត្រូវបានថ្លែងនៅក្នុងកិច្ចសន្យា "បើសិន-បន្ទាប់មក"—បើសិនអ្នកធ្វើដូច្នេះ បន្ទាប់មកព្រះនឹងធ្វើដូច្នោះ។ ស្វែងរកសេចក្តីសន្យា និងបំពេញការថ្លែងដូចខាងក្រោមនៅក្នុងស្បៀវភៅសរសេររបស់អ្នក។

បើសិនៈ

- សាសន៍ដទៃ . . .
- រឹងរូស . . .

បន្ទាប់មកៈ

- ពួកគេនឹងត្រូវបានរាប់បញ្ចូល . . .
- ពួកគេនឹងត្រូវបាន . . .
- ពួកគេនឹងមិនត្រូវ . . .
- រណ្តៅដ៏ជ្រៅ . . .

៤ ស្វែងរកភស្តុតាងនៅក្នុងសារពតិមាន

នៅក្នុង នីហ្វៃទី1 14:7–10 ទេវតាបានប្រាប់នីហ្វៃថា មនុស្សធ្វើការសំរេចចិត្ត នៅក្នុងជំរើសពីរ។

1. រំលឹកខទាំងនោះឡើងវិញ ហើយសង្ខេបជំរើសទាំងពីរនោះ ថាជាអ្វី (សូមមើលវគ "ការយល់ដឹងអំពីព្រះគម្ពីរ")។
2. រកមើលអត្ថបទ និងការផ្សាយពាណិជ្ជកម្មនៅក្នុងសារពតិមាន ហើយស្វែងរកយ៉ាងតិចឧទាហរណ៍ពីរ នៃមនុស្ស, ក្រុម, ឬជាទស្សនវិជ្ជា ដែលសាតាំងចង់ឱ្យយើងទុកចិត្តទៅលើវត្ថុទាំងនោះ ជាជាងទុកចិត្តទៅលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ពន្យល់ ពីមូលហេតុ ដែលវត្ថុទាំងនោះមិនអាចនាំយើងឱ្យមាន "សេចក្តីសុខសាន្ត និងជីវិតនៅអស់កល្បជានិច្ច" (ខ 7)។

៥ សរសេរសំនួរសាកល្បងរបស់អ្នកផ្ទាល់

នៅទីបញ្ចប់នៃការនិមិត្ត នីហ្វៃបានឃើញ ការប្រយុទ្ធដែលនឹងកើតឡើងនៃ "សាសនាចក្រនៃកូនចៀមរបស់ព្រះ" និងសាសនាចក្រនៃអារក្ស។ នីហ្វៃក៏បានរៀនផងដែរថា នឹងមានព្យាការី ដែលនឹងចែកចាយវិវរណៈស្រដៀងគ្នា នៅច្រើនឆ្នាំក្រោយមកទៀត។

1. ស្វែងរក នីហ្វៃទី1 14:11–30 ហើយសរសេរ សំនួរសាកល្បង ពីប្រាំមួយ ទៅ ប្រាំបី ដែលអ្នកគិតថា វាជាសំនួរសំខាន់ សំរាប់ឆ្លើយនៅក្នុងខទាំងនេះ។ ចូរកុំភ្លេចឆ្លើយសំនួរ។
2. តើអ្នកបានរៀនអ្វីខ្លះនៅក្នុងខទាំងនេះ ដែលប្រហែលអនាគតរបស់អ្នកដូចគ្នា នឹងខគម្ពីរទាំងនោះ?

នៅក្នុងនីហ្វៃទី1 11–14 គឺជាកំណត់ត្រាអំពី ការនិមិត្ត ដ៏អស្ចារ្យ នីហ្វៃបានទទួលចំលើយទៅនឹងសេចក្តីប្រាថ្នារបស់គាត់ "ឃើញអ្វីព្ធ ដែលឱពុក [របស់គាត់]បានឃើញមក" (សូមមើលនីហ្វៃទី1 11:3)។ ចូរកត់សំគាល់ នៅក្នុងនីហ្វៃទី1 15 តើនីហ្វៃ គិតយ៉ាងដូចម្តេចអំពី លេមិន និង លេមយួល នៅពេលដែលត្រឡប់មកវិញ ក្រោយពីត្រូវបានណែនាំដោយទេវតា។ នៅពេលដែល អ្នក អាននូវផំពូកនេះ រកមើលពីមូលហេតុដែលនីហ្វៃ អាចដើរនៅក្នុងពន្លឺដោយវិវរណៈដ៏ទេវភាព ហើយបងពូរបស់ គាត់ញាប់ញ័រ នៅក្នុងភាពងងឹត។ ចូរកត់សំគាល់ផងដែរ អំពីការពន្យល់បន្ថែម ដែលនីហ្វៃបានផ្តល់ឱ្យ ហើយអាចជួយយើងយល់ ពីវិវរណៈដែល នីហ្វៃ និងឱពុកគាត់ លីហៃបានទទួល។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 15

ប្រកែកគ្នា, ឈ្លោះគ្នា (ខ 2, 6)—ប្រកែកគ្នា, ឈ្លោះគ្នា

សម្តែង (ខ 13)—បង្ហាញ

ត្រូវបានបំភាន់ (ខ 20)—បញ្ចូលជាមួយប្រជាជនដទៃ ដើម្បីឱ្យសញ្ជាតិរបស់ពួកគេមិនអាចប្លែកពីគេ

សូប់ស្ងាត់ (ខ 20)—សូប់

ព្រួញភ្លើងរបស់មារសត្រូវ (ខ 24)—ការវាយប្រហារ យ៉ាងសាហាវរបស់សាតាំង

ចំណេះវិជ្ជា (ខ 25)—សមត្ថភាព, អំណាច

ឡើង (ខ 30)—រះ

ថ្ងៃសាកល្បង (ខ 31)—ពេលសំរាប់សាកល្បង និងបំភ្លឺ (សំដៅលើជីវិតនៅលើផែនដីនេះ, ជីវិតដែលរមែងស្លាប់)

រូបកាយ (ខ 31)—រូបកាយ

ទាក់ទងទៅនឹង (ខ 33)—ដែលត្រូវធ្វើជាមួយ, ដែលជាប់ទំនាក់ទំនងជាមួយ

នីហ្វៃទី1 15:13, 16—តើការបំបៅគឺជាអ្វី?

សំរាប់ការពន្យល់ដែលថា វង្សនៃអ៊ីស្រាអែល គឺដូចជាដើមឈើ ហើយការបំបៅ គឺដូចជាការតែងលំអ សូមមើលនៅក្នុង នីហ្វៃទី1 10:14 សំរាប់វគ្ត "ការយល់ដឹងអំពីព្រះគម្ពីរ" (ទំព័រ00)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពដូចខាងក្រោម (ក–គ) នៅពេលអ្នកសិក្សានៅក្នុងនីហ្វៃទី1 15។

៦ ស្វែងរកគំរូ "បើសិន-បន្ទាប់មក"

នីហ្វៃបានពួបងពូរបស់គាត់និយាយថា ពួកគេមិនយល់ពីសុបិនរបស់ឱពុករបស់គេទេ។

1. រំលឹកនីហ្វៃទី1 15:1–9 ឡើងវិញ ហើយពន្យល់ពីអ្វីដែលនីហ្វៃ បានធ្វើ ដើម្បីយល់ពីអ្វីដែលឱពុករបស់ពួកគេបាននិយាយ។
2. នៅក្នុងស្យៀវភៅសរសេររបស់អ្នក ចូរបញ្ចប់សេចក្តីថ្លែងដូចខាងក្រោម ដើម្បីបង្ហាញពី គំរូនៃ "បើ-បន្ទាប់មក" ដើម្បីទទួល វិវរណៈដែលនីហ្វៃបានឱ្យនៅក្នុងខទី 11:

   បើសិនៈ

   - អ្នកណាមិន . . .
   - ហើយសូមដល់ . . .
   - ជាមួយ

   បន្ទាប់មកៈ

   - រឿងនេះ ច្បាស់ជា . . .
3. គិតអំពីសេចក្តីថ្លែង "បើ" និងអ្វីដែលអ្នកគួរតែពង្រីក ក្នុងការអានរបស់អ្នក ដើម្បីទទួលចំលើយពីព្រះវរបិតាសួគិ។

៧ ដាក់សចក្តីថ្លែងឱ្យតាមលំដាប់លំដោយ

នៅក្នុងការឆ្លើយចំពោះបងពូរបស់គាត់ នីហ្វៃបានប្រដូចវង្សនៃអ៊ីស្រាអែល ទៅនឹងដើមអូលីវ។ ប្រើនីហ្វៃទី1 15:12–20 ដើម្បីជួយអ្នកជំនួសសេចក្តីថ្លែងដូចខាងក្រោម តាមលំដាប់លំដោយៈ

- ដំណឹងល្អបានទៅដល់សាសន៍ដទៃ ពីព្រោះសាសន៍យូដា និងសាសន៍លេមិន បដិសេធដំណឹងល្អ។
- សាសន៍ដទៃនឹងទទួលដំណឹងល្អ ហើយនឹងបំបៅជាប់ជាមួយនឹងដើមអូលីវ ដែលជាតំណាងសាសន៍អ៊ីស្រាអែល។
- សាសន៍នីហ្វៃ គឺជាមែកដែលបាក់ ចេញពីដើមនៃសាសន៍អ៊ីស្រាអែល។
- ដើមនឹងត្រូវបានស្តារឡើងវិញ ដើម្បីបំពេញសេចក្តីសន្យា ដែលបានធ្វើចំពោះអ៉ាប្រាហាំ។
- កូនចៅរបស់លីហៃ នឹងលឺ និងទទួលស្គាល់ដំណឹងល្អ។

៨ អនុវត្តតាមការដកស្រង់

អែឌើរ ទ្យែល អេ. ម៉ាកស្វែល ជាសមាជិកនៃក្រុមសាវ៉ែកដប់ពីរ បានមានប្រសាសន៍ថាៈ "អ្នកដើរតាមពិតប្រាកដមិនខ្លាចព្រួញ ភ្លើងរបស់មារសត្រូវទេ ដោយយកសេចក្តីជំនឿទុកជាខែល ជាមួយនឹងដៃម្ខាង នៅពេលដែលដៃម្ខាងទៀតកាន់ដំបងដែក . . .។ មិនត្រូវឱ្យមានការកាន់ខុសទេ វានឹងត្រូវប្រើដៃទាំងពីរ! (នៅក្នុង Conference Report, ខែមេសា 1987, 87 ឬ *Ensign*, ខែឧសភា 1987, 70)។

អាននៅក្នុង នីហ្វៃទី1 15:21–36 ដោយយកចិត្តទុកដាក់ ហើយបន្ទាប់មក សរសេរកថាខ័ណ្ឌដែលប្រាប់ថា ជំនឿហើយនឹងបន្ទូល របស់ព្រះអាចជួយអ្នកឈ្នះលើការល្បួង ដែលអ្នកប្រឈមមុខនឹងការល្បួងនោះ។

នីហ្វៃទី1 16

ជុំមូល និងធ្នូបាក់ យ៉ាងចំឡែក

តើអ្នកធ្លាប់បានសំគាល់ទេ នៅពេលដែលអ្នកពោរពេញទៅដោយ ព្រះវិញ្ញាណ វាងាយស្រួលបំផុត ក្នុងការអត់ធ្មត់ប្រឈមនឹង អ្វីដែលខុសក្នុងជីវិតរបស់អ្នក? ម្យ៉ាងវិញទៀត ប្រជាជនភាគច្រើនបានស្វែងយល់ថា នៅពេលដែលរយៈចំងាយ រវាងពួកគេនិង ព្រះអម្ចាស់ កាន់តែនៅឆ្ងាយពីគ្នា នោះពួកគេមានការគ្រប់គ្រងលើកំហឹងរបស់ពួកគេ ក៏លែងសូវមាន។ នៅក្នុងនីហ្វៃទី1 16 អ្នកនឹងអានអំពី បទពិសោធន៍ទាំងពីរយ៉ាង។ ពេលខ្លះ ព្រះអម្ចាស់ ប្រើការមិនអនុគ្រោះ ដើម្បីបង្រៀនមេរៀន ដែលសំខាន់ព្ធ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 16

រឿងដ៏ធ្ងន់ព្ធ (ខ 1–2)—សេចក្តីពិត ដែលពិបាកទទួលយក

កាត់ទំលុះគេរហូតដល់ដួងចិត្ត (ខ 2)—លើកយកកំហុសអ្នកដទៃមកនិយាយ

ទូន្មាន (ខ 4)—ណែនាំ, លើកទឹកចិត្ត

សម្ភារៈ (ខ 11)—អាហារ និងគ្រឿងផ្គត់ផ្គង់

ព្រួញ (ខ 15)—អាវុធសំរាប់បរបាញ់គុបដោយដុំថ្ម

ព្រួញនៅតែប្រើនៅសម័យយើងសព្វថ្ងៃនេះ នៅកន្លែងខ្លះព្ធ។

ទ្សើយហាត់ជាខ្លាំង (ខ 19)—ល្ហិតល្ហៃ, អស់កំលាំង

ស្តីប្រដៅ (ខ 25)—ស្តីបន្ទោស, កែលំអ

នីហ្វៃទី1 16:10—តើ "ជុំមូលមួយដែលមានក្សូក្សាច់ដម្លែក" នោះ គឺជាអ្វី?

ក្សូក្សាច់ នៅក្នុងខនេះមានន័យថា ធ្វើដោយប្រយ័ត្ន ច្បាស់លាស់ សាំញាំ។ ព្រះអម្ចាស់បានរៀបចំ ជុំមូលនោះ ដើម្បីដឹកនាំលីហៃ និងក្រុមដ៏តូចរបស់គាត់ ទៅកាន់ដែនដីសន្យា។ យើងបានរៀនអំពីជុំ មូលនោះពីអាលម៉ាថា វាបានណែនាំទិសដៅដូចជាគ្រីវិស័យ ហើយត្រូវបានហៅថា លីអាហូណា (សូមមើលអាលម៉ា 37:38)។

លីហៃនិងគ្រួសាររបស់គាត់ បានដឹងថា លេអាហូណា មានជុំពីរ ឬ ទ្រនិចពីរ ដែលបង្ហាញពួកគេពីទិសដៅធ្វើដំណើរ (សូមមើល នីហ្វៃទី1 16:10)។ វាក៏មានកន្លែងមួយដែរ នៅលើជុំមូលនោះ ដែលមានតួអក្សរផុសចេញមក "ហើយបានប្តូរទៅតាម ពេលវេលា" (ខ 29, សូមមើលផងដែរ ខ 26–30)។ ទិសដៅនេះដើរតាមតែ សេចក្តីជំនឿរបស់ពួកគេតែប៉ុណ្ណោះ (សូមមើល ខ 28–29)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព គ (សកម្មភាព ក និង ខ គឺអាចជ្រើសរើសបាន) នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី1 16។

ក សរសេរនិយមន័យ

បងព្ធរបស់នីហ្វៃ បានរអ្ទិររទាំនឹងនីហ្វៃ ព្រោះនីហ្វៃបាននិយាយទៅកាន់ពួកគេ នូវ "រឿងដ៏ធ្ងន់ព្ធ។" (នីហ្វៃទី1 16:1)

1. ចូរសិក្សានៅក្នុង ខ 1–3 ហើយពន្យល់ តើអ្នកគិតថា "រឿងដ៏ធ្ងន់ព្ធ" មានន័យដូចម្តេច។
2. ពន្យល់ថា ហេតុអ្វីសេចក្តីពិតដូចគ្នានោះមិនមែនជា "រឿងដ៏ធ្ងន់ព្ធ" សំរាប់នីហ្វៃ។

ខ គូររូបភាព

ចូរសិក្សា នីហ្វៃទី1 16:10–30 ហើយគូររូបភាពលេអាហូណា ទៅតាមទ្រង់ទ្រាយតាមការស្មានរបស់អ្នក។

គ សង្ខេបពីអ្វីដែលបានកើតឡើង

គ្រួសាររបស់លីហៃបានរង់ទុក្ខវេទនា នៅពេលដែលធ្នូរបស់នីហ្វៃបាក់។

1. សង្ខេបពីអ្វីដែលកើតឡើង ដែលមាននៅក្នុងខដូចខាងក្រោម នៅក្នុងនីហ្វៃទី1 16 បន្ទាប់មក ពន្យល់ ពីអ្វីដែលអ្នកគិតថា គ្រួសាររបស់លីហៃអាចរៀន ពីបទពិសោធន៍នីមួយព្ធនោះ

   ក. ខទី 17–19 ឃ.ខទី 24–29

   ខ. ខទី 20–21 ង. ខទី 30–31

   គ. ខទី 22–23

2. តើបទពិសោធន៍បាក់ធ្នូរបស់នីហ្វៃ អាចជួយអ្នកដូចម្តេចខ្លះ បើសិនជាវំពេចនោះ អ្នកត្រូវបាត់បង់ការងាររបស់អ្នក ដែលជាផ្នែកសំខាន់ ដើម្បីផ្គត់ផ្គង់ម្ហូបអាហារ និងសំលៀកបំពាក់ និងគ្រួសាររបស់អ្នក?
3. បើទោះបីជាលីហៃបានរអ្ទិរទាំ តើអ្នកគិតថា ហេតុអ្វីបានជានីហ្វៃនៅតែទៅពិភាក្សាជាមួយលីហៃ ពីកន្លែងដែលត្រូវទៅបរបាញ់សត្ធ?

នីហ្វៃទី1 17

"ចូរអ្នកសង់សំពៅមួយ"

ក្រុមដ៏តូចរបស់លីហៃ ក៏បានបញ្ចាប់ការធ្វើដំណើររបស់ពួកគេ នៅក្នុងទីរហោស្ថាន នៅពេលដែលព្រះអម្ចាស់បានដឹកនាំពួកគេ ទៅកាន់កន្លែង

ដែលមានជីជាតិ នៅជិតឆ្នេរសមុទ្រ ដែលពួកគេហៅថា ដែនដីបរិបូរណ៍។ នៅក្នុង នីហ្វៃទី1 17 នីហ្វៃបានចែក បទពិសោធន៍នៅក្នុងទីរហោស្ថាន របស់គាត់ ដែលគាត់មិនបានប្រាប់ពីមុន។ សូមរកមើលថា តើពួកគេបានធ្វើដំណើរអស់រយៈពេល ប៉ុន្មាន នៅក្នុងទីរហោស្ថាន តើពួកគេហូបអ្វី តើពួកគេរស់នៅតាមរបៀបណា ដោយការបរិភោគអាហារបែបនោះ។ ធ្វើការកំណត់ចំណាំផងដែរ ថាហេតុអ្វី បានជាលេមិន និងលេមយួលរអ៊ូរទាំម្ដងទៀត។

រូបភាព៖ ជើរ៉េ អាសមុស្សិ៍ រក្សាសិទ្ធិដោយមូលនិធិសំរាប់ការស្រាវជ្រាវ និងការសិក្សាមរមន។

ផ្លូវដែលលីហៃអាចធ្វើដំណើរ នៅក្នុងទីរហោស្ថាន

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 17

អស់រយៈពេលជាច្រើនឆ្នាំ (ខ 3–4)—ស្នាក់នៅមួយរយៈខ្លី

ទោះបី (ខ 6)—ទោះបី

រំលាយ (ខ 9, 16)—រលាយ

ឧបករណ៍ផ្លុំ (ខ 11)—ឧបករណ៍សំរាប់ផ្លុំខ្យល់ ឬភ្លើងដើម្បីឱ្យវារឹតតែក្ដៅឡើង



ខាងក្រោម

ក្រិត្យក្រម (ខ 22)—ច្បាប់, វិន័យ

សេវកភាព (ខ 24–25)—ទាសភាព

ជាទម្ងន់ (ខ 25)—ផ្ទុក, បន្ទុក

ទាស់ទឹង (ខ 30, 42)—និយាយអាក្រក់, និយាយប្រមាថ

យល់ថាសាច់ឈាមទាំងអស់ដូចគ្នា (ខ 35)—ចាត់ទុកថា កូនចៅរបស់ទ្រង់ទាំងអស់គឺដូចគ្នា

បានប្រដៅ (ខ 41)—អប់រំ, កែលំអ

ចេញពីគ្នា (ខ 45)—ដាច់ផ្ដេកៗ

ទុក្ខព្រួយហើយឈឺខ្លោចផ្សារ (ខ 47)—ទុក្ខព្រួយយ៉ាងខ្លាំង

ឆេះ (ខ 48)—កំទេច

ស្វិត (ខ 48)—រួញ, ស្ងួត

សូន្យបាត់ទៅ (ខ 48)—គ្មានអ្វីៗ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ ដូចខាងក្រោម (ក–ង) នៅពេលអ្នកសិក្សានៅក្នុងនីហ្វៃទី1 17។

ក តើនីហ្វៃបានបង្រៀនអ្វីខ្លះ អំពីការធ្វើដំណើរនៅក្នុងទីរហោស្ថាន?

1. រំលឹកឡើងវិញ នូវនីហ្វៃទី1 17:1–6, 12 ហើយឆ្លើយនូវសំនួរ ដូចខាងក្រោម អំពីការធ្វើដំណើរនៅក្នុងទីរហោស្ថាន៖
   - ក. តើពួកគេចំណាយពេល អស់រយៈប៉ុន្មានក្នុងការធ្វើដំណើរ ពីយេរូសាឡិម ទៅកាន់ដែនដីបរិបូរណ៍?
   - ខ. តើពួកគេបរិភោគអ្វី ជាចំបងនៅក្នុងទីរហោស្ថាន?
   - គ. តើអ្នកគិតថា ហេតុអ្វីបានជានីហ្វៃនិយាយថា "ព្រះពរព្រះអម្ចាស់ដែល ទ្រង់បានប្រទានមកឱ្យយើង នោះច្រើនណាស់" (ខ 2)?
2. ស្វែងរក គំរូនៅក្នុងខទី 3 "ហេតុដូច្នេះហើយ យើងឃើញថា" មេរៀនដែលបានបញ្ជាក់ពី "បើសិន–បន្ទាប់មក" ៖

   បើសិន "កូនចៅមនុស្ស ______________________

   បន្ទាប់មក "ទ្រង់នឹង ______________ ហើយ ______________ ផ្ដល់ ______________________

3. អ្នកប្រហែលជាមិនចាំបាច់ ឆ្លងកាត់សមុទ្រខ្សាច់ទេ តែជីវិតរបស់អ្នក នៅតែមានការប្រឈមមុខពិបាកៗ។ ពន្យល់ពីរបៀប ដែលអ្នកអាចអនុវត្ត មេរៀន "ហេតុដូច្នោះហើយ យើងឃើញ" នៅក្នុងជីវិតរបស់អ្នក។

ខ ពិពណ៌នាអំពីឧទាហរណ៍ នៅសម័យនេះ

ព្រះអម្ចាស់បានបញ្ជាឱ្យនីហ្វៃសង់សំពៅមួយ—កិច្ចការនោះគឺអាស្រ័យទៅលើសមត្ថភាពធម្មជាតិរបស់នីហ្វៃ។ ធ្វើការ សិក្សានៅក្នុង នីហ្វៃទី1 17:7–11 ហើយធ្វើការកំណត់ចំណាំ អំពីអ្វីដែលព្រះអម្ចាស់បានធ្វើ ហើយអ្វីដែលទ្រង់បានគំរូវ ឱ្យ នីហ្វៃធ្វើ។ បន្ទាប់មកសរសេរ រឿងរបស់មនុស្សសម័យនេះ បើអ្នកត្រូវបានសួរឱ្យធ្វើអ្វីមួយដែលពិបាក ហើយត្រូវតែ ពឹងទៅលើព្រះអម្ចាស់ ដើម្បីចេះធ្វើការងារនោះ។

គ ធ្វើការប្រៀបធៀបបងៗរបស់នីហ្វៃ

1. សិក្សានៅក្នុង នីហ្វៃទី1 16:1–3, 18–20, 37–38, 17:17–21, 48 ធ្វើបញ្ជីពីមូលហេតុដែលលេមិន និងលេមយួល បានរអ៊ូរទាំ ឬបានខឹង ហើយហេតុអ្វីបានជាពួកគេ "សប្បាយ។"

2. សិក្សានៅក្នុង នីហ្វៃទី1 16:4–5 , 17:19, 47 ធ្វើបញ្ជីពីមូលហេតុ ដែលនីហ្វៃសប្បាយជាខ្លាំង ហើយមូល ហេតុដែលនីហ្វៃ មានទុក្ខលំបាកជាខ្លាំង។

3. តើអ្នកបានរៀនអំពី បុគ្គលិកលក្ខណៈអ្វីខ្លះ អំពីមនុស្សទាំងនេះ មកពីបញ្ជីទាំងពីរនេះ?

4. ធ្វើការប្រៀបធៀប ពីអ្វីដែលលេមិន និងលេមយួលបាននិយាយថា ពួកគេបានដឹងនៅក្នុង នីហ្វៃទី1 16:38, 17:19, 22 ជាមួយនឹងអ្វីដែលពួកគេ បាននិយាយថា ពួកគេបានដឹងនៅក្នុង នីហ្វៃទី1 17:55។ តើអ្វីដែលបានផ្លាស់ប្តូរការយល់ដឹងរបស់ពួកគេ?

5. តើអ្នកបានរៀនអ្វីខ្លះ អំពីនីហ្វៃទី1 17 ដែលអាចជួយអ្នក កាន់តែដូចនីហ្វៃ ហើយមិនដូចលេមិន និងលេមយួល?

២ សរសេរបទពិសោធន៍នោះ នៅក្នុងពាក្យរបស់អ្នកផ្ទាល់

នីហ្វៃបានរំលឹកបងប្អូនរបស់គាត់ ពីរឿងរបស់ម៉ូសេ ដែលបានដឹកនាំកូនចៅ របស់អ៊ីស្រាអែលចេញ ពីស្រុកអេស៊ីប្ត ហើយប្រៀប ធ្យេបរឿងនោះ ជាមួយលីហៃ ដែលបានដឹកនាំគ្រួសាររបស់គាត់ ចេញពី យេរូសាឡិម (សូមមើល នីហ្វៃទី1 17:23–45)។

1. រំលឹកឡើងវិញនូវខទាំងនោះ ហើយសរសេរយ៉ាងតិចបួនចំណុច ពីភាពស្រដៀងគ្នា អំពីអ្វីដែលកើតឡើងចំពោះ ប្រជាជនរបស់ម៉ូសេ និងអ្វីដែលកើតឡើងចំពោះក្រុមដ៏តូចរបស់លីហៃ។

2. អានដោយយកចិត្តទុកដាក់ នៅក្នុង នីហ្វៃទី1 17:45 ហើយពន្យល់ថា តើអ្នកគិតថាវាមានន័យដូចម្តេចពាក្យថា "ចាប់អារម្មណ៍" ពីព្រះបន្ទូលរបស់ព្រះអម្ចាស់ ឬប្រាប់ពីពេលដែលអ្នកមានអារម្មណ៍ថា ព្រះគម្ពីរបាននិយាយមកកាន់អ្នក។

៣ ពន្យល់ពីរូបភាព

បងប្អូនរបស់នីហ្វៃ មិនបានសប្បាយចិត្ត ហើយមានតែព្រះចេស្តា នៃព្រះម្ចាស់តែប៉ុណ្ណោះ ដែលអាចរក្សាពួកគេ ដើម្បីកុំឲ្យពួកគេ យកជីវិតរបស់នីហ្វៃបាន។ នៅខាងស្តាំ គឺជាការពិពណ៌នាពីអ្វីដែលកើតឡើង នៅក្នុង នីហ្វៃទី1 17:48–55។ តើមានអ្វីកើត ឡើងនៅក្នុងរូបភាព ហើយចូរប្រាប់ថា តើរូបភាពនោះតំណាងឲ្យខមួយណា។

នីហ្វៃទី1 18

ការធ្វើដំណើរទៅកាន់ដែនដីសន្យា

តើអ្នកធ្លាប់ស្គាល់ អ្នកណាដែលកំពុងរងទុក្ខ ដោយមកអំពីកាបកម្មរបស់ពួកគេ តែពួកគេមិនចង់ប្តូរទេ? តើគេបានប្រែចិត្ត ហើយឬនៅ? តើគេបានតស៊ូប៉ុណ្ណាពីមុនគេផ្លាស់ប្តូរអត្តចរិតរបស់ពួកគេ? តើអ្នកណាខ្លះដែលត្រូវទទួលរងនូវឥទ្ធិពលពីគេ? នៅក្នុង នីហ្វៃទី1 18 លេមិន និងលេមយួល បានមានបទពិសោធន៍ដូច្នោះ។ ចូររកមើលអ្វីដែល ធ្វើឲ្យពួកគេប្រែចិត្ត។

ចូរកត់សំគាល់ផងដែរ ពីភាពរឹងរូសរបស់ពួកគេដែលធ្វើឲ្យប៉ះទង្គិច ដល់ក្រុមគ្រួសាររបស់ពួកគេ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 18

វិចិត្រ (ខ 1)—ខុសប្រក្រតី, ពិសេស

បានបង្កើត (ខ 7)—បានភ្ជាយជាឪពុករបស់គេ

ស្បៃង (ខ 8)—អាហារ និងសម្ភារៈផ្សេងទៀត

គ្រហឹមគ្រហែង (ខ 17)—និយាយចេញ

ចាស់ជរាទៅហើយ (ខ 17)—ចាស់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ ចេញពីសកម្មភាពដូចខាងក្រោម (ក–គ) នៅពេលដែលអ្នកសិក្សានៅក្នុង នីហ្វៃទី1 18។

ក សម្គាសត្វអង្គុម្នាក់

គ្រួសាររបស់លីហៃ បានរៀបចំខ្លួនជាស្រេច ដើម្បីធ្វើដំណើរ ដោយកប៉ាល់ដែលមានក្បួរក្បាច់ដ៏អស្ចារ្យ ទៅកាន់ដែន ដី សន្យាដែលពួកគេមិនដែលបានស្គាល់ពីមុន (នីហ្វៃទី1 18:1–7)។ បើសិនជាអ្នកជាអ្នកយកពត៌មាន ដែលបញ្ជូនឲ្យទៅសម្គាស សមាជិកគ្រួសាររបស់លីហៃ ពីមុនពួកគេ ធ្វើដំណើរ តើអ្នកគិតថា ពួកគេនឹងនិយាយអ្វី? ជ្រើសរើសមនុស្សបីនាក់ ចេញពី ក្រុមរបស់លីហៃ ហើយសួរសំនួរពីរ ដែលអ្នកនឹងសួរ ក្នុងនាមជាអ្នកយកសារពត៌មាន។ ហើយសរសេរអ្វីដែលអ្នកគិតថា មនុស្សទាំងនោះនឹងប្រាប់ ក្នុងការឆ្លើយចំលើយរបស់អ្នក។

ខ កុំឲ្យរំលងសេចក្តីរាយការណ៍សំខាន់ៗ

រឿងនៃការធ្វើដំណើរ របស់គ្រួសាររបស់លីហៃ ទៅកាន់ដែនដីសន្យា គឺគួរឲ្យចាប់អារម្មណ៍ណាស់ ហើយមានសេចក្តីរាយការណ៍ សំខាន់ៗ ដែលងាយរំលង។ បន្ទាប់ពីអាន នីហ្វៃទី1 18 ឆ្លើយនូវសំនួរដូចខាងក្រោមៈ

1. តើសមាជិកថ្មី នៃគ្រួសាររបស់លីហៃត្រូវបានប្រាប់នៅពេលណា នៅក្នុងជំពូកទី1?

2. ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់ ទុក្ខឲ្យនីហ្វៃមានការលំបាកយ៉ាងយូរដល់ដាងធ្វើឲ្យគាត់មានសេរីភាព ដោយប្រើអព្ភូតហេតុ ដូចទ្រង់បានធ្វើនៅក្នុងនីហ្វៃទី1 7:18, 16:39 ហើយ 17:48?

3. តើមានអ្វីកើតឡើង នៅក្នុងជំពូកនេះ ដែលចំពេញការព្យាករណ៍ របស់ព្រះអម្ចាស់នៅក្នុង នីហ្វៃទី1 17:13?

ឥ ស្វែងរកមេរៀនសំរាប់ជីវិត

រឿងនៃការធ្វើដំណើរ តាមកប៉ាល់ ទៅកាន់ដែនដីសន្សា ក៏ជានិមិត្តសញ្ញា នៃជីវិតរបស់យើង នៅលើផែនដីនេះដែរ។ ឧទាហរណ៍ មនុស្សជាច្រើន ដូចជាបងឲ របស់នីហ្វៃនៅក្នុង នីហ្វៃទី1 18:9 បានគិតតែសេចក្តីត្រូវការខាងលោកិយ ហើយបាន បំភ្លេចព្រះ នឹងការពឹងអាស្រ័យរបស់ពួកគេ ទៅលើព្រះចេស្តាររបស់ទ្រង់។ ឆ្លើយនូវសំនួរដូចខាងក្រោម ដើម្បីបញ្ជាក់ថា រឿងនេះ អាចជាបទពិសោធន៍ដូចអ្វី ដែលយើងអាចជួបប្រទះ

1. តើអ្វីដែលនីហ្វៃ បានធ្វើចំពោះបងឲ របស់គាត់នៅក្នុងខទី10 គឺដូចគ្នានឹងសតិសម្បជញ្ញះ (ពន្លឺនៃព្រះគ្រីស្ទ) របស់យើង យ៉ាងដូចម្តេច?
2. តើគ្រីវិស័យ ដែលមិនដើរហើយមានព្យុះ គឺដូចគ្នានឹងអ្វីកើតឡើង ចំពោះយើងយ៉ាងដូចម្តេច នៅពេលយើង "ខ្ទះ" សតិសម្បជញ្ញ របស់យើង?
3. តើនីហ្វៃបានប្រៀបធៀប គ្រីវិស័យទៅនឹងជីវិត របស់យើងដូចម្តេច?
4. តើមានអ្វីកើតឡើង នៅពេលដែលនីហ្វៃ ធ្វើការអធិស្ឋាន? តើអ្នកអាចអនុវត្តវា ទៅនឹងជីវិតរបស់អ្នកយ៉ាងដូចម្តេច? (ជាពិសេសសូមមើលនៅខ 1–3, 21–23)។
5. តើនីហ្វៃបានពិពណិនាអំពីអត្ថចរិតឈ្លើយ របស់បងឲគាត់ នឹងកូនឲរបស់អ៊ីសម៉ាអែស និងប្រពន្ធ របស់ពួកគេ នៅក្នុង (ខ 9) ហើយតើវាអាចប្រៀបធៀបជាមួយអត្ថចរិត និងការបាត់បង់នូវការគោរពគ្នាសព្វថ្ងៃនេះ យ៉ាងដូចម្តេច?

នីហ្វៃទី1 19

"ដើម្បីបញ្ជុះបញ្ជូល ពួកគេឱ្យបានច្រើន ថែមទៀត ឱ្យជឿដល់ព្រះអម្ចាស់"

ហេតុអ្វីមនុស្សខ្លះ ស្រឡាញ់ព្រះគម្ពីរ ហើយស្វែងរកសម្បត្តិ នៃការកំសាន្តចិត្ត, សេចក្តីសង្ឃឹម, និងការលើកទឹកចិត្ត នៅក្នុង ព្រះគម្ពី អំឡុងពេលដែលអ្នកផ្សេងទៀត គ្មានការចាប់អារម្មណ៍ពីព្រះគម្ពីរ ឬគិតថាវាគ្មានប្រយោជន៍? នីហ្វៃបានប្រាប់យើងថា អ្វីដែលគាត់បាន សរសេរ គឺមិនមែនផ្តាប់ចិត្តលោកិយទេ តែដើម្បីសព្វព្រះហរទ័ញ ដល់ព្រះហើយ "គាប់ចិត្តដល់អស់អ្នកណា ដែលមិនមែនជារបស់ផង លោកិយនោះវិញ" (នីហ្វៃទី1 6:5)។ ហេតុអ្វីអ្នកគិតថា មនុស្សដែលមិនមានចិត្តគិតតែវត្ថុ នៅជីវិតនេះ នោះមាន ការចាប់អារម្មណ៍ បន្តិចបន្តួចទៅ លើជីវិតអស់លក្សជានិច្ច? នៅពេលដែលអ្នកសិក្សានៅក្នុង នីហ្វៃទី1 19 រកមើលអ្វីឲដែល ព្រះអម្ចាស់បានធ្វើនិង កំពុងតែធ្វើ ដើម្បីលើកទឹកចិត្ត កូនចៅរបស់ទ្រង់ ឱ្យមកផ្ទះនិងរស់នៅជាមួយទ្រង់ ម្តងទៀត។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 19

ឆ្លាក់ត្រាទុក (ខ 2)—បានកើតឡើង

ធ្វើខុស (ខ 6)—ធ្វើឱ្យមានកំហុស

ផ្នូរ (ខ 10)—កន្លែងបញ្ជុះសព (ជាផ្នូរ រឺជាគុហាបញ្ជុះសព)

ប្រេះចេញ (ខ 12)—រហែកជាផ្នែកឲ

វាយ (ខ 13)—ទុក្ខវេទនា, ទណ្ឌកម្ម

ទីផ្សេលគ្មះជាទីទំនៀល (ខ 14)—មនុស្សដែលទទួលការធ្វើទុក្ខបុកម្នេញ

នីហ្វៃទី1 19:1–6—ផ្ទាំងទាំងពីរផ្នែក

នៅក្នុងនីហ្វៃទី1 9 នីហ្វៃបានសរសេរថា គាត់បានធ្វើផ្ទាំងពីរផ្នែក។ ផ្ទាំងដំបូង គឺជាផ្ទាំងធំរបស់នីហ្វៃ ដែលគាត់កត់ត្រាពឹស្តារ ពីប្រវត្តិរបស់ប្រជាជនរបស់គាត់ ផ្នែកទីពីរ គឺជាផ្ទាំងតូចរបស់នីហ្វៃ ដែលជាប្រវត្តិបញ្ជីពិសិដ្ឋនៃសាសនា។ នៅក្នុងនីហ្វៃទី1 19 ឃ្លាដែលថា "ផ្ទាំងដំបូង" ឬ "ផ្ទាំងផ្សេងទៀត" គឺជាផ្ទាំងធំរបស់នីហ្វៃ ហើយឃ្លាដែលថា "ផ្ទាំងទាំងនេះ" គឺជាផ្នែកតូច (សូមមើល "ប្រភពសំខាន់ សំរាប់ព្រះគម្ពីរមរមន" ទំព័រ 12)។

នីហ្វៃសង្ឃឹមថា នៅអនាគត កូនចៅជំនាក់ក្រោយអាចស្វែងរកការសរសេរទាំងនោះ ដែលអាចជួយពួកគេ ខិតទៅជិតព្រះគ្រីស្ទ។

នីហ្វៃទី1 19:10—តើស៊ីណុក នីអ៊ុម និងស៊ីណូស ជានរណា?

នីហ្វៃបានដកស្រង់ពីស៊ីណុក នីអ៊ុម និងស៊ីណូស ជាព្យាការីនៅសម័យសញ្ញាចាស់ ដែលបានបញ្ជាក់យ៉ាងពិស្តារអំពីការព្យាករណ៍ នៃព្រះគ្រីស្ទ ដែលត្រូវបានកត់ត្រានៅក្នុងផ្ទាំងលង្ហិន។ សក្ខីភាពរបស់ពួកគាត់មិនមាននៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលយើង មានសព្វថ្ងៃនេះទេ។ ការសរសេររបស់ពួកគាត់គឺ មាននៅក្នុង "ភាគដ៏ច្បាស់ ហើយពិសេសឲ" ខ្លះឲ ដែល "សាសនាចក្រ ដ៏ធំនិងគួរឱ្យខ្ពើមឆ្អើម" បានដកយកសេចក្តីពិតចេញ (នីហ្វៃទី1 13:26)។ បើគ្មានព្រះគម្ពីរមរមនទេ នោះយើងមិនស្គាល់ ព្យាការី ដ៏ស្មឹគ្រស្មោះ និងការព្យាករណ៍របស់ពួកគេ នៃសម័យព្រះគម្ពីរសញ្ញាចាស់ទេ។

ការសិក្សាព្រះគម្ពីរ

ពេលអ្នកអាននៅក្នុង នីហ្វៃទី1 19 ធ្វើសកម្មភាពពីរ ចេញពីសកម្មភាពដូចខាងក្រោម (ក–គ)។

ឥ ធ្វើបញ្ជី "ភាគដ៏ច្បាស់ ហើយពិសេសឲ"

ព្រះអម្ចាស់បានបញ្ជានីហ្វៃ ឱ្យបញ្ជូលផ្ទាំងទីពីររបស់គាត់ (ផ្ទាំងតូច) ដែលជាភាគសំខាន់ ហើយពិសេសឲជាច្រើន ដែលមានការ បាត់បង់ពីព្រះគម្ពីរបឺប (សូមមើលនីហ្វៃទី1 19:3 និងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ")។

1. រំលឹកឡើងវិញនៅក្នុង នីហ្វៃទី1 19:8–14 និងធ្វើបញ្ជីពីសេចក្តីពិត ដែលនីហ្វៃបានរៀនអំពីកំណើត ជីវិត និងការសុគតរបស់ ព្រះយេស៊ូវគ្រីស្ទ និងអ្វីដែលកើតឡើង ចំពោះវង្ស អ៊ីស្រាអែល បន្ទាប់ពីការសុគតរបស់ទ្រង់។
2. ចំពោះសេចក្តីពិត ដែលអ្នកបានសរសេរ បញ្ជាក់ពីអ្វីដែលនីហ្វៃ បាននិយាយថា គាត់បានរៀនពីទេវតា និងពីអ្វីដែល គាត់បាន រៀន ពីការសរសេររបស់ ស៊ីណុក នីអ៊ុម ស៊ីណូស។

២ ធ្វើការវិភាគ ពីការណ៍ទាំងឡាយដែលអាចខុសគ្នា

ពិចារណាពីការព្យាករណ៍ដែលពិសេសឲ្យ អំពីជីវិតព្រះយេស៊ូវ ដែលព្រះគម្ពីរមរមនបានស្គារឡើងវិញ (សូមមើលនីហ្វៃទី1 19:8–14)។ តើអ្នកគិតថា ការជ្បើរបស់សាសន៍ យូដា និងគ្រីស្ទានផ្សេងទៀត អាចខុសគ្នាយ៉ាងដូចម្តេច បើសេចក្តីពិតទាំងនោះ នៅតែមាននៅក្នុងព្រះគម្ពីរសញ្ញាចាស់របស់យើង?

៣ ការទន្ទេញព្រះគម្ពីរ—នីហ្វៃទី1 19:23

នីហ្វៃបានអានរឿងជាច្រើន ទៅកាន់គ្រួសាររបស់គាត់ ដែលជាការដកស្រង់ចេញពី ការសរសេររបស់ព្យាការីអេសាយ។ អានទៅ ក្នុងនីហ្វៃទី1 19:22–24 និងពន្យល់ហេតុអ្វីនីហ្វៃ ចង់ឱ្យក្រុមគ្រួសាររបស់គាត់ (និងពួកយើង) យល់ពាក្យរបស់អេសាយ។

នីហ្វៃទី1 20–21

សារដំណឹងមកពីព្យាការីអេសាយ

នីហ្វៃបានអាន ការព្យាករណ៍របស់ព្យាការី អេសាយទៅកាន់ប្រជាជនរបស់គាត់ ដើម្បី "បញ្ចុះបញ្ចូលពួកគេឱ្យបានច្រើនថែម ទៀត ឱ្យជ្បើដល់ព្រះអម្ចាស់ ជាព្រះដ៏ប្រោសលោះពួកគេ" (នីហ្វៃទី1 19:23)។ នៅក្នុងនីហ្វៃទី1 20–21 ត្រូវបានកត់ត្រា អំពីការព្យាករណ៍សំខាន់ៗ ទាំងនោះរបស់អេសាយ ចេញពីផ្ទាំងលង្ហិន ដែលស្រដៀងទៅនឹងការព្យាករណ៍នៅក្នុងព្រះគម្ពីរសញ្ញា ចាស់។ នៅពេលដែលអ្នកអានជំពូកទាំងនេះ ចូររកមើលពីអ្វី ដែលព្យាការីអេសាយ បានបង្រៀនអំពី វង្សអ៊ីស្រាអែល។ ហេតុអ្វីពួកសាសន៍អ៊ីស្រាអែល ត្រូវទទួលទុក្ខលំបាក អស់ជាច្រើនសតវត្សរ៍ហើយតើព្រះអម្ចាស់ធ្វើអ្វី ដើម្បីនាំយករាសស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ឱ្យត្រលប់មករកទ្រង់ម្តងទៀត? ជាផ្នែកមួយនៃ វង្សអ៊ីស្រាអែលសម័យថ្មី យើងអាចឆ្លើយតប ពាក្យរបស់អេសាយ ក្នុងជីវិតរបស់យើងបាន ផងដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 20

ស្បថ (ខ 1)—ការចុះសេចក្តីសញ្ញាកិច្ចសន្យា

ពួកគេពឹងផ្អែកទៅលើ (ខ 2)—ពឹងទៅលើ អាស្រ័យទៅលើ រក្សាសេចក្តីស្មោះត្រង់ទៅលើ

រឹងចចេស (ខ 4)—ក្សាលរឹង

ចិត្តក្សត់ (ខ 8)—គ្មានភាពស្មោះត្រង់ គ្មានភក្តីភាព

អ្នកបះបោរ (ខ 8)—អ្នកដែលប្រាចាកពីព្រះបញ្ញាតិ

ផ្អាក (ខ 9)—ផ្អាក, ពន្យាពេល, បន្លាយពេល

សំរង់ (ខ 10)—បានធ្វើឱ្យបរិសុទ្ធ

បានលាត (ខ 13)—បានលូកទៅ

ពួជ . . . ហើយផលដែលកើតមកនោះ (ខ 19)—កូនចៅ(កូនៗ ចៅៗ និងផ្សេងៗទៀត)

បំប្រេះ (ខ 21)—បំបែក

នីហ្វៃទី1 20:1—តើ "ទឹករបស់យូដា" គឺជាអ្វី?

អែលឌើរ ប្រ៊ីស អរ មិកខនយ៉ី បានសរសេរថាះ "ព្យាការីអេសាយបាននិយាយថា 'វង្សរបស់យ៉ាកុប' បាន 'ចេញ ពី*ទឹករបស់ យូដា*' (អេសាយ 48:1) សេចក្តីផ្លែង ដ៏គួរឱ្យចាប់អារម្មណ៍ចំពោះពួកបរិសុទ្ធថ្ងៃ ចុងក្រោយ នៅក្នុងចំណុចនោះ ដែលថា ពាក្យរបស់ព្យាការីអេសាយ ត្រូវបានកត់ត្រាទុកនៅលើ ផ្ទាំងលង្ហិន ដែលត្រូវបានបន្ថែមនៅឃ្លា '*ឬចេញពីទឹក នៃបុណ្យ ជ្រមុជទឹក*' (នីហ្វៃទី1 20:1) ដូច្នេះ គឺជាការរក្សាពីព្រះគម្ពីរសញ្ញាចាស់ដ៏សុទ្ធសាធស្តីពីពិធីបុណ្យជ្រមុជទឹក "(*Mormon Doctrine* ការសង្ខេប ជាលើកទីពីរ [1966], 832)។ នេះជាតំរូដ៏អស្ចារ្យនៃ "វគ្គសំខាន់ៗ និងពិសេស" សេចក្តីពិតត្រូវបានដកចេញពី ព្រះគម្ពីរប៊ីប (នីហ្វៃទី1 13:29)។

នីហ្វៃទី1 20:1–2—"ពួកគេហៅខ្លួនគេជាអ្នកក្រុងបរិសុទ្ធ"

ដូចដែលបានដកស្រង់ចេញពី នីហ្វៃទី1 20:1–2 ព្យាការីអេសាយ បានវាយផ្ទាលវង្សអ៊ីស្រាអែលដែលគេប្រកាសថា ធ្វើតាមព្រះអម្ចាស់ តែមិនគោរពតាមបញ្ញាតិទាំងឡាយរបស់ទ្រង់។ ពួកគេគិតថា ដោយសារពួកគេ គឺជាវាស្ត្រនៃសេចក្តីសញ្ញា និងរស់នៅក្នុងទីក្រុងបរិសុទ្ធ នៃយេរូសាឡិម នោះព្រះនឹងរក្សាពួកគេជានិច្ច។ ព្យាការីអេសាយ បានរំលឹកពួកគេថា វាមិនមែនជា *កន្លែង* ដែអ្នករស់នៅទេ តែជា*រឿប* ដែលអ្នករស់នៅវិញទេ តើដែលវាសំខាន់នោះ (សូមមើល ខ18–22)។ គោលការដូច គ្នានេះ នៅតែពិតក្នុងពេលបច្ចុប្បន្ន។

ផ្ទះរបស់ឌីពុកខ្ជុំ © Al Rounds

យេរូសាឡិម ទីក្រុងបរិសុទ្ធពីបូរាណ

នីហ្វៃទី1 20:3–8—"យើងបានថ្លែងប្រាប់ នូវការណ៍ដែលកន្លង . . .។ យើងបានបង្ហាញឱ្យអ្នកឃើញការណ៍ថ្មីទៀត"

ព្រះអម្ចាស់បានបង្ហាញភស្តុងតាង ឬមូលហេតុជាច្រើនដល់កូនចៅរបស់ទ្រង់ ដើម្បីឱ្យគេជ្បើដល់បន្ទូលរបស់ទ្រង់ និងព្យាការីរបស់ ទ្រង់។ នៅក្នុងនីហ្វៃទី1 20:3–8 ទ្រង់បានបង្ហាញនូវភស្តុតាងទាំងនោះ និងបានពន្យល់ពីហេតុអ្វីការព្យាករណ៍ទាំងនោះ សំខាន់។ តាំងពីពេលចាប់ផ្តើមព្រះ បានបើកសំដែង នូវព្រឹត្តកាណ៍ជាច្រើន ដែលនឹងកើតឡើងនៅ ក្នុងពេលអនាគតខាងមុខ។ គោលបំណងនៃការព្យាករណ៍ដ៏យូរលង់របស់ទ្រង់ គឺដើម្បីបង្កាពួកទុច្ចរិត កុំឱ្យគោរពដល់រូបសំណាក ឬក៏ព្រះក្លែងក្លាយ ដែល ផ្ទុយពីកិច្ចការដ៏អស្ចារ្យរបស់ទ្រង់ (សូមមើលខ 3–5)។ ព្រះទ្រង់ក៏បានបើកសំដែងផងដែរ ពីព្រឹត្តិការណ៍ ដែលកើតឡើងក្លាមៗ ដូច្នេះ ពួកទុច្ចរិតមិនអាចនិយាយ "ខ្ញុំដឹងថា" (សូមមើលខទី 6–8)។

នីហ្វៃទី1 20:14–17—ព្រះអម្ចាស់គាំទ្រ ព្យាការីរបស់ទ្រង់

ព្រះអម្ចាស់ស្រលាញ់ព្យាការីរបស់ទ្រង់ហើយ "គេនឹងធ្វើឱ្យព្រះបន្ទូលបានសំរេច ដែលគេបានថ្លែងប្រាប់ពួកគេ" (ខ 14)។ នៅក្នុងវិវរណៈសម័យនេះ ព្រះអម្ចាស់បានប្រកាសថាះ ទោះជាដោយសំលេងរបស់យើងផ្ទាល់ ឬក៏ដោយសម្លេងនៃ ពួកអ្នក បំរើរបស់យើងក្តី គឺដូចគ្នាដែរ (សូមមើល គ និង ស 1:38)។

នីហ្វៃទី1 21

អ្នកគង្វាល (ខ 1)—អ្នកគង្វាលចៀម នៅក្នុងករណីនេះគឺជាអ្នកដឹកនាំនៅក្នុងសាសនាយូដា

តាំងពីផ្ទៃ (ខ 1)—មុនពេលខ្ញុំចាប់កំណើត

បំពង់ព្រួញ (ខ 2)—បំពង់សំរាប់យូរផ្លែព្រួញ

ឥតប្រយោជន៍ និងបង់កំលាំង (ខ 4)—ត្មានអ្វីឲ្យទាំងអស់

ស្ពប់ខ្ពើម (ខ 7)—ស្ពប់ ស្ពប់យ៉ាងខ្លាំង

ចោលស្ងាត់ទុកជាកេរ្តិ៍មរតក (ខ 8)—ទទេ ឬកប់ទុក្ខកេរ្តិ៍មរតក

ចារិក (ខ 16)—កាត់ គូស ឬធ្វើឱ្យមានចំណាំ

ចង្ឈៀត (ខ 20)—តូចពេក ឬចង្ឈៀត នៅពេលដែលព្រះអម្ចាស់ប្រមូលផ្ទុំ កូនចៅរបស់ទ្រង់ ទៅសឹ៊យូន ពួកគេនឹងមានត្មាច្រើនឥតគណនា។

ដើររសាត់ព្រាត់ (ខ 21)—ត្មានគោលដៅ

នីហ្វៃទី1 21:1—ការសាងឡើងវិញដ៏មានសារៈសំខាន់ ចេញពីផ្ទាំងលង្ហិន

ប្រយោគទីមួយនៃការព្យាករណ៍ របស់ព្យាការីអេសាយ ត្រូវបានដកស្រង់នៅក្នុងនីហ្វៃទី1 21:1 គឺមិននៅក្នុងជំពូក ដែលទាក់ទង នៅក្នុងព្រះគម្ពីរនៃអេសាយទេ (សូមមើល អេសាយ 49:1)។ សំភារៈនេះគឺជា ភស្តុតាង នៅលើផ្ទាំងលង្ហិន ដែលនីហ្វៃបានប្រើ គែត្រូវបានបាត់ ចេញពីព្រះគម្ពីរ ប៊ីបយើងបច្ចុប្បន្ននេះ។ អេសាយ 49 (ឬ នីហ្វៃទី1 21)បានប្រាប់អំពី ការយាងមក នៃព្រះមែស៊ី និងការប្រមូលផ្ទុំ នៃវង្សអ៊ីស្រាអែល និងការនាំយកដំណឹងល្អ ទៅកាន់សាសន៍ដទៃ។ ដោយសារព្រះគម្ពីរមរមន យើងរៀនថា ដំណឹងនេះ គឺជាការណែនាំជាពិសេសទៅកាន់ សាសន៍អ៊ីស្រាអែល (ដូចជាត្រួសាររបស់លីហៃ) ដែលត្រូវបានបាត់ ដូចជាមែកដែល បាត់ចេញពីសាខាយ៉ាងណា នៃអ៊ីស្រាអែល ហើយបានខ្ចាត់ខ្ចាយទៅ។ យើងក៏បានរៀនផងដែរថា មូលហេតុនៃការខ្ចាត់ខ្ចាយ របស់ពួកគេ គឺមកពីអំពើទុច្ចរិតរបស់អ្នកដឹកនាំរបស់ពួកគេ នៅក្នុងយេរូសាឡិម។

នីហ្វៃទី1 21:1–9—តើអ្នកណាដែលព្រះបានហៅ តាំងពីមុនគាត់បានចាប់កំណើតមក?

ខទី 1–9 បានពិពណិនា ពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានហៅពីមុនការ ប្រសូត្ររបស់ទ្រង់ (សូមមើល ខ1) ជាពាក្យ ដែលកាត់ទំលុះបេះដូង របស់ពួកទុច្ចរិត ដូចជាដាវដ៏មុត (សូមមើលខ ទី 2) ជីវិតដែលមិនប្រឡាក់ជាត្ថព្រួញខាត់រលីង (សូមមើលខទី 2) ដែលជាជីវិតសំរាប់សាសន៍ដទៃ (សូមមើលខទី 6) និងត្រូវបានស្ពប់ដោយមនុស្ស (សូមមើលខ 7)។ ជីវិត របស់ព្យាការី នៅពេលខ្លះដូចជា គំរូ ឬបែបនានា ពីព្រះអង្គសង្គ្រោះ ខទាំងនេះអាចយកមកអនុវត្ន៍ចំពោះ ព្យាការីអេសាយ។ ខទាំងនោះក៏អាចអនុវត្តចំពោះ ព្យាការីយ៉ូសែប ស្មឹធផងដែរៈ

- *ទ្រង់បានត្រូវតែងតាំង តាំងពីមុនកំណើតលោកិយ។* ទ្រង់បានធ្វើទីបន្ទាលថាះ "មនុស្សត្រប់រូបដែលបានហៅ ឱ្យបង្រៀន ទៅកាន់ពិភពលោក គឺត្រូវបានតែតាំង នៅក្នុងការប្រជុំដ៏ធំ នៅក្នុងស្ថានសួគ៌ ដែលជាគោលបំណង ពីមុនផែនដីចាប់ផ្តើម។ ខ្ញុំត្រូវបានហៅចំពោះកិច្ចការនេះ នៅក្នុងការប្រជុំដ៏ធំនោះ។" (*Teachings of the Prophet Joseph Smith,* 365, សូមមើល នីហ្វៃ ទី2 3:7–15 ផងដែរ)។
- *បន្ទូលរបស់ទ្រង់ គឺមុត ឯជីវិតរបស់ទ្រង់គឺជា ត្ថព្រួញដែលខាត់រលីង។* ទ្រង់បានមានបន្ទូលថាះ "យើងដូចជាថ្ម ដ៏ធំហើយធ្ងន់ ដែលរមៀលធ្លាក់ចុះពីលើភ្នំ ដ៏ខ្ពស់ ហើយការខាត់រលីង ដែលយើងបានទទួល គឺនៅពេលជ្រុងនោះប៉ះនឹងអ្វីមួយទៀត ក្ងដកម្ម ជាមួយនឹងអ្វីមួយផ្សេងទៀត ការបង្ខិតបង្ខំ ប្រឆាំងជាមួយនឹងសាសនា ដោយសង្ឃក្លែងក្លាយ . . . រួមទាំងតុលាការ និងចៅក្រម ស៊ីសំណូក . . . ត្រូវបានគាំទ្រ ដោយមនុស្សអាក្រក់ ការប្រមាថព្រះ មនុស្សពុករលួយ អសីលធមិខាងភេទ . . . ហើយបានទរក គឺនៅគ្រប់ជ្រុងទាំងអស់។ នៅពេលនោះយើង នឹងក្លាយជាត្ថព្រួញដែលខាត់រលីង នៅក្នុងបំពង់ព្រួយ របស់ព្រះ ដ៏មានមហិទ្ធិឬទ្ធិ (*Teachings of the Prophet Joseph Smith,* 304)។
- *ទ្រង់ត្រូវបានបញ្ជូន ឱ្យធ្វើជាពន្លឺដល់សាសន៍ដទៃ។* ព្រះអម្ចាស់បានប្រកាស់ទៅកាន់គាត់ថាះ តំណរនេះនឹងទទួលពាក្យ របស់យើងដោយសារអ្នក (សូមមើល ត និង ស 5:7–10 សូមមើលផងដែរ ត និង ស 86:11)។
- *ទង់ត្រូវបានស្ពប់ដោយមនុស* ទេវតាមរ៉ូណៃបានព្យាករណ៍ថា ទាំងមនុស្សល្អ និងមនុស្សអាក្រក់ នឹងត្រូវថ្លែងប្រាប់ដោយ និយាយ យ៉ូសែប ក្នុងចំណោមមនុស្សទាំងអស់ (សូមមើល ប្រវិត្ត—យ៉ូសែប ស្មឹធ 1:33)។

ការសិក្សាព្រះគម្ពីរ

នៅពេលដែលអ្នកសិក្សានៅក្នុង នីហ្វៃទី1 20–21 ធ្វើសកម្មភាពពីរ (ក–ង) ចេញពីសកម្មភាពដូចខាងក្រោម។

ក ស្វែងរកចំលើយ

អេសាយបានយើញ ការធ្លាក់ចុះនៃកូនចៅនៃអ៊ីស្រាអែល។ គាត់បានប្រាប់ ដល់ពួកគេ ឱ្យកែប្រែចិត្ត ដើម្បីពួកគេអាច អនុវត្ត កិច្ចការដែលព្រះអម្ចាស់ បានប្រទានឱ្យពួកគេ ដើម្បីពួកគេបានទទួលពរជ័យ ពីទ្រង់។ សូមអាន នីហ្វៃទី1 20:1–11 20 ហើយឆ្លើយសំនួរដូចខាងក្រោមៈ

1. តើព្រះអម្ចាស់បានធ្វើអ្វី ដើម្បីបង្ហាញដល់រាស្ត្ររបស់ទ្រង់ថា ទ្រង់គឺជានរណា? (សូមមើលខ 3–8 មើលផងដែរ "ការយល់ដឹង អំពីព្រះគម្ពីរ" (នីហ្វៃទី1 20:3–8)។
2. តើហេតុអ្វីអ្នកគិតថា អេសាយប្រើពាក្យចំរឹងដែក (ខ 4)ដើម្បីពិពណិនា ពីកូនចៅរបស់អ៊ីស្រាអែល?
3. ទោះបីជាមនុស្សបាន បះបោរនៅពេលមុន តើព្រះអម្ចាស់បានមានបន្ទូល ថាទ្រង់នឹងធ្វើអ្វីដើម្បីពួកគេ? ហេតុអ្វី? (សូមមើលខ 9–11)។
4. តើព្រះអម្ចាស់បានប្រាប់ប្រជាជន ថាពួកគេនឹងត្រូវធ្វើអ្វី? (សូមមើល ខ 20 សូមមើលផងដែរ នៅ ម៉ូសាយ 26:29–30)។
5. តើការបង្រៀនរបស់អេសាយនេះ អាចអនុវត្តនៅក្នុងសម័យរបស់យើងបាន យ៉ាងដូចម្តេច "ទុកជាប្រយោជន៍ និងការចេះដឹង ដល់យើង" (នីហ្វៃទី1 19:23)?

ខ ពន្យល់ពីភាពស្រដៀងគ្នា

នៅក្នុង នីហ្វៃទី1 20:11–17 ព្រះអម្ចាស់បានប្រកាសថា ត្ថនាទីរបស់ទ្រង់ គឺជាអង្គបង្កបង្កើត និងអង្គសង្គ្រោះ។ ខទាំងនេះ ក៏បានប្រាប់ផងដែរ អំពីសេចក្តីស្រលាញ់ និងការគាំទ្ររបស់ទ្រង់ចំពោះ ព្យាការីរបស់ទ្រង់។ នៅក្នុងខ 18–22 អេសាយបាន ពិពណិនាពីអ្វីដែលនឹងត្រូវកើតឡើង ចំពោះ កូនចៅនៃអ៊ីស្រាអែល នៅពេលដែលពួកគេបានប្រតិបត្តិតាមយ៉ាងពិតប្រាកដ។ បន្ទាប់មក គាត់បាន អំពាវនាវឱ្យពួកគេប្រែចិត្ត។

1. រំលឹកឡើងវិញ នីហ្វៃទី1 20:18–22 ហើយពន្យល់ពីភាពស្រដៀងគ្នា (ការប្រៀបធៀប ការប្រើ *ដូច* ឬ *ដូចជា*) អេសាយ បានប្រើ—ទន្លេ, ទឹករលក ខ្សាច់ និងត្រួស—ដើម្បីពិពណ៌នាពីកិច្ចសន្យា របស់ព្រះអម្ចាស់ចំពោះអ្នក ដែលមានចិត្តស្ម័គ្រស្មោះ។

2. អ្នកគិតថា ហេតុអ្វីបានជាពួកទុច្ចរិត គ្មានសេចក្តីសុខសាន្ត? (ខ 22)។

ក ការព្យាករណ៍ អាចត្រូវបានបំពេញតាមរបៀបច្រើនជាងមួយ

លក្ខណៈព្យាករបស់អេសាយជាច្រើនគឺថា ការព្យាករណ៍នោះមានការអនុវត្ត និងការបំពេញច្រើនជាងមួយ។

1. សិក្សានៅក្នុង នីហ្វៃទី1 21:1–10 ហើយពន្យល់ ពីរបៀបដែល ខទាំងនេះបានពិពណ៌នាអំពីព្រះយេស៊ូវគ្រីស្ទ។

2. ពន្យល់ដងដែរថា តើខទាំងនេះ ពិពណ៌នាពីព្យាការីយ៉ូសែប ស៊្មីធយ៉ាងដូចម្តេច (សូមមើលវគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ”)។

ខ តើអ្នកអាចចងចាំ ព្រះអង្គសង្គ្រោះដោយរបៀបណា?

1. នៅពេលដែល ព្រះអម្ចាស់មិនអាចប្រទានពរដល់សាសន៍ អ៊ីស្រាអែល (ស៊ីយ៉ូន)ដោយសារ ប្រជាជនមិនប្រតិបត្តិតាម តើប្រជាជនដឹងថា មានអ្វីកើតឡើង? (សូមមើលនីហ្វៃទី1 21:14)។

2. តើព្រះអម្ចាស់បានមានព្រះបន្ទូល ពីអ្វីដែលតែងតែ ធ្វើឱ្យទ្រង់ចាំពីប្រជាជនរបស់ទ្រង់? (សូមមើល ខទី16)។

3. សរសេរកថាខ័ណ្ឌ ពន្យល់ពីអ្វីដែលអាចជួយអ្នក ឱ្យចងចាំព្រះអង្គសង្គ្រោះ ទាំងពេលនៅក្នុងព្រះវិហារ និងនៅពេល ផ្សេងៗ ទៀត។

“ខ្ញុំស្រឡាញ់ស្រាអែលណាស់ យើងមិនដែលភ្លេចអ្នកឡើយ”

គ តំរៀបគំនិតតាមលំដាប់លំដោយ

នៅក្នុង នីហ្វៃទី1 21:22–26 កិច្ចសន្យារបស់អេសាយថា ព្រះអម្ចាស់នឹងសង្គ្រោះរាស្ត្ររបស់ទ្រង់។ នៅបន្ទាប់តទៅនេះគឺជា គំនិតដ៏សំខាន់ៗជាច្រើន មកពីខទាំងនេះ។ រៀបចំគំនិតទាំងនេះ ឱ្យតាមលំដាប់លំដោយ ដែលមាននៅក្នុងសារដំណឹងនេះ។

- ព្រះអម្ចាស់នឹងបញ្ឈប់មនុស្ស ដែលមានអំពើបាប និងមនុស្សទុច្ចរិត ចូលក្នុងការឃុំឃាំង។
- មនុស្សដែលមានឥទ្ធិពល និងព្រះវិញ្ញាណរបស់ព្រះ នឹងអាចជួយដល់សាសនាចក្រ។
- មនុស្សគ្រប់រូបនឹងស្គាល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ។
- ព្រះអម្ចាស់នឹងច្បាំងជាមួយ អ្នកដែលប្រឆាំងជាមួយនឹងសាសនាចក្រ។
- អស់អ្នកណាដែលទុកចិត្តទៅលើព្រះអម្ចាស់នឹងមិនភ័យខ្លាចចំពោះដំណឹងល្អឡើយ។
- ព្រះអម្ចាស់នឹងសាង សាសនាចក្ររបស់ទ្រង់ឡើងវិញនាក្នុងចំណោមពួកសាសន៍ដទៃ ដែលជាមាត្រដ្ឋាន របស់មនុស្សសុចរិត ចំពោះពិភពលោក។
- ជនណាប្រឆាំងជាមួយនឹងសាសនាចក្រនឹងបំផ្លាញខ្លួនឯង។

នីហ្វៃទី1 22
ព្រឹត្តិការណ៍នៅថ្ងៃចុងក្រោយ

នីហ្វៃបានដឹងថា ពាក្យរបស់អេសាយ ពិបាកយល់ដល់មនុស្សមួយចំនួន។ ដាក់ស្តែង គ្រួសាររបស់នីហ្វៃផ្ទាល់ បានសួរ នីហ្វៃ ឱ្យពន្យល់ ពីការដកស្រង់នៅក្នុង នីហ្វៃទី1 20–21 (សូមមើល នីហ្វៃទី1 22:1)។ នៅពេលដែលអ្នកអាននៅក្នុងនីហ្វៃ ទី1 22 កត់ចំណាំ ពីការពន្យល់របស់នីហ្វៃ ពីសេចក្តីពិតដ៏សំខាន់ៗ ដែលបានរកឃើញ នៅក្នុង នីហ្វៃទី1 20–21។ ជាទូទៅ កត់ចំណាំ ពីអ្វីដែលនីហ្វៃ បានទំនាយអំពីការខ្ចាត់ខ្ចាយនៃវង្សអ៊ីស្រាអែល និងភូនាទីរបស់សាសន៍ដទៃ នៅក្នុងការប្រមូល ផ្តុំរបស់អ៊ីស្រាអែល នៅថ្ងៃចុងក្រោយ។ ចូរចងចាំថា ទោះបីជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ សព្វថ្ងៃនេះ ជាវង្សអ៊ីស្រាអែល ដោយសារព្រះជ ឬដោយសារកិច្ចសន្យា គឺត្រូវបានរាប់បញ្ចូលជាមួយនឹង “សាសន៍ដទៃ” ដែលបានបញ្ជាក់ពីភូនាទី នៃការ ប្រមូលផ្តុំនៃវង្សអ៊ីស្រាអែល នៅក្នុងជំពូកនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី1 22

ថ្លែង (ខ 2)—បានបង្ហាញ បានធ្វើឱ្យដឹង

លាតព្រះពាហុ (ខ 10)—បង្ហាញអំណាចរបស់ទ្រង់

ទីអាប់អ្ហរ (ខ 12)—ស្ថានភាពដែលមិនអាចយល់

ធ្វើទុកដាក់ (ខ 14)—អន្តរាក់ ការចាប់បាន

អនុវត្តសេចក្តីជំនុំជំរះ (ខ 21)—អនុវត្តសេចក្តីជំនុំជំរះ

អំណាចឥទ្ធិឫទ្ធិ (ខ 24)—អំណាច ការគ្រប់គ្រង សិទ្ធិអំណាច

នីហ្វៃទី1 22:8—តើ “កិច្ចការដ៏អស្ចារ្យ” អ្វីខ្លះដែល ព្រះអម្ចាស់នឹងធ្វើនៅថ្ងៃចុងក្រោយ?

នៅក្នុងប្រវត្តិដ៏យូរលង់ភាគច្រើន កូនចៅនៃអ៊ីស្រាអែល មិនមានសេចក្តីជំនឿទៅលើព្រះដែលបានចាត់ទុកពួកគេថា ជាប្រជាជនជំរើសរបស់ទ្រង់ឡើយ។ ចំពោះពរជ័យ ពួកគេចង់បានពរជ័យ ផ្នែកលោកិយជាជាងពរជ័យតាមរបៀបព្រះ។ ជាលទ្ធផល ពួកគេភាគច្រើនត្រូវបាន ខ្ចាត់ខ្ចាយនៅក្នុងពិភពលោក ហើយបាត់បង់អត្តសញ្ញាណរបស់ពួកគេ។ កូនចៅរបស់លីហៃ គឺជាឧទាហរណ៍ជាក់ស្តែង ដែលគ្រួសារតែមួយ ត្រូវបានខ្ចាត់ខ្ចាយ ហើយមិនចាំអតសញ្ញាណរបស់ពួកគេ។ ពួកគេបានដឹងថា ពួកគេជានរណា។ កិច្ចការដ៏អស្ចារ្យ នាថ្ងៃចុងក្រោយ គឺដើម្បីប្រមូលផ្តុំ នៃកូនចៅជាច្រើន របស់អ៊ីស្រាអែលដែលសុខចិត្ត ត្រឡប់មករកព្រះអម្ចាស់វិញ។ ទោះបីជាសមាជិកនៃសាសនាចក្រសព្វថ្ងៃនេះ ជាវង្សអ៊ីស្រាអែល នីហ្វៃបានហៅពួកយើងថា សាសន៍ដទៃ ព្រោះយើងចេញពីជាតិសាសន៍ជាច្រើន។

ការសិក្សាព្រះគម្ពីរ

ពេលអ្នកសិក្សានៅក្នុង ទីហ្សៀទី1 22 ធ្វើសកម្មភាពពីរ ចេញពីសកម្មភាពដូចខាងក្រោម (ក–ឃ)។

ក ការខ្ចាត់ខ្ចាយនៃអ៊ីស្រាអែលៈ នរណា កន្លែងណា ពេលណា ហើយហេតុអ្វី?

ពាក្យរបស់អេសាយ ដែលទំនាយអំពីការខ្ចាត់ខ្ចាយ នៃវង្សអ៊ីស្រាអែល គឺត្រូវបានរកឃើញនៅក្នុង ទីហ្សៀទី1 21:1។ ទីហ្សៀបាន ពន្យល់បន្ថែមទៀត អំពីការខ្ចាត់ខ្ចាយនោះ នៅក្នុងទីហ្សៀទី1 22:3–5។ សង្ខេបពត៌មានបន្ថែម ដែលយើង បានរៀនពី ការខ្ចាត់ខ្ចាយ ពីទីហ្សៀ។ កុំភ្លេចពន្យល់ គឺអ្នកណា ដែលបានខ្ចាត់ខ្ចាយ ពេលណា ហើយកន្លែងណា ដែលពួកគេបានខ្ចាត់ខ្ចាយ ហើយហេតុអ្វី។

ខ ផ្គូរផ្គងគំនិតជាមួយនឹងខគម្ពីរ

នៅក្នុង ទីហ្សៀទី1 21:22, អេសាយបានទំនាយពីតនាទី របស់សាសន៍ដទៃ នៅក្នុងការប្រមូលផ្តុំនៃវង្សអ៊ីស្រាអែល។ នៅក្នុង ទីហ្សៀទី1 22 ទីហ្សៀបានឱ្យយើងនូវ ពត៌មានបន្ថែម អំពីការប្រមូលផ្តុំ។ សរសេរនូវសេចក្តីថ្លែង ដូចខាងក្រោម នៅក្នុងស្បៃភៅ សរសេររបស់អ្នក ហើយបន្ទាប់ពីសរសេររួច កត់ខទាំងនេះចេញពី ទីហ្សៀទី1 22:6–12 ដែលមានទំនាក់ទំនងជាមួយនឹង គំនិតទាំងអស់នេះ:

- អំណាចរបស់ព្រះអម្ចាស់ គឺសំខាន់សំរាប់សាសន៍ដទៃ ដើម្បីប្រទានពរដល់ប្រជាជនទាំងអស់ ដោយសារដំណឹងល្អ។
- ទ្រព្យសម្បត្តិ និងភាពភាពរុងរឿងរបស់សាសន៍ដទៃ នឹងត្រូវបានប្រើជាជំនួយ ដល់កិច្ចការអ្នកផ្សាយសាសនា ដែលជាតំរូវការនៃ ការប្រមូលផ្តុំ ការខ្ចាត់ខ្ចាយនៃវង្សអ៊ីស្រាអែល។
- អ៊ីស្រាអែលនឹងប្រមូលផ្តុំ ដោយការបែមកយល់ដឹង អំពីព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអង្គសង្គ្រោះរបស់ពួកគេ។
- សាសន៍ដទៃជាច្រើននឹងធ្វើឱ្យកូនចៅរបស់លីហៃខ្ចាត់ខ្ចាយ។
- សាសន៍ដទៃ នឹងប្រសិទ្ធពរដល់វង្សនៃអ៊ីស្រាអែលទាំងមូល ដោយការបង្រៀនដំណឹងល្អដល់ពួកគេ។
- ព្រះអម្ចាស់នឹងទាំយកដំណឹងល្អ ទៅដល់សាសន៍ដទៃជាច្រើន។ ជាតិទាំងនោះនឹង ត្រឡប់ទៅជាពរជ័យដល់កូនចៅរបស់លីហៃ ដោយការចែកចាយដំណឹងល្អជាមួយពួកគេ។
- សេចក្តីសញ្ញានៃព្រះអម្ចាស់នឹងត្រូវបើកសំដែង ទៅកាន់ពិភពលោក តាមរយៈអំណាចរបស់ព្រះអម្ចាស់។

គ សរសេរក្បាលរឿងសារពត៌មាន

នៅក្នុង ទីហ្សៀទី1 22:13–18 ទីហ្សៀបានពិពណ៌នា ពីសេចក្តីជំនុំជំរះ ដែលនឹងមានចំពោះមនុស្ស ទុច្ចរិត នៅថ្ងៃចុងក្រោយ។ រាល់ខនីមួយៗ សរសេរក្បាលរឿងសារពត៌មាន ដែលសង្ខេបពីព្រឹត្តិការណ៍ ដែលទីហ្សៀបានពិពណ៌នា។

ឃ ធ្វើការប្រៀបធៀប

ទីហ្សៀបានពន្យល់ពីភាពខុសគ្នាខ្លះៗ រវាងអ្វីដែលនឹងកើតឡើង ចំពោះមនុស្សសុចរិត នឹងអ្វីដែលនឹងកើតឡើង ជាមួយនឹង មនុស្សទុច្ចរិតនៅថ្ងៃចុងក្រោយ។

1. សិក្សានៅក្នុង ទីហ្សៀទី1 22:16–26 នឹងធ្វើបញ្ជី កិច្ចសន្យាចំពោះមនុស្សសុចរិត។ ហើយធ្វើបញ្ជីមួយទៀត ពីទណ្ឌកម្ម ចំពោះមនុស្សទុច្ចរិត។
2. អាននៅក្នុង ទីហ្សៀទី1 22:28–31 ហើយពន្យល់ ពីអ្វីដែលទីហ្សៀចង់ឱ្យយើង រៀនពីអ្វីដែលគាត់បានសរសេរ។

ព្រះគម្ពីរនីហ្វៃទីពីរ

នីហ្វៃទី2 ចាប់ផ្តើមដារត្រួចឆ្នាំ បន្ទាប់ពីគ្រួសាររបស់លីហៃ បានចាកចេញពីយេរូសាឡិម និងបន្ទាប់ពីពួកគេបានមកដល់ ដែនដី សន្យា។ នៅក្នុងជំពូកបួនជំពូង នីហ្វៃបានកត់ត្រា ពាក្យណែនាំចុងក្រោយរបស់ឪពុកគាត់ មុនពេលគាត់ស្លាប់។ នៅពេលដែលអ្នក អានទៅក្នុង នីហ្វៃទី2 កត់សំគាល់ពីអ្វីដែលកើតឡើងទៅកាន់ក្រុមគ្រួសាររបស់គាត់ បន្ទាប់ពីលីហៃបានស្លាប់។

ការប្រឹក្សារបស់លីហៃ នៅក្នុង នីហ្វៃទី2 1 គឺមានអត្ថន័យជាពិសេសចំពោះលេមិន និងលេមយួល។ ពីមុនអ្នកអាន នៅក្នុង ជំពូកនោះ ចូរគិតពីអ្វីដែលអ្នកប្រហែលជាចង់និយាយ ទៅកាន់លេមិន និងលេមយួល បើសិនអ្នកជា ឪពុកម្តាយ របស់ពួកគេ។ សំគាល់ពីអ្វីដែលលីហៃបាននិយាយ និងពិចារណាពីអ្វីដែលធ្វើឱ្យអ្នក គិតថាវាប្រហែលជាអាចកើតឡើង ចំពោះកូនប្រុស របស់គាត់។



ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 1

ប៉ាយប៉ាច់ដល់ (ខ 1)—រំលឹក និយាយលឿឲ

ទោះបីបានឆ្លងកាត់ការវេទនា (ខ 5)—ទោះបីជាយើង បានប្រឈមមុខនិង ឧបសគ្គ និងការសាកល្បង

ធ្វើសេចក្តីសញ្ញា (ខ 5)—ធ្វើការសន្យាពិសិដ្ឋ

កេរ្តិ៍អាករ (ខ 5, 8–9)—កម្មសិទ្ធិឬទ្រព្យសម្បត្តិគ្រួសារ

ទុកសំរាប់តែ (ខ 7, 32)—ការរៀបចំជាពិសេស ឬ ការឧទិស្ឋសំរាប់គោលបំណងពិសិដ្ឋ

ជិះជាន់ (ខ 9)—បញ្ហា អន្តរាយ

ចុះអន់ថយ (ខ 10)—ការធ្លាក់ចុះយ៉ាងសែនឆ្ងាយ

ការធ្វើទោស (ខ 12)—ការធ្វើទណ្ឌកម្មព្រឹត្តិការណ៍ដែលបង្ហាញ ពីសេចក្តីជុំនុំរំនះរបស់ព្រះ

ព្រោសលោះ (ខ 15)—សង្គ្រោះ អត្ថន័យចំគឺ "ការនាំចេញផុតពីសេវកភាព"

មាត្រា (ខ 16)—ច្បាប់ បញ្ញត្តិ ការគ្រប់គ្រង

សេចក្តីបារម្ភ (ខ 16)—បារម្ភ

ទទួលរងនូវ (ខ 22)—នាំមកដាក់លើអ្នក

ទីងងឹត (ខ 23)—ស្ថានភាពដែលមិនអាចយល់

តឹងរឹង (ខ 26)—សេចក្តីបន្ទោស

ពុំអាចទប់ទល់បាន (ខ 26)—មិនអាចបញ្ឈប់

ឱ្យចេញសំដី (ខ 27)—ពាក្យសំដី

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 1 ធ្វើសកម្មភាព ក និង ខ។

ក បញ្ចប់នូវប្រយោគទាំងឡាយនេះ

នៅក្នុង នីហ្វៃទី2 1:5–12 គឺជាពាក្យរបស់លីហៃ និយាយទៅកាន់កូនៗរបស់គាត់ អំពីដែនដីដែលជាកេរ្តិ៍អាករ របស់ពួកគេ ដែលរួមមានអាមេរិកខាងជើង និងខាងត្បូង។ បំពេញសេចក្តីថ្លែងដូចខាងក្រោម ហើយសង្ខេបការបង្រៀនរបស់លីហៃ។ ព្យាយាមសរសេរឃ្លាទាំងនេះ តាមគំនិតរបស់អ្នក តែត្រូវប្រាកដថា ឃ្លាទាំងនេះ គឺចេញពីការបង្រៀនរបស់លីហៃ

1. យោងទៅលើកូនចៅរបស់លីហៃ ដែនដីនោះគឺជាកេរ្តិ៍អាករ របស់. . . . (សូមមើល ខទី 5–7។)

2. បើសិនអ្នកទាំងនោះ រស់នៅលើ ដែនដីសន្យា ទីឯចំរើព្រះអង្គ ហើយគោរពតាមបទបញ្ញត្តិ របស់ទ្រង់ បន្ទាប់មក . . . (សូមមើលខទី 7, 9–12។)

3. ព្រះអម្ចាស់មិនខ្វៀជាតិផ្សេងឲ្យ ស្គាល់ពីដែនដីសន្យា ព្រោះ . . . (សូមមើលខទី 8។)

២ "ធ្វើជាមនុស្ស"

អែលឌើរ ខែលូស អ៊ុ. អាសេយ ដែលធ្លាប់ជាសមាជិក នៃគណៈប្រធាន នៃក្រុមចិតសិបនាក់ បានប្រាប់ពីបទពិសោធន៍ ដែលលោកមាន ក្នុងនាមជាសង្ឃរាយុដប់ប្រាំបីឆ្នាំនៅក្នុងកាន់បព្វជិតភាពអើរ៉ុន នៅពេលដែលគាត់បានជំទាស់មិនចូលរួមសកម្មភាពដែលមិនសមរម្យ។ គាត់បានសរសេរថា៖ "នៅពេលដែលខ្ញុំបានដើរចេញ . . . មិត្តរបស់ខ្ញុំ បានចំអកខ្ញុំខ្ញុំ ដោយស្រែកថា 'នៅពេលណាទើបឯងភ្ញាក់ខ្លួន?' 'ពេលណាទើបឯងឈប់ធ្វើជាកូនក្មេង និងឈប់ធ្វើជាមនុស្សឆ្កួតនឹងសាសនា?' 'តើពេលណាទើបឯង ធ្វើជាមនុស្សម្នានឹងគេ?' (*In the Lord's service* [1990], 46, សូមមើល Conference Report, ខែមេសា 1992, 58, ឬ *Ensign* ខែឧសភា 1992, 40)។ លីហៃបានសុំកូនឲ្យរបស់គាត់ឱ្យ "ធ្វើជាមនុស្ស" (នីហ្វៃទី2 1:21) តែលីហៃ ចង់មានន័យផ្សេងទៀត ដូចពាក្យដែនចង់និយាយក្នុងរឿងនេះ។ សំរាប់សកម្មភាពនេះ បំពេញលេខ 1 បន្ទាប់មកបំពេញលេខ 2 ឬក៏លេខ 3 ក៏បាន។

1. យោងទៅលើអ៊ូ ដែលលីហៃបានបង្រៀនទៅក្នុង នីហ្វៃទី2 1:13–24 សរសេរយ៉ាងតិចត្រាំចំណុចអំពីលក្ខណៈ ដែលលីហៃបាន ភ្ជាប់ ការធ្វើជាមនុស្សរបស់ព្រះ។ នៅរាល់ចំណុចទីមួយៗ សរសេរខ ដែលអ្នកបានរកឃើញ។

2. សរសេរកថាខ័ណ្ឌ ដែលខុសគ្នារវាងអ៊ូ ដែលអ្នកបានសរសេរ និងក្មេងប្រុសនៅក្នុងរឿងរបស់អាសេយ និងមនុស្ស លោកិយ និយមជាច្រើន ទីឯគិតអំពីរបៀប ដើម្បីធ្វើជាមនុស្សវាមានន័យផ្សេងទៀត។

3. រំលឹកឡើងវិញនូវខ 13 និង 15 និងសរសេរកថាខ័ណ្ឌ ប្រៀបធៀបពីស្ថានភាពរបស់មនុស្ស សុចរិតដូចជាលីហៃ ជាមួយនឹង ស្ថានភាពរបស់មនុស្ស លោកិយនិយម ដូចជាលេមិន និងលេមយួល។

ព្រះយេស៊ូវគ្រីស្ទបានបង្រៀនថា៖ "តើគួរឱ្យអ្នករាល់គ្នាប្រព្រឹត្តបែបណាទៅ? យើងត្រាប់អ្នករាល់គ្នាជាព្រាកដថា ត្រូវឱ្យបានដូចជាយើង" (នីហ្វៃទី3 27:27)។

នីហ្វៃទី2 2
សេរីភាពដែជ្រើសរើស ពីព្រោះតែជង្វាយធួន

យ៉ាកុបគឺជាកូនទីមួយ ក្នុងចំណោមកូនពីរនាក់ទៀតរបស់លីហៃ និងសារ៉ាយ ដែលកើតនៅក្នុងទីរហោស្ថាន (សូមមើលនីហ្វៃទី1 18:7)។ ដូច្នេះយ៉ាកុប គាត់បានទទួលបទពិសោធន៍ ពីការសោកល្វីងជាច្រើនខណៈដែលគាត់កំពុងតែរីកធំឡើង។ . . . ទាំងការ ពិបាកក្នុងការ ធ្វើដំណើរ និងភាព "រឹងរូសរបស់បងប្អូនរបស់គាត់" (នីហ្វៃទី2 2:1)។ ជំពូកនេះរបស់លីហៃនៅក្នុងនីហ្វៃទី2 2 គឺវាមានអត្ថន័យ ពិសេសចំពោះ យ៉ាកុប និងជួយពន្យល់គាត់ថា វាពិបាកដើម្បីមានសេចក្តីសុខសាន្ត និងសេចក្តីអំណរ នៅក្នុង ពិភពលោកនៃការលំបាកវេទនា និងការប្រឆាំងគ្នា។ នេះជាជំពូកមួយ នៅក្នុងចំណោមជំពូកទាំងឡាយ នៅក្នុងព្រះគម្ពីរមរមន ដែលប្រាប់យើងច្រើន អំពីដែនការណ៍នៃសុភមង្គលរបស់ព្រះវរបិតាសួគ៌។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 2

ជីវេទនា (ខ 1)—ទុក្ខវេទនា

ធ្វើឱ្យ (ខ 2)—ដាច់គោលចំណងពិសិដ្ឋ ដាច់ដោយឡែក

ព្រោសលោះ (ខ 3)—អ្នកដែលបានបង់ថ្លៃ ដើម្បីសង្គ្រោះ អ្នកផ្សេងទៀត ពីសេវកភាព ខាងវិញ្ញាណ (ព្រះយេស៊ូវគ្រីស្ទ)

សុចរិត (ខ 5)—ការបង្ហាញពីការជ្រះស្អាត ពីអំពើបាប ឬទុក្ខទោស និងការអភ័យទោស

ទន់ទាប (ខ 7)—ពោរពេញដោយ ការសោកស្តាយ ចំពោះអំពើបាប ដោយរាបទាប

បុណ្យគុណ (ខ 8)—ភាសាផ្អែមល្ហែម និងកិច្ចការល្អ (ចំនុចនេះ គឺជាជង្វាយធួន របស់ព្រះអង្គសង្គ្រោះ—ដែលរួមទាំងការ រងការឈឺចាប់ សុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់)

ព្រះគុណនៃព្រះមែស៊ីដ៏បរិសុទ្ធ (ខ 8)—អំណាចរបស់ព្រះយេស៊ូវគ្រីស្ទ

អង្វរជំនួស (ខ 9–10)—ជាអ្នកនៅ កណ្តាល ដើម្បីជួយក្រុមពីរ ឱ្យដោះស្រាយ បញ្ហា ឬការខ្វែងគំនិតគ្នា (នៅក្នុងចំនុចនេះ ព្រះអង្គសង្គ្រោះបានជួយ ទុស្សទាំងអស់ ដែលត្រូវបានកាត់ផ្តាច់ចេញពី ព្រះវរបិតា ដោយសារតែអំពើបាប)

ដែលចែងអំពី (ខ 10)—ការអនុវត្ត សម្បើម

ភ្ជាប់ទៅនឹង (ខ 10)—បានភ្ជាប់

ប្រមូលគ្នា (ខ 11)—ការប្រមូលផ្តុំវត្ថុ មួយឬ វត្ថុច្រើន ហើយផ្តុំទៅជាវត្ថុតែមួយ

ដោយឥតប្រយោជន៍ (ខ 12)—គ្មាន គោលចំណង គ្មានអ្វីៗ

មានអ្វីមកល្បួង (ខ 16)—ល្បួង បញ្ជុះ បញ្ជូល

ពន្យារវែង (ខ 21)—យ៉ាងវែង

ស្ថានភាពពិសោធន៍ (ខ 21 សូមមើល ខ 30 ផងដែរ)—ពេលសំរាប់សាកល្បង ឬបំភ្លឺ

ការធ្វើអំពើរំលងច្បាប់ បានធ្វើអំពើ រំលងច្បាប់ (ខ 21–22)—ធ្វើឱ្យដូច ឬរំលោភលើច្បាប់

ព្រោសលោះ (ខ 26)—លើកលែង

ជាប្រយោជន៍ (ខ 27)—សំខាន់ ដែល ត្រូវការចាំបាច់

បង្រួបបង្រួម (ខ 27–28)—អ្នកដែលធ្វើ កិច្ចការ ដើម្បីឱ្យក្រុមពីរត្រូវគ្នា ដែលមិនចុះសំរុងនឹងគ្នា (នៅក្នុងចំណុចនេះ គឺជា ព្រះយេស៊ូវគ្រីស្ទ)

គំនិត (ខ 30)—គោលចំណង

នៅក្នុងនីហ្វៃទី2 2:3–10 "ផ្លូវត្រូវបានរៀបចំជាស្រេច . . . ឯសេចក្តីសង្គ្រោះនឹងបានដោយទទេ"

ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ គឺនឹងបានដោយទទេសំរាប់មនុស្សគ្រប់រូប ដែលមកពីការធ្លាក់ចុះ ផ្តល់លក្ខខ័ណ្ឌឱ្យច្រើនពីឥទ្ធិពល នៃអំពើបាបផ្តាល់ខ្លួន (សូមមើលតាមផ្សាក្រោម)។ ដូចដែលលីហៃបានប្រាប់យ៉ាកុប "ការសង្គ្រោះនឹងបានដោយទទេ" (នីហ្វៃទី2 2:4)។ យើងមិនអាចសង្គ្រោះដោយសកម្មភាពណាមួយ របស់យើងបានឡើយ តែដោយជង្វាយធួនរបស់ ព្រះយេស៊ូវគ្រីស្ទវិញ។ មានតំរូវការដែលយើងត្រូវតែចំពេញ គឺដើម្បីទទួលប្រយោជន៍ ពីជង្វាយធួនរបស់ ព្រះអង្គសង្គ្រោះ។ លីហៃបានទិយាយថា ដែនការណ៍សង្គ្រោះ គឺសំរាប់តែ "ជនណាដែលមានចិត្តសង្រេង និងវិញ្ញាណទន់ទាប ហើយគ្មានអ្នក ណាមួយសោះ ដែលអាចតបស្នងការចុងចំដុត នៃត្រកូវិន័យបាន" (ខ 7)។ បើសិនជាយើងអាច ប្រកាសពីលក្ខខ័ណ្ឌ ដែលមាន ប្រយោជន៍ ពីជង្វាយធួនរបស់ព្រះគ្រីស្ទ យើងត្រូវតែមានជំនឿទៅលើទ្រង់ យើងត្រូវតែកែប្រែចិត្ត ពីអំពើបាបរបស់យើង។ វាគ្មានផ្លូវណាទៀត ដើម្បីទទួលប្រយោជន៍ ពីការព្រោសលោះដូចនេះបានទេ។

លទ្ធផលនៃការធ្លាក់របស់អ័ដាម ដែលយើងត្រូវការការប្រោសលោះ

- សេចក្តីស្លាប់ខាងសាច់ឈាមៈ យើងទាំងអស់គ្នា កើតមកជាមួយនឹងរូបកាយ ដែលនឹងត្រូវស្លាប់។
- សេចក្តីស្លាប់ខាងវិញ្ញាណៈ យើងទាំងអស់គ្នា កើតមកក្នុងពិភពធ្លាក់មួយហើយ ដែលត្រូវបានផ្តាច់ចេញពីព្រះវរបិតា សួគ៌របស់យើង។
- យើងរស់នៅក្នុង ទគរទឡែស្ទាល, ផែនដីដែលធ្លាក់ចុះ។

ពរជ័យដ៏ឥតលក្ខខ័ណ្ឌនៃដង្វាយធួន

- អស់អ្នកទាំងឡាយដែល បានរស់នៅនឹងត្រូវរស់ឡើងវិញជាមួយ នឹងរូបកាយអមតៈ (សូមមើល អាលម៉ា 11:42–44)។
- យើងទាំងអស់គ្នា នឹងត្រូវទាំយកទៅមុខវត្តមានរបស់ព្រះ ដើម្បីទទួលសេចក្តីជំនុំជំរះ (សូមមើល អាលម៉ា 11:44, ហេលេមិន 14:15–17)។
- ផែនដីនឹងធ្វើឱ្យទៅជាទគរសេឡេស្ទាល (សូមមើល គ និង ស 88:18–20)។

លទ្ធផលនៃការធ្លាក់ចុះ របស់យើង ដែលយើងត្រូវការសេចក្តីប្រោសលោះ

- នៅពេលដែលយើងទទួលខុសត្រូវចំពោះការជ្រើសរើសរបស់យើង អំពើបាបរបស់យើង ធ្វើឱ្យយើងមិនមានភាព សក្តិសម ដើម្បីត្រឡប់ទៅកាន់ទី វត្តមានរបស់ព្រះវរបិតាសួគ៌របស់យើង (សូមមើល ម៉ូសាយ 16:2–5)។

លក្ខខ័ណ្ឌពរជ័យនៃដង្វាយធួន

- បើសិនយើងមានសេចក្តី ជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ហើយធ្វើបុណ្យ ជ្រមុជទឹក យើងអាចជ្រះស្អាត ពីអំពើបាប របស់យើង។ តាមរយៈអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចបានបរិសុទ្ធ និងមានភាពសក្តិសម ដើម្បីចូលរួមក្នុងទីវត្តមាន របស់ព្រះវរបិតា និងបានក្លាយដូចជាទ្រង់ (សូមមើលអាលម៉ា 34:13–17, 42:15 ម៉ូរ៉ូណៃ 10:32–33, គ និង ស 76:58, 132:19–20, ម៉ូសេ 5:5–11)។

នីហ្វៃទី2 2:5—“តាមច្បាប់គ្មានសាច់ឈាមណា សុចរិតទេ”

សុចរិតមានន័យថា គឺគ្មានទោសកំហុស និងមិនត្រូវការសេចក្តីអភ័យបាប គឺអាចទទួលយកបានជាមនុស្សសុចរិត នៅចំពោះព្រះ។ លីហៃបានបង្រៀនថា យោងទៅតាមក្រិត្យវិន័យ គ្មានន្រណាមួយសុចរិតទេ (ធ្វើឱ្យសុចរិត) តែដោយ ការរំលោភលើច្បាប់ មនុស្សត្រូវបានកាត់ចេញពីព្រះ (សូមមើល នីហ្វៃទី2 2:5)។ ដូចដែលសាវ័កប៉ុល បានបង្រៀន “ពីព្រោះគ្រប់គ្នា បានធ្វើបាប ហើយ ខ្វះមិនដល់សិរីល្អនៃព្រះ” (រ៉ូម 3:23)។ “ដូចនេះ យោងទៅតាមក្រិត្យវិន័យ ដែលបានចែង បើគ្មានក្រិត្យវិន័យទេ គឺគ្មាន អ្វីៗទាំងអស់ តែក្រិត្យវិន័យគឺជាអ្នកអនុវត្ត មនុស្សនឹងត្រូវកាត់ចេញ ទាំងខាងរូបកាយ និងខាងវិញ្ញាណ។ មនុស្សនឹងត្រូវ កាត់ចោលខាងរូបកាយ ដោយសារពួកគេមិនអាចគោរពតាមក្រិត្យវិន័យយ៉ាងល្អឥតខ្ចោះ ហើយពួកគេនឹងត្រូវកាត់ចោល ខាងវិញ្ញាណ ដោយសារការរំលោភលើច្បាប់ ដែលពួក គេធ្វើអ្វីមួយ មិនស្អាតស្អំ ‘គ្មានវត្ថុមិនស្អាតណា អាចស្ថិត . . . ក្នុងវត្តមាន របស់ទ្រង់ទេ’ (ម៉ូសេ 6:57, សូមមើល នីហ្វៃទី2 9:6–10)” (Gerald N. Lund, “The Fall of Man and His Redemption,” in Monte S. Nyman ហើយ Charles D. Tater Jr., អ្នកពិនិត្យផ្សេងទៀត *The Book of Mormon: Second Nephi, the Doctrinal Structure* [1989], 90)។ “សេចក្តីប្រោសលោះនឹងមកដោយព្រះ នឹងតាមរយៈព្រះមែស៊ីដ៏បរិសុទ្ធ “ពីព្រោះ” ទ្រង់ថ្វាយ ព្រះអង្គទ្រង់ជាយញ្ញបូជាជំនួសអំពើបាប ដែលអាចតបបងការចុងបំផុត នៃក្រិត្យវិន័យបាន” (នីហ្វៃទី2 2:6–7)។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 2 ចូរធ្វើសកម្មភាពបីដូចខាងក្រោម (ក–ឃ)។

ក ពន្យល់ពីរបៀបមួយដែល សេចក្តីសង្គ្រោះ នឹងទទួលបានដោយទទេរ

1. សិក្សានៅក្នុង នីហ្វៃទី2 2:3–9 ហើយពន្យល់អំពីសេចក្តីថ្លែងការណ៍ របស់លីហៃ ដែលថា “សេចក្តីសង្គ្រោះ នឹងបានដោយ ទទេរ” (ខ 4) ហើយ ការនិយាយរបស់លីហៃ គឺថា សេចក្តីសង្គ្រោះ គឺសំរាប់អ្នកទាំងឡាយដែល ជ្បឿ និងធ្វើតាមព្រះយេស៊ូវគ្រីស្ទ (សូមមើលខ 9) ទាំងពីរយ៉ាងគឺសុទ្ធតែពិត។ (បើចាំបាច់ សូមមើលវគ្គជំនួយ “ការយល់ដឹងអំពីព្រះគម្ពីរ”)។
2. ស្វែងរកនៅក្នុង នីហ្វៃទី2 2:5–8 ហើយពន្យល់ពីគំលៃ ដែលព្រះអង្គសង្គ្រោះបានបង់ ដើម្បីសង្គ្រោះយើងខាងរូបកាយ និងខាងវិញ្ញាណ។ តើស្ថានភាពរបស់យើងនឹងទៅ ជាយ៉ាងណា បើយើងគ្មានព្រះអង្គសង្គ្រោះ? (សូមមើលខ 5)។

ខ ក្រិត្យវិន័យរបស់ព្រះ ជាគន្លឹះទៅកាន់សុភមង្គល

មនុស្សខ្លះបានគិតថា ក្រិត្យវិន័យមនុស្សគឺជាអ្នករៀបចំ—ហើយថាវា គ្មានក្រិត្យវិន័យដ៏អស់កល្បជានិច្ចទេ ហេតុដូច្នេះហើយ វាក៏គ្មានអំពើបាបដែរ។ ពួកគេជឿថា មនុស្សអាចធ្វើអ្វីឲ្យបាន តាមតែគេចង់ធ្វើ ឱ្យតែគេមិនធ្វើឱ្យនរណាម្នាក់ មានការ ឈឺចាប់ ។ បន្ទាប់ពីការបង្រៀនពីសេចក្តីត្រូវការ “ផ្តួយចំពោះរឿងគ្រប់សារពើ” (នីហ្វៃទី2 2:11) លីហៃបានពន្យល់ ពីទំនាក់ទំនង នៃ ក្រិត្យវិន័យរបស់ព្រះ ជាមួយនឹងសុភមង្គលរបស់យើង។ អានទៅក្នុង នីហ្វៃទី2 2:13 ហើយសរសេរ ទៅក្នុងស្បៃវគ៌ា សរសេរ របស់អ្នក ពីគោលការណ៍ដែលអ្នកគិតថា លីហៃបានបង្រៀន។

គ ការទន្ទេញខគម្ពីរ—នីហ្វៃទី2 2:25

1. នៅក្នុងខដ៏ខ្លីនេះ បានចែងអំពីសេចក្តីពិតដ៏សាមញ្ញ អំពីការធ្លាក់។ ចូរអានផងដែរនៅក្នុង នីហ្វៃទី2 2:22–23 ដែលពន្យល់ពីអ្វីដែលនឹងកើតឡើង បើអ័ដាមមិនបានធ្វើបាប ដោយបរិភោគផ្លែហាមឃាត់។ សរសេរ “ដោយសារ ការធ្លាក់ របស់អ័ដាម . . .” ហើយបញ្ចប់ប្រយោគ ដោយសរសេរ លទ្ធផល នៃការធ្លាក់របស់អ័ដាម ដែលបានបង្ហាញ នៅក្នុងនីហ្វៃទី2 2:22–25។ (ពេលខ្លះលីហៃបានពន្យល់ ពីអ្វីដែល *មិន* អាចកើតឡើង បើគ្មានការធ្លាក់ចុះទេ សរសេរ លទ្ធផលនោះឡើងវិញ ហើយពន្យល់ពីអ្វីដែល *បាន* កើតឡើង។)
2. លីហៃបាននិយាយថា “មានមនុស្សលោក ដើម្បីឱ្យគេអាចមានសេចក្តីអំណរ” (ខ 25)។ រំលឹកឡើងវិញពីខនានានៅក្នុង នីហ្វៃទី2 2 ដែលមានពាក្យ *សុភមង្គល, សេចក្តីអំណរ, ទុក្ខវេទនា, ដែលរងទុក្ខវេទនា* (ខ 5, 10–11, 13, 18, 23, 25, 27)។ តើលីហៃបានបង្រៀនអំពីអ្វី នៅក្នុងខទាំងនោះ អំពីរបៀបចង់មូលហេតុ ដែលយើងអាចមានសេចក្តីអំណរ ហើយគេនរណាចង់ឱ្យយើងមាន?

ការទន្ទេញខគម្ពីរ—នីហ្វៃទី 2 2:27

នៅក្នុងស្បៃរគោសរសេររបស់អ្នក គូសឱយ៉ាក្រាម ហើយសរសេរពីគោលលទ្ធិសំខាន់ៗ ដែលបានបង្រៀននៅក្នុងខនេះ។ ធ្វើឱយ៉ាក្រាមនេះ ដើម្បីឱ្យអ្នកអាចព្យួរវា នៅកន្លែងដែលអ្នក អាចងាយឃើញឱយ៉ាក្រាមនោះញឹកញាប់ ដើម្បីរំលឹកអ្នកអំពី សេចក្តីពិតដ៏សំខាន់នេះ។

នៅក្នុង នីហ្វៃទី2 3 លីហៃបានប្រាប់ឈ្មោះមនុស្ស ប្អូនទាក់ដែលមានឈ្មោះថា យ៉ូសែប។ ពាក្យរបស់គាត់ គឺនិយាយពីកូន ប្រុស តូចជាងគេ របស់គាត់ គឺ យ៉ូសែប។ លីហៃក៏បាននិយាយពី ព្យាការីដ៏អស្ចារ្យ គឺយ៉ូសែប ដែលត្រូវបាន យកទៅលក់ ឱ្យទៅប្រទេសអេស៊ីព្ទ។ គឺជាយ៉ូសែប ដែលគ្រួសាររបស់លីហៃ បានចុះមក។ លីហៃបានដកស្រង់ការព្យាករណ៍ មួយដែលយ៉ូសែប ទៅ អេស៊ីព្ទបានធ្វើមុនពេលគាត់ស្លាប់។ នៅក្នុងការព្យាករណ៍នោះ យ៉ូសែប បាននិយាយអំពីថ្ងៃចុងក្រោយ នៅពេលដែលអ្នក សិក្សានៅក្នុងជំពូកនេះ ស្បែនពី នរណាជា យ៉ូសែបទាំងពីរ នៅសម័យចុងក្រោយនេះ ហើយហេតុអ្វី បានជា ពួកគេសំខាន់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 3

ចេញពីផលនៃ . . . ពោះលោក (ខ 5–7, 11–12, 18–19, 21)—កូនចៅ

សម្តែង (ខ 5)—បង្ហាញ, បានធ្វើឱ្យដឹង

អ្នកមើលឆុត (ខ 6–7, 11, 14)—មនុស្សដែលអាចដឹង ពីអ្វីៗ ដែលនៅអតីត, បច្ចុប្បន្ន, និងអនាគត (សូមមើលម៉ូសាយ 8:13–17)

បានតំកើងខ្ពស់ (ខ 7)—ឱ្យតំលៃ, បានគេគោរព

សេចក្តីក្លែងក្លាយ, បានក្លែងបន្លំ (ខ 12, 14)—ធ្វើឱ្យតាន់ច្រឡំ, ឬតាន់ច្រឡំ, មិនមានរបៀប, ការច្របូកច្របល់, បានច្របូកច្របល់

ដើម្បីតទល់នឹង (ខ 12)—បញ្ឈប់

ចាប់ផ្តើម (ខ 13)—ចាប់ផ្តើម

ស្តាប់តាម (ខ 23)—ស្តាប់តាម ហើយគោរពតាម

ការសាងឡើងវិញ (ខ 24)—នាំយកមកវិញ (នៅក្នុងចំណុចនេះ គឺដើម្បីនាំយកអ៊ីស្រាអែល មកកាន់ព្រះរបស់គេវិញ សេចក្តីពិត និងកិច្ចសន្យា, និងដែនដីរបស់ពួកគេ)

នីហ្វៃទី2 3:6–21—តើការព្យាករណ៍របស់យ៉ូសែប បានរកឃើញនៅកន្លែងណា?

ការព្យាករណ៍របស់យ៉ូសែប ដែលបានយកទៅលក់ទៅ ឱ្យស្រុកអេស៊ីព្ទ គឺត្រូវបានដកស្រង់ ដោយលីហៃ ទៅកាន់កូន របស់គាត់គឺយ៉ូសែប គឺមិនត្រូវបានរកឃើញនៅក្នុងគម្ពីរប៊ីបសព្វថ្ងៃនេះទេ។ លីហៃបានរកវាឃើញនៅលើ ផ្ទាំងលង្ហិន ដែលកូនរបស់គាត់ បានយកពីឡាបាន់ នៅឯយេរូសាឡិម (សូមមើល នីហ្វៃទី1 3:3, 19–20, 5:10–16, នីហ្វៃទី2 4:1–2)។

នីហ្វៃទី2 3:6–18—ព្យាការីយ៉ូសែប នៅសម័យចុងក្រោយ

ការព្យាករណ៍ពីយ៉ូសែប នៅសម័យបូរាណ គឺសំដៅពីព្យាការីយ៉ូសែប នៅសម័យចុងក្រោយ ដែលជាព្យាការីដ៏អស្ចារ្យ ទឹងដា ពរជ័យមួយ ដល់ទាំងកូនចៅរបស់លីហៃ និងវង្សអ៊ីស្រាអែល ទាំងអស់ ការព្យាករណ៍បាននិយាយថា យ៉ូសែប នៅសម័យ ចុងក្រោយនេះ នឹងមានឈ្មោះដា ឪពុកផងដែរ គឺយ៉ូសែប។ ព្យាការីសម័យចុងក្រោយ គឺជាព្យាការី យ៉ូសែប ស្មីត។ ហេតុ ដូច្នេះ ហើយ គឺមានយ៉ូសែប ប្អូនទាក់ខុសឪគ្នា ដែលបាននិយាយនៅក្នុងនីហ្វៃទី2 3: យ៉ូសែប ស្រុក អេស៊ីព្ទ, យ៉ូសែប កូនប្រុស របស់លីហៃ ព្យាការីយ៉ូសែប ស្មីត និងយ៉ូសែប ស្មីត ឪដែលជាឪពុក របស់ព្យាការីយ៉ូសែប ស្មីត)។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 3 ធ្វើសកម្មភាព ក ឬធ្វើសកម្មភាព ខ តាមការដែលអ្នកចង់ធ្វើ។

ក ធ្វើការពិភាគទៅលើ បេសកកម្មរបស់ព្យាការី

1. អ្នកមើលឆុតបានបញ្ជាក់នៅក្នុង នីហ្វៃទី2 3:6–21 គឺជាព្យាការីយ៉ូសែប ស្មីត។ សរសេរពីអ្វី នៅពេលដែលអ្នករៀនអំពី បេសកកម្មរបស់គាត់ នៅក្នុងការព្យាករណ៍។ (វាមានយ៉ាងតិចដប់ចំណុច ដែលបានបង្ហាញនៅក្នុងខទាំងនោះ។) ព្យាយាម សរសេរវា តាមពាក្យរបស់អ្នក។
2. ជ្រើសរើសផ្នែកមួយនៃបេសកកម្មរបស់ ព្យាការីយ៉ូសែប ស្មីត ហើយពន្យល់ ហេតុអ្វីវាសំខាន់ ហើយមានឥទ្ធិពលនៅក្នុង ជីវិតរបស់អ្នក។

ខ ពាក្យព្យាករណ៍ត្រូវបានបំពេញនៅក្នុងជំនាន់របស់យើង

មានព្រះគម្ពីរពីរដែលបានបង្ហាញនៅក្នុង នីហ្វៃទី2 3:12—មួយគឺសរសេរដោយកូនចៅរបស់យ៉ូសែប (ព្រះគម្ពីរមរមន) ហើយមួយទៀតត្រូវបានសរសេរ ដោយសាសន៍យូដា (ព្រះគម្ពីរប៊ីប)។

1. សរសេរពីអ្វីដែលពាក្យព្យាករ បាននិយាយពីព្រះគម្ពីរទាំងពីរនេះ នឹងត្រូវសំរេច។
2. ពិភាក្សាពីការមានព្រះគម្ពីរទាំងពីរនេះ បានបំពេញពីគោលបំណងដែលអ្នកបានសរសេរ។
3. អានសេចក្តីបន្ថែមក្នុងពេលថ្មីៗនេះ នៅចំណងដើង ព្រះគម្ពីរមរមន។ នៅក្នុងរបៀបណាមួយ ដែលព្រះគម្ពីរមរមន គឺជា "សក្ខីបទមួយទៀត អំពីព្រះយេស៊ូវគ្រីស្ទ"?

អែលឌើរ បិយ ឃេ. ដាកកឺ ជាសមាជិកនៃក្រុមសាវ័កដប់ពីរនាក់ បានមានប្រសាសន៍ថា ព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន "គឺត្រូវបានដើរទន្ទឹមគ្នា ដែលថានៅពេលដែលអ្នកអាន ព្រះគម្ពីរមួយ នោះអ្នកនឹងខិតជិតទៅព្រះគម្ពីរ មួយទៀត នៅពេលដែលអ្នករៀន ទូវព្រះគម្ពីរមួយ នោះនឹងត្រូវបានបំភ្លឺដោយ ព្រះគម្ពីរមួយទៀត។ ព្រះគម្ពីរទាំងពីរនេះ គឺពិតប្រាកដ នៅក្នុងដៃរបស់យើង។ ការព្យាករណ៍របស់ អេសេគាល" នៅក្នុងអេសេគាល 37:15–19 "គឺឡូវនេះព្រះគម្ពីរបានឈរយ៉ាងពេញលេញ" (នៅក្នុង Conference Report ខែតុលា 1982, 75 ឬ *Ensign,* ខែវិច្ឆិកា 1982, 53)។

នីហ្វៃទី2 4
ទំនុកដំកើងរបស់នីហ្វៃ

ពាក្យចុងក្រោយខ្លះៗ ដែលព្យាការីលីហៃដ៏អស្ចារ្យ បានទិយាយគឺត្រូវបានកត់ត្រានៅក្នុង នីហ្វៃទី2 4 ។ បន្ទាប់ពីសេចក្តីស្លាប់ របស់ឱពុកគាត់។ នីហ្វៃបានកត់ត្រាតំនិតខ្លះៗ និងអារម្មណ៍ខាងវិញ្ញាណរបស់គាត់ផ្ទាល់។ គាត់បានសរសេរអំពី អារម្មណ៍និងគំនិត ទាំងនោះ ជាទំរង់កំណាព្យ . . . គឺដូចជាទំនុកដំកើងនៅក្នុង ព្រះគម្ពីរសញ្ញាចាស់។ ជាក់ស្តែងគឺនៅក្នុង នីហ្វៃទី2 4:16–35 ជាទូទៅគឺត្រូវបានហៅថា "ទំនុកដំកើងរបស់នីហ្វៃ។" ទំនុកដំកើងនេះ អាចជាប្រភពនៃកំលាំង សំរាប់អ្នកទាំងឡាយណា ដែលស្រលាញ់ព្រះអម្ចាស់ និងចង់បំរើទ្រង់ តែពួកគេញ្ញែយបារម្ភ ដោយមកពីភាពទន់ខ្សោយរបស់ពួកគេ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 4

ផ្លាក់ទៅលើក្សាលឱពុកម្តាយ

របស់ចៅវិញ (ខ 6)—ឱពុកម្តាយរបស់ចៅ គឺជាអ្នកទទួលខុសត្រូវ

ជរាណាស់ (ខ 12, 24)—ចំរើនវ័យ

សេចក្តីដាស់តឿន (ខ 13)—ការកែលំអរអំពីអំពើបាប

បានបង្ខំឱ្យ (ខ 14)—បានបញ្ជា បង្គាប់

វេទនា (ខ 17)—ទុក្ខវេទនា ត្មានតំលៃ

សោកសៅ (ខ17)—ទុក្ខព្រួយ

ព័ទ្ធដោយ (ខ 18)—ត្រូវព័ទ្ធជុំវិញ

រំខាន (ខ 18)—បញ្ហា

បានបំភាន់ (ខ 22)—ដាក់មានលំដាប់លំដោយ ភាន់ច្រលំ

បានហាមឃាត់ (ខ 25)—បានបញ្ជា

ព្រះអម្ចាស់ទ្រង់បានយាង (ខ 26)—ព្រះយេស៊ូវត្រីស្ត ជាតួអង្គអទិទេពបង្រៀនដល់អ្នកដទៃ

ទន់ខ្សោយ (ខ 26, 29)—ធ្វើឱ្យទន់ខ្សោយ

សង្រេង (ខ 32)—បន្ទាបខ្លួន ត្មានអំនួត

ទន់ទាប (ខ 32)—បន្ទាបខ្លួន សោកសៅចំពោះអំពើបាប

ស្រះ (ខ 33)—បិទ

ដៃនៃមនុស្ស (ខ 34)—ប្រាជ្ញារបស់មនុស្ស

ដោយសទ្ធា (ខ 35)—ដ៏សំបូរសប្បាយមេត្តាករុណា

ទុច្ចរិត (ខ 35)—មិនសមរម្យ សំរាប់មូលហេតុមិនត្រឹមត្រូវ

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក និង ខ នៅពេលដែលអ្នកសិក្សានៅក្នុងនីហ្វៃទី2 4។

ក ការចងចាំពីព្យាការីលីហៃ

រំលឹកឡើងវិញនូវ ពាក្យចុងក្រោយរបស់លីហៃ នៅក្នុងនីហ្វៃទី2 4:1–11។ ពិចារណាពីអ្វីដែលអ្នកបានរៀន អំពីលីហៃ ចាប់តាំងពីនីហ្វៃទី1 1 ហើយសរសេរពីបុគ្គលិកលក្ខណៈ របស់លីហៃបីចំណុច ដែលអាចធ្វើឱ្យអ្នក ងាយនឹកចាំអំពីគាត់។ សំរាប់ចំណុចនិមួយៗ ចូរពន្យល់ពីមូលហេតុដែលអ្នក ជ្រើសរើសយកចំណុចនោះ ហើយអំពីគំនិតធម្មតារបស់អ្នកថា ការចងចាំ ចំនុចនោះនឹងក្លាយជាពរដ៏យ ដល់ភូនចៅរបស់គាត់ ដោយរបៀបណា។

ខ សរសេរអំពីរឿងនៃពលឹងរបស់អ្នក

នៅក្នុងនីហ្វៃទី2 4:15–35 យើងបានអានទូវ "អំពីរឿងនៃព្រលឹងរបស់ [នីហ្វៃ]" (ខ 15)។ នេះជាខព្រះគម្ពីរល្អ ដើម្បីអានឱ្យ ខ្លាំងៗ។ បន្ទាប់ពីអ្នកបានអានវា ជ្រើសរើសយកឃ្លា ឬ ប្រយោគប្រាំពីអ្វីដែលនីហ្វៃបានទិយាយ ដែលជាផ្នែកមួយ "អំពីរឿង [របស់អ្នក]។" ពន្យល់ពីមូលហេតុដែលអ្នកគិតថា ចំនុចនីមួយៗ សំខាន់សំរាប់អ្នក។

នីហ្វៃទី2 5
ត្រូសារបែកបាក់មួយ

ថ្ងៃបើពាក្យតំបូន្មានរបស់លីហៃ ឱ្យមានការរួបរួមគ្នា (សូមមើល នីហ្វៃទី2 1:21) ក៏ដោយ ក៏នៅតែមានការបែកបាក់នៅក្នុងត្រូសារ ដោយសារតែ ប្រភពការប្រណែនទិងកំហឹង របស់លេមមិន និងលេមយួល មានចំពោះប្អូនប្រុសរបស់ពួកគេ គឺនីហ្វៃ។ តែដូចដែល នីហ្វៃ បានថ្លែងទីបន្ទាល់នៅក្នុង នីហ្វៃទី1 1:20 ព្រះអម្ចាស់មានសេចក្តីមេត្តាករុណា ដើម្បីជួយរំដោះអ្នកមានសេចក្តីជំនឿ។ នៅពេលដែលអ្នកអាន នីហ្វៃទី2 5 កត់សំគាល់ ពីភាពខុសគ្នារវាងការរស់នៅរបស់មនុស្សពីរក្រុម ដែលជាលទ្ធផល នៃអាកប្បកិរិយា និងសកម្មភាពរបស់ពួកគេ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 5

ល្មម (ខ 4, 34)—ត្រប់ត្រាន់

ក្រិត្យក្រម (ខ 10)—វិន័យ, ច្បាប់

ព្រោះ (ខ 11)—ដាំ

ច្រូតកាត់ (ខ 11)—ច្រូតកាត់

ល្ឃូង (ខ 21)—ការល្ឃូង, ដែលធ្វើឱ្យទាក់ចិត្ត

ដ៏ត្ងរឱ្យស្អប់ (ខ 22)—ត្ងរឱ្យស្អប់ខ្ពើមរអើម, ស្អប់

ខ្ជិលច្រអូស (ខ 24)—ភាពខ្ជិលច្រអូស

ល្ឋិចកិច្ចកល (ខ 24)—មនុស្សលាក់ពុត, មិនស្មោះត្រង់, ប៊ិនប្រសប

រំពាត់ (ខ 25)—ទុក្ខលំបាក, បណ្តាសា, ទារុណ្ឌកម្ម

តែងតាំង (ខ 26)—តែងតាំងសំរាប់គោលបំណងពិសិដ្ឋ

នីហ្វៃទី2 5:20–25—"បណ្ណាសា" មិនមែនជា "ស្បែកក្រមៅ" នោះទេ

"បណ្ណាសា" ដែលព្រះអម្ចាស់បាន ដាក់ទៅលើពួកជនបះបោរ សាសន៍លេមិនទោះគឺត្រូវកាត់ចេញពីវត្តមានរបស់ទ្រង់ (សូមមើលនីហ្វៃទី2 5:20–21)។ ព្រះអម្ចាស់បានដាក់បណ្ណាសា "ឱ្យពួកគេមានស្បែកក្រមៅ" ដើម្បីកុំឱ្យច្រឡំជាមួយនឹង សាសន៍នីហ្វៃ ឬបើសាសន៍ទាំងពីររៀបការជាមួយគ្នា ពួកគេនឹងនាំយកបណ្ណាសាមកដាក់ លើខ្លួនរបស់ពួកគេ (សូមមើលខ 21–23)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលដែលអ្នកអាន នៅក្នុងនីហ្វៃទី 2 5។

ភ្ជ គូសបញ្ជាក់ពីភាពខុសគ្នា

1. គូសតារាងដូចនៅខាងក្រោម នៅក្នុងស្បៀវភៅសរសេររបស់អ្នក ហើយបំពេញនូវពត៌មានដែល អ្នកបានរកឃើញ នៅក្នុងបទគម្ពីរយោង ដែលបានឱ្យៈ

សាសន៍នីហៃ	អ្វីដែលត្រូវរក	សាសន៍លេមិន
	តើមេដឹកនាំមានអារម្មណ៍ យ៉ាងដូចម្តេច? តើពួកគេបានធ្វើអ្វី? (សូមមើល នីហ្វៃទី2 5:1–4, 12, 14–18, 26, 29, 31–32)។	
	តើប្រជាជនបានធ្វើអ្វី? (សូមមើលខទី 6–11, 15, 17, 20–22, 24–27)	
	តើបានលទ្ធផលអ្វី? (មើលខទី 11, 13, 16, 20–22, 25–27, 34)។	

2. សាសន៍នីហ្វៃ "បានរស់នៅ ដោយមានសុភមង្គល" (នីហ្វៃទី2 5:27)។ រំលឹកឡើងវិញនូវ នីហ្វៃទី2 5 ហើយសរសេរវិធីបី ដើម្បីរស់នៅ "ប្រកបដោយមានសុភមង្គល"។

នីហ្វៃទី2 6

យ៉ាកុបបានបង្រៀនប្រជាជន អំពី ការសរសេររបស់ព្យាការីអេសាយ

នៅក្នុងនីហ្វៃទី2 5:26 យើងបានអានថា នីហ្វៃបានតែងតាំង យ៉ាកុប និងយ៉ូសែប ដើម្បីធ្វើជា "សង្ឃ ហើយជា ត្រូ" សំរាប់ សាសន៍នីហ្វៃ។ ការបង្រៀនខ្លះៗ របស់យ៉ាកុបត្រូវបានកត់ត្រានៅក្នុង នីហ្វៃទី2 6–10 ដែលជាការបង្រៀន អស់រយៈពេលពីរថ្ងៃ ដែលគាត់បានបង្រៀនទៅកាន់ប្រជាជន នីហ្វៃ។ ភាគច្រើនគឺនៅក្នុងជំពូក 6–8 យ៉ាកុបបានដកស្រង់ ពាក្យរបស់អេសាយ (អេសាយ 49:22–52:2)។ គាត់ក៏បានពន្យល់ផងដែរ ពីមូលហេតុដែលគាត់ដកស្រង់ សារដំណឹងទាំងនោះ ហើយពីអ្វីដែលប្រជាជនគួរ តែធ្វើដើម្បីឱ្យកាន់តែយល់ដឹង ពាក្យទាំងនោះកាន់តែខ្លាំងឡើង។ អ្នកប្រហែលជាចង់អានជំពូក 6–10 មុន ដើម្បីរក្សាពត៌មាន ដូចខាងក្រោម នៅក្នុងគំនិតរបស់អ្នក។ បន្ទាប់មកត្រឡប់ទៅវិញ ហើយសិក្សា រាល់ជំពូក ដោយប្រើជំនួយនៅក្នុងស្បៀវភៅណែនាំ។

- *"ដើម្បីឱ្យបងប្អូនអាចចេះដឹង ហើយសរសើរ ដំកើងដល់ព្រះនាម នៃព្រះរបស់អ្នករាល់គ្នា" (នីហ្វៃទី2 6:4)។ នៅពេលដែល អ្នកអាន នៅក្នុងជំពូកទី 6–8 សូមមើលពីអ្វីដែលយ៉ាកុប បានបង្រៀនអំពីព្រះ ហើយពីរបៀបដែលគាត់បាន លើកទឹកចិត្ត ប្រជាជនរបស់គាត់ ឱ្យលើកដំកើងដល់ទ្រង់ ដើម្បី (ស្រលាញ់ និងធ្វើតាមទ្រង់ ដោយការអោនលំទោន និងការគោរព)។*
- *"ពួកគេប្រៀបដូចជាអ្នករាល់គ្នា" (នីហ្វៃទី 26 :5)។ នេះជាលើកទីពីរ ហើយ ដែលព្យាការីនៅក្នុង ព្រះគម្ពីរមរមន បានទិយាយ ថាប្រៀបប្រដូចពាក្យរបស់អេសាយ ទៅនឹងខ្លួនរបស់យើង (សូមមើលនីហ្វៃទី1 19:23 មើល "ការប្រៀបធៀបបទគម្ពីរ" ផងដែរ នៅក្នុងទំព័រ 00 នៃស្បៀវភៅណែនាំនេះ)។*
- *នៅក្នុងនីហ្វៃទី2 :8–15 យ៉ាកុបបានពន្យល់ ពីអត្ថន័យ នៃដំណឹងខ្លះៗ ដែលគាត់បានអានទៅកាន់ប្រជាជនរបស់គាត់។*
- *"ខ្ញុំបានអានការណ៍ទាំងនេះ គឺដើម្បីឱ្យអ្នករាល់គ្នា អាចដឹងអំពីសេចក្តីសញ្ញានៃព្រះអម្ចាស់" (នីហ្វៃទី2 9:1)។ នៅពេលដែល អ្នកអានជំពូកទី 6–8 ចូរពិចារណា ពីអ្វីដែលបានរៀនអំពីសេចក្តីសញ្ញានៃព្រះអម្ចាស់—តើសេចក្តីសញ្ញានោះជាអ្វី ហើយ ហេតុអ្វីព្រះអម្ចាស់បានតាំងចិត្តបំពេញសេចក្តីសញ្ញានោះ ឱ្យទាល់តែបាន។*
- *"ខ្ញុំពោលការណ៍ទាំងអស់ទៅកាន់អ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នាត្រេកអរ" (នីហ្វៃទី2 9:3)។ នៅពេលដែលអ្នក អានពាក្យរបស់លោកអេសាយ គិតអំពីមូលហេតុដែលសេចក្តីសញ្ញាទាំងនេះបាន ធ្វើឱ្យអ្នកត្រេកអរ។*
- *នៅក្នុងនីហ្វៃទី2 9:4–54 យ៉ាកុបបានពិភាក្សា ពីគោលលទ្ធិនៅពីក្រោយសារដំណឹងរបស់លោកអេសាយ។*
- *នៅក្នុងនីហ្វៃទី2 10 យ៉ាកុបបានបញ្ជូល ការបង្រៀន ដែលគាត់បានបង្រៀនកាលពីថ្ងៃមុន។*

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 6

បារម្ភ (ខ 3)—អារម្មណ៍នៃភាពខ្ចល់ខ្ចាយ

ទូន្មាន (ខ 3)—បានជម្រុញ, លើកទឹចិត្ត

ទង់ជ័យ (ខ 6)—អ្វីមួយដែលរៀបឡើងដោយអំណាច ធ្វើជាច្បាប់ ដើម្បីកាត់ក្តីអ្នកដទៃ ហើយក៏ជាសញ្ញាផងដែរ (នៅក្នុងចំណុចនេះ សញ្ញានោះគឺជាដំណឹងល្អ)

បានបង្ហាញ (ខ 9, 14)—បង្ហាញ, ធ្វើឱ្យមានការទទួលស្គាល់

វាយ (ខ 9)—វាយដោយរំពាត់ ដែលមានចំរៀករឆេចរឆូចតូចៗ នៃឆ្អឹង ឬកំទេចថ្ម នៅខាងចុងគេ

វាយដំ ហើយមានទុក្ខវេទនា (ខ 10)—ដាក់ទណ្ឌកម្ម និងការឈឺចាប់ខាងរូបកាយ និងចុកចាប់ខាងសតិអារម្មណ៍

ដេញទៅមក (ខ 11)—ទៅវិញទៅមក

រងទុក្ខដល់វិនាស (ខ 11)—បានអនុញ្ញាតឱ្យកំទេចទាំងអស់

ព្យុះ (ខ 15)—ព្យុះដ៏កំណាចយោរយៅ

អាសន្នរោគ (ខ 15)—ត្រោះកាច, ជំងឺ

របឹប (ខ 17)—អ្នករងត្រោះដោយខ្មាំងសត្រូវ

ត្រូវដោះចេញ (ខ 16)—ដោះលែងអ្នកទោស

ដែលតតាំងនឹង (ខ 17)—វាយប្រឆាំង

សង្កិតសង្កន់ (ខ 18)—ការប្រព្រឹត្តចំពោះជនណាមួយ ដោយអយុត្តិធម៌

នៅក្នុងនីហ្វៃទី2 6:6–18–តើព្រឹត្តិការណ៍ ដែលកើតឡើងទាំងនេះ មានលំដាប់លំដោយ ដែរឬទេ?

ព្រឹត្តិការណ៍នៅក្នុងនីហ្វៃទី2 6 គឺមិនបានសរសេរតាមលំដាប់លំដោយ ដែលបានកើតឡើង ឬនឹងត្រូវកើតឡើងទេ។ បើព្រឹត្តិការណ៍តាមលំដាប់លំដោយ នោះប្រហែលជាលំដាប់លំដោយ នៃខគឺ 8–11, 6–7, 11–8។ គោលការណ៍ណែនាំ នៃប្រធានបទ ខាងក្រោមគឺមានជាប់ទាក់ទងជាមួយនឹង ខទាំងនេះ:

- ខទី 6–7 មានផ្ទុកនូវការព្យាការណ៍របស់លោកអេសាយ ពីការប្រមូលផ្ទុំនៃសាសន៍អ៊ីស្រាអែល នៅក្នុងជំនាន់របស់យើង ដែលបានជួយដោយ សាសន៍ដទៃ។

- នៅក្នុងខទី 8–9 ប្រាប់ពីការធ្លាក់ចុះនៃយេរូសាឡិម និងភាពជាទាសភាពរបស់សាសន៍យូដា នៅក្នុងបាប៊ីឡូន និងការត្រឡប់ ទៅកាន់ទីក្រុងយេរូសាឡិមវិញ នៅក្រោមការត្រប់ត្រងស៊ីរូសដ៏អស្ចារ្យ នៃពើស៊ី ។
- ការប្រាប់ពីមុននៅក្នុង ខទី 9–11 ពីការយាងមកជាលើកទីមួយ របស់ព្រះយេស៊ូវគ្រីស្ទ ទៅកាន់ពួកសាសន៍យូដា នឹងពីអ្វីដែល ពួកគេនឹងទទួលរងទុក្ខ ហើយត្រូវខ្ចាត់ខ្ចាយ ដោយសារការបដិសេធទ្រង់។
- នៅក្នុងខទី11–18 មានផ្ទុកនូវការពន្យល់បន្ថែមទៀត របស់យ៉ាកុប ពីការព្យាការណ៍របស់លោកអេសាយ នៅក្នុងខទី 6–7 ដែលមានពីការ ប្រមូលផ្ទុំនៃអ៊ីស្រាអែល នៅថ្ងៃចុងក្រោយ។

នីហ្វៃទី2 6:7, 13—"រង់ចាំ" ព្រះអម្ចាស់

ពាក្យថា *រង់ចាំ* ដែលបានប្រើដោយលោកអេសាយ មានន័យថា នៅតែរក្សាការចងចិត្តយ៉ាងខ្លាំង ក្នុងកំឡុងពេលដែលរង់ចាំ រហូតដល់មានអ្វីដែលនឹងកើតឡើង។ ដើម្បី "រង់ចាំព្រះអម្ចាស់" គឺដើម្បីមានសេចក្តីស្មោះត្រង់ចំពោះទ្រង់ រហូតដល់ពេល ដែលទ្រង់យើញថា សមរម្យដើម្បីចាក់ព្រះពររបស់ទ្រង់។

នីហ្វៃទី2 6:12—"សាសនាចក្រដ៏ធំ គួរឱ្យខ្ពើមឆ្អើម"

សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" នីហ្វៃទី1 13:5–9 (ទំព័រ 24)។

នីហ្វៃទី2 6:14—ព្រះអម្ចាស់នឹងប្រុងចាំជួយ ប្រជាជនរបស់ទ្រង់ជាលើកទីពីរ

នៅលើកទីមួយដែលព្រះអម្ចាស់ បានជួយប្រជាជនរបស់ទ្រង់ សាសន៍អ៊ីស្រាអែល គឺទ្រង់បាននាំពួកគេចេញពី ស្រុកអេស៊ីព្ទ ហើយធ្វើឱ្យពួកគេរីកចំរើនឡើងនៅក្នុងដែនដីសន្យារបស់ពួកគេ។ ជាលើកទីពីរដែលទ្រង់ ប្រុងចាំជួយប្រជាជនរបស់ទ្រង់ គឺនៅក្នុងពេលកាន់ កាប់ត្រូតត្រានេះ។ ព្យាការីយ៉ូសែប ស្មីធបានបង្រៀនថាៈ "ពេលវេលានឹងមកដល់ នៅពេលដែលព្រះនៃ អ័ប្រាហាំ, នៃអ៊ីសាក, នៃយ៉ាកុប នឹងបញ្ជូនព្រះពាហុរបស់ទ្រង់ ជាលើកទីពីរដើម្បីជួយកូនចៅ របស់ប្រជាជនរបស់ទ្រង់" (*Teachings of the Prophet Joseph Smith,* 14)។ កូនសោសំរាប់ ប្រមូលផ្ទុំនេះ គឺត្រូវបានសាងឡើងវិញ ដោយ លោកម៉ូសេ នៅក្នុងព្រះវិហារបរិសុទ្ធយើតឡឺន នៅក្នុងឆ្នាំ 1836 (សូមមើល គ និង ស 110:11)។

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព គ ឬក ឬខ ក៏បាន នៅពេលដែលអ្នកអាននៅក្នុងនីហ្វៃទី2 6។

ក ហេតុអ្វីខ្ញុំគួរតែស្តាប់?

1. ចូរនឹកស្រមៃថា អ្នកកំពុងតែរស់នៅក្នុងសម័យនៃយ៉ាកុប។ មកពីការអានរបស់អ្នកនៅក្នុងនីហ្វៃទី2 6:1–4 សរសេរ យ៉ាងតិចមូលហេតុបី ដែលអ្នកអាចលើកទឹកចិត្តមិត្តរបស់អ្នកម្នាក់ ឱ្យស្តាប់ការបង្រៀនរបស់យ៉ាកុបជាមួយអ្នក។
2. ពន្យល់ថាតើមូលហេតុទាំងនោះ អាចអនុវត្ត ចំពោះការស្តាប់តាមថ្នាក់ ដឹកនាំបព្វជិតភាពសព្វថ្ងៃនេះ យ៉ាងដូចម្តេច។

ខ ពន្យល់ពីភាពខុសគ្នា

1. អានពាក្យរបស់យ៉ាកុប ដែលនឹង "បង្ហាញអង្គទ្រង់" នៅលើកទីមួយ និងលើកទីពីរ (សូមមើល នីហ្វៃទី2 6:8–10, 14–15)។ ប្រៀបធៀបពី ការលេចចេញទាំងពីរ ដោយការកត់សំគាលអំពីភាពស្រដៀងគ្នា និងខុសគ្នា។
2. តើហេតុអ្វីអ្នកគិតថា ការយាងមកជាលើកទីពីរ របស់ព្រះអង្គសង្គ្រោះ នឹងមានការខុសគ្នាយ៉ាងខ្លាំង ពីការយាងមកជាលើក ទីមួយរបស់ទ្រង់?

គ ប្រដូចទៅនឹងបទគម្ពីរ

នីហ្វៃនឹងយ៉ាកុប បានប្រាប់ប្រជាជន របស់ពួកគាត់ ឱ្យគួរតែប្រៀបធៀប ឬអនុវត្តបទគម្ពីរ ជាពិសេសគឺពាក្យរបស់លោក អេសាយ ទៅនឹងខ្លួនរបស់ពួកគេ (សូមមើល នីហ្វៃទី1 19:23, នីហ្វៃទី2 6:5)។ ដើម្បីប្រៀបធៀបបទគម្ពីរ ទៅនឹងជីវិតរបស់យើង គឺដើម្បីរៀនពីអត្ថន័យ នៃវគ្គនៅក្នុងព្រះគម្ពីរនោះ កំណត់ថាគោលការណ៍នោះជាអ្វី ហើយអនុវត្តគោលការណ៍ទាំងនោះ ទៅនឹង ខ្លួនរបស់យើង។ ចូរសិក្សា នៅក្នុងនីហ្វៃទី2 6:6–18 ហើយសរសេរយ៉ាងតិច គោលការណ៍ ឬ សេចក្តីពិតបី ហើយប្រាប់ពីគោល ការណ៍ ឬ សេចក្តីពិតនោះ ដែលអាចអនុវត្តទៅនឹងជីវិតរបស់អ្នកយ៉ាងដូចម្តេច។

ពាក្យព្យាការណ៍យ៉ាងពឹស្តារដ៏អស្ចារ្យរបស់លោកអេសាយ គឺត្រូវបានរកឃើញនៅក្នុង អេសាយ 50 នៅក្នុងព្រះគម្ពីប៊ីប ហើយក៏បាន កត់ត្រានៅក្នុងនីហ្វៃទី2 7 ជងដែរ។ មើលសេចក្តីណែនាំនៅក្នុងនីហ្វៃទី2 6 សំរាប់សេចក្តីណែនាដ៏ពិស្តាបន្ថែមទៀត សំរាប់ជំពូក នេះ នឹងជំពូកផ្សេងព្វទៀត គឺចេញពីការសរសេរ របស់លោកអេសាយ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 7

សំបុត្រ (ខ 1)—ឯកសារស្របច្បាប់

ម្ចាស់បំណុល (ខ 1)—មនុស្សដែលជាម្ចាស់លុយ

សំពត់ឆ្មៃ (ខ 3)—សំលៀកបំពាក់ដែលធ្វើដោយ រោមពពែ ឬដោយរោមរបស់អូដ្ហបូកពីរ ដែលគេមនិស្សៀកពាក់ នៅពេល មានទុក្ខព្រួយ

អ្នកដែលវាយ (ខ 6)—មនុស្សដែលវាយ ឬវាត់អ្នកដទៃ

ចោចពុកចង្កា (ខ 6)ទាញរោមចេញពីពុកចង្ការបស់ខ្ញុំ, គឺជាសញ្ញានៃភាពមិនគោរព

ជ្រប់មុខ (ខ 7)—ធ្វើឱ្យអាម៉ាស់មុខ

ថ្មដែកភ្លើង (ខ 7)—ថ្មដ៏រឹង

តាំងជាសុចរិត (ខ 8)—អភ័យទោស

ក្រវាត់ (ខ 11)—ព័ទ្ធជុំវិញ

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក និង ខ នៅពេលអ្នកអាននៅក្នុង នីហ្វៃទី2 7។

ក ស្វែងរកសារដំណឹងមួយ

ចូរស្វែងរកនៅក្នុងនីហ្វៃទី2 7 ហើយស្វែងរកសារដំណឹងមួយ ដែលអ្នកគិតថាអាចជួយ មនុស្សដូចខាងក្រោម។ សរសេរសារដំណឹង នោះនៅក្នុងស្រៀវភៅសរសេររបស់អ្នក ហើយពន្យល់ពីមូលហេតុដែលអ្នក គិតថា វានឹងអាចជួយមនុស្សគ្រប់រូបទាំងនោះ។

1. មនុស្សដែលមិនប្រត្តិបត្តិតាម បទបញ្ញាតិ ហើយមានអារម្មណ៍ថា ព្រះអម្ចាស់នឹងមិនជួយពួកគាត់តទៅទៀតទេ។
2. មនុស្សដែលបាកយល់ ថាហេតុអ្វីបានជាសំខាន់ធ្វើតាមបទញ្ញាតរបស់ព្រះអម្ចាស់។

ខ ការព្យាករណ៍

តើខមួយណានៅក្នុង នីហ្វៃទី2 7 ដែលបានសរសេរដោយលោកអេសាយ ប៉ុន្តែហាក់បីដូចជា ការមានបន្ទូលរបស់ ព្រះយេស៊ូវគ្រីស្ទ? ពន្យល់ពីមូលហេតុ។

នីហ្វៃទី2 8

"សូមតើនឡើង សូមតើនឡើង"

តើមានន្យណាម្នាក់ ឬអ្វីមួយដែលអ្នកតែងតែអាច ពឹងអាស្រ័យបាន នៅក្នុងជីវិតនេះទេ? លោកអេសាយបានឆ្លើយទៅនឹង សំនួរនោះ ដែលអាចរកនៅក្នុងនីហ្វៃទី2 8 ។ នៅពេលដែលអ្នកអានន្ទូវជំពូកនោះ សញ្ជឹងគិត វាពរជ័យ ដែលនឹងអាចសាងជីវិត របស់អ្នកនៅលើ គ្រឹះដែលនឹងមិនរលំឡើយ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 8

ដាប់ (ខ 1)—កាត់

ដើមដៃ (ខ 5, 9)—កំលាំង, អំណាច

លើកចោល (ខ 6)—បានធ្វើរួចហើយ

សេចក្តីត្មះតិះដៀល (ខ 7)—ក្តីបន្ទោសមិនយល់ព្រម

ពាក្យបង្កាច់ (ខ 7)—ធ្វើឱ្យអាម៉ាស់មុខ, ពាក្យប្រមាថ

ប្រោសលោះ (ខ 10)—ប្រោសលោះ, ជួយឱ្យរួចពីទាសភាព (ខនេះគឺហាក់ដូចជាសំដៅទៅសាសន៍អ៊ីស្រាអែល ដែលលើកត្មាទាំងហ្វូងចេញពីអេស៊ីព្ទ នៅសម័យរបស់ម៉ូសេ ឆ្លងកាត់សមុទ្រក្រហម)

សេចក្តីក្រោធរបស់អ្នក ដែលសង្កត់សង្កិន (ខ 13)—ភាពសាហាវ ឬភាពយោយៅរបស់ខ្មាំងសត្រូវ

អ្នកដែលជាប់ជាឈ្លើយ (ខ 14)—មនុស្សដែលធ្លាក់ក្នុងសេវកភាព នៅក្រៅដែនដីកំណើតរបស់ពួកគេ

ជាប្រាកដ (ខ 14)—ប្រញ៉ាប់ប្រញាល់

កាក (ខ 17, 22)កករ និងរូបធាតុផ្សេងព្ធ ដែលមាននៅផ្នែកខាងក្រោមនៃ ដបស្រា "ជឹកនូវកាក" អ្វីមួយផ្នែកអាក្រក់ ជាងគេបំផុត

សេចក្តីបន្ទោស (ខ 20)—ការធ្វើទោសដើម្បីកែលំអ

ពួកមិនកាត់ស្បែក (ខ 24)—មិននៅក្នុងសេចក្តីសញ្ញា, មនុស្សដែលមិនគោរព ឬប្រត្តិបិត្តតាមព្រះអម្ចាស់

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក និង ខ នៅពេលដែលអ្នកអាននៅក្នុង នីហ្វៃទី2 8។

ក នៅក្នុងពាក្យរបស់អ្នកផ្ទាល់

នៅក្នុងនីហ្វៃទី2 8:17–21 (សូមមើលអេសាយ 51:17–21 ផងដែរ) ព្រះអម្ចាស់បានប្រាប់ឱ្យសាសន៍អ៊ីស្រាអែលឱ្យដឹងថា វាគ្មាន សេចក្តីសុខសាន្ត ឬ សេចក្តីលួងលោមនៅក្នុងអំពើបាបទេ។ ផ្ទុយទៅវិញព្រះអម្ចាស់ បានថ្លែងពីសេចក្តីសុខសាន្ត និងការ លួងលោមដែលមកពីការធ្វើតាមទ្រង់។ អាននីហ្វៃទី2 8:3, 6–8, 11–12, 22–24 ហើយសរសេរតាមពាក្យសំដីផ្ទាល់ របស់អ្នកពីអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល ទៅកាន់សាសន៍អ៊ីស្រាអែលអំពី ជនទាំងឡាយ ណាដែលទុកចិត្តទ្រង់ និងធ្វើតាមទ្រង់។

ខ ប្រដូចទៅនឹងបទគម្ពីរ

ជ្រើសរើសសេចក្តីថ្លែង ក្នុងចំណោមសេចក្តីថ្លែងទាំងនោះ ហើយសរសេរពីអ្វីដែលអ្នក អាចជាទិយាយទៅកាន់មិត្តម្នាក់របស់អ្នក ដែលបានបង្ហាញពីអារម្មណ៍។ ប្រើអ្វីដែលអ្នកបានរៀននៅក្នុងនីហ្វៃទី2 8 ហើយរួមទាំងពាក្យសន្យាមួយ ឬច្រើនទៀត របស់ព្រះ អម្ចាស់ នៅពេលដែលអ្នកធ្វើសកម្មភាព ក។

1. "ខ្ញុំដឹងថា ខ្ញុំគួរតែប្រែចិត្ត ហើយត្រឡប់ទៅចង់ផ្លាស់វិញ ហើយរស់នៅតាម ការបង្រៀននៃ ដំណឹងល្អ តែខ្ញុំព្រួយបារម្ភ ពីអ្វីដែល មិត្ត និងនិយោជក អាចគិតឬនិយាយអំពីខ្ញុំ។ ខ្ញុំចង់ផ្លាស់ប្តូរជីវិតយ៉ាងខ្លាំង!"
2. "ខ្ញុំបានព្យាយាមកែប្រែចិត្ត តែខ្ញុំមានអារម្មណ៍មានបាប គ្រប់ពេលវេលា។ តើខ្ញុំពិតជាបានទទួលការអភ័យទោស មែនឬ ហើយអាចមានអារម្មណ៍ជ្រះស្អាតម្តងទៀតឬ? ហើយបើទោះបីជាខ្ញុំកែប្រែចិត្ត—ខ្ញុំបានធ្វើឱ្យមនុស្សជាច្រើនឈឺចាប់ ដោយមក ពីអំពើបាបរបស់ខ្ញុំរួចទៅហើយ។ តើការប្រែចិត្តរបស់ខ្ញុំមានប្រយោជន៍អ្វី?"
3. "តើហេតុអ្វីខ្ញុំគួរតែប្រែចិត្ត? តើហេតុអ្វីការរស់នៅតាមសាសនា ប្រសើរជាងជីវិតដែលខ្ញុំរស់នៅសព្វថ្ងៃនេះ?"

នីហ្វៃទី2 9

"ឱ ផែនការណ៍នៃព្រះ
របស់យើងធំណស់ន៏!"

នៅក្នុងជំពូករបស់អេសាយ ដែលយ៉ាកុបបានដកស្រង់ នៅក្នុងនីហ្វៃទី2 6–8 បានបើកសំដែងច្រើនអំពី អំណាចរបស់ព្រះអម្ចាស់ ដែលបានរំដោះប្រជាជន

របស់ទ្រង់។ ទោះបីជាយ៉ាងណាក៏ដោយ អេសាយបានថ្លែង ពីអ្វីដែលព្រះអម្ចាស់នឹងធ្វើ ចំពោះវង្ស អ៊ីស្រាអែល ដើម្បីបញ្ចុះបញ្ចូលពួកគេ ឱ្យប្រែចិត្តពីសត្រូវរបស់ពួកគេ ហើយប្រមូលផ្តុំពួកគេទៅកាន់ដែនដីសន្យា យ៉ាកុបបានលើកទឹកចិត្ត ប្រៀបធៀបពាក្យ របស់លោកអេសាយ ទៅនឹងជីវិតរបស់យើងម្នាក់ឯ (សូមមើល នីហ្វៃទី2 6:5)។ សេចក្តីស្លាប់និងស្ថានឃុំព្រលឹង ដែលជាឧទាហរណ៍មួយដ៏អស្ចារ្យ ពីការប្រៀបធៀប ការបង្រៀនរបស់អេសាយ គឺត្រូវបានរកឃើញនៅក្នុង នីហ្វៃទី2 9 ដូចដែលយ៉ាកុបបានបង្រៀន និងថ្លែងទីបន្ទាល់អំពីអំណាចរបស់ព្រះអម្ចាស់ ដើម្បីបញ្ចុះបញ្ចូលពួកយើងចេញពី សត្រូវដ៏មានអំណាច របស់យើង—សេចក្តីស្លាប់ និងស្ថានឃុំព្រលឹង។ ជំពូកនេះមានទូវសេចក្តីពិតដ៏សំខាន់ៗ អំពីផែនការណ៍របស់ព្រះវរបិតាសួគ៌ សំរាប់កូនចៅរបស់ទ្រង់រួមទាំងសារៈ សំខាន់នៃជង្ហាយធួន របស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងគំរោងការណ៍នោះ។



ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 9

ប្រទានមកលើ (ខ 3)—ឱ្យ

ជាការចាំបាច់ (ខ 5, 47–48)—ចាំបាច់, សំខាន់

ត្បិតជាចាំបាច់ (ខ 5)—ចាំបាច់ ឬភាពសមរម្យ

នឹងនៅក្នុង (ខ 58)—នៅក្រោមអំណាច ឬការត្រួតត្រងរបស់

ពុករលួយ (ខ 7)—ពាក្យនេះសំដៅទៅលើរូបកាយមនុស្ស, ដែលនឹងស្លាប់

មិនពុករលួយ, ភាពមិនពុករលួយ (ខ 7, 13)—ពាក្យនេះសំដៅទៅលើរូបកាយដែលបានរស់ឡើងវិញដែលនឹងរស់នៅ ជារៀងរហូត

សេចក្តីជំនុំជំរះលើកទីមួយ (ខ 7,)—"នោះនឹងត្រូវស្លាប់ជាមិនខាន"(លោកុប្បត្តិ 2:17) គឺជាសេចក្តីជុំវិញជុំវិញជំពូងបំផុត របស់ព្រះដែលបានប្រកាសទៅកាន់មនុស្សលោក

ពោកបញ្ជោត (ខ 9)—ពោក, ធ្វើឱ្យយល់ខុស

ក្លែងខ្លួនជា (ខ 9)—ភាពដូចគ្នា

អមតៈ (ខ 13, 15)—អាចរស់រហូតតទៅ (ជាពិសេសក្នុងសភាពរស់ឡើងវិញ)

បានបញ្ចោញ (ខ 17)—សម្តែង, បំពេញ

ពុំញញើត (ខ 18, 42)—ស្ងប់

ការកាត់ទោស (ខ 25)—ដំនុំជំរះឱ្យមានទោស

ឧបាយកល (ខ 28)—ការពោកប្រាស់

អំពើមោឃៈ (ខ 28)—អំណត, អត្ថានិយម

ភាពទន់ទាប (ខ 28)—ភាពទន់ខ្សោយ

មិនផ្តល់ប្រយោជន៍អ្វីដល់ពួកគេឡើយ (ខ 28)—មិនធ្វើល្អចំពោះពួកគេ

ការបណ្តោយខ្លួនឱ្យធ្លាក់ (ខ 39)—បណ្តោយឱ្យធ្លាក់ក្នុងការល្បួង

ចិត្តដែលជាប់ទៅ (ខ 39)—ខាងលោកិយ, ឱ្យសេចក្តីចង់បានខាងលោកិយ ឬសេចក្តីប៉ងប្រាថ្នា

អ្នកឈ្លាសវៃ (ខ 43)—ប្រយ័ត្នប្រយែង, ប្រាជ្ញា

ត្រូវខ្យិ (ខ 46)—បានបង្ខំ, បង្គាប់

ចំណី (ខ 46)—អ្នករងគ្រោះ

កើតទុក្ខ (ខ 47)—ធ្វើទុក្ខបុកម្នេញ

ស្ងប់ខ្ពើម (ខ 49)—ស្ងប់, មិនចូលចិត្ត

ការយាងចុះមក (ខ 53)—ការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ជាអង្គដ៏ទេវភាពចំពោះអ្នកដទៃ

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព (ក–ឃ)ដូចខាងក្រោម នៅពេលដែលអ្នកសិក្សា នីហ្វៃទី2 9។

ក ធម្មជាតិរបស់ព្រះអទិទេព

ព្យាការីយ៉ូសែប ស៊្មីធ បានបង្រៀនថា វត្ថុលក្ខណៈមួយ ក្នុងចំណោមវត្ថុដែលពិសេសៗ ដើម្បី "អនុវត្តសេចក្តីជំនឿចំពោះព្រះ ទៅកាន់ជីវិត និង ផែនការណ៍សង្គ្រោះ" គឺត្រូវការ "គំនិតដ៏ត្រឹមត្រូវមួយ អំពីលក្ខណៈ, ភាពល្អឥតខ្ចោះ និងគលក្ខណៈសម្បត្តិរបស់ [ព្រះ]" (*Lectures on Faith* [1985], 38)។ សរសេរពីអ្វីដែលអ្នក បានរៀនអំពីព្រះចេញពីសេចក្តីថ្លែងប្រកាស់របស់យ៉ាកុប (សេចក្តីថ្លែង ដែលផ្តើមដោយការប្រកាស់ "ឱ្យ") នៅក្នុងនីហ្វៃទី2 9:8, 10, 13, 17, 19–20។

ខ សរសេរសំនួរ

វិធីសាស្ត្រមួយ នៃការសិក្សាព្រះគម្ពីរ គឺការសញ្ជឹងគិត ពីអ្វីដែលអ្នកកំពុងអាន ដែលមានជាទូទៅចំលើយសំខាន់ៗពីព្រះ ហើយបន្ទាប់ មកគឺសួរខ្លួនរបស់អ្នកផ្ទាល់ "តើសំនួរទាំងនោះគឺជាអ្វី?" សេចក្តីពិតជាច្រើន អំពីផែនការណ៍នៃ សេចក្តីសង្គ្រោះរបស់ ព្រះវរបិតាសួគ៌ មានចំពោះកូនចៅរបស់ទ្រង់ គឺមាននៅក្នុងនីហ្វៃទី2 9:5–27។ សរសេរយ៉ាងតិចឱ្យបានគ្រាំសំនួរសំខាន់ៗ អំពី គោលលទ្ធិដែលអាចឆ្លើយចេញពីខទាំងនេះ។ បន្ទាប់ពីសួរសំនួរនីមួយៗ រកចំលើយ នៅក្នុងនីហ្វៃទី2 9។

គ ទន្ទេញព្រះគម្ពីរ—នីហ្វៃទី2 9:28–29

1. តើគោលលទ្ធិ ដែលបានបង្រៀននៅក្នុង នីហ្វៃទី2 9:20 អាចអនុវត្តចំពោះបញ្ហា របស់មនុស្សខ្លះៗ ដែលយ៉ាកុបបាននិយាយ បានយ៉ាងដូចម្តេច? (សូមមើល ខ 28–29)។
2. សូមប្រើនីហ្វៃទី2 9:28–29 ដើម្បីជួយអ្នកក្នុងការពន្យល់ ពីអ្វីដែលអ្នកអាចនឹងនិយាយទៅកាន់សមាជិកនៃសាសនាចក្រ ម្នាក់ដែលបានធ្វើដូចនឹងសេចក្តីថ្លែងការណ៍ដូចខាងក្រោមៈ
   ក. "ខ្ញុំមិនចាប់ញ្ជាយាមដើម្បី មានការអប់រំច្រើនពេកទេ។ អ្វីៗទាំងអស់នោះមិនសំខាន់ ហើយជារបស់លោកិយតែប៉ុណ្ណោះ។"
   ខ. "វាមិនអ្វីទេគ្រាន់ តែផឹកគ្រឿងស្រវឹងតែបន្តិចបន្តួច។ អ្នកវិទ្យាសាស្ត្របានបង្ហាញថា មនុស្សផឹកគ្រឿងស្រវឹងបន្តិចបន្តួច គឺមានសុខភាពល្អជាងមនុស្សដែលមិន ដែលផឹកគ្រឿងស្រវឹងសោះ។"
   គ. "ខ្ញុំមិនយល់ទេថា ហេតុអ្វីក៏គាត់ត្រូវបាន ហៅឱ្យបំរើនូវកិច្ចការនោះនៅក្នុងសាសនាចក្រ។ ខ្ញុំមានបទពិសោធន៍ច្រើនជាងគាត់ ហើយចំពោះព្រះគម្ពីរវិញ គាត់មិនឆ្លាតណាស់ណាទេ។"

ឃ គូររូបភាព

ផ្គូរផ្គងគំនូរទៅនឹងអ្វី ដែលបានបង្ហាញនៅក្នុងនីហ្វៃទី2 9:41–42

នីហ្វៃទី2 10

ភាពពេញលេញនៃ សេចក្តីសញ្ញារបស់ព្រះអម្ចាស់

ជាថ្មីម្តងទៀត យ៉ាកុបបានពិភាក្សាពីអនាគតរបស់ វង្សអ៊ីស្រាអែល នៅក្នុងនីហ្វៃទី2 10។ គាត់បានព្យាករពីអ្វី ដែលនឹងកើត ឡើងចំពោះសាសន៍យូដា នឹងអ្វីដែលអាចនឹងកើតឡើងចំពោះ ប្រជាជនរបស់គាត់ផ្ទាល់ នឹងអំពីអ្វីដែលនឹងកើតឡើងចំពោះ សាសន៍ដទៃដែលនឹងទទួលដែនដីរបស់ប្រជាជនរបស់គាត់ជាមរតក។ រកមើលពីមូលហេតុដែលសាសន៍យូដា ត្រូវខ្ចាត់ខ្ចាយ ហើយពីអ្វី ដែលនឹងត្រូវកើតឡើង ពីមុនពួកគេត្រូវបានប្រមូលផ្តុំមកផ្ទះវិញម្តងទៀត។ ចូរកត់សំគាល់ផងដែរពីអ្វីដែលយ៉ាកុប បាននិយាយពីអ្វីដែលយើងត្រូវធ្វើពីមុនយើងអាច "ទទួលទៅក្នុងនគរដ៏អស់កល្បជានិច្ចនៃព្រះ" (ខ 25)។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 10

គឺជាការចាំបាច់ (ខ 3)—ការចាំបាច់

កើតឡើង (ខ 4)—បានសម្តែង

ឧបាយកលផ្នែកសង្ឃ (ខ 5)—ការង្រៀនសំរាប់ប្រយោជន៍ និងការសរសើរ (សូមមើល នីហ្វៃទី2 2៖29)

បែកខ្ញែក (ខ 8)—ខ្ចាត់ខ្ចាយ

ពង្រឹង (ខ 12)—ពង្រឹង

បាវគេ (ខ 16)—អ្នកបំរើ ឬ ទាសករ

នឹងទុក (ខ 19)—តែងតាំងសំរាប់គោលបំណងពិសិដ្ឋ

សម្រុះសម្រួលខ្លួន (ខ 24)—ត្រូវប្រត្តិបិត្តតាម, ស្រុះស្រួលជាមួយ

ព្រះគុណអស្ចារ្យ (ខ 25)—អំណាចពីព្រះ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខដូចខាងក្រោម នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 10។

ក្ប បញ្ចប់នូវឃ្លាខាងក្រោម

1. ជាតិសាសន៍យូដា គឺជាជាតិសាសន៍តែមួយនៅលើផែនដី ដែលនឹង . . . (សូមមើលនីហ្វៃទី2 10៖3–4។)
2. មនុស្សនៅក្រុងយេរូសាឡិម បានឆ្កាងព្រះយេស៊ូវ ដោយសារតែ . . . (សូមមើល ខ 4–5។)
3. ដោយសារអំពើបាបរបស់ពួកគេ សាសន៍យូដា . . . (សូមមើលខ 6។)
4. សាសន៍យូដានឹងត្រូវបានប្រមូលផ្តុំ . . . (សូមមើល ខទី 7–9។)

ខ អ្វីដែលគួរតែចងចាំ

1. តាមរយៈសក្ខីភាពរបស់គាត់នៅក្នុងនីហ្វៃទី2 10៖23–24 តើគំនិតសំខាន់ពីរដែលយ៉ាកុបចង់ឱ្យប្រជាជន របស់គាត់ចងចាំ ជាអ្វី? តើវាមានន័យយ៉ាងដូចម្តេចដើម្បី "សម្រុះសម្រួលជាមួយព្រះ"?
2. តើជីវិតរបស់អ្នកនឹងមានលក្ខណៈខុសប្លែកយ៉ាងដូចម្តេច បើអ្នកតែងតែ ចងចាំសេចក្តីពិតទាំងពីរនោះ?
3. សេរសេរអំពីរឃ្យេបពីរ ដែលអ្នកនឹងព្យាយាមចងចាំ ពីសេចក្តីពិតទាំងពីរនេះ សំរាប់សប្តាហ៍ក្រោយ។

នីហ្វៃទី2 11

សាក្សីបីនាក់នៃព្រះយេស៊ូវគ្រីស្ត

បន្ទាប់ពីបានអានពាក្យ របស់យ៉ាកុប នៅក្នុងជំពូកទាំងប្រាំពីមុន យើងត្រឡប់ទៅកាន់ពាក្យ របស់នីហ្វៃវិញម្តងទៀត។ នីហ្វៃក៏បានដកស្រង់ពាក្យ របស់ព្យាការីអេសាយ ហើយនៅក្នុងនីហ្វៃទី2 11 គាត់បានឱ្យនូវមូលហេតុខ្លះៗ ដែល គាត់បានធ្វើដូច្នេះ។

នៅក្នុងទំព័របុពូកថា នៃព្រះគម្ពីរមរមន អ្នកបានអានពីទីបន្ទាល់ របស់សាក្សីពិសេសបីនាក់ អំពីព្រះគម្ពីរមរមន។ នៅក្នុងនីហ្វៃទី2 11 អ្នកនឹងអានអំពីសាក្សីពិសេសបីនាក់ នៅក្នុងព្រះគម្ពីរមរមន។ រកមើលពីអ្វីដែលគេបានធ្វើទីបន្ទាល់អំពី។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 11

ល្មម (ខ 1)—ត្រាប់ត្រាន់

និមិត្តរូប (ខ 4)—និមិត្តសញ្ញា

នីហ្វៃទី2 11៖4—តើ "អ្វីឲដែលត្រូវបានប្រទានឱ្យ ដោយព្រះ" ជានិមិត្តសញ្ញាពីព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច?

នីហ្វៃបានថ្លែងទីបន្ទាល់ថា "អ្វីឲដែលត្រូវបានប្រទានឱ្យដោយព្រះ" គឺជាគំរូ ឬនិមិត្តសញ្ញាអំពីព្រះយេស៊ូវគ្រីស្ត អំពីជីវិត និងការ បង្រៀន និងដង្វាយធួនរបស់ទ្រង់។ ចំពោះព្យាការីម៉ូសេ ព្រះអម្ចាស់បានប្រកាសថា "អ្វីឲទាំងអស់ គឺត្រូវបានបង្កើតនឹងធ្វើ ឡើងដើម្បីថ្លែងអំពីទ្រង់" (សូមម៉ូសេ 6៖63)។ ជីវិតនិងបេសកម្មរបស់ម៉ូសេ គឺជាគំរូជាក់ស្តែង ដែលបង្ហាញថា អ្វីឲទាំងអស់នោះ ជាការពិត។ ម៉ូសេបានធ្វើអ្វី ចំពោះសាសន៍អ៊ីស្រាអែល នៅសម័យរបស់គាត់ ជាឧទាហរណ៍ ឬគំរូមួយនៃអ្វីដែលព្រះយេស៊ូវគ្រីស្ត នឹងធ្វើចំពោះមនុស្សទាំងឡាយ។ សំរាប់ប្រជាជនរបស់គាត់ម៉ូសេ គឺជាអ្នកជួយបញ្ជូនអ្នកង្គ្រោះជាអ្នកចេញនូវក្រិត្យវិន័យជាអ្នក ជំនុំជំរះនិងជាអ្នកដឹកនាំ។ តាំងពីយូរណាស់មកហើយ ព្រះយេស៊ូវគ្រីស្ត ជាតួអង្គធ្វើកិច្ចការអស់ទាំងនោះ ហើយមានច្រើនជាងនោះទៀតសំរាប់កូនឲទាំងអស់របស់ព្រះវរបិតាសួគិ។

វាមិនត្រឹមតែការរស់នៅរបស់ព្យាការី ដែលរំលឹកយើងអំពីព្រះអង្គសង្គ្រោះនោះទេ។ ព្រះយេស៊ូវ ទ្រង់ផ្ទាល់បានប្រើនូវកិច្ចការយ៉ាង សាមញ្ញដើម្បីធ្វើជានិមិត្តសញ្ញា អំពីតួនាទី របស់ទ្រង់ក្នុងជីវិត របស់យើង។ ទ្រង់បានបង្រៀនថា ទ្រង់គឺជានំបុ័ង (សូមមើលយ៉ូហាន 6:35)ទ្រង់គឺជាទឹក (សូមមើលយ៉ូហាន 7:37–38) ជាពន្លឺ (សូមមើលយ៉ូហាន 8:12) ទ្រង់គឺជាគល់ (មើល យ៉ូហាន 15:5) ជាមេមាន់ (សូមមើលម៉ាថាយ 23:37)។ អែឌើរ ប្រ៊ីស អរ. មិកខនឃី ដែលជាសមាជិក នៃក្រុមសាវក ទាំងដប់ពីរនាក់បានបង្រៀនថាៈ "បើយើងមាននូវការចេះដឹងគ្រប់គ្រាន់យើងនឹងអាចឃើញនូវ គ្រប់គោលលទ្ធិនៃដំណឹងល្អ នៅក្នុងគ្រប់ពិធីការ ដែលជាផ្នែកបង្ហាញឱ្យឃើញពីសាសនា នូវរាល់ការសម្តែង ដែលបានបញ្ជាដោយព្រះ នៅគ្រប់អ្វីឲ្យទាំងអស់ ដែលព្រះអទិទេពបានឱ្យដល់ កូនចៅរបស់ទ្រង់ ដែលជានិមិត្តសញ្ញាពីការបង្រៀន ដ៏អស់កល្បជានិច្ច នៃព្រះគ្រីស្ត ដ៏អស់កល្បជានិច្ច" (*The Promised Messiah: The First coming of Christ* [1978], 378)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សានីហ្វៃទី2 11។

ក គឺជានរណា? គឺនៅកន្លែងណា? គឺហេតុអ្វី?

1. *នរណា* ជាសាក្សីពិសេសទាំងបីនាក់ របស់ពីព្រះយេស៊ូវគ្រីស្ត ដែលបានទិយាយនៅក្នុងនីហ្វៃទី2 11?
2. *ហេតុអ្វី* អ្នកគិតថា នីហ្វៃចង់ឱ្យយើងដឹង អំពីសាក្សីទាំងនាក់នេះ? នៅក្នុងចំលើយរបស់អ្នក ប្រើពាក្យសំដីនីហ្វៃបានទិយាយ នៅក្នុងនីហ្វៃទី2 11 ជាមួយនឹងគំនិតរបស់អ្នកផ្ទាល់។

ខ គឺអ្វីនាំឱ្យអ្នកមានសេចក្តីរីករាយ?

1. ស្វែងរក "ចិត្តខ្ទុំរីករាយ" ឱ្យបានប្រាំដង ដែលនីហ្វៃបានទិយាយនៅក្នុងនីហ្វៃទី2 11។ សរសេរពីអ្វី ដែលបាននាំឱ្យនីហ្វៃ មានសេចក្តីរីករាយ និងពេញចិត្ត។
2. សរសេរជាឃ្លារបស់អ្នកផ្ទាល់អំពី "ចិត្តខ្ទុំរីករាយ" ឱ្យបានបីឃ្លា ដូចគ្នាទៅនឹងរបៀបរបស់នីហ្វៃ . . . ដែលជា នូវអ្វីដែលនាំអ្នក ឱ្យមានសេចក្តីរីករាយ និងភាពពេញចិត្ត ហើយសូមពន្យល់ពីមូលហេតុ។

នៅក្នុងជំពូកទាំងដប់បី ខាងមុខនេះ នីហ្វៃទី2 12–24 គឺត្រូវបានដកស្រង់ចេញពីព្រះគម្ពីរ របស់លោកអេសាយ (សូមមើល អេសាយ 2–14)។ នីហ្វៃបានទិយាយថា គាត់បានបញ្ជូលសក្ខីភាព របស់លោកអេសាយពីព្រោះ ជំពូកទាំងនោះ មានផ្ទុកនូវ សក្ខីភាពអំពីព្រះគ្រីស្ត ដូច្នេះអស់អ្នកដែលបានអាន នោះនឹង "លើកចិត្តគេឡើង ហើយអរសប្បាយសំរាប់មនុស្សទាំងអស់" (នីហ្វៃទី2 11:8 មើលខ 2 ផងដែរ)។ រំលឹកឡើងវិញនូវអ្វីដែលគាត់ និងប្អូនប្រុសរបស់គាត់គឺ យ៉ាកុបបានទិយាយពីមុន នីហ្វៃបានបង្រៀនថា "ប្រៀបធៀប" ពាក្យសំដីអេសាយ ទៅនឹងខ្លួនរបស់យើង នៅពេលដែលយើងព្យាយាម ចង់បញ្ជាក់ពីអ្វីមួយ ដែលបានកើតឡើង នៅក្នុងព្រះគម្ពីរ ដែលអាចអនុវត្តទៅនឹង ជីវិតយើងសព្វថ្ងៃនេះ។

បន្ទាប់ពីបានដកស្រង់ចេញពីព្រះគម្ពីរអេសាយ នីហ្វៃបានសរសេរពីការយល់ដឹងសារដំណឹង របស់លោកអេសាយ។ អ្នកអាចអាន នៅក្នុងនីហ្វៃទី2 25:1–8 ពីមុនអ្នកអានទៅនីហ្វៃទី2 12–24 ហើយស្វែងរកពីអ្វីដែលនីហ្វៃ បានបង្រៀនអំពីការព្យាករណ៍ របស់លោកអេសាយ។ លោកអេសាយ គឺខុសពីអ្នកសរសេរផ្សេងឲ្យទៀត នៅក្នុងព្រះគម្ពីរមរមន។ គាត់បានប្រើជាទំរង់កំណាព្យ នឹងជាភាសានិមត្តិសញ្ញា ដូចជា សណ្តាប់នៃពួកសាសន៍យូដា ដើម្បីផ្ទេរសារដំណឹងរបស់គាត់។ នៅពេលដែលអ្នកសំលឹងរកនូវ គោលការណ៍នៃដំណឹងល្អដែលតំណាងដោយកំណាព្យ និងនិមិត្តសញ្ញារបស់គាត់នោះ ហើយអាចប្រៀបធៀប ទៅនឹងសម័យរបស់ យើងទៅនឹងខ្លួនរបស់អ្នក អ្នកអាចរកនូវសារដំណឹងជាច្រើន នៅក្នុងជំពូកនេះ ដែលវាមានន័យយ៉ាងជ្រាវជ្រៅចំពោះអ្នក។

នៅពេលដែលលោកអេសាយ បានព្យាករ នៅពេលនោះមានអាណាចក្រពីរ នៃសាសន៍អ៊ីស្រាអែល—អាណាចក្រខាង ត្បូងនៃសាសន៍យូដា និងអាណាចក្រខាងជើង នៃសាសន៍អ៊ីស្រាអែល (ត្រូវបានហៅថា អេប្រាហិម ផងដែរ)។ សាសន៍ អ៊ីស្រាអែលជាច្រើន នៅក្នុងអាណាចក្រទាំងពីរបានចាកចេញពីព្រះអម្ចាស់ហើយដាក់ សេចក្តីទុកចិត្ត របស់ពួកគេ ទៅលើរូបចំលាក់ និងនៅក្នុងប្រាជ្ញា និងកំលាំងរបស់ពួកគេទៅវិញ។ បន្ទែមពីលើនោះ ទៅទៀត សាសន៍ទាំងពីរ កំពុងតែនៅក្រោមការគំរាម គំហែងដោយសារសង្គ្រាម នៃសត្រូវជិតខាងជាក់ស្តែងគឺអំណាច នៃសាសន៍អាសស៊ើរ។ សារដំណឹងរបស់លោកអេសាយ គឺបញ្ជាក់ ច្បាស់អំពីអំពើបាបរបស់សាសន៍អ៊ីស្រាអែល និងលទ្ធិផលនៃអំពើបាប អំពីអ្វីដែលមនុស្សគួរធ្វើ ដើម្បីប្រែចិត្ត ហើយសេចក្តី មេត្តាដ៏ទន់ភ្លន់ទាំងឡាយ នៃព្រះអម្ចាស់ និងមានចំពោះពួកគេ បើពួកគេប្រែចិត្ត។ សារដំណឹងនេះ អាចប្រៀបប្រដូច ទៅដល់ ប្រជាជននៃសេចក្តីសញ្ញាទាំងអស់ទាំងអស់ ដែលបានវង្វេងចេញពីព្រះអម្ចាស់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 12

ជំកើងឡើង (ខ 2, 11, 17)—លើកឡើងខ្ពស់, ទុកនៅកន្លែងដែលខ្ពស់

នឹងសំរេចរៀង (ខ 4)—ហៅឱ្យប្រែចិត្ត, ពាក្យស្តីបន្ទោស

ទំនៀមទំលាប់ពីស្រុកខាងកើត (ខ 6)—យកការចិញ្ចឹមបីបាច់ខាងវិញ្ញាណ របស់ពួកគេពីមនុស្សក្រៅសាសនា នៃសាសន៍អាស៊ើរ និងបាប៊ីឡូន

ត្រូទាយ (ខ 6)—មនុស្សដែល *ព្យាយាម* ប្រាប់ពីព្រឹត្តិការណ៍ ពេលអនាគតមុន, ត្រូទាយ

ឬកខ្ពស់ (ខ 12)—មោទនភាព

ចិត្តឆ្មើងឆ្មៃ (ខ 11, 17)—អំនួត

សាបសូន្យទៅអស់រលីង (ខ 18)—កំទេចអស់រលីង

បោះចោល (ខ 20)—គប់ចោល

ចូរលែងទុកចិត្តដល់មនុស្ស (ខ 22)—ឈប់ទុកចិត្តលើមនុស្ស

ពឹងដល់ (ខ 22)—បានគិត, បានពិចារណា

នីហ្វៃទី2 12:2–4—“ភ្នំជាទីសាងព្រះវិហារនៃព្រះអម្ចាស់”

នៅសម័យរបស់លោកអេសាយ ឃ្លាដែលថា “ភ្នំជាទីសាងព្រះវិហារនៃព្រះអម្ចាស់” គឺសំដៅយ៉ាងជាក់លាក់អំពីព្រះវិហារបរិសុទ្ធ នៅក្នុងយេរូសាឡិម។ ព្យាការីនៅសម័យយើងបានបង្រៀនថា ឃ្លានោះក៏មានន័យចំពោះ ព្រះវិហារបរិសុទ្ធទាំងអស់ ដែលក្លាយជា “ភ្នំនៃព្រះអម្ចាស់” ដែលមនុស្សអាចមក ហើយរៀនពីផ្លូវរបស់ព្រះ ដូច្នោះពួកគេអាចដើរ នៅផ្លូវរបស់ទ្រង់។ ប្រធាន ហារីគ ដបុលយូ ហ៊ីនធើរ បានបង្រៀនថា និមិត្តរបស់លោកអេសាយ គឺអាចអនុវត្តទាំងចំពោះបុគ្គល និងលោកិយទាំងមូល។ បន្ទាប់ពីការ លើកទឹកចិត្តសមាជិកដើម្បីធ្វើ “ថ្វាយបង្គំ និងសេចក្តីសញ្ញាព្រះវិហារបរិសុទ្ធ និងការរៀបអាពាហ៍ពិពាហ៍ នៅឯព្រះវិហារបរិសុទ្ធ ជាគោលបំណងរបស់យើងនៅលើផែនដី និងមានពិសោធនៅលោកិយនេះ” គាត់បានឱ្យនូវសេចក្តីអញ្ជើញ និងការសន្យាដូចខាងក្រោមៈ

“សូមឱ្យអ្នកទុកអន្ទន៉យ និងភាពស្រស់ស្អាត និងសេចក្តីសុខសាន្ត នៃព្រះវិហារបរិសុទ្ធ ចូលមកក្នុងជីវិតរាល់ថ្ងៃរបស់អ្នក ឱ្យកាន់តែជាក់ច្បាស់ដើម្បីឱ្យថ្ងៃសហវត្សរ៍នឹងខាងជីវិតមតះដ៏ល្អក្រៃលែង ដែលជាពេលសន្យាថា ‘ពួកគេនឹងយកដាវរបស់ ខ្លួនដំធ្វើជាជាលន៉ង្គល ហើយលំពែងគេធ្វើជាដង្កាវវិញ នគរមួយនឹងមិនលើកដាវទាសនឹងនរគរមួយទៀតឡើយ . . . [ប៉ុន្តែនឹង] ដើរក្នុងពន្លឺរបស់ព្រះអម្ចាស់’ (អេសាយ 2:4–5)” នៅក្នុង Conference Report ខែតុលា ឆ្នាំ1994។ 118 ឬ *Ensign* ខែវិច្ឆកា ឆ្នាំ1994, 88)។

នីហ្វៃទី2 12:12—“ថ្ងៃរបស់ព្រះអម្ចាស់”

“ថ្ងៃរបស់ព្រះអម្ចាស់” គឺជាឃ្លាដែលសំដៅទៅលើ ពេលនៃសេចក្តីជំនុំជំរះ។ សំរាប់ពួកសាសន៍អ៊ីស្រាអែលជាច្រើន វាជាពេលដែល សាសន៍អាសស៊ើរ និងបាប៊ីឡូនចេញធ្វើចម្បាំង។ ការយាងមកជាលើកទីពីរ របស់ព្រះគ្រីស្ទគឺជា “ថ្ងៃនៃព្រះអម្ចាស់” នៅពែល ដែលពួកទុច្ចរិត ត្រូវបានកំទេចចោល។ សំរាប់កំរិតចេះដឹងរបស់បុគ្គលម្នាក់ព្ធ ថ្ងៃនៃព្រះអម្ចាស់ប្រហែលជាថ្ងៃ ដែលយើងស្លាប់ហើយត្រឡប់ទៅរកព្រះ ឬជាពេលមួយថ្ងៃដែលយើងនឹងដឹងថា កាលះទេសះរបស់យើង គឺមិនៅក្រោមការគ្រប់គ្រងរបស់យើង គឺយើងត្រូវការជំនួយរបស់ព្រះអម្ចាស់។ ដូចដែលពាក្យដកស្រង់ចេញពី នីហ្វៃទី2 12:10–22 លោកអេសាយបានពិពណ៌នា ពីវត្ថុលោកិយដែលហាក់ដូចជាមានតំលៃដ៏ខ្ពស់បំផុត ប៉ុន្តែនឹងក្លាយជាគ្មានន័យអ្វីទាំងអស់ នៅថ្ងៃនោះ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលដែលអ្នកអាន នីហ្វៃទី2 12។

ក្ត៉ នឹកស្រមៃពីសារជំណឹង

ដូចដែលពាក្យដកស្រង់នៅក្នុងនីហ្វៃទី2 12:2–4 លោកអេសាយ បានព្យាករ ពីពរជ័យនឹងមកដល់សាសន៍អ៊ីស្រាអែល នៅពេលដែលពួកគេ ទុកព្រះវិហារបរិសុទ្ធ និងពិធីការក្នុងព្រះវិហារបរិសុទ្ធ និងសេចក្តីសញ្ញា ឱ្យខ្ពស់ជាងវត្ថុខាងលោកិយនានា។ នៅក្នុង នីហ្វៃទី2 12:5–9 គឺជាការពិពណ៌នារបស់គាត់ ពីអ្វីដែលប្រជាជន បានមានអារម្មណ៍ថាវា សំខាន់នឹងពីអ្វីដែលពួក គេបានទុកចិត្តជំនួសព្រះអម្ចាស់។ គូររូបភាពដែលតំណាងឱ្យ សារជំណឹងរបស់លោកអេសាយ នៅក្នុងនីហ្វៃទី2 12:1–9។ អ្នកអាចគូរវា ដោយប្រើការប្រមូលរូបភាព ចេញពីទស្សនាវដ្តី និងសារពត៌មាន ឬ ប្រើទាំងពីរមុខនោះចូលគ្នាតែម្តង។ បញ្ជូលទាំង អ្វីព្ធ ដែលអ្នកគិតថាជា ឧទាហរណ៍សម័យថ្មី នៃរូបចំលាក់ និងផ្លូវខុស ពីការណែនាំរបស់លោក អេសាយបាននិយាយនៅ ខ 6–9 ។

នៅក្នុងនីហ្វៃទី2 13:1–12 គឺជាការពិភាក្សាបន្តទៀត របស់លោកអេសាយពីអ្វី ដែលនឹងកើតឡើង បើសាសន៍អ៊ីស្រាអែល នៅតែដាក់សេចក្តីជំនឿ របស់ពួកគេ នៅលើសាសនាខុស។ លោកអេសាយបានហៅសាសន៍អ៊ីស្រាអែល របស់គាត់ថាជា “ពួកកូនស្រីក្រុងស៊ីយ៉ូន” (ខ 16)ដែលតំណាងឱ្យតំនិត ដែលថាពួកគេជាកូនចៅក្នុងសេចក្តីសញ្ញា ហើយប្រៀបធៀបពួកគេទៅជា ស្ត្រីដែលមានទៅដោយភាពអំនួត ហើយត្រូវបានចាញ់។ ផ្ទុយគ្នាទៅវិញនៅក្នុងនីហ្វៃទី2 14 គឺជាការពណ៌នារបស់លោកអេសាយ ពីអ្វីដែលនឹងកើតឡើង នៅពេលដែលពួកកូនស្រីក្រុងស៊ីយ៉ូន បន្ទាបខ្លួន ប្រែចិត្ត និងត្រឡប់ទៅរកព្រះអម្ចាស់របស់ពួកគេវិញ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 13

ព្រមទាំងបង្អែកជាស្បៀងអាហារ (ខ 1)—រាល់ការទ្រទ្រង់របស់ពួកគេទាំងអស់

ជាងបុិនប្រសប់ (ខ 3)—ជំនាញខាងសិប្បករ

អ្នកមានវោហារយ៉ាងចំណាន (ខ 3)—អ្នកនិយាយសរសើរនិងបញ្ជុះបញ្ជូល

សង្កត់សង្កិន (ខ 5)—គ្រងអំណាចលើ, មានបន្ទុកដធ្ងន់ធ្ងរ

ជាន់ទាប (ខ 5)—ទាបបំផុត

បង្អុចបង្អាល (ខ 8)—ធ្វើឱ្យឈ្លោះគ្នា

ទឹកមុខ (ខ 9)—ការលេចចេញ

វិបផាន់ (ខ 14)—វត្ថុដែលយកពីអ្នកដទៃដោយការគំរាមកំហែង និងហិង្សា

ផាត់ (ខ 16)—គ្រេកគ្រអាល, ការគ្មានគោរពចំពោះច្បាប់ព្រហ្មចារីយ៍ភាព

ងើបងើយ (ខ 16)—ការដើរដោយធ្វើឱ្យមានការចាប់អារម្មណ៍

សំរាតកេរ្ដិ៍ខ្មាសគេ (ខ 17)—ធ្វើឱ្យគេដឹង, ធ្វើឱ្យពួកគេមានភាពអាម៉ាស់

សំណាញ់សក់ (ខ 18)—សំណាញ់ដាក់សក់

កងក (ខ 18)—ខ្សែដែលមានរាងដូចចំណិតលោកខែ ដែលបង្ហាញពីការគោរពនៃលោកខែ

កន្សែងទទូរ . . . ផាហ៊ុម . . .
ការបូបឃ្សូរ (ខ 22)—អាវផាយ, កន្សែងទទូលក្បាល, ប្រដាប់រមូលសក់

ខ្សែក្រវាត់ (ខ 24)—ខ្សែក្រវាត់

ក្បាលទំពែក (ខ 24)—បែក ឬ រហែក

សំពត់ឆ្នៃ (ខ 24)—រ៉ូប

សំពត់ល្បើក (ខ 24)—សំលៀកបំពាក់ដែលធ្វើពីរោមរបស់ពពែ ឬរោមរបស់សត្វអូដ្ឋដែលត្រូវបានប្រើនៅពេលមានទុក្ខព្រួយ

ខ្សឹបខ្សួល (ខ 26)—យំ, ថ្ងូរ

នឹងត្រូវចោល (ខ 26)—ទំនេរ, ត្រូវចោលដោយព្រះ

នីហ្វៃទី2 14

ដំនៀលពី (ខ 1)—ខ្មាស់អៀន, ភាពអាម៉ាស់

លំអ (ខ 2)—ទាក់អារម្មណ៍

សំអាត (ខ 4)—សំអាត, បរិសុទ្ធ

រោងបាំរាំ (ខ 6)—ជម្រក

ជាទីជំរក (ខ 6)—សេចក្ដីសុខសាន្ត និងសុវត្ថិភាព

ជាទីបាំងខ្លួន (ខ 6)—ជម្រក

នីហ្វៃទី2 13–14—តើពេលណាទើបការព្យាករណ៍របស់លោកអេសាយ នឹងត្រូវបានសំរេច?

បុគ្គលលក្ខណៈមួយ ក្នុងចំណោមបុគ្គលិកលក្ខណៈជាច្រើន នៃការព្យាករណ៍របស់លោកអេសាយ គឺថាការព្យាករណ៍ទាំងនោះ នឹងត្រូវបានសំរេចច្រើនជាងរឿងតែមួយ។ ការការសំរេចនូវសោកនាដកម្ម បានពិពណ៌នានៅក្នុងនីហ្វៃទី2 13 (អេសាយ 3) គឺអាចត្រូវមើលឃើញនៅក្នុងព្រឹត្តការណ៍ដែលព័ទ្ធទៅដោយ ការធ្លាក់ចុះនៃយូដា និងយេរូសាឡិម (សូមមើល នីហ្វៃទី2 13:8, អេសាយ 3:8) នៅក្នុងដៃរបស់សាសន៍បាប៊ីឡូន ប្រហែលជាកំឡុងពេល ឆ្នាំ587 ម.គ។ ចូរកត់សំគាល់ថា នៅឯក្បាលរឿង នៅក្នុងនីហ្វៃទី2 14 មានសំរេចនូវព្រឹត្តិការណ៍ក្នុងមួយត្រូវបានសំរេចយ៉ាងច្បាស់លាស់ក្នុងចំណោមព្រឹត្តិការណ៍ផ្សេងៗនៅក្នុង "ពេលមួយពាន់ឆ្នាំ។" នៅពេលដែលយើងមើលនៅក្នុង នីហ្វៃទី2 13 និមិត្តសញ្ញានៅក្នុងខនោះ គឺមិនពិបាកយល់ទេ ដែលពិពណ៌នា អំពីអំពើបាប នៅសម័យចុងក្រោយនេះ។

នីហ្វៃទី2 14:1—ស្រីទាំងប្រាំពីរនាក់

បន្តពីរឿងរបស់ពួកកូនស្រីក្រុងស៊ីយ៉ូន ដែលបានចាប់ផ្ដើមនៅក្នុង នីហ្វៃទី2 13 នៅជំពូកទី 14 មានផ្ទុកនូវការពិពណ៌នា របស់លោកអេសាយ អំពីស្រីដែលបន្ទាបខ្លួនយ៉ាងខ្លាំង ដោយនៅក្នុងស្ថានភាពនោះពួកនាង នឹងស្ម័គ្រចិត្តរៀបការជាមួយ នឹងបុរសតែម្នាក់។ ព្រះអម្ចាស់បានប្រើនិមិត្តសញ្ញា នៃការរៀបការទៅជាចំណងមិត្តភាព រវាងទ្រង់និងសាសនាចក្ររបស់ទ្រង់ ព្រះអម្ចាស់គឺជាកូនកំលោះ រីឯសាសនាចក្ររបស់ទ្រង់ គឺជាកូនក្រមុំ។ ដោយការគ្មានភាពស្មោះត្រង់ស្មោះ និងការគោរពរូបចំលាក់ ជានិមិត្តសញ្ញាសាសន៍អ៊ីស្រាអែល បានចាកចេញពីព្រះអម្ចាស់ ហើយទៅរៀបការជាមួយនឹងអ្នកផ្សេងទៀត។ ដូចដែលបាន ពិពណ៌នានៅក្នុង នីហ្វៃទី2 12–13 ទោះបីជារូបព្រះទាំងនោះ មិនអាចការពារពួកគេ ហើយត្រូវបានកំទេចចោលនៅក្នុង "ថ្ងៃរបស់ព្រះអម្ចាស់" (សូមមើល នីហ្វៃទី2 12:12–13)។ បន្ទាប់មកសាសន៍អ៊ីស្រាអែល ក៏បានដឹងថាអ្វីដែលនាង បានទុក សេចក្ដីទុកចិត្តទៅលើ គឺមិនអាចជួយពួកនាងទេ (សូមមើល នីហ្វៃទី2 13:8)។ ហើយនិមិត្តសញ្ញានៅក្នុងនីហ្វៃទី2 14:1 បានពិពណ៌នាអំពីការបន្ទាបខ្លួនរបស់ពួកកូនស្រីក្រុងស៊ីយ៉ូន នៅពេលដែលពួកគេចង់រៀបការ ម្ដងទៀត ឬត្រឡប់ទៅ កាន់ព្រះអម្ចាស់។ ប្រភេទ នៃការបន្ទាបខ្លួននោះ គឺជាលទ្ធផលនៃការប្រោសលោះ និងការជ្រះសំអាតរបស់ពួកនាង (សូមមើលនីហ្វៃទី2 14:2–4)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលដែលអ្នកអាន នីហ្វៃទី2 13–14។

ក ស្វែងរកប្រធានបទ

នៅក្នុងនីហ្វៃទី2 13–14 មានរូបភាពដ៏មានអំណាចមួយចំនួន ដែលលោកអេសាយបានប្រើ ដើម្បីពិពណ៌នាពីអ្វី ដែលធ្វើឱ្យមនុស្ស មិនមករកព្រះគ្រីស្ទ ហើយក៏ជាគោលការណ៍ដ៏សំខាន់ ដែលមានទំនាក់ទំនងជាមួយនឹង ការយាងមករបស់ព្រះគ្រីស្ទ។ ចូរសរសេរ ប្រធានបទដូចខាងក្រោម នៅក្នុងសៀវភៅសរសេររបស់អ្នក។ បន្ទាប់ពីបានសរសេរនូវ រាល់ប្រធានបទនីមួយៗ សរសេរពាក្យ និងឃ្លាចេញពីនីហ្វៃទី2 13–14 ដែលពិពណ៌នាពីអ្វីដែលលោកអេសាយ បានបង្រៀនអំពីប្រធានបទទាំងនោះ និងខដែល អ្នករកឃើញ និងឃ្លាទាំងនោះ។

1. អំនួត និងលោកិយ

2.សោកស្ដាយចំពោះអំពើបាប

3. ព្រះចេស្ដារបស់ព្រះ ដើម្បីលាងជំរះយើងពីអំពើបាប និងភាពអាម៉ាស់

4. អំណាចនៃការកាន់ សេចក្ដីសញ្ញា ដើម្បីការពារយើងចេញពីវិញ្ញាណអាក្រក់

នីហ្វៃទី2 15
អំពើបាបនិងផលនៃអំពើបាប

នៅក្នុងនីហ្វៃទី2 15 (អេសាយ 5) គឺជាការបញ្ជាក់បន្ដរបស់លោកអេសាយចំពោះអំពើបាប នៃកូនចៅរបស់សាសន៍អ៊ីស្រាអែល និងលទ្ធផលបើប្រជាជនមិនប្រែចិត្តទេ។ បើអ្នកអានដោយប្រយ័ត្ន អ្នកនឹងដឹងថា អំពើបាបនៃប្រជាជន នៅសម័យរបស់លោក អេសាយ គឺដូចជាអំពើបាបដែលមនុស្សប្រព្រឹត្តនៅសព្វថ្ងៃនេះដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 15

ខាងឯ (ខ 1)—អំពី

របង (ខ 5)—របងការពារ

ការជំនុំជំរះ (ខ 7)—យុត្តិធម៌, ត្រឹមត្រូវ

ការសង្កត់សង្កិន (ខ 7)—មិនយុត្តិធម៌ ឬសកម្មភាពយោរយៅ

ចោលទទេ (ខ 9)—ទំនេរ

ទំហំ 10 រ៉ី . . . ប៉ោត និង . . . ពង្រោះ . . . ថាំង (ខ 10)—កសិដ្ឋានដែលគេអាចសំរេចផលតិចជាងអ្វីដែលគេគួរសំរេច

អត់ឃ្លាន (ខ 13)—បានអត់បាយ

ពួកអឹកធឹក (ខ 14)—ដំណើរអធិកអធម

ញែកចេញជាបរិសុទ្ធ (ខ 16)—ធ្វើឱ្យបរិសុទ្ធ

អូសទាញ (ខ 18)–អូសទាញ

គំនិតស្រួច (ខ 21)—ការប្រយ័ត្ន, ប្រាជ្ញា

អ្នកដែលស៊ីចំណូក (ខ 23)—ចាត់ទុកថាមានកំហុស

ក្នុងភ្លើង (ខ 24)—ត្របដណ្តប់ដោយភ្លើង ឬសំបកនៃត្រាប់ធញ្ញជាតិ

នីហ្វៃទី2 15:8—"អ្នកដែលសង់ផ្ទះជាប់គ្នា"

រាល់ត្រួសារនីមួយៗ នៅក្នុងអឺស្រាអែល ត្រូវបានចាត់ចែងឱ្យដីធ្លីនៅពេលដែលគេទៅដល់ដែនដីសន្យា នៅក្នុងសម័យរបស់ លោកម៉ូសេ និងយ៉ូស្វេ។ ដែនដីនេះគឺមិនសំរាប់លក់ទេ (សូមមើលលេវីវិន័យ 25:23–24, ពង្សាវតារក្សាត្រទី1 21:1–3) តែមនុស្សដែលមានចិត្តលោភ គឺបានព្យាយាមត្រប់ល្បិចកលដើម្បីលក់ដីនោះ។ "សង់ផ្ទះជាប់គ្នា" គឺសំដៅពី ការល្បួងនៃ មនុស្សដែលមានចិត្តលោភ ដែលបានទិញដីទាំងអស់នៅអឺស្រាអែល។

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក នៅពេលដែលអ្នកអាន នីហ្វៃទី2 15។

ក៉ សារដំណឹងសម័យថ្មី

ពាក្យថា *ទុក្ខវេទនា* គឺសំដៅពីលក្ខខ័ណ្ឌដែលមានទុក្ខសោកសៅយ៉ាងខ្លាំង។ លោកអេសាយបានប្រើពាក្យនោះ ប្រាំមួយដងដើម្បីបញ្ជាក់ពីអំពើបាប នៃសាសន៍អឺស្រាអែល (សូមមើល នីហ្វៃទី2 15:8–22)។ គាត់បានដឹងថា បើពួកគេមិនកែប្រែចិត្ត ផលនៃអំពើបាប នឹងនាំឱ្យពួកគេនូវទុក្ខសោកយ៉ាងខ្លាំង . . . ជាពិសេសនៅពេលនៃ សេចក្តីជំនុំជំរះ ។ បើសិនជាលោកអេសាយ គឺជាព្យាការីនៅលើផែនដីសព្វថ្ងៃនេះ នោះគាត់ប្រហែលជាអាចរកឃើញនូវអំពើបាប ដែលមាន លក្ខណៈដូចគ្នា។ សសេរសេចក្តីថ្លែងពី "ទុក្ខវេទនា" សម័យនេះ សំរាប់រឿងប្រាំមួយដែលលោកអេសាយបានបញ្ជា។ រាល់សេចក្តីថ្លែងនីមួយៗ បង្ហាញពីឧទាហរណ៍ ពីរបៀបដែលមនុស្សបានប្រព្រឹត្ត ឬត្រូវបានល្បួងឱ្យប្រព្រឹត្តនូវអំពើបាបសព្វថ្ងៃនេះ។

នីហ្វៃទី2 16

លោកអេសាយបានឃើញព្រះអម្ចាស់

នីហ្វៃបាននិយាយថា លោកអេសាយបានឃើញព្រះអម្ចាស់ (សូមមើល នីហ្វៃទី2 11:2)។ បញ្ចីរបស់លោកអេសាយ មានកំណត់អំពីទស្សនៈនិមិត្ត និងការហៅឱ្យបំរើរបស់លោក ដើម្បីឱ្យធ្វើជាព្យាការី មាននៅក្នុងនីហ្វៃទី2 16។ ព្យាការីយ៉ូសែប ស្មឹធ បានមានប្រសាសន៍ថាះ "មនុស្សទាំងអស់ដែលត្រូវការ

ហៅឱ្យបំរើ បង្រៀនទៅដល់ប្រជាជននៅលើផែនដី គឺត្រូវបានតែង តាំងសំរាប់គោលបំណងនោះ នៅក្នុងប្រជុំដ៏ធំ នៅឯស្ថានសួគិ តាំងពីមុនផែនដីត្រូវបានកើត" (Teachings of the Prophet Joseph Smith, 365)។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 16

រំភាយ (ខ 1)—ជាយ៉ូបរបស់ទ្រង់, ការពិពណិនាអំពីជាយូបសាយពេញក្នុងព្រះវិហារបរិសុទ្ធ គឺជានិមិត្តសញ្ញា និងការតំណាងឱ្យភាពដ៏អស្ចារ្យ របស់ព្រះអម្ចាស់

ពួកសេរភីម (ខ 2, 6)—ភាពជាស្ថានសួគិ, ទេវតា

ត្រូវវិនាស (ខ 5)—ខ្ទេចខ្ទី, កំទេចចោល

អត់ទោស (ខ 7)—ត្រូវបានសំអាត, ត្រូវបានធ្វើឱ្យបរិសុទ្ធ

ឥតដឹងឡើយ (ខ 9)—មិនដឹង ឬមិនយល់

ត្រូវចោល (ខ 12)—ចាកចេញ, រត់ចោល

នីហ្វៃទី2 16:2—ហេតុអ្វីបានជាពួក សេរភីមមានស្លាប?

ស្លាបតំណាងឱ្យអំណាចដើម្បីផ្លាស់ប្តូរ, សកម្មភាព, និងការធ្វើអ្វីឲ្យផ្សេងទៀត (សូមមើល ត និង ស 77:4)។

នីហ្វៃទី2 16:8—លោកអេសាយ បានធ្វើតាមគំរូរបស់ព្រះអង្គសង្ក្រោះ

លោកអេសាយ បានឆ្លើយតបចំពោះការហៅ ឱ្យបំរើ ដែលមានលក្ខណៈស្រដៀង និងព្រះយេស៊ូវគ្រីស្ទ បានឆ្លើយតបកាល ពីអតីតជាតិ (សូមមើលម៉ូសេ 4:1, អ័ព្រាហាំ 3:27)។

នីហ្វៃទី2 16:9–11—តើលោកអេសាយត្រូវធ្វើអ្វី នៅពេលដែលគាត់បង្រៀន?

នៅក្នុងខទី9 បានពន្យល់ថា ទោះបីជាលោកអេសាយ បានធ្វើឱ្យសេចក្តីពិតត្រូវបានដឹង ដល់ប្រជាជនរបស់លោកក៏ដោយក៏ ពួកគេនៅតែបដិសេធសេចក្តីពិតនោះ។ ពាក្យពេចន៍នៅក្នុងខទី 10 គឺជាការសើចចំអក ឬការបញ្ឈឺ។ ព្រះអម្ចាស់បាន មានព្រះបន្ទូលថា នៅពេលដែលលោកអេសាយ កាន់តែបង្រៀនពីសេចក្តីពិត គឺប្រជាជននឹងកាន់តែបិទភ្នែកនិងត្រចៀក របស់គេជិត។ ទោះជាយ៉ាងណាក៏ដោយ ការហៅឱ្យបំរើរបស់លោកអេសាយ គឺដើម្បីបង្រៀន និងថ្លែងទីបន្ទាល់ រហូតដល់ត្រចៀក និងភ្នែករបស់ប្រជាជនទាំងមូលបិទ ឬដូច នៅក្នុងខទី 11 បាននិយាយថា រហូតដល់គ្មានទរណាម្នាក់ ដែលអាចបង្រៀនទៅកាន់។ មរមន និងម៉ូរ៉ូណៃ ត្រូវបានផ្តល់នូវការហៅបំរើដូចគ្ននាពេលក្រោយ នៅក្នុងព្រះគម្ពីរមរមន (សូមមើល ម៉ូរ៉ូណៃ 9 :6)។

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក នៅពេលដែលអ្នកអាន នីហ្វៃទី2 16។

ក៉ តើមេរៀនជាអ្វី?

1. តើលោកអេសាយបានមានអារម្មណ៍យ៉ាងណានៅចំពោះវត្តមានរបស់ព្រះអម្ចាស់? (សូមមើល ខទី5)។
2. តើអ្វីបានផ្លាស់ប្តូរអារម្មណ៍របស់គាត់? (សូមមើលខទី 6–7)។
3. តើរឿងទាំងនោះបានបង្រៀនយើង អំពីអ្វីដែលយើងគួរតែធ្វើ ដើម្បីឈរក្នុងវត្តមានរបស់ព្រះអម្ចាស់ ដោយមានការទុកចិត្ត ទៅលើខ្លួនឯង?

នីហ្វៃទី2 17–19

ការព្យាករណ៍ពីព្រះមែស៊ី

នៅក្នុងជំពូកទី 17–19 នៃនីហ្វៃទី2 (អេសាយ 7–9) បានផ្តោតទៅលើព្រឹត្តិការណ៍ និងមនុស្សពីប្រវត្តិសាស្ត្រ ចេញពីសម័យកាល របស់លោកអេសាយ (គាត់ព្យាករប្រមាណជាឆ្នាំ 740–700 ម.គ)។ អាណាចក្រ នៃយូដា . . . ជាអ្នក ដែលលោកអេសាយបានព្យាករ នៅក្នុងជំពូកទាំងនេះ . . . គឺត្រូវគំរាមតបហែង ដោយអាណាចក្រខាងជើង នៃអ៊ីស្រាអែល (ដែលត្រូវបានហៅថា អេប្រាហិម) ដែលបានចូលរួម ជាមួយអាសស៊ើរ ដើម្បីឈ្លានពានសាសន៍យូដា (នីហ្វៃទី2 17:1–2)។ សារដំណឹងរបស់ព្រះអម្ចាស់ តាមរយៈព្យាការីអេសាយ គឺថាប្រជាជនយូដា គួរតែដាក់សេចក្តីទុកចិត្ត ទៅលើព្រះ អម្ចាស់ ហើយទ្រង់នឹងការពារពួកគេ។ ពួកគេមិនបានចូលរួមជាមួយសាសន៍ដទៃ ដើម្បីធានាការពារនោះទេ (សូមមើលនីហ្វៃទី2 18:11–12) ឬក៏ស្តាប់តាមនូវ គំប្រឹក្សាពីអ្នកដទៃឡើយ (សូមមើល ខទី19–22) ប៉ុន្តែពួកគេដាក់សេចក្តីទុកចិត្តទៅលើ ព្រះអម្ចាស់វិញ (មើលខទី 8 –10, 13–17)។



ទីកន្លែងដែលមាននៅក្នុងនីហ្វៃទី2 17–19

ប្រហែលជាមូលហេតុដ៏សំខាន់បំផុត ដែលព្រះអម្ចាស់បានសន្យាថា និងការពារអាណាចក្រយូដា គឺដោយសារនៅពេលដែល ទ្រង់មកដើម្បី បំពេញការបង្រៀនខាងលោកិយរបស់ទ្រង់ ទ្រង់នឹងចាប់កំណើតនៅក្នុង ត្រកូសារនៃយូដា ដែលជាដំណរ នៃស្តេចដាវីឌ។ គឺមានន័យថា ទ្រង់នឹងថែរក្សាប្រជាជនរបស់ទ្រង់ រហូតដល់ការសន្យានោះ ត្រូវបានកើតឡើង (សូមមើលនីហ្វៃទី2 20:27 ចងចាំពាក្យថា មែស៊ី មានន័យថា "អ្នកដែលបានចាក់ប្រេងតាំង")។ នៅពេលដែលអ្នកអាន នូវជំពូកទាំងនេះ មើលសំរាប់ការព្យាករណ៍សំខាន់ៗ អំពីការចាប់កំណើត និងបេសកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានរកឃើញនូវរាល់ ពាក្យរបស់លោកអេសាយ ទៅកាន់សាសន៍យូដា។ សូមពិចារណាផងដែរ អំពីសារដំណឹងរបស់ លោកអេសាយពីការទុកចិត្ត ទៅលើអំណាចនៃការការពាររបស់ព្រះអម្ចាស់ ដែលអនុវត្តទៅកាន់អ្នកផ្តាល់ ក៏ដូចជាអ្នកទាំងឡាយណា ដែលកំពុងរង់ចាំការយាងមកជាលើកទីពីរ របស់ព្រះមែស៊ី។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 17

វង្សដាវីឌ (ខ 2)—ស្តេចរបស់សាសន៍យូដា

ច្នលដៃ (ខ 2)—ចូលរួមជាសន្ធិសញ្ញា

ចុងប្រឡាយ (ខ 3)—ផ្លូវទឹកសំរាប់ផ្លាស់ប្តូរទឹក

កន្ទុយឧសដែលហុយផ្សែង (ខ 4)—ចន្លុះដែលអណ្តាតភ្លើងបានរលត់អស់ ហើយមានតែផ្សែងហ៊ុយ

ធ្វើឱ្យមានសេចក្តីទុក្ខវេទនា (ខ 6)—ធ្វើឱ្យខឹង, ធ្វើទារុណកម្ម

ទំលាយឱ្យមានផ្លូវចូលបាន (ខ 6)—ធ្វើឱ្យយើងអាចចូល

អេម៉ាញូអែល (ខ 14)—ពាក្យរបស់ហេព្រើរមានន័យថា "ព្រះគង់នៅជាមួយយើង" សំដៅចំពោះ ព្រះយេស៊ូវគ្រីស្ទ

ខ្ពើម (ខ 16)—ស្រុកសត្រូវរបស់អ្នក

ទីឆ្ងាយបំផុត (ខ 18)—ឆ្ងាយជាងគេបំផុត

ចប (ខ 25)—ប្រភេទនៃចបកាប់ សំរាប់កាប់ដី

នីហ្វៃទី2 17:8, 16—ការព្យាករណ៍មួយដែលប្រឆាំងនឹងសត្រូវនៃសាសន៍យូដា

ការព្យាការណ៍ពីមហន្តរាយរបស់អេប្រាហិម (អាណាចក្រខាងជើងនៃអ៊ីស្រាអែល)និងអាសស៊ើរនេះ ត្រូវបានសំរេចនៅក្នុងឆ្នាំ 721 ម.គ. នៅពេលដែលពួកគេត្រូវបានផ្តួល ដោយអាសស៊ើរ (សូមមើលនីហ្វៃទី2 18:4)។ សាសន៍អ៊ីស្រាអែលជាច្រើន នៃអាណាចក្រខាងជើង ត្រូវបានដឹកនាំចេញពីស្រុករបស់ខ្លួនទៅស្រុកអាសស៊ើរ (សូមមើល ពង្សាវតារក្សត្រទី2 17:22–23)ហើយពួកគេក៏ត្រូវបានស្គាល់ "ពួជអំបូរដែលបាត់នៃសាសន៍អ៊ីស្រាអែល" (សូមមើលនីហ្វៃទី3 15:15, 17:4)។

នីហ្វៃទី2 18

ពេញស្រុក (ខ 8)—ពេញទទឹងទាំងមូល

ចូររួបរួមគ្នាចុះ . . . ក្រវ៉ាត់ចង្កោះខ្លួន (ខ 9)—ត្រៀមខ្លួនជាស្រេចដើម្បីច្បាំង

សាបសូន្យ (ខ 10)—គ្មានអ្វីឮទាំងអស់

ជាទីបរិសុទ្ធ (ខ 14)—កន្លែងដែលមានសុវត្ថិភាព និងការពារ

ជាអន្ទាក់និងជាដង់ (ខ 14)—អន្ទាក់

ទុក្ខវេទនា (ខ 21)—នៅពេលពិបាក ឬស្ថានការដែលប្រកបដោយគ្រោះថ្នាក់

ក្តៅក្រហាយ (ខ 21)—ធ្វើឱ្យខឹង ឬក៏ធុញ

នីហ្វៃទី2 18:1–8—ម៉ាហេ-សាឡាល-ហាសបាស

នៅក្នុងនីហ្វៃទី2 17 យើងបានអានថា ព្រះអម្ចាស់បានសន្យាអេហាស ដែលជាស្តេចនៃយូដាថា ទ្រង់នឹងនៅជាមួយនឹង ប្រជាជន យូដា ហើយថែរក្សាពួកគេ។ ជាសញ្ញាព្រះអម្ចាស់បានប្រាប់អេហាសថា នឹងមានស្ត្រីម្នាក់នឹងមានកូនប្រុសមួយ ហើយកូន នោះគឺជាអេម៉ាញូអែល ដែលមានន័យថា “ទ្រង់គង់ជាមួយយើង។” អែលឌើរ ដេប្រ៊ូ អរ. ហូលលេន ដែលជាសមាជិក នៃក្រុមសាវកដប់ពីរនាក់ បានបង្រៀនថា “ការព្យាករណ៍របស់លោកអេសាយ គឺមានជាពហុវចនៈ។ ចំណុចសំខាន់បំផុតនិងភ្លាមៗនោះ ប្រហែលជាផ្តង់គំនិតទៅលើប្រពន្ធរបស់លោកអេសាយ ដែលជាស្ត្រីដ៏បរិសុទ្ធ និងល្អប្រពៃដែលទាំមកនូវកូនប្រុសមួយ នៅសម័យនោះ កូនប្រុសនោះក៏បានក្លាយជាគំរូ និងស្រមោលដ៏អស្ចារ្យ ក៏បានធ្វើឱ្យសំរេចនូវពាក្យព្យាករណ៍ ដែលព្យាករអំពី កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ” (*Christ and the New Covenant* [1997], 79)។

នៅក្នុងនីហ្វៃទី2 18 យើងបានអានថា ប្រពន្ធរបស់លោកអេសាយ នឹងមានកូន ហើយព្រះអម្ចាស់បានប្រាប់ថា ឱ្យដាក់ឈ្មោះកូន នោះ ម៉ាហេ-សាឡាល-ហាសបាស ដែលមានន័យថា “រឹបជាន់ជិតណាស់ហើយ គេរួតរះមកចាប់រំពា” ឬ “មហន្តរាយនឹង ជិតកើត ឡើងហើយ។” ស្តេចនៃយូដា បានបដិសេធពាក្យប្រឹក្សារបស់ លោកអេសាយ ជំនួសឱ្យព្រះគង់នៅជាមួយពួកគេ ពួកគេនឹងមាន ទទួលរងនូវការខូចខាត នៅក្នុងដៃនៃសាសន៍អាសស៊ើរ។ ទោះជាយ៉ាងណាក៏ដោយដូចដែលបានកត់ត្រានៅក្នុង ការព្យាករណ៍របស់លោកអេសាយនៅពេលចុងក្រោយ ព្រះអម្ចាស់ មិនអនុញ្ញាតឱ្យ សាសន៍អាសស៊ើរ ចូលទៅកំទេច ប្រជាជនយូដាបានឡើយ។ ទ្រង់បានថែរក្សាទីក្រុងយេរូសាឡិម អស់រយៈពេល 100ឆ្នាំទៀត នៅពេលដែលពួកគេនឹងត្រូវយកទៅធ្វើជាឈ្លើយ ដោយសារ ចាញ់សង្គ្រាម—សាសន៍ពុំចិញ្ចឹង។ ទីបញ្ចប់ សេចក្តីមេត្តាករុណា នៃការការពាររបស់ព្រះអម្ចាស់ បានញែកផ្លូវសំរាប់សាសន៍យូដា ឱ្យត្រឡប់ទៅកាន់យេរូសាឡិមវិញ ហើយដើម្បីឱ្យព្រះយេស៊ូវ ចាប់កំណើតនៅក្នុងសាសន៍យូដា នៃដែនដីដែលបានព្យាករ នៅក្នុងព្រះគម្ពីរ ហេតុដូច្នេះហើយ ព្រឹត្តិការណ៍នោះបានចំពេញ នូវការព្យាករណ៍ដែលបានឱ្យទៅ អេហាស ដោយលោកអេសាយ (មើលនីហ្វៃទី2 17:14)។

នីហ្វៃទី2 19

ត្រូវគេមើលងាយ (ខ 1)—បញ្ហាមានច្រើន, ទារុណកម្ម

រឹបប (ខ 3)—ទ្រព្យសម្បត្តិ ដែលយកពីសត្រូវនៅក្នុងសង្គ្រាម

នឹម (ខ 4)—ឈើដែលសំរាប់ដាក់នៅជុំវិញក របស់សត្វ ឬមនុស្ស ដើម្បីពួកគេអាចទាញ ឬអូសវត្ថុដែលធ្ងន់ៗ, នេះជានិមិត្តសញ្ញានៃសេរភាព ឬទាសករ

ដងវែក, ដំបង (ខ 4)—ដំបងដែលត្រូវបានប្រើដើម្បីគ្រវែង ឬវាយសត្វ ឬទាសករ ហើយពេលខ្លះគឺត្រូវបានប្រើជាជំនួយ ក្នុងការដើរ

សេចក្តីឧស្សាហ៍ (ខ 7)—សេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំង

ចិត្តធំ (ខ 9)—សេចក្តីក្លាហាន ឬ ភាពរឹងប៉ឹង

សត្រូវ (ខ 11)—សត្រូវ

លាក់ពុត (ខ 17)—ជាមនុស្សធ្វើខុសពីសេចក្តីពិតនៅក្នុងខ្លួនគេ

សេចក្តីជំកួត (ខ 17)—ភាពឆ្កួតលីលា

គុម្ពបន្លា (ខ 18)—រុក្ខជាតិបន្លា ឬ បន្លា

នីហ្វៃទី2 19:1–7—ការព្យាករណ៍អំពីតំបន់នៃស្រុកកាលីឡេ

ផ្នែកខាងជើងស្ទើរតែទាំងអស់នៃអ៊ីស្រាអែល នៅសម្ទ្រកាលីឡេ គឺជាតំបន់នៃអ៊ីស្រាអែលដំបូង ដែលត្រូវឈ្លានពានដោយសត្រូវ ដែលមកពីទិសខាងជើង (សូមមើលផែនទី នៅទំព័រ 49)។ នៅពេលដែលសត្រូវឈ្លានពានទាំងនោះ បានមក នៅក្នុងតំបន់នេះ បានទទួលរងនូវការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង។ ការព្យាករណ៍របស់លោកអេសាយ បានដកស្រង់ចេញនៅក្នុងនីហ្វៃទី2 19:1–7 ដែលបានសន្យាថា តំបន់នៃស្រុកកាលីឡេ នឹងត្រូវបានរំដោះឱ្យរួចតាមរយៈទារកតូចមួយ។ ជាពូជអំបូរនៃស្តេចដេវីឌ ដែលជា “ព្រះដ៏ប្រសើរអស្ចារ្យ” របស់ពួកគេ។ តំបន់ស្រុកកាលីឡេនេះជាកន្លែងដែលព្រះយេស៊ូវ នឹងចំណាយពេលច្រើនបំផុត នៅក្នុងការបង្រៀនក្នុងជីវិតមតៈរបស់ទ្រង់។ ដូចដែលបានកត់ត្រានៅក្នុងនីហ្វៃទី2 19:5 ទ្រង់បានផ្លាស់ប្តូរសេវកភាព និងបន្ទុករបស់ពួកគេ ដោយមិន ប្រើការតស៊ូខាងរូបកាយ តែដោយការឆេះនៅខាងក្នុងនៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើលផងដែរ គ និង ស 19:31)។

ការសិក្សាព្រះគម្ពីរ

ចូររធ្វើសកម្មភាព ក នៅពេលដែលអ្នកអានៅក្នុង នីហ្វៃទី2 17–19។

ក ការព្យាករណ៍អំពីព្រះយេស៊ូវគ្រីស្ទ

1. តើខមួយណា នៅក្នុងនីហ្វៃទី2 17 (អេសាយ 7) ដែលម៉ាថាយ 1:20–23 បានបង្ហាញថាបានសំរេច? អ្នកអាចធ្វើ បទគម្ពីរយោងគម្ពីរទាំងពីរនេះ។
2. សរសេរពីឈ្មោះ និងរវាងព្រះនាមផ្សេងៗរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានរកឃើញនៅក្នុងនីហ្វៃទី2 18:13–14, 19:6។ នៅជិតខនីមួយៗ សរសេរពីមូលហេតុ ដែលឈ្មោះ និងនាមទាំងនោះ សមរម្យសំរាប់ទ្រង់។

នីហ្វៃទី2 20

សត្រូវនៃប្រជាជនរបស់ព្រះ នឹងត្រូវកំទេចចោល

ព្រះអម្ចាស់បានអនុញ្ញាតឱ្យសាសន៍អាសស៊ើរឈ្នះសង្គ្រាមលើអាណាចក្រខាងជើងនៃអ៊ីស្រាអែល។ ទ្រង់ក៏បានអនុញ្ញាតឱ្យពួកគេកំទេចចោល ផ្នែកដាច្រើននៃអាណាចក្រយូដាផងដែរ។ នៅក្នុងនីហ្វៃទី2 20 (អេសាយ 10) យើងបានអាន ពីព្រះបន្ទូលរបស់ព្រះ អំពីសាសន៍អាស៊ើរ

ហើយអំពីមូលហេតុដែលសាសន៍អាសសើរមិនបានអនុញ្ញាតឱ្យ ឈ្នះសង្ក្រាម លើ សាសន៍យូដា។

នៅពេលដែលអ្នកអានទូវជំពូនេះ គិតពីរបៀបដែលពាក្យរបស់លោកអេសាយ យកទៅអនុវត្តចំពោះប្រជាជន របស់ព្រះអម្ចាស់ នៅថ្ងៃចុងក្រោយ ហើយ អស់អ្នកណាដែលត្រូវបានធ្វើទុក្ខបុកម្នេញ។ ការបង្រៀនទៅក្នុងជំពូកនេះ ក៏អាចប្រៀបធៀបទៅ នឹង មនុស្ស ដែលចាកចេញពីព្រះអម្ចាស់ ហើយមាន អារម្មណ៍ថា សេចក្តីជំនុំជំរះរបស់ព្រះ ធ្លាក់មកលើគាត់ ឬ ទាង ឬអ្នក ទាំងឡាយ ណាដែល ឆ្ងល់ថា តើវាមានសេចក្តីសង្ឃឹមទេ បើពួកគេត្រឡប់ ទៅកាន់ព្រះទង់វិញ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 20

បញ្ញាតិទុច្ចរិត (ខ 1)—ការចេញនូវ ក្រិត្យវិន័យ ឬច្បាប់ទុច្ចរិត

វៀចវេរ (ខ 1)—អយុត្តិធម៌, សោកសៅ

តែងច្បាប់ (ខ 1)—បញ្ជា

ជំនុំជំរះ (ខ 2)—យុត្តិធម៌, ត្រឹមត្រូវ

របឹប (ខ 2, 6)—អ្នករងគ្រោះ

ត្នាន់ក្នាញ់ (ខ 25)—កំហឹង, ទ្រៀយហត់

ភក់ (ខ 6)—ភក់ដ៏ជ្រៅ

វិសេសជាង (ខ 10)—លើស

សេចក្តីអង់អាច (ខ 12)—ក្លាហាន, មោទនភាព

ប្រើ (ខ 15)—កាត់, កាប់

ខ្លួនរីងរៃ (ខ 18)—មនុស្សដែលចុះអន់ថយ ក្នុងការតស៊ូ

សំណល់ (ខ 20–22)—ផ្នែកដែលនៅ សេសសល់

ពឹងផ្អែកលើ (ខ 20)—ពឹងទៅលើ

មានការបំផ្លាញ (ខ 22–23)—ការហិនហោច

ពន្យុះរំពាត់ (ខ 26)—ពន្យុះឱ្យមាន ការដាក់ទោស

ផ្តាច់មែកឈើ (ខ 33)—កាត់មែកឈើ

ពួកនៅទីខ្ពស់ (ខ 33)—អំនួត

នីហ្វៃទី2 20:28–34—ទីក្រុងនៅក្នុងអឺស្រាអែល និងយូដា

ខទាំងនេះគឺពិពណិនាអំពី សត្រូវដែលមកពីទិសខាងជើង ធ្វើដំណើរមកកាន់យេរូសាឡិម ហើយ បានកំទេចទីក្រុងនៅតាមផ្លូវនោះ។

នៅពេលដែលពួកសត្រូវបានមកដល់ទីក្រុងយេរូសាឡិម ព្រះអម្ចាស់នឹងធ្វើឱ្យសត្រូវចុះអន់ថយ ហើយពួកយូដានឹងត្រូវបាន ថែរក្សា។ ប្រវត្តិសាស្ត្រមួយដែល ត្រូវបានបំពេញ គឺត្រូវបានកត់ត្រានៅ ក្នុង អេសាយ 36–37។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលដែលអ្នកអានទៅក្នុង នីហ្វៃទី2 20។

ក បញ្ជាក់អំពីគោលការណ៍

1. យោងទៅតាម នីហ្វៃទី2 20:13–16 តើសាសន៍អាសសើរ មានអាកប្បកិរយដូចម្តេច នៅ ពេលពួកគេខឹងព្រះអម្ចាស់? (អាកប្បកិរិយាដូចគ្នានេះ ធ្វើឱ្យសាសន៍អឺស្រាអែលនាំមកដល់ខ្លួន គេនូវផលវិបាកសូមមើលនីហ្វៃទី2 12:8–9, 15:21)។ តើរបៀបអ្វីដែលមនុស្ស បានបង្ហាញនូវ អាកប្បកិរយាដូចគ្នានោះនៅសម័យនេះ?
2. យោងទៅតាម ខទី20–22 តើការផ្លាស់ប្តូរអ្វី ដែលសំណល់នៃកូនចៅរបស់អឺស្រាអែលនឹងធ្វើ ដែលនឹងនាំពួកគេឱ្យត្រឡប់ទៅ កាន់ព្រះអម្ចាស់វិញ? តើការណ៍ទាំងនេះអាចយកទៅអនុវត្តចំពោះ មនុស្សសម័យនេះបាន យ៉ាងដូចម្តេច តើនរណាចង់ទៅ ឬ ត្រូវការទៅកាន់ព្រះអម្ចាស់វិញ?

នីហ្វៃទី2 21–22

ថ្ងៃដ៏អស្ចារ្យរបស់ព្រះអម្ចាស់

នៅពេលដែលលោកមូរ៉ៃណ បានមកជួបជាមួយនឹង យ៉ូសែប ស្មីធ នៅក្នុងឆ្នាំ 1823 គាត់បានប្រាប់ យ៉ូសែប ស្មីធថា នៅក្នុង អេសាយ ជំពូកទី 11 (ដែលមាននៅក្នុងនីហ្វៃទី2 21) "ជិតបានសំរេចហើយ" (សូមមើល ប្រវត្តិ របស់—យ៉ូសែប ស្មីធ 1:40)។ ការណ៍នេះជួយយើងយល់ពីការព្យាករណ៍ របស់លោកអេសាយ ដែលមាននៅក្នុង នីហ្វៃទី2 21–22 គឺអំពីថ្ងៃចុងក្រោយ នឹងការសោយរាជ្យរបស់ព្រះគ្រីស្ទ នៅពេលមួយពាន់ឆ្នាំ។

ជំពូកទាំងនេះគឺជាប្រភពនៃសេចក្តីសង្ឃឹមចំពោះសាសន៍អឺស្រាអែល ដែល យល់ថា ទោះបីជាព្រះអម្ចាស់ នឹងកាត់ ចោល ប្រជាជនរបស់ទ្រង់ដោយ ព្រោះអំពើទុច្ចរិត ហើយមានតែគល់ឈើ អង្កត់ឈើដែលនៅសល់បន្ទាប់ពី ការកាត់ត្រូវបានបញ្ចប់ នោះព្រះមែសឺ (មើលនីហ្វៃទី2 21:1)។ សារដំណឹង នេះក៏អាច ឱ្យសេចក្តីសង្ឃឹមចំពោះបុគ្គលម្នាក់ព្ធ ដែលមានអារម្មណ៍ថា ជីវិតរបស់ពួកគេអភ័ព។ ព្រះមានព្រះចេស្តាដើម្បីធ្វើឱ្យ រៀងដ៏អស្ចារ្យកើត មានចេញពីភាពហិនហោចអស់ទាំងនោះ។ អស់អ្នកទាំងនោះដែលយក ប្រយោជន៍ ពីពរជ័យ នៃសេចក្តីមេត្តាករុណារបស់ទ្រង់ នឹងមានអារម្មណ៍ ច្រៀងសរសើរដល់ព្រះ ដូចដែលរកឃើញនៅក្នុង នីហ្វៃទី2 22។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 21

មែក (ខ 1)—ការលូតលាស់ថ្មី, ធាងមួយ

ឬស (ខ 1)—ផ្នែកសំខាន់នៃដើមឈើ ឬរុក្ខជាតិ

សមរេចក្តី (ខ 3, 4)—ស្តីបន្ទោស ឬកែលំអរដោយមានបំណងល្អ

សេចក្តីទៀងត្រង់ (ខ 4)—យុត្តិធម៌, ត្រឹមត្រូវ

រាបទាប (ខ 4)—ទាប, បន្ទាបខ្លួន

ខ្យល់ដង្ហើម (ខ 4)—អប់រំ (អត្ថន័យខុស ពីពាក្យ *មែក* នៅក្នុងខទី 1)

ខ្សែក្រវាត់ចង្កេះ, ខ្សែក្រវាត់កម្លាំង (ខ 5)—ឃ្លាទាំងពីរនេះគឺនិយាយអំពីខ្សែ ក្រវាត់

ភូនដែលនៅបៅដោះ (ខ 8)—ទារក, ក្រោមការចិញ្ចឹមបីបាច់

ទង់ (ខ 10, 12)—ជាទង់ ឬជាផ្ទាំងបដា ដែលមនុស្សសច្ចាប្រណិធានទៅចំពោះទង់ជា តិនោះ ទាំងអស់គ្នា

ខ្ចាត់ខ្ចាយ (ខ 12)—ខ្ចាត់ខ្ចាយ

សេចក្តីច្រណែន (ខ 13)—ការច្រណែនឈ្នានីសអំពី

ពួក (ខ 13)—សត្រូវ

ធ្វើទុក្ខ (ខ 13)—ធ្វើឱ្យខឹង, ទារុណ្ឌកម្ម

ប្លន់ (ខ 14)—កំទេចចោលហើយ ទ្រព្យសម្បត្តិ

ពាក់ស្បែងជើង (ខ 15)—ដែលធ្វើឱ្យ យើងរបស់ពួកគេមិនសើម

ទីហ្វេទី2 21:1–5—ព្រះយេស៊ូវគ្រីស្ទគឺជាមែក

អែលឌើរ ជេហ្វ្រី អរ. ហូលែន បាននិយាយពីទីហ្វេទី2 21 ហើយបានបង្រៀនថា៖ “វាត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ដោយសារ ព្រះគម្ពីរមរមន ហើយគោលលទ្ធិ និងសេចក្តីសញ្ញា ដែលជាលក្ខណៈគោលការណ៍នៅក្នុងសារដំណឹងនេះ គឺជាព្រះយេស៊ូវគ្រីស្ទ” (*Christ and the New Covenant*, 86, សូមមើលផងដែរ ទីហ្វេទី2 30:7–9, គ និង ស 113:1–6)។ អ៊ីសាយបាន បញ្ជាក់អំពីទីហ្វេទី2 21:1 ជាឪពុករបស់ស្តេចដាវីឌ ហើយជាឪពុកវង្សត្រកូលស្តេចនៃអ៊ីស្រាអែល។ ទោះបីជាវង្សត្រកូល នៃស្តេច ដាវីឌ មិនទៅសោយរាជ្យ នៅយូដាទៅសម័យនៃកំណើតរបស់ព្រះគ្រីស្ទក៏ដោយ ព្រះយេស៊ូវបានប្រសូត្រនៅក្នុងវង្សត្រកូលនោះ (សូមមើលម៉ាថាយ 1:1–17)។ ព្រះយេស៊ូវបានបំពេញនូវ ការព្យាករណ៍របស់លោកអេសាយ ហើយទ្រង់បានប្រសូត្រនៅក្នុងសម័យនៃយូដា ដែលដូចជាដើម ឈើដែលគេះខ្ទេចខ្ទី ដាងដើមឈើដែលដុះលូតលាស់ នៅពេលមួយនៃសម័យរបស់ ដាវីឌ និងសាឡូម៉ូន។

ព្រះអម្ចាស់ ដែលព្រះអម្ចាស់បានដឹកនាំលីហៃនិងគ្រួសាររបស់គាត់ ចេញពីយេរូសាឡិម។ សាសន៍បាប៊ីឡូន គឺជាពួកលោកិយនិយម ហើយសាសន៍ដែលគោរពរូបព្រះ។ ការព្យាករណ៍ ទាំងអស់ នេះរបស់លោកអេសាយ បានបង្ហាញថា ទោះបីជាព្រះអម្ចាស់បានប្រើសាសន៍បាប៊ីឡូន ដើម្បីដាក់ទារុណ្ឌកម្មសាសន៍យូដា ថ្ងៃនៃសេចក្តីជំនុំជំរះ របស់សាសន៍បាប៊ីឡូនគឺ នឹងមកដូចដែលសាសន៍យូដាបានទទួល។

ពីព្រោះតែភាពលោកិយនិយម និងសេចក្តីទុច្ចរិត របស់សាសន៍បាប៊ីឡូន វាក៏ក្លាយទៅជានិមិត្តសញ្ញា ចំពោះអ្នកដែលលោកិយ និយម និងអ្នកដែលទុច្ចរិត (សូមមើល គ និង ស 1:16, 133:14)។ សេចក្តីបំផ្លិចបំផ្លាញខាងវិញ្ញាណ របស់សាសន៍បាប៊ីឡូន នឹងកើតឡើង នូវការយាងមកជាលើកទីពីរ របស់ព្រះយេស៊ូវគ្រីស្ទ។ ចូរពិចារណាអំពី របៀបដែលការព្យាករណ៍ ទាំងនេះ និងយកអានុវត្តកាលពីគ្រានោះ និងអំពីរបៀបដែលការព្យាករណ៍ទាំងនោះ អាចលើកទឹកចិត្តរបស់អ្នក ឱ្យអ្នកនៅក្នុងសេចក្តីជំនឿ នៅពេលដែលសាសន៍បាប៊ីឡូនហាក់ដូចជាមានអំណាច។ ធ្វើការ គត់សំគាល់ នៅក្នុងទីហ្វេទី2 24 (អេសាយ 14) ដែលលោកអេសយាបានប្រៀបធៀបស្តេចបាប៊ីឡូនទៅនឹង លូស៊ីហ្វើ។ តាមរយៈសារ ដំណឹងនេះ យើងរៀនថា អារក្សសាតាំងបានធ្លាក់ចុះ នៅពីជីវិតអតីតជាតិ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលដែលអ្នកអានទៅក្នុងទីហ្វេទី2 21–22។

ក) រៀនថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ

1. ចូរសរសេរអំពីអ្វីដែលអ្នកបានរៀនអំពីព្រះអង្គសង្គ្រោះនៅក្នុងទីហ្វេទី2 21:1–5, 22:1–6។
2. ជ្រើសរើសនូវរឿងមួយចេញពីការសរសេរអ្នកដែល បំផុសគំនិតរបស់អ្នកឱ្យ “លើកចិត្តអ្នកឡើង ហើយអរសប្បាយ” ដូចជាសេចក្តីសង្ឃឹមរបស់ទីហ្វេ នៅក្នុងទីហ្វេទី2 11:8។ ពន្យល់ពីមូលហេតុដែលរឿងនោះ បំផុសគំនិត និងលើកចិត្តដល់អ្នក។

ទីហ្វេទី2 23–24
ការធ្លាក់ចុះនៃបាប៊ីឡូន

ថតរូបដោយ ឌីណេ ស៊េប៊ឺ ចំពោះលើ ជិន ហ្វៀបេរ កុំសិតសិន នៅឆ្នាំ 1976

នគររបស់យូដាត្រូវបាន ជៀសផុតពីការបំផ្លិចបំផ្លាញ ពីដៃរបស់អាសស៊ើរ នៅក្នុងឆ្នាំ 721 ម.គ.។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការកើនឡើងនៃសេចក្តីទុច្ចរិតរបស់សាសន៍យូដា សាសន៍បាប៊ីឡូនបានឈ្នះលើសាសន៍យូដា ប្រហែលជាឆ្នាំ 587 ម.គ.ស។ វាគឺជាការរត់គេចពីការបំផ្លិចបំផ្លាញនោះ ដែល

ការយល់ដឹងអំពីព្រះគម្ពីរ

ទីហ្វេទី2 23

បន្ទុក (ខ 1)—សារដំណឹងនៃសេចក្តីជំនុំជំរះ

ពួកបរិសុទ្ធ (ខ 3)—ប្រជាជនសុចរិតនៅក្នុងសេចក្តីសញ្ញា, ពួកបរិសុទ្ធ

ស្វូរអឺកធឹក (ខ 4)—ភាន់ច្រឡំ, គ្មានរបៀប

គ្រូតគ្រា (ខ 4)—ហោរួមគ្នា

ឱ្យរលីង (ខ 9, 22)—ទទេ

សេចក្តីឆ្មើងឆ្មៃ (ខ 11)—អំនួត, ការមានអារម្មណ៍ថាខ្លួនប្រសើរជាងអ្នកដទៃ

កំហែងចិត្ត (ខ 16)—ចាប់អូសទៅ ហើយនាំយកចេញទៅដោយអំពើហិង្សា, ការចាប់

ផលដែលកើតពីផ្ទៃ (ខ 18)—កុមារតូចៗ

សំលេងសត្វយំ (ខ 21)—សត្វលោកដ៏សោកសៅ នេះសំដៅលើសត្វព្រៃរស់នៅវាលខ្សាច់

ពពែព្រៃ (ខ 21)—ពពែឈ្មោល ឬបិសាច

ពន្យា (ខ 22)—បន្ថយពេល

ទីហ្វេទី2 23:11, 15, 19—អំពើបាបនៃអំនួត

យើងបានអានទៅក្នុង ទីហ្វេទី2 23–24 ជាព្រះបានដាក់ទោសសាសន៍បាប៊ីឡូន ចំពោះអំពើបាបដូចគ្នា ដែលទ្រង់បាន ដាក់ទោសចំពោះ សាសន៍អ៊ីស្រាអែល និង សាសន៍អាសស៊ើរ—ទោសទាំងអស់នោះគឺមកពីការមានអំនួត (សូមមើល ទីហ្វេទី2 12:10–12, 13:15–26, 15:15, 21, 18:9–10, 20:12–15)។

ទីហ្វេទី2 24

ជាប់នឹង (ខ 1)—ចូលរួមជាមួយ

សង្កត់សង្កិន (ខ 2, 4)—អ្នកដែលត្រួតត្រាលើ ហើយធ្វើបាបពួកគេ

ពោលពាក្យ (ខ 4)—ការនិយាយយ៉ាងខ្លីដែលបង្រៀនពីសេចក្តីពិត

ឈប់ទ្រឹង (ខ 4)—ឈប់មានអំណាច

ដំបងពេជ្រ (ខ 5)—សំភារៈដែលជាតំណាងអានុភាពសំរាប់គ្រប់គ្រង

ឃាត់ឃាំង (ខ 6)—បង្ការ ឬ បញ្ឈប់

សេចក្តីរុងរឿងឧត្តម (ខ 11)—ភាពត្រចេះត្រចង់

ឡើងទៅ (ខ 13–14)—ឡើងទៅ

សាកសព (ខ 19)—រូបកាយដែលស្លាប់

ចេញឈ្មោះគេ (ខ 20)—ល្បីរន្ទឹ, ការប្រាវព្ធពិធីសំរាប់ការសំរេចដ៏អស្ចារ្យ

សត្វប្រមា (ខ 23)—សត្វស្លាបដែលស៊ីត្រី, ក្រសា

អំបោស (ខ 23)—អំបោស

រំលប់រំលាង (ខ 27)—រំសាយ, ធ្វើឱ្យមានប្រសិទ្ធភាព

រំពាត់ (ខ 29)—ឈើប្រើសំរាប់ដាក់ទណ្ឌកម្ម ឬជាជំនួយនៅពេលដើរ

ត្បិតនឹង កើតមានពស់វែក ចេញពីពូជសត្វពស់មក ហើយ . . . នឹងក្លាយទៅជាពស់ភ្លើងហោះ (ខ 29)—ពស់ត្មានពិសនឹងមក ចេញមកពីពស់ដែលមានពិស

ពូជពង្ស (ខ 30)—ប្រភព, កំណើត

ត្រូវរលាយ (ខ 31)—កំទេចចោល, ទីបញ្ចាប់

មូលហេតុមួយដែលនីហ្វៃបានថ្លែង ក្នុងការញ្ចូលនូវពាក្យរបស់លោកអេសាយ នៅលើផ្ទាំងតូច នោះគឺជាសក្ខីភាពរបស់លោក អេសាយអំពីព្រះគ្រីស្ទ (មើលនីហ្វៃទី2 11:1, 4, 68)។ បន្ទាប់ពីនីហ្វៃបានបញ្ចាប់ ការដកស្រង់ពាក្យរបស់លោកអេសាយ គាត់ បានពន្យល់ថា គាត់ដឹងថាពាក្យរបស់លោកអេសាយនឹង ពិបាកយល់ តែពាក្យរបស់លោកគឱ្យមានតំលៃណាស់។ ស្វែងរកពីរប្រៀប ដែលនីហ្វៃ បានន៏យាយដែលអាចជួយយើងយល់ពីការព្យាករណ៍របស់លោកអេសាយកាន់តែប្រសើរ (សូមមើលនីហ្វៃទី2 25:1–8 ឱ្យច្បាស់លាស់)។ សូមរកមើលផងដែរពីការព្យាករណ៍របស់នីហ្វៃផ្ទាល់ អំពីព្រះគ្រីស្ទ ដែលគាត់បានឱ្យ "យ៉ាងច្រើន" (នីហ្វៃទី2 25:4)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ ដូចខាងក្រោម នៅពេលអ្នកសិក្សានៅក្នុងនីហ្វៃទី2 23–24។

ក៉ សរសេរចំណោទស្វរ

ការព្យាករណ៍របស់លោកអេសាយ ពីសេចក្តីបំផ្លិចបំផ្លាញនៃ ក្រុងបាប៊ីឡូន និងស្តេចនៃក្រុងបាប៊ីឡូន ដែលមានទៅក្នុង នីហ្វៃទី2 23–24។ សរសេរចំណោទសំនួរឱ្យបានដប់ ហើយដែលផ្តោតអំពី ពីអ្វីដែលអ្នកគិតថា ជាតំនិតដ៏សំខាន់បំផុតដែលបានបង្រៀន នៅក្នុងជំពូកទាំងពីរនេះ។ សរសេរចំលើយ ហើយដាក់នៅក្នុងវង្សក្រចក បន្ទាប់ពីសំនួរនីមួយៗ។

ខ សង្ខេបគោលលទ្ធិ

1. សរសេរនូវសេចក្តីថ្លែងឱ្យមួយចំនួន ដែលសង្ខេបពីអ្វីដែលអ្នកបានរៀន នៅក្នុងនីហ្វៃទី2 24:4–20 អំពីរប្រៀបដែលលូស៊ីហ្វើរ បានក្លាយជាសាតាំង ហើយតើអ្វីបានកើតឡើងចំពោះលូស៊ីហ្វើរ និងអ្នកដែលធ្វើតាមលូស៊ីហ្វើរ។
2. តើមានអ្វីខ្លះទៀតដែលអ្នកបានរៀន ចេញពីអារក្សសាតាំង និងអ្នកដើរតាមវា ចេញពីគោលលិទ្ធ និងសេចក្តីសញ្ញា 76:25–30, 33, 36–38, 44–46 និងម៉ូសេ 4:1–4 ?

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 25

អំគួរខ្ពើមឆ្អើម (ខ 2)—អំពើបាប, គំនិត ឬសកម្មភាពដែលធ្វើឱ្យព្រះអន់ចិត្ត

ទុក (ខ 8)—មានព្រំដែន

ធ្វើទុក្ខ (ខ 16)—ទារុណ្ឌកម្ម

ចាំបាច់ (ខ 16, 30)—ចាំបាច់, សំខាន់បំផុត

ស្រុះស្រួល (ខ 23)—ការសម្រុះសម្រួលឡើងវិញ បន្ទាប់ពីមិនបានត្រូវគ្នា

ព្រះគុណ (ខ 23)—អំណាចរបស់ព្រះយេស៊ូវគ្រីស្ទ

យ៉ាងខ្ជាប់ខ្ជួន (ខ 24)—គោលបំណងដ៏ម៉ឹងម៉ាត់

គ្រប់គ្រាន់ (ខ 28)—ល្មម

ពុំត្រូវ (ខ 29)—មិនទៅក្នុងរប្រៀបឬកំរិតណាមួយ

នីហ្វៃទី2 25:1–8—គន្លឹះទាំងប្រាំដើម្បីយល់ពាក្យរបស់លោកអេសាយ

នៅពេលដែលនីហ្វៃកំពុងពន្យល់ ពីមូលហេតុដែលពាក្យ របស់លោកអេសាយ "ពិបាកយល់សំរាប់មនុស្សជាច្រើន" (មើលនីហ្វៃទី2 25:1) គាត់ក៏បានប្រាប់នូវគន្លឹសដូចខាងក្រោម ដើម្បីឱ្យយើងកាន់តែងាយយល់នូវពាក្យ របស់លោកអេសាយៈ

1. *យល់ពីសាសន៍យូដា* (ខ 1–2, 5)។ "រប្រៀបនៃការព្យាករណ៍នៅក្នុងចំណោមពួកសាសន៍យូដា" ដូចជាការប្រើនិមិត្តសញ្ញា និងអត្ថន័យពិតប្រាកដ និង "រឿងរ៉ាវនៃសាសន៍យូដា" ផ្សេងពីទៀតដែលពិសេស។
2. *ប្រើគម្ពីរសម័យថ្មី* (ខ 3–4)។ គម្ពីរសម័យថ្មី គឺជាវិធីអធិប្បាយដ៏ប្រសើរបំផុត របស់លោកអេសាយ។ នីហ្វៃបានព្យាករ "យ៉ាងច្បាស់" ពីអ្វីជាច្រើនដែលលោកអេសាយបានន៏យាយអំពីភាពដ៏ល្អនៃនិមិត្តសញ្ញា។ នៅពេលដែលយើងយល់ពីដំណឹង ល្អប្រសើរ នោះធ្វើឱ្យយើងកាន់តែងាយយល់ នូវពាក្យរបស់លោកអេសាយ ផងដែរ។
3. *អធិស្ឋានសំរាប់ "វិញ្ញាណនៃការព្យាករណ៍"* (ខ 4)។ នៅពេលដែលយើងរស់នៅដោយភាពសក្តិសម នៃអំណោយទាន ព្រះវិញ្ញាណ នោះអ្វីឲ្យទាំងអស់នឹងត្រូវបានស្តែង ឱ្យដឹងតាមឆន្ទះរបស់ព្រះអម្ចាស់ ហើយនៅពេលដែលយើងសក្តិសមដើម្បី ទទួលនូវអ្វីឲ្យទាំងអស់នោះ (សូមមើលផងដែរ អាលម៉ា 12:9–11)។
4. *សិក្សាពីភូមិសាស្ត្រនៃដែនដីបរិសុទ្ធ* (ខ 6)។ លោកអេសាយ តែងតែប្រើពាក្យដែនដីបរិសុទ្ធ—ប្រជាជន ជាតិ និងទីកន្លែង—ដើម្បីពន្យល់នូវសារដំណឹងរបស់លោក។
5. *មើលការសំរេចនៃការព្យាករណ៍* (ខ 7,8)។ ផ្នែកទាំងឡាយណាដែលលោកអេសាយ បានព្យាករណ៍ ដែលបន្យល់នូវការមិន ច្បាស់លាស់ នឹងទៅជាច្បាស់លាស់ ចំពោះយើងនៅពេលដែលយើងឃើញនូវ ការព្យាករណ៍នោះត្រូវបានសំរេចនៅក្នុងថ្ងៃចុង ក្រោយនេះ។

នីហ្វៃទី2 25:23—យើងទាំងអស់គ្នាបានសង្គ្រោះ ដោយសារព្រះគុណ ក្រោយពីយើងអាចធ្វើដោយខ្លួនឯង

យើងទាំងអស់គ្នាបានសង្គ្រោះ ដោយដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវតែមកកាន់ព្រះគ្រីស្ទ ហើយនៅក្នុងក្រុមរបស់ទ្រង់ ដើម្បីទទួលពរជ័យដែលទ្រង់ ឱ្យយើងដោយឥតគិតថ្លៃ។ យើងមកកាន់ព្រះគ្រីស្ទ ដោយយើងត្រូវ “យើងអាចធ្វើដោយខ្លួនឯង” ដើម្បីចងចាំទ្រង់ និងរក្សាសេចក្តីសញ្ញារបស់យើង ហើយគោរពតាមបញ្ញត្ត របស់ទ្រង់ (សូមមើល គ និង ស 20:77, 79 សូមមើលផងដែរ អ័ព្រាហាំ 3:25)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សានៅក្នុងនីហ្វៃទី2 25។

ក ធ្វើតារាងពេលវេលា

ធ្វើតារាងពេលវេលានៅក្នុង ស្បៀវភៅសរសេររបស់អ្នក សរសេរវានៅក្នុង “ជំនាន់របស់នីហ្វៃ” នៅផ្នែកម្ខាង ហើយ “ការយាងមក ជាលើកទីពីរ របស់ព្រះយេស៊ូវគ្រីស្ទ” ផ្នែកនៅម្ខាងទៀត។ បំពេញវាចូលយ៉ាងគិត ការព្យាករណ៍របស់នីហ្វៃ ព្រាំ ដែលមាននៅ ក្នុងនីហ្វៃទី2 25:10–19។ នៅពេលដែលអ្នកអាន ទូរដំពូកបន្ទាប់ទៀត អ្នកប្រហែលជាចង់បញ្ចូលនូវគំនិតថែមទៀត នៅក្នុងតារាងពេល វេលារបស់អ្នក។

ខ ឆ្លើយនូវសំនួររបស់ អ្នកដែលមិនមែនជាសមាជិក

1. ធ្វើការស្រមៃមើល បើសិនជាមានណាម្នាក់ដែលមិនមែន ជាសមាជិកនៃសាសនាចក្រ បានសួរអ្នកថា “តើពួកបរិសុទ្ធថ្ងៃចុងក្រោយ គោរព ឬក៏ជឿទៅលើព្រះយេស៊ូវទេ?” សរសេរសេចក្តីពិតព្រាំ ចេញពីនីហ្វៃទី2 25:20–30 ដែលអ្នកអាចចង្អុលបង្ហាញអំពី សេចក្តីជំនឿរបស់យើងចំពោះព្រះយេស៊ូវគ្រីស្ទ និងទំនាក់ទំនងរបស់យើងចំពោះទ្រង់។
2. តើអារម្មណ៍ឬសក្ខីភាព ផ្តាល់ខ្លួនណាមួយដែលអ្នកនឹងចែកចាយចំពោះបុគ្គលនោះ?

បន្ទាប់ពីការព្យាករណ៍នៅក្នុង នីហ្វៃទី2 25 អំពីសេចក្តីបំផ្លិចបំផ្លាញ និងការខ្ចាត់ព្រាត់របស់ពួកសាសន៍យូដា នីហ្វៃបានព្យាករ អំពីសេចក្តីបំផ្លិចបំផ្លាញ និងការខ្ចាត់ព្រាត់នៃកូនចៅ របស់លោកនៅក្នុងជំពូកទី 26។ ចូរធ្វើការកត់ចំណាំ ហេតុអ្វីបាន ជាលោកនិយាយថា សេចក្តីបំផ្លិចបំផ្លាញនឹងកើតឡើង ហើយតើលោក និងព្រះអម្ចាស់មានអារម្មណ៍យ៉ាងណា អំពីរឿងនោះ។

នីហ្វៃក៏បាននិយាយអំពីពួកសាសន៍ដទៃនៅថ្ងៃចុងក្រោយ និងអំពីមិត្តភាព របស់ពួកគេជាមួយនឹង ប្រជាជនរបស់លោក។ នៅក្នុងករណីនេះ សាសន៍ដទៃគឺជា សាសន៍ផ្សេងឮ និងប្រជាជននៅក្នុងពិភពលោក ដែលមិនមែនជាពួកសាសន៍យូដា ឬកូនចៅរបស់លីហៃទេ។ ពីព្រោះពួកគេរស់នៅក្នុង “សាសន៍ដទៃ” ព្យាការីយ៉ូសែប ស៊្មីធ និងអ្នកដទៃទៀត ដែលមានចំណែកក្នុងការកសាងឡើងវិញនៃដំណឹងល្អនឹងត្រូវបានរាប់ថា ជាសាសន៍ដទៃ នៅក្នុងការព្យាករណ៍ របស់នីហ្វៃ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 26

ការទាស់ទែង (ខ 2)—ការប្រកែក, ការមិនយល់ស្រប

ចំបើង (ខ 4, 6)—មែកស្តួតខ្លឹញ ដែលមាននៅសល់បន្ទាប់ពីការច្រូតកាត់ស្រូវរួច

សឹងតែបំផ្លាញខ្ញុំ (ខ 7)—ស្ទើរតែយកកំលាំងទាំងអស់របស់ខ្ញុំ

ឥតប្រយោជន៍ (ខ 10)—គ្មានអ្វីសោះ

ចុះចូល (ខ 10)—ចុះចូល, ចុះចាញ់

តស៊ូ (ខ 11)—ខិតខំធ្វើការងារ

ការចុះអន់ថយ (ខ 15, 17, 19)—ធ្លាក់ចុះបន្តិចម្តងៗ

ទាស់នឹងគេ (ខ 15)—វាយប្រហារ

ការឈ្នានីស (ខ 21)—ការប្រណែនឈ្នានីស

ការឈ្លោះប្រកែក (ខ 21)—ការឈ្លោះគ្នា

ចិត្តអាក្រក់ (ខ 21, 32)—ប៉ងធ្វើឱ្យអ្នកដទៃមានគ្រោះថ្នាក់

អួរសទៅ (ខ 22)—ខ្សែពួរ

សុខុមាលភាព (ខ 29)—សុភមង្គល និងអ្វីៗដែលល្អ

សិរីយ៉ូន (ខ 29–31)—ទឹកដីរបស់ព្រះនៅលើផែនដី

អំពើសហាយស្មន់ (ខ 32)—អំពើបាបខាងផ្លូវភេទ

ពួកអ្នកឥតសាសនា (ខ 33)—អ្នកដែលមិនជឿ

នីហ្វៃទី2 26:20—ថ្មជំពប់ដ៏ធំរបស់ពួកសាសន៍ដទៃ

យោងទៅតាមការបង្រៀនរបស់នីហ្វៃ នៅក្នុងនីហ្វៃទី1 13:29 ពួកសាសន៍ដទៃ បានជំពប់ដោយសារ “សេចក្តីជ័ច្បាស់ និងពិសេសទាំងប៉ុន្មាន” ត្រូវបានផ្លាស់ប្តូរចេញពីព្រះគម្ពីរ ហើយបានបន្សល់ទុកឱ្យពួកគេនូវរូបភាពមិនច្បាស់លាស់នៃ គោលលទ្ធិពិត នៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាពបី (ក–គ)នៅខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី2 26។

ក គូររូបភាព

គូររូបភាពឱ្យពេញមួយទំព័រនៅក្នុង ស្បៀវភៅសរសេររបស់អ្នក ដែលជាតំណាងឱ្យគំនិតនៅក្នុងនីហ្វៃទី2 26:3, 8, 10 អំពីមូលហេតុដែល ពួកសាសន៍នីហ្វៃត្រូវបំផ្លាញចោល។

២ ប្រធានបទសំខាន់នៃដំណឹងល្អ សំរាប់ជំនាន់របស់យើង

1. ប្រធាន អែសរ៉ា ថាហ្ហ ប៉ែនសឹន មានប្រសាសន៍ថាះ "បញ្ជីនៃប្រវត្តិសាស្ត្ររបស់ពួកសាសន៍ នីហ្ហៃ គឺគ្រាន់តែជាការ ប្រាប់មុន អំពីការយាងមកជួបរបស់ព្រះអង្គសង្គ្រោះ ដើម្បីបើកបង្ហាញពីភាពដូចគ្នាទៅនឹងជំនាន់របស់យើងផ្ទាល់ នៅពេលដែល យើងចូលរួមនៅក្នុងការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ" (ក្នុង Conference Report, ខែមេសា ឆ្នាំ1987, 3, ឬ *Ensign,* ខែឧសភា ឆ្នាំ1987, 4)។ យោងទៅលើអ្វីដែលនីហ្ហៃបានបង្រៀនអំពីពេលវេលានោះនៅក្នុង នីហ្ហៃទី2 26ះ1–11 ចូរធ្វើបញ្ជីប្រធានបទដំណឹងល្អចំនួនបី ដែលអ្នកចង់រួមបញ្ចូល បើអ្នកត្រូវបាន ចាត់តាំងឱ្យឡើងនិយាយ អំពីការរៀបចំដើម្បី នៅជាមួយនឹងព្រះអង្គសង្គ្រោះ ក្នុងពេលការយាងមកជាលើកទីពីររបស់ទ្រង់។ នៅជិតនឹងប្រធានបទនីមួយៗ ចូរសរសេរនូវ ខគម្ពីរដែលបានរកបាននៅក្នុង នីហ្ហៃទី2 26។

2. ចូរបន្ថែមប្រធានបទចំនួនបួនទៀតនៅក្នុងបញ្ជីរបស់អ្នក យោងទៅលើអ្វីដែលនីហ្ហៃបានបង្រៀន នៅក្នុង នីហ្ហៃទី2 26ះ20–22, 29–32 អំពីពួកសាសន៍ដទៃនៅក្នុងថ្ងៃចុងក្រោយ។

៣ រៀនពីសារះសំខាន់នៃសេចក្តីពិតអំពីព្រះ

1. យោងទៅតាមអ្វីដែលអ្នកបានអានទៅក្នុង នីហ្ហៃទី2 26ះ23–28, 33 ចូរធ្វើបញ្ជីសេចក្តីថ្លែងការណ៍ចំនួនបី អំពីលក្ខណៈ របស់ព្រះអម្ចាស់។

2. ចំពោះសេចក្តីថ្លែងការណ៍នីមួយៗ ចូរពន្យល់ពីភាពខុសគ្នា ដែលអ្នកគិតថា បានធ្វើឱ្យអ្នកដឹងជាពិសេសថា ជាសេចក្តីពិត អំពីព្រះអម្ចាស់។

នៅក្នុង នីហ្ហៃទី2 26ះ16–17 នីហ្ហៃបានព្យាករថា ពាក្យសំដីរបស់លោក និងពាក្យសំដីរបស់ប្រជាជនលោក នឹងត្រូវ និយាយ "ចេញពីដី" មកទៅកាន់កូនចៅរបស់លោកនៅ ថ្ងៃចុងក្រោយ។ នៅក្នុងនីហ្ហៃទី2 27 លោកបានព្យាករថែមទៀត អំពីហេតុការណ៍ដែលនឹងកើតឡើងជាយ៉ាងណា "នៅគ្រាចុងក្រោយ ឬនៅថ្ងៃ នៃពួកសាសន៍ដទៃ" (ខ 1)។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្ហៃទី2 27

ព្យុះសង្ឃរា (ខ 2)—ព្យុះដ៏សាហាវ

ស្ទាក់ស្ទើរ ហើយភាំងឆ្ងល់ (ខ 4)—ឈប់ហើយគិតសូមមើល ឬក៏សញ្ជឹងគិតអំពីអ្វីមួយនោះ

អ្នកមើលឆុត (ខ 5)—ព្យាការី, មនុស្សដែលពោរពេញទៅដោយទស្សនះនិមិត្តខាងវិញ្ញាណ

រក្សា (ខ 22)—សង្គ្រោះ

បង្គាប់ (ខ 25)—បទបញ្ញត្តិ, គោលការណ៍

នឹងរាប់ទុក (ខ 27–28)—តំលៃ, គោរព

សភាពជាងងឹត (ខ 29)—ស្ថានភាពដែលមិនអាចយល់

រាបសា (ខ 30)—ទាប, បន្ទាបខ្លួន

មនុស្សដែលសូមមើលងាយ (ខ 31)—មនុស្សដែលត្រូវគេសើចចំអក

មនុស្សដែលក្រើនរំញកនៅត្រង់ទ្វារក្រុង (ខ 32)—មនុស្សដែលមានសិទ្ធិអំណាចប្រាប់មកអ្នក នៅពេលដែលអ្នកធ្វើអ្វីខុស (ដូចជា អ្នកចៅក្រម, ប៊ីស្សប, ឬឱពុកម្តាយ)

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុងនីហ្ហៃទី2 27 ចូរធ្វើសកម្មភាព ក ដូចខាងក្រោម។

៤ ពន្យល់ពីសេចក្តីសំរេច នៃការព្យាករណ៍

1. នៅក្នុងស្យៀវភៅសរសេររបស់អ្នក ចូរធ្វើតារាងមួយ ដូចខាងក្រោម។ នៅក្នុងកូឡោន ត្រូវបិទស្លាក "ការព្យាករណ៍" រួចសរសេរ ខគម្ពីរមកពីនីហ្ហៃទី2 27 ដែលមានការព្យាករណ៍ ត្រូវបានសំរេច ដោយព្រឹត្តិការណ៍ ដែលបានពិពណិនា នៅក្នុងបទ គម្ពីរយោង ដែលអ្នកអានទៅក្នុងកូឡោន "ដែលបានសំរេច"។

ការព្យាករណ	សេចក្តីសំរេច
	ប្រវត្តិរបស់—យ៉ូសែប ស្មឹធ 1ះ59, 63–64
	ទីបន្ទាល់របស់ សាក្សីបីនាក់
	ទីបន្ទាល់របស់ សាក្សីប្រាំបីនាក់
	ប្រវត្តិរបស់—យ៉ូសែប ស្មឹធ 1ះ63–65
	ប្រវត្តិរបស់—យ៉ូសែប ស្មឹធ 1ះ19

2. សូមអានបទគម្ពីរនៅក្នុងកូឡោន "សេចក្តីសំរេច" រួចឱ្យឈ្មោះរបស់មនុស្សដែលបាននិយាយ នៅក្នុងឃ្លាដូចខាងក្រោម នៅក្នុង នីហ្វៃទី2 27ៈ "មនុស្សម្មាក់" (ខ 9) "អ្នកផ្សេងទៀត" (ខ 9, 15) "ពួកសាក្សីបីនាក់" (ខ 12) "មួយចំនួនតូច" (ខ 13) "អ្នកមានចំណេះ" (ខ 15, 18) "អ្នកដែលគ្មានចំណេះ" (ខ 19–20)។

នីហ្វៃទី2 28

អំពើបាប

និងអន្ទាក់នៅថ្ងៃចុងក្រោយ

នៅក្នុង នីហ្វៃទី2 27 នីហ្វៃបានព្យាករណ៍ពីការលេចចេញមក នៃព្រះគម្ពីរមរមន នៅក្នុងថ្ងៃចុងក្រោយ ដើម្បីធ្វើជាពន្លឺ លើសេចក្តី ងងឹតនៃការក្សត់សាសនា។ នៅក្នុងនីហ្វៃទី2 28 នីហ្វៃបានពិពណ៌នា ពីអ្វីដែលសាតាំងនឹងព្យាយាមធ្វើ ដើម្បីកុំឱ្យមនុស្ស សូមមើលឃើញនូវពន្លឺ នឹងរៀនអំពីព្រះអម្ចាស់ និងសេចក្តីពិតរបស់ទ្រង់។ អស់អ្នករាល់គ្នាណាដែលអានយល់ដឹង និងធ្វើ

តាមការ ទូន្មាននៅក្នុង នីហ្វៃ ទី2 28 នឹងមានប្រយោជន៍យ៉ាងច្រើន នៅក្នុងការឈ្នះលើអន្ទាក់របស់សាតាំង និងការបង្រៀនខុស ឆ្គងរបស់មនុស្ស នៅថ្ងៃចុងក្រោយ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 28

បានបង្គាប់ (ខ 1)—បានបញ្ជា, បង្ខិតបង្ខំ

សំណល់ (ខ 2)—ផ្នែកដែលនៅសល់

ឈ្លោះប្រកែកគ្នា (ខ 4)—ឈ្លោះគ្នា, ការវែកញែក

ប្រទានសំដី (ខ 4)—វិវរណៈ, ការបំផុសគំនិត

លទ្ធិ (ខ 5–6, 14, 26, 30)—បទបញ្ញត្តិ, គោលការណ៍

ពុំចាប់ទោស (ខ 8)—ចាត់ទុកថាគ្មានទោស

ទីបរិសុទ្ធ (ខ 13)—អាគារនៃសាសនាចក្រ

បង្ខូចផ្លូវ (ខ 15)—ធ្វើឱ្យអាក្រក់

ផេរប្រមាថ (ខ 16)—ការនិយាយអាក្រក់, ភាសាប្រមាថ និងបំពាន

បង្ក្រាប (ខ 21)—ធ្វើឱ្យស្ងប់

បំពេ (ខ 21)—ធ្វើឱ្យមានការសំរាកយ៉ាងស្ងប់ស្ងាត់

ខាងរូបកាយ (ខ 21)—ខាងលោកីយ, មិនមែនខាងវិញ្ញាណ

ត្រូវចាប់ទៅ (ខ 23)—ចាប់បាន

ឬយកសាច់ឈាមធ្វើ ជាដៃរបស់ខ្លួន (ខ 31)—ការគិតថាមនុស្សជាប្រភពធំបំផុតនៃអំណាច

ដៃយើងនៅតែលាតទុក (ខ 32)—អាចរកបានអំណាចដែលមានសំរាប់ជួយ

នីហ្វៃទី2 28ៈ7 –8—"ចូរយើងស៊ីផឹក ហើយអរសប្បាយទៅចុះ"

យើងនឹងគាំទ្រថា មានមនុស្សជាច្រើននៅក្នុងលោកីយសព្វថ្ងៃនេះ ដែលជឿនៅក្នុងអាកប្បកិរិយាដែលបង្ហាញនៅក្នុង នីហ្វៃទី2 28ៈ7–8។ ប្រធានយ៉ូសែប ហ្វីលឌីង ស្មីធ បានដកស្រង់ពាក្យទាំងនោះ ហើយមានប្រសាសន៍ថាៈ "ចូរកុំគិតថាការនិយាយនោះ ជាការនិយាយ របស់លោកិយឡើយ . . .។ វាគឺជាការនិយាយរបស់សមាជិកនៃសាសនាចក្រ" (*Ye Earnestly* . . . [1970], 143។ មានសមាជិកខ្លះព្ធ នៃសាសនាចក្រជឿថា ពួកគេអាចប្រព្រឹត្តអំពើបាប ឥឡូវនេះ ហើយកែប្រែចិត្តនៅពេលក្រោយ។ ពួកគេជឿថា ការរស់នៅក្នុងដំណឹងល្អ នឹងដកយកភាពសប្បាយរីករាយក្នុងជីវិត របស់ពួកគេ។ ដោយសារបទពិសោធន៍ ហើយនឹងវិវរណៈ យើង អាចដឹង ហើយសូមមើលឃើញពី "សេចក្តីទុច្ចរិតមិន ដែលធ្វើឱ្យមានសុភមង្គលទេ" (អាលម៉ា 41ៈ10)ហើយថា "គ្មានវត្ថុ មិនស្អាតណាអាចចូលទៅក្នុងនគររបស់ព្រះឡើយ" (សូមមើល នីហ្វៃទី1 15ៈ34)។

ប៊ីស្សប រីជ៉ឌ ស៊ី អិជ្ជលី ជាទីប្រឹក្សានៅក្នុង គណៈប៊ីស្សបជាអធិបតី បានមានប្រសាសន៍ថាៈ "យើងមិនអាចនិយាយថា យើងអាចប្រព្រឹត្តិអំពើបាបបន្តិចបន្តួច នៅក្នុងយុវវ័យរបស់យើង ឬថា យើងគ្រាន់តែល្បងល ទៅជិតខ័ណ្ឌសីមានៃ អំពើបាប បន្តិចបន្តួចតែប៉ុណ្ណោះនោះទេ។ អំពើបាបគឺគ្មានខ័ណ្ឌសីមាទេ។ នៅរាល់សកម្មភាព ល្អ ឬ អាក្រក់ គឺមានផលវិបាករបស់វា។ រាល់សកម្មភាពល្អអភិវឌ្ឍសម្ថភាពរបស់យើងដើម្បីធ្វើអំពើល្អ និងឈរកាន់តែរឹងមាំ ដើម្បីប្រឆាំងជាមួយនឹងអំពើបាប ឬភាពបរាជ័យ។ នៅរាល់ការធ្លាក់ចុះក្នុងកំហុស ថ្វីបើបន្តិចបន្តួចក្តី នឹងធ្វើឱ្យយើងកាន់តែទទួលយកឥទ្ធិពលរបស់សាតាំង ហើយក្រោយមកវានឹងល្បួងយើង។ សាតាំងយកយើងបន្តិចម្តងព្ធ ចោកបញ្ឆោតយើងឱ្យទៅរកផលវិបាកទាំងឡាយ ដែលសូម មើលទៅដូចជាអំពើបាបតែបន្តិចបន្តួច រហូតដល់វាចាប់យើងឱ្យធ្លាក់ចុះក្នុងកំហុសដ៏ធំ។ នីហ្វៃបានពិពណ៌នា បច្ចេកទេសនេះដូចជាសភាពដ៏ស្ងប់ស្ងាត់មួយ ការល្ងងលោម ហើយបញ្ឆោរយើងឱ្យធ្លាក់ រហូតដល់សាតាំងអាចចាប់ [យើង] ជាប់ដោយច្រវាក់ ដ៏អប្រីយ៍របស់វា ចាប់ពីនោះទៅ គឺពុំអាចរំដោះឱ្យរួចបានឡើយ (នីហ្វៃទី2 28ៈ22 សូមមើលផងដែរនៅ 21)" (នៅក្នុង Conference Report ខែតុលា ឆ្នាំ1994, 54 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ1994, 40)។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 28 ចូរធ្វើសកម្មភាពពីរនៃសកម្មភាព (ក–គ) ដូចខាងក្រោម។

ក ចំណេះចំណានព្រះគម្ពីរ—នីហ្វៃទី2 28:7–9

1. ចូរសរសេរឃ្លាថ្មីមួយ ដើម្បីបង្ហាញពីគំនិតខុសឆ្គងនីមួយៗនៅក្នុង នីហ្វៃទី2 28:7—9 ដែលនីហ្វៃបានទិយាយថា នឹងជាទំពេញទិយម នៅក្នុងជំនាន់របស់យើង (ឧទាហរណ៍ គំនិតនៅក្នុងខទី 7 អាចបញ្ជាក់ត្រាប់អ្នក “ទៅធ្វើអ្វីដែលអ្នកអាច ព្រោះអ្នករស់បានតែម្តង”)។
2. ចំពោះឃ្លានីមួយៗ ស្វែងរកយ៉ាងតិចខគម្ពីរចំនួនបី ដែលពន្យល់ពីមូលហេតុ ដែលអាកប្បកិរិយានោះគឺជា គោលលទ្ធិ “ខុសហើយឥតប្រយោជន៍ និងឆ្កួត” (ខទី 9)។
3. ចូរពន្យល់ពីមូលហេតុដែលអ្នក សំរេចជ្រើសរើសយកខគម្ពីរនីមួយៗ។ អ្នកប្រហែលជាចង់សរសេរសេចក្តីយោង នៅរឹមទំព័រ ជិតនឹង នីហ្វៃទី2 28:7–9 ដើម្បីឱ្យអ្នកអាចជួយពង្រឹងដល់អ្នកដទៃ ដែលអាចត្រូវល្បួងក្នុងរឿងដូច គ្នាទាំងនេះតែវា គឺជា ទស្សនៈវិជ្ជាជ័ព្ទតលិលាទេ។

ខ បញ្ជាក់ពីវិធីសាស្ត្ររបស់សាតាំង

1. សូមអានៅក្នុងនីហ្វៃទី2 28:19–23 ហើយធ្វើបញ្ជីពីវិធីខុសឆ្គគ្នា ដែលសាតាំង បានព្យាយាម ដើម្បី “ចង” មនុស្សឱ្យនៅក្នុង “ច្រវាក់ដ៏ជាប់អស់កល្បអង្វែង” របស់វា។
2. សំរាប់ចំណុចនីមួយៗ នៅក្នុងបញ្ជីរបស់អ្នក ចូរឱ្យជាឧទាហរណ៍ ពីរបៀបដែលសាតាំងប្រើវិធីសាស្ត្រ ទាំងនោះ ចំពោះ មនុស្សវ័យក្មេងសម័យនេះ។

គ មនុស្សដែលមានទុក្ខសោក

ទុក្ខវេទនា គឺជាពាក្យដែលសំដៅទៅលើសេចក្តីទុក្ខព្រួយ និងការសោកស្តាយយ៉ាងខ្លាំង។ ចូរសរសេរពីអាកប្បកិរិយា និងសកម្មភាពចេញមកពី នីហ្វៃទី2 28:15–16, 24–32 ដែលនីហ្វៃបានទិយាយថា នឹងនាំមកនូវ “ទុក្ខវេទនា” ដល់ប្រជាជន។

ពេលខ្លះមនុស្សដែលមិនមែនជាសាមាជិកនៃ សាសនាចក្រ បានដំទាស់ថា ព្រះគម្ពីរមរមនមិនអាចជា ព្រះគម្ពីរពិតបានទេ ដោយសារព្រះគម្ពីរមីប គឺជា ព្រះគម្ពីរតែមួយគត់ ដែលព្រះបានប្រទានដល់មនុស្ស។ នៅក្នុងនីហ្វៃទី2 29 នីហ្វៃបានព្យាករ អំពីការបង្ក្រៀវនៃខុសឆ្គងនេះ ហើយសរសេរដោយយកចិត្តទុកដាក់ ទៅកាន់មនុស្សទាំងឡាយ ដែលបង្ហាញអាកប្បកិរិយា បែបនោះ។ ជំពូកនេះគឺជា ការបន្តរឿងគំនិតទាំងឡាយ ដែលបានបញ្ជាក់នៅចុងបញ្ចប់នៃ នីហ្វៃទី2 28 អំពីពួកសាសន៍ដទៃ ដែលកាន់តែបដិសេធបន្ទូលរបស់ព្រះ ហើយទុកចិត្តទៅលើ ការសិក្សារបស់គេផ្ទាល់ (សូមមើលនីហ្វៃទី2 28:27–32)។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 29

ពួកគេ (ខ 1)—ពួកសាសន៍ដទៃ

ទង់ជ័យ (ខ 2)—អ្វីមួយដែលរ្យេបចំឡើងដោយសិទ្ធិអំណាច ក្នុងទាមជាអ្នកត្រួតត្រា ដែលអ្នកដទៃត្រូវបានកាត់ក្តី (ដំណឹងល្អ)

ហួចហោ (ខ 2–3)—សំលេងដែលធ្វើដើម្បីឱ្យមានការចាប់អារម្មណ៍ពីអ្នកដទៃ និយាយ ហៅ

ការធ្វើជំណើរ (ខ 4)—ការធ្វើការដោយឈើចាប់ ធ្វើការខ្លាំង ភាពមិនអនុគ្រោះ

ការព្យាយាម (ខ 4)—ការខិតខំប្រឹងប្រែងដោយខ្លាប់ខ្ជួន ការលះបង់

នីហ្វៃទី2 29:12–14—“ពាក្យរបស់ពួកពួជអំបូរ នៃសាសន៍អ៊ីស្រាអែល ដែលបាត់”

អែលឌើរ ប្រ៊ូស អរ. មិកខនឃី បានឱ្យដាយោបល់ថា បញ្ជីប្រវត្តិដែល បានទិយាយនៅក្នុង នីហ្វៃទី2 29:12–14 នឹង “លេចចេញមក នៅក្នុង រយៈបជ័អស្ចារ្យ ក្រោមការដឹកនាំរបស់ប្រធាន នៃសាសនាចក្រព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ ដែលជា អ្នកទទួលវិវរណៈ ហើយជាអ្នកបកប្រែ និងជាអ្នកកាន់កូនសោរនៃនគរ របស់ព្រះ នៅលើផែនដី ដែលជាទំនាក់ទំនងចំពោះមនុស្ស ទាំងអស់ រួមទាំងកុលសម្ព័ន្ធទាំងដប់” (*The Millennial Messiah,* 217)។ យើងដឹង ថាព្រះអង្គសង្គ្រោះ បានយាងមកជួបជាមួយនឹង កុលសម្ព័ន្ធដែលបាត់មួយចំនួន នៃអ៊ីស្រាអែល បន្ទាប់ពីការ រស់ឡើងវិញរបស់ទ្រង់ និងបន្ទាប់ពីទ្រង់យាងមកជួបជាមួយនឹង ពួកសាសន៍នីហ្វៃ (សូមមើល នីហ្វៃទី 3 16:1–3, 17:4)។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 29 ចូរធ្វើសកម្មភាព ក ដូចខាងក្រោម។

ក ការឆ្លើយចំពោះអ្នកវិះគន់ ព្រះគម្ពីរមរមន

ការចូលរួមក្នុងការឈ្លោះប្រកែករបស់មនុស្សនៅក្នុងជំនាន់របស់យើង ដែលនិយាយថា គេមានព្រះគម្ពីរបីបួនទៅហើយ ហើយមិនត្រូវការនូវ ព្រះគម្ពីរណាទៀតទេ នីហ្វៃបានផ្តល់ឱ្យនូវគោលការណ៍ចំនួនត្រាំពីរទៅដល់មនុស្សទាំងនោះ គួរតែគិត មុនពេល ដែលមនុស្សទាំងនោះនឹងបដិសេធព្រះគម្ពីរមរមនថា ជាព្រះគម្ពីរ។ សេចក្តីថ្លែងការណ៍ និងសំនួរទាំងឡាយ ដូចមាននៅ ខាងក្រោមនេះសំដៅទៅលើអ្វីដែលនីហ្វៃបានសរសេរទុក។ ចូរសរសេរសេចក្តីថ្លែងការណ៍ និងសំនួរទាំងនោះនៅក្នុងស្មៀវភៅ សរសេររបស់អ្នក ហើយបន្ទាប់មកសរសេរពីអ្វីដែល នីហ្វៃបានសរសេរនៅ ក្នុងនីហ្វៃទី2 29:7–11 អំពីសេចក្តីថ្លែងការណ៍ និងសំនួរនីមួយៗ ព្រមជាមួយនឹងខគម្ពីរ ដែលរកបានការដកស្រង់។ (បញ្ជីគឺមិនមានជាលំដាប់លំដោយ តាមដែលរកឃើញ នៅក្នុងជំពូកទេ)។

1. ព្រះធ្វើការងាររបស់ទ្រង់ តាមរយៈសាក្សី ពីរ ឬ បីនាក់ (សូមមើល ម៉ាថាយ 18:16, 2 កូរិនថូសទី2 13:1)។ ព្រះគម្ពីរមរមនគឺជាសាក្សីទីពីរ ដែលបញ្ជាក់ថា ការបង្រៀននៅក្នុងព្រះគម្ពីរបីបគឺជាការពិត (សូមមើល មរមន 7:8–9)។

2. ហេតុអ្វីបានជាអ្នករអ៊ូរទាំអំពីការមានព្រះគម្ពីរថែមទៀត ដើម្បីជួយដឹកនាំអ្នកដូច្នេះ?

3. តើអ្នកគិតថា ព្រះគម្ពីរបីបមានន័យឮៗ ដែលព្រះបានមានបន្ទូល ឬនឹងមានបន្ទូលដែរឬទេ?

4. ដោយសារព្រះ ទ្រង់បានមានបន្ទូលនៅក្នុងព្រះគម្ពីរបីប តើនោះមានន័យថា ទ្រង់មិនអាចមានបន្ទូល នៅត្រង់ពេល និងនៅកន្លែងផ្សេងឬ?

5. ព្រះគម្ពីរបីបគឺជាបញ្ជីប្រវត្តិនៃទំនាក់ទំនងរបស់ព្រះ ជាមួយនឹង ពួកសាសន៍អ៊ីស្រាអែល នៅមជ្ឈឹមបូរាណាប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់គឺជាព្រះនៃអ៊ីស្រាអែលនៅត្រង់ទីកន្លែង និងត្រង់ជាតិសាសន៍។ ទ្រង់ក៏បានចែកព្រះបន្ទូល ទ្រង់ទៅដល់ពួកគេ។

6. ព្រះបានមានបន្ទូល ទៅត្រង់ជាតិសាសន៍ ទ្រង់បានបញ្ជាពួកគេឱ្យតត់ត្រានូវបន្ទូលរបស់ទ្រង់។ យើងនឹងត្រូវកាត់ក្តី ចេញមកពីការសរសេរទាំងនោះ (សូមមើល វិវរណៈ 20:12–13)។

7. បទគម្ពីរផ្សេងៗទៀតនៃព្រះគម្ពីរ មានផ្តុំគទីបន្ទាល់អំពីសក្តិភាពបន្ថែមទៀតនៃដំណឹងល្អ ថាព្រះទ្រង់នៅតែជវដែល ទោះពីម្សិល ថ្ងៃនេះ និងរហូតតទៅ។

នីហ្វៃទី2 30

អំណាចរបស់ព្រះគម្ពីរមរមន

*អែលឌើរ ប្រ៊ូស អរ. មិកខនឃី បានសរសេរថា៖ "មនុស្សពីរបីនាក់នៅលើផែនដី ទោះជានៅក្នុង ឬក្រៅសាសនាចក្រ ក៏បានដឹងនូវអ្វីៗអំពីព្រះគម្ពីរមរមនដែរ។ ពីរបីនាក់ក្នុងចំណោមមនុស្ស ដែលបានដឹងពីផ្នែកនៃព្រះគម្ពីរមរមនដឹងថា ព្រះគម្ពីរមរមនបានមានគួនាទី ហើយនឹងត្រូវមានគួនាទី នៅក្នុងការរៀបចំផ្លូវសំរាប់ការយាងមករបស់ទ្រង់ ដែលជាសាក្សីថ្មីម្នាក់" (*The Millenial Messiah, *159)។*

នីហ្វៃគឺជាមនុស្សម្នាក់នៅក្នុងចំណោម "មនុស្សពីរបីនាក់នោះ" ដែលយល់អំពីគួនាទីរបស់ព្រះគម្ពីរមរមន នៅក្នុងថ្ងៃចុង ក្រោយ។ នីហ្វៃបានសរសេរអំពីការខ្ចាត់ខ្ចាត់នៃពួកសាសន៍យូដា ទីងការធ្លាក់ចុះនៃប្រជាជនរបស់លោក ទីងសេចក្តីទុច្ចរិត របស់ពួកសាសន៍ ជនៃនៅក្នុងថ្ងៃចុងក្រោយ នៅពេលដែលមនុស្សជារច្រើន នឹងបដិសេធព្រះគម្ពីរមរមន ដែលជាសាក្សីទីពីររបស់ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់។ នៅពេលអ្នកអាននៅក្នុងនីហ្វៃទី2 30 សូមរក សូមមើលពីអ្វីដែលនីហ្វៃ បានព្យាករថា ព្រះគម្ពីរ មរមនទីង ប្រទានពរដល់ក្រុមប្រជាជនទាំងបីនោះ ពីមុនការយាងមក ជាលើកទីពីរ របស់ព្រះយេស៊ូវគ្រីស្ទ

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 30

,មិនទ្រាំឱ្យ (ខ 1)—ទុកឱ្យ អនុញ្ញាតឱ្យ

ចាប់ផ្តើម (ខ 8)—ចាប់ផ្តើម

ត្រប់ពូជមនុស្ស (ខ 8)—ក្រុមគ្រួសារ

ជំនុំជំរះ (ខ 9)—ទាំមកនូវសេចក្តីយុត្តិធម៌

ស្មោះត្រង់ (ខ 9)—យុត្តិធម៌ ត្រឹមត្រូវ

ជាខ្សែក្រវាត់ទ្រង់, ជាខ្សែក្រវាត់កម្លាំងទ្រង់ (ខ 11)—ឃ្លាទាំងពីរសំដៅទៅលើខ្សែក្រវាត់ ឬឈ្មោងដែលរុំនៅជុំវិញចង្កោះ របស់មនុស្ស (ត្រូវបានប្រើជានិមិត្តសញ្ញានៅក្នុងនេះ)

ក្មេងបៅដោះ (ខ 14)—ការចិញ្ចឹមក្មេង

ពស់ហនុមាន, ពស់វែក (ខ 14)—ពស់មានពីស

នីហ្វៃទី2 30:2—តើនរណាជា ប្រជាជនជាប់កិច្ចសន្យានៃព្រះអម្ចាស់?

កត់ចំណាំនៅក្នុងនីហ្វៃទី2 30:2 ដែលព្រាប់ថាមនុស្សទាំងអស់ណា មានជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តគឺជា "ប្រជាជនដែល ជាប់កិច្ចសន្យា នៃព្រះអម្ចាស់"។ នេះគឺជាមូលហេតុដែលប៉ុលនិយាយថា "ពួកគេទាំងអស់គ្នា ដែលចុះកិច្ចសន្យា គឺមិនមែនជាសាសន៍ អ៊ីស្រាអែលទាំងអស់ទេ" (រ៉ូម 9:6)។ ដើម្បីក្លាយជាសមាជិកម្នាក់នៃវង្សអ៊ីស្រាអែល មានសិទ្ធិទទួល ពរដ៏ធំទាំងអស់ នៃគ្រួសារដាប់កិច្ចសន្យា គឺតំរូវឱ្យមានច្រើនជាជាងពូជពង្ស។ អ្នកដែលមិនបានកើតនៅក្នុងវង្សអ៊ីស្រាអែល នឹងក្លាយជាសមាជិកនៃគ្រួសារ ដែលដាប់កិច្ចសន្យា តាមរយៈសេចក្តីជំនឿរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ ការកែប្រែចិត្ត និងការចុះ សេចក្តីសន្យានៅពេលធ្វើពិធីបុណ្យជ្រមុជទឹក ដែលដង្ហាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ធ្វើឱ្យកើតមានឡើង។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 30 ធ្វើសកម្មភាព ក នៅដូចខាងក្រោមនេះ។

ក តើអ្នកបានរៀនអំពីអ្វី?

1. សរសេរដើមរឿងចំនួនបី ដែលនៅកាត់ពីខាងលើក្បាលទំព័រមួយ នៅក្នុងស្បៀវភៅសរសេរ របស់អ្នក: ពួកសាសន៍យូដា, កូនចៅរបស់លោកលីហៃ និងពួកសាសន៍ជរិទ។ សូមអាននៅក្នុងនីហ្វៃទី2 30:1–7 ហើយនៅពីក្រោមដើមរឿងនីមួយៗ ចូរធ្វើបញ្ជីពីអ្វីដែលអ្នកបានរៀនអំពីក្រុមនោះ។ ចូរ ដាក់សញ្ញាផ្កាយនៅជិតសេចក្តីថ្លែងការណ៍ទាំងឡាយនៅក្នុងបញ្ជីរបស់អ្នក ដែលមានទំនាក់ទំនងជាមួយនឹង ព្រះគម្ពីរមរមន។

2. នៅក្នុង នីហ្វៃទី2 30:8–18 នីហ្វៃបានពិពណ៌នាអំពីព្រឹត្តិការណ៍ពីរ ឬកំឡុងពេល ដែលព្រះគម្ពីរមរមន បានជួយរៀបចំ យើង។ តើកំឡុងពេលទាំងនោះ ជាទូទៅត្រូវបានហៅថាអ្វី?

3. ចំពោះព្រឹត្តិការណ៍ទាំងពីរនីមួយៗ បានបញ្ជាក់នៅខាងលើ ចូរធ្វើបញ្ជីពីអ្វីៗទាំងអស់ ដែលនៅក្នុងជំពូកទី 30 បានបង្រៀនអ្នក អំពីព្រឹត្តិការណ៍ទាំងនោះ។
4. តើអ្នកគិតថា អ្វីដែលសក្តិសមជាងគេបំផុត ដើម្បីរស់នៅក្នុងកំឡុងពេល ដែលបានពិពណ៌នានៅក្នុង ខទី12–18?

នីហ្វៃទី2 31
គោលលទ្ធិរបស់ព្រះគ្រីស្ទ

យើងបានរៀនត្រើនមកពីនីហ្វៃ និងអំពីនីហ្វៃ តាំងពីការចាប់ផ្តើមនៃព្រះគម្ពីរមរមន។ មុនពេលនីហ្វៃ បានរៀបនឹងចាកចេញ ពីជីវិតនេះទៅ លោកបានប្រគល់ផ្តាំងចំណារ ទៅឱ្យយ៉ាកុប ដែលជាប្អូនប្រុសរបស់លោក នីហ្វៃបានសង្ខេប រាល់ការបង្រៀន សំខាន់ៗអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងបានបន្សល់ទុកនូវសក្ខីភាព នៃសេចក្តីពិតពេញលេញពីអ្វីដែលលោកបានសរសេរ។

នៅក្នុងនីហ្វៃទី2 31:2 នីហ្វៃបានសរសេរថា លោកចង់ផ្តល់ឱ្យយើងនូវ "ពាក្យពីរបីម៉ាត់ . . . ដែលទំនាយ អំពីគោលលទ្ធិរបស់ព្រះ គ្រីស្ទ។" បន្តាប់មកនៅក្នុងខទី 21 លោកបានថ្លែងទីបន្ទាល់ថា លោកបានបង្រៀនពីគោលលទ្ធិពិតរបស់ព្រះគ្រីស្ទ។ ចូរសិក្សាដោយ យកចិត្តទុកដាក់អំពីអ្វីដែលមាន រវាងខទី2 និង 21 ដើម្បីអ្នកអាចរៀន ពីធាតុសំខាន់ៗ នៃគោលលទ្ធិរបស់ព្រះគ្រីស្ទ ជាយ៉ាង ណានោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 31

ក៏ល្មមគ្រប់គ្រាន់ចំពោះ (ខ 2)—គ្រប់គ្រាន់សំរាប់គោលបំណងរបស់ខ្ញុំ

គោលលទ្ធិ (ខ 2, 21)—គោលការណ៍, សេចក្តីពិត

តើមកពីហេតុអ្វីបានជា (ខ 6)—នៅក្នុងវិធីណា

ធ្វើទីបន្ទាល់ដល់ (ខ 7)—កសាង សេចក្តីពិត, ផ្តល់ជាភស្តុតាង

លាក់ពុត (ខ 13)—សំដែងធ្វើជាអ្វីមួយ ដែលមិនមាន

ពោកបញ្ឆោត (ខ 13)—មិនស្មោះត្រង់

ផ្តាច់ (ខ 17)—អត់ឱនទោស

គុណបុណ្យ (ខ 19)—សេចក្តីល្អ ឬភាពអស្ចារ្យដែលឱ្យសិទ្ធិដល់អ្នកណាម្នាក់ ដើម្បីផ្តល់ជាកិត្តិយស ឬជារង្វាន់

ដោយខ្ជាប់ខ្ជួន (ខ 20)—គោលដៅ ឬដោយគំនិតម៉ឺងម៉ាត់

នីហ្វៃទី2 31:13–14—"ភាសាទេវតា"

សូមមើល នីហ្វៃទី2 32:2–3 ដើម្បីជួយអ្នកយល់ពីអត្ថន័យ ភាសាទេវតា។

នីហ្វៃទី2 31:21—ភាពតែមួយនៃក្រុមព្រះបិអង្គ

ដោយសារការមិនយល់ពីគោលលទ្ធិដែលទាក់ទងនឹងធម្មជាតិ នៃព្រះឱ្យបានពេញលេញ មនុស្សបានយល់ខុសពីសេចក្តីថ្លែង ដែលទាក់ទងជាមួយនឹងសមាជិកក្រុមព្រះបិអង្គដែល "តែមួយ។" ព្រះវរបិតា និងព្រះរាជបុត្រា *ទាំងពីរអង្គ* បានបង្ហាញព្រះអង្គ ទ្រង់ដល់ព្យាការីយ៉ូសែប ស្ម៊ីធ (សូមមើល ប្រវត្តិរបស់–យ៉ូសែប ស្ម៊ីធ 1:17) ហើយត្រូវបានបើកបង្ហាញចំពោះលោកថា ក្រុមព្រះបិអង្គគឺដាច់ដោយឡែកពីគ្នា ជាតួអង្គផ្សេងគ្នា (សូមមើល គ និង ស 130:22)។ ទោះជាយ៉ាងណាក៏ដោយ តួអង្គទាំង បីគឺ "តែមួយ" ក្នុងនេះមានន័យថា ជាបន្ទូល ឬសកម្មភាពរបស់តួអង្គមួយ ទក្រុមព្រះបិអង្គនោះ ក៏ជាបន្ទូល ឬសកម្មភាព របស់ព្រះពីរអង្គទៀតដែរ (សូមមើល នីហ្វៃទី3 11:32–36)។ ទ្រង់ទាំងបីអង្គ គឺមានគោលដៅតែមួយ។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 31 ចូរធ្វើសកម្មភាពដូច យ៉ាងតិចពីរ ចេញពីសកម្មភាព (ក–ឃ) ដូចខាងក្រោមនេះ។

ក សង្ខេបការបង្រៀនរបស់នីហ្វៃ

នៅក្នុងកថាខ័ណ្ឌមួយ ចូរធ្វើការសង្ខេប "គោលលទ្ធិរបស់ព្រះគ្រីស្ទ" ដែលរកបាននៅក្នុង នីហ្វៃទី2 31:3–20។ ត្រូវឱ្យប្រាកដថា រួមបញ្ចូលនូវរាល់គោលការណ៍សំខាន់ៗទាំងអស់។

ខ ហេតុអ្វីធ្វើពិធីបុណ្យជ្រមុជទឹក?

© 1988 Greg K. Olsen

1. អាននីហ្វៃទី2 31:5–9 ហើយធ្វើបញ្ជីអំពីមូលហេតុដែល ព្រះយេស៊ូវបានធ្វើបុណ្យជ្រមុជទឹក។
2. តើអ្វីទៅដែលយើងត្រូវតែ បន្តែមក្នុងបញ្ជី បើយើងកំពុងតែធ្វើបញ្ជីមូលហេតុ ដែលយើងត្រូវតែធ្វើបុណ្យជ្រមុជទឹក? (សូមមើល គ និង ស 33:11, មាត្រានៃសេចក្តីជំនឿ 1:4)។

គ គូរ

ចូរគូរ ឬ ធ្វើឌីយ៉ាក្រាមដែលដាតំណាងពីអ្វី ដែលនីហ្វៃបានបង្រៀននៅក្នុង នីហ្វៃទី2 31:17–20 ជាវិធីដែលយើង អាចទទួល បានជីវិតអស់កល្បជានិច្ច។ សូមបញ្ចូលរាល់គំនិត និង ធាតុទាំងអស់ដែលនីហ្វៃបានទិយាយអំពីនោះ។ ចូរបង្ហាញដល់មិត្តភក្តិ និងសមាជិកគ្រួសារ ហើយសួរពួកគេ បើអត្ថន័យទាំងនោះច្បាស់លាស់ ចំពោះពួកគេ។

៥ ផ្តល់ការពន្យល់បន្ថែម

នៅពេលខ្លះពាក្យ ឬ ឃ្លាសាមញ្ញនៅក្នុងព្រះគម្ពីរ អាចតំណាងឱ្យ គំនិតដ៏ស៊ីជំរៅ សំខាន់ និងប្រកបដោយអំណាច។ ចូរធ្វើការ ពិចារណាទៅលើពាក្យ និងឃ្លាដូចខាងក្រោម ដែលដកចេញមក នីហ្វៃទី2 31។ ចូរពន្យល់ពីសារៈសំខាន់ និងសារដំណឹង ចេញពីឃ្លានីមួយៗនោះ។

1. "ភាពតូចនៃផ្លូវ" (ខ 9)
2. "ដោយពេញចិត្តប្រាថ្នា" (ខ 13)
3. "ទ្វារ" (ខ 17)
4. "ដោយទទួលទាន" (ខ 20)

នីហ្វៃទី2 32

នីហ្វៃបន្តបង្រៀនពីគោលលទ្ធិរបស់ព្រះគ្រីស្ត

ដំណើរដើម្បីទទួលបានជីវិតអស់កល្បជានិច្ច តាមរយៈព្រះយេស៊ូវគ្រីស្ត ដែលនីហ្វៃបានសរសេរអំពីនោះ នៅក្នុង នីហ្វៃទី2 31 គឺល្អ, ជ្រាលជ្រៅ និងជាការពន្យល់ដោយសាមញ្ញ។ តើនោះពិតជាអ្វីៗទាំងអស់ដែលយើង ត្រូវធ្វើឬ?

នីហ្វៃយល់ឃើញថា មានមនុស្សខ្លះនៅតែពិចារណា ពីអ្វីដែលគេគួរតែធ្វើ បន្ទាប់ពីពួកគេបានចូលទៅ "តាមផ្លូវនោះ" (នីហ្វៃទី2 32:1)។ នៅក្នុង នីហ្វៃទី2 32 នីហ្វៃបានពន្យល់ ពីរបៀបដែលយើងត្រូវបន្តធ្វើ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី2 32

ពិចារណាគិត (ខ 1, 8)—គិតឱ្យស៊ីជំរៅអំពីអ្វីមួយ

ទៅតាមផ្លូវនោះ (1, 5)—នៅលើផ្លូវដែលនាំទៅកាន់ជីវិតអស់កល្បជានិច្ច (ដូចដែលបានពន្យល់នៅក្នុង នីហ្វៃទី2 31)

យល់ថា (ខ 8)—គំនិត, អារម្មណ៍, កត់សំគាល់

ញែក (ខ 9)—តែតាំងឡើងសំរាប់គោលបំណងពិសិដ្ឋ

នីហ្វៃទី2 32:3—"បន្ទូលរបស់ព្រះគ្រីស្ត នឹងប្រាប់អ្នកអ្វីៗទាំងអស់ដែលអ្នកត្រូវធ្វើ"

អែលឌើរ ប៊ីយ យេ. ផាកកឺ បានបង្រៀនថាះ "បើសិន [អ្នក] បានយល់អំពីវិវរណៈ នោះអ្នកនឹងគ្មានសំនួរ—ផ្ទាល់ខ្លួន ឬពីសង្គម, ពីនយោបាយ, ពីវិជ្ជាជីវៈ—ដែលត្រូវការប្រព្រឹត្តទៅដោយគ្មានចំលើយនោះទេ។ នៅត្រង់នោះហើយ ដែលវិវរណៈ មានទូវភាព ពេញលេញ នៃភាពអស់កល្បជានិច្ចនៃដំណឹងល្អ។ នៅត្រង់នោះហើយ ដែលយើងអាចស្វែងរកគោលការណ៍នៃសេចក្តីពិត ដែលនឹងដោះស្រាយរាល់ការយល់ច្រឡំ និងបញ្ហាទាំងឡាយ និងស្ថានភាពលំបាកទាំងអស់ ដែលនឹងប្រឈមចំពោះគ្រួសារ ឬបុគ្គលណាម្នាក់ៗនៅក្នុងនោះ" ("Teach the Scriptures," នៅក្នុង *Charge to Religious Educatiors* [ចោះពុម្ពជាលើកទី 3], 89)។



នីហ្វៃទី 32:8–9—ការអធិស្ថាន

ប្រធាន គរដឹន ប៊ី. ហ៊ីងឃ្លី បានបង្រៀនថាះ "យើងអាចធ្វើឱ្យមានការរីកចំរើនយ៉ាងអស្ចារ្យ នៅក្នុងការណែនាំពី ភាពឥត ខ្ចោះនៅក្នុងឥរិយាបទផ្ទាល់ខ្លួនរបស់យើង។ យើងអាចបានល្អឥតខ្ចោះនៅក្នុង អធិស្ឋានរបស់យើងទៅកាន់ ព្រះវរបិតាស្ថគិ របស់យើង។ មានរឿងខ្លះៗ ដែល ពិបាកយ៉ាងខ្លាំង ដើម្បីធ្វើឱ្យបានល្អឥតខ្ចោះ តែខ្ញុំសង្ឃឹមថា អ្នកគ្រប់គ្នា . . . នឹងលុត ជង្គង់ចុះនៅពេលយប់ និងពេលព្រឹក ហើយថ្លែងអំណរ គុណចំពោះព្រះអម្ចាស់ សំរាប់ពរជ័យទាំងឡាយរបស់ទ្រង់ ថ្លែងអំណរ គុណទ្រង់ចំពោះ ព្រះទ័យល្អរបស់ទ្រង់ថ្លែងអំណរគុណ ចំពោះ ព្រះអម្ចាស់ សំរាប់អំណោយទាំងអស់ ដែលទ្រង់បានប្រទានឱ្យ ហើយអធិស្ឋានសំរាប់ភាពរឹងមាំ ក្នុងការធ្វើអ្វីដែលត្រូវ ហើយចង ចំាពីអ្នកទីទាល់ និងអ្នកមានទុក្ខព្រួយនៅពីមុនព្រះអម្ចាស់។ បងប្អូនប្រុសស្រីទាំងឡាយ យើងអាចបានល្អ ឥតខ្ចោះនៅក្នុងការអធិស្ឋានរបស់យើង" (Inspirational Thoughts, *Ensign*, ខែកក្កដា ឆ្នាំ1998, 2)។

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកសិក្សានៅក្នុង នីហ្វៃទី2 32 ចូរធ្វើសកម្មភាព ក និង ខ ដូចខាងក្រោម។

ក ចំណេះចំណានបទគម្ពីរ—នីហ្វៃទី2 32:3

1. យោងទៅតាម នីហ្វៃទី2 32:1–3 តើយើងត្រូវធ្វើអ្វីខ្លះ បន្ទាប់ពីយើងបានដើរនៅលើផ្លូវដែលនាំទៅកាន់ជីវិតអស់កល្បជានិច្ច?
2. តើអ្វីដែលលីហៃបានឃើញនៅក្នុងទស្សនៈនិមិត្តរបស់លោកនោះ នឹងជួយឱ្យមនុស្សនៅលើផ្លូវបានយ៉ាងដូចម្តេច (សូមមើល នីហ្វៃទី1 8)?
3. ចូរសរសេរឈ្មោះនៃមធ្យោបាយចំនួនបីផ្សេងៗពីគ្នា ដែលព្រះបន្ទូលរបស់ព្រះគ្រីស្ត អាចត្រូវបានទទួលយក និងប្រកាន់ យ៉ាងខ្ជាប់ខ្ជួន។

ខ ចំណេះចំណានបទគម្ពីរ—នីហ្វៃទី2 32:8–9

ចូរធ្វើការស្រមៃថា អ្នកមានមិត្តម្នាក់ដែល មានការច្របូកច្របល់ជាមួយនឹងសក្ខីភាពរបស់គាត់ ឬនាង ហើយបានធ្វើការ ពន្យល់ទៅកាន់អ្នក នូវពាក្យ ដូចខាងក្រោម។ ចូរសរសេរនូវពាក្យនីមួយៗ នៅក្នុងស្យៀវភៅសរសេររបស់អ្នក ហើយបន្ត រាជាមួយឃ្លា ឬប្រយោគមួយ មកពីនីហ្វៃទី2 32:8–9 ដែលអាចជួយដល់អ្នកដឹងពីអ្វីដែល អ្នកគួរតែនិយាយទៅ កាន់មិត្តរបស់អ្នក។

1. “ខ្ញុំមិនអធិស្ឋានជាញឹកញាប់ទេ”
2. “នៅពេលខ្លះ ខ្ញុំគិតថា ខ្ញុំប្រហែលជាគួរតែអធិស្ឋាន តែបន្ទាប់មកខ្ញុំគ្មានអារម្មណ៍ចូលចិត្ត អធិស្ឋានទេ ដូច្នេះខ្ញុំមិនអធិស្ឋាន។”
3. “ដោយសារខ្ញុំមានបទពិសោធន៍ខាងវិញ្ញាណ តែបន្តិចបន្តួច នោះខ្ញុំគិតថា ខ្ញុំនឹងគ្រាន់តែឈប់អធិស្ឋានប៉ុណ្ណោះ។”
4. “ខ្ញុំបានអានព្រះគម្ពីរខ្លះៗ តែវាហាក់ដូចជាមិនបានជួយខ្ញុំទេ។ តើអ្វីអាចជួយខ្ញុំឈ្នះនូវអារម្មណ៍នេះបាន?”

ពាក្យចុងក្រោយបំផុត ដែលនីហ្ហៃបានសរសេរនៅក្នុងព្រះគម្ពីរមរមន អាចរកបាននៅក្នុង នីហ្ហៃទី 2 33។ នៅក្នុងនោះ លោកបានបង្ហាញពីសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ និងការតាំងចិត្ត ចំពោះប្រជាជនរបស់លោកព្រមទាំងសក្ខីភាព ដ៏មានអំណាចរបស់លោក អំពីព្រះយេស៊ូវគ្រីស្ទ។ យើងក៏បានរៀនផងដែរ ថាតើលោកមានអារម្មណ៍យ៉ាងណាអំពីអ្វី ដែលលោកបានសរសេរ ហើយអ្វីដែលលោកកំពុងសរសេរគួរតែមាន អត្ថន័យយ៉ាងថ្លៃថ្លាចំពោះអ្នកទាំងឡាយ ណាដែលបានអានពីការសរសេររបស់លោក។ នៅពេលដែលអ្នកអាន ចូរពិចារណាទៅលើសក្ខីភាព ដ៏ពិសេសនេះមកពីព្យាការីម្នាក់ក្នុងចំណោមព្យាការីជំរើសរបស់ព្រះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្ហៃទី2 33

រាប់ទុកជារបស់ឥតប្រយោជន៍ទៅវិញ (ខ 2)—ចាត់ទុកថារបស់ទាំងនោះគ្មានតម្លៃ

តឹងតែង (ខ 5)—ធ្ងន់ធ្ងរ, អារម្មណ៍ និងភាសាតឹងតែង

សេចក្តីសប្បុរស (ខ 9)—សេចក្តីស្រឡាញ់ដ៏សុទ្ធសាធរបស់ព្រះគ្រីស្ទ (សូមមើល មរ៉ូណៃ 7:47)

ស្រុះស្រួល (ខ 9)—ការប្រមូលផ្តុំមកវិញនូវសាមគ្គីភាព បន្ទាប់ពីការមិនយល់ស្របគ្នា

ថ្ងៃនៃការសាកល្បង (ខ 9)—ពេលនៃការសាកល្បង និងការបំភ្លឺ (មានន័យថា ជីវិតផែនដីនេះ, ជីវិតដែលរមែងស្លាប់)

ការសិក្សាព្រះគម្ពីរ

នៅពេលអ្នកអាននៅក្នុង នីហ្ហៃទី2 33 ចូរធ្វើសកម្មភាព ក ឬ ខ ដូចខាងក្រោមនេះ។

ក “តម្លៃដ៏ខ្ពស់”

1. នីហ្ហៃបានសរសេរថា ការបង្រៀននៅក្នុងព្រះគម្ពីរមរមន គឺជាការបង្រៀននៃ “តម្លៃដ៏ខ្ពស់” (នីហ្ហៃទី2 33:3)។ សូមអាន ខ 4–5 ហើយសរសេរវិធីចំនួនបួន ដែលព្រះគម្ពីរមរមនអាចប្រសិទ្ធិពរដល់យើង។
2. ចូរសរសេរពីរបៀបដែលព្រះគម្ពីរមរមន មានឥទ្ធិពលចំពោះអ្នក ដែលចេញពីវិធីមួយក្នុងចំណោមវិធីទាំងនោះ ឬពន្យល់ពីវិធីទាំងបួននោះ ដែលមានសារៈសំខាន់បំផុតសំរាប់អ្នក នៅក្នុងការសិក្សាព្រះគម្ពីរមរមនកន្លងមកនេះ។

ខ ការត្រៀមសំរាប់បេសកកម្ម

ការនិយាយនៅក្នុងការប្រជុំបព្វជិតភាព នៅក្នុងសន្និសីទទូទៅមួយ ប្រធាន អើសរ៉ា ថាហ្ហ ប៊ែនសឹន បានមានប្រសាសន៍ថា ព្រះ គម្ពីរមរមន “នឹងក្លាយជាសៀវភៅដ៏សំខាន់បំផុត ដែលអ្នកនឹងអាននៅក្នុងការត្រៀមខ្លួន”

គម្ពីរយ៉ាកុប

តើយើងបានដឹងអ្វីខ្លះអំពី ព្យាការីយ៉ាកុប?

បន្ថែមពីលើការធ្វើជាប្អូនម្នាក់របស់នីហៃ យើងស្គាល់លោកយ៉ាកុប មានដូចខាងក្រោមៈ

- លោកបានកើតជាកូនរបស់សាវ៉ាយ និងលីហៃ នៅកំឡុងពេលប្រាំបីឆ្នាំ ដែលពួកគេធ្វើដំណើរ នៅក្នុងទីរហោដ្ឋាន។
- លោកមានអាយុតិចជាងដប់ឆ្នាំនៅពេលដែល លោកទៅដល់ដែនដីសន្យា។
- លោកត្រូវបាន "តែងតាំង" ឱ្យធ្វើជាសង្ឃ និងជាគ្រូបង្រៀន ដោយបងប្រុសរបស់លោកគឺនីហៃ (សូមមើលនីហៃទី2 6ៈ2, យ៉ាកុប 1ៈ18)។
- លោកបានក្លាយទៅជាអ្នករក្សាបញ្ជីប្រវត្តិបន្ទាប់ពីនីហៃ (សូមមើល យ៉ាកុប 1ៈ1–2)។ នៅពេលនោះ លោកមានអាយុ ប្រហែលជាហាសិបឆ្នាំ។
- នៅក្នុងយុវវ័យរបស់លោក លោកមានកិត្តិយសដែលបានឃើញព្រះអង្គសង្គ្រោះ (សូមមើល នីហៃទី2 2ៈ3–4, 11ៈ2–3)។
- លោកគឺជាឱពុកដ៏សុចរិតម្នាក់ (សូមមើល អេណុស 1ៈ1)។
- លោកគឺជាគ្រូបង្រៀនម្នាក់ក្នុងចំណោម គ្រូបង្រៀនគោលលទ្ធិដ៏អស្ចារ្យ នៅក្នុងព្រះគម្ពីរមរមន (សូមមើល នីហៃទី2 6–10, យ៉ាកុប 1–7)។

គោលលទ្ធិសំខាន់ៗ ត្រូវបានបង្រៀននៅក្នុងគម្ពីរយ៉ាកុប

យ៉ាកុបគឺជាគ្រូបង្រៀនម្នាក់ដ៏អស្ចារ្យ នៅក្នុងចំណោមគ្រូបង្រៀនគោលលទ្ធិ ដែលប្រកបដោយអានុភាពបំផុត នៅក្នុងព្រះគម្ពីរមរមន។ រឿងមួយចំនួនទៀត យើងអាចរៀននៅក្នុងគម្ពីរយ៉ាកុបមានដូចជាៈ

- សារៈសំខាន់នៃការបំពេញតាមមុខងាររបស់យើង (សូមមើល យ៉ាកុប 1)
- គ្រោះថ្នាក់នៃអំនួត, ព្រទ្យសម្បត្តិ និងអមតភាព (សូមមើល យ៉ាកុប 2–3)
- របៀបដើម្បីកើនសេចក្តីជំនឿយ៉ាងខ្លាំងក្លា (សូមមើល យ៉ាកុប 4)
- ការខ្ចាត់ខ្ចាយ និងការប្រមូលផ្តុំនៃអ៊ីស្រាអែល (សូមមើល យ៉ាកុប 5)
- ការប្រឈមមុខជាមួយនឹងការក្បត់សាសនា និងអ្វីដែលអាចកើតឡើងចំពោះអ្នកដែលស្វែងរកទីសំគាល់ (សូមមើល យ៉ាកុប 7)

នៅពេលណាដែលយើងស្រលាញ់អ្នកណាម្នាក់ យើងនឹងខូល់ខ្វាយអំពីសុខុមាលភាពរបស់មនុស្សម្នាក់នោះ។ ព្យាការីយ៉ាកុប បានពិពណិនាអំពីសេចក្តីស្រលាញ់ដែលលោកមានចំពោះប្រជាជន របស់លោកដូចជា "សេចក្តីបារម្ភ។" លោកបានព្យាករ ដោយការយល់ដឹងអំពីដែនការណ៍សង្គ្រោះ និងបានដឹងអំពីផលវិបាកទាំងឡាយ ដែលនឹងមកលើពួកគេ បើពួកគេនៅក្នុងអំពើបាបរបស់ពួកគេទៀត។ ចូរកត់ចំណាំពីរបៀបដែល ព្រះអម្ចាស់ បានប្រទានពរដល់យ៉ាកុប ដោយសារតែ "សេចក្តីជំនឿ និងសេចក្តីព្រួយបារម្ភដ៏ខ្លាំង" (សូមមើល យ៉ាកុប 1ៈ5–6)។

ការយល់ដឹងអំពីព្រះគម្ពីរ

យ៉ាកុបទី 1

ឆ្លាក់ (ខ 1)—ការកាត់ ឬសរសេរនៅលើលោហៈធាតុ

ការសំខាន់ៗ (ខ 4)—ផ្នែកដ៏សំខាន់បំផុត

សេចក្តីព្រួយបារម្ភ (ខ 5)—បារម្ភ, ខូល់ខ្វាយ

ញែក (ខ 14)—បញ្ជាក់

បណ្តោយខ្លួនឱ្យប្រព្រឹត្ត (ខ 15)—បណ្តោយទៅ, ធ្វើឱ្យសេចក្តីប៉ងប្រាថ្នារបស់គេសប្បាយហួសកំណត់

ស្រីស្នំ (ខ 15)—ប្រពន្ធស្របច្បាប់ ដែលមានថានៈទាបនៅក្នុងសង្គម ដែលមានសិទ្ធិទាបជាងប្រពន្ធធម្មតា

យ៉ាកុប 1ៈ1—ផ្ទាំងតូច

យ៉ាកុបបានសរសេរបញ្ជីប្រវត្តិពិសិដ្ឋរបស់លោក នៅលើផ្ទាំងតូចរបស់នីហៃ។ (សំរាប់ជាការពន្យល់មួយអំពី ផ្ទាំងផ្សេងៗដែល បានក្លាយជាព្រះគម្ពីរមរមន សូមមើល "ប្រភពសំខាន់ៗសំរាប់ ព្រះគម្ពីរមរមន" ទំព័រ 00។)

យ៉ាកុប 1ៈ7–8—"នៅក្នុងគ្រា . . . នៅក្នុងទីរហោដ្ឋាន"

បន្ទាប់ពីព្រះអម្ចាស់បានធ្វើអព្ភូតហេតុអស្ចារ្យជាច្រើន ដោយការនាំកូនចៅនៃអ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទ ពួកគេបានខឹង នឹងទ្រង់ដោយការមិនគោរពប្រតិបត្តិរបស់ពួកគេ។ ជាលទ្ធផល នៅជំនាន់នោះ គឺមិនបានអនុញ្ញាតឱ្យចូលទៅក្នុងដែនដីសន្យាទេ។

យ៉ាកុប 1:17–19—“យើងបានជំរើងការងាររបស់យើង”

ប្រធាន ថូម៉ាស អេស. ម៉នសិន ទីប្រឹក្សាទីមួយ នៅក្នុងគណៈប្រធានទីមួយ បានពន្យល់ពីមូលហេតុដែល យើងត្រូវការការជំរើង ការងាររបស់យើង ហើយតើយើងត្រូវជំរើងវាយ៉ាងដូចម្តេចៈ

“ប្រធាន យ៉ូហានេ ថេលើរ ព្រមានយើងថា ‘បើអ្នកមិនជំរើងមុខងាររបស់អ្នក នោះព្រះនឹងឱ្យអ្នកទទួលខុសត្រូវ ចំពោះអ្នកទាំង ឡាយដែលអ្នកត្រូវជួយពួកគេ ដោយការធ្វើនូវករណីកិច្ច របស់អ្នក . . .។’

“តើមនុស្សម្នាក់អាចជំរើងមុខងារមួយបានយ៉ាងដូចម្តេច? ដោយងាយស្រួល គឺការធ្វើការបំរើដែលទាក់ទងនឹងទៅនឹង ការងារនោះ” (នៅក្នុង Conference Report, ខែមេសា ឆ្នាំ1996, 61 ឬ *Ensign* ខែឧសភា ឆ្នាំ1996, 43)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព (ក–ខ)ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សានៅក្នុង យ៉ាកុប 1។

ក ស្វែងរកការឆ្លុះបញ្ចាំងរបស់យ៉ាកុប

នៅក្នុងជំពូកទីមួយនេះ យ៉ាកុបបានផ្តល់ឱ្យយើងនូវការឆ្លុះបញ្ចាំងមួយអំពីអ្វី ដែលលោកនីឆុសរសេរនៅក្នុង យ៉ាកុបទី2–3។ ចូរស្វែងរកចំលើយ ចំពោះសំនួរដូចខាងក្រោមនេះ នៅក្នុងយ៉ាកុបទី1ៈ

1. តើ “ការប្រព្រឹត្តអំពើទុច្ចរិត” (ខ 15) ដែលពួកសាសន៍នីហ្វៃបានចូលរួមជាមួយនោះ គឺជាអ្វី?
2. តើអំពើបាបទាំងនោះ ផ្សេបទៅនឹង ការប្រព្រឹត្តអំពើទុច្ចរិតនៅក្នុងលោកិយសព្វថ្ងៃនេះ មានន័យយ៉ាងដូចម្តេចដែរ?

ខ សរសេរសំបុត្រ

ឧបមាថា អ្នកគឺជាអ្នកជឹកនាំម្នាក់នៅក្នុងក្រុមបព្វជិតភាព ឬថ្នាក់យុវនារីរបស់អ្នក ហើយអ្នកត្រូវបានសុំឱ្យ ផ្តល់ការប្រឹក្សាចំពោះ សមាជិកម្នាក់នៅក្នុងក្រុមរបស់អ្នក ដែលមិនបានបំពេញនូវមុខងាររបស់គាត់ ឬនាងនោះ។ សូមប្រើអ្វី ដែលយ៉ាកុបបានបង្រៀន នៅក្នុងយ៉ាកុប 1:17–2:3 ហើយសរសេរសំបុត្រមួយច្បាប់ទៅកាន់ បុគ្គលម្នាក់នេះ ដើម្បីជួយពួកគេ ឱ្យយល់ អំពីសារៈសំខាន់ នៃការបំពេញករណីកិច្ចរបស់យើង នៅក្នុងមុខងាររបស់យើង (សូមមើលផងដែរ នៅវគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” ក្នុងយ៉ាកុប 1:17–19)។

យ៉ាកុបបានចាប់ផ្តើមកិច្ចការបំរើរបស់លោកដោយ ការបង្រៀន ទៅកាន់ប្រជាជនរបស់លោក ឱ្យផ្សះផ្សារឿងពីអំពើបាបបីយ៉ាងៈ ការស្រលាញ់ទ្រព្យសម្បត្តិ អំនួត និងការគ្មានភក្តីភាព។ នៅពេលដែលពួកសាសន៍នីហ្វៃត្រូវធ្លាក់ទៅក្នុងសេចក្តីទុច្ចរិត គឺតែងតែ ធ្លាក់នៅក្នុងអំពើបាបទាំងបីនេះ។ ដូចដែលអ្នកបានឃើញនៅក្នុងពិភពលោក តើអំពើបាបទាំងនោះ ជារឿយៗមានវត្តមាននៅក្នុង ពេលបច្ចុប្បន្ននេះ ឬទេ? តើអំពើបាបប្រភេទណានៅសព្វថ្ងៃនេះ ដែលធ្វើឱ្យមនុស្ស និងជាតិសាសន៍ទាំងឡាយ ត្រូវធ្លាក់ខ្លួនទៅក្នុងសេចក្តីទុច្ចរិត?

ការយល់ដឹងអំពីព្រះគម្ពីរ

យ៉ាកុប 2

ត្រូវអត់ឱន (ខ 9)—បង្ខំ, បង្ខិតបង្ខំ

ឱ្យទ្ធានដល់ (ខ 9)—ព្រមាន, ជំរុញ

ល្អងលោម (ខ 9)—ការជួយសំរាលទុក្ខ

បាតដៃនៃទិព្វញ្ញាណ (ខ 13)—ព្រះ

ចាត់ទុកជាសុចរិត (ខ 14)—ចាត់ថា អ្នកគ្មានទោស, អត់ឱយទោសឱ្យអ្នក

កើនអំពើទុច្ចរិត (ខ 23)—ការកើនខាងអំពើទុច្ចរិត

សាហាយស្មន់ (ខ 23, 28, 33)—អំពើបាបខាងផ្លូវភេទ

ស្រីស្នំ (ខ 24, 27)—ប្រពន្ធស្របច្បាប់ ដែលមានឋានៈទាបនៅក្នុងសង្គម ដែលមានសិទ្ធិ ទាបជាងប្រពន្ធធម្មតា

យ៉ាកុប 2:13—“សំឡេកបំពាក់របស់ខ្លួនមានតំលៃខ្ពស់”

មានមនុស្សជាច្រើននៅសព្វថ្ងៃនេះ ដែលវិនិច្ឆ័យអំពីតម្លៃរបស់មនុស្សដទៃ តាមរយៈការមើលឃើញពីក្រសា ឬការស្លៀកពាក់ របស់ពួកគេ។ “ឃ្លាដែលថា’ សំឡេកបំពាក់ដ៏មានតំម្លៃ’ កើតឡើងច្រើនជាងដប់ពីរដងនៅក្នុងព្រះគម្ពីរមរមន។ វាស្ទើរតែ បានពិពណ៌នា ជាឱកាសអំពីប្រជាជនមួយដែលរីកចំរើន ដោយព្រះអម្ចាស់ បានភ្លាមទៅជាមនុស្សចូលចិត្តនឹងខ្លួនឯង និងវត្ថុរបស់ ពួកគេដែលបានមក ហើយក្រោយមក ក៏បានចាប់ផ្តើមដំនួសដោយភាពតានតឹងដ៏ធ្ងន់ធ្ងរ តាមរយៈទឹកមុខខាងក្រៅរបស់ពួកគេ ជាជាងភាពស្អាតស្អំ នៃសរសៃខាងក្នុងខ្លួនរបស់ពួកគេ” (McConkie និង Millet, *Doctrinal Commentary on the Book of Mormon,* 2:14)។

យ៉ាកុប 2:23–30—ការរៀបអាពាហ៍ពិពាហ៍ច្រើនដង ដែលគ្មានការអនុញ្ញាត ជាអំពើគួរឱ្យខ្ពើមឆ្អើមចំពោះព្រះ

ដើម្បីយល់ពីសេចក្តីថ្លែងរបស់យ៉ាកុបនៅទីនេះ វាជាជំនួយដើម្បីកំណត់ចំណាំថា មានតែហ្លួងដាវីឌ និងហ្លួងសាឡូម៉ូនតែប៉ុណ្ណោះ ដែលត្រូវបានដាក់ទោស ដោយសារការយកប្រពន្ធ និងស្រីស្នំជាច្រើន។ អ័ព្រាហាំ យ៉ាកុប ម៉ូសេ ក៏មានប្រពន្ធ និងស្រីស្នំច្រើនដងដែរ តែមិនត្រូវបានដាក់ទោសទេ។ នៅក្នុងវិវរណៈថ្មី ព្រះអម្ចាស់បានពន្យល់ថា ហ្លួងដាវីឌ និងសាឡូម៉ូន មានបាប នៅពេល ដែលពួកគេយកប្រពន្ធច្រើន ដែលព្រះអម្ចាស់មិនបានឱ្យពួកគេ (សូមមើល គ និង ស 132:34–39)។ យ៉ាកុប ក៏បានបង្ហាញថា មូលហេតុមួយ ដែលព្រះអម្ចាស់បានអនុញ្ញាត ឱ្យមានការរៀបអាពាហ៍ពិពាហ៍ច្រើនដង នៅពេលនោះ គឺដើម្បីបន្តពូជ ចំពោះទ្រង់ តែបើទ្រង់មិនបានបញ្ជាឱ្យធ្វើដូច្នោះ ការរៀបអាពាហ៍ពិពាហ៍ច្រើនដង គឺត្រូវបានហាមឃាត់ (សូមមើល យ៉ាកុប 2:30)។

យ៉ាកុប 3

ល្អងលោម (ខ 1)—កំសាន្តចិត្ត

ធ្វើទោស (ខ 3)—ដាក់ទោស

ជេរប្រមាថ (ខ 9)—ជេរប្រមាថ, ប្រើភាសាបំពាន

ចូរធ្វើឱ្យសតិនៃព្រលឹងអ្នកចាប់អារម្មណ៍ឡើង (ខ 11)—ដាស់សមត្ថភាព និងវេទនាអារម្មណ៍ឡើង

ការកំផិត និងការអាសអាភាស (ខ 12)—អំពើបាបខាងផ្លូវភេទ និងការត្រេកត្រអាលនឹងកាមគុណ

យ៉ាកុប 3:11—តើការស្លាប់ជា “លើកទីពីរ” គឺជាអ្វី?

កូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ ទីឈរពីមុខព្រះអម្ចាស់ សំរាប់សេចក្តីជំនុំរុះ។ អ្នកទាំងឡាយណាដែល មិនប្រែចិត្ត និងគ្មានភាពសក្តិសម ដើម្បីទទួលកំរិតនៃភាពរុងរឿង អ្នកទាំងឡាយណា ដែលស្លាប់ដោយមានការ ពាក់ព័ន្ធនឹងរឿង ដែលមិនមែនជាសេចក្តីសុចរិត នឹង

ត្រូវកាត់ចេញពីវត្តមានរបស់ព្រះ។ នេះគឺត្រូវបានហៅថា "ការស្លាប់ជាលើកទីពីរ" (សូមមើលអាលម៉ា 12:15–18, ហេលេមិន 14:14–19)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ដូចខាងក្រោម នៅពេលអ្នកសិក្សាយ៉ាកុប 2–3 ។

ក ស្វែងរកគោលការណ៍នៃជំណឹងល្អ

1. ចូរប្រៀបធៀបយ៉ាកុប 2:5, អាលម៉ា 12:3 និងគោលលទ្ធិ និងសេចក្តីសញ្ញា 6:16 ហើយ នៅក្នុងស្រៀវភៅសរសេរ របស់អ្នក ចូរពិពណិនាពីព្រះចេស្តារបស់ព្រះ ដែលគ្មានអ្នកណាម្នាក់មាន លើកលែងតែត្រូវបានប្រទានឱ្យដោយទ្រង់។
2. តើការដឹងថា ព្រះមានព្រះចេស្តានេះ នឹងមានឥទ្ធិពលចំពោះការអធិស្ឋានរបស់បុគ្គលម្នាក់យ៉ាងដូចម្តេចខ្លះ?

ខ ចំណេះចំណានបទគម្ពីរ—យ៉ាកុប 2:18–19

ចូររំលឹកឡើងវិញនូវការប្រឹក្សារបស់យ៉ាកុប ចំពោះប្រជាជនរបស់លោក អំពីគ្រោះថ្នាក់នៃភាពឆ្មើងឆ្មៃ និងព្រឡសម្បត្តិ នៅក្នុងយ៉ាកុប 2:12–21។ ចូរសរសេរកថាកខ័ណ្ឌចំនួន បួន ដែលមានពិពណិនាអំពីរបៀប ដែលគ្រួសាររបស់អ្នក សាលារបស់អ្នក សហគមន៍របស់អ្នក និងប្រទេសរបស់អ្នកនឹងមានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ បើមនុស្សគ្រប់ឲគ្នា ធ្វើតាមការប្រឹក្សារបស់យ៉ាកុប ជាពិសេសនោះគឺនៅក្នុងខ 17–19។

គ សង្ខេបឡើងវិញពីអ្វីដែលយ៉ាកុបបានបង្រៀន

ចូររំលឹកឡើងវិញនូវអ្វីដែលយ៉ាកុបបានបង្រៀន អំពីការរៀបអាពាហ៍ពិពាហ៍ និងបរិសុទ្ធភាព នៅក្នុងយ៉ាកុប 2:23–35, 3:10–12។ ចូរធ្វើការសង្ខេបពីអ្វីដែលយ៉ាកុបបានបង្រៀនដល់យើង អំពីប្រពន្ធ ម្តាយ និងកូនស្រី។

យ៉ាកុប 4

ចូរស្រុះស្រួលនឹងព្រះ តាមរយះដង្វាយធួននៃព្រះគ្រីស្ត

តើអ្នកដឹងអ្វីខ្លះអំពីដង្វាយធួននៃព្រះគ្រីស្ត? តើពលិកម្មរបស់ទ្រង់មានឥទ្ធិពលចំពោះអ្នកយ៉ាងដូចម្តេច? តើអ្នកយល់អំពី ភាពបន្ទាន់ ឬភាពអស់សង្ឃឹម ដែលអ្នកត្រូវការព្រះអង្គសង្គ្រោះឬទេ? យ៉ាកុប បានព្យាករថា ពួកសាសន៍យូដា ដែលព្រះ យេស៊ូវ នឹងរស់នៅក្នុងចំណោមពួកគេនោះ នឹងមិនយល់អំពីទ្រង់ និងបេសសកម្មរបស់ទ្រង់ឡើយ។ ពួកគេនឹងបដិសេធទ្រង់ និងជំណឹងល្អ របស់ទ្រង់ (សូមមើលយ៉ាកុប 4:15) ហើយជាលទ្ធផល ពួកគេនឹងត្រូវវាយ និងខ្ចាត់ព្រាត់ដូចជា កុលសម្ព័ន្ធទាំងដប់ពីរ ដែលមាននៅពីមុនពួកគេនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

យ៉ាកុប 4

ការសូមមើលងាយ (ខ 3)—មិនគោរព, មិនដឹងគុណ

ការបន្ទាបខ្លួន (ខ 7)—ការស្ម័គ្រចិត្តដើម្បីប្រទានពរ

ស្រុះស្រួល (ខ 11)—ចុះកិច្ចព្រមព្រៀងឬព្រមទទួលជាមួយព្រះតាមរយះដង្វាយធួន

ទទួល (ខ 12)—ឈោងចាប់

យ៉ាកុប 4:11—"ផលតំបូងនៃព្រះគ្រីស្ត"

មនុស្សគ្រប់គ្នា ដែលបានរស់នៅលើផែនដី នឹងត្រូវបានរស់ឡើងវិញ តែអ្នកទាំងឡាយណាដែល "បានស្រុះស្រួលនឹង [ព្រះ] តាមរយះ ដង្វាយធួននៃព្រះគ្រីស្ត" គឺជា "ផលតំបូងនៃព្រះគ្រីស្ត។" ពួកគេទាំងនោះ ដែលនឹងបានរស់ឡើង វិញ នៅក្នុងការ រស់ឡើងវិញជាលើកទីមួយ និងទទួលគ្រងមរតកនៅនគរសេឡេស្ទាល។

យ៉ាកុប 4:14–17—ព្រះយេស៊ូវគ្រីស្តគឺជា "មូលដ្ឋានតែមួយដ៏ប្រសើរ"

"សូមមើលហួសទីដៅ" (យ៉ាកុប 4:14) មានន័យថា ពួកសាសន៍យូដា កំពុងតែស្វែងរកអ្វីឲ្យផ្សេងឡៀតក្រៅពី ព្រះយេស៊ូវ គ្រីស្ទឱ្យជួយសង្គ្រោះពួកគេ។ យ៉ាកុបបានព្យាករថា ពួកសាសន៍យូដានឹងបដិសេធព្រះមែស៊ី ដែលជា "ថ្ម ដែលគេអាច សាងមូលដ្ឋាន ដ៏ជាប់ល្អមុត" (ខ 15)។ បន្ទាប់មកលោកក៏បាននិយាយសំដៅទៅលើព្រះគម្ពីរ ដែលនិយាយថា ទ្រង់នៅតែជា "មូលដ្ឋានតែមួយដ៏ប្រសើរ" របស់ពួកគេ (ខ 16 សូមមើលទំនុកដំកើង 118:22, ម៉ាថាយ 21:42)។ បើយើងមិនសង់ នៅលើព្រះយេស៊ូវគ្រីស្ទទេ នោះយើងនឹងមិនទទួលបានការសន្យា នៃសេចក្តីសប្បាយរីករាយដ៏អស់កល្បជានិច្ច ជាមួយទ្រង់ បានឡើយ។ យ៉ាកុប 5–6 បានពន្យល់អំពីរបៀប ដែលពួកសាសន៍យូដា និងវង្សនៃអ៊ីស្រាអែលទាំងអស់ នឹងត្រូវបានសាង នៅលើមូលដ្ឋានគ្រឹះ នៃព្រះយេស៊ូវគ្រីស្ត។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សា យ៉ាកុប 4។

ក រូបមន្តសំរាប់ ជំនឿដ៏រឹងប៉ឹង

យ៉ាកុប បានពិភាក្សា អំពីរបៀបដែលលោកអាចទទួលបានសេចក្តីជំនឿដ៏រឹងប៉ឹង និងអំណាចដើម្បីរំកិលភ្នំ។

1. សូមរំលឹក យ៉ាកុប 4:6–7 សារឡើងវិញ ហើយស្វែងរកពាក្យ *ស្តាប់ស្តាប់មើល វិវរណៈ ការព្យាករណ៍ ទីបន្ទាល់ សេចក្តីសង្ឃឹម* និងព្រះគុណ។
2. សូមប្រើពាក្យទាំងនោះ មកពិភាក្សា អំពីរបៀបដែលយ៉ាកុបបានបង្រៀនថា យើងអាចមានសេចក្តីជំនឿ ដែលប្រកបដោយ អានុភាព។

ខ ហេតុអ្វីចាំបាច់ស្តាប់តាមព្រះ?

យ៉ាកុប បានសរសេរអំពីសេចក្តីអស្ចារ្យរបស់ព្រះ ហើយហេតុអ្វីបានជាយើងគួរតែស្តាប់តាមទ្រង់។ ចូរស្រាវជ្រាវ នៅក្នុងយ៉ាកុប 4:8–13 ដើម្បីរកឆ្លើយសំរាប់សំនួរដូចខាងក្រោមៈ

1. តើយើងអាចរៀនអំពីព្រះបានយ៉ាងដូចម្តេច?
2. តើដោយអំណាចអ្វីដែល ផែនដីត្រូវបានបង្កើត?
3. តើហេតុអ្វី យើងគួរតែស្តាប់តាមព្រះដំបូន្មានរបស់ព្រះ?
4. តើពរជ័យអ្វីខ្លះ ដែលនឹងត្រូវផ្តល់ឱ្យទៅអ្នកទាំងឡាយនា ដែលស្រុះស្រួលនឹងព្រះ តាមរយៈដង្វាយធួន? (សូមមើល ផងដែរ នៅវគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់យ៉ាកុប 4:11។)
5. តើសេចក្តីពិតជាអ្វី? តើនរណាជឿងអំពីសេចក្តីពិតទាំងអស់នោះ?
6. ចូរប្រើប្រាស់ អ្វីដែលអ្នកបានរៀន ពីសំនួរមុនៗ នៅពេលមានអ្នកណាម្នាក់មិនគិតថា ការរៀនអំពីព្រះ អាចជួយដល់ពួកគេ តើអ្នកនិយាយអ្វីទៅកាន់មនុស្សនោះវិញ?

រូបាធិដ្ឋានមួយ គឺជារឿងដែលប្រើជានិមិត្តសញ្ញា ដើម្បីពន្យល់ពីសេចក្តីពិតសំខាន់ៗ។ រូបាធិដ្ឋាននៃដើមអូលីវ នៅក្នុងយ៉ាកុប 5 បង្ហាញយើងអំពីគោលបំណងរបស់ព្រះអម្ចាស់នៅក្នុងការខ្ចាត់ខ្ចាយ និងការប្រមូលផ្តុំ នៃវង្សអ៊ីស្រាអែល។ នៅក្នុងជំពូកទី 6 ព្យាការីយ៉ាកុប បានសង្ខេបចំនុចសំខាន់ៗនៃរូបាធិដ្ឋាន។ នៅចុងបញ្ចប់នៃយ៉ាកុប 4 យ៉ាកុបបានសួរថា តើពួកសាសន៍យូដាអាចសាងនៅលើ “មូលដ្ឋានពិត” នៃព្រះយេស៊ូវគ្រីស្ទ បន្ទាប់ពីពួកគេបានបដិសេធទ្រង់ដោយរបៀបណា (សូមមើល យ៉ាកុប 4:17)។ សូមរកសូមមើលចំលើយដើម្បីឆ្លើយសំនួរនោះ នៅក្នុងយ៉ាកុប 5–6។

ការយល់ដឹងអំពីព្រះគម្ពីរ

យ៉ាកុប 5

បានដុះឡើងហើយចាស់ទៅ (ខ 3)—ដុះឡើងហើយចាស់

វាតទី (ខ 9, 30)—បន្ទុក

ទីទំនាបបំផុត (ខ 13–14, 19, 38)—ទាបបំផុត

ត្រង់ទីណា (ខ 13)—ត្រប់ទីកន្លែង

ឯកន្លែង (ខ 20)—កន្លែង

ត្រង់ណោះ (ខ 21, 23–25)—ទីនេះ

ស្ងិត (ខ 40, 43, 45)—ស្ងិត ឬ រួញ

កាប់រំលំ, កាប់រំលំ (ខ 46–47, 49)—កាត់

បានដាក់ដី, ដាក់ដី (ខ 47, 64)—បានដាក់ដី, ដាក់ដី

យ៉ាកុប 5:1—តើនរណាជាព្យាការី សិណូស?

សិណូស ជាមួយនឹង សិណុក និង នីអ៊ុម គឺជាព្យាការី នៅក្នុងដំនាន់ព្រះគម្ពីរសញ្ញាចាស់ ដែលការសរសេរទាំងឡាយ មិនត្រូវបានរក ឃើញនៅក្នុងព្រះគម្ពីរចប់ទេ តែបានរកឃើញនៅក្នុងផ្នាំឯលឆិន (សូមមើល នីហ្វៃទី1 19:10 វគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់ នីហ្វៃទី1 19:10 ទំព័រ 30)។

យ៉ាកុប 5—ការយល់ដឹងអំពីរូបាធិដ្ឋាន របស់សិណូស

ត្រប់វត្ថុនៅក្នុងរូបាធិដ្ឋាន គឺមិនមែនជាអត្ថន័យជាសំខាន់ ដូចជានិមិត្តសញ្ញា សំរាប់អ្វីផ្សេងទៀតនោះទេ តែនិមិត្តសញ្ញាចំបងពិត ត្រូវតែដឹង ដើម្បីអាចយល់អំពីរូបាធិដ្ឋាន។ និមិត្តសញ្ញាដែលមានដូចខាងក្រោមនេះ គឺមានសារៈសំខាន់ ដើម្បីយល់អំពីរូបាធិដ្ឋាននៃដើមអូលីវៈ

និមិត្តសញ្ញា	តើវាអាចតំណាងឱ្យអ្វី
ចំការ	ពិភពលោក
ចៅហ្វាយនៃចំការ ម្ចាស់នៃចំការ	ព្រះ
អ្នកបំរើ	ព្យាការីរបស់ព្រះអម្ចាស់
ដើមអូលីវស្រុក	វង្សនៃអ៊ីស្រាអែល, រាស្ត្រនៃ សេចក្តីសញ្ញារបស់ព្រះអម្ចាស់
ដើមអូលីវព្រៃ	ពួកសាសន៍ដទៃ ឬមិនមែនជាពួកសាសន៍ អ៊ីស្រាអែល (ក្រោយមកនៅក្នុងរូបាធិដ្ឋាន មែក ព្រៃ គឺជាពួកអ៊ីស្រាអែល ដែលក្បត់សាសនា)
មែក	ក្រុមប្រជាជន
ឫសនៃដើមអូលីវស្រុក	សេចក្តីសញ្ញាដែលព្រះអម្ចាស់ បានធ្វើជាមួយ នឹងកូនចៅរបស់ទ្រង់ គឺជាប្រភពនៃកម្លាំងជំ មាំមួន និងជាជីវិតចំពោះភាពស្មោះត្រង់
ផ្លែ	ជីវិត ឬកិច្ចការរបស់មនុស្ស
ជីក, ជ្រួយគល់, ដាក់ដី	ព្រះអម្ចាស់ធ្វើកិច្ចការ សំរាប់កូនចៅរបស់ទ្រង់ ដើម្បីជួយពួកគេឱ្យគោរពប្រតិបត្តិ និងគោរពញាដោយផ្លែ
ការផ្សាំមែកទាំងឡាយ	ការខ្ចាត់ខ្ចាយនៃក្រុមប្រជាជន ទូទាំង ពិភពលោក ឬការដាក់ពួកគេវិញនៅក្នុងកន្លែង ដើម ដែលពួកគេបានចេញមក
ការបំពោជាប់	ការចូលរួមនៃប្រជាជនមួយក្រុម ទៅមួយក្រុម ទៀត ដោយសំដៅទៅការខ្ចាត់ខ្ចាយ នៃវង្ស អ៊ីស្រាអែល វាក៏មានន័យថា “ទីងបានជឿងអំពី ព្រះមែស៊ីដ៏ពិត” (សូមមើល នីហ្វៃទី1 10:14)
មែកដែលពុក	ប្រជាជនដែតស្លាប់ខាងវិញ្ញាណ មកពីអំពើបាប និងការក្បត់សាសនា
បោះមែកចូលទៅក្នុងភ្លើង	សេចក្តីជំនុំជំរះរបស់ព្រះ



ការបំពុលមែក

យ៉ាកុប 5:8–10—តើវាមានន័យយ៉ាងដូចម្តេច ដើម្បី “បំពុល” មែក?

ដើម្បីបំពុលមែកឱ្យមានការលូតលាស់ ដើម ឬ រុក្ខជាតិ ដែលនៅរស់គឺត្រូវកាត់មែកចេញមក ហើយផ្សាំជាមួយនឹង កន្លែងផ្សេង ទៀត (សូមមើលតាមរូបភាព)។ មែកនៅក្នុងរូបាធិដ្ឋាននេះ គឺតំណាងក្រុមប្រជាជន ដែលព្រះអម្ចាស់យកចេញពីកន្លែងមួយ ទៅដាំនៅកន្លែងមួយទៀត។ ការយល់នៅក្នុងព្រះគម្ពីរ *ការបំពុល* មានន័យថា “បានដឹងអំពីព្រះ មែនទីពិត” (នីហ្វៃទី1 10:14)។

យ៉ាកុប 5:8, 13–14, 19–25—មែក “ដ៏ទន់ខ្ចី” នៃវង្សអ៊ីស្រាអែល

“មែកដ៏ទន់ខ្ចី” ហាក់ដូចជា ជាប្រជាជនទាំងឡាយណាដែល ឆ្លើយតបចំពោះ “ការជ្រួយគល់ និងដាក់ដី” ដោយព្រះ និងព្យាការី របស់ទ្រង់។ មែកទាំងនោះគឺជាមនុស្សងាយបង្រៀនជាង មែកចាស់ ឬក្រុមនៃពួកសាសន៍អ៊ីស្រាអែល ដែលត្រូវតែធ្វើការផ្លាស់ប្តូរ និងកំទេចចោល។

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានបង្រៀនថា “នៅក្នុងរឿងប្រៀបប្រដូចនោះ ដើមអូលីវ គឺជាវង្សនៃអ៊ីស្រាអែល . . .។ នៅក្នុងដ៏កំណើត ដើមអូលីវចាប់ផ្តើមងាប់។ ដូច្នេះព្រះអម្ចាស់បានយកមែកផ្សេងៗ ដូចជាពួកសាសន៍នីហ្វៃ, កុលសម្ព័ន្ធ ដែលបានបាត់ និងដូចជាអ្នក ផ្សេងៗទៀត ដែលព្រះអម្ចាស់បានដឹកនាំពួកគេចេញ ដែលយើងមិនបានដឹងអ្វីទាំងអស់អំពី ពួកគេ ទៅផ្នែកផ្សេងទៀតនៃផែនដី។ ទ្រង់បានដាំពួកគេនៅត្រប់ទឹកន្លែង នៅក្នុងចំការរបស់ទ្រង់ ដែលជាពិភពលោក នេះ” (*Answers to Gospel questions,* បានប្រមូលផ្តុំដោយ Josph Fielding Smith Jr., 5 វ៉ុល [1957–66], 4:204)។

រូបាធិដ្ឋានរបស់ស៊ីណូស បានជួយយើងឱ្យយល់ថា ការខ្ចាត់ខ្ចាយនៃមែកនៃអ៊ីស្រាអែល នៅពាសពេញពិភពលោក គឺជាការដ៏ឃឺមួយទាំងចំពោះពួកសាសន៍អ៊ីស្រាអែល និងសំរាប់កូនចៅផ្សេងៗទៀត របស់ព្រះវរបិតាសួគ៌ ផងដែរ។ អែលឌើរ ប្រ៊ូស អរ. ម៉ិកខនឃី ដែលជាសមាជិកនៃក្រុម នៃសាវ័កទាំងដប់ពីរនាក់ បានពន្យល់ថា “ដាទូទៅ ព្រះអម្ចាស់បញ្ជូនពួជរបស់យ៉ាកុបមកលើផែនដី [អ៊ីស្រាអែល] វិញ្ញាណទាំងនោះ កាលនៅពីអតីតដាត៏ បានរីកចំរើនការប៉ុនប្រសប់ពិសេសមួយ សំរាប់ជីវភាពខាងវិញ្ញាណ និងសំរាប់ជីវិតពិសេសក្តីពិត។ អ្នកទាំងឡាយណា ដែលកើតនៅ ក្នុងពួជយ៉ាកុបនេះ មានឈាមរបស់សាសន៍អ៊ីស្រាអែល នៅក្នុងសរសៃឈាម របស់ពួកគេ ហើយរកឃើញថា ពួកគេងាយទទួលយក ដំណឹងល្អ ដែលនិយាយថា មាន *ឈាមនៃការជ្រើ*” (*Mormon Doctrine,* 81)។

នៅពេលដែលការខ្ចាត់ខ្ចាយ នៃអ៊ីស្រាអែលបានលាយឡំជាមួយសាសន៍ដទៃ ឈាមរបស់អ៊ីស្រាអែល គឺត្រូវបាន រាលដាលកាន់តែច្រើនឡើង។ អែលឌើរ ដេម អ៊ុ. ហ្វោស ដែលជាសមាជិកនៃក្រុមសាវ័កទាំងដប់ពីរនាក់ ក្រោយមកបានលើកឡើងថា “ការខ្ចាត់ខ្ចាយនៃវង្សអ៊ីស្រាអែល ពាសពេញពិភពលោក បានជួយសាចឈាម នៃពួកអ្នកជ្រើ ដើម្បីឱ្យជាតិសាសន៍ជាច្រើនទៀត អាចទទួលទានផែនការណ៍ នៃដំណឹងល្អឥឡូវ” (នៅក្នុង Conference Report, ខែតុលា ឆ្នាំ1982, 127 ឬ *Ensign,* ខែវិច្ឆិកា ឆ្នាំ1982, 87–88)។

យ៉ាកុប 5:32–46—តើពេលណាទើបដើមទាំងអស់ត្រូវពុករលួយ?

ផ្នែកនៃរូបាធិដ្ឋាន នៅពេល ដែលដើមទាំងអស់មានផ្លែមិនល្អ ហាក់ដូចជាតំណាងឱ្យពេលនៃការក្បត់សាសនា មុនពេលការសាងឡើងវិញនៃដំណឹងល្អ។ នៅពេលព្រះអម្ចាស់មានបន្ទូលទៅកាន់ លោកយ៉ូសែប ស្ម៊ីធនៅក្នុងទស្សនៈមិត្តជំបូង ទ្រង់បានត្រាប់យ៉ូ សែបថា លោកមិនត្រូវចូលរួមនៅក្នុងព្រះវិហារមួយណា នៅជំនាន់នោះទេ ពីព្រោះព្រះវិហារទាំងអស់នោះ “មិនពិត” (ប្រវត្តិ—របស់ យ៉ូសែប ស្ម៊ីធ 1:19)។

យ៉ាកុប 6

មនុស្សរឹងរូស (ខ 4)—ក្បាលរឹង

និយាយបោក (ខ 4)—និយាយប្រឆាំង, ផ្តួយ

សូមអង្វរ (ខ 5)—អង្វរ, សុំ

ដាច់ទៅនឹង, ដាច់នឹង (ខ 5)—ចូលរួមជាមួយ, កាន់ឱ្យដាច់ទៅនឹង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សាយ៉ាកុប 5–6។

ក តើរូបាធិដ្ឋានរបស់ស៊ីណូស បង្រៀនយើងអ្វី អំពីវង្សនៃអ៊ីស្រាអែល?

បន្ទាប់ពីអ្នកបានសិក្សានៅ អំពីរូបាធិដ្ឋានដើមអូលីវ នៅក្នុងយ៉ាកុប 5 ចូរសរសេរនៅក្នុងស្បៃវរសៅសរសេររបស់អ្នក ទោះបីជាសេចក្តី ផ្លែឯខាងក្រោមត្រូវ ឬខុស ហើយធ្វើបញ្ជីនៃទាំងឡាយ ដែលអ្នករកឃើញចំលើយ (សំរាប់ជំនួយ បន្ថែម សូមប្រើតារាងនៅទំព័រ 67 នៅក្នុងស្បៃវរសៅនេះ)។

1. ដើមអូលីវស្រុក តំណាងឱ្យវង្សនៃអ៊ីស្រាអែល ហើយមែកដែលពុក តំណាងឱ្យមនុស្សទុច្ចរិត។
2. ម្ចាស់ចំការជ្រួយគល់ និងថែរក្សាដើម ដើម្បីឱ្យវាមានផ្លែល្អ។
3. មែកអូលីវទន់ខ្ចីដ៏ពិត បានប្រឆាំង ហើយត្រូវបានផ្សាំ ឬ ខ្ចាត់ខ្ចាយ ដោយការដាក់ទារុណកម្ម។
4. មែកអូលីវទន់ដ៏ខ្ចី បានត្រូវដាំនៅក្នុងដីល្អ ដែលបានលូតលាស់ចេញផ្លែល្អ ហើយផ្លែដែលអាក្រក់អាចតំណាងឱ្យពួក សាសន៍នីហ្វៃ និងពួកសាសន៍លេមិន។
5. មានត្រាមួយ នៅពេលដើមទាំងអស់មានសុទ្ធតែផ្លែអាក្រក់ទាំងអស់។ បន្ទាប់មកព្រះអម្ចាស់ បន្តដើម្បីសាងដំណឹងល្អ ឡើងវិញតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ។
6. មែកនៃដើមអូលីវដែល បានខ្ចាត់ខ្ចាយ ក្រោយមកត្រូវបានចំពៅជាមួយនឹង ដើមអូលីវដើមវិញ។
7. មិនដែលមានពេលណាមួយ ដែលដើមអូលីវ មានសុទ្ធតែផ្លែល្អទាំងអស់នោះទេ។

ខ តើរូបាធិដ្ឋាននេះអាចអនុវត្តចំពោះខ្ញុំបានយ៉ាងដូចម្តេច

នៅក្នុងស្បៃវរសៅសរសេររបស់អ្នក សូមឆ្លើយនូវសំនួរណាមួយនៃ សំនួរទាំងបី ដូចខាងក្រោម:

1. តើនៅក្នុងផ្នែកអ្វីនៃរូបាធិដ្ឋាន ដែលអ្នកគិតថា យើងកំពុងរស់នៅសព្វថ្ងៃនេះ? ហេតុអ្វី?
2. អ្នកគិតថា ហេតុអ្វី យ៉ាកុប ស្ម័គ្រចិត្តដើម្បីសរសេរនូវរូបាធិដ្ឋានវែងអន្លាយនេះ នៅលើផ្ទាំងមាស?
3. តើការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល មានអត្ថន័យយ៉ាងណាចំពោះអ្នក?
4. តើអ្នករៀនអ្វីខ្លះមកពី រូបាធិដ្ឋាននេះ អំពីការខ្វល់ខ្វាយរបស់ព្រះវរបិតាសួគ៌ ចំពោះកូនចៅរបស់ទ្រង់ទាំងអស់?
5. តើមានរឿងអ្វីខ្លះដែលព្រះអម្ចាស់ បានធ្វើនៅក្នុងជីវិតរបស់អ្នក ដើម្បី “ជ្រួយគល់” ហើយ “ដាក់ដី” អ្នក?
6. យ៉ាកុប 6 គឺជាការសង្ខេបនៃ យ៉ាកុប 5។ តើខគម្ពីរនៅក្នុងយ៉ាកុប 6:5–13 ដែលអ្នកគិតថា ជាការសង្ខេបដ៏ប្រសើរបំផុត អំពីរូបាធិដ្ឋាន នៃដើមអូលីវមានអត្ថន័យចំពោះអ្នក? ពន្យល់ពីមូលហេតុដែលអ្នករើសរើសខទាំងនោះ?

រូបឧបាធិដ្ឋាននៃដើមអូលីវ (យ៉ាកុប 5)

ការមកជួបជាលើកទីមួយ

ពីមុនពេលនៃព្រះគ្រិស្ត (ខ 13–14)



ការមកជួបជាលើកទីមួយៈ ព្រះបានឃើញការក្បត់សាសនា របស់សាសន៍អ៊ីស្រាអែលតាំងពីបុរាណ។ ទ្រង់បានចាត់ពួកព្យាការី ឱ្យមកបង្រៀនពីការប្រែចិត្ត តែមានមនុស្សតែពីរបីនាក់ ដែលបានស្តាប់។ ទ្រង់បានទុកឱ្យពួកទុច្ចរិតត្រូវបំផ្លាញ ហើយនាំពួកសាសន៍ដទៃមក។ មែកទុច្ចរិតពីរបីនៃអ៊ីស្រាអែល បានត្រូវខ្ចាត់ខ្ចាយតាមពេញពិភពលោក។

ការមកជួបជាលើកទីពីរ

ពេលនៃព្រះគ្រិស្ត (ខ 15–28)

ការមកជួបជាលើកទីពីរៈ ព្រះបានឃើញថា អ៊ីស្រាអែល (ដែលជាឬសដើមចាស់) គឺត្រូវបានថែរក្សា និងផ្តល់ផ្លែល្អ។ មែកខ្ចាត់ខ្ចាយនៃអ៊ីស្រាអែល កំពុងផ្តល់ផ្លែល្អដែរ លើកលែងតែពួកសាសន៍ដទៃ និងពួកសាសន៍លេមិន ដែលមានផ្លែផ្អែមខ្លះ ល្អ ហើយខ្លះអាក្រក់។

ការមកជួបជាលើកទីប

ការក្បត់សាសនាជំពូក (ខ 29–49)

ការមកជួបជាលើកទីបៈ ព្រះបានរកឃើញថា ក្រិស្តសាសនា (ឬសនៃដើមចាស់បង្កើតឡើងទាំងសាសន៍អ៊ីស្រាអែល និងសាសន៍ដទៃ) ត្រូវបានប្រែជាពុករលួយ ប៉ុន្តែឬសនៅតែល្អ។ ដើមធម្មជាតិ ដែលត្រូវខ្ចាត់ខ្ចាយ កំពុងពុករលួយផងដែរ។

ការមកជួបជាលើកទីប្លន

ការប្រមូលផ្តុំនៃអ៊ីស្រាអែល ហើយដំណឹងល្អទីនឹងមានទូទាំងពិភពលោក (ខ 50–76)



សិហស្សវត្សរ៍

(ខ 76–77)

ការមកជួបជាលើកទីប្លនៈ ព្រះហើយនឹងអ្នកបំរើរបស់ទ្រង់ សាងដំណឹងល្អទៅក្នុងបរិសុទ្ធភាពឡើងវិញ។ ពួកគេចាប់ផ្តើមប្រមូលផ្តុំ អ៊ីស្រាអែលដែលខ្ចាត់ខ្ចាយ ហើយនាំយកដំណឹងល្អទៅទូទាំងពិភពលោក។ ទៅពេលដែលសេចក្តីសុចរិត កើនឡើង ពួកទុច្ចរិតត្រូវ បានបំផ្លាញ ហើយគ្មានពួកទុច្ចរិតនៅសេសសល់ទេ (ការយាងមកដាលើកទីពីរនៃព្រះគ្រិស្ត)។ សេចក្តីសុចរិតនៅសំអាប់ពេលដ៏យូរ (សហស្សវត្សរ៍) ។ ទៅពេលដែលអារក្សចូលមកនៅក្នុងពិភពលោកម្តងទៀត ព្រះនឹងបំបែក ពួកសុចរិតចេញពីពួកទុច្ចរិត ហើយ សំអាតផែនដីដោយភ្លើង។

យ៉ាកុប 7

ចំណេះដឹងរបស់មនុស្ស ទល់នឹងអំណាចរបស់ព្រះ

តើអ្នកធ្លាប់ពិភាក្សាដំណឹងល្អ ជាមួយនឹងអ្នកដែលមានចំណេះដឹងខ្ពស់ និងមនុស្សដែលពូកែដោហារ ដែលមិនត្រឹមតែ មិនជឿទេ តែបានចាប់កំហុសនៃសេចក្តីជំនឿរបស់អ្នកឡែតនោះ? វាអាចជាគំរាមគំហែង និងការភ័យខ្លាចបន្តិចបន្តួច ដងដែរ។ នៅក្នុង យ៉ាកុប 7 យ៉ាកុប ប្រាប់នូវបទពិសោធន៍ដូច្នេះ។ ចូរធ្វើការកំណត់សំគាល់ថា ហេតុអ្វីយ៉ាកុប “មិនបាត់បង់” សេចក្តីជំនឿរបស់លោក (យ៉ាកុប 7:5)។

ការយល់ដឹងអំពីព្រះគម្ពីរ

យ៉ាកុប 7

បង្ខូច (ខ 7)—ប្លែ, ពុករលួយ

សេចក្តីប្រមាថ (ខ 7)—និយាយអាក្រក់, មិនគោរព ឬគ្មានគារវភាពទៅលើវត្ថុពិសិដ្ឋ

សេចក្តីទុក្ខលំបាក (ខ 26)—រងទុក្ខលំបាក

ជំរាបលា (ខ 27)—លាហើយ

យ៉ាកុប 7:13–20—គ្រោះថ្នាក់នៃអ្នកដែល ស្វែងរកទីសំគាល់

សេរេម បានន័យថា “ចូរបង្ហាញទីសំគាល់មកដល់ខ្ញុំ” (យ៉ាកុប 7:13) តែទីសំគាល់មិនមែនជាអ្វី ពិតប្រាកដដែលគាត់ ចង់បាន ទេ។ សាតាំងបានបំភាន់សេរេមថា វាមិនអាចទៅរួចបានទេ ដើម្បីដឹងអ្វីមួយ ដែលសូមមើលមិនឃើញ។ យ៉ាកុបបានដឹងថា ទោះបីជាមិនអាច សូមមើលឃើញព្រះវិញ្ញាណបរិសុទ្ធក៏ដោយ តែអំណាចរបស់ទ្រង់មិនអាចបដិសេធ បាន។ អ្នកជឿលើ ព្រះយេស៊ូវគ្រីស្ទ គឺត្រូវបានសន្យាជាទីសំគាល់ មិនមែនដើម្បីបង្កើតជំនឿ ប៉ុន្តែនោះគឺដោយសារ ជំនឿរបស់គេ។ អ្នកដែលស្វែងរក ទីសំគាល់ ដោយគ្មានជំនឿ និងត្រូវទទួលទារុណកម្ម ដោយភស្តុតាងដែលគេស្វែងរក (សូមមើល គ និង ស 63:9–11)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សានៅក្នុង យ៉ាកុប 7។

ក ពិនិត្យសូមមើលសត្រូវរបស់យ៉ាកុប

ដើម្បីឱ្យកាន់តែយល់ពីអ្វីដែល សេរេមបានបង្រៀន ហើយហេតុអ្វីគាត់ អាចបោកបន្លំមនុស្សជាច្រើន ចូរសរសេរប្រយោគ 1–9 ចូលក្នុងស្បៃវែតៅសរសេរបស់អ្នក ហើយបំពេញលើផ្ទៃកដែលខ្វះជាមួយនឹងពតិមាន ចេញពីយ៉ាកុប 7:1–9។ រួចហើយឆ្លើយ សំនួរទី 10 និង 11។

1. សេរេម បានបង្រៀនថា វាគួរតែគ្មាន _____។
2. គាត់បានធ្វើការ _____។
3. គាត់ជា _____។
4. គាត់មានភាពឥតខ្ចោះ _____។
5. គាត់ប្រើប្រាច់ និងអំណាចនៃ _____។
6. ប្រភពនៃអំណាចរបស់គាត់ គឺជា _____។
7. គាត់បានបង្រៀនថា ប្រជាជនមិនគួរចាំសូមមើល ការយាងមករបស់ព្រះគ្រីស្ទទេ តែគួរតែគោរពជំនួសឱ្យច្បាប _____។
8. គាត់បានន័យាយថា យ៉ាកុបមិនអាចដឹងអំពីការយាងមក នៃព្រះគ្រីស្ទ ដោយសារយ៉ាកុបមិនអាចប្រាប់ពី _____។
9. សេរេម បានន័យាយថា គ្មានព្រះគ្រីស្ទទេ វាមិនដែលមាន ហើយក៏មិន _____។
10. សេចក្តីថ្លែងទាំងពីរចុងក្រោយរបស់សេរេម ផ្ទុយនឹងគ្នា។ ចូរពន្យល់ថាហេតុអ្វី សេចក្តីថ្លែងទី 8 និង ទី 9 ទាំងពីរមិនពិត។
11. តើអ្វីៗទាំងនោះ អាចប្រាប់អ្នកពីអារក្សធ្វើការចំពោះយើង យ៉ាងដូចម្តេចខ្លះ?

ខ ពិនិត្យសូមមើលកំលាំងរបស់យ៉ាកុប

សូមរំលឹក យ៉ាកុប 7:5, 8, 10–12, 21–22 សារឡើងវិញ ហើយសរសេរកថាខ័ណ្ឌមួយ នៅក្នុងស្បៃវែតៅសរសេរ របស់អ្នក យ៉ាងហោចណាស់ មូលហេតុបី ថាហេតុអ្វីយ៉ាកុប “មិនបាត់បង់សេចក្តីជំនឿ” ដោយចំណេះដឹង និងអំណាចនៃការន័យាយរបស់ សេរេម។

គម្ពីរអេណុស

តើអ្វីដែលអ្នកគួរតែដឹង មុនពេលអានទៅក្នុងគម្ពីរអេណុស

អេណុសគឺជាកូនប្រុសរបស់យ៉ាកុប (សូមមើល យ៉ាកុប 7:27) ហេតុដូច្នេះហើយ អេណុស គឺជាចៅប្រុសរបស់លីហៃ។ អេណុសបានចិទបញ្ជីប្រវត្តិរបស់លោក ដោយបង្ហាញថា គាត់កាន់តែចាស់ហើយ ដែលតាំងពីលីហៃបានចាកចេញ ពីយេរូសាឡិម 179ឆ្នាំ បានកន្លងទៅហើយ។ នោះនឹងជំនួសកាលចរិឆ្លួច នៃការសរសេររបស់លោកប្រហែលជាឆ្នាំ 420 ម.គ។

មានមនុស្សពីរបីនាក់ដូចជា ប៉ុល, អេណុស និង អាលម៉ាជាកូន បានដឹងអំពីទោសកំហុសដ៏ធ្ងន់ធ្ងរ និងធម្មជាតិនៃភាពរុងរឿង នៃការសន្យារបស់ព្រះចំពោះពួកសុចរិត វាហាក់ដូចជាមកនៅពេលតែមួយ។ សូមធ្វើការផ្លាស់ប្តូរសំរាប់មាន (ការផ្លាស់ សាសនា)ឱ្យប្រសើរជាង ដែលប្រហែលមិនបានភ្លាមៗទេ។ យោងទៅតាមដំបូន្មាននៃការប្រែចិត្ត ប្រធាន អ៊ែសរ៉ា ថាប់ប៊ែនសឺន បានមានប្រសាសន៍ថា:

"យើងត្រូវតែប្រយ័ត្នប្រយែង នៅពេលយើង ព្យាយាមប្រែក្លាយខ្សែកាន់តែដូចជាព្រះខ្លាំងឡើង ដែលយើងនឹងមិនប្រែ ទៅជាបាក់ ទឹកចិត្ត និងបាត់បង់សេចក្តីសង្ឃឹម។ ការប្រែក្លាយឱ្យដូចជាព្រះយេស៊ូវគ្រីស្ទ គឺជាឆាកជីវិតដែលប្រកបដោយ ការខិតខំយ៉ាងខ្លាំង ហើយទាក់ទងទៅនឹងការលូតលាស់ និងផ្លាស់ប្តូរដោយយ៉ឺតៗ ជាញឹកញាប់ណាស់ ដែលស្ទើរតែសូមមើលមិនឃើញ។ នៅក្នុង ព្រះគម្ពីរបានចុះបញ្ជីអំពីជំណើរឈ្វើងដ៏ អស្ចារ្យរបស់មនុស្សដែលមានជីវិតផ្លាស់ប្តូរដែលគួរឱ្យរំភើបខ្លាំង ភ្លាមៗ ដូចដែលវាមាន ចំពោះ អាលម៉ាជាកូន ប៉ុល នៅលើផ្លូវទៅកាន់ ដាម៉ាស អេណុសអធិស្ឋានរហូតដល់ឃប់, ស្តេចឡាម៉ូណៃ។ គំរូដ៏គួរឱ្យក្តាក់ដូច្នេះ នៃព្រះចេស្តារដើម្បីផ្លាស់ប្តូរ ទោះបីជា ប្រឡាក់នៅក្នុងអំពើបាប ក៏មានឱ្យទូវការទុកចិត្តថា ជង្វាយធួនអាចមានមកដល់ សូម្បីតែ អស់អ្នកទាំងឡាយណា ដែលមានការអស់សង្ឃឹមដ៏ខ្លាំងបំផុតនោះក៏ដោយ។

តែយើងត្រូវតែប្រយ័ត្នប្រយែង នៅពេលយើងពិភាក្សាអំពីគំរូដ៏អស្ចារ្យទាំងនេះ។ ថ្វីបើគំរូទាំងនោះជាការពិត ហើយប្រកបដោយ អំណាចក៏ដោយ ក៏គំរូទាំងនេះជាករណីលើកលែងគ្រើនជាងច្បាប់។ ចំពោះប៉ុលរាល់គ្នា ចំពោះអេណុសរាល់គ្នា និងចំពោះ ស្តេចឡាម៉ូណៃរាល់គ្នាមានប្រជាជនរាប់រយនឹងរាប់ពាន់នាក់ ដែលស្វែងរក ជំណើរការនៃការប្រែចិត្ត ដែលកាន់តែល្អិតល្អន់ និងស្តុចស្តើងជាង។ ពីមួយថ្ងៃទៅ មួយថ្ងៃ ពួកគេកាន់តែខិតជិតព្រះអម្ចាស់ ដោយការដឹងខ្លួនបន្តិចម្តងៗ ពួកគេកំពុងតែ សាងជីវិតមួយឱ្យដូចជាព្រះ" ("A Mighty Change of Heart Ensign", *ខែតុលា ឆ្នាំ1989, 5)។*

នៅពេលដែលអ្នកសិក្សាគម្ពីរអេណុស ចូរកត់ចំណាំអំពីឬសនៃបទពិសោធន៍របស់លោក—តើអ្វីដែលបានជីកនាំឱ្យអេណុសលុត ជង្គង់របស់លោកចុះអំពាវនាវទៅព្រះអម្ចាស់ "ក្នុងការអធិស្ឋាន និងការទូលអង្វរដ៏ខ្លាំងសំរាប់ព្រលឹងខ្ញុំផ្ទាល់" (អេណុស1:4)។ ចូរធ្វើការកត់ចំណាំផងដែរពីផលផ្លែដែល បានមក—ទាំងខ្លួនលោក និងអ្នកដទៃ—នៅពេលដែលលោកស្វែងរក និងបានទូវការអភ័យបាប។

ការយល់ដឹងអំពីព្រះគម្ពីរ

អេណុស 1

ជំបូន្មាន (ខ 1)—ការបង្រៀន និងការហ្វឹកហាត់, ដូចអ្វីដែលឪពុកម្តាយជាទីស្រឡាញ់ផ្តល់ឱ្យទៅកូនចៅរបស់គេ។

សេចក្តីដាស់តឿន (ខ 1)—ការព្រមានឱ្យប្រឆាំងនឹងអំពើបាបដោយរាបសា ឬការខុសឆ្គង, ប្រឹក្សា។

កាចសាហាវ (ខ 20)—កាចសាហាវ, ឃោរឃៅ

ដាវ (ខ 20)—ដាវកោង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សាអេណុស 1។

ក តើជាការអធិស្ឋានប្រភេទណា?

1. ចូរស្រាវជ្រាវនៅក្នុង អេណុស 1:1–10 ហើយធ្វើបញ្ជីនៅក្នុងស្បៀវភៅសរសេរ របស់អ្នក អំពីពាក្យដែលបាន ពិពណ៌នា ពីអ្វីដែល អេណុស កំពុងគិតមានអារម្មណ៍ និងរបៀបដែលលោកអធិស្ឋាន។ តើ ការអធិស្ឋានរបស់អេណុស ខុសពី ការអធិស្ឋាន ច្រើនទៀតយ៉ាងដូចម្តេច?
2. ចូរពន្យល់ពីរបៀបដែលយើងអាច ធ្វើ ឱ្យការអធិស្ឋានផ្ទាល់ខ្លួនរបស់យើង កាន់តែមានប្រសិទ្ធិភាព ដោយធ្វើតាមគំរូ របស់ អេណុស។

ខ តើលទ្ធផល នៃការទទួលការអភ័យទោសខាង សាច់ឈាម គឺជាអ្វី?



1. ការខ្វល់ខ្វាយតំបូងរបស់អេណុស គឺអំពីខាង សាច់ឈាម និងភាពសមរម្យសំរាប់សេចក្តីសង្រ្គោះ ផ្ទាល់របស់លោក (សូមមើល អេណុស 1:1–8)។ បន្ទាប់ពីលោក ទទួលការអភ័យចំពោះ អំពើបាប របស់លោក នោះការខ្វល់ខ្វាយរបស់លោកបានធូរ ស្រាល។

   សូមគូសតាមឌីយ៉ាក្រាម ចូលនៅក្នុងស្បៀវភៅ សរសេររបស់អ្នក ហើយធ្វើស្លាកឈ្មោះរបស់មនុស្ស ដែលអេណុស បានអធិស្ឋានឱ្យ នៅលើកទី2 (សូមមើល ខ9–10) និងលើកទី3 (សូមមើល ខ 11–17)។
2. តើការអធិស្ឋានរបស់អេណុស ស្រដៀងទៅនឹងអារម្មណ៍របស់លីហៃ នៅក្នុងនីហ្វៃទី1 8:10–18 យ៉ាងដូចម្តេចខ្លះ? តើអេណុស និងលីហៃបង្រៀនយើងអ្វីខ្លះ អំពីអ្នកដែលផ្លាស់ប្តូរ គំនិតពិតប្រាកដ ហើយបានកើតឡើងវិញម្តងទៀត?

គម្ពីរយ៉ារ៉ុម

តើយើងដឹងអ្វីខ្លះ អំពីយ៉ារ៉ុម?

យ៉ារ៉ុម គឺជាកូនប្រុសរបស់អេណុស, ជាចៅប្រុសរបស់យ៉ាកុប និងជាចៅទួតរបស់លីហៃ (សូម មើល យ៉ារ៉ុម 1:1)។ គម្ពីររបស់លោក គ្របដណ្តប់លើពេលវេលាមួយ ប្រហែលជា ហុកសិបឆ្នាំ ពីឆ្នាំ 420–361 ម.គ. (សូមមើលអេណុស 1:25, យ៉ារ៉ុម 1:13)។

សេចក្តីរីករាយមួយនៃ ភាពជាសមាជិកនៅក្នុងសាសនាចក្រពិត គឺការសូម មើលឃើញអំពីការព្យាការណ៍ របស់ព្រះអម្ចាស់ និងការ សន្យារបស់ទ្រង់ បានត្រូវបំពេញ នៅក្នុងជីវិតរបស់យើងផ្ទាល់ជាយ៉ាងណា។ ព្រះអម្ចាស់បាន សន្យានីហ្វៃ និងប្រជាជនរបស់ លោកជាច្រើនដងថា បើសិនជាពួកគេ កាន់តាមបញ្ញត្តិទាំងឡាយរបស់ព្រះ នោះពួកគេនឹងចំរើនឡើង នៅលើផែនដី ហើយពួកគេ នឹងគេចផុតពីសត្រូវ របស់ពួកគេ (សូមមើល នីហ្វៃទី1 1:20, 2:20–24)។ យ៉ារ៉ុម សរសេរគម្ពីររបស់លោក ដើម្បី ថ្លែង ទីបន្ទាល់ថា ព្រះអម្ចាស់រក្សា សេចក្តីសន្យារបស់ទ្រង់។ សូមរកសូមមើលនូវអ្វីដែលពួក សាសន៍នីហ្វៃ ត្រូវធ្វើដើម្បីឈ្នះលើ សត្រូវ របស់គេនៅក្នុងសម័យរបស់យ៉ារ៉ុម។

ការយល់ដឹងអំពីព្រះគម្ពីរ

យ៉ារ៉ុម 1

ល្មមគ្រប់គ្រាន់សំរាប់ខ្ញុំហើយ (ខ 2)—គឺគ្រប់គ្រាន់សំរាប់ខ្ញុំហើយ

ទទួល (ខ 4)—ទំនាក់ទំនង, ការទាក់ទង

សម្តែងឱ្យ (ខ 4)—ត្រូវបានបង្ហាញ, ផ្តល់ឱ្យ

ពួកគេមិនដេរ ឬក៏ពោលពាក្យប្រមាថ (ខ 5)—ពួកគេមិនគួរប្រើឬនិយាយដោយគ្មានការគោរពដល់វត្ថុពិសិដ្ឋ, ពួកគេមិនមែនភ្ជួតលើលាទេ។

ត្រូវបានបញ្ឆាក់ (ខ 9)—បំភ្លឺថាជាការពិត

ការទាស់ទែងគ្នា, និងការបែកបាក់ខ្ញែក (ខ 13)—ការឈ្លោះគ្នា, ការឈ្លោះប្រកែក និងបែកខ្ញែកគ្នា

ភ ស្វែងរកបញ្ជី

យ៉ារ៉ុម បានសរសេរថា “ហើយយើងបានរៀបចំ ចាំទប់ទល់នឹងពួកសាសន៍លេមិន យ៉ាងដូច្នោះហើយ ទើបពួកគេមិនចំរើនឡើង ឈ្នះយើង” (យ៉ារ៉ុម 1:9)។

1. ចូរស្រាវជ្រាវនៅ ខ 4–8 ហើយធ្វើបញ្ជីនៅក្នុងស្បៀវភៅសរសេររបស់អ្នក យ៉ាងតិចមធ្យោបាយចំនួនបី ដែល ពួកសាសន៍ នីហ្វៃបានរៀបចំសំរាប់សង្គ្រាមរបស់គេ។
2. ចេញមកពីបញ្ជីរបស់អ្នក ចូរជ្រើសរើសរឿងមួយ ដែលអ្នកអាចធ្វើដើម្បី ជួយអ្នកឱ្យឈ្នះលើសេចក្តីល្បួង និងឥទ្ធិពល ទាំងឡាយរបស់សាតាំង ហើយពន្យល់ថាការធ្វើដូច្នោះ អាចការពារកុំឱ្យសាតាំងមានការចំរើនប្រឆាំងនឹងអ្នក។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សា យ៉ារ៉ុម 1។

ព្រះគម្ពីរអោមណៃ

តើនរណាជាអោមណៃ?

អោមណៃ ជាកូនរបស់យ៉ារ៉ុម ជាចៅប្រុសរបស់អេណុស និងជាចៅទួតរបស់យ៉ាកុប។

តើមានអ្វីពិសេសអំពីគម្ពីរនេះ?

គម្ពីររបស់អោមណៃ មានផ្ទុកនូវការសរសេរ របស់អ្នករក្សាបញ្ជីប្រវត្តិនីហ្វៃ ចំនួនប្រាំខុសៗគ្នា លើយគ្របដណ្តប់ លើពេលវេលា ចាប់ពី ឆ្នាំ361 ម.គ. ទៅដល់ឆ្នាំប្រហែលជា 130 ម.គ. (សូមមើល យ៉ារ៉ុម 1:13, ម៉ូសាយ 1:10)។ គម្ពីរអោមណៃគឺជា គម្ពីរចុងក្រោយដែលបានបកប្រែចេញពីម្ចាំងតូចរបស់នីហ្វៃ (សូមមើល ប្រភពសំខាន់ៗសំរាប់ព្រះគម្ពីរមរមន” ទំព័រ 12)។

គម្ពីរអោមណៃ មានតែសាមសិបខប៉ុណ្ណោះ។ វាត្រូវបានសរសេរដោយអ្នកសរសេរចំនួនប្រាំនាក់ផ្សេងគ្នា ហើយមានគ្របដណ្តប់ ប្រហែលជារយៈពេល 200ឆ្នាំ។ ដោយការសរសេររបស់បុរសទាំងនេះមានដោយសង្ខេប ពួកគេបានជួយយើងរៀនពីអ្វីដែលបាន កើតឡើង រវាងពេលវេលានៃអ្នក រក្សាបញ្ជីប្រវត្តិ អោមណៃ និងរជ្ជកាលនៃស្តេចបេនយ៉ាមីន។ ការចាប់អារម្មណ៍ជាពិសេស គឺពីអ្វីដែលបានកើតឡើងក្នុងសម័យ របស់ស្តេចម៉ូសាយទី1 ដែលជាឪពុករបស់ស្តេចបេនយ៉ាមីន នៅពេលដែលពួកសាសន៍នីហ្វៃ សុចរិតត្រូវបានដឹកនាំម្តងទៀតឱ្យរត់គេចទៅ ផ្នែកផ្សេងទៀតនៃដែនដី។

ការយល់ដឹងអំពីព្រះគម្ពីរ

អោមណៃ 1

វិន័យ (ខ 2)—បទបញ្ញត្តិ, ច្បាប់, ក្បួន

បានប្រគល់ផ្តាំងទាំងនេះដល់ (ខ 3)—បញ្ជូនផ្តាំងទៅដល់, ឱ្យផ្តាំងទៅ

ទ្រាំ (ខ 6)—ទុកឱ្យ, អនុញ្ញាត

ដាស់តឿន (ខ 13)—ប្រឹក្សា, ឱ្យដំបូន្មាន

ច្រៃប្រួល (ខ 17)—បានផ្លាស់ប្តូរពីកំណែពិត

ចំការ (ខ 22)—បានធ្វើឱ្យច្របូកច្របល់

ពូជ (ខ 25)—កូនចៅ ឬពូជអំបូរ

អោមណៃ 1:12–30 តើនរណាជានរណាដែលនៅក្នុងគម្ពីរ អោមណៃ?

អាម៉ាលេកៃ ជាអ្នកសរសេរទីប្រាំ នៅក្នុងព្រះគម្ពីរអោមណៃ ដែលបានប្រាប់ពីក្រុមផ្សេងពួគ្នា ដូចខាងក្រោម នៅក្នុងគម្ពីរ អោមណៃ 1:12–30 (សូមមើល "តារាងកាលប្រវត្តិព្រះគម្ពីរមរមន" (ទំព័រ 213)ៈ

- ពួកសាសន៍នីហ្ចៃ ដែលបានដើរតាមស្តេចម៉ូសាយទី 1 ចេញពីដែនដីនីហ្ចៃ ហើយចូលទៅក្នុងព្រៃ រហារស្ថាន រហូតដល់ពួកគេ មកដល់ ដែនដី សាវ៉ាហិមឡា
- ពួកសាសន៍លេមិន (ហើយគ្រប់ពួកសាសន៍នីហ្ចៃ ដែលចូលរួមជាមួយពួកគេ) ដែលនៅក្នុងដែនដីនីហ្ចៃ
- ប្រជាជននៃដែនដីសេវ៉ាហិមឡាយ (ពេលខ្លះហៅថា ពួកសាសន៍មូលេក) ដែលបានចេញមកពីក្រុងយេរ៉ូសាឡិម នៅរដ្ឋកាល នៃសេដេគា (ប្រហែលជាឆ្នាំ587 ម.គ.)
- "កូរីអានទុមើរ និងការប្រហារបង់នៃប្រជារាស្ត្ររបស់លោក" (ខ 21 បានហៅថា ពួកសាសន៍យ៉ារេឌ) ដែលបានចេញមកពីប៉ម៉នៃក្រុងបាបិល
- ក្រុមនៃពួកសាសន៍នីហ្ចៃ គឺស៊ីនិព្ធ បានដឹកនាំចេញពីដែនដីសាវ៉ាហិមឡា ដែលត្រឡប់ទៅកាន់ ដែនដីនីហ្ចៃវិញ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពដូចខាងក្រោម (ក–គ)នៅពេលអ្នកសិក្សានៅក្នុងអោមណៃ 1។

ក្ស៊ ស្វែងរកប្រធានបទស្រដៀងពួគ្នា

គម្ពីរអោមណៃ មានទូវការសរសេររបស់បុរសប្រាំខុសពួគ្នាគឺៈ អោមណៃ អ៉ម៉ារុន កេមីស អ៉ប៊ីណាដុម និងអាម៉ាលេកៃ។

1. សូមសរសេរឈ្មោះរបស់ពួកគេនីមួយព្ធ នៅក្នុងស្សៀវភៅសរសេររបស់អ្នក បន្ទាប់ពីឈ្មោះនីមួយព្ធ ចូរធ្វើបញ្ជីខគម្ពីរ ដែលបុរសម្នាក់ព្ធនោះបានសរសេរ។
2. តើព្រឹត្តិការណ៍ ស្រដៀងគ្នាអ្វីខ្លះ ដែលអោមណៃ អ៉ម៉ារ៉ុន អ៉ប៊ីណាដុម និងអាម៉ាលេកៃ សរសេរនោះ? តើអ្វីខ្លះដែលការណ៍ នោះអាចបង្រៀនយើងអំពីគម្ពីរនេះ ដែលត្រូវបានគ្រប ដណ្តប់អស់រយៈពេលប្រហែលជា 200ឆ្នាំ?

ខ្ស៊ ធ្វើការប្រៀបធៀប

ចូរអានអោមណៃ 1:12–13 ហើយបន្ទាប់មកអាន នីហ្ចៃទី1 2:1–4 និងនីហ្ចៃទី 2 5:5–8។

1. តើដំណើររឿងនេះមានអ្វីជាទូទៅ?
2. តើពួកគេបានឱ្យឧទាហរណ៍ទាំងអស់ ពីអ្វីដែលនីហ្ចៃបានបង្រៀននៅក្នុងនីហ្ចៃទី1 1:20 បាន យ៉ាងដូចម្តេច?
3. តើមេរៀនអ្វីខ្លះ ដែលអ្នកអាចរៀន ចេញមកពីដំណើររឿងទាំងនោះ ដែលនឹងអាចអនុវត្តទៅនឹង ជីវិតរបស់អ្នកបាន?

ត្ស៊ ការសំរេចនៃការព្យាករណ៍

ត្រូសាររបស់លីហៃ និងប្រជាជននៃដែនដីសាវ៉ាហិមឡា (នៅពេលខ្លះបានហៅថា វង្សនៃមូលេក) ទាំងពីរក្រុមនេះបានភៀសចេញ ពីក្រុងយេរ៉ូសាឡិម ប៉ុន្តែនៅពេលខុសពួគ្នា។ ភាពខុសគ្នាសំខាន់មួយ រវាងពួកគេ គឺថាត្រូសាររបស់លីហៃ បានយកព្រះគម្ពីរទៅ ជាមួយពួកគេ ហើយប្រជាជននៃ ដែនដីសាវ៉ាហិមឡា មិនបានយកព្រះគម្ពីរទៅជាមួយទេ។ សូមរំលឹក អោមណៃ 1:14–17 សារ ឡើងវិញ ហើយពន្យល់ថាតើមានអ្វីដែលមានឥទ្ធិពលទៅនឹងភាព ខុសគ្នានោះ ដែលមាន ចំពោះ ប្រជាជននៃដែន ដីសាវ៉ាហិមឡា ដែលតើការណ៍នោះបានបង្ហាញសេចក្តីពិត នៃអ្វីដែលព្រះអម្ចាស់ មានបន្ទូលនៅក្នុងនីហ្ចៃទី1 4:12–17 យ៉ាងម៉េចខ្លះ។

ឃ្ស៊ គូរអំពីទំនាក់ទំនងរវាងក្រុមទាំងនោះ

នៅក្នុងស្សៀភៅសរសេររបស់អ្នក ចូរគូសឌីយ៉ាក្រាមមួយ ដូចដែលមានបង្ហាញនៅខាងក្រោម ដោយមានបិទស្លាក ឈ្មោះរបស់ក្រុមប្រាំផ្សេងពួគ្នា ដែលបានប្រាប់នៅក្នុងគម្ពីរអោមណៃ។ សូម បញ្ចូលការពន្យល់មួយរបស់ក្រុមនីមួយព្ធ និងកាលបរិច្ឆេទសំខាន់ព្ធ (សំរាប់ជាជំនួយ សូមមើលវគ្ត "ការយល់ដឹង អំពីព្រះគម្ពីរ" សំរាប់អោមណៃ 1:12–30, "តារាងកាលប្រវត្តិព្រះគម្ពីរមរមន" ទំព័រ 213)។ អ្នកប្រហែលជា ចង់ធ្វើស្លាកឈ្មោះរបស់ក្រុមទាំងនោះ នៅរឹមទំព័រ នៃព្រះគម្ពីរមរមន របស់អ្នក នៅក្នុងគម្ពីរអោមណៃ។



ឲ្ស៊ ស្វែងរកចំលើយ

អាម៉ាលិកៃ បានបញ្ចប់បញ្ជីប្រវត្តិរបស់លោក ជាមួយនឹងការសង្ខេប ពីជីវិតរបស់ស្តេចបេនយ៉ាមីន ជាបុត្រារបស់ស្តេចម៉ូសាយទី 1។ នៅពេលអ្នកអានអោមណៃ 1:23–30 ចូរឆ្លើយសំនួរដូចខាងក្រោម នៅក្នុងស្សៀវភៅសរសេររបស់អ្នកៈ

1. តើស្តេចបេនយ៉ាមីន ទទួលជោគជ័យយ៉ាងដូចម្តេច ក្នុងនាមជាអ្នកចម្បាំងរបស់ស្តេចម្នាក់?
2. ហេតុអ្វីអាម៉ាលិកៃ ឱ្យបញ្ជីប្រវត្តិនីហ្ចៃ ទៅស្តេចបេនយ៉ាមីន?
3. តើយើងដឹងយ៉ាងម៉េចថា អាម៉ាលិកៃ ជាបុរស សុចរិត?
4. តើមានអ្វីកើតឡើង ចំពោះក្រុមទីមួយ ដែលបានចាកចេញពីដែនដីសាវ៉ាហិមឡា ហើយចង់ ត្រឡប់ទៅកាន់ ដែនដីនីហ្ចៃវិញ?

ពាក្យរបស់មរមន

ក គម្ពីរនៃពេលខុសឆ្គា

គម្ពីរដ៏ខ្លីមួយដែលហៅថា ពាក្យរបស់មរមន គឺត្រូវបានសរសេរដោយព្យាការីមរមន និងជាអ្នករក្សាបញ្ជីប្រវត្តិ ប្រហែលជា ឆ្នាំ385 គ.ស. ច្រើនជាង 500ឆ្នាំ បន្ទាប់ពីអ្នកសរសេរចុងក្រោយនៅក្នុងគម្ពីរណោមណៃ។ វាគឺជាការពន្យល់របស់មរមន សំរាប់បញ្ចូលទៅក្នុងផ្នាំងតូចនីហ្វៃជាមួយនឹងការសង្ខេបរបស់លោក នៃផ្នាំងធំនីហ្វៃ។ អ្នកនឹងរៀនច្រើនទៀតអំពីព្យាការីមរមន ក្រោយពីអ្នកសិក្សាអំពី ការសរសេររបស់លោក។

លោកមរមន ក៏ដូចជានីហ្វៃ (សូមមើលនីហ្វៃទី1 9:5, 19:3) មិនបានដឹងថា ហេតុអ្វីផ្នាំងទាំងពីរនេះ ត្រូវដណ្តប់នៅក្នុងរយៈ ពេលសំខាន់ៗ ដូចគ្នាដូច្នេះ។ មរមនបានបញ្ចូលនៅក្នុង ផ្នាំងតូចរបស់នីហ្វៃជាមួយការសង្ខេបរបស់លោក ពីផ្នាំងធំ របស់នីហ្វៃដោយសព្វគ្រប់ ពីព្រោះព្រះអម្ចាស់ បានបំផុសគំនិតលោកឱ្យធ្វើដូច្នោះ។ សូមរកសូមមើលថាហេតុអ្វី បានជាលោកមរមន មានអារម្មណ៍ថា ផ្នាំងតូចសំខាន់ខ្លាំង យ៉ាងនេះ។ (សំរាប់ពត៌មានបន្ថែមសូមមើល "ប្រភពសំខាន់នៃ ព្រះគម្ពីរមរមន" ទំព័រ 12)។

ការយល់ដឹងអំពីព្រះគម្ពីរ

ពាក្យសំដីនៃមរមន 1

ប្រយោជន៍ (ខ 2)—ប្រយោជន៍, ពរជ័យ

ការសង្ខេប (ខ 3)—ការសរសេរខ្លីៗ

ការទាស់ទែង (ខ 16)—ការឈ្លោះគ្នា, ការវិវាទគ្នា

ការបែកបាក់គ្នាជាច្រើន ចូលដៃទៅឯពួកសាសន៍លេមិន (ខ 16)—ពួកសាសន៍នីហ្វៃជាច្រើន បានចាកចេញ ដើម្បីចូលរួមជាមួយសាសន៍លេមិន

ពាក្យសំដីនៃមរមន 1:5–7—តើគោលបំណងដ៏ឆ្លាតវៃមានអ្វីខ្លះសំរាប់បញ្ចូលទៅក្នុងផ្នាំងតូចរបស់នីហ្វៃ?

ព្រះអម្ចាស់បានបញ្ជានីហ្វៃ ឱ្យរក្សាបញ្ជីប្រវត្តិទាំងពីរផ្នែកនេះ ប្រវត្តិសាស្ត្ររបស់មនុស្សនៅលើផ្នាំងធំ ហើយសំរាប់ "គោលបំណងដ៏ពិសេស" អំពីខាងសាសនាគឺមាននៅលើផ្នាំងតូច (សូមមើលនីហ្វៃទី1 9)។ ទោះបីជា មរមនបានធ្វើការសង្ខេប ចេញពីផ្នាំងធំ នៃនីហ្វៃ ដែលគ្របដណ្តប់នៅជំនាន់ លីហៃ ទៅស្តេចមេនយ៉ាមិន លោកបានត្រូវបំផុសគំនិតឱ្យសរសេរបន្ថែម នៅក្នុងផ្នាំងតូចនៃនីហ្វៃ ដែល គ្របដណ្តប់នៅក្នុងពេលដូចគ្នា "សំរាប់គោលបំណងដ៏ឆ្លាត" (ពាក្យសំដីនៃមរមន 1:7)។ លោកបានបន្ថែមគម្ពីរទាំងពីរនោះ ដោយគ្មាន ធ្វើការផ្លាស់ប្តូរគម្ពីរនោះណាមួយទេ។ សំរាប់ការពន្យល់មួយនៃអ៊ូដែល ជាគោលបំណងដ៏ឆ្លាតនោះ សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់និហ្វៃទី1 9:3–6 (ទំព័រ 20)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព (ក–គ) នៅពេលអ្នកសិក្សាពាក្យសំដីនៃមរមន 1។

ក ផ្គូរផ្គងឃ្លាជាមួយនឹងនិយមន័យ

នៅពេលខ្លះវាពិបាក ដើម្បីដឹងថា ផ្នាំងមួយណា ដែលមរមនបានសំដៅទៅលើនោះ នៅពេលដែលលោក បានសរសេរបញ្ជីប្រវត្តិ ផ្សេងៗ ដែលលោកកំពុងតែធ្វើ។ ចូរសរសេរឃ្លាដូចខាងក្រោម នៅក្នុងស្បៃវាសរសេរ របស់អ្នក។ បន្ទាប់មក នៅពេលដែល អ្នកអានពាក្យសំដីនៃមរមន 1:1–9 សូមផ្គូរផ្គងនិយមន័យ មួយចេញពីនិយមន័យទាំងបួនខាងក្រោម ទៅនឹងឃ្លានីមួយៗ។ អ្នកប្រហែលជាចង់សរសេរនិយមន័យនៅក្នុងរឹមទំព័រ នៃព្រះគម្ពីររបស់អ្នក នៅជិតនឹងឃ្លានីមួយៗ។

ឃ្លានីមួយៗ
"បញ្ជីប្រវត្តិដែលខ្ញុំបានធ្វើ" (ខ 1)
"បញ្ជីប្រវត្តិទាំងនេះ" (ខ 2)
"ផ្នាំងនីហ្វៃ" (ខ 3)
"បញ្ជីប្រត្តិទាំងឡាយ ដែលបានប្រគល់មកក្នុងដៃខ្ញុំ" (ខ 3)
"ខ្ញុំបានរកឃើញផ្នាំងទាំងនេះ" (ខ 4)
"ផ្នាំងទាំងនេះពេញចិត្តខ្ញុំ" (ខ 4)
"ខ្ញុំរើសវត្ថុទាំងនេះ" (ខ 5)
"បញ្ជីប្រវត្តិរបស់ខ្ញុំ" (ខ 5)
"ផ្នាំងនីហ្វៃ" (ខ 5)
"ខ្ញុំនឹងយកផ្នាំងទាំងនេះ" (ខ 6)
"បញ្ចប់បញ្ជីប្រវត្តិរបស់ខ្ញុំ" (ខ 9)

និយមន័យ

1. ព្រះគម្ពីរមរមន
2. បញ្ជីប្រវត្តិរបស់នីហៃ (ផ្នាំងធំ)
3. បញ្ជីប្រវត្តិសាសនារបស់នីហៃ (ផ្នាំងតូច)
4. ការប្រមូលផ្តុំនៃបញ្ជីប្រវត្តិ ដែលមរមនបានប្រើ ដើម្បីធ្វើការសង្ខេបរបស់លោក

២ រៀបចំគំរបស្បែរភៅ

នៅក្នុងស្បែរភៅសរសេររបស់អ្នក គួរគំរបស្បែរភៅមួយ សំរាប់ផ្នាំងតូចរបស់នីហៃ ដែលបង្ហាញអំពីអ្វីដែលមាននៅក្នុង ស្បែរភៅ។ រៀបចំគំរបស្បែរភៅ ដើម្បីធ្វើឱ្យមនុស្សចាប់អារម្មណ៍អាន។ សូមអានពាក្យសំដីនៃមរមន ១:3–6 សំរាប់គំនិត ដែលអ្នកប្រហែលជាចង់បញ្ចូល នៅក្នុងគំរបស្បែរភៅរបស់អ្នក។

៣ ធ្វើតារាងពេលវេលា

ដោយសារគម្ពីរម៉ូសាយចាប់ផ្តើម នៅពេលដែលស្តេចបេនយ៉ាមីនចាស់ជរា លោកមរមនចង់ឱ្យយើងដឹង អំពីការសំរេចដ៏ ធំរបស់លោក។ បន្ទាប់ពីអានពាក្យសំដីនៃមរមន ១:12–18 សូមធ្វើតារាងពេលពីព្រឹត្តិការណ៍ នៅក្នុងជីវិតរបស់ស្តេច បេនយ៉ាមីន។ បន្ទាប់មក សូមសរសេរឃ្លាមួយ ដែលសង្ខេបអំពីជីវិតរបស់លោក។

គម្ពីរម៉ូសាយ

តើនរណាសរសេរគម្ពីរម៉ូសាយ?

គម្ពីរនៅក្នុងព្រះគម្ពីរមរមន ដែលចេញមកពីផ្នាំងតូចរបស់នីហៃ (នីហៃទី 1–អាម៉ាណៃ) គឺមិនបានសង្ខេបដោយលោក មរមនទេ។ លោកបានដាក់ផ្នាំងទាំងនេះ ដោយគ្មានការផ្លាស់ប្តូរ ជាមួយនឹងការសង្ខេបផ្នាំងធំរបស់លោកទេ។ នៅក្នុងការ ចាប់ផ្តើមជាមួយនឹងគម្ពីរម៉ូសាយ យើងកំពុងអានអំពីការសង្ខេបរបស់លោកមរមននៃផ្នាំងធំរបស់នីហៃ។

គម្ពីរម៉ូសាយ គឺត្រូវបានដាក់ឈ្មោះសំរាប់ស្តេច និងព្យាការីម៉ូសាយ ដែលជាឬត្រារបស់ស្តេច បេនយ៉ាមីន ដែលត្រូវដាចៅប្រុសរបស់ស្តេចម៉ូសាយទី 1 ដែលអ្នកបានអាន នៅក្នុងគម្ពីរអាម៉ាណៃ (សូមមើលអោមាណៃ 1:12)។

តើអ្នកអាចស្វែងរកអ្វីខ្លះ នៅក្នុងព្រះគម្ពីរម៉ូសាយ?

នៅក្នុងម៉ូសាយអ្នកនឹងអានអំពី វីរៈបុរសដ៏អស្ចារ្យជាច្រើន ដូចជាស្តេចបេនយ៉ាមីន ស្តេចម៉ូសាយទី 2 អ័ប៊ីណាដៃ និង អាលម៉ា ជាឪពុក។ អ្នកនឹងរកឃើញជំណើររឿងនៃមនុស្សដ៏ឃោរឃៅ ដូចជាស្តេចណូអេ និងអាមូឡុន។ ជាសំខាន់បំផុតនោះ អ្នកនឹងរក ឃើញជំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ មានពន្យល់នៅក្នុងទេសនកថា ហើយក៏បានបង្ហាញនៅក្នុងរឿងដ៏អស្ចារ្យជាច្រើនដង។

គម្ពីរម៉ូសាយ ចាប់ផ្តើមឡើងប្រហែលជា ឆ្នាំ130 ម.គ.ស ហើយបានបញ្ចប់ប្រហែលជា ឆ្នាំ 91 ម.គ.ស។ ទោះបីជាយ៉ាងណា ក៏ដោយ វាមិនមែនជារឿងបន្តគតឈប់ឈរមួយទេ។ នៅក្នុងការសង្ខេបរបស់លោក មរមនបានចងក្រងជំណើររឿងដែលទាក់ទង ទៅនឹងក្រុមសាសន៍នីហៃបី ៖

- ពួកសាសន៍នីហៃនៅក្នុងដែនដីសេរ៉ាហិមឡា (ម៉ូសាយ 1–8, 25–29)
- ពួកសាសន៍នីហៃ ដែលបានធ្វើតាមសិទិព្ធ បានត្រឡប់ទៅដែនដីនីហៃវិញ (ម៉ូសាយ 9–22)
- អាលម៉ាជាឪពុក និងក្រុមផ្លាស់ប្តូរគំនិតរបស់លោក (ម៉ូសាយ 23–24)

តារាងខាងក្រោមមានបង្ហាញអំពី ចំនែកនៃជំណើររឿងព្រះគម្ពីរមរមន ដែលគ្របដណ្តប់ដោយគម្ពីរម៉ូសាយ (សំរាប់ពិស្តារបន្ថែម សូមមើល “តារាងកាលប្រវត្តិព្រះគម្ពីរមរមន” ទំព័រ 213)។



ម៉ូសាយ1
សារៈសំខាន់នៃបញ្ជីប្រវត្តិពិសិដ្ឋ

តើអ្នកធ្លាប់បានគិតថា ជីវិតរបស់អ្នកនឹងទៅជាយ៉ាងណា បើគ្មានព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមនឬទេ? តើអ្នកដឹងអំពីគោលបំណង នៃជីវិតនៅលើផែនដីនេះ និងអ្វី ដែលអ្នកសង្ឃឹមថានឹងមានបន្ទាប់ពីសេចក្តីស្លាប់ឬទេ? គឺដូចជា ព្រះគម្ពីរមរមន គឺជាសាក្សីដ៏ពិតចំពោះយើងថា យ៉ូសែប ស៊្មីធ គឺជាព្យាការី របស់ព្រះ ផ្ទាំងរបស់នីហ្វៃ និងផ្ទាំងលង្ហិន គឺជាសាក្សីចំពោះពួកសាសន៍ នីហ្វៃថា ព្រះអម្ចាស់ពិតជាបានជីកនាំ ជីវិតជីតារបស់ពួកគេ ឱ្យចាកចេញពី ផែនដីយេរូសាឡិម។

នៅពេលអ្នកអាន ម៉ូសាយ 1–5 សូមចងចាំនៅក្នុងចិត្តអ្នកថា ការបង្រៀន របស់ព្រះអម្ចាស់ គឺមិនបានផ្តល់ឱ្យ ដើម្បីហៅមនុស្សទុច្ចរិតឱ្យប្រែចិត្តទេ។ ពួកសាសន៍នីហ្វៃទាំងនេះ គោរពតាមបទបញ្ញត្តិ និងស្មោះត្រង់ចំពោះ សេចក្តីសញ្ញារបស់ពួកគេ នោះជាមូលហេតុ ដែលស្តេចបេនយ៉ាមីនចង់ឱ្យ ឈ្មោះថ្មីទៅកាន់ពួកគេ (សូមមើលម៉ូសាយ 1:11)។ ចូរស្វែងរកឈ្មោះថ្មី នោះថា ជាឈ្មោះអ្វី ហើយតើអ្នកអាចទទួលពរដ៏ល្អដូចគ្នាបានដោយ របៀបណា។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 1

រក្សាទុក (ខ 5)—បានរក្សាទុកសំរាប់ គោលបំណងពិសេស

ការអាថិកំបាំង (ខ 5)—សេចក្តីពិតរៀន បានតែតាមរយៈសេចក្តីជំនឿ និង វិវរណៈប៉ុណ្ណោះ

ចុះអន់ថយ (ខ 5)—ការធ្លាក់ចុះបន្តិចម្តងៗ

ជរា (ខ 9)—បានលូតលាស់, បានប្រែជា

ជាការចាំបាច់ (ខ 9)—សមរម្យ, គួរឱ្យចង់បាន

ប្រកាស (ខ 10)—សេចក្តីប្រកាស, ការរអាង

ញែកចេញ (ខ 11)—ទទួលស្គាល់, បានដឹង

បានលុបចោល (ខ 12)—បានលុប

កំផិត (ខ 13)—មិនស្មោះត្រង់ចំពោះ សេចក្តីសញ្ញា និង ការសន្យា, ខូះសីលធម៌

ប្រគល់បន្ទុក (ខ 15–16)—ការទទួល ខុសត្រូវ

នាំមកទូវ (ខ 17)—រកបាន

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 1។

ក សរសេរកំណត់ហេតុមួយ

ឧទាហរណ៍ថា អ្នកគឺជាម៉ូសាយទី2 ដែលជាប្រត្រារបស់ស្តេចបេនយ៉ាមីន។ សូមសិក្សាម៉ូសាយ 1:1–8 ហើយបន្ទាប់មកសរសេរកំណត់ហេតុ នៅក្នុងស្មៅគោសរសេររបស់អ្នក ដែលសង្ខេបអំពី ដំបូន្មានរបស់ឪពុកអ្នក ដែលបានផ្តល់ឱ្យអ្នកនៅក្នុងខគម្ពីរទាំងនោះ។ ត្រូវត្រាកដថាមានរួមបញ្ចូល យ៉ាងហោចណាស់គោលការណ៍សំខាន់ពីរ ដែលគាត់បានបង្រៀនអ្នកអំពីព្រះគម្ពីរ។

ខ បង្កើតចំណោទមួយ

រំលឹកសារឡើងវិញ ម៉ូសាយ 1:11–18 រួចហើយសរសេរយ៉ាងហោចណាស់ចំណោទសំនួរចំនួន ប៊ិះ មួយចេញមកពីខ 11–12, មួយចេញមកពី 13–15, ហើយមួយទៀតចេញមកពី 16–18។ ចូរកុំភ្លេចបញ្ចូលចំលើយ។

ម៉ូសាយ2
ការបំរើព្រះ

© 1967 Bill L. Hill

ដូចដែលស្តេចបេនយ៉ាមីន បាន និយាយនៅពេលចុងក្រោយនៃ ជីវិតរបស់ទ្រង់ ទ្រង់ក៏បានសំរេចចិត្ត ដើម្បីនិយាយ ទៅកាន់ប្រជាជន របស់ទ្រង់ អំពីដំណឹងល្អ ហើយ ប្រកាស់ប្រាប់អំពីស្តេចថ្មីរបស់ ពួកគេ។ ការនិយាយរបស់ស្តេច បេនយ៉ាមីន ចាប់ផ្តើមនៅក្នុង ម៉ូសាយ2 ហើយបន្តរហូតដល់ ជំពូកទី3 និងទី4។ ទេសនកថាដ៏មានអំណាចនេះ អាចជួយយើងយល់អំពី ដំណឹងល្អ។ ចូរចងចាំថា ទេសនកថានេះ គឺមិនបាននិយាយទៅកាន់ សមាជិកដែលមិនស្មោះត្រង់នោះទេ ប៉ុន្តែនិយាយទៅកាន់ប្រជាជន ដែល រស់នៅក្នុងសេចក្តីសុខសាន្ត។ ប្រជាជនរបស់ស្តេច បេនយ៉ាមីន គឺជា សមាជិកស្មោះត្រង់ ដែលរៀបចំដារស្រេចដើម្បីបោះដំហានថ្មីនៅក្នុង ការរីកចំរើនរុងរឿង ដែលឆ្ពោះទៅរកការកើតខាងវិញ្ញាណឡើងវិញម្តងទៀត (សូមមើល ម៉ូសាយ 1:11, 5:7)។ នៅពេលអ្នកសិក្សា អំពីទេសនកថា របស់ស្តេចបេនយ៉ាមីន ចូរកំណត់ចំណាំអំពីមូលហេតុ ដែលទ្រង់បានផ្តល់ឱ្យ ដើម្បីព្យាយាមប្រែក្លាយ ទៅជា "ពួកបរិសុទ្ធតាមរយៈដង្វាយធួនរបស់ ព្រះគ្រីស្ទ" (ម៉ូសាយ 3:19)។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 2

កូនសត្វច្បង (ខ. 3)—កូនទីមួយ

សូមមើលងាយ (ខ. 9)—ប្រព្រឹត្តដូចជា មិនសំខាន់

ទន់ខ្សោយ (ខ. 11)—តាពទន់ខ្សោយ, ជម្ងឺ

តាំងឡើង (ខ. 11)—តែងតាំងសំរាប់ គោលបំណងពិសិដ្ឋ

ទ្រទ្រង់ (ខ. 11)—បានអនុញ្ញាត, យល់ព្រម

ជិធ្ងន់ (ខ. 14)—បានដាក់បន្ទុក

ដ៏ឥតប្រយោជន៍ (ខ. 21)—មិនមានតំលៃ, មិនសក្តិសម

ផ្លាស់ប្តូរ (ខ. 22)—ផ្លាស់ប្តូរ

បានធ្វើពីមុនមក (ខ. 31)—បានធ្វើពីមុន

ចុះឈ្មោះយល់ព្រម (ខ. 33)—ប៉ងប្រាថ្នា, ចង់បាន

ត្រូវតបស្នង (ខ. 34)—ផ្តល់, ប្រគល់ឱ្យ

ម៉ូសាយ 2:16–17—ហេតុអ្វីព្រះតំរូវឱ្យយើង បំរើគ្នាទៅវិញទៅមក?

ប្រធាន មារីអន ជី. រ៉ូមនី ដែលជាសមាជិក នៃគណៈប្រធានទីមួយ បានបង្រៀនថាៈ

"ការបំរើ គឺមិនមែនជាអ្វីមួយ ដែលយើងស៊ូទ្រាំនៅលើផែនដីនេះ ដើម្បីយើងអាចទទួលបានសិទ្ធិ ដើម្បីទៅរស់នៅ ក្នុងនរគ សេឡាស្ទាលនោះទេ។ ការបំរើ សំខាន់ខ្លាំងណាស់ ចំពោះជីវិត លើកដំកើងដែលបានធ្វើឡើងនៅក្នុង នរគសេឡាស្ទាល។

"ការដឹងថា ការបំរើ គឺជាអ្វីដែលធ្វើឱ្យព្រះវរបិតាសួគ៌បានសំរេច ហើយការដឹងថា យើងចង់ទៅកន្លែង ដែលទ្រង់គង់នៅ និងប្រែក្លាយដូចទ្រង់ គឺហេតុអ្វីយើងត្រូវបានបញ្ជាឱ្យបំរើគ្នាទៅវិញទៅមកឡេត? សំរាប់ថ្ងៃដ៏រុងរឿង នៅពេលអ្វីៗទាំងអស់នេះ មកដល់ដូចតាមធម្មជាតិ ពីព្រោះតែបេះដូងដ៏បរិសុទ្ធរបស់យើង។ នៅថ្ងៃនោះ នឹងគ្មានសេចក្តីត្រូវការសំរាប់បទបញ្ញត្តិឡេតទេ ពីព្រោះយើងនឹងមានបទពិសោធន៍សំរាប់ខ្លួនយើងផ្ទាល់ថា យើងពិតជា បានសប្បាយតែម្យ៉ាងគត់ នៅពេលដែលយើងភ្ជាប់ នៅក្នុងការបំរើដោយគ្មានចិត្តអាត្មានិយម" (នៅក្នុង Conference Report, ខែតុលា ឆ្នាំ1982, 135, ឬ *Ensign,* ខែវិច្ឆិកា ឆ្នាំ1982, 93)។

ម៉ូសាយ 2:20–24—ហេតុអ្វីស្តេចបេនយ៉ាមីននិយាយថា យើងគឺ "ជាអ្នកបំរើដ៏ឥតប្រយោជន៍" ដូច្នេះ?

ស្តេចបេនយ៉ាមីនបានឱ្យមូលហេតុពីរយ៉ាង ថាហេតុអ្វីបានជាយើងគ្មានប្រយោជន៍។ ទីមួយ អ្វីៗដែលយើងមាន ហើយអាចធ្វើទៅបាន ដោយសារតែអំណោយរបស់ព្រះសំរាប់ជីវិតនៃកូនចៅគ្រប់រូបរបស់ទ្រង់តែប៉ុណ្ណោះ (សូមមើល ម៉ូសាយ 2:23)។ យើងជាប់ជំពាក់បំណុលទ្រង់ សំរាប់ជីវិតយើងគ្រប់គ្នា។ ទីពីរ ទោះបីជាយើងគោរពប្រតិបត្តិ "ទ្រង់នឹងប្រទានពរយើងភ្លាម ហេតុដូច្នេះហើយព្រះអង្គបានសងអ្នកវិញ។ ហើយយើងក៏នៅតែជំពាក់បំណុលព្រះអង្គ" (ខ 24)។ ចំនុចសំខាន់បំផុតនៃពរជ័យទាំងអស់នេះគឺ ប្រាកដហើយ គឺជាអំណោយទាននៃដង្វាយធួន។ តំលៃដែលព្រះយេស៊ូវគ្រីស្ទ បានបង់ថ្លៃ ដើម្បីប្រោសលោះយើង ពីអំពើបាប និងសេចក្តីស្លាប់ គឺគ្មានព្រំដែន នឹងជាតំលៃដែលយើងមិនអាចសងវិញបាន។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនគួរគិតថា ព្រះប្រៀបធ្រៀបពីអ្វីទាំងអស់ ដែលទ្រង់បានធ្វើ ចំពោះយើង ទៅនឹងអ្វីដែលយើងធ្វើចំពោះទ្រង់ឡើយ។ ទ្រង់ស្រលាញ់យើង ហើយពេញចិត្តរាល់ការខិតខំរបស់យើងទាំងអស់ ដើម្បីបំរើ និងគោរពតាម។

ម៉ូសាយ 2:27–28—តើ "ដើម្បីឱ្យខ្ញុំអាចកំចាត់សំលៀកបំពាក់ខ្ញុំពីឈាមនៃអ្នករាល់គ្នា" មានអត្ថន័យយ៉ាងដូចម្តេច?

សាសន៍អ៊ីស្រាអែលពីបុរាណ វាគឺជាការសាមញ្ញសំរាប់សហគមន៍មួយ សង់ប៉មមួយ ដែលមានអ្នកចាំយាម ដាក់នៅទីនោះ ដើម្បី ព្រមានដល់ប្រជាជនអំពីគ្រោះថ្នាក់ដែលអាចមានមកដល់។ បើអ្នកចាំយាមធ្វើការព្រមានខុស នៅពេលដែលសត្រូវមក ដល់ គាត់នឹងត្រូវទទួលខុសត្រូវចំពោះជីវិត ដែលបាត់បង់នៅក្នុងការច្បាំង ឬនៅក្នុងភាសាព្រះគម្ពីរសញ្ញាចាស់ថា "ឈាម" របស់ពួកគេនឹងនៅលើដៃ និងសំលៀកបំពាក់ របស់អ្នកចាំយាម។ ស្តេចបេនយ៉ាមីនបានយល់ថា មុខងារបស់ទ្រង់ ធ្វើជាព្យាការី និងជាស្តេច គឺដូចជាអ្នកចាំយាម នៅលើប៉មនោះអញ្ចឹង ដែរ (សូមមើលអេសេគាល 33:1–9)។ បើសិនជាទ្រង់បានបង្រៀនខុស និងថ្លែងទីបន្ទាល់ដោយមិនស្ម័គ្រស្មោះ ហើយមិនព្រមានដល់ប្រជាជន ឱ្យប្រែចិត្តនោះទេ "ឈាម" របស់ពួកគេ (ការនិយាយខាងវិញ្ញាណ)នឹងប្រឡាក់នៅលើសំលៀបំពាក់របស់ទ្រង់ (សូមមើល យ៉ាកុប 1:18–19 ផងដែរ)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក–គ នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 2។

ក សរសេរជាការពិពណ៌នាមួយ

1. សូមរំលឹកឡើងវិញ ម៉ូសាយ 2:9–16 ហើយសរសេរជាការពិពណ៌នាមួយអំពីស្តេចបេនយ៉ាមីនជាអ្នកដឹកនាំប្រភេទណា ហើយរួមបញ្ចូលទាំង គុណសម្បត្តិទាំងអស់ ដែលអ្នកបានរកឃើញ នៅក្នុងខទាំងនោះ។
2. ហេតុអ្វីអ្នកចង់រស់នៅក្នុងទីកន្លែង ដែលគ្រប់គ្រងដោយស្តេចដូចជាស្តេចនេះដូច្នេះ?

ខ ចំណេះចំណានបទគម្ពីរ—ម៉ូសាយ 2:17

ស្តេចបេនយ៉ាមីនបានពន្យល់ថា នៅពេលយើងបំរើមនុស្សដទៃ គឺយើងដូចជាយើងបំរើព្រះដោយពិត។

1. ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់តំរូវឱ្យយើងបំរើគ្នាទៅវិញទៅមក? (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ ម៉ូសាយ 2:16–17 ដើម្បីជាជំនួយបន្ថែម)។
2. ចូរពិពណ៌នាពីពេលវេលាមួយ នៅពេលអ្នកបានបំរើអ្នកដទៃ និងប្រាប់អំពីអាម្មរណ៍របស់អ្នកអំពីការបំរើ ។

គ ចូរគិតពិចារណាអំពីការបង្រៀនរបស់ស្តេចបេនយ៉ាមីន

ទេសនកថារបស់ស្តេចបេនយ៉ាមីន គឺពោរពេញដោយគោលលទ្ធិដ៏សំខាន់ៗ ដែលគួរតែចែកចាយគំនិតដោយ ប្រុងប្រយ័ត្ន។ សូមសិក្សាម៉ូសាយ 2:18–41 ហើយឆ្លើយសំនួរ *បីណាមួយក៏បាន* នៅខាងក្រោមនេះ

1. តើពាក្យរបស់អ្នកណាដែល ម៉ូសាយ 2:18 បានរំលឹកដល់អ្នកនោះ (សូមមើល លូកា 22:24–26)? តើខគម្ពីរនោះបានបង្រៀនអ្នកអ្វីខ្លះ អំពីអ្នកដឹកនាំដែលសុចរិត?
2. សូមអានម៉ូសាយ 2:20–24។ តើយើងជា "អ្នកបំរើដ៏ឥតប្រយោជន៍" ដោយរបៀបណា? តើអ្នកគិតថា ព្រះមានព្រះទ័យយ៉ាងដូចម្តេច ចំពោះយើង ទោះបីជាយើងជា "អ្នកបំរើដ៏ឥតប្រយោជន៍" ក៏ដោយនោះ?
3. សូមអានម៉ូសាយ 2:25 និង ហេលមិន 12:4–13។ តើយើងត្រូវបានគិតថា មិនស្មើនឹងធូលីដីលើផែនដី នេះដោយរបៀបណា?
4. សូមរំលឹក ម៉ូសាយ 2:27–28 ឡើងវិញ។ ហេតុអ្វីស្តេចបេនយ៉ាមីនចង់និយាយ ជាមួយប្រជាជនទ្រង់ម្តងជាពេល ចុងក្រោយដូច្នេះ? តើយើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីឱ្យប្រាកដថា សំលៀកបំពាក់របស់យើងមិនប្រឡាក់ ដោយឈាម របស់មនុស្សទូទៅ? (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ") សំរាប់ម៉ូសាយ 2:27–28 ដើម្បីជាជំនួយបន្ថែម។
5. តើ ការចេញ "មុខបះបោរទាស់នឹងព្រះ" មានអត្ថន័យយ៉ាងដូចម្តេច? (សូមមើល ខ 36–37)។ ចូរពិពណ៌នាយ៉ាង ហោចណាស់អំពីស្ថានការណ៍ចំនួន ពីរ ដែលសមាជិក នៃសាសនាចក្រម្នាក់ ដែលមានអាយុស្មើនឹងអ្នក អាចស្ថិតនៅក្នុង "ការបះបោរ" ហើយប្រហែលជាមិនបានដឹងថា ខ្លួនកំពុងធ្វើការបះបោរនោះ។
6. នៅក្នុង ខ 38–41 ស្តេចបេនយ៉ាមីនបាននិយាយអំពី "ស្ថានការណ៍ដ៏ស្មែងខ្លាច" និង "ស្ថានភាពដ៏មានពរ និងរីករាយ។" តើឃ្លា នីមួយៗមានន័យយ៉ាងដូចម្តេច? តើអ្នកណានឹងស្ថិតនៅក្នុងលក្ខខ័ណ្ឌនីមួយៗនោះ?

ម៉ូសាយ 3

ការញ្យាករណ៍ពីព្រះគ្រីស្ត

ម៉ូសាយ 3 គឺជាការបន្ត នៃទេសនកថាដ៏អស្ចារ្យ របស់ស្តេចបេនយ៉ាមីន ទៅកាន់ប្រជាជនរបស់ទ្រង់។ ច្រើនជាងមួយរយ ឆ្នាំមុនពេលការចាប់កំណើតរបស់ ព្រះគ្រីស្ត ទេវតាមួយអង្គបានយាងមកជួប ស្តេចបេនយ៉ាមីន ហើយបានប្រាប់ទ្រង់ អំពីការយាងមករបស់ព្រះអង្គសង្គ្រោះ នៅក្នុងព្រឹត្តិការណ៍ដ៏គួរឱ្យស្ងប់ស្ងែង។ សូមរកសូមមើលការពន្យល់ ដែលប្រាប់ថាតើ ព្រះអង្គសង្គ្រោះ អាចជួយយើងឱ្យត្រឡប់ទៅជួបព្រះ វរបីតាស្ថគិយើងវិញបានដោយរបៀបណានោះ។ បន្ទាប់ពីអានជំពូក នេះរួចហើយ អ្នកនឹងមានការយល់ដឹងកាន់តែប្រសើរឡើង អំពីអ្វី ដែលព្រះគ្រីស្ទបានធ្វើដើម្បីយើងទាំងអស់គ្នា។



© 1967 Bill L. Hill

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 3

ដំណឹង (ខ 3)—ដំណឹង

មានចេស្តាបំផុត (ខ 5)—មានអំណាចលើអ្វីទាំងអស់

រោងឧបោសថឥដ្ឋ (ខ 5)—រូបរាងកាយ

សេចក្តីបារម្ភ (ខ 7)—សោកសៅ, ទុក្ខព្រួយយ៉ាងខ្លាំង, ឈឺចាប់យ៉ាងខ្លាំង

វាយ (ខ 9)—វាយជាមួយនឹងខ្សែតី ដែលមានកំទេចឆ្អឹង ឬថ្មរឆេតរឆូតនៅខាងចុង

ធ្ងន់នឹង (ខ 11, 16)—បង់តំលៃ

មានផល (ខ 15)—មានតម្លៃ

ងាយប្រដៅ (ខ 19)—ស្ម័គ្រចិត្តដើម្បីគោរព

ត្រូវបានដាក់ (ខ 25)—ត្រូវបានតាំងចិត្ត, បញ្ជូនទៅឱ្យ

ម៉ូសាយ 3:15—"និមិត្តរូប និងស្រមោល"

និមិត្តរូប និងស្រមោល គឺជានិមិត្តសញ្ញា ដែលបង្រៀន និងថ្លែងទីបន្ទាល់អំពីសេចក្តីពិតដ៏អស្ចារ្យ។ ក្រិត្យវិន័យ របស់លោកម៉ូសេ មានន្ទវនិមិត្តសញ្ញាជាច្រើន ដែលបានបង្រៀន ហើយនឹងថ្លែងទីបន្ទាល់អំពី ជីវិតនាពេលអនាគត និងការបង្រៀនរបស់ព្រះអង្គ សង្គ្រោះ។ ឧទាហរណ៍ ក្ងនទីមួយ, ចៀមឈ្មោលបរិសុទ្ធ ដែលត្រូវបានប្រើជាការបូជា គឺជានិមិត្តសញ្ញា (និមិត្តរូប) និងរំលឹក (ស្រមោល) នៃពលិកម្មដង្វាយធ្ងនរបស់ព្រះយេស៊ូវគ្រីស្ទនាពេលអនាគត ដែលជាក្ងនចៀមនៃព្រះ (សូមមើល អាលម៉ា 25:15)។

ម៉ូសាយ 3:19—តើ "មនុស្សខាងសាច់ឈាម" ដែលយើងត្រូវតែដកចេញ គឺជាអ្វី?

អែលឌើរ ន្យែល អេ. ម៉ាកស្វែល ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានពន្យល់ថាះ

"ដំបូងបំផុត មនុស្សខាងសាច់ឈាមជា 'សត្រូវរបស់ព្រះ។' (ម៉ូសាយ 3:19។) នេះមានន័យថា បុគ្គលម្នាក់ឲ (ទោះបីជា យល់ដឹងយ៉ាងពេញលេញអំពីការជំពាក់ទាក់ទង ទៅនឹងការតស៊ូផ្ទាល់របស់ពួកគេ ឬក៏អត់ក៏ដោយ) នឹងប្រឆាំងទៅនឹង គោលបំណងចុងក្រោយ បង្អស់របស់ព្រះសំរាប់មនុស្សទាំងអស់ដូចដែល យើងបានដឹងហើយថា' គឺដើម្បីនាំឱ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច ដល់មនុស្ស។ (ម៉ូសេ 1:39។) សូមផ្តល់ជាចំណាប់អារម្មណ៍ ដ៏អស់កល្បរបស់យើង ហេតុដូច្នោះហើយ មនុស្សខាងសាច់ឈាម គឺមិនមែនជាមិត្តរបស់យើងផងដែរ ទោះបីជា នៅពេលខ្លះយើងហាក់ដូចជា នៅជិតស្និតជាមួយនឹងមនុស្សខាងសាច់ឈាមក៏ដោយនោះ . . .។

"ជំនួសឱ្យការក្លាយជាពួកបរិសុទ្ធម្នាក់ ការធ្វើដូចជាក្ងនក្មេង និងស្មត្រ៉ចិត្តធ្វើអ្វីឲ្យគ្រប់យ៉ាង ចំពោះព្រះវរបិតាដ៏អស់កល្ប របស់យើង មនុស្សខាងសាច់ឈាមគឺជាការបះបោរ និងតស៊ូនៅក្នុងការដើរតាមចិត្តរបស់ខ្លួន។ មនុស្សខាងសាច់ឈាម មានចរិតរបស់ក្ងនក្មេង មិនមែនដូចជាក្ងនក្មេងទេ។

"មនុស្សខាងសាច់ឈាម ក៏ជាមនុស្សត្បាលរឹងក្នុងការស្វែងរកសុភមង្គលនៅក្នុងអំពើទុច្ចរិតផងដែរ—ដែលមានកើតឡើងឱ្យ មានការយល់ដឹងដ៏តិចតួចអំពីធម្មជាតិ នៃសុភមង្គល និងជាសកល . . .។

"ហេតុដូច្នោះហើយ នេះគឺជាមនុស្សខាងសាច់ឈាម នៅក្នុងការប្រឹងប្រែងដើម្បីរស់នៅ 'ដោយគ្មានព្រះនៅក្នុងលោកីយ' និងបានដាក់ខ្លួនឱ្យក្លាយជាទាសករ ចំពោះសភាវគតិពីធម្មជាតិរបស់គាត់ ដែលតាមពិតទៅ ការរស់នៅគឺ 'ផ្ទុយទៅនឹង ស្ថានភាពនៃសុភមង្គល។' (អាលម៉ា 41:11។)" (*Notwithstanding My Weakness* [1987], 71–2)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ដូចខាងក្រោម នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 3។

ក ប្រើលេខយោង

ស្តេចបេនយ៉ាមីន ត្រូវបានបង្រៀនដោយទេវតាអំពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ។

1. នៅពេលអ្នកអានម៉ូសាយ 3:1–8 ចូរសរសេរហេតុការណ៍សំខាន់ប្រាំយ៉ាងអំពីព្រះយេស៊ូវគ្រីស្ទ។

ខ តើនរណាខ្លះ ដែលលោហិតរបស់ព្រះយេស៊ូវសង្គ្រោះពួកគេ?

បើសិនជា ដង្វាយធ្ងនរបស់ព្រះយេស៊ូវគ្រីស្ទ មិនបានបង់សំរាប់អំពើបាបរបស់យើងទេ នោះយើងមិនអាចបានសង្គ្រោះ ឡើយ។ នៅក្នុង ម៉ូសាយ 3:11–18 ស្តេចបេនយ៉ាមីនបានបញ្ជាក់អំពីក្រុមនៃប្រជាជនចំនួនបី ដែលលោហិតរបស់ព្រះគ្រីស្ទធ្វើឱ្យ "ធ្ងន។" ចូរស្វែងរកខគម្ពីរទាំងនោះ ហើយពិពណិនាអំពីប្រភេទមនុស្សទាំងបីក្រុមនោះ។ តើស្តេចបេនយ៉ាមីនទិយាយថា យើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីទទួលសេចក្តីសង្គ្រោះដែលនឹងមានមក "តាមរយះព្រះលោហិតដ៏ធ្ងននៃព្រះគ្រីស្ទជាព្រះអម្ចាស់ដ៏មានព្រះចេស្តា បំផុតប៉ុណ្ណោះ" បាននោះ (ខ 18)?

គ ការទន្ទេញខគម្ពីរ—ម៉ូសាយ 3:19

ដើម្បីជួយអ្នកឱ្យយល់សារៈសំខាន់នៃការដាក់ចុះ មនុស្សខាងសាច់ឈាម ហើយក្លាយជាពួកបរិសុទ្ធម្នាក់នោះ ចូរឆ្លើយសំនួរដូច ខាងក្រោមនេះ នៅពេលអ្នកសិក្សាម៉ូសាយ 3:19៖

1. តើ “មនុស្សខាងសាច់ឈាម” ជាអ្វី ហើយហេតុអ្វីមនុស្សខាងសាច់ឈាមជាសត្រូវរបស់ព្រះ? (សូមមើល កូរិនថូសទី 1 2:12–14, អាលម៉ា 41:11 វគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់ម៉ូសាយ 3:19)។
2. តើព្រះវិញ្ញាណបរិសុទ្ធ “ទាក់ចិត្ត” យើងយ៉ាងដូចម្តេចខ្លះ?
3. តើជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មានតួនាទីដូចម្តេចខ្លះ ក្នុងការជួយអ្នកឱ្យក្លាយជាពួកបរិសុទ្ធម្នាក់? (សូមមើល ម៉ូសាយ 5:2, 27:25–26)។

ម៉ូសាយ 3:19 លើកទឹកចិត្តឱ្យយើងដាក់ចុះ “មនុស្សខាងសាច់ឈាម” ហើយប្រែក្លាយជា “ពួកបរិសុទ្ធតាមរយៈដង្វាយ ធួនរបស់ព្រះគ្រីស្ទជាព្រះអម្ចាស់។” ក្នុងម៉ូសាយ 4 អ្នកនឹងអានពីរបៀបដែលប្រជារាស្ត្ររបស់ស្តេចបេនយ៉ាមីន ទទួលជ័យជំនះ ក្នុងការធ្វើ ដូច្នោះ។ ក្រោយមកស្តេចបានប្រាប់ពួកគេ ពីរបៀបឱ្យជ្រៀសវាងពីការបាត់បង់នូវពរជ័យដ៏អស្ចារ្យទាំងឡាយ ដែលពួកគេបានទទួល។ សូមរកសូមមើលរបៀបទាំងឡាយ ដែលស្តេចបេនយ៉ាមីនមានបន្ទូល អំពីអ្នកដែលរស់ប្តូរគំនិតដ៏ពិត។

ម៉ូសាយ 4 មានបញ្ជាលទាំងសន្ទរកថារបស់ស្តេចបេនយ៉ាមីន ទៅកាន់ប្រជាជនរបស់ទ្រង់ ដែលបានចាប់ផ្តើមនៅក្នុងម៉ូសាយ 2។ ត្រូវដឹងថា មរមនបានបញ្ចូលការតាមដានខ្លះៗទៅលើការបង្រៀន របស់ស្តេចបេនយ៉ាមីន នៅក្នុងម៉ូសាយ 5។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 4

បានក្រឡេកទតសូមមើលជុំវិញ (ខ 1)—សូមមើលជុំវិញ

ស្ថានភាពសាមញ្ញ (ខ 2)—ខាងលោកីយ ឬលក្ខខ័ណ្ឌធ្លាក់ចុះ

ការអត់ឱនទោស (ខ 3, 11–12)—ការអត់ឱនចំពោះអំពើបាប

ឃល់ (ខ 9)—ឃល់

ជួយដល់ (ខ 16)—ជួយ, សង្គ្រោះ, ជួយឧបត្ថម

ទុកឱ្យអ្នកសុំទានមកសុំ (ខ 16, 22)—សុំ ឬសុំឱ្យជួយ

ទុកដៃនៅស្បៃម (ខ. 17)—ទុកដៃឱ្យនៅស្បៃម

ចែករំលែក (ខ. 17, 21, 26)—ឱ្យ, ចែកចាយ

បានកាត់ទោសជននោះ (ខ. 22)—ជំនុំជំរះគាត់ដូចជាមិនសមរម្យ

លោភលន់ (ខ. 25)—សេចក្តីប៉ងប្រាថ្នាដែលអត្មានិយម

មិនត្រូវឱ្យ (ខ.27)—គំរូវការ

ចាំបាច់ (ខ. 27)—ចាំបាច់, សំខាន់

បៃបផ្សេងៗគ្នា (ខ. 29)—ជារ៉ែន, ផ្សេងៗ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ និងសកម្មភាព គ ឬ ឃ នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 4។

ក វិភាគទៅលើអ្វីដែលបានកើតឡើង

ជាលទ្ធផលនៃការផ្លាស់ប្តូរដ៏អស្ចារ្យមួយ បានកើតមានចំពោះប្រជាជន នៅពេលពួកគេអនុវត្តតាមការបង្រៀនរបស់ស្តេច បេនយ៉ាមីន នៅក្នុងជីវិតរបស់ពួកគេ។

1. សូមអានម៉ូសាយ 4:1–3 ហើយឆ្លើយសំនួរទាំងឡាយ នៅក្នុងតារាងខាងក្រោម នៅក្នុងស្បៃវតៅសរសេររបស់អ្នក។

តើពួកគេបានដឹងអ្វី?	តើពួកគេបានស្អប់អ្វី?	តើលទ្ធផលគឺជាអ្វី?

2. តើអ្វីដែលបានកើតឡើងចំពោះប្រជាជនទាំងនេះ ជាឧទាហរណ៍នៃអ្វីដែលស្តេចបេនយ៉ាមីនមានបន្ទូលថា ពួកគេគួរតែធ្វើនៅក្នុង ម៉ូសាយ 3:19 ដូចម្តេចខ្លះ?
3. តើរឿងទាំងនេះស្រដៀងនឹងអ្វីដែលលីហៃបានឃើញនៅក្នុងសុបិនរបស់លោកយ៉ាងដូចម្តេច? (សូមមើល នីហ្វៃទី1 8:10–12)។

ខ ស្វែងរកបញ្ជី

ស្តេចបេនយ៉ាមីន ចង់ឱ្យប្រជាជនរបស់ទ្រង់ យល់ពីរបៀបដើម្បីបានសង្គ្រោះចូលក្នុងនគរព្រះ។ ដូចដែលបានបង្ហាញនៅក្នុង ម៉ូសាយ 4:1–3 ពួកគេបានទទួលបទពិសោធន៍ដូចម្តេច ក្នុងការទទួលនូវការអត់ឱនបាបរបស់ពួកគេ ដែលជាលទ្ធផល នៃសេចក្តីជំនឿរបស់ពួកគេ។

1. នៅក្នុង ខ 4–10 ស្តេចបេនយ៉ាមីន បានពន្យល់ពីអ្វីដែលជាតំរូវការសំរាប់សេចក្តីសង្គ្រោះ។ ចូរសិក្សាខទាំងនេះ ហើយនៅក្នុងស្បៃវតៅសរសេររបស់អ្នក ចូរធ្វើបញ្ជីមួយអំពីសេចក្តីពិតដែលទ្រង់បានមានបន្ទូលថា យើងគួរតែយល់ (សូមមើល ខ 5–7) ហើយបញ្ជី ផ្សេងទៀតគឺអំពីគោលការណ៍ ដែលទ្រង់មានបន្ទូលថា តំបូងយើងត្រូវតែ “ជឿ” ហើយបន្ទាប់មក “ធ្វើ” ដើម្បីទទួលបានសេចក្តីសង្គ្រោះ (សូមមើល ខ 8–10)។
2. ទោះបីដារយើងបានទទួលការអត់ឱនទោស ហើយបានត្រូវធ្វើឱ្យជ្រះស្អាតក៏ដោយ ក៏វាមិនតែងតែងាយស្រួល ដើម្បីឱ្យ បាននៅ តែជ្រះស្អាតនោះទេ។ ចូរសិក្សា ខ 11–12 ហើយធ្វើបញ្ជីអំពីអ្វីដែលស្តេចបេនយ៉ាមីនមានបន្ទូលថា យើងត្រូវតែធ្វើដើម្បី “ទទួលការផ្តាច់បាប [របស់យើង]”។
3. នៅក្នុងខ 12–16 ស្តេចបេនយ៉ាមីន បានសរសេរនូវពរជ័យដែលនឹងក្លាយជារបស់យើង “បើ” យើងធ្វើតាមអ្វីដែលបានបង្រៀន នៅក្នុងខទី 11។ ចូរធ្វើការកត់ចំណាំថា “ការទទួលការផ្តាច់បាបរបស់យើង” គឺមិនគ្រាន់តែជាពរជ័យមួយនៃការគោរព ប្រតិបត្តិទេ។ ចូរធ្វើបញ្ជីអំពីពរជ័យ ដែលទ្រង់បានប្រាប់ ហើយបន្ទាប់មកជ្រើសរើសយកពរជ័យពីរ ហើយពន្យល់ថា ហេតុអ្វីពរជ័យទាំងនោះគួរជាប៉ងប្រាថ្នា ចំពោះអ្នកដូច្នេះ។

គ តើការដោះសាររបស់ពួកគេជាអ្វីខ្លះ?

រូបភាពខាងក្រោម បង្ហាញអំពីគំនិតរបស់ស្តេចបេនយ៉ាមីន អំពីអ្នកទាំងឡាយណាដែលបដិសេធមិនព្រមឱ្យទៅអ្នកក្រីក្រ។ សូមអានម៉ូសាយ 4:17–25 ហើយនៅក្នុងស្បៃវតៅសរសេររបស់អ្នក សូមធ្វើការបញ្ចប់សេចក្តីថ្លែង ជាមួយនឹងអ្វីដែល មនុស្សនៅក្នុងស្ថានភាពនីមួយៗអាចនិយាយ។ តើស្តេចបេនយ៉ាមីន មានបន្ទូលអ្វីខ្លះ ដែលជាអត្ថបទវិតរបស់ពួកគេ?

ខ្ញុំនឹងមិនចែករំលែកព្រោះ . . .

ខ្ញុំមិនអាចចែករំលែកព្រោះ . . .

ចំណេះចំណានបទគម្ពីរ—ម៉ូសាយ 4:30

1. នៅក្នុងសៀវភៅសរសេររបស់អ្នក គូរគំនូររូបព្រាងឲ ឬគូរគំនូរដាពាក្យស្លោក ឬគំនូរដែលបង្ហាញពីគំនិតរបស់ស្តេច បេនយ៉ាមីន ដែលបានបង្រៀនទៅក្នុងម៉ូសាយ 4:30។
2. ចូរពន្យល់ថាហេតុអ្វីអ្នកគិតថា វាគឺជាការណ៍សំខាន់ដើម្បី "ប្រយ័ត្ន" ចំពោះគំនិត ពាក្យសំដី និងសកម្មភាពរបស់យើង។

ម៉ូសាយ 5
ការប្រែក្លាយជាកូនចៅនៃព្រះគ្រីស្ត

ម៉ូសាយ 5 មានន្ទរបញ្ជីប្រវត្តិមួយអំពីការទូន្មានរបស់ស្តេចបេនយ៉ាមីន ចំពោះប្រជាជនរបស់ទ្រង់ បន្ទាប់ពីទេសនកថា ដែលមាន នៅក្នុង ម៉ូសាយ 2–4។ ចូរចងចាំថា ទេសនកថារបស់ទ្រង់ គឺត្រូវបានផ្តល់ឱ្យដើម្បីបំផុសគំនិត និងជំរុញទឹកចិត្តឱ្យធ្វើល្អ និងឱ្យក្លាយជាមនុស្សមានការគោរពប្រតិបត្តិ ទៅដល់កំរិតដ៏ខ្ពស់នៃសេចក្តីសុចរិត និងការផ្លាស់ប្តូរគំនិតដ៏ពិត (សូមមើលការណែនាំចំពោះ ម៉ូសាយ 1 នៅក្នុងសៀវភៅសិក្សាណែនាំនេះ ទំព័រ 75)។ សូមរកសូមមើលជំបូន្មានរបស់ស្តេចបេនយ៉ាមីន ដែលបានជួយធ្វើឱ្យមនុស្សផ្លាស់ប្តូរ និងពរជ័យដ៏អស្ចារ្យជាងគេ ដែលពួកគេបានទទួល នោះជាលទ្ធផលនៃការផ្លាស់ប្តូរ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 5

បំណង (ខ. 2)—ប្រាថ្នាយ៉ាងខ្លាំង

ត្រូវការ (ខ. 3)—សមរម្យ, គួរឱ្យចង់បាន

ព្រះសិរ (ខ. 8)—ព្រះនាមរបស់ព្រះគ្រីស្ត

ខ្នាប់ខ្ជួន (ខ. 15)—ពោរពេញទៅដោយ

ម៉ូសាយ 5:7—ហេតុអ្វីបានយើងត្រូវបានហៅថាជាកូនចៅរបស់ព្រះគ្រីស្ត?

ព្រះវរបិតារបស់យើង គឺជាឱពុកខាងវិញ្ញាណរបស់យើង (សូមមើល ហេព្រើរ 12:9)។ ឱពុកនៅលើលោកីយរបស់យើងនេះ គឺជាឱពុកខាងសាច់ឈាមរបស់យើង ជារូបកាយដែលអាចស្លាប់បាន។ នៅក្នុងទេសនកថាដ៏អស្ចារ្យរបស់ទ្រង់ ស្តេចបេនយ៉ាមីន បានពន្យល់ថា ដោយសារពលិកម្មដង្ហាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ត គឺជាឱពុកខាងវិញ្ញាណ នៃការចាប់កំណើត សារជា ថ្មីរបស់យើង (សូមមើល ម៉ូសាយ 3:19, 5:7)។ "ការផ្លាស់ប្តូរដ៏ធំ" ដែលចេញមកពីក្នុងចិត្តនៃប្រជាជន របស់ស្តេចបេនយ៉ាមីន គឺជាគំរូដ៏មានអំណាចក្នុងការ "កើតម្តងទៀត" (សូមមើល ម៉ូសាយ 4:2–3, 5:2, 27:24–26, យ៉ូហាន 3:5)។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ បានបង្រៀនថា ព្រះគ្រីស្ត "បានក្លាយជាឱពុកព្រោះទ្រង់បានឱ្យយើងនូវ អមតភាព ឬ ជីវិតដ៏នៅអស់ កល្បជានិច្ច តាមរយៈការសុគត និងពលិកម្មនៅលើឈើឆ្កាងរបស់ទ្រង់" (*Answers to Gospel Questions,* 4:178–79)។

ម៉ូសាយ 5:8–15—តើ "ការលើកដាក់ខ្លួននូវព្រះនាមនៃព្រះគ្រីស្ត" មានន័យដូចម្តេច?

អែលឌើរ អិម. រូសសែលិល បាឡាដ ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានពន្យល់ថាះ "តាមរយៈបុណ្យជ្រមុជទឹក យើងលើក ដាក់លើខ្លួនរបស់យើង នូវព្រះនាមនៃព្រះគ្រីស្ត និងសន្យាថាធ្វើនូវអ្វីឲ ដែលទ្រង់នឹងធ្វើ រួមទាំងការគោរពបទបញ្ញត្តិរបស់ព្រះ។ ក្នុងការឆ្លើយតបមកវិញ ព្រះអម្ចាស់សន្យាថា នឹងបញ្ជូនព្រះវិញ្ញាណរបស់ទ្រង់ ឱ្យដឹកនាំ, ពង្រឹង និងលួងលោមយើង [សូមមើល នីហ្វៃទី2 31:13, ម៉ូសាយ 18:8–10]។ ប្រហែលជា ការណ៍ដែល សំខាន់បំផុតនោះ ទ្រង់ក៏បានសន្យាផងដែរថា នឹងអភ័យ ទោសចំពោះអំពើបាបរបស់យើង នៅពេលយើងប្រែចិត្តពិតប្រាកដ [សូមមើល នីហ្វៃទី2 31:17]។ ជាក់ស្តែងណាស់ អ្នកទាំង ឡាយណាដែលចូលទៅក្នុងទឹក នៃពិធីបុណ្យជ្រមុជទឹក អំពើបាបរបស់ពួកគេត្រូវលាងសំអាត។ ពួកគេជ្រមុជចូលទៅក្នុងអាង ជ្រមុជទឹក អំពើបាបត្រូវបានលាងអស់ និងជ្រះស្អាត ដូចជាថ្ងៃដែលពួកគេទើបបានកើត" (*Our Search For Happiness* [1993], 90)។

ការលើកដាក់លើខ្លួនយើងនូវព្រះនាមរបស់ព្រះគ្រីស្ត មិនមែនគ្រាន់តែសំរាប់តែពេលមួយរយៈនោះទេ។ ប្រធាន ប៊ិយយេ ជាកកឺ ជាប្រធានស្តីទីនៃក្រុមសាវកដប់ពីរនាក់ បានមានប្រសាសន៍ថាះ "មានមនុស្សខ្លះបានឆ្ងល់ថា បើពិធីបុណ្យជ្រមុជ ទឹករបស់ពួកគេ ធ្វើឡើងឆាប់ពេក។ បើពួកគេអាចធ្វើបុណ្យជ្រមុជទឹក ហើយចាប់ផ្តើមជ្រះស្អាតតែនៅក្នុងពេលនេះ។ ប៉ុន្តែនោះវាមិនចាំបាច់ទេ! តាមរយៈពិធីការ នៃការប្រសិទ្ធិពរនំប៉ុង និងទឹក អ្នករំលឹកឡើងវិញនូវ សេចក្តីសញ្ញា ដែលអ្នកបានធ្វើនៅពិធីបុណ្យជ្រមុទឹក។ នៅពេលអ្នកបំពេញតាមលក្ខខ័ណ្ឌ នៃការប្រែចិត្តទាំងអស់ ទោះបីជាវាពិបាកក៏ដោយ ក៏អ្នកអាចត្រូវបានអភ័យទោស ហើយកំហុសរបស់អ្នក នឹងមិនធ្វើឱ្យគំនិតរបស់អ្នកច្របូកច្របល់ទៀតឡើយ" (នៅក្នុង Conference Report, ខែមេសា ឆ្នាំ1997, 10, ឬ *Ensign,* ខែឧសភា ឆ្នាំ1997, 10)។

ចូរធ្វើការកត់ចំណាំថា តើដំណឹងល្អមានភាពផ្សេងគ្នាជាយ៉ាងណា ចេញពីគំនិតរបស់លោកីយ។ វាហាក់ដូចជាកង្វល់ធម្មតា ចំពោះ មនុស្សជាច្រើនដើម្បី ស្វែងរកថាតើ "ពួកគេជានរណា។" ស្តេចបេនយ៉ាមីន បានបញ្ជាក់ថា សំនួរដ៏សំខាន់បំផុតគឺ "តើអ្នក ជា*នរណា*។" ដើម្បីលើកដាក់លើខ្លួនរបស់យើង នូវព្រះនាមនៃព្រះគ្រីស្ត មានន័យថា យើងគឺជាកូនចៅរបស់ ទ្រង់តាមរយៈសេចក្តីសញ្ញា។ នៅពេលដែល ពេលវេលារបស់យើងនៅលើលោកីយចប់ទៅ យើងនឹងអាច "ត្រូវបានហៅដោយ ព្រះនាមនៃគ្រីស្ត" (ម៉ូសាយ 5:9) ហើយជាកូនចៅនៃទ្រង់ (សូមមើល ខ 15) ឬយើង នឹង "ត្រូវបានហៅដោយឈ្មោះផ្សេងទៀត" ហើយមិនមែន ជាកូនចៅនៃព្រះគ្រីស្ត តែជាកូនចៅនៃអារក្ស (ខ 10 សូមមើល អាលម៉ា 5:38–39)។



ម៉ូសាយ 6–7

ប្រជាជនរបស់លិមហៃ រស់នៅក្រោមសេវកភាព

បន្ទាប់ពីធ្វើបញ្ជីប្រវត្តិ នៃជនទាំងឡាយណាដែលបានធ្វើសេចក្តីសញ្ញាជាមួយព្រះគ្រីស្ទ ស្តេចបេនយ៉ាមីន បានតែងតាំងបុត្រា របស់ទ្រង់ ម៉ូសាយ (ម៉ូសាយទី 2) ឱ្យគ្រប់គ្រងនគរ។ តើអ្នកគិតថា ស្តេចថ្មីនឹងធ្វើអ្វីគំរាងបំផុត នោះ? អ្នកអាចភ្ញាក់ ផ្អើលចំពោះអ្វី ដែលម៉ូសាយបានធ្វើ។ ម៉ូសាយ 7 ផ្តល់ជាការរំលឹកឡើងវិញពីអ្វីដែលបានកើតឡើង ចំពោះពួកសាសន៍នីហ្វៃ ដែលបានត្រឡប់ទៅ កាន់ដែនដីនីហ្វៃវិញ ដែលយើងអានទៅក្នុង អោមណៃ 1:27–30។ អ្នកនឹងអានរឿងនេះ យ៉ាងពិស្តារ បំផុតនៅក្នុង ម៉ូសាយ 9–22។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 6

ការចាំបាច់ (ខ. 1)—សមរម្យ, គួរឱ្យចង់បាន

ម៉ូសាយ 7

រំខាន (ខ. 1)—ការស្នើរសុំម្តងទៀត

ខិតខំ (ខ. 12)—ព្យាយាម

ក្រោមបង្គាប់ (ខ. 18, 22)—នៅក្រោមការគ្រប់គ្រងរបស់អ្នកដទៃ

ប្រសិទ្ធិភាព (ខ. 18)—ប្រសិទ្ធិភាព

មានចិត្តចង់ (ខ. 21)—ការចង់បានយ៉ាងខ្លាំង

ឧបាយកលដ៏អាក្រក់ (ខ. 21)—ប្រើមធ្យោបាយបោកបញ្ឆោត

ជួយសង្គ្រោះ (ខ. 29)—ជួយ, សង្គ្រោះ, ឧបត្ថម្ភ

ឃាំង (ខ. 29)—ចិទ

ម៉ូសាយ 7:1–6—តើដែនដីលីហៃ-នីហ្វៃ មានទំនាក់ទំនងអ្វីជាមួយនឹង ដែនដីសារ៉ាហិមឡា?

នៅគ្រាមួយ បន្ទាប់ពីស្តេចម៉ូសាយទី1 (ជាឪពុករបស់ស្តេចបេនយ៉ាមីន) បានមកដល់ដែនដីសារ៉ាហិមឡា ប្រជាជនមួយក្រុមចង់ ត្រឡប់ទៅដែនដីនីហ្វៃវិញ។ ក្រុមទីមួយ ដែលបានត្រឡប់ទៅវិញត្រូវបរាជ័យ ព្រោះតែការឈ្លោះទាស់ទែងគ្នា (សូមមើល អោមណៃ 1:27–28)។ ក្រុមទីពីរ ត្រូវបានដឹកនាំដោយសិទ្ធិពូ បានទទួលដោគជ័យក្នុង ការសាងសង់លំនៅភូមិនៅដែនដីនៃលីហៃ-នីហ្វៃ (សូមមើល អោមណៃ 1:29–30, ម៉ូសាយ 7:9, 21)។ ប្រហែលជា ហាសិបឆ្នាំក្រោយមក ស្តេចម៉ូសាយទី 2 បានបញ្ជូន ក្រុមមួយក្រោមការដឹកនាំ របស់អាំម៉ូន ដើម្បីស៊ើបសូមមើលពីអ្វី ដែលបានកើតឡើងចំពោះ ប្រជាជនរបស់សិទ្ធិពូ (សូមមើល ម៉ូសាយ 7:1–6)។ សំរាប់ពត៌មាន បន្ថែម សូមមើល "ទីតាំងដែលអាចរកបាននៅក្នុងព្រះគម្ពីរមរមន (នៅក្នុងទំនាក់ទំនងនឹងគ្នាទៅវិញទៅមក)" (ទំព័រ 212)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាម៉ូសាយ 5។

ក ពន្យល់ពីអ្វីដែលបានកើតឡើង

ម៉ូសាយ 5 បង្ហាញនូវដំហានសំខាន់ខ្លះៗ ដែលយើងទាំងអស់គ្នាត្រូវធ្វើ ដើម្បីមកកាន់ព្រះគ្រីស្ទ។

1. ចូរគូរឌីយ៉ាក្រាមមួយ ដែលស្រដៀងគ្នាដូចខាងក្រោម នៅក្នុងស្បៃវរោសរបស់អ្នក ហើយចំពេញនៅក្នុងប្រអប់ ជាមួយនឹងចំលើយ ចំពោះសំនួរទាំងនោះ។ (អ្នកនឹងត្រូវគូរប្រអប់របស់អ្នកឱ្យធំជាងនេះ។)



2. ចូរសរសេរឧទាហរណ៍ថ្មីមួយ អំពីរបៀបដើម្បីក្លាយជាបុត្រា ឬបុត្រីខាងវិញ្ញាណនៃព្រះគ្រីស្ទ ដែលមានឥទ្ធិពលចំពោះ សកម្មភាពរបស់មនុស្សពីមួយថ្ងៃទៅមួយថ្ងៃ។



ម៉ូសាយ 8

តើអ្វីទៅជាអ្នកមើលឆុត?

ក្នុងម៉ូសាយ 7 ស្តេចលិមហៃ បានពន្យល់យ៉ាងខ្លី ពីអ្វីដែលបានកើតឡើង ចំពោះប្រជាជនរបស់ទ្រង់ តាំងពីពេលដែលអប្បុកោ របស់ទ្រង់ សីទិព្វ បានដឹកនាំក្រុមអាណានិគមនីហ្គៃ ចេញពីដែនដីសារ៉ាហិមឡា ត្រលប់ទៅកាន់ដែនដីនៃលីហៃ-ទីហ្គៃ វិញ។ នៅក្នុងម៉ូសាយ 8 អាំម៉ូនបានពន្យល់ទៅកាន់លិមហៃ អំពីបញ្ហាប្រវត្តិពីបុរាណ ដែលអាចត្រូវបានបកប្រែ និងអំពីភាពខុសគ្នារវាង ព្យាការី និងអ្នកមើលឆុត។ ហេតុអ្វីបានជាលិមហៃត្រូវការនូវពត៌មាននោះ? តើជំពូកនេះជួយបង្កើន នូវសេចក្តីអំណរគុណ ចំពោះអ្នកដឹកនាំ នៃសាសនាចក្រសព្វថ្ងៃនេះយ៉ាងដូចម្តេច?

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 8

រ្បេចរាប់ឱ្យគេស្គាប់, បានរ្បេចរាប់ឱ្យគេស្គាប់ (ខ. 1–3)—និយាយម្តងទៀត, រំលឹកឡើងវិញ

បកប្រែ (ខ. 6)—បកប្រែ

ដុះស្នឹម (ខ. 11)—ដែលមានរណ្តៅ, ខ្វេចខាត

ប្រដាប់បកប្រែ (ខ. 13)—យ៉ូរីមនិងធូមីម

រាក់កំដែលមែន (ខ. 20)—រឹងរូស, មិនងាយបង្រៀន

ម៉ូសាយ 8:16—“អ្នកមើលឆុតគឺជាអ្នកទទួលវិវរណៈ ហើយជាព្យាការីផងដែរ”

យោងតាមការពិពណ៌នារបស់អាំម៉ូននៅក្នុង ម៉ូសាយ 8:13–18 យើងរ្បេចថា នៅពេលដែលព្យាការី និងអ្នកមើលឆុតទាំងពីរ ទាក់ប្រកាសបន្ទូលរបស់ព្រះ អ្នកមើលឆុតមានន័យថា ជាអ្នកទទួលវិវរណៈមកពីព្រះ ដែលមិនអាចរកបានចំពោះ ព្យាការីត្រប់ រូបនោះទេ (សូមមើល ខ 13)។ លោកមិនត្រឹមតែអាចសូមមើលឃើញពីអនាគតទេ តែក៏អាចមើលឃើញ ពីអតីតកាល និងរឿងលាក់ កំពុងផងដែរ ដោយពន្លឺនៃទេវភាព (សូមមើល ខ 17)។ អ្នកមើលឆុត “មើលឃើញ” ដោយអំណាចរបស់ព្រះ ដែលមិនអាចសូមមើល ឃើញដោយភ្នែកទទេ (សូមមើល ម៉ូសេ 6:35–36)។ នៅរាល់ពេល ដែលយើងគាំទ្រអ្នកដឹកនាំ នៃសាសនាចក្រនៅក្នុងសន្និសិទទូទៅ យើងទទួលស្គាល់គណៈប្រធានទីមួយ នៃសាសនាចក្រ និងក្រុមសាវកដប់ពីរនាក់ ជាព្យាការី ជាអ្នកមើលឆុត និងជាអ្នកទទួលវិវរណៈ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សាម៉ូសាយ 6–7។

ក សរសេរបញ្ជីប្រវត្តិរបស់អ្នកផ្ទាល់

ស្តេចបេនយ៉ាមីនបានសុំឱ្យធ្វើបញ្ជីប្រវត្តិ ចំពោះអ្នកទាំងឡាយណាដែលចុះសេចក្តីសញ្ញា ដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូសាយ 6:1)។ សព្វថ្ងៃនេះនៅក្នុងសាសនាចក្រ យើងក៏រក្សាបញ្ជីប្រវត្តិផងដែរ។ រាល់សមាជិក នៃសាសនាចក្រ មានបញ្ជី ប្រវត្តិមួយ ដែលបង្ហាញអំពីទំនាក់ទំនងនៃគ្រួសារ និងកាលបរិច្ឆេទសំខាន់ៗ។ ក៏ដូចជាប្រជាជន នៃស្តេច បេនយ៉ាមីន ឈ្មោះរបស់ អ្នកត្រូវបានកត់ត្រា ជាម្នាក់ដែលបានចុះកិច្ចសន្យាជាមួយនឹងព្រះគ្រីស្ទ។ ចូរសរសេរព្រឹត្តិការណ៍សំខាន់ មួយចំនួន ដែលមាន ហើយនឹងអាចកើតមានឡើងនៅក្នុងជីវិតរបស់អ្នក។ ចំពោះព្រឹត្តិការណ៍ទាំងនោះ ដែលបានកើតរួចទៅហើយ សូមសរសេរ កាលបរិច្ឆេទផងដែរ។

ខ សរសេរសំបុត្រ

ឧទាហរណ៍ថា អ្នកបានរស់នៅក្នុងសម័យរបស់លិមហៃ ហើយអ្នកមានសមាជិកក្នុងគ្រួសារមានជម្ងឺ និងមិនអាចស្តាប់ឮការនិយាយ របស់លិមហៃ ទៅកាន់ប្រជាជនរបស់លោក។ សូមសិក្សា ម៉ូសាយ 7:17–33 ហើយបន្ទាប់មកសរសេរសំបុត្រមួយច្បាប់ ទៅកាន់ គ្រួសាររបស់អ្នក ដោយប្រាប់ឱ្យបានច្បាស់លាស់អំពីគោលការណ៍សំខាន់ៗ ដែលលិមហៃបានបង្រៀន។ សូមប្រាកដថា អ្នកពន្យល់ដូចខាងក្រោមនេះ:

1. ហេតុអ្វីពួកគេគួរតែ “បានការក្សាន្តចិត្ត” (ខ. 18)
2. ហេតុអ្វីពួកសាសន៍លេមិនទុកឱ្យប្រជាជនត្រឡប់ទៅកាន់ដែនដីលីហៃ-ទីហ្គៃ វិញដូច្នេះ
3. មូលហេតុពិតប្រាកដ ចំពោះបញ្ហានៅពេលបច្ចុប្បន្ន
4. តើប្រជាជនត្រូវធ្វើអ្វីខ្លះ ដើម្បីបានរួចផុត

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 8។

ក ផ្ទើសារលិខិត និងផែនទីមួយ

លិមហៃបានប្រាប់អាំម៉ូនឱ្យទៅស្វែងរក ក្រុមដែលត្រូវបានបញ្ជូនឱ្យទៅទិសខាងជើង ដើម្បីស្វែងរកដែនដីសាវ៉ាហិមឡា។ ពួកគេ មិនបានរកឃើញដែនដីសាវ៉ាហិមឡាទេ ហើយបែរជាបានរកឃើញដែនដី នៃសាសន៍យ៉ារេឌទៅវិញ (ត្រូវបានហៅថា ជាដែនដី នៃទិសខាងជើង ឬដែនដីដែលស្ងប់ស្ងាត់ ផងដែរ)។

1. នៅក្នុងស្បៀវភៅសរសេររបស់អ្នក សូមគូសផែនទីមួយ ដូចនឹងផែនទីដែលនៅក្នុងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ ម៉ូសាយ 7:1–6 ហើយបន្ថែមបន្ទាត់សំរាប់ធ្វើជាផ្លូវថ្មល់ ដែលក្រុមនៃអ្នកស៊ើបអង្កេតនេះអាចធ្វើដំណើរ (សូមមើល ផែនទីផងដែរ ទំព័រ 80)។
2. ឧទាហរណ៍ថា អ្នកគឺជាអ្នកដឹកនាំនៃក្រុមនោះ។ សូមសិក្សាម៉ូសាយ 8:7–11 ហើយសរសេរជាសារលិខិតមួយ ដែលមានពិពណ៌នាពីអ្វីដែល អ្នកបានរកឃើញនៅទីនោះ។

ខ ប្រាប់ថា វាមានអត្ថន័យអ្វីសព្វថ្ងៃនេះ

1. សូមសិក្សាម៉ូសាយ 8:13–18 ហើយពិពណ៌នាអំពីអំណោយ ដែលស្តេចម៉ូសាយមាន ក្នុងនាមជាអ្នកមើលឆុតម្មាក់ ដែល ធ្វើឱ្យទ្រង់មិនត្រឹមតែជាព្យាការីទេ (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ម៉ូសាយ 8:16 សំរាប់ជាជំនួយបន្ថែម)។
2. សូមរំលឹកឡើងវិញនូវសារលិខិតថ្មីៗ ដែលយើងបានទទួលពីព្យាការីសម័យថ្មីរបស់យើងជាអ្នកមើលឆុត និងជាអ្នកទទួល វិវរណៈ (ចេញពីសន្ទរកថានៃសន្និសីទ, ទស្សនាវដ្តីសាសនាចក្រ និងអត្តបទ ឬធនធានផ្សេងឲ្យទៀតដែលអ្នកអាចរកបាន) រួចពិពណ៌នាអំពីសេចក្តីពិត និងសេចក្តីអន្តរាយខ្លះៗ ដែលពួកគេ "ឃើញ" ថាមនុស្សភាគច្រើនៅក្នុងពិភពលោក មិនអាចមើល ឃើញ។

ម៉ូសាយ 9–10
ការចាប់ផ្តើមនៃបញ្ជីប្រវត្តិរបស់ស៊ីនិព្វ

ចូរចងចាំថា នៅពេលអ្នកអាន ម៉ូសាយ 9–24 មានក្រុមពីរ ហើយពេលខ្លះ មានក្រុមបី បានបំបែកចេញពីសាសន៍នីហ្វៃ ដែលរស់នៅលើផ្នែកផ្សេងនៃ ដែនដី (សូមមើល រូបភាពដែលបង្ហាញ និងតារាងបរិច្ឆេទ នៃព្រះគម្ពីរមរមន នៅទំព័រ 213)។

ចងចាំថា ម៉ូសាយទីមួយ ត្រូវបានព្រមានដោយព្រះអម្ចាស់ ឱ្យដឹកនាំមនុស្ស សុចរិតដែលនឹងធ្វើតាមទ្រង់ "ភៀសខ្លួនចេញពីដែន ដីនីហ្វៃ" (អោមណៃ 1:12)។ ទ្រង់ និងប្រជាជនរបស់ទ្រង់ បានរកឃើញក្រុមប្រជាជនផ្សេងទៀត ដែលរស់នៅក្នុង ដែនដីមួយ ដែលពួកគេហៅថា ដែនដីសាវ៉ាហិមឡា។ នៅទីបំផុតទ្រង់បានក្លាយជាស្តេច នៅលើការប្រមូលផ្តុំ នៃក្រុមប្រជាជនសាសន៍នីហ្វៃ និងប្រជាជននៃដែនដីសាវ៉ាហិមឡា។ ម៉ូសាយទីមួយ ក្រោយមកមានបុត្រារបស់ទ្រង់ បេនយ៉ាមីន និងចៅប្រុសរស់ទ្រង់ ម៉ូសាយ ទីពីរ។

នៅពេលខ្លះ បន្ទាប់ពីម៉ូសាយទីមួយ បានមកដល់ដែនដីសាវ៉ាហិមឡា ស៊ីនិព្វ បានដឹកនាំក្រុមប្រជាជនសាសន៍នីហ្វៃមួយ ឱ្យត្រឡប់ ទៅកាន់ដែនដីនីហ្វៃវិញ (សូមមើល អោមណៃ 1:27–30, ម៉ូសាយ 7:21)។ នៅទីនោះទ្រង់បានបង្កើតឱ្យ មានអណានិគមក្នុង ចំណោមសាសន៍លេមិន និងបានក្លាយជាស្តេចរបស់ពួកគេ។ ម៉ូសាយ 9–22 គឺត្រូវបានយកចេញពីបញ្ជីប្រវត្តិ របស់ស៊ីនិព្វ។ ដំណើររឿងនោះគ្រប់គ្រងរយៈពេលហាសិបឆ្នាំ និងរួមទាំងដំណើររឿងនៃអ្នកទទួលជោគជ័យរបស់ស៊ីនិព្វះ កូនប្រុសរបស់ស្តេច ណូអេ និងចៅប្រុសរបស់របស់ទ្រង់ លិមហៃ។ អ្នកនឹងអានផងដែរ អំពីអ័ប៊ីណាដៃ និងអាលម៉ាជាឱពុក ដែលជាព្យាការីពីររូប ដ៏អស្ចារ្យ ដែល បេសកកម្មបានចាប់ផ្តើម ហើយត្រូវបញ្ចប់ទៅវិញដោយពិបាកយ៉ាងខ្លាំង។



ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 9

ដែនដីនៃកេរ៉ឹអាករដំបូង (ខ 1)—កន្លែងដំបូងដែលពួកគេតាំងលំនៅ បន្ទាប់ពីមកដល់ទ្វីបអាមេរិក

មនុស្សយោរយៅ (ខ 2)—គឹងតែង, គឹង

មានចិត្តចង់បាន (ខ 3)—ដែលមានចិត្តចង់បានជាខ្លាំង

រង់ទុក្ខ (ខ.3)—ទណ្ឌកម្ម, រងទុក្ខលំបាក

គំនិត (ខ.5)—អត្តចរិត, សេចក្តីប៉ងប្រាថ្នា

ខ្លាំងពូកែ (ខ.11)—លូតលាស់, ប្រែក្លាយ

លោភលន់ (ខ.12)—ពោរពេញ

សោកសៅ (ខ.19)—សេចក្តីសោកសៅយ៉ាងអស្ចារ្យ

ម៉ូសាយ 10

ក្រវាត់ខ្សែនៅចង្កេះ (ខ. 8)—ខ្សែក្រវាត់ស្បែកវែង

ចង្កេះ (ខ. 8)—ចង្កេះ

ខឹង (ខ. 14)—ខឹងយ៉ាងខ្លាំង

លើកទឹកចិត្ត (ខ. 19)—លើកទឹកចិត្ត, ជម្រុញ

ម៉ូសាយ 10:11–18—ត្រោះថ្នាក់នៃទំនៀមទំលាប់ខុសឆ្គង

ពួកសាសន៍លេមិនបានបង្រៀនកូនចៅរបស់ពួកគេអំពី "សម្ពប់ដ៏អស់កល្ប" ចំពោះពួកសាសន៍នីហ្ហៃ ពីព្រោះទំនៀមទំលាប់ខុសឆ្គង ដែលពួកគេបានរៀនពីជីដូនជីតារបស់ពួកគេ (សូមមើល ម៉ូសាយ 10:13–17)។ ម៉ូសាយ 10:11–18 បានបង្ហាញនូវសេចក្តីពិត នៃវិវរណៈដូចខាងក្រោម ដែលបានផ្តល់ទៅដល់ព្យាការី យ៉ូសែប ស្មីធ៖ ហើយអាកំណាចនេះមក ហើយយកពន្លឺ និងសេចក្តីពិត ដោយសារការមិនគោរពតាម ចេញពីកូនចៅមនុស្ស និងពីព្រោះតែទំនៀមទំលាប់នៃពួកអយ្យកោរបស់ពួកគេ (សូមមើល គ និង ស 93:39)។

អែលឌើរ រីជឆ៉ឌ ជេ. ស្កត់ ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានបង្រៀនពីរបៀបដែលយើងអាច ជៀសវាងពីការបាត់បង់ពន្លឺ នៃដំណឹងល្អ ពីព្រោះតែមកពីទំនៀមទំលាប់ខុសឆ្គងៈ

"សូមសិក្សាព្រះគម្ពីរ និងប្រឹក្សានៃព្យាការី ដោយយកចិត្តទុកដាក់ ដើម្បីយល់ពីរបៀបដែលព្រះអម្ចាស់ចង់ឱ្យអ្នករស់នៅ។ បន្ទាប់មកវាយតំលៃនៅរាល់ផ្នែកនីមួយៗ នៃជីវិតរបស់អ្នក ហើយធ្វើការកែខៃតាមសេចក្តីត្រូវការ។ ចូរស្វែងរកជំនួយពីអ្នកដទៃ ដែលអ្នកគោរព ដែលជាអ្នកមានលទ្ធភាព ដើម្បីបោះបង់ចោលនូវជំនឿសឹប់ ឬទំនៀមទំលាប់ខ្លះៗ ដែលខុស ពីផែនការណ៍ នៃ ព្រះអម្ចាស់។ នៅពេលមានការសង្ស័យ ចូរសួរខ្លួនរបស់អ្នកថា់ តើនេះជាអ្វីដែល ព្រះអង្គសង្គ្រោះចង់ឱ្យខ្ញុំធ្វើឬ? . . .

"ខ្ញុំសូមធ្វើទីបន្ទាល់ថា អ្នកនឹងប្តូរទីដែលមានឧបសគ្គ ឆ្ពោះទៅរកសុភមង្គល ហើយស្វែងរកសេចក្តីសុខសាន្ត ដ៏មហិមាជាង នៅពេល ដែលអ្នកមានស្វាមីភក្តិជាដំបូង ចំពោះសមាជិកភាពរបស់អ្នក នៅក្នុងសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់ ដែលជាគ្រឹះ នៅក្នុងជីវិតរបស់អ្នក។ ពេលណាដែលគ្រួសារ ឬទំនៀមទំលាប់ជាតិសាសន៍ ឬប្រពៃណី ប្រឆាំងនឹង ការបង្រៀន របស់ ព្រះ ចូរទុកវាមួយឡែកសិន។ នៅ កន្លែងណា ដែលគ្រួសារ និងប្រពៃណីស៊ីគ្នាជាមួយនឹង ការបង្រៀនរបស់ទ្រង់ ពួកគេគួរតែមាន សេចក្តីមាន អំណរ និងធ្វើតាម ដើម្បីរក្សានូវវប្បធម៌ និងមរតករបស់អ្នក។ មានមរតកមួយ ដែលអ្នកមិនត្រូវការ ផ្លាស់ប្តូរឡើយ ។ វាគឺជាមរតកដែលមកពីការធ្វើជាបុត្រី ឬបុត្រារបស់ព្រះវរបិតានៅស្ថានសួគ៌។ ព្រោះសុភមង្គលនឹងគ្រប់គ្រងជីវិតរបស់អ្នកដោយ មរតកនោះ" (នៅក្នុង Conference Report, ខែមេសា ឆ្នាំ1998, 112, 114 ឬ *Ensign,* ខែឧសភា ឆ្នាំ1998, 86–87)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 9–10។

ក ចូរមក ស្តាប់តាមសំលេងនៃព្យាការី

រៀងនៅក្នុងម៉ូសាយ 9 ឆ្លើយនឹងសំនួរថ្មីបំផុតមួយៈ តើវាមានប្រយោជន៍អ្វី ក្នុងការមានព្យាការីនៅរស់ សំរាប់យើង បើយើងមិនស្តាប់ចំពោះអ្វីដែលលោកបានមានប្រសាសន៍ផងនោះ?

1. ចូររំលឹកអោមណៃ 1:12–13 សារឡើងវិញ ហើយពន្យល់ថា តើនរណាបានដឹកនាំសាសន៍ នីហ្ហៃ ចេញពីដែនដីនៃនីហ្ហៃទៅកាន់ ដែនដីសាវ៉ាហិមឡា ហើយ*ហេតុអ្វី*។
2. ចូររំលឹក ម៉ូសាយ 9:1–3 សារឡើងវិញ ហើយពិពណ៌នាថា តើនរណាបានដឹកនាំក្រុម នៃសាសន៍នីហ្ហៃទាំងនេះ ត្រឡប់ទៅកាន់ដែនដីនីហ្ហៃវិញ ហើយ*ហេតុអ្វី*។
3. សូមសិក្សាម៉ូសាយ 9:4–19 ហើយសង្ខេបពីអ្វីដែលបានកើតឡើង ចំពោះសាសន៍នីហ្ហៃ ដែលបានត្រឡប់ទៅកាន់ដែនដី នីហ្ហៃវិញ។
4. តើបទពិសោធន៍របស់ពួកគេជាមួយនឹងសាសន៍លេមិន បង្រៀនអ្នកអ្វីខ្លះ អំពីមូលហេតុ ដែលព្រះអម្ចាស់បានប្រាប់ពួកគេឱ្យ ចាកចេញតាំងពីដើម?
5. ចូរពិពណ៌នាពីការផ្លាស់ប្តូរ ដែលបានកើតឡើងចំពោះមនុស្សទាំងនេះ ពីម៉ូសាយ 9:3 ទៅ ម៉ូសាយ 17–19 ហើយពិពណ៌នាពី របៀប ដែលផ្លាស់ប្តូរនោះបានជួយសង្គ្រោះពួកគេ។
6. ប្រជាជនរបស់សឺនិញ បានរៀនមេរៀនសំខាន់នោះ តែពួកគេគួរតែអាចជៀសវាងពីសង្គ្រាម ហើយសង្គ្រោះជីវិតជាច្រើន បើ ពួកគេគ្រាន់តែធ្វើតាមព្យាការីរបស់ពួកគេ ម៉ូសាយទីមួយ ហើយស្នាក់នៅក្នុងដែនដីសាវ៉ាហិមឡា។ ចូរគិតអំពីការប្រឹក្សា ដែល អ្នកបានលឺ មកពីព្យាការីនៅរស់ បានឱ្យដល់សាសនាចក្រក្នុងពេលថ្មីៗនេះ។ ចូរសរសេរគោលការណ៍បី ដែលព្យាការីបានបង្រៀន ដល់យើងឱ្យធ្វើ និងពិពណ៌នា ពីបញ្ហាដែលអ្នកគិតថា អ្នកអាចជៀសវាងបាន បើ អ្នកធ្វើតាមពាក្យប្រឹក្សារបស់លោក។

ខ អនុវត្តពាក្យទូន្មានរបស់ព្រះអម្ចាស់ នៅក្នុងជីវិតរបស់អ្នកផ្ទាល់

ម៉ូសាយ 10:11–18 មានចុះបញ្ជីអំពីចំនួន នៃទំនៀមទំលាប់ខុសឆ្គង (ជំនឿ) របស់សាសន៍លេមិន ដែលត្រូវបានបង្រៀន ដល់កូនចៅរបស់ពួកគេ និងបង្កើនទូវការស្អប់របស់ពួកគេឆ្ពោះទៅកាន់សាសន៍នីហ្ហៃ។

1. ចំពោះព្រឹត្តិការណ៍នីមួយៗ ដូចខាងក្រោម មានពិពណ៌នាពីជំនឿខុសឆ្គង ឬការបកប្រែរបស់សាសន៍លេមិន និងបន្ទាប់មកពន្យល់ ពីអ្វីដែលពិតជាបានកើតឡើងៈ
   ក. ការចាកចេញពីទីក្រុងយេរូសាឡិម
   ខ. ការឆ្លងកាត់សមុទ្រ
   គ. ការមកដល់ដែនដីសន្យា (ឬដែនដីជាកេរ្តឺ៍មរតកតំបូងរបស់ពួកគេ)
   ឃ. នីហ្ហៃ និងពួកអ្នកស្មោះត្រង់ទាំងអស់ រត់គេចចេញពីលេមិន និងលេមយួល ទៅក្នុងទីរហោស្ថាន
2. ចូររំលឹកសេចក្តីថ្លែងរបស់អែលឌើរ ស្កត ឡើងវិញនៅក្នុងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ម៉ូសាយ 10:11–13។ ចូរពន្យល់ ពីអ្វី ដែលអ្នកត្រូវតែធ្វើ ដើម្បីបញ្ជាក់ពីប្រពៃណី ឬទំនៀមទំលាប់ទាំងឡាយ ចេញពីវប្បធម៌ ឬសញ្ជាតិ របស់អ្នក ដែលមិនស៊ីគ្នា ជាមួយនឹងដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ។

ម៉ូសាយ 11–12

ស្តេចទុច្ចរិត ណូអេ និងព្យាការីអ័ប៊ីណាដៃ

តើមានភាពខុសគ្នាអ្វីខ្លះ នៅពេលដែលមានអ្នកដឹកនាំសុចរិត? ចូរគិតអំពីអ្វីដែលបានកើតឡើង ចំពោះប្រជាជនសុចរិតរបស់ ស្តេចបេនយ៉ាមីន នៅក្នុង ម៉ូសាយ 1–5។ តើអ្នកគិតថា មានអ្វីបានកើតឡើង ចំពោះប្រជាជនរបស់

សិនិព្វ នៅពេលស្តេច ទុច្ចរិតណូអេ បានគ្រប់គ្រងពួកគេ? នៅពេលអ្នកអាន ម៉ូសាយ 11–12 ចូរធ្វើការកត់ចំណាំម្តងទៀត ពីអត្តចរិត និងសកម្មភាព នៃអ្នកដឹកនាំ ដែលមានឥទ្ធិពលចំពោះជីវិតរបស់ប្រជាជនដ៏យ៉ាងណា។ សូមមើលផងដែរ ចំពោះឥទ្ធិពល នៃទីបន្ទាល់ដ៏ ក្លាហានរបស់អ័ប៊ីណាដៃ ដែលមានចំពោះប្រជាជននេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 11

ប្រគល់ឱ្យ (ខ. 1)—បានឱ្យ, បានអនុញ្ញាតឱ្យ

ស្រីស្នំ (ខ. 2)—ប្រពន្ធស្របច្បាប់ដែលមានឋានៈទាបនៅក្នុងសង្គម និងមានសិទ្ធិតិចជាងប្រពន្ធធម្មតា

សហាយស្មន់ (ខ. 2, 6)—អំពើបាបខាងផ្លូវភេទ

សត្វ (ខ. 3)—សត្វដែលនៅតូចល្អដែលយកមកសំលាប់

ភ្ជាយទៅជាអ្នកថ្វាយបង្គំរូបព្រះ (ខ. 7)—បានចាប់ផ្តើមថ្វាយបង្គំរូបព្រះក្លែងក្លាយ

បង្អែក (ខ. 11)—ជញ្ជាំងកំពស់ដើមទ្រូង

កន្លែងសំណាក់ (ខ. 13)—កន្លែងសំរាប់ស្មាក់នៅ

ស្រីពេស្យា (ខ. 14)—ស្ត្រីដែលគ្មានសីលធម៌

អ្នកប្រមឹក (ខ. 15)—អ្នកដែលផឹកស្រាហួសកំណត់, មនុស្សប្រមឹក

ខឹង (ខ. 26–27)—ខឹងយ៉ាងខ្លាំង

ម៉ូសាយ 11:2—ស្តេចណូអេ "មានប្រពន្ធ និងស្រីស្នំជាច្រើន"

នៅសម័យនេះ ព្រះអម្ចាស់បានហាមមិនឱ្យអនុវត្តក្នុងការមានប្រពន្ធច្រើនជាងមួយ និងការយកស្រីស្នំជាច្រើនឡើយ (សូមមើល វត្ត "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ យ៉ាកុប 2:23–30 ទំព័រ 63)។

ម៉ូសាយ 12

ដោយអំណត់អត់ ដោយជំងឺអាសន្នរោគ (ខ. 4)—ដោយការអត់ឃ្លាន និងជំងឺ

ជាប់ (ខ. 5)—ចង

គ (ខ. 5)—មិនអាចនិយាយបាន

បង្ហាញនូវ (ខ. 8)—បើកសម្តែង, ការធ្វើអ្វីមួយនៅក្នុងទីសាធារណៈ

និយាយខុស (ខ. 19)—ឱ្យគាត់និយាយជំទាស់ខ្លួនគាត់

បំភាន់ពួកគេ (ខ. 19)—ធ្វើឱ្យពួកគេច្របូកច្របល់

បង្ខូចផ្លូវ, បានបង្ខូចផ្លូវ (ខ. 26)—ការផ្លាស់ប្តូរ, ភាពពុករលួយ

ម៉ូសាយ 12:31–32 "តើសេចក្តីសង្គ្រោះបានមកដោយសារក្រិត្យវិន័យ លោកម៉ូសេឬ?"

អ័ប៊ីណាដៃបានសួរដល់ពួកសង្ឃទុច្ចរិតរបស់ស្តេចណូអេ បើសិនជាសេចក្តីសង្គ្រោះបានមក "ដោយសារក្រិត្យវិន័យលោកម៉ូសេ" (ម៉ូសាយ 21:31)។ ពួកគេបានឆ្លើយថា មនុស្សម្នាក់អាចត្រូវបានសង្គ្រោះ ដោយសារការរស់នៅតាមក្រិត្យវិន័យលោកម៉ូសេ។ ចំលើយនោះ ទោះបីដាយ៉ាងណាក៏ដោយ គឺគ្រាន់តែជាសេចក្តីពិតតែមួយផ្នែកប៉ុណ្ណោះ។ អ័ប៊ីណាដៃ បានឱ្យចំលើយយ៉ាងពេញលេញជាងនេះ នៅក្នុងម៉ូសាយ 13:27–35។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ដូចខាងក្រោម នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 11–12។

ក បំពេញក្នុងបញ្ជី

1. ចូរស្វែងរកពាក្យ នៅក្នុងម៉ូសាយ 11:1–15 នៅខាងក្រោមនេះ ហើយបន្ទាប់មកសរសេរប្រយោគសំរាប់ពាក្យនីមួយៗ ដោយមានការពន្យល់ពីរបៀបដែល ទង្វើត្រូវបានផ្លាស់ប្តូរ នៅពេលណូអេមានអំណាចៈ

ក. បទបញ្ញត្តិ	ច. អ្នកថ្វាយបង្គំរូបព្រះ
ខ. ប្រពន្ធ	ឆ. អាគារ
គ. អំពើបាប	ជ. ប៉ម
ឃ. មួយភាគដប់	ឈ. ការរស់នៅដោយអាយុមុខ
ង. ពួកសង្ឃ	ញ. ស្រា

2. ចូរធ្វើបញ្ជីពីភាពខុសគ្នាខ្លះៗ រវាងស្តេចណូអេ និងស្តេចបេនយ៉ាមីន ជាមនុស្ស ដែលអ្នកបានអានទៅក្នុងម៉ូសាយ 1–2។ តើស្តេចមួយណាដែលអ្នកចង់ឱ្យធ្វើជាអ្នកដឹកនាំរបស់អ្នក? ហេតុអ្វី?

ខ ប្រៀបធៀបការព្យាករណ៍

ព្រះអម្ចាស់បានហៅអ័ប៊ីណាដៃ ឱ្យព្រមានដល់ស្តេចណូអេ និងប្រជាជនរបស់ទ្រង់ឱ្យប្រែចិត្ត ឬត្រូវទទួលរងនូវការដាក់ទណ្ឌកម្ម។

1. សូមស្រាវជ្រាវម៉ូសាយ 11:20–25 ហើយស្វែងរកឃ្លា "លើកលែងតែគេប្រែចិត្ត" និង "លើកលែងតែប្រជារាស្ត្រនេះ ប្រែចិត្ត។" ចូរធ្វើបញ្ជីទណ្ឌកម្មចំនួនបួន ដែលអ័ប៊ីណាដៃ បានឱ្យដែលនឹងមានមករលើប្រជាជន បើពួកគេមិនប្រែចិត្ត។
2. តើស្តេចណូអេ និងប្រជារាស្ត្ររបស់ទ្រង់បានធ្វើអ្វីខ្លះ នៅពេលពួកគេបានឮសារដំណឹងរបស់អ័ប៊ីណាដៃ? (សូមមើល ម៉ូសាយ 11:26–29)។
3. នៅក្នុងម៉ូសាយ 12 យើងអានថា ពីរឆ្នាំក្រោយមក ព្រះអម្ចាស់ បានបញ្ជូនអ័ប៊ីណាដៃមកម្តងទៀត ដើម្បីព្យាករដល់ប្រជាជន។ ចូរស្រាវជ្រាវម៉ូសាយ 12:1–7 សំរាប់ពាក្យថា *នឹង* និង *នឹង* បន្ទាប់មកសរសេរពីអ្វីដែលអ័ប៊ីណាដៃបាននិយាយ *អាច* តើគេឡើងចំពោះប្រជាជនទាំងនោះ។
4. តើពាក្យ *នឹង* និង *នឹង* ធ្វើឱ្យការព្យាករណ៍ជាលើកទីពីររបស់អ័ប៊ីណាដៃ ខុសពីការព្រមានជាលើកទីមួយរបស់លោក នៅក្នុងម៉ូសាយ 11:20–25 ដូចម្តេចខ្លះ?
5. សូមអានម៉ូសាយ 12:8 ហើយពន្យល់ពីអ្វីដែលព្រះអម្ចាស់ បន្ទាប់មកបានត្រាប់ អ័ប៊ីណាដៃ ពីអ្វីដែលអាចកើតឡើង ចំពោះ ប្រជាជន នៅពេលនោះ "លើកលែងតែគេប្រែចិត្ត។"

គ ស្វែងរកការអនុវត្តសំរាប់សម័យថ្មី

នៅក្នុងម៉ូសាយ 12:9–37 អ្នកអានអំពីការចាប់ខ្លួនរបស់អ័ប៊ីណាដៃ និងការចាប់ផ្តើមទទួរការសាកសួររបស់លោក នៅពីមុខស្តេច ណូអេ និងពួកសង្ឃរបស់ទ្រង់។

1. សូមរំលឹក ខទី 9–16 សារឡើងវិញ ហើយពន្យល់ ពីអ្វីដែលអ្នកគិតថា ជាមូលហេតុពិតប្រាកដដែលជាកំហឹងរបស់ប្រជាជន មានអារម្មណ៍ប្រឆាំងនឹងអ័ប៊ីណាដៃ។ តើអ្វីទាំងនេះអាចអនុវត្តនៅក្នុងសម័យរបស់យើងយ៉ាងដូចម្តេច នៅពេលសមាជិកអាច បញ្ហាក្នុងការទទួលយកការប្រឹក្សារបស់ព្យាការីដែលបានឱ្យមកនោះ?
2. តើមូលហេតុអ្វីដែលអ័ប៊ីណាដៃបានឱ្យ នៅក្នុងម៉ូសាយ 12:27 ទៅដល់ពួកសង្ឃមិនយល់ពីខគម្ពីរទាំងនោះ? សូមអាន ផងដែរ នៅក្នុង កូរិនថូសទី 1 2:11–14 ហើយពន្យល់ពីអ្វី ដែលខគម្ពីរទាំងពីរនោះ បង្រៀនអំពីការធ្វើឱ្យការសិក្សាព្រះគម្ពីររបស់ អ្នកជាការសិក្សាដ៏ប្រសើរបំផុត។



នៅពេលដែលព្រះអម្ចាស់ចាត់តាំងដល់យើង ទ្រង់ក៏ឱ្យយើងនូវអំណាចដើម្បីបំពេញវាផងដែរ (សូមមើល ទីម៉ូថេ ទី 1 3:7)។ ការចាត់តាំងរបស់អ័ប៊ីណាដៃគឺដើម្បីឱ្យហោស្តេចណូអេ និងប្រជាជនរបស់ទ្រង់ប្រែចិត្ត។ នៅក្នុងម៉ូសាយ 13–14 អ្នកនឹងអាន អំពីវិធីដ៏អស្ចារ្យ ដែលព្រះអម្ចាស់បានជួយដល់អ័ប៊ីណាដៃដើម្បីបំពេញការចាត់តាំងនោះ។ នៅពេលអ្នកអាន ទីបន្ទាល់ដ៏ម៉ឺងម៉ាត់របស់លោក ចូរនឹកគិតថា អ័ប៊ីណាដៃ កំពុងបង្រៀនរឿងទាំងនេះ ទៅកាន់អ្នកដឹកនាំនយោបាយដ៏មានអំណាចនៅសព្វថ្ងៃនេះ។ តើអ្នកមានអារម្មណ៍ថា អ្នកដឹកនាំទាំងនោះ នឹងប្រព្រឹត្តចំពោះអ័ប៊ីណាដៃយ៉ាងដូចម្តេច?

នៅក្នុងម៉ូសាយ 14 យើងអានថា អ័ប៊ីណាដៃបានដកស្រង់ អេសាយ 53 ដែលពិណិតាអំពីថ្លៃដែលព្រះគ្រីស្ទ និងបង់សំរាប់អំពើ បាបរបស់យើង និងតើមនុស្សមិនជឿគុណចំពោះអំណោយនេះដាយ៉ាងណា។ ហេតុអ្វីអ្នកគិតថា អ័ប៊ីណាដៃជ្រើសរើសយកជំពូក នោះមកដកស្រង់ជ្រាប់ដល់សង្ឃទុច្ចរិតទាំងនោះដូច្នេះ?

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 13

មនុស្សឆ្កួត (ខ 1, 4)—មនុស្សឆ្កួត

ហ៊ាន (ខ. 5)—ហ៊ាន

បរិសុទ្ធ (ខ. 19)—ធ្វើឱ្យបរិសុទ្ធ ឬពិសិដ្ឋ

លោភចង់ (ខ. 24)—មាន
សេចក្តីប៉ងត្រាថ្នាហួសប្រមាណ ឬអត្មានិយម

ចាំបាច់ (ខ. 27)—សំខាន់, ដែលចាំបាច់

ក្រឹត្យវិន័យនៃពិធីប្រព្រឹត្ត (ខ. 30)—
ក្បួនវិន័យ និងពិធីការនៃក្រឹត្យវិន័យម៉ូសេ

ម៉ូសាយ 13:10—"ជាគំរូ ហើយជាស្រមោលអំពីអ្វី ដែលនឹងកើតឡើងនៅថ្ងៃក្រោយ"

ជាគំរូ ហើយជាស្រមោល គឺជានិមិត្តសញ្ញា និងជាការរំលឹក ដែលបង្រៀន និងថ្លែងទីបន្ទាល់ពីសេចក្តីពិតដ៏អស្ចារ្យ (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" នៃម៉ូសាយ 3:15 ទំព័រ 77)។ អ័ប៊ីណាដៃបានត្រាមានស្តេចណូអេ និងសង្ឃរបស់ទ្រង់ថា អ្វីដែលពួកគេ ជ្រើសរើសធ្វើចំពោះគាត់ នឹងជា "គំរូ" ឬនិមិត្តសញ្ញាពីអ្វីដែលនឹងកើតឡើងចំពោះពួកគេនិងអ្នកផ្សេងទៀតវិញ។ អ្នកនឹងអានអំពីការសំរេចនៃការព្យាករណ៍នេះ នៅពេលក្រោយនៅក្នុងម៉ូសាយ 19 និងអាលម៉ា 25។

ម៉ូសាយ 13:27–28—"សេចក្តីសង្គ្រោះពុំបានមក ដោយសារក្រឹត្យវិន័យ តែប៉ុណ្ណោះទេ"

នៅក្នុងម៉ូសាយ 13:27–28 អ័ប៊ីណាដៃបានកែគំរូនូវតំនិតខុសឆ្គង ដែលបានបង្ហាញដោយស្តេចណូអេ និងពួកសង្ឃ របស់ស្តេចណូអេ (សូមមើល ម៉ូសាយ 12:31–32)។ គាត់បានបង្រៀនថា ដោយការគោរពតាមតែច្បាប់របស់ម៉ូសេ តែប៉ុណ្ណោះ មិនអាចនាំពួកគេទទួលសេចក្តីសង្គ្រោះទេ។ ពួកគេទាំងអស់គ្នាត្រូវការព្រះអង្គសង្គ្រោះ ដើម្បីឱ្យរួច (បង់ថ្លៃ) សំរាប់ អំពើបាប របស់ពួកគេ ឬ "ពួកគេនឹងពុំផ្សៀវផុតពីសេចក្តីវិនាស ទោះជាមានក្រឹត្យវិន័យលោកម៉ូសេក្តី។"

រ៉ៃលខេរ ប្រ៊ុស អរ. មាកខនឃី ដែលជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ អនុវត្តមេរៀនដូចគ្នានេះមកសម័យរបស់យើងដែរ

"ឥឡូវនេះ ចូរយើងសន្មត់ថាជាករណីក្នុងសម័យថ្មីនេះ។ សន្មត់ថា យើងមានព្រះគម្ពីរ ជំណឹងល្អ បព្វជិតភាព សាសនាចក្រ ពិធីការផ្សេងៗ អង្គការ សូម្បីតែកូនសោរនៃនគរ—អ្វីៗ ដែលពេលឥឡូវនេះ និងពេលតទៅ គ្រប់ពាំងឈើនិងក្បៀស—នៅតែគ្មានជង្ងាយ ធួនរបស់ព្រះគ្រីស្ទទេ។ ក្រោយពីនោះគឺអ្វី? តើយើងអាចសង្គ្រោះឬទេ? តើការងារល្អរបស់យើងអាចជួយ សង្គ្រោះយើងដែរឬទេ? តើយើង នឹងបានទទួលរង្វាន់ចំពោះសេចក្តីសុចរិតរបស់យើងឬទេ?

"ព្រោកដណាស់ថា យើងមិនអាចបានសង្គ្រោះនោះទេ។ យើងមិនអាចសង្គ្រោះដោយកិច្ចការតែម្យ៉ាង ហើយមិនថាការនោះល្អ យ៉ាងណាទេ យើងបានសង្គ្រោះដោយសារព្រះ បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ដើម្បីបង្ហូរលោហិតរបស់ទ្រង់ ទៅក្នុងសួនច្បារ តែតរសម៉ាទី និងនៅលើភ្នំលលាក្បាល ហើយដោយតាមរយៈទ្រង់អ្នកទាំងអស់នឹងត្រូវបានលោះ។ យើងបានសង្គ្រោះដោយលោហិត របស់ព្រះគ្រីស្ទ (សូមមើលកិច្ចការ 20:28, កូរិនថូសទី 1 6:20)។

"អ័ប៊ីណាដៃបកស្រាយថាៈ' សេចក្តីសង្គ្រោះ ពុំមែនបានមកដោយសារសាសនាចក្រតែប៉ុណ្ណោះទេ ហើយចេតិ្តនាជង្ងាយធួន ដែលបានផ្តល់ឱ្យដោយគុណនៃព្រះ ជាអំណោយឥតគិតថ្លៃនោះទេ មនុស្សទាំងអស់នឹងមិនអាចច្បៀសផុតពីសេចក្តីវិនាសឡើយ ហើយទោះជា សាសនាចក្រ និងអ្វីៗដែលទាក់ទងទៅនឹងសេចក្តីសង្គ្រោះនោះ" (*Doctrine of the Restoration: Sermons and Writings of Bruce R. McConkie,* ចោះពុម្ពដោយ Mark L. McConkie [1987], 76)។

ម៉ូសាយ 14

ទ្រង់ទ្រាយល្អ ឬសណ្ឋាន (ខ. 2)—
ការសូមមើលទៅស្អាតខុសពីធម្មតា ឬភាពទាក់ចិត្ត

រាប់អាន (ខ. 3)—តិរៀ, គោរព

ការវាយផ្តាលដែលនាំឱ្យយើងបានជាមេត្រី (ខ. 5)—ការដាក់ទោសដែលព្រះគ្រីស្ទបានទទួល នោះផ្តល់ឱ្យយើងនូវមេត្រី

ស្មាមរំពាត់ (ខ. 5)—របួសដែលស្មាមដោយការវាយ ឬវាត់, រងការឈឺចាប់និងទុក្ខវេទនា របស់ទ្រង់

យ៊ីនយ៉ូរ (ខ. 10)—បន្ទាយ

រងវេទនា (ខ. 11)—រងវេទនា, ឈឺចាប់

បានអង្វរជំនួស (ខ. 12)—ការពារ, សូមអង្វរជំនួសឱ្យ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងគ និងសកម្មភាព ខ ឬឃ នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 13–14។

ក សរសេរសំបុត្រ

ស្រមៃថា អ្នកគឺជាអ្នកបំរើនៅក្នុងកន្លែងកាត់ក្តីរបស់ស្តេចណូអេ ហើយនៅទីនោះ នៅពេលអ័ប៊ីណាដៃត្រូវបានទាំទាជំនុំជំរះ។ ចេញពីអ្វីដែលអ្នកបានរៀននៅក្នុងម៉ូសាយ 12:17–14:12 ចូរសរសេរនៅក្នុងស្បៃវគោសរសេររបស់អ្នក ជាសំបុត្រមួយច្បាប់ ទៅកាន់មិត្តរបស់អ្នក ដោយមានការពិពណ៌នាពីអ្វីដែលបានកើតឡើង។ ត្រូវឱ្យច្រាកដ ដើម្បីបញ្ចូលនូវការសង្ខេបមួយ នៃអ្វីដែលអ័ប៊ីណាដៃនិយាយ និងការព្យាករណ៍របស់គាត់។ ចូរពិពណ៌នាផងដែរ ពីរបៀបដែលស្តេច និងពួកសង្ឃរបស់ទ្រង់បាន ឆ្លើយតប និងរឿងដែលមិនធម្មតា ជាច្រើនបានកើតឡើង។ សូមបញ្ចូលទាំងចំណាប់អារម្មណ៍របស់អ្នកពីការព្យាករណ៍របស់អ័ប៊ីណាដៃ។ រឿងទាំងនេះអាចជាទំរង់សំរាប់ការនិយាយនៅមៅងអតិសេកនំប៉ុង និងទីកនៅថ្ងៃអនាគត។

ខ បទបញ្ញត្តិទាំងដប់ប្រការសព្វថ្ងៃនេះ

នៅក្នុងម៉ូសាយ 12:34–13:24 អ័ប៊ីណាដៃ បានសូត្របទបញ្ញត្តិទាំងដប់ប្រការទៅកាន់ស្តេចណូអេ និងពួកសង្ឃរបស់ទ្រង់។

1. ចូរសែ្វងរក ហើយគូសចំណាំនូវរាល់បទបញ្ញត្តិទាំងដប់ប្រការនីមួយៗ នៅក្នុងព្រះគម្ពីររបស់អ្នក (ចូរប្រៀបធៀប និក្ខមនំ 20:3–17 សំរាប់ជំនួយបន្ថែម)។
2. ចូរជ្រើសរើសបទបញ្ញត្តិបី ចេញពីបទបញ្ញត្តិដប់ប្រការ ហើយសំរាប់បទបញ្ញត្តិនីមួយៗ ចូរសរសេរកថាខ័ណ្ឌដែលពិពណ៌នាពី របៀប ដែលអ្នកជិតខាង ឬសមាគមរបស់អ្នក អាចផ្លាស់ប្តូរ បើម្នាក់ៗជឿ និងរស់នៅតាមបទបញ្ញត្តិដប់ទាំងប្រការ។

៣ វិភាគអំពីចំលើយរបស់អ័ប៊ីណាដៃ

អ័ប៊ីណាដៃបានសួរពួកសង្ឃទុច្ចរិត បើមនុស្សអាចបានសង្គ្រោះ ដោយការរស់នៅតាមក្រិត្យវិន័យរបស់ម៉ូសេតែប៉ុណ្ណោះឬ (សូមមើលម៉ូសាយ 12:31–32)។ ពួកសង្ឃបានឆ្លើយថា មនុស្សអាចត្រូវបានសង្គ្រោះដោយការរស់នៅតាម ក្រិត្យវិន័យ លោកម៉ូសេ។ អ័ប៊ីណាដៃ បន្ទាប់មកបានពន្យល់មូលហេតុអ្វីបានជាចំលើយនោះមិនត្រឹមត្រូវពិតប្រាកដ (សូមមើល ម៉ូសាយ 12:33–13:26)។ អ័ប៊ីណាដៃបានឯកភាពថា ការប្រតិបត្តិតាមក្រិត្យវិន័យរបស់ព្រះ រួមទាំងបទបញ្ញត្តិដប់ប្រការ ដែលម៉ូសេបានទទួល គឺជាការចាំបាច់ តែមិនត្រប់ត្រាន់ទេ។ បន្ទាប់មកអ័ប៊ីណាដៃ បានបង្រៀនមេរៀនយ៉ាងសំខាន់មួយ។ សិក្សានៅក្នុងម៉ូសាយ 13:27–35 ហើយឆ្លើយនូវសំនួរដូចខាងក្រោមៈ

1. តើអ័ប៊ីណាដៃបានន្រិយាយថា អ្វីនឹងអាចកើតឡើង ជាមួយនឹងក្រិត្យវិន័យលោកម៉ូសេនៅពេលអនាគត?
2. តើគោលបំណងនៃក្រិត្យវិន័យលោកម៉ូសេគឺជាអ្វី? (សូមមើល ខទី 29–30)។
3. តើព្រះអម្ចាស់បានព្យាយាមបង្រៀនពួកគេអំពីអ្វី តាមរយៈពិធីការផ្សេងៗ និងការបូជានៃក្រិត្យវិន័យនៃម៉ូសេ? (សូមមើល ខទី 31–35)។
4. តើហេតុអ្វីក្រិត្យវិន័យផ្ទាល់មិនត្រប់ត្រាន់ដើម្បីសង្គ្រោះនរណាម្នាក់? (សូមមើល រ៉ូម 3:20, 23, នីហ្ចៃទី2 2:5–7)។
5. តើការពន្យល់របស់អ័ប៊ីណាដៃ អំពីក្រិត្យវិន័យលោកម៉ូសេ អាចអនុវត្តទៅនឹងក្រិត្យវិន័យនៃពិធីការនៃដំណឹងល្អនៅក្នុង សម័យរបស់យើងបានយ៉ាងដូចម្តេច? (សូមមើល វត្ត "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ម៉ូសាយ 13:27–28)។

៤ ផ្តូរផ្តងយ្លាទៅនឹងខ

ដើម្បីគាំទ្រដល់ការបង្រៀនរបស់គាត់អំពីតំរូវការនៃព្រះអង្គសង្គ្រោះ អ័ប៊ីណាដៃបានដកស្រង់ការបង្រៀនខ្លះៗ អំពីព្រះ យេស៊ូវគ្រីស្ទ របស់ព្យាការីអេសាយ ។

1. សូមអានម៉ូសាយ 14 ហើយបន្ទាប់មកចំលងប្រយោគដូចខាងក្រោមចូលទៅក្នុងសៀវភៅសរសេររបស់អ្នក។ នៅជិតយ្លា នីមួយៗ ចូរសរសេរលេខនៃខ ដែលសេចក្តីពិតនោះត្រូវបានរកឃើញ។



ក. ទ្រង់បានសុគតជាមួយនឹងមនុស្សទុច្ចរិតទោះបីជាទ្រង់មិនបានធ្វើអ្វីខុសសោះឡើយ។

ខ. ទ្រង់ទទួលរងអំពើបាបរបស់យើង ហើយការដាក់ទោសរបស់ទ្រង់នាំមកយើងនូវមេត្រី។

គ. មនុស្សជាច្រើនបដិសេធទ្រង់ ដែលធ្វើឱ្យទ្រង់សោកសៅជាខ្លាំង។

ឃ. ទ្រង់មិនបានព្យាយាមដើម្បីការពារខ្លួនរបស់ទ្រង់ ឬដើម្បីសង្គ្រោះជីវិតរបស់ទ្រង់។

ង. ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកបំរើសុចរិត ដោយសារតែដង្វាយធួនរបស់ទ្រង់ នឹងសង្គ្រោះមនុស្សជាច្រើន។

ម៉ូសាយ 15–16

អ័ប៊ីណាដៃបង្រៀនពីព្រះយេស៊ូវគ្រីស្ទ ហើយពន្យល់ថា នរណានឹងត្រូវបានសង្គ្រោះ

តើអ្នកធ្លាប់មានឱកាសនិយាយជាមួយនរណាម្នាក់មកពីសាសនាចក្រនៃគ្រីស្ទនិកផ្សេងទៀតអំពី តើព្រះជាអ្វីឬទេ? សានាចក្រនៃគ្រីស្ទនិកដទៃ ភាគច្រើនបង្រៀនគោលលទ្ធិនៃព្រះតែមួយ ថា ព្រះជាព្រះវរបិតា, ព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ គឺជាការសំដែងខុសគ្នា ឬទឹកមុខនិងរូបរាងដូចគ្នា។ នៅពេលដែលលោកឃើញព្រះវរបិតា និងព្រះរាជបុត្រា នៅក្នុងព្រៃដ៏ស្ងប់ស្ងាត់ព្យាការី យ៉ូសែប ស្មីធ បានរៀនថា ក្រុមព្រះមានតួអង្គបីដាច់ពីគ្នា (សូមមើលប្រវត្តិរបស់—យ៉ូសែប ស្មីធ 1:15–20, ត និង ស 130:22–23)។

នៅក្នុងម៉ូសាយ 15 អ័ប៊ីណាដៃបានបង្រៀនថា ព្រះយេស៊ូវគឺជា "ព្រះវរបិតា និងព្រះរាជបុត្រា" ហើយថា "ហើយអង្គទាំងពីរគឺជា ព្រះតែមួយ មែន ហើយគឺជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច នៃផ្ទៃមេឃនិងផែនដី" (ខ 2, 4)។ រឿងនេះហាក់ដូចជាធ្វើឱ្យច្រឡំ នៅលើកទីមួយ តែនៅពេលយល់ឱ្យបានត្រឹមត្រូវ វាបើកសម្ដែងសេចក្តីពិតដ៏សំខាន់អំពីក្រុមព្រះបីអង្គ ជាពិសេសព្រះយេស៊ូវគ្រីស្ទ ដែលយើងនៅពេលខ្លះសូមមើលរំលង។ ត្រូវប្រយ័ត្នកុំអានរំលងសេចក្តីពិតនោះ នៅពេលដែលអ្នកសិក្សាអំពីទីបន្ទាល់របស់ អ័ប៊ីណាដៃ។

ម៉ូសាយ 15–16 រួមមានទាំងការបង្រៀនរបស់អ័ប៊ីណាដៃ នៅពីមុខស្តេចណូអេ និងពួកសង្ឃទុច្ចរិតរបស់ទ្រង់។ សូមរកមើល សំរាប់ការពន្យល់ របស់លោកថា តើនរណានឹងត្រូវបានសង្គ្រោះ ដោយដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយតើនរណានឹង មិនត្រូវបានប្រោសលោះ។ នៅទីបញ្ចាប់នៃជំពូកទាំងនេះ អ្នកនឹងអាចពន្យល់កាន់តែល្អឡើង ពីអ្វីដែលយើងអាចសង្ឃឹម នៅពេលដែលមនុស្សទាំងអស់ នឹងត្រូវបានរស់ឡើងវិញ។

អ័ប៊ីណាដៃ

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 15

ដោយសាច់ឈាម (ខ 2)—ធ្វើឱ្យខាងរូបកាយសាច់ឈាមគោរពប្រតិបត្តិ

ចាប់កំណើត (ខ 3)—បានបង្កើត, បានឱ្យជីវិត

ចំអកឡកឡឹយ (ខ 5)—ទាត់ចោល

សំរាប់អង្វរជំនួស (ខ 8)—ការពារ, សូមអង្វរជំនួសឱ្យ

នៅចន្លោះ (ខ 9)—រវាង

ពូជ (ខ 10)—កូន, កូនចៅ (ការប្រើនៅទីនេះជានិមិត្តសញ្ញា ឬខាងវិញ្ញាណ)

ចេតនា (ខ 26)—ដោយមានបំណង, ដោយចេតនា

ម៉ូសាយ 15៖1–7—តើព្រះគ្រីស្ទអាចជាព្រះវរបិតា និងព្រះរាជបុត្រាបានយ៉ាងដូចម្ដេច?

នៅក្នុងឆ្នាំ 1916 គណៈប្រធានទីមួយ និងក្រុមសាវកដប់ពីរនាក់ បានប្រាប់នូវសេចក្ដីថ្លែងមួយយ៉ាងក្បោះក្បាយអំពីព្រះវរបិតា និងព្រះរាជបុត្រា។ នៅខាងក្រោមគឺជាគំរូខ្លះៗ ដែលពួកគេបានបង្រៀនថាព្រះយេស៊ូវគ្រីស្ទត្រូវបានតំណាងដូចជាព្រះវរបិតា៖

1. ទ្រង់គឺជាអ្នកបង្កើតនៃវត្ថុសព្វសារពើរ ហេតុដូច្នេះហើយ គឺមាននៅក្នុងវគ្គព្រះគម្ពីរជាច្រើន ដូចជា “ព្រះវរបិតាដ៏នៅអស់កល្ប ជានិច្ច នៃផ្ទៃមេឃ និងផែនដី” (សូមមើល ម៉ូសាយ 15៖4, 16៖15, អាលម៉ា 11៖38–39, អេធើរ 4៖7)។
2. ទ្រង់គឺជាព្រះវរបិតានៃអ្នកទាំងឡាយណា ដែលទទួល ពលិកម្មដង្វាយធួនរបស់ទ្រង់ និងចុះសេចក្ដីសញ្ញាជាមួយទ្រង់ ដើម្បីគោរពតាមដំណឹងល្អដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ (សូមមើល ម៉ូសាយ 5៖7, 15៖10–13, អេធើរ 3៖14, គ និង ស 25៖1)។
3. ទ្រង់គឺជាព្រះវរបិតា ដោយ “តំណែងដ៏ទេវភាពនៃសិទ្ធិអំណាច។” នេះមានន័យថា ព្រះអង្គសង្គ្រោះគឺជា អ្នកមានអំណាចដ៏ពេញ លេញ និងបេសកកម្មជាតំណាងឱ្យព្រះបិតារបស់ទ្រង់ ថាអ្វីក៏ដោយដែលទ្រង់ធ្វើគឺជាការប្រតិបត្តិតាមឆន្ទៈព្រះវរបិតារបស់ទ្រង់ ដែលបានអនុញ្ញាត និងចងភ្ជាប់ប្រសិទ្ធភាព តាំងពីការបើកសម្ដែងដោយការជ្រើសរើសជាតំណាងរបស់ព្រះវរបិតា។

ម៉ូសាយ 15៖21—តើការរស់ឡើងវិញជាលើកទីមួយគឺជាអ្វី?

“ការរស់ឡើងវិញជាលើកទីមួយ” ដែលអ័ប៊ីណាដៃបានសំដៅទៅលើនោះគឺជាការចាប់ផ្ដើមនៃការរស់ឡើងវិញជាលើកទីមួយរបស់ព្រះ យេស៊ូវគ្រីស្ទ។ នៅពេលនោះ អ្នកទាំងឡាយណាដែលបានស្លាប់ពីមុនទ្រង់ ជាអ្នកសមនឹងបានទទួលនៃភាពរុងរឿងនៃនគរ សេឡេស្ទាល គឺត្រូវបានរស់ឡើងវិញ។ នៅពេលដែលព្រះអង្គសង្គ្រោះមកម្ដងទៀត ទ្រង់នឹងជាអ្នកបំរើដែលបានហៅថា ពេលព្រឹកនៃ ការរស់ឡើងវិញ នៅពេលដែលអ្នកដទៃសមនឹងទទួលភាពរុងរឿងនៃ នគរសេឡេស្ទាលនឹងត្រូវបានរស់ឡើងវិញ (សូមមើល គ និង ស 88៖96–98)។ ការរស់ឡើងវិញជាលើកទីមួយនឹងបន្តរហូតដល់ពេលបញ្ចប់នៃសហស្សវត្ស។

ម៉ូសាយ 16

សង្កៀតធ្មេញ (ខ. 2)—សង្កៀតធ្មេញចូលគ្នាដោយកំហឹង ឬឈឺចាប់

បញ្ឆោត (ខ. 3)—បោកបញ្ឆោត, ល្បួង

ខាងលោកិយ, កាមរាគ, អាក្រក់ (ខ. 3)—ទាក់ទងនឹងការពេញចិត្តខាងរូបកាយ និងសេចក្ដីប៉ងប្រាថ្នាខាងលោកិយ

ពុករលួយ (ខ.10)—ជីវិតដែលអាចស្លាប់

មិនពុករលួយ (ខ. 10)—អមតៈ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរចេញពី ក–ឃ ហើយសកម្មភាពមួយចេញពី ង–ច នៅពេលដែលអ្នកសិក្សាម៉ូសាយ 15–16។

ក ការសង្ខេបគោលលិទ្ធិ

ចូរសិក្សាពាក្យរបស់អ័ប៊ីណាដៃនៅក្នុង ម៉ូសាយ 15៖1–7 ហើយពន្យល់ពីរបៀបដែលព្រះយេស៊ូវគឺជា “ព្រះវរបិតា ហើយជាព្រះ រាជបុត្រា” ផង (សូមមើល វគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់ម៉ូសាយ 15៖1–7 សំរាប់ជំនួយបន្ថែម)។

ខ តើសំនួរគឺជាអ្វី?

នៅខាងក្រោមនេះ គឺជាឃ្លាដែលចេញពីម៉ូសាយ 15៖8–9។ ខគម្ពីរទាំងនោះពន្យល់ ពីរបៀបដែលព្រះយេស៊ូវគ្រីស្ទ បានផ្ដល់ឥស្សរៈភាពដល់យើងពីអំពើបាប និងសេចក្ដីស្លាប់។ ចូរពិចារណារាល់ឃ្លាទីមួយៗ ហើយគិតរកសំនួរមួយ ដែលអាចត្រូវបានឆ្លើយដោយឃ្លានោះ។

ចំលើយ	តើសំនួរគឺជាអ្វី?
“ផ្ដាច់ ចំណងទាំងឡាយនៃ សេចក្ដីស្លាប់”	
“សំរាប់អង្វរជំនួសកូនចៅមនុស្ស”	
“ដោយមានចិត្តក្ដួលមេត្តា”	
“បានលើកដាក់អង្គទ្រង់នូវអំពើ ទុច្ចរិតរបស់ពួកគេ”	
“បានបំពេញការទាមទារ ទាំងឡាយនៃសេចក្ដីយុត្តិធម៌”	

គ ស្វែងរកបញ្ជី

អ័ប៊ីណាដៃបានឱ្យឧទាហរណ៍ទាំងឡាយ ដែលថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះវរបិតា។

1. ចូរសិក្សាម៉ូសាយ 15៖11–13 ហើយធ្វើជាបញ្ជីនៃក្រុមប្រជាជនចំនួនពីរ ដែលនឹងហៅថា “គ្រាប់ពូជ” (មានន័យថា កូនចៅ) នៃព្រះយេស៊ូវគ្រីស្ទ។
2. ចូរអានខទី 14–17 ហើយពិពណ៌នាអំពីក្រុមផ្សេងទៀតដែលត្រូវបានហៅថា “គ្រាប់ពូជ” នៃព្រះគ្រីស្ទ ព្រោះពួកគេធ្វើដូចគ្នា នេះ ដូចនឹងអ្នកទាំងឡាយ ដែលនៅក្នុងក្រុមទីពីរ ដែលអ្នកធ្វើបញ្ជី។

ឃ តើនរណានឹងចេញមកនៅពេលមានការរស់ឡើងវិញជាលើកទីមួយ?

នៅក្នុងម៉ូសាយ 15៖19–26 អ័ប៊ីណាដៃបានពិពណ៌នាអំពីក្រុមប្រជាជនចំនួនបី ដែលនឹងចេញពីមកពីការរស់ឡើងវិញជា លើកទីមួយ ដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច។

1. សូមអានខទាំងឡាយនោះ រួចរកមើលពាក្យគន្លឹះ *ដឿ ល្ងិតល្ងង់ និង កូនចៅ*។ ចូរសរសេរជាប្រយោគមួយ ហើយពិពណ៌នាអំពី ក្រុមទាំងបី។
2. ពរជ័យមួយនៃការមានព្យាការីដែលរស់នៅ គឺថាព្យាការីអាចបំភ្លឺគោលលទ្ធិ។ វាហាក់ដូចជាអ័ប៊ីណាដៃបានចង្អុលបង្ហាញថា *មនុស្សគ្រប់រូប* ដែលបានស្លាប់ដោយគ្មានបានលឺពីដំណឹងល្អ នឹងទទួលជីវិតដ៏នៅអស់កល្បជានិច្ចដោយស្វ័យប្រវត្តិ តែនោះមិនមែន ជាមូលហេតុទេ។ សូមអានគោលលទ្ធិ និងសេចក្ដីសញ្ញា 137៖7–9 ហើយពន្យល់ពីរបៀបដែលខទាំងនោះបញ្ជាក់ អំពីមនុស្ស ទាំងអស់ ដែល “បានស្លាប់ដោយមិនបានដឹងអំពីដំណឹងល្អ” នោះនឹងទទួលមរតកនគរសេឡេស្ទាល។
3. សូមអានម៉ូសាយ 15៖26–27 ហើយពិពណ៌នាអំពីអ្នកទាំងឡាយដែលនឹង *មិន* ចេញមកក្នុងពេលនៃការរស់ឡើងវិញជាលើក ទីមួយ។

ង ឆ្លើយតបសំបុត្រ

សន្មត់ថា អ្នកទទួលសំបុត្រដូចខាងក្រោមមកពីមិត្តម្នាក់ ដែលអ្នកបានជួបនៅពេលធ្វើដំណើរ នៅកាលពីរដូវក្ដៅមុន។ សូមប្រើ សេចក្ដីពិត ដែលអ័ប៊ីណាដៃបានបង្រៀននៅក្នុងម៉ូសាយ 16 និងសរសេរនៅក្នុងសៀវភៅសរសេររបស់អ្នក ជាការឆ្លើយតប ទៅនឹងសំនួរមិត្តរបស់អ្នក។

ជូនចំពោះមិត្តសំលាញ់

ខ្ញុំបានគិតអំពីការនិយាយរបស់យើងកាលពីរដូវក្តៅមុន។ ខ្ញុំបានមានអារម្មណ៍ខុសប្លែក នៅពេលដែលអ្នកបានប្រាប់ខ្ញុំ ពីអ្វីដែលអ្នក ជឿ។ នៅពេលដែលខ្ញុំបានគិតអំពីអ្វីដែលអ្នកបាននិយាយ ទាក់ទងទៅនឹងព្រះយេស៊ូវគ្រីស្ត ខ្ញុំបានយល់ច្រឡំអំពីរឿងមួយ។ អ្នកបាននិយាយថា អ្នកជឿថាព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះរបស់អ្នក។ ខ្ញុំមិនយល់ថា ហេតុអ្វីយើងចាំបាច់ត្រូវការសង្គ្រោះ ឬ តើយើងត្រូវការសង្គ្រោះពីអ្វី។ បើព្រះបានបង្កើតយើង នោះយើងមិនមែនជាមនុស្សអាក្រក់ណាស់ណាទេ។ ផងដែរ ខ្ញុំមាន អារម្មណ៍រំភើបចំពោះសន្តិភាព ដែលហាក់ដូចជាមកពីសេចក្តីជំនឿរបស់អ្នក។ អ្នកហាក់ដូចជាសប្បាយជាងខ្ញុំ។ ហេតុអ្វីដូច្នេះ? តើអ្វីនឹងកើតឡើងបើខ្ញុំមិនជឿដូចជាអ្នក ហើយមិនធ្វើអ្វីព្រ ដែលសាសនាចក្ររបស់អ្នកបានបង្រៀននោះ? ខ្ញុំសង្ឃឹមថា អ្នក មានពេលដើម្បីឆ្លើយសំបត្រខ្ញុំ ព្រោះខ្ញុំពិតជាចង់ដឹងអំពីសេចក្តីជំនឿរបស់អ្នក។

ពីមិត្តរបស់អ្នក

៦ បញ្ជាប់ប្រយោគ

ក្នុងម៉ូសាយ 16:6–9 អ៉ប៊ីណាដៃបានធ្វើទីបន្ទាល់អំពីសេចក្តីស្លាប់ដែលនឹងត្រូវបានយកឈ្នះ សំរាប់មនុស្សទាំងអស់ តាមរយៈ ព្រះចេស្តារ របស់ព្រះយេស៊ូវគ្រីស្ទជាយ៉ាងណា។ ចូរបញ្ជាប់ប្រយោគខាងក្រោមនេះ ដោយប្រើអ្វីដែលអ្នកបានរៀន ចេញពីខទាំងឡាយនោះ:

1. បើសិនព្រះគ្រីស្ទមិនមកទេ នោះ . . .
2. បើព្រះគ្រីស្ទមិនឈ្នះលើសេចក្តីស្លាប់ទេ នោះ . . .
3. ពីព្រោះតែការរស់ឡើងវិញរបស់ទ្រង់ . . .
4. ពីព្រោះព្រះគ្រីស្ទគឺជាជីវិត និងជាពន្លឺនៃពិភពលោកនេះ នោះ . . .
5. សេចក្តីពិតដែលអ៉ប៊ីណាដៃបានបង្រៀន បានធ្វើការមានការផ្លាស់ប្តូរក្នុងជីវិតរបស់ខ្ញុំ ព្រោះ . . .

ម៉ូសាយ 17–18

អាលម៉ាជឿអ៉ប៊ីណាដៃ

នៅក្នុងម៉ូសាយ 12–16 អ៉ប៊ីណាដៃបានស្តីបន្ទោសស្តេចណូអេ និងពួកសង្ឃទុច្ចរិតរបស់ទ្រង់ ហើយបានហៅពួកគេឱ្យប្រែចិត្ត។ អ្នកប្រហែលជាតិតទុកស្តេចទុច្ចរិតបានបដិសេធសារលិខិត ហើយបានបញ្ជាឱ្យសំលាប់អ៉ប៊ីណាដៃ។ ប៉ុន្តែមានម្នាក់ក្នុង ចំណោមពួកសង្ឃរបស់ស្តេចណូអេ បានជឿដល់សារដំណឹងរបស់អ៉ប៊ីណាដៃ ហើយបានប្រែចិត្ត។ មិនត្រឹមតែប៉ុណ្ណោះតាត់ថែមទាំង ព្យាយាមជួយជីវិតរបស់អ៉ប៊ីណាដៃទៀត។ បុរសម្នាក់នេះមានតួនាទីសំខាន់ នៅក្នុងព្រះគម្ពីរម៉ូសាយតទៅមុខទៀត។ តើសេចក្តីក្លាហ៊ានយ៉ាងណាដែលអ្នកគិតថា អាចធ្វើដើម្បីឈរចំពោះស្តេចនិងពួកសង្ឃដែលធ្វើតាម និងការពារមនុស្សដែលពួកគេ ខឹងជាមួយ ហើយចង់សំលាប់?

អាលម៉ា



© 1996 Ronld K. Crosby

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 17

ចោទប្រកាន់ទោសលើរូបអ្នក (ខ. 7)—បទឧក្រិដ្ឋដែលចោទប្រកាន់អ្នក

ជេរប្រមាថ (ខ. 12)—សូមមើលងាយ, ប្រមាថ

ដុតស្ឃែក (ខ. 13)—វាយ, វាត់

អង្កត់ឧស (ខ .13)—បាច់នៃមែកឈើតូចព្ច, ដំបង ឬ មែក

ម៉ូសាយ 18

ការយាងទៅ (ខ. 2)—ឡើងលើ, ឡើងទៅ

ជ្រកកោនទីនោះ (ខ. 5)—បានទៅទីនោះ

ដុះយ៉ាងក្រាស់ (ខ. 5)—រុក្ខជាតិដុះយ៉ាងក្រាស់

ទាស់ទែងគ្នា (ខ. 21)—ការឈ្លោះគ្នា, ការវាយគ្នា

ចែករំលែក (ខ 27)—ឱ្យ, ចែកចាយ

ដឹងជាមុនស្រេច (ខ 34)—បានប្រាប់អំពី

ម៉ូសាយ 18:13—តើអាលម៉ាទទួលអំណាចដើម្បីធ្វើបុណ្យជ្រមុជទឹកដោយរបៀបណា?

ប្រធាន យ៉ូសែប ហ្ស្មីលឌីង ស្មីធ បានបង្រៀនថាះ "យើងអាចសន្និដ្ឋានថា អាលម៉ា បានកាន់បព្វជិតភាពជាមួយអ្នកដទៃ ពីមុនតាត់ បានប្រែទៅជារំខានចំពោះស្តេចណូអេ។ ទោះបីជារឿងនេះដូច្នេះ ឬមិនធ្វើឱ្យមានភាពខុសប្លែកគ្នា ខ្លាំងក៏ដោយ ព្រោះនៅក្នុងគម្ពីរម៉ូសាយ ត្រូវបានលើកឡើងដោយបញ្ជាក់ថា អាលម៉ាបានកាន់សិទ្ធិអំណាចនោះ [សូមមើល ម៉ូសាយ 18:13, 18]" (*Answers to Gospel Questions*, 3:20)។

ម៉ូសាយ 18:14–15—តើមនុស្សម្នាក់អាចធ្វើបុណ្យជ្រមុជទឹកឱ្យខ្លួនគាត់បានឬទេ?

នៅពេលដែលអាលម៉ា បានជ្រមុជទឹកឱ្យហេលេមិន នៅឯទឹកមរមន អាលម៉ាបានជ្រមុជហេលេមិន ចុះទៅក្នុងទឹក ហើយអាលម៉ា បានជ្រមុជទៅក្នុងទឹកជាមួយហេលេមិន។ ជាមួយនឹងបុណ្យជ្រមុជទឹក បន្ទាប់ អាលម៉ាគ្រាន់តែជ្រមុជអ្នកដែលទទួលបុណ្យជ្រមុជ ទឹក ហើយមិនបានជ្រមុជខ្លួនរបស់លោក ចូលទៅក្នុងទឹកទេ។ ប្រធាន យ៉ូសែប ហ្ស៊ីលឌីង ស្មីធ បានពន្យល់ថាះ "នៅពេលដែល អាលម៉ា បានធ្វើបុណ្យជ្រមុជទឹកខ្លួនរបស់លោក ជាមួយហេលេមិន នោះមិនមែនជាហេតុ ដែលអាលម៉ាធ្វើបុណ្យជ្រមុជទឹក ឱ្យខ្លួន របស់លោកទេ ប៉ុន្តែគ្រាន់តែជាសញ្ញាមួយ [សញ្ញា] ទៅកាន់ព្រះអម្ចាស់ ពីការបន្ទាបខ្លួនរបស់លោក និងការកែប្រែចិត្ត ដ៏ពេញលេញ របស់លោក" (*Anwser to Gospel Questions*, 3:203)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ និងសកម្មភាពមួយចេញពីសកម្មភាពផ្សេងទៀត (ក–គ) នៅពេលដែលអ្នកសិក្សា ម៉ូសាយ 17–18។

ក៣ តើអ័ប៊ីណាដៃបានធ្វើអ្វី រហូតដល់ "មានទោសដល់ស្លាប់"?

បន្ទាប់ពីការស្តាប់អ័ប៊ីណាដៃ វាបានធ្វើឱ្យស្តេចណូអេ និងពួកសង្ឃរបស់ទ្រង់ ប្រើរយៈពេលបីថ្ងៃ ដើម្បីស្វែងរក ពាក្យចោទ ប្រកាន់ប្រឆាំងនឹងអ័ប៊ីណាដៃ ហើយប្រកាសថា អ័ប៊ីណាដៃ "មានទោសដល់ស្លាប់" (សូមមើល ម៉ូសាយ 17:6–8)។

1. សូមអាន ម៉ូសាយ 17:6–8 និងការពន្យល់របស់លិមហៃពីមុន នៅក្នុងម៉ូសាយ 7:26–28។ តើអ្វីជាពាក្យចោទប្រកាន់ របស់ពួកគេប្រឆាំងនឹងអ័ប៊ីណាដៃ?
2. ហេតុអ្វីអ្នកគិតថា ស្តេចណូអេ និងពួកសង្ឃរបស់ទ្រង់ បានខឹងជាខ្លាំងដោយមកពី "អំពើឧក្រិដ្ឋ" នោះ?

ខ៣ សរសេរដំណើររឿងនៃសាក្សីដែលឃើញដោយផ្ទាល់ភ្នែក

ម៉ូសាយ 17:9–20 បានកត់ត្រានូវសក្ខីភាព និងការញាករណ៍ចុងក្រោយរបស់អ័ប៊ីណាដៃ។ ចូរសិក្សាខទាំងនោះ ហើយបន្ទាប់មក សរសេរនូវដំណើររឿង នៃព្រឹត្តិការណ៍ ហាក់ដូចជាអ្នកបាន នៅទីនោះ ក្នុងនាមជាអ្នកយកពតិមានសំរាប់កាសែតមួយ។ សូមកុំភ្លេច ពន្យល់ពីអ្វីដែលអ័ប៊ីណាដៃ បានបញ្ជូលនៅក្នុងការញាករណ៍នេះ ចំពោះអ្វីដែលគាត់បានញាករួចទៅហើយ អំពីស្តេចណូអេ នៅក្នុងម៉ូសាយ 12:3។

ក៣ ឱ្យគំរូថ្មីមួយ

មុនពេលអញ្ជើញនរណាម្នាក់ឱ្យទទួលបុណ្យជ្រមុជទឹក អាលម៉ា បានពន្យល់ទៅកាន់ពួកគេ នូវការសន្យាខ្លះៗ ដែលត្រូវបានធ្វើ ដោយការចុះសេចក្តីសញ្ញានោះ។

1. នៅក្នុងស្យែវភៅសរសេររបស់អ្នក ធ្វើតារាងដូចជាតារាងដែលបានបង្ហាញនៅទីនេះ។ នៅពេលដែលអ្នកសិក្សា ម៉ូសាយ 18:8–10 ចូរប្រើពាក្យនៅក្នុងរង្វង់ក្រចក ដើម្បីជួយអ្នកបញ្ជាក់ ពីសេចក្តីត្រូវការ ដែលអាលម៉ាបានបញ្ជាក់ សេចក្តីសន្យាដែលយើង បានធ្វើ និងសេចក្តីសន្យា ដែលព្រះអម្ចាស់បានធ្វើ។ ចូរបំពេញនៅក្នុងតារាង ជាមួយនឹងពតិមាន ដែលអ្នករកឃើញ។ អ្នកប្រហែល ជាចង់គូស និងដាក់លេខ តាមសេចក្តីសន្យាទាំងនោះនៅក្នុងព្រះគម្ពីររបស់អ្នក។

សេចក្តីត្រូវការតំបូង	អ្វីដែលខ្ញុំសន្យា	អ្វីដែលព្រះអម្ចាស់សន្យា
1. (សេចក្តីប៉ងប្រាថ្នា)	1. (បន្ទុក)	1. (ប្រោសលោះ)
	2. (ទួញយំ)	2. (ទីមួយ)
	3. (ល្ងងលោម)	3. (អស់កល្បជានិច្ច)
	4. (ឈរ)	4. (ព្រះវិញ្ញាណ)
	5. (បំរើ)	
	6. (រក្សា)	

2. ចូរជ្រើសរើសសេចក្តីសន្យាបី ដែលយើង បានធ្វើនៅក្នុងពិធីបុណ្យជ្រមុជទឹក ហើយឱ្យជាគំរូថ្មីៗ នៃអ្វី ដែលពួកគេចង់មានន័យ អំពីសាសនាចក្រនៅសព្វថ្ងៃនេះ។

៥ ធ្វើការប្រៀបធៀបអារម្មណ៍របស់អ្នក

ម៉ូសាយ 18:11–16 ពិពណិនាពីអ្វី ដែលបានកើតឡើង ហើយរបៀបដែលប្រជាជន បានមានអារម្មណ៍នៅពេលដែលអាលម៉ា ធ្វើពិធីបុណ្យជ្រមុជទឹក នៅឯទឹកមរមន។ នៅក្នុងស្យែវភៅសរសេរបស់អ្នក ចូរសរសេរកថាខ័ណ្ឌមួយ ដែលពិពណិនា ពីរបៀបដែលអ្នក បានមានអារម្មណ៍ នៅក្នុងពិធីបុណ្យជ្រមុជទឹករបស់អ្នក។ តើអ្នកបានឃើញ សេចក្តីសន្យារបស់ព្រះអម្ចាស់បាន សំរេចនៅក្នុងជីវិត របស់អ្នកយ៉ាងដូចម្តេច? តើអ្នកថ្លែងអំណរគុណ ក្នុងពេលឥឡូវនេះ ច្រើនជាងកាលពីមុន អ្នកធ្វើ ពិធីបុណ្យជ្រមុជទឹក របស់អ្នកអ្វីខ្លះ?

១ សរសេរពិពណ៌នាអំពីអ្នកដឹកនាំសាសនាចក្រ

បន្ទាប់ពីអាលម៉ា បានធ្វើបុណ្យជ្រមុជទឹកឱ្យប្រជាជន លោកត្រូវរៀបចំសាសនាចក្រ នៅក្នុងព្រៃរហោស្ថាន សំរាប់ជាការថែរក្សា ដល់ពួកគេ។ ម៉ូសាយ 18:18–26 ព្រាប់អំពីក្រុមសង្ឃ ឬ អ្នកដឹកនាំសាសនាចក្រ ដែលគាត់ហៅនោះ។

1. សូមសិក្សាខទាំងនោះ បន្ទាប់មកសរសេរនូវការពិពណ៌នា ពីតំរូវការ សំរាប់អ្នកដឹកនាំសាសនាចក្រទាំងនោះ។ (ឧទាហរណ៍: “ក អ្នកដឹកនាំសាសនាចក្រម្នាក់ គឺជា . . . ហើយស្ម័គ្រចិត្តដើម្បីធ្វើ . . .”) តើតំរូវការទាំងនោះ ផ្តួចជាការងារហៅឱ្យបំរើរបស់ប៊ីស្សព ឬ ប្រធានសាខាសព្វថ្ងៃនេះ យ៉ាងដូចម្តេច?
2. សូមអានម៉ូសាយ 18:21–30 ហើយសរសេរការពិពណ៌នាផ្សេងទៀត ពីអ្វីដែលបានសង្ឃឹមទុក នៃសមាជិកថ្មី។
3. ហេតុអ្វីអ្នកគិតថា មនុស្សទាំងនោះសប្បាយដល់ដ្ឋេះ?

តើអ្នកធ្លាប់ឃើញនរណាម្នាក់ ដែលត្រូវគេធ្វើទុក្ខបុកម្នេញ ហើយក្រោកឈរឡើងទៅចំពោះមុខ អ្នកដែលធ្វើទុក្ខបុកម្នេញនោះទេ? នៅក្នុងម៉ូសាយ 19 អ្នកនឹងអានពីរបៀបដែលគេខាន បានក្រោកឈរឡើង នៅចំពោះមុខស្តេចទុច្ចរិតណូអេ។ អ្នកក៏នឹងអានផង ដែរ ពីការដែលស្តេចណូអេ បានរួចផុតពីកណ្តាប់ដៃរបស់គេខាន តែគេចមិនផុតពីការព្យាករណ៍របស់អ័ប៊ីណាដៃជាយ៉ាងណា។ នៅពេលអ្នកអានជំពូក នេះ ធ្វើការកត់ចំណាំផងដែរ អំពីរបៀបដែលការព្យាករណ៍របស់អ័ប៊ីណាដៃអំពី ប្រជាជនត្រូវបាន បំពេញ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 19

យ៉ាងខ្លាំង (ខ. 7)—ធ្វើឱ្យឈឺចាប់, ធ្វើឱ្យភ័យខ្លាច

នៅជាមួយ (ខ. 13)—ស្នាក់នៅជាមួយ, គង់នៅ

បង់ពន្ធដារ (ខ. 15, 26)—ពន្ធដារ, បានបង្កិតបង្កំឱ្យបង់ពន្ធដើម្បីមានសេចក្តីសុខសាន្ត

រុកគួន (ខ. 29)—បញ្ហា, ទុក្ខទោស

ស្តេចណូអេ

ស្តេចលីមហៃ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព (ក–គ) ដូចខាងក្រោមនេះ នៅពេលអ្នកអានម៉ូសាយ 19។

ក គូររូបភាពចេញពីរឿង

បន្ទាប់ពីអ្នកអានម៉ូសាយ 19 ចូររើសរើសយករូបភាពមួយចេញពីរឿងនេះ ហើយគូសរូបភាពសាមញ្ញមួយចេញពីរឿងនេះ នៅក្នុង ស្បៀវភៅសរសេររបស់អ្នក។ សូមបញ្ចូលនូវរាល់ពាក្យសំខាន់ៗ ទាំងអស់ដោយលំអិតសំរាប់ផ្នែកនៃរឿង ដែលអ្នករើសរើស គូរនោះ។ នៅជិតគំនូររបស់អ្នក ចូរពន្យល់ពីអ្វីដែលអ្នកបានគូរ ហើយធ្វើបញ្ជីខគម្ពីរដែលអ្នកបានបង្ហាញ។

ខ ផ្គូរផ្គងការព្យាករណ៍ជាមួយនឹងការសំរេចតាមព្យាករ

1. សូមរំលឹកឡើងវិញពីការព្យាករណ៍របស់អ័ប៊ីណាដៃ អំពីស្តេចណូអេ និងប្រជាជនរបស់ទ្រង់ក្នុងម៉ូសាយ 12:2–3។ បន្ទាប់មកសិក្សា ម៉ូសាយ 19 ហើយស្វែងរក និងសរសេរខគម្ពីរទាំងឡាយ ដែលបង្ហាញថា ការព្យាករណ៍ទាំងពីរនោះ ត្រូវបានចំពេញ។ អ្នកប្រហែលជាចង់សរសេរលេខយោង សំរាប់ការព្យាករណ៍ នៅលើរឹមដើមទំព័រ នៃព្រះគម្ពីររបស់អ្នក នៅជិតនឹងខគម្ពីរដែលបង្ហាញពីការចំពេញការព្យាករណ៍នោះ។
2. នៅក្នុងស្បៀវភៅសរសេររបស់អ្នក ចូរពន្យល់ពីរបៀប ដែលការព្យាករណ៍នីមួយៗ ត្រូវបានចំពេញ។

គ រំលឹកឡើងវិញពីបុគ្គលិកលក្ខណៈ

គ្រោះកម្មរបស់ស្តេចណូអេ គឺបានពិពណ៌នាក្នុងម៉ូសាយ 19:18–24។ ឧបមាថា អ្នកគឺជាអ្នកយកពត៌មាន ដែលកំពុងធ្វើដំណើរ ជាមួយ ប្រជាជនហើយបានសម្ភាសជាមួយនឹងមនុស្សម្នាក់ក្នុងចំណោមពួកគេនោះ ដែលបានទៅជាមួយស្តេចណូអេ។ ចូរសរសេរ ពីអ្វីដែលអ្នកគិតថា គាត់នឹងឆ្លើយតបនឹងសំនួរដូចខាងក្រោម:

- ហេតុអ្វីបានជាអ្នកទៅជាមួយស្តេច ជំនួសឱ្យការរស់នៅជាមួយក្រុមគ្រួសាររបស់អ្នកដូច្នេះ?
- ហេតុអ្វីបានជាស្តេចមិននៅជាមួយអ្នកឥឡូវនេះ?
- តើមានអ្វីកើតឡើងចំពោះទ្រង់?
- តើមានអ្វីកើតឡើងចំពោះពួកសង្ឃរាជ្យ?
- ហេតុអ្វីបានជាអ្នកត្រឡប់មកវិញ?
- បើសិនជាអ្នកមានឱកាសដើម្បីធ្វើម្តងទៀត តើអ្នកនឹងធ្វើឱ្យមានភាពខុសគ្នាជាយ៉ាងណា?

ពួកសង្ឃរបស់ស្តេចណូអេភាគច្រើន គឺជាមនុស្សទុច្ចរិត។ ក្នុងម៉ូសាយ 20 អ្នកនឹងអានពីរបៀប ដែលពួកគេបន្តនៅក្នុង សេចក្តីទុច្ចរិតរបស់ពួកគេ ទោះបីជាបន្ទាប់ពីស្តេចណូអេ ត្រូវបានសំលាប់ ហើយពួកគេបានរត់គេចទៅរស់នៅក្នុងព្រៃរហោរស្ថាន។ នៅពេលអ្នកអាននៅក្នុង ជំពូកនេះ ចូរកត់ចំណាំពីអំណាចដែលប្រជាជនរបស់លីមហៃមាន នៅពេលច្បាំងគ្នា សំរាប់ហេតុផល សុចរិតមួយនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 20

ពុំហ៊ាន (ខ. 3)—ពុំហ៊ាន

សាហាវអស្ចារ្យ (ខ. 10)—ហឹង្សា, ការបង្ខិតបង្ខំ

ខំប្រឹងយ៉ាងអស់ពីសមត្ថភាព (ខ. 11)—ដាក់ន្ទូវការខិតខំយ៉ាងខ្លាំងក្លា

រុំរបួសឱ្យ (ខ. 13)—រុំរបួស

សូមកុំ (ខ. 17)—ឈប់, តស៊ូ

កុំយករឿងនេះមកចោទប្រកាន់ដល់ពួកយើងឡើយ (ខ. 17)—កុំស្តីបន្ទោសដល់ពួកគេ

ចាត់ខឹង (ខ. 19–20, 22, 24)—រសាយកំហឹង, បន្ធូរអារម្មណ៍

ទម្លាក់ទោស (ខ. 23)—ទម្លាក់ទោសលើ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកអានម៉ូសាយ 20។

ក្ត៉ ត្រីអ្នកបានរៀនអ្វីពីគេខាន?

អ្នកបានអានអំពីព្រឹត្តិការណ៍ ដែលទាក់ទងគេខាន ជាច្រើនដងរួចមកហើយ។ ឧទាហរណ៍ គាត់បានឈរឡើងចំពោះស្តេច ណូអេ ហើយបានបញ្ជូនមនុស្សរបស់គាត់ទៅស៊ើបថា មានអ្វីកើតឡើងចំពោះស្តេច និងមនុស្សទាំងឡាយ ដែលបានចាកចេញពី ត្រូសារ របស់ពួកគេ ហើយរត់គេចទៅជាមួយស្តេច (សូមមើល ម៉ូសាយ 19)។ សូមសិក្សាម៉ូសាយ 20 ហើយឆ្លើយសំនួរដូចខាងក្រោមៈ

1. តើគេខានមានមុខនាទីអ្វី នៅក្រោមការគ្រប់គ្រងរបស់ស្តេចលិមហៃ?
2. តើ គេខាន ធ្វើអ្វីដើម្បីបញ្ឈប់ពួកសាសន៍លេមិន ពីការឈ្លានពានលើពួកគេម្តងទៀត? (សូមមើល ម៉ូសាយ 20៖14–24)។
3. តើ គេខាន បានទិយាយអ្វីខ្លះ ដែលជាមូលហេតុនៃទុក្ខវេទនារបស់ប្រជាជនលិមហៃ កំពុងទទួល?
4. តើរឿងនេះបើកបង្ហាញអំពី គេខាន ជាមនុស្សប្រភេទណា?

ខ្ សរសេរជាចំណោទមួយ

ចេញពីការអានរបស់អ្នក នៅម៉ូសាយ 20 ចូរសរសេរសំនួរប្រាំអំពីព្រឹត្តិការណ៍សំខាន់ឲ ឬគោលការណ៍នៅក្នុងជំពូកនោះ។ ត្រូវឱ្យប្រាកដថា មានបញ្ជូលចំលើយ និងខទាំងឡាយ ដែលចំលើយត្រូវបានរកឃើញ បន្ទាប់ពីសំនួរនីមួយឲ។

ម៉ូសាយ 21–22
សេវកភាព និងការំដោះ

បើអ្នកស្ថិតក្នុងសេវកភាព ចំពោះសត្រូវដែលបានប្រើអ្នក ដូចជាសត្វមួយ ហើយបានប្រើអ្នកវែកបន្ទុកធ្ងន់ឲ តើអ្នក នឹងនិយាយអ្វី ដើម្បីបានសេរីភាព របស់អ្នកវិញ? តើអ្នកនឹងងាកទៅសុំជំនួយពីកន្លែងណា? នៅពេលអ្នកអានម៉ូសាយ 21–22 ចូរស្វែងរក អ្វីដែលប្រជាជនលិមហៃ បានធ្វើនៅក្នុងស្ថានភាពនោះ។ ចូរធ្វើការកត់ចំណាំជងដែរ ពីរបៀប ដែលការព្យាករណ៍ របស់អ៉ប៊ីណាដៃ នៅបន្ត ដើម្បីបានបំពេញ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 21

ទួញសោក (ខ. 9)—ការបង្ហាញពីការបាត់បង់, ការសោកស្តាយ

ដាក់ខ្លួនក្រោម (ខ. 13)—ប្រគល់ឱ្យ

ចំរើនឡើងបន្តិចម្តងឲ (ខ. 16)—បានទទួលពរបន្តិចម្តងឲ

ម៉ូសាយ 21៖22–24—រឿងពីរមកជាមួយគ្នា ម្តងទៀត

វាគឺជាជំនួយមួយ ដើម្បីចងចំាថា ម៉ូសាយ 1–8 គឺជាការសង្ខេបរបស់មរមន នៃបញ្ជីប្រវត្តិរបស់ម៉ូសាយ និងមានកត់ត្រារឿង របស់នីហ្ចៃ ក្នុងដែនដីសាវ៉ាហ៊ិមឡា រហូតដល់រជ្ជកាលនៃស្តេច ម៉ូសាយ ទី2 (សូមមើល "តារាងកាលបរិច្ឆេទ នៃព្រះគម្ពីរមរមន" ទំព័រ 213)។ ម៉ូសាយ 9–22 បានយកចេញពីបញ្ជីប្រវត្តិនៃ ស៊ីនឹព និងប្រាប់អំពីរឿងរបស់សាសន៍នីហ្ចៃ ដែលបានចាកចេញពីដែនដី សាវ៉ាហ៊ិមឡា នៅជំនាន់របស់ម៉ូសាយ ទី1 ហើយបានដើរតាម ស៊ីនិព្វត្រឡប់ទៅកាន់ដែនដីលីហៃ-នីហ្ចៃវិញ។



នៅក្នុងម៉ូសាយ 7–9 យើងបានអានថា ម៉ូសាយ ទី2 បានបញ្ជូនបេសកកម្មមួយ ដែលដឹកនាំដោយអាំម៉ូន ដើម្បីស៊ើបពីអ្វីដែល បាន កើតឡើងចំពោះ កាលវិទ្យារបស់ស៊ីនិព្វ ដែលបានចាកចេញពី

ដែនដីសារ៉ាហិមឡា ជាងហាសិបឆ្នាំមុន។ អាំម៉ូនបានរកឃើញ ចោរបស់សិនិព្វ ស្តេចលិមហៃ និងប្រជាជនរបស់ទ្រង់នៅក្រោមសេរភាព របស់សាសន៍លេមិន។ នៅក្នុងម៉ូសាយ 21 យើង បានអានអំពីការមកដល់របស់អាំម៉ូន និងមនុស្សរបស់លោក ចេញមកពីទស្សន៍របស់លិមហៃ។

ម៉ូសាយ 22

នៅពេលនេះ (ខ. 3–4)—ពីមុន, ពីមុននេះ

ផ្សាយព្រាប់ (ខ. 6)—សេចក្តីប្រកាស, ការប្រកាស

ពន្ធដារ (ខ. 7)—ពន្ធ, បង្កិតបង្ខំឱ្យបង់ ដើម្បីឱ្យមានសេចក្តីសុខសាន្ត

ស្បៀងអាហារ (ខ. 7)—ម្ហូបអាហារ និងសម្ភារៈផ្សេងៗ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ ចេញពីសកម្មភាព (ក–គ) ដូចខាងក្រោម នៅពេលអ្នកសិក្សាម៉ូសាយ 21–22។

ក តើការព្យាការណ៍នេះ ត្រូវបានបំពេញដោយរបៀបណា?

ទោះបីជាអ័ប៊ីណាដៃ ត្រូវបានសំលាប់តាំងពីយូរមុនទោះក៏ដោយ ការព្យាករណ៍របស់លោកនៅតែបំពេញ។

1. ចូរប្រៀបធៀបម៉ូសាយ 12:1–8 ទៅ 21:1–8។ ចូរពន្យល់ពីអ្វីដែលបានកើតឡើង ចំពោះប្រជាជនលិមហៃ ដែលអ័ប៊ីណាដៃ បានព្យាករ។
2. ចូរប្រៀបធៀប ម៉ូសាយ 11:23–25 ទៅ 21:13–15។ ចូរពិពណ៌នាពីអ្វីផ្សេងៗទៀត ដែលបានកើតឡើង ចំពោះប្រជាជនរបស់លិមហៃ ដែលត្រូវបានព្យាករដោយអ័ប៊ីណាដៃ។

ខ ស្វែងរកមូលហេតុពិត

ដូចដែលព្យាការីអ័ប៊ីណាដៃបានធ្វើការព្យាករណ៍ ប្រជាជនរបស់លិមហៃត្រូវបានដាក់ក្រោមសេរភាព របស់ពួកសាសន៍ លេមិន។ នៅក្នុងស្មៅវគៅ សរសេររបស់អ្នក ចូរគូសតារាងមួយដូចរូបភាពខាងក្រោមៈ

ការព្យាយាមរត់គេច	លទ្ធផល
ម៉ូសាយ 21:6–9	
ម៉ូសាយ 21:10–11	
ម៉ូសាយ 21:12	
ម៉ូសាយ 21:25–26 (ម៉ូសាយ 8:7–8)	
ម៉ូសាយ 21:13–15, 22:1–16	

1. ចូរសិក្សាពីខគម្ពីរ ដែលបានធ្វើបញ្ជីនៅក្នុងកូឡោនទីមួយ ហើយនៅក្នុងកូឡោនដូចគ្នានោះ ធ្វើការពិពណ៌នាដោយសង្ខេបៗ ពីការព្យាយាមរបស់ប្រជាជនលិមហៃ បានធ្វើដើម្បីរត់គេចពីសេរភាពរបស់ពួកសាសន៍លេមិន។ បន្ទាប់មក នៅក្នុងកូឡោនទីពីរ ធ្វើការពិពណ៌នាពីលទ្ធផលនៃការព្យាយាមទីមួយៗ។
2. សូមរំលឹកឡើងវិញពីអ្វីដែលអ័ប៊ីណាដៃ បានព្យាករនៅក្នុងម៉ូសាយ 11:23 និងប្រើខនោះ ដើម្បីពន្យល់ពីមូលហេតុពិត ដែលការ ព្យាយាមរត់គេចទាំងបួនលើកដំបូង គឺមិនបានសំរេច។
3. ហេតុអ្វីអ្នកគិតថា អាំម៉ូន និងមនុស្សរបស់គាត់មកពីទីក្រុងយេរ៉ូសាឡិម នៅពេលបន្ទាប់ពីប្រជាជនលិមហៃ “គេបានបន្ទាបខ្លួន” ហើយ “បានស្រែកអំពាវនាវទៅកាន់ព្រះ” តែប៉ុណ្ណោះដូច្នេះ (ម៉ូសាយ 21:14)?
4. តើអ្នកគិតថា អ្នកណាដែលបានបំផុសគំនិតដល់គេខាង ដើម្បីគិត ពីគំរោងរត់គេចបានដោគជ័យ?
5. សូមគិតអំពី “សេរភាព” ដែលមានមកទៅពេល មនុស្សម្នាក់ធ្លាក់ក្នុងការល្បួងរបស់អារក្ស។ តើអ្នកមើលឃើញអ្វី ខ្លះអំពីបទពិសោធន៍ របស់ប្រជាជនលិមហៃ ដែលគួរតែអនុវត្តចំពោះការខិតខំប្រឹងប្រែងរបស់យើងដោយផ្ទាល់ ដើម្បីរត់គេច ពីសេរភាពនៃអំពើបាប?

គ គូសផែនទី

ចូរសិក្សា ម៉ូសាយ 21:23–27 និង ម៉ូសាយ 8:7–9 និងគូសផែនទីដែលជាការបង្ហាញពីផ្លូវដែលអាចធ្វើទៅបាន នៅពេលដែល ប្រជាជនលិមហៃចំនួនសែសិបបីនាក់ បានធ្វើបេសកកម្ម។ ចូរបង្ហាញពីផែនដីដែលពួកគេបានស្វែងរក ហើយទីងផែនដីដែលពួកគេ បាន រកឃើញជំនួសឱ្យផែនដីដែលពួកគេបានស្វែងរកនោះ។ ចូរប្រើរូបភាពផែនដីនៃព្រះគម្ពីរមរមន នៅក្នុងស្មៅវគៅ ណែនាំការ សិក្សានេះ (ទំព័រ 91) សំរាប់ជាជំនួយ។

ម៉ូសាយ 23–24
សេរភាព និងសង្គ្រោះ សំរាប់ប្រជាជនអាលម៉ា

ដោយការត្រឡប់ទៅយេរ៉ូសាឡិមវិញប្រកបដោយសុវត្ថិភាព របស់ប្រជាជនលិមហៃ ម៉ូសាយ 23–24បាន ផ្តាស់ប្តូរចេញ ពីប្រជាជនរបស លិមហៃ ឆ្ពោះទៅរកអ្វីដែលបានកើតឡើង ចំពោះអាលម៉ា និងអ្នកដែលជឿ ដែលបានដើរតាមគាត់។ យើងបានអានពីការរត់គេចរបស់ពួកគេ ពីទាហាននៃស្តេចណូអេ នៅក្នុងម៉ូសាយ 18។ នៅពេលដែលអ្នកអានជំពូកនេះ អ្នកនឹងស្វែងយល់ផងដែរ ពីអ្វីដែលបានកើតឡើងចំពោះដៃគូរមុនរបស់អាលម៉ា—ពួកសង្ឃទុច្ចរិតរបស់ស្តេចណូអេ។ ពួកគេបន្តការបញ្ចុះបញ្ចូល ក្នុងវិធីដ៏ទុច្ចរិតរបស់ពួកគេ។ នៅពេលអ្នកអាន ចូរធ្វើការកត់ចំណាំពីការព្យាករណ៍របស់អ័ប៊ីណាដៃ កំពុងបន្តនៃការបំពេញ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 23

ចំាបាច់ (ខ 7)—សមរម្យ, ដែលផ្តល់ជំរុញ

លើកដំកើង (ខ 7)—ឲ្យតំលៃ, គោរព

អន្ទាក់ (ខ 9)—អង្គប់

ជីធ្ងន់ធ្ងរ (ខ 9)—ពោរពេញទៅដោយទុក្ខព្រួយ, ពោរពេញទៅដោយការឈឺចាប់

ការលំបាក (ខ 10)—ការទទួលរងទុក្ខវេទនា

ចំណង (ខ 13)—ទាសភាព

ចំណងនៃអំពើទុច្ចរិត (ខ 13)—ការដាប់ឃុំឃាំងពិសេរីភាពផ្ទាល់ខ្លួន, លទ្ធផលនៃអំពើបាប

ទាក់ទង (ខ 18)—ការមានទំនាក់ទំនងជាមួយ

ម៉ូសាយ 23:21–24—សេវកភាពសំរាប់ប្រជាជនរបស់អាលម៉ា

ការព្យាករណ៍របស់អ័ប៊ីណាដៃប្រឆាំងនឹងស្តេចណូអេ និងប្រជាជនរបស់ទ្រង់មានជាពីរផ្នែក។ នៅពេលដែលអ័ប៊ីណាដៃ បានព្រមានដល់ពួកគេ នៅលើកទីមួយលោកបានប្រាប់ដល់ពួកគេថា ពួកគេនឹងទទួលរងទុក្ខវេទនា និងសេវកភាព បើពួកគេមិន ប្រែចិត្តទេនោះ (សូមមើល ម៉ូសាយ 11)។ នៅពេលដែលលោកព្រមានពួកគេជាលើកទីពីរ ពីរឆ្នាំក្រោយមក ពួកគេនៅតែមិនប្រែ ចិត្ត។ នៅក្នុងការព្រមានជាលើកទីពីររបស់លោក លោកបានប្រាប់ដល់ពួកគេថា សេវកភាព និងទុក្ខវេទនាប្រាកដជាធ្លាក់មកលើ ពួកគេ បើពួកគេនៅតែមិនប្រែចិត្ត ពួកគេនឹងត្រូវកំទេចចោល (សូមមើល ម៉ូសាយ 12)។ ទោះបីជាអាលម៉ា និងប្រជាជន របស់គាត់បានប្រែចិត្តបន្ទាប់ពីការព្រមានជាលើកទីពីររបស់អ័ប៊ីណាដៃ ពួកគេមិនប្រែចិត្តឆាប់ៗឲ្យគ្រប់គ្រាន់ ដើម្បីរត់គេចពីការ ព្យាករណ៍អំពីពីសេវកភាព និងទុក្ខវេទនានោះទេ។

ម៉ូសាយ 24

ឈ្លាសវៃ (ខ 7)—ឆ្លាត, បោកបញ្ឆោត

លួចប្លន់ (ខ 7)—ការលួចប្លន់ដោយបង្ខិតបង្ខំ

លង់លក់ (ខ 19)—ជ្រៅ, ធ្ងន់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរដូចខាងក្រោម (ក–ឃ)នៅពេលអ្នកសិក្សានៅក្នុងម៉ូសាយ 23–24។

ក ការថែរក្សាមនុស្ស និងទីកន្លែងដោយយកចិត្តទុកដាក់



ឱយ៉ាក្រោមដែលមានភ្ជាប់មកជាមួយ គឺចេញពីវគ្គនៃ "តារាងកាលវិទ្យារបស់ព្រះគម្ពីរមរមន" (សូមមើលទំព័រ 213)។ គូសតារាង ឬផ្តាននវាឲ្យដូច នៅក្នុងសៀវភៅសរសេររបស់អ្នក និងអានរបស់អ្នកចេញពី ម៉ូសាយ 1–24 ហើយសរសេរឈ្មោះ និងទីកន្លែង ដូចខាងក្រោម និងទីកន្លែងដែលពួកគេធ្វើដំណើរទៅលើតារាង៖ សិទ្ធិ ម៉ូសាយទី1 ស្តេចណូអេ អ័ប៊ីណាដៃ ស្តេចបេនយ៉ាមីន ស្តេចម៉ូសាយទី2 ស្តេចលិមហៃ អាលម៉ាដាបង ដែនដីសារ៉ាហិមឡា ដែនដីលីហៃ-នីហ្វៃ។

ខ ពន្យល់ពីអ្វីដែលមិនបានគិតទុក

នៅក្នុងម៉ូសាយ 23:16–24:4 មានព្រឹត្តិការណ៍ជាច្រើនដែលបានកើតឡើង ដែលហាក់ដូចជាព្រឹត្តការណ៍មិនធម្មតា។ ធ្វើការ សិក្សារាល់សំនួរទីមួយៗ នៅខាងក្រោម ហើយពន្យល់ថា ហេតុអ្វីអ្នកគិតថា ព្រឹត្តិការណ៍ទីមួយៗបានកើតឡើង បែបយ៉ាងដូច្នោះ៖

1. តើអ្នកជឿថា ព្រះអម្ចាស់បានអនុញ្ញាតឲ្យអាលម៉ា និងប្រជាជនរបស់គាត់ធ្លាក់ក្នុងសេវកភាពចំពោះពួកសាសន៍លេមិន នៅពេលដែលពួកគេបានប្រែចិត្ត និងសុចរិត? (ត្រូវប្រាកដ ដើម្បីបញ្ចូលពីអ្វីដែលអ្នកបានរៀនចេញពីម៉ូសាយ 11:23, 12:1–2 នៅក្នុងចំលើយរបស់អ្នក សូមមើល វគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" ម៉ូសាយ 23:21–24 សំរាប់ជាជំនួយបន្ថែម។)
2. តើអ្នកគិតថា ហេតុអ្វីបានជាស្តេចរបស់ពួកសាសន៍លេមិន (ដែលដេញតាមប្រជាជនលិមហៃ) មានសេចក្តីមេត្តា ករុណាចំពោះអាលម៉ា និងប្រជាជនរបស់គាត់?
3. តើអ្នកគិតថា ហេតុអ្វីបានជាកូនស្រីរបស់ពួកសាសន៍លេមិន សូមអង្វរដល់ពួកសាសន៍លេមិន ដើម្បីឲ្យមានទូវសេចក្តី មេត្តាករុណា ទៅលើពួកសង្ឃទុច្ចរិតទាំងនោះ ដែលជាអ្នកចាប់ចំរិតពួកគេ?
4. តើហេតុអ្វីអ្នកគិតថា អាមូឡុន និងពួកសង្ឃទុច្ចរិតផ្សេងៗទៀត ត្រូវបានឲ្យនូវមុខតំណែងនៃអំណាចក្នុងចំណោមពួក សាសន៍លេមិន?

គ ធ្វើការប្រៀបធៀបតួអង្គ

ទាំងអាមូឡុន និងអាលម៉ា សុទ្ធតែធ្លាប់ធ្វើជាសង្ឃនៅមុខតុលាការ នៃស្តេចណូអេ តែពួកគេត្រូវបានទទួលនូវផ្លូវដ៏ពិបាក តាំងពីពេលនោះមក។

1. ធ្វើការស្វែងរកនៅក្នុង ម៉ូសាយ 23:6–20 និង អាលម៉ា 24:8–12 ហើយសរសេរនូវកថាខ័ណ្ឌដែលប្រៀបធៀបពីប្រភេទ នៃមនុស្សដូចជាអាលម៉ា បានក្លាយជាមនុស្សប្រភេទដូចជា អាមូឡុន។
2. តើភាពខុសគ្នាទាំងនេះបង្រៀនអ្នកអំពីអ្វី ដែលមានឥទ្ធិពលលើសក្តិភាពនៃដំណឹងល្អ ដែលកើតមានចំពោះមនុស្ស? តើអ្នកគិត ថាហេតុអ្វីបានជាមនុស្សទុច្ចរិតមានកំហឹងចំពោះអ្នកទាំងឡាយណា ដែលព្យាយាមធ្វើល្អ?

ឃ ប្រៀបធៀបការរត់គេច

មានការចាប់អារម្មណ៍ដែលខុសប្លែកគ្នាមួយចំនួន ពីរបៀបដែលអាលម៉ានិងប្រជាជនរបស់គាត់ត្រូវបានដោះលែងពីកណ្តាប់ដៃ របស់ពួកសាសន៍លេមិន និងពីរបៀបដែលលិមហៃ និងប្រជាជនរបស់គាត់ត្រូវបានសង្គ្រោះ។ សង្គ្រោះបានមកពីការសិក្សានៃ ម៉ូសាយ 21–24 រួចឆ្លើយនូវសំនួរដូចខាងក្រោម៖

1. តើភាពខុសគ្នាអ្វីខ្លះ ដែលអ្នករកឃើញទាក់ទងនឹង *ពេល* ដែលក្រុមនីមួយៗ បានសំរេចចិត្តងាកទៅរកព្រះអម្ចាស់វិញ តាមរយះការអធិស្ឋានសំរាប់ការរំដោះឱ្យរួច? (ប្រៀបធៀប ម៉ូសាយ 21:11–15 និង 23:25–29, 24:9–12)។
2. តើមានភាពខុសគ្នាអ្វីដែលអ្នករកឃើញ ដែលជារបៀបដែលព្រះអម្ចាស់បានជួយក្រុមនីមួយៗ ជាមួយនឹងបន្ទុករបស់ពួកគេ? (ប្រៀបធ្យៀប ម៉ូសាយ 21:15–17 និង 24:13–15)។
3. តើមានភាពខុសគ្នាអ្វីដែលអ្នករកឃើញ នៅក្នុងការពាក់ព័ន្ធនៃព្រះអម្ចាស់ ពីអ្វីដែលបានកើតឡើងចំពោះអ្នកយាម ពួកសាសន៍លេមិន ដែលអនុញ្ញាតឱ្យក្រុមនីមួយៗ រត់បាត់ទៅ? (ប្រៀបធៀប ម៉ូសាយ 22:3–11 និង 24:16–19)។
4. តើមានភាពខុសគ្នាអ្វីខ្លះ ដែលអ្នករកឃើញនៅក្នុងការចូលរួមពាក់ព័ន្ធរបស់ព្រះអម្ចាស់ ចំពោះអ្វីដែលបានកើតឡើងជាមួយ ពួកទាហានដែលត្រូវបានបញ្ជូនទៅចាប់ក្រុមនីមួយៗនោះ? (ប្រៀបធៀប ម៉ូសាយ 22:13–16 និង 24:20–25)។
5. តើការសាកល្បង និងឧបសគ្គក្នុងពេលបច្ចុប្បន្ទនេះ ស្រដៀងនឹងអ្វីដែលប្រជាជនអាលម៉ាបានប្រឈមមុខ ដូចម្តេចខ្លះ?
6. តើគំរូអ្វីខ្លះ ដែលធ្វើឱ្យចិត្តរឹងរូស ពេលបច្ចុប្បន្ទនេះ?

ម៉ូសាយ 25

អាលម៉ាបានរៀបចំឡើងនូវ សាសនាចក្ររបស់ព្រះ

ក្រុមខុសៗគ្នា នៃពួកសាសន៍នីហ្វៃ នៅទីបញ្ចាប់បានត្រឡប់រកគ្នាវិញ ដោយមានសុវត្ថិភាពនៅក្នុងដែនដីសាវ៉ាហិមឡា។ ឧបមាថា អ្នកគឺជាសាសន៍នីហ្វៃដែលរស់នៅក្នុងដែនដីសាវ៉ាហិមឡាពេញមួយជំនាន់។ តើអ្នកអាចមានគំនិតអ្វី បន្ទាប់ពីការលឺនូវ រឿងរបស់ ប្រជាជនលិមហៃ និងប្រជាជនរបស់អាលម៉ា? កំណត់ចំណាំពីស្តេចម៉ូសាយទី 2 និងអាលម៉ាបានធ្វើ ចំពោះសុខុមាលភាព របស់ប្រជាជននៅសាវ៉ាហិមឡា។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 25

ចាកចេញ (ខ 7)—បានស្នាក់នៅ, ឧានបន្សល់

ព្រួយបារម្ភ (ខ 11)—ទុក្ខព្រួយ, សោកសៅ

ទូន្មាន (ខ 16)—ជម្រុញ, លើកទឹកចិត្ត, បង្រៀន

ម៉ូសាយ 25:1–4, 13—តើនរណាជានីហ្វៃ?

មនុស្សពីរក្រុមសំខាន់ៗ នៅក្នុងព្រះគម្ពីរមរមន គឺជាពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន។ ទោះបីជាយ៉ាងណាក៏ដោយ មិនថាក្រុមមួយណាឡើយ ត្រូវបានរៀបចំឡើងជាក្រុមមួយដ៏សុចរិត។ ពួកសាសន៍លេមិន មិនត្រឹមតែរួមបញ្ចូល កូនចៅរបស់លេមិន លេមយួល និងអ្នកផ្សេងៗទៀតមកពីរក្រុមរបស់លីហៃ ដែលស្នាក់នៅជាមួយពួកគេ ប៉ុន្តែពួកទុច្ចរិត សាសន៍នីហ្វៃដែលក្រោយមកបានចូលរួមជាមួយពួកគេ។ ពួកសាសន៍នីហ្វៃ មានរួមទាំងកូនចៅ នៃសាសន៍នីហ្វៃ និងអ្នកដែលមកពីក្រុមរបស់លីហៃ ដែលបានធ្វើតាមគាត់ ព្រមទាំងប្រជាជននៃដែនដីសាវ៉ាហិមឡា (សូមមើល ម៉ូសាយ 25:13)។



តារាងតំលៃ គឺប្រហែលគ្នា

វាប្រហែលជាងាយស្រួលជាងដើម្បីចងចាំថា ជាទូទៅ ពួកសាសន៍នីហ្វៃគឺជាអ្នកទាំងឡាយណាដែលធ្វើតាម ដំណឹងល្អនៃ ព្រះយេស៊ូវគ្រីស្ទ ហើយពួកសាសន៍លេមិនបានធ្វើតាមដំណឹងល្អឡើយ។ មានប្រជាជនច្រើនជាងពីរដង នៃអស់អ្នកដែល ត្រូវបានហៅថា ពួកសាសន៍លេមិន នៅពេលដែលមាន ពួកសាសន៍លេមិន ដែលជាពួកសាសន៍នីហ្វៃ និងប្រជាជននៃ ដែនដីសាវ៉ាហិមឡា បានប្រមូលផ្តុំគ្នា (សូមមើល ម៉ូសាយ 25:2–3)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សាម៉ូសាយ 25។

ក្ត៉ តើពួកគេមានអារម្មណ៍យ៉ាងណា?

នៅពេលដែលមនុស្សស្តាប់ទូវរៀង ដែលបានកើតឡើង នៅក្នុងកំឡុងពេល និងបន្ទាប់ពីសម័យរបស់ស្តេចណូអេ ពួកគេ "កើត សេចក្តីអស្ចារ្យហើយងឿងឆ្ងល់ជាខ្លាំង" (សូមមើល ម៉ូសាយ 25:7)។ អានទូវខខាងក្រោម ហើយពិពណ៌នាពីអ្វីដែលអ្នក បានដឹងថា ពួកគេមានអារម្មណ៍យ៉ាងណា។ លេខ 1 ត្រូវបានឱ្យជាគំរូមួយ។

1. ម៉ូសាយ 25:8—ពួកគេបានដឹងថា ប្រជាជនលិមហៃ ត្រូវបានរំដោះចេញពីសេវកភាពរបស់ពួកសាសន៍លេមិន។ រឿងនោះ បានធ្វើឱ្យពួកគេមានសេចក្តីអំណរយ៉ាងខ្លាំង។
2. ម៉ូសាយ 25:9
3. ម៉ូសាយ 25:10
4. ម៉ូសាយ 25:11
5. ម៉ូសាយ 25:12

ខ ការជួបជុំនៅក្នុងដែនដីសាវ៉ាហិមឡា

1. នៅក្នុងម៉ូសាយ 25:1 យើងបានអានថា ម៉ូសាយបានហៅមនុស្សទាំងអស់ឱ្យមកជួបជុំគ្នា។ ការជួបជុំគ្នានេះ អាចប្រៀបធៀប ទៅនឹងសន្និសីទទូទៅ ដែលយើងធ្វើជាទៀងទាត់នៅក្នុងសាសនាចក្រនាពេលបច្ចុប្បន្ទនេះ។ នៅក្នុងស្រៀវភៅសរសេររបស់អ្នក សរសេរជាទំរង់រប្រៀបវារះ ឬរបាយការណ៍ដូចដែលបង្ហាញនៅទីនេះ ហើយបំពេញវា នៅក្នុងស្រៀវភៅសិក្សា របស់អ្នក ខគម្ពីរទាំងឡាយដែលបានសរសេរទុក។

រប្រៀបវារះនៃការប្រជុំក្នុងដែនដីសាវ៉ាហិមឡា
កាលបរិច្ឆេទះ (សូមមើលកាលបរិច្ឆេទដែលបាន ផ្តល់ជាយោបល់ម៉ូសាយ 24:25)
គណះអធិបតីះ (សូមមើល ម៉ូសាយ 25:1)

អ្នកឡើងនិយាយទី1ៈ (សូមមើល ម៉ូសាយ 25ៈ5)
ប្រធានបទៈ (សូមមើល ម៉ូសាយ 25ៈ15–16)
ការឆ្លើយតបពីប្រជាជនៈ (សូមមើល ម៉ូសាយ 25ៈ17)

អ្នកឡើងនិយាយទី2ៈ (សូមមើល ម៉ូសាយ 25ៈ14)
ប្រធានបទៈ (សូមមើល ម៉ូសាយ 25ៈ15–16)
ការឆ្លើយតបពីប្រជាជនៈ (សូមមើល ម៉ូសាយ 25ៈ17)

បន្ទាប់ពីសន្និសីទៈ
(សូមអាន ម៉ូសាយ 25ៈ18–23 ហើយពិពណ៌នាពីអ្វីដែលបានកើតឡើងបន្ទាប់ពីការប្រជុំដ៏សំខាន់នេះ។)

2. តើបទពិសោធន៍របស់ពួកគេអាចអនុវត្តចំពោះទៅនឹងសម័យរបស់យើងបានយ៉ាងដូចម្តេច?
3. យោងតាមម៉ូសាយ 25ៈ24 តើព្រះអម្ចាស់បានធ្វើអ្វីខ្លះសំរាប់ប្រជាជនទាំងនេះ?
4. តើហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីដឹង ពីអ្វីដែលព្រះអម្ចាស់បានធ្វើសំរាប់ពួកគេ?

ពួកសាសន៍នីហ្វៃទាំងអស់ត្រឡប់មកដែនដីសារ៉ាហិមឡាវិញដោយសុវត្ថិភាព និងបានរួចផុតពីសាសន៍លេមិន អ្នកប្រហែលជាគិត ថា ជីវិតអាចនោរពេញទៅដោយសេចក្តីសុខសាន្ត និងគ្មានបញ្ហាអ្វីសោះ។ តែជីវិតហាក់ដូចជាមិនមែនតែងតែដូច្នោះទេ។ មនុស្សពេញវ័យជាច្រើនទៅក្នុងចំណោមពួកសាសន៍នីហ្វៃ បានទទួលនូវបទពិសោធន៍នៃឧបសគ្គដ៏ពិបាកជំបុង ដែលមកពីអំពើ ទុច្ចរិត និងសេចក្តីអំណរ ដែលមកពីការទទួលនូវការអភ័យទោសពីព្រះអម្ចាស់ និងសេចក្តីសង្គ្រោះ។ កូនចៅរបស់ពួកគេ ទោះជា យ៉ាងណាក៏ដោយ ពុំទទួលបានបទពិសោធន៍ដូចគ្នានោះទេ និងពួកគេជាច្រើនបានបដិសេធន៍នូវការបង្រៀន និងសក្តិភាពពីឪពុក ម្តាយរបស់ពួកគេ។ តើមនុស្សវ័យក្មេងនាពេលបច្ចុប្បន្ននេះ មានភាពស្មុគស្មាញក្នុងរបៀបដូចគ្នានោះទេ ហើយធ្វើការបះបោរ ប្រឆាំងនឹងឪពុកម្តាយ ដែរឬទេ? នៅពេលអ្នកអាន ម៉ូសាយ 26 សូមមើលពីអ្វីដែលព្រះអម្ចាស់បានបញ្ជាក់ ហេតុផលនៃការបះបោរ និងចំពោះការជីកនាំ ឆ្ពោះទៅរកការបះបោរ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 26

បែកបាក់ (ខ 5)—ការមិនយល់ស្របគ្នា, ការឈ្លោះទាស់ទែងគ្នា

ប្រព្រឹត្តអំពើបាប (ខ 6)—បានព្រមានប្រឆាំងនឹងការអនុវត្តអំពើបាប

អំពើទុច្ចរិតផ្សេងៗ (ខ 11)—អំពើបាបផ្សេងៗ

រំលងច្បាប់ (ខ 19)—មនុស្សដែលធ្វើខុសច្បាប់

កម្រិតកិច្ចការ (ខ 37)—ត្រួតត្រា, គ្រប់គ្រង

ប្រយ័ត្នប្រយែង (ខ 37)—ដោយប្រយ័ត្ន, ដោយយកចិត្តទុកដាក់

ម៉ូសាយ 26ៈ5–12—ក្រិត្យវិន័យរបស់ព្រះនិងច្បាប់របស់មនុស្ស

វាជាការសំខាន់ណាស់ដើម្បីយល់ពីភាពខុសគ្នា រវាងអ្វីទៅដែលហៅថា អំពើបាប និងអ្វីទៅដែលហៅថាបទឧក្រិដ្ឋ។ បទឧក្រិដ្ឋគឺជា ការប្រព្រឹត្តល្មើសនិងច្បាប់នៃដែនដី រីឯអំពើបាបគឺជាការប្រព្រឹត្តល្មើសនឹងក្រិត្យវិន័យរបស់ព្រះ។ ជាធម្មតាសកម្មភាពអាចប្រព្រឹត្ត ទៅទាំងពីរ តែសកម្មភាពខ្លះគឺជាអំពើបាប តែប្រហែលជាមិនប្រឆាំងនិងច្បាប់របស់មនុស្សទេ។ អាលម៉ា ស្វែងរកដំបូងពីស្តេច ព្រោះមកពីការធ្វើខុសនៃប្រជាជនរបស់គាត់។ ស្តេចម៉ូសាយបានដឹងថា ទោះបីជាជំនឿជាច្រើនរបស់មនុស្សទាំងនេះ គឺជាជំនឿ ខុសឆ្គង ហើយថា សមាជិកខ្លះៗ នៃសាសនាចក្រត្រូវបានបោកបញ្ឆោតដោយ “ពាក្យបញ្ចោរ” (ម៉ូសាយ 26ៈ6) សមាជិកនៃ សាសនាចក្រមិនជំទាស់ទឹងច្បាប់របស់ទីក្រុងទេ។ បន្ទាប់មកអាលម៉ា ក៏ត្រឡប់ទៅរកព្រះអម្ចាស់វិញ ដើម្បីជួយគាត់អាចប្រឈមមុខ ជាមួយនឹងការប្រព្រឹត្តខុសនៅក្នុងសាសនាចក្រ។ សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 134 សំរាប់វិវរណៈ សម័យថ្មី ស្តីពីប្រធានបទដូចគ្នានេះ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពណាមួយចេញពីសកម្មភាព (ក–ឃ)នៅពេលអ្នកសិក្សាម៉ូសាយ 26។

ក ស្វែងរកមូលហេតុ

វាហាក់ដូចជានៅគ្រប់ជំនាន់ទាំងអស់ គឺមានមនុស្សវ័យក្មេងនៃ “ជំនាន់មនុស្សដែលកំពុងពេញវ័យ” (ម៉ូសាយ 26ៈ1) ដែលជា អ្នកបដិសេធនូវគោលការបង្រៀនរបស់ឪពុកម្តាយរបស់ពួកគេ។ ម៉ូសាយ 26 បានពិពណ៌នានូវ ស្ថានភាព នៅក្នុងដែនដី សារ៉ាហិមឡា។

1. សិក្សាម៉ូសាយ 26ៈ1–5 ហើយបន្ទាប់មកគូសឱយ៉ាក្រាមនៅក្នុងស្បៃវគៅសរសេររបស់អ្នក ដូចជាតារាងដែលបង្ហាញនៅទី នេះ។ យកសញ្ញាសំនួរ (?) មកជំនួសក្នុងប្រអប់ ជាមួយនឹងអ្វីដែលបានជីកនាំទៅរក ឬបណ្តាលឱ្យមានបញ្ហាដែលបានសរសេរនៅ ក្នុងខទាំងនេះ។



2. គិតអំពីមនុស្សដែលអ្នកអាចស្គាល់ ដែលជាអ្នកនឹងមិនព្យាយាមស្គាល់ពីជំណឹងល្អ ឬ អ្នកទាំងឡាយណាដែលប្រកែកមិន ព្រមចូលរួម ឬធ្វើជាសមាជិកសកម្មនៅក្នុងសាសនាចក្រ។ សរសេរកថាខ័ណ្ឌ ដែលជាការពន្យល់ពីភាពស្រដៀងគ្នា ដែលអ្នកឃើញ រវាងមូលហេតុនៃបញ្ហារបស់ពួកគេ និងមូលហេតុនៃបញ្ហាទាំងនោះ នៅក្នុងដែនដីសារ៉ាហិមឡា។
3. អានគោលលទ្ធិ និងសេចក្តីសញ្ញា 136ៈ32–33 ហើយពន្យល់ពីអ្វីដែលយើងអាចធ្វើ ដើម្បីយកឈ្នះបញ្ហា និងមូលហេតុ របស់វា។

២ ស្វែងរកដំណោះស្រាយ

នៅក្នុងម៉ូសាយ 26 មរមនបានពិពណិនាពីបញ្ហាពិបាកព្ធ ដែលអាលម៉ាបានប្រឈមមុខក្នុងនាមជាអ្នកដឹកនាំសាសនាចក្រ។ សេចក្តីប្រកាសជាផ្លូវការចំនួនពីរច្បាប់ នៅចុងបញ្ចប់នៃ គោលលទ្ធិ និងសេចក្តីសញ្ញា ធ្វើការពិពណិនាពីបញ្ហាពិបាកព្ធ ដែលប្រធាន ស្តែនស៊ើរ ដបុលយូ យិមបឹល បានប្រឈមក្នុងនាមជាប្រធានសាសនាចក្រ នៅក្នុងសម័យរបស់យើងនេះ។

1. សិក្សាម៉ូសាយ 26:1–12 ហើយពិពណិនាពីបញ្ហាដែលអាលម៉ាបានប្រឈមមុខ។
2. អានសេចក្តីប្រកាសជាផ្លូវការពីរច្បាប់ ហើយពិពណិនាពីបញ្ហាដែល ប្រធាន ស្តែនស៊ើរ ដបុលយូ យិមបឹល បានប្រឈមមុខ។
3. អានម៉ូសាយ 26:13–14 ហើយសរសេរពាក្ស ឬ ឃ្លាដែលពិពណិនាពីរបៀបដែលអាលម៉ា *ទទួលអារម្មណ៍* នឹងអ្វីដែលគាត់ ត្រូវធ្វើ មុន "សំលេងរបស់ព្រះអម្ចាស់បានបន្លឺមកលោក។"
4. ចូរស្វែងរកសេចក្តីប្រកាសជាផ្លូវការពីរច្បាប់ ហើយសរសេរពាក្ស និងឃ្លាដែលពន្យល់ពីអ្វីដែលប្រធាន ស្តែនស៊ើរ ដបុលយូ យិមបឹល និងគណៈប្រធានទីមួយ បានធ្វើពីមុនពួកលោកបានទទួលវិវរណៈ។
5. តើបញ្ហីទាំងនេះបង្រៀនអ្នកអំពី ការរៀបចំដើម្បីទទួលវិវរណៈ អ្វីខ្លះ?

៣ ស្វែងរកពរជ័យ

ពាក្យថាប្រទាន *ពរជ័យ* គឺត្រូវបានបញ្ជាក់នៅក្នុងខនីមួយៗ នៃម៉ូសាយ 26:15–19។

1. ស្វែងរកខទាំងនោះ ហើយសរសេរពីអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា នរណាត្រូវបានទទួល "ពរជ័យ" នៅ រាល់ខនីមួយៗ ហើយ*រហតុអ្វី* ពួកគេត្រូវបានប្រទានពរជ័យ។
2. តើសេចក្តីសញ្ញា ឬ ការសន្យាអ្វីខ្លះ ដែលព្រះអម្ចាស់ប្រទានដល់អាលម៉ា នៅក្នុងម៉ូសាយ 26:20?

៤ ស្វែងរកចំលើយ

អាលម៉ាបានស្វែងរកព្រះអម្ចាស់យើញ និងបានទទួលវិវរណៈ នូវអ្វីដែលត្រូវធ្វើស្តីអំពីសមាជិកនៃសាសនាចក្រ ដែលប្រព្រឹត្ត អំពើបាប ធ្ងន់ធ្ងរ។ នៅពេលដែលអ្នកអាន ម៉ូសាយ 26:21–39 ស្វែងរកចំលើយ សំរាប់សំនួរដូចខាងក្រោមៈ

1. តើព្រះអម្ចាស់បានធ្វើអ្វី សំរាប់អ្នកទាំងឡាយណាដែលជឿ និងបានទទួលបុណ្យជ្រមុជទឹក? (សូមមើល ខ 21–24)។
2. តើអស់អ្នកដែលជំទាស់មិនព្រមប្រែចិត្ត និងទទួលស្គាល់ដំណឹងល្អ មានជោគវាសនាយ៉ាងដូចម្តេច? (សូមមើល ខ 25–28)។
3. តើសាសនាចក្រត្រូវធ្វើយ៉ាងដូចម្តេចនៅពេលដែលសមាជិកប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ និងក្រោយមកប្រែចិត្ត? (សូមមើល ខ 29–31)។
4. តើសាសនាចក្រត្រូវធ្វើយ៉ាងដូចម្តេច នៅពេលដែលសមាជិកគ្មានរនួះ ប្រែចិត្ត? (សូមមើល ខ 32)។
5. តើវាមានន័យយ៉ាងដូចម្តេច ក្នុងការ "មិនបានរាប់ចូល" ក្នុងចំណោមប្រជាជនរបស់ព្រះអម្ចាស់? (សូមមើល ខ 36)។
6. តើសកម្មភាពរបស់អាលម៉ាអ្វីខ្លះ ដែលជះឥទ្ធិពលចំពោះសាសនាចក្រ? (សូមមើល ខ 37–39)។

ម៉ូសាយ 27

ការផ្លាស់ប្តូរគំនិតរបស់អាលម៉ាជាកូន

តើអ្នកគិតថា អ្នកអាចមានអារម្មណ៍បែបណា បើអ្នកខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា ដើម្បីបានសំរេចអ្វីមួយ តែត្រាន់ ដើម្បីឱ្យនរណា ម្នាក់មក ព្យាយាមបំផ្លាញ អ្វីដែលអ្នកកំពុងធ្វើ តែប៉ុណ្ណោះ? តើវាធ្វើឱ្យមានភាពខុសគ្នាទេ បើមនុស្សដែលកំពុងព្យាយាមបំផ្លាញ នូវការងាររបស់អ្នកនោះ គឺជាមនុស្សម្នាក់ដែលអ្នកស្រលាញ់? រឿងទាំងនោះគឺជាស្ថានភាពមួយទាំងព្យាការី អាលម៉ា និងស្តេចម៉ូសាយបានប្រឈមមុខ។ នៅក្នុងម៉ូសាយ 27 អ្នកនឹងអាន ពីចេទនាដែលចង់បំផ្លាញការងារ របស់បុរសដ៏ អស្ចារ្យទាំងនេះ គឺជាកូនប្រុសផ្ទាល់របស់ពួកគេ! នៅពេលអ្នកអាន ធ្វើការកត់ចំណាំពីសេចក្តីជំនឿ នៃឱពុកដ៏ល្អ និងរនួះរបស់ ព្រះវរបិតាដែល គង់នៅឯស្ថានសួគិរបស់យើង ដែលផ្តល់រង្វាន់សំរាប់សេចក្តីជំនឿ ដ៏អស្ចារ្យ។ ព្រឹត្តិការណ៍នៃជំពូកនេះ មានរឿងដែល ធ្វើឱ្យរំភើបខ្លាំង ហើយជះឥទ្ធិពលដល់ក្រុមយុវជនទាំងនោះ ព្រមទាំងដល់ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនផងដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 27

ការប្រៀតប្រៀន (ខ 1)—បង្ខិតបង្ខំ, ធ្វើឱ្យខ្លាច

ការឡើងចាង (ខ 4)—ឬកកោង, ភាពឆ្មើងឆ្មៃ

គោរព (ខ 4)—គោរពតំលៃ

ឧបសគ្គមួយដ៏ធំ (ខ 9)—ការរារាំង, ឧបសគ្គ

បែកចេញ (ខ 18)—បំបែកជាផ្នែក

ទូន្មាន (ខ 23)—ការអញ្ជើញ, ការលើកទឹកចិត្ត

ប្រម៉ាត់ល្វីងជូរចត់ (ខ 29)—ទំរង់នៃភាពល្វីងជូរចត់ដ៏លើសលប់បំផុត

ជ្រោះជ្រៅ (ខ 29)—រណ្តៅដ៏ជ្រៅ, ជំរៅដ៏សែនជ្រៅ

ទុក្ខវេទនា (ខ 29)—បានធ្វើទារុណកម្មយ៉ាងខ្លាំង

ល្ងងលោមចិត្ត (ខ 33)—ល្ងងលោម, ធានារ៉ាប់រង

ធ្ងន់ធ្ងរ (ខ 33)—ភាពលំបាក, ធ្ងន់ធ្ងរ

អស់ពីចិត្ត (ខ 35)—យ៉ាងរំភើបចិត្ត, យ៉ាងអន្ទះសារ

ម៉ូសាយ 27:11–26—ការផ្លាស់ប្តូរសាសនាដ៏គួឱ្យកត់សំគាល់របស់អាលម៉ាជាកូន

ដំណើររឿងនៃការផ្លាស់ប្តូរសាសនារបស់អាលម៉ាជាកូន គឺជាគំរូដ៏អស្ចារ្យ ចំពោះដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ បានធ្វើដល់ សំរាប់ជនទាំង ឡាយណាដែលប្រែចិត្ត។ ដើម្បី "ទទួលការប្រោសលោះពីព្រះអម្ចាស់" (ម៉ូសាយ 27:24) ទោសកំហុសត្រូវ បានសង្រ្គោះ, តម្លៃ លោះ ឬនាំមកវិញពីស្ថានភាពជំពាក់បំណុលដ៏ធំ (សូមមើល ខ 27–29)។ ដើម្បី "កើតដោយព្រះ វិញ្ញាណ" "កើតម្តងទៀត" ឬ "កើតមកពីព្រះ" មានន័យថា ដើម្បីមានការផ្លាស់ប្តូរពីសភាពធ្លាក់ចុះនៃលោកិយ ទៅកាន់ "ស្ថានភាពនៃសុចរិតវិញ" និងក្លាយជា "សត្វលោកថ្មី" (ខ ទី 25–26)។ យើងទាំងអស់គ្នានឹងមិនធ្វើជាទាសករនៃអំពើបាបទៀត ទេ តែមានសេចក្តីប៉ងប្រាថ្នាធ្វើអំពើ ល្អជានិច្ចវិញ (សូមមើល ម៉ូសាយ 5:2)។

រឯរៀងនៃការផ្លាស់ប្តូរគំនិតរបស់អាលម៉ាជាកូន មានការចាប់អារម្មណ៍យ៉ាងខ្លាំង ប្រធានអែសរ៉ា ថាហ្ព ប៉ែនសឹន បានផ្តល់នូវ ការដាស់តឿនដូចខាងក្រោមៈ

"យើងត្រូវតែប្រយ័ត្នប្រយែង នៅពេលដែលយើង ព្យាយាមប្រែក្លាយដើម្បីឱ្យកាន់តែ ដូចព្រះ ដែលយើងមិនត្រូវបាត់ទឹកចិត្ត និងបាត់បង់សេចក្តីសង្ឃឹម។ ការប្រែក្លាយឱ្យដូចជាព្រះយេស៊ូវគ្រីស្ត គឺជាដំណើរជីវិត ហើយជាញឹកញាប់ និងផ្លាស់ប្តូរយ៉ុតឲ ដែលស្ទើរតែមើលមិនឃើញ។ ព្រះគម្ពីរបានកត់ត្រាដំណើររៀងដ៏អស្ចារ្យនៃមនុស្ស ដែលមានជីវិតផ្លាស់ប្តូរប្រកបដោយការ ពេញចិត្តៈ អាលម៉ាជាកូន ប៉ុលធ្វើដំណើរទៅកាន់ ដាម៉ាស អេណុស អធិស្ឋានយ៉ាងខ្លាំងរហូតដល់យប់ស្តេចឡាម៉ូណៃ។ គំរូដ៏គួរឱ្យភ្ញាក់ផ្អើលនៃអំណាចនេះត្រូវ ផ្លាស់ប្តូរទោះបីជាអ្នកទាំងនោះ បានប្រឡាក់នៅក្នុងអំពើបាប ដង្វាយធួនអាចឆ្ពោះទៅដល់ការអស់សង្ឃឹមដ៏ជ្រៅនេះបាន។

"តែយើងត្រូវតែប្រយ័ត្នប្រយែង ដូចដែលយើងពិភាក្សា ដោយទុកចិត្តថា គំរូដ៏អស្ចារ្យទាំងនេះ។ ទោះបីជា ការពិភាក្សាពិត ហើយមានអំណាច, ការពិភាក្សានេះជាការលើកលេងច្រើនជាងច្បាប់។ ត្បិតគ្រប់ប៉ុល ត្បិតគ្រប់អេណុស និងត្បិតគ្រប់ ស្តេចឡាម៉ូណៃ មានប្រជាជនរាប់រយនិងរាប់ពាន់ នាក់ដែលស្វែងរកដំណើរការ នៃការប្រែចិត្ត កាន់តែមានល្បិចកលច្រើន កាន់តែមិនអាចយល់បាន។ ពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេកាន់តែខិតជិតព្រះអម្ចាស់ ដោយដឹងតែបន្តិចបន្តួច ពួកគេកំពុងតែ សាងជីវិតដូចជាព្រះ។ ពួកគេរស់នៅដោយស្ងប់ស្ងាត់ក្នុងសេចក្តីល្អ ដោយការបំរើ និងការតាំងចិត្ត . . .។

"យើងមិនត្រូវបាត់បង់សេចក្តីជំនឿទេ។ សេចក្តីសង្ឃឹមគឺជាយុថ្កា ចំពោះព្រលឹងរបស់មនុស្ស។ អារក្សចង់ឱ្យយើងបោះចោលនូវ យុថ្កានោះ។ នៅក្នុងវិធីនេះ អារក្សអាចនាំមកឱ្យយើង នូវការបាត់ទឹកចិត្ត និងការចុះចាញ។ តែយើងមិនត្រូវបាត់បង់សេចក្តី សង្ឃឹមទេ។ ព្រះអម្ចាស់សព្វព្រះហឬទ័យ នៅរាល់ការខិតខំប្រឹងប្រែងរបស់យើង ទោះបីជាវាតូចក៏ដោយ ជាការព្យាយាម ដើម្បីប្រែក្លាយឱ្យដូចទ្រង់ជាប្រចាំថ្ងៃ។ ហេតុដូច្នេះហើយ យើងអាចយើញថា យើងនៅមានផ្លូវវែងឆ្ងាយឆ្ពោះទៅកាន់ ភាពល្អឥត ខ្ចោះ ដែលជាការការពារ យើង មិនត្រូវបោះបង់សេចក្តីសង្ឃឹមទេ" ("A Mighty Change of Heart" *Ensign,* ខែតុលា ឆ្នាំ 1989, 5)។

ម៉ូសាយ 27:29—តើ "ទុក្ខវេទនាដ៏អស់កល្បជានិច្ច" អាចនៅបានរយៈពេលប៉ុន្មាន?

នៅពេលដែលអាលម៉ាជាកូន បាត់បង់ស្មារតី គាត់បាន "ឆ្លងកាត់ការវេទនាជាច្រើន ការប្រែចិត្ត នៅពេលជិតស្លាប់" (ម៉ូសាយ 27:28)។ ការទទួលរងទុក្ខវេទនារបស់គាត់នោះ ខ្លាំងក្លាណាស់ ដែលគាត់បានពិពណិនាថា ទុក្ខវេទនារបស់គាត់ចាប់ផ្តើម "ញាំញី ដោយការទទួលរងទុក្ខវេទនាដ៏អស់កល្បជានិច្ច" (ខ 29)។ ឃ្លាដែលថា "ទុក្ខវេទនាដ៏អស់កល្បជានិច្ច" អាចជាការភាន់ច្រឡំចាប់តាំងពីយើងបានដឹងចេញពីជំពូកនេះ ថាគាត់បាត់បង់ស្មារតី គឺអស់រយៈពេលជាងពីរថ្ងៃ។

យើងត្រូវតែយល់ថា ពាក្យ *អស់កល្បជានិច្ច* មានអត្ថន័យផ្សេង ចំពោះព្រះអម្ចាស់ ជាជាងចំពោះលោកីយ។ នៅក្នុង វិវរណៈសម័យថ្មីព្រះអម្ចាស់បានមានបន្ទូលថាៈ

"យើងមិនចេះសូន្យឡើយ ហើយទោសដែលយើងចេញពីព្រះហស្តរបស់យើងទៅ គឺជាទោសដ៏មិនចេះចប់មិនចេះហើយ ត្បិតមិន ចេះសូន្យឡើយគឺជាព្រះនាមរបស់យើង។ ហេតុដូច្នោះហើយ—

ទោសដ៏អស់កល្បជានិច្ច គឺជាទោសមកពីព្រះ" (សូមមើល គ និង ស 19:10–11)។

ពាក្យដូចជា "ទុក្ខវេទនាដ៏នៅអស់កល្បជានិច្ច" គឺមានការពិពណិនាច្រើនអំពី*ប្រភេទ* នៃទុក្ខវេទនា (ទុក្ខវេទនារបស់ព្រះ) ជាជាងរយៈពេលនៃការរងទុក្ខ (សូមមើល គ និង ស 19:6–12)។ សូមចងចំាផងដែរថា នេះពិពណិនាអំពីការដាក់ ទណ្ឌកម្មចំពោះអំពើបាប ដែលមិនបានប្រែចិត្ត។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពណាមួយក៏បានចេញពីសកម្មភាព (ក–យ)នៅពេលអ្នកសិក្សា ម៉ូសាយ 27 ។

ក្ស រើសយកសេចក្តីថ្លែងពិតប្រាកដ

បន្ទាប់ពីអានម៉ូសាយ 27:1–7 អានទូវសេចក្តីថ្លែងដូចខាងក្រោម និងចង្អុលបង្ហាញ ថាតើសេចក្តីថ្លែងទាំងនោះ ពិត ឬ ខុស។ បើអ្នកគិតថាសេចក្តីថ្លែងនេះខុស សរសេរវាឡើងវិញឱ្យបានត្រឹមត្រូវ។

1. ពួកសាសន៍នីហ្ចៃ នៅក្នុងដែនដីសារ៉ាហិមឡា ទាំងអស់គ្នាបានរួមរួមគ្នា ក្នុងនាមជាសមាជិករបស់សាសនាចក្រ។
2. ស្តេចបានចេញច្បាប់ថា មនុស្សគ្រប់គ្នាត្រូវគោរពដល់សាសនាចក្រ
3. សមាជិកនៃសាសនាចក្រដែលក្រីក្រ បានរអ៊ូរទាំដោយការប្រព្រឹត្តមិនល្អពីសមាជិកដែលមាន។
4. អ្នកដឹកនាំរបស់សាសនាចក្រទាំងអស់ ជាអ្នកស្មំគ្រចិត្តបំរើដោយគ្មានប្រាក់កំរើ។
5. ព្រោះដោយមានសមាជិកក្រីក្រច្រើនពេកទើបសាសនាចក្របានពុះពារ ចំពោះភាពក្រីក្រនេះ។

ខ សរសេរវាដោយពាក្យផ្ទាល់របស់អ្នក

ការយាងមកនៃទេវតា បានមានឥទ្ធិពលដ៏ខ្លាំងក្លាមកលើអាលម៉ាជាកូន។

1. សិក្សាម៉ូសាយ 28:13–16 សរសេរជាពាក្យរបស់របស់អ្នកឡើងវិញពីអ្វីដែលទេវតាបានមានបន្ទូល។ សូមចងចាំថា ទេវតា ត្រូវបានដឹកនាំ ហើយបានមានបន្ទូលនៅក្នុងរបៀបមួយ ដែលអាលម៉ាមិនអាចដោះសាបាន។
2. តើអ្នករកឃើញអ្វីខ្លះនៅក្នុងខទាំងនេះ ដែលជួយពន្យល់ ពីមូលហេតុដែលព្រះអម្ចាស់បានបញ្ជូនទេវតាទៅកាន់ អាលម៉ាជាកូន និងបុត្រានៃម៉ូសាយ?

ត្ស ដឹកនាំការសម្ភាសន៍

គិតអំពីសមាជិកនៅក្នុងវួដ សាខា សង្កាត់ ឬ មណ្ឌល ឬប្រហែលជាញ្ញាតិសណ្តានរបស់អ្នក ដែលជាអ្នកមានជំនឿទៅលើព្រះ និងគោរពប្រតិបត្តិចំពោះដំណឹងល្អ ដែលអ្នកកោតសរសើរ។

1. ធ្វើការសម្ភាសន៍សមាជិកម្នាក់នោះ ហើយសួរនូវសំនួរដូចខាងក្រោមៈ
   - តើអ្នកទទួលទីបន្ទាល់ នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ត ដោយរបៀបណា?
   - តើទីបន្ទាល់របស់អ្នកបានមានក្នុងរយៈពេលតែមួយ ឬ បានមានក្នុងរយៈពេលដ៏យូរមកហើយ?
   - តើអ្នកត្រូវចំណាយពេលប៉ុន្មាន ដើម្បីបង្ហាញពីគំនិតនៃការគោរព និងសេចក្តីស្មោះត្រង់របស់អ្នក?
2. ពិពណិនាពីលក្ខណៈស្រដៀង ឬខុសគ្នា ពីបទពិសោធន៍របស់ពួកគេ ពីបទពិសោធន៍របស់អាលម៉ាជាកូន នៅក្នុងម៉ូសាយ 27:23–32។
3. សូមអានផងដែរ នូវសេចក្តីថ្លែងការណ៍របស់ប្រធាន អែសរ៉ា ថាហ្ព ប៉ែនសឹន នៅក្នុងវគ្គនៃ "ការយល់ដឹងអំពីព្រះគម្ពីរ" ម៉ូសាយ 27:11–26 និងពន្យល់ពីអ្វីដែលអ្នកបានរៀនអំពី របៀបនៃការប្រែក្លាយឱ្យដូចជាព្រះគ្រីស្ត។

៥ ពន្យល់ពីភាពខុសគ្នានៃរឿងទាំងនោះ

1. រំលឹកឡើងវិញម៉ូសាយ 27:8–10, 32–37 និងពិពណិនាពីរបៀបដែល អាលម៉ាជាកូន និងកូនប្រុសទាំងបួន នៃម៉ូសាយ បានផ្លាស់ប្តូរ ដែលជាលទ្ធផលនៃបទពិសោធន៍ក្នុងការផ្លាស់ប្តូរគំនិតរបស់ពួកគេ។
2. តើបុរសទាំងនេះជាគំរូ យ៉ាងដូចម្តេចដែរ ចំពោះអ្វីដែលម៉ូសាយ 27:25–26 បានបង្រៀនយ៉ាងដូចម្តេច? តើពីគំរូនេះ ង្រៀនយើងអំពីមនុស្សម្នាក់ ដែលបានផ្លាស់ប្តូរគំនិតដ៏ពិតប្រាកដ អ្វីខ្លះ?

ម៉ូសាយ 28
ស្តេចម៉ូសាយ ជាអ្នកមើលឆុត

បើសិនបើអ្នក ឈើដោយសារជំងឺកាចសាហាវ ដែលបានសំលាប់មនុស្សរាប់ពាន់នាក់ ដែលនៅជុំវិញអ្នក ហើយបន្ទាប់មកអ្នកត្រូវ បានឱ្យនូវរូបមន្ត ថ្នាំដ៏មានតទ្ធិពល ដែលបានព្យាបាលអ្នកជាទាំងស្រុង តើអ្នកនឹងធ្វើអ្វីជាមួយនឹងរូបមន្តនៃថ្នាំនេះ? តើអ្នកនឹងរក្សាវាទុក្ខ សំរាប់តែខ្លួនរបស់អ្នកឬ? តើអ្នកនឹងរលក់វាទេ? តើអ្នកនឹងឱ្យវាទៅអ្នកដទៃទេ? ក្នុងរបៀបនេះ ដៀងទៅនឹងស្ថានភាពរបស់កូនប្រុសទាំងបួននៃម៉ូសាយ។ នៅពេលអ្នកអានម៉ូសាយ 28 ចូរមើល "ជំងឺ" នោះជាជំងឺអ្វី និងអ្វីដែល ពួកគេបានធ្វើ ជាមួយនឹងការព្យាបាលដែលពួកគេត្រូវបានផ្តល់ឱ្យ។

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 28

ជាមនុស្សអាក្រក់បំផុត (ខ 4)—មនុស្សទុច្ចរិតបំផុត

ការវេទនា (ខ 4)—សោកសៅ, ទុក្ខព្រួយ

បំភាន់ (ខ 17)—ធ្វើឱ្យភាន់ច្រឡំ

ប្រដាប់បកប្រែ (ខ 20)—យូរីមនិងធូមីម (សូមមើល ខ 13–14 ផងដែរ)

ម៉ូសាយ 28:11–19—តើនៅត្រង់ចំនុចណាដែលយើងអាចរកពតិមានដែលថា ម៉ូសាយបានបកប្រែចេញពីផ្ទាំងមាសនេះ?

ផ្ទាំងមាសត្រូវបានរកឃើញដោយប្រជាជនលិមហៃ ដែលប្រាប់រឿងអំពីពួកសាសន៍យ៉ារេឌ។ មរ៉ូណៃក្រោយមកក៏សរសេរ សង្ខេបពីប្រវត្តិបញ្ហីនោះ ដែលមាននៅក្នុងព្រះគម្ពីរអេធើរ (សូមមើល អេធើរ 1:1)។ សូមមើល "ប្រភពដ៏សំខាន់ នៃព្រះគម្ពីរមរមន" ផងដែរ (ទំព័រ 12)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សាម៉ូសាយ 28។

៣ សរសេរសំបុត្រទៅស្តេចម៉ូសាយ

នៅក្នុងម៉ូសាយ 28:1–5 មរមនបានពន្យល់ពីអ្វី ដែលកូនប្រុសទាំងបួននៃម៉ូសាយ បានអារម្មណ៍អំពីការបំរើបេសកកម្ម ទៅកាន់ពួកសាសន៍លេមិន។

1. សិក្សាខទាំងនោះ នឹងធ្វើការកត់ចំណាំនូវមូលហេតុទាំងអស់ ដែលអ្នកអាចរកឃើញ ហើយពន្យល់ពីមូលហេតុដែលពួកគេចង់ ទៅបំរើបេកកម្ម។
2. សរសេរសំបុត្រទៅកាន់ស្តេចម៉ូសាយ ហាក់ដូចជាអ្នកគឺជាអាំម៉ូន ឬអើរ៉ុន ហើយពន្យល់ពីទីកន្លែងដែលអ្នកចង់ទៅ និងមូលហេតុ។ សូមប្រាកដច្បាស់បញ្ជូលនូវមូលហេតុទាំងឡាយដែលអ្នកបានរកឃើញនៅក្នុងខ 1–5។
3. តើមូលហេតុមួយណាដែលអ្នកអាចគិតថា មានសារៈសំខាន់បំផុតសំរាប់បុរសទាំងនោះ? ហេតុអ្វី?



ការបំរើបេសកកម្មច្រើនជាងអ្វីទាំងអស់ ដែលកូនប្រុសនៃម៉ូសាយមានបំណងដើម្បីបំរើបេសកកម្ម ច្រើនជាងអ្វីទាំងអស់។

៤ ស្វែងរកការពិត

នៅពេលដែលកូនប្រុសម៉ូសាយ ត្រូវបានហៅឱ្យទៅបំរើបេសកកម្ម ទៅកាន់ពួកសាសន៍លេមិន ស្តេចម៉ូសាយត្រូវបានផ្តល់កាតព្វកិច្ច ដើម្បីធ្វើការសំរេចចិត្តសំខាន់ព្ធ មួយចំនួន។ ស្រាវជ្រាវម៉ូសាយ 28:5–20 ដើម្បីឆ្លើយចំពោះសំនួរដូចខាងក្រោមៈ

1. តើមានអ្វីដែលធ្វើឱ្យម៉ូសាយជឿដើម្បីឱ្យកូនប្រុសរបស់គាត់ ទៅបំរើបេសកកម្ម ដល់ពួកសាសន៍លេមិនដែលជាសត្រូវ? (សូមមើល ខ 5–9)។
2. តើការសន្យាទាំងបីអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ម៉ូសាយ ទាក់ទងនឹងកូនប្រុសរបស់គាត់? (សូមមើល ខ 7)។
3. តើកូនប្រុសម៉ូសាយបានលះបង់អ្វីខ្លះ ដើម្បីទៅបំរើបេសកកម្ម? (សូមមើល ខ 10)។
4. តើផ្ទាំងចំណាទាំងបីផ្នែក ត្រូវបាននិយាយនៅក្នុងខទី 11 អ្វីខ្លះ?
5. តើផ្ទាំងមួយណាដែលម៉ូសាយបានបកប្រែ ហើយតើទ្រង់អាចបកប្រែផ្ទាំងនោះ ដោយរបៀបណា? (សូមមើល ខ 11–13)។
6. តើអ្នកអាចស្វែងរកពតិមាន ដែលម៉ូសាយបានបកប្រែចេញពីផ្ទាំងមាសពីកន្លែងណា?

7. តើម៉ូសាយបានឱ្យបញ្ជីប្រវត្តិទៅនរណា? តើបានបង្រៀនយើងអ្វីខ្លះ អំពីព្រះហឫទ័យនៃព្រះអម្ចាស់ក្នុងការអត់ឱនបាប?

ក្នុងចំណោមកូនប្រុសម៉ូសាយទាំងអស់ គ្មានឥរណាម្នាក់ចង់បំរើស្តេចបន្ទាប់ឡើយ។ ផ្ទុយទៅវិញពួកគេជ្រើសរើសបំរើ បេសកកម្ម ទៅកាន់ពួកសាសន៍លេមិន (សូមមើល ម៉ូសាយ 28:5–10)។ នៅក្នុងម៉ូសាយ 29 អ្នកនឹងអានអំពីការលំបាក នៃការសំរេចចិត្ត របស់ពួកគេ ដែលកើតមានចំពោះពួកសាសន៍នីហ្វៃ និងអ្វីដែលស្តេចម៉ូសាយបានសំរេចចិត្តធ្វើ។ នៅពេល ដែលអ្នកអានជំពូកនេះ ចូរធ្វើការកត់ចំណាំពីអ្វី ដែលម៉ូសាយបាននិយាយអំពីអ្វីដែលល្អ និងអាក្រក់ ស្តីអំពីការគ្រប់គ្រង ដែល ជីកទាំដោយស្តេច។ តើអ្វីជាការរីកចំរើន និងគ្រោះថ្នាក់ ដែលគាត់បានឃើញ នឹងការគ្រប់គ្រងនេះ?

ការយល់ដឹងអំពីព្រះគម្ពីរ

ម៉ូសាយ 29

ខ្ចាយឈាម, ការខ្ចាយឈាម (ខ 7, 23)—ការផ្លាស់ប្តូរពីល្អទៅអាក្រក់, ការពុករលួយ

ចំបាច់ (ខ 13, 16, 24)—សមរម្យ, គួរឱ្យចង់បាន

សមត្ថភាព (ខ 14)—សមត្ថភាព

អន្តរាគមអំពីព្រះដ៏បង្កបង្កើត ដ៏ជ្រាបសព្វសារពើ (ខ 19)—ព្រះយាងមកជួយសង្គ្រោះពួកគេ

ទម្លាក់ (ខ 21)—ដកចេញ, បំបាត់ចោល

បង្កើត (ខ 23)—បង្កើត, កសាង

ផ្ទុយ (ខ 26)—ប្រឆាំងទីង, ដំទាស់ទីង

លំបាក (ខ 33)—ការរងទុក្ខ, ការឈឺចាប់

លះបង់ (ខ 38)—បានលះបង់

កម្រៃ (ខ 40)—អ្នកមាន

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាម៉ូសាយ 29។

ក ធ្វើជាចំណុច

នៅខាងក្រោមគឺជាសេចក្តីថ្លែង ដែលពេញចិត្តឱ្យមានស្តេច។ ប្រើគំនិតមកពី ម៉ូសាយ 29:18–25 ដើម្បីកែទូរសេចក្តីថ្លែង ដែលអ្នកគិតថា ជាសេចក្តីថ្លែងខុស។

1. ស្តេចគឺជាមនុស្សតែម្នាក់គត់ បញ្ហារបស់ស្តេចមិនផ្តល់ផលប៉ះពាល់លើប្រជាជនទេ។
2. ស្តេចបំរើដល់ឆន្ទៈរបស់ប្រជាជន។
3. ស្តេចគឺធ្វើឡើងដោយច្បាប់របស់ប្រទេស។
4. ការគ្រប់គ្រងដ៏ប្រសើរបំផុត គឺជាការគ្រប់គ្រងទាំងនោះចេញពីស្តេច។

ខ បញ្ជាក់ពីគោលការណ៍សំខាន់ៗ

ម៉ូសាយ 29:25–31 បានច្រាច់ទូរគោលការណ៍សំខាន់ៗជាច្រើន។ នៅខាងក្រោមគឺជាពាក្យគន្លឹះ និងលេខយោងចេញពីម៉ូសាយ 29។ បន្ទាប់ពីការអានព្រះគម្ពីរ សរសេរពីគោលការណ៍ទូទៅដែលបានច្រាច់។

1. ការធម្មតា (ខ 26)
2. ការបំផ្លិចបំផ្លាញ (ខ 27)
3. ការជំនុំជំរះមិនសុចរិត (ខ 28–29)
4. ទទួលខុសត្រូវទៅលើក្បាលគេផ្ទាល់ (ខ 30)
5. ធ្លាក់ទៅលើក្បាលរបស់ស្តេច (ខ 31)

ព្រះគម្ពីរអាលម៉ា

តើនរណាបានសរសេរគម្ពីរអាលម៉ា?

ដូចនៅពេលអ្នកកត់សំគាល់ពីទំព័រទី1 នៃព្រះគម្ពីរអាលម៉ា ចំណងជើងពេញលេញ និងសេចក្តីផ្តើមពន្យល់ថា អាលម៉ា គឺជាកូន ប្រុសរបស់អាលម៉ា ដែលតែងតែហៅថា អាលម៉ាជាកូន គឺជាព្យាការីដែលព្រះគម្ពីរនេះបានដាក់ឈ្មោះឱ្យ។ ព្រះគម្ពីរនេះគឺជាការ សង្ខេបរបស់មរមន ពីព្រះគម្ពីរអាលម៉ាចេញពីផ្ទាំងធំនៃនីហ្ហៃ (សូមមើល "ប្រភពសំខាន់ចំពោះព្រះគម្ពីរមរមន" ទំព័រ 12)។

នៅពេលដែលព្រះគម្ពីរនេះដាក់តាមឈ្មោះរបស់អាលម៉ា វារួមទាំងការសរសេររបស់អ្នកនិពន្ធផ្សេងទៀតៈ

- ជំពូកទី 1–44 គឺចេញពីបញ្ជីប្រវត្តិរបស់អាលម៉ា។
- ជំពូកទី 45–62 គឺដកចេញពីការសរសេររបស់ហេលេមិន ដែលជាកូនម្នាក់ក្នុងចំណោមកូនរបស់អាលម៉ាទាំងអស់។
- ជំពូកទី 63 គឺជាពតិមានសំខាន់ ដែលបានកត់ត្រាដោយសិ៊បឡុន ដែលជាកូនមួយទៀតរបស់អាលម៉ា។

តើខ្ញុំនឹងរកឃើញអ្វីខ្លះនៅក្នុងព្រះគម្ពីរអាលម៉ា?

គម្ពីរអាលម៉ាគឺជា គម្ពីរដ៏ធំជាងគេនៅក្នុងព្រះគម្ពីរមរមន តែព្រះគម្ពីរអាលម៉ា មានរយៈពេលតិចជាង 40 ឆ្នាំ (ប្រហែលជា ឆ្នាំ 91–ឆ្នាំ 52 ម.ត)។ នៅក្នុងព្រះគម្ពីរនេះ អ្នកនឹងរកឃើញរឿងដ៏អស្ចារ្យមួយចំនួន នៃអ្នកផ្សព្វផ្សាយសាសនា ក្នុងព្រះគម្ពីរ មរមន។ ឧទាហរណ៍ អ្នកនឹងរៀនអំពីអ្វីដែលបានកើតឡើង ចំពោះកូនប្រុសទាំងបួននៃស្តេចម៉ូសាយ ដែលជាអ្នក ដែលទៅបំរើ បេសកកម្មនៅក្នុងចំណោមពួកសាសន៍លេមិន ជាជាងឱ្យគេម្នាក់ក្នុងចំណោមពួកគេ ធ្វើជាស្តេចនៅលើពួកសាសន៍នីហ្ហៃ។ អ្នកអានពីការសំរេចចិត្តរបស់ពួកគេនៅក្នុងអាលម៉ា 28។

គម្ពីរអាលម៉ា ក៏មានទូវការបង្រៀនខាងគោលលទ្ធិសំខាន់ៗ មួយចំនួន នៅក្នុងព្រះគម្ពីរមរមន។ អ្នកនឹងបាន អានអំពីគោលការណ៍នោះ ដូចជាៈ

- មុខងារបព្វជិតភាពមុនជីវិតដែលអាចស្លាប់បាននេះ។
- អំណាចនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត នាំមកនូវការរស់ឡើងវិញ ចំពោះមនុស្សទាំងអស់ និងការសង្ត្រោះអ្នកដែល ប្រែចិត្ត។
- ចេស្តានៃព្រះបន្ទូលគឺអស្ចារ្យជាងចេស្តានៃដាវ។
- ទំនាក់ទំនងដ៏សំខាន់រវាង ការបង្កើត ការធ្លាក់ចុះ និងដង្វាយធួន
- របៀបដែលសេចក្តីជំនឿក្នុងព្រះយេស៊ូវគ្រីស្ត និងការប្រែចិត្តជួយយើង ទទួលបានសេចក្តីមេត្តាករុណា តាមរយៈដង្វាយធួន និងធ្វើ ឱ្យស្តប់ស្តល់ចំពោះតំរូវការយុត្តិធម៌។

ព្រះគម្ពីរអាលម៉ាមានទូវបញ្ជីប្រវត្តិនៃសង្ត្រាមជាច្រើនផងដែរ ជាពិសេសគឺនៅក្នុងជំពូក 43–62។ អ្នកនឹងកត់សំគាល់យើញថា ទោះបីជាជំពូកទាំងនេះ និយាយអំពីសង្ត្រាមដ៏អាក្រក់ ជំពូកទាំងនេះ នៅតែបង្រៀនពីចំណុចសំខាន់ និងសេចក្តីពិតដែលគ្មានទី បំផុត មានសារៈសំខាន់សំរាប់សម័យរបស់យើង។

អាលម៉ាគឺជាមេចៅក្រម នៃដែនដីសាវ៉ាហិមឡា និងជាអ្នកដឹកនាំនៃសាសនាចក្រ។ ការប្រឈមមុខមួយក្នុងចំណោមការប្រឈម មុខដំបូងផ្សេងព្វទៀតរបស់លោក គឺដើម្បីអង្គុយនៅកន្លែងជំនុំជំរះរបស់បុរសម្នាក់ឈ្មោះថានីហ្ហរ ដែលជាអ្នករៀបចំឡើងនូវ សាសនាចក្រដែលប្រកួតប្រជែង ដែលបានបង្រៀនលទ្ធិក្លែងក្លាយ និងសំលាប់សាសន៍នីហ្ហៃស្មោះត្រង់ម្នាក់។ ប្រជាជនជាច្រើនសព្វ ថ្ងៃនេះ ជឿ និងបង្រៀនទូវលទ្ធិក្លែងក្លាយដូចគ្នានេះ ដែលនីហ្ហរបានបង្រៀន។ នៅពេលដែលអ្នកអានអាលម៉ា 1 ចូរគិតពីអ្វីដែលជា កំហុសនៅក្នុងលទ្ធិរបស់នីហ្ហរ និងហេតុអ្វីអាលម៉ានិយាយថា លទ្ធិនោះត្រោះថ្នាក់។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 1

ករណីយកិច្ច (ខ 1)—ដែលតំរូវ

ធ្វើការទាស់នឹង (ខ 3)—ការធ្វើការប្រឆាំងដ៏ខ្លាំងក្លា

ប្រជាប្រិយភាព (ខ 3)—កោតសរសើរពីមនុស្ស, ស្រុះស្រួល

សំលៀកបំពាក់ដ៏មានតម្លៃ (ខ 6, 27)—សំលៀកបំពាក់ដែលមានតម្លៃ

ស្តីបន្ទោស (ខ 7)—ការកែលំអរ, ការព្រមាន

មានអាយុច្រើនហើយ (ខ 9)—ចាស់ហើយ

ឧបាយកល (ខ 12)—ព្យាយាម

សងសឹក (ខ 13)—ទារុណកម្ម

ដ៏ថោកទាប (ខ 15)—ដែលអាប់កេរ្តឹ៍ឈ្មោះ, ភាពអាម៉ាស់

រំលែក (ខ 20)—ឱ្យ, បង្រៀន

តតាំង (ខ 22)—ឈ្លោះប្រកែក, វាយគ្នា

ត្រូវបានលុចចេញ (ខ 24)—បានផ្លាស់ប្តូរ, លុបចោល

ត្រូវឱ្យស្រលាញ់ (ខ 27)—ត្រូវឱ្យចាប់អារម្មណ៍

បណ្តោយខ្លួន (ខ 32)—បណ្តោយតាមសេចក្តីប៉ងប្រាថ្នារបស់ពួកគេ

និយាយផ្តេសផ្តាស (ខ 32)—ការឈ្លោះដោយឥតប្រយោជន៍, ការនិយាយដោយគ្មានប្រយោជន៍

ប្រព្រឹត្ត (ខ 33)—ហ៉ាន

អាលម៉ា 1:12—តើឧបាយកលផ្នែកសង្ឃគឺជាអ្វី? តើការបង្រៀនរបស់នីហ៊ូរ គឺជាអ្វី បានជាមានប្រជាប្រិយភាពយ៉ាងនេះ?

ដូចដែលបានបញ្ជាក់ពីនីហ៊ូ “ឧបាយកលផ្នែកសង្ឃគឺជា ការបង្រៀនរបស់មនុស្ស ហើយតាំងខ្លួនឡើងជាពន្លឺដល់លោកិយវិញ ដើម្បី គេអាចបានកំរៃ និងការសរសើរដំកើងពីលោកិយ ប៉ុន្តែគេមិនស្វែងរក សុខុមាលភាពនៃក្រុងស៊ីយ៉ូនឡើយ” (នីហ៊ូទី 2 26:29)។ យោងទៅតាមការពន្យល់នោះ អ្វីដែលនីហ៊ូរបានបង្រៀនគឺជា ឧបាយកលផ្នែកសង្ឃ។

- គាត់បានរិះគន់ដល់សាសនាចក្រ និងបានបង្រៀនថា ពួកសង្ឃ និងគ្រូបង្រៀន ត្រូវតែមានប្រជាប្រិយភាពជាមួយនឹង ប្រជាជន (សូមមើល អាលម៉ា 1:3)។ រឿងនេះបង្ហាញច្បាស់យើងថា គាត់ចង់ឱ្យប្រជាជនសរសើរដល់គាត់ ហើយធ្វើតាមគាត់ជាជាង តាមព្រះ។
- គាត់បានបង្រៀនថា ពួកសង្ឃ និងគ្រូបង្រៀនទាំងអស់ (ដូចជារូបរបស់គាត់ផ្ទាល់) គួរតែទទួលច្រាក់ខែពីការប្រែប្រួលប្រដៅ ជាជាងធ្វើការដើម្បីឧបត្ថមដល់ខ្លួនរបស់គេ ផងដែរ (សូមមើល ខ 3)។ រឿងនេះបង្ហាញថា សេចក្តីប៉ងប្រាថ្នារបស់គាត់ គឺដើម្បីកម្រៃ និងកេងលើកំលាំងរបស់អ្នកដទៃ។
- ដើម្បីទទួលបានច្រាក់កម្រៃមកពីការប្រែប្រួលប្រដៅ នីហ៊ូរក៏ដូចជាត្រូវក្លែងក្លាយទាំងអស់ បានបង្រៀនទូរអ្វីដែលមនុស្សចង់ស្តាប់។ គាត់ ធ្វើបង្រៀនថា “មនុស្សលោកទាំងអស់ត្រូវតែបានសង្គ្រោះនៅថ្ងៃចុងក្រោយ” (ខ 4)។ លទ្ធិនោះគ្រាកដជា ពេញចិត្តចំពោះ អ្នកដែលមិនប្រតិបត្តិតាម។ តើវាងាយស្រួល និងកក់ក្តៅយ៉ាងណាទៅដើម្បីលើថា មនុស្សទាំងអស់ នឹងត្រូវបានសង្គ្រោះដំនួសឱ្យ ការបង្រៀន គោលការណ៍ដូចជា សេចក្តីជំនឿ ការប្រែចិត្ត និងការគោរពតាមការចាំបាច់ សំរាប់សេចក្តី សង្គ្រោះ។ ការណ៍នេះ បង្ហាញយើងថា នីហ៊ូរ យកចិត្តទុកដាក់ទៅលើសុខុមាលភាពរបស់គាត់ផ្ទាល់ជាង ការជួយដល់ប្រជាជន ឱ្យលូតលាស់ឡើងក្នុងសេចក្តីសុចរិត និងសុខុមាលភាពរបស់ក្រុងស៊ីយ៉ូន។

នីហ៊ូរ បានអនុវត្តការធ្វើយ៉ាតដល់គេខាង តែនោះមិនបានបញ្ចប់នូវប្រជាប្រិយភាពការបង្រៀនរបស់គាត់នោះទេ។ នៅពេល អ្នកបន្តការ សិក្សារបស់អ្នកអំពីព្រះគម្ពីរមរមន អ្នកនឹងជួបតាមលំដាប់លំដោយនេះ (ដូចជា សាសន៍អាំលិសៃ សាសន៍អាម៉ាលេកៃ សាសន៍អាមូឡុន សាសន៍អាំម៉ូណៃហា) ដែលបានធ្វើតាមការបង្រៀនរបស់នីហ៊ូរ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយក្នុងចំណោមសកម្មភាព (ក–គ)ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 1។

ក កែលទ្ធិ

នីហ៊ូរ ទទួលភាពអាម៉ាស់ដោយឧបាយកលផ្នែកសង្ឃ និងការធ្វើយ៉ាត។

1. ដើម្បីជួយអ្នកយល់នូវលទ្ធិរបស់នីហ៊ូរ និងគ្រោះថ្នាក់នៃឧបាយកលផ្នែកសង្ឃ ចូរគូរតារាងមួយនៅក្នុងស្បៃវគៅសរសេរ របស់អ្នកដូចជា តារាងដែលបានបង្ហាញទៅទីនេះ។

នីហ៊ូរ	ឧបាយកលផ្នែកសង្ឃ	បទពិសោធន៍
1.		
2.		
3.		

2. នៅក្នុងកូឡោនទីមួយ ចូរសរសេរធាតុបី នៃលទ្ធិរបស់នីហ៊ូរចេញពីអាលម៉ា 1:3–4។
3. នៅក្នុងកូឡោនទីពីរ ពន្យល់ពីរប្បេបដែលលទ្ធិក្លែងក្លាយនីមួយៗ នីហ៊ូរបានបង្រៀនសមនឹងឧបាយកលផ្នែកសង្ឃ ដូចដែលបាន ពិពណ៌នា នៅក្នុងនីហ៊ូទី 2 26:29 (សូមមើល វគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់អាលម៉ា 1:12 សំរាប់ជាជំនួយបើ ត្រូវការ)។
4. នៅក្នុងកូឡោនទីបី ចូរកែទូរាល់គំនិតក្លែងក្លាយនីមួយៗ ជាមួយនឹងការពន្យល់ពីអ្វីដែលអ្នកកាន់បទពិសោធន៍ពិតត្រាកដ នឹងបង្រៀន។

ខ តើវាខុសទេ ដើម្បីការពារសេចក្តីពិត?

នៅក្នុងអាលម៉ា 1:19–20 អ្នកនឹងអានអំពីការធ្វើទុក្ខបុកម្នេញដែលសមាជិកនៃសាសនាចក្របានប្រឈមមុខ។

1. តើសមាជិកនៃសាសនចក្រខ្លះៗ បានឆ្លើយតបនឹងការធ្វើទុក្ខបុកម្នេញនោះរប្បេបណាខ្លះ? (សូមមើល ខ 21–22)។
2. តើការឆ្លើយតបរបស់ពួកគេ ទៅនឹងការធ្វើទុក្ខបុកម្នេញ ជះឥទ្ធិពលអ្វីខ្លះទៅលើសមាជិកនៃសាសនចក្រផ្សេងៗទៀត ហើយទៅ ទីបំផុតរបស់ពួកគេផ្ទាល់? (សូមមើល ខ 22–24)។
3. តើការឆ្លើយតបចំពោះការប្រឆាំង ពីសមាជិកទាំងនោះ ស្រដៀងគ្នាទៅនឹងការឆ្លើយតបរបស់នីហ៊ូរ ដែលរកឃើញទៅក្នុង អាលម៉ា 1:7–9 យ៉ាងដូចម្តេច?
4. ចូរពន្យល់ពីអ្វីដែលជំពូកនេះ បង្រៀនយើងអំពីការឆ្លើយតបចំពោះការធ្វើទុក្ខបុកម្នេញ និងហេតុអ្វីការណ៍នោះជាវិធីដ៏ប្រសើរ បំផុត។

គ សម័យនៃជីវិតយុវវ័យរបស់នីហ៊ូ

ចូររំលឹកអាលម៉ា 1:25–33 ឡើងវិញដែលពិពណ៌នាពីជីវិតក្នុងសាសនាចក្រ នៅសម័យរបស់អាលម៉ា ហើយបំពេញនូវ ការចាត់តាំងមួយចេញពីការចាត់តាំងខាងក្រោម។

1. ឧបមាថា អ្នកជាយុវវ័យម្នាក់នៅក្នុងសម័យរបស់អាលម៉ា។ ចូរពិពណ៌នាពីនៃសម័យនោះ តើមានលក្ខណៈយ៉ាងណា ចំពោះអ្នក នៅក្នុងសង្គមដ៏មានពរដ៏ម័យនោះ។ ឱ្យមានគំនិតឆ្លៃឆ្លើយ និងពិពណ៌នាអំពីក្រុមគ្រួសាររបស់អ្នក រប្បេបចំទៅសាលា អ្វីដែលអ្នក ត្រូវស្លៀកពាក់ រប្បេបដែលអ្នកដទៃប្រព្រឹត្តចំពោះអ្នក និងរប្បេបដែលអ្នកប្រព្រឹត្តចំពោះអ្នកដទៃ និងមិត្តភាពរបស់អ្នក ចំពោះអ្នក ដែលគ្មានជំទៀ។
2. ចូររប្រៀបធៀបសហគមរបស់អ្នក ជាមួយនឹងសហគមមួយដែលបានពិពណ៌នានៅក្នុង អាលម៉ា 1:25–33។ តើសហគម ទាំងពីរ ស្រដៀងគ្នាយ៉ាងដូចម្តេច? តើវាខុសគ្នាយ៉ាងដូចម្តេច? តើអ្នកនឹងធ្វើអ្វីដើម្បីធ្វើឱ្យសហគមមួយរបស់អ្នក កាន់តែដូចនឹង សហគមដែលអាលម៉ាពិពណ៌នា?

អាលម៉ា 2–3

ការបះបោរនៃពួកសាសន៍អាំលិសៃ

សេចក្តីស្លាប់របស់ទីហ្វរ (សូមមើលអាលម៉ា 1) មិនបានបញ្ចប់ទូរបញ្ជា ដែលបានបង្កឡើងដោយការបង្រៀនដែល ការបំផុសគំនិត របស់គាត់មកពីអារក្សទេ។ នៅក្នុងអាលម៉ា 2–3 អ្នកនឹងអានអំពីអាំលិសៃ ដែលជាអ្នកធ្វើតាមទីហ្វរ ដែលជាអ្នកចង់បាន ច្រើនជាង ការចាប់ផ្តើម នូវសាសនាចក្រដែលប្រកួតប្រជែង សំរាប់កម្រៃផ្ទាល់ខ្លួន។ នៅពេលអ្នកអានដំណូកនេះ ស្វែងរកអ្វីដែលអាំលិសៃពិត ជាចង់បាន និងរបៀបដែលអាលម៉ា និងសមាជិកនៃសាសនចក្រផ្សេងទៀត បានប្រឈមមុខចំពោះ ការគំរាម គំហែងនោះ។ ចូរកត់ចំណាំផងដែរ ពីការពិភាក្សារបស់អាលម៉ា អំពីវិធីដែលមនុស្សទុច្ចរិតកត់សំគាល់ខ្លួនរបស់ពួកគេអនុវត្ត មកក្នុងសម័យរបស់យើងសព្វថ្ងៃនេះផងដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 2

ខិតខំ (ខ 2)—ព្យាយាម

សម្លេង (ខ 3–4)—ពោះឆ្មោត

ធ្វើឱ្យាបាត់បង់ (ខ 4)—យកចេញ

ទាស់ទែង (ខ 5)—ការឈ្លោះប្រកែក, ជជែក

ជ័រអស្ចារ្យ (ខ 5)—ការធ្វើឱ្យចំឡែក, ការភ្ញាក់ផ្អើល

ញែកខ្លួនចេញ (ខ 11)—ត្រូវបានស្គាល់ដោយ, បានបញ្ជាក់

សាហាវឮ (ខ 37)—ឃ្លានយ៉ាងខ្លាំង

អាលម៉ា 3

ដើរទន្ទ្រានលើ (ខ 2)—ជាន់ឈ្លី, បានប្រព្រឹត្ត

កោរ (ខ 4)—កោរ

ជុំវិញខ្លួន (ខ 5)—រុំ ឬ ចង

កូនចៅខ្លួនលាយឡំជាមួយនឹងកូនចៅ (ខ 9, 15)—រៀបការហើយមានកូនជាមួយ

ត្រូវបានហៅតាមឈ្មោះ (ខ 10)—ត្រូវបានបញ្ជាក់ដោយឈ្មោះនោះ

ការកាត់ទោស (ខ 19)—ការដាក់ទណ្ឌកម្ម, ការកាត់ទោស

ចុះធ្វើតាម, ធ្វើតាម (ខ 26–27)—បានចំបាំងម្តងទៀត, បានចុះធ្វើតាម

អាលម៉ា 3:6–12—តើនរណាជាពួកសាសន៍លេមិន ហើយតើនរណាជាពួកសាសន៍នីហ្វៃ?

នៅពេលនោះ ក្នុងជំណើរការបង្រៀននៃព្រះគម្ពីរមរមន អត្តសញ្ញាណនៃសាសន៍នីហ្វៃ និងសាសន៍លេមិនម្តាក់ គឺមិនពិតជាមានបញ្ហាច្រើន ពីបញ្ហាពូជអំបូរ ដូចជាបញ្ហានៃអ្នកដែលជឿ។ អ្នកទាំងឡាយដែលត្រូវបាន “ពួកលេមិនដឹកនាំទៅ” (អាលម៉ា 3:10) គឺត្រូវបាន ហៅថា សាសន៍លេមិន យោងទៅតាមពូជពិតត្រាកដនៃគ្រួសាររបស់ពួកគេ។ អ្នកទាំងឡាយណាដែល ជឿនៅក្នុងប្រវត្តិបញ្ជីរបស់នីហ្វៃ និងអ្នកទាំងឡាយណាដែល “ជឿតាមព្រះបញ្ញត្តិ ទាំងឡាយនៃព្រះ” (ខ 11) ត្រូវបានស្គាល់ថាជា ពួកសាសន៍ នីហ្វៃ យោងទៅតាមពូជរបស់ពួកគេ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ គ នៅពេលអ្នកសិក្សាអាលម៉ា 2–3។

ក ពិពណ៌នាពីបញ្ហា

អាំលិសៃ

អាំលិសៃគឺជាមនុស្សដែលមានការប៉ិនប្រសព្វ និងមានល្បិចកល។ អាលម៉ាបានដឹងថា អាំលិសៃរៀបគំរោងគំរាមគំហែងពិត ព្រោកជមួយចំពោះសហគមរបស់នីហ្វៃ។

1. សិក្សាអាលម៉ា 2:1–4 ហើយពិពណ៌នាពីអ្វីដែលអាំលិសៃបានរៀបគំរោងដើម្បីធ្វើ។
2. តើខ 5–10 បង្ហាញថា កង្វល់របស់អាលម៉ាអំពីអាំលិសៃ គឺត្រឹមត្រូវយ៉ាងដូចម្តេច?

ខ ស្វែងរកការអនុវត្តន៍

អាលម៉ា 2:12–38 ពិពណ៌នាអំពីការរៀបចំ និងចម្បាំងដែលកើតឡើងនៅក្នុងសង្គ្រាមរវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍ អាំលិសៃ និងពួកសាសន៍លេមិន។ នៅពេលដែលអ្នកគិតពិចារណាពីព្រឹត្តិការណ៍ទាំងនេះ ចូរគិតអំពីចម្បាំងទាំងឡាយនេះ ដូចជាចម្បាំងដែលអ្នកត្រូវតែតវ៉ាយប្រឆាំងជាមួយនឹងអំពើទុច្ចរិត។ ឆ្លើយតបនឹងសំនួរដូចខាងក្រោម៖

1. តើផែនការរបស់អាំលិសៃចំពោះពួកសាសន៍នីហ្វៃ ស្រដៀងគ្នាទៅនឹងផែនការរបស់អារក្សចំពោះអ្នកដូចម្តេច?

2. ចូរពិពណ៌នារឿងពីរយ៉ាងគិចដែលអាលម៉ាបានធ្វើឱ្យអាំលិសៃបរាជ័យ ដែលដូចនឹងអ្វីដែលអ្នកអាចធ្វើ ដើម្បីការពារ ខ្លួនរបស់អ្នក ប្រឆាំងនឹងការវាយប្រហាររបស់អារក្ស។

គ ឱ្យគំរូថ្មីមួយ

នៅក្នុងអាលម៉ា 3 មរមនបានរំលឹកយើងពីបណ្តាសាដែលមកលើពួកសាសន៍លេមិន នៅក្នុងសម័យរបស់នីហ្វៃ (សូមមើល នីហ្វៃទី 2 5:20–25 វគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់នីហ្វៃទី 2 5:20–25, ទំព័រ 40)។

1. សូមរំលឹកអាលម៉ា 3:4–10 សារឡើងវិញ ហើយពន្យល់ពីមូលហេតុដែលទាំឱ្យមានបណ្តាសានោះ។
2. តើព្រះអម្ចាស់សន្យាធ្វើអ្វីខ្លះ ចំពោះអ្នកទាំងឡាយណាដែលបានចូលរួមជាមួយនឹង ពួកសាសន៍លេមិន វាយប្រឆាំងនឹងពួក សាសន៍នីហ្វៃ? (សូមមើល ខ 9–17)។
3. តើពួកសាសន៍អាំលិសៃធ្វើអ្វីខ្លះ ដើម្បីបំពេញនូវការសន្យានោះចំពោះពួកគេផ្ទាល់?
4 តើប្រជាជន “គួសថ្ងាសលើពួកគេ” ដូចជាអ្នកដែលមិនជឿនៅសព្វថ្ងៃនេះ ដូចម្តេច?

អាលម៉ា 4

អាលម៉ាប្រគល់វេទិកាជំនុំជំរះ

ព្រះអម្ចាស់បានសន្យាពួកសាសន៍នីហ្វៃជាច្រើនដងថា បើពួកគេនឹងគោរពតាមព្រះបញ្ញត្តិ ពួកគេនឹងបានរីកចំរើនទៅក្នុងដែនដី (ឧទាហរណ៍ សូមមើលម៉ូសាយ 1ៈ7)។ នៅក្នុងអាលម៉ា 2–3 អ្នកបានអានពីពួកសាសន៍នីហ្វៃដែលស្មោះត្រង់ ត្រូវបាន សង្គ្រោះពីការគំរាមគំហែងរបស់ពួកអាំលីសៃ-លេមិនដោយការអធិស្ឋានទៅកាន់ព្រះអម្ចាស់ដើម្បីទទួលកំលាំង។ ព្រះអម្ចាស់បានប្រទានពរដល់ពួកគេ ហើយពួកគេត្រូវបាន។

នៅក្នុងអាលម៉ា 4 ត្មានសត្រូវមកពីខាងក្រៅ ត្មានសង្គ្រាម ឬ ការឈ្លោះទាស់ទែងគ្នាទេ តែរឿងពិតនោះ ស្ថានភាពគឺអស់ សង្ឃឹមជាង ពេលដែលពួកសាសន៍លេមិនបានរាតត្បាត។ តើប្រភពនៃគ្រោះថ្នាក់នោះ គឺជាអ្វី? ធ្រន ជតយ្យ ខេនទូន ដែលជា ទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ បានបង្រៀនថាះ "យើងទាំងអស់គ្នា ត្រូវតែព្យាយាមនៅគ្រប់រឿងទាំងអស់ ហើយក្នុងពេលឆាប់ឲ ឬក្រោយមក នោះយើងនឹងត្រូវបានទទួលនូវភាពរុងរឿង និងភាពសម្បូណ៍។ មនុស្សជាច្រើនដែល នៅតែធ្វើជាពួកបរិសុទ្ធ ថ្ងៃចុងក្រោយដ៏ស្មោះត្រង់ នៅពេលដែលពួកគេកំពុងតែក្រ នឹងមិនអាចឈរឡើងនៅពេលដែលពួក គេមាន។ ទ្រព្យសម្បត្តិ [មាន]ឥទ្ធិពលដ៏ពុករលួយណាស់មកលើដួងចិត្តមនុស្សជាតិ ហើយវាតំរូវឱ្យមនុស្ស បរិសុទ្ធមានភាពស្មោះត្រង់ប្រកបដោយគុណធម៌ រាបសារ និងឈរឡើង នៅពេលត្រូវបានហ៊ុំព័ទ្ធដោយគ្រឿងប្រណិត និងទ្រព្យសម្បត្តិ នៅពេល ពួកគេនៅក្នុង កាលះទេសះក្រីក្រ និងទុរគត" (Gospel Truth, ចោះពុម្ពដោយ Jerreld L Newquist, [ឆ្នាំ 1957, 1974], 2ៈ19 រ៉ុលទី2)

នៅពេលអ្នកសិក្សាអាលម៉ា 4 សូមមើលពីរបៀប ដែលសេចក្តីថ្លែងការណ៍របស់ប្រធាន ខេនទូន អនុវត្តទៅកាន់អ្នកទាំងនោះ ដែលជាសាសន៍នីហ្វៃ និងចំពោះយើង!

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 4

ឈីចាប់ (ខ 2)—បញ្ហា, ទារុណកម្ម

តើតទុក្ខ (ខ 7)—មានអារម្មណ៍សោកសៅ, ពោរពេញទៅដោយទុក្ខព្រួយ

ព្យាបាទ (ខ 9)—សេចក្តីកំណាច, ការស្អប់ខ្ពើម

បន្ទាបខ្លួន (ខ 13)—ការបន្ទាបខ្លួន

ឧបត្ថម្ភ (ខ 13)—ការជួយ, ការគាំទ្រ, ការចិញ្ចឹមបីបាច់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាអាលម៉ា 4។

ក្ប ប្រៀបធៀបពេលវេលាពីរ

មានទូវចំណាប់អារម្មណ៍ស្រដៀងគ្នា ហើយសំខាន់ខុសឲគ្នា រវាងការពិពណិនាអំពីសាសនាចក្រ នៅក្នុងអាលម៉ា1 និងអាលម៉ា 4 ។ នៅក្នុងឆ្នាំទីពីរនៃរជ្ជកាលនៃពួកចៅក្រម សាសនាចក្រ និងសមាជិកមានការរីកចំរើន (សូមមើល អាលម៉ា 1ៈ31)នៅរយៈ ពេលប្រាំមួយឆ្នាំក្រោយមក សាសនាចក្រ "បានចាប់ផ្តើមចុះអន់ថយ នូវការលូតលាស់ទៅវិញ" (អាលម៉ា 4ៈ9–10)។

1. ចូរគូសតារាងមួយនៅក្នុងស្រៀវភៅសរសេររបស់អ្នក ដែលស្រដៀងទៅនឹងតារាងដែលបានបង្ហាញនៅទីនេះ។ ចូរសិក្សានូវ ខគម្ពីរទាំងឡាយ សរសេរខនៅរាល់កូឡោនទីមួយឲ និងពិពណិនា ពីប្រធានបទទីមួយឲ មានទំនាក់ទំនងជាមួយនឹងសាសនាចក្រ នៅក្នុងកំឡុងពេលទីមួយឲនោះ។ ឧទាហរណ៍ ការរីកចំរើនរបស់សមាជិកយ៉ាងណាខ្លះ និងអ្វីដែលជះឥទ្ធិពលទៅលើពួកគេ ដោយសារភាពរុងរឿងនោះ? (សូមមើល អាលម៉ា 1ៈ29–31, 4ៈ6–8)។

	អាលម៉ា 1ៈ25–31	អាលម៉ា 4ៈ6–12
ការធ្វើទុក្ខបុកម្មេញ		
ភាពស្មើគ្នា និងសេចក្តីសប្បុរស		
អំនួត		
សេចក្តីសុខសាន្ត		
ភាពរុងរឿង		

2. ចូរប្រៀបធៀបបញ្ជីពីរ និងសង្ខេបពីមូលហេតុដែលសាសនាចក្រចាប់ផ្តើមចុះអន់ថយ នៅក្នុងអាលម៉ា 4។
3. ចូរគិតអំពីជីវិតរបស់អ្នកនៅក្នុងចំនុចដូចគ្នានេះ។ តើមានវិធីណាខ្លះដែលអ្នកអាចបង្កើនទូវកំរិតនៃសេចក្តីសុចរិតរបស់អ្នក ហើយហេតុដូច្នោះ នឹងជួយដល់សាសនាចក្រឱ្យរីកចំរើនបាន?

អាលម៉ា 5

មានការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្ត

តើអ្នកធ្លាប់លឺនរណាម្នាក់ និយាយអ្វីមួយដូចជា "អ្នកមិនចាំបាច់ធ្វើឱ្យល្អឥតខ្ចោះពេក ដើម្បីទៅស្ថានសួគិទេ ព្រះនឹងអនុញ្ញាត ឱ្យអ្នកទៅស្ថានសួគិ ដរាបណាអ្នកជៀសវាងពីរឿងដែលមិនល្អឲ នោះ។" ប្រហែលជាអ្នកស្គាល់មនុស្សដែលមិនបាននិយាយ បែបនេះ តែរស់នៅតាមជំនឿរបស់គេថាវាជាការពិត។ តើអ្នកនឹងនិយាយអ្វីទៅកាន់មនុស្សបែបនេះ? តើយើងត្រូវធ្វើឱ្យល្អ បែបណាទៅ ដើម្បីទៅរស់នៅជាមួយព្រះ? តើសេចក្តីមេត្តាករុណារបស់ព្រះនឹងធ្វើអ្វីសំរាប់យើង ហើយតើយើងត្រូវធ្វើអ្វី ដើម្បីទទួលសេចក្តីមេត្តាករុណានោះ? អាលម៉ា 5 គឺជាកន្លែងដ៏ល្អ ដើម្បីស្វែងរកចំលើយចំពោះសំណួរបែបនោះ។

អាលម៉ា បានប្រគល់មុខតំណែងរបស់លោក ក្នុងនាមជាមេចៅក្រម ដើម្បីចំណាយពេលវេលារបស់លោក ក្នុងការកសាង សាសនាចក្រឡើងវិញ (សូមមើល អាលម៉ា 4:11–20)។ លោកបានចាប់ផ្តើមនៅក្នុងទីក្រុងសាវ៉ាហិមឡា។ អាលម៉ា 5 គឺ ស្រដៀងទៅនឹង សន្ទិសីទទូទៅមួយ ដែលមានមកពីព្យាការីអាលម៉ា។ សារដំណឹងដែលលោកចែកចាយ គឺជាសារដំណឹង មួយដ៏សំខាន់បំផុតនៅក្នុងព្រះគម្ពីរមរមន។ នៅពេលអ្នកអានពីអ្វីដែលលោកបាននិយាយ ចូរគិតអំពី រឿបដែលលោក បាននិយាយមកនោះយកមកអនុវត្តចំពោះខ្លួនអ្នក។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 5

អ្នករាល់គ្នាបានខ្លះៗ (ខ 6)—ការចងចាំ

ទទួលព្រះភ័ក្ត្ររបស់ទ្រង់ នៅក្នុងទឹកមុខរបស់អ្នករាល់គ្នា (ខ 14)—ប្រែក្លាយដូចជាព្រះគ្រីស្ទនៅក្នុងអត្តចរិត និងឥរិយា

ទីជំនុំជំរះ (ខ 18)—តុលាការជំនុំជំរះ

ការចងចាំការទាស់នឹង (ខ 18)—ការមិនគោរពប្រតិបត្តិដោយមានឆន្ទៈ, ជំទាស់

សំលៀកបំពាក់ជននោះត្រូវតែសំអាត (ខ 21)—និមិត្តសញ្ញា ដើម្បីទទួលការជំរះនូវអំពើបាប

ចំអកឡកឡឺយ (ខ 30)—សោចចំអកឱ្យ, ការបង្ហាញនូវការមិនគោរព

អះអាង (ខ 49)—បានប្រកាស, សម្តែង

ភាន់ច្រឡំ (ខ 43)—មានកំហុស

តំណែង (ខ 49)—សិទ្ធិអំណាចបញ្ចជិតភាព

អាលម៉ា 5:9—តើអ្នកបានសង្ត្រោះឬ?

អែលឌើរ ដាល់លិន អេចអូកស៍ ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានមានប្រសាសន៍ថាៈ "ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ប្រើពាក្យថា *សង្ត្រោះ* និង *សេចក្តីសង្ត្រោះ* ពាក្យទាំងនោះយ៉ាងហោចណាស់មានន្ទវអន្ទន៍យ ប្រាំមួយខុសឲគ្នា។ យោងទៅតាម ពាក្យសំដីខ្លះៗទាំងនេះ សេចក្តីសង្ត្រោះរបស់យើងគឺត្រូវបានអះអាងថា—យើងបានសង្ត្រោះរួចទៅហើយ។ ម្យ៉ាងវិញទៀត សេចក្តីសង្ត្រោះត្រូវតែបាននិយាយដូចជាអំពីព្រឹត្តការណ៍នាអនាគត . . . ឬអាស្រ័យទៅលើលក្ខខ័ណ្ឌនាពេលអនាគត . . .។ នៅក្នុង អត្ថន័យទាំងឡាយនោះ ឬប្រភេទនៃសេចក្តីសង្ត្រោះទាំងអស់នេះ គឺនៅក្នុង និងតាមរយៈព្រះយេស៊ូវគ្រីស្ទ" (ក្នុង Conference Report, ខែមេសា ឆ្នាំ1998, 76, ឬ *Ensign* ខែឧសភា ឆ្នាំ1998, 55)។ ផ្នែកខាងក្រោមគឺជាការសង្ខេប ពីអត្ថន័យប្រាំមួយ ខុសឲគ្នា នៃអ្វីដែល អែលឌើរ អូកស៍ បានមានប្រសាសន៍ៈ

1. យើងត្រូវបានសង្ត្រោះមកពីឥទ្ធិពលនៃសេចក្តីស្លាប់ជានិរន្តរ៍។ ព្រោះតែការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ។
2. យើងទាំងអស់គ្នា ត្រូវបានសង្ត្រោះពីអំពើបាប តាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ និងដោយការធ្វើតាមផែនការនៃដំណឹងល្អ។ ការប្រែចិត្ត គឺជាផ្នែកដ៏សំខាន់ ដើម្បីបានសង្ត្រោះចេញពីលទ្ធផលនៃអំពើបាបរបស់យើង។
3. យើងបានសង្ត្រោះនៅពេលដែលយើង "បានកើតមកពីព្រះ។" ការកើតមកពីព្រះ កើតឡើងនៅពេលយើងចូលក្នុងសេចក្តី សញ្ញាមួយទំនាក់ទំនងជាមួយនឹងព្រះគ្រីស្ទ ដោយការទទួលបុណ្យជ្រមុជទឹក ដោយការទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ហើយ លើកដាក់ខ្លួនទូវព្រះនាមរបស់ព្រះគ្រីស្ទ។ យើងត្រូវតែស្មោះត្រង់រក្សា និងរំលឹកឡើងវិញនូវទំនាក់ទំនងនៃសេចក្តីសញ្ញានោះផងដែរ។
4. យើងត្រូវបានសង្ត្រោះពី ភាពល្ងង់ខ្លៅនៃភាពងងឹត នៅពេលយើងរៀនអំពីផែនការដំណឹងល្អ។ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នាំពន្លឺមកក្នុងជីវិតរបស់យើង។
5. យើងបានសង្ត្រោះពីសេចក្តីស្លាប់ទីពីរ ដែលជាទីបញ្ចប់នៃសេចក្តីស្លាប់ខាងវិញ្ញាណ ព្រោះតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ មនុស្សគ្រប់រូបលើកលែងតែមនុស្សពីរបីនាក់ដែលក្លាយជាពួកកូនអន្តរធាន ក្រៅពីនោះនឹងបានចូលនៅក្នុងនគរ នៃភាពរុងរឿង។
6. សេចក្តីសង្ឃឹមរបស់យើងគឺថា នៅទីបញ្ចប់យើងទាំងអស់គ្នានឹងត្រូវបានសង្ត្រោះនៅក្នុងនគរសេឡេស្ទាល។ លើសពីនេះទៀត តំរូវការផ្សេងទៀត សេចក្តីសង្ត្រោះនេះ ឬការលើកដំកើងព្រមទាំងតំរូវផងដែរថាយើងធ្វើនៅក្នុងសេចក្តីសញ្ញាពិសិដ្ឋ នៅក្នុងព្រះវិហារ បរិសុទ្ធរបស់ព្រះ និងនៅតែស្មោះត្រង់ចំពោះសេចក្តីសញ្ញាទាំងនោះ (សូមមើល Conference Report, ខែមេសា ឆ្នាំ 1998, ទំព័រ 76–78, ឬ *Ensign,* ខែឧសភា ឆ្នាំ 1998, ទំព័រ 55–57)។

អាលម៉ា 5:7–14—តើការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្តនេះគឺជាអ្វី?

បើយើងស្វែងរកខគម្ពីរពីរបី ដែលពិពណ៌នាអំពីការផ្លាស់ប្តូរនេះ យើងបានរៀនពីបុគ្គលិកលក្ខណៈខ្លះៗ ដែលបានបង្ហាញដោយ អ្នកទាំងឡាយដែលមានបទពិសោធន៍ ការផ្លាស់ប្តូរដ៏ធំនេះ រួមមានដូចខាងក្រោមៈ

- ពួកគេ "ពុំមានបំណងនឹងធ្វើអំពើទុច្ចរិតទៀតឡើយ ប៉ុន្តែចង់ធ្វើល្អជានិច្ចវិញ" (ម៉ូសាយ 5:2)។
- ពួកគេ "ផ្លាស់ប្តូរពីសភាពសាច់ឈាម និងសភាពធ្លាក់ទៅកាន់ស្ថានភាពនៃសេចក្តីសុចរិតវិញ" (ម៉ូសាយ 27:25)។
- ពួកគេ "ភ្ញាក់ពី . . . ដំណេកដ៏លង់លក់" និង "បានចែងចាំងដោយពន្លឺនៃព្រះបន្ទូលដ៏អស់កល្បជានិច្ច" (អាលម៉ា 5:7)។
- "គេបានបន្ទាបខ្លួន ហើយទុកចិត្តទៅលើព្រះដ៏ពិត ហើយមានព្រះជន្មរស់រហូតដល់ទីបំផុត" (អាលម៉ា 5:13)។

អែលឌើរ ម៉ីរីល ជេ. បេឌមេន ជាសមាជិកនៃក្រុមចិតសិបនាក់ បានបង្រៀនពីរឿបដែលមនុស្សម្នាក់អាចទទួលបានការផ្លាស់ប្តូរដ៏ ធំៈ "ការផ្លាស់ប្តូរនៅក្នុងដួងចិត្ត និងព្រលឹងកើតឡើងជាលទ្ធផលមួយនៃការដាំ និងថែរក្សាគ្រាប់ពូជ [សូមមើល អាលម៉ា 32:28]។ ការសិក្សាព្រះគម្ពីរ ការអធិស្ឋាន ការគោរពប្រតិបត្តិ និងការបំរើគឺជាធាតុសំខាន់ នៅក្នុងការស្ថាបនា សេចក្តីជំនឿក្នុងព្រះគ្រីស្ទ" (ក្នុង Conference Report ខែតុលា ឆ្នាំ 1992, 38, ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1992, 28)។

ទាំងស្តេច បេនយ៉ាមីន និងអាលម៉ា បានបកស្រាយអំពីអំណាចនៃការផ្សាយបន្ទូលព្រះ ដើម្បីនាំមកនូវការផ្លាស់ប្តូរដ៏ធំ (សូមមើល ម៉ូសាយ 4:1–3, 5:1–2, អាលម៉ា 5:7, 11–13)។

និយាយអំពីអំណាចនៃព្រះគម្ពីរ ជាពិសេសគឺព្រះគម្ពីរមរមន ក្នុងការផ្លាស់ប្តូរជីវិត ប្រធានអើសរ៉ាថាហ្ចូ ប៉ែនសឹន បានប្រកាសថាៈ "ព្រះគម្ពីរមរមនមិនត្រឹមតែបង្រៀនយើងពីសេចក្តីពិតនោះទេ ត្បិតព្រះគម្ពីរមរមន បានផ្លាស់ប្តូរជីវិត។ ព្រះគម្ពីរមរមន មិនត្រឹម តែធ្វើទីបន្ទាល់អំពីព្រះគ្រីស្ទនោះទេ ត្បិតព្រះគម្ពីរមរមនបានផ្លាស់ប្តូរជីវិត។ តែមានអ្វីច្រើនជាងនោះទៅ ទៀត។ មានអំណាច នៅក្នុងព្រះគម្ពីរ ដែលនឹងចាប់ផ្តើមហូរចូលទៅក្នុងជីវិតរបស់អ្នក នៅវេលាណាដែលអ្នកចាប់ផ្តើមសិក្សាព្រះគម្ពីរនេះ ដោយពិត ប្រាកដ។ អ្នកនឹងស្វែងរកឃើញនូវអំណាចដ៏មហិមាដើម្បីតទល់នឹងការល្បួង។ អ្នកនឹងស្វែងរកអំណាច ដើម្បីច្រៀសវាងពី ការបោក បញ្ឆោត។ អ្នកនឹងស្វែងរកឃើញនូវអំណាចដើម្បីបន្តដើរនៅលើផ្លូវដ៏តូចនិងចង្អៀត។ ព្រះគម្ពីរគឺត្រូវបានហៅថាជា 'បន្ទូល ទាំងឡាយនៃជីវិត' (គ និង ស 84:85) ហើយគ្មានអ្វីពិតជាងព្រះគម្ពីរមរមនទេ។ នៅពេលអ្នកចាប់ផ្តើមស្រេកឃ្លានទូវព្រះបន្ទូលទាំងនោះ អ្នកនឹងរកឃើញជីវិតដ៏ប្រសើរ និងកាន់តែសម្បូរណ៍ច្រើនឡើង" (ក្នុង Conference Report, ខែតុលា ឆ្នាំ 1986, 6, ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1986, 7)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង សកម្មភាពមួយទៀតចេញពីសកម្មភាព (ខ–យ)នៅពេលអ្នកសិក្សា អាលម៉ា 5។

ភ សរសេរសំបុត្រមួយច្បាប់

ស្រមៃថា អ្នកមានមិត្តម្នាក់ ដែលជាអ្នកមិនទទួលយកសាសនា និងដំណឹងល្អដោយពិតប្រាកដ។ អត្តចរិតរបស់ពួកគេគឺថា យើងពិតជាមិនចាំបាច់ធ្វើល្អ ដើម្បីបានការសង្ត្រោះនោះទេ។ មិត្តរបស់

អ្នកជឿថា ព្រះស្គាល់ពីភាពទន់ខ្សោយរបស់យើង ហើយទោះជាយ៉ាងណាក៏ដោយទ្រង់នឹងសង្គ្រោះយើង យើងគួរតែចៀសវាងនូវអំពើបាបធ្ងន់ធ្ងរបានហើយ។ អ្នកពិតជា ស្រឡាញ់មិត្តរបស់អ្នកខ្លាំងណាស់ ហើយចង់ឱ្យពួកគេយល់ និងស្វែងរកសុភមង្គល។ សូមសរសេរសំបុត្រទៅមិត្តម្នាក់នេះ ដោយ ពន្យល់ពីអ្វីដែលមិនត្រឹមត្រូវអំពីគំនិតរបស់ពួកគេ ដែលទាក់ទងទៅនឹងដង្វាយធួន។ ចូរប្រើសេចក្តីពិតដែលអាលម៉ា បានបង្រៀន នៅក្នុងអាលម៉ា 5:10–42 ដើម្បីជួយអ្នកបង្រៀនដល់មិត្តរបស់អ្នក។ ត្រូវប្រាកដថាមានពន្យល់ពីចំណុចទាំងឡាយខាងក្រោម នេះ នៅក្នុងសំបុត្ររបស់អ្នក៖

- តើពាក្យ *សង្គ្រោះ* មានន័យដូចម្តេច?
- តើការមានបទពិសោធន៍ "ការផ្លាស់ប្តូរដ៏ធំ" និង "បានកើតមកពីព្រះ" មានអត្ថន័យដូចម្តេច? តើគោលការណ៍នេះ អាច ជួយផ្លាស់ប្តូរមនុស្សម្នាក់ដោយរបៀបណា?
- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមានការផ្លាស់ប្តូរដ៏ធំនោះ?
- តើវាចាំបាច់ទេ ដើម្បីទទួលបទពិសោធន៍នៃការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្តយើង និងបានកើតមកពីព្រះនោះ?
- តើយើងនឹងក្លាយជាអ្វី បើយើងមិនមានការផ្លាស់ប្តូរ?

២ ពន្យល់ពីថ្ងៃជំនុំជំរះ

អាលម៉ាបានពិពណិនាអំពីថ្ងៃជំនុំជំរះ នៅពេលដែលយើងទាំងអស់គ្នា នឹងមកខាងមុខព្រះភក្ត្រព្រះ ដើម្បីទទួលការជំនុំជំរះ។

1. ចូរប្រើពតិមាននៅក្នុងអាលម៉ា 5:16–25 រួចប្រៀបធៀបពីអារម្មណ៍នៃការមិនប្រែចិត្ត និងការប្រែចិត្ត។
2. គោលលទ្ធិ និងសេចក្តីសញ្ញា 76:5–10 មានផ្តល់ពតិមានបន្ថែមទៀតស្តីអំពីរបៀបប្រែចិត្ត និងអ្នកសុចរិតនឹងត្រូវបាន ទទួលពរ។ ចូរសិក្សាខទាំងនោះ ហើយប្រៀបធៀបពីអ្វីដែលព្រះអម្ចាស់ឱ្យដល់មនុស្សទាំងឡាយណាដែលធ្វើតាមទ្រង់ ជាមួយនឹងអ្វី ដែលអារក្សឱ្យដល់មនុស្សដែលធ្វើតាមវា។ តើអ្នកចង់បានមួយណាជាង? ហេតុអ្វី? តើអ្នកមានអារម្មណ៍បែបណា បើ ព្រះអម្ចាស់មានបន្ទូលជាពាក្យទាំងនោះនៅក្នុងអាលម៉ា 5:16 មកកាន់អ្នក?

៣ ប្រៀបធៀបនឹងសម័យថ្មី

អាលម៉ាបានដឹងថាសមាជិកសាសនាចក្រនៅសម័យរបស់គាត់បានប្រឈមមុខជាមួយនឹងបញ្ហា ប្រឈមមុខដ៏ពិបាក។ ចូរស្រាវ ជ្រាវនៅក្នុងអាលម៉ា 5:26–35, 52–62 ហើយសរសេរនូវបញ្ហា ប្រឈមមុខពីរដែលអាលម៉ា បានលើកឡើងថា ក៏ជាបញ្ហា ប្រឈមមុខនៅក្នុងសម័យរបស់យើងផងដែរ។ ចូរប្រើនូវអ្វីដែលអ្នកបានរៀនពីអាលម៉ា រួចពន្យល់ពីអ្វីដែលយើងអាចធ្វើ ដើម្បីយកឈ្នះលើបញ្ហាទាំងនោះ។

៤ សរសេរពាក្យគន្លឹះសង្ខេបមួយ

អាលម៉ាបានចែកចាយសក្ខីភាពរបស់គាត់នៅក្នុង អាលម៉ា 5:37–52។ សរសេរពាក្យប្រាំដែលអ្នកគិតថាសំខាន់ ឬ ឃ្លានៅក្នុង សក្ខីភាពរបស់អាលម៉ា។ ពន្យល់ពីមូលហេតុការជ្រើសរើសរាល់ពាក្យនីមួយៗ ឬ ឃ្លានីមួយៗ។

អាលម៉ា 6–7

អាលម៉ាផ្សព្វផ្សាយនៅក្នុងទីក្រុងគេខាន

បន្ទាប់ពីការពង្រឹងសាសនាចក្រនៅក្នុងដែនដីសាវ៉ាហិមឡាមក អាលម៉ាបានផ្លាស់ទីលំនៅទៅកាន់ទីក្រុងគេខាន។ អាលម៉ាបានរក យើញថាសមាជិកនៅក្នុងសាសនាចក្រ នៅទីនោះមានជំនឿ ស្មោះត្រង់ខ្លាំងជាងសមាជិកដែលនៅទីក្រុង សាវ៉ាហិមឡា។ ហេតុដូច្នោះហើយ សារដំណឹងរបស់គាត់ទៅកាន់ពួកបរិសុទ្ធនៅក្នុងទីក្រុងគេខានភាគច្រើន គឺមិនបានហៅឱ្យប្រែចិត្តទេ ដែលវាដូចជាការណែនាំ និងការលើកទឹកចិត្តមួយវិញ។ ចូរធ្វើការកត់ចំណាំពីអ្វីដែលអាលម៉ា បានបង្រៀននៅក្នុង អាលម៉ា 6–7 អំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះ និងអ្វីដែលយើងត្រូវធ្វើដើម្បីបានជ្រះស្អាតដោយដង្វាយធួនរបស់ទ្រង់។

អាលម៉ា

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 6

សេរី (ខ 5)—ការផ្តល់ឱ្យដោយសេរី, គ្មានព្រំដែន

រប្យៀបរៀបចំ (ខ 7)—ច្បាប់

អាលម៉ា 7

ការសុំក្តីសន្តោសពីទ្រង់ (ខ 3)—ការអធិស្ឋានសំរាប់ជំនួយដ៏ទេវភាព

ត្តូរឱ្យស្វែងខ្លាច (ខ 3, 18)—វិបត្តិ, ស្ថានភាពគួរឱ្យអស់សង្ឃឹម

ពិសេស (ខ 10)—មនុស្សដែលសម និងមានមុខងារពិសេស

តាមជម្ងឺ (ខ 12)—ភាពទន់ខ្សោយ, មិនល្អឥតខ្ចោះ

ត្រូវជួយ (ខ 12)—ជួយ, គាំទ្រដល់

ហ៊ុំព័ទ្ធ (ខ 15)—បញ្ហា

ដំណើររបស់ទ្រង់គឺជាវង់មួយដ៏នៅអស់កល្បជានិច្ច (ខ 20)—ផ្លូវរបស់ព្រះគឺនៅអស់កល្បជានិច្ច និងគ្មានភាពផ្លាស់ប្តូរ

រហ័សធ្វើតាមការល្អ (ខ 23)—ត្រៀមខ្លួនជាស្រេច ដើម្បីទទួលការណែនាំ និងពាក្យទូន្មាន។

សង្កត់ចិត្ត (ខ 23)—ដែលចេះប្រមាណ, ប្រើការគ្រប់គ្រងលើខ្លួនឯង

អាលម៉ា 7:11–13—តើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទជួយខ្ញុំដោយរបៀបណា?

ពួកគ្រីស្ទានជាច្រើនយល់ថា ដោយការទទួលរងទុក្ខរបស់ទ្រង់នៅក្នុងសួនច្បារគែតសេម៉ានី ហើយនៅលើឈើឆ្កាងព្រះអង្គសង្គ្រោះ បានសងថ្លៃអំពើបាបរបស់យើង។ នៅក្នុងអាលម៉ា 7:11–13

ញ្យាការីអាលម៉ាបានពន្យល់ថា ដង្វាយធ្ងន់របស់ទ្រង់ បានសងថ្លៃនៃ អំពើបាប ហើយមានច្រើនជាងនោះទៀត។ អាលម៉ាបានធ្វើទីបន្ទាល់ថា ព្រះអង្គសង្គ្រោះបានយាងមកលើផែនដី ដើម្បីលើកដាក់ខ្លួនទ្រង់នូវរាល់ការឈឺចាប់ត្រប់ប្រភេទ ដែលជាផ្នែកមួយនៃបទពិសោធន៍នៃជីវិតរមែងស្លាប់នេះ។

- ទ្រង់លើកដាក់លើខ្លួនទ្រង់នូវការ "ឈឺចាប់ និងជម្ងឺរបស់រាស្ត្រទ្រង់" (ខ 11)។ ការឈឺចាប់នេះ មានន្ទូវទុក្ខវេទនាត្រប់ ប្រភេទ ដែលនឹងធ្លាក់មកលើយើង ទោះបីជាយើងមិនបានធ្វើអ្វីខុសក៏ដោយ។
- ទ្រង់យកដាក់លើព្រះអង្គទ្រង់ នូវសេចក្តីស្លាប់ ដើម្បីយើងអាចត្រូវបានរស់ឡើងវិញ (សូមមើល ខ 12)។
- ទ្រង់យកដាក់លើព្រះអង្គទ្រង់ នូវជម្ងឺរបស់យើង (សូមមើល 12) ដែលរួមមានទាំងភាពទន់ខ្សោយ និងភាពមិនល្អ ឥតខ្ចោះនៃរូបកាយ គំនិត ឬ អត្តចរិត ដែលយើងស្មុតស្មាញ នៅក្នុងសេចក្តីប៉ងប្រាថ្នារបស់យើង ដើម្បីប្រែក្លាយឱ្យដូចជាព្រះគ្រីស្ទ។
- ទ្រង់យកដាក់លើព្រះអង្គទ្រង់ នូវអំពើបាបរបស់យើង ដើម្បីឱ្យយើងអាចបានទទួលការអភ័យទោស (សូមមើល ខ 13)។

អែលឌើរ ចន អេច. ហ្ស្រូប៊ឺហ្ត ជាសមាជិកនៃក្រុមចិតសិបនាក់ បានមានប្រសាសន៍ថាះ "ខ្ញុំសូមធ្វើទីបន្ទាល់ថា ត្មានន្រណាម្នាក់ ផ្លាប់ ឬនឹងមានបទពិសោធន៍អំពីកាលះទេសះណាមួយនេះឡើយ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ខ និង ក ឬ គ នៅពេលអ្នកសិក្សាអាលម៉ា 6–7។

ក៏ សង្ខេបឡើងវិញពីសេចក្តីសញ្ញានៃបុណ្យជ្រមុជទឹក

សេចក្តីសញ្ញាគឺជាការយល់ព្រម សន្យា ឬចុះកិច្ចសន្យារវាងមនុស្សពីរនាក់ ឬពីរក្រុម។ ប្រៀបធៀបអាលម៉ា 7:15–16 និងគោលលទ្ធិ និងសេចក្តីសញ្ញា 20:77 និងសរសេរសង្ខេបឡើងវិញពីអ្វីដែលយើងសន្យានឹងព្រះវរបិតាសួគៃ និងអ្វីដែលទ្រង់ សន្យានឹងយើង នៅពេលដែលយើងធ្វើសេចក្តីសញ្ញានៃបុណ្យជ្រមុជទឹក (សូមមើល ម៉ូសាយ 18 សំរាប់ជាជំនួយបន្ថែម)។

ខ ប្រៀបធៀបដង្វាយធ្ងនទៅនឹងសម័យរបស់យើង

ក្នុងអាលម៉ា 7:9–16 អាលម៉ាបានចែកចាយសក្ខីភាពរបស់លោក អំពីដំណើរជីវិត និងបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ។

1. ចូរស្រាវជ្រាវនៅក្នុងខ 11–13 ហើយសរសេរពីការប្រឈមមុខផ្សេងឲគ្នាចំនួនបួន ដែលយើងអាចជួបប្រទះនៅក្នុងជីវិតនេះ ដែលជីវិត និងដង្វាយធ្ងនរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយយើងបាន (សូមមើល វត្ត "ការយល់ដឹងអំពីព្រះគម្ពីរ" ផងដែរសំរាប់អាលម៉ា 7:11–13)។
2. សំរាប់រាល់ស្ថានភាពនីមួយឲដូចខាងក្រោម ចូរបញ្ជាក់ពីការប្រឈមមុខចំនួនបួន ដែលវាបានបង្ហាញ និងពន្យល់ ពីរបៀប ដើម្បីវិលត្រឡប់ទៅរកព្រះយេស៊ូវគ្រីស្ទវិញ នឹងអាចជួយដល់បុគ្គលនោះ:
   ក. មេលីនដា មានអាយុ ដប់ពីរឆ្នាំ។ កាលពីខែមុន នាងទទួលរងនូវគ្រោះថ្នាក់ឡានបុក ដែលបន្សល់ទុកឱ្យនាងនូវជើងពិការ។
   ខ. ជូអាន បានធ្វើការសំរេចចិត្តដ៏អាក្រក់ខ្លះឲ ហើយបានធ្វើនូវរឿងដ៏អាម៉ាស់។ គាត់មានអារម្មណ៍មួរម៉ៅ និងឥតតម្លៃ។
   គ. ម៉ៃគល មានអាយុ 45 ឆ្នាំ។ គាត់មានប្រពន្ធ និងកូន។ គាត់ទើបតែដឹងថា គាត់មានជំងឺមហារីក ហើយវេជ្ជបណ្ឌិតមាន ប្រសាសន៍ថា គាត់មិនអាចរស់ច្រើនជាងមួយឆ្នាំទៀតទេ។ ម៉ៃគល សោកសៅ ច្របូកច្របល់ និងមានកំហឹងខ្លះឲ។
   ឃ. អ៊ីមម៉ា ត្រូវបានហៅឱ្យធ្វើជាប្រធានថ្នាក់ឡូរ៉ែល។ នាងមិនដែលមានមុខងារមួយនេះពីមុនទេ។ នាង ស្រឡាញ់ដំណឹងល្អ ហើយនាងពិតជាចង់ធ្វើកិច្ចការឱ្យបានល្អ តែនាងមានអារម្មណ៍ភ័យខ្លាច និងត្មានសមត្ថភាព។

ក៏ បង្ហាញព្រះគម្ពីរ

ចូរសិក្សាអាលម៉ា 7:19–21 និងគូររូបភាពមួយអំពីគោលការណ៍នៃដំណឹងល្អសំខាន់ ដែលអ្នករកហើយថាមានពិពណិនានៅ ទីនេះ។ ដាក់ចំណង ដើងរូបភាពរបស់អ្នកជាមួយនឹងយ្លាដែលពន្យល់ពីអ្វីដែលជាតំណាងឱ្យរូបភាពនោះ។

កិច្ចការជ្យពូជ្យាយសាសនា គំរូវឱ្យមានការខំប្រឹងដ៏ខ្លាំង ហើយនឹងអាចមានការបាក់ទឹកចិត្តជាច្រើនគ្រា។ នៅពេលដែល ប្រធាន គរដឹន ប៊ី. ហ៊ីងឃ្លី នៅជាអ្នកជ្យពូជ្យាយសាសនារ៉ាយក្មេង នៅក្នុងប្រទេសអង់គ្លេស លោកមានអារម្មណ៍បាក់ទឹកចិត្តយ៉ាងខ្លាំង។ "[លោក] បានសរសេរទៅឱពុកលោកថា លោកមិនឃើញមានការរីកចំរើនអ្វីសោះ ក្នុងកិច្ចការជ្យពូជ្យាយសាសនានេះ ហើយថា លោកមិនឃើញមានមូលហេតុអ្វីសោះ ក្នុងការចំណាយពេលរបស់លោក និងថវិការរបស់ឱពុកលោកដោយឥតប្រយោជន៍នោះ។ ការឆ្លើយតបវិញ ក្នុងនាមជាឱពុក និងជាប្រធានសង្កាត់ លោក ប្រើអាន់ ហ៊ីងឃ្លី បានផ្ញើតបទៅវិញយ៉ាងសង្ខេបហើយចំចំណុច ថាះ ់ គរដឹន ជាទីស្រឡាញ់ ឱពុកបានទទួលសំបុត្រកូនហើយ ក្នុងពេលថ្មីឲនេះ។ ឱពុកមានតែយោបល់តែមួយប៉ុណ្ណោះថាះ បំភ្លេចខ្លួនឯង ហើយទៅធ្វើការចុះ" (Sheri L. Dew, Go Forward With Faith: The Biography of Gordon B. Hinckley *[1996], 64)*។

អាលម៉ា បានបាក់ទឹកចិត្ត ពេលដែលកំពុងតែផ្សព្វផ្សាយនៅក្នុងដែនដីអាំម៉ូណៃហា។ នៅពេលអ្នកអាន ពិបទពិសោធន៍របស់គាត់ ចូរស្វែងរកវប្បបដែលព្រះអម្ចាស់បានលើកទឹកចិត្ត ហើយបានផ្តល់កំលាំងដល់គាត់ ដើម្បីឱ្យគាត់បន្តកិច្ចការតទៅទៀត។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 8

រប្បបដ៏ចរិសុទ្ធនៃព្រះ (ខ. 4)—បព្វជិតភាពមុលគីស្សាដែក

ដេរប្រមាថ (ខ. 13)—មើលងាយ បំពាន

សេចក្តីត្រាំត្រា (ខ. 14)—សេចក្តីទុក្ខព្រួយ ការសោកសង្រេង ការឈឺចាប់

ការផ្ទុយនឹងក្រឹត្យក្រម (ខ. 17)—ប្រឆាំងនឹងច្បាប់

កាន់តែធ្លាក់ខ្លួនធ្ងន់ធ្ងរទៅៗ (ខ. 28)—កាន់តែអាក្រក់ឡើង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរខាងក្រោមនេះ (ក–គ) នៅពេលអ្នកសិក្សា អាលម៉ា 8។

ក សរសេរអត្ថបទមួយ

ប្រៀបធៀបបទពិសោធន៍របស់អាល់ម៉ា នៅក្នុងដែនដីមេលេក (សូមមើល អាលម៉ា 8:3–6) ហើយនៅក្នុងដែនដី អាំម៉ូណៃហា (សូមមើល ខ 7–13)។ បើសិនជា អ្នកគឺជាអ្នកការសែតម្នាក់ ដែលត្រូវបានចាត់ឱ្យសរសេរអត្ថបទមួយ អំពីការទៅជួបសួរសុខ ទុក្ខរបស់អាលម៉ានៅកន្លែងទីមួយៗ តើអ្នកនឹងសរសេរពីអ្វីខ្លះ? សូមកុំភ្លេចបញ្ចូលនូវរប្បប ដែលគេប្រព្រឹត្តចំពោះគាត់ ហើយតើហេតុអ្វីបានជាអ្នកគិតថាពួកគេប្រព្រឹត្តមកលើគាត់រប្បបនោះ។

ខ សង្ខេបពីអ្វីដែលបាននិយាយ

ទេវតាមួយអង្គ បានមានបន្ទូលទៅកាន់អាលម៉ា និងអាមូលេក។

1. សង្ខេបពីអ្វីដែល ទេវតាមានបន្ទូលទៅកាន់ អាលម៉ា (សូមមើល អាលម៉ា 8:14–17) និង អាមូលេក (សូមមើល អាលម៉ា 8:20, 10:7)។
2. តើអ្វីដែលទេវតាបានមានបន្ទូល អាចលើកទឹកចិត្តដល់ពួកអ្នកផ្សព្វផ្សាយសាសនាសព្វថ្ងៃនេះយ៉ាងដូចម្តេច?

គ សរសេរសំបុត្រមួយទៅផ្ទះ

ស្រមៃថា អ្នកជាអាលម៉ា ឬក៏ជាអាមូលេក ដែលកំពុងសរសេរសំបុត្រទៅកាន់ក្រុមគ្រួសាររបស់អ្នក។ សិក្សា អាលម៉ា 8:21–32 រួចហើយសរសេរសំបុត្រមួយច្បាប់ទៅផ្ទះ អំពីអ្វី ដែលកំពុងកើតឡើង នៅក្នុងបេសកកម្មលើទឹកដី អាំម៉ូណៃហា។

អាលម៉ា 9

អាលម៉ាប្រកាសអំពីការប្រែចិត្ត ទៅកាន់ប្រជាជននៅដែនដីអាំម៉ូណៃហា

មនុស្ស នៃដែនដីអាំម៉ូណៃហា មានចិត្តរឹងរូស ខឹងសម្បារ ហើយស្រែកមើលងាយដល់អាលម៉ា និង អាមូលេក។ ក្រោយមក អ្នកផ្សាយសាសនាដ៏ស្មោះត្រង់ទាំងពីរនាក់នេះ ត្រូវបានចាប់ដាក់គុក។ បើសិនជាអ្នកប្រឈមមុខជាមួយ នឹងការប្រឆាំងប្រភេទ នេះ តើអ្នកនឹងមានប្រតិកម្មយ៉ាងដូចម្តេច? នៅពេលអ្នកអាន អាលម៉ា 9 ចូរនឹកគិតថា អ្នកនៅទីនោះជាមួយអាលម៉ា។ តើ អ្នកត្រូវមានសេចក្តីក្លាហានរប្បបណា ដើម្បីប្រឈមមុខ នឹងប្រជាជនទាំងនោះ? តើអ្នកអាចនិយាយអ្វីខ្លះ ដើម្បីជា ជំនួយយ៉ាងប្រសើរបំផុត ចំពោះពួកគេ? ការបង្រៀនរបស់អាលម៉ា និងអាមូលេក ដល់ប្រជាជននៅដែនដីអាំម៉ូណៃហា មាននៅក្នុងជំពូក 9–14។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 9

ជជែកគត (ខ. 1)—ប្រកែក ជជែក

ក្បាលរឹង (ខ. 5, 31) រឹងរូស ភាពឆ្មើងឆ្មៃ

ពូជមនុស្សខូច (ខ. 8)—មនុស្សអាក្រក់

ជាប់ឃុំឃាំងក្នុងស្ថានភាពមួយ (ខ. 11)—ជាប់នៅក្នុងស្ថានភាពមួយ

បានបញ្ជាក់ (ខ. 14)—បញ្ជាក់ថាពិត

អត់ឱនច្រើនជាង (ខ. 15, 23)—ប្រសើរជាង

ទុកឱ្យគេបន្តការរស់នៅ (ខ. 16)—ពន្យាពេលរបស់ពួកគេ

នៅជិតដៃបង្កើយ (ខ. 25)—នឹងមកដល់ឆាប់ៗ

សេចក្តីយុត្តិធម៌ (ខ. 26)—ស្មើភាពយុត្តិធម៌

ទុកឱ្យ (ខ. 33)—អនុញ្ញាតឱ្យ

អាលម៉ា 9:26–27—ដំណើរការ នៃការប្រែចិត្ត ដែលធ្វើឱ្យជាសះស្បើយ



ប្រធាន ដេម អ៊ី. ហ្វោស ទីប្រឹក្សាទីពីរនៃគណៈប្រធានទីមួយ មានប្រសាសន៍ថា៖ “យើងទាំងអស់គ្នា ធ្លាប់ប្រព្រឹត្តខុស ជាច្រើនដងកន្លងមក។ ខ្ញុំឈឿថា ព្រះដែលមានព្រះទ័យល្អ និងមានមេត្តាករុណា ចំពោះយើងត្រង់គ្នាដែលជាកូនចៅ ទីរឹងនិច្ឆ័យយើងដោយយោគយល់ តាមដែលទ្រង់អាចធ្វើទៅបាន ចំពោះកំហុសដែលយើងធ្វើហើយផ្តល់ពរដ៏យឱ្យយើង ជាអតិបរិមា ចំពោះសេចក្តីល្អដែលយើងធ្វើ។ ភាពវិសេសបំផុត របស់អាលម៉ា [នៅក្នុងអាលម៉ា 9:26] ហាក់ដូចជា មានការអះអាង ដ៏ពិតត្រង់ជាមួយ សំរាប់ខ្ញុំនៃរឿងទាំងនេះ។ (នៅក្នុង Conference Report, ខែ តុលា ឆ្នាំ 1996, 75 ឬ *Ensign,* ខែវិច្ឆិកា ឆ្នាំ1996, 53)។

ការសិក្សាព្រះគម្ពីរ

ធ្វើសកម្មភាព ក និង ខ ឬក៏សកម្មភាព គ នៅពេលអ្នកសិក្សាអាលម៉ា 9។

ក តើយើងអាចរៀនអ្វីខ្លះពីប្រវត្តិសាស្ត្រ?

ចូរសាប់ចំនួនប៉ុន្មានដង ដែលអាលម៉ាបានប្រើឃ្លា "តើអ្នកមិនចាំទេឬថា" និង "តើអ្នកឆាប់ភ្លេចម្ល៉េះថា" នៅក្នុងអាលម៉ា 9:7–14។

1. ធ្វើបញ្ជីឧទាហរណ៍ ដែលគាត់ប្រើក្នុងប្រវត្តិសាស្ត្ររបស់ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ដើម្បីបង្ហាញពីភាពចាំបាច់ នៃការប្រែចិត្ត។
2. សរសេរគំនិតរបស់អ្នក អំពីរបៀបដែលឧទាហរណ៍ ទីមួយៗជួយដល់ប្រជាជនទៅក្នុងដែនដីអាំម៉ូណៃហាឱ្យប្រែចិត្ត។
3. តើដោយរបៀបណាខ្លះ ដែលគំរូរបស់គាត់ជួយអ្នកឱ្យមានចំណងប្រែចិត្តកាន់តែខ្លាំង?

ខ ទទួលយកការកែលំអគ្នា

អាលម៉ាធ្វើបញ្ជីពិពរណ៌យ៉ាងច្រើនដែលពួកសាសន៍នីហ្វៃ បានពិសោធនៅក្នុងអាលម៉ា 9:18–22។

1. បង្កើតកូឡោនពីរ នៅក្នុងស្បៃវែងសរសេររបស់អ្នក។ នៅក្នុងកូឡោនទីមួយ ធ្វើជាបញ្ជីពរជ័យខាងលោកិយ៍ (រូបកាយ) ដែលពួកសាសន៍នីហ្វៃបានទទួល ហើយនៅក្នុងកូឡោនទីពីរ ធ្វើជាបញ្ជីពរជ័យខាងវិញ្ញាណដែលពួកគេ បានទទួល។
2. អានន្ទវការប្រមានរបស់អាលម៉ា នៅក្នុងអាលម៉ា 9:23–24។ តើការប្រមានរបស់គាត់អនុវត្តទៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា 82:3 យ៉ាងដូចម្តេច? ហេតុអ្វី?

គ ធ្វើផ្ទាំងក្រដាសមួយផ្ទាំង

បង្កើតផ្ទាំងក្រដាសមួយផ្ទាំង ដែលជាតំណាងឱ្យគោលលទ្ធិ ដែលបានបង្រៀនទៅក្នុងអាលម៉ា 9:25–30។ រៀបចំផ្ទាំងក្រដាស តាមរបៀបមួយ ដែលអ្នកអាចប្រើវាទៅក្នុងថ្នាក់ ដើម្បីជួយដល់សិស្សដទៃទៀត យល់ឱ្យកាន់តែច្បាស់ ពីការបង្រៀនរបស់ អាលម៉ាអំពីព្រះយេស៊ូវគ្រីស្ទ។

អាមូលេក

ប៊ីស្សព អេដ. ដាវីឌ ប៊ឺតុន ដែលក្នុងពេលនោះ ជាទីប្រឹក្សាទីមួយ នៅក្នុងគណៈប៊ីស្សបជាអធិបតី បានបង្រៀនថា "អាលម៉ា និង អាមូលេក បានស្គាប់ទេវតា។ ពួកគេបានឆ្លើយតប ទៅនឹងការហៅឱ្យបំរើការផ្សព្វផ្សាយសាសនា ហើយពួកគេប្រកាសពី ការប្រែចិត្ត។ ពួកគេឈរយ៉ាងរឹងមាំប្រឈមមុខ នឹងសេចក្តីវេទនា និងការដាប់គុក។ ពួកគេគឺជាវីរបុរស ជីវិតរបស់ពួកគេ គឺមានភាពសក្តិសម និងប្រតិបត្តិតាម" (នៅក្នុង Conference Report, ខែមេសា ឆ្នាំ1993, 60 ឬ Ensign, *ខែឧសភា ឆ្នាំ 1993, 47)។ នៅពេលអ្នកអានពីការផ្លាស់គំនិត និងទីបន្ទាល់របស់អាមូលេក ចូរពិចារណាអំពីរបៀបដែលចំណេះជឿរបស់គាត់អំពីព្រះយេស៊ូវគ្រីស្ទ បានជួយដល់គាត់ នៅក្នុងពេលលំបាកលំបិននោះ។ តើអាមូលេក មានគុណសម្បត្តិអ្វីខ្លះ ដែលអ្នកមានចំណង់ ព្យាយាមធ្វើតាម?*

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 10

សាច់ញាតិ ញាតិសន្តាន ក្រុមញាតិ (ខ. 4, 7, 11)—សមាជិកគ្រួសារ

ដៃដ៏ឧស្សាហ៍របស់ខ្ញុំ (ខ. 4)—កិច្ចការធ្ងន់ កិច្ចការឡើងត្រង់របស់ខ្ញុំ

សេចក្តីអាថិកំបាំង (ខ. 5)—សេចក្តីពិតដែលអាចដឹងបានតាមរយៈតែវិវរណៈដ៏ទេវភាពប៉ុណ្ណោះ

ការរក្សា (ខ. 5)—ការសង្គ្រោះ

សម្តែង (ខ. 10)—បានដឹង

ប្រើកលល្បិច (ខ. 13)—រៀបចំមិនស្មោះ ហើយដែលបោកបញ្ឆោត ក្នុងការសួរសំនួរ និងការនិយាយ

បង្ខូច (ខ. 18)—ផ្លាស់ប្តូរ ពុករលួយ

ជម្ងឺអាសន្នរោគ (ខ. 22–23)—ជម្ងឺឬក៏រោគ

ដេរប្រមាថដល់ បង្អាប់ដល់ (ខ. 24, 29)—រិះគន់ ដេរប្រមាថ

អ្នកដឹកមុខ (ខ. 31)—ទីមួយនៅក្នុងតំណែង ឬសារសំខាន់

អាលម៉ា 10:22–23—"ការអធិស្ឋានៃពួកសុចរិត"

ប្រធាន ស្តែនស៊ើរ ជបុលយូ ឃិមប៊ីល ដែលពេលនោះជា ប្រធានស្តីទី នៃក្រុមសាវក 12 ទាក់មានប្រសាសន៍ថា: "សម្លេងដ៏ច្រើន នៃការលួងលោមវិញ្ញាណ បានតាំទ្រឱ្យមានសេចក្តីសប្បាយរីករាយខាងសាច់ឈាម និងការពេញចិត្តខាងរូបកាយ។ ពិតពលោក យើងបច្ចុប្បន្នគឺប្រហាក់ប្រហែលគ្នាទៅនឹងសម័យនៃព្យាការីពួកសាសន៍ នីហ្វៃ ដែលបានមានប្រសាសន៍ថា: '. . . បើពុំដោយសារ ការអធិស្ឋាន នៃពួកសុចរិត . . . អ្នករាល់គ្នាច្បាស់ជា ឥឡូវនេះត្រូវទទួលរងដោយការបំផ្លិចបំផ្លាញទាំងស្រុងទៅហើយ . . .' (អាលម៉ា 10:22)។ តាមពិតទៅមានអ្នកទ្បើងត្រង់ និងមានចិត្តស្មោះត្រង់ រស់នៅតាមព្រះបញ្ញត្តិទាំងអស់ ហើយជីវិត និងការអធិស្ឋានរបស់ពួកគេ បានរក្សាពិភពលោកចេញពីការបំផ្លិចបំផ្លាញ" (នៅក្នុង Conference Report, ខែ មេសា 1971, 7 ឬ *Ensign ខែមិថុនា ឆ្នាំ 1971, 16)*។

ជីដូនជីតារបស់អាមូលេក



ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរខាងក្រោមនេះ (ក–គ) នៅពេលអ្នកសិក្សាអាលម៉ា 10។

ក ការសម្តែងសន៍អ្នកផ្តាស់សាសនាថ្មីម្នាក់

ពិភាក្សាជាមួយអ្នកផ្តាស់សាសនាថ្មីម្នាក់ ចូលមកសាទាចក្រ អំពីការផ្លាស់សាសនា និងទីបន្ទាល់របស់គាត់។ ប្រៀបធៀបបទ ពិសោធន៍ នៃអ្នកផ្តាស់ប្តូរសាសនានេះ ជាមួយបទពិសោធន៍របស់អាមូលេក នៅក្នុងអាលម៉ា 10:1–11។ ឆ្លើយសំនួរដូចខាង ក្រោមនេះ:

1. តើបទពិសោធន៍របស់ពួកគេស្រដៀងគ្នាដូចម្តេចខ្លះ?
2. តើបទពិសោធន៍របស់ពួកគេខុសគ្នាដូចម្តេចខ្លះ?
3. តើអាលម៉ា 10:8 ស្រដៀងគ្នានឹង និហ្វៃទី1 3:7 ដូចម្តេចខ្លះ?

ខ ចូរធ្វើបញ្ជីពាក្យមួយ

1. នៅពេលអ្នកអានអាលម៉ា 10:12–32 ចូរចុះបញ្ជីពាក្យទាំងឡាយណា ដែលបានពិពណ៌នាអំពីពួកមេធាវី និងពួកចៅក្រម នៅក្នុងដែនដីអាំម៉ូណៃហា។
2. តើហេតុអ្វីបានជាអ្នកគិតថា អ្នកស្រុកចេះដឹងមានទ្រព្យ និងមានឥទ្ធិពលទាំងនោះ មានការខ្វល់ខ្វាយជាមួយនឹង ពាក្យរបស់អាលម៉ា និងអាមូលេកខ្លាំងម្ល៉េះ?

គ ពន្យល់

នៅក្នុងអាលម៉ា 10:22–23 អាមូលេកបានបង្រៀន គោលលទ្ធិ ដ៏សំខាន់មួយ។ សិក្សាពីខទាំងនោះ ហើយឆ្លើយនូវសំណួរ ខាងក្រោមនេះ:

1. តើអ្វីដែលបានការពារដល់ទីក្រុងអាំម៉ូណៃហាឱ្យរួចពីសេចក្តីបំផ្លិចបំផ្លាញ?
2. តើមានឧទាហរណ៍អ្វីខ្លះ ដែលបង្ហាញថា គោលការណ៍នេះពិត សំរាប់ពេលបច្ចុប្បន្ននេះ?
3. តើគោលការណ៍នេះ ផ្តល់ឱ្យអ្នកនូវការកំសាន្តចិត្ត និងការរ៉ាប់រងអ្វីខ្លះដល់អ្នក?

តើអ្នកនឹងបដិសេធមិនធ្វើទីបន្ទាល់ ដោយចំនួនលុយដ៏ច្រើនឬ? នៅក្នុងអាលម៉ា 11 សិរីអែសរ៉ុម ជាចៅក្រមទុច្ចរិតម្នាក់ បាន ប្រណាំងប្រជែង នឹងការបង្រៀនរបស់អាលម៉ា និងអាមូលេក។ ចូរស្វែងរកថា តើលុយដែលគាត់បានផ្តល់ទៅឱ្យអាមូលេក មានចំនួនប៉ុន្មាន ដើម្បីកុំឱ្យអាមូលេកទទួលស្គាល់ ថាមានព្រះ។ សូមកត់សំគាល់ផងដែរ អំពីរបៀបដែលអាមូលេកបានបំភាន់ សិរីអែសរ៉ុម។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 11

បានបង្ខំ (ខ. 2)—បង្ខិតបង្ខំ

ការគិតគូរ (ខ. 5, 14, 18)—របៀបនៃការគិត

ប្រយោជន៍ (ខ. 24)—លុយ

ពុំចង់ឱ្យ (ខ. 25)—រក្សា

ការបន្ទរនូវចំណងនៃសេចក្តីស្លាប់ផ្តាច់ចំណងនៃសេចក្តីស្លាប់ខាងសាច់ឈាម (ខ.41–42)—ការឈ្នះលើសេចក្តីស្លាប់ តាមរយៈជំណើរវិលត្រឡប់ទៅវិញ

ខាងសាច់ឈាម (ខ. 42)—រូបកាយ, ជីវិតរមែងស្លាប់

ការសាងឡើងវិញ (ខ. 44)—ជំណើរវិលត្រឡប់ទៅវិញ

ហោឱ្យឆ្លើយ (ខ. 44)—ហោឱ្យឆ្លើយ ទទួលរ៉ាប់រងក្នុងការប្រព្រឹត្តខុស

កុំឱ្យពុករលួយបានឡើយ (ខ. 45)—មិនស្លាប់ម្តងទៀតឡើយ

អាលម៉ា 11:5–19—ប្រព័ន្ធរូបិយវត្ថុរបស់សាសន៍នីហ្វៃ

តារាងខាងក្រោមនេះ នឹងជួយអ្នកឱ្យយល់កាន់តែច្បាស់ពីរឿង អំពីប្រព័ន្ធរូបិយវត្ថុរបស់សាសន៍នីហ្វៃ នៅអំឡុងពេល នៃរដ្ឋាភិបាល នៃពួកចៅក្រម។ សំគាល់ពី តម្លៃជាប្រចាំរបស់ចៅក្រមម្នាក់ នៅពេលនោះគឺ មានតម្លៃស្មើគ្នានឹងមាសមួយ សិរីណាញ (សូមមើល អាលម៉ា 11:3)។

តម្លៃ និងរង្វាល់ទាំងឡាយរបស់សាសន៍នីហ្វៃ		
កាក់ក្រាក់ = កាក់មាស = តម្លៃជាគ្រាប់ធញ្ញជាតិ		
លេអា	**ក្នាន**	**រង្វាល់ 1/8**
សិបលុម	**ក្នាន**	**រង្វាល់1/4**
សិបឡុន	**ក្នាន**	**រង្វាល់1/2**
សិរីណាញ	**សិរីនុម**	**1 រង្វាល់**
អាន់ទីអូន	**ក្នាន**	**រង្វាល់1 1/2**
អាំណូរ	**សិរីអុន**	**2 រង្វាល់**
អែសរ៉ុម	**ស៊ីម**	**4 រង្វាល់**
អុនតៃ	**លិមណា**	**7 រង្វាល់**

អាលម៉ា 11:38–39—តើព្រះយេស៊ូវគ្រីស្ទគឺជា "ព្រះវរបិតាដ៏នៅអស់កល្បជានិច្ច" តាមរបៀបណា?

សូមមើល ផ្នែកនៃ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់ម៉ូសាយ 15:1–7 (ទំព័រ 87)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សា អាលម៉ា 11។

ក ចូរធ្វើគណិតសាស្ត្រ

សូមអានអាលម៉ា 11:1–19 រួចហើយដោះស្រាយចំណោទ នៃគណិតសាស្ត្រដូចខាងក្រោមនេះ:

1. តើត្រាក់ឈ្នួលជាប្រចាំថ្ងៃ របស់ពួកចៅក្រមសាសន៍នីហ្វៃម្នាក់ អាចទិញគ្រាប់ធញ្ញជាតិបានប៉ុន្មានរង្វាល់? (សូមមើល ខ. 3, 7)។
2. តើថ្លៃឈ្នួលប៉ុន្មានថ្ងៃ ទើបមានតម្លៃស្មើនឹងត្រាក់មួយអុនតៃ? (សូមមើល ខ. 11–13)។
3. តើថ្លៃឈ្នួលប៉ុន្មានថ្ងៃ ដែលស៊ីអែសរ៉ុមបានស្នើឱ្យទៅអាមូលេក បើសិនជាគាត់ព្រមបដិសេធទីបន្ទាល់របស់គាត់? (សូមមើល ខ. 22)
4. តាមអ្នកស្មាន តើចំនួនលុយដែលជាសំណូករបស់ស៊ីអែសរ៉ុម សំរាប់សព្វថ្ងៃនេះមានតំលៃប៉ុន្មាន?
5. តើអ្នកគិតថា ហេតុអ្វីបានជា ពតិមានអំពីប្រព័ន្ធលុយរបស់ពួកសាសន៍នីហ្វៃមានសារៈសំខាន់?

ខ ខគម្ពីរដែលជួយអ្នកផ្សព្វផ្សាយសាសនា

អ្នកផ្សាយសាសនាទាំងឡាយ ត្រូវបានសួរសំណួរដដែរច្រើន។ ចូរសរសេរ ខ ណាមួយមកពីអាលម៉ា 11:36–46 ដែលអ្នកនឹងប្រើ ដើម្បីឆ្លើយសំណួរនីមួយៗដូចខាងក្រោមនេះ:

1. តើខ្ញុំនឹងមានទ្រង់ទ្រាយដូចម្តេច ពេលខ្ញុំរស់ឡើងវិញ?

2. តើមនុស្សប៉ុន្មានទាក់ ដែលរស់នៅលើផែនដីនេះនឹងបានរស់ឡើងវិញ?

3. តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីចូលទៅក្នុងស្ថានសួគ៌?

4. បន្ទាប់ពីខ្ញុំបានរស់ឡើងវិញ តើខ្ញុំនឹងស្លាប់ម្តងទៀតទេ?

អាលម៉ា 12

អាលម៉ាបង្រៀនអំពីផែនការសង្គ្រោះ

អ្នកអាចមានឱកាសយ៉ាងច្រើន នៅក្នុងជីវិតរបស់អ្នក ដើម្បីចែកចាយជំណឹងល្អជាមួយអ្នកដទៃ និងបង្រៀនដូនទាំងឡាយណា ដែលមិនមែនជាសមាជិកនៃសាសនាចក្រ។ អាលម៉ា 11 គឺជា បញ្ជីប្រវត្តិនៃបទពិសោធន៍របស់អាម៉ូលេក ជាមួយ សីរ៉ែអេសរ៉ុម។ អាលម៉ា 12 គឺជា បញ្ជីប្រវត្តិនៃការបង្រៀនរបស់អាលម៉ាទៅសីរ៉ែអេសរ៉ុម និងប្រជាជន នៅជុំវិញនោះ។ នៅពេលអ្នកអានជំពូកទី 12 ចូរគិតអំពីរបៀប ដែលអ្នកផ្សព្វផ្សាយសាសនាទាំងឡាយសព្វថ្ងៃនេះ អាចប្រើការបង្រៀន ឬក៏គោលលទ្ធិទាំងនេះ នៅក្នុងការពិភាក្សារបស់ពួកគេ។



សីរ៉ែអេសរ៉ុម

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 12

ការដឹង (ខ. 1)—ការចេះដឹង ការទឹកឃើញឡើងវិញ

បាននិយាយដូច្នេះថា (ខ. 2)—បាននិយាយដោយរបៀបនេះ

ដ៏ល្អិត ភាពល្អិតល្អន់ (ខ. 4)—ផ្លាតវាងវៃ ប៉ិនប្រសប់

បន្ទោសបង្អាប់ (ខ. 4)—រិះគន់ ដេប្រមាថ

អន្ទាក់ (ខ. 6)—អង្គប់

បានប្រទានឱ្យ (ខ. 9)—ដាក់

ព្រាប់ (ខ.9)—ផ្តល់ឱ្យ

ការយកចិត្តទុកដាក់ និងការព្យាយាម (ខ. 9)—ការគោរពប្រតិបត្តិ និងសេចក្តីស្មោះស្ម័គ្រ

មានសេចក្តីរីករាយបើសិនជា (ខ. 14)—ព្រាថ្នា សុខចិត្ត

ចេរូចីន (ខ. 21)—របៀបរស់នៅមួយប្រភេទរបស់ទេវតា

លុបចោល (ខ. 23)—ឥតប្រយោជន៍

ស្ថានភាពពិសោធន៍ ស្ថានភាពរៀបចំ (ខ. 24, 26)—ពេលនៃការសាកល្បង

ចាប់តាំងពីកំណើតលោកិយមក (ខ. 25)—នៅក្នុងជីវិតមុនឆាកជីវិតនេះ

ការអភ័យទោស (ខ. 34)—ការអត់ឱនបាប

ធ្វើឱ្យខ្លាល់ ការធ្វើឱ្យខ្លាល់ ខ្លាល់ (ខ. 36–37)—ផ្តល់នូវហេតុផលមួយ ធ្វើឱ្យមនុស្សម្នាក់ទៀតខឹង "ធ្វើឱ្យខ្លាល់ដាលើក ជំពូង" អាចសំដៅទៅលើការធ្លាក់នៃមនុស្សលោក ឬក៏នៅពេល ដែលកូនចៅនៃអ៊ីស្រាអែលបានរអ៊ូរទាំ ហើយបានជ្រើសរើសសេចក្តីទុច្ចរិត បន្ទាប់ពីព្រះអម្ចាស់ បានរំដោះចេញពីស្រុកអេស៊ីព្ទ។

អាលម៉ា 12:9–10—តើខ្ញុំអាច "ដឹងនូវអាថ៌កំបាំងទាំងឡាយនៃព្រះ" បានយ៉ាងដូចម្តេច?

ការបើកសំដែងសម័យថ្មី បានអះអាងថា យើងរីកចំរើនមួយដំហានម្តងៗ។ យើងទទួលបានពន្លឺ និងសេចក្តីពិត កាន់តែច្រើន ពេល យើងរក្សាព្រះបញ្ញត្តិទាំងឡាយ ហើយរស់នៅដោយពិតចំពោះពន្លឺ និងសេចក្តីពិត ដែលយើងមានរួចជាស្រេចនោះ។ (សូមមើល គ និង ស 84:44–47, 93:20, 27–28។)

អាលម៉ា 12:16–18, 32—តើសេចក្តីស្លាប់ទីពីរជាអ្វី?

អែលឌើរ ប៊ិច ឃេ. ផាកគឺ សមាជិកនៃ ក្រុមសាវក 12 ទាក់ បានពន្យល់ថាៈ ដង្វាយធួន មានសារៈសំខាន់យ៉ាងខ្លាំង ចំពោះមនុស្ស ដើម្បីសំអាតពួកគេ ពីអំពើបាប ហើយឈ្នះលើសេចក្តីស្លាប់ទីពីរ ដែលជាសេចក្តីស្លាប់ខាងវិញ្ញាណ ដែលជាការ បែកចេញពីព្រះវរបិតារបស់យើងនៅស្ថានសួគ៌។ ត្បិតព្រះគម្ពីរច្រាប់យើង ច្រាំពីរដងថា "គ្មានអ្វី ដែលមិនស្អាតអាចចូល ទៅក្នុងវត្តមាននៃព្រះបានឡើយ" (នៅក្នុង Conference Report, ខែមេសា ឆ្នាំ 1988, 82 ឬ *Ensign,* ខែឧសភា ឆ្នាំ1988, 70 សូមមើលផងដែរ នៅលេខ 5 នៅក្នុងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" អាលម៉ា 5:9, ទំព័រ (104)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរខាងក្រោមនេះ (ក–ត)នៅពេលអ្នកសិក្សាអាលម៉ា 12។

ក កំណត់ន័យ នៃពាក្យមួយ

1. អានអាលម៉ា 12:6 រួចហើយកត់ត្រាទុក ឃ្លាចំនួនបី ដែលសំគាល់នូវ គោលចំណងរបស់សាតាំង។

2. ចំពោះឃ្លានីមួយៗ ដែលអ្នកបានកត់ត្រាទុក ចូរសរសេរវិធីមួយ ដែលអារក្សសាតាំងប្រើ ដើម្បីអូសទាញយុវវ័យនៅ បច្ចុប្បន្ននេះ។

3. សិក្សាអាលម៉ា 12:9–11 រួចហើយសរសេរនូវន័យមន័យសំអាប់ពាក្យ "ច្រវាក់នៃស្ថានឥរក។"

ខ សរសេរសន្ទរកថាមួយ

ចូរនឹកស្រមៃថា អ្នកត្រូវបានចាត់ឱ្យនិយាយ នៅក្នុងការប្រជុំធ្វើពិធីប្រសិទ្ធិពរនំប៉័ង និងទឹក ក្នុងប្រធានបទស្តីអំពី "សេចក្តីជំនុំជំរះចុង ក្រោយ"។ សរសេរសន្ទរកថាខ្លីមួយ ដោយប្រើ អាលម៉ា 12:12–18 ជាពាក្យមានយោង។ ប្រើការដកស្រង់ពាក្យសំដី យ៉ាងហោចណាស់ចំនួនពីរ ចេញមកពីខទាំងនោះ។

គ ការធ្លាក់

អាន អាលម៉ា 12:19–27 រួចហើយឆ្លើយសំនួរខាងក្រោមនេះ៖

1. តើអ្វីបានកើតឡើង នៅពេលដែលអ័ដាមបានទទួលទានផ្លែឈើហាមឃាត់?

2. តើអ្វីទីងកើតឡើង បើអ័ដាមបានទទួលទានដើមឈើនៃជីវិត បន្ទាប់ពីគាត់បានទទួលទានផ្លែឈើហាមឃាត់? (សូមមើល ខ 23)។

3. តើហេតុអ្វី "ស្ថានភាពពិសោធន៍" ចាំបាច់ត្រូវមាន មុនពេលការរស់ឡើងវិញ និងសេចក្តីជំនុំជំរះ? (សូមមើលអាលម៉ា 42:4–5)។

អាលម៉ា 13

បព្វជិតភាពនៃព្រះ

បព្វជិតភាពគឺជា សិទ្ធិអំណាចនៃព្រះ ដែលបានប្រគល់ដល់បុរស ដើម្បីបម្រើសំរាប់សេចក្តីសង្ត្រោះ ក្នុនចៅរបស់ទ្រង់។ ព្រះវរបិតាសួគិ បានជ្រើសរើសបុរសនៅក្នុងជីវិតមុនឆាកជីវិតនេះ ជាមនុស្សដែលទ្រង់បានដឹងថា នឹងអាចជួយទ្រង់នៅក្នុងជីវិត មរណបម្បាណនេះ។ តើទ្រង់អាចដឹងថា គួរជ្រើសរើសអ្នកណា បានយ៉ាងដូចម្តេច? អាលម៉ា បានពន្យល់អំពីរឿងនេះ ព្រម ទាំងជួយយើងឱ្យយល់ អំពីការទទួលខុសត្រូវដ៏ធំ ដែលមានចំពោះអ្នកទាំងឡាយណា ដែលទទួលបព្វជិតភាព។ បន្ទាប់ពីអាន អាលម៉ា 13 អ្នកនឹងអាចពន្យល់បានថា ហេតុអ្វីបានជាបព្វជិតភាព មានសារៈសំខាន់ហើយតើព្រះអម្ចាស់សង្ឃឹមអ្វីពីអ្នក ដែលកាន់អំណាចបព្វជិតភាព។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 13

រំពឹកអ្នកទៀតឱ្យនឹកឃើញដល់ (ខ. 1)—សុំឱ្យអ្នកគិតតាំងពីដំបូង

បុព្វវិជ្ជា នៃព្រះ បុព្វវិជ្ជារបស់ទ្រង់លើការណ៍ទាំងអស់ (ខ. 3, 7)—សមត្ថភាពនៃព្រះ ដើម្បីដឹងថ្ងៃអនាគតជាមុន។

បានញែកជាបរិសុទ្ធ (ខ. 11)—ធ្វើឱ្យស្អាតពីអំពើបាប

សំលៀកបំពាក់បានលាងឱ្យស (ខ. 11)—អំពើបាបត្រូវបានអភ័យទោស

ស្អប់ខ្ពើម (ខ. 12)—ស្អប់

ផលដែលសម (ខ. 13)—កិច្ចការល្អដែលបំពេញ តាមសេចក្តីត្រូវការ

គំរូ (ខ. 16)—សញ្ញា ភាពស្រដៀងគ្នា

ក្រាស់ក្រែល (ខ. 17)—ក្លាយជា

ធ្វើខុសន័យ (ខ. 20)—បង្ខែងបង្ខែរអត្ថន័យ

អាលម៉ា 13ៈ 1–18—"របៀបដ៏បរិសុទ្ធនៃព្រះ"

ឃ្លាថា "របៀបដ៏បរិសុទ្ធនៃព្រះ" ឬក៏ទំរង់របស់ឃ្លានេះ បានបង្ហាញជារឿយៗនៅក្នុងអាលម៉ា 13។ វាសំដៅទៅលើ បព្វជិតភាពមុិលគីស្សាដែក។ កាលពីមុនជំនាន់របស់ លោកមុិលគីស្សាដែក បព្វជិតភាពនោះ បានហៅថា *បព្វជិតភាពបរិសុទ្ធ បន្ទាប់ពីរបៀបនៃព្រះរាជបុត្រានៃព្រះ។*

"ប៉ុន្តែមកពីការគោរពកោតក្រែង ឬភក្តីភាពនៃព្រះនាមនៃព្រះដ៏ខ្ពស់បំផុត គឺដើម្បីកុំឱ្យប្រើព្រះនាមរបស់ព្រះអង្គជាញឹកញាប់ពេក ទើបសាសនាចក្រពីសម័យបូរាណ បានហៅបព្វជិតភាព តាមលោកមុិលគីស្សាដែក ឬបព្វជិតភាពមុិគីស្សាដែក" (ត និង ស 107ៈ3–4)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ ឬ គ នៅពេលអ្នកសិក្សាអាលម៉ា 13។

ក ពន្យល់ពីអត្ថន័យរបស់វា

នៅពេលអ្នកអានអាលម៉ា 13ៈ1–6 ចូរធ្វើការសង្ខេបសារលិខិត ដោយពាក្យរបស់អ្នក។

ខ ចូរសម្ភាសអ្នកកាន់បព្វជិតភាព

ចូរអានអាលម៉ា 13ៈ7–13 ជាមួយនរណាម្នាក់ ដែលកាន់បព្វជិតភាពមុិលគីស្សាដែក។ ចូរសួរសំនួរ រួចហើយសរសេរនូវ ការឆ្លើយតបរបស់គាត់ ដូចខាងក្រោមនេះៈ

1. នៅក្នុងគំនិតរបស់អ្នក តើគោលការណ៍សំខាន់បំផុតអ្វីខ្លះ ដែលបានបង្រៀននៅក្នុងខទាំងអស់នេះ?
2. តើហេតុអ្វីបានជាអ្នកគិតថា ការកាន់អំណាចបព្វជិតភាពមុិលគីស្សាដែក គឺជាឯកសិទ្ធិមួយ?
3. តើអ្នកគិតថា នឹងទៅជាយ៉ាងណាដែរ បើអ្នកកាន់បព្វជិតភាពត្រប់រូបដើរតាមការពិពណិនាទៅក្នុងខ 12?

ត ចូរណែនាំពីអ្នកដឹកនាំក្នុងសាសនាចក្រម្នាក់

អ្នកត្រូវបានស្នើរសុំឱ្យធ្វើការណែនាំ លោកមុិលគីស្សាដែក ដែលជាអ្នកឡើងនិយាយក្នុងការប្រជុំពិសេស។ ចូរប្រើ អាលម៉ា 13ៈ14–19 ដើម្បីប្រមូលយកនូវហេតុការណ៍ខ្លះព្ធ មកប្រើនៅក្នុងការណែនាំរបស់អ្នក។ ចូរសរសេរនូវអ្វី ដែលអ្នកនឹងនិយាយ ដើម្បីធ្វើការណែនាំពីបុរសដ៏អស្ចារ្យម្នាក់នេះ។

អាលម៉ា 14

សារលិខិតនៃជំណឹងល្អធ្វើឱ្យពួកទុច្ចរិតខឹង

ជារឿយៗត្រូវការភាពក្លាហាន ដើម្បីធ្វើតាមការបង្រៀននៃអ្នកបំរើរបស់ព្រះអម្ចាស់។ ការប្រឈមមុខនឹងឧបសគ្គទាំងឡាយ របស់មនុស្សរាបសារសូមមើលក្នុងអាលម៉ា 14 យ៉ាងណាក៏ដោយ គឺជាការណ៍ដ៏អស្ចារ្យយ៉ាងពិត។ អ្នកអាចមានការភ្ញាក់ផ្អើល ពីទំហំយ៉ាងច្រើនរបស់អ្នកផ្លាស់សាសនាថ្មីនិងមនុស្សសុចរិតដទៃទៀត ត្រូវតែធ្វើការស៊ូទ្រាំ នៅក្នុងសេចក្តីជំនឿរបស់ពួកគេ។ ពិសេសចូរធ្វើការកត់សំគាល់ជាថា អាមូលេកមានអារម្មណ៍យ៉ាងណាអំពីអ្វី ដែលគាត់យើញ ព្រមទាំងធ្វើការកត់សំគាល់ ជាពិសេស នៃកម្លាំងនិងប្រាជ្ញារបស់អាលម៉ាផងដែរ។ លើសពីនេះទៅទៀត ចូរព្យាយាមនឹកគិតពីអ្វីដែលពួកទុច្ចរិតគិត នៅពេលពួកគេ យើញពីអ្វីព្ធ ដែលបានកើតឡើងជាយថាហេតុចំពោះអាលម៉ា និងអាមូលេក។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 14

បានបន្ទាបបន្ទោក (ខ. 2, 5, 7)—បានរិះគន់ បានជេរប្រមាថ

ដោយសម្ងាត់ (ខ. 3)—ភាពសម្ងាត់ ដោយស្ងាត់

កើតទុក្ខ (ខ. 6)—ធ្វើទារុណកម្ម ធ្វើឱ្យឈឺចាប់

សម្លាប់ (ខ. 9)—ការរងទុក្ខ និងការសម្លាប់ ដោយសារតែសេចក្តីជំនឿ ឬការជឿរបស់អ្នកណាម្នាក់

ត្រូវភ្លើងឆេះ ត្រូវភ្លើងឆេះនោះ (ខ. 9–10, 14)—ត្រូវបំផ្លាញ ត្រូវឆេះរហូតដល់ស្លាប់

រារាំងមិនឱ្យ (ខ. 11)—បានបង្ខំ បានបញ្ជាទះ (ខ. 14–15, 17, 20, 24–25)—វាយ

ស្ពាន់ធ័រ (ខ. 14)—ការដុតស្ពាន់ធ័រ ជានិមិត្តរូបនៃការឈឺចិត្ត និងទារុណកម្ម ដ៏ឈឺចាប់របស់ពួកទុច្ចរិត

បានប្រេះជាពីរ (ខ. 27)—ហែកជាពីរ ចំណែក

ដើរត្រង់ (ខ. 28)—ដោយភ្លាមៗ

អាលម៉ា 14:8–11–តើហេតុអ្វី ព្រះអម្ចាស់ទុកឱ្យពួកសុចរិតរងទុក្ខ?

អារម្មណ៍ដូចជាអាមូលេក នៅពេលគាត់បានឃើញការរងទុក្ខរបស់មនុស្សសុចរិត និងរាបសារ។ យ៉ាងណាក៏ដោយ អាលម៉ាបានជួយគាត់ (និងពួកយើង) ឱ្យយល់ថា ព្រះវរបិតាស្ថគិមានការនិមិត្តឃើញយ៉ាងមហិមាជាងអ្វីៗ ដែលមនុស្សប្រុសស្រី នៃមតះភាពនេះបានឃើញដែលវាហាក់បីដូចជាសោកនាដកម្មមួយនោះ។ អែលឌើរ ស្តែនស៊ើរ ដបុល យូ ឃិមបឹល ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានពន្យល់ថាះ

"យើងឃើញថា មានមនុស្សជាច្រើនបានរិះគន់ នៅពេលដែលមនុស្សសុចរិតម្នាក់ត្រូវបានសម្លាប់ ឱពុកម្តាយវ័យក្មេង ត្រូវបាន យកចេញពីត្រួសារមួយ ឬនៅពេលមានសេចក្តីស្លាប់មកគំរាមគំហែង។ មនុស្សខ្លះបែរជាមានការឈឺចាប់ នៅពេលដែលការអធិស្ឋានដដែលឲជាញឹកញាប់តែហាក់ដូចជាគ្មានចម្លើយ។ មនុស្សខ្លះបាត់បង់នូវសេចក្តីជំនឿ ហើយបែរជាមានភាពជូរចត់ នៅពេលដែលឃើញការគ្រប់គ្រងយ៉ាងមាំទាំ ពីមនុស្សពិសិដ្ឋត្រូវបានគេមិនយកចិត្តទុកដាក់ . . . ប៉ុន្តែបើសិនជាអ្នកជំងឺទាំងអស់ បានជាសះស្បើយ បើសិនជាពួកសុចរិតត្រូវបានការពារ ហើយពួកទុច្ចរិតត្រូវបំផ្លាញចោល នោះកម្មវិធីទាំងមូលរបស់ព្រះវរបិតា នឹងទុកជាមោឃះ ហើយមូលដ្ឋានគោលការណ៍នៃដំណឹងល្អ សេរីភាពក្នុងការជ្រើសរើសនឹងត្រូវបញ្ចប់ . . .

ពួកយើងភាគច្រើន មាន"គួរតែរាល់ការអធិដ្ឋានទទួលបានចម្លើយភ្លាមៗ ស្របតាមបំណងប្រាថ្នាដ៏អាត្មានិយម និងការយល់ដឹងមានព្រំដែនរបស់យើង ឬ មានការរងទុក្ខ សេចក្តីទុក្ខព្រួយ ការខកចិត្ត ឬសេចក្តីស្លាប់តែបន្តិចបន្តួច ឬគ្មានតែម្តង ហើយបើសិនជាមិនមានការទាំងនេះទេ ក៏នឹងគ្មានវត្តមាននៃការសប្បាយ ភាពជោគជ័យ ដំណើររស់ឡើងវិញ ជីវិតអស់កល្បជានិច្ច និងភាពជាព្រះផងដែរ" ("Tragedy or Destiny," *Improvement Era,* ខែ មិនា ឆ្នាំ 1996, 180, 210, សូមមើលអាលម៉ា 60:13, គ និង ស 98:13)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សាអាលម៉ា 14។

ក ចូរពន្យល់អំពីគោលការណ៍

1. ចូរសិក្សាអាលម៉ា 14:8–11, 60:13 ហើយចូរដកស្រង់ពាក្យចេញពីអែលឌើរ ឃឺមបឹល មាននៅក្នុងវគ្គ "ការយល់ដឹងអំពី ព្រះគម្ពីរ" អាលម៉ា 14:8–11 ហើយបន្ទាប់មកពន្យល់ថា ហេតុអ្វីបានជាអ្នកមានជំនឿទៅលើអាលម៉ា និងអាមូលេក ដែល មិនប្រើអំណាចបព្វជិតភាព ដើម្បីសង្គ្រោះមនុស្សសុចរិត ដែលនឹងត្រូវសំលាប់។ ចូរធ្វើការកត់សំគាល់ជាពិសេស អំពីការណែ នាំរបស់ព្រះវិញ្ញាណ ដែលអាលម៉ាធ្វើតាម។
2. តើមានអ្វីឆ្លុះបញ្ចាំងពីប្រសាសន៍របស់អែលឌើរ ឃឺមបឹល បានពន្យល់ពីមូលហេតុ ដែលអាលម៉ា និងអាមូលេក ត្រូវតែចាំយ៉ាងយូរ មុនពេលពួកគេទទួលអំណាច ដើម្បីរំដោះខ្លួនពួកគេពីក្នុងគុកឬទេ? (សូមមើលអាលម៉ា 14:26–29)។

ខ សំនួរមិនបានឆ្លើយតប

បន្ទាប់ពីការបង្ខំឱ្យអាលម៉ា និងអាមូលេក មើលគេដុតអ្នកមានជំនឿដោយស្មោះត្រង់នោះហើយ ពួកចៅក្រមទុច្ចរិត នៃដែនដី អាំម៉ូណៃហា បានចោទសួរសំនួរជាច្រើនទៅពួកគេ មានសំនួរចំនួនប្រាំពីរ ដែលបានកត់ទុកក្នុងបញ្ជី នៅក្នុងអាលម៉ា 14:14–21។

1. ចូរស្វែងរកសំនួរទាំងនោះ ហើយសរសេរសំនួរនៅក្នុងស្បៀវភៅសរសេរ រួចសរសេរចម្លើយ ដែលអ្នកគិតថា អាលម៉ា និងអាមូលេក បានផ្តល់ជាគំនិតថា ចម្លើយទាំងនោះត្រឹមត្រូវ។
2. ចូរំលឹក អាលម៉ា 14:2–5 ឡើងវិញ ហើយបន្ទាប់មកអាន នីហ្ចៃទី 3 14:6 និងម៉ាថាយ 27:11–14 ហើយពន្យល់ពីមូល ហេតុអ្វី ដែលអ្នកគិតថា ពួកគេបដិសេធ ក្នុងការឆ្លើយសំនួររបស់ពួកចៅក្រមទុច្ចរិត។
3. តើវាគឺជាការចំបាច់ឬ ដើម្បីឆ្លើយទៅមនុស្សគ្រប់រូប ដែលចំអកដល់អ្នក ដោយមកពីសេចក្តីជំនឿរបស់អ្នក ឬមនុស្សដែល ទិទៀនកិច្ចការរបស់ព្រះអម្ចាស់ឬទេ? ហេតុអ្វីក៏ឆ្លើយតប ឬហេតុអ្វីមិនឆ្លើយតប?

© 1991 Gary L. Kapp

អាលម៉ា 15

បេសកកម្មទៅក្នុងដែនដីសៃដុម

នៅពេលអ្នកបានរៀនទៅក្នុងអាលម៉ា 14 មនុស្សទុច្ចរិតនៃដែនដីអាំម៉ូណៃហា រួមទាំងសិ៊ីអែសរ៉ុមបានបណ្តេញប្រជាជនខ្លះៗ ដែលជឿ លើសាររបស់អាលម៉ា

ហើយមនុស្សផ្សេងទៀតត្រូវឆេះក្នុងភ្លើង។ អាលម៉ា 15 ប្រាប់យើងអំពីកន្លែងដែលអ្នកជឿទាំង នោះបានចាកចេញទៅ ហើយពីអ្វី ដែលកើតឡើងចំពោះសិរីអែសរ៉ុម និងអាម៉ូលេក និងអ្នកដែលបាត់បង់អ្វីៗពួកគេមានទៅក្នុងដែនដីអាំម៉ូណៃហានោះ។ ចូរកត់សំគាល់ផងដែរអំពីអ្វីដែលជំពូកនេះបង្ហាញយើងអំពីឥទ្ធិពលនៃការជឿកំហុស និងអំណាច នៃដង្វាយធួន។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 15

សេចក្តីទុក្ខដ៏ធំ (ខ. 3)—ការរងទុក្ខ

កើតទុក្ខ (ខ. 3)—ទារុណកម្ម ឈឺចាប់

សូមអង្វរខ្សឹ (ខ. 5)—អង្វរ សុំ

ចោទ (ខ.15)—ផ្តល់នូវការជឿទុកចិត្តចំពោះ

សង្កេតឃើញ, បានឈ្នះ (ខ. 17)—បញ្ឈប់ ឈប់

ទីបរិសុទ្ធទាំងឡាយ (ខ. 17)—កន្លែងថ្វាយបង្គំ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយ ទៅតាមសកម្មភាព (ក–គ) នៅពេលអ្នកសិក្សាអាលម៉ា 15។

ក តើគាត់នឹងនិយាយអ្វីខ្លះ?

ចូររំលឹកនូវអាលម៉ា 15:1–4 ឡើងវិញ ហើយបន្ទាប់មកសរសេរដាសារលិខិតមួយ សំដែងចេញពីអ្វីដែលអ្នកគិតថា សិរីអែសរ៉ុម ចង់និយាយទៅកាន់អាលម៉ា និងអាម៉ូលេក។

ខ សរសេរចូលទៅក្នុងស្បៃវគៅកំណត់ហេតុ

ចូរសរសេរនៅក្នុងស្បៃវគៅកំណត់ហេតុ ប្រសិនបើអ្នកជា សិរីអែសរ៉ុម ឬអាលម៉ា ដែលកំពុងតែប្រាប់អំពីបទពិសោធ មាន ពិពណ៌នានៅក្នុងអាលម៉ា 15:5–12។

គ ផ្តល់ឧទាហរណ៍មួយក្នុងសម័យបច្ចុប្បន្ន

1. ចេញពីអាលម៉ា 15:16 ចូរធ្វើជាបញ្ជីអំពីអ្វី ដែលអាម៉ូលេកធ្វើការលះបង់ ដើម្បីបំរើព្រះអម្ចាស់។
2. ចូរសរសេរដា ការពិពណ៌នាមួយ អំពីនរណាម្នាក់ ដែលអ្នកស្គាល់ទីងមានឆន្ទៈ ធ្វើការលះបង់ទៅបំរើបេសកកម្ម ដូចដា អាម៉ូលេក។

អាលម៉ាព្រមានដល់មនុស្សទុច្ចរិតនៃដែនដីអាំម៉ូណៃហាថា ពួកគេនឹងត្រូវបំផ្លាញចោល បើពួកគេពុំប្រែចិត្តទេ (សូមមើល អាលម៉ា 8:16–17, 9:4)។ អាលម៉ា 16 ប្រាប់ពីរបៀបដែលការព្យាករណ៍ត្រូវបានសំរេច។ ដោយការនឹកស្មានមិនដល់អ្នកដែលនៅសល់ ទាំងប៉ុន្មាននៅលើដែនដី មានការសប្បាយរីករាយយ៉ាងក្រៃលែង ចំពោះពរជ័យពីព្រះអម្ចាស់ នៅពេលព្រះវិហាររីកដុះដាល នៅក្រោមការបង្រៀនរបស់អាលម៉ា និងថ្នាក់ដឹកនាំ។ នៅពេលអ្នកអានជំពូកនេះ ចូរគិតអំពីអ្វីដែលមរមនចង់ឱ្យពួកយើងរៀនអំពីភាពផ្ទុយគ្នានៃរឿងរបស់ដែនដីអាំម៉ូណៃហា ជាមួយនឹងការពិពណ៌នានៃពរជ័យ ដែលបានមកពីពួកសុចរិត។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 16

ឱ្យបានត្រប់ត្រាន់ (ខ. 3)—ដំឡូម

សាបសូន្យ (ខ.10–11)—គ្មានមនុស្សរស់នៅ

សាកសពទាំងឡាយត្រូវហែកស៊ីអស់ (ខ. 10)—ហែកសាកសព

សាលាប្រជុំទាំងឡាយ (ខ. 13)—សាសនាចក្រ កន្លែងថ្វាយបង្គំ

ការផ្សាំ គឺដាការដាក់មែកឈើមួយមែក ជាមួយនឹងមែកមួយទៀត។ មែកឈើ គឺដាសញ្ញាមួយដែលយើងបានចូលជាមួយ ព្រះយេស៊ូវគ្រីស្ទ។

បានបំបៅជាប់ទៅនឹងដើមទំពាំងបាយជូរពិត (ខ. 17)—ចូលរួមជាមួយព្រះគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់

ការជណ្តើម (ខ. 18)—ការទាស់ទែង ការឈ្លោះប្រកែក

ការគំនុំ (ខ. 18)—ចង់ឱ្យអ្នកដទៃរងទុក្ខ សួបប់

ការបង្ហាប់ (ខ. 18)—ការរិះគន់ ការដេរប្រមាថ

ការអាសអាភាស (ខ. 18)—សកម្មភាព ដែលមានតណ្ហា

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយក្នុងសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 16។

ក គូសដែនទីមួយ

1. នៅក្នុងស្បៃវគៅសរសេររបស់អ្នក ចូរគូសរូបដែនទីសាមញ្ញមួយ នៃដែនដីនៅក្នុងព្រះគម្ពីរមរមន មានទៅទំព័រ (202)។ ចូរធ្វើជាផ្លាកឈ្មោះដែនទីមួយ ទីងទីកន្លែង ដែលបានបញ្ជាក់រួចហើយទៅក្នុងអាលម៉ា 16:1–8។ បន្ទាប់មកយកសញ្ញាព្រួញ និងការពន្យល់ផ្សេងៗ មកបង្ហាញពីអ្វីដែលបានកើតឡើងនៅក្នុង 1–8។
2. តើមេរៀនអ្វីខ្លះ ដែលអ្នកគិតថា មរមនចង់ឱ្យពួកយើងរៀនមកពីរឿងនេះ?

ខ ទឹកគិតថា ខ្លួនអ្នកនៅក្នុងរឿងនេះ

ចូររំលឹកឡើងវិញ អំពីស្ថានភាពជីវិត នៅក្នុងដែនដីសារ៉ាហិមឡា បន្ទាប់ពី "ការតាំងសាសនាចក្រកើតឡើងទូទៅទាំងដែនដី" (អាលម៉ា 16:15, សូមមើល ខ. 15–21)។ ចូរពិពណ៌នាអំពីវត្ថុពីរយ៉ាង ដែលអ្នកចូលចិត្តជាទីបំផុតអំពីការរស់នៅ ក្នុង កន្លែងនោះ។

ក ពិពណ៌នាអំពីផលប្រយោជន៍

ចូរស្រាវជ្រាវនៅក្នុងអាលម៉ា 16 ហើយពិពណ៌នា យ៉ាងហោចណាស់ផលប្រយោជន៍ចំ ដែលនឹងមាននៅក្នុងសមាគមរបស់អ្នក បើសិនជាម្នាក់ៗរស់នៅក្នុងជំណឹងល្អ។

អាំម៉ូន អើរ៉ុន អ៊ូមណើរ ហិមណៃ

នៅក្នុងម៉ូសាយ 28 បុត្រាទាំងបួននៃស្តេចម៉ូសាយ ក្នុងចំណោមពួកគេសុទ្ធតែមានបំណងព្រាថ្នាទៅបំរើបេសកកម្ម ច្រើនជាងធ្វើដា ស្តេច។ នៅអាលម៉ា 17 គឺជាការចាប់ផ្តើមនូវជំណើររឿងនៃបេសកកម្មរបស់ពួកគេទៅពួកលេមិន ជាការបង្ហាញពីគំរូដ៏ អស្ចារ្យមួយ ពីអត្ថន័យក្នុងការធ្វើជាអ្នកផ្សព្វផ្សាយសាសនា។ ពេលអ្នកអាន នៅក្នុងជំពូកបន្តបន្ទាប់ទៀតនោះ សូមយកចិត្ត ទុកដាក់ជាពិសេស ទៅលើអ្វី ដែលអ្នកនឹងរៀន អំពីការរៀបចំសកម្មភាព និងការបង្រៀននៃអ្នកផ្សព្វផ្សាយសាសនា ដែល មានជោគជ័យ។ ចូរចងចាំថា អ្នកមិនចាំបាច់ធ្វើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងម្នាក់ ដើម្បីចាប់ផ្តើមអនុវត្តនូវអ្វី ដែលអ្នក បានរៀននោះទេ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 17

មុតមាំ (ខ. 2)—ជុះជាល

ការនឿយហត់ (ខ. 5)—ភាពនឿយហត់

សេចក្តីអាក្រក់ (ខ. 9)—ការអាក្រក់

ខ្ជិលច្រអូស (ខ. 15)—ខ្ជិល

តាមតំណែង (ខ. 18)—ការចាត់តាំង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សា អាលម៉ា 17។

ភ បង្ហាញពីគំរូ

1. ចូរបង្កើតតារាងសាមញ្ញមួយ ដូចតារាងមួយនៅខាងក្រោម នៅក្នុងស្បៀវភៅសរសេររបស់អ្នក។ បន្ទាប់មកធ្វើការស្រាវជ្រាវ អាលម៉ា 17:2–3 ហើយធ្វើដាបញ្ជី ដាក់នៅក្នុងប្រអប់អំពីគំរូនៃការធ្វើតាមរបស់បុត្រាម៉ូសាយ ដើម្បីឱ្យមានអំណាចខាង វិញ្ញាណ។

តើពួកគេធ្វើអ្វី ដើម្បីរៀបចំ	→	តើអ្វីជាលទ្ធផល

2. ដាពិសេសតើពរជ័យខាងវិញ្ញាណមួយណា ដែលអ្នកចង់ទទួលនោះ? តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីទទួលពរជ័យនោះ?

ខ អនុវត្តព្រះគម្ពីរ

សូមពិចារណាអំពីស្ថានភាពខាងក្រោមនេះ៖ អែលខើរ ក្រោន និងអែលខើរ ទិលសុន ជាអ្នកផ្សព្វផ្សាយសាសនាទីមួយ ដែល បានចាត់ឱ្យទៅក្នុងទីក្រុងដាច់ស្រយាលតូចមួយ។ អតិបាលក្រុងម្នាក់បានជឿថា អែលខើរទាំងពីរនេះមកដល់ក៏បានផ្ញើរសារមួយ ទៅថា អ្នកទាំងពីរមិនស្វាគមន៍ឱ្យនៅក្នុងទីក្រុងរបស់គាត់ទេ។ នៅពេលព្រឹកនោះ ក្នុងម៉ោងសិក្សាដំណឹងល្អរបស់ពួកគេ អែលខើរទាំងពីរនាក់នេះបាន អាននៅក្នុងអាលម៉ា 17។ អ្នកទាំងពីរមានអារម្មណ៍ថា ពួកគេគួរតែអនុវត្តនូវអ្វីដែលគេបានរៀនពីគម្ពីរនោះ មកក្នុងស្ថានភាពបច្ចុប្បន្នរបស់ពួកគេ។

1. ចូរសរសេរអំពីទិបញ្ជាប់នៃរឿង រួមមានទាំងពីអ្វី ដែលអ្នកគិត ចំពោះអែលខើរទាំងពីរនាក់នោះ អាចធ្វើដើម្បីអនុវត្ត នូវអ្វី ដែលពួកគេរៀនពី អាលម៉ា 17។ ចូរព្យាយាមដើម្បីបញ្ចូលគោលលទ្ធិនៃកិច្ចការផ្សព្វផ្សាយសាសនាដ៏មានប្រសិទ្ធភាព ឱ្យកាន់តែច្រើនតាមដែលអាចធ្វើទៅបាន។
2. នៅចុងបញ្ចប់នៃរឿងរបស់អ្នក ចូរធ្វើដាបញ្ជីគោលការណ៍ និងខគម្ពីរទាំងឡាយ ដែលពួកគេបានអនុវត្តនៅពេលអ្នក រកឃើញនៅក្នុងគោលការណ៍ទីមួយៗ។

បទពិសោធន៍មួយរបស់អ្នកផ្សព្វផ្សាយសាសនា ដែលមានជោគជ័យ ជារឿយៗពឹងផ្អែកមុនជំពូងបង្អស់លើការណែនាំសារលិខិត នៃដំណឹងល្អនេះ។ តើអ្នកអាចចាប់ផ្តើមបង្រៀនដំណឹងល្អ ទៅដល់ស្តេចដោយរបៀបណា? នៅពេលអ្នកអាន អាលម៉ា 18 សូមរកមើល ឧទាហរណ៍បន្ថែមពីរបៀបបង្រៀនដំណឹងល្អ ដែលប្រកបដោយប្រសិទ្ធភាពចំពោះអ្នកដទៃ— ទាំងការបង្រៀន និងរបៀប ដើម្បីបង្រៀនដំណឹងល្អផងដែរ។

© 1995 Gary L. Kapp

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 18

ប្លន់ (ខ. 7)—ការលួច

ហ៉ាន (ខ. 11)—ក្លាហាន

ទឹកមុខ (ខ.12)—អាការៈ មុខ

យល់គំនិត (ខ. 16)—យល់ ស្គាល់

យល់គំនិត (ខ. 18)—ដឹង

កលោបាយ (ខ. 23)—ដោយល្បិច ដោយយុទ្ធសាស្ត្រ

បានអធិប្បាយប្រាប់ (ខ. 38–40)—បានពន្យល់

ការបាត់បង់រូបទ្រង់ (ខ. 43)—មានអារម្មណ៍សោកសៅ ដោយសារពួកគេគិតថាទ្រង់សុគត

អាលម៉ា 18:36–43—អំណាចនៃគោលការណ៍ដំណឹងល្អ

តើអ្នកចាប់ផ្តើមពីកន្លែងណាទៅ នៅពេលអ្នកមានឱកាសមួយ ដើម្បីបង្រៀនដំណឹងល្អទៅនរណាម្នាក់ ដែលមិនធ្លាប់ដឹងអំពី ព្រះសោះនោះ? ចូរធ្វើការកត់សំគាល់ថា អាំម៉ូនបានចាប់ផ្តើម ដោយការឆ្លើយសំនួររបស់ស្តេចឡាម៉ូណៃ អំពីនិស្សីយនៃព្រះ (សូមមើល អាលម៉ា 18:18–28) ហើយបន្ទាប់មកបង្រៀនទ្រង់អំពីការបង្កបង្កើត (សូមមើលខ 28–36) ការធ្លាក់ រួម ទាំងការប្រព្រឹត្ត ដែលនាំឱ្យមានការធ្លាក់នៃពួកអយ្យកោរបស់ទ្រង់ (សូមមើលខ 36–38) និងដង្វាយធួន ឬ "ផែនការនៃ សេចក្តីប្រោសលោះ" (សូមមើលខ 39)។ ការជ្រើសរើសរបស់អាំម៉ូនគឺថា ត្រូវង្រៀនពីអ្វីដែលត្រូវបង្រៀន បាន បំផុសគំនិត និងមានឥទ្ធិពលយ៉ាងខ្លាំងចំពោះ ស្តេចឡាម៉ូណៃ (សូមមើលខ 42–43)។

អែលឌើរ វ៉ាស្សល អិម. នែលសុន ជាសមាជិកនៃក្រុមសាវកទាំងដប់ពីរនាក់ បានជួយពួកយើងឱ្យយល់ថា ហេតុអ្វីគោលលទ្ធិ ទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំងៈ "គោលលទ្ធិគឺជា ផ្នែកសំខាន់នៃផែនការណ៍ យើងគួរតែព្យាយាម ដើម្បីយល់ពីអត្ថន័យនៃ ដង្វាយធួន។ ដូច្នេះមុនពេលយើងអាចយល់ពីដង្វាយធួន យើងត្រូវតែយល់ពីការធ្លាក់នៃលោកអ័ដាម។ ហើយពីមុនពេល យើង អាចពោរពេញទៅដោយអំណរគុណ ចំពោះការធ្លាក់ចុះនោះ យើងត្រូវយល់ជាមុនពីការបង្កបង្កើត។ ព្រឹត្តការណ៍ទាំងបីនេះ—ការបង្កបង្កើត ការធ្លាក់ និង ដង្វាយធួន—គឺជាសរសរដ៏ខ្ពស់ជាងគេនៃផែនការណ៍របស់ព្រះ ហើយសរសរគោលលទ្ធិទាំងបីនេះ គឺជាគោលលទ្ធិ ដែលជាប់ទាក់ទងគ្នាទៅវិញទៅមក" (នៅក្នុង Conference Report, ខែតុលា ឆ្នាំ 1993, 45, ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1993, 33)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 18។

ក ប្រៀបធៀបព្រះគម្ពីរទៅនឹងឧទាហរណ៍មួយក្នុងពេលចប្ចុប្បន្ន

1. ចូរអានរឿងខាងក្រោមនេះ ដែលបានប្រាប់ដោយ អែលឌើរ រ៉ូបើត អ៊ុ. វែល ជាសមាជិកក្នុងក្រុមចិតសិបនាក់។ តើរឿងនេះ មានលក្ខណៈស្រដៀងគ្នា ទៅនឹងបទពិសោធន៍របស់អាំម៉ូន មានទៅក្នុងអាលម៉ា 17–18 ឬទេ?

"មានអែលឌើរពីរនាក់ បានជួប និងបង្រៀនសាស្ត្រាចារ្យម្នាក់ . . . គាត់មិនបើកចិត្តទទួលយកដំណឹងរបស់ពួកគេសោះ ប៉ុន្តែ បុរសនោះមានជម្ងឺត្រូវទៅមន្ទីរពេទ្យ ដើម្បីធ្វើការវះកាត់។ អំឡុងពេលនៅមន្ទីរពេទ្យ គាត់បានជាសះស្បើយឡើងវិញ គែនៅទីធ្លា ក្រោយផ្ទះស្មៅ និងសួនច្បាររបស់គាត់បែរជាស្ងិតស្រពោន។ អ្នកផ្សព្វផ្សាយសាសនាទាំងពីរនេះ មានការចាប់អារម្មណ៍ ក៏ចំណាយពេលនៅថ្ងៃ សំរាករបស់ខ្លួនមកជំរះស្មៅ គម្រឹមដើមឈើដែលដាំធ្វើជារបង ហើយស្រោចទឹកផ្កាឱ្យបុរសនោះ។

"ប្រពន្ធរបស់បុរសនោះ បានប្រាប់អំពីអ្វី ដែលអ្នកផ្សព្វផ្សាយសាសនាបានធ្វើ។ បុរសនោះក៏បានសុំឱ្យអែលឌើរមកមន្ទីរពេទ្យ រួចហើយគាត់និយាយ ទាំងទឹកភ្នែករលីងរលោងថា 'នៅក្នុងមួយជីវិតរបស់ខ្ញុំ មិនដែលមានយុវវ័យណាម្នាក់ ខិតខំខ្នះខ្នែងធ្វើ ការគ្រប់យ៉ាងសំរាប់ខ្ញុំដូច្នេះទេ។'

"ឬកពារបស់គាត់មានការផ្លាស់ប្តូរ។ គាត់ស្តាប់ការពិភាក្សារបស់អ្នកផ្សព្វផ្សាយសាសនា។ កាលពីមុនគាត់ មានការសង្ស័យ តែឥឡូវនេះ គាត់បានយកចិត្តទុកដាក់យ៉ាងខ្លាំង ហើយមានការឱនលំទោនិងការបន្ទាបខ្លួនតែម្តង។ នេះគឺជាការអធិស្ឋាន នៅលើកទីមួយរបស់គាត់ គឺបានធ្វើតាំងពីគាត់នៅក្មេងមកម្លេះ ហើយឥឡូវគាត់បានទទួលនូវសក្ខីភាព និងបានទទួលបុណ្យជ្រមុជ ទឹកទៀតផង" (នៅក្នុង Conference Report ខែតុលា ឆ្នាំ 1985, 36 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1985, 28)។

2. តើកិច្ចការបំរើ ប្រភេទណាខ្លះ ដែលអ្នកអាចផ្តល់ទៅឱ្យគ្រួសារ អ្នកជិតខាង និងសមាគមរបស់អ្នកនៅពេលនេះក្នុងជីវិត របស់អ្នក?

ខ គម្រោងការណ៍ក្នុងការបង្រៀនដំណឹងល្អ

អាំម៉ូន បានណែនាំដំណឹងល្អ ទៅដល់ស្តេចមួយជំហានម្តងឲ។

1. ចូរគូសជាគម្រោងមួយនៅក្នុង ស្សៀវភៅសរសេររបស់អ្នក ដូចដែលបានបង្ហាញនៅទីនេះ រួចហើយបំពេញនូវជំហាន នីមួយឲ ជាមួយនឹងការបង្រៀនយ៉ាងសង្ខេបរបស់អាំម៉ូន ទៅដល់ស្តេចលេមិន នៅក្នុងអាលម៉ា 18:24–40។



2. ចូរពន្យល់ ពីមូលហេតុ ដែលអ្នកគិតថា អាំម៉ូនធ្វើការជ្រើសរើសបង្រៀន គោលលទ្ធិទាំងឡាយតាមលំដាប់លំដោយ ដូច្នេះ (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" អាលម៉ា 18:36–43 ដើម្បីជាជំនួយ បើសិនជាត្រូវការ)។

គ គោលលទ្ធិ នៃការចែកចាយដំណឹងល្អ

ចូរសរសេរគោលលិទ្ធិសំខាន់ឲចំនួនបី ដែលអ្នកបានរៀនមកពី អាលម៉ា 17–18 អំពីការចែកចាញដំណឹងល្អ ដែលអ្នកគិតថា សមាជិកគ្រប់គ្នានៅក្នុងសាសនាចក្រអាចប្រើបាន—ដោយមិនមែនសំរាប់តែអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនោះទេ។

អាលម៉ា 19
ព្រះអគ្គមហេសីរបស់ស្តេចឡាម៉ូណៃ និងអ្នកដទៃទៀត បានផ្លាស់សាសនា

នៅអាលម៉ា 19 មានចុះបញ្ជីនូវបទពិសោធន៍ខាងវិញ្ញាណដ៏អស្ចារ្យ។ បទពិសោធន៍ទាំងនោះ អាចមានភាពអស្ចារ្យដូចនេះ ទៅទៀត បើសិនជាអ្នកធ្វើការអានសារឡើងវិញ នូវការពិពណ៌នា នៅក្នុងអាលម៉ា 17:14–15 អំពីប្រភេទមនុស្ស ដែលអាំម៉ូន កំពុងធ្វើការក្នុងចំណោមពួកគេ។ ចូរធ្វើការយកចិត្តទុកដាក់ជាពិសេស ទៅលើអ្វីដែលអាំម៉ូន ចង់ឱ្យយើងរៀនពីបទពិសោធន៍ ទាំងឡាយនេះ ដូចបានចុះបញ្ជីនៅចុងបញ្ចប់ នៃអាលម៉ា 19។

© 1996 Ronald K. Crosby

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 19

ផ្នូរ (ខ. 1, 5)—កន្លែងបញ្ចុះសព

ស្បៃ (ខ. 6)—វាំងនន

ជ្រួលជ្រាប (ខ. 6)—បំពេញ រំភួក

ដេកស្តូកនៅលើដី (ខ. 17–18)—នៅរាបទន្ទឹងដី

ស្តីបន្ទោស (ខ. 20–21, 26)—មិនអនុញ្ញាត បន្ទោស

បានបង្រៀន (ខ. 33)—បានជួយ

បាននិយាយ (ខ. 34)—និយាយ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សាអាលម៉ា 19។

ក ជំណើរការ នៃការផ្លាស់សាសនា

អាលម៉ា 19 បង្រៀនយ៉ាងច្រើន អំពីជំណើរការនៃការផ្លាស់សាសនា។ ចូរឆ្លើយនូវសំនួរខាងក្រោមនេះ ដើម្បីជួយអ្នកឱ្យរក ឃើញជំណើរការនេះ៖

1. ដកស្រង់ចេញពី អាលម៉ា 19:6, 33 តើអ្នកគិតថាពាក្យ ឬឃ្លាអ្វី ដែលសំខាន់បំផុតដើម្បីពិពណ៌នាអំពីការផ្លាស់សាសនា របស់ស្តេច ឡាម៉ូណៃ និងអ្នកបំរើទ្រង់? តើហេតុអ្វី អ្នកគិតថាពាក្យ ឬឃ្លានីមួយៗ ដែលអ្នកបានជ្រើសរើសនោះសំខាន់?

2. យោងទៅតាម អាលម៉ា 19:16–17 តើអ័ប៊ិស បានផ្លាស់សាសនាយ៉ាងដូចម្តេច?
3. យោងទៅតាមអាលម៉ា 19:29–35 តើពួកលេមិនផ្សេងទៀត បានផ្លាស់សាសនាយ៉ាងដូចម្តេច?
4. តើហេតុអ្វីក៏អ្នកគិតថា មានមនុស្សខ្លះមិនធ្វើការផ្លាស់សាសនា?

ចូរគិតអំពីពាក្យ ឃ្លា ឬបទពិសោធន៍ នៅក្នុងអាលម៉ា 19 មកដាជំណើរការនៃការផ្លាស់គំនិតរបស់ខ្លួនឯងវិញ។

ខ តើសីលធម៌នៃសាច់រឿងជាអ្វី?

នៅក្នុងអាលម៉ា 19:36 ប្រវត្តិសាស្ត្រព្យាការីមរមន បានពន្យល់ពីអ្វីដែលគាត់ចង់ឱ្យយើងរៀនពីបទពិសោធន៍របស់អាំម៉ូន។

1. ប្រើដាពាក្យរបស់អ្នក ធ្វើការពន្យល់អំពីអ្វី ដែលអាំម៉ូន បានឱយាយនៅក្នុងមេរៀន ហើយធ្វើជាបញ្ជីយ៉ាងតិចមានព្រឹត្តការណ៍ ពីរ មកពីអាលម៉ា 17–19 ដែលបង្ហាញពីគោលលទ្ធនោះ។
2. តើគោលលទ្ធិ ធ្វើឱ្យមានភាពខុសគ្នាយ៉ាងណាខ្លះនៅក្នុងជីវិតរបស់អ្នក?

អាលម៉ា 20

អាំម៉ូនជួបបិតារបស់ឡាម៉ូណៃ

មិនមែនកូនប្រុសទាំងអស់របស់ម៉ូសាយ មានជោគជ័យនៅក្នុងការផ្សព្វផ្សាយសាសនាដូច អាំម៉ូននោះទេ។ នៅក្នុងអាលម៉ា 20 អ្នកនឹងអានអំពី ប្អូនប្រុសរបស់អាំម៉ូន អេរ៉ុន និងដៃគូរបស់គាត់ត្រូវបានចាប់ដាក់គុក។ អ្នកនឹងអាន អំពីរបៀប ដែលអាំម៉ូនយកឈ្នះជួយរំដោះពួកគេឱ្យរួច ដោយរងនូវការកាប់មួយដាវពីបិតា របស់ស្តេចឡាម៉ូណៃ! នេះជាការចាប់ផ្តើមក្នុងស្ថានភាពដ៏មានគ្រោះថ្នាក់ ទឹងត្រូវបានបញ្ចប់ ដូចគ្មានទីឯទិកាសដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យផ្សេងទៀត។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 20

បានប្រាប់ (ខ. 11, 13)—បានពន្យល់

ដោយកលល្បិច (ខ. 13)—លបលួចធ្វើ

សូមទ្រង់ចាំបាច់តែស៊ូទ្រាំអត់ធ្មត់ចុះ (ខ. 18)—ជាការចាំបាច់ ដែលអ្នកត្រូវឈប់

មានការសងសឹក (ខ. 18)—ទារុណកម្ម

អាចធ្វើឱ្យ (ខ. 24)—មានឥទ្ធិពលលើ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយក្នុងចំណោមសកម្មភាព (ក–គ) នៅពេលអ្នកសិក្សាអាលម៉ា 20។

ក្ស សម្ភាសអ្នកផ្សព្វផ្សាយសាសនាម្នាក់

1. ចូរំលឹកអាលម៉ា 20ះ1–5 ឡើងវិញ ហើយពន្យល់ថា តើអាំម៉ូនដឹងថា ប្អូនប្រុសរបស់គាត់ជាប់គុកដោយរបៀបណា។
2. ចូរសម្ភាសនរណាម្នាក់ ដែលធ្លាប់ធ្វើការបំរើនៅក្នុងសង្កាត់ ឬមណ្ឌលបេសកកម្មរបស់អ្នក ឬកំពុងតែបំរើបេសកកម្ម ហើយសុំពួកគាត់ឱ្យចែកចាយបទពិសោធន៍មួយ ជាមួយអ្នកនៅពេលពួកគេត្រូវបានដឹកនាំដោយព្រះវិញ្ញាណ។ ចូរធ្វើការ សង្ខេបបទពិសោធន៍នោះ មកចូលក្នុងស្យៀវភៅសរសេររបស់អ្នក។

ខ បញ្ចាប់ប្រយោគ

អាំម៉ូន និយាយដោយត្រង់ឲ្យទៅស្តេចឡាម៉ូណៃជាបិតាបានខ្លាល់។ ខាងក្រោមមានឃ្លា ដែលបានសង្ខេបអំពីអ្វីដែលគាត់និយាយ និងអំពីរបៀបដែលបិតារបស់ស្តេចឡាម៉ូណៃបានធ្វើការឆ្លើយតបទៅគាត់។ ចូរសរសេរឃ្លាទាំងនោះ នៅក្នុងស្យៀវភៅសរសេរ របស់អ្នក ហើយបញ្ចាប់ឃ្លានោះ ដោយការប្រើពាក្យសំដីរបស់អ្នកផ្ទាល់ រួចប្រើពាក្យដែលអ្នកបានរៀននៅក្នុងអាលម៉ា 20ះ17–27។ បន្ទាប់ពីបានបញ្ចាប់ឃ្លានីមួយឲ្យហើយ ចូរចង្អុលបង្ហាញថានរណាជាអ្នកនិយាយ។

1. កុំសម្លាប់បុត្ររបស់ព្រះអង្គ។ ប៉ុន្តែបើអ្នកសម្លាប់ គឺគ្រាន់បើជាង ដែល . . .
2. បើសិនជាអ្នកស្លាប់ បន្ទាប់មក . . .
3. យើងដឹងថា បើយើងសម្លាប់បុត្រារបស់យើង . . .
4. សូមឱ្យបងប្អូនរបស់ខ្ញុំ ចេញពីគុក . . .
5. បើលោកលើកលែងជីវិតឱ្យខ្ញុំ . . .
6. ពីព្រោះតែលោកស្រឡាញ់បុត្រារបស់យើង . . .

គ ចិត្តផ្លាស់ប្តូរ

សូមប្រើពាក្យដកស្រង់មកពី អាលម៉ា 20 ដើម្បីឆ្លើយនឹងសំនួរទី 1 និងទី 2។ ចូរឆ្លើយសំនួរទី 3 ដោយពាក្យសំដីរបស់អ្នកផ្ទាល់ះ

1. តើបិតារបស់ស្តេចឡាម៉ូណៃមានអារម្មណ៍យ៉ាងដូចម្តេច អំពីអាំម៉ូន នៅពេលពួកគេជួបគ្នាជាលើកដំបូង?
2. ហេតុអ្វីក៏ទ្រង់ផ្លាស់ព្រះទ័យ?
3. តើមេរៀនទេះ បានបង្រៀនយើងធ្វើអ្វីខ្លះ អំពីការជួបទាក់ទងជាមួយមនុស្ស ដែលប្រឆាំងនឹងសេចក្តីពិត?

អាលម៉ា 21
អាំម៉ូន និងបងប្អូនរបស់គា
ត់បង្រៀនពួកសាសន៍លេមិន

អាលម៉ា 21–26 គឺជាបញ្ជី នៃកិច្ចការអ្នកផ្សព្វផ្សាយសាសនា របស់អើរ៉ុន មូឡូកៃ ហើយនឹងបងប្អូនរបស់គាត់។ បទពិសោធន៍ របស់ពួកគេ គឺមានភាពខុសគ្នាយ៉ាងច្រើន ពីបទពិសោធន៍របស់អាំម៉ូន។ នៅពេលអ្នកអាន អាលម៉ា 21 សូមរកមើលថា តើបទ ពិសោធន៍នេះ មានភាពខុសគ្នាយ៉ាងដូចម្តេច ហើយតើមកពីហេតុអ្វី។ អ្នកប្រហែលជាមានការភ្ញាក់ផ្អើល នៅពេលអ្នកដឹងថានរណាជាអ្នក ដែលបណ្តាលឱ្យពួកគេមានបញ្ហាយ៉ាងច្រើនបំផុតនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 21

កំណើត (ខ. 1)—ចាប់កំណើត

ជោគជាំ (ខ. 3)—កើនឡើង ប្រែជា

អំពើជ៏គួរខ្ពើមឆ្អើមទាំងឡាយ (ខ. 3)—អំពើបាប គំនិត និងសកម្មភាពដែលធ្វើឱ្យព្រះ មិនសព្វព្រះហឬទ័យ

សាលាប្រជុំ ទីបរិសុទ្ធទាំងឡាយ (ខ. 5–6, 11, 16, 20)—សាសនាចក្រកន្លែងថ្វាយបង្គំ

ប្រោសលោះ (ខ. 7)—សង្គ្រោះ

មានចិត្តឧស្សាហ៍ (ខ. 23)—អស់ពីចិត្តចង់បានយ៉ាងខ្លាំង

អាលម៉ា 21ះ3—តើពួកសាសន៍អាមូលេកៃ និងប្រជាជនអាមូឡុនជានរណា?

ពួកសាសន៍អាម៉ាលេកៃ គឺជាពួកក្បត់សាសន៍នីហ្វៃ។ នេះជាលើកទីមួយ ដែលព្រះគម្ពីរមរមន បានប្រាប់អំពីពួកសាសន៍ អាម៉ាលេកៃនេះ។ ប្រជាជនអាម៉ូឡុន គឺជាពូជអំបូរ ពួកសង្ឃទុច្ចរិតរបស់ស្តេចណូអេ ដែលបានបោះបង់ចោលក្រុមគ្រួសារ របស់ពួកគេ រួចរត់ភៀសខ្លួនចូលទៅក្នុងទីរហោដ្ឋាន រៀបការជាមួយកូនស្រីពួកលេមិន ហើយបានក្លាយជាសង្គមពួកលេមិន (សូម មើលម៉ូសាយ 23ះ31–35)។

អាលម៉ា 21ះ4—តាមរបៀបនីហ្វរ

ចំពោះពតិមានអំពី "តាមរបៀបនីហ្វរ" សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" អាលម៉ា 1ះ12 (ទំព័រ 101)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សា អាលម៉ា 21។

ក្ស សរសេរសំបុត្រមួយច្បាប់



បន្ទាប់ពីអ្នកអានអាលម៉ា 21 នៅក្នុងស្យៀវភៅសរសេររបស់អ្នក សូមសរសេរសំបុត្រមួយច្បាប់ទៅឱ្យគ្រួសាររបស់អ្នក សន្មត់ថាអ្នក គឺជាអើរ៉ុន ហើយពិពណិនាដោយសង្ខេប អំពីបទពិសោធន៍របស់អ្នក។

ខ ខគម្ពីរដែលអ្នកចូលចិត្តបំផុត

សូមរំលឹកអាលម៉ា 21:9 ឡើងវិញ។ ឧបមាថា អ្នកចង់ "បើកព្រះគម្ពីរ" ទៅឱ្យមិត្តម្នាក់ ដែលមានចម្ងល់អំពី ព្រះអង្គសង្គ្រោះ។ តើមានខគម្ពីរនៅក្នុងព្រះគម្ពីរមរមនណាខ្លះ ដែលអ្នកបានសិក្សាពីមុននឹងចង់ចែកចាយខគម្ពីរនោះ ជាមួយពួកគេ? ហេតុអ្វី?

អាលម៉ា 22

អើរ៉ុនបង្រៀនដល់ស្តេច របស់ប្រជាជនឡាម៉ូណៃ

អ្នកផ្សព្វផ្សាយសាសនាទាំងអស់ គឺត្រូវបានប្រគល់អំណាចឱ្យបង្រៀនដំណឹងល្អ។ ទោះជាយ៉ាងណាក៏ដោយ ការចាត់ចែងនេះ នាំមក នូវការប្រឈមមុខជាមួយឧបសគ្គជាច្រើន។ អ្នកផ្សព្វផ្សាយសាសនាម្នាក់ត្រូវតែសួរ តើខ្ញុំបង្រៀនពីអ្វី? តើខ្ញុំអាចជួយមនុស្ស ឱ្យមានព្រះវិញ្ញាណបានយ៉ាងដូចម្តេច? តើខ្ញុំអាចឆ្លើយតប នឹងសំនួររបស់ពួកគេដូចម្តេច? សូមស្វែងរកឧទាហរណ៍ ដែលមិនផ្តុំយកពីការបង្រៀនដំណឹងល្អ នៅពេលអ្នកអាន អំពីអើរ៉ុនបង្រៀនបិតារបស់ស្តេចឡាម៉ូណៃ។ ចូរប្រៀបធៀបពីរបៀប និងពីអ្វីដែលគាត់បង្រៀនជាមួយនឹងបទពិសោធន៍របស់អាំម៉ូន នៅក្នុងអាលម៉ា 18:22–40។

បិតារបស់ឡាម៉ូណៃ

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 22

ចិត្តទូលំទូលាយ (ខ. 3)—មិនមានសេចក្តីកំណាញ់

ស្ថានភាពសាច់ឈាម (ខ. 13)—មនុស្ស ឬស្ថានភាពខាងរូបកាយ

បានបុណ្យ (ខ. 14)—មានភាពសក្តិសម និង ឬមានសិទ្ធិទទួល

ដកយកវិញ្ញាណអាក្រក់ចេញពីទ្រូងយើង (ខ. 15)—ផ្លាស់ចេញពីចិត្ត ឬព្រលឹងខ្ញុំ

ផ្លូវ (ខ. 17)—ដួលចុះដោយការគោរពដ៏ជ្រាលជ្រៅ

បានបាត់ខឹង (ខ. 25)—ធ្វើឱ្យមានសន្តិភាព

ឃាំង (ខ. 33)—ពន្ធ័ជុំវិញ

អាលម៉ា 22:12–14—ដើម្បីឱ្យយល់ពី ជង្វាយធួនទីមួយ យើងត្រូវតែយល់ពី គោលលទ្ធិ នៃការបង្កប់ងើត និងការធ្លាក់នៃលោកអ័ដាម

អែលឌើរ ប្រ៊ូស អរ. មិកខនឃី ជាសមាជិកនៃក្រុមសាវក 12 នាក់ បានសរសេរថាៈ "ផែនការដ៏នៅអស់កល្បជានិច្ច របស់ ព្រះវរបិតាត្រូវការការបង្កប់ងើត ការធ្លាក់ចុះ ហើយនឹងជង្វាយធួនទាំងអស់នេះផ្សំឡើងរួមគ្នា នៅក្នុងការបង្រៀបបង្រួមមួយ ទាំងមូល" (*A New Witness for the Articles of faith* [1985], 82)។

ប្រធាន អ៊ែសរ៉ា ថាប់. ប៊ែនសិន បានជួយយើងឱ្យយល់ដូចតទៅនេះៈ

"ពួកបរិសុទ្ធក្នុងព្រះគម្ពីរមរមន ស្គាល់ថាផែនការណ៍ នៃការត្រាស់លោះ ត្រូវតែចាប់ផ្តើមជាមួយនឹងដំណើរការនៃការធ្លាក់ នៃលោកអ័ដាម . . .។

"គឺដូចជាមនុស្សម្នាក់ មិនត្រូវការអាហារ រហូតទាល់តែគាត់ឃ្លាន ដូច្នេះគាត់មិនចង់បានសេចក្តីសង្គ្រោះនៃព្រះគ្រីស្ទ រហូតដល់ គាត់ដឹងថា ហេតុអ្វីបានជាគាត់ត្រូវការព្រះគ្រីស្ទ។

"គ្មានទណ្ឌាម្នាក់អាចដឹង ឱ្យត្រប់ត្រាន់ និងដោយត្រឹមត្រូវថា ហេតុអ្វីបានជាគាត់ត្រូវការព្រះគ្រីស្ទនោះទេ រហូតទាល់តែគាត់យល់ ហើយទទួលយកគោលលទ្ធិ នៃការធ្លាក់ចុះ ហើយការធ្លាក់ចុះនេះមានឥទ្ធិពលដល់មនុស្សទាំងអស់។ ហើយគ្មានស្បៃវែកាណា នៅក្នុងពិភពលោកនេះ អាចពន្យល់ពីគុណសម្បត្តិនៃគោលលទ្ធិនេះឱ្យបានល្អ ដូចជាព្រះគម្ពីរមរមន នោះទេ . . .

"តើយើងកំពុងតែទទួលយក និងបង្រៀនអំពីអ្វី ដែលវិវរណៈប្រាប់យើង អំពីការបង្កប់ងើត អ័ដាម និងការធ្លាក់របស់មនុស្ស ហើយនឹងការត្រាស់លោះពីការធ្លាក់នោះ តាមរយៈជង្វាយធួនរបស់ព្រះគ្រីស្ទឬទេ? . . .

តើយើងយល់ ហើយតើយើងកំពុងតែបង្រៀន និងប្រកាស អំពីជង្វាយធួន ដោយមានប្រសិទ្ធិភាពឬទេ? តើការរងទុក្ខ របស់ព្រះអម្ចាស់នៅក្នុងសួនច្បារគែតសេម៉ានី ហើយនឹងនៅលើ ភ្នំរលាក្បាលមានអត្ថន័យអ្វីខ្លះ ចំពោះខ្លួនយើងម្នាក់ៗ?

តើការត្រាស់លោះពីការធ្លាក់ សំរាប់យើងមានន័យអ្វីខ្លះ? (នៅក្នុង Conference Report, ខែមេសា ឆ្នាំ1987, 1 06–7 ឬ *Ensign* ខែឧសភា ឆ្នាំ1987, 85)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាអាលម៉ា 22។

ក សំគាល់ពាក្យគន្លឹះ

1. រំលឹកអាលម៉ា 22:5–11 ឡើងវិញ ហើយធ្វើជាបញ្ជីពាក្យគន្លឹះចំនួនប្រាំ ដែលបង្ហាញអំពីគោលគំនិតនៅក្នុងសារលិខិតនេះ។
2. ចូរគូសជារង្វង់នូវពាក្យ ដែលអ្នកគិតថា សំខាន់បំផុត ហើយពន្យល់ហេតុអ្វីបានជាអ្នករើសយកពាក្យនោះ។
3. តើអ្នកគិតថា ហេតុអ្វីបានជាអ្នកផ្សព្វផ្សាយសាសនាទាំងអស់ ធ្វើការចាប់ផ្តើម ដោយការបង្រៀនអំពី មូលដ្ឋាននៃគោលលទ្ធិ ដំណឹងល្អដូច្នេះ?

ខ ឆ្លើយសំនួរ

1. យោងទៅតាមអាលម៉ា 22:12–14 តើគោលលទ្ធិសំខាន់ៗបី ដែលអើរ៉ុនបង្រៀនទៅដល់ស្តេចមានអ្វីខ្លះ? (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" នៅក្នុងអាលម៉ា 22:12–14 ដើម្បីជាជំនួយ បើសិនជាត្រូវការ)។

2. បន្ទាប់ពីអ្នកគោលលទ្ធិទាំងនេះរួចហើយ ស្តេចបានសួរសំនួរពីរសំខាន់ៗ (សូមមើលខ. 15)។ សូមសរសេរសំនួរទាំងពីរនោះ តាមពាក្យសំដីរបស់អ្នក។

3. ចូរប្រើ អាលម៉ា 22:15–18 ធ្វើជាគំរូមួយ រួចសរសេរនូវការឆ្លើយតបរបស់អ្នក បើសិនជាមានមិត្តម្នាក់ បានសួរសំនួរដូចគ្នា ទាំងនោះដល់អ្នក។



អាលម៉ា 23

ពួកសាសន៍អាន់តៃ-ទីហ្គៃ-លីហៃ

តើអ្នកមានស្គាល់នរណាម្នាក់ ដែលបានផ្លាស់គំនិតថ្វាយព្រះអម្ចាស់ និងដំណឹងល្អរបស់ទ្រង់ តាមរយៈកិច្ចការផ្សព្វផ្សាយសាសនា ឬទេ? តើពួកគេមានការផ្លាស់ប្តូរ នៅពេលគេទទួលដំណឹងល្អយ៉ាងដូចម្តេចខ្លះ? តើការសិក្សាព្រះគម្ពីរមានន័យ មានឥទ្ធិពល ក្នុងជីវិតរបស់អ្នក ដោយរបៀបណាខ្លះ? នៅពេលអ្នកអាន អាលម៉ា 23 ចូរកត់សំគាល់ថា ដោយវិធីណា ដែលសារលិខិតដំណឹងល្អ អាំម៉ូនបានបង្រៀនគេនោះ ផ្លាស់ប្តូរចិត្តប្រជាជន។ ចូរស្វែងរកសេចក្តីសញ្ញា ដែលពួកគេបានធ្វើ ហើយពិចារណាថា វាមានឥទ្ធិពល អ្វីខ្លះដល់អនាគតរបស់ពួកគេ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 23

ក្រិត្យ (ខ. 2)—ច្បាប់ របៀប

ចេញចូលបានដោយសេរី (ខ. 2)—សេរីភាព ដើម្បីចេញ ចូលតាមចិត្តគេចង់

ប្លន់ (ខ. 3)—លួចប្លន់

ការតែងតាំង (ខ. 4)—ការតែងតាំងសំរាប់គោលបំណងដ៏ពិសិដ្ឋមួយ

បានពិភាក្សា (ខ. 16)—និយាយរកពាក្យពំណែនាំ

ញែកចេញ (ខ. 16)—ដឹង ឬសំគាល់ដោយ

មានចិត្តឧស្សាហ៍ (ខ. 18)—ខំធ្វើការរុងរឿង

ការទាក់ទង (ខ. 18)—ទំនាក់ទំនងជិតស្និទ្ធ និងទំនាក់ទំនង

អាលម៉ា 23:17—តើឈ្មោះ ពួកសាសន៍ អាន់តៃ-ទីហ្គៃ-លីហៃ មានន័យអ្វីខ្លះ?

ឈ្មោះ *អាន់តៃ-ទីហ្គៃ-លីហៃ* អាចមានន័យថា អ្នកផ្លាស់សាសនាថ្មីទាំងឡាយណា ដែលមានបំណងចង់ធ្វើដូចជា ទីហ្គៃ និងលីហៃ ហើយបានជ្រើសឈ្មោះថ្មីមួយ ដែលឆ្លុះបញ្ចាំងអំពីសេចក្តីត្រេកអរដ៏សុចរិតរបស់ពួកគេ។ តាមការសិក្សាបង្ហាញ ឱ្យឃើញថា នៅក្នុងភាសាខ្លះ មានឃ្លាសតល់ទាក់ទងគ្នាទៅនឹងពាក្យ *ប្រឆាំង* ដែលមានន័យថា “ប្រឈមនឹង” ឬ “ប្រឈមមុខ” ដូចជាអ្នកឆ្លុះកញ្ចក់។ ពាក្យប្រឆាំងនេះ ក៏អាចមានន័យស្រដៀងគ្នាទៅនឹងពាក្យ *ការធ្វើត្រាប់តាម*។ នៅក្នុងសភាពនេះ ឈ្មោះ អាន់តៃ-ទីហ្គៃ-លីហៃ អាចសំដៅទៅលើអ្នកទាំងឡាយណា ដែលមានចំណង់ដើម្បីធ្វើតម្រាប់តាមអ្វី ដែលបាន បង្រៀនដោយពួជអំបូររបស់ ទីហ្គៃ និងលីហៃ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 23។

ក ការផ្លាស់សាសនាដោយពិត

សូមអាន អាលម៉ា 23:6–13 ហើយឆ្លើយសំនួរដូចខាងក្រោមនេះ៖

1. ពួកលេមិន បានទទួលបុណ្យជ្រមុជទឹក តើការនេះ បានបង្ហាញថា ពួកគេផ្លាស់គំនិតថ្វាយព្រះអម្ចាស់ឬទេ?
2. តើអ្នកគិតថា ហេតុអ្វីពួកសាសន៍លេមិនទាំងនោះ “ពុំបោះបង់ចោលសាសនាឡើយ” (ខ. 6)?
3. តើមនុស្សសព្វថ្ងៃនេះ អាច “ដាក់ចុះ” គ្រឿងសស្ត្រាវុធ នៃការបះបោរទាស់នឹងព្រះបានឬទេ?

ខ ការបង្រៀនដំណឹងល្អ

ចូរសិក្សាអាលម៉ា 23:4–6 ហើយឆ្លើយសំនួរខាងក្រោមនេះ៖

1. តើអើរ៉ុន និងបងប្អូនរបស់គាត់ ប្រើឆន្ទានុជ្ញាដូចជាការបង្រៀនទៅក្នុងអង្គការបឋមសិក្សាឬទេ?
2. តើមានអំណាចអ្វី ដែលបានជួយពួកគេទៅក្នុងការបង្រៀនរបស់គេនោះ?
3. តើឃ្លា ដែលបានពិពណ៌នា អំពីប្រសិទ្ធិភាពនៃការបង្រៀនរបស់ពួកគេនៅកន្លែងណា?
4. តើបទពិសោធន៍ទាំងនោះ បានជួយការពារជ្រឹងសក្តិភាពរបស់អ្នកអ្វីខ្លះ?

គ ពន្យល់ថា ជាអ្នកណា ហើយតើហេតុអ្វី

ចូររំលឹក អាលម៉ា 23:6–13, 16–18 សារឡើងវិញ។ ចូរពន្យល់ ថាតើប្រជាជនមួយណា ដែលបានលើកដាក់ ឈ្មោះអាន់ តៃ-ទីហ្គៃ-លីហៃមកលើខ្លួនពួកគេ ហើយតើហេតុអ្វី ពួកគេមានភាពស្មោះត្រង់ក្នុងការគោរពបទបញ្ញត្តិទាំងឡាយ។

អាលម៉ា 24

រក្សាសេចក្តីសញ្ញា

ចូរគិតអំពីសេចក្តីសញ្ញា ដែលអ្នកបានធ្វើ នៅពិធីបុណ្យជ្រមុជទឹក ហើយសេចក្តីសញ្ញាទាំងនោះសំខាន់ប៉ុណ្ណា។ តើអ្នកនឹង សុខចិត្តលះបង់ជីវិត ជាជាងបំផ្លាញសេចក្តីសញ្ញាទាំងនោះឬទេ? ពួកសាសន៏ អាន់តៃ-នីហ្វៃ-លីហៃ បានឱ្យតម្លៃទៅលើ សេចក្តីសញ្ញារបស់ពួកគេ លើសពីជីវិតរបស់ពួកគេទៅទៀត។ នៅពេលអ្នកអានអំពីការតាំងចិត្តរបស់ពួកគេ ចូរគិតអំពីការ លើកទឹកចិត្ត ដែលបានតម្រូវឱ្យអ្នករក្សាសេចក្តីសញ្ញារបស់ខ្លួន នៅក្នុងពិភពលោកសព្វថ្ងៃនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 24

បុណ្យគុណទាំងឡាយ (ខ. 10)—អំពើសុចរិត ជង្វាយធួន

ស្មាមប្រឡាក់ (ខ. 11–13, 15)—ការហើរពពាណិ ស្មាម នៅក្នុងខ. 11 ហើយដាលើកទឹមួយប្រើនៅក្នុងខ 12 និង 15 ត្រូវបានប្រើជានិមិត្តរូប ដែលមានន័យថា ទោស ឬអំពើបាប

បានប្រទាន (ខ. 15)—ផ្តល់ឱ្យ

ការបញ្ជាក់ (ខ. 18)—ការសន្យា

ក្រាប (ខ. 21)—ដាក់ចុះ

ការឈឺចាប់ (ខ. 25)—មានអារម្មណ៍ឈឺចាប់ និងទុក្ខព្រួយ

វែកញែក (ខ. 30)—ស្គាល់ ឃើញ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាអាលម៉ា 24។

ក ខុស ឬត្រូវ?

ចូរសរសេរនូវសេចក្តីថ្លែងការណ៍ នៅក្នុងស្បៀវភៅសរសេររបស់អ្នក។ ការប្រើអាលម៉ា 24:11–19 ដើម្បីបង្ហាញច្បាស់ថា សេចក្តីថ្លែងការណ៍មួយណាត្រឹមត្រូវ ដោយសរសេរ *ត្រូវ* នៅខាងចុងប្រយោគ។ ចូរសរសេរសេចក្តីថ្លែងការណ៍ ដែលខុស ម្តងទៀត ដើម្បីកែឱ្យបានត្រូវវិញ។

1. ប្រជាជនមានអារម្មណ៍ថា ពួកគេជាអ្នករងើងជាងគេបង្អស់ ក្នុងចំណោមមនុស្សលោក ដោយសារតែការកាប់សំលាប់ ដែល ពួកគេបានធ្វើមួយរយៈមកនោះ ដើម្បីមកធ្វើការប្រែចិត្តគំនិតរបស់ពួកគេ (សូមមើល ខ. 11)។
2. ពួកសាសន៏ អាន់តៃ-នីហ្វៃ-លីហៃ មានភាពល្បីដាក់ថា ពួកគេអាចបានទទួលការអភ័យទោស បើពួកគេទៅធ្វើចំពាំង ម្តងទៀត (សូមមើល ខ. 12–13)។
3. ប្រជាជនបានទំលាក់អាវុធ ព្រោះពួកគេខ្លាច នឹងទៅធ្វើសង្គ្រាម ហើយនឹងត្រូវសំលាប់ (សូមមើល ខ. 16)។
4. ជាជាងការសំលាប់ និងការលួច ប្រជាជនទាំងនេះបានប្រែចិត្តគំនិត ដោយបានសំរេចចិត្ត ដើម្បីឱ្យពួកសាសន៏នីហ្វៃ ចាប៊ីម នឹងថែរក្សាវិញ (សូមមើល ខ. 18)។
5. ការប្រែចិត្តគំនិតរបស់ពួកគេ គឺខ្លាំងមែនទែន ដែលពួកគេសុខចិត្តស្លាប់ ជាជាងធ្វើអំពើបាប (សូមមើល ខ. 19)។

ខ បង្កើតជាប្រដាប់គូសចំណាំអំពីប្រវត្តិសាស្ត្រមួយ

ចូរអាន អាលម៉ា 24:17–26។ សូមគិតថា ប្រដាប់គូសចំណាំអំពីប្រវត្តិសាស្ត្រមួយ គឺដាក់ឱ្យមើលឃើញពី កន្លែងដែលព្រឹត្តការណ៍ទាំងនោះបានកើតឡើង។ ចូរធ្វើការគូសចំណាំនៅលើអ្វី តាមចិត្តរបស់អ្នក គិតថាគូសចំណាំ ហើយនឹងអ្វី ដែលអ្នកគួរសរសេរនៅលើវា។

អាលម៉ា 25

ការព្យាករណ៍ត្រូវបានសំរេច

ព្រះអម្ចាស់បានបញ្ជូនព្យាការី ឱ្យទៅបំរើដាទូតរបស់ទ្រង់ ហើយឱ្យពួកគេបានស្គាល់នូវឆន្ទៈរបស់ទ្រង់។ នៅពេលខ្លះ ពួកគេទស្សទាយអំពីហេតុការណ៍នៅក្នុងពេលអនាគត។ អាលម៉ា 25 បង្ហាញនូវភាពអស្ចារ្យ ដែលមានរៀបរាប់អំពី ការសំរេច តាមពាក្យព្យាករបស់ព្យាការីអ័ប៊ីណាដៃ ដែលត្រូវគេសម្លាប់នោះ។ នៅពេលអ្នកអាន អំពីសារលិខិត នៃព្យាការីបច្ចុប្បន្ន ចូរធ្វើការគិតសញ្ជឹង ហើយថាមូលហេតុអ្វី យើងនឹងមានសុភមង្គលដ៏មហិមា នៅពេលដែលយើងធ្វើតាមការណែនាំរបស់គាត់។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 25

ការសងសឹក (ខ. 1)—សងសឹក

បានដណ្តើម (ខ. 5)—យកដោយមិនយុត្តិធម៌ ឬដោយបង្ខំ

ប្រភេទ (ខ. 10—គំរូ តាពជូច

ត្រូវបានបញ្ជាក់ (ខ. 12)—ដែលបញ្ជាក់ថាការពិត

ត្រូវកាន់តាមការប្រព្រឹត្តខាងក្រៅទាំងនេះ (ខ.15)—ពិធីទាំងឡាយ ដែលទាក់ទងនឹងច្បាប់របស់ម៉ូសេ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ ឬគ នៅពេលអ្នកសិក្សា អាលម៉ា 25។

ក ពិនិត្យមើលក្នុងព្រះគម្ពីរ

ចូរអានទៅក្នុងអាលម៉ា 8:16 និងអាលម៉ា 16:9 ដែលបានផ្តល់ដាគំនិតឱ្យយល់ថា ហេតុអ្វីប្រជាជន នៅក្នុងដែនដី អាំម៉ូណៃហា ត្រូវបំផ្លាញចោល។ ចូរសរសេរសង្ខេបអំពីអ្វី ដែលបានកើតឡើង ចំពោះពួកសាសន៏អាំម៉ូណៃហា និងអំពីមូលហេតុ។

ខ តើការព្យាករណ៍ បានសំរេចយ៉ាងដូចម្តេច?

1. អ័ប៊ីណាដៃ បានព្យាករអំពីពួកដែលចោទប្រកាន់គាត់ និងពូជអំបូររបស់ពួកគេ នៅពេលដែលគាត់ត្រូវគេដុតឱ្យស្លាប់។ ចូរអានន្ទវាក្យចុងក្រោយរបស់អ័ប៊ីណាដៃ នៅក្នុងម៉ូសាយ 17:14–19 រួចហើយធ្វើដាបញ្ជីសង្ខេបមួយ អំពីធាតុនីមួយៗ នៃការព្យាករណ៍របស់គាត់។

2. ចូរស្រាវជ្រាវនៅក្នុងអាលម៉ា 25:4–12 ដើម្បីស្គាល់ថា ព្រឹត្តការណ៍ណាមួយ ដែលបានធ្វើឱ្យសំរេចទូវពាក្យរបស់ អ័ចីណាដៃ។ សូមដាក់លេខ ខគម្ពីរ នៅបន្ទាប់ទីង ការព្យាករណ៍ នៅក្នុងបញ្ជីរបស់អ្នក។
3. ចូរពិភាក្សាជាមួយឪពុកម្តាយរបស់អ្នក ត្រួបង្រៀន ឬសមាជិកពេញវ័យផ្សេង ទៀតនៅក្នុងសាសនាចក្រ អំពីការសំរេច តាមពាក្យព្យាកររបស់ព្យាការីសម័យថ្ងៃចុងក្រោយខ្លះៗ។ ចូរសរសេរទុកនូវអ្វី ដែលអ្នកបានរៀន។

ក ស្វែងរកគំនិតគន្លឹះ

មានប្រជាជនលេមិនជាច្រើន ចូលរួមជាមួយប្រជាជន អាន់តៃ-និហ្វៃ-លីហៃ ហើយបានទទួលយកក្រិត្យវិន័យលោកម៉ូសេ។ ចូរស្វែងរក នៅក្នុងអាលម៉ា 25:15–16 ឃ្លាទាំងឡាយណា ដែលពន្យល់ថា ហេតុអ្វីក្រិត្យវិន័យលោកម៉ូសេ គឺជាផ្នែក ដ៏សំខាន់មួយនៃជំណឹងល្អ នៅសម័យនោះ ហើយបន្ទាប់មកសង្កេបឱ្យទៅជាមួយប្រយោគ ហេតុអ្វីអ្នកគិតថា ក្រិត្យវិន័យនេះ មានប្រយោជន៍ចំពោះសាសន៍និហ្វៃ។

អាលម៉ា 26

“ដោយកម្លាំងរបស់ទ្រង់ ខ្ញុំអាចធ្វើកិច្ចការគ្រប់យ៉ាង”

អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ជាញឹកញាប់ត្រលប់មកផ្ទះវិញ ជាមួយនឹងសេចក្តីអំណរយ៉ាងខ្លាំងក្រៃលែង។ នៅពេល អ្នកផ្សព្វផ្សាយសាសនាប្រកបដោយជំនឿ ត្រលប់មកវិញ តើពួកគេជាធម្មតានិយាយចំពោះតែបទពិសោធន៍បេសកកម្ម មនុស្ស ដែលគេបានបង្រៀនរបស់ពួកគេ និងព្រះអម្ចាស់ឬ? នៅពេលអ្នកអានអាលម៉ា 26 ចូរគិតថាអ្នកនៅទីនោះជាមួយអាលម៉ា នៅពេលគាត់បានឆ្លុះបញ្ចាំង អំពីបេសកកម្មរបស់គាត់ តើគាត់មើលទៅដូចជាពោរពេញទៅដោយអំនួត ឬក៏បន្ទាបខ្លួន? តើគាត់ផ្តល់ការស្ងើចសរសើរទៅដល់អ្នកណា ចំពោះជោគជ័យរបស់គាត់? តើអ្នកអាចរៀនអ្វីខ្លះ អំពីការដឹងគុណ តាមរយៈគំរូរបស់គាត់?

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 26

ជ្រោះជ្រៅ (ខ. 3)—រូងយ៉ាងជ្រៅមួយ, ជម្រៅយ៉ាងជ្រៅមួយ

ក្រោលនៃព្រះ (ខ. 4)—សាសនាចក្រ

ច្រូតបាន . . . បានប្រមូលយកទៅទុកក្នុងជង្រុក (ខ. 5)—សំដៅទៅលើការប្រមូលផល ជារឿយៗយ៉ាងសមញ្ញ ក្នុងការនិយាយ អំពីអ្នកផ្លាស់ប្រែចិត្ត បានទាំមកក្នុងសាសនាចក្រ។

ជ័ឥតប្រៀបថ្លឹមបាន (ខ. 15)—យ៉ាងសម្បូរណ៍

សេចក្តីអត់ធ្មត់ (ខ. 16)—ការស៊ូទ្រាំ

ដាក់ទោស (ខ. 19)—ផ្តល់ឱ្យ ប្រព្រឹត្ត

ប្រែចិត្ត (ខ. 21)—ការប្រែចិត្ត ការបន្ទាបខ្លួន

បានស៊ូរងនូវគ្រប់ការខ្វះខាត (ខ. 28)—ធ្វើលើសពីតំរូវការ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរខាងក្រោមនេះ (ក–គ) នៅពេលអ្នកសិក្សាអាលម៉ា 26។

ខ បំពេញតារាងខាងក្រោម

អាំម៉ូន បានប្រើសំដីបរិយាយ ដើម្បីបង្ហាញអំពីគំនិតរបស់គាត់ នៅក្នុងអាលម៉ា 26:3–7។ ចូរថតចម្លង រួចហើយបំពេញ នៅក្នុង តារាងខាងក្រោមនេះ៖

អាលម៉ា 26	ពាក្យរបស់អាំម៉ូន	អត្ថន័យ
ខ. 3	“ជ្រោះជ្រៅ ជឹងធឹតបំផុត”	ស្ថានភាពដែលពោរពេញទៅ ដោយអំពើបាបជាទីបំផុត
ខ. 3	“ត្រៀងឧបករណ៍នៅ ក្នុងព្រះហស្តនៃព្រះ”	
ខ. 5	“ចំការទុំហើយ”	
ខ.5		បានធ្វើការចែកចាយជំណឹងល្អ ហើយនឹងមានបទពិសោធន៍ដ៏ ជោគជ័យ
ខ. 5		អ្នកផ្លាស់ប្រែចិត្តបានទាំមកក្នុង សាសនាចក្រ
ខ. 6		ឈរយ៉ាងរឹងមាំ នៅក្នុងសេក្តីជំនឿ នៅពេលមានសេចក្តីល្បួង
ខ. 7	“ព្រះអម្ចាស់នៃ រង្វង់ច្រូតកាត់”	

ឃ ឆ្លើយដោយខ្លួនឯង

ចូររំលឹក អាលម៉ា 26:10 សារឡើងវិញ ហើយស្វែងរកនូវអ្វី ដែលអើរ៉ុនគិតអំពី អាំម៉ូនថា អាំម៉ូនកំពុងធ្វើអ្វី។

1. ចូរអានអាលម៉ា 26:11–16 រួចហើយសង្ខេបអ្វី ដែលអ្នកមានអារម្មណ៍ថា អាំម៉ូន គឺពិតជាបាននិយាយ និងធ្វើ។
2. ចូរធ្វើបញ្ជីអំពី ភាពត្រូវទាំងឡាយណា ដែលមានទៅក្នុងជីវិតរបស់អ្នក ទៅពេលអ្នកបានទទួលជំនួយមកពីព្រះអម្ចាស់។

គ សរសេរសំបុត្រមួយច្បាប់

1. ចូរអាន គោលលទ្ធិ និងសេចក្ដីសញ្ញា 18:13–16 ហើយធ្វើជាបញ្ជី នៃសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់មានចំពោះ អ្នកទាំង ឡាយណា ដែលបែកចាយដំណឹងល្អ។ សូមស្វែងរកនូវការពិពណ៌នាទៅក្នុងអាលម៉ា 26:1–4, 13–14, 35 ដែលមានភាព ស្រដៀងគ្នា ទៅនឹងសេចក្ដីសង្គ្រោះទាំងនោះ រួចហើយទៅជាប់នឹងសេចក្ដីសង្គ្រោះមួយៗ ក្នុងបញ្ជីរបស់អ្នកសរសេរលេខ ខគម្ពីរ ដែលបង្ហាញនោះ។
2. ចូរសរសេរសំបុត្រមួយច្បាប់ទៅអ្នកផ្សព្វផ្សាយសាសនា ដែលអ្នកស្គាល់ ឬនិយាយជាមួយអ្នកបញ្ចប់បេសកកម្ម រួចហើយ ទាញយក ខ ពីក្នុងអាលម៉ា 26 ដែលអ្នកចូលចិត្តជាងគេនោះ។ សូមស្នើពួកគេឱ្យផ្ញើរការពិពណ៌នាសង្ខេបមួយ មកឱ្យអ្នក ដែលនិយាយអំពីសេចក្ដីអំណរដ៏អស្ចារ្យ ដែលពួកគេមាន ពេលកំពុងតែបំរើព្រះអម្ចាស់។

ជាការពិតណាស់ ដែលពួកលេមិនយ៉ាងច្រើន បានផ្លាស់គំនិតថ្វាយព្រះអម្ចាស់ ហើយបានធ្វើការលះបង់ជីវិតរបស់ពួកគេ ជាជាង លើកដាវរបស់គេឡើងម្ដងទៀត ដើម្បីបង្ហាញនូវការតាំងចិត្តដ៏គួរឱ្យស្ញប់ស្ញែងរបស់ពួកគេចំពោះព្រះអម្ចាស់។ នៅពេលអ្នកអាន នៅក្នុងអាលម៉ា 24 ចូរកត់សំគាល់ថា សកម្មភាព នៃអ្នកដែលមានភក្ដីភាព ហើយផ្លាស់ប្រែចិត្ត ពួកលេមិនបានជួយឱ្យពួកសាសន៍ លេមិន ជាច្រើនទៀត មានការប្រែចិត្តគំនិត។ ទោះជាយ៉ាងណាក៏ដោយ មិនមែនមានមនុស្សទាំងអស់ បានទទួលដោយសកម្មភាពរបស់ពួកគេទាំងអស់នោះទេ។ ពួកសាសន៍លេមិនផ្សេងទៀត (និងពួកសាសន៍នីហ្វៃ ដែលបានខ្ចាត់ខ្ចាយ) បន្តព្យាយាម ដើម្បីបំផ្លាញពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 27

ជាឥតប្រយោជន៍ (ខ. 1)—ឥតប្រយោជន៍

វិនាស (ខ. 10, 12)—ស្លាប់

សាកល្បង (ខ. 15)—ការសាកល្បងកំណត់ទៅក្នុងអារម្មណ៍របស់ពួកគេ

ប្រែចិត្ត (ខ. 18)—សេចក្ដីប្រែចិត្ត បន្ទាបខ្លួន

ចិញ្ចឹម (ខ. 24)—គាំទ្រ ផ្ដល់ជាសម្ភារៈសំរាប់

បានញែកចេញ (ខ. 26–27)—បានស្គាល់ បានសំគាល់

ចិត្តឧស្សាហ៍ ដែលមានចិត្តឧស្សាហ៍ (ខ. 27–30)—ចំណង់យ៉ាងខ្លាំង ការលះបង់

ការស្អប់ខ្ពើម (ខ. 28)—ស្អប់ ការស្អប់

និយាយឱ្យ (ខ. 28)—ធ្វើឱ្យទុកចិត្តអួសទាញ

ឈើចាប់ (ខ. 29)—ធូន់ ដោយឈើចាប់យ៉ាងខ្លាំង

វេទនា (ខ. 29)—បង្ខំ រំលោបបំពាន

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 27។

ក តើមានផែនការអ្វីខ្លះ?

នៅក្នុងតារាងខាងក្រោមនេះ នឹងជួយឱ្យតាមដានតាមបញ្ហា ដែលអាលម៉ាបានជួបប្រទះ ហើយនឹងផែនការ ដែលគាត់សំរេចចិត្ត ដើម្បីអនុវត្តន៍។ ចូរចម្លងនូវតារាងនេះ នៅក្នុងសៀវភៅសរសេររបស់អ្នក រួចបន្ទាប់មកប្រើគតិមាន នៅក្នុងអាលម៉ា 27:1–12 ដើម្បីជួយអ្នកបំពេញទៅក្នុងតារាងនោះ។



ខ តើមានគុណសម្បត្តិអ្វីខ្លះ?

1. យោងទៅតាម អាលម៉ា 27:18 តើអ្នកណា ដែលបានមានបទពិសោធន៍ នៃសេចក្ដីសប្បាយ និងសុភមង្គលលើសលប់ជាងគេ?
2. តើអ្នកណា ដែលមិនដឹងថាការបង្រៀន របស់អាលម៉ា 27:18 ត្រូវ ឬក៏ខុស ឬទេ?

គ សំគាល់នូវពាក្យ និងឃ្លាទាំងឡាយ

1. ចូរធ្វើបញ្ជីពាក្យ និងឃ្លាទាំងឡាយ មកពី អាលម៉ា 27:27–30 ដែលញែកខ្លួនចេញជាសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ដែលជាប្រជាជនអាំម៉ូន។
2. តើពាក្យ ឬឃ្លាទាំងអស់នោះ មួយណា ដែលអ្នកនឹងចង់ដឹងជាពិសេស? តើហេតុអ្វី?

អាលម៉ា 28

ពួកសាសន៍នីហ្វៃ
ការពារប្រជាជនរបស់អាំម៉ូន

ការអនុញ្ញាតឱ្យប្រជាជនរបស់អាំម៉ូនរស់នៅក្នុងដែនដី ជាកន្លែង ដែលពួកនីហ្វៃ ធ្លាប់បានរស់នៅយ៉ាងសុខស្រួល និងរីកចំរើន។ ប៉ុន្តែ តើវានឹងមានតំលៃអ្វី បើការសំរេចចិត្តមួយនេះ មានជាប់ទាក់ទងទៅនឹងការបាត់បង់ ឱពុកឬបងប្អូន នៅក្នុងសង្គ្រាម ដើម្បី ការពារពួកគេទាំងនោះ? អាលម៉ា 28 បង្ហាញយើងពីរបៀបដែលពួកនីហ្វៃបានធ្វើការតាំងចិត្ត ដើម្បីជួយអ្នកទាំងឡាយណា ដែលកំពុងតែត្រូវការជំនួយ ហើយកំពុងធ្វើអ្វី ដែលពួកគេដឹងថា ព្រះអម្ចាស់ចង់ឱ្យពួកគេធ្វើ។ ចូរធ្វើការយកចិត្តទុកដាក់ជា ពិសេសទៅលើខគម្ពីរចុងក្រោយគេ នៅក្នុងជំពូកនេះ ដែលញាការីមរមន បានរំលឹកពួកយើងថា ការរងទុក្ខនឹងទុក្ខព្រួយ ដែលយើងអាន នៅក្នុងអាលម៉ា 28 នោះមិនចាំបាច់ថា ត្រូវតែកើតឡើងនោះទេ។ គាត់ បានបញ្ជាក់ពីមូលហេតុពិតនៃរឿង ទាំងនេះ ហើយនឹង "ភាពមិនស្មើរគ្នា"—ដទៃទៀត ឬក៏ពាក្យម្យ៉ាងទៀតថា ហេតុអ្វីក៏មានព្រឹត្តិការណ៍ខ្លះកើតឡើងដោយ មិនត្រឹមត្រូវ ឬយុត្តិធិមដូច្នេះ។ គាត់បានរំលឹកយើងជងដែរអំពីអ្វី ដែលយើងអាចការពារទុកជាមុនកុំឱ្យព្រឹត្តិការណ៍ទាំងនេះ កើតឡើងមក។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 28

ការកាន់ទុក្ខដ៏ធំ (ខ. 4)—សេចក្តីទុកព្រួយដ៏ធំ ការទួញសោក

ដ៏សំខាន់ (ខ. 6)—សេចក្តីប្រាកដប្រជាសេចក្តី

មិនអាចថ្លែងអស់បាន (ខ. 8)—ដែលហាក់ដូចជាមិនអាចយល់បាន

ត្រូវរលួយ (ខ. 11)—ការពុករលួយ ការស្អុយរលួយ

ត្រូវដាក់ទៅក្នុង (ខ. 11)—ចាត់តាំងបានប្រព្រឹត្ត

វេទនា (ខ. 11)—សោកសង្រេងទុក្ខលំបាក

រំភើប (ខ. 12)—ប្រារព្ធ បង្ហាញនូវសេចក្តីសប្បាយ ពេញចិត្ត

ធ្វើឡើង ដើម្បីដាក់អន្ទាក់ (ខ. 13)—បានបង្កើត ឬគម្រោងដាក់អន្ទាក់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាអាលម៉ា 28។

ក ស្ថានភាពមតះ

នៅក្នុងអាលម៉ា 28:13 មរមនបានសរសេរសេចក្តីថ្លែងការណ៍មួយនៃសេចក្តីថ្លែងការណ៍ពីរ "ហើយហេតុនេះ យើងយើញថា"។ បន្ទាប់មក គាត់បានពន្យល់មេរៀនមួយ ដែលយើងអាចរៀនមកពីការពិពណិនាអំពីព្រឹត្តិការណ៍ទាំងនោះ។ នៅក្នុងពាក្យ សំដីរបស់ អ្នកផ្ទាល់ ចូរសង្ខេបមេរៀនដែលគាត់បានបង្រៀន ហើយពន្យល់ថាតើមេរៀននេះ មានទំនាក់ទំនងយ៉ាងណាខ្លះ ជាមួយនឹងព្រឹត្តការណ៍ផ្សេងៗ ដែលបានប្រាប់នៅក្នុងជំពូកនេះ។ នៅក្នុងអាលម៉ា 28:14 មានបន្ថែមនូវសេចក្តីថ្លែងការណ៍ពីរទៀត "ហើយ ហេតុនេះយើងយើញថា"។ អ្នកប្រហែលជាចង់ធ្វើជាការគូសចំណាំ សេចក្តីថ្លែងការណ៍ទាំងនោះ នៅក្នុងព្រះគម្ពីររបស់អ្នក។

អាលម៉ា 29

"ឱ ខ្ញុំចង់បានទៅជាទេវតាមួយ"

ការបំរើបេសកកម្ម ដែលប្រកបដោយកិត្តិយស បានផ្តល់ជាបទពិសោធន៍ យ៉ាងមានតម្លៃជាច្រើន និងឱកាសផ្សេងៗ សំរាប់ការរីក ចំរើនខាងវិញ្ញាណ។ ការបំរើ នាំឱ្យមានអារម្មណ៍មួយនៅក្នុងដួងចិត្ត ដែលពោរពេញទៅដោយសេចក្តីសប្បាយ។ នៅពេលអ្នកអាន អាលម៉ា 29 ចូរព្យាយាមដើម្បីយល់នូវសេចក្តីសប្បាយ ដែលអាលម៉ាមាននោះ នៅពេលគាត់គិតអំពីពរជ័យជាច្រើន ដែលបាន ប្រទានមកដល់គាត់ ហើយនឹងអ្នកដទៃទៀត ដោយសារតែគាត់ចូលរួមនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់។ អ្នកផ្សព្វផ្សាយសាសនាទាំងអស់សព្វថ្ងៃនេះ អាចមានអារម្មណ៍សប្បាយប្រភេទដូចគ្នា នៅពេលពួកគេ ផ្តល់ពរជ័យទៅដល់ អ្នកដទៃតាមរយះកិច្ច ការបំរើរបស់ពួកគេ។ ចូរកត់ចំណាំជងដែរ អំពីឥទ្ធិពលនៃសេចក្តីសប្បាយរបស់អាលម៉ា មានមកលើសេចក្តីប្រាថ្នារបស់គាត់។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 29

ពេញចិត្ត (ខ. 3)—បំពេញចិត្ត

ប្រទាន, ប្រទានឱ្យ (ខ. 3–4)—ផ្តល់ឱ្យ ចាត់ចែងឱ្យ

ខ្ចល់ខ្ចាយ (ខ. 4)—មានអារម្មណ៍ទារុណ ឬឈឺចាប់

មិនអាចកែប្រែ (ខ. 4)—មិនអាចផ្លាស់ប្តូរបាន

សេចក្តីសោកស្តាយនៃសតិសម្បជញ្ញះ (ខ. 5)—ស្តាយក្រោយ មានអារម្មណ៍ដឹងកំហុស

យើញថា ល្មមនឹងឱ្យ (ខ. 8)—មានអារម្មណ៍ថា សមរម្យ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរក្នុងសកម្មភាពខាងក្រោមនេះ (ក–គ) នៅពេលអ្នកសិក្សាអាលម៉ា 29។

ក ផ្តល់ជាយោបល់ខ្លះៗ

ការប្រើនូវអ្វី ដែលអ្នករៀនពីអាលម៉ា 29 រួចសរសេរសំបុត្រសំរាប់ជាការឱ្យជាយោបល់មួយ ដើម្បីឱ្យទៅយុវជនម្នាក់ នៅពេលគាត់ចេញដំណើរទៅតំបន់បេសកកម្មរបស់គាត់។ ចូរបន្ថែមគំនិតពីរយ៉ាងតិច ដែលដកមកពីអាលម៉ា 29 អំពីឥរិយាបទ នៃអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យម្នាក់។

ខ ការកត់ចំណាំពាក្យសំខាន់

ពាក្យ *ចងចាំ* មានបង្ហាញពីរទៅបីដងនៅក្នុងអាលម៉ា 29:10–13។ អ្នកប្រហែលជាចង់គូសចំណាំផ្នែកសំខាន់ នៅរាល់ពេល ដែលមានពាក្យនោះលេចឡើងមក។

1. តើអាលម៉ានៅចងចាំអ្វីខ្លះ? តើហេតុអ្វី គាត់ចងចាំរឿងទាំងនោះ?

2. តើអ្នកនៅចងចាំអ្វីខ្លះ ចំពោះពេលដែលអ្នកចង់ឱ្យមានអារម្មណ៍ នៃជីវភាពខាងវិញ្ញាណរបស់អ្នករីកចំរើនឡើងនោះ?

ក ឱ្យអត្ថន័យនៃពាក្យមួយ

យោងទៅតាមអាលម៉ា 29:13–17 តើអាលម៉ា បានឱ្យអត្ថន័យនៃពាក្យ *ដោតដំយ* ក្នុងការធ្វើជាអ្នកបំរើម្នាក់របស់ ព្រះអម្ចាស់—ដូចជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នោះមានន័យ យ៉ាងដូចម្តេចខ្លះ? (សូមមើល អាលម៉ា 8:15 អំពីអ៊ូ ដែលទេវតា ធ្លាប់ទៅដល់ អាលម៉ាជាមុននៅក្នុងជីវិតរបស់គាត់ ដែលជាមូលហេតុឱ្យគាត់មានសេចក្តីសប្បាយ ទោះបីជាការខំប្រឹងប្រែង របស់គាត់មើលទៅហាក់បីដូចជាមិនប្រកបដោយដោតដំយក៏ដោយ។)



"ប្រធាន អែសរ៉ា ថាប់ បិនសឺន បានរំលឹកដល់ពួកយើងថា ព្រះគម្ពីរមរមនបង្ហាញឱ្យឃើញពីសត្រូវរបស់ព្រះគ្រីស្ទ. . . . ព្រះគម្ពីរ មរមន ជួយធ្វើជាបន្ទាយនៃព្រះគ្រីស្ទឱ្យ តទល់ទៅនឹងតម្រោងអំពើអាក្រក់នៅក្នុងសម័យយើងនេះ។ ប្រភេទនៃការក្បត់សាសនា នៅក្នុងព្រះគម្ពីរមរមន មានភាពស្រដៀងគ្នាទៅនឹងប្រភេទ ដែលយើងមានសព្វថ្ងៃនេះ។ ចំពោះព្រះ អ្វីដែលទ្រង់ញាណគ្មានគឺ ព្រំដែនទេ ដូច្នេះឥទ្ធិពលនៃព្រះគម្ពីរមរមនបានបង្ហាញយើងឱ្យឃើញពីកំហុស និងជីវិតរបៀបដើម្បីប្រឆាំងទៅនឹងកំហុសនៃ ការអប់រំ នយោបាយសាសនា និងគំនិតទស្សនៈវិជ្ជាក្នុងពេលរបស់យើងឥឡូវនេះ" ("The Book of the Mormon Is the Word of God" Ensign, ខែមករា ឆ្នាំ 1988,3)។

អាលម៉ា 30 គឺដូចជាជំពូកមួយ ដែលបានមានប្រសាសន៍ ដោយប្រធាន ប៊ិនសឺន។ នៅក្នុងជំពូកនេះអ្នកនឹងរៀនអំពី អ្នកទទឹង នឹងព្រះគ្រីស្ទ ដែលការដាក់ទាំងឡាយ ដែលមានភាពស្រដៀងគ្នាទៅនឹងការបង្រៀន និងជំនឿរបស់មនុស្សខ្លះសព្វថ្ងៃនេះ។ នៅ ពេលអ្នកអាន ចូរស្វែងរកកំហុស នៅក្នុងតក្កវិជ្ជា ដែលគាត់ប្រើ ដើម្បីឱ្យមានកំហុស និងអំពើទុច្ចរិត បង្រៀនទៅធ្វើឱ្យអ្នកឈ្លាស វៃផ្សែងឮអាចទទួលយកបាន។ ជំពូកនេះ មានតម្លៃជាទីបំផុតដើម្បីជួយពួកយើងឱ្យកត់សំគាល់ ហើយបដិសេធនឹងការបង្រៀន ខុសនៃសម័យរបស់យើង។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 30

ជំទាស់ (ខ. 7)—ប្រឆាំង ផ្ទុយ

ទីម (ខ. 13, 28)—ទំនាក់ទំនង

ជីឆ្កួតវង្វេងមួយ (ខ. 16)—ភ្ញាក់ផ្អើល និងយល់ច្រលំ

វិកលភាព (ខ. 16)—ឆ្កួត ឬស្ថានភាពច្របូកច្របល់

រស់នៅ (ខ. 17)—មានជីវិតរស់នៅ

ការរេរែចចំនែខ្លួន (ខ. 17)—ប្រើការត្រួតពិនិត្យទៅលើសកម្មភាពរបស់មនុស្សម្នាក់

ធ្វើឱ្យគេងើយក្បាល (ខ. 18, 23)—មិនមានអារម្មណ៍ជីវកំហុស មានអំនួត

ដើរបង្ខិចផ្លូវ បានបង្ខិចផ្លូវ (ខ. 22, 60)—ការផ្លាស់ប្តូរ ភាពពុករលួយ

ជណ្តើម (ខ. 23)—ដែលមិនយុត្តិធម៌ ឬយកអំពើហឹង្សា

បំពាន ចង់បំពានខ្លួន (ខ. 27, 31–32)—ធ្វើច្រើនជាងអ៊ូ ដែលត្រូវការរស់នៅក្នុងភាពប្រណិតដែលហួសប្រមាណ

រវើរវាយ (ខ. 28)—ចំណាង់ក្តាមឮ ដោយគ្មានគិត

បណ្តុះបង្អាប់ (ខ. 29, 31)—ជេរប្រមាថ រិះគន់

ការប្រមាថ (ខ. 30)—និយាយអំពីវត្ថុពិសិដ្ឋដោយមិនមានការគោរព

ពាក្យក្រអោង (ខ. 31)—កាន់តែញុះញង់ឱ្យឡើង និងមានចំណាងយ៉ាងខ្លាំងក្លា

ទ្វារគ្រប់កលល្បិច (ខ. 42)—ផែនការគម្រោងការណ៍

បង្ហាញថា (ខ. 44)—បង្ហាញភស្តុតាង ចង្អុលបង្ហាញ

គ (ខ. 47, 49, 52)—មិនអាចនិយាយបាន

ចេញវាចា (ខ. 49–50)—មានលទ្ធភាពនិយាយបាន

លោកីយ (ខ. 53)—ខាងលោកីយ មិនមែនខាងវិញ្ញាណ

អាលម៉ា 30:12–50 ការរិះគន់សាសនាចក្រ និងការស្វែងរកទីសំគាល់

ក្យាការីយ៉ូសែប ស៊្មីធ បានបង្រៀនថាៈ "មនុស្សដែលឆើបឆៀង ដើម្បីបន្ទោសអ្នកដទៃ ស្វែងរកកំហុសទាស់និងសាសនាចក្រ ដោយនិយាយថាអ្នកដទៃជាមនុស្សកែមិនរួច ដែលគិតថាខ្លួនឯងជាមនុស្សសុចរិត ខណៈនោះយើងដឹងយ៉ាងច្បាស់ថា មនុស្សម្នាក់ នោះ ស្ថិតនៅលើផ្លូវមួយដ៏ខ្ពស់ឆ្ពោះទៅរកការក្បត់សាសនាហើយ បើសិនគាត់មិនព្រមកែប្រែចិត្តទេ នោះនឹងមានការក្បត់សាសនា ក្នុងគ្រាដែលព្រះមានព្រះជន្មរស់។ គោលលទ្ធិ គឺត្រឹមត្រូវដូចជាព្រះបន្ទូលមួយ ដែលព្រះយេស៊ូវបានមានបន្ទូលថា អ្នកណា "ស្វែង រកទីសំគាល់ គឺជាមនុស្សកំផិតហើយ" ហើយដែលគោលលទ្ធិ គឺអស់កល្បជានិច្ច មិនងាករេ និងរឹងមាំដូចជាសរសរនៃឋានសួគ៌ ពេលណាក៏ដោយដែលអ្នកឃើញមនុស្សម្នាក់កំពុងស្វែងរកទីសំគាល់នោះ អ្នកអាចសរុបសេចក្តីមកថា គាត់ជាមនុស្សកំផិត" (*Teaching of the prophet Joseph Smith,* 156–57)។ សេចក្តីពិតនៃសេចក្តីថ្លែងការណ៍របស់គាត់ អាចរកបាន នៅក្នុងអាលម៉ា 30:18,53។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ ហើយបន្ទាប់មកធ្វើសកម្មភាព គ ឬ ឃ នៅពេលអ្នកសិក្សាអាលម៉ា 30។

ក ពន្យល់អំពីឥទ្ធិពលនានា

អែលឌើរ ប៊ិយ ខេ ប៉ាកគឺ សមាជិកនៃក្រុមសាវកដប់ពីរនាក់ បានបង្រៀនថាៈ "ការយល់ដឹងអំពីគោលលទ្ធិពិត អាចផ្លាស់ប្តូរ អាកប្បកិរិយា និងឫកពា" (នៅក្នុង Conference Report ខែតុលា ឆ្នាំ1986, 20 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ1986, 17)។ ប្រហែលជាមានន័យផងដែរថា ការផ្សើទៅលើគោលលទ្ធិ *មិនពិត* នឹងអាចផ្លាស់ប្តូរអាកប្បកិរិយា និងឫកពាមនុស្សម្នាក់បានដែរ។ យើងអាចមើលអំពីនេះ នៅក្នុងដំណើររឿងរបស់កូរីហ៊ូរ។

1. ចូរធ្វើជាតារាងមួយ ដែលមានកូឡោនបួន ដូចជាតារាងមួយនៅខាងក្រោមនេះ។ នៅក្នុងកូឡោនទីមួយ ចូរធ្វើជាបញ្ជីយ៉ាងតិច ចំនួនព្រាំ នៃគោលលទ្ធិ ឬការបង្រៀនរបស់កូរីហ៊ូរ

បានប្រកាសដូចជាសេចក្តីពិតនោះ នៅក្នុងអាលម៉ា 30:13–18។ នៅក្នុង កូឡោនទីពីរ ចូរសរសេរពីអ្វី ដែលមានឥទ្ធិពលដល់ការជ្បឿរបស់អ្នកថា គោលលិទ្ធិនឹងមានអាកប្បកិរិយា និងឬកពារបស់ មនុស្សម្នាក់។ នៅក្នុងកូឡោនទីបី ចូរសរសេរអំពីគោលលិទ្ធិពិត។ បន្ទាប់មក នៅក្នុងកូឡោន ក្រោយគេ ចូរសរសេរអំពីឥទ្ធិពល ដែលគោលលិទ្ធិពិតទាំងនេះដូចជាមានទូវ អាកប្បកិរិយា និងឬកពារបស់មនុស្សម្នាក់ដែរ។

ឥទ្ធិពល នៃសេចក្តីពិត និងគោលលិទ្ធិមិនពិត			
គោលលិទ្ធិមិនពិតរបស់កូរីហ៊ូរ	ឥទ្ធិពលចំពោះអាកប្បកិរិយា និងឬកពា	គោលលិទ្ធិពិត	ឥទ្ធិពលចំពោះអាកប្បកិរិយា និងឬកពា

2. យោងទៅតាមអាលម៉ា 30:17–18 តើកូរីហ៊ូរកំពុងមានឥទ្ធិពល ឬសង្ឃឹមថា នឹងមានឥទ្ធិពល ទៅលើអាកប្បកិរិយា និងឬកពារបស់មនុស្សបានយ៉ាងដូចម្តេចខ្លះ?

ក ការអធិប្បាយអំពីបញ្ហានៅក្នុងតក្កវិជ្ជា

នៅពេលមនុស្សមានការដែក ពួកគេជាញឹកញាប់ព្យាយាម ប្រើតក្កវិជ្ជា ដើម្បីបង្ហាញថា ពួកគេមានការទទួលខុសត្រូវអ្វី ចំពោះមុខ តំណែងរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការដែកអំពីតក្កវិជ្ជា ចាប់ផ្តើមដាមួយនឹងគំនិតព្រាកដប្រជាផ្សេងៗ ដែលមនុស្សម្នាក់មានជំនឿ ឬស្មានថាជាសេចក្តីពិត។ កូរីហ៊ូរមិនមានសេចក្តីសង្ឃឹម។ គាត់បានធ្វើ "ជាតក្កវិជ្ជា" ពីរ មានរួមទាំង អាលម៉ា 30:12–18។ ពួកគេអាចចង្អុលបង្ហាញជាលទ្ធផល នៃតក្កវិជ្ជារបស់គាត់ ហើយមានការដែក នៅពេលគាត់និយាយ "ហេតុដូច្នេះ" ឬដោយពាក្យម្យ៉ាងទៀត "យើងត្រូវតែរាប់បញ្ចូលតក្កវិជ្ជានោះ។"

1. ចូរកត់សំគាល់អំពីទីបញ្ចប់របស់កូរីហ៊ូរ នៅក្នុង ខ 15។ បន្ទាប់មកកត់សំគាល់ពីអ្វី ដែលគាត់បានស្មានថា ជាការពិត នៅទីបញ្ចប់។
2. ចូរកត់សំគាល់អំពីទីបញ្ចប់របស់កូរីហ៊ូរ នៅក្នុង ខ. 17។ បន្ទាប់មកកត់សំគាល់ពីអ្វី ដែលគាត់គិតស្មានថា ជាការពិត នៅទីបញ្ចប់។
3. តើ ការស្មានរបស់កូរីហ៊ូរមានបញ្ហាអ្វីខ្លះ អំពីសេចក្តីពិតនោះ?
4. កូរីហ៊ូរបានសួរទៅអ្នកមានជំនឿទាំងឡាយ អំពីរឬប្រ ដែលពួកគេដឹងដោយពិត ពីអ្វីដែលពួកគេជ្បើថា ពិតនោះ។ យើងក៏អាចសួរដូចជាកូរីហ៊ូរដែរ។ ចូរកត់ចំណាំ អំពីអ្វី ដែលអាលម៉ាបានសួរគាត់ នៅក្នុង ខ 40។ តើមានភស្តុតាងអ្វី ដែលអាលម៉ាផ្តល់ ខ 41 និង44 អំពីអ្វី ដែលគាត់ (អាលម៉ា)ជ្បើថា ជាការពិតនោះ?

ខ តើមនុស្សនៅសព្វថ្ងៃនេះអាចនិយាយយ៉ាងដូចម្តេចដែរ?

ចូរធ្វើជាតារាងអំពីសេចក្តីថ្លែងរបស់កូរីហ៊ូរ នៅក្នុងអាលម៉ា 30:12–18, 23–28 ដែលប្រជាជននៅតែប្រើ នៅពេល មានការដែកទាស់ជាមួយនឹងសេចក្តីពិតនៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទសព្វថ្ងៃនេះ។ បន្ទាប់មកធ្វើជាតារាងជាសេចក្តីថ្លែង ទីមួយៗមកពីកូរីហ៊ូរ ចូរសរសេរពីរឬប្រ ដែលប្រជាជនប្រើការដែកដូចគ្នានេះនៅក្នុងពេលបច្ចុប្បន្ន។

ឃ ផ្តល់ការគាំទ្រចំពោះការបញ្ចប់នេះ

នៅក្នុងអាលម៉ា 30:60 មរមនបានពន្យល់អំពីអ្វី ដែលគាត់ចង់ឱ្យយើងរៀនពីគំរូរបស់កូរីហ៊ូរ។ ចូររប្រើអ្វីដែលអ្នកបានរៀន នៅក្នុងអាលម៉ា 30 ដើម្បីធ្វើជាចម្លើយមួយអំពីអ្វី ដែលនឹងគាំទ្រចំពោះសេចក្តីពិតនៃសេចក្តីថ្លែងការណ៍របស់មរមន។

អាលម៉ា 31

បេសកកម្មទៅដល់ពួកសាសន៍សូរាំ

នៅទីបញ្ចប់នៃអាលម៉ា 30 យើងដឹងថា កូរីហ៊ូរស្លាប់ នៅពេលកំពុងសុំទាន ក្នុងចំណោមប្រជាជនមួយ ដែលហៅថា ពួកសាសន៍ សូរាំ។ នៅក្នុងអាលម៉ា 31 យើងអានអំពីអាលម៉ា និងអ្នកដទៃទៀតកំពុងធ្វើដំណើរទៅ ប្រកាសដំណឹងល្អ ក្នុងចំណោមពួកគេ។ ថ្វីបើ ពួកគេបានដាន់ឈ្លីកូរីហ៊ូរនៅក្រោមជើងរបស់ពួកគេក៏ដោយ គំនិតរបស់កូរីហ៊ូរដារច្រើន បានបង្ហាញចេញមកនៅក្នុង សាសនានៃពួកសាសន៍សូរាំ។ ចូរស្វែងរកគំនិតទាំងនោះ នៅពេលអ្នកអាននៅក្នុងជំពូកនេះ។ អ្នកនឹងអានការអធិស្ឋានពីរដង្ហុយគ្នា នៅក្នុងអាលម៉ា 31 ផងដែរ។ នៅពេលធ្វើដូច្នេះ ចូរពិចារណាអំពីអ្វី ដែលការអធិស្ឋានទាំងនោះ បង្ហាញអំពីមនុស្ស ដែលបានធ្វើ ការអធិស្ឋាន។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 31

ជំណឹងល្អ (ខ. 1)—ដំណឹងល្អ ពតិមាន

ការទាក់ទង (ខ. 4)—ទំនាក់ទំនងផ្ទៃក្នុង និងការទំនាក់ទំនង

ដែលបែកចេញ (ខ. 8)—ប្រឆាំង, អ្នករត់ចោល

ការទូលអង្វរ (ខ. 10)—ការអង្វរ

បានរើស (ខ. 16–17)—ការជ្រើសរើសជាពិសេស

ព្រួយបារម្ភ (ខ. 24)—ទុក្ខព្រួយ

អួតខ្លួន (ខ. 27)—ពោរពេញដោយអំនួត និងភាពឥតប្រយោជន៍

អំពើមិនស្មោះត្រង់ (ខ. 30)—ខ្វះភាពស្មោះត្រង់ ឬសេចក្តីស្មោះត្រង់

សេចក្តីទន់ខ្សោយ ទន់ខ្សោយ (ខ. 30)—សេចក្តីទន់ខ្សោយ

ស៊ូទ្រាំ (ខ. 33)—អត់ធ្មត់

លោកទះដៃទៅលើពួកគេ (ខ. 36)—ដាក់ដៃរបស់គាត់នៅលើក្បាលពួកគេ សំរាប់ពរជ័យបពូជិតភាព

អាលម៉ា 31:3—ពួកសាសន៍សូរាំ

នៅក្នុងស្បៃវែកៅមរមន មានមនុស្សពីរក្រុម ហៅថា ពួកសាសន៍សូរាំ។ ទីមួយ គឺជាពូជពង្សរបស់សូរាំ ដែលជាអ្នកបំរើរបស់ ឡាបាន់ ដែលជាអ្នកចាកចេញពីក្រុងយេរូសាឡិម ជាមួយនីហ្វៃ។ ទីពីរ គឺជាអ្នកដើរតាមពួកនីហ្វៃមួយក្រុមដែលជាអ្នកក្បត់ សាសនាឈ្មោះ ថា សូរាំ ដែលដឹកនាំប្រជាជនឱ្យប្រឆាំងជាមួយនឹងពួកនីហ្វៃ និងផ្លូវនៃព្រះអម្ចាស់។

អាលម៉ា 31:5—"ព្រះចេស្តានៃព្រះបន្ទូល"

វាជាការគួរឱ្យចាប់អារម្មណ៍ ដើម្បីកត់ចំណាំថា អាលម៉ា បានរិះរកវិធី ដើម្បីដោះស្រាយ បញ្ហានយោបាយមួយ ដោយការ ព្យាបាលខាងវិញ្ញាណ។ ពួកនីហ្ចែព្រួយបារម្ភថា ពួកសាសន៍សូរាំ នឹងចាក់រុកឱ្យពួកលេមិន ធ្វើសង្គ្រាមប្រឆាំងនឹងពួកគេ។ អាលម៉ាមានអារម្មណ៍ថា វិធីដែលល្អបំផុត ដើម្បីការពារនោះ គឺការប្រកាសដំណឹងល្អទៅដល់ពួកសាសន៍សូរាំ ដើម្បីឱ្យពួកគេ មានបទពិសោធន៍ នៃការផ្លាស់ប្តូរចិត្ត។ អាលម៉ា បានជ្រើសរើសធ្វើការដោះស្រាយទៅលើអ្វី ដែលបណ្តាលឱ្យមានបញ្ហា មិន មែនទៅលើរោគសញ្ញានោះទេ។

នៅក្នុងប្រសាសន៍ ដែលឱ្យឈ្មោះថា "ព្រះដេស្តានៃព្រះបន្ទូល" ដោយប្រធានអើសរ៉ា ថាប់ប៉ែនសឹន បានផ្តល់ជាយោបល់ ទៅដល់អ្នកដឹកនាំបពូជិតភាព អំពីការដោះស្រាយលើឬសគល់នៃ បញ្ហានៅក្នុងសាសនាចក្រៈ "ជារឿយៗយើងបានចំណាយ កំលាំងយ៉ាង ច្រើនក្រៃលែងក្នុងការព្យាយាម ដើម្បីបង្កើនកំពស់សកម្មភាពនៅក្នុងសង្កាត់របស់យើង។ យើងធ្វើការយ៉ាងយកចិត្តទុកដាក់ ដើម្បីបង្កើនភាគរយនៃអ្នកចូលរួមក្នុងការប្រជុំក្នុងប្រសិទ្ធិពរនំប៉ុង និងទឹក។ យើងធ្វើការងារ ដើម្បីទទួលយក ភាគរយខ្ពស់ជាង យុវជនរបស់យើងទៅបេសកកម្ម។ យើងខំប្រឹងព្យាយាមដើម្បីបង្កើនចំនួននៃអ្នករៀបការនៅក្នុងព្រះវិហារ បរិសុទ្ធ។ ទាំងអស់នេះ គឺជាការខំប្រឹងប្រែងដ៏គួរឱ្យកោតសរសើរ ហើយដែល សំខាន់ ដើម្បីឱ្យនគរីកចំរើន ឡើង។ ប៉ុន្តែ នៅពេលសមាជិកម្នាក់ឲ និងក្រុមគ្រួសារពន្លិចខ្លួនពួកគេ នៅក្នុងការអានព្រះ គម្ពីរជាទៀងទាត់ និងជាប់លាប់នោះ គំបន់ដទៃទៀតនៃសកម្មភាពនឹងមកដោយស្វ័យប្រវត្តិតែម្តង។ ទីបន្ទាល់នឹងបង្កើនឡើង។ ការតាំងចិត្តនឹងបានរឹងមាំ។ ក្រុមគ្រួសារនឹងបានរឹងប៉ុង។ វិវរណៈផ្ទាល់ខ្លួននឹង—(*Ensign* ខែឧសភា ឆ្នាំ1986, 81)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 31។

ក្ស សរសេរឧទាហរណ៍មួយ

នៅក្នុងអាលម៉ា 31:5 អ្នកដឹងថា អាលម៉ាបានជៀដល់បន្ទូលរបស់ព្រះថា មានព្រះដេស្តា ដើម្បីបំផុសគំនិតមនុស្សឱ្យធ្វើអ្វី ដែល ដាវ ឬកម្លាំងនៃឧប្បករណ៍ដទៃទៀតមិនអាចធ្វើបាន។ ចូរផ្តល់ឧទាហរណ៍មួយ ក្នុងជីវិតអ្នកផ្ទាល់ ដោយបង្ហាញពីរបៀប ដែលព្រះគម្ពីរ ឬការបង្រៀនរបស់អ្នកដឹកនាំ នៃសាសនាចក្រ បានបណ្តាលចិត្តអ្នក ឱ្យប្រព្រឹត្តិនៅក្នុងផ្លូវមួយ ដែលគ្មាន មនុស្សណាម្នាក់ អាចមកបង្ខំអ្នកឱ្យប្រព្រឹត្តិ ឬធ្វើអ្វីបានឡើយ។

ខ បង្កើតការទំនាក់ទំនងមួយ

ចូរសរសេរឃ្លា មកពីអាលម៉ា 31:8–20 ដែលបង្ហាញពីរបៀប នៃការបង្រៀន និងការអនុវត្ត អំពើទុច្ចរិតរបស់ពួកសាសន៍សូរាំ មាន ភាពស្រដៀងគ្នាទៅនឹងអ្វី ដែលកូរីហូរបានបង្រៀន។ បន្ទាប់ពីឃ្លានីមួយៗ ចូរសរសេរលេខ នៃខគម្ពីរមួយមកពីអាលម៉ា 30 ដែលកូរីហូរ ជាអ្នកបង្រៀន គំនិតនោះ។

គ្ស ធ្វើការប្រៀបធៀបមួយ

ចូរប្រៀបធៀបពីអាកប្បកិរិយា និងការអធិស្ឋាន នៃពួកសាសន៍សូរាំ នៅក្នុងអាលម៉ា 31:13–18, 23 ទៅនឹងអាកប្បកិរិយា និង ការអធិស្ឋានរបស់អាលម៉ា នៅក្នុងអាលម៉ា 31:24–38។ សូមបញ្ចូលការប្រៀបធៀបរបស់អ្នក យ៉ាងតិចនូវចំនួនពីររបៀប សំខាន់ៗ ដែលមានភាពខុសគ្នា។ នៅទីបញ្ចប់ សូមសរសេរពីអ្វី ដែលអ្នកគិតថា អ្នកអានសម័យទំនើបនេះ គួរតែរៀន ដើម្បីជួយ ពួកគេចេះគោលការណ៍ នៃការអធិស្ឋាន។

អាលម៉ា 32
ធ្វើការពិសោធន៍ដល់ពាក្យសំដី

នៅក្នុងអាលម៉ា 31 អ្នកអានអំពីកិច្ចការផ្សព្វផ្សាយសាសនា ក្នុងចំណោមពួកសាសន៍សូរាំ។ បើអ្នកជាអាលម៉ា តើអ្វីទៅ ដែលអ្នក ចង់បង្រៀនទៅដល់ពួកគេ? តើអ្នកនឹងបង្រៀន យ៉ាងដូចម្តេច?

អាលម៉ា 32 គឺជាវត្ថុសំណប់របស់អ្នកផ្សព្វផ្សាយសាសនា ព្រោះជំពូកនេះ បានជួយពន្យល់ទៅមនុស្ស ដែលពួកគេបង្រៀន អំពីរបៀប ដែលពួក គេអាចមករកចំណេះដឹងនៃសេចក្តីពិតដ៏ពេញលេញ នៃគោលការណ៍ដំណឹងល្អ។ ទោះជាយ៉ាងណាក៏ដោយ វាមិនមែនសំរាប់តែអ្នកស្វែងយល់ពីសាសនានៃសាសនាចក្រប៉ុណ្ណោះទេ។ យើងទាំងអស់គ្នា—ដោយមិនគិតពីកំពស់ នៃជីវភាពខាងផ្លូវវិញ្ញាណ—អាចអនុវត្តគោលការណ៍ទាំងឡាយ ដែលអាលម៉ាបានបង្រៀននៅក្នុងជំពូកនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 32

ពុំល្អ (ខ. 2)—ភាពគ្រោកគ្រាត ភាពរាប

សំលៀកបំពាក់ (ខ. 2)—សំលៀកបំពាក់

មើលងាយ (ខ. 3)—មិនឱ្យតម្លៃ

ជាឥតប្រយោជន៍ (ខ. 3)—ឥតតម្លៃ ឬមិនសូវមានប្រយោជន៍

ស្អប់ (ខ. 5, 12)—មិនចូលចិត្ត ស្អប់

បានប្រែចិត្ត (ខ. 7)—កែប្រែចិត្ត បន្ទាបខ្លួន

ត្រូវគេបង្ខំ (ខ. 13–16, 25)—បង្ខំដោយព្រឹត្តិការណ៍ផ្សេងៗ

រំលែក (ខ. 23)—ផ្តល់ឱ្យ

បានបំភាន់ (ខ. 23)—ច្របូកច្របល់

ពង្រីកនូវសម្ថភាពរបស់អ្នក (ខ. 27)—ឱ្យវាងវៃ និងតាំងចិត្ត

សមូំនៅស្ឋេម (ខ. 34)—អសកម្ម មិនប្រើ

អាចញែកចេញបាន (ខ. 35)—ដែលគួរឱ្យយោគយល់ ស្តែងឱ្យឃើញ

ឥតជីជាតិ (ខ. 39)—មិនមានឱ្យផល ដោយគ្មានវត្ថុសំរាប់ធ្វើការថែទាំ ឱ្យរីកលូតលាស់

ច្រូតកាត់ (ខ. 43)—ផល ប្រមូល



អាលម៉ា 32:21–22—តើមានភាពខុសគ្នាអ្វីខ្លះ រវាង ជ្រឿ ជំនឿ និងចំណេះដឹង?

ជ្រឿ អាចជាការទទួលរងអំពើ ដែលគ្រាន់តែបានទទួលស្គាល់ថា អ្វីមួយជាការពិត នៅពេលជំនឿ នោះគឺជាសេចក្តីពិតមែន។ ជំនឿតំរូវឱ្យជ្រឿ និងទុកចិត្ត។ វាផ្តល់ ឱ្យយើងមានការជ្រឿជាក់ ហើយមានជំនឿសឹប់ និងនាំឱ្យយើងធ្វើសកម្មភាព។ យើងមិន អាច មានជំនឿ ដោយមិនជ្រឿនោះទេ ប៉ុន្តែយើងអាចជ្រឿ ហើយមិនមានជំនឿបាន។ ហេតុដូច្នេះ ត្រឹមតែជ្រឿទៅលើព្រះយេស៊ូវ គ្រីស្ទ វាមិនទាន់គ្រប់ គ្រាន់នៅឡើយទេ។ ដើម្បីឱ្យដំណឹងល្អ ផ្តល់ពរជ័យដល់ជីវិតរបស់យើង យើងត្រូវតែ មានជំនឿថា ដំណឹងល្អ បានបណ្តាលចិត្តឱ្យ ពួកយើងចង់ធ្វើតាមទ្រង់។ ចំណេះដឹង ចូលចិត្តជ្រឿ ត្រូវការសកម្មភាព ដើម្បីជាប្រយោជន៍ ដល់យើង។ ជាធម្មតា ការដឹងថា អ្វីមួយ ដែលអាចជួយ ឬធ្វើទុក្ខទោសដល់យើង មិនល្អសំរាប់យើងទេ លុះត្រាតែយើងអនុវត្ត ចំណេះដឹង ទាំងនោះ។ មាន ចំណេះដឹង ជាពិសេសមួយ ដែលនឹងមក នៅពេលយើងអនុវត្តជំនឿ ហើយស្វែងរក ដើម្បីរស់នៅ ក្នុងដំណឹងល្អ។ នៅពេលយើងធ្វើសកម្មភាព ការជ្រឿជាមួយនឹងជំនឿរបស់យើង ធ្វើឱ្យព្រះវិញ្ញាណ នឹងប៉ះដួងចិត្ត និងគំនិតរបស់យើង។ យើងទទួលបានសាក្សីខាងវិញ្ញាណមកពីព្រះវិញ្ញាណបរិសុទ្ធ ដែល ធ្វើយើងអាចនិយាយ "យើងដឹង" ថាព្រះគ្រីស្ទជា ព្រះអង្គសង្គ្រោះ និងថាសាសនាចក្រនេះពិត។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 32។

ក ចំណេះចំណានព្រះគម្ពីរ—អាលម៉ា 32:21

1. ចូរសរសេរឧទាហរណ៍មួយ ដោយមានគូសបង្ហាញពីរបៀប ដែលការគោរពប្រតិបត្តិ ចំពោះ ព្រះបញ្ញត្តិទាំងឡាយ នៃព្រះ បង្ហាញពីជំនឿរបស់មនុស្សម្នាក់។ នៅក្នុងឧទាហរណ៍របស់អ្នក ចង្អុលបង្ហាញអំពីនិស្ស័យមនុស្សម្នាក់ ដែលមិន "មានចំណេះដឹង ដ៏ឥតខ្ចោះ" ប៉ុន្តែមាន "សង្ឃឹមទៅលើអ្វីព្រ ដែលមើលមិនឃើញ ហើយពិត។"
2. ឧបមាថា អ្នកកំពុងនិយាយអំពីជំនឿជាមួយនឹងមិត្តម្នាក់។ អ្នកបានផ្តល់ និយមន័យរបស់អាលម៉ា អំពីជំនឿនៅក្នុង អាលម៉ា 32:21 ឱ្យទៅមិត្តអ្នក។ បន្ទាប់មក មិត្តរបស់អ្នកសួរថា "ប៉ុន្តែ តើអ្នកអាច ដឹងពីអ្វីមួយ ដែលមើលមិនឃើញ ហើយពិតបាន ដោយរបៀបណា?" តើអ្នកនឹងឆ្លើយ ដូចម្តេច? សូមផ្តល់ជាឧទាហរណ៍ជាក់លាក់មួយ នៃអ្វីមួយ ដែលអ្នកដឹងថាពិត ប៉ុន្តែមើលមិន ឃើញ។

ខ សរសេរការបង្រៀនណែនាំ

ចូរសរសេរការបង្រៀនណែនាំជាដំណាក់ព្រ សំរាប់ "ធ្វើការពិសោធន៍" ដូចអាលម៉ាបានពិពណិនា នៅអាលម៉ា 32:27–43។ ចូរឱ្យប្រាកដថា អ្នកមានបញ្ជូលទាំងការដាស់តឿន ចំពោះអ្វី ដែលនឹង រារាំងមនុស្សម្នាក់មិនឱ្យទទួលបានលទ្ធផលរុងរឿង នោះ។

គ ចូរស្វែងរក ហើយពន្យល់ពីគំនិតដដែល

ចូរស្វែងរកពាក្យចំនួនបី ដែលបង្ហាញនៅក្នុងខគម្ពីរនីមួយព្រ នៃអាលម៉ា 32:41–43។ ចូរពន្យល់ ពីអ្វី ដែលអ្នកគិតថា អាកប្បកិរិយា និងគុណសម្បត្តិទាំងបីនោះ នីមួយព្រសំខាន់នៅក្នុង ដំណើរការរីកចំរើនខាងវិញ្ញាណ និងការយល់ដឹង។ អ្នកប្រហែល ជាចង់គូសចំណាំពាក្យទាំងនោះ នៅក្នុងព្រះគម្ពីររបស់អ្នក។

អាលម៉ា 33

ពាក្យទាំងឡាយ ដែលពួកគេគួរតែបណ្តុះឡើង

នៅក្នុងអាលម៉ា 32 អាលម៉ាបានបង្រៀនពួកសាសន៍សូរាំ អំពីដំណើរការ នៃការរីកចំរើន ក្នុងជំនឿ ខាងវិញ្ញាណ និងចំណេះ ដឹង។ គាត់បានលើក ទឹកចិត្តពួកគេ ឱ្យបណ្តុះសេចក្តីពិតនៃដំណឹងល្អ នៅក្នុងចិត្តរបស់ពួកគេ តាម រយៈបន្ទូលនៃព្រះ រួចហើយ ពន្យល់ថា តើគ្រាប់ល្អិត នៃបន្ទូលនៃព្រះនោះ អាចដុះជាដើមឈើនៃពន្លឺយ៉ាងធំ សេចក្តីអំណរ និងជីវិតជារៀងរហូតមួយ បានយ៉ាងដូចម្តេច។ នៅក្នុងអាលម៉ា 33 យើងអានអំពីសេចក្តីពិតនៃ ដំណឹងល្អយ៉ាងជាក់លាក់មួយ ដែលគាត់ចង់ឱ្យពួកគេ "បណ្តុះ" នៅពេល នោះ។ ចូរកត់សំគាល់ថា របៀប នៃការបង្រៀនរបស់អាលម៉ាបាន ឆ្លើយយ៉ាងច្បាស់ រាល់សំនួរ និងបញ្ហា ដែលគាត់យើញនៅចំណោម ពួកសាសន៍សូរាំ នៅក្នុងអាលម៉ា 31–32។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 33

គិតខុសយ៉ាងធំ (ខ. 2)—ធ្វើ កំហុសធំមួយ

បានប្រទាន (ខ. 16)—បានផ្តល់ឱ្យ ចែករំលែក

និមិត្តរូប (ខ. 19)—សញ្ញា ភាពដូចគ្នា

ចោលភ្នែកមើល (ខ. 21)—មើលជុំវិញ

ខ្ជិលច្រអូស (ខ. 21)—ខ្ជិល

អាលម៉ា 33:3–17—លោកស៊ីណូស និងលោកស៊ីណុក

សូមមើល វគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" ចំពោះ នីហ្វៃទី1 19:10 (ទំព័រ 30)។

អាលម៉ា 33:18–22—តើហេតុអ្វី បានជាលោកម៉ូសេ លើកពស់ នៅលើបង្គោលឡើង?

អែលឌើរ ប្រ្វិស អរ មិកខនឃី ជាសមាជិកម្នាក់នៅក្នុងក្រុមសាវកដប់ពី នាក់បានបង្រៀនថាះ "លោកម៉ូសេ នៅក្នុងទីរហោដ្ឋាន នៅពេលព្រះអម្ចាស់ចាត់ឱ្យពស់ភ្លើងហោះចុះមកក្នុងចំណោម ពួកគេ ដើម្បីឱ្យចឹក និងសម្លាប់ប្រជាជនអ៊ីស្រាអែល ជាច្រើន ពស់មួយនោះ ធ្វើឡើងពីលង្ហិន ហើយដាក់នៅលើបង្គោល។ បន្ទាប់មកអ្នកទាំងអស់ណា ដែលត្រូវចឹកដោយសត្វលូន មានពឹស និងអ្នក ដែលបានមើល ដោយជំនឿលើពស់លង្ហិនបានរស់ អ្នកណាដែលមិនមើលត្រូវស្លាប់។ តើ ហេតុអ្វី? ដោយសារម៉ូសេ ត្រូវបានបញ្ជា ដោយព្រះ ឱ្យធ្វើដូច្នោះ ហើយរឿងនេះ ជាពិធីការ នៅ ក្នុងសាសន៍អ៊ីស្រាអែល—ជាពិធីការមួយ ដែលធ្វើឡើង នៅក្នុងនិមិត្តរូប នៃ សេចក្តី ដែលបាន សន្យាថា ព្រះមែស៊ី នឹងត្រូវគេលើកឡើងឈើឆ្កាង ហើយអ្នកទាំងឡាយណា ដែលមើល ទៅទ្រង់ ដោយជំនឿ នឹងរស់ៈ អ្នកណាដែលមិនជ្រឿនឹងស្លាប់" (*The Mortal Messiah: From Bethlehem to Calvary*, វ៉ុលទី 4។ [1979–81], 1:476–77)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សា អាលម៉ា 33។

ក ជំណោះស្រាយរបស់ព្រះ

1. នៅអាលម៉ា 31:8–23 និង 32:2–5 យើងអានអំពីបញ្ហារបស់ពួកសាសន៍សូរាំ និងផ្លូវ ដែលពួកគេជាច្រើន បានដើរ វង្វេងបាត់ទៅ។ ចូរគូសសំគាល់ យ៉ាងហោចណាស់បញ្ហាពីរ ដែលពួកគេមាន និងការបង្រៀនខុស ហើយបន្ទាប់មកសង្ខេប អំពីអ្វី ដែលអាលម៉ាបង្រៀន នៅអាលម៉ា 33 ផ្តល់ជាចំលើយ ឬដំណោះស្រាយ ចំពោះបញ្ហានីមួយព្រ ដែលអ្នកបានធ្វើជា បញ្ជីនោះ។

2. តើហេតុអ្វី បានវាជាការសំខាន់សំរាប់អាលម៉ា ទោះបង្រៀនពួកសាសន៍សូរ៉ាំ អំពីបទពិសោធន៍នៅលើបន្ទូលនៃព្រះ (នៅក្នុង អាលម៉ា 32) មុនពេលផ្តល់ការដាស់តឿន ដល់ពួកគេពីមធ្យោបាយផ្សេងៗ ដើម្បីពួកគេអាចដោះស្រាយបញ្ហាបាន (នៅ អាលម៉ា 33)?

ខ ពស់នៅលើបង្គោលមួយ

1. ចូរអានជនគណនា 21:4–9 និងអាលម៉ា 33:18–22 ហើយពន្យល់ពីរបៀប ដែលពស់លង្ហិននៅលើបង្គោល គឺជានិមិត្ត សញ្ញាមួយ (សញ្ញា) នៃព្រះយេស៊ូវគ្រីស្ទ (សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" នៅអាលម៉ា 33:18–22 ដើម្បីជា ជំនួយ បើសិនជាត្រូវការ)។

2. តើអ្នកអាចមើល ឬបែរទៅរកព្រះគ្រីស្ទ ឱ្យជួយអ្នកនៅក្នុងជីវិត បានយ៉ាងដូចម្តេច?

តើអ្នកធ្លាប់វង្វេងឬទេ? នៅអាលម៉ា 34 អាមូលេកធ្វើបន្ទាល់ថា បើមិនមានជង្វាយធួននៃព្រះអង្គសង្គ្រោះនោះទេ មនុស្ស គ្រប់រូបនឹងស្លាប់ នៅក្នុងសេចក្តីស្លាប់ពីរផ្សេងគ្នា ហើយវង្វេងជារៀងរហូតតទៅ។ ដូចជាឥទ្ធិពលដ៏ធ្ងន់ធ្ងរ នៃការធ្លាក់នៃ លោក អ័រដាម មាននៅលើមនុស្សគ្រប់រូប។ នៅពេលអ្នកអាន ពិចារណា ពីរបៀបដែលជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ បានជួយយើងឱ្យ ឈ្នះ លើសេចក្តីស្លាប់ទាំងពីរនេះ។ ចូរចងចាំថា ចំពោះយើងដើម្បីទទួលបានគ្រប់ពរជ័យ នៃផែនការ នៃសេចក្តីប្រោសលោះ របស់ព្រះ យើងត្រូវតែចូលរួម ធ្វើអ្វី ដែលព្រះវរបិតា តំរូវឱ្យយើងធ្វើនោះ។ ចូរសំឡងរកអ្វីដែលអ្នក ត្រូវតែធ្វើ ដើម្បីបំពេញតាម ផែនការទ្រង់។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 34

បែកចេញពី (ខ. 2)—ប្រឆាំង ក្បត់សាសនា

ការចាំបាច់ (ខ.9–10, 13)—ចាំបាច់សំខាន់

គ្រប់ពាំងឈើ និងក្បៀស (ខ. 13)—សូម្បី តែផ្នែកចុងបង្អស់ (ពាំងឈើ និងក្បៀស គឺជាសញ្ញាសរសេរតូចឯបំផុត នៅក្នុងភាសាហេព្រើរ)

ពុំទាំមកឱ្យអ្នកនូវផលអ្វីសោះ (ខ. 28)—គឺគ្មានតម្លៃសំរាប់អ្នក មិនបានជួយដល់អ្នកទេ

ជាកាក (ខ. 29)—សំណល់ តម្លៃ ឬគ្មានប្រយោជន៍

បង្អង់នូវពេលវេលា បង្អង់ថ្ងៃ (ខ. 33, 35)—ផ្អាកមួយរយៈ ពន្យា

ក្រោមអំណាចរបស់ (ខ. 35)—គ្រប់គ្រងដោយ

ផេរប្រមាថ (ខ. 40)—ផេរ រិះគន់

អាលម៉ា 34:9–14—"ការបូជាដ៏មហិមាចុងក្រោយបង្អស់មួយ"

អាមូលេកបង្រៀនថា "ការបូជាដ៏និរន្តរ៍ និងអស់កល្ប" នឹងមានអំណាច ដើម្បីប្រោសលោះកូនចៅនៃព្រះ ពីការធ្លាក់នៃលោក អ័រដាម ដែលទាំមកនូវអំពើបាប និងស្លាប់នៅក្នុងពិភពលោកនេះ (សូមមើលអាលម៉ា 34:10–12)។ អែលឌើរ វ៉ាស្សូល អែម នៃលសិន បង្រៀនថា "ព្រះយេស៊ូវគឺជាអង្គតែមួយគត់ ដែលអាចថ្វាយការបូជាដ៏និរន្តរ៍មួយនេះ តាំងតែពីទ្រង់ចាប់ កំណើតជា មួយម្តាយខាងសាច់ឈាម និងព្រះវរបិតាអមតៈមកម្ល៉េះ។ ដោយសារតែសិទ្ធិ ដែលមានមកពីកំណើតតែមួយនោះ ព្រះយេស៊ូវ គឺជា ព្រះដ៏និរន្តរ៍" (នៅក្នុង Conference Report ខែតុលា ឆ្នាំ 1996, 46 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1996, 35)។

អាលម៉ា 34:32–34—តើហេតុអ្វី បានជាការប្រែចិត្ត និងការរៀបចំខ្លួនសំខាន់នៅក្នុងជីវិតនេះ?

អែលឌើរ ប្រ៊ូស អរ មាក់ខនឃី បង្រៀនថា "ជីវិតនេះ គឺជាពេលសំរាប់ឱ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ។ អ្នកទាំង ឡាយ ដែលមានឧកាសនៅក្នុងជីវិតនេះ ដើម្បីទទួលសេចក្តីពិត គឺមានភាពក្លាហានកិច្ចដើម្បីទទួលយកសេចក្តីពិតនោះ បើមិនដូច្នោះ ទេ សេចក្តីសង្គ្រោះទាំងមូលនឹងបដិសេធពួកគេ។ សេចក្តីសង្ឃឹមនៃរង្វាន់តាមរយៈនេះ ហៅថា *ជីវិតស្លាប់ទើបជីវិតខ្លួន* គឺជាការឥតប្រយោជន៍" (*Mormon Doctrine* 136)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–ឃ)ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 34។

ក តើការបង្កើតទីបន្ទាល់មួយគឺជាអ្វី?

អាលម៉ា 34:8–16 មានចុះបញ្ជី នៃផ្នែកមួយ នៃទីបន្ទាល់របស់អាមូលេក។

1. ចូររំលឹកនៅផ្នែក នៃខគម្ពីរខាងក្រោមនេះ សារឡើងវិញ មកពីអាលម៉ា 34 ហើយសរសេរនៅក្នុងស្បៃវគ៌សរសេរ របស់អ្នក ពីអ្វី ដែលអ្នកគិតថា អ្នកដឹងពីអត្ថន័យរបស់វា ៖ខ 8–9, 10–12,13–14 និង15–16។

2. ចូរពន្យល់ពីអ្វី ដែលអ្នកគិតថាវាជាមូលដ្ឋាន នៃទីបន្ទាល់របស់អាមូលេក។

3. តើផ្នែកណាមួយនៃទីបន្ទាល់របស់អាមូលេក គឺជាផ្នែកមួយនៃទីបន្ទាល់របស់អ្នកដែរ?

ខ សរសេរសំបុត្រមួយច្បាប់

មិត្តម្នាក់ត្រាប់អ្នកថា ទាងមិនបានអធិស្ឋានឡើតទេ ព្រោះទាងមិនមានកន្លែងផ្តាល់ខ្លួនមួយ ដើម្បីធ្វើការអធិស្ឋាន ហើយមិន ដឹងថា គួរធ្វើការអធិស្ឋានអំពីអ្វី។ ចូរសិក្សាអាលម៉ា 34:17–27 រួចហើយសរសេរសំបុត្រមួយច្បាប់ ទៅទាង ដោយពីង ផ្នែកទៅលើ ប្រឹក្សារបស់អាមូលេក ដែលផ្តល់ឱ្យមានយោបល់ត្រាំ ថាតើកន្លែងណា ហើយនៅពេលណា ទាងអាចអធិស្ឋាន និងអំពីអ្វី ដែលទាង អាចអធិស្ឋានោះ។

គ ចំណេះចំណានខគម្ពីរ—អាលម៉ា 34:32–34

អ្នកមានការព្រួយបារម្ភអំពីមិត្តម្នាក់ ដែលមិនគោរពតាមព្រះបញ្ញត្តិ។ ការពន្យល់របស់គាត់មានចុះនៅខាងក្រោម។ ចូរ សរសេរការពន្យល់ទាំងនោះ នៅក្នុងស្បៃវគ៌សរសេររបស់អ្នក។ បន្ទាប់មក

សរសេរការឆ្លើយតបចំពោះវានីមួយៗ។ រួមទាំង ពាក្យ និងឃ្លា ដែលជាចម្លើយរបស់អ្នក មកពី អាលម៉ា 34:32–34។

1. “ខ្ញុំនឹងប្រែចិត្ត មុនពេលខ្ញុំទៅបេសកកម្ម ប៉ុន្តែបន្ទាប់ពីនោះមក ខ្ញុំចង់សប្បាយខ្លះ។”
2. “មែនហើយ បើសិនជាខ្ញុំស្លាប់ ខ្ញុំអាចប្រែចិត្តបានជានិច្ច ទៅក្នុងពិភពវិញ្ញាណ។ តើវាមិន សំរាប់អញ្ចឹងទេឬអី?”

២៥ សរសេរចំណោទសំនួរមួយ

ចំពោះខនីមួយៗ ទៅអាលម៉ា 34:37–41 ចូរសរសេរសំនួរមួយ ដែលអាចរកចំលើយនៅក្នុង ខគម្ពីរ ទាំងនោះ។ បន្ទាប់ពីសំនួរ នីមួយៗ សូមបញ្ចូលចំលើយរបស់អ្នក។

អាលម៉ា 35

ពួកសាសន៍សូរាំ ដែលផ្លាស់ប្រែចិត្ត ក្បៀសខ្លួនចូល ទៅក្នុងដែនដីយើសុន

ការរស់នៅតាមដំណឹងល្អ នៅពេលខ្លះតំរូវឱ្យមានការផ្លាស់ប្តូរដ៏លំបាកជាច្រើន នៅក្នុងជីវិតរបស់ពួកយើង។ យើង ប្រហែលជា ត្រូវផ្លាស់ប្តូរការងារ ជ្រើសរើសមិត្តថ្មី ឬត្រូវផ្លាស់ចេញទៅរស់កន្លែងផ្សេង។ នៅពេលអ្នកសិក្សា អាលម៉ា 35 ចូរកត់សំគាល់ អំពី ការលំបាកក្នុងការផ្លាស់ប្តូរ ដែលមកក្នុង ជីវិតរបស់ពួកសាសន៍សូរាំ ដែលផ្ទៀ ទៅលើពាក្យរបស់អាលម៉ា និងអាម៉ូលេក ហើយពីរបៀប ដែល ព្រះអម្ចាស់ បានផ្តល់ជាផ្លូវមួយសំរាប់ពួកគេ រកឃើញសេចក្តីអំណរ នៅក្នុងដំណឹងល្អ។ ចូរគិតអំពី របៀបដែលផ្លូវនេះ អាចផ្តល់ឱ្យអ្នកជាក្តីសង្ឃឹម នៅក្នុងបញ្ហា ដែលអ្នកប្រឈមមុខ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 35

បានច្រឹក្សា (ខ. 3)—បានពិភាក្សា បានឱ្យជាយោបល់

កលល្បិច (ខ. 3)—ដែលជំនាញ

ដោយសម្ងាត់ (ខ. 5)—ដោយស្ងាត់ដោយឡែក

បានបញ្ចោញពាក្យ (ខ. 9)—បាននិយាយ បានបញ្ចោញ

រវាង (ខ. 13)—រវាង

រឹងរូស (ខ. 15)—ប្រែជារឹងមាំក្នុងសេចក្តីសុចរិត

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយនៃសកម្មភាព(ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 35។

ក អធិប្បាយអំពីផែនការសម្ងាត់

ចូរអ្នកក្លែងធ្វើជាអ្នកស៊ើបការណ៍ម្នាក់ ដែលបានជ្រៀតចូល ទៅក្នុងអ្នកដឹកនាំរបស់ពួកសាសន៍សូរាំ។ បន្ទាប់មកអាន នៅអាលម៉ា 35:1–6 ចូរសរសេរជាការចំណាំមួយ ដែលពិពណ៌នាអំពី ផែនការណ៍ទុច្ចរិតរបស់ពួកសាសន៍សូរាំ និងពីរបៀប ដែលផែនការណ៍នោះ វាមានឥទ្ធិពលទៅលើអ្នកទាំងឡាយ ដែលរស់នៅតាមគោលការណ៍ដំណឹងល្អ។

ខ សរសេររបាយការណ៍ នៃដំណឹងមួយ

ចូរអានអាលម៉ា 35:7–12 ហើយសរសេរជារបាយការណ៍សារពត៌មានមួយ លើរឿបត្តិនៅក្នុង ដែនដីយើសុន។ រួមមានដូចខាងក្រោមៈ

1. ដំណើរឿងមួយ។
2. ឧទាហរណ៍នៃការគំរាមគំហែងមួយ ដែលអ្នកគិតថាអាច “បានបញ្ចោញគំនិត” ដោយពួកសាសន៍សូរាំ។
3. ការសង្កេបទូវការឆ្លើយតបមួយ របស់ប្រជាជនអាំម៉ូន ហើយរបៀប ដែលវាអាចធ្វើឱ្យស្ថានភាពខ្លះ បានប្រសើរឡើង នៅកន្លែងអ្នករស់នៅ។

គ ពិពណ៌នាអំពីអារម្មណ៍

1. ពិចារណា អាលម៉ា 35:14–16 ហើយពិពណ៌នាពីអារម្មណ៍របស់អាលម៉ាអំពីស្ថានភាព និងអ្វី ដែលគាត់បានធ្វើនោះ។
2. តើទាំងនេះ មានភាពស្រដៀងគ្នា ទៅនឹងអ្វី ដែលព្យាការីសម័យចុងក្រោយ បានបង្រៀនយើង អំពីការរៀបចំក្រុមគ្រួសារ របស់យើង សំរាប់ពេលលំបាក បានព្យាករហើយសំរាប់ពេល អនាគតឬទេ?

អាលម៉ា 36

អាលម៉ា បង្រៀនហេលេមិន អំពី ការផ្លាស់គំនិតរបស់គាត់

តើសេចក្តីស្រលាញ់របស់ឪពុកម្នាក់ ប្រៀបចំភ្លូនចៅរបស់គាត់ ដើម្បីតទល់នឹងសេចក្តីល្បួងរបស់សាតាំងបានយ៉ាងដូចម្តេចខ្លះ? តើគាត់អាច បំផុសគំនិតពួកគេ ដើម្បីចងចាំបានពរជ័យនៃដំណឹងល្អ ឱ្យច្រើនដងដោយការទាក់ទាញ ខាងសាច់ឈាម នៃលោកីយនេះ តាមរបៀបណាខ្លះ?អាលម៉ា 36–42 គឺជាបញ្ជីនៃ ការទូន្មានរបស់ព្យាការីអាលម៉ាទៅកាន់កូនប្រុសរបស់គាត់។ សូមសិក្សាជំពូក ទាំងនេះ ដោយការអធិស្ឋាន ដើម្បីយល់អំពីអ្វី ដែលអាលម៉ា ចង់ឱ្យកូនចៅ

របស់គាត់ស្គាល់ ហើយធ្វើតាម។ សេចក្តីពិត ដែល គាត់បង្រៀន គឺជា សេចក្តីសន្យា ចំពោះពរជ័យក្នុងជីវិតនេះ និងអស់ល្បជានិច្ច លើសពីអ្វីព ដែលសាតាំងចង់ឱ្យមកយើង។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 36

សង្ឃឹមថា (ខ. 3)—សុំ អង្វរ

ដោយការណ៍ខាងសាច់ឈាម (ខ. 4)—ខាងរូបកាយ មតះ

គំនិតខាងលោកីយ (ខ. 4)—ប្រាជ្ញា ខាងលោកីយ

ត្រូវញាំញី, បានញាំញី (ខ. 12, 14, 16–17)—ទុក្ខបុកម្មេញ កង្វល់

ត្រូវកើតទុក្ខ (ខ. 12, 17, 19)—ទុក្ខបុកម្មេញ ឈឺចាប់ នៅក្នុងជម្រៅទុក្ខព្រួយ

ផ្ទួតផ្រាប (ខ. 21)—យ៉ាងខ្លាំងក្លា

អាលម៉ា 36:18—ប្រមាត់ល្វីងជូរចត់

យើងមានបទពិសោធន៍ "ប្រមាត់ល្វីងជូរចត់" នៅពេលយើងមានអារម្មណ៍វិប្បដិសារី ឬអារម្មណ៍ នៃទុក្ខព្រួយយ៉ាងខ្លាំង ចំពោះការ ធ្វើខុស។ ប៉ុន្តែមិនមែនមានមនុស្សគ្រប់គ្នា អនុញ្ញាតឱ្យខ្លួនពួកគេ មានអារម្មណ៍នៃវិប្បដិសារីនោះទេ។ ប្រធាន ស្តែនស៊ើរ ដបុល យូ យឹមបឹល បង្រៀនថា "ចំពោះ អ្នកទាំងឡាយណា ដែលជ្រើសរើសយកការផ្លាស់ប្តូរដោយយថាហេតុនេះ នឹងក្លាយ ទៅជាក្រិន ហើយបាត់បង់ចំណង់របស់ពួកគេ ដើម្បីធ្វើការប្រែចិត្ត។ ការផ្លាស់ប្តូរដទៃទៀត គឺអនុញ្ញាតឱ្យ វិប្បដិសារី ដឹកនាំ [យើង] ទៅកាន់ទុក្ខព្រួយ ទាំងស្រុង បន្ទាប់មកមានការប្រែចិត្ត ហើយទីបញ្ចប់ ទៅរកការអភ័យទោស ជាយថាហេតុ ដែរ" ("The Gospel of Repentance" *Ensign* ខែតុលា ឆ្នាំ1982, 4)

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 36។

ក្ត តើអ្នកនៅចងចាំ ពីសេវកភាពរបស់ឱពុកអ្នកឬទេ

អាលម៉ា 36 ចាប់ផ្តើម ហើយបញ្ចប់ទៅវិញដោយពាក្យទូន្មានរបស់អាលម៉ា ទៅកាន់កូនប្រុស របស់គាត់ ហេឡេមិន ដើម្បី ចងចាំ ពីសេវកភាពរបស់ឱពុកនៃពួកគេ ហើយ ជាយថាហេតុការដោះលែងនោះ ដោយសារអំណាចរបស់ព្រះ(សូមមើលអាលម៉ា 36:2, 28–29)។ ចូរកត់សំគាល់ពីរប្រៀប ដែលអាលម៉ាប្រើនៅក្នុងជីវិតរបស់គាត់ ដូចជាឧទាហរណ៍មួយ នៃគោលការណ៍ នោះ។

1. ចូរអានអាលម៉ា 36:6–16 ហើយពិពណិនាអំពីរប្រៀប ដែលអាលម៉ាត្រូវជាប់នៅក្នុងសេវកភាព។
2. ចូរអានខ 17–21 ហើយពិពណិនាអំពីរប្រៀប ដែលអាលម៉ា ត្រូវបានដោះលែង ដោយសារ អំណាចរបស់ព្រះ។
3. ចូរសរសេរជាកថាខ័ណ្ឌដ៏សង្ខេបមួយ ដែលមានពន្យល់អំពី រប្រៀបនៃព្រឹត្តការណ៍ទាំងនោះជួយ អ្នកឱ្យជឿលើអំណាចរបស់ព្រះ ដើម្បីដោះលែងអ្នកពីការសាកល្បងនៃជីវិត ដែលហាក់បីដូចជា ទុកអ្នកឱ្យនៅក្នុងសេវកភាពនោះ។

ខ ឱ្យស្គាល់ធាតុផ្សេងព្ធ

ពឹងផ្អែកទៅលើអាលម៉ា 36:13–24 បានផ្តល់ជាភស្តុតាងថា អាលម៉ាមានបទពិសោធន៍នៃ ធាតុនីមួយព្ធ នៃការប្រែចិត្ត ខាងក្រោម នេះ:

1. ទទួលស្គាល់ អំពើបាប
2. មានអារម្មណ៍ទុក្ខព្រួយដោយស្មោះពិត
3. សារភាព
4. ធ្វើឱ្យមានដូចដើមវិញ (សងវិញនូវអ្វីដែលបាត់បង់នោះ)

ត្ត ពន្យល់អំពីយ្លាគន្លឹះ

ចូរពិចារណាអំពីពរជ័យ ដែលបានចុះបញ្ចីនៅក្នុងអាលម៉ា 36:25–29។ នៅក្នុងយ្លា ឬពាក្យគន្លឹះ ខាងក្រោមនេះ ចូរធ្វើការ សង្ខេបអំពីពរជ័យទាំងឡាយ ដែលមានទាក់ទងជាមួយវា ហើយ ពន្យល់ថា ហេតុអ្វីពរជ័យនោះសំខាន់:

1. "បានកើតមកអំពីព្រះ" (ខ. 26)
2. "ទទួលការគាំទ្រ" (ខ. 27)
3. "លើកឱពុកឡើង" (ខ. 28)

តើអ្នកធ្លាប់ប្រើត្រីវិស័យ ឬទេ? តើត្រីវិស័យអាចធ្វើអ្វីខ្លះ សំរាប់អ្នក? មានជាច្រើនដង នៅពេលដែលយើងត្រូវ ការត្រីវិស័យ ខាងវិញ្ញាណមួយ ដើម្បីដឹកនាំ និងណែនាំយើង។ ព្រះអម្ចាស់ បានផ្តល់ដល់យើងនូវត្រីវិស័យ ខាងវិញ្ញាណ។ នៅពេល អ្នក អានអាលម៉ា 37 សូមស្វែងរកមើលថា តើត្រីវិស័យខាងវិញ្ញាណជាអ្វី ហើយថា ត្រីវិស័យនេះ ជាជំនួយយ៉ាងណាខ្លះ សំរាប់ អ្នកនាសព្ធថ្ងៃនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 37

ព្រះបញ្ញាត្តិដ៏បរិសុទ្ធ (ខ. 5)—ព្រះគម្ពីរ

បំភាន់ (ខ.)6—ច្រឡំ

អត់ធ្មត់រងចាំ (ខ. 11)—ឈប់

ប្រដាប់បកប្រែទាំងនេះ (ខ. 21)—ត្បូងយូរីម និងធូមីម

កាសេឡិម (ខ. 23)—ដែលជាឈ្មោះ ជាក់លាក់មួយ ប្រគល់ឱ្យទៅអ្នកមើលឆុត មិនស្គាល់ម្នាក់

ខ្លាចក្រែង (ខ. 27)—ប្រហែល

ឱ្យស្អប់ (ខ. 29)—ស្អប់

ដ៏ចម្លែក (ខ. 39)—ធ្វើឡើងដោយ ប្រុងប្រយ័ត្ន លំអិត

ខ្ជិលច្រអូស (ខ. 41, 43, 46)—ខ្ជិល

សុភមង្គល (ខ. 44)—សេចក្តីរីករាយដ៏ មហិមា

ច្រកភ្នំ (ខ. 45)—ច្រកភ្នំ, និមិត្តសញ្ញានៃ ជីវិតមតះ

អាលម៉ា 37:21–31—ផ្ទាំងទាំងម្តៃបួនសន្លឹក និងបក្សពួកសម្ងាត់

អាលម៉ា បានព្រមានហេឡេមិន ឱ្យការពារបញ្ជីប្រវត្តិរបស់ពួកសាសន៍យ៉ារេឌ (ផ្ទាំងទាំងម្តៃបួនសន្លឹក) ដើម្បីឱ្យពាក្យសម្បថ ទីសំគាល់ និងសេចក្តីសញ្ញា នៃបក្សពួកសម្ងាត់ថាត្រូវបំផ្លាញពួកសាសន៍ យ៉ារេឌ កុំឱ្យដឹងនៅក្នុងចំណោមពួកសាសន៍នីហ្ចៃ។ អែលឌើរ ប្រ្ចិស អរ មិកខនយ៉ី បានសរសេរថាះ "គ្រប់ជំនាន់រហូតចុះមក មានក្រុម អង្គការ និងសាសនាចក្រ ហើយ នឹងរដ្ឋាភិបាលជាច្រើន មាន ពាក្យសម្បថ និងគម្រោងការណ៍សម្ងាត់ស្រដៀងគ្នា—ទាំងអស់ហ្នឹងបានបំផុសឡើងដោយសាតាំង"



ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ និងសកម្មភាព គ នៅពេលអ្នកសិក្សា អាលម៉ា 37។

ក ចំណេះចំណានខគម្ពីរ—អាលម៉ា 37:6–7

មានមនុស្សខ្លះ ហាក់ដូចជាគិតថា ព្រះគម្ពីរគឺជាការសរសេរ ពីអតីតកាលតែប៉ុណ្ណោះ ហើយមិនអាចជួយអ្វីដល់ពួកគេ នៅសព្វថ្ងៃនេះទេ។

1. សូមរំលឹកអាលម៉ា 37:6–7 ឡើងវិញ និងផ្តល់ជាឧទាហរណ៍ នៃខគម្ពីរមួយ “តូច ហើយសាមញ្ញ” ដែលជាពរជ័យមួយ នៅក្នុងជីវិតរបស់អ្នក។
2. ចូរស្រាវជ្រាវអាលម៉ា 37:8–20 ហើយធ្វើជាបញ្ជីយ៉ាងហោចណាស់បី “ជាប្រយោជន៍ដ៏ថ្លៃស្វាងមួយ” ដែលព្រះគម្ពីរ បានថែរក្សា ហើយសង្ឃេបពីរបៀប ដែលប្រយោជន៍ទាំងនេះអាចជាពរជ័យ ចំពោះប្រជាជននៅសព្វថ្ងៃនេះ។

ខ ចំណេះចំណានខគម្ពីរ—អាលម៉ា 37:35

ចូរគិតអំពីអាលម៉ា 37:35 ហើយតើអ្នកនឹងបង្រៀនខគម្ពីរនេះ ទៅកុមារអាយុក្រាំឆ្នាំ ដោយរបៀបណា។ ចូរសរសេរ គម្រោង នៃអ្វី ដែលអ្នកនឹងនិយាយ ដើម្បីគាំទ្រយោបល់របស់អ្នក ជាមួយនឹងពត៌មាននៅខ 36–37។

គ សរសេរការណែនាំ

នៅអាលម៉ា 37:38–47 អាលម៉ាប្រៀបធៀប លេអាហូណា ឬអ្នកទាំងឆ្នូវ ជាព្រះគម្ពីរ ឬ “ព្រះបន្ទូលនៃព្រះគ្រីស្ទ។”

1. ចូររំលឹក ខគម្ពីរទាំងនេះសារឡើងវិញ ហើយសរសេរជាការណែនាំមួយ ពីរបៀបប្រើប្រាស់លេអាហូណា។
2. ចូរពន្យល់អំពីរបៀប ដែលការណែនាំទាំងនោះ អាចជួយអ្នកឱ្យចេះប្រើព្រះគម្ពីរបានកាន់តែប្រសើរជាងមុនផងដែរ។

អាលម៉ា 38

អាលម៉ាឱ្យដំបូន្មាន ដល់សិបឡុនជាកូនប្រុសរបស់គាត់

ដំបូន្មានរបស់អាលម៉ា ទៅដល់សិបឡុនជាកូនប្រុសរបស់គាត់ គឺដោយសង្ខេប (ត្រាន់តែជាដំពូកខ្លីមួយ) ប៉ុន្តែពោរពេញទៅ ដោយអំណាច។ ចូរសិក្សាអំពីដំពូកនេះ ដោយប្រុងប្រយ័ត្ន ទៅពេលអ្នករៀនអំពីភាពខ្លាំង និងភាពទន់ខ្សោយរបស់សិបឡុន។ ចូររកមើលមធ្យោបាយណា ដែលអ្នកអាចទាំឱ្យមានសេចក្តីអំណរ ដល់ឪពុកម្តាយរបស់អ្នកផងដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 38

ជាប់ចំណង (ខ. 4)—ជាប់ខ្មោះ ចងភ្ជាប់

ការបារម្ភ (ខ.)—ទុក្ខព្រួយ សោកសង្រេង ឈឺចាប់

ចេះទប់ចិត្ត (ខ. 10)—ជាកណ្តាល ប្រើការត្រួតពិនិត្យលើខ្លួនឯង

កោងកាច (ខ.12)—បង្ខំ, ត្របសង្កត់

កាន់ចិត្តស្រគត់ស្រគំ (ខ. 15)—រម្យទម

អាលម៉ា 38:12—“ទប់អស់ទាំងតណ្ហារបស់កូន”

គោលបំណងនៃការទប់ គឺដើម្បីត្រួតពិនិត្យ ហើយទាំរសេះ កុំឱ្យរំហែក ឬបំផ្លាញគោលបំណងនោះចោល។ នេះជាអត្ថន័យនៃជំបូន្មាន ដើម្បី “ទប់” តណ្ហារបស់យើង។ “តើក្រាដ្ឋានៃការបដិសេធខ្លួនឯង ដោយសារអ្វីមួយ ខុសដាមួយនឹងតណ្ហារបស់យើង ឬដោយ សារអ្វីមួយ ត្រូវស្មានឹងតណ្ហារបស់យើងនោះមានអ្វីខ្លះ? អាលម៉ាបង្រៀនកូនប្រុសរបស់គាត់ថា ៖ ‘សូមមើលថាកូនទប់អស់ទាំងតណ្ហា របស់កូន *ដើម្បីឱ្យកូនអាចបានពោរពេញទៅដោយសេចក្តីស្រឡាញ់*។’ (សូមមើលអាលម៉ា 38:12 ការសង្កត់បន្ថែម)។ គាត់ មិនបាន និយាយផ្តាច់ ឬសូម្បីតែសង្កត់សង្កិន លើតណ្ហារបស់អ្នកទេ ប៉ុន្តែឱ្យ*ទប់* តណ្ហាទាំងនោះ—ត្រួតពិនិត្យ ផ្តុំ និងយក ចិត្តទុកដាក់ ទៅលើពួកគេ។ តើហេតុអ្វី? ពីព្រោះការដាក់ពិន័យ ធ្វើឱ្យមានសេចក្តីស្រឡាញ់ច្រើនជាង ហើយជ្រៅជ្រះជាង” (Bruce C. Hafen និង Marie K. Hafen, *The Belonging Heart* [1994], 302)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សាអាលម៉ា 38។

ក្រ ត្រលប់ពីភាពទន់ខ្សោយ ឱ្យទៅជាខ្លាំងវិញ

1. ចូរគូរកូឡោនពីរ នៅក្នុងស្បៃវគៅសរសេររបស់អ្នក ហើយក្នុងកូឡោនមួយមានចំណងស្លាក “តាពខ្លាំងរបស់សិបឡុន” ហើយ នៅកូឡោនមួយទៀតចំណងស្លាក “ការព្រួយបារម្ភដែលធ្វើឱ្យសិបឡុនខ្សោយ” ចូរអានអាលម៉ា 38:1–5,10–15 ហើយធ្វើជាបញ្ជីអំពីអ្វី ដែលអ្នក គិតថា ជាតាពខ្លាំង និងការព្រួយបារម្ភរបស់គាត់នោះ។

2. ចូរអានអេធើរ 12:27 រួចហើយពន្យល់អំពី ការស្តាប់តាមការព្រួយបារម្ភ នៃអ្នកដឹកនាំរបស់យើង អាចជួយពង្រឹងយើងយ៉ាង ណាខ្លះនោះ។

ខ សរសេរសំបុត្រមួយច្បាប់

អាលម៉ា បង្រៀនកូនប្រុសរបស់គាត់សិបឡុន អំពីជំណើរការ នៃការទទួលចំណេះដឹងខាងវិញ្ញាណ។

1. ចូរគូសតារាងមួយ ដូចជាមួយនៅខាងក្រោមនេះ ប៉ុន្តែមានតែសំនួរទេ។ នៅពេលអ្នកសិក្សាអាលម៉ា 38:6–9 ឡើងវិញ ចូរសរសេរចម្លើយ នៃសំនួរទាំងនោះ ហើយនៅខាងក្នុងប្រអប់ រួចសរសេរខគម្ពីរមួយ ឬច្រើន ដែលនឹងឆ្លើយសំនួរទាំងនេះ។



2. នៅក្នុងស្បៃវគៅសរសេររបស់អ្នក ចូរសរសេរដាស់បុត្រមួយច្បាប់ ទៅកាន់មិត្តម្នាក់ រួចធ្វើការពិពណ៌នាពីរបៀប ដែលអាច ទទួលបានចំណេះដឹងខាងវិញ្ញាណ។

អាលម៉ា ពេញចិត្តកូនប្រុសរបស់គាត់ ហេឡាមិន និងសិបឡុន។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនពេញចិត្ត ជាមួយនឹង ការប្រព្រឹត្តដោយគ្មានសីលធម៌របស់កូនប្រុសរបស់គាត់ កូរីអានតុនទេ។ អាលម៉ា ស្គាល់អំពីសេចក្តីឈឺចាប់ ដែលទាក់ទងជា មួយនឹងអំពើបាប និងចង់ឱ្យអ្នកដទៃ ជ្បៀសវាងពីសេចក្តីឈឺចាប់ទាំងនោះ (សូមមើល អាលម៉ា 36:11–16)។ ដោយហេតុ ដូច្នេះហើយ គាត់មានអ្វីៗច្រើនទៀត ដើម្បីនិយាយទៅកាន់ កូរីអានតុន ជាជាងទៅកាន់កូនប្រុសដទៃទៀតរបស់គាត់។ ចូរកត់ ចំណាំអំពីអ្វីដែលអាលម៉ា បានឱ្យដំបូន្មានដល់កូនប្រុសរបស់គាត់ ដើម្បីធ្វើឱ្យឈ្នះលើអំពើបាបរបស់ខ្លួន។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 39

ទាំឱ្យឪពុកព្រួយបារម្ភ (ខ. 3)—ធ្វើឱ្យមានទុក្ខព្រួយ ធ្វើឱ្យមានការរំខាន

ស្រីខ្ចី (ខ. 3)—ស្ត្រីក្មេងសិលធម៌ស្រស់ថ្កាមាស

កើតទុក្ខ (ខ. 7)—ទារុណ្ឌ ឈឺចាប់ ក្តីទុក្ខព្រួយយ៉ាងធ្ងន់

ចោះបង់ចោល (ខ. 9)—លះបង់ ចោះបង់

ជ្បៀសវាង (ខ. 9)—បដិសេធ ឈប់

ឈប់ធ្វើទង្វើ (ខ. 12)—រក្សាខ្លួនអ្នកពីការធ្វើអ្វីមួយ ជ្បៀសវាង

ដំណឹង (ខ. 15)—ដំណឹង

អាលម៉ា 39:5–6—តើអំពើបាបខាងកាមគុណ ធ្ងន់ធ្ងរយ៉ាងណា នៅចំពោះព្រះនេត្រព្រះ?

ក្នុងសារលិខិតមួយអានទៅកំឡុងខែតុលា ឆ្នាំ 1942 នៅសន្និសីទទូទៅ គណៈប្រធានទីមួយបានប្រកាសថា

អំពើបាបខាងកាមគុណ . . . ឈរនៅក្នុងភាពធំសម្បើម បន្ទាប់ពីអំពើឃាតកម្ម . . .

“. . . អ្នកមិនអាច មានការទាក់ទងជាមួយនឹងមនុស្ស ដែលមិនមែនជាប្តីប្រពន្ធរបស់ខ្លួន ដោយមានទំនាក់ទំនងខាងផ្លូវភេទខុស សីលធម៌. . . . ហើយអាចរត់គេចផុតពីការដាក់ទណ្ឌកម្ម និងការជំនុំជំរះ ដែលព្រះអម្ចាស់ បានប្រកាស ដើម្បីប្រឆាំងនឹងអំពើបាប នេះបានឡើយ” (នៅក្នុង Conference Report ខែតុលា ឆ្នាំ 1942, 11)។

អាលម៉ា 39:6—តើនៅក្នុងហេតុផលណា ដែលអំពើឃាតកម្ម អាចទទួលការអភ័យទោសបាន?

អែលឌើ ប្រ៊ូស អរ មិកខនឃី បង្រៀនថា “ឃាតករ តាមយថាហេតុអាចអភ័យទោសបាន ប៉ុន្តែក្នុងហេតុផលតែម្យ៉ាងថា អំពើបាបទាំងអស់នឹងត្រូវបានអភ័យទោស លើកលែងតែអំពើបាប ដែលប្រឆាំងនឹងព្រះវិញ្ញាណបរិសុទ្ធ ពួកគេមិនអាចអភ័យ ទោស ដោយនៅក្នុងហេតុផលថា សេចក្តីសង្គ្រោះសេឡេស្ទាល គឺធ្វើឱ្យមានឡើងសំរាប់ពួកគេបានឡើយ” (*Mormon Doctrine* 520)។

អែលឌើរ ស្តែនស៊ើ ដបុលយូ ឃិមបឹល ជាសមាជិកនៃក្រុមសាវ័កដប់ពីរនាក់ ពន្យល់ថា

“យ៉ូហាន បានសរសេរថា” គ្មានឃាតករម្នាក់ណា ដែលទទួលជីវិតអស់កល្បជានិច្ច ដោយការនៅជិតទ្រង់។ [យ៉ូហាន 3:15] ឃាតករ បដិសេធសេចក្តីសង្គ្រោះដោយខ្លួនឯង នៅក្នុងនរកសេឡេស្ទាល ហើយនៅក្នុងហេតុផលនេះ គាត់មិនអាចបានទទួល ការអភ័យទោស ចំពោះបទឧក្រិដ្ឋរបស់គាត់បានទេ. . . .

“ច្រាកដណាស់ ទាំងច្បាប់របស់ដែនដី និងព្រះ ទទួលស្គាល់ពីភាពខុសគ្នាដ៏សម្បើម រវាងឃាតកម្ម ឬការកាប់សម្លាប់ដោយមាន ចេតនា និងមនុស្សឃាតដែលមិនបានគិតទុកជាមុន។ ដូចគ្នានេះដែរ មនុស្សដោយហេតុអាក្រក់ ត្រូវតែយកជីវិតអ្នកដទៃ នៅក្នុង សង្គ្រាម” (*The Miracle of Forgiveness* [ឆ្នាំ 1969], 127, 129)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ខ និង ឃ នៅពេលអ្នកសិក្សា អាលម៉ា 39។

ក តើហេតុអ្វីក៏អាលម៉ា ពោរពេញទៅដោយទុក្ខព្រួយ?

1. សូមអាន អាលម៉ា 39:1–11 ហើយធ្វើបញ្ជី ប្រើងចំនួនត្រាំ ដែលអាលម៉ា មានអារម្មណ៍ព្រួយចិត្តថា កូរីអានតុន បានធ្វើ ឬមិនបានធ្វើ ដែលរារាំងកូរីអានតុន ពីការធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏ល្អម្នាក់។

2. ចូរសរសេរអំពីអ្វី ដែលកូរីអានតុនត្រូវការធ្វើ ដើម្បីប្រែចិត្ត (សូមមើល ខ 7–13)។

ខ សរសេរសំបុត្រមួយច្បាប់

ប្រធាន រ៉ៃសឺរ៉ា ថាប់ ប៊ែនសឺន បង្រៀនថាៈ “អំពើបាប កំពុងរុកគួនទៅដំទាន់នោះ គឺជាអំពើកាមគុណគ្មានសីលធម៌” (នៅក្នុង Conference Report ខែមេសា ឆ្នាំ1986, 4, ឬ *Ensign* ខែឧសភា ឆ្នាំ1986, 4)។ សូមរំលឹក អាលម៉ា 39:3–9 សារឡើងវិញ ហើយសរសេរដាកថាក័ណ្ឌ នៅក្នុងស្បៃភៅសរសេររបស់អ្នក ដើម្បីជួយពង្រឹងដល់ទរណាម្នាក់ ឱ្យតទល់ទឹងសេចក្តីល្បួងនៃអមតៈភាព។

1. ចូរពន្យល់អំពី អំពើខាងកាមគុណដ៏ធ្ងន់ធ្ងរ នៃអមតៈភាព។

2. សូមគ្រាប់ថា ហេតុអ្វីអ្នកជ្រើសរើស មិនឱ្យចូលទៅក្នុងសេចក្តីល្បួង។

3. ចូរប្រើសេចក្តីថ្លែងការណ៍នៅក្នុងវគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់អាលម៉ា 39:5–6 ហើយពន្យល់ ពីមូលហេតុ ដែលអ្នកគិត ថាអំពើបាបទាំងនេះ មានភាពធ្ងន់ធ្ងរយ៉ាងខ្លាំង (សូមមើល គ និងស 42:24–25)។

គ តើគំរូរបស់អ្នក ធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

ចូររំលឹក អាលម៉ា 39:11–13 សារឡើងវិញ ហើយគិតអំពី ឥទ្ធិពលនៃគំរូ របស់កូរីអានតុន មានចំពោះពួកសាសន៍សូរ៉ាំ។

1. ចូរប្រៀបធៀប អំពីអ្វី ដែលកូរីអានតុនបានធ្វើ (សូមមើលខ. 11) ជាមួយអ្វី ដែលគាត់បានហៅឱ្យប្រកាស (សូមមើលខ. 15–16)។

2. តើឥទ្ធិពល នៃគំរូអាក្រក់អ្វីខ្លះ អាចមានមកលើប្រជាជន?

3. តើឥទ្ធិពល នៃគំរូល្អអ្វីខ្លះ អាចមានមកលើប្រជាជន?

អាលម៉ា 40

ពិភពវិញ្ញាណ និងការសាងឡើងវិញ

តើអ្នកធ្លាប់មានមិត្តដែលមកសួរថា តើយើងទៅកន្លែងណា បន្ទាប់ពីយើងស្លាប់ដែរឬទេ? តើអ្នកនឹងឆ្លើយសំនួរនោះ យ៉ាងដូច ម្តេច? នៅក្នុងអាលម៉ា 40 គឺជាចម្លើយរបស់អាលម៉ា ចំពោះសំនួរខ្លះៗ អំពីជីវិតក្រោយពីសេចក្តីស្លាប់។ សូមអានអំពីអ្វី ដែល អាលម៉ា បង្រៀន ហើយសូមមើលបើសិនជាគាត់ ឆ្លើយសំនួរផ្សេងៗ ដែលអ្នកធ្លាប់មានអំពី ជីវិតក្រោយនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 40

រូបកាយដ៏ពុករលួយនេះ ក៏ពុំអាចប្រដាប់ដោយភាពមិនពុករលួយបានដែរ (ខ. 2)—រូបកាយមតៈនេះនឹងមិនមានជំណើរអស់ ឡើងវិញទេ

មានចន្លោះមួយរវាង (ខ. 6)—ពេលរវាង

យ៉ាងភ័យខ្លាចនៃការពិរោធដ៏ឆ្ងល់ឆាប (ខ. 14)—ខឹងនៅក្នុងភាពត្រឹមត្រូវយ៉ាងខ្លាំង

ភាពរស់នៅ, ត្រូវផ្តន្ទាទោស (ខ. 15, 17, 26)—ចាត់ចែង ការជំនុំជំរះ

ការសាងឡើងវិញ (ខ. 23)—នាំត្រលប់មកវិញ

កាក (ខ. 26)—កាក និងរូបធាតុខាងក្រៅដែលស្ថិតនៅបាតដបស្រា ដើម្បី “ផឹកកាក” នៃអ្វីៗ ផឹកនៅផ្នែក ដែលអាក្រក់របស់ វា។

© 1994 Johnn M. Hegsted

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព គ និងសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សា អាលម៉ា 40។

ក បញ្ចប់ប្រយោគ

ចូរធ្វើវិភាគ អាលម៉ា 40:1–8 ហើយស្វែងរកពាក្យ ដែលបំពេញប្រយោគនីមួយៗ ខាងក្រោមនេះ។ ចូរសរសេរប្រយោគ ដែលពេញលេញ នៅក្នុងស្បៃភៅសរសេររបស់អ្នក។

1. “គ្មានជំណើរស់ឡើងវិញទេ . . . លុះត្រា _____”។

2. “មានពេលមួយ ដែលបានកំណត់ទុក សំរាប់ _____”។

3. “ត្រូវតែមាន _____”។

ខ ស្ថានបរមសុខ ឬស្ថានជាប់ឃុំឃាំង?

អាលម៉ា 40:11–15 បានសំគាល់ពី លក្ខខ័ណ្ឌពីរ នៅក្នុងពិភពវិញ្ញាណ។ ចូរអានខគម្ពីរទាំងនោះ ហើយធ្វើបញ្ជី នៃដលវិបាក ខ្លះៗ ទៅតាមសេចក្តីស្លាប់ ដើម្បីសេចក្តីសុចរិត និងដើម្បីសេចក្តីទុច្ចរិត។

គ ភ្ជាប់សេចក្តីថ្លែងការណ៍ ទៅនឹងខគម្ពីរមួយ

តាមអ្វី ដែលអ្នកបានរៀន នៅអាលម៉ា 40:15–26 ចូរសរសេរសេចក្តីថ្លែងការណ៍ នៃគោលលទ្ធិអំពីជំណើរសាងឡើងវិញ សំរាប់ឃ្លានីមួយៗខាងក្រោមនេះៈ

1. វិញ្ញាណ និងរូបកាយ

2. នៅវេលា នៃជំណើរស់ឡើងវិញរបស់ព្រះគ្រីស្ទ

3. រវាងសេចក្តីស្លាប់ និងជំណើរស់ឡើងវិញ

4. ស្ថានភាពនៃសុភមង្គល ឬស្ថានភាពទុក្ខវេទនា

5. ឈរនៅចំពោះព្រះ

6. អ្វីៗទាំងអស់ទីងសាងឡើងវិញ

អាលម៉ា 41

"អំពើទុច្ចរិតពុំ ដែលជាសុភមង្គលឡើយ"

តើអ្នកធ្លាប់មានមន្ទិលទេ ថាហេតុអ្វីមនុស្សខ្លះ ហាក់ដូចជាចង់ផ្សេងពីផលវិបាកនានា ដែលមកពីការធ្វើអ្វីមួយខុស? អាលម៉ា ពន្យល់ដល់កូនប្រុសរបស់គាត់ កូរីអានតុនអំពីអ្វី កើតឡើង ចំពោះអ្នកទាំងឡាយណា ដែលគិតថាមានសុភមង្គល នៅក្នុងអំពើ ទុច្ចរិត។ នៅពេលអ្នកអាន អាលម៉ា 41 ចូរកត់ចំណាំការបង្រៀន អំពីការជំនុំជំរះចុងក្រោយ អំពីគោលការណ៍ នៃការសាង ឡើងវិញ ហើយ ដែលនៅក្នុងជំណើររស់ឡើងវិញ មនុស្សគ្រប់រូបនឹងទទួលបានម្តងទៀត នៅចរិតលក្ខណៈ និងអាកប្បកិរិយា ដែលពួកគេទទួលបាននៅក្នុងមតៈភាព។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 41

បានធ្វើខុសវិន័យ (ខ. 1)—បានធ្វើឱ្យរមួល រមួល ឬផ្លាស់ប្តូរអត្ថន័យ

ការចាំបាច់ (ខ. 2–3)—តម្រូវ

ពុំអាចផ្លាស់ប្តូរបានឡើយ (ខ. 8)—មិនអាចផ្លាស់ប្តូរបាន

ខាងសាច់ឈាម (ខ. 11, 13)—លោកិយ មតៈ

ផ្លូវដោះសារ (ខ. 15)—អត់យទោស

អាលម៉ា 41:2—តើ "ផែនការនៃការសាងឡើងវិញ ជាអ្វី"?

ពាក្យ*ការសាងឡើងវិញ* មានន័យថា ទាំត្រលប់មកវិញស្ថានភាពពីអតីត។ អាលម៉ា 40:1–41:2 ពិពណ៌នាអំពី ផែនការណ៍ នៃការសាងឡើងវិញ ដូចជាជំណើររស់ឡើងវិញ នៅពេលវិញ្ញាណ និងរូបកាយ ទាំមករួមគ្នាម្តងទៀត។ អត្ថន័យបន្ថែមទៀត គឺមានផ្តល់ឱ្យ នៅអាលម៉ា 41:3–15។ ផែនការណ៍ នៃការសាងឡើងវិញ មានរួមទាំងការជំនុំជំរះចុងក្រោយផងដែរ នៅ ពេល យើង ទទួលរង្វាន់ ទៅតាមអ្វី ដែលយើងបានធ្វើក្នុងមតៈភាព។ ប្រធានយ៉ូសេប ហ៊ីលឌីង ស្ម៊ីធ បង្រៀន ថា "មានច្បាប់ ទេវភាពមួយ នៃការទូទាត់។ ដូច្នេះ មតៈភាព គឺជាមូលដ្ឋាននៃការសាកល្បង។ មនុស្ស ទីងវិនិច្ឆ័យទៅតាមអំពើរបស់ពួកគេ ហើយមានរង្វាន់ ឬទណ្ឌកម្ម ចំពោះអំពើ ដែលបានធ្វើ នៅក្នុងរូបកាយមតៈ។ គ្មានការរើសអើង នៅក្នុងនគរព្រះទេ។ អ្វី ដែល ម្នាក់ៗបាន ទទួល គឺជាអ្វី ដែលគាត់សមនឹងបាន" (*Answers to Gosple Question* 5:16)។ នៅក្នុងហេតុផលជំពិតមួយ អ្វីៗ ដែល យើងធ្វើ ដើម្បីមានភាពអស់កល្បជានិច្ច គឺកំណត់ដោយការប្រព្រឹត្ត និងចំណង់របស់ យើងនៅក្នុងមតៈភាពនេះ (សូមមើល គ និងស 88:21–32)។

អាលម៉ា 41:11—"ប្រមាត់ល្ងីងចូរចត់"

សូមមើល "ការយល់ដឹងអំពីព្រះគម្ពីរ" ចំពោះអាលម៉ា 36:18 (ទំព័រ 130)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សាអាលម៉ា 41។

ក ឆ្លើយសំនួរមួយ

សូមអានអាលម៉ា 41:1–6 ហើយសរសេរចំលើយ សំរាប់សំនួរពីរខាងក្រោមមួយណាក៏បាន អំពី ផែនការនៃការសាងឡើងវិញ:

1. នៅក្នុងខគម្ពីរទាំងនេះ ពាក្យ*ការសាងឡើងវិញ* ពេលខ្លះ សំដៅទៅលើ ជំណើររស់ឡើងវិញ។ ចូរពន្យល់ តាមរយៈប្រយោគផ្សេងៗ អំពីពាក្យ *ការសាងឡើងវិញ* ត្រូវបានប្រើនៅទីនេះ។

2. តើផែនការ នៃការសាងឡើងវិញ អោយមានភាពយុត្តិធម៌ និងត្រឹមត្រូវបានយ៉ាងដូចម្តេច?

3. តើអ្វីបានកើតឡើងចំពោះជនទុច្ចរិត តាមការជំនុំជំរះនៃព្រះ?

4. ទៅតាម ម៉ូសាយ 4:30 តើអ្វី ដែលទំនងជា ជីវិតរបស់យើងនឹងត្រូវបានកាត់សេចក្តីតាមនោះ?

ខ ចំណេះចំណានខគម្ពីរ—អាលម៉ា 41:10

ប្រធានរ៉ែសឺរ៉ា ថាប់ ប៊ែនសឺនមានប្រសាសន៍ថា "អ្នកមិនអាចធ្វើខុស ហើយមានអារម្មណ៍ល្អទេ។ វាមិនអាចទៅរួចឡើយ!" ("To 'the Rising Generation,'" *New Era* ខែមិថុនា ឆ្នាំ 1986, 5)។ សូមប្រើអាលម៉ា 41:3–10 ដើម្បីជាជំនួយដល់អ្នកក្នុង ការឆ្លើយសំនួរខាងក្រោមនេះ:

1. តើហេតុអ្វី សេចក្តីថ្លែងការណ៍របស់ប្រធាន ប៊ែនសឺនពិត ទាំងនៅក្នុងជីវិតនេះ និងជីវិតទីង មកដល់?

2. តើហេតុអ្វី អំពើទុច្ចរិត មិនដែលមានសុភមង្គល? តើហេតុអ្វី យើងអាចបានសប្បាយដាង នៅ ពេលយើងព្យាយាមធ្វើតាមគំរូ និងការបង្រៀននៃព្រះយេស៊ូវគ្រីស្ទ?

អាលម៉ា 42

សេចក្តីមេត្តាករុណា និង សេចក្តីយុត្តិធម៌

នៅពេលអាលម៉ា បញ្ចប់ការបង្រៀនរបស់គាត់ ទៅដល់ភូរីអានតុន គាត់បានឆ្លើយសំនួរ អំពីជីវិតនឹងទៅជាយ៉ាងណា បើគ្មាន ការប្រែចិត្តពីអំពើបាបគ្មានច្បាប់ និងគ្មានការដាក់ទារុណកម្មទេ។ ព្រះអាចមានទាំងយុត្តិធម៌ និងប្រកបដោយមេត្តាករុណា។ អាលម៉ា 42 អាចជួយអ្នកយល់ថា ហេតុអ្វីក៏អ្នកមកនៅលើផែនដីនេះ ហើយតើជីវិតនៅលើផែនដីសំខាន់យ៉ាងណាសំរាប់សេចក្តីរីកចំរើនដ៏អស់កល្ប ជានិច្ចរបស់អ្នក។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 42

ត្រូវដាក់ទៅក្នុង (ខ. 1, 14)—ដាក់ឱ្យធ្វើ វិនិច្ឆ័យ

ចេរូប៊ីន (ខ. 2–3)—ជាប្រភេទមួយនៃការរស់នៅរបស់ទេវតា

ពេលសាកល្បង ស្ថានភាពសាកល្បង (ខ. 4, 10, 13)—ពេលនៃការសាកល្បង (ជីវិតមតះ)

ខាងសាច់ឈាម សេចក្តីស្លាប់ខាងសាច់ឈាម (ខ. 7–9)—ខាងរូបកាយមតះ

ស្តប់ស្តល់ (ខ. 15)—បំពេញ គ្រប់គ្រាន់

ការសោកស្តាយនៅក្នុងស្មារតី (ខ. 18)—ខ្មាស់អៀន ដឹងកំហុស ស្តាយក្រោយ

អនុវត្ត (ខ. 22)—អនុវត្ត ធ្វើឱ្យប្រតិបត្តិ

ប្រែចិត្ត (ខ. 23–24)—កែប្រែចិត្ត បន្ទាបខ្លួន

ពុំអាចទាល់តែសោះ (ខ. 25)—បន្តិចបន្តួច ចំណែកតូច

ការស្រគត់ស្រគំ (ខ. 31)—ភាពមធ្យ័ត

អាលម៉ា 42:7–9, 15—សេចក្តីស្លាប់ខាងសាច់ឈាម និងសេចក្តីស្លាប់ខាងវិញ្ញាណ មកដោយការធ្លាក់ចុះ ហើយត្រូវបានយក ឈ្នះ ដោយដង្វាយធួន នៃព្រះយេស៊ូវគ្រីស្ត

នៅក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ត គណៈប្រធានទីមួយ និងក្រុមសាវកដប់ពីរនាក់ បានប្រកាសថាះ

"ព្រះអង្គបានប្រទានព្រះជន្មរបស់ទ្រង់ ដើម្បីធ្វើឱ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សទាំងអស់។ ព្រះជន្មរបស់ទ្រង់ គឺជាអំណោយទានជំនួសឱ្យមនុស្សទាំងអស់ ដែលធ្លាប់បានរស់នៅលើផែនដី។

"យើងសូមថ្លែងទីបន្ទាល់ដោយម៉ឺងម៉ាត់ថា ព្រះជន្មរបស់ទ្រង់ ដែលជាសារៈសំខាន់បំផុត នៅក្នុងប្រវត្តិសាស្ត្រមនុស្ស នោះពុំមែនចាប់ផ្តើមនៅភូមិបេថ្លេហិម ឬបញ្ចប់នៅភ្នំកាលវ៉ារីនោះទេ។ ព្រះអង្គ គឺជាព្រះរាជបុត្រាច្បងបង្អស់នៃព្រះវរបិតា ជាព្រះរាជបុត្រាបង្កើតតែមួយ នៅក្នុងសាច់ឈាម ជាព្រះដ៏ប្រោសលោះ នៃពិភពលោក។

"ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញពីផ្នូរ ដើម្បី" ជាផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ "(1 កូរិនថូស 15:20)" (*ព្រះគ្រីស្ត៏មានព្រះជន្មរស់* [ថ្ងៃទី 1 ខែមករា ឆ្នាំ 2000 អត្ថបទលេខ 36299])។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ខ ឬសកម្មភាព ក និង គ នៅពេលអ្នកសិក្សាអាលម៉ា 42។

ក៏ សរសេរចំលើយរបស់អ្នក

សូមប្រើ អាលម៉ា 42:1–10 ដើម្បីជួយក្នុងការឆ្លើយសំនួរដូចខាងក្រោមនេះ

1. តើសេចក្តីស្លាប់ពីរ ដែលមកជាលទ្ធផលនៃការធ្លាក់នៃលោកអ័ដាមមានអ្វីខ្លះ?
2. តើសេចក្តីស្លាប់មួយណា ដែលនឹងគ្មានឥទ្ធិពល បើសិនជាលោកអ័ដាមបានបរិភោគដើមឈើនៃជីវិត?
3. តើសេចក្តីស្លាប់មួយណា ដែលអ័ដាមនឹងនៅតែមានបទពិសោធន៍ បើសិនជាលោកបានបរិភោគនៃដើមឈើនៃជីវិត?

4. តើអ្វីនឹងជាផលវិបាក បើសិនជាលោកអ័ដាមបានបរិភោគ នៃដើមឈើនៃជីវិត បន្ទាប់ពីការធ្លាក់ចុះ?
5. តើព្រះអម្ចាស់បានធ្វើអ្វី ជាមួយនឹងដើមឈើនៃជីវិត បន្ទាប់ពីការធ្លាក់ចុះ? តើហេតុអ្វី?
6. តើគោលបំណងមួយ នៃពេលសាកល្បង ឬជីវិតមតះជាអ្វី?
7. តើអ្នកអាចប្រើពេលវេលាសាកល្បងរបស់អ្នក ដោយការឈ្លៀសវៃបានយ៉ាងដូចម្តេច?

ខ បំពេញនៅក្នុងឌីយ៉ាក្រាម

ចូរគូរឌីយ៉ាក្រាមខាងក្រោមនេះ នៅក្នុងសៀវភៅសរសេររបស់អ្នក។ សូមប្រើអាលម៉ា 42:11–24 និងសេចក្តីថ្លែងការណ៍កណ្ត "ការយល់ដឹងអំពីព្រះគម្ពីរ" នៅអាលម៉ា 42:7–9, 15 ដើម្បីបំពេញ ដោយនិយាយមាត់ទទេ ជាមួយលទ្ធផល ធំចំបងពីរ នៃការធ្លាក់ចុះ និងបំពេញនៅក្នុងផ្ទៃបួនជ្រុងទ្រវែងនូវរបៀបដែលលទ្ធផលទាំងនោះ ត្រូវបានយកឈ្នះលើ។ បន្ទាប់មកឆ្លើយ សំណួរទាំងនេះ។



1. យោងទៅតាមខ 15 តើដង្វាយធួនបាន "នាំមក" និងតើបានធ្វើឱ្យ "ស្តប់ស្តល់" អ្វីខ្លះ?
2. ចូរសរសេរប្រយោគខាងក្រោមនេះ នៅក្នុងសៀវភៅរបស់អ្នក រួចបំពេញនៅក្នុងប្រឡោះ ជាមួយនឹងពតិមានមកពីខ 17: មនុស្សមិនអាច _____ លុះត្រាតែដំបូងគាត់ _____ ដែលគាត់មិនអាចធ្វើបាន លុះត្រាតែមាន _____ ដែលមិនអាចមានជីវិតដោយគ្មាន _____។
3. តើដង្វាយធួន ឈ្នះលើសេចក្តីស្លាប់ខាងសាច់ឈាមបានយ៉ាងដូចម្តេច? (សូមមើល ខ. 23)។
4. តើដង្វាយធួន ឈ្នះលើសេចក្តីស្លាប់ខាងវិញ្ញាណ ដែលនាំមកដោយការធ្លាក់នៃលោកអ័ដាមបានដូចម្តេចខ្លះ? (សូមមើល ខ. 23)។
5. តើសេចក្តីមេត្តាករុណាផ្តល់ទៅឱ្យក្រុមមួយណា? (សូមមើល ខ. 23–24)។
6. តើការដឹងអំពីដង្វាយធួនមានចំពោះអ្នក មានឥទ្ធិពលមកលើអារម្មណ៍របស់អ្នកចំពោះព្រះយេស៊ូវគ្រីស្ទដោយវិធីណា?

ត៏ សរសេរសង្ខេប

ពាក្យចុងក្រោយរបស់អាលម៉ា ទៅដល់កូនប្រុសរបស់គាត់ភូរីអានតុន មាននៅក្នុងអាលម៉ា 42:27–31។ ចូរនឹកគិតថា ធ្វើ ជាឱពុកម្តាយ ដែលកូនប្រុសស្រីមានចិត្តរឹងរូស។ សូមរំលឹកអាលម៉ា 42:27–31 សារឡើងវិញ ហើយសរសេរដោយសង្ខេបនូវ អ្វី ដែលអ្នកនឹងនិយាយ ដើម្បីកែតម្រូវ និងពង្រឹងដល់កូនរបស់អ្នក។

អាលម៉ា 43

ពួកសាសន៍នីហ្វៃការពារផ្ទះសំបែង សេរីភាព គ្រួសារ និងសាសនារបស់ពួកគេ

អាលម៉ា 43 បានណែនាំមេទ័ពម៉ូរីណាថាជា អ្នកដឹកនាំពលទ័ពសាសន៍នីហ្វៃ ដ៏អស្ចារ្យ ហើយបន្តជំណើររឿង នៃសង្គ្រាម រវាងពួកសាសន៍លេមិន និង ពួកសាសន៍នីហ្វៃ។ មានមូលហេតុជាច្រើន ដែលម៉ូរីណា បញ្ចាលទូវជំណើរ រឿងនៃសង្គ្រាម នៅក្នុង ព្រះគម្ពីរមរមន។ នៅពេលអ្នកអាន និងសិក្សានៅ ក្នុងទំព័រទាំងនេះ ចូរគិតអំពីអ្វី ដែលអ្នកនឹងមានឆន្ទៈ ដើម្បីច្បាំងសំរាប់រឿង នោះ។ តើមានវត្ថុអ្វីខ្លះ ដែលអ្នកនឹងប្រថុយជីវិតរបស់អ្នកដើម្បីការពារ?

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 43

រឃ្យែបដ៏បរិសុទ្ធនៃព្រះ (ខ. 2)—បញ្ជាដ៏តភាព

ឱ្យនៅក្រោមអំណាច (ខ. 7)—គ្រប់គ្រង

ជណ្តើមយកអំណាច (ខ. 8)—យកដោយគ្មានយុត្តិធម៌ ឬដោយអំពើហឹង្សា

បង្ខំចិត្ត (ខ. 14)—តម្រូវឱ្យ

ដែលក្រវាត់នៅចង្កេះ (ខ. 20)—ចងនៅជុំវិញចង្កេះរបស់ពួកគេ

ពួន (ខ. 27)—ការចិទចាំង លាក់

មធ្យោបាយ (ខ. 30)—ឃ្យែបចំដោយប្រុងប្រយ័ត្ន

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ ឬគ នៅពេលអ្នកសិក្សា អាលម៉ា 43។

ក សំគាល់ពីហេតុផលដែលនាំឱ្យមានសង្គ្រាម

1. សូមអាន អាលម៉ា 43:4–8 ហើយធ្វើបញ្ជីពីមូលហេតុរបស់ពួកសាសន៍លេមិន ដែលចាប់ផ្តើមបង្ករឱ្យមានសង្គ្រាម។
2. សូមអាន ខ 9–12, 26, 30 ហើយធ្វើបញ្ជីពីមូលហេតុរបស់ពួកសាសន៍នីហ្វៃ ក្នុងការប្រយុទ្ធនៅក្នុងសង្គ្រាម។
3. សូមអាន ខ 18–21 ហើយធ្វើបញ្ជីពីរឃ្យែបដែលពួកសាសន៍នីហ្វៃ ឃ្យែបចំសំរាប់ធ្វើសង្គ្រាម។
4. តើអ្នកអាចឃ្យែនពីពួកសាសន៍នីហ្វៃអ្វីខ្លះ អំពីការឃ្យែបចំខ្លួនពួកគេ ដើម្បីឈ្នះលើការល្បួង នៃមគ៌ភាព? (សូមមើល គ និង ស 27:15–18 ផងដែរ)។

ខ ពិពណ៌នាអំពីម៉ូរីណា

1. សូមអានអាលម៉ា 43:16–17, 23–26, 53–54 ហើយសរសេរការពិពណ៌នារបស់ម៉ូរីណា ជាអ្នកដឹកនាំពលទ័ពសាសន៍ នីហ្វៃ ដ៏អស្ចារ្យ។
2. ចូរពិពណ៌នាអំពីមនុស្សម្នាក់ ដែលអ្នកស្គាល់ ដែលមានចរិតលក្ខណៈដូចម៉ូរីណា។
3. ចូរសំគាល់នូវចរិតលក្ខណៈពីរយ៉ាងរបស់ម៉ូរីណា ដែលអ្នកចង់បានយ៉ាងខ្លាំង។

គ គូរផែនទីមួយ

ចូររំលឹកអាលម៉ា 43:22–53 សារឡើងវិញ នៅពេលអ្នកសិក្សាអំពីប្រវត្តិរបស់ទាហាន ហើយធ្វើដូចខាងក្រោមនេះ៖

1. សំដៅទៅលើ “កន្លែងដែលអាចរកបាន នៅក្នុងព្រះគម្ពីរមរមន (ទាក់ទងគ្នាទៅវិញទៅមក)” (ទំព័រ 212) ហើយកត់សំគាល់អំពីកន្លែងមួយចំនួនដែលបានគ្រាប់នៅក្នុងអាលម៉ា 43:22–53។
2. ចូរប្រៀបធៀបទូវអ្វី ដែលបានបំផុសដល់ពួកសាសន៍លេមិន ឱ្យធ្វើការប្រឆាំង ជាមួយនឹងអ្វី ដែលបានបំផុសដល់ពួកសាសន៍ នីហ្វៃ ហើយពន្យល់ថា ហេតុអ្វីពួកសាសន៍នីហ្វៃឈ្នះ (សូមមើល ខ. 43–50)។
3. ចូរសរសេរឃ្លាមួយ អំពីអ្វី ដែលអ្នកគិតថា ជាមេរៀនដ៏សំខាន់បំផុត ដែលបានរៀនមកពីការប្រយុទ្ធគ្នានោះ។

អាលម៉ា 44

ជ័យជំនះរបស់សាសន៍នីហ្វៃ

តើហេតុអ្វី បានជាម៉ូរីណាគ្រាប់ដល់អ្នកចំពាំងរបស់គាត់ឱ្យឈប់ច្បាំង នៅ ពេលពួកគេជិតនឹងបំផ្លាញសត្រូវរបស់ពួកគេទៅហើយ នោះ? តើការណ៍ នេះគ្រាប់អ្នកអ្វីខ្លះ អំពីចិត្តរបស់ម៉ូរីណា? ភាពជាអ្នកដឹកនាំរបស់ម៉ូរីណាខុស គ្នាយ៉ាងខ្លាំងពីភាពជាអ្នកដឹកនាំរបស់ សេរ៉ាហិមណា។ អ្នកគួរតែចងចាំថា ពួកគេទាំងពីរគឺជាសាសន៍នីហ្វៃ ហើយការប្រយុទ្ធជាច្រើននោះ មានរវាង សាសន៍នីហ្វៃ ដែលប្រកបដោយជំនឿ និងពួកក្បត់សាសនាសាសន៍នីហ្វៃ ជាមួយពួកសាសន៍លេមិន ពួកគេត្រូវបានបញ្ចុះបញ្ចូល ដើម្បីឱ្យប្រយុទ្ធ ជាមួយពួកមានជំនឿសាសន៍នីហ្វៃ។ សង្គ្រាមនេះអាចត្រូវបានការពារ បើសិនជាមិនមានប្រជាជនដូច សេរ៉ាហិមណាទេនោះ។ តើអ្នកមាន អារម្មណ៍យ៉ាងណាខ្លះ នៅពេលមានអ្វីមួយមករារាំងមិនឱ្យហេតុការណ៍ កើតឡើង នៅក្នុងជីវិតរបស់អ្នក?

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 44

មួយរយៈ (ខ. 1)—ចម្ងាយយ៉ាងខ្លីមួយ

ធ្វើឱ្យមាន (ខ. 7)—ប្រគល់ បណ្តាលឱ្យ

ដល់ស្លាប់ (ខ. 7)—ស្លាប់ទាំងអស់

ដងដាវ (ខ. 12)—ដង

ខឹង (ខ. 16)—ខឹង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរនៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 44។

ក ដឹកនាំការសម្ភាសន៍មួយ

ចូរនឹកគិតថា អ្នកអាចសម្ភាសន៍មេបញ្ជាការមរ៉ូណៃ និងសេរ៉ាហិមណា បន្ទាប់ពីសង្ត្រាម។ ចូររំលឹក អាលម៉ា 44:1–9 សារឡើងវិញ ហើយបញ្ចូលផ្នែកដែលមានដូចខាងក្រោមនោះ នៅក្នុងកិច្ចសម្ភាសរបស់អ្នកៈ

1. ចូរប្រៀបធៀបអំពីអ្វី ដែលមរ៉ូណៃ និងសេរ៉ាហិមណា បានទិយាយដែលជាមូលហេតុ ដើម្បីឱ្យពួកសាសន៍នីហ្វៃមានជ័យជំនះ (សូមមើល អាលម៉ា 44:3–4, 9)។
2. ចូរពន្យល់ ហេតុអ្វីក៏អ្នកគិតថា សំរាប់មនុស្សខ្លះមានការលំបាក ដើម្បីស្គាល់ព្រះចេស្តានៃព្រះ (សូមមើល នីហ្វៃទី3 2:1–2)។

ខ សរសេររបាយការណ៍សារពតិមាន

ចូរសរសេររបាយការណ៍សារពតិមានមួយ អំពីកន្លែងធ្វើសង្ត្រាម ដែលមានចុះបញ្ជីនៅ អាលម៉ា 44:11–24 ដើម្បីឱ្យអ្នកស្តាប់មានការរសាប់រសល់ អំពីជំណឹងនៃសង្ត្រាមនោះ។

គ ធ្វើការប្រៀបធៀបមួយ

1. ចូររំលឹក អាលម៉ា 44:11–24 សារឡើងវិញ ហើយធ្វើបញ្ជីអំពីវិធី ដែលមរ៉ូណៃ បានបង្ហាញទាំងនៅក្នុងសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណា សូម្បីតែនៅពេលធ្វើសង្ត្រាម (សូមមើល អាលម៉ា 43:54)។
2. សូមអាន អាលម៉ា 42:22–24 ហើយប្រៀបធៀបអំពីសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណារបស់មរ៉ូណៃ ទៅនឹងសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណារបស់ព្រះ។

គើនៅពេលណា ដែលអ្នកមានការសម្ភាសន៍ជាលើកចុងក្រោយជាមួយឱពុក ឬអ្នកដឹកនាំបព្វជិតភាពរបស់អ្នក?មុនពេលប្រគល់ បញ្ជី ហើយនឹងភាពជា

អ្នកដឹកនាំទៅឱ្យហេលេមិន កូនប្រុសរបស់គាត់ អាលម៉ា បានសម្ភាសហើយប្រសិទ្ធពរដល់ហេលេមិន។ ចូររកមើលអំពីរបៀបនៃការសម្ភាសន៍របស់ហេលេមិន ទៅប្រៀបធៀបជាមួយនឹងការសម្ភាសន៍ ដែលអ្នកបានទទួលនោះ។ ចូរកត់ចំណាំនូវការណែនាំដ៏សំខាន់ ដែលគាត់បានទទួល ហើយតើការហៅឱ្យបំរើរបស់គាត់លំបាកយ៉ាងណា។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 45

អន់ថយ (ខ. 10, 12)—ធ្លាក់ចេញ បន្តិចម្តងព្ធ

ជម្ងឺអាសន្នរោគ (ខ. 11)—ជម្ងឺ

សាបសូន្យអស់ទៅ (ខ. 11, 14)—បំផ្លាញទាំងស្រុង

អំពើអាសអាភាស (ខ. 12)—អំពើគ្មានសីលធម៌ តណ្ហា

ការបែកបាក់គ្នា (ខ. 21, 23)—ការប្រឆាំង ការក្បត់

ច្បាប់ (ខ. 21)—ការកែលំអ ការរៀបចំសារជាថ្មី

អាលម៉ា

អាលម៉ា 45:18–19—តើអាលម៉ាត្រូវបានប្រែរូបឬ?

ប្រធានយ៉ូសែប ហ្វីលឌីង ស្មុីធ បង្រៀនថាៈ "វាគឺជាតំនិតដ៏មានមូលហេតុបំផុត ដើម្បីជឿថា ទាំងម៉ូសេ និងអាលម៉ា ក៏ដូចជា អេលីយ៉ា និងយ៉ូហាន [វិវរណៈជន] ត្រូវបានប្រែរូប ដើម្បីសំរេចនូវការងារខ្លះ ដែលព្រះអម្ចាស់មានបំរុងសំរាប់ពួកគេនៅថ្ងៃណា មួយទៅអនាគត" (*Answers to Gospel Questions* 5:38)។ នៅពេលមនុស្សសុចរិតម្នាក់ព្ធ ត្រូវបានប្រែរូបរូបកាយ របស់ពួកគេត្រូវបានផ្លាស់ប្តូរ ដូច្នេះពួកគេមិនស្ថិតនៅក្រោមការឈឺចាប់ ឬសេចក្តីស្លាប់នៃជីវិតមតៈទេ។ ពេលខ្លះមនុស្សដែល ប្រែរូប គឺត្រូវបានយកទៅពីផែនដី ដោយគ្មាននូវការពិសោធន៍នៃសេចក្តីស្លាប់ទេ ដើម្បីនឹងសំរេចតាមគោលបំណងរបស់ ព្រះអម្ចាស់។ ទោះជាយ៉ាងណាក៏ដោយ មនុស្សដែលត្រូវបានយកទៅឯព្រះអង្គនឹងទទួលនូវការផ្លាស់ប្តូរនៅក្នុង ពេលអនាគត នៅពេលពួកគេឆ្លងកាត់ពីស្ថានភាពប្រែរូប ទៅជាស្ថានភាពជំណើររស់ឡើងវិញ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា45។

ក ការសម្ភាសន៍ជាមួយអាលម៉ា

អាលម៉ា 45:1–8 មាននូវការសម្ភាសន៍របស់អាលម៉ា ជាមួយនឹងកូនប្រុសរបស់គាត់ហេលេមិន។ ចូរនឹកគិតថា អាលម៉ា កំពុងធ្វើការសម្ភាសន៍ជាមួយអ្នក។ ចូរសរសេរសំណួរបស់អាលម៉ា និងរបៀបដែលអ្នកនឹងឆ្លើយសំណួរនោះ។

២ ការផ្តល់មតិរបស់អ្នក

សូមរំលឹកអាលម៉ា 45:9–14 សារឡើងវិញ។

1. សូមសង្កេតការព្យាករណ៍សំខាន់ៗ ដែលអាលម៉ា សុំឱ្យហេលេមិន រក្សាទុកជាសម្ងាត់។
2. ចូរសរសេរនូវមតិរបស់អ្នក អំពីមូលហេតុ ដែលការព្យាករណ៍ ត្រូវការរក្សាទុកជាសម្ងាត់។
3. តើការព្យាករណ៍នេះ បង្រៀនយើងអ្វីខ្លះ អំពីសមត្ថភាពរបស់អាលម៉ា ដើម្បីព្យាករ និងមើលពីអនាគតដោយចាត់ទុក ថាជាអំណោយមួយមកពីព្រះ?

៣ មនុស្សត្រូវបានប្រែរូប

សូមអានអាលម៉ា 45:18–19 សេចក្តីថ្លែងការណ៍ដោយប្រធាន យ៉ូសែប ហ៊ីលម៉ិង ស្មីធ នៅក្នុងកណ្តុ “ការយល់ដឹងអំពីព្រះគម្ពីរ” សំរាប់អាលម៉ា 45:18–19 សូមសរសេរយ៉ាងហោចណាស់អំពីសេចក្តីពិតបី ដែលអ្នករៀនអំពីមនុស្សដែលត្រូវបានប្រែរូប មកពីប្រតពទាំងបីនេះ។

តើអ្នកមានចង់ចាំនូវការអាន អំពីការប្រឆាំងរបស់អាំលិសៃ នៅក្នុងអាលម៉ា 2 ឬទេ?ការប្រឆាំងស្រដៀងគ្នាមួយ បានកើតឡើង នៅអាលម៉ា 46។ អាម៉ាលិកាយជាមនុស្សម្នាក់ទៀត ចង់ធ្វើជាស្តេច បានស្វែងរកវិធីរំលំអ្នកត្រួតត្រាពួកសាសន៍នីហ្វៃ។ សូមស្វែង រកមើល នូវមេបញ្ជាការរបស់សាសន៍នីហ្វៃ ដែលបានបោះដំហានទៅមុខ ដើម្បីជំទាស់អាម៉ាលិកាយ។ គាត់ទីងក្លាយជាវិរបុរស ម្នាក់ ក្នុងចំណោមវីរបុរសទាំងឡាយ ដែលអ្នកពេញចិត្តយ៉ាងខ្លាំង នៅក្នុងព្រះគម្ពីរមរមន។ ចូរកត់ចំណាំផងដែរ នូវវិធីសាស្ត្រ ដែលមេបញ្ជាការនេះ ប្រើដើម្បីសម្រុះសម្រួលប្រជាជនរបស់គាត់ ឱ្យទទួលបាននូវសេរីភាព ហើយពិចារណាពីមូលហេតុដែលទាំងឱ្យ មានឥទ្ធិពលខ្លាំងដល់ម្ល៉េះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 46

ខឹង (ខ. 2–4)—ខឹង

ភាពមិននឹងនរ (ខ. 7)—មិនមានសុវត្ថិភាព ដោយប្រថុយ

មានកលល្បិច (ខ. 10)—ផែនការដ៏ឆ្លាត

ចងក្រណាត់ (ខ. 12–13, 19, 21)—ហែក ដែលរហែក

ក្រវាត់នៅជាប់នឹងចង្កេះរបស់ពួកគេ (ខ. 21)—ចងនៅជុំវិញចង្កេះរបស់ពួកគេ

សំណល់ (ខ. 23–24, 27)—ផ្នែកដែលនៅសល់

ទៅខាងមុខ (ខ. 32)—បញ្ជាប់តាមទាន់ ហើយកាត់ផ្តាច់

ឡើងលើ (ខ. 36)—លើកឡើង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 46។

ក កត់សំគាល់នូវពាក្យគន្លឹះ

1. ចូរគូរកូឡោនបី ហើយចិទនៅលើវាអំពី “ចំណង់របស់អាម៉ាលិកាយ” “វិធីសាស្ត្ររបស់អាម៉ាលិកាយ” និង “ឥទ្ធិពលរបស់ អាម៉ាលិកាយ។” ចូររំលឹកអាលម៉ា 46:1–7 សារឡើងវិញ ហើយធ្វើបញ្ជីពាក្យគន្លឹះ នៅក្រោមចំណងជើងទាំងនេះ។
2. ចូរស្រាវជ្រាវនូវ ខ 8–10 ហើយពន្យល់អំពីអ្វី ដែលយើងអាចរៀនពី លទ្ធផលនៃឥទ្ធិពលរបស់អាម៉ាលិកាយ មានចំពោះ ពួកសាសន៍នីហ្វៃ។
3. តើប្រជាជន ក្រុម ឬអង្គការទាសាសន៍ថ្ងៃនេះ អាចមានចំណង់ដូចគ្នា និងប្រើវិធីសាស្ត្រដូចគ្នា ដូចដែលអាម៉ាលិកាយបានធ្វើ ដែរឬទេ?

ខ សរសេរនូវកំណែថ្មីទំនើបមួយ

សូមអាននូវអ្វី ដែលមេបញ្ជាការម៉ូរីណាសរសេរនៅលើទង់ឥស្សរភាព នៅអាលម៉ា 46:12។ (អ្នកអាចគូសចំណាំ នៅក្នុងព្រះគម្ពីររបស់អ្នក។) ចូររៀបចំទង់ឥស្សរភាពរបស់អ្នកផ្ទាល់ ដែលអ្នកដាក់តាំងនៅក្នុងបន្ទប់របស់អ្នក ឬនៅថ្នាក់សិក្ខាសាលា។ សូមបញ្ចូលនូវពាក្យ ឬរូបភាពនៃអ្វី ដែលអ្នកមានអារម្មណ៍ថា ជាការបង្កា និងការពារដ៏មានតម្លៃ។

គ ពន្យល់អំពីរូបភាព

សូមរំលឹក អាលម៉ា 46:21–28 សារឡើងវិញ ហើយសរសេរបញ្ជូលទៅក្នុងស្បៃរភៅកំណត់ហេតុ បើអ្នកបាននៅទីនោះ។ ចូរពន្យល់អំពីអ្វី ដែលកើតឡើង នៅក្នុងរូបភាព និងអំពីអារម្មណ៍ដែលអ្នកអាចមានកាលដែលអ្នកបានស្តាប់មេទ័ពម៉ូរីណា។

អាលម៉ា 47

បុរសដែលចង់ធ្វើជាស្តេច

សេចក្តីពិតដែលថា អាម៉ាលិកាយត្រូវតែគេស្រុះស្រួលខ្លួនចេញពីដែនដីសារ៉ាហិមឡា ដើម្បីសង្គ្រោះជីវិតរបស់គាត់ គឺមិនបានបញ្ជាក់ប៉ះ ផែនការរបស់គាត់ ដើម្បីឱ្យមានអំណាចនោះទេ។ គាត់ បានគ្រោងដើម្បីប្រើពួកសាសន៍លេមិន ឱ្យជួយច្បាំងនឹងពួកសាសន៍នីហ្វៃ ដូច្នេះគាត់អាចក្លាយទៅជាស្តេចនៅលើដែនដីទាំងមូល។ អ្នកនឹងរកឃើញថា ផែនការដ៏ឆ្លាតវៃរបស់គាត់ បានបង្ហាញគ្រឹមតែ អំពើទុច្ចរិតរបស់គាត់ ហើយថាគាត់មិនសូវខ្វល់ខ្វាយអំពីនរណាឡើយ ក្រៅតែពីខ្លួនឯងប៉ុណ្ណោះ។

លីហុនតៃ

អាម៉ាលិកាយ

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 47

សេចក្តីប្រកាស (ខ. 1–2)—សារលិខិតជាផ្លូវការ ឬការប្រកាស

បង្ខំឱ្យប្រជាជនប្រដាច់អាវុធ (ខ. 3)—បង្ខំពួកគេឱ្យប្រយុទ្ធ

នោះជាកន្លែង (ខ. 5)—ទីនោះ

យ៉ាងមុតមាំ (ខ. 6)—ការតាំងចិត្តដោះស្រាយ

ព្រម (ខ. 6)—បង្ខំ បង្គាប់

ទម្លាក់ស្តេចពីបល្ល័ង្កចោល (ខ. 8)—ដកពីអំណាច

សារទូត (ខ. 10, 32)—អ្នកនាំសារ ឬពួកអ្នកនាំសារជាផ្លូវការ

ជាសន្សឹមៗ (ខ. 18)—បន្តិចម្តងៗ ពេលបន្តិចម្តងៗ

ទីសំគាល់ (ខ. 23)—និមិត្តរូប

ការបន្ល (ខ. 30, 35)—មិនស្មោះត្រង់ ការបញ្ឆោត

ប្រកបដោយកលល្បិច (ខ. 35)—ដែលបោកបញ្ឆោត ដោយកលល្បិច

ពួកដែលបែកចេញ (ខ. 35–36)—ប្រឆាំង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះនៅពេលអ្នកសិក្សា អាលម៉ា 47។

ក ធ្វើគម្រោងផែនការ

អាលម៉ា 47:4–19 ប្រាប់យើងអំពីផែនការរបស់អាម៉ាលិកាយ ដើម្បីក្លាយជាស្តេច។ សូមប្រើខដែលមានចុះបញ្ជីខាងក្រោម នេះ រួចពន្យល់អំពី *អ្វី* និង*ហេតុអ្វី* នៅក្នុងផែនការរបស់គាត់។

តើអាម៉ាលិកាយធ្វើអ្វីខ្លះ?	តើហេតុអ្វី បានជាគាត់ធ្វើវា?
(សូមមើលខ. 5)	(សូមមើលខ. 4)
(សូមមើលខ. 10)	(សូមមើលខ. 8)
(សូមមើលខ. 13)	
(សូមមើលខ. 18)	

ខ តើពួកគេនឹងនិយាយអ្វីខ្លះ?

បន្ទាប់ពីអានទូរអ្វី ដែលអាម៉ាលិកាយធ្វើ ទៅអាលម៉ា 47:20–29 ចូរសរសេរទូរសេចក្តីថ្លែងការណ៍ខ្លីមួយ ដែលអ្នកគិតថា វាជាតំណាងឱ្យអ្វី ដែលក្រុមនៃប្រជាជនទីមួយៗ ខាងក្រោមនេះ នឹងនិយាយអំពីអ្វី ដែលបានកើតឡើងៈ

1. អ្នកបំរើរបស់ស្តេច
2. អ្នកបំរើរបស់អាម៉ាលិកាយ
3. ប្រជាជនរបស់អាំម៉ូន

គ សរសេរសេចក្តីថ្លែងការណ៍ “ហេតុដូច្នេះហើយយើងឃើញថា”

អាលម៉ា 47:36 បង្រៀនទូរសេចក្តីពិតដ៏គួរឱ្យចាប់អារម្មណ៍អំពីជីវិត។ ចូរពិចារណាអំពីអ្វី ដែលលោកមរមន បានសរសេរ ហើយបន្ទាប់មកតាត់សរសេរមេរៀនមួយ ដែលយើងអាចរៀនមកពីខគម្ពីរនេះ ហើយតើមេរៀននេះ អាចអនុវត្តទៅក្នុងពេល បច្ចុប្បន្នដោយរបស់យើងរបៀបណា។

អាលម៉ា 48

មេទ័ពម៉ូរ៉ៃណា បុរសរបស់ព្រះ

ចូរគិតអំពីអ្នកដឹកនាំម្នាក់ ដែលមានឥទ្ធិពលដ៏ខ្លាំងនៅក្នុងជីវិតរបស់អ្នក? តើគុណសម្បត្តិអ្វីខ្លះ ដែលអ្នកគិតថាអ្នកដឹកនាំ ដ៏មានជោគជ័យម្នាក់គួរតែមាន? ព្រះអម្ចាស់ប្រទានពរដល់ពួកសាសន៍នីហ្វៃជាមួយនឹងអ្នកដឹកនាំដ៏អស្ចារ្យម្នាក់ក្នុងគ្រាមួយ ដែលពួកសាសន៍លេមិន បានតាំងចិត្តដើម្បីគ្រប់គ្រងលើដែនដីទាំងមូល។ តើការណ៍អ្វីខ្លះដែលធ្វើឱ្យមេបញ្ជាការម៉ូរ៉ៃណាអស្ចារ្យ?នៅពេលអ្នកអាន អាលម៉ា 48 ចូរសំគាល់នូវចរិតលក្ខណៈរបស់គាត់ខ្លះៗ ដែលអ្នកចង់បាន

នៅក្នុងជីវិតរបស់អ្នក។ សូមរកមើលផងដែរនូវការបង្ហាញការដឹងគុណ ដែលលោកមរមនបានជ្រៀនូវសេចក្តីក្លាហានរបស់អ្នកដឹកនាំ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 48

ទីតាំង (ខ. 5–8)—ដោយសុវត្ថិភាព ទីជម្រក

បន្ទាយ (ខ. 9)—សំណង់ប្រើសំរាប់ការពារ

បំរើ (ខ. 19)—ជាប្រយោជន៍, មានប្រយោជន៍ មានប្រសិទ្ធិភាព

ដោយរុញរា ការរុញរា (ខ. 21–22)—ដោយភាពស្ទាក់ស្ទើរ

ព្រៃផ្សៃ (ខ. 24)—សាហាវ គិរឆ្ឆាន

អាលម៉ា 48:19—"ក៏បំរើប្រជាជនមិនអន់ជាង"

© 1998 Merrett T. Smith

នៅពេលយើងអានអំពីវិរបុរសដ៏អស្ចារ្យនានា នៅក្នុងព្រះគម្ពីរ ពេលខ្លះយើងអាចមានអារម្មណ៍ថា យើងមិនអាចប្រៀបនឹង មាត្រដ្ឋានដ៏ខ្ពស់របស់ពួកគេ ឬមិនទទួលជោគជ័យច្រើន ដើម្បីជួយកសាងនរគព្រះបានឡើយ។ ប្រធានហារីដ ដបុលយូ ហឹនធើរ ដែលក្រោយមកជាប្រធាន នៃក្រុមសាវកដប់ពិរនាក់ បង្រៀនថាះ "មិនមែនសិស្សនៅសាលាទាំងអស់ នឹងក្លាយទៅជាសិស្សជំនិត របស់ប្រធាន ឬប្រធានសមាគមសង្គ្រោះ ឬត្រូនៃក្រុមអែលឌើរនោះទេ។ មិនមែនអ្នកទាំងអស់គ្នានឹងក្លាយដូចជាមរ៉ូណៃ ទទួល បានការស្រែក អបអរសាទរពីអ្នកធ្វើការរួមគ្នារបស់អ្នករាល់ពេល រាល់ថ្ងៃនោះទេ។ ទេ មនុស្សភាគច្រើននឹងនៅស្ឋៀមស្ងាត់ ញាតិសន្តានដែលមិនស្គាល់បានមក ហើយទៅវិញ ហើយធ្វើការរបស់ពួកគេដោយគ្មានភាពអឹកធឹកឡើយ។ ចំពោះអ្នកទាំងឡាយ ណា ដែលមានអារម្មណ៍ថា ខ្លួនឯកកោរ ឬមានការភ័យខ្លាច ឬត្រឹមតែមិនអស្ចារ្យនោះ ខ្ញុំនិយាយថា អ្នក 'ក៏បំរើ ប្រជាជនមិន អន់ជាង' មនុស្សដ៏អស្ចារ្យនៅក្នុងសង្គមរបស់អ្នក។ អ្នក គឺជាផ្នែកមួយនៃកងទ័ពរបស់ព្រះផងដែរ" ('"No less Serviceable"' នៅក្នុង *Brigham Young University 1990—91 Devotional and Fireside Speeches* [1991], 2)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 48។

ក្ប ប្រៀបធៀបការរៀបចំ

ទាំងមរ៉ូណៃ និងអាម៉ាលិកាយ មានផែនការ ដើម្បីយកឈ្នះ នៅក្នុងសង្គ្រាមដែលនឹងមកដល់។

1. ចូរំលឹក អាលម៉ា 48:1–10 សារឡើងវិញ ហើយប្រៀបធៀបនូវអ្វី ដែលអ្នកដឹកនាំម្នាក់ព្យបានធ្វើ ដើម្បីរៀបចំប្រជាជនរបស់ពួកគេ។
2. តើជាដំបូងមេទ័ពមរ៉ូណៃធ្វើអ្វី ដើម្បីរៀបចំប្រជាជនរបស់គាត់? តើការណ៍នោះបង្រៀនអ្នកអ្វីខ្លះ អំពីប្រាជ្ញា និងជំនឿរបស់គាត់?
3. តើដោយវិធីណាខ្លះ ដែលអ្នកអាចអនុវត្តនូវអ្វី ដែលមរ៉ូណៃបានធ្វើ ដើម្បីតទល់នូវអ្វី ដែលអ្នកជួបប្រទះនៅក្នុងជីវិត?

ខ សរសេរការណែនាំមួយ

សូមប្រើគំនិតចេញពីអាលម៉ា 48:10–13, 17–18 រួចសរសេរយ្លាមួយ ដែលអាចអានបានបើសិនជាអ្នកត្រូវសុំឱ្យធ្វើការណែនាំ អំពីលោកមរ៉ូណៃ នៅពេលអ្នកនិយាយនៅក្នុងការប្រជុំពិសេសរបស់យុវជនយុវនារី។

គ តើពួកគេជឿអ្វីអំពីសង្គ្រាម?

ឧបមាថាត្រូប្រវត្តិសាស្ត្ររបស់អ្នក សុំឱ្យសមាជិកក្នុងថ្នាក់របស់អ្នក ស្រាវជ្រាវអំពីសាសនា ឬវប្បធម៌ ដែលមានសេចក្តីជំនឿ ជាក់លាក់អំពីសង្គ្រាម។

1. សូមសិក្សា អាលម៉ា 48:14–16, 23–25 ហើយសរសេរនូវយ្លាមួយ ដែលពន្យល់អំពីជំនឿនៃពួកសាសន៍នីហ្ចៃ។
2. តើអ្នកគិតថា វានឹងមានការផ្លាស់ប្តូរអ្វីខ្លះ នៅក្នុងពិភពលោក បើសិនជាមនុស្សម្នាក់ព្យមានជំនឿបែបនោះ?

អាលម៉ា 48 ប្រាប់យើងអំពីការរៀបចំនីមួយព្យ របស់មរ៉ូណៃ និងអាមាលិកាយ បង្កើតឡើងដើម្បីធ្វើសង្គ្រាម។ នៅអាលម៉ា 49 អ្នកនឹងអានអំពីលទ្ធផលនៃការរៀបចំទាំងនោះ។ តើអ្នកគិតថា មានភាពខុសគ្នាអ្វីខ្លះ នឹងកើតមានឡើងដោយមកពីការទុកចិត្ត លើកម្លាំងរបស់ខ្លួនឯង ដូចជាអាមាលិកាយ ដែលជំទាស់នឹងការទុកចិត្តទៅលើព្រះអម្ចាស់ ដូចជាមរ៉ូណៃ? នៅពេលអ្នកអានក្នុងជំពូកនេះ ចូរស្វែងរកនូវរបៀប ដែលអ្នកអាចអនុវត្តគោលការណ៍ទាំងឡាយ ដែលអ្នកបានរៀននៅក្នុងជីវិតអ្នកផ្ទាល់។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 49

បានដាក់ (ខ. 2)—ទុក

ភ្លីដី (ខ. 4)—ជញ្ជាំងនៃភក់ជ្រាំ ឬដី

បានជួសជុល (ខ. 11)—បានផ្លាស់ប្តូរ

ដ៏ធ្ងន់ធ្ងរ (ខ. 21)—មហិមា ធ្ងន់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សា អាលម៉ា 49។

ក្ប ធ្វើជាអ្នកយកការណ៍នៃសង្គ្រាមមួយ

ឧបមាថា អ្នកគឺជាអ្នករាយការណ៍សារពតិមាន ដែលត្រូវបានចាត់ឱ្យដើរតាមកងទ័ពពួកលេមិន ចូលទៅក្នុងទីលានប្រយុទ្ធ។

1. ចំពោះខគម្ពីរទាំងបី ទីមួយៗ បានដាក់នៅខាងក្រោមនេះ សូមធ្វើការរៀបចំដើមរឿង ហើយសរសេរពាក្យការណ៍សារពិតមាន សង្ខេបមួយ ដោយពិពណ៌នាទៅដល់អ្នកអានរបស់អ្នក អំពីអ្វីដែលបានកើតឡើង៖ អាលម៉ា 49:1–12, 13–25 និង 26–30។

2. សាវកប៉ុល បង្រៀនថា “ត្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច នឹងពួកម្ចាស់ នៃសេចក្តីងងឹតនៅលោកីយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ” (សូមមើល អេភេសូរ 6:12)។ ចូរពន្យល់អំពីរបៀបដែលអ្នកអាចយកមេរៀន ដែលអ្នកបានរៀនអំពីការរៀបចំ របស់ពួកសាសន៍នីហ្វៃ ដើម្បីធ្វើសង្គ្រាម ហើយយកការរៀបចំទាំងនោះ មកអនុវត្តក្នុងការប្រយុទ្ធ ឬតស៊ូប្រឆាំងនឹងអំពើបាប និងអំពើទុច្ចរិតនៅខាងវិញ្ញាណ របស់អ្នកវិញ។

អាលម៉ា 50

ព្រះអម្ចាស់នឹងចំរើនដល់ភូន ចៅស្តាប់បង្គាប់របស់ទ្រង់

តើជាញឹកញាប់ប៉ុណ្ណា ដែលការអានព្រះគម្ពីរមរមនរបស់អ្នក ដែលអ្នកបានអានអំពី សេចក្តីសន្យារបស់ព្រះអម្ចាស់ថា បើសិនជា ប្រជាជននឹងរក្សាបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះគេនឹងបានចំរើនឡើងនៅលើដែនដីសន្យា? ហើយ តើជាញឹកញាប់ ប៉ុណ្ណា ដែល អ្នកឃើញពិតស្មុគស្មាញនៃសេចក្តីពិតនៃការសន្យានោះ នៅក្នុងជីវិតរស់នៅរបស់ ប្រជាជននៅក្នុងព្រះគម្ពីរមរមន? អាលម៉ា 50 បានផ្តល់ជាគំរូមួយទៀតអំពីសេចក្តីពិត។ តើហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់ឱ្យអ្នកបំរើរបស់ទ្រង់ រំលឹកសារដំណឹងនោះឡើងវិញ យ៉ាងញឹកញាប់ដូច្នេះ?

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 50

ចំរុងស្រួចទាំងស្រុង (ខ. 3)—របងស្រួច បង្គោលស្រួច

ការធានា (ខ. 12)—សន្យា

ត្រូវបានបញ្ជាក់ (ខ. 19)—ដែលបញ្ជាក់សេចក្តីពិត

ត្រូវបានដាក់ទៅក្នុង (ខ. 22)—ចាត់ឱ្យ ប្រគល់ឱ្យ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សា អាលម៉ា 50។

ក គូររូបភាពមួយ

អាលម៉ា 50:1–6 បានផ្តល់នូវការពិពណ៌នាអំពី ប្រភេទនៃការសង់របងការពារ ដើម្បីការពារទីក្រុង។ ចូរគូរ របងទាំងនោះឱ្យមានរាងដូចតាមការគិតរបស់អ្នក។ ចូរចងចាំថា របងការពារទាំងនោះ មានភាពរឹងមាំគ្រប់គ្រាន់ ដែលពួកសាសន៍នីហ្វៃ អាចទប់ទឹងចំនួនដ៏សន្ធឹករបស់អ្នកចម្បាំងពួកសាសន៍លេមិនទ។

ខ ពន្យល់អំពីមូលហេតុ

អាលម៉ា 50:23 មានន័យការសង្កេតដ៏សំខាន់ អំពីជំនាន់នោះ នៅក្នុងប្រវត្តិសាស្ត្រពួកសាសន៍នីហ្វៃ។

1. ចូរសិក្សា អាលម៉ា 50:17–22 ហើយធ្វើបញ្ជីអំពី សេចក្តីពិត ដែលមរមន ចង់ឱ្យយើងរៀនសូត្រតាម។

2. អ្នកគិតថា ហេតុអ្វីប្រជាជនទាំងនោះ សប្បាយរីករាយខ្លាំងយ៉ាងនេះ?

អាលម៉ា 51

ការប្រឆាំងជាមួយពួកអ្នកនិយមស្តេច

តើអ្នកធ្លើអ្វីខ្លះ នៅពេលបានជួបជាមួយនឹងគំនិតប្រឆាំង នៅលើរឿងដ៏សំខាន់? នៅពេលអ្នកអានអាលម៉ា 51 សូមរកមើលទូរ ការប៉ះទង្គិច ដែលពួកសាសន៍នីហ្វៃ ជួបប្រទះ និងអ្វី ដែលធ្វើឱ្យស្ថានភាពមានផលវិបាកកាន់តែខ្លាំងឡើង។ សូមគិតថា តើក្រុម មួយណា ដែលអ្នកនឹងរើសយក បើអ្នករស់នៅក្នុងអំឡុងពេលនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 51

ត្រកូលខ្ពស់ (ខ. 8)—អតិជន គោតទ្រព្យអានុភាព

ខឹង (ខ. 13–14)—ខឹង

សំណូមពរ (ខ. 15)—សរសេរស្នើសុំជាផ្លូវការ

មានឋាម (ខ. 21)—ឈ្មោះ មាតិការ

ដែលអះអាងថា ជាឈាម (ខ. 21)—អះអាងថា ជាមនុស្សមានឋានៈខ្ពស់តាំងពីកំណើតរបស់ពួកគេ។

កលល្បិច (ខ. 27)—ផែនការដ៏ឆ្លាតឧបាយកល

រុញឱ្យថយក្រោយ (ខ. 31)—រុញមកក្រោយ

វាយរំខាន (ខ. 32)—បន្តវាយ និងរំខាន

លំពែង (ខ. 34)—លំពែង



អាលម៉ា 51:5–6—តើអ្នកណាជា ពួកមនុស្សសេរី និងពួកនិយមស្តេច?

មានរដ្ឋាភិបាលពីរប្រភេទ ដែលមានពិពណ៌នានៅ អាលម៉ា 51។ ប្រភេទទីមួយ គឺពឹងផ្អែកទៅលើគំនិតប្រជាជនជាធំ (ពួកមនុស្សសេរី)គឺនឹងជ្រើសរើស “ធ្វើអ្វីៗ ដែលត្រឹមត្រូវ” (ម៉ូសាយ 29:26)។ ប្រភេទមួយទៀត គឺជាក្រុមមនុស្ស (ពួកនិយមស្តេច) ដែលចង់បាន “អានុភាព និងសិទ្ធិអំណាចលើប្រជាជន” (អាលម៉ា 51:8) សំរាប់ខ្លួនពួកគេ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 51។

ក្ស សរសេរជាការពិពណ៌នាមួយ

តើសារលិខិតប្រភេទអ្វី ពេលពួកអ្នកនិយមស្តេច និងពួកមនុស្សសេរីផ្តល់ឱ្យ ដែលបានអូសទាញ ប្រជាជនមកគាំទ្រខាងពួកគេ? បន្ទាប់ពីអានអាលម៉ា 51ះ1–8 សូមសរសេរនូវការពិពណ៌នា ដ៏សង្ខេបមួយ អំពីទស្សនៈគោលនយោបាយរបស់ពួកគេ។

ខ ស្វែងរកចម្លើយ

នៅពេលអ្នកសិក្សាអាលម៉ា 51ះ13–21 ចូរសរសេរចម្លើយ តាមសំណួរដូចខាងក្រោមៈ

1. តើអ្វីខ្លះ ជាការឆ្លើយតបរបស់ពួកអ្នកនិយមស្តេច ចំពោះការវាយប្រហាររបស់ពួកសាសន៍លេមិន?
2. តើរដ្ឋាភិបាល ឆ្លើយតបទៅនឹងសកម្មភាពរបស់ពួកអ្នកនិយមស្តេច ដូចម្តេចខ្លះ?
3. តើមូ៉រ៉ៃណៃ បញ្ជាប់ការបះបោរ នៃពួកអ្នកនិយមស្តេចបាន ដោយរបៀបណា?
4. តើហេតុអ្វី អ្នកគិតថា ជាការចាំបាច់សំរាប់មូ៉រ៉ៃណៃ បានធ្វើនូវអ្វី ដែលគាត់បានធ្វើ?
5. តើហេតុអ្វីអ្នកសន្មត់ថា មរមន បានបញ្ជូលនូវការលំអិតទាំងអស់នោះ អំពីការឈ្លានពានលើ សេរីភាព នៅក្នុងសេចក្តីសង្ខេប របស់គាត់ នៃបញ្ជីនីហ្ហៃដូច្នេះ? (សូមមើល មរមន 8ះ34–35)។

ត្ស និទានរឿងមួយ

សូមរំលឹក អាលម៉ា 51ះ29–37 សារឡើងវិញ ហើយតាមពាក្យសំដីអ្នកផ្ទាល់ ចូរសរសេររឿងមួយ នៃទីអាន់គុម និងអាម៉ាលិកាយ ដែលអ្នកអាចនិទានសំរាប់កុមារក្នុងថ្នាក់អង្គការបឋមសិក្សា។



អាលម៉ា 52

ជ័យជំនះរបស់ពួកនីហ្ហៃ

តើអ្នកធ្លាប់ប្រឈមមុខជាមួយនឹងគ្រោះថ្នាក់ផ្ទួនៗ ឬទេ? គ្រោះថ្នាក់ផ្ទួនៗ គឺជាស្ថានភាពមួយ គំរូវឱ្យមានការជ្រើសរើស ដ៏លំបាកឆ្លាស់ទៅឆ្លាស់មក។ នៅអាលម៉ា 52 ពួកសាសន៍នីហ្ហៃ ជួបប្រទះនឹងគ្រោះថ្នាក់ផ្ទួនៗ យ៉ាងធ្ងន់ធ្ងរមួយទៀត។ នៅពេលអ្នក អានក្នុងជំពូកនេះ សូមមើលពីរបៀប ដែលព្រះអម្ចាស់ បានជួយដល់ពួកគេ ឱ្យរួចផុតពីគ្រោះថ្នាក់ផ្ទួនៗនោះ ហើយសូមគិតអំពី មធ្យោបាយនានា ដែលដំណោះស្រាយនោះ អាចជួយអ្នកក្នុងគ្រោះថ្នាក់ផ្ទួនៗរបស់អ្នក។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 52

លាក់ (ខ. 6)—មានសុវត្ថិភាព ទីជម្រក

ជាតម្លៃលោះ (ខ. 8)—តម្លៃនៃការប្តូរប្រាក់

ដើម្បីវាយ (ខ. 10)—វាយប្រហារ ទណ្ឌកម្ម

ឧបាយសឹក (ខ. 10)—ផែនការដោយប្រុងប្រយ័ត្ន

បញ្ជោរ (ខ. 19)—ល្ងងលោម អូសទាញ

អ្នកសារទូតទាំងឡាយ (ខ. 20)—អ្នកនាំសារជាផ្លូវការ

សំរេច (ខ. 21)—បានសំរេច

បញ្ជោត (ខ. 21)—ល្បិច ទាក់អន្ទាក់

ដោយខ្លាំងក្លា (ខ. 24)—ថាមពលកម្លាំង

មានចិត្តមិនចុះចាញ់ (ខ. 33)—ដោយមិនមានឆន្ទះលះបង់ ឬចុះចាញ់

ហាមមិនឱ្យ (ខ. 37)—បញ្ឈប់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សា អាលម៉ា 52។

ក្ស កត់សំគាល់អំពីគ្រោះថ្នាក់ផ្ទួនៗ ហើយធ្វើការសង្ខេបអំពីជំណោះស្រាយ

ពួកសាសន៍លេមិន បានដណ្តើមយកទីក្រុងរបស់ពួកសាសន៍នីហ្ហៃជាច្រើន ហើយបានប្រើ បន្ទាយការពាររបស់ខ្លួន ដើម្បីការពារ ទាហានរបស់ខ្លួន ពីកងទ័ពរបស់ពួកសាសន៍នីហ្ហៃ។ សូមអាន អាលម៉ា 52ះ16–20 ហើយកត់សំគាល់អំពី គ្រោះថ្នាក់ផ្ទួនៗ ដែលអ្នកដឹកនាំរបស់ពួកសាសន៍នីហ្ហៃបានជួបប្រទះ។

1. ចូររំលឹកសារឡើងវិញ នូវខ 21–32 ហើយសរសេរឃ្លាខ្លីមួយ សង្ខេបអំពី ឧបាយសឹករបស់ពួកសាសន៍នីហ្ហៃ ដែលបានប្រើ ដើម្បីយកឈ្នះលើពួកសាសន៍លេមិន។
2. តើផែនការ ឬការសំរេចចិត្តអ្វីខ្លះ អ្នកអាចធ្វើក្នុងពេលឥឡូវនេះ ដែលនឹងជួយអ្នកយកឈ្នះលើ ការវាយប្រហាររបស់សាតាំង នៅក្នុងដំណើរជីវិតរបស់អ្នក?

អាលម៉ា 53

កងពលកំឡោះពីរពាន់នាក់

ហេលេមិន

អែលឌើរ រិក ឌី. ភិនហ្គើរ ជាសមាជិកក្រុមចិតសិបនាក់ មានប្រសាសន៍ថា ៖“អ្នកទាំងឡាយ ដែលបានអានព្រះគម្ពីរមរមន គឺពិត ជាបានស្គាល់ច្បាស់នូវរឿងនៃកូនប្រុសហេលេមិន។ (សូមមើល អាលម៉ា 53:56–58) នៅពេលឪពុករបស់ពួកគេ បានផ្លាស់ ប្រែគំនិតមកទទួលជំណឿដ៏ល្អ ឪពុកទាំងឡាយបានធ្វើសេចក្តីសញ្ញាជាមួយព្រះអម្ចាស់ថា គាត់ទាំងអស់គ្នានឹងមិនលើកអាវុធម្តងទៀតទេ។ ប៉ុន្តែដោយថាហេតុ ត្រួសាររបស់ពួកគេ ត្រូវបានគំរាមគំហែងដោយកងទ័ពរបស់សត្រូវ ដើម្បីធ្វើការរាតត្បាតមកលើ ពួកគេ ដែលឪពុកទាំងឡាយនឹងត្រូវជ្រើសរើសធ្វើសង្គ្រាម ឬក៏ត្រូវស្លាប់។ ដោយហេតុថា យុវជនពីរពាន់នាក់ទៀត មិនបានជាប់ នឹងសេចក្តីសញ្ញាដូចគ្នានេះ យុវជនទាំងពីរពាន់នាក់ ក៏បានធ្វើការស្ម័គ្រចិត្ត ដើម្បីការពារឪពុកម្តាយរបស់ពួកគេ និងផ្ទះរបស់ពួកគេ” (នៅក្នុង Conference Report ខែតុលា ឆ្នាំ1982, 34 ឬ Ensign ខែវិច្ឆិកា ឆ្នាំ1982, 25)។ តើយើងអាចរៀនអ្វីខ្លះ អំពី សេចក្តីជំនឿ និងសកម្មភាពរបស់ពួកគេ? ប្រធាន ដេម អ៊ី ហ្វោស្ត បានប្រាប់ដល់អ្នកកាន់បព្វជិតភាពអើរ៉ុន នៃសាសនាចក្រ ថាៈ “តាមអ្វីដែលខ្ញុំគិតយុវជនរាល់គ្នាដូចជាអ្នកចម្បាំងកំឡោះរបស់ហេលេមិន ‘មានចិត្តក្លាហានអង់អាចដ៏អាចជាអតិបរមា ហើយ មានកម្លាំង និងធ្វើកិច្ចការជាអតិបរមាដែរ។ យើងសង្ឃឹមលើអ្នកដូចជាពួកគេ ជាមនុស្សស្មោះត្រង់គ្រប់ពេលវេលា ទោះនៅក្នុង កិច្ចការណាក៏ដោយដែល [អ្នក]ត្រូវបានប្រគល់ឱ្យ”’ (នៅក្នុង Conference Report ខែមេសា ឆ្នាំ 1998, 57 ឬ Ensign ខែឧសភា ឆ្នាំ 1998, 43)។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 53

បង្ខំ ត្រូវបានបង្ខំ (ខ. 1, 5, 15)—បង្ខំ

របងដែលធ្វើពីឈើនោះ (ខ. 4)—ជញ្ជាំងឈើ

បានប្រើខ្សៀ (ខ. 7)—ប្រើ

ឧបាយកល (ខ. 8– 9)—ការលបធ្វើអំពើអាក្រក់

ការបែកចេញទាំងឡាយ (ខ. 8–9)—ជម្លោះ ការបះបោរប្រឆាំង

ចិត្តក្លាហានអង់អាច (ខ. 20)—ក្លាហានបំផុត

ស្រគត់ស្រគំ (ខ. 21)—ដោយភាពមធ្យ័ត

កំឡោះ (ខ. 22)—ដំទង់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 53។

ក ស្គាល់ពីជំណោះស្រាយ

កងទ័ពរបស់ពួកសាសន៍ឌីហ្វៃ បានទទួលជោគជ័យ ប៉ុន្តែក្រោយមក បានជួបប្រទះនឹងបញ្ហាខ្លះៗ។

1. សូមអាន អាលម៉ា 53:1–7 ហើយយ៉ាងហោចណាស់បញ្ជាក់ពីបញ្ហារបស់ពួកសាសន៍ឌីហ្វៃចំនួនបី ដែលពួកគេបានជួប ប្រទះនៅពេលនោះ។
2. ចូរបញ្ជាក់ពីជំណោះស្រាយរបស់មេទ័ពម៉ូរីណៃ ដែលធ្វើការដោះស្រាយ ចំពោះបញ្ហានីមួយៗ។

ខ ប្រៀបធៀបសេចក្តីសញ្ញាទាំងឡាយ

1. សូមធ្វើការប្រៀបធៀបសេចក្តីសញ្ញា ដែលប្រជាជនអាំម៉ូនបានធ្វើ (សូមមើល អាលម៉ា 53:10–15) ទៅនឹងសេចក្តីសញ្ញា ដែលបានធ្វើ ដោយកូនប្រុសរបស់ពួកគេ (សូមមើលខ. 17)។
2. សូមសរសេរកថាកណ្តុំមួយ ដែលពន្យល់ថា ហេតុអ្វីបានជាមានសារៈសំខាន់ ដើម្បីរក្សានូវសេចក្តីសញ្ញាទាំងឡាយ។

គ ចូរស្វែងរកនូវលក្ខណៈស្រដៀងគ្នា

សូមអាន អាលម៉ា 53:20–21 ហើយសរសេរអំពីលក្ខណៈទាំងឡាយ ដែលកងពលកំឡោះពីរពាន់នាក់មាន ហើយអ្នកផ្សេង ផ្សាយ សាសនាពេញមើងរបស់យើងក៏មានៗ។

អាលម៉ា 54

ការផ្លាស់ប្តូរសំបុត្រ

មេទ័ពម៉ូរីណា បានសរសេរសំបុត្រទៅឱ្យអាំម៉ូរុន ដែលជាអ្នកដឹកនាំពួកសាសន៍លេមិន ដើម្បីធ្វើការចរចារ ប្តូរឈ្លើយសង្គ្រាម។ តើអ្នកនឹងសរសេរអ្វីខ្លះនៅក្នុងសំបុត្រទៅឱ្យស្ត្រីរបស់អ្នក? អ្វីដែលម៉ូរីណាបាន ជ្រើសរើស ដើម្បីសរសេរប្រហែលជាធ្វើឱ្យ អ្នកមានការភ្ញាក់ផ្អើល។ នៅពេលអ្នកអានសំបុត្ររបស់ម៉ូរីណា និងការឆ្លើយតបរបស់អាំម៉ូរុន ចូរកត់សំគាល់អំពីអារម្មណ៍ ដ៏ជ្រាលជ្រៅទៅលើដំណោះទាំងសងខាង។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 54

ស្បៃរុង (ខ. 2)—ម្ហូបអាហារ និងសម្ភារៈផ្គត់ផ្គង់

សំបុត្រមួយ (ខ. 4, 11, 14–15, 24)—សំបុត្រ

ជារនៃព្រះពិរោធដ៏មានមហិទ្ធិឫទ្ធិរបស់ទ្រង់ (ខ. 6)—ការដាក់ទារុណកម្មរបស់ព្រះ

ដែលជាជែនដីកេរ្តិ៍អាករដំបូងរបស់យើង (ខ. 12)—កន្លែង ដែលប្រជាជនរបស់យើងរស់នៅជំបូង (ជែនដីរបស់នីហ្វៃ)

សងឈាមឱ្យទ្រង់ទៅលើអ្នក (ខ. 16)—សម្លាប់អ្នក ព្រោះអ្នកបានសម្លាប់គាត់

បានហាមាត់បញ្ចេញ (ខ. 19)—និយាយ បានបញ្ជាក់

វិនាសសាបសូន្យ (ខ. 20)—បំផ្លាញទាំងស្រុង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 54។

ក សំបុត្រចប្បាប់

សូមរំលឹកសារឡើងវិញអំពី ការផ្លាស់ប្តូរសំបុត្រ នៅអាលម៉ា 54:1–4, 11–12, 15, 20។

1. តើនរណាបាន សរសេរសំបុត្រជាលើកទីមួយ? តើគាត់បានស្នើសុំអ្វីខ្លះ?
2. តើនរណាបានសរសេរសំបុត្រជាលើកទីពីរ? តើផែនការរបស់មេទ័ពម៉ូរីណាមានអ្វីខ្លះ ចំពោះការប្តូរឈ្លើយសង្គ្រាម?
3. តើនរណាបានសរសេរសំបុត្រជាលើកទីបី? តើហេតុអ្វីគាត់យល់ព្រមចំពោះលក្ខខ័ណ្ឌនេះ?

ខ ចូរសរសេរសេចក្តីសន្យាសារជាថ្មី

សូមពិចារណាចំពោះ ការសន្យារបស់មេបញ្ជាការម៉ូរីណា ហើយសរសេរឡើងវិញនូវការសន្យាជាភាសាទំនើប។

1. ការសន្យាទីមួយ (សូមមើល អាលម៉ា 54:6)
2. ការសន្យាទីពីរ (សូមមើលខ. 10)
3. ការសន្យាទីបួន (សូមមើលខ. 12)
4. តើហេតុអ្វីអ្នកគិតថា ម៉ូរីណាខឹងជាមួយនឹងអាំម៉ូរុនយ៉ាងខ្លាំងដូច្នេះ? តើអ្នកមានអារម្មណ៍ដូចម្តេច នៅពេលអ្នកឃើញនរណា ម្នាក់ កំពុងតែគំរាមគំហែងអ្នកដទៃទៀត ដោយការបង្ខិតបង្ខំខាងរាងកាយ?

គ ប្រៀបធ្យៀបបុរសពីរនាក់

សូមធ្វើការប្រៀបធ្យៀបសំដីរបស់ម៉ូរីណា (សូមមើល អាលម៉ា 54:4–14)ជាមួយនឹងពាក្យសំដីរបស់អាំម៉ូរុន (សូមមើលខ. 16–24)។ ចូរសរសេរនូវអ្វី ដែលអ្នកបានរៀន អំពីបុរសទាំងពីរនាក់នេះ តាមអ្វីដែលពួកគេបានសរសេរ។

អាលម៉ា 55

ពួកឈ្លើយសង្គ្រាមរបស់សាសន៍នីហ្វៃ ត្រូវបានទទួលសេរីភាព

ព្រះអង្គសង្គ្រោះ បានបង្រៀនដល់សិស្សរបស់ទ្រង់ថា "ចូរធ្វើជាអ្នកឆ្លាតដូចជាពស់" (សូមមើល ម៉ាថាយ10:16)។ សិស្សរបស់ទ្រង់ នៅឯទ្វីបអាមេរិក ក៏ត្រូវការផងដែរនូវការបំផុសគំនិត និងប្រាជ្ញា នៅពេលខ្លះភាពឆ្លាតវៃត្រូវបានយក មកការពារសេរីភាពរបស់ពួកគេ។ សូមមើល អំពីកលឧបាយសឹក ដែលម៉ូរីណា ប្រើដើម្បីជួយសង្គ្រោះពួកឈ្លើយសង្គ្រាម នៅក្នុងសង្គ្រាម ដោយគ្មានបាត់បង់ជីវិតម្នាក់សោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 55

ការបន្លប់ (ខ. 1)—កុហក ការបំភាន់

ជាឧត្តគតិមួយដ៏ឃុត្តិធមិ (ខ. 1)—គោលការណ៍សុចរិត គោលដៅ

បន្តិចម្តងៗ (ខ. 14)—ឆាប់ៗ

ជាខ្លាំង (ខ. 17)—បំផុត ជ្រាលជ្រៅទាំងស្រុង

ដំហាន (ខ. 21)—ចម្ងាយខ្លី

កលល្បិច (ខ. 27)—គម្រោងការអាក្រក់សម្ងាត់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សា អាលម៉ា 55។

ក បង្កើតជាការសាកល្បងមួយ

រំលឹកឡើងវិញ អំពីរបៀប ដែលម៉ូរ៉ូណៃបានរំដោះពួកឈ្លើយសង្គ្រាមសាសន៍នីហ្វៃ នៅអាលម៉ា 55:4–24 ហើយសរសេរដា សំនួរសាកល្បងចំនួនត្រឹមមួយ និងចម្លើយ។ សំនួរទាំងឡាយ គួរតែតំរូវឱ្យមានប្រយោគមួយពេញលេញ នៅក្នុងចម្លើយ។

អាលម៉ា 56

កងពលកំឡោះពីរពាន់នាក់ នៅក្នុងចម្បាំង

តើអ្នកធ្លាប់ទាក់ទងជាមួយអ្នកណាម្នាក់តាមសំបុត្រឬទេ? ប្រហែលជា អ្នកបានសរសេរដា ប្រចាំទៅលេងមិត្តភក្តិ ឬសមាជិកគ្រួសារ ដែលកំពុងបំរើបេសកកម្ម។ ប្រហែលជាអ្នកបានពង្រីកនូវមិត្តភាពជាមួយនរណាម្នាក់ នៅក្នុងទីក្រុង ឬប្រទេសដទៃទៀត។ នៅ ពេលយើង ចែកចាយ ដំណឹងល្អ វាអាចបិទាច់ដល់ព្រលឹងវិញ្ញាណមនុស្សផ្សេងទៀត បំភ្លឺដល់ដំនាក់មួយ ហើយមានសេចក្តីរីករាយ ក្រៃលែង ចំពោះបុគ្គលរូបនោះ។ នៅពេលអ្នកអាន អាលម៉ា 56 ចូរតត់ចំណាំអំពី ដំណឹងល្អ ដែលហេលេមិន បានចែកចាយ អំពីកងទ័ពថ្មីរបស់គាត់។ សូមតត់ចំណាំផងដែរ នូវអ្វី ដែលហេលេមិន សរសេរទៅឱ្យមេបញ្ជាការម៉ូរ៉ូណៃ អំពីការការពាររបស់ ព្រះអម្ចាស់ ចំពោះយុវជន ស្មោះត្រង់ទាំងនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 56

នៅក្នុងភូមិភាគ (ខ. 1)—ផ្នែក វគ្គ

សេចក្តីទុក្ខលំបាក (ខ. 2, 7)—បញ្ហា ទុក្ខព្រួយ

ខ្ញុំគ្រាន់តែ (ខ. 5)—វាគ្រប់គ្រាន់សំរាប់ខ្ញុំ

ល្អងចិត្ត (ខ. 11)—កំសាន្តចិត្ត ធានាវ៉ាប់រង

កំពុងចំណាយកម្លាំង (ខ. 15)—កំពុងធ្វើការ កំពុងធ្វើការងារ

អង់អាច (ខ. 16)—ដោយក្លាហាន

ហ៊ាន (ខ. 24–25, 40)—ហាន

ស្ទុះទៅមុខ (ខ. 29)—សំរុកទៅមុខ ដើម្បីវាយប្រហារ

បណ្តាលមកពី (ខ. 51)—បណ្តាល

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា អាលម៉ា 56។

ក ភាពក្លាហាននៅក្នុងចម្បាំង

សូមអានអាលម៉ា 56:42–56 ហើយឆ្លើយសំនួរខាងក្រោមនេះ:

1. តើហេតុអ្វី កូនប្រុសនៃប្រជាជន របស់អាំម៉ូនពោរពេញ ទៅដោយសេចក្តីក្លាហានដូច្នេះ?
2. តើអ្វីខ្លះ ដែលបណ្តាលឱ្យហេលេមិន “មានសេចក្តីអំណរដាខ្លាំង” បន្ទាប់ពីការប្រយុទ្ធ?

ខ សរសេរសំបុត្រមួយច្បាប់

សូមរំលឹកអាលម៉ា 56:27–29, 47–48, 54–56 សារឡើងវិញ ហើយនឹកគិតថា អ្នកគឺជាកងទ័ពកំឡោះម្នាក់។ ចូរសរសេរ សំបុត្រមួយច្បាប់ ទៅឱ្យឪពុកម្តាយរបស់អ្នកដោយមានពន្យល់ពីរបៀប ដែលការបរិភ្គាគ និងឥទ្ធិពលរបស់គាត់ទាំងពីរនាក់ បាន ជួយអ្នក ឱ្យធ្វើជាទាហានមួយរូប។

គ ពន្យល់អំពី អ្វីដែលកំពុងកើតឡើងនៅក្នុងខគម្ពីរ

នៅលើផែនទីខាងក្រោមនេះ មានបង្ហាញអំពីព្រឹត្តការណ៍ទាន នៅអាលម៉ា 56:27–54។ ចូរធ្វើបញ្ជីខគម្ពីរយោងទីមួយៗ សរសេរទៅលើផែនទី ហើយបន្ទាប់មកពន្យល់អំពីអ្វី ដែលកើតឡើង នៅក្នុងជំណើរឡើង។



អាលម៉ា 57

កងទ័ពកំឡោះពីរពាន់នាក់ រួចផុតពីសេចក្តីស្លាប់

ក្នុនចៅ ដែលស្មោះត្រង់ ធ្វើតាមការបង្រៀនរបស់ឱពុកម្តាយនិង អ្នកដឹកនាំសុចរិតអាចធ្វើសំរេចនូវការណ៍ធំឲ្យ នៅក្នុងជីវិតរបស់ពួក គេ។ អ្នកចម្បាំងកំឡោះពីរពាន់នាក់ របស់ហេលេមិន គឺជាក្នុនឲ្យ ដែលប្រកបដោយភាពក្លាហាន ចេញទៅច្បាំងនៅក្នុងសង្ត្រាម ប្រឆាំងនឹងពួកសាសន៍លេមិន។ នៅពេលអ្នកអាន អាលម៉ា 57 សូមគិតអំពីអ្វី ដែលអ្នកចម្បាំងកំឡោះទាំងនោះ ធ្វើបានសំរេច ហើយហេតុអ្វីបានជាពួកគេអាចធ្វើបានសំរេច។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 57

សំបុត្រ (ខ. 1–3)—លិខិត

ទៅប្រយុទ្ធ (ខ. 7)—ទៅធ្វើ

បានជំនួយ (ខ. 12)—ជួយ គាំទ្រ ពង្រឹង

ត្រូវបង្ខំ (ខ. 13)—បង្ខំ បង្ពាប់

ក្លាហានយ៉ាងប្តូរផ្តាច់ (ខ. 20)—មិនភ័យខ្លាច ក្លាហាន

ឱ្យនាំ (ខ. 22)—យក ការពារ

ការណ៍ (ខ. 26)—ការផ្តល់កិត្តិយសចាត់តាំង

បានផ្ទុំគ្នាជាក្រុមឲ្យ (ខ. 33)—ជាក្រុមមួយ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សា អាលម៉ា 57។

ក្ស សសេរពាក្យគន្លឹះ

រំលឹកអាលម៉ា 57:19–27 សារឡើងវិញ។

1. ចូរសរសេរពាក្យគន្លឹះ និងឃ្លា ដែលអ្នកគិតថា ត្រូវពន្យល់អំពីអ្វី ដែលអ្នកចម្បាំងកំឡោះបានធ្វើ ហើយមានជំនឿចំពោះ ការដែលពួកគេត្រូវបានសង្ត្រោះដោយអព្ភូតហេតុដ៏អស្ចារ្យ។
2. ចូរសរសេរសង្ខេបអំពីរឃ្យេប ដែលអ្នកបានបណ្ណុះសេចក្តីជំនឿរបស់អ្នក និងអំពីត្រាមួយ ពេលអ្នកបានទទួលជំនួយពីព្រះចេស្តា នៃព្រះ ព្រោះតែជំនឿរបស់អ្នក។

ខ ប្រាវព្ធធ្វើសន្ទិសីទថ្មីមួយ

ចូរនឹកគិតថា អ្នកគឺជា អ្នកតំណាងម្នាក់ នៃរដ្ឋាភិបាលពួកសាសន៍នីហ្វៃ ប្រាវព្ធធ្វើសន្ទិសីទថ្មីមួយ ស្តីអំពីសង្ត្រាម។ សូមប្រើ ពតិមាន នៅអាលម៉ា 57:19–36 ឆ្លើយនូវសំនួរដូចខាងក្រោមនេះ

1. តើមានចំនួនមនុស្សប៉ុន្មាន ដែលត្រូវបានសម្លាប់ និងរបួស នៅក្នុងការប្រយុទ្ធក្នុងពេលថ្មីឲ្យនេះ?
2. តើអ្នកទទួលខុសត្រូវ ចំពោះអត្រាមរណៈទាបនៅក្នុងចំណោមកងពលកំឡោះពីរពាន់នាក់ យ៉ាងដូចម្តេច?
3. តើហេតុអ្វី បានជាមានពួកឈ្លើយសង្ត្រាមសាសន៍លេមិនជាច្រើន ត្រូវស្លាប់?

អាលម៉ា 58

ពួកសាសន៍នីហ្វៃ យកបានទីក្រុងម៉ាន់តៃ

ជាញឹកញាប់ កងទ័ពពួកសាសន៍នីហ្វៃ ប្រឈមមុខជាមួយនឹងកងទ័ពពួកសាសន៍លេមិនយ៉ាងសន្ធឹកនៅក្នុងការប្រយុទ្ធ។ នៅ អាលម៉ា 58 ប្រាប់ពីត្រាមួយ ដែលកងទ័ពពួកសាសន៍នីហ្វៃមានការអស់សង្ឃឹម ខាងជំនួយសម្ភារៈ និងកម្លាំងបន្ថែម។ តើអ្នកធ្លាប់មានអារម្មណ៍រន្ធត់ក្នុងស្ថានភាពនានា នៅក្នុងជីវិតរបស់អ្នកឬទេ? តើអ្វីបានជួយដល់អ្នក? នៅពេលអ្នកអាន ជំពូកនេះ សូមកត់ចំណាំនូវអ្វី ដែលបានលើកទឹកចិត្តដល់ពួកសាសន៍នីហ្វៃឱ្យបន្តទៅមុខទៀត។ សូមស្វែងរកសេចក្តីជំនឿ ដែលបានផ្តល់ដល់ពួកសាសន៍នីហ្វៃ ឱ្យប្តេជ្ញាចិត្តយកឈ្នះលើសេចក្តីលំបាកវេទនារបស់ពួកគេ។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 58

បញ្ជោត (ខ. 1)—ល្បិច ដាក់អន្ទាក់

សារទូត (ខ. 4)—អ្នកនាំសារជាផ្លូវការ ឬអ្នកនាំសារ

បានស្ទុះចេញមក (ខ. 6)—សំរុកទៅមុខ ដើម្បីវាយប្រហារ

ឧបាយសឹក (ខ. 6, 28)—ផែនការដ៏ប្រុងប្រយ័ត្ន

ត្រូវទៅពួនលាក់ខ្លួន បានទៅពួនលាក់ខ្លួន (ខ. 16–17)—ពួន

មានការបែកបាក់គ្នា (ខ. 36)—ការបែកចេញជាក្រុម

ក្រិត្យក្រម (ខ. 40)—ច្បាប់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សា អាលម៉ា 58។

ក្ស គិតអំពីការអនុវត្តថ្មីមួយ

សូមអាន អាលម៉ា 58:1–13។

1. តើពួកសាសន៍នីហ្វៃ ធ្វើអ្វីខ្លះ នៅពេលពួកគេប្រឈមមុខនឹងស្ថានភាពដ៏រន្ធត់នានា?
2. សូមសរសេរអំពីស្ថានភាពថ្មីមួយ ដែលអាចដោះស្រាយបាន តាមសកម្មភាពស្រដៀងគ្នានេះ។

ខ បើសិនជាអ្នកវិញ

សូមអាន អាលម៉ា 58:39–41។

1. ចូរធ្វើជាបញ្ជីដោយសង្ខេបនូវអ្វី ដែល ហេលេមិន បានទិយាយអំពីកងទ័ពកំឡោះ។
2. បើសិន អ្នកគឺជាយុវនារីម្នាក់ តើអ្នកមានអារម្មណ៍យ៉ាងណា អំពីការធ្វើមិត្តភក្តិជាមួយគ្នា ឬស្វែងរកគូរ ជាមួយយុវជន ដែលមានគុណសម្បត្តិទាំងអស់នេះ? តើហេតុអ្វី? បើសិនជាអ្នកជាយុវជនម្នាក់វិញ តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច បើអ្នកត្រូវបានគេពិពណិនាថា មាន

គុណសម្បត្តិទាំងអស់នេះ? តើអ្នកអាចធ្វើការផ្លាស់ប្តូរអ្វីខ្លះ នៅក្នុងជីវិតរបស់អ្នក ដើម្បីអភិវឌ្ឍន៍គុណសម្បត្តិទាំងនេះ?

អាលម៉ា 59

មូរ៉ៃណៃបញ្ជូនកំលាំងជំនួយ

កំលាំងរបស់ពួកសាសន៍លេមិន បានកើនឡើងយ៉ាងខ្លាំងក្លា ហើយបានគំរាមគំហែងទីក្រុងនានា របស់ពួកសាសន៍នីហ្វៃ។ មេ បញ្ជាការមូរ៉ៃណៃ បានបញ្ជូនសំបុត្រមួយច្បាប់ទៅដល់ ពេហ្ហូរ៉ាន ដើម្បីស្នើសុំកងទ័ព ហើយនឹងសម្ភារៈបន្ថែម ដើម្បីជួយការពារ ទឹកដីរបស់ពួកគេ ប៉ុន្តែជំនួយពុំបានមកឡើយ។ នៅពេលអ្នកអាន អាលម៉ា 59 សូមកត់ចំណាំអំពីអ្វី ដែលបានកើតឡើង ដែលជាលទ្ធផលនៃការខ្វះការគាំទ្រ ហើយសូមរកសូមមើលនូវកង្វល់យ៉ាងតិចពីរ ដែលមូរ៉ៃណៃមានអំពីប្រជាជន និងរដ្ឋាភិបាល របស់គាត់ ដែលគួរតែផ្តល់ការគាំទ្រដល់គាត់។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 59

ដែលត្រូវបានបង្ខំ (ខ. 6)—បានបង្ខំ

ការមិនអើពើ (ខ. 13)—ខ្វះចំណាប់អារម្មណ៍ ធ្វេសប្រហែស

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សា អាលម៉ា 59។

ក សរសេរសំបុត្រមួយច្បាប់

សូមរំលឹក អាលម៉ា 59:3–13 សារឡើងវិញ ហើយសរសេរសំបុត្រមួយច្បាប់ ទៅដល់ពេហ្ហូរ៉ាន ដែលរួមមាននូវបញ្ហា និងកង្វល់ ទាំងឡាយ ដែលអ្នកមានអំពីស្ថានភាពនោះ បើសិនជាអ្នកគឺជាមូរ៉ៃណៃ។

អាលម៉ា 60

សំបុត្ររបស់មូរ៉ៃណៃ ទៅកាន់ពេហ្ហូរ៉ាន

មេទ័ពមូរ៉ៃណៃ ចាំមើលយ៉ាងយកចិត្តទុកដាក់ពីគុណូភាពនៃអំណាច ដែលបានផ្លាស់ប្តូរចំពោះពួកសាសន៍លេមិន។ នៅពេល កងទ័ពពួកសាសន៍លេមិនកើនចំនួនយ៉ាងច្រើន ពួកសាសន៍នីហ្វៃ មិនទទួលបានទាំងសម្ភារៈ និងជំនួយបន្ថែមពីពេហ្ហូរ៉ានឡើយ។ បើអ្នកជាមូរ៉ៃណៃ តើអ្នកនឹងមានកង្វល់អ្វីខ្លះ? តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្តេច ជាមួយពេហ្ហូរ៉ាន? អាលម៉ា 60 គឺជាសំបុត្រមួយច្បាប់ ដែលមូរ៉ៃណៃបានសរសេរទៅកាន់ពេហ្ហូរ៉ាន។ ចូរគិតថាប្រសិនបើ គំនិត និងអារម្មណ៍របស់មូរ៉ៃណៃស្រដៀងគ្នា ទៅនឹងអារម្មណ៍ទាំងឡាយដែលអ្នកអាចមាន។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 60

បានបន្ថែមកម្លាំងគ្រប់គ្រាន់ (ខ. 5)—ផ្តល់ឱ្យ ប្រគល់ឱ្យ

ទ្រឹង (ខ. 7)—គំនិតមិនលុះ

ការខ្ជិលច្រអូស (ខ. 14)—សេចក្តីខ្ជិល

បានកំចាត់ (ខ. 16)—បានខ្ចាត់ខ្ចាយ

ការបះបោរ (ខ. 27)—ការប្រឆាំង

ដណ្តើម (ខ. 27)—ការដណ្តើមយកដោយអយុត្តិធម៌ ឬដោយអំពើហឹង្សា

អ្នករាល់គ្នាស្ទុះស្ទារឡើង (ខ. 29)—ដាស់ខ្លួនឯងឡើង ចាត់វិធានការ

បង្អាក់ (ខ. 30)—រារាំងផ្លូវ រារាំង

ប្រតិបត្តិតាម (ខ. 34)—រក្សាភក្តីភាពគាំទ្រ

អាលម៉ា 60:23–24—"ខាងក្នុងប្រដាប់នឹងត្រូវលាងជាមុន"

មានសារៈសំខាន់ណាស់ ដើម្បីរក្សាចិត្ត និងគំនិតរបស់យើងឱ្យបានស្អាតជាជាងខ្ចល់ខ្វាយជ្រុលហួសនឹងការសំអាតតែខាងក្រៅ ដូច ជាក្នុងសុភាសិតបង្រៀនថា "ត្បិតគេ [បុរសម្នាក់] គិតនៅក្នុងចិត្តជាយ៉ាងណា គេក៏យ៉ាងនោះដែរ" (សុភាសិត 23:7)។ នៅពេល បានប្រទះនឹងសិស្សរបស់ទ្រង់ ដែលមិនបានធ្វើតាមទំនៀមទំលាប់នៃការលាងដៃរបស់ពួកគេ មុនពេលបរិភោគព្រះយេស៊ូវ បង្រៀនថា "ដ្បិតគឺពីក្នុងចិត្តនោះឯង ដែលចេញអស់ទាំងគំនិតអាក្រក់ គឺការកាប់សំឡាប់គេ ផិតគ្នា សហាយស្មន់ លួចប្លន់ ធ្វើបន្ទាល់ ក្លែងក្លាយ ហើយនឹងជេរប្រមាថ។" ទ្រង់បន្តមានបន្ទូលថា "សេចក្តីទាំងនេះ ទើបធ្វើឱ្យមនុស្សស្មោគគ្រោក មែន" តែដែលបរិភោគឥតលាងដៃ នោះមិនមែនធ្វើឱ្យស្មោគគ្រោកទេ (ម៉ាថាយ 15:19–20)។

មូរ៉ៃណៃមានកង្វល់ចំពោះ ព្រលឹងជាតិរបស់គាត់ ជម្ងឺខាងវិញ្ញាណ ហើយត្រូវការលាងសំអាត។ ប្រធានអ៊ីសរ៉ា ថាពូ បើនស៊ីន បង្រៀនអំពីតំរូវការ ដើម្បីលាងសំអាតដូចគ្នានេះ នៅក្នុងសម័យរបស់យើងៈ

"ប្រសិនបើ យើងត្រូវលាងជំរះសរសៃឈាមខាងក្នុង យើងត្រូវតែលះបង់ភាពគ្មានសីលធម៌ ហើយត្រូវតែស្អាតស្អំ. . . .

"បងប្អូនប្រុសស្រី ជាទីស្រឡាញ់របស់ខ្ញុំ នៅពេលយើងលាងសំអាតសរសៃឈាមខាងក្នុង នោះនឹងមានការផ្លាស់ប្តូរធ្វើឡើងនៅ ក្នុងជីវិតរស់នៅរបស់យើងផ្ទាល់ នៅក្នុងក្រុមគ្រួសារ និងនៅក្នុងសាសនាចក្រ" (នៅក្នុង Conference Report ខែមេសា ឆ្នាំ 1986, 4, 6 ឬ *Ensign* ខែឧសភា ឆ្នាំ 1986, 5, 7)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) នៅពេលអ្នកសិក្សា អាលម៉ា 60។

ក ការជ្រើសរើសអ្នកដឹកនាំម្នាក់

ចូរគិតថា មេទ័ពម៉ូរ៉ៃណា គឺជាបេក្ខជនម្នាក់ ដែលនឹងក្លាយទៅជាអ្នកដឹកនាំ នៃប្រទេសរបស់អ្នក។ សូមអាន អាលម៉ា 60:2–10 ហើយធ្វើបញ្ជីគុណសម្បត្តិទាំងនោះ ដែលអ្នកគិតថា នឹងធ្វើឱ្យគាត់ក្លាយជាអ្នកដឹកនាំដ៏ល្អម្នាក់។

ខ ជ្រើសរើសសេចក្តីថ្លែងការណ៍

សូមមើលអាលម៉ា 60:10–15 ហើយសរសេរនៅក្នុងស្បៃវគៅសរសេររបស់អ្នក នូវសេចក្តីថ្លែងការណ៍ប៊ិ ដូចខាងក្រោម ដែលអ្នកមានអារម្មណ៍ថា អាចដាក់តំណាងឱ្យជ័ព្រសើរបំផុត នៃគំនិតរបស់ម៉ូរ៉ៃណា ដែលបានបញ្ជាក់នៅក្នុងសំបុត្ររបស់គាត់ ទៅកាន់ពេហ៊ូរ៉ាន។

1. អ្នកដឹកនាំពួកសាសន៍នីហ្វៃ ស្រឡាញ់ និងគាំទ្រដល់កងទ័ពរបស់ពួកគេ។
2. អ្នកដឹកនាំពួកសាសន៍នីហ្វៃ មានការទទួលខុសត្រូវ ចំពោះសេចក្តីស្លាប់ នៃទាហានរបស់ពួកគេ។
3. អ្នកដឹកនាំពួកសាសន៍នីហ្វៃ អង្គុយជុំគ្នាដោយគ្មានធ្វើអ្វីសោះ នៅពេលកងទ័ពទាំងឡាយស្លាប់នៅក្នុងចម្បាំង។
4. កងទ័ពពួកសាសន៍នីហ្វៃបានស្លាប់ដោយសារតែការខ្វះជំនឿរបស់ពួកគេ។
5. រដ្ឋាភិបាលសាសន៍នីហ្វៃ មានការរិឹលច្រអូស និងធ្វេសប្រហែល ចំពោះកងទ័ពរបស់ខ្លួន។

គ សរសេរឃ្លាសារឡើងវិញ

នៅខាងក្រោមនេះ មានឃ្លាប្រយោគមួយចំនួន ដែលបានដកស្រង់មកពីអាលម៉ា 60:23–36។ សូមអានឃ្លានីមួយៗ នៅក្នុងបរិបទ ដែលមានទាក់ទងទៅនឹងខ ហើយសរសេរឃ្លាសារឡើងវិញ តាមពាក្យរបស់អ្នក។

1. “រហូតដល់យើងលាងខាងក្នុងប្រដាប់របស់យើងជាមុនសិន” (ខ. 24)
2. “ខ្ញុំនឹងចាក់រុកឱ្យមានការបះពោរទាំងឡាយ នៅក្នុងចំណោមពួកអ្នករាល់គ្នា” (ខ. 27)
3. “គឺដោយសារអំពើទុច្ចរិតរបស់អ្នក ដែលយើងត្រូវរងនូវការបាត់បង់ជ័ព្រេីន” (ខ. 28)
4. “ហើយបើអ្នកមិនជួយដល់ពួកយើងទេ មើលចុះខ្ញុំនឹងមករកអ្នករាល់គ្នា” (ខ. 30)
5. “អំពើទុច្ចរិតរបស់អ្នករាល់គ្នា គឺបណ្តាលមកពីការស្រឡាញ់ភាពរុងរឿងរបស់អ្នក និងវត្ថុឥតប្រយោជន៍ទាំងឡាយនៃលោក នេះ” (ខ. 32)
6. “ខ្ញុំមិនសែ្ងរកអំណាចទេ តែរកទាញទម្លាក់វាចុះវិញ” (ខ. 36)

អាលម៉ា 61

ការឆ្លើយតបរបស់ពេហ៊ូរ៉ាន ទៅម៉ូរ៉ៃណាវិញ

ទីក្រុងសារ៉ាហិមឡា និងរដ្ឋាភិបាលសាសន៍នីហ្វៃ ត្រូវបានរឹបអូសយកដោយពួកសត្រូវនៃសេរីភាព ហើយនឹងសេចក្តីសុចរិត។ វា គឺជាពេលដែលប្រកបទៅដោយគ្រោះថ្នាក់ ពេលពេហ៊ូរ៉ាន ទទួលសំបុត្រពីម៉ូរ៉ៃណានោះ។

តើអ្នកនឹងមានប្រតិកម្មយ៉ាងដូចម្តេច ចំពោះសំបុត្ររបស់ម៉ូរ៉ៃណា បើអ្នកគឺជាពេហ៊ូរ៉ាន? នៅពេលអ្នកអានការឆ្លើយតប របស់ពេហ៊ូរ៉ាន ចូរចងចាំអំពីភាពខ្លាំងក្លា នៃសំបុត្ររបស់ម៉ូរ៉ៃណា ហើយគិតអំពី ពេហ៊ូរ៉ាន ថាគាត់ជាមនុស្សប្រភេទណា។

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 61

គំរាមគំហែង (ខ. 4)—ពាក់ទឹកចិត្ត

ត្រូវនៅក្នុងស្ថានភាពទល់នឹងការជំនះ (ខ. 7)—បង្ករហេតុ

ហ៊ានៈ (ខ. 7)—ក្លាហាន

សម្ព័ន្ធមិត្ត (ខ. 8)—ភាពជាដៃគូ សន្ធិសញ្ញា

បានរិះគន់ (ខ. 9)—ទិឡ្យែន បន្ទោស

តម្រូវឱ្យ (ខ. 12)—ចាំបាច់ បានតម្រូវ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា អាលម៉ា 61។

ក បញ្ហា និងដំណោះស្រាយ



សូមគូរក្លូឡោនពីរ នៅក្នុងស្បៃវគៅសរសេររបស់អ្នក ហើយចិទស្លាកស្តីអំពី “បញ្ហា” ហើយមួយទៀតស្តីអំពី “ដំណោះស្រាយ។” សូមអានអាលម៉ា 61 ហើយពិភាក្សាអំពីបញ្ហាពេហ៊ូរ៉ានដែលបានប្រឈមមុខ និងសរសេរអំពីសកម្មភាពទាំងឡាយ ដែល គាត់បានផ្តល់អនុសាសន៍។ សូមអាននៅក្បាលជំពូកដល់ អាលម៉ា 51 ហើយពន្យល់ពីរបៀប ដែលអ្នកគិតថាម៉ូរ៉ៃណា នឹងឆ្លើយតប ចំពោះដំណោះស្រាយរបស់ ពេហ៊ូរ៉ាន។

ខ ផ្តល់ឧទាហរណ៍មួយ

សូមរំលឹក អាលម៉ា 61:15–21 សារឡើងវិញ។

1. ចូរសរសេរឧទាហរណ៍ពីរស្តីអំពីប្រជាជន ដែលអ្នកស្គាល់ ជាអ្នកដែលមានដោគជ័យ ពីព្រោះពួកគេទទួលបានកម្លាំងមកពី ព្រះអម្ចាស់។
2. ចូរសរសេរឱ្យបានពីររបៀបអំពីអ្វី ដែលអ្នកអាចទទួលបានកម្លាំងកាន់តែច្រើន មកពីព្រះអម្ចាស់ នៅក្នុងជីវិតរបស់អ្នក។

អាលម៉ា 62

ម៉ូរ៉ៃណាធ្វើដំណើរទៅជួយពេហ៊ូរ៉ាន

ដោយសារតែសេចក្តីក្លាហាន និងសមត្ថភាពដឹកនាំរបស់មូ៉ឌៀ និងអ្នកដឹកនាំសាសន៍នីហ្វៃដទៃទៀត ការបះបោរនៃពួកអ្នក និយមស្តេចនៅក្នុងសាវ៉ាហិមឡា ត្រូវបានសរសេរទុក ហើយការធ្វើសង្គ្រាម ជាមួយនឹងពួកសាសន៍លេមិន ទីបំផុតត្រូវបានបញ្ចប់។ តើអ្នកគិតថា ការបះបោរមានឥទ្ធិពលប្រភេទណាខ្លះ ចំពោះប្រទេសជាតិ? តើការប៉ះទង្គិចអ្វីខ្លះ ដែលអ្នកគិតថា បានធ្វើឱ្យសង្គ្រាម បំផ្លិចបំផ្លាញមានការអូសបន្លាយរវាងពួកសាសន៍លេមិន មកលើសង្គមរបស់ពួកសាសន៍នីហ្វៃ និងសាសនាចក្រ? សូមរក មើលចម្លើយ ចំពោះសំនួរទាំងនេះ នៅពេលអ្នកសិក្សាអាលម៉ា 62។

មូ៉ឌៀ

ពេហូ៉ាន

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 62

ពួកដែលបែកចេញ (ខ. 6)—ពួកបះបោរសាសន៍នីហ្វៃ

យ៉ាងអង់អាច (ខ. 37)—យ៉ាងក្លាហានដោយសេចក្តីក្លាហាន

បានប្រគល់បញ្ជា (ខ. 43)—បានលះបង់

វិន័យ (ខ. 44)—ការកែតំរូវ ការរៀបចំសារឡើងវិញ

ខ្លាំងពូកែ (ខ. 48, 51)—រីកលូតលាស់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សាអាលម៉ា 62។

ក ធ្វើគម្រោងព្រឹត្តការណ៍

ចំពោះព្រឹត្តការណ៍សំខាន់ឲ្យនីមួយឲ្យខាងក្រោមនេះ មាននៅអាលម៉ា 62:1–11 រួចសរសេរសេចក្តីលំអិតពីរ ដែលទាក់ទងទៅ នឹងរឿងៈ

1. លើកមាត្រដ្ឋានឡើង (សូមមើលខ. 1–5)
2. ឈ្នះលើពួកអ្នកនិយមស្តេច (សូមមើលខ. 6–9)
3. គោរពច្បាប់ (សូមមើលខ. 10–11)

ខ តើអ្នកនឹងនិយាយអ្វីខ្លះ?

សូមរំលឹក អាលម៉ា 62:12–17 សារឡើងវិញ។ ចូរនឹកគិតថា អ្នកធ្វើជាអ្នកដឹកនាំនៃប្រជាជនអាំម៉ូន។ ចូរសរសេរនូវអ្វី ដែលអ្នកអាចនិយាយ ទៅកាន់ពួកឈ្លើយសង្គ្រាមសាសន៍លេមិន។

គ សរសេរអំពីដំណឹងមរណភាព

សូមអានអាលម៉ា 62:35–38 ហើយសរសេរអំពីដំណឹងមរណភាពរបស់ទីអានគុម។ (ដំណឹងមរណភាព គឺជាសេចក្តីប្រកាសអំពី ការស្លាប់របស់មនុស្ស ដែលរួមមានទាំងពតិមានសង្ខេបអំពីមរណភាព។) ពតិមានរួមមានដូចជា គាត់ជានរណា តើគាត់ មានជោគ ជ័យអ្វីខ្លះ និងមូលហេតុដែលគាត់បានធ្វើ។

ឃ សង្ខេបវគ្ត

សូមរំលឹកអាលម៉ា 62:39–51 សារឡើងវិញ។

1. ចូរចុះបញ្ជីមូលហេតុមួយចំនួន ដែលអ្នកគិតថា ពួកសាសន៍នីហ្វៃមួយចំនួនមានចិត្ត "រឹងទទឹង" ដោយសារសង្គ្រាម នៅពេលអ្នកដទៃទៀត "មានចិត្តទន់ភ្លន់"។
2. ពន្យល់នូវរបៀបដែលហេលេមិន និងបងប្អូនរបស់គាត់ ជួយដល់ប្រជាជនយកឈ្នះលើឥទ្ធិពលនៃសង្គ្រាម។
3. តើអ្នកអាចធ្វើអ្វីខ្លះ ក្នុងពេលឥឡូវនេះ ដើម្បីរៀបចំសំរាប់ពេលលំបាក ដែលនឹងមកដល់ក្នុងជីវិតរបស់អ្នក ដើម្បីកុំឱ្យចិត្តរបស់ អ្នករឹងទទឹង?

អាលម៉ា 63

ការផ្លាស់ទីលំនៅរបស់ពួកសាសន៍នីហ្វៃទៅកាន់ដែនដីទិសខាងជើង

នៅទីបញ្ចប់នៃសង្គ្រាមរបស់ពួកសាសន៍លេមិន ពួកសាសន៍នីហ្វៃបានពង្រីកទីលំនៅរបស់ពួកគេ ទៅកាន់ដែនដីទិសខាងជើង។ តើអ្នកគិតថា ហេតុអ្វីបានជាការផ្លាស់ទីលំនៅជារឿងគួរឱ្យចង់ធ្វើទៅវិញ? តើការណ៍នេះ ដើម្បីជាប្រយោជន៍ក្នុងការមាន ទឹកដីថ្មី ហើយមានឱកាសច្រើន ឬក៏មានមូលហេតុអ្វីផ្សេងទៀតឬ? អ្នកខ្លះ ដែលបានចាកចោលទៅដែនដី នៅទិសខាងជើង ត្រូវបាត់សូន្យឈឹង ហើយនៅតែមិនស្គាល់កន្លែង ដែលពួកគេបានតាំងលំនៅ។ តើពួកគេបានធ្វើដំណើរទៅកន្លែងណា?

ការយល់ដឹងអំពីព្រះគម្ពីរ

អាលម៉ា 63

បញ្ជីពិសិដ្ឋទាំងឡាយ (ខ. 1, 11)—បញ្ជីពិសិដ្ឋរបស់ពួកសាសន៍នីហ្វៃ និងវត្ថុទាំងឡាយ

ត្រូវបានប្រគល់ទៅឱ្យ (ខ. 13)—ផ្តល់ឱ្យ

អាលម៉ា 63:5–9—តើនរណា ជាហាកូត?

ហាកូត សង់សំពៅយ៉ាងធំ ហើយបើកទៅខាងជើង។ ទិសដៅរបស់គាត់ គឺពួកនីហ្វៃមិនបានដឹងទាល់តែសោះ។ ព្យាការីសម័យជាន់ ក្រោយបានប្រកាសថា សំពៅរបស់ហាកូត បានទៅដល់កោះនៃមហាសមុទ្រប៉ាស៊ីហ្វីក កន្លែងដែលពួកគេបានក្លាយទៅជាផ្នែកមួយ នៃវប្បធម៌របស់ប្រជាជនប៉ូលីនេស្យេន។ នៅឆ្នាំ 1913 មានការឆ្លើយជាទូរលេខ ដែលគាត់បានទទួលមុនពេលថា [ប្រហែល] ជាពួកគេខ្លះ ជាប្រជាជនរបស់ហាកូត ប្រធាន យ៉ូសែប អែហ្ស ស្មីធ បានប្រាប់ដល់ពួកបរិសុទ្ធជនជាតិប៉ូលីនេស្យេនមួយក្រុមថា ៖"ខ្ញុំចង់និយាយទៅកាន់បងប្អូនប្រុសស្រី ដែលមកពីប្រទេសញ៉ូស៊ីឡែន ថា អ្នករាល់គ្នាមានមួយ ចំនួនគឺជា ប្រជាជនរបស់ ហាកូត ហើយមិនមែនប្រហែលឡើយ" អំពីរឿងនេះទេ! គាត់ពន្យល់ថា នៅពេលដែលគាត់ជាអ្នកផ្សព្វផ្សាយសាសនា នៅ

ហាវ៉ៃ ព្រះវិញ្ញាណបានធ្វើជាសាក្សីដល់គាត់ថា ប្រជាជនប៉ូលីនេសៀន គឺជាពូជអំបូរបស់លីហៃ (នៅក្នុង William A. Cole និង Elwin W. Jensen, *Israel in the Pacific* [1961], 388)។ ក្រោយមកនៅក្នុងពាក្យអធិស្ឋានឆ្លង នៃព្រះវិហារ បរិសុទ្ធរដ្ឋហាវ៉ៃ ប្រធាន ហ៊ី ប៊ើ ចេ ក្រាន្ត ថ្លែងអំណរគុណដល់ព្រះវរបិតាសួគិថា "នៅក្នុងទឹកដីជាទីគាប់ចិត្តនេះ ប្រជាជនមួយពាន់ និងរាប់ម៉ឺន ទាក់ នៃកូនចៅរបស់លីហៃ បានមកទទួលយកចំណេះដឹងខាងដំណឹងល្អ" ("The Dedicatory Prayer in the Hawaii Temple" *Improvement Era* ខែកុម្ភះ ឆ្នាំ 1920, 283)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សា អាលម៉ា 63។

ក ធ្វើលេខ

ចូរំលឹកអាលម៉ា 43:3, 17, 62:39, 63:3 ដើម្បីគណនាអំពីពតិមានដូចខាងក្រោមៈ

1. តើមរ៉ូណៃ ចំណាយរយៈពេលប៉ុន្មានឆ្នាំ ក្នុងការធ្វើសង្គ្រាមជាមួយពួកសាសន៍លេមិន?
2. តើគាត់សប្បាយរីករាយនឹងសន្តិភាព ពេលចូលនិវត្ត បន្ទាប់ពីបញ្ចប់សង្គ្រាម រយៈពេលប៉ុន្មានឆ្នាំ?

ខ សរសេរអំពីអ្វី ដែលអ្នកបានរៀន

ឥឡូវអ្នកបានអានគម្ពីរអាលម៉ា។ ចូរសរសេរអំពី ខគម្ពីរ រឿង ឬផ្នែកខ្លះនៃគម្ពីរ ដែលអ្នកមានអារម្មណ៍ថា មានឥទ្ធិពលល្អ នៅក្នុងជីវិតរបស់អ្នក។ សូមប្រាប់ពីរបៀប ដែលវា បានជួយអ្នក ឱ្យក្លាយជាមនុស្សដ៏ប្រសើរម្នាក់។

គម្ពីរហេលមិន

រយៈកាលសុចរិត និងទុច្ចរិត

មកដល់ចំនុចនេះ នៅក្នុងព្រះគម្ពីរមរមន អ្នកបានអានអំពីរយៈកាល ដែលពួកសាសន៍នីហ្វៃសុចរិត ហើយអំពីរយៈកាល ដែល ពួកគេទុច្ចរិត។ នៅក្នុងគម្ពីរហេលេមិន ពួកគេត្រលប់ទៅវិញ ទៅមក រវាង សេចក្តីសុចរិត និងទុច្ចរិត ដូច្នេះជារៀយៗ ការណ៍នេះ ស្ទើរតែមានទូវការភាន់ច្រលំ។ ប្រាកដណាស់ការណ៍នេះ បានធ្វើឱ្យយើង មិនយល់ថា ហេតុអ្វីក៏ពួកគេ គ្មានស្ថេរភាព ដូច្នេះ។ អ្នកអាចចង់ធ្វើការកត់ត្រា នៅក្នុងសៀវភៅសរសេររបស់អ្នក ឬធ្វើការចំណាំពិសេសមួយ នៅក្នុងព្រះគម្ពីររបស់អ្នក ជារៀងរាល់ពេល ដែលអ្នកអានថា បើមានការផ្លាស់ប្តូរពីសេចក្តីសុចរិត ទៅជាទុច្ចរិត ឬពីអំពើទុច្ចរិតទៅសុចរិតវិញ នៅក្នុងគម្ពីរហេលេមិន។ ចូរធ្វើការចំណាំជាពិសេស នៅហេលេមិន 12 ដែលជាការពន្យល់អំពីការផ្លាស់ប្តូរទាំងនេះ។

ពួកសាសន៍លេមិន ក៏ធ្វើការផ្លាស់ប្តូរផងដែរ

ទិដ្ឋភាពមិនធម្មតាមួយទៀត នៃគម្ពីរហេលេមិន គឺថា ពួកសាសន៍លេមិន ជាញឹកញាប់សុចរិតច្រើន ជាងពួកសាសន៍នីហ្វៃ។ ព្យាការីម្នាក់ដែលគួរឱ្យចងចាំបំផុតនៅក្នុងគម្ពីរនេះ ហើយនៅក្នុងព្រះគម្ពីរមរមនទាំងមូល គឺជាសាសន៍លេមិន ម្នាក់ ឈ្មោះសាំយូអែល។

ការរៀបចំសំរាប់ព្រះអង្គសង្គ្រោះ

គម្ពីរហេលេមិនបញ្ចប់ មុនពេលព្រះយេស៊ូវ ត្រីស្ទចាប់កំណើតតែបន្តិចប៉ុណ្ណោះ។ ប្រធាន អែសរ៉ា ថាប់ ប៉ែនសឹន បង្រៀនថាៈ "បញ្ជីប្រវត្តិរបស់សាសន៍នីហ្វៃ ជាពេលចំបង នៃការយាងមករបស់ព្រះអង្គសង្គ្រោះ ដើម្បីបើកបង្ហាញនូវភាពស្របគ្នាជាច្រើន ក្នុងសម័យរបស់យើងផ្ទាល់ ដូចដែលយើងគិតស្មានទុកជាមុន នៅថ្ងៃនៃការយាងមក ជាលើកទីពីររបស់ព្រះ អង្គសង្គ្រោះ" (នៅក្នុង Conference Report ខែមេសា ឆ្នាំ1987, 3 ឬ *Ensign* ខែឧសភា ឆ្នាំ1987, 4)។ អ្នកនឹងចង់សូមមើលនូវភាពស្រប គ្នាទាំងនេះៈ នៅពេលអ្នកអានគម្ពីរហេលេមិន។

ហេលេមិន 1

សង្ក្រាមនៅក្នុងដែនដីសាវ៉ាហិមឡា

នៅពេលចៅក្រមសាសន៍នីហ្វៃដ៏អស្ចារ្យ ពេហ្ហ៉ារានបានសម្លាប់ មានភាពស្មុគស្មាញកើតឡើង ចំពោះអ្នក មកជំនួសគាត់។ ការណ៍នេះនាំឱ្យមានការបែកចេញ និងការបង្ហូរឈាម។ នៅក្នុងកំឡុងពេលនោះ ពួកសាសន៍នីហ្វៃ ប្រឈមមុខជាមួយនឹងសត្រូវ ពីរគឺះ គិសគូមេន និងកូរីអានទុមមើរ។ តើបុរសទាំងពីរនាក់នោះ ជានរណា ហើយតើពួកគេមានគោលបំណងអ្វី?កាលដែលពួកគេ ប្រយុទ្ធប្រឆាំងនឹងពួកសាសន៍នីហ្វៃ ដោយវិធីផ្សេងពួគ្នា ពួកគេមានចំណង់ដូចគ្នា គឺដើម្បីមកបំផ្លាញសង្គមរបស់ពួកសាសន៍នីហ្វៃ។

ពេហ្ហ៉ារាន I	**ពេហ្ហ៉ារាន II**	**ពេគូមេណៃ**	**ម៉ូរ៉ៃណៃហា**
មេចៅក្រ៏ មដ៏អស្ចារ្យ	ត្រូវបាន៏ តែងតាំងឡើង ធ្វើជា៏ មេចៅក្រមថ្មី ត្រូវធ្វើឃាត៏ ដោយ៏ គិសគូមេនិ	ជាបងប្រុស៏ របស់ពេហ្ហ៉ារា II ត្រូវបាន៏ តែងតាំង ឱ្យធ្វើ៏ ជាមេចៅក្រម បន្ទាប់ពីបង៏ របស់គាត់ស្លាប	អ្នកដឹកនាំ នៃកងទ័ពពួក៏ សាសន៍នីហ្វៃ ជាកូនប្រុស៏ របស់មេបញ្ជាក៏ ារម៉ូរ៉ៃណៃ
ពេអានកៃ	**គិសគូមេន**	**កូរីអានទុមមើរ**	**ទូបាឡុត**
ជាបងរបស់៏ ពេហ្ហ៉ារាន II ដែលដឹកនាំ៏ ការបះបោរប្រឆ៏ ាំងនឹងបងប្រុស៏ របស់គាត់	បានសម្លាប់៏ ពេហ្ហ៉ារាន II ហើយបន្ទាប់៏ មករៀបចំជា៏ សង្គមសម្ងាត់៏ មួយ	បានបែកចេញពី៏ ពួកសាសន៍៏ នីហ្វៃ ដែលជា៏ អ្នកដឹកនាំ៏ កងទ័ពពួក៏ សាសន៍លេមិន	ជាបុត្ររបស់៏ ស្តេចសាសន៍៏ លេមិន៏ អាំម៉ូរ៉ុន

កត់ចំណាំ: ដើម្បីជួយក្នុងការបញ្ចេញសំឡេងឈ្មោះទាំងនេះ សូមមើល៏ ការណែនាំនៃការបញ្ចេញសំឡេងនៅទីបញ្ចប់នៃ ព្រះគម្ពីរមរមន (ទំព័រ 534)។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេឡាមិន 1

ច្រើនឥតគណនា (ខ. 14)—ធំណាស់ រាប់មិនអស់

បានវាយពួកទាហានយាមឱ្យ បរាជ័យ (ខ. 20)—សំលាប់អ្នកយាម

ការពារ (ខ. 22)—បន្ទាយ ប៉ម

នៅក្នុង (ខ. 23)—ស្នាក់នៅ

រដ្ឋធានី (ខ. 27)—មុជ្ឈមណ្ឌលអ្នករាជការ

បានស្ទាក់ផ្លូវ (ខ. 30)—បញ្ឈប់ពួកគេ

សម្រុកចូល (ខ. 32)—ធ្វើទីតាំងភ្លាម

កណ្តាល (ខ. 32)—ចំកណ្តាល

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) នៅខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 1។

ក្ត៉ គើនរណា បានធ្វើអ្វី?

1. សូមសរសេរប្រយោគមួយ ពីសកម្មភាពនៃមនុស្សនីមួយៗខាងក្រោមនេះ នៅក្នុងហេលេមិន 1ះ ពេហ្ហ៉ារាន (កូនប្រុស) ពេអានកៃ ពេគូមេណៃ គិសគូមេន កូរីអានទុមមើរ ទូបាឡុត ម៉ូរ៉ៃណៃហា។
2. សូមធ្វើការពិចារណាទូវអ្វី ដែលហេលេមិន 1ះ13–17 បង្ហាញអំពីកូរីអានទុមមើរ និងទូបាឡុត។ សូមប្រើពតិមាន នៅក្នុង ខគម្ពីរទាំងនេះ ដើម្បីបញ្ជាក់ពីអ្វី ដែលបុរសទុច្ចរិតទាំងពីរនាក់នេះ មានដូចគ្នា។ អ្នកអាចមានការផ្ទាក់ផ្អើល។

ខ្ត៉ រឿងសីលធម៌

1. តើមានមេរៀនអ្វីខ្លះ ដែលអ្នកគិតថា ពួកសាសន៍នីហ្វៃ គួរតែរៀន មកពីក្នុងព្រឹត្តការណ៍ នៅហេលេមិន 1? សូមផ្តល់ជា ឧទាហរណ៍ជាក់លាក់ដែលយកចេញពីក្នុងជំពូកនោះ។
2. តើមានមេរៀនអ្វីខ្លះ ដែលអ្នកគិតថា មនុស្សនៅជំនាន់របស់យើង អាចរៀនពីហេលេមិន 1? សូមផ្តល់ជាឧទាហរណ៍ជាក់លាក់ ដែលយកចេញមកពីក្នុងជំពូកនោះ។

ត្ត៉ គូររូបភាពមួយ

នៅហេលេមិន 1ះ18–34 គឺជាការពិពណិនាអំពីត្រោះថ្នាក់ បណ្តាលមកពីការផ្លាស់ប្តូរទីតាំងរបស់កងទ័ពកូរីអានទុមមើរ ដែលជាលទ្ធផលនាំឱ្យគាត់ទទួលបរាជ័យ។ បន្ទាប់ពីអាននៅក្នុងជំណើររឿងនេះ សូមគូររូបភាពបង្ហាញ ពីអ្វីបានកើតឡើង ចំពោះកងទ័ពលេមិន ហើយហេតុអ្វីក៏ម៉ូរ៉ៃណៃហា អាចមានលទ្ធភាពធ្វើឱ្យពួកគេបរាជ័យបាន។

ហេលេមិន 2

បក្សពួកកាឌីអានតុន

នៅហេលេមិន 1 មរមនបាន សរសេរអំពីមេចៅក្រមពីរនាក់ ត្រូវបានគេធ្វើឃាត។ នៅពេលអ្នកអាន ហេលេមិន 2 សូមកត់ចំណាំ ថា នរណាជាមេចៅក្រមថ្មី។ តើហេតុអ្វី អ្នកសន្មត់ថា ពួកគេជ្រើសរើសគាត់? តើគាត់បានធ្វើអ្វីខ្លះ ដើម្បីការពារកុំឱ្យ មេចៅក្រម ទីបីត្រូវគេធ្វើឃាតឡេត? តើការគំរាមគំហែងដែលថ្មី និងដ៏មានអនុភាពនេះ បានមានយ៉ាងណា ចំពោះ

ពួកសាសន៍នីហ្វៃ? សូមចំណាំផងដែរនូវអ្វី ដែលមរមនបានបង្រៀន អំពីឥទ្ធិពលនៃបក្សពួកខ្ពស់សម្ងាត់ទាំងនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 2

បានដេកចាំ (ខ. 3)—ការរង់ចាំដោយសម្ងាត់

ការរួមគំនិត (ខ. 8)—ក្រុមដែលរៀបចំដើម្បីធ្វើសកម្មភាពសម្ងាត់

ហេលេមិន 2:8—តើបក្សពួកខ្ពស់សម្ងាត់ គឺជាអ្វី?

បក្សពួក ឬអង្គការកាឌីអានតុន គឺជាបក្សពួកខ្ពស់សម្ងាត់។ បក្សពួកខ្ពស់សម្ងាត់ គឺជាក្រុមនៃមនុស្ស ដែលប្រើវិធី សាស្ត្រទុច្ចរិតដើម្បីឱ្យ បានអំណាច និងទ្រព្យសម្បត្តិ។ ពួកគេ ធ្វើឡើងដាសម្ងាត់ ពីព្រោះពួកគេចង់បញ្ឆោត និងយកផលប្រយោជន៍ពីអ្នកដទៃ។ ពួកគេធ្វើឡើងដោយបន្លំ សម្លាប់ និងការបំភាន់ ហើយគឺជាសត្រូវនឹងរដ្ឋាភិបាលស្មោះត្រង់ និងមនុស្ស ល្អត្រប់ទីកន្លែង។ ពួកគេ មានឆន្ទៈ ដើម្បីធ្វើអ្វីក៏ដោយឱ្យតែ ចាំបាច់សំរាប់ជាប្រយោជន៍ ចំពោះមូលហេតុរបស់ពួកគេ។ ព្យាការីសម័យថ្មីបានព្រមាន ដល់យើងថា នៅសព្វថ្ងៃនេះ មានអង្គការមួយ ដែលមានគ្រោះថ្នាក់ ដូចជាបក្សពួក របស់កាឌីអានតុន នៅក្នុងសម័យនៃពួកសាសន៍នីហ្វៃអញ្ចឹងដែរ។

កាឌីអានតុន

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា ហេលេមិន 2។

ក កត់សំគាល់នូវធាតុសំខាន់ៗ

1. នៅហេលេមិន 2:13–14 តើមរមន បានសរសេរអ្វីខ្លះអំពី ឥទ្ធិពលនៃបក្សពួកខ្ពស់សម្ងាត់ ក្នុងចំណោមពួកសាសន៍នីហ្វៃ?
2. ដោយប្រើហេលេមិន 1:9–12 ហើយ 2:1–8, 11 រួចធ្វើបញ្ជីអំពីបក្សពួកខ្ពស់សម្ងាត់ ព្រមទាំងមូលហេតុ និងរបៀប ដែលពួកគេធ្វើ។

ខ ផ្តល់ជាឧទាហរណ៍ទំនើបមួយ

1. សូមធ្វើការពិចារណា ពីអ្វី ដែលអ្នកបានរៀនមកពីការធ្វើសកម្មភាព ក រួចសរសេរអំពីរបៀបដែលជីវិតរបស់អ្នក អាចមាន ឥទ្ធិពលពីបក្សពួកខ្ពស់សម្ងាត់។
2. តើអ្នកគិតថា យើងអាចជួយការពារកុំឱ្យមានបក្សពួកខ្ពស់សម្ងាត់ រីកដុះដាលឡើងបានយ៉ាងដូចម្តេច?

ហេលេមិន 3

ពេលវេលានៃការចំរុងចំរើន និងការចំរើនឡើង

ហេលេមិន 3 មានប្រវែងជា ដប់ឆ្នាំនៃព្រឹត្តការណ៍ នៅក្នុងចំណោមពួកសាសន៍នីហ្វៃ។ វា គឺជាពេលវេលាមួយ នៅពេលពួក សាសន៍នីហ្វៃ មានបទពិសោធន៍នៃការចំរុងចំរើនយ៉ាងខ្លាំង។ មានការចំរើនឡើងដ៏អស្ចារ្យផងដែរ នៅក្នុងសាសនាចក្រ។ មរមន បានធ្វើការកត់ចំណាំជាពិសេស អំពីអ្វីដែល យើងអាចរៀនមកពីជំណើរឿងនេះ។ សូមយកចិត្តទុកដាក់ជាពិសេស នៅលើ ឃ្លាដែលថា "ហើយ ហេតុដូច្នោះ យើងឃើញថា" និង "យើងឃើញថា" ចំពោះមេរៀនសំខាន់ៗទាំងនោះ។

ហេលេមិន ដែលជាកូនប្រុសរបស់ហេលេមិន

ទោះជាយ៉ាងណាក៏ដោយ មិនមែនអ្វីៗទាំងអស់ សុទ្ធតែមានជំណើរការបានល្អនោះទេ។ សូមកត់ចំណាំនូវផលវិបាក ដែលសាសន៍ នីហ្វៃបានប្រឈមមុខ។ តើអ្វីខ្លះ ដែលបណ្តាលឱ្យមានផលវិបាកទាំងអស់នោះ?

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 3

ការបែកបាក់គ្នា (ខ. 1, 3, 14, 17)—ការឈ្លោះប្រកែក ការបះបោរ

ចូលទៅក្នុងទីកន្លែងណា ដែលត្រូវឆ្កា (ខ. 5–6)—ត្រូវបានបំផ្លាញ បង្អិនបង្អោច

ទុកឱ្យមនុស្សជាច្រើន (ខ. 13)—កំពុងតែធ្វើអ្វីផ្សេងៗ

សមភាព (ខ. 20)—យុត្តិធម៌

ផ្តាច់អស់ទាំងកលល្បិច (ខ. 29)—សម្តែង និងបំផ្លិចបំផ្លាញ

កលល្បិច (ខ. 29)—ដោយភាពឆ្លាតវៃដោយការបោកបញ្ឆោត

អន្តាក់ (ខ. 29)—អង្គប់

ឧបាយកល (ខ. 29)—ការបោក

ដើម្បីកប់ (ខ. 29)—ស្រូប

ការល្វងលោមចិត្ត (ខ. 35)—សំរាលទុក្ខ

ការញែកចិត្តឱ្យបរិសុទ្ធ (ខ. 35)—ការធ្វើឱ្យស្អាត ហើយបរិសុទ្ធ

ការបូជាចិត្ត (ខ. 35)—ការឱ្យ ការថ្វាយ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) នៅខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 3។

ក ធ្វើជាតារាងពេលវេលាមួយ

នៅក្នុងហេលេមិន 3 គឺជាកាលបរិច្ឆេទ។ នៅក្នុងខគម្ពីរនីមួយៗ ត្រូវបានធ្វើជាបញ្ជីនៅលើតារាងពេលវេលាដូចខាងក្រោមនេះ ដោយ មានជាព្រឹត្តការណ៍ និងឆ្នាំជាបន្តបន្ទាប់ ដែលមានព្រឹត្តការណ៍បានកើតឡើង។ នៅក្នុងស្សៀវភៅសរសេររបស់អ្នក សូមគូរតារាងពេលវេលា ដែលមានភាពស្រដៀងគ្នា ទៅនឹងតារាងមួយខាងក្រោម ហើយបំពេញនៅក្នុងតារាង ជាមួយនឹងអ្វីៗ ដែលអ្នករៀននៅហេលេមិន 3។

តារាងពេលវេលាះ ហេលេមិន 3

ខ	1	3	18	19	23	32	33	37
ឆ្នាំ								
គើអ្វីបានកើតឡើង?								

ខ ពន្យល់អំពីទំនាក់ទំនង

យោងទៅតាមហេលេមិន 3:1 គើការឆ្មើងឆ្មៃ និងការបែកញែកគ្នា មានទំនាក់ទំនងនឹងគ្នាអ្វីខ្លះ?

គ អនុវត្តព្រះគម្ពីរ

ចូរនឹកគិតថា អ្នកមានមិត្តម្នាក់ ដែលកំពុងមានការពិបាកក្នុងការធ្វើសេចក្តីសំរេចចិត្តឱ្យបានត្រឹមត្រូវ។ មិត្តរបស់អ្នកដឹងថា ដំណឹង ល្អពិត ប៉ុន្តែ ការជ្រើសរើសខុស បានធ្វើឱ្យគាត់មានអារម្មណ៍ដឹងពីកំហុស និងមានសំនួរអំពីលទ្ធភាពនៃការប្រែចិត្ត ហើយថា គើការប្រែចិត្ត មានប្រយោជន៍ឬ ក៏អត់។ គើមានមធ្យោបាយជាក់លាក់អ្វីខ្លះ ដែលអ្នកអាចប្រើ ហេលេមិន 3: 27–30, 35 ដើម្បីជួយមិត្តរបស់អ្នក ឱ្យជៀសផុត ពីសេចក្តីល្បួងឱ្យត្រលប់មកសាសនាចក្រវិញ ហើយបង្កើនជំនឿរបស់ពួកគេ នៅក្នុង ព្រះយេស៊ូវគ្រីស្ទវិញ?

ហេលេមិន 4
អំពើទុច្ចរិត និងផលវិបាក

ការចំរុងចំរើន អាចនាំឱ្យមានន្ទវអំពើទុច្ចរិត។ អំពើទុច្ចរិត បន្ទាប់មកអាចឈានទៅរកសេចក្តីបំផ្លិចបំផ្លាញ។ នេះជាការពិត មិន មែន សំរាប់តែពួកសាសន៍នីហ្វៃប៉ុណ្ណោះទេ ក៏ប៉ុន្តែសំរាប់មនុស្សបច្ចុប្បន្នផងដែរ។ គើហេតុអ្វី យើងត្រូវតែមានន្ទវការគំរាមគំហែង ដោយការបំផ្លិចបំផ្លាញ មុនពេលយើងទទួលស្គាល់ថា យើងមានការលំបាកខាងវិញ្ញាណ? គើហេតុអ្វី បានជាពួកសាសន៍នីហ្វៃ មិនគោរពព្រះអម្ចាស់ ទាំងត្រាណ្ម និងអាក្រក់? នៅហេលេមិន 4 មរមន បានពិពណិនារំពីអ្វី ដែលកើតឡើង អំពីភាពចំរុងចំរើន នាំទៅរកអំពើទុច្ចរិត។ សំដីរបស់គាត់អាចយកមកអនុវត្តចំពោះយើង និងចំពោះទិដ្ឋភាពសង្គមរបស់យើងបានខ្លះឲ្យផង ដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 4

ខិតខំ (ខ. 3)—ព្យាយាម

ការជិះជាន់ (ខ. 12)—អំពើយោរយៅ

មានចិត្តក្លាហាន (ខ. 16)—ចាកចេញ ចាប់ផ្តើម

បានបោះបង់ចោល (ខ. 21)—មិនអើពើ មិនគោរព រាប់អានដោយស្តួចស្តើង

ស្រវាគោង (ខ. 25)—កាន់យ៉ាងណែន នៅតែស្មោះត្រង់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សា ហេលេមិន 4។

ក អំពើបាបជាសកល

1. មានពាក្យនិយាយថា ការឆ្មើងឆ្មៃ គឺជាអំពើបាបជាសកល មានន័យថា ស្ទើរតែត្រប់អំពើបាបមានការទំនាក់ទំនងទៅនឹង ការឆ្មើងឆ្មៃផងដែរ។ នៅក្នុងស្សៀវភៅសរសេររបស់អ្នក ចូរគូសទំនាក់ទំនងនេះ ដោយការដាក់ពាក្យ *ការឆ្មើងឆ្មៃ* នៅចំកណ្តាល ទំព័រ។ គូររង្វង់ជុំវិញពាក្យ ហើយគូរព្រួញចេញពីរង្វង់ទៅត្រប់ទិសទាំងអស់។ នៅខាងចុងព្រួញនីមួយៗ ចូរធ្វើបញ្ជីនៃអំពើបាប មួយដែលហេលេមិន 4:12–13 និយាយថា វាកើតឡើងដោយសារការឆ្មើងឆ្មៃ របស់ពួកសាសន៍នីហ្វៃ។

2. សូមជ្រើសរើសយកអំពើបាបបី ដែលអ្នកសរសេរ មកពន្យល់អំពីរបៀប ដែលការឆ្មើងឆ្មៃ អាចនាំទៅរកប្រភេទ នៃអំពើបាប នោះ។
3. គើហេលេមិន 3:35 និយាយថា យើងត្រូវធ្វើអ្វីខ្លះ ដើម្បីការពារ ឬបំបាត់ចោលនូវការឆ្មើងឆ្មៃ ពីជីវិតរបស់យើង ហើយការពារ ពីអំពើបាបប្រភេទផ្សេងឲ្យគ្នាជាច្រើនទៀត?

ខ ឥឡូវខ្ញុំឃើញ

1. ចូរស្វែងរក និងគូសពណិចំណាំលើឃ្លាដែលថា "ពួកគេបានឃើញ" នៅហេលេមិន 4:23–26 ហើយធ្វើបញ្ជីពី ផលវិបាក នៃអំពើបាបដែលពួកសាសន៍នីហ្វៃបានឃើញ។
2. គើមានពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់បានផ្តល់ដើម្បីជួយដល់យើង "ឃើញ" ពីផលវិបាកជាមុន ដើម្បីកុំឱ្យយើងបានទទួលបទ ពិសោធន៍ អំពីផលវិបាកទាំងនោះ? (សូមមើលម៉ូសាយ 8:16–18)។
3. ចូរឱ្យឧទាហរណ៍ នៃផលវិបាកជាក់លាក់មួយ ដែលព្រះអម្ចាស់បានជួយអ្នក ឬត្រូសាររបស់អ្នកឱ្យដឹង និងចៀសវាងពីផលវិបាក ដោយសារតែពរជ័យនេះ។

ហេលេមិន 5

នីហ្វៃ និងលីហៃ នៅក្នុងគុក

នីហ្វៃ គឺជាកូនប្រុសរបស់ហេលេមិន បានលះបង់វេទិការជំនុំជំរះ ដើម្បីចំណាយពេលកាន់តែច្រើន ចេញទៅប្រកាសដំណឹងល្អ ដូច ដែលអាលម៉ាបានធ្វើកាលពី ពីរបីទសវត្សរ៍មុន (សូមមើល អាលម៉ា 4:15–19)។ តើសកម្មភាពរបស់ព្យាការីទាំងពីរនាក់នោះ បង្រៀនយើងអំពី របៀបអ្វីខ្លះ ដើម្បីកែទំរង់សង្គមមួយឱ្យបានប្រសើរបំផុត? ដៃគូរបស់នីហ្វៃ នៅក្នុងការប្រៀនប្រដៅ គឺជាប្អូនប្រុស របស់គាត់ឈ្មោះ លីហៃ បុរសដែលមានកម្លាំងខាងវិញ្ញាណដូចជានីហ្វៃដែរ (សូមមើល ហេលេមិន 11:19)។ នៅហេលេមិន 5 អ្នកនឹង អានអំពីអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យទាំងនោះ និងអំពីដំបូន្មានដែលពួកគេទទួលបានពីឪពុក របស់ពួកគេ។ នៅពេលអ្នក អានជំពូកនេះ ចូរស្វែងរកភស្តុតាង ដែលពួកគេស្តាប់តាមដំបូន្មានរបស់ឪពុកពួកគេ។

នីហ្វៃ និងលីហៃត្រូវបានព័ទ្ធជុំវិញដោយអណ្តាតភ្លើង ©1966 Ronald K. Crosby

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 5

ទុំល្មម (ខ. 2)—ល្មមញាំ

ដំណឹងល្អ (ខ. 11, 29)—សារល្អៗពិតមាន

អៀនខ្មាស់ (ខ. 17)—ពិបាកយល់ ហើយជំទាស់ ភាន់ច្រលំ

សម្លេងអឺងកង (ខ. 30)—លឺខ្លាំង

បានបែកខ្ញែកទៅ(ខ. 31, 42–43)—ចាកចេញ បាត់រូបរាង

ប្រេះចេញពីគ្នា (ខ. 33)—បែកពីគ្នា

សន្ទនា (ខ. 38–39)—និយាយ

បានអនុញ្ញាតឱ្យ (ខ. 49)—ប្រាប់ អញ្ជើញ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 5។

ក ពាក្យដ៏សំខាន់មួយ

អែលឌើរ ស្ពែនស៊ើរ ដបុលយូ ឃិមបឹល ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ មានប្រសាសន៍ថាៈ "នៅពេលអ្នកមើលនៅក្នុង វចនានុក្រម ដើម្បីរកពាក្យ ដែលសំខាន់បំផុត តើអ្នកដឹងថា ពាក្យនោះជាអ្វីទេ? វាអាចជាពាក្យ 'ចងចាំ'។ ដោយសារអ្នកទាំង អស់គ្នា បានធ្វើសេចក្តីសញ្ញា—អ្នកដឹងនូវអ្វី ដែលអ្នកត្រូវធ្វើ ហើយអ្នកដឹងពីរបៀបដើម្បីធ្វើវា—តំរូវការដ៏ធំបំផុតរបស់យើង គឺឱ្យមានការចងចាំ . . .។ 'ការចងចាំ' គឺជាពាក្យ។ 'ការចងចាំ' គឺជាកម្មវិធី" ("Circles of Exaltation"[ថ្លែងសុន្ទរកថា ទៅ កាន់អ្នកអប់រំខាងសាសនា 28 មិថុនា 1968], 8)។

1. ចូរស្វែងរក ហើយគូសពណ៌ចំណាំនូវពាក្យ*ចងចាំ* នៅក្នុងពាក្យដំបូន្មានរបស់ហេលេមិន ចំពោះកូនប្រុសរបស់គាត់ នៅហេលេមិន 5:5–14 រួចហើយធ្វើជាបញ្ជី នៅក្នុងសៀវភៅសរសេររបស់អ្នក អំពីអ្វី ដែលគាត់ចង់ឱ្យពួកគេចងចាំ។
2. សូមជ្រើសរើសវត្ថុមួយ មកពីក្នុងបញ្ជីរបស់អ្នក ហើយពន្យល់អំពីឥទ្ធិពលរបស់វត្ថុនោះ ដែលនឹងមានក្នុងជីវិតរបស់មនុស្ស បើ សិនជាពួកគេចងចាំគោលការណ៍នោះជានិច្ច។
3. យោងទៅតាមហេលេមិន 5:5, 14 តើនីហ្វៃ និងលីហៃឆ្លើយតប ចំពោះដំបូន្មានឪពុករបស់ពួកគេ យ៉ាងដូចម្តេច?

ខ ការទន្ទេញខគម្ពីរ—ហេលេមិន 5:12

ចូរបង្កើតរូបភាពតាមរបៀបខ្លះៗ—ដែលអ្នកអាចគូរវា សូមប្រើរូបភាព ដែលអ្នកកាត់ចេញ ឬផ្គុំរូបភាពទាំងពីរ—ដែលនឹងអាច ជួយអ្នកក្នុងការបង្រៀន ហេលេមិន 5:12 ដល់កុមារនៅអង្គការបឋមសិក្សា។ សូមចែកចាយរូបភាពនោះ ជាមួយគ្រួសារ របស់ អ្នក។

គ ផ្តល់ជាភស្តុតាង

ព្រះគម្ពីរ ជាញឹកញាប់ និយាយអំពី ព្រះចេស្តានៃព្រះបន្ទូលរបស់ព្រះ។ នេះគឺសំដៅទៅលើឥទ្ធិពលនៃការបង្រៀនដំណឹងល្អ និងរបៀប ដែលដំណឹងល្អ ជួយមនុស្សឱ្យផ្លាស់ប្តូរ ហើយកែប្រែចិត្តពីអំពើបាបរបស់ពួកគេ។ នៅពេលអ្នករំលឹកពី ហេលេមិន 5:13–19 សារ ឡើងវិញ សូមរកសូមមើល ឧទាហរណ៍ "ព្រះចេស្តានៃព្រះបន្ទូល។" ចូរពន្យល់ពីរបៀប ដែលប្រជាជន នៃសមាគមន៍សាសន៍នីហ្វៃ បានទទួលការផ្លាស់ប្តូរ ដែលជាលទ្ធផល នៃការប្រកាសរបស់ហេលេមិនទៅកាន់ពួកគេ។

ហេលេមិន 6

ការចំរុងចំរើននាំទៅរកអំពើទុច្ចរិត . . . ម្តងទៀត!

នៅហេលេមិន 6 យើងអានអំពីឥទ្ធិពលខ្លះៗ នៃបេសកកម្មរបស់នីហ្វៃ និងលីហៃក្នុងចំណោមប្រជាជន—ជាពិសេសក្នុងចំណោម ពួកសាសន៍លេមិន។ មានសន្តិភាព និងការចំរុងចំរើនជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ជាញឹកញាប់វាមានភាពងាយស្រួលជាង ដើម្បីបំភ្លេចព្រះអម្ចាស់ នៅគ្រាមានសន្តិភាព និងគ្រាចំរុងចំរើន។ នៅពេលមនុស្ស មានអារម្មណ៍ផ្តោតទៅលើសេចក្តីល្បួង នៃ ពិភពលោកនេះ អារក្សអាចទទួលបានអំណាចយ៉ាងច្រើន មកគ្រប់ដណ្តប់លើពួកគេ។ ឧបករណ៍ដ៏មានឥទ្ធិពល ជាងគេបំផុត មួយដែលសាតាំងប្រើ នោះគឺជាបក្សពួកព័ន្ធសម្ងាត់។ បក្សព័ន្ធសម្ងាត់ កើនឡើង នៅកន្លែងដែលមានភាពអាត្មានិយម ភាពលោភលន់ និងការស្រេកឃ្លានអំណាច។ នៅក្នុងជំពូកនេះ មានកត់ត្រាអំពីរបៀប ដែលសាតាំង និងបក្សព័ន្ធសម្ងាត់បានទទួលអំណាចយ៉ាង ច្រើន ក្នុងចំណោមសាសន៍នីហ្វៃជាថ្មី។ តើយើងអាច

រៀនអ្វីខ្លះ ពីការណ៍នេះ? សូមអានដោយយកចិត្តទុកដាក់ ដើម្បីឱ្យយើញពីអ្វី ដែលមរមន និងព្រះអម្ចាស់ចង់ឱ្យយើងយល់ ដើម្បីកុំឱ្យមានកំហុស និងត្រូវ ធ្លាក់ចុះ ទៅក្រោមអំណាចនៃមាសត្រូវ ដូចគ្នានឹង កំហុសទាំងនោះទៀតឡើយ។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 6

មិនប្រែចិត្ត (ខ. 2)—មិនមានការប្រែចិត្ត មិនសុំការអភ័យទោសចំពោះអ្វីដែលធ្វើខុស

ទូន្មាន (ខ. 4)—លើកទឹកចិត្ត ជំរុញ

បានទំនាក់ទំនង (ខ. 8)—ជំនួញ ការទំនាក់ទំនង

បានចំរើនឡើង (ខ. 12)—ចំរុងចំរើន ជោគជ័យ

ល្ងចប្លន់ (ខ. 17–18, 21, 23)—យកពី អ្នកដទៃដោយបង្ខំ ឬដោយហឹង្សា

បានបញ្ជោត (ខ. 26)—ធ្វើអ្វីមួយ ដែល សូមមើលទៅគួរឱ្យចង់បាន ល្បួង

បានទាក់ទាញ (ខ. 38)—ល្បួងបញ្ជោត មិនឱ្យស្តាប់បង្គាប់

របឹប (ខ. 38)—ល្ងចទ្រព្យសម្បត្តិ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–យ)ខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 6។

ក្ស រកសូមមើលឃ្លាសំខាន់ៗ

1. ហេលេមិន 6:31 បង្រៀនយើងថា អារក្ស បានក្តាប់ជាប់នូវចិត្ត "ភាគច្រើន" នៃពួកសាសន៍ នីហ្វៃ។ អារក្សមិនអាចធ្វើ និងមិន អាចបង្ខំពួកគេឱ្យនៅក្រោមអំណាចរបស់វាទេ។ សូមស្វែងរក យ៉ាងតិចនូវឃ្លាពីរ ដែលពិពណ៌នាអំពី រប្យៀបដែលអារក្ស អាច មានអំណាចមកលើចិត្ត នៃពួក សាសន៍នីហ្វៃ។ ចូរសរសេរឃ្លាទាំងនោះ នៅក្នុងស្យៀវភៅសរសេររបស់អ្នក។
2. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីការពារមិនឱ្យសាតាំងមកក្តាប់ជាប់នូវចិត្តរបស់អ្នក? អ្នកអាចពិចារណា នូវគោលការណ៍ខ្លះៗ ដែលអ្នកបានរៀន នៅហេលេមិន 5 ដែលជាផ្នែកខ្លះនៃចម្លើយរបស់អ្នក។

ខ គិតអំពីសំនួរមួយ

នៅក្នុងស្យៀវភៅសរសររបស់អ្នក ចូរធ្វើតារាងមួយ ដែលស្រដៀងគ្នាទៅនឹងតារាង ដូចខាងក្រោម នេះ ដែលមានឃ្លា ចេញពីហេលេមិន 6:21–31។ សូមគិតអំពីសំនួរមួយដែលអាចឆ្លើយ ដោយ ឃ្លាដែលបានផ្តល់ឱ្យនោះ។ រៀងទីមួយ គឺជាគំរូ ដើម្បីជួយអ្នកចាប់ផ្តើម។

ហេលេមិន 6	ចម្លើយ	សំនួរ
ខ. 21	អារក្ស	តើនរណា ជាអ្នកបំផុស៊ គំនិតឱ្យដល់ពួក៊ អ្នកដឹកនាំបក្សព័ន្ធសម្ងាត់?
ខ. 22	"ដើម្បីពួកគេអាចញែកឱ្យ៊ ដឹងបងប្អូន ដែលបានចូល៊ ក្នុងសេចក្តីសញ្ញា"	
ខ. 26	កាឌីអាន់គុន	
ខ. 28	"ទៅក្នុងសេចក្តីបំផ្លិចបំផ្លាញ"	
ខ. 30	"ជាអ្នកនិពន្ធ នៃអំពើបាបទាំងអស់"	
ខ. 31	"បានជាន់ឈ្លីនៅក្រោម៊ ជើងរបស់ពួកគេ"	

គ្ស តើអ្នកអាចធ្វើអ្វីខ្លះ?

1. ចូរធ្វើជាបញ្ជី នូវអ្វី ដែលហេលេមិន 6:17–40 បានបង្រៀនអំពី បក្សព័ន្ធសម្ងាត់។ ចូរកត់ចំណាំខគម្ពីរ នៅកន្លែង ដែល អ្នកបានរកឃើញរឿងរ៉ាវនីមួយៗ នៅក្នុងបញ្ជីរបស់អ្នក។
2. យោងទៅតាម ហេលេមិន 6 ចូរធ្វើជាបញ្ជី នៃរឿងបីផ្សេងទៀត ដែលអ្នកអាចធ្វើ ដើម្បីជួយ ទប់ទល់ ឬបំបាត់ចោលនូវ បក្សព័ន្ធសម្ងាត់ និងការជះឥទ្ធិពលអាក្រក់របស់ពួកគេ មកក្នុង សង្គមរបស់អ្នក។ សូមឱ្យជាសេចក្តីយោងមួយមកពី ហេលេមិន 6 (ឬ សេចក្តីយោងដទៃទៀត នៅក្នុងព្រះគម្ពីរ) ចំពោះគំនិតនីមួយៗ ដែលអ្នករកបាន។

ឃ ធ្វើការប្រៀបធៀបមួយ

នៅក្នុងស្យៀវភៅសរសេររបស់អ្នក ចូរធ្វើជាតារាងមួយ ដែលស្រដៀងគ្នាដូចមាននៅខាងក្រោម ដើម្បីធ្វើការប្រៀបធៀប ពីស្ថានភាព នៃពួកសាសន៍នីហ្វៃ ជាមួយនឹងស្ថានភាព នៃពួកសាសន៍ លេមិន នៅចុងបញ្ចប់ហេលេមិន 6។ ចំពោះខគម្ពីរនីមួយៗ ដែលបានសរសេរចេញពី ហេលេមិន 6 ចូរសរសេរនូវស្ថានភាពនៃពួកសាសន៍នីហ្វៃ ឬក៏ពួកសាសន៍លេមិន ដែលជំពូកនេះបានបើក បង្ហាញ។ មានខគម្ពីរខ្លះ បានផ្តល់ពតិមានតែ អំពីក្រុមមួយក្នុងចំណោមក្រុមទាំងនោះប៉ុណ្ណោះ។

ពួកសាសន៍នីហ្វៃ	ហេលេមិន 6	ពួកសាសន៍លេមិន
	ខ. 34	
	ខ. 35	
	ខ. 36	
	ខ. 37	
	ខ. 38	
	ខ. 39	
	ខ. 40	

ហេលេមិន 7

នីហ្វៃប្រកាសពីការប្រែចិត្ត ទៅដល់ប្រជាជនរបស់ គាត់

នីហ្វៃ បានប្រៀនប្រដៅដំណឹងល្អ នៅយ៉ាង ឆ្ងាយពីផ្ទះរបស់គាត់។ នៅពេលគាត់ ត្រលប់មកវិញ គាត់ងៀងឆ្ងល់ និងខកចិត្ត ចំពោះ អំពើទុច្ចរិតយ៉ាងខ្លាំង នៃប្រជាជនរបស់គាត់។ ហេលេមិន 7 ប្រាប់យើងអំពីអ្វី ដែលគាត់និយាយទៅ កាន់ប្រជាជន អំពីស្ថានភាព របស់ពួកគេ។

នីហ្វៃ

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 7

ដែនដីកំណើតរបស់លោក (ខ. 3)—កន្លែងដែលគាត់កើត (សារ៉ាហិមឡា)

បានដណ្តើមយក (ខ. 4)—ដណ្តើមអំណាច ដោយមិនស្របច្បាប់

ស្មោះត្រង់ (ខ. 4)—ដោយសមរម្យ

ងាយប្រដៅ (ខ. 7)—បញ្ចុះបញ្ចូល

ត្រូវរស់ក្នុង (ខ. 9)—តាំងចិត្ត ត្រូវចិត្ត

មានចិត្តអស្ចារ្យ (ខ. 15)—មានអារម្មណ៍ស្ងើចសរសើរ

បណ្តោយខ្លួនត្រូវដឹកនាំដោយ (ខ. 16)—សេចក្តីល្បួង

មកដល់ឥឡូវនេះ (ខ. 22)—ពីមុនកាលពីមុន

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា ហេលេមិន 7។

ក ការផ្តល់គំនិតឱ្យមានបទទំនុកដំកើងមួយ

សូមរំលឹក ហេលេមិន 7:1–11 សារឡើងវិញ។ តើមានទំនុកដំកើងមួយណាល្អ សំរាប់ជួយលើកកម្លាំងខាងវិញ្ញាណពួក សាសន៍នីហ្វៃ? តើហេតុអ្វី? (ចំពោះជំនួយបន្ថែម សូមមើលមាតិកាដើមរឿងនៅខាងក្រោយស្បៃរកោទំនុកដំកើងព្រះ។)

ខ កត់សំគាល់ គំនិតសំខាន់ៗ

សូមប្រើអ្វី ដែលអ្នករៀននៅ ហេលេមិន 7:11–29 ហើយឆ្លើយសំនួរដូចខាងក្រោមៈ

1. តើនីហ្វៃ បាននិយាយអ្វីខ្លះ ដែលជាដើមហេតុនៃ “ការទួញសោកដ៏ធំ” (ខ. 11) ចំពោះពួកសាសន៍នីហ្វៃ?
2. តើនីហ្វៃនិយាយថា នឹងមានអ្វីខ្លះ នឹងកើតឡើង បើសិនជាពួកគេមិនប្រែចិត្តទេនោះ? (សូមរកមើលឃ្លា “លើកលែងតែអ្នកប្រែចិត្ត” ដែលបានចែងម្តងហើយម្តងទៀត នៅក្នុងខគម្ពីរទាំងនោះ។)
3. តើមានការព្រមានអ្វីខ្លះ ដែលអ្នកបានឮ មកពីព្យាការីនៅរស់របស់យើង ដើម្បីផ្តល់ឱ្យដល់ប្រជាជននៅក្នុងសម័យរបស់យើង នេះ?

ហេលេមិន7 បង្ហាញឱ្យយើងឃើញថា នីហ្វៃ ប្រែប្រួលប្រដៅពីការប្រែចិត្តដោយចំឭ។ តើមានអ្វីខ្លះ កើតឡើង នៅពេលលីហៃ នីហ្វៃ អ័រមិណាដៃអាលម៉ា និងអាមូលេក និយាយចំឭទៅកាន់ប្រជាជនរបស់ពួកគេនោះ? តើអ្នកគិតថា ការបង្រៀនរបស់នីហ្វៃ ត្រូវបាន ប្រជាជនរបស់គាត់ទទួលយកដោយរបៀបណា? ចូរយកចិត្តទុកដាក់ជាពិសេស ចំពោះអ្វី ដែលចៅក្រមកាឌីអាន់តុន បាននិយាយ និងធ្វើនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 8

ចាប់មនុស្ស (ខ. 1)—ចាប់ខ្លួន

ដេរប្រមាថ (ខ. 2, 5)—ដេរប្រមាថស្តីបន្ទោស

ផ្ទុយនឹង (ខ. 3)—ប្រឆាំង

កើតឡើងដល់ (ខ. 8)—កើតឡើងចំពោះ

ក៏ត្រូវរុញរា (ខ. 10)—ប្រើកម្លាំង

ត្រូវបានបង្ខំ (ខ. 11)—ជំរុញដោយព្រះវិញ្ញាណ

លង្ហិន (ខ. 14)—ទង់ដែង

ហេលេមិន 8:19–20—តើសិលូស សិណុក និងអេសាយ៉ាសជានរណា?

នេះ គឺជាគ្រាតែមួយ ដែលអេសាយ៉ាស ត្រូវបានចែងនៅក្នុងព្រះគម្ពីរ។ ក៏ដូចជាសិលូស និងសិណុក ដែលការបង្រៀនរបស់ពួកគាត់ មានចារនៅលើផ្ទាំងលង្ហិន (សូមមើល វគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” ក្នុងនីហ្វៃទី1 19:10 ទំព័រ“30”)។

ហេលេមិន 8:21—មូលេក កូនប្រុសរបស់សេដេគា

ពូជអំបូររបស់មូលេក គឺជាចំណែកមួយ នៃប្រជាជនរបស់ដែនដីសារ៉ាហិមឡា ដែលត្រូវបានរកឃើញដោយម៉ូសាយទីមួយ និងប្រជាជន របស់គាត់ (សូមមើល អោមណៃ 1:14–19)។ ពួកគេក្លាយទៅជាពួកសាសន៍នីហ្វៃ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សា ហេលេមិន 8។

ក ធ្វើការប្រៀបធៀបមួយ

1. នៅហេលេមិន 8:1–10 អ្នកដឹកនាំទុច្ចរិតរបស់ប្រជាជនខ្លះ បានធ្វើការវៀលទោសដល់នីហ្វៃ។ យោងទៅតាមខទី 4 និង10 តើហេតុអ្វីក៏ពួកគេ មិនចាប់នីហ្វៃ ហើយយកគាត់ចេញទៅ ដើម្បីធ្វើទុក្ខទោសដល់គាត់?
2. ដោយមានភាពផ្ទុយគ្នា ទៅនឹងអារម្មណ៍នៃមនុស្សទុច្ចរិត នៅហេលេមិន 8 ចូរកត់សំគាល់ទៅលើឃ្លានៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា 121:45 ដែលមានពិពណ៌នាអំពីអារម្មណ៍ យើងអាចទទួលនៅពេលយើងរស់នៅប្រកបដោយគុណធម៌ និងមាន ជីវិតដ៏សុចរិត។
3. ចូរសរសេរសេចក្តីថ្លែងការណ៍មួយ ដែលសង្ខេបមកពីមេរៀន យើងបានរៀនពី ហេលេមិន 8:4, 10។

ខ បំពេញទំរង់គំនិត

នីហ្វៃ បានប្រើឧទាហរណ៍កាលពីជំនាន់ដើម ដើម្បីជួយប្រជាជនឱ្យយល់ពីសេចក្តីពិត។ នៅក្នុងស្បៃរកោសរសេររបស់អ្នក ចូរធ្វើដា ឱយ៉ាក្រាម ដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងឱយ៉ាក្រាមមួយខាងក្រោមនេះ ដើម្បីធ្វើដាគម្រោងយោលសំខាន់ៗ នៅក្នុង ការបង្ហាញរបស់នីហ្វៃ។ សូមប្រើ ហេលេមិន 8:11–20 ដើម្បីបំពេញត្រង់ចំនុច ដែលខ្វះ នៅលើគម្រោង។

នីហ្វៃ បង្រៀនពីសេចក្តីពិត ក៏ដូចគ្នានឹងព្យាការីដទៃទៀតបានបង្រៀនពីមុនមកផងដែរ។



ហេលេមិន 9

ឃាតករត្រូវបានរកឃើញ

តើធ្វើដូចម្តេច ដើម្បីឱ្យមនុស្សម្នាក់ ដឹងថា ទណាម្នាក់ គឺជាព្យាការី? នៅចុងបញ្ចប់នៃហេលេមិន 8 នីហ្វៃធ្វើការព្យាករណ៍ អំពីការស្លាប់របស់មេចៅក្រម។ វាហាក់ដូចជាសមហេតុវាសមផលម្យ៉ាងដែរ នៅពេលប្រជាជនរកឃើញសេចក្តីពិត នៃការព្យាករណ៍នោះ ការណ៍នោះ បានបង្ហាញចំពោះពួកគេថា នីហ្វៃគឺជាព្យាការី។ នៅពេលអ្នកអាន ហេលេមិន 9 ចូររកសូមមើល នូវប្រតិកម្ម ដែលកើតឡើងខុសឆ្គងគ្នា នៃការព្យាករណ៍របស់គាត់ ហើយគិតពីមូលហេតុដែលប្រជាជនមានន្ទូវ ប្រតិកម្មខុសឆ្គងគ្នាយ៉ាងដូច្នេះ។ តើប្រជាជន ទាំងនោះ យល់អំពីតួនាទីរបស់ព្យាការី ឬទេ? តើតួនាទីសំខាន់បំផុត របស់ព្យាការីគឺជាអ្វី?

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 9

ដែលស្បែកពាក់ (ខ. 6)—ការចិទចាំង

បានវាយ (ខ. 8)—វាយ

បានពន្យល់ច្រាប់ (ខ. 16)—ពន្យល់អំពីការយល់ឃើញរបស់ពួកគេ

ត្រូវបានដោះលែង (ខ. 18)—ឱ្យមានសេរីភាព

របៀបផ្សេងៗ (ខ. 19)—ភាពខុសឆ្គគ្នា

ចាប់កំហុស (ខ. 19)—ធ្វើឱ្យគាត់និយាយអ្វីដែលខុស

ជនផ្សំគំនិត (ខ. 20)—ចូលរួមក្នុងការរួមគំនិតក្បត់

មានចិត្តកាត់ស្បែក (ខ. 21)—មនុស្សដែលមានចិត្តមិនបរិសុទ្ធ

ជឿង (ខ. 30)—ស្គាល់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ដូចខាងក្រោម នៅពេលអ្នកសិក្សា ហេលេមិន 9។

ក តើពួកគេដឹងអំពីអ្វី?

សូមអំលើក ហេលេមិន 9:1–15 សារឡើងវិញ ហើយឆ្លើយសំនួរដូចខាងក្រោមៈ

1. តើសាសន៍នីហ្វៃទាំងព្រំទាក់ បានឃើញអ្វីខ្លះ ចេញពីការព្យាករណ៍របស់នីហ្វៃ?
2. តើហេតុអ្វី បានជាពួកគេមាន “ការភ័យខ្លាច” និង “ញ័រ” ហើយ “ដួលចុះទៅលើដី” ដោយសារតែអ្វី ដែលពួកគេបានឃើញដូច្នេះ ទៅវិញ? (សូមឱ្យគ្រាកដថា ដកស្រង់ខគម្ពីរពីហេលេមិន 7 សំរាប់ធ្វើជាចម្លើយរបស់អ្នក។)
3. តើហេតុអ្វីបានជា សាសន៍នីហ្វៃទាំងព្រំទាក់នោះត្រូវចាប់ជាក់គុក?

ខ ស្វែងរកមូលហេតុពិត

1. យោងទៅតាមហេលេមិន 9:16–20 តើពួកចៅក្រមទុច្ចរិតធ្វើការពន្យល់អ្វីខ្លះ អំពីការព្យាករណ៍ដ៏ត្រឹមត្រូវរបស់នីហ្វៃ?
2. បើសិនជា ពួកចៅក្រមទុច្ចរិត ត្រូវបានសុំឱ្យពន្យល់ពីមូលហេតុដែលពួកគេគិតថា នីហ្វៃ ធ្វើនូវអ្វីដែលពួកគេចោទប្រកាន់ តើអ្នកគិតថា ពួកគេនឹងនិយាយ យ៉ាងដូចម្តេច?
3. តើអ្នកគិតថា ពួកគេមានមូលហេតុត្រឹមត្រូវអ្វីខ្លះ មកចោទប្រកាន់នីហ្វៃ?
4. តើពួកចៅក្រមទាំងនោះ មានលក្ខណៈស្រដៀងគ្នានឹងមនុស្សសព្វថ្ងៃ យ៉ាងដូចម្តេចខ្លះ ដែលបដិសេធនូវភស្តុតាងអំពី ព្រះមានព្រះជន្មរស់ ព្រមទាំងនិយាយទៅកាន់ព្យាការីរបស់ទ្រង់?

គ បញ្ចប់ប្រយោគ

សូមចម្លងនូវប្រយោគ ដែលមិនទាន់បញ្ចប់ដូចខាងក្រោមនេះ ចូលទៅក្នុងស្បៀវភៅសរសេររបស់អ្នក។ បន្ទាប់មក បញ្ចប់ប្រយោគ ទាំងនេះ យោងទៅតាមពតិមាន ដែលមានទៅក្នុងហេលេមិន 9:39–41។

1. ប្រជាជនភាគខ្លះ ជឿលើពាក្យសំដីរបស់នីហ្វៃ ពីព្រោះ . . .
2. ប្រជាជនខ្លះទៀត ស្តាប់ និងជឿតាមពួកសាសន៍នីហ្វៃទាំងព្រំទាក់ ពីព្រោះ . . .
3. ខ្លះនិយាយថា នីហ្វៃ គឺជាព្យាការី ពីព្រោះ . . .
4. អ្នកដទៃទៀតនិយាយថា គាត់ គឺជាព្រះ ពីព្រោះ . . .

ហោលេមិន 10

នីហៃទទួលបានអំណាចយ៉ាងអស្ចារ្យ

យើងអាចគិតថា ប្រជាជនចង់ធ្វើតាមនីហៃ បន្ទាប់ពីការព្យាករណ៍របស់គាត់បានសំរេច អំពីមេចៅក្រម។ ទោះជាយ៉ាងណាក៏ ដោយ ការឈ្លោះប្រកែកគ្នា នៅចុងបញ្ចប់ នៃហោលេមិន 9 គឺជាភស្តុតាងថា អព្ភូតហេតុមិនបានផ្លាស់ប្តូរចិត្តរបស់ប្រជាជនទេ។ សូមមើល នៅហោលេមិន 10 សំរាប់គុណសម្បត្តិខ្លះៗ ដែលអាចជួយឱ្យមនុស្សម្នាក់ឈរយ៉ាងខ្ជាប់ខ្ជួនបាន។ សូមធ្វើការកត់ ចំណាំ ផងដែរ នូវអំណាចពិសេសរបស់ព្រះអម្ចាស់ ដែលបានប្រទានទៅឱ្យនីហៃ ហើយអំពីមូលហេតុ ដែលគាត់ទុកចិត្ត នឹងពរជ័យមួយ នេះ។ តើអំណាច ដែលបាន មកពីព្រះនេះ មានឥទ្ធិពលចំពោះប្រជាជន យ៉ាងដូចម្តេច? តើអំណាចនេះមានឥទ្ធិពលមកលើពួកគេដោយរបៀបណា?

នីហៃ

ការយល់ដឹងអំពីព្រះគម្ពីរ

ហោលេមិន 10

រវាងឮខ្លួន (ខ. 1)—ទីនេះ និងទីនោះ

ទន់ខ្សោយ (ខ. 3)—ព្រួយ ខកចិត្ត ធ្លាក់ទឹកចិត្ត

បានរកជីវិតរបស់អ្នកផ្តាល់ (ខ. 4)—ព្រួយបារម្ភតែចំពោះខ្លួនឯង

ជម្ងឺអាសន្នរោគ (ខ. 6)—ជម្ងឺ មេរោគនៃរុក្ខជាតិ ឬមនុស្ស

ភ្ជាប់ (ខ. 7)—ចងភ្ជាប់ ឬឱ្យពិតប្រាកដដោយសិទ្ធិអំណាចដាក់លាក់នៃបព្ចឹងិតភាព

វាយ (ខ. 10)—វាយប្រហារ ទណ្ឌកម្ម

សូម្បីតែ (ខ. 13)—សូម្បីតែ

នាំចេញ (ខ. 16)—យកទៅ

ហោលេមិន 10:4–10—នីហៃ ទទួលអំណាចដ៏ជាក់លាក់ មកពីព្រះ

ហោលេមិន 10:7 បង្ហាញថា ព្រះអម្ចាស់សន្យានឹងនីហៃថា ទោះជាអ្វីក៏ដោយដែលអ្នកនឹងភ្ជាប់ ឬស្រាយនៅលើផែនដី ក៏នឹងត្រូវ បានភ្ជាប់ ឬស្រាយនៅលើស្ថានសួគ៌ផងដែរ។ នេះ គឺជាអំណាចដូចគ្នានឹងអំណាច ដែលព្រះអង្គសង្គ្រោះ ផ្តល់ឱ្យ ពេត្រុស យ៉ាកុប យ៉ូហានេ (សូមមើល ម៉ាថាយ 16:19) និងព្យាការីយ៉ូសែប ស្ម៊ីធ (សូមមើល គ និងស 128:8–10, 132:46)។ អំណាច ឬភូនសោរដូចគ្នានេះ គឺត្រូវបានកាន់ដោយប្រធាន នៃសាសនាចក្រព្រះនៃយេស៊ូគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ យើងរៀនពី ជំណើររឿង នៅហោលេមិន 10 ថា អំណាចនេះ គឺប្រគល់ឱ្យចំពោះតែអ្នកណា ដែលព្រះអម្ចាស់ទុកព្រះទ័យប៉ុណ្ណោះ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា ហោលេមិន 10។

ក តើហេតុអ្វីនីហៃ ទទួលបានអំណាច ដ៏អស្ចារ្យយ៉ាងនេះ?

1. ចូរធ្វើបញ្ជី នៃការសន្យារបស់ព្រះអម្ចាស់ ធ្វើជាមួយនីហៃ នៅហោលេមិន 10:4–10។
2. យោងទៅតាមខគម្ពីរទាំងនោះ តើហេតុអ្វីក៏ព្រះអម្ចាស់ សព្វព្រះហឫទ័យប្រគល់ឱ្យនីហៃ នូវអំណាចដ៏អស្ចារ្យនេះ?
3. សូមអាន គោលលទ្ធិ និងសេចក្តីសញ្ញា 50:29 ផងដែរ ហើយពន្យល់នូវអ្វី ដែលខនេះ បង្រៀនអំពី មូលហេតុដែលនីហៃ ទទួលពរជ័យយ៉ាងច្រើនដូច្នេះ។ សូមពន្យល់ផងដែរ ថាតើខនេះមានអត្ថន័យយ៉ាងណាខ្លះចំពោះអ្នក។

ខ តើអ្នកនឹងនិយាយអ្វី?

ចូរនឹកស្រមៃថា អ្នក គឺជាសាសន៍នីហៃម្នាក់ រស់នៅក្នុងជំនាន់ ហោលេមិន 10 ហើយអ្នក គឺជាសាក្សី នៃអ្វី ដែលកត់ត្រានោទី នោះ។ បើសិនជា អ្នកកំពុងតែសរសេរសំបុត្រទៅលេងមិត្តម្នាក់ ដែលរស់នៅទីក្រុងឆ្ងាយ អំពីព្យាការីនីហៃ តើចរិតលក្ខណៈបី អ្វីខ្លះរបស់នីហៃដែលអ្នក នឹងត្រាប់នៅក្នុងសំបុត្ររបស់អ្នក? ចូរពន្យល់នូវអ្វី ដែលជាការចាប់អារម្មណ៍ ចំពោះចរិតលក្ខណៈទីមួយៗ ដែល បានធ្វើឱ្យអ្នកគិតអំពីនីហៃ។

ហោលេមិន 11

នីហៃ ប្រើអំណាចរបស់គាត់ ក្នុងនាមជាប្រជាជន

បើសិន អ្នកជាមនុស្សម្នាក់ដែលទទួលបានអំណាចនៃព្រះអម្ចាស់ ដែលប្រគល់ទៅឱ្យនីហៃ នៅហោលេមិន 10 តើអ្នកនឹង ប្រើអំណាចនោះ ដោយល្អបំផុត ដោយរបៀបណា ដើម្បីជួយដល់ប្រជាជនរបស់អ្នក? ហោលេមិន 11 ត្រាប់ យើងនូវអ្វី ដែលនីហៃ បានធ្វើ ហើយអំពីអ្វីដែលប្រជាជនធ្វើឆ្លើយតបមកវិញ។ សូមរកមើលឱ្យបានច្រើនអំពី ឥទ្ធិពលនៃក្រុមចោរ កាឌីអាន់តុន មានចំពោះប្រជាជាតិផងដែរ។ តើអ្នកគិតថាអ្វីទៅ ដែលជាបញ្ហាយ៉ាងធំបំផុត នៅក្នុងចំណោមប្រជាជននីហៃ? តើបញ្ហានេះ បង្ហាញឱ្យ (ឃើញ)នៅក្នុងពេលបច្ចុប្បន្ន ដោយរបៀបណាដែរ?

ការយល់ដឹងអំពីព្រះគម្ពីរ

ហោលេមិន 11

នៅក្រោមបារ (ខ. 9)—ក្រណាត់ គ្រាតឲ្យរហែកមួយផ្តាំង ជាទីសំគាល់នៃភាពទុក្ខព្រួយ

បានស្ងប់ (ខ. 11)—បំពេញ ទាំមកដល់ទីបញ្ចប់

បានគោរព (ខ. 18)—ពិចារណា ទទួលគោរព

អន់ (ខ. 19)—បំណែកតូច ផ្នែកតូច

ការខូចខាត (ខ. 27)—ការខូចខាត ការច្រលំ ការបំផ្លិចបំផ្លាញ

ត្រូវបង្ខំ (ខ. 31)—បានបង្ខំ

ដែលនៅពាសពេញ (ខ. 31)—កាន់កាប់ បំពេញ

កែប្រែគំនិត (ខ. 36)—ប្រែចិត្ត កែផ្លាស់ប្តូរ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក –គ) ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 11។

ក ចូរធ្វើការកត់សំគាល់ជាលំអិត

ចូរសរសេរក្សាលរឿងនៅខាងក្រោម ចូលទៅក្នុងស្បៃវភៅសរសេររបស់អ្នក។ ចូរស្វែងរក និងធ្វើបញ្ជីយ៉ាងលំអិត ដែលដកស្រង់ ចេញមកពីដំណើររឿងនៅ ហេលេមិន 11:1–18 ដែលទាក់ទងទៅនឹងក្សាលរឿងនីមួយៗ។

- បញ្ហា
- ដំណោះស្រាយរបស់នីហ្វៃ
- ឥទ្ធិពល
- លទ្ធផលចុងក្រោយ

ខ បង្កើតជាទំព័រខាងមុខ

ហេលេមិន 11:17–22 ពិពណិនាអំពីអ្វី ដែលបានកើតឡើង កំឡុងពេលបួនប្រាំឆ្នាំ នៃរដ្ឋកាលនៃពួកចៅក្រម (ប្រមាណជាឆ្នាំ 16 –14 ម.គ.ស)។ ចូរប្រើគំរូដែលមាននៅទំព័រខាងមុខដូចខាងក្រោមនេះ សំរាប់រយៈពេលចិតសិបប្រាំមួយឆ្នាំ រួចបង្កើតទំព័រខាង មុខកាសែត សំរាប់រយៈពេលចិតសិបប្រាំពីរ និងចិតសិបប្រាំបីឆ្នាំ ដោយប្រើនូវព្រឹត្តការណ៍នានា ដែលបានកើតឡើងមកពិពណិនាអំពីឆ្នាំនីមួយៗ។

គ តើការណ៍នេះ កើតឡើងយ៉ាងដូចម្តេច?

ចូររំលឹក ហេលេមិន 11:28–37 សារឡើងវិញ ហើយឆ្លើយសំនួរដូចខាងក្រោមៈ

1. តើកងទ័ពពួកសាសន៍នីហ្វៃ និងកងទ័ពពួកសាសន៍លេមិនបានព្យាយាមធ្វើអ្វីខ្លះ ដើម្បីកំចាត់ពួកចោរកាឌីអាន់គុន?
2. តើពួកគេទទួលបានដោគជ័យ យ៉ាងដូចម្តេច ?
3. តើហេតុអ្វីបានជាពួកចោរកាឌីអាន់គុន បែរជាមានអំណាច យ៉ាងខ្លាំងដូច្នេះទៅវិញ? តើមេរៀនអ្វី ដែលយើងអាចរៀន សំរាប់សម័យ របស់យើង?

ហេលេមិន 12
"ហើយយើងយើញបែបនេះថា"

នៅហេលេមិន 12 លោកមរមន បានបកប្រែដំណើររឿងនៃសាសន៍នីហ្វៃ របស់គាត់ ដើម្បីនិយាយដោយត្រង់ឲមករកយើង។ នៅ ក្នុងជំពូកមុន គាត់សរសេរអំពីរបៀប ដែលពួកសាសន៍នីហ្វៃ ប្រែពីទុច្ចរិត ទៅជាសុចរិត ហើយបន្ទាប់មកត្រលប់ទៅជា ទុច្ចរិតម្តងទៀត—ម្តង ហើយម្តងទៀត។ ជាពិសេសអ្វី ដែលហាក់ដូចជាធ្វើឱ្យមានការមួរម៉ៅចំពោះលោកមរមន គឺថាពួក សាសន៍នីហ្វៃ និងជាមនុស្សសុចរិត គែនៅពេលពួកគេត្រូវការជាចាំបាច់ នូវជំនួយពីព្រះអម្ចាស់ប៉ុណ្ណោះ។ ពួកគេហាក់ដូចជាមិន បានធ្វើល្អ នៅពេលព្រះអម្ចាស់ប្រទានពរជ័យ និងចំរុងចំរើនដល់ពួកគេនោះទេ។ សូមអានជំពូកនេះ ដោយយកចិត្តទុកដាក់ ពីព្រោះតែពីការណ៍នេះ ត្រូវបានសរសេរឡើង សំរាប់សម័យ និងពេលវេលារបស់យើង។ សង្ឃឹមថា យើងអាចរៀនពីដំបូន្មានរបស់លោកមរមន ហើយជៀសវាងពីបញ្ហា ដែលពួកសាសន៍នីហ្វៃ ធ្លាប់មានបទពិសោធន៍នោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 12

ហើយសរុបសេចក្តីមក (ខ. 2)—ដោយច្បាស់លាស់

ជំបូន្មាន (ខ. 5)—ពាក្យទូន្មាន ការបង្រៀន

ពុំយកជាការ (ខ. 6)—គិតថាគ្មានតម្លៃ គ្មានន័យ

ត្រូវបណ្តាសា (ខ. 18–20)—ទទួលទោស បណ្តាសា

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ)ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 12។

ក សូមមើលគោលការណ៍

1. នៅក្នុងខគម្ពីរបីតំបូង នៃហេលេមិន 12 លោកមរមន បានសរសេរអំពីអ្វី ដែលយើងគួរតែ "យើញ" ពីគំរូ នៃពួកសាសន៍ នីហ្វៃ។ អ្នកអាចចង់គូសពណិចំណាំនៅលើយ្លា "យើងអាចយើញថា" និង "យើងយើញបែបនេះថា" នៅខ 1–3។ បន្ទាប់មក សរសេរ នៅក្នុងស្បៃវភៅសរសេររបស់អ្នក ជាពាក្យរបស់អ្នកផ្ទាល់ នូវគោលការណ៍ ដែលលោកមរមន ចង់ឱ្យយើងយល់យ៉ាងពិតប្រាកដ។
2. ចូរបន្ថែមទៅក្នុងការសរសេររបស់អ្នកនូវគោលការណ៍នៃព្រះ និងមនុស្ស ដែលលោកមរមន បានចង្អុលបង្ហាញនៅខ 4–6។
3. ចូរលើកឧទាហរណ៍មួយ ដែលបង្ហាញអំពីគោលការណ៍មួយ នៃគោលការណ៍ទាំងនោះ ដែលអ្នកបានយើញនៅកន្លែងការងារ បច្ចុប្បន្ទនេះ។

ខ ធ្វើការជ្រើសរើស ហើយប្រើពាក្យសំខាន់ៗ

ហេលេមិន 12:8–20 ពិពណិនាអំពី ព្រះចេស្តានៃព្រះ។ ចំពោះខគម្ពីរនីមួយៗ នៅក្នុងសារលិខិតនេះ ចូរធ្វើការជ្រើសរើស នូវ ពាក្យ ឬឃ្លាមួយ ដែលអ្នកគិតថា សំខាន់នៅក្នុងរឿងដែលលោកមរមន កំពុងបង្រៀនដល់យើង។ បន្ទាប់ពីអ្នកសរសេរពាក្យគន្លឹះ រួចហើយ សូមប្រើពាក្យទាំងនោះ ដើម្បីសរសេរជាសង្ខេប ពីសារលិខិតរបស់លោកមរមន ដែលមាននៅខទាំងឡាយនោះ។

គ សរុបសេចក្តី

ហេលេមិន 12:23–26 មានតំបូន្មានរបស់លោកមរមន ចំពោះអ្វី ដែលជាបំណងប្រាថ្នារបស់ព្រះអង្គសង្គ្រោះសំរាប់យើង។ ចូរនឹកស្រមៃថា អ្នកមានមិត្តម្នាក់ដែលមានបញ្ហាស្រដៀងគ្នាទៅនឹងបទពិសោធន៍របស់ពួកសាសន៍នីហ្វៃបានជួបប្រទះ។ សន្មត់ថា អ្នកបាន ពន្យល់ពីគោលការណ៍

លោកមរមនបង្រៀន នៅហេលេមិន 12:1–22 រួចហើយតាមសំដីរបស់អ្នក ចូរសរសេរដំបូន្មានដូចគ្នានេះ ទៅឱ្យមិត្តរបស់អ្នក។

ហេលេមិន 13

សាំយូអែល ជាសាសន៍លេមិន ព្យាការទៅកាន់ពួកសាសន៍នីហ្ចៃ

ស្ថានភាពនៅហេលេមិន 13 គឺមានភាពខុសគ្នាពីស្ថានភាព ដែលយើងរកបាននៅក្នុងព្រះគម្ពីរមរមន។ នៅជំពូកនេះ ប្រាប់យើងអំពីព្យាការីម្នាក់ជាសាសន៍លេមិន ដែលបានធ្វើការព្យាករណ៍ទៅដល់អ្នកមិនប្រែចិត្ត ដែលជាសាសន៍នីហ្ចៃ អំពីការបំផ្លិចបំផ្លាញនឹងមានដល់ពួកគេ។ ពួកសាសន៍នីហ្ចៃ បដិសេធសាំយូអែល—ប៉ុន្តែមិនមែនដោយសារតែគាត់គឺជាសាសន៍ លេមិន នោះ ទេ។ នៅពេលអ្នកអានជំពូកនេះ ចូរគិតអំពីសារដំណឹងរបស់សាំយូអែល និងមូលហេតុ ដែលគាត់ចង់និយាយអំពីដំណឹង នេះ។ ចូរស្វរខ្លួនឯងថាហេតុអ្វីបានជាប្រជាជន បដិសេធសាំយូអែល និងសារដំណឹងរបស់គាត់។ តើហេតុអ្វីបានជាមនុស្ស នៅពេលណាក៏ដោយ តែងតែបដិសេធសារដំណឹងរបស់ព្យាការីអញ្ចឹង?

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 13

ដំណឹង (ខ. 7)—ពតិមាន

ជម្ងឺអាសន្នរោគ (ខ. 9)—ជម្ងឺ រោគពិស ឬរោគឆ្លង

អំពើគួរឱ្យស្អប់ខ្ពើមទាំងឡាយ (ខ. 14–17)—អំពើបាបដ៏ខ្លាំងសម្បើម

អាចរកឃើញទ្រព្យសម្បត្តិនោះវិញឡើយ (ខ. 19)—សន្សំវា ប្រើវា ដើម្បីបានផលចំណេញ

ការបែកបាក់ (ខ. 22)—ការឈ្លោះប្រកែក ការទាស់ទែង

ព្យាបាទ (ខ. 22)—សេចក្តីប្រាថ្នាឱ្យអន្តរាយ

ដោយឥតបានប្រយោជន៍ (ខ. 32)—ទណ្ឌកម្ម

ថ្ងៃសាកល្បង (ខ. 38)—ការសាកល្បងនៅមតះភាព

ហេលេមិន 13:24–29—ការបដិសេធព្យាការី

នៅពេលយើងបដិសេធព្យាការីពិត ដែលជាអ្នកមើលឃើញដោយពន្លឺនៃវិវរណៈ ហើយបែរជាដើរតាមអ្នកទាំងឡាយណា ដែលគ្មានពន្លឺដ៏ទេវភាព នោះយើងពិតជាកំពុងដើរតាម "ពួកខ្ចាក់" (ហេលេមិន 13:29)។ ប្រធាន ម៉ើរ៉ុន ជី រ៉ូមនី ដែលជា សមាជិក នៃគណៈប្រធានទីមួយ មានប្រសាសន៍ថាៈ "អ្នកទាំងឡាយណា ដែលអះអាងថាទទួលយកដំណឹងល្អ ហើយដែលនៅ ពេលដូចគ្នានោះ រិះគន់ និងបដិសេធក្នុងការធ្វើតាមដំបូន្មានរបស់ព្យាការីនោះ គឺសន្មត់ថា មិនអាចការពារជំហររបស់ខ្លួនបានទេ។ ដូច្នេះនឹងមានវិញ្ញាណមួយ នាំទៅរកការក្បត់ សាសនា" (ក្នុង Conference Report ខែមេសា ឆ្នាំ 1983, 21 ឬ *Ensign* ខែឧសភា ឆ្នាំ 1983, 17)។ ប្រធាន អើសរ៉ា ថាប់ ប៊ើនសឹន នៅពេលគាត់ជាប្រធាននៃក្រុមសាវកដប់ពីរនាក់ បង្រៀនថាៈ "តើយើងអាចឆ្លើយតបទៅនឹងប្រសាសន៍របស់ព្យាការីនៅរស់បានយ៉ាងដូចម្តេច នៅពេលគាត់ប្រាប់យើងនូវអ្វី ដែលយើងគួរតែដឹង ប៉ុន្តែបែរជាយើងមិនចង់ឮវិញ នោះគឺជាការសាកល្បងនៃសេចក្តីស្មោះត្រង់របស់យើង" ("Fourteen Fundamentals in Follwing The Prophet" ក្នុង *1981 Devotional Speeches of the Year* [1981], 28)។

ហេលេមិន 13:38—តើអាចទទួលសុភមង្គលបានដោយរបៀបណា?

ព្យាការីយ៉ូសែបស្មីធ បង្រៀនថាៈ

"សុភមង្គលគឺជាគោលបំណង និងផែនការនៃជីវិតរស់នៅរបស់យើង និងជាទីបញ្ចប់ផងដែរ បើសិនជាយើងតស៊ូ នៅលើផ្លូវ ដែលឆ្ពោះទៅរកសុភមង្គល ហើយនៅលើផ្លូវនេះមានដូចជាគុណធម៌ សេចក្តីទៀងត្រង់ សេចក្តីស្មោះត្រង់ ភាពបរិសុទ្ធ និងការរក្សារាល់ ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ . . .

" . . . ទ្រង់មិនដែលបង្កើតពិធីការមួយ ដើម្បីផ្តល់ព្រះបញ្ញត្តិដល់រាស្ត្ររបស់ទ្រង់ ដោយមិនមានផែនការ [បានត្រោង] នៅក្នុង លក្ខណៈលើកតំកើងសុភមង្គល ដែលទ្រង់បានត្រោងទុក ហើយដែលនឹងគ្មានទីបញ្ចប់ក្នុងទំហំដ៏មហិមាបំផុតនៃសេចក្តីល្អ និងសិរីល្អ ចំពោះអ្នកទាំងឡាយ ដែលក្លាយជាអ្នកទទួលច្បាប់ និងពិធីការរបស់ទ្រង់នោះឡើយ" (*History of the Church,* 5:134–135)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពក និង ខ នៅពេលអ្នកសិក្សា ហេលេមិន 13។

ក ធ្វើបញ្ជីនៃពីអំពើបាប និងផលវិបាកនៃអំពើបាប

1. ចូរស្វែងរក ហើយធ្វើជាបញ្ជី នៃអំពើបាប ដែលព្រះអម្ចាស់មានបន្ទូលថា អំពើបាប គឺជាការល្បួងដ៏ធំបំផុតចំពោះមនុស្សលោក (សូមមើលខ. 7–8, 14–24, 26–28, 38)។
2. តើអំពើបាបមួយណា ដែលអ្នកគិតថា គឺជាការល្បួងដ៏ធំបំផុត ចំពោះមនុស្សវ័យស្របាលគ្មានឹងអ្នក នាពេលបច្ចុប្បន្ននេះ?
3. ចូរធ្វើបញ្ជី នៃផលវិបាក ដែលព្រះអម្ចាស់បានធ្វើការព្រមាន បើពួកសាសន៍នីហ្ចៃមិនព្រមប្រែចិត្ត ទេនោះ (សូមមើលខ 8. –10, 17–20,29–38)។
4. តើផលវិបាកទាំងនេះ និងធ្លាក់មកលើអ្នកទាំងឡាយណា ដែលបដិសេធក្នុងការកែប្រែចិត្តនៅបច្ចុប្បន្ននេះដោយរបៀបណា?

ខ ព្យាការីពិត ព្យាការីក្លែងក្លាយ

នៅហេលេមិន 13:24–28 សាំយូអែល បានពិពណិនាពីរបៀប ដែលពួកសាសន៍នីហ្ចៃ បដិសេធព្យាការីពិត ហើយគោរព ដល់ព្យាការី ក្លែងក្លាយ។ ចូរសំលឹកខគម្ពីរ ទាំងនោះសារឡើងវិញ ជាមួយនឹងឱពុកម្តាយ ឬអ្នកដឹកនាំសាសនាចក្រ ហើយរួមគ្នា ធ្វើការបំពេញប្រយោគដូចនៅខាងក្រោមនេះ

1. ចូរធ្វើបញ្ជីគំរូខ្លះ មកបង្ហាញពីរបៀប ដែលប្រជាជនបដិសេធព្យាការីពិត នៃព្រះអម្ចាស់នៅបច្ចុប្បន្ននេះ។
2. ចូរធ្វើបញ្ជីគំរូខ្លះ អំពីប្រជាជន ឬអង្គការទាំងឡាយ ដែលពួកគេមួយចំនួនសង្ឃឹមចង់បានការដឹកនាំ និងការណែនាំ ជាជាងមានព្យាការីនៃព្រះអម្ចាស់។

3. ចូរធ្វើការស្រាវជ្រាវ ហេលេមិន 13:29–39 ហើយពិពណិនាពីរប្បៀបដែលខគម្ពីរទាំងនេះ អាចត្រូវបានសំរេច នៅក្នុងសម័យ របស់យើង។

©1995 Acey Harper

ហេលេមិន 14

សញ្ញានៃការប្រសូត្រ និង ការសុគតរបស់ព្រះគ្រីស្ត

ពួកសាសន៍នីហ្វៃ ត្រូវបានបំបែកចេញយ៉ាងឆ្ងាយ ពីកិច្ចការបំរើនៅក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ យ៉ាងច្រើនគីឡូ ម៉ែត្រ។ ពួកគេបានដឹងអំពីព្រះយេស៊ូវគ្រីស្ត និងដំណឹងល្អរបស់ទ្រង់ តាមរយះព្រះគម្ពីរ និងទីបន្ទាល់នៃព្យាការីរបស់ពួកគេ និងដោយ វិវរណៈផ្ទាល់ខ្លួន។ នៅហេលេមិន 14 អ្នកនឹងរៀន នូវទីសំគាល់ ដ៏ជាក់លាក់ខ្លះ ដែលបានសន្យាដល់ពួកសាសន៍នីហ្វៃថា នឹងមានជា សញ្ញា អំពីការប្រសូត្រ និងការសុគតរបស់ព្រះយេស៊ូវគ្រីស្ត នៅប្រទេសអ៊ីស្រាអែល។ នៅពេលអ្នកបន្តការសិក្សា ក្នុងហេលេមិន រហូតដល់ក្នុងនីហ្វៃទី 3 ចូររកមើលនូវការសំរេចតាមទីសំគាល់ទាំងនោះ។ ចូរគត់ចំណាំផងដែរ ចំពោះអ្នកណា ដែលបានជឿ ដល់សាក្សីទាំងនោះ និងអ្នកដែលមិនជឿ និងអំពីមូលហេតុ។

យើងស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នាមួយ។ យើងត្រូវបានបំបែកចេញពីពេលដែលមានកិច្ចការបំរើមតះ របស់ព្រះអង្គសង្គ្រោះ ជាច្រើនរយឆ្នាំមកហើយ។ យើងមានសាក្សីដូចគ្នា និងឱកាស ដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន។ យើងក៏មានទីបន្ទាល់របស់ព្យាការី សម័យថ្មីផងដែរថា ព្រះយេស៊ូវគ្រីស្ត ពិតជាព្រះរាជបុត្រារបស់ព្រះ ហើយថាទ្រង់នឹងយាងមកម្តងទៀត។ យើងមានទីសំគាល់ ជាក់លាក់ផងដែរ ដែលបានសន្យាអំពី ការយាងមកជាលើកទីពីរនោះ។ នៅពេលអ្នកអាននូវរប្បៀប ដែលការព្យាករណ៍ យ៉ាង ពេញលេញ អំពីការយាងមកជាលើកទីមួយ ត្រូវបានសំរេច ចូរពិចារណាពីភាពស្រដៀងគ្នា ទៅនឹងការព្យាករណ៍ ដែលយើងមាន អំពីការយាងមកជាលើកទីពីររបស់ទ្រង់ (សូមមើល ត និង ស 1:37–38 ផងដែរ)។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 14

ដោយគោលបំណង (ខ. 11–12, 28–29)—គោលបំណង

ព្រះគុណ (ខ. 13)—ដង្ហាយធួន និងចរិកលក្ខណៈ អាកប្បកិរិយា

ការសុគត នៃទ្រង់ (ខ. 15)—ជាការចាំបាច់ ចំពោះទ្រង់

ជាការចាំបាច់ (ខ. 15)—ការចាំបាច់សារៈសំខាន់

ត្រូវកាប់រំលំ (ខ. 18)—កាត់ចេញ

បែកជាពីរ (ខ. 22)—ដែលបែកទៅជាពីរ

មានព្យុះសង្សរា (ខ. 23, 27)—ព្យុះកំណាច

ហេលេមិន 14:18–20—តើ "សេចក្តីស្លាប់ខាងវិញ្ញាណ" ឬ "សេចក្តីស្លាប់ទីពីរ" ជាអ្វី?

ចំពោះពតិមានបន្ថែម សូមមើល វគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" នៅអាលម៉ា 12 (ទំព័រ 110)។

ហេលេមិន 14:29–31—យើងអាចជ្រើសរើសសកម្មភាពរបស់យើង ប៉ុន្តែមិនអាចជ្រើសរើសនូវផលវិបាកបានទេ

អែលឌើរ រីឆាត ជី ស្តត ជាសមាជិក នៃក្រុមសាវ័កដប់ពីរនាក់ បង្រៀនថាះ

"នៅពេលអ្នកដទៃ ឱ្យតំបូន្មានដល់អ្នក គើអ្នកធ្លាប់មាននិយាយថា 'ខ្ញុំ ត្រាន់តែមិនជឿពីអ្វីដែលអ្នកធ្វើ។ ទាំងនោះ គឺជា មាត្រដ្ឋាន និងជាគោលការណ៍របស់អ្នក។ ខ្ញុំ មានវិធីរបស់ខ្ញុំហើយ' ដែរឬទេ? សូមឱ្យយល់ថា ត្មានទរណាម្នាក់អាចផ្លាស់ប្តូរ សេចក្តីពិតបានទេ។ សមស្របនិយកម្ម មានការគ្របសង្កត់លើការចូលចិត្តតែនឹងខ្លួនឯង រាល់ជម្លោះរបស់មនុស្ស កំហឹងឬឆន្ទៈ ផ្ទាល់ខ្លួនមិនអាចផ្លាស់ប្តូរសេចក្តីពិតបានទេ។ អារក្ស ដឹងនូវការណ៍នេះ ដូច្នេះវាព្យាយាមបង្កើតបរិយាកាសថ្មី ដែលអ្នកមិនមានចំណង់ ដើម្បីចាប់ផ្តើមឱ្យមានអារម្មណ៍ថា ត្រាន់តែមិនអាចជ្រើសរើសនូវអ្វី ដែលត្រូវធ្វើតែប៉ុណ្ណោះទេ ប៉ុន្តែអាច កំណត់នូវអ្វី ដែលត្រឹមត្រូវ ដើម្បីធ្វើផងដែរ។ អារក្ស ខិតខំអូសទាញយើង ឱ្យរស់នៅក្រៅពីសេចក្តីពិត ដោយការសម ស្របនិយកម្មលើសកម្មភាពរបស់យើងថា គឺជា*ការជ្រើសរើសត្រឹមត្រូវ*។

សូមមើលស្បៀវភៅធនធានសិក្សាព្រះគម្ពីរមរមន របស់ត្រូ

"សូមឱ្យយល់ថា ត្មានទរណាម្នាក់ មានសិទ្ធិ ដើម្បីជ្រើសរើសអ្វីដែលជាការត្រឹមត្រូវនោះទេ។ ព្រះដំកល់ទុកនូវបុព្វសិទ្ធិនោះ សំរាប់ព្រះអង្គទ្រង់។ សិទ្ធិសេរីភាពរបស់យើង អនុញ្ញាតឱ្យយើងធ្វើការជ្រើសរើសក្នុងចំណោមផ្លូវឆ្លាស់គ្នាជាច្រើន ប៉ុន្តែបន្ទាប់ មកយើងត្រូវបានចងជាប់ទៅនឹងផលវិបាកដែលព្រះបានកំណត់ទុកមកនោះ។ ក្រោយមកបើសិនជាយើងមិនចូលចិត្តផ្លូវ ដែលយើងរើសយកនោះទេ មានវិធីដោះស្រាយតែមួយគត់ គឺតាមរយះនៃការប្រែចិត្ត" (ក្នុង Conference Report ខែតុលា ឆ្នាំ 1992, 82–83 ឬ *Ensign,* ខែវិឆ្ឆិកា ឆ្នាំ 1992, 61)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សា ហេលេមិន 14។

ក្ឋ ធ្វើបញ្ជីអំពីទីសំគាល់ផ្សេងៗ

1. ចូរបង្កើតជាកូឡោនពីរ នៅក្នុងស្បៀវភៅសរសេររបស់អ្នក។ ចំណងជើងនៅក្នុងកូឡោនទីមួយគឺ "ទីសំគាល់ នៃការប្រសូត្រ របស់ព្រះគ្រីស្ត" ហើយកូឡោនមួយទៀត មានចំណងជើងថា "ទីសំគាល់ នៃការសុគតរបស់ព្រះគ្រីស្ត។" ចូរធ្វើសរសេរអំពីទី សំគាល់ ដែលសាំយូអែលឱ្យ

ទៅប្រជាជន នៅហេលេមិន 14:2–7, 20–28 ផងដែរ ចូរសរសេរខគម្ពីរ ដែលទីសំគាល់នីមួយៗ ត្រូវបានកត់ត្រាទុក។

2. យោងទៅតាម ហេលេមិន 14:8–13, 28–31 តើគោលបំណង នៃទីសំគាល់ ជាអ្វី?

ខ តើហេតុអ្វី ព្រះយេស៊ូវគ្រីស្ទត្រូវតែសុគត?

Det Nationalhistoriske Museum på Frederiksborg

ហេលេមិន 14:14 ចាប់ផ្តើមការព្យាករណ៍ របស់សាំយូអែលអំពីទីសំគាល់ នៃការសុគតរបស់ព្រះយេស៊ូគ្រីស្ទ។ មានផ្នែកមួយ នៃការព្យាករណ៍នេះ ដែលសាំយូអែលបានពន្យល់ថា ហេតុអ្វីបានជា គឺជាការចាំបាច់ដែលព្រះគ្រីស្ទត្រូវសុគត។ ចូរធ្វើការសង្កេប ពី ការបង្រៀនដ៏សំខាន់ទាំងនេះ ដោយការសរសេរពីមូលហេតុ ដែលសាំយូអែល ផ្តល់ឱ្យនៅហេលេមិន 14:15–19។

ឆ ឆ្លើយ ដោយប្រើព្រះគម្ពីរ

ឧបមាថា មានយុវជនម្នាក់ និយាយមកកាន់អ្នកថា "មនុស្សគ្រប់រូប ធ្វើឱ្យខ្ញុំឆ្អួតហើយ! ឪពុកម្តាយខ្ញុំ អ្នកដឹកនាំខ្ញុំ គ្រូបង្រៀនខ្ញុំ—មនុស្សគ្រប់រូប ចេះតែគ្រាប់ខ្ញុំឱ្យធ្វើនេះ ធ្វើនោះ។ តើហេតុអ្វីបានជាមានព្រះបញ្ញត្តិច្រើនយ៉ាងនេះ? តើហេតុអ្វី ពួកគេមិនទុកឱ្យ ខ្ញុំនៅតែឯង ហើយឱ្យខ្ញុំធ្វើការសំរេចដោយខ្លួនឯងទៅ?" ចូរប្រើហេលេមិន 14:29–31 និងការបង្រៀនរបស់អែលឌើរ ស្កុតមក ពីវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" ដើម្បីសរសេរជាការឆ្លើតតប ទៅនឹងសំនួររបស់យុវជនម្នាក់នោះ។ សូមឱ្យព្រាកដជា មាន បញ្ជាលនូវការពិភាក្សា នៃទំនាក់ទំនង រវាងសិទ្ធិសេរីភាពក្នុងការជ្រើសរើស ផលវិបាក និងព្រះបញ្ញាត្តិ នៃព្រះវរបិតាសួគ៌។

នៅក្នុងជំណើរឈ្វើង ស្ទើរតែទាំងអស់ នៃព្រះគម្ពីរមរមន បានបង្ហាញថាពួកសាសន៍នីហ្វៃ សប្បាយនឹងពរជ័យ នៃជំណឹងល្អ រួមមានទាំងការសប្បាយនឹងការមានឯកសិទ្ធិ ដើម្បីមានព្យាការី និងព្រះគម្ពីរ។ ព្រះអម្ចាស់មានបន្ទូលថា ឯអស់អ្នកណា ដែលគេប្រគល់ទុកជាច្រើនឱ្យ នោះគេនឹងទារជាច្រើនពីអ្នកនោះវិញ (សូមមើលលូកា 12:48, គ និង ស 82:3)។ ចូររកមើល ពីរបៀបបង្រៀនគោលការណ៍របស់សាំយូអែល ដែលមានទៅក្នុងហេលេមិន 15។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលេមិន 15

ត្រូវចោលស្វាត់ (ខ. 1)—ធ្វើឱ្យអន្តរាយ បំផ្លិចបំផ្លាញ ទទេ

បំបោកបញ្ឆោត (ខ. 2)—បំភ្លៅដោះកូនរបស់ពួកគេ

ទីកន្លែងសំរាប់ជ្រកពួន (ខ. 2, 12)—ទីជម្រកដែលមានសុវត្ថិភាព

បានផ្តាច់ផ្តាល (ខ. 3)—កែតំរូវដោយការធ្វើទណ្ឌកម្ម ឬការធ្វើទុក្ខទោស

ដោយប្រយ័ត្នប្រយែង (ខ. 5)—នៅក្នុងសេចក្តីសុចរិត

ក្រិត្យក្រមទាំងឡាយ (ខ. 5)—ច្បាប់

ចុះអន់ថយដោយការឥតជំនឿ (ខ. 11, 15)—បែរចេញបន្តិចម្តងៗពីសេចក្តីពិត

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សាហេលេមិន 15។

ក ពន្យល់អំពីគំនិត

1. យោងទៅតាម ហេលេមិន 15:3 និងគោលលទ្ធិ និងសេចក្តីសញ្ញា 95:1, 101:1–9 តើគោលបំណងនៃការផ្តាច់ផ្តាលរបស់ ព្រះអម្ចាស់ គឺជាអ្វី?

2. តើការផ្តាច់ផ្តាល បង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះយើងដូចម្តេចខ្លះ?

3. តើមានរបៀបណាខ្លះ ដែលថា ការផ្តាច់ផ្តាលដោយសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ មានភាពស្រដៀងគ្នា ទៅនឹងសេចក្តីស្រឡាញ់របស់ឪពុកម្តាយ នៅពេលពួកគាត់ផ្តាច់ផ្តាលកូនឮ?

4. សូមរំលឹកការព្រមានរបស់សាំយូអែល ដល់ពួកសាសន៍នីហ្វៃ នៅហេលេមិន 15:14–17 ហើយពន្យល់ពីរបៀប ដែលថាព្រះគម្ពីរនេះ មានភាពស្រដៀងគ្នាទៅនឹងការព្រមានរបស់ព្រះអម្ចាស់ ដែលមាននៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា 82:1–4។

ខ របៀបដើម្បីមានភាពរឹងមាំ និងខ្ជាប់ខ្ជួន

សាំយូអែល បង្ហាញឱ្យឃើញថា ពួកសាសន៍លេមិន ដែលផ្តាស់ប្រែគំនិត តាមរយៈការប្រកាសរបស់អាំម៉ូន និងបងប្អូនរបស់គាត់ ឱ្យនៅតែមានភាពស្មោះត្រង់ សូម្បីតែនៅពេល ដែលពួកសាសន៍នីហ្វៃ មិនមានការស្មោះត្រង់ក៏ដោយ (សូមមើល ហេលេមិន 15:1–6)។

1. ចូរស្រាវជ្រាវ ហេលេមិន 15:7–8 ហើយកត់សំគាល់អំពីអ្វី ដែលបានកើតឡើង ចំពោះពួកសាសន៍លេមិនទាំងនោះ ដែលធ្វើឱ្យ ពួកគេមាន "ភាពរឹងមាំ និងខ្ជាប់ខ្ជួននៅក្នុងជំនឿយ៉ាងខ្លាំង"។

2. ចូរគូរដាតារាងដូចខាងក្រោម នៅក្នុងស្បៀវភៅសរសេររបស់អ្នក ហើយបំពេញនូវចំណុចខ្លះខាត មកពីអ្វីដែលអ្នកបានរៀននៅ ក្នុងខ 7–8។



3. តើមានផ្នែកអ្វីខ្លះ នៃដំណើរការណ៍នេះ ដែលអ្នកមានអារម្មណ៍ថា អ្នកត្រូវការពង្រីក សេចក្តីជំនឿរបស់អ្នកចំពោះ ព្រះយេស៊ូវគ្រីស្ត?

ហេលមិន 16

ប្រតិកម្ម ចំពោះការប្រកាសរបស់ សាំយូអែល



នៅក្នុងកំឡុងពេលដែលហេលមិន 13–15 ជាបញ្ហីមួយ នៃការព្យាករណ៍ របស់សាំយូអែល ក្នុងចំណោមពួកសាសន៍នីហ្វៃ ពេលនោះហេលមិន 16 មានចុះបញ្ហីពីរប្រៀបផ្សេងគ្នា ដែលប្រជាជនឆ្លើយតប ចំពោះការព្យាករណ៍ របស់គាត់។ សារលិខិតដំណឹងល្អ អាចផកចេញនូវប្រតិកម្មផ្សេងពីគ្នាជាច្រើន។ ប្រធាន ស្តែនស៊ើរ ផបុលយូ យិមបឹល មានប្រសាសន៍ថា ការថ្វាយបង្គំ "គឺជាការទទួលខុសត្រូវរបស់បុគ្គលម្នាក់ព្ធ ហើយថ្វីបើវា បាននិយាយមកពីកន្លែងវេទិការ ហើយបើសិនជាមាន សមាជិក ម្នាក់ចង់ថ្វាយបង្គំ ចំពោះ ព្រះអម្ចាស់ នៅក្នុងវិញ្ញាណ និងសេចក្តីពិត គាត់អាចធ្វើដូច្នោះបាន ដោយ ការចូលរួម នៅក្នុងការប្រជុំទាំងឡាយរបស់គាត់ ការទទួលទានប្រសិទ្ធិពរ នំបុ័ង និងទឹក និងការនឹកគិតត្រិះរិះពីភាពដ៏អស្ចារ្យនៃដំណឹងល្អ។ បើសិនជា ការបំរើនៅ [ព្រះវិហារ]គឺជាការខុសឆ្គងចំពោះអ្នក នោះអ្នកក៏មាន ការខុសឆ្គងផងដែរ។ គ្មានទរណាម្នាក់ អាចថ្វាយបង្គំ ជំនួសអ្នកបានទេ អ្នកត្រូវតែធ្វើការរង់ចាំ ដោយខ្លួនអ្នកផ្ទាល់ ចំពោះព្រះអម្ចាស់" ("The Sabbath—A Delight" Ensign ខែមករា ឆ្នាំ1978, 5)។ នៅពេល អ្នកអាន ពីរប្រៀបដែលប្រជាជន ធ្វើការឆ្លើយតបចំពោះលោកសាំយូអែល ចូរពិចារណាអំពីរ ប្រៀបដែលអ្នកអាចនឹងធ្វើការឆ្លើយតបចំពោះសារលិខិត។ ហើយចូរគត់សំគាល់ផងដែរ ពីរប្រៀបដែលអារម្មណ៍មានការផ្លាស់ប្តូរ នៅពេលដែលពេលវេលាជាច្រើន បានកន្លងហួសទៅពីពេលដែលសាំយូអែស ធ្វើការព្យាករណ៍។

ការយល់ដឹងអំពីព្រះគម្ពីរ

ហេលមិន 16

ដើរយ៉ាងត្រង់តទៅចំពោះ (ខ. 10)—ត្រង់ទៅមុខ នៅក្នុងសេចក្តីសុចរិត

ការប្រែប្រួល (ខ. 12)—ការផ្លាស់ប្តូរ

ការឆ្លាតវៃ (ខ. 21)—ឆ្លាត ដោយ ការឆ្លាតវៃ

ឥតប្រយោជន៍ (ខ. 22)—មិនប្រើការ បាន ឆ្ពួតលីលា

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សា ហេលមិន 16។

ក ប្រៀបធៀបពីការបែកបាក់នៅក្នុងចំណោមប្រជាជន

1. ចូរសរសេរ ដូចខាងក្រោមនៅក្នុងស្រៀវភៅសរសេររបស់អ្នកៈ"ជាច្រើន" (ហេលមិន 16:1) "ជនទាំងឡាយណា" (ខ. 2) "ជាច្រើនទៀត" (ខ. 3) "ជនទាំងឡាយណា" (ខ. 5) "ជាភាគច្រើន" (ខ. 6) "មនុស្សភាគច្រើន" (ខ. 10) "មនុស្សភាគតិច" (ខ. 10) "ប្រជារាស្ត្រ" (ខ. 12) "មនុស្ស និងអ្នកប្រាជ្ញទាំងឡាយ" (ខ. 14) "ប្រជាជន" (ខ. 15–22) "ប្រជាជនរបស់ ព្រះអម្ចាស់" (ខ. 23)។ បន្ទាប់ពីការសរសេររួចហើយ ចូរសរសេរតាមគំនិត របស់អ្នក ពីរប្រៀបដែលក្រុមនៃប្រជាជន ជាក់លាក់នោះ បានធ្វើការឆ្លើយតបចំពោះសារលិខិត របស់សាំយូអែល ការបង្រៀនរបស់នីហ្វៃ ឬទីសំគាល់ និងការង្រៀងឆ្ងល់ ដែលពួកគេមាន ក្នុងរយៈពេលប្រាំឆ្នាំ ពីមុនពេលការប្រសូត្ររបស់ព្រះយេស៊ូគ្រីស្ត។
2. ចូរពិចារណា អំពីអ្វីដែលវាត្រូវតែកើតមានជាយ៉ាងណានោះ ដើម្បីក្លាយជាអ្នកដើរតាមដ៏ស្មោះត្រង់ ចំពោះព្រះយេស៊ូវគ្រីស្ត នៅក្នុងសម័យកាលនៃហេលមិន 16។ ចូរសរសេរ នូវអ្វី ដែលអ្នកអាចធ្វើនៅបច្ចុប្បន្ននេះ នៅក្នុងការរៀបចំខ្លួនអ្នក សំរាប់ការយាងមក ជាលើកទីពីរ របស់ទ្រង់ ហើយហេតុអ្វី បានជាវាសំខាន់។

នីហ្គែទីបីៈ គម្ពីរនីហ្គែ

អំពីគម្ពីរនីហ្គែទី3

រហូតដល់ឆ្នាំ 1879 មានការចោះពាក្យព្រះគម្ពីរមរមន ហើយព្រះគម្ពីរមួយនេះ ត្រូវបានដាក់ចំណងជើងដោយងាយថា "ព្រះគម្ពីរនីហ្គែ កូនប្រុសរបស់លីហៃ ដែលជាកូនប្រុសរបស់ហេលេមិន។" អែលឌើរ អើរសាន់ ក្រាត ដែលជាសមាជិក នៃក្រុមសាវកដប់ពីរនាក់ បានផ្តល់អនុសាសន៍បន្ថែម ចំពោះដើមរឿងនេះ ដោយថាជា "នីហ្គែទី 3" ហើយដែលត្រូវបានអនុម័តដោយគណៈប្រធានទីមួយ។

លោកមរមន ប្រមូលផ្តុំព្រះគម្ពីរនីហ្គែទី3 មកពីបញ្ជីរបស់ព្យាការីម្នាក់ឈ្មោះ នីហ្គែ ដែលជាប់ខ្សែលោហិតមកពី ត្រួសារអាលម៉ា ដែលជាអ្នកមើលថែរក្សាបញ្ជី (សូមមើលតាមតារាង)

អ្នកថែរក្សាបញ្ជី

- អាលម៉ាជាឪពុក
- អាលម៉ាជាកូន
- ហេលេមិន
- ហេលេមិន ជាកូនប្រុសរបស់ហេលេមិន
- នីហ្គែ
- នីហ្គែ ជាកូនប្រុសរបស់នីហ្គែ

ព្រះគម្ពីរនេះ ចាប់ផ្តើមនៅក្នុងពេល នៃការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ។ ក្នុងដំពូកពីរបីដំបូង បានគ្រាប់អំពីអ្វី ដែលកើត មានក្នុងចំណោមពួកសាសន៍នីហ្គែ និងពួកសាសន៍លេមិន កំឡុងពេលនៃជីវិតមគតាពរបស់ព្រះយេស៊ូវគ្រីស្ទ។ ផ្នែកសំខាន់ បំផុតរបស់ នីហ្គែទី3 មានចុះអំពីព្រះបន្ទូល និងសកម្មភាពផ្តាល់របស់ព្រះអង្គសង្គ្រោះ ក្នុងកំឡុងពេល នៃការយាងមក ធ្វើទស្សនកិច្ចរបស់ទ្រង់ជាមួយនីហ្គែប្រជាជន នៅក្នុងព្រះគម្ពីរមរមន បន្ទាប់ពីការឆ្កាង និងដំណើររស់ឡើងវិញរបស់ទ្រង់។

តើអ្នកធ្លាប់ត្រូវបានគេចំអក ដោយសារជំនឿរបស់អ្នកឬទេ? ចូរពិចារណាថា តើមនុស្សម្នាក់ត្រូវការមានជំនឿខ្លាំងប៉ុណ្ណា ដើម្បី ឱ្យនៅតែស្ថិតក្នុងសេចក្តីពិត ហើយស្មោះត្រង់ សូម្បីតែត្រូវចាប់ដាក់គុក ឬកាត់ទោសដល់ស្លាប់ក៏ដោយ។ ការផ្សើ ទៅលើ បទពិសោធន៍របស់សាសន៍នីហ្គែ និងសាសន៍លេមិនទោះ វាជាការលំបាកណាស់ ព្រោះពេលវេលាកាន់តែខិតមកជិតដល់ ដើម្បីឱ្យ បានសំរេចតាមការព្យាករណ៍ របស់សាំយ៉ូអែល អំពីការយាងមករបស់ ព្រះយេស៊ូវគ្រីស្ទ។ នៅពេលអ្នកអាននីហ្គែទី3 1 ចូរព្យាយាមទឹកគិតពីអ្វី ដែលអ្នកគ្មានជំនឿ អាចនឹងនិយាយទៅកាន់អ្នកមានជំនឿ ហើយតើវានឹង ពិបាកប៉ុណ្ណាដើម្បីឱ្យពួកគេ នៅតែមានភាពស្មោះត្រង់ដដែលនៅក្នុងរយៈ ពេលនោះ។ យើងភាគច្រើនធ្លាប់ឮរឿងមួយអំពី ការប្រសូត្ររបស់ព្រះអង្គ សង្គ្រោះ នៅបេថ្លេហិម ប៉ុន្តែព្រឹត្តការណ៍ដែលបានកើតឡើងក្នុងចំណោម ប្រជាជននៃព្រះគម្ពីរមរមន នៅវេលានៃការប្រសូត្ររបស់ព្រះ គ្រីស្ទនោះ គឺជាការសំខាន់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 1

ដោយបានប្រគល់បន្ទុកឱ្យ (ខ. 2)—ការទទួលខុសត្រូវ

ជំនួស (ខ. 3)—ជំណែង

អស្ចារ្យឡើង (ខ. 4)—ធ្ងន់ឡើង

ឥតប្រយោជន៍ (ខ. 6, 8)—មិនប្រើការបាន ឆ្កួតលីលា

ចលាចល (ខ. 7)—មានការរំខាន

ទាំងការតូចតាចក្តី (ខ. 20, 25)—ទាំងផ្នែកតូចៗ

ខំបញ្ជាក់តាម (ខ. 24)—ការខំប្រឹងប្រែង

ជាការចាំបាច់ (ខ. 24)—ចាំបាច់

ទោះជាពាំងឈើមួយ ឬត្បៀសមួយ (ខ. 25)—ផ្នែកតូចជាងគេ

បានរាតត្បាត (ខ. 27)—បន្ទាយ

មនុស្សដែលបែកចេញ (ខ. 28)—មនុស្ស ដែលឈប់ជឿ ហើយចូលរួមជាមួយសត្រូវ

មានគំនិតផ្តាល់ខ្លួន (ខ. 29)—អាត្មានិយម ការឈ្លោះប្រកែក

ជំនាន់ ដែលកំពុងកើនឡើង (ខ. 30)—យុវវ័យ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា នីហ្វៃទី3 1។

ក បង្កើតជាកំណត់ហេតុមួយ

1. ចូរសរសេរនូវអ្វី ដែលអ្នកគិតអំពីមនុស្សម្នាក់ កំពុងរស់នៅក្នុងពេលនោះ ប្រហែលជាគាត់អាចសរសេរពីកំណត់ហេតុរបស់ពួកគេ បន្ទាប់ពីព្រឹត្តការណ៍ទាំងនេះ នៅនីហ្វៃទី 3 1:1–21។ ចូរពិចារណាអំពីស្ថានភាព—ក្តីសង្ឃឹម ភាពភ័យខ្លាច និងប្រតិកម្មដែល មនុស្សម្នាក់នេះអាចនឹងកើតមានឡើង។
2. ចូរពន្យល់នូវអ្វី ដែលយើងអាចរៀនអំពី ព្រះអម្ចាស់ និងព្យាការីរបស់ទ្រង់ មកពីបទពិសោធន៍មួយរយៈនោះ។

ខ ការផ្លាស់ប្រែចិត្ត

1. ចូរធ្វើជាបញ្ជី យ៉ាងតិច ពីមនុស្សចំនួនបួនក្រុមផ្សេងគ្នា ដោយយោងទៅលើនីហ្វៃទី3 1:22–30 ហើយពណ៌នាថាតើទិ សំគាល់ផ្សេងៗ នៃការប្រសូត្ររបស់ព្រះគ្រីស្ទ មានឥទ្ធិពលចំពោះទីបន្ទាល់ និងការផ្លាស់ប្រែគំនិត របស់ក្រុមទីមួយៗដោយរយៈ ណាដែរ។
2. តើការណ៍នេះបង្ហាញអ្នកអ្វីខ្លះ អំពីសារៈសំខាន់នៃទីបន្ទាល់ នៅក្នុងការផ្លាស់ប្រែចិត្ត?

"ប្រជាជនភាគច្រើន" បានធ្វើការផ្លាស់ប្រែចិត្ត នៅពេលមានទីសំគាល់នៃការប្រសូត្ររបស់ព្រះគ្រីស្ទ (សូមមើល នីហ្វៃទី3 1:22)។ ទោះជាយ៉ាងណាក៏ដោយទីសំគាល់ មិនអាចធ្វើការផ្លាស់ប្រែគំនិតរបស់ប្រជាជនបានឡើយ ប៉ុន្តែទីសំគាល់ទាំងនោះ ផ្តល់ជាកម្លាំង និងការបញ្ជាក់សេចក្តីពិត ចំពោះអ្នកទាំងឡាយណា ដែលមានការផ្លាស់ប្រែគំនិតរួចហើយ។ នីហ្វៃទី3 2 មានចុះបញ្ជីនូវអ្វី ដែល បានកើតឡើង នៅពេលប្រជាជន មានការផ្លាស់ប្រែគំនិត មកពីងផ្នែកទៅលើទីសំគាល់ ហើយបានភ្លេចអំពី ការណ៍អស្ចារ្យ និងព្រឹត្តការណ៍ទាំងឡាយ ដែលពួកគេឈរធ្វើជាសាក្សីនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 2

រាប់ (ខ. 8)—រាប់ចំនួន គណនា

គ្មានមនុស្សរស់នៅ (ខ. 11)—បំផ្លិចបំផ្លាញ

ការកាប់សម្លាប់ (ខ. 11)—ការបំផ្លិចបំផ្លាញ ការបង្ហូរឈាម

ត្រូវបង្ខំចិត្ត (ខ. 12)—ត្រូវបានបង្ខំ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា នីហ្វៃទី3 2។

ក ពោះដំហានចុះក្រោម

ទោះបីជាមានការផ្លាស់ប្តូរ នៅក្នុងអាកប្បកិរិយារបស់ប្រជាជន ដែលអ្នកបានអាន នៅនីហ្វៃទី3 2:3 ហាក់ដូចជាបានកើតឡើង យ៉ាងឆាប់រហ័សក៏ដោយ ការណ៍នេះមិនបានកើតឡើងក្នុងពេលតែម្តងនោះទេ។

1. ចូរបង្កើតឱយ៉ាក្រាមមួយ ដែលតំណាងឱ្យការពោះដំហានបន្តិចម្តងៗ របស់ប្រជាជនខ្លះ ដែលនាំពួកគេមកពី "ការផ្តាច់ ចាបធ៏មហិមា" នៅនីហ្វៃទី3 1:23 ទៅរក "អំពើទុច្ចរិតដ៏ធំ" នៅនីហ្វៃទី3 2:3។ ចូរធ្វើផ្លាកឈ្មោះ នៃការពោះដំហានទីមួយៗ ដោយដកស្រង់កថាខ័ណ្ឌ មកពីនីហ្វៃទី3 1:27–2:3។
2. ចូរធ្វើឱយ៉ាក្រាមមួយទៀត ដែលតំណាងឱ្យដំណើរឈានឡើងឆ្ពោះទៅរកជីវភាពខាងវិញ្ញាណកាន់តែអស្ចារ្យ។ ចូរកត់សំគាល់ នូវអ្វី ដែលអ្នកអាចធ្វើ ដើម្បីនៅតែមានការស្មោះត្រង់ចំពោះដំណឹងល្អ ហើយអ្វីដែលអ្នកអាចបង្កើនជំនឿ និងទីបន្ទាល់របស់អ្នក ចំពោះព្រះយេស៊ូវគ្រីស្ទ។

ខ គោលការណ៍ការពារ

1. តើពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនបានធ្វើអ្វីខ្លះ ដើម្បីការពារខ្លួនពួកគេ និង "បានយកប្រៀប" លើពួកចោរ កាឌីអានតុន? (សូមមើលនីហ្វៃទី 3 2:11–12, 17)។
2. តើអ្វីខ្លះ ដែលធ្វើឱ្យពួកចោរកាឌីអានតុន "យកប្រៀបលើពួកគេបាន"? (សូមមើលខ. 18)។
3. តើអ្នកគិតថា សារលិខិត នៃខប្បត្តិហេតុទាំងនេះ អាចមានចំពោះសមាជិករបស់សាសនាចក្រថ្ងៃដែរឬទេ?

តើអ្នកធ្លាប់មានការភិតភ័យ ដោយសារតែឥទ្ធិពលអាក្រក់នៅក្នុងលោកីយ៍នេះ ឬទេ? ព្រះគម្ពីរ បង្រៀនយើងថា "ត្យិតព្រះ ទ្រង់ មិនបានប្រទានឱ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាចសេចក្តីស្រឡាញ់ និងប្រាជ្ញានឹងធឹង វិញ" (ធីម៉ូថេ ទី2 1:7) និងប្រសិនជាអ្នករាល់គ្នាបានប្រុងប្រៀបទុកជាស្រេច នោះអ្នករាល់គ្នានឹងមិនត្រូវខ្លាចឡើយ (ត និង ស 38:30)។ នៅនីហ្ចៃទី3 3:3–4 ពួកចោរកាឌីអានគុន បានព្យាយាមយកឈ្នះលើភាពខ្លាច នៅក្នុងដួងចិត្តអ្នកស្មោះត្រង់។ នៅពេលអ្នកសិក្សាជំពូកទាំងនេះ ចូរកត់ចំណាំពីរប្រៀប ដែលពួកសាសន៍នីហ្ចៃ និងពួកសាសន៍ លេមិន ធ្វើការឆ្លើយតបទៅ នឹងអំពើអាក្រក់ ដោយជំនឿជំនួសឱ្យភាពភ័យខ្លាច។



គីឌឌីអានហៃ

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្ចៃទី3 3

ភាពរឹងប៉ឹង (ខ. 2, 5)—ការតាំងចិត្ត ដ៏មុតមាំ ភាពខ្នាប់ខ្ជួន

កាន់អាវុធ (ខ. 3)—ជាមួយនឹងសាស្ត្រាវុធរបស់ពួកគេ

ដោយយល់ដល់សុខុមាលភាពរបស់លោក (ខ. 5)—បារម្ភអំពីអ្នក

ក្រោយ (ខ. 8)—បន្ទាប់

វិនាសសូន្យ (ខ. 8)—ត្រូវបំផ្លិចបំផ្លាញ

បានបែកចេញ, បែកចេញ (ខ. 10–11)—បះបោរ ការបះបោរ

សេចក្តីប្រកាស (ខ. 13, 22)—សារលិខិត ការប្រកាសដំណឹង

ពួកគេបានខិតខំយ៉ាងខ្លាំង (ខ. 16)—ធ្វើឱ្យមានការខំប្រឹងយ៉ាងខ្លាំង

នីហ្ចៃទី3 4

រាលចេញ (ខ. 1)—ប្រញាប់

សត្ត (ខ. 2, 20)—សត្តធ្វើជាអាហារ

ប្លន់ (ខ. 4–5)—លួច យកដោយប្រើការបង្ខំ

ស្បៀងអាហារ (ខ. 4, 18–19)—សម្ភារះ

អាចរស់នៅ (ខ. 4–5)—នៅរស់

បានស្លៀកពាក់តាម (ខ. 7)—ស្លៀកពាក់

ការក្សាល (ខ. 7)—ការសក់

បានសូម (ខ. 10)—សូមជាមួយ

បានចាប់ផ្តើមឡើង (ខ. 11)—ចាប់ផ្តើម

ឡោមព័ទ្ធជុំវិញ (ខ. 16–18, 23)—នៅជុំវិញ ហើយវាយប្រហារ

ការខ្វះខាត (ខ. 19)—ខ្វះ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សានីហ្ចៃទី3 3–4។

ក ការយល់ដឹង ហើយយកឈ្នះលើឥទ្ធិពលអំពើអាក្រក់នានា

1. ចូរធ្វើបញ្ជីតារាង នូវអ្វីដែលគាឌឌីអានហៃ និងសេណារៃហា បានធ្វើ និងនិយាយ នៅនីហ្ចៃទី3 3:1–10, 4:7, 16–23 ដែលរំលឹកដល់អ្នក អំពីវិធីសាស្ត្រ និងសេចក្តីល្បួងរបស់សាតាំង។
2. តើអ្នកអាចអនុវត្តជំបូន្មានរបស់ ឡាកូនីអូស និងគីឌគីឌដូណៃ ដែលមានទៅនីហ្ចៃទី3 3:11–22, 24–26, 4:8–10, 15, 18, 33 ដើម្បីយកឈ្នះលើការវាយប្រហាររបស់សាតាំង ក្នុងពេលបច្ចុប្បន្ននេះ បានយ៉ាងដូចម្តេច?

ខ សំលៀកបំពាក់ ដែលធ្វើឱ្យចាប់អារម្មណ៍

1. ចូរពិពណិនាអំពី រប្រៀបដែលពួកចោរកាឌីអានគុនស្លៀកពាក់ (សូមមើល នីហ្ចៃទី3 4:7–8) ហើយពន្យល់ថា ហេតុអ្វីក៏អ្នក គិតថា ពួកគេស្លៀកពាក់រប្រៀបនេះ។ តើសំលៀកបំពាក់រប្រៀបនេះ បានផ្តល់ជាផលប្រយោជន៍ឬទេ?
2. ចូរពិពណិនាពីស្ថានភាពមួយ នៅក្នុងជីវិតរបស់អ្នក នៅពេលអ្នកពិតជាចង់ធ្វើឱ្យមានការចាប់អារម្មណ៍ តាមរប្រៀប ដែលអ្នក ស្លៀកពាក់។
3. ចូរធ្វើការសង្ខេបនូវជំបូន្មាន ដែលបានផ្តល់ឱ្យ ដោយអ្នកដឹកនាំនៅក្នុងសាសនាច្រក ទៅលើ "សំលៀកបំពាក់ និងអាការះខាង ក្រៅ" ដូចដែលបានផ្តល់ឱ្យនៅក្នុងកូនស្បៀវភៅ*ដើម្បីគុណភាពនៃយុវជនយុវនារី*។

នីហ្ចៃទី3 5

ការពន្យល់ និងទីបន្ទាល់មកពីលោកមរមន

នៅនីហ្ចៃទី3 4 អ្នកនឹងអានអំពីរប្រៀបគំរាមគំហែង របស់ពួកចោរកាឌីអានគុន ដែលបានធ្វើឱ្យពួកសាសន៍នីហ្ចៃ និងពួកសាសន៍ លេមិន កែប្រែចិត្ត។ នៅ

នីហ្វៃទី3 5 អ្នកនឹងអានអំពីពរជ័យ ដែលពួកសាសន៍ទាំងពីរបានទទួល ដោយសារតែ ការប្រែចិត្តរបស់ពួក គេ។ តាំងពីពេលដែលអ្នកបានអាន នៅក្នុងព្រះគម្ពីរមរមនមកនោះ តើអ្នកគិតថា រយះពេលនៃសន្តិភាព និង ការចំរុងចំរើន ស្ថិត នៅបានយូរអង្វែងប៉ុណ្ណា? លោកមរមន បានណែនាំខ្លួន គាត់ផងដែរ នៅក្នុងជំពូកនេះ ហើយលោកបានពន្យល់ថា ហេតុអ្វីបានជា លោកថែរក្សា ហើយសង្ខេបបញ្ជីទាំងឡាយនោះ ដែលឥឡូវយើងហៅថា ព្រះគម្ពីរមរមន។ ចូរកត់ចំណាំថា នៅថ្ងៃចុងក្រោយ ដំណឹងល្អនឹងប្រគល់ ទៅដល់មនុស្សគ្រប់ូរប ហើយថា វង្សអ៊ីស្រាអែលនឹងត្រូវបានប្រមូលផ្តុំឡើងវិញ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 5

បានលះបង់ (ខ. 3)—ឈប់

អំពើសាហាយស្មន់ទាំងឡាយ (ខ. 3)—អំពើអសីលធម៌ខាងផ្លូវភេទ

បានកើតឡើង (ខ. 8)—កើតឡើងជួបប្រទះ

ដំណើរការទាំងអស់ (ខ. 9)—ប្រវត្តិព្រឹត្តការណ៍

បានចាកលោកទៅ (ខ. 14)—ស្លាប់

ការចាប់ផ្តើម (ខ. 16)—ការផ្តើម

សំណល់ (ខ. 23–24)—ផ្នែកដែលនៅសល់

ត្រូវខ្ទាត់ព្រាត់ចេញទៅ (ខ. 26)—ខ្ទាត់ខ្ទាយ

នីហ្វៃទី3 5:13—លោកមរមន ជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ

អែលឌើរ ស្សូឌើរ អែម ប៊ើរធិន ដែលជាសមាជិកនៃក្រុមចិតសិបនាក់ បង្រៀនថា "ក្នុងភាសាអង់គ្លេស យ៉ាងហោចណាស់ ក៏ពាក្យ *វិន័យ* មានន្ទូវឬសគល់ដូចគ្នាទៅនឹងពាក្យ*សិស្ស*ផងដែរ" (នៅ Conference Report ខែតុលា ឆ្នាំ 1985, 81 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1985, 65)។ យើងក៏អាចនិយាយបានថា សិស្សគឺជាមនុស្សមានវិន័យម្នាក់ ដែលមានការព្រមទទួលរៀន ហើយរស់ នៅដោយយោងទៅតាមគោលលទ្ធិ ហើយរស់នៅតាមរបៀបមួយនៃជីវិត (សូមមើល យ៉ូហាន 3:25)។ លោកមរមន គឺជាអ្នក ដើរតាមព្រះយេស៊ូគ្រីស្ទ ហើយគាត់រស់នៅ ស្របទៅតាមការបង្រៀនរបស់ទ្រង់។

នីហ្វៃទី3 5:21–26—វង្សយ៉ាកុប និងពូជរបស់យ៉ូសែប

នៅនីហ្វៃទី3 5:21–26 លោកមរមនរំលឹកដដែលពាពីប្រធានបទនៃព្រះគម្ពីរមរមន—ការប្រមូលផ្តុំនៃ វង្សយ៉ាកុប ឬវង្សអ៊ីស្រាអែល។" សំណល់នៃពូជរបស់យ៉ូសែប" សំដៅទៅលើកូនចៅរបស់ លីហៃ ដែលរស់នៅសព្វថ្ងៃនេះ។ ការព្យាករណ៍ អំពីកូនចៅរបស់លីហៃគឺ ឥឡូវត្រូវបានសំរេចនៅ ក្នុងមាគាឹ ដែលមិនគួរឱ្យនឹកស្មានដល់។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សានីហ្វៃទី3 5។

ក ជួបជាមួយនឹងអ្នកនិពន្ធ

1. ចូររំលឹក នីហ្វៃទី3 5:8–20 សារឡើងវិញ ហើយធ្វើបញ្ជី យ៉ាងហោចណាស់ ឱ្យបានប្រាំចំណុចពីអ្វីដែលអ្នកបានរៀនពីះ

   ក. លោកមរមន។

   ខ. ការសង្ខេបបញ្ជីរបស់លោកមរមន ដើម្បីព្រះគម្ពីរមរមន។

2. តើចំណេះដឹងនេះ បង្កើនន្ទូវការយល់ដឹងដល់អ្នក និងសេចក្តីអំណរគុណអ្វីខ្លះ ដែលអ្នកមានចំពោះព្រះគម្ពីរមរមន?

នីហ្វៃទី3 6
ពីសុចរិតទៅ
"ទុច្ចរិតដ៏គួរស្មែងខ្លាច"

ចូរគិតអំពីនរណាម្នាក់ ដែលមានអាយុស្មើនឹងអ្នក ដែលជាមនុស្សសុចរិត ហើយមានទីបន្ទាល់យ៉ាងរឹងមាំ។ ចូរនឹកគិតថា រយះពេលបួនឆ្នាំ ពីឥឡូវនេះទៅ អ្នកជួបមនុស្សម្នាក់នេះម្តងទៀត ហើយគាត់មានជាប់ទាក់ទងនៅ ក្នុងអំពើទុច្ចរិតគ្រប់ប្រភេទ ទាំងអស់។ តើមានរឿងអ្វីខ្លះ អាចត្រូវបានកើតឡើងនៅក្នុងរយះពេលបួនឆ្នាំ? តើការណ៍នេះ អាចកើតឡើងយ៉ាងឆាប់រហ័ស បានយ៉ាងដូចម្តេចទៅ នៅពេលមនុស្សម្នាក់នោះ ធ្លាប់មានទីបន្ទាល់យ៉ាងរឹងមាំនោះ?ការណ៍នេះ មានលក្ខណៈស្រដៀង គ្នាទៅនឹងរឿងនៅ នីហ្វៃទី3 6។ នៅជំពូកនេះ ចាប់ផ្តើមនៅឆ្នាំម្តៃប្រាំមួយ បន្ទាប់ពីការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ ហើយ បញ្ចប់នៅឆ្នាំទីសាមសិប។ នៅពេលអ្នកអានពីអ្វីដែលបានកើតឡើង ចំពោះពួកសាសន៍នីហ្វៃ នៅក្នុងពេលដ៏ខ្លីមួយ ចូរយកចិត្តទុកដាក់ទៅលើមូលហេតុផ្សេងព្យ ដែលលោកមរមន បានផ្តល់អំពីការធ្លាក់ចុះយ៉ាងឆាប់រហ័យរបស់ពួកគេនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 6

បានបរិភោគ (ខ. 2)—ញាុំ

ដើម្បីពួកគេអាចមានទីកន្លែងសំរាប់ចិញ្ចឹមជីវិត (ខ. 3)—គ្រប់គ្រាន់ដើម្បីរស់

រារាំង (ខ. 5)—បញ្ឈប់ ការពារ

មានការទាស់ទែងគ្នា(ខ. 10)—ឈ្លោះប្រកែក ការទាស់ទែង

ញែកចេញ (ខ. 12)—បែកចេញពីគ្នាបានដឹង

ល្ងិតល្ងង់ (ខ. 12)—មិនរៀន គ្មានការអប់រំ

បណ្តុះបង្អាប់ តបត (ខ. 13)—ជេរប្រមាថ បរិហារ

សារភាព (ខ. 13)—កែប្រែចិត្ត

ផ្ទុយ (ខ. 24)—ប្រឆាំង

ញាតិសន្តាន (ខ. 27)—សមាជិកគ្រួសារ

រឹងទទឹង (ខ. 30)—មិនគោរព បង្កហេតុ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សា នីហ្វៃទី3 6។

ក បង្កើតជាផែនទីផ្លូវមួយ

1. នៅក្នុងសៀវភៅសរសេររបស់អ្នក ចូរគូរផែនទីផ្លូវមួយ ដែលចាប់ផ្តើមនៅក្នុង "ស្ថានភាពនៃសេចក្តីសុចរិត" ហើយបញ្ចប់នៅ គ្រង់ "ស្ថានភាពទុច្ចរិតមួយដ៏គួរស្មែងខ្លាច។" ចូរសិក្សានីហ្វៃទី3 6:9–18 ដោយប្រយ័ត្នប្រយែង ហើយចុចចំណុចនៅលើផែនទី ដែលតំណាងឱ្យ "ទីកន្លែង" ដែលប្រជាជន ទៅតាមផ្លូវ ចុះទៅរកស្ថានភាពទុច្ចរិតមួយដ៏គួរឱ្យស្មែងខ្លាច។ ចូរដាក់ឈ្មោះចំណុច នីមួយព្យ ដែលពិពណិនាន្ទូវអ្វី ពួកសាសន៍នីហ្វៃបានធ្វើ ដើម្បីបង្ហាញពី

ការផ្លាស់ប្តូររបស់ពួកគេ ចេញពីសេចក្តីសុចរិត ហើយ កត់ចំណាំខគម្ពីរ ដែលអ្នកបានរកឃើញ នោះផង។

2. ចូរបន្ថែមផ្លូវមួយទៀត នៅលើផែនទីរបស់អ្នក ដែលនាំទៅរកជីវិតអស់កល្បជានិច្ច។ ពេលនៅលើផ្លូវផ្សេងទៀត ធ្វើជាស្លាក នៃចំណុច ដើម្បីជាតំណាងឱ្យអ្វី ដែលប្រជាជនមួយចំនួនបានធ្វើ នៅនីហ្ភៃទី3 6 ដើម្បីឱ្យស្ថិតនៅក្នុងសេចក្តីសុចរិត ទោះបីនៅពេល មានមនុស្សដទៃទៀត ស្ទើរតែទាំងអស់ កំពុងតែធ្វើដំណើរឆ្ពោះទៅរកសេចក្តីទុច្ចរិតក៏ដោយ។

២ ផលវិបាកដ៏ធ្ងន់ធ្ងរ

1. តាមពាក្យសំដីរបស់អ្នក ចូរសង្ខេបនូវអ្វី ដែលលោកមរមន បានកត់ចំណាំ ជាពិសេសពីកំហុស នៃសេចក្តីទុច្ចរិត របស់ប្រជាជន នៅនីហ្ភៃទី3 6:17–18។

2. តើម៉ូសាយ 2 :36–39 និយាយប្រាប់អ្វីខ្លះ ដែលវាជាផលវិបាកខ្លះៗចំពោះអាកប្បកិរិយា និងឥរិយាដូច្នេះ?

តើហេតុអ្វីក៏មានពេលខ្លះ វាពិបាក ចំពោះអ្នកមានទ្រព្យ ដើម្បីឱ្យពួកគេ នៅតែមានភាពស្មោះត្រង់ ក្នុងពេល ដែលជីវិត របស់ពួកគេ មាន ការចំរុងចំរើន? បន្ទាប់ពីពួកសាសន៍នីហ្ភៃ និងសាសន៍លេមិន យកបានសេរីភាព របស់ពួកគេ នៅក្នុងសង្គ្រាមដ៏ធំ ជាមួយនឹងពួកចោរកាឌីអានតុន ត្មានអ្វីក្រៅពីអំពើបាបរបស់ពួកគេ ដែល រារាំងពួកគេពីការចំរុងចំរើនបន្តទៅទៀត (សូមមើល នីហ្ភៃទី 3 6:4–5)។ មានអ្នកខ្លះ ចង់មានបាន ជាជាងមានសេរីភាពពីសង្គ្រាម ហើយចេះតែចង់បាន។ ពួកគេ ចង់បានសេរីភាព ពីច្បាប់ របស់មនុស្ស និងពីព្រះបញ្ញត្តិរបស់ព្រះ។ អែលឌើរ នែល អេ. ម៉ាក់ស្វែលជា សមាជិកក្រុមសាវកទាំងដប់ពីរនាក់ បង្រៀនថាៈ "យើងមានសេរីភាពក្នុង ការគោរព ឬមិនគោរពព្រះបញ្ញត្តិ របស់ព្រះ ប៉ុន្តែយើងមិនមានសេរីភាព ដើម្បីផ្លាស់ប្តូរ មាតិកានៃព្រះបញ្ញត្តិ ទាំងនោះឡើយ។ សូម្បីតែ យើងក៏មិនអាចច្យេសវាងនូវផលវិបាក នៃការមិនគោរពព្រះបញ្ញត្តិទាំងឡាយ នោះបានផងដែរ។ ជាញឹកញាប់ ការជ្រើសរើស គួរតែរួមបញ្ចូលនូវផលវិបាក ដែលមកពីចំណង់ដែលយើងចង់" (Wherefore, Ye Must Press Forward [1977], 11)។ នៅពេលអ្នកអាន នូវអ្វី ដែលបានកើតឡើង ចំពោះប្រជាជនទាំងនោះ ដែលមាន នៅនីហ្ភៃទី3 7 ចូរគិតអំពី ថាតើពួកគេ ពិតជាសប្បាយនឹងផលវិបាក នៃចំណង់ទុច្ចរិតរបស់ពួកគេដែរឬអត់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្ភៃទី3 7

បទបញ្ជាទាំងឡាយ (ខ. 6)—ច្បាប់ទាំងឡាយ

ផ្លូកញីបែរទៅជានន្សែលនៅក្នុងខ្នាចវិញ (ខ. 8)—ផ្លូកមួយក្បាលនន្សែលក្នុងភក់

អ្នកបែកបាក់ (ខ. 12)—មនុស្ស ដែលប្រឆាំងនឹង អ្នកនៅក្នុងអំណាចទាំងឡាយ

ត្រូវបង្អាក់ (ខ. 13)—បង្អាក់ បន្ថយល្បឿន

បំពារបំពាន (ខ. 14)—ធ្វើខុសអំពើបាប

ពុំត្រប់ត្រាន់ទេ (ខ. 17)—មិនត្រប់ត្រាន់

ធ្វើសញ្ញា (ខ. 21)—បង្ហាញ ចង្អុលបង្ហាញ

ភាពពិការ (ខ. 22)—ភាពទន់ខ្សោយ

បានមក (ខ. 22)—ពរដ៉ប ឥទ្ធិពលដោយ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សា នីហ្ភៃទី3 7។

ក ស្វែងរកការពិត

ចូរបង្ហើយនូវប្រយោគខាងក្រោមនេះ ដោយពាក្យរបស់អ្នកផ្ទាល់ ជាមួយនឹងអ្វី ដែលអ្នករៀន នៅនីហ្ភៃទី3 7។ សូមសរសេរ ប្រយោគនីមួយៗ នៅក្នុងស្បៀវភៅសរសេររបស់អ្នក។

1. បន្ទាប់ពីមេចៅក្រមត្រូវបានសម្លាប់ . . . (សូមមើលខ.1–8)

2. យ៉ាកុប . . . (សូមមើលខ. 9–14)

3. ជំនឿរបស់នីហ្វៃ ខ្លាំងក្លាណាស់ . . . (សូមមើលខ. 15–20)

4. ប្រជាជន ដែលផ្លាស់ប្រែចិត្ត . . . (សូមមើលខ. 21–2)

២ តើហេតុអ្វីព្រះអម្ចាស់បង្ហាញអព្ភូតហេតុដល់ពួកទុច្ចរិត?

នៅនីហ្វៃទី3 7:14 យើងឃើញថា វាមានរយៈពេលសាមសិបមួយឆ្នាំ ចាប់ពីការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ។ មិនយូរប៉ុន្មាន មានការព្យាករណ៍ពីការបំផ្លិចបំផ្លាញ នៅពេលព្រះយេស៊ូវគ្រីស្ទសុគត បានមានមកលើប្រជាជនទាំងនោះ (សូមមើលនីហ្វៃទី3 8:5)។

1. ចូររំលឹកនីហ្វៃទី3 7:15–22 សារឡើងវិញ ហើយធ្វើបញ្ជីនៃតស្មុតាងអំពីព្រះចេស្តានៃព្រះទាំងអស់ ដែលរកឃើញនៅក្នុង ខគម្ពីរទាំងនេះ និងពីរបៀបផ្សេងៗ ដែលប្រជាជនមានប្រតិកម្មមកលើតស្មុតាងនោះ។

2. សូមអាន អេសេគាល 33:6–11 (នៅក្នុងព្រះគម្ពីរសញ្ញាចាស់) ហើយពន្យល់ថា ហេតុអ្វីបានជាអ្នកគិតថា ព្រះអម្ចាស់ បាន បង្ហាញដល់ពួក នីហ្វៃនូវព្រះចេស្តាដ៏មហិមាយ៉ាងដូច្នេះ។

3. តើព្យាការីដែលនៅរស់របស់យើងបានផ្តល់ ជំបូន្មានអ្វីខ្លះ ដើម្បីរៀបចំប្រជាជន ចំពោះការព្យាករណ៍ដែលបានព្យាករ អំពីការ បំផ្លិចបំផ្លាញ ដែលនឹងកើតមានទាការយោងមកជារលើកទីពីរនៃព្រះអង្គសង្គ្រោះ?

នៅការយាងមកជារលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ ពួកទុច្ចរិតនឹងត្រូវបំផ្លាញចោល ហើយពួកសុចរិតនឹងលើកទៅនៅជាមួយ ព្រះ អង្គសង្គ្រោះ។ តើអ្នកធ្លាប់បានពិចារណាពីអ្វី ដែលនឹងកើតឡើងជាយ៉ាងណានោះទេ? នៅនីហ្វៃទី3 8 គឺជាការពិពណ៌នាអំពី ការបំផ្លិចបំផ្លាញទាំងឡាយ ដែលមាននៅក្នុងចំណោមពួកសាសន៍នីហ្វៃ នៅពេលព្រះយេស៊ូវត្រូវឆ្កាងនៅយេរូសាឡិម។ នៅពេល អ្នកអាន ចូរកត់ចំណាំថា នរណាត្រូវបានបំផ្លាញចោល ហើយថាតើមកពីមូលហេតុអ្វី។ សូមកត់ចំណាំផងដែរនូវព្រឹត្តិការណ៍ទាំងឡាយ ដែលបានកើតឡើង ដូចដែលសាំយូអែលជាសាសន៍លេមិនបានព្យាករ (សូមមើលហេលេមិន 14:20–27)។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 8

មនុស្សត្រឹមត្រូវ (ខ. 1)—សុចរិត ស្មោះត្រង់

ការគិត (ខ. 2)—ការរាប់ ការគណនា

បានទន្ទឹងរង់ចាំ (ខ. 3)—ចំណាង់ចំណងខ្លាំង

មានព្យុះសង្ឃរា (ខ. 6,12, 17)—ព្យុះកំណាច

ប្រែចេញពីគ្នា (ខ. 6)—បែកចេញពីគ្នា

ស្ងាត់ឈឹង (ខ. 14)—ទទេ

ប្រែបែកជាពីរ (ខ.18)—បំបែកជាពីរ

ដួលដេក (ខ. 20)—ស្លាប់

ចំហាយ (ខ. 20)—ពពក

នីហ្វៃទី3 8:25—ការបដិសេធព្យាការី

អ្នកទាំងឡាយនៅរស់ក្រោយពីការបំផ្លិចបំផ្លាញ ដែលមានពិពណ៌នា នៅក្នុងនីហ្វៃទី3 8 បានឱ្យដឹងថា បើសិនជាមនុស្ស ភាគច្រើនមិនបានបដិសេធព្យាការីនោះទេ ពួកគេនឹងមិនត្រូវបានបំផ្លាញចោលដែរ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សានីហ្វៃទី3 8។

ក ប្រៀបធៀបព្រឹត្តិការណ៍ពីរ

1. តើអ្វីខ្លះ ដែលធ្វើឱ្យប្រជាជនចាំមើលដោយ “ការទន្ទឹងរង់ចាំ” (ខ. 3) តើហេតុអ្វី?

2. ចូរធ្វើការសង្កេតនូវអ្វី ដែលគោលលទ្ធិ និងសេចក្តីសញ្ញា 133:38–45 ដោយនិយាយអំពីពួកសុចរិត ថាតើពួកគេនឹង មានអារម្មណ៍យ៉ាងណា នៅពេលការយាងមកជារលើកទីពីរមកដល់។

3. ចូរធ្វើការប្រៀបធៀបនីហ្វៃទី3 8 ៈ4–22 និងយ៉ូសែប ស៊្មីធ—ម៉ាថាយ 1:28–33 រួចហើយសរសេរពីភាពស្រដៀងគ្នា ដែលអ្នកឃើញ នៅរវាងការយាងមកនៃព្រះអង្គសង្គ្រោះ មកជួបនឹងពួកសាសន៍នីហ្វៃ និងអ្វី ដែលបានព្យាករជាមុនពីការយាង មកជារលើកទីពីររបស់ទ្រង់។

ខ សរសេរសំបុត្រ ឱ្យខ្លួនឯង

1. តើហេតុអ្វីបានជាប្រជាជន “មានការទួញយំ” “ទ្រហោយំ” និង “ខ្សឹកខ្សួល” នៅនីហ្វៃទី3 8:23?

2. មកពីនីហ្វៃទី3 8:24–25 តើពួកគេត្រាថ្មាអ្វីខ្លះ ដើម្បីឱ្យពួកគេ ដូចជាមនុស្សម្នាក់ ដែលបានធ្វើអ្វីមួយ ច្បៀសវាងនូវ សោកនាដកម្មដ៏ធំនេះ?

3. ឧបមាថា អ្នកគឺជាព្យាការីម្នាក់របស់ព្រះអម្ចាស់។ ចូរសរសេរសារលិខិតមួយ ទៅដល់មនុស្សទាំងអស់ ដែលកំពុងខ្វល់ខ្វាយពីអ្វី ដែលគេត្រូវធ្វើ ដើម្បីច្បៀសវាងពីសេចក្តីសន្យា អំពីការបំផ្លិចបំផ្លាញនៅថ្ងៃចុងក្រោយ បើសិនជាមិនប្រែចិត្តនោះទេ។

ប្រជាជន ដែលនៅរស់ពីគ្រោះធម្មជាតិ មានពិពណ៌នានៅនីហ្វៃទី3 8 បានឮសំលេងព្រះយេស៊ូវគ្រីស្ទ នៅក្នុងសេចក្តីងងឹត។ សារលិខិតរបស់ទ្រង់ មាន

ចុះបញ្ជីនៅក្នុងនីហ្វៃទី3 9។ ជាពេលស្ងាត់ស្ងៀមមួយរយะ ហើយបន្ទាប់មកពួកគេ ក៏បានឲ្យសំលេង របស់ទ្រង់ម្តងទៀត។ សារលិខិតរបស់ទ្រង់ មានចុះបញ្ជីនៅនីហ្វៃទី3 10។ ចូរយកចិត្តទុកដាក់ ចំពោះអ្វី ដែលព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូល អំពីការបំផ្លិចបំផ្លាញនៅក្នុងដែនដី និងអ្វី ដែលអ្នកទាំងនោះត្រូវធ្វើដើម្បីមានជីវិត។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 9

វេទនា (ខ. 2)—ទុក្ខព្រួយ សោកសង្រេង

មករកយើងទៀតទាស់នឹងពួកគេ (ខ. 5,7–9, 11)—ស្រែកមករកយើងសំរាប់យុត្តិធម៌

នៅកន្លែង (ខ. 7)—កន្លែង

អាលផា និងអូមេកា (ខ. 18)—អក្សរទីមួយ និងចុងក្រោយ នៃតួរអក្សរបស់ភាសាក្រិច តំណាងឱ្យព្រះចេស្តារបស់ទ្រង់លើវត្ថុទាំងអស់ ចាប់តាំងពីដើមរហូតដល់ចប់

ការខ្ជាយឈាមទៀតទេ (ខ. 19)—ការបូជាសត្ច នៅក្រោមច្បាប់របស់ម៉ូសេ

ចិត្តសង្រេង (ខ. 20)—ចិត្តរាបទាបអាចបង្រៀនបាន

វិញ្ញាណទន់ទាប (ខ. 20)—ការប្រែចិត្ត អាចបង្រៀនបាន

នីហ្វៃទី3 9:13—"ដើម្បីយើងអាចមើលអ្នកឱ្យជា"

វាជារឿងដ៏គួរឱ្យអស្ចារ្យណាស់ ដែលប្រជាជនគ្រប់រូបអាចនៅរស់ក្រោយពីការបំផ្លិចបំផ្លាញ។ អ្នកទាំងឡាយណា ដែលនៅ សល់ គឺជាអ្នកសុចរិតគ្រប់គ្រាន់ដើម្បីមានជីវិត ប៉ុន្តែនៅមានតំរូវការជាច្រើនពីពួកគេផងដែរ។ ពួកគេត្រូវបានបញ្ជាឱ្យ "ត្រលប់" និង "ប្រែចិត្ត" ហើយ "ផ្លាស់ចិត្តគំនិតដើម្បីយើងអាចមើលអ្នកឱ្យជា។" ប្រធានហារ៉ូល ប៊ី លី មានប្រសាសន៍ថាះ "អព្ភូតហេតុដ៏អស្ចារ្យជាងគេ ដែលខ្ញុំយើញសព្វថ្ងៃនេះ គឺថាមិនមានការចាំបាច់ក្នុងការព្យាបាលជម្ងឺខាងរាងកាយទេ ប៉ុន្តែអព្ភូតហេតុដ៏ អស្ចារ្យបំផុត ខ្ញុំយើញគឺជាការព្យាបាលជម្ងឺ ខាងវិញ្ញាណវិញ" (នៅក្នុង Conference Report ខែមេសា ឆ្នាំ 1973, 178 ឬ Ensign ខែកក្កដា ឆ្នាំ1973, 123)។

នីហ្វៃទី3 9:16—"យើងបានមករករាស្ត្រយើង តែរាស្ត្រយើងពុំបានទទួលយើងសោះ"

ព្រះយេស៊ូវ បានចាប់ផ្តើមការបង្រៀនរបស់ទ្រង់ ក្នុងចំណោមរាស្ត្រដែលនៅក្នុងសេចក្តីសន្យា កាលពីបុរាណ វង្សអ៊ីស្រាអែល—ជាពិសេសចំពោះសាសន៍យូដា។ ពួកគេមានពាក្យរបស់ព្យាការី និងក្រិត្យវិន័យរបស់លោកម៉ូសេ ហើយពួកគេបានធ្វើជាសាក្សី នៃអព្ភូតហេតុ ជាច្រើនរបស់ព្រះអង្គសង្គ្រោះ ហើយពួកគេទាំងអស់គ្នាធ្វើទីបន្ទាល់អំពីទ្រង់។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែលក្ខខ័ណ្ឌ គ្មានជំនឿរបស់ពួកគេ ពួកគេជាច្រើនបានបដិសេធទ្រង់ និងបដិសេធការបង្រៀនរបស់ទ្រង់ផងដែរ។ (សូមមើលផងដែរ នៅយ៉ូហាន 1:11, ត និង ស 6:21។)

នីហ្វៃទី3 10

ឈប់ឃំសោក និងទួញ (ខ. 2)—ឈប់ឃំ និងទុក្ខសោក

បានចិញ្ចឹម (ខ. 4)—ពង្រឹង និងពរជ័យ

រសាត់បាត់ (ខ. 9)—ចេញបាត់ទៅ

ប្រេះ (ខ. 9)—បែកជាពីរ

សម្លេងកងរំពង (ខ. 9)—ញ្ជខ្លាំង

បានភ្ជាប់ (ខ. 10)—ចូលរួម

ដែលជាសំណល់នៃពូជពួកគេ (ខ. 16–17)—ខ្សែស្រឡាយនៃពូជពង្សរបស់ពួកគេ

យាងឡើងទៅលើ (ខ. 18)—ឡើងទៅលើ

ដូចជាមេមាន់គេឿងកូនរបស់វា ហើយព្រះអង្គសង្គ្រោះ ផ្តល់ការការពារថែរក្សា ចំពោះអ្នកទាំងឡាយណា ដែលដើរតាមទ្រង់ ដោយបន្ត ធ្វើការព្រមានដល់ពួកគេ ពីគ្រោះថ្នាក់ និងប្រមូលពួកគេឱ្យស្ថិតនៅក្នុងសុវត្ថិភាព។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី3 9–10។

ក្ត្រ គូសបញ្ជាក់ពីគំនិតដដែលឲ្យមួយ

1. នៅពេលអ្នករំលឹក នីហ្វៃទី3 9:5, 7–9, 10:12 សារឡើងវិញ ចូររកមើលនូវអ្វី ដែលព្រះអង្គសង្គ្រោះ បានធ្វើការគូសបញ្ជាក់ យ៉ាងច្បាស់លាស់ វាជាមូលហេតុប្រជាជនខ្លះ ត្រូវបានបំផ្លាញចោល និងអ្នកដទៃទៀត ត្រូវបានខ្ជាត់ព្រាត់។
2. តើលោកមរមនចង់ឱ្យយើងយល់ អ្វីខ្លះ នៅនីហ្វៃទី3 10:14–16?
3. យោងទៅតាមគោលលទ្ធិ និងសេចក្តីសញ្ញា 1:14 តើការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ មានលក្ខណៈស្រដៀងគ្នា ទៅនឹងការបង្ហាញព្រះអង្គទ្រង់ នៅក្នុងព្រះគម្ពីរមរមនដូចម្តេចខ្លះ?

ខ "មករកយើង"

1. ចូរបង្កើតតារាងពីរ នៅក្នុងស្បៀវភៅសរសេររបស់អ្នក។ នៅក្នុងតារាងម្ខាង ធ្វើជាបញ្ជីនៃអ្វីដែលព្រះយេស៊ូវ មានបន្ទូលថា ដើម្បីធ្វើឱ្យ "សុចរិតជាង" នៅនីហ្វៃទី3 9:12–22។ នៅតារាងម្ខាងទៀត ចូរធ្វើបញ្ជីនៃអ្វី ដែលព្រះយេស៊ូវ បានសន្យានឹងពួកគេ នៅក្នុងខគម្ពីរទាំងនោះ។
2. តើរឿងនេះបង្រៀនដល់អ្នកអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ដែលផ្តល់សេចក្តីជំនឿឱ្យអ្នក ដើម្បីធ្វើនូវអ្វីដែលទ្រង់សុំ និងទុកចិត្តឱ្យ ធ្វើ ដើម្បីទ្រង់អាចបំពេញតាមការសន្យារបស់ទ្រង់?

ត្ត្រ ការស្គាល់ពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ

1. ចូរធ្វើការប្រៀបធៀបអំពីការឆ្លើយតបរបស់អារក្ស ចំពោះការបំផ្លិចបំផ្លាញ នៅក្នុងដែនដី នៅនីហ្វៃទី3 9:2 ជាមួយនឹងការ ឆ្លើយតបរបស់ព្រះអង្គសង្គ្រោះ នៅនីហ្វៃទី3 9:13–14, 10:4–6។
2. សូមអាននីហ្វៃទី2 2:18, 27, 26:24–25 ហើយពន្យល់ថា ហេតុអ្វីក៏ការឆ្លើយតបរបស់អារក្ស និងព្រះយេស៊ូវ មានភាព ខុសគ្នាឆ្ងាយយ៉ាងនេះ។
3. ចូរសរសេរអំពីគ្រាមួយ ពេលដែលព្រះអង្គសង្គ្រោះ "បានប្រមូល" ឬ "បានចិញ្ចឹម" អ្នកដូចដែលទ្រង់បានសន្យាថា ធ្វើសំរាប់ ប្រជាជនរបស់ទ្រង់ នៅនីហ្វៃទី10:4–6។

នីហ្វៃទី3 11

ព្រះអង្គសង្គ្រោះទ្រង់លេចមក!

សំរាប់រយះពេល 600 ឆ្នាំ ព្យាការីរបស់សាសន៍នីហ្វៃ និងសាសន៍លេមិនបានទិយាយ សរសេរ និងបានព្យាករ អំពីការយាង មករបស់ព្រះគ្រីស្ទ។ ពួកគេដឹងថា ទ្រង់នឹងមកឯពួកគេ កំឡុងពេលនៃជីវិត ដែលអាចស្លាប់បានរបស់ទ្រង់ ប៉ុន្តែថា ទ្រង់នឹងលេចមកឯ ពួកកូនចៅលីហៃ បន្ទាប់ពីដំណើររស់ឡើងវិញរបស់ទ្រង់ (សូមមើលនីហ្វៃទី2 26:9, អាលម៉ា 16:20)។ អ្នកមានជំនឿ ដាក់សេចក្តីជំនឿ និងសេចក្តីសង្ឃឹមទាំងអស់របស់ពួកគេ ទៅលើទ្រង់ និងបេសកកម្មសង្គ្រោះរបស់ទ្រង់។ នៅនីហ្វៃទី3 11 អ្នកនឹងអាន អំពីការសំរេចដោយត្រចះត្រចង់ តាមការព្យាករណ៍ទាំងនោះ។ បញ្ជីនៃការយាងមករបស់ព្រះអង្គ សង្គ្រោះនៅទ្វីបអាមេរិក មានបន្តទៅនីហ្វៃទី3 28។ នៅពេល អ្នកអានជំពូកនេះ ចូរពិចារណានូវអ្វី ដែលត្រូវកើតឡើងចំពោះ អ្នកទាំងនោះ ដែលមានវត្តមាន នៅពេលព្រះអង្គសង្គ្រោះលេចមក។ សូមពិចារណា ដោយប្រុងប្រយ័ត្ននូវអ្វី ដែលព្រះគ្រីស្ទ បានជ្រើសរើសដើម្បីមានបន្ទូល និងធ្វើនៅក្នុងពេលដ៏ខ្លី ដែលទ្រង់គង់នៅជាមួយនឹងពួកគេ ហើយអ្វី ដែលបង្រៀនយើងនោះនឹងអ្វី ដែលទ្រង់ចាត់ទុកថាសំខាន់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 11

ពួកគេបានក្រលេកមើល (ខ. 3, 8)—មើល

ខ្លួនប្រាណ (ខ. 3)—រាងកាយ

ហ៉ាន (ខ. 8)—ក្លាហាន

យល់ថា (ខ. 8)—ដឹង

បានស៊ូទ្រាំតាម (ខ. 11)—គោរព

ឡើងទៅ (ខ. 12)—ឡើងទៅលើ

សម្លេងព្រមគ្នា (ខ. 16)—ជាមួយគ្នា

ហូសាណា! (ខ. 17)—សូមផ្តល់ឱ្យខ្ញុំនូវសេចក្តីសង្គ្រោះ!

តាមរបៀបនេះ (ខ. 22–23)—តាមវិធីនេះ

ការប្រកែក (ខ. 22, 28)—ការឈ្លោះប្រកែក ការទាស់ទែង

ពន្លិច (ខ. 26)—គ្របពីលើទាំងស្រុង

គ្រងនគរព្រះទុកជាមរតក (ខ. 33, 38)—ទទួលតាមច្បាប់គ្រឹមត្រូវពេញលេញ

ទ្វារនៃស្ថានរក (ខ. 39–40)—អំណាចរបស់អារក្ស

ឈ្នះ (ខ. 39–40)—យកជ័យជំនះ ឈ្នះ

នីហ្វៃទី3 11:14–15—ស្នាមរបួសរបស់ព្រះអង្គសង្គ្រោះ

អែលឌើរ ដែហ្វ្រី អ័រ ហូលលែន ជាសមាជិកក្រុមសាវកដប់ពីរនាក់ បានប្រកាសថាះ

"ទោះបី អំណាចនៃដំណើររស់ឡើងវិញ អាចមាន—ហើយដោយគ្មានសង្ឃ័យថា ថ្ងៃមួយនឹងមាន—ការសាងឡើងវិញទាំងស្រុង ហើយធ្វើឱ្យស្នាមរបួសមកពីការឆ្កាងឱ្យនៅថ្មី ទោះជាយ៉ាងណាក៏ដោយក៏ព្រះគ្រីស្ទមានមូលហេតុ ក្នុងការសំរេចព្រះទ័យ ដើម្បី រក្សាស្នាមរបួសទាំងនោះផងដែរ ព្រមទាំងការបង្ហាញព្រះកាយរបស់ទ្រង់នៅថ្ងៃចុងក្រោយ គឺជាពេលដែលទ្រង់បង្ហាញសញ្ញាទាំងនោះ ហើយនឹងបើកបង្ហាញថា ទ្រង់បានត្រូវរបួស 'នៅក្នុងផ្ទះរបស់មិត្តសំឡាញ់ [ខ្ញុំ]' [សាការី 13:6, សូមមើលផងដែរនៅ គ និង ស 45:52]។

"ស្នាមរបួសនៅលើព្រះហស្ត ព្រះបាទ និងនៅចំហៀងព្រះអង្គទ្រង់ មានសញ្ញាសំគាល់ថា នៅក្នុងជីវិតរមែងស្លាប់មានរឿង ដ៏ឈឺចាប់បានកើតមានឡើង សូម្បីតែមនុស្សបរិសុទ្ធ និងល្អឥតខ្ចោះផងដែរ ទីសំគាល់នៃសេចក្តីទុក្ខលំបាកនោះ គឺ*មិនមែន* ជាភស្តុតាងថា ព្រះមិនស្រឡាញ់ពួកយើងនោះទេ។ វាគឺជាកត្តាដ៏សំខាន់ និងដោយក្តីសង្ឃឹម ដែលវាគឺជា *ស្នាមរបួស* របស់ព្រះ គ្រីស្ទជាអង្គ ដែលយាងមកដើម្បីជួយសង្គ្រោះយើង។ ទ្រង់ជាអង្គដែលមានស្នាមនៃពលិកម្ម ដែលជាជាលិការនៃសេចក្តីស្រឡាញ់ គំណាងឱ្យការបន្ទាបខ្លួន និងការអភ័យទោសគឺជាមេបញ្ជាការនៃព្រលឹងរបស់យើង។ ភស្តុតាងនៃការឈឺចាប់នៅក្នុងជីវិតរមែង ស្លាប់គឺដោយគ្មានការសង្ឃ័យដ៏អស់ពីចិត្ត ដើម្បីផ្តល់ជាកម្លាំងចិត្តដល់អ្នកដទៃ ដែលមានការឈឺចាប់ និងរបួសផងដែរដោយសារ ជីវិតនេះ សូម្បីតែនៅក្នុងផ្ទះរបស់មិត្តសំឡាញ់ពួកគេ" (*Christ* and *the New Covenant* [1997], 258–59)។

នីហ្វៃទី3 11:1–8—តើព្រះមានបន្ទូលមកកាន់មនុស្សលោកដោយរបៀបណា?

ប្រធានយ៉ូសែប អែហ្ស ស្មីធ ជាទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានទីមួយ មានប្រសាសន៍ថាៈ "ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ មាន បន្ទូលមកកាន់ខ្ញុំ—មិនមែនតាមត្រចៀក មិនមែនតាមភ្នែក ប៉ុន្តែមកកាន់វិញ្ញាណរបស់ខ្ញុំ មកកាន់ជីវិតរបស់ខ្ញុំ និងជាផ្នែកដ៏អស់ កល្បជានិច្ច—ហើយបានបើកបង្ហាញចំពោះខ្ញុំថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ត ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់" (*Teaching of the Presidents of the Church: Joseph F. Smith* [1998],7)។

នីហ្វៃទី3 11:27, 32–36—ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ គឺតែមួយ

នៅនីហ្វៃទី3 11 គឺជាទីបន្ទាល់មួយទៀត នៃគោលលទ្ធិ ដែលថា សមាជិកនៃក្រុមព្រះបីអង្គ មានតួអង្គដាច់ដោយឡែកពីគ្នា ប៉ុន្តែ មានការរួបរួមគ្នាយ៉ាងខ្លាំងនៅក្នុងការខំប្រឹងប្រែងរបស់ទ្រង់ទាំងបីអង្គ "ដើម្បីនាំមកនូវជីវិតអមតៈ និងអស់ដ៏កល្បជានិច្ចរបស់ មនុស្ស" (សូមមើលម៉ូសេ 1:39)។ ក្រុមព្រះទាំងបីអង្គ មានបន្ទូលជំនួសឱ្យគ្នាទៅវិញទៅមក ហើយធ្វើទីបន្ទាល់ឱ្យគ្នាទៅវិញ ទៅមកពីព្រោះតែទ្រង់ទាំងបីអង្គ មានគោលបំណង និងគោលលទ្ធិរួមគ្នា។ ប្រជាជន ឲសំលេងរបស់ព្រះវរបិតា ពួកគេបានឃើញ និងឲ្យព្រះ យេស៊ូវគ្រីស្ត ហើយពួកគេត្រូវបានបង្រៀនពីភាពខុសគ្នា ប៉ុន្តែមានការរួបរួមគ្នា ក្នុងតួនាទី នៃតួអង្គទាំងពីរនេះ និងព្រះវិញ្ញាណ បរិសុទ្ធ។ (សូមមើលផងដែរ នៅយ៉ូហាន 17:20–23 ហើយនឹងគោលលទ្ធិ និងសេចក្តីសញ្ញា 130:22 បាននិយាយអំពីសមាជិកភាពរបស់ក្រុមព្រះបីអង្គ ហើយមានភាពរួមគ្នា ប៉ុន្តែតួអង្គដាច់ដោយឡែក)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–ង)ខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី3 11។

ក្ស សរសេរនូវការឡើងនិយាយមួយ

ឧបមាថា អ្នកត្រូវបានចាត់ឱ្យនិយាយនៅក្នុងការប្រជុំធ្វើពីធីប្រសិទ្ធិពរនំប៉ុង និងទឹកដែលមានប្រធានបទ "រៀនស្តាប់ព្រះបន្ទូល។"

1. ចូរសរសេរជាការនិយាយមួយ ដោយការប្រើនីហ្វៃទី3 11:1–8 ដើម្បីពន្យល់ពីរបៀប ដែលយើងអាចរៀបចំខ្លួនរបស់យើង ឱ្យបានកាន់តែល្អប្រសើរឡើង ក្នុងការស្តាប់តាមព្រះបន្ទូលរបស់ព្រះ។ ចូរពិចារណាអំពីសំនួរពិភាក្សាដែលស្រដៀងគ្នានៅខាង ក្រោមៈ តើសំលេងមកដោយរបៀបណា? តើសំលេងនោះត្រូវបានពិពណិនាយ៉ាងដូចម្តេចខ្លះ? ហេតុអ្វីក៏ពួកគេមិនឲសំលេងនៅលើកទីមួយ?
2. សូមអានគោលលទ្ធិ និងសេចក្តីសញ្ញា 136:32–33 ហើយប្រើជំនួយសិក្សា នៅក្នុងព្រះគម្ពីររបស់អ្នក ដើម្បីស្វែងរក សូមមើល វគ្គជាច្រើនទៀត ដែលអាចជួយមនុស្សម្នាក់ឱ្យស្តាប់ និងយល់នូវសំលេងរបស់ព្រះ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ចូរពន្យល់វគ្គទាំងនេះ នៅក្នុងការឡើងនិយាយរបស់អ្នក (សូមមើលគ និង ស 1:38, 18:34–36 សំរាប់ជាជំនួយបន្ថែម)។

ខ ពិចារណានូវអត្ថន័យពិត

1. ព្រះយេស៊ូវអាចណែនាំព្រះអង្គទ្រង់ នៅក្នុងគ្រប់វិធីទាំងអស់ តើហេតុអ្វីក៏អ្នកគិតថា ទ្រង់មានបន្ទូលនូវអ្វី ដែលទ្រង់បានធ្វើ នៅនីហ្វៃ ទី3 11:10–11 យ៉ាងដូច្នេះទៅវិញ? តើយើងអាចរៀនអ្វីខ្លះ អំពីព្រះអង្គសង្គ្រោះតាមរយៈការណែនាំព្រះកាយ របស់ទ្រង់?
2. សូមអានគោលលទ្ធិ និងសេចក្តីសញ្ញា 19:16–20 ហើយពន្យល់នូវអ្វី ដែលមានទាក់ទងនៅក្នុងការផឹកនូវ "កែវល្វីង។"

ត្ធើជាសាក្សី

1. ចូររំលឹកនីហ្វៃទី3 11:14–16 សារឡើងវិញ ហើយពន្យល់នូវអ្វី ដែលព្រះយេស៊ូវចង់ឱ្យប្រជាជនដឹង និងអ្វី ដែលប្រជាជនបាន ធ្វើដើម្បីទទួលសាក្សីនោះ។
2. ចូរសរសេរជាប្រយោគពីរបី រួចពន្យល់ ហេតុអ្វីក៏អ្នកគិតថា ព្រះយេស៊ូវ អនុញ្ញាតឱ្យប្រជាជនមើល ហើយពាល់ទ្រង់ ម្នាក់ម្តងឲ យ៉ាងដូច្នេះទៅវិញ។
3. តើអ្នក អាចដឹងថា ព្រះយេស៊ូវ មានព្រះជន្មរស់ឡើងវិញបានយ៉ាងដូចម្តេច បើអ្នកមិនទាំងបានឃើញ ឬក៏ប៉ះស្នាមរបួស របស់ទ្រង់ដោយផ្ទាល់ផងនោះ?

ឃ ចូរសរសេរអំពីគោលលទ្ធិ នៃពិធីបុណ្យជ្រមុជទឹក

ចូរសរសេរយ៉ាងតិចនូវសេចក្តីពិតសំខាន់ឲចំនួនបួន ដែលយើងរៀនអំពី ពិធីបុណ្យជ្រមុជទឹក មកពីអ្វីដែលព្រះយេស៊ូវ មានបន្ទូល និងបានធ្វើនៅនីហ្វៃទី3 11:18–40។

ង ចំណេះចំណានខគម្ពីរ—នីហ្វៃទី3 11:29

1. ចូរសរសេរសំនួរពីរ អំពីការប្រកែកគ្នា ដែលអាចឆ្លើយបានមកពីការអាន នីហ្វៃទី3 11:28–30។ បន្ថែមទាំងចម្លើយ។
2. ចូរអានសុភាសិត 15:1 ហើយធ្វើការសង្ខេបនូវអ្វី ដែលខគម្ពីរនេះនិយាយអំពីវិធីមួយ ដើម្បីជៀសវាងពីការប្រកែកគ្នា។ បន្ទាប់ មកឱ្យយោបល់សំរាប់ជាវិធីពីរទៀត ដែលអ្នកគិតថា មនុស្សម្នាក់អាចជៀសវាងពីការប្រកែកគ្នា នៅក្នុងរង្វង់គ្រួសារ។

> អែលឌើរ លីន ជី រ៉ូប៊ីន ជាសមាជិកក្រុមចិតសិប មានប្រសាសន៍ថាៈ
>
> "កំហឹង គឺជាការបន្ទន់ទៅតាមឥទ្ធិពលរបស់សាតាំង ដោយការចុះចាញ់លើការគ្រប់គ្រងលើខ្លួនឯង. . . .
>
> "ការយល់ដឹងអំពីទំនាក់ទំនងរវាង សិទ្ធិសេរីភាព និងកំហឹង គឺជាជំហានទីមួយ នៅក្នុងការកំចាត់ចោលកំហឹង ចេញពីជីវិតរបស់ យើង។ យើងអាចជ្រើសរើសមិនឱ្យមានកំហឹង" (នៅក្នុង Conference Report ខែមេសា ឆ្នាំ 1998, 106, ឬ *Ensign* ខែឧសភា ឆ្នាំ 1998, 80–81)។

នីហ្វៃទី3 12

ទេសនកថានៅព្រះវិហារ បរិសុទ្ធ ផ្នែកទីមួយ

ទេសនកថានៅលើភ្នំ មាននៅក្នុងម៉ាថាយ 5–7 នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលអាចចាត់ទុកថា ជាប្រភពតែមួយគត់ ដើម្បី ស្វែងរកគ្រឹះ នៃការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ត អំឡុងពេលនៃការបំរើនៅក្នុងជីវិតរមែងស្លាប់របស់ទ្រង់។ វាមិនគួរឱ្យភ្សាក់ ផ្អើលទេ ដែលព្រះយេស៊ូវគ្រីស្ត បានបង្រៀនស្ទើរតែដូចគ្នាទាំងស្រុង ទៅនឹងទេសនកថារបស់ទ្រង់ ចំពោះ ពួកសាសន៍នីហ្វៃ នៅពេលទ្រង់យាងទៅជួប នឹងពួកគេ។ ចូរធ្វើការកត់ចំណាំពីរបៀប ទ្រង់ថ្លែងទេសនកថានៅកាន់កូនចៅរបស់លីហៃ បានធ្វើឱ្យ កាន់តែច្បាស់ និងផ្តល់ការ យល់ដឹងបន្ថែមចំពោះអ្វី ដែលយើងបានរៀននៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ទេសនកថានៅព្រះវិហារនោះ មានចុះបញ្ជី នៅក្នុង នីហ្វៃទី3 12–14។ វាបានបង្រៀនយើងនូវអ្វី ដែលព្រះអង្គសង្គ្រោះ មានសង្ឃឹមចំពោះអ្នកទាំងឡាយ ដែលមានបំណងចង់ធ្វើជាសិស្សរបស់ទ្រង់។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 12

ស្តាប់បង្គាប់ (ខ. 1)—គោរព

សេចក្តីកំសត់ខាងវិញ្ញាណ (ខ. 3)—បន្ទាបខ្លួន

ស្លូតត្រង់ (ខ. 5)—រាបសារ ស្ងៀទ្រាំ

ជេរ (ខ. 11)—និយាយបំពានអំពី

ជាតិ (ខ. 13)—រសជាតិ ឥទ្ធិពល

ក្រិត្យវិន័យ ឬការព្យាករណ៍នៃពួកព្យាការី (ខ. 17)—ក្រិត្យវិន័យលោកម៉ូសេ និងការបង្រៀនរបស់ព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់

ចាំងឈើមួយ ឬក្ស្យៀសមួយ (ខ. 18)—សំបុត្រ និងសញ្ញាតូចបំផុតនៅក្នុងអក្សរសាស្ត្រហេព្រើរ

អាចោរម្សៀត (ខ. 22)—ឈ្មោះជេរប្រមាថ (សំដៅទៅលើមនុស្សម្នាក់ល្ងីល្ងើរ)

ពួកក្រុមជុំនំ (ខ. 22)—ចៅក្រម

រឿងអ្វី (ខ. 23)—អ្វីក៏ដោយ

ផ្សះផ្សា (ខ. 24)—ធ្វើឱ្យមានសន្តិភាព

អ្នកដើមចោទ (ខ. 25)—សត្រូវ

បង់មួយស៊ីណាញជាមុន (ខ. 26)—តម្លៃពេញ (ស៊ីណាញ គឺជាលុយរបស់សាសន៍នីហ្វៃ)

ចង់បាន (ខ. 28)—មានគំនិតមិនបរិសុទ្ធអំពីអ្វីមួយ ល្មោភ

លើកលើឈើឆ្កាង (ខ. 30)—ធ្វើអ្វីមួយដោយលំបាក ដើម្បីសំរេចតាមភាពជាសិស្សរបស់អ្នក

ជិត (ខ. 32)—អំពើបាបខាងផ្លូវភេទ

ស្បថកុហក (ខ. 33)—ក្បត់សន្យារបស់អ្នក សន្យាដោយខុសឆ្គង

ស្បថ (ខ. 34, 36)—ធ្វើសម្បថ ឬសន្យា

ទុក្ខប្រៀតប្រៀន (ខ. 44)—ដោយវិធីយោរយៅ ឬស្អប់ខ្ពើម

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ដូចខាងក្រោម នៅពេលអ្នកសិក្សានីហ្វៃទី3 12។

ក្ស៊ រប្យើបដើម្បីទទួលពរជ័យ

1. ចូរស្វែងរក និងគូសបន្ទាត់ពីក្រោមពាក្យ *ទទួលពរជ័យ* រាល់ពេល ដែលឃើញពាក្យនោះ នៅក្នុងនីហ្វៃទី3 12:1–11។ នៅ ក្នុងវគ្គ នៃទេសនកថារបស់ព្រះយេស៊ូវនេះ គឺជារឿយៗត្រូវបានហៅថា "បរមសុខ" បន្ទាប់ពីពាក្យរបស់ឡាតាំង ចំពោះពាក្យ "ទទួលពរជ័យ" មានន័យថា "ដើម្បីឱ្យមានសំណាង ឬសប្បាយរីករាយ"
2. នៅក្នុងស្បៀវភៅសរសេររបស់អ្នក ចូរធ្វើតារាងមួយ ដែលស្រដៀងគ្នាទៅនឹងឧទាហរណ៍ដូចខាងក្រោម រួចបំពេញក្នុងតារាង ជាមួយនឹងពតិមាន ដែលអ្នករៀននៅក្នុងនីហ្វៃទី3 12:1–12 និងចេញពីគំនិត និងអារម្មណ៍ផ្ទាល់របស់អ្នក។

អ្វីដែលព្រះយេស៊ូវ មានបន្ទូលនឹងធ្វើឱ្យយើង "ទទួលពរជ័យ"	ពរជ័យទាំងឡាយ ដែលព្រះយេស៊ូវមានបន្ទូលថានឹងមកដល់	ហេតុអ្វីក៏មនុស្សម្នាក់មានសំណាង ឬសប្បាយរីករាយ
ស្តាប់បង្គាប់តាមពាក្យសំដីទាំងឡាយ នៃសិស្សទាំងដប់ពីរនាក់ ដែលព្រះយេស៊ូវទ្រង់បានជ្រើសរើស (ខ. 1)	ធ្វើបុណ្យជ្រមុជដោយទឹក ភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ (ខ.1)	ពីព្រោះពិធីបុណ្យជ្រមុជទឹក មានសារះសំខាន់សំរាប់ការរំដោះបាប

ខ្ ពន្យល់អំពីការប្រៀបធៀបទាំងឡាយ

នៅនីហ្វៃទី3 12:13–16 ព្រះយេស៊ូវ បានធ្វើការប្រៀបធៀបអ្នកដើរតាមទ្រង់ ទៅនឹងអំបិល និងពន្លឺ។ មនុស្សខ្លះ ប្រហែលជា គិតថា ទ្រង់គួរតែនិយាយថា ពួកគេគឺដូចជាមាស បើសិនជាទ្រង់ពិតជាចង់ឱ្យពួកគេមានអារម្មណ៍ថាខ្លួនពួកគេមានតំលៃ។ ចូរធ្វើ ការពិភាក្សាការបង្រៀននេះ ជាមួយនឹងឱពុកម្តាយ ឬត្រូរបស់អ្នក រួចធ្វើដូចខាងក្រោមនេះ:

1. ចូរធ្វើបញ្ជី នៃមូលហេតុទាំងអស់ ដែលអ្នកអាចគិតថា ហេតុអ្វីអំបិល មានសារះប្រយោជន៍ជាងមាស។
2. ចូរធ្វើការពន្យល់ថា ហេតុអ្វីពន្លឺ គឺជានិមិត្តសញ្ញាមួយសមរម្យ សំរាប់សិស្សពិតរបស់ព្រះយេស៊ូវគ្រីស្ទ។

ក្ស៊ អត្តន័យពិត នៃច្បាប់

ព្រះយេស៊ូវ ប្រាប់ដល់ពួកសាសន៍នីហ្វៃថា ទ្រង់មិនមែនមកសំរាប់បំផ្លាញច្បាប់ទេ តែដើម្បីធ្វើឱ្យបានសំរេចវិញ (សូមមើល នីហ្វៃទី3 12:17)។ វិធីមួយក្នុងចំណោមវិធីទាំងឡាយ ដែលទ្រង់បានធ្វើនោះ គឺដើម្បីជួយដល់ប្រជាជន ឱ្យយល់ពីអត្តន័យពេញលេញ នៃច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលទ្រង់ បានប្រទានឱ្យកាលពីមុនមកដល់កូនចៅអ៊ីស្រាអែល។ ខាងក្រោមនេះ គឺជាបញ្ជីមួយ នៃច្បាប់ទាំងឡាយដែលទ្រង់បានជួយដល់ពួកគេឱ្យយល់កាន់តែប្រសើរឡើង នៅក្នុងនីហ្វៃទី3 12:20–48។ ចូរធ្វើការពន្យល់ពីអត្តន័យពេញលេញ នៃច្បាប់នៅក្នុងដំណឹងល្អរបស់ព្រះគ្រីស្ទ ដូចដែលទ្រង់បានផ្តល់នូវចំនុចសំខាន់ៗនៃច្បាប់ នៅក្នុងជំពូកនេះ។

1. "កុំសម្លាប់មនុស្សឱ្យសោះ" (ខ. 21)។
2. "កុំឱ្យជិតឱ្យសោះ" (ខ. 27)។
3. "កុំឱ្យស្បថកុហកឡើយ" (ខ. 33)។
4. "ភ្នែកឱ្យធួននឹងភ្នែក ហើយធ្មេញឱ្យធួននឹងធ្មេញ" (ខ. 38)។
5. "ចូរស្រឡាញ់អ្នកជិតខាងឯង" (ខ. 43)។

នីហ្វៃទី3 13

ទេសនកថានៅព្រះវិហារ ផ្នែកទីពីរ

© 1995 Gary L. Kapp

នៅក្នុងនីហ្វៃទី3 13 ព្រះអង្គសង្គ្រោះ បន្តការបង្រៀនអំពីកំរិត នៃសេចក្តីសុចរិត ដែលខ្ពស់ជាង ហើយបានបង្ហាញពីបញ្ហា នៃអំពើ កំពុត។ អំពើកំពុត គឺមនុស្សម្នាក់និយាយរឿងមួយ ហើយធ្វើរឿងមួយផ្សេងទៀត។ ឧទាហរណ៍ មនុស្សម្នាក់ ប្រកាសជា សាធារណៈមិនឱ្យមើលរឿងវីឌីអូមិន សមរម្ស តែគាត់បែរជាមើលវីឌីអូនោះដោយសំងាត់។ ចូរធ្វើការកត់ចំណាំ ថាព្រះ អង្គសង្គ្រោះបង្រៀនថា យើងត្រូវធ្វើអ្វី ដែលត្រឹមត្រូវសំរាប់ មូលហេតុត្រឹមត្រូវ ទាំងអាកប្បកិរិយាជាសាធារណៈ និងផ្ទាល់ខ្លួន។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 13

ធ្វើទាន (ខ. 1–4)—ចិត្តល្អ បរិច្ចាគ

មានពុត (ខ. 2, 5, 16)—មនុស្សដែលនិយាយផ្សេងធ្វើផ្សេង

ក្នុងបន្ទប់ (ខ. 6)—កន្លែងផ្ទាល់ខ្លួននៅក្នុងផ្ទះរបស់អ្នក

ពោលពាក្យឥតប្រយោជន៍ផ្ទួនៗ (ខ. 7)—និយាយពាក្យដដែលៗសារឡើងវិញ ដោយគ្មានគិត ឬមានអារម្មណ៍

ពួកសាសន៍ដទៃ (ខ. 7)—មនុស្ស ដែលមិនទទួលដំណឹងល្អ

បានបរិសុទ្ធ (ខ. 9)—បរិសុទ្ធ ពិសិដ្ឋ

ទឹកមុខ (ខ. 16)—អាការៈ ឬមុខ

អ្នកស្មោះស្ម័ត្រទាំងស្រុង (ខ. 22)—សំដៅទៅលើសេចក្តីសុចរិត មិនរំខាន

ទ្រព្យសម្បត្តិ (ខ. 24)—មានទ្រព្យ ខាងលោកីយ

សំលៀកបំពាក់ (ខ. 25, 28)—សំលៀកបំពាក់

សាបព្រោះ (ខ. 26)—ដាំដុះ

ច្រូតកាត់ (ខ. 26)—ប្រមូលផល

មួយហាត់ (ខ. 27)—ឯកតា នៃការវាស់វែង (ប្រហែល ឬ 46 សង់ទីម៉ែត្រ)

កំពស់ (ខ. 27)—កំពស់

ធ្វើការ (ខ. 28)—ធ្វើការងារ

ស្រាវរវៃ (ខ. 28)—ធ្វើសំលៀកបំពាក់

បានតែងអង្គ (ខ. 29)—ស្លៀកពាក់យ៉ាងស្រស់ស្អាត

សេចក្តីលំបាកនៅថ្ងៃណា នោះគឺ ល្មមត្រឹមថ្ងៃនោះហើយ (ខ. 34)—ថ្ងៃនីមួយៗមានកង្វល់ត្រប់ត្រាន់សំរាប់ថ្ងៃនោះ

នីហ្វៃទី 3 13:25–34—កុំឱ្យខ្ងល់ខ្ងាយអំពីអ្វី ដែលអ្នកនឹងបរិភោគ ផឹក ឬស្លៀកពាក់ឡើយ

មានមនុស្សជាច្រើនមានការយល់ច្រឡំអំពីសេចក្តីទូន្មានរបស់ព្រះអង្គសង្គ្រោះ "កុំឱ្យខ្ងល់ខ្ងាយនឹងជីវិតរបស់អ្នក" នៅក្នុងម៉ាថាយ 6:25–34។ មានអ្នកខ្លះបានគិតថា វាមានន័យថាកុំឱ្យពួកគេ បារម្ភអំពីការងារ និងការឧបត្ថម្ភខ្លួនឯង។ នៅក្នុងទស្សនៈ របស់នីហ្វៃ នៃទេសនកថានេះ ជួយយើងឱ្យយល់ថាពាក្យទូន្មាននេះ គឺសំដៅជាពិសេសចំពោះសាវកទាំងដប់ពីរនាក់ និងសិស្ស សាសន៍ នីហ្វៃដប់ពីរនាក់ ដែលលះបង់ការប្រកបកិច្ចការខាងលោកីយរបស់ពួកគេ ហើយបានបូជាអស់ទាំងកម្លាំងរបស់ពួកគេ ចំពោះមុខងាររបស់ពួកគេ។ យ៉ាងណាក៏ដោយ សមាជិកទាំងអស់នៃ សាសនាចក្រ អាចអនុវត្តគោលការណ៍ទាំងនេះ ចំពោះខ្លួន ពួកគេ ដោយការយកចិត្តទុកដាក់ឱ្យកាន់តែច្រើនទៅលើរឿងខាងវិញ្ញាណ ហើយខ្ងល់ខ្ងាយរឿងខាងលោកិយបន្តិចបន្តួច។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយ នៃសកម្មភាព (ក–គ) ដូចខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី3 13។

ក ផ្តល់ឧទាហរណ៍ថ្មីមួយ

ចូររំលឹកនីហ្វៃទី3 13:1–24 សារឡើងវិញ រួចធ្វើបញ្ជីឧទាហរណ៍បួន ដែលព្រះយេស៊ូវ បានប្រទានឱ្យអំពីការធ្វើរឿងត្រឹមត្រូវ សំរាប់មូលហេតុខុស។ បន្ទាប់ពីឧទាហរណ៍នីមួយៗ ចូរផ្តល់ឧទាហរណ៍ថ្មីមួយ ពីរបៀប ដែលមនុស្សម្នាក់អាចធ្វើរឿងទាំងនេះ សំរាប់មូលហេតុត្រឹមត្រូវ។

ខ ការអធិស្ឋានកាន់តែមានអត្ថន័យ

ចូរសរសេរអំពីវិធី ដែលអ្នកអាចប្រើនីហ្វៃទី3 13:5–15 ដើម្បីបង្រៀនមេរៀនខ្លីមួយ អំពីការអធិស្ឋាន ទៅកុមារតូចៗនៅក្នុង ថ្នាក់។ ចូរបន្ថែមគំនិតទាំងអស់ ដែលអ្នកចង់ចែកចាយអំពីខគម្ពីរ ទាំងនេះ និងរបៀប ដែលខគម្ពីរ អនុវត្តចំពោះ សមាជិកក្នុងថ្នាក់។

គ គិតអំពីពាក្យស្មើរសុំមួយ

ចូរពិពណិនាអំពីស្ថានភាពទូទៅចំពោះមនុស្សវ័យដូចអ្នក យ៉ាងតិចឱ្យបានពីរ ដែលស្ថានភាពទាំងនោះ មានទាក់ទងក្នុងការធ្វើការ សំរេចចិត្តជាច្រើន។ វិធីណា ដែលពាក្យទូន្មានរបស់ព្រះអង្គសង្គ្រោះ នៅក្នុងនីហ្វៃទី3 13:19–20,33 អាចជួយឱ្យធ្វើការសំរេច ចិត្តដោយសុចរិត។

តើអ្នកស្គាល់នរណាម្នាក់ ដែលមើលទៅហាក់ដូចជាមានអារម្មណ៍ថា ធ្វើជាសមាជិកនៅក្នុងព្រះវិហារមានសារៈសំខាន់ ប៉ុន្តែ ការរក្សាបទបញ្ញត្តិទាំងអស់ គឺពិតជាមិនតំរូវឱ្យរក្សា ឬរំពឹងទុកនោះទេ? នៅក្នុងនីហ្វៃទី3 14 មានលក្ខណៈស្រដៀងគ្នានឹងម៉ាថាយ 7 ព្រះយេស៊ូវគ្រីស្ទ បានផ្តល់ដំបូន្មានជាក់លាក់ ចំពោះអ្នកទាំងឡាយ ដែលអះអាងថា ដើរតាមទ្រង់ តែបែរជាមិនរក្សាបទបញ្ញត្តិ របស់ទ្រង់ទេ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 14

រង្វាស់ណា ដែលអ្នករាល់គ្នាវាស់ (ខ. 2)—មាត្រដ្ឋាន ដែលអ្នកវាស់ ឬធ្វើការវិនិច្ឆ័យ

កំទេច (ខ. 3–5)—កំទេចតូចៗ ឬចំណុច

ធ្មឹម (ខ. 3–5)—កំទេចឈើធំ

ផ្ទ្រក (ខ. 6)—ផ្ទ្រក

ខ្ងេះ (ខ. 6)—ហែក

ក្រិត្យវិន័យ ហើយជាការព្យាករណ៍ របស់ពួកព្យាការី (ខ. 12)—អត្ថន័យ នៃក្រិត្យវិន័យរបស់ម៉ូសេ និងការបង្រៀនរបស់ព្យាការី នៅក្នុងព្រះគម្ពីរសញ្ញាចាស់

ចង្អៀត (ខ. 13–14)—តូចចង្អៀត គឺងរឹង

ដែលឆក់ស៊ី (ខ. 15)—ពាក្យជានិមិត្ត សញ្ញាអំពីមនុស្សដែលជាអ្នកជញ្ជាក់ឈាមគេ យកប្រយោជន៍ និងធ្វើឱ្យអ្នកដទៃរងគ្រោះ ដើម្បីបំពេញតាមចំណង់របស់ពួកគេផ្ទាល់

និយាយ (ខ. 23)—និយាយ

ពួកទទឹងច្បាប់ (ខ. 23)—ធ្វើអំពើអាក្រក់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី3 14។

ក៣ តើអ្នកឆ្លើយតបដោយរបៀបណា?

បទបញ្ញត្តិរបស់ព្រះយេស៊ូវនៅក្នុងនីហ្វៃទី3 14:1–5 (ឬម៉ាថាយ 7:1–5) គឺជារឿយៗមានការភាន់ច្រឡំ និងសូម្បីតែការ ប្រើក៏ខុសដែរ។ ឧទាហរណ៍ ចូរនឹកគិតថាមានមិត្តម្នាក់ បានអញ្ជើញអ្នកឱ្យចូលរួមក្នុងសកម្មភាព ដែលអ្នកដឹងថាវា ប្រឆាំងនឹង មាត្រដ្ឋានរបស់ព្រះ។ មិត្តរបស់អ្នកបានស្រង់ពាក្យពីម៉ាថាយ 7:1–5 ហើយនិយាយថា បើអ្នកមិនយល់ព្រម នោះអ្នកធ្វើ ការវិនិច្ឆ័យដល់គាត់ និងអ្នកដទៃទៀត ហើយថានោះគឺមិនមែនជាអ្វី ដែលពួកគ្រីស្ទានគួរធ្វើទេ។ ចូរសរសេរនូវអ្វី ដែលអ្នកគិត ថាព្រះអង្គសង្គ្រោះនឹងឱ្យអ្នកនិយាយ។ នៅក្នុងការបកប្រែព្រះគម្ពីរបឺប ដ៏មានការបំផុសគំនិតរបស់ យីង ជេម ព្យាការី យ៉ូសែប ស្មឺធ បានស្រាយបំភ្លឺពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ដែលយើងត្រូវតែ "កុំឱ្យវិនិច្ឆ័យមិនសុចរិត ដែលអ្នកមិន ត្រូវវិនិច្ឆ័យនោះ ឡើយ ប៉ុន្តែចូរធ្វើការវិនិច្ឆ័យដោយសេចក្តីសុចរិត" (នីហ្វៃទី3 14:15–20 និងម៉ូរៃណៃ 7:14–19 ប្រហែលជាអាចជួយដល់អ្នក ផងដែរ)។

ខ ការអធិស្ឋាន និងការទទួលចំលើយ

1. តើអ្នកបានរៀនអ្វីខ្លះ អំពីព្រះវរបិតាសួគិ មកពីការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងនីហ្វៃទី3 14:7–11?
2. តើអាស្រ័យទៅលើកត្តាអ្វីខ្លះ ដែលខគម្ពីរទាំងនេះបង្រៀន តើព្រះវរបិតាសួគិនឹងធ្វើអ្វី បើសិនជាអ្នកសុំនំប៉ុង ឬត្រីនោះ? តើទ្រង់នឹងផ្តល់អ្វីដែលមានមហន្តរាយដល់យើងទេ? តើឱពុកម្តាយរបស់អ្នកនឹងធ្វើអ្វីខ្លះ?
3. ចូរសរសេរអំពីពេលមួយ ដែលអ្នកបានថ្លែងអំណរគុណដល់ព្រះវរបិតាសួគិ ចំពោះអ្វីដែលទ្រង់មិនបានប្រទានដល់អ្នក តាមអ្វី ដែលគំនិតអ្នកចង់បាន។ ចូរពន្យល់ថាហេតុអ្វី និងរបៀបអ្វី ដែលបទពិសោធន៍នោះ អាចជួយអ្នកនៅក្នុងការអធិដ្ឋាន និង សំណូមពររបស់អ្នកទៅថ្ងៃអនាគត។
4. ចេញពីអ្វី ដែលអ្នករៀននៅក្នុងនីហ្វៃទី3 18:20 គោលលទ្ធិ និងសេចក្តីសញ្ញា 50:28–29, 88:64–65 ចូរសង្ខេប ពីរបៀប ដែលព្រះវរបិតាសួគិរបស់យើងឆ្លើយតបចំពោះសំណូមពររបស់យើង។

ក៣ ចូរសរសេរសំនួររបស់អ្នក

ចូរសរសេរសំនួរសំខាន់ និងប្រកបដោយអត្ថន័យយ៉ាងតិចចំនួនបី ដែលមនុស្សតែងមានជារឿយៗ ដែលអាចឆ្លើយតបបាន នៅក្នុង នីហ្វៃទី 3 14:13–27។ សូមផ្តល់ចំលើយចេញពីព្រះគម្ពីរ។

នីហ្វៃទី3 15–16

ក្រិត្យវិន័យលោកម៉ូសេ និង "ចៀមដទៃ"

រហូតមកដល់ការយាងមកជួបរបស់ព្រះយេស៊ូវគ្រីស្ទ កុមារតូចឲសុចរិត នៃសាសន៍អ៊ីស្រាអែល ដែលរស់នៅក្នុងទ្វីបអាមេរិក បានរស់នៅក្នុងក្រិត្យវិន័យលោកម៉ូសេ។ នៅក្នុងនីហ្វៃទី3 15 ព្រះយេស៊ូវ បានបង្រៀនប្រជាជនថា ក្រិត្យវិន័យលោកម៉ូសេ ត្រូវបានសំរេចហើយនៅក្នុងទ្រង់។ នៅក្នុងជំពូកទី15–16 ព្រះយេស៊ូវ បានពន្យល់ថា ការយាងមកជួបរបស់ទ្រង់ជាមួយនឹងពួកគេ គឺជាការសំរេចនៃការព្យាករណ៍មួយ ដែលទ្រង់បានធ្វើនៅក្នុងជីវិតមតះ (សូមមើលយ៉ូហាន 10:16)។ ការពន្យល់របស់ទ្រង់ មានបញ្ជូលបន្ថែមទាំងការព្យាករណ៍ទាំងឡាយអំពីវង្សអ៊ីស្រាអែល។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 15

ទតមើលជុំវិញ (ខ.1)—ក្រឡេកមើលជុំវិញ

ឃើញថា (ខ.2)—ដឹងដោយឯកឯង គ្មានអ្នកណាប្រាប់

ក្រោល (ខ.17–21)—ហ្វូងដែលបានរៀបចំរួច

សម្តែង (ខ.23)—ធ្វើឱ្យដឹង

នីហ្វៃទី3 15:2–7—ការសំរេចនៃក្រិត្យវិន័យលោកម៉ូសេ

នៅពេលព្រះយេស៊ូវប្រកាសថា ក្រិត្យវិន័យលោកម៉ូសេ ត្រូវបាន "សំរេចហើយ" និង "បានចប់ហើយ" ទ្រង់មិនបានប្រាប់ថា គោលការណ៍ និងគោលលទ្ធិទាំងឡាយត្រូវបានចប់ហើយទេ ប៉ុន្តែជាងនោះទៅទៀត ការប្រារព្ធ និងពលិកម្ម ដែលបានបង្ហាញ ចំពោះដង្វាយធួនត្រូវបានបញ្ចប់ (សូមមើល អាលម៉ា34:13–14)។ អ្នកបានរៀនរួចហើយពីរបៀប ដែលគោលការណ៍ខ្លះៗ នៃក្រិត្យវិន័យ ត្រូវបានប្រគល់ទៅឱ្យលោកម៉ូសេ តាមពិតទៅក្រិត្យវិន័យនេះត្រូវបានបន្តនៅក្នុងច្បាប់ នៃដំណឹងល្អ (សូមមើល នីហ្វៃទី3 12:21–48 សូមមើលផងដែរនៅក្នុង នីហ្វៃទី3 24:25 ត និងស 59:5–14)។ ម្យ៉ាងវិញទៀត របៀប ដែលដំណឹង ល្អ អនុវត្តនៅក្រោមក្រិត្យវិន័យលោកម៉ូសេ ត្រូវបានមកដល់ទីបញ្ចប់ ប៉ុន្តែមិនមែនជាបទបញ្ញត្តិ គោលការណ៍ និងគោលលទ្ធិ នៃដំណឹងល្អសំខាន់ៗ ដែលមាននៅជារៀងរហូតនោះទេ។

នីហ្វៃទី3 16

ទោះជា (ខ.8)—ទោះជាយ៉ាងណាក៏ដោយ

ត្រូវវាយដំ និង. . . . ត្រូវរងទុក្ខ (ខ.9)—វាយ និងធ្វើទុក្ខដោយសារអ្នកដទៃ

ទីផ្សេលគ្មេះ និងទីដំនៀល (ខ.9)—និយាយអំពីមធ្យោបាយអាក្រក់

ការអរបោក (ខ.10)—ការអនុវត្តមិនស្មោះត្រង់

ការលាក់ពុត (ខ.10)—អំពើទុច្ចរិត

ឧបាយកលផ្នែកសង្ឃ (ខ.10)—ធ្វើការប្រកាស ដើម្បីរកលុយ និងដំកើងនរណាម្នាក់ (សូមមើលនីហ្វៃទី 26:29)

អំពើសហាយស្មន់ (ខ.10)—ប្រព្រឹត្តអំពើខាងផ្លូវភេទគ្មានសីលធម៌

អ្នកយាម (ខ.18)—នៅជំនាន់បូរាណ អ្នកយាមឈរនៅលើប៉មមើលសត្រូវ ឬអ្នកធ្វើដំណើរ (នៅក្នុងករណីនេះ អ្នកយាមទន្ទឹងមើលដំណឹងល្អ ដែលក្រុងស៊ីយ៉ូន ត្រូវបានបង្កើតឡើង)

លាតព្រះពាហុបរិសុទ្ធរបស់ទ្រង់ (ខ.20)—បង្ហាញអំណាចរបស់ទ្រង់

នីហ្វៃទី3 16:4–15—ពួកសាសន៍ដទៃ

ពាក្យថា *ពួកសាសន៍ដទៃ* មានន័យថា "ប្រជាជាតិ។" សំដៅទៅលើអ្នកទាំងឡាយណា ដែលមិនមែនជាវង្សអ៊ីស្រាអែល ឬអ្នក ដែលមិនជឿលើព្រះនៃអ៊ីស្រាអែល។ នៅពេលពាក្យនោះ ត្រូវបានប្រើនៅក្នុងព្រះគម្ពីរមរមន ពាក្យនេះចង់សំដៅទៅលើអ្នកទាំង ឡាយណាដែលមកពីប្រជាជាតិពួកសាសន៍ដទៃ ដែលជាប្រជាជាតិទាំងអស់ណា នៅខាងក្រៅទឹកដីអ៊ីស្រាអែល សូម្បីតែពួក គេមានឈាមជាពូជអំបូរនៃអ៊ីស្រាអែលក៏ដោយ (សូមមើលនីហ្វៃទី1 13:13–19)។

ការសិក្សាព្រះគម្ពីរ

ចូររង្វើសកម្មភាពពីរ នៃសកម្មភាព (ក–ឃ) នៅពេលអ្នកសិក្សានីហ្វៃទី3 15–16។

ក ចុះចំណែកឯក្រិត្យវិន័យលោកម៉ូសេវិញ?

1. សូមអានម៉ូសាយ 13:27–30 និងអាលម៉ា 25:15–16 និងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់នីហ្វៃទី3 15:2–7 រួចសង្ខេបនូវអ្វី ដែលពួកគេបង្រៀន អំពីក្រិត្យវិន័យ លោកម៉ូសេ។
2. ចូរសង្កេចពីអ្វី ដែលព្រះយេស៊ូវមានបន្ទូលអំពីក្រិត្យវិន័យលោកម៉ូសេ នៅក្នុងនីហ្វៃទី3 15:2–10។
3. ចូរពន្យល់ពីអ្វី ដែលអ្នកគិតថាព្រះយេស៊ូវ ចង់មានន័យ នៅក្នុងប្រយោគទីមួយ នៃនីហ្វៃទី3 15:9។

ខ ធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់

ឧបមាថា មានមនុស្សម្នាក់ មិនមែនជាសមាជិក នៃសាសនាចក្រសួរអ្នក ពីយ៉ូហាន 10:16 មានន័យដាយ៉ាងណា។

1. ចូរប្រើអ្វី ដែលអ្នករៀនចេញពីនីហ្វៃទី3 15–16 រួចសរសេរពីអ្វី ដែលអ្នកនឹងនិយាយអំពីមនុស្សម្នាក់នោះ។
2. តើអ្នកនឹងនិយាយអ្វីខ្លះ បើសិនជាអ្នក ត្រូវគេសួរថា "តើខ្ញុំអាចដឹងថា អ្វីដែលព្រះគម្ពីរមរមន បានទំនាយនោះ ជាការពិត បានដោយរបៀបណា?"

គ តើមេរៀនអំពីអ្វី?

1. យោងទៅតាមនីហ្វៃទី3 15:11–16:5 តើហេតុអ្វី បានជាសិស្សព្រះយេស៊ូវមិនទៅទីក្រុងយេរូសាឡិម ដើម្បីដឹងថា អ្នកណា គឺជា"ចៀមដទៃ" ដូច្នេះ?
2. តើព្រះអម្ចាស់បញ្ជាអ្វីខ្លះ ដើម្បីប្រាកដថា ចំណេះដឹងនេះនឹងមិនត្រូវបាត់បង់ទៅឡើយ?
3. យោបល់មេរៀនពីរ ដែលយើងអាចរៀនអំពីហេតុការណ៍នេះ។

ឃ ការព្យាករណ៍នឹងត្រូវបានសំរេច

នៅពេលព្រះគម្ពីរមរមនទំនាយអំពីពួកសាសន៍ដទៃ គឺសំដៅទៅលើមនុស្សគ្រប់រូប ដែលមិនមែនជាវង្សអ៊ីស្រាអែល ឬអ្នក ដែលមិនមែនមកពីដែនដីនៃអ៊ីស្រាអែល។ ទោះបីជាសមាជិកនៃសាសនាចក្រភាគច្រើនសព្វថ្ងៃនេះ គឺជាសមាជិកនៃវង្សអ៊ីស្រា អែល ដោយខ្សែស្រឡាយ ចំពោះប្រជាជននៅក្នុងព្រះគម្ពីរមរមន យើងបានចាត់ទុកថាជាពួកសាសន៍ដទៃ។

1. តើព្រះអម្ចាស់សន្យាថានឹងប្រទានដល់ពួកសាសន៍ដទៃ (ពួកយើង)អ្វីខ្លះ នៅក្នុងនីហ្វៃទី3 16:1–7? តើការព្យាករណ៍នេះ បានសំរេចឬទេ? បើបានសំរេច តើកើតឡើងដោយវិធីណា?
2. តើទ្រង់មានបន្ទូលថាអ្វីខ្លះ នឹងកើតឡើង បើពួកសាសន៍ដទៃ ទទួលតាមសំណើររបស់ទ្រង់ ហើយអ្វីនឹងកើតឡើង បើពួកគេ បដិសេធ? (សូមមើលខ 8–15)។ តើគស្តុតាងអ្វីខ្លះ ដែលអ្នកបានឃើញថាមានកើតឡើងនាបច្ចុប្បន្ននេះ?
3. តើព្រះអម្ចាស់សន្យានឹងពូជអំបូររបស់លីហៃអ្វីខ្លះ? (សូមមើលខ. 16)។

នីហ្វៃទី3 17

"សេចក្តីអំណររបស់យើង បានពោរពេញហើយ"

ប្រជាជនភាគច្រើន ដែលរស់នៅជំនាន់ព្រះយេស៊ូវក្នុងអំឡុងពេលនៃការបង្រៀនរបស់ទ្រង់នៅលើផែនដី មិនជឿថាទ្រង់ គឺជាព្រះ មែសុី ដែលបានសន្យាមកនោះទេ។ អ្នកទាំងឡាយណា ដែលបានឃើញព្រះអង្គសង្គ្រោះនៅក្នុងដែនដីបរិបូរណ៍ ជឿទៅលើទ្រង់ ថ្វាយបង្គំទ្រង់ និងស្តាប់ការបង្រៀនរបស់ទ្រង់ ពិព្រោះពួកគេជាសំណល់នៃពួកសុចរិត ដែលនៅរស់អំឡុងពេលនៃការបំផ្លិច បំផ្លាញ នៅពេលដែលទ្រង់ត្រូវរង្គាំង (សូមមើលនីហ្វៃទី3 10:9–14)។ នៅក្នុងនីហ្វៃទី3 17 ថ្ងៃដំបូងរបស់ពួកគេជាមួយទ្រង់កាន់តែខិត ទៅជិតដល់ពេលដែលត្រូវបែកគ្នាហើយ។ ចូរព្យាយាមនឹកគិតថាអ្នកនៅទីនោះ នៅពេលអ្នកអានដំពូកនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

3 នីហ្វៃ 17

ទ្រាំនៅ (ខ.5)—នៅ នៅតែ

ចិត្ត (ខ. 6–7)—អារម្មណ៍ខាងក្នុង

សេចក្តីអាណិតមេត្តា (ខ.6–7)—អារម្មណ៍នៃការអាណិតអាសូរ ស្រឡាញ់ និងសន្តានចិត្តល្អ

ខ្វិន (ខ. 7,9)—មនុស្សពិការ

គ (ខ. 7)—កំរើកដោយពិបាក ឬឈឺចាប់

បាក់ដៃបាក់ជើង (ខ. 7)—របួសដោយប្រការណាមួយ

ល្មមគ្រប់គ្រាន់ (ខ. 8)—គ្រប់គ្រាន់

អ្នកគ (ខ. 9)—មិនអាចនិយាយបាន

សុខភាពល្អ (ខ. 10)—ល្អ មានសុខភាព

យល់រឿង (ខ. 17)—ពិចារណា នឹកគិត

សូមឱ្យ (ខ. 19)—ប្រាប់ពួកគេឱ្យ

បំរើ (ខ. 24)—បង្រៀន ប្រទានពរ បំរើ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពមួយ នៃសកម្មភាព (ក–គ) នៅពេលអ្នកសិក្សានីហ្វៃទី3 17។

ក គំរូសំរាប់ការរៀនសូត្រ

1. តើព្រះយេស៊ូវសុំឱ្យពួកសាសន៍នីហ្វៃធ្វើអ្វីខ្លះ នៅក្នុងនីហ្វៃទី 17:1–3 ដើម្បីជួយពួកគេឱ្យយល់កាន់តែប្រសើរអំពីការបង្រៀន របស់ទ្រង់?
2. ចូរធ្វើបញ្ជីមួយអំពីអ្វី ដែលអ្នកអាចធ្វើ ដើម្បីអនុវត្តគោលការណ៍ សំរាប់ការរៀនសូត្រដូចគ្នាទាំងនោះ ទៅក្នុងការសិក្សាដំណឹង ល្អផ្ទាល់ខ្លួន។

ខ បើសិនជាអ្នកនៅទីនោះ

នៅពេលអ្នកពិចារណាអំពីអ្វីទាំងអស់ ដែលបានកើតឡើងនៅនីហ្វៃទី3 17 ចូរសរសេរអំពីព្រឹត្តិការណ៍ជាក់លាក់ណាមួយ ដែលអ្នក ចូលចិត្តមើល ឬចូលរួមនោះ ព្រមទាំងពន្យល់ពីមូលហេតុ។

គ រៀនអំពីនិស្ស័យរបស់ព្រះយេស៊ូវគ្រីស្ទ

ចូរប្រៀបធៀបអ្វី ដែលព្រះយេស៊ូវបានធ្វើនៅក្នុងនីហ្វៃទី3 17:14 ជាមួយនឹងអ្វី ដែលបានកើតឡើងនៅខ. 15–24 ហើយឆ្លើយ សំនួរដូចខាងក្រោមនេះ៖

1. តើហេតុអ្វីបានជាព្រះយេស៊ូវមានកង្វល់នៅក្នុងចិត្ត នៅខ 14?
2. តើហេតុអ្វីទ្រង់ព្រះកន្សែងនៅ ខ 21–23?
3. តើព្រឹត្តិការណ៍ទាំងនោះបង្រៀនយើងអ្វីខ្លះ អំពីព្រះយេស៊ូវ?
4. តើការដឹងអំពីអារម្មណ៍របស់ព្រះយេស៊ូវជាមួយយើង ជួយឱ្យអ្នកដែលមានបាបប្រែចិត្តបានដោយរបៀបណា?

នីហ្វៃទី3 18

ព្រះអង្គសង្គ្រោះណែនាំអំពីពិធីប្រសិទ្ធិពរនំបុ័ង និងទឹក

ក្នុងការស្ថិតនៅក្នុងវត្តមានរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាការអស្ចារ្យ និងជាបទពិសោធន៍ខាងវិញ្ញាណ សំរាប់ប្រជាជននៅក្នុងដែនដី បរិបូរណ៍។ វាជាការងាយស្រួលដើម្បីយល់ថាហេតុអ្វីពួកគេមិនចង់ឱ្យទ្រង់យាងទៅ (សូមមើលនីហ្វៃទី3 17:5)។ មុនពេល ទ្រង់ចាកចេញពីពួកគេ ទោះជាយ៉ាងណាក៏ដោយទ្រង់ បានបង្រៀនពួកគេ ពីរបៀបដែលពួកគេ អាចបានព្រះវិញ្ញាណរបស់ទ្រង់ គង់នៅជាមួយនឹងពួកគេជាដរាប។ ព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងនីហ្វៃទី3 18 អំពីការទទួលព្រះវិញ្ញាណរបស់ទ្រង់ គឺអនុវត្តចំពោះពួកយើងសព្វថ្ងៃនេះ ដូចជាចំពោះប្រជាជននៅក្នុងព្រះគម្ពីរមរមន។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 18

ជាទីបន្ទាល់ (ខ. 10–11)—ធ្វើទីបន្ទាល់ដោយរបៀបជាក់លាក់មួយ

ខ្លាចក្រែង (ខ. 15, 18)—ព្រោះខ្លាចថា

រែងអ្នករាល់គ្នាដូចជាស្រូវអញ្ចឹង (ខ. 18)—មានអ្នកនៅក្នុងអំណាចរបស់វា

ទទួលទានសាច់ និងលោហិត (ខ. 28–30)—ទទួលទាននំបុ័ង និងទឹក

ចែកដល់ (ខ. 28,30, 32)—បំរើប្រទានពរ

ទោស (ខ. 29)—ឈប់រីកចំរើនខាងវិញ្ញាណ

ដោយអស់ពីដួងចិត្ត (ខ. 32)—ដំណោះស្រាយផ្ទាល់ខ្លួន ដើម្បីគោរពប្រតិបត្តិ

ការកាត់ទោស (ខ. 33)—ទារុណកម្ម

នីហ្វៃទី3 18:6–14—ការប្រទានពរនំបុ័ង និងទឹក

អែលឌើរ ជែហ្វ្រី អរ ហូលែន បានបង្រៀនថា៖ "គ្រប់ពិធីការ នៃដំណឹងល្អទាំងអស់ សង្កត់ធ្ងន់ទៅលើដង្វាយធួន នៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ តាមវិធីមួយ ឬផ្សេងទៀត ហើយនេះពិតជាមូលហេតុ ដែលថាហេតុអ្វីពិធីការពិសេសនេះ ប្រារព្ធឡើងព្រមទាំង និមិត្តសញ្ញា និងនិមិត្តរូបទាំងឡាយ ដែលមានធ្វើឱ្យយើងកាន់តែងាយស្រួល និងដដែលៗច្រើនជាងពិធីការផ្សេងៗទៀតនៅក្នុង ជីវិតរបស់យើង។ ពិធីការនេះ យើងបានហៅថាជាពិធីការ '*ពិសិដ្ឋបំផុតបរិសុទ្ធបំផុត* ជាងគ្រប់ការប្រជុំទាំងឡាយ នៃសាសនា ចក្រ។' (Joseph Fielding Smith, *Doctrine of Salvation*, ប្រមូលផ្ដុំដោយ Bruce R. McConkie, វ៉ុលទី3 [Salt Lake City: Bookcraft 1954–56], 2:340)" (នៅក្នុង Conference Report ខែកញ្ញា–តុលា ឆ្នាំ1995, 88–89 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1995, 67–68)។

អែលឌើរ មែលវីន ជេ បាលលើត ជាសមាជិកនៃក្រុមសាវកទាំងដប់ពីរនាក់ មានប្រសាសន៍ថា៖

"ក្នុងចំណោមពួកយើង តើនរណាដែលមិនទទួលស្នាមរបួស ខាងវិញ្ញាណ តាមរយៈ ពាក្យសំដី គំនិត និងទង្វើរ ចេញពីថ្ងៃឈប់ សំរាកមួយ ទៅថ្ងៃឈប់សំរាកមួយទៀតឬទេ? យើងធ្វើកិច្ចការទាំងឡាយដែលយើងមានវិប្បដិសារី ហើយមានបំណងដើម្បីទទួល ការអភ័យទោស។ . . . ប្រសិនបើមានអារម្មណ៍ណាមួយនៅក្នុងព្រលឹងរបស់យើង ដែលយើងចង់ទទួលបាននូវការអភ័យទោសខណៈ នេះវិធីសាស្ត្រដើម្បីទទួលការអភ័យទោស គឺមិនធ្វើតាមរយៈការទទួលបុណ្យជ្រមុជទឹកម្ដងទៀតនោះទេ . . . ប៉ុន្តែត្រូវប្រែ ចិត្តពីអំពើបាបរបស់យើង ហើយទៅរកអ្នកទាំងឡាយណា ដែលយើងបានធ្វើបាប ឬប្រព្រឹត្តខុសជាមួយនោះ ដើម្បីទទួលបានការ អភ័យទោសពីពួកគេ ហើយបន្ទាប់មកទៅរកកន្លែងធ្វើពិធីប្រសិទ្ធិពរនំបុ័ង និងទឹក បើសិនជាយើងប្រែចិត្តដោយស្មោះស្ម័គ្រ ហើយដាក់ខ្លួនចូលទៅក្នុងកាលៈទេសៈត្រឹមត្រូវ នោះយើងនឹងទទួលបានការអភ័យទោស ហើយការព្យាបាលខាងវិញ្ញាណនឹងមានមក ដល់ព្រលឹងរបស់យើង . . .។

"ខ្ញុំជាសាក្សីម្នាក់ ថាមានព្រះវិញ្ញាណមកចូលរួមនៅក្នុងការធ្វើពិធីប្រសិទ្ធិពរនំបុ័ង និងទឹក ដែលផ្ដល់ភាពកក់ក្ដៅក្នុងព្រលឹង តាំងពី ក្បាល រហូតដល់ចុងជើង អ្នកនឹងទទួលអារម្មណ៍ថា ដំបៅខាងវិញ្ញាណ ត្រូវបានព្យាបាល ហើយបន្ទុកត្រូវបានសំរាលឡើង។ ការ កំសាន្តចិត្ត និងសុភមង្គល មាននៅក្នុងព្រលឹងវិញ្ញាណ ដែលសក្តិសម ហើយមានបំណងដ៏ពិត ដើម្បីទទួលទានអាហារខាងវិញ្ញាណនេះ" (*Melvin J. Ballard: Crusader for Righteousness* [ឆ្នាំ1966], 132–33)។

នីហ្វៃទី3 18:28–29—តើនៅពេលណា យើងមានភាពសក្តិសម ដើម្បីទទួលទាននំប៉ុង និងទឹក?

អែលឌើរចន អេច ហ្ស្ពូចបើ៉ជ សមាជិកនៃក្រុមចិត្តសិប បានបង្រៀនថាះ "បើសិនជាយើងមានបំណងចង់រីកចំរើន (នោះត្រូវតែ ធ្វើការប្រែចិត្ត) ហើយវាមិនស្ថិតនៅក្រោមការដាក់កម្រិតរបស់បញ្ជិតភាពទេ ហើយ តាមគំនិតខ្ញុំ យើងមានភាពសក្តិសម។ ទោះ ជាយ៉ាងណាក៏ដោយ បើយើងគ្មានបំណងចង់រីកចំរើនទេ បើយើងគ្មានចេតនា ដើម្បីដើរតាមការណែនាំនៃព្រះវិញ្ញាណបរិសុទ្ធទេ យើងត្រូវតែសួរថាះ តើយើងមានភាពសក្តិសមដើម្បីទទួលទាន ឬតើយើងចំអកដល់គោលបំណងទាំងអស់ នៃពិធី ប្រសិទ្ធិពរនំប៉ុង និងទឹកឬទេ?" (នៅក្នុង Conference Report ខែមេសា ឆ្នាំ1989, 50 ឬ *Ensign* ខែឧសភា ឆ្នាំ1989, 38)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងសកម្មភាព ខ ឬគ នៅពេលអ្នកសិក្សានីហ្ចៃទី3 18។

ក ជម្រៅនៃការយល់ដឹងរបស់អ្នក

1. ចូរសរសេរសេចក្តីពិតសំខាន់ចំនួនប្រាំ ដែលយើងបានរៀនអំពីពិធីការប្រសិទ្ធិពរនំប៉ុង និងទឹកមកពីអ្វី ដែលព្រះយេស៊ូវបាន បង្រៀននៅក្នុងនីហ្ចៃទី3 18:1–14, 28–32។
2. ចូរធ្វើការប្រៀបធៀបអំពីអ្វី ដែលព្រះយេស៊ូវមានបន្ទូលអំពីពិធីប្រសិទ្ធិពរនំប៉ុង និងទឹកនៅក្នុងនីហ្ចៃទី3 18:12–13 ទៅនឹង អ្វីដែលទ្រង់មានបន្ទូលអំពីពិធីបុណ្យជ្រមុជទឹកនៅក្នុងនីហ្ចៃទី3 11:38–40។ តើមានអ្វីខ្លះ ដែលបង្ហាញអំពីសារៈសំខាន់ នៃពិធី ប្រសិទ្ធិពរនំប៉ុង និងទឹក?
3. ចូរអាននីហ្ចៃទី3 18:1–14, 28–32 និងអានពាក្យស្រង់អំពីពិធីប្រសិទ្ធិពរនំប៉ុង និងទឹកមកពីវគ្ត "ការយល់ដឹងអំពីព្រះគម្ពីរ" រួចសរសេរផែនការណ៍មួយ ដែលអ្នកមានបំណងចង់ធ្វើ ដើម្បីធ្វើឱ្យពិធីប្រសិទ្ធិពរនំប៉ុង និងទឹក ក្លាយជាផ្នែកមួយកាន់តែមាន អត្តន័យយ៉ាងខ្លាំង នៅក្នុងជីវិតរបស់អ្នក។

ខ តើសំនួរគឺជាអ្វី?

ចូរសរសេរសំនួរចំនួនប្រាំអំពីការអធិស្ឋាន ដែលអាចឆ្លើយ មកពីនីហ្ចៃទី3 18:15–23។ បន្ទាប់ពីសំនួរនីមួយៗ ចូរសរសេរ ចំលើយ របស់អ្នក ព្រមជាមួយនឹងខគម្ពីរ ដែលមានចំលើយនៅក្នុងនោះ។

គ តើវាធ្វើទៅបានដោយរបៀបណា?

នៅក្នុងនីហ្ចៃទី3 12:14–16 ព្រះយេស៊ូវ ប្រាប់ដល់អ្នកដើរតាមទ្រង់ថា ពួកគេត្រូវធ្វើជា "ពន្លឺនៃប្រជាជននេះ" ហើយចូរឱ្យពន្លឺ របស់អ្នករាល់គ្នា បានភ្លឺនៅមុខប្រជាជននេះ។ គោលលទ្ធិនេះ បានអនុវត្តដោយស្មើភាពគ្នា ចំពោះយើងនៅសព្វថ្ងៃនេះដែរ។ យោងទៅតាមនីហ្ចៃទី3 18:22–25 តើពន្លឺអ្វី ដែលយើងត្រូវលើកឡើង? តើយើងលើកពន្លឺនេះឡើងដោយរបៀបណា?

នីហ្ចៃទី3 19

ព្រះយេស៊ូវអធិស្ឋានជាមួយ និងសំរាប់ប្រជាជន

បន្ទាប់ពីព្រឹត្តិការណ៍នៅក្នុងនីហ្ចៃទី3 18 ព្រះយេស៊ូវគ្រីស្ទ ចាកចេញពីប្រជាជន ហើយយាងទៅស្ថានសួគិវិញ។ ជំពូក 19 មានប្រាប់ យើងអំពីអ្វី ដែលប្រជាជនបានធ្វើពេញមួយយប់ និងនៅថ្ងៃបន្ទាប់ នៅពេលព្រះយេស៊ូវយាងត្រលប់មកវិញ។ នៅចុង ជំពូកនេះ គឺជាទីបន្ទាល់របស់ព្រះយេស៊ូវ អំពីកំលាំង នៃសេចក្តីជំនឿ របស់ពួកគេ។ នៅពេលអ្នកអាន ចូររកមើលអ្វី ដែលពួកគេ បានធ្វើ ដែលបានឆ្លុះបង្ហាញពីសេចក្តីជំនឿ របស់ពួកគេ និងពិចារណាាមើលថា តើអ្នកអាចធ្វើតាមគំរូរបស់គេ បានដោយរបៀបណា។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្ចៃទី3 19

បែកចេញពីគ្នា (ខ.1)—បែកពីគ្នា

សម្លេងអ្វីអរពាសពេញ (ខ. 2–3)—និយាយត្រប់ទឹកន្លែងទាំងអស់

ខុសពី (ខ. 8)—ផ្សេងពីគ្នា

ឈប់ (ខ. 24, 30)—ឈប់

ពួកគេមិនបានបន្ថែមពាក្យអ្វីឡើយ (ខ. 24)—ពួកគេអធិស្ឋានតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ

ព្រះភក្ត្រ (ខ. 25)—អាការៈខាងក្រៅ មុខ

នីហ្ចៃទី3 19:11–13—តើប្រជាជនទាំងនេះមិនទាន់រៀបចំខ្លួនរួចស្រេច ដើម្បីទទួលបុណ្យជ្រមុជទឹកឬអី?

ប្រធានយ៉ូសែប ហ្ចីលឌីង ស្មីធ ជាប្រធាន នៃក្រុមសាវកទាំងដប់ពីរនាក់ បានបង្រៀនថាះ

"ទោះបីជា ពួកគេបានទទួលបុណ្យទឹកពីមុនសំរាប់ការផ្តាច់បាបរបស់ពួកគេក៏ដោយ. . . . ព្រះអង្គសង្គ្រោះ បានបញ្ជាដល់នីហ្ចៃ និង ប្រជាជន ឱ្យធ្វើបុណ្យជ្រមុជទឹកម្តងទៀត ពីព្រោះទ្រង់បានរៀបចំសាសនាចក្រថ្មីមួយទៀត នៅក្រោមដំណឹងល្អ។ កាលពីមុន សាសនាចក្រត្រូវបានរៀបចំឡើងនៅក្រោមក្រិត្សវិន័យ [លោកម៉ូសេ]។

"ចំពោះមូលហេតុដូចគ្នានេះ យ៉ូសែប ស្មីធ និងអ្នកទាំងឡាយ ដែលបានទទួលបុណ្យជ្រមុជទឹកអំឡុងពេលមុនថ្ងៃទី6 ខែមេសា ឆ្នាំ1830 ត្រូវធ្វើបុណ្យជ្រមុជទឹកម្តងទៀត នៅថ្ងៃនៃការរៀបចំសាសនាចក្រ" *Doctrines of Salvation,* ប្រមូលផ្ទុំដោយ Bruce R McConkie រ៉ុលទី3 [ឆ្នាំ1954–56], 2:336)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ខ និងសកម្មភាព ក ឬគ នៅពេលអ្នកសិក្សានីហ្ចៃទី3 19។

ក ការទទួលព្រះវិញ្ញាណបរិសុទ្ធ

បន្ទាប់ពីយើងទទួលបុណ្យជ្រមុជទឹក មនុស្ស ដែលធ្វើការបញ្ជាក់ដល់យើង នឹងប្រទានពរដល់យើង ដើម្បី "ទទួលព្រះវិញ្ញាណ បរិសុទ្ធ។" ឬដោយពាក្យម្យ៉ាងទៀតថា អំណាចនៃបញ្ជិតភាព អាចប្រគល់ ឬប្រទានអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែវាអាស្រ័យ លើទៅយើង ដើម្បីទទួលព្រះវិញ្ញាណបរិសុទ្ធនោះតែប៉ុណ្ណោះ។

1. តើពួកសិស្សធ្វើអ្វីខ្លះ នៅក្នុងនីហ្ចៃទី3 19:8–14 ដែលនាំឱ្យពួកគេមានបទពិសោធន៍ នៃការទទួលព្រះវិញ្ញាណបរិសុទ្ធ?
2. តើអ្នកអាចធ្វើតាមគំរូរបស់សិស្សទាំងអស់នោះបានដោយរបៀបណា ដើម្បីមានអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងជីវិត របស់អ្នកឱ្យបានកាន់តែញឹកញាប់ឡើង? នៅពេលអ្នកឆ្លើយ ចូរធ្វើការពិចារណាផងដែរអំពីអ្វី ដែលអ្នករៀននៅក្នុងនីហ្ចៃទី3 18។

២ ការអធិស្ឋានរបស់ព្រះយេស៊ូវ

1. ចូរធ្វើបញ្ជីអំពីអ្វីដែលព្រះយេស៊ូវមានបន្ទូលនៅក្នុងការអធិស្ឋានរបស់ទ្រង់ ពីអ្នកទាំងឡាយណា ដែលជឿដល់ទ្រង់ (សូមមើលនីហ្វៃទី3 19:19–23, 27–29)។
2. តើអ្វីខ្លះ ដែលកន្ត្រាក់អារម្មណ៍របស់អ្នកបំផុត អំពីអ្វី ដែលព្រះយេស៊ូវបានអធិស្ឋាននោះ?
3. តើការផ្លាស់ប្តូរអ្វីខ្លះអាចនឹងកើតឡើងនៅក្នុងជីវិតរបស់អ្នក ដែលជាប្រចាំថ្ងៃអ្នកដឹងថា ព្រះអង្គសង្គ្រោះអធិស្ឋានសំរាប់អ្នក?

៣ គំរូនៃសេចក្តីជំនឿ

នៅក្នុងនីហ្វៃទី3 19:35 ព្រះយេស៊ូវមានបន្ទូលថា សិស្ស បានបង្ហាញពី "សេចក្តីជំនឿដ៏អស្ចារ្យ។" ចូរសរសេរពីអ្វី ដែលអ្នកគិតថា គឺជាគំរូ នៃសេចក្តីជំនឿសំខាន់ពីរ នៅក្នុងនីហ្វៃទី3 19។

នៅក្នុងនីហ្វៃទី3 20–22 គឺជាការព្យាករណ៍អំពីវង្សអ៊ីស្រាអែល និងសាសន៍ដទៃ និងពីរបៀបដែលព្រះអម្ចាស់ បំពេញតាម សេចក្តីសញ្ញាទាំងឡាយ ដែលទ្រង់ធ្វើជាមួយកូនចៅរបស់ទ្រង់។ កូនចៅរបស់អស់អ្នកដែលទ្រង់បានធ្វើសេចក្តី សញ្ញាជាមួយត្រូវ បានហៅថា "កូនចៅក្នុងសេចក្តីសញ្ញា" ហើយមានសិទ្ធិទទួលពរជ័យជាក់លាក់ ដែលមានទំនាក់ទំនងនឹងអ្នកធ្វើសេក្តីសញ្ញាទាំង នោះ បើពួកគេស្មោះត្រង់។ នៅទីបញ្ចប់ទោះយ៉ាងណាក្តី សេចក្តីសញ្ញា របស់ព្រះអម្ចាស់ គឺមានសំរាប់ រាល់កូនចៅទាំងអស់ នៃព្រះវរបិតាសួគិ៍ នឹងមានឱកាស ដើម្បីក្លាយទៅជាផ្នែកមួយនៃសេចក្តីសញ្ញារបស់ត្រួសារ ហើយទទួល សេចក្តីសង្គ្រោះ និងការលើកតម្កើង។ ការបង្រៀននៅក្នុងជំពូកទាំងបីនេះ គឺជាទីបន្ទាល់មកពីព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ថា ដល់ ពេល ទ្រង់នឹងសំរេចរាល់ផ្នែកទាំងអស់នៃសេចក្តីសញ្ញាដ៏អស្ចារ្យនេះ ទាំងវង្សអ៊ីស្រាអែល និងសាសន៍ដទៃ—ម្យ៉ាងទៀត សំរាប់ត្រួសាររបស់ព្រះទាំងមូល។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 20

សំណល់ (ខ. 10, 13, 16)—ផ្នែកដែលនៅសល់

មរតក (ខ. 14, 29, 33, 46)—ទ្រព្យសម្បត្តិ (ជារឿយៗវាសំដៅទៅលើអ្វី ដែលប្រគល់មកពីឱពុកម្តាយ ឬជីដូនជីតាដទៃ ទៀត)

ជាន់ល្លីនៅក្រោមជើង (ខ. 16)—ដើរពីលើ

កណ្តាប់ស្រូវ (ខ. 18)—ដើមស្រូវចងផ្តុំគ្នា

ជង្រុក (ខ. 18)—ការបែនស្រូវដាក់ក្នុងជង្រុក

យើងនឹងធ្វើឱ្យស្មែងរបស់អ្នករាល់គ្នាទៅដូចដែក ហើយយើងនឹងធ្វើឱ្យក្រចករបស់អ្នករាល់គ្នាទៅដូចលង្ហិន (ខ. 19)—ខ្ញុំនឹងធ្វើ ឱ្យអ្នកខ្លាំងឡើងនៅថ្ងៃចុងក្រោយ។

ថ្វាយផលប្រយោជន៍ (ខ. 19)—ធ្វើឱ្យទ្រព្យរបស់ពួកគេពិសិដ្ឋ ដោយការឧទ្ទិស

ទាំងត្រួសារ (ខ. 25, 27)—ក្រុមត្រួសារ

រំពាត់ (ខ. 28)—ការវាយមួយ (និមិត្តរូបនៃការសាកល្បង និងបញ្ហា)

បានលាតព្រះពាហុដ៏បរិសុទ្ធរបស់ទ្រង់ (ខ. 35)—បង្ហាញពីអំណាចរបស់ទ្រង់

មិនកាត់ស្បែក (ខ. 36)—អ្នកទាំងឡាយណា ដែលមិនធ្វើសេចក្តីសញ្ញាជាមួយព្រះអម្ចាស់

ពុំបានអ្វី (ខ. 38)—គ្មានតម្លៃអ្វីសោះ

ពួកអ្នក ដែលលើកយកត្រៀងព្រះអម្ចាស់អើយ (ខ. 41)—ធ្វើកិច្ចការរបស់ព្រះអម្ចាស់, យកតាមនូវអ្វីដែលពិសិដ្ឋ

នៅពីខាងក្រោយ (ខ. 42)—ការការពារ

សរសើរ (ខ. 43)—ដំកើង

ទឹកមុខ (ខ. 44)—អាការះខាងក្រៅរូបភាព

ប្រែប្រួល (ខ. 44)—ខូចខាត ខូចធ្វើឱ្យប្រឡាក់

នីហ្វៃទី3 21

ខ្ចាត់ព្រាត់ ត្រូវខ្ចាត់ព្រាត់ (ខ. 1, 26–27)—ការខ្ចាត់ព្រាត់ ខ្ចាត់ខ្ចាយ

ធ្វើឱ្យកើតឡើង (ខ. 5)—ធ្វើ

ទតឃើញ (ខ. 6)—ក្លាយទៅជាចំបាច់សំរាប់

ត្រូទាយ (ខ. 16)—មនុស្សដែលអះអាងថាប្រាប់ពីអនាគត ឬធ្វើអព្ភូហេតុផ្សេងៗ ប៉ុន្តែមិនមែនមកពីព្រះទេ

ដើមឈើ (ខ. 18)—កន្លែងដែលមនុស្សថ្វាយបង្ស្ហំរបសំណាក នៅជំនាន់ព្រះគម្ពីរសញ្ញាចាស់

ឧបាយកលផ្នែកសង្ស (ខ. 19)—ធ្វើការប្រកាសដើម្បីរកលុយ និងការសរសើរ (សូមមើលនីហ្វៃទី2 26:29)

ការសងសឹក (ខ. 21)—ធ្វើឱ្យយុត្តិធមិ ដោយភាពកាចសាហាវ ទារុណកម្ម

នីហ្វៃទី3 21:6—សាសន៍ដទៃ អាចបានរាប់ទុកនៅចំណោមរាស្ត្រយើង ឱវង្សអ៊ីស្រាអែល

ប្រធានយ៉ូសែប ហ្ចីលឌីង ស្មីធ បានបង្រៀនថាះ "មនុស្សត្រប់រូប ដែលរើសយកដំណឹងល្អ ក្លាយទៅជាវង្សអ៊ីស្រាអែល។ ម្យ៉ាងទៀត ពួកគេក្លាយទៅជាសមាជិក នៃពួជជំរើស ឬកូនចៅរបស់អ័ប្រាហាំតាមរយះអ៊ីសាក និងយ៉ាកុប ដែលសេចក្តីសន្យាត្រូវបានធ្វើឡើង មកនោះ" (*Doctrines of Salvation* 3:246 សូមមើលផងដែរនៅនីហ្វៃទី2 30:1–2)។

នីហ្វៃទី3 21:22–25—(សូមមើលផងដែរនៅនីហ្វៃទី3 20:22)—ក្រុងយេរូសាឡិមថ្មី

ទីក្រុងយេរូសាឡិមថ្មី នឹងសង់ឡើងនៅក្នុងឃុំចាកសុនខោទី រដ្ឋមិសស្សរី ហើយនឹងត្រូវបានហៅថាទីក្រុងស៊ីយ៉ូន (សូមមើល ត និង ស 45:64–68, 57:1–3 ម៉ូសេ 7:62)។

នីហ្វៃទី3 22

ស្ត្រីអារ (ខ. 1)—ស្ត្រីដែលមិនអាចមានកូន

ឈីចាប់នឹងសំរាល (ខ. 1)—ឈីចាប់ពេលសំរាលកូន

បង់ខ្លួននៅតែឯង (ខ.1, 3)—តែម្នាក់ឯង ឱ្យនៅម្នាក់ឯង ទទេ ចោះបង់ចោល

ត្មះតិះដៀល (ខ. 4)—ខ្មាស់អៀន និងអាម៉ាស់មុខចំពោះអំពើបាបដែលបានធ្វើមកពីមុន

ត្បូងកណ្ដៀង, ត្បូងទទឹម, ត្បូងបានកេត (ខ. 11–12)—ត្បូង និងថ្មមានតម្លៃ

ជាងដែក (ខ. 16)—ជាងដែក (ជាងដែលធ្វើលោហៈទៅជាឧបករណ៍ដែលអាចប្រើប្រាស់បាន)

នីហ្វៃទី3 22:2—សំពត់ត្រលាស ខ្សែ ចំរឹង

អេសាយ ប្រៀបធៀបវង្សអ៊ីស្រាអែល ទៅនឹងត្រសាល។ ខ្សែកាន់តែវែង និងសំពត់ត្រសាលនិងចំរឹងកាន់តែរឹងមាំ នោះត្រសាល នឹងកាន់តែធំទៅតាមនោះ។



ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព(ក–ឃ)ខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី3 20–22។

ក ការប្រមូលផ្តុំសាសន៍អ៊ីស្រាអែល

ការប្រមូលផ្តុំសាសន៍អ៊ីស្រាអែល គឺមិនគ្រាន់តែសំរាប់ប្រជាជនជនជាតិទៃ ពីកន្លែងផ្សេងៗនោះទេ តែវាពាក់ព័ន្ធនឹងយើង និងសម័យ របស់យើង។ ចូរសិក្សានីហ្វៃទី3 20:13, 18–19, 29–33, 21:1, 20–28, 22:13–14, 17 ហើយធ្វើបញ្ជីពីអ្វី ដែលព្រះ អម្ចាស់ មានបន្ទូលអំពីមូលហេតុ ដែលទ្រង់ប្រមូលសាសន៍អ៊ីស្រាអែល និងអ្វីនឹងកើតឡើងនៅពេលទ្រង់បានធ្វើនោះ។

ខ ពរជ័យមកពីព្រះអម្ចាស់

1. យោងទៅតាមនីហ្វៃទី3 20:25–26 តើរបៀបមួយ នៃរបៀបទាំងឡាយ ដែលព្រះអម្ចាស់ បានប្រទានពរ និងបន្តប្រទានពរ ដល់ “កូនចៅនៃសេចក្តីសញ្ញា” ជាអ្វី?
2. យោងទៅតាមនីហ្វៃទី3 20:27 តើព្រះអម្ចាស់ប្រទានពរដល់ប្រជាជាតិសាសន៍ដទៃតាមវិធីណាខ្លះ?
3. តើពរជ័យទាំងពីរនោះ បានជួយអ្នកនៅក្នុងជីវិតយ៉ាងដូចម្តេចខ្លះ? (សូមមើលការណែនាំចំពោះនីហ្វៃទី3 20–22 និងវគ្គ “ការ យល់ដឹងអំពីព្រះគម្ពីរ” សំរាប់ជាជំនួយ បើសិនជាត្រូវការនោះ។)

គ សារលិខិតមួយសំរាប់ប្រជាជាតិសាសន៍ដទៃ

1. តាមពាក្យសំដីរបស់អ្នក ចូរពន្យល់ថា តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ នៅក្នុងនីហ្វៃទី3 21:14–21 អំពីអ្វី ដែលនឹងកើតឡើង បើពួកសាសន៍ដទៃមិនប្រែចិត្ត?ចូរប្រើឧទាហរណ៍នៅសម័យឥឡូវនេះ ពីអ្វីដែលបាននិយាយនោះ។
2. តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ នៅក្នុងនីហ្វៃទី3 21:22–25 អំពីសាសន៍ដទៃ ដែលប្រែចិត្ត ហើយត្រូវបានប្រមូលផ្តុំ ទៅកាន់យេរូសាឡិមថ្មី?

ឃ ពាក្យប្រដូចរបស់លោកអេសាយ

នៅក្នុងនីហ្វៃទី3 22 ព្រះអង្គសង្គ្រោះ ស្រង់ពាក្យរបស់អេសាយ 54 ដែលគឺជាទំបន្ទាល់ដែលអាចបំផុសគំនិតពីសេចក្តីស្រឡាញ់ របស់ព្រះអម្ចាស់ចំពោះប្រជាជនរបស់ទ្រង់ នៅពេលទ្រង់បំពេញតាមសេចក្តីសញ្ញារបស់ទ្រង់អំពីការប្រមូលផ្តុំពួកគេ ហើយចូល ទៅក្នុងវត្តមាននៃព្រះ។

1. ទូទាំងបទគម្ពីរ ព្រះអម្ចាស់ជារឿយៗ ធ្វើការប្រៀបធៀបទំនាក់ទំនង នៃសេចក្តីសញ្ញារបស់ទ្រង់ និងសាសនាចក្រ ទៅនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍។ ទ្រង់គឺជាស្វាមី ហើយសាសនាចក្រគឺជាភរិយា។ ចូរពិចារណាអំពីគុណសម្បត្តិខ្លះៗ របស់ព្រះអម្ចាស់ក្នុងការធ្វើជាស្វាមីល្អម្នាក់ចំពោះសាសនាចក្ររបស់ទ្រង់ មានដូចជាធ្វើជាគំរូដ៏សុចរិតមួយ ហើយផ្តល់សេចក្តី ស្រឡាញ់ តំរូវការខាងសម្ភារៈ ការកំសាន្តចិត្ត និងការការពារចំពោះគ្រួសារ។ ចំពោះការទទួលខុសត្រូវនីមួយៗទាំងនេះ អាចស្វែង រកថាកំណុំយ៉ាងតិចឱ្យបានមួយចេញពីនីហ្វៃទី3 22 ដែលបង្ហាញពីរបៀបព្រះអម្ចាស់ គឺជា “ស្វាមី”ដ៏ល្អឥតខ្ចោះ ចំពោះសាសនា ចក្រ។
2. តើសារលិខិតនីហ្វៃទី3 22អាចជួយកំសាន្តចិត្តដល់អ្នកផ្លាស់សាសនាថ្មីម្នាក់បានដោយរបៀបណា? តើយើងអាចប្រើអ្វី ដែលព្រះអម្ចាស់មានបន្ទូលនៅក្នុងនីហ្វៃទី3 22 ដើម្បីជួយយើងឱ្យយកចិត្តទុកដាក់ចំពោះអ្នកផ្លាស់សាសនាថ្មីឲ្យដូចម្តេចខ្លះ?

តើអ្នកផ្លាប់មានគំនិត ឬបទពិសោធន៍ ដែលអ្នកចង់នៅចងចាំឬទេ? តើអ្នកបានសរសេរគំនិត ឬបទពិសោធន៍នោះទុក ដូច្នេះអ្នក អាចចងចាំបានល្អឬទេ? តើអ្នកផ្លាប់គិតដែរឬទេថា បើអ្នកមិនរក្សាទុកបញ្ជី នៃបទពិសោធន៍ និងគំនិតទាំងនោះ ការចងចាំអំពី រឿងទាំងឡាយនឹងបាត់រលត់ទៅ និងផ្លាស់ប្តូរ? សូមស្វែងរកមើលពីរបៀប ដែលព្រះយេស៊ូវបង្រៀនអំពីគោលការណ៍របស់ទ្រង់ ទៅដល់ពួកសាសន៍នីហ្វៃ នៅក្នុងនីហ្វៃទី3 23។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 23

ដោយព្យាយាម (ខ. 1)—ដោយខ្នាប់ខ្នួន និងខំប្រឹងប្រែងអស់ពីកម្លាំង

ពី (ខ. 2)—អំពី

ស្តាប់តាម (ខ. 5)—ស្តាប់ ហើយគោរពតាម

បានពន្យល់ (ខ. 6, 14)—បង្រៀនពន្យល់អំពីអត្ថន័យ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សានីហ្វៃទី23។

ក ច្បាស់លាស់

1. ពាក្យពីរដូចគ្នា ដែលព្រះយេស៊ូវបានប្រើ ដើម្បីពិពណ៌នាពីរបៀប ដែលយើងអានពាក្យ ព្យាករណ៍របស់លោកអេសាយ។ អ្នកប្រហែលជាចង់គូសបន្ទាត់ពីក្រោមពាក្យទាំងពីរនេះនៅ ក្នុងព្រះគម្ពីររបស់អ្នក។
2. ចូរសរសេរវិធីបីយ៉ាង ដែលមនុស្សម្នាក់អាចប្រើក្នុងការអានព្រះគម្ពីរ តាមរបៀបព្រះយេស៊ូវ បានពិពណ៌នា។

ខ តើសារលិខិតអាចអនុវត្តនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា?

សូមរំលឹកនីហ្វៃទី3 23:6–12 សារឡើងវិញ ហើយពិពណ៌នាអំពីអ្វី ដែលព្រះយេស៊ូវ បានសុំឱ្យ នីហ្វៃធ្វើ ហើយបន្ទាប់មកសរសេរ ពីរបៀប ដែលអ្នកគិតថាសារលិខិតនេះ អាចអនុវត្តចំពោះអ្នក។

នីហ្វៃទី3 24–25
ពាក្យព្យាករណ៍របស់ម៉ាឡាគី

ម៉ាឡាគី គឺជាព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានបង្រៀននៅក្នុង ឆ្នាំប្រហែល 430 ម.ស ជិត 200ឆ្នាំ បន្ទាប់ពី លីហៃចាកចេញពីយេរូសាឡិម។ នៅក្នុងនីហ្វៃទី3 24–25 ព្រះអង្គសង្គ្រោះបានមានបន្ទូល ដែលឥឡូវជាគម្ពីរ ម៉ាឡាគី 3–4 ដូច្នេះពួកសាសន៍នីហ្វៃ នឹងទទួលបានន្ទូវការបង្រៀនដ៏សំខាន់ ទាំងនោះ។ ជំពូកទាំងនោះ មានសារលិខិតពិសេសសំរាប់យើងក្នុង ថ្ងៃចុងក្រោយនេះផងដែរ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 24

ធន់នៅ (ខ. 2)—រស់នៅតាម រំក

ជាងសំរង (ខ. 2–3)—មនុស្សដែល រំលាយថ្ម ដើម្បីយករលោហៈធាតុពិតចេញមក (និមិត្តសញ្ញានេះ គឺត្រូវបានប្រើដើម្បី បង្រៀនថា មនុស្សនឹងត្រូវសំអាត ពីភាពមិនស្អាត អំពើបាបរបស់ពួកគេ នៅពេលការយាងមក ជាលើកទីពីររបស់ព្រះគ្រីស្ទ។)

ជាងប្រមោក (ខ. 2)—មនុស្សដែលធ្វើ ឱ្យសំលៀកបំពាក់សស្អាត

សំអាត សំរង (ខ. 3)—ធ្វើឱ្យស្អាត

ពួកមន្តអាគម (ខ. 5)—មនុស្ស ដែល អនុវត្តការបង្រៀនមន្តអាគមរបស់សាតាំង និងមានចរិកពុករលួយ

កេងបំបាត់ឈ្នួល (ខ. 5)—ឆោតប្រាស់ ឬយកប្រយោជន៍ពីបុគ្គលិក

ត្រូវវិនាស (ខ. 6)—បំផ្លិចបំផ្លាញ

ស៊ីបង្ខូច (ខ. 11)—អ្នកបង្កិនបង្កោច

ជាខ្លាំង (ខ. 13)—មោះមុត រឹងមាំ

ឥតអំពើ (ខ. 14)—គ្មានតម្លៃ ឬផល ប្រយោជន៍

តាំងឡើង (ខ. 15)—សំរេចដោតជ័យ ល្បងលព្រះ (ខ. 15)—ប្រឆាំងនឹង ព្រះអម្ចាស់ ដោយការមិនគោរពតាម បទបញ្ញត្តិរបស់ទ្រង់

កោតខ្លាច (ខ. 16)—ដោយការ គោរពបូជា ស្រឡាញ់ និងគោរពតាម

នីហ្វៃទី3 24:3–4—ពួកកូនប្រុសរបស់លេវី

នៅក្រោមក្រិត្យវិន័យលោកម៉ូសេ សមាជិកនៃកុលសម្ព័ន្ធលេវី កាន់បព្វជិតភាព ហើយត្រាស្នាធិការ ទាំងឡាយ នៃក្រិត្យវិន័យ សំរាប់ប្រជាជន។ សព្វថ្ងៃនេះ យើងហៅថាបព្វជិតភាព ដែលពួកគេកាន់ ថាជា “បព្វជិតភាពអើរ៉ុន” (សូមមើល គ និងស13:1, 84:31–32, 128:24)។

នីហ្វៃទី3 24:10–12—ពរជ័យនៃដង្វាយមួយភាគដប់

និយាយអំពីពរជ័យនៃដង្វាយមួយភាគ ដប់ខាងវិញ្ញាណ និងខាងរាងកាយ ប្រធានហ៊ីងលី ចេ ក្រាន្ត មាន ប្រសាសន៍ថាៈ “ភាពរុងរឿង មាន ចំពោះអ្នកទាំងឡាយណា ដែលរក្សា ច្បាប់បង់ដង្វាយមួយភាគដប់។ នៅ ពេលខ្ញុំនិយាយអំពីភាពរុងរឿងខ្ញុំមិន ចង់គិតអំពីវា ថាជាលុយកាក់តែម្យ៉ាងនោះទេ . . . អ្វី ដែលខ្ញុំរាប់ថាជាភាពរុងរឿង . . . គឺជា ការលូតលាស់ខាងឯចំណេះដឹងអំពីព្រះ និងទីបន្ទាល់ និងអំណាច ដើម្បីរស់នៅក្នុងជំណឹងល្អ និងដើម្បីបំផុសគំនិតដល់ក្រុមគ្រួសាររបស់យើងឱ្យធ្វើដូច្នេះដែរ។ នោះ គឺជាភាពរុងរឿង ពិតៗ” (*Gospel Standards* [ឆ្នាំ1941], 58)។

នីហ្វៃទី3 25

ជញ្ជ្រាំង (ខ. 1)—គល់ស្រូវស្ងួត ដែល ទុកចោលនៅស្រែ បន្ទាប់ពីប្រមូលស្រូវរួច

ឥតមានឫស ឬមែក (ខ. 1)—ឥតមាន ឪពុកម្តាយ ជីដូនដីតា (ដូនតា) ទឹងកូនចៅ (អ្នកតំណរក្រោយ)

ច្បាប់ (ខ. 4)—ច្បាប់

ថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចរបស់ ព្រះអម្ចាស់ (ខ. 5)—ការយាងមកជា លើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ

នីហ្វៃទី3 25:5–6—ព្រះអម្ចាស់នឹងបញ្ជូនអេលីយ៉ា

ការសំរេចសេចក្តីសន្យា របស់ព្រះអម្ចាស់នេះ គឺតាមរយៈម៉ាឡាគី លោកអេលីយ៉ា បានត្រលប់មក ផែនដីវិញ នៅក្នុងឆ្នាំ1836 នៅក្នុងព្រះវិហារបរិសុទ្ធឃឺតឡិន ហើយបានធ្វើឱ្យកូនសោរ នៃបព្វជិតភាពដំណើរការឡើងវិញ ដើម្បីធ្វើពិធីការសង្គ្រោះ សំរាប់ អ្នកទាំងឡាយណា ដែល ស្លាប់ (សូមមើលគ និង ស 110:13–16)។ លោកសាងឡើងវិញនូវអ្វី ដែលពេលខ្លះសំដៅទៅ លើ អំណាចនៃការផ្សារភ្ជាប់នៃបព្វជិតភាព។ ដោយសារអំណាចនេះហើយ ទើបក្រុមគ្រួសារ អាច ផ្សារភ្ជាប់ជាមួយគ្នា សំរាប់ភាពអស់ កល្បជានិច្ច។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងសកម្មភាព ខ នៅពេលអ្នកសិក្សានីហ្វៃ24–25។

ក តើអ្នកណាខ្លះនឹងរស់ ហើយអ្នកណាខ្លះនឹងមិនរស់នៅក្នុងការយាងមកជាលើកទីពីរ?

ចូរបង្កើតភូឡោនពីរនៅក្នុងស្បៃវគៅសរសេរសរសេររបស់អ្នក។ នៅក្នុងភូឡោនមួយ សរសេរពាក្យ និងឃ្លាចេញពីនីហ្វៃទី3 24–25 ដែលពិពណ៌នាថា នរណា*នឹងមិន* “ធន់នៅបាន” ហើយអ្វីនឹងកើតមានឡើងចំពោះពួកគេ។ នៅក្នុងភូឡោនផ្សេងទៀត សរសេរពីអ្វី ដែលដំណឹងទាំងពីរនេះនិយាយអំពីអ្វី ដែល*នឹង* “ធន់នៅបាន” ហើយអ្វីនឹងកើតមានឡើងចំពោះពួកគេ ហើយពួកគេនឹងធ្វើអ្វី។

ខ ពរជ័យ នៃដង្វាយមួយភាគដប់

1. តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ នៅក្នុងនីហ្វៃទី3 24:8–9 អំពីអ្នកទាំងឡាយណា ដែលមិនបង់ដង្វាយរបស់ពួកគេ?
2. ចេញពីខ 10–12 ចូរសរសេរពីអ្វី ដែលព្រះអម្ចាស់មានបន្ទូលអំពីអ្នកទាំងឡាយ ដែលបង់ដង្វាយមួយភាគដប់របស់ពួកគេ។
3. ចូរធ្វើការប្រៀបធៀប គោលលទ្ធិ និងសេចក្តីសញ្ញា 64:23 ទៅនឹងនីហ្វៃទី3 25:1 រួចហើយសរសេរពីអ្វី ដែលព្រះអម្ចាស់ បានសន្យាចំពោះអ្នកបង់ដង្វាយដោយស្មោះត្រង់។ បន្ថែមពីលើដង្វាយមួយភាគដប់ តើអ្វីខ្លះទៀត ដែលយើងអាចធ្វើពលិកម្ម ចំពោះព្រះអម្ចាស់ នៅក្នុងការប្រែចិត្ត សំរាប់ការយាងមកជាលើកទីពីរ?

គ តើវាមានឥទ្ធិពលមកលើអ្នកដូចម្តេច?

ចូរសរសេរអំពីវិធីសំខាន់បំផុត ដែលអ្នកបានគិតថា ការសំរេច នៅក្នុងនីហ្វៃទី3 25:5–6 មានឥទ្ធិពលមកលើជីវិតរបស់អ្នក។

នីហ្វៃទី3 26

ការសាកល្បងសំរាប់ប្រជាជននៅក្នុងថ្ងៃចុងក្រោយ

ការយាងមកជួបជាលើកទីពីររបស់ព្រះយេស៊ូវ ជាមួយនឹងពួកសាសន៍នីហ្វៃ មានចាប់ផ្តើមនៅក្នុងនីហ្វៃទី3 19 ហើយបញ្ចប់នៅក្នុង ជំពូក26។ អ្នកនឹងកត់សំគាល់ឃើញថា លោកមរមនបានពន្យល់នៅក្នុងជំពូកនេះថា ព្រះយេស៊ូវមានបន្ទូល ហើយធ្វើរឿងជាច្រើន នៅក្នុងចំណោមប្រជាជនច្រើនជាងអ្វី មានចុះបញ្ជីនៅក្នុងព្រះគម្ពីរមរមន។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់ក៏មានបន្ទូលផងដែរថា នៅថ្ងៃណាមួយនឹងមានបញ្ជីប្រវត្តិបន្ថែមពីលើអ្វី ដែលមាននិយាយនិងធ្វើនេះ។ នៅពេលអ្នកអាន សូមរកមើលថា តើមានមូល ហេតុអ្វី ពួនជាយើងមិនមានបញ្ជីប្រវត្តិទាំងនោះ ហើយយើងគួរធ្វើអ្វី ដើម្បីមានបញ្ជីប្រវត្តិ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 26

ជ័រអស្ចារ្យ (ខ. 3)—មហិមា

សាកល្បង (ខ. 9, 11)—ល្បងលល

សម្តែង (ខ. 9)—ជីង សម្តែង

ការកាត់ទោស (ខ. 10)—ការដាក់ទោស បញ្ជាប់ការរីកចំរើន ជាប់ពិរុទ្ធ

ហាមឃាត់ (ខ. 11)—បញ្ហាមិនឱ្យធ្វើអ្វីមួយ

និយាយ (ខ. 14, 16)—និយាយ

ហើយរបស់របរទាំងអស់របស់គេ គឺជារបស់រួម (ខ. 19)—ចែកចាយរាល់អ្វីៗដែលគេមានចំពោះគ្នាទៅវិញទៅមក

នីហ្វៃទី3 26:9–11—“ការណ៍ដែលធំជាងឯទៀតនឹងពុំបានសម្តែង”

ប្រធានយ៉ូសែប ហ្វីលឌីង ស្ម៊ីធ ជាប្រធាន នៃក្រុមសាវកដប់ពីរនាក់ មានប្រសាសន៍ថា៖ “នៅពេលយើងផ្តាល់ ដែលជាសមាជិក នៃសាសនាចក្រ មានឆន្ទៈដើម្បីរក្សាបទបញ្ញត្តិទាំងឡាយដូចដែលបានប្រគល់មកឱ្យយើង ហើយបង្ហាញពីសេចក្តីជំនឿរបស់យើង នោះ. . . . បន្តាប់មកព្រះអម្ចាស់ នឹងរៀបចំរួចជាស្រេច ដើម្បីនាំមកនូវកំណត់បញ្ជីផ្សេងឲ្យទៀតមកឱ្យយើង ប៉ុន្តែឥឡូវនេះ យើងមិន ទាន់រៀបចំខ្លួនរួចជាស្រេច ដើម្បីទទួលបញ្ជីប្រវត្តិនេះនៅឡើយទេ។ ហេតុអ្វី? ពីព្រោះយើងមិនទាន់បានរស់នៅតាមដែល យើង បានតំរូវឱ្យ. . . . នៅក្នុងការអានបញ្ជីប្រវត្តិដែលបានប្រទានមកឱ្យយើងនៅឡើយ ហើយមិនទាន់បានធ្វើតាមពាក្យទូន្មានរបស់ បញ្ជីប្រវត្តិនេះផងដែរ” (នៅក្នុង Conference Report ខែកញ្ញា–តុលា ឆ្នាំ 1961, 20)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សានីហ្វៃទី3 26។

ក ការណ៍ធំ និងការណ៍តូច

1. សូមរំលឹក នីហ្វៃទី3 26:6–12 សារឡើងវិញ ហើយសរសេរពីអ្វី ដែលអ្នកបានរៀនទៅក្នុងព្រះគម្ពីរមរមន។
2. សូមអានផងដែរ នៅអាលម៉ា 12:9–11, គោលលទ្ធិ និងសេចក្តីសញ្ញា 84:54–58 និងវគ្គ “ការយល់ដឹងអំពីព្រះគម្ពីរ” នៅខាងលើ ហើយសរសេរអំពីអ្វី ដែលយើងម្នាក់ត្រូវតែធ្វើ និងអ្វីដែលសាសនាចក្រទាំងមូល ត្រូវតែធ្វើ ដើម្បីទទួល “ការណ៍ ដែលធំជាង” មកពីព្រះអម្ចាស់។
3. ចូរធ្វើបញ្ជីខ្លះ “នៃការណ៍ដែលធំជាង” ដែលកើតមានឡើងនៅក្នុងចំណោមពួកសាសន៍នីហ្វៃ បន្តាប់ពីព្រះយេស៊ូវយាងត្រលប់ ទៅវិញ (សូមមើល នីហ្វៃទី3 26:15–21)។

នីហ្វៃទី3 27

“នេះគឺជំណឹងល្អរបស់យើង”

កំឡុងពេលនៃការយាងមកជួបរបស់ព្រះអម្ចាស់ទាំងពីរលើក នៅគ្រាដំបូងនៅអាមេរិក ព្រះយេស៊ូវគ្រីស្ទផ្ទាល់ បានបង្រៀនអំពី ដំណឹងល្អរបស់ទ្រង់ ហើយដឹកនាំឱ្យសាងសាសនាចក្ររបស់ទ្រង់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ។ ទ្រង់ជ្រើសរើស និងតែងតាំង អ្នកដឹកនាំឱ្យបន្តកិច្ចការរបស់ទ្រង់។ ពួកគេបានបន្តបង្រៀនដំណឹងល្អរបស់ទ្រង់ ហើយធ្វើពិធីការសង្គ្រោះដោយបព្វជិតភាព។ ដូចមានចុះបញ្ជីនៅក្នុងនីហ្វៃទី3 27 បន្ទាប់ពីពេលមិនច្បាស់លាស់មួយ ដែលព្រះយេស៊ូវ បានយាងមកជួបសាវកសាសន៍នីហ្វៃរបស់ទ្រង់ជាលើកទីបី។ ការយាងមកជួបនេះ បង្រៀនយើងថា ព្រះយេស៊ូវគ្រីស្ទ គឺជាម្ចាស់នៃសាសនាចក្ររបស់ទ្រង់ ដែលនៅមិន ឆ្ងាយ ហើយផ្តល់ការណែនាំទៅដល់អ្នកដឹកនាំសាសនាចក្ររបស់ទ្រង់។ ព្រះអម្ចាស់បន្តដឹកនាំសាសនាចក្ររបស់ទ្រង់តាមរយៈអ្នក បំរើរបស់ទ្រង់ ដែលបានតែងតាំងមកនោះ។ ប្រធានគរដើន ប៊ី ហ៊ីងឃ្លី កាលនៅជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានធ្វើទីបន្ទាល់ថា៖ “សូមឱ្យយើងយល់ទាំងអស់គ្នាថា ព្រះយេស៊ូវគ្រីស្ទឈរធ្វើជាម្ចាស់លើសាសនាចក្រនេះ ដែលមានព្រះនាមដ៏ពិសិដ្ឋរបស់ទ្រង់។ ទ្រង់មើលលើសាសនាចក្រ។ ទ្រង់ដឹកនាំសាសនាចក្រ។ ឈរនៅខាងស្តាំព្រះហស្តនៃព្រះវរបិតាសួគ៌របស់ ទ្រង់ ទ្រង់ដឹកនាំកិច្ចការនេះ” (នៅក្នុង Conference Report ខែមេសា ឆ្នាំ1994, 75 ឬ Ensign ខែឧសភា ឆ្នាំ1994, 59)។ នៅពេលអ្នកអាន ចូរកត់ចំណាំពីអ្វីដែលព្រះយេស៊ូវបានបង្រៀនអំពីដំណឹងល្អរបស់ទ្រង់នៅក្នុងជំពូកនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 27

ការប្រកែកគ្នា (ខ. 3)—ឈ្លោះប្រកែក មិនយល់ព្រម

កាបំរំលំ (ខ. 11–12, 17)—កាត់

ទាញ (ខ. 14–15)—នាំ ទាក់ទាញ

ញែកចេញបរិសុទ្ធ (ខ. 20)—ធ្វើឱ្យស្អាត ហើយបរិសុទ្ធ សំអាត

កូននៃអន្តរធាន (ខ. 32)—ម្នាក់ ដែលមានបទពិសោធន៍ខាងឯសេចក្តីស្លាប់ទីពីរ (ខាងវិញ្ញាណ)

នីហ្វៃទី3 27:3–8—ឈ្មោះរបស់សាសនាចក្រ

ព្រះយេស៊ូវ បានធ្វើឱ្យមានភាពច្បាស់លាស់នៅក្នុងនីហ្វៃទី3 27 ថាសាសនាចក្ររបស់ទ្រង់ នឹងត្រូវហៅនៅក្នុងព្រះនាមរបស់ ទ្រង់។ នៅពេលព្រះអម្ចាស់ បានសាងដំណឹងល្អឡើងវិញនៅក្នុងសម័យរបស់យើងនេះ ទ្រង់បើកសម្តែងថា សាសនាចក្ររបស់ទ្រង់ នឹងហៅតាមព្រះនាមរបស់ទ្រង់ម្តងទៀត (សូមមើល គ និង ស 115:3–4)។ ព្រះវិហារផ្សេងព្វទៀតទាំងអស់ ដែលអះអាងថា ជាពួកគ្រីស្ទាន នៅជំនាន់លោកយ៉ូសែប ស៊្មីធ មានមួយចំនួនត្រូវបានហៅតាមព្រះនាមរបស់ព្រះយេស៊ូវ។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ខ និងសកម្មភាព ក ឬ គ នៅពេលអ្នកសិក្សានីហ្វៃទី3 27។

ក “ដោយនូវឈ្មោះយើង”

1. អ្នកប្រហែលជាចង់គូសចំណាំនៅក្នុងនីហ្វៃទី3 27:1–10 នៅគ្រង់ឃ្លាណា ដែលមានព្រះនាមរបស់ព្រះគ្រីស្ទ (ដូចជា “ដោយនូវព្រះនាមព្រះយេស៊ូវ” “ព្រះនាមព្រះគ្រីស្ទ” “តាមឈ្មោះនេះ” “នូវព្រះនាមព្រះអង្គ” ឬ “ដោយនូវឈ្មោះយើង”) ។ សូមអានម៉ូសាយ 3:17, 5:7–13 ផងដែរ ហើយសរសេរកថាភ័ណ្ឌមួយ ដែលបានពន្យល់ពីមូលហេតុថា ហេតុអ្វីក៏អ្វីៗទាំងអស់ យើងធ្វើ ឬនិយាយនៅក្នុងសាសនាចក្រ ត្រូវតែធ្វើឡើង “នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។”

ខ តើអ្វីទៅជា “ដំណឹងល្អ”?

ពាក្យ *សិក្ខាបទ* តាមន័យរបស់ពាក្យ មានន័យថា “ដំណឹងល្អ” ឬ “ដំណឹងរីករាយ។”

1. សូមអានទីហ្វៃទី3 27:9–21 ដោយយកចិត្តទុកដាក់ ហើយគូសបន្ទាត់ពីក្រោមពាក្យ *ដំណឹងល្អ* រាល់ពេលអ្នកឃើញ ពាក្យនេះ។
2. តើព្រះយេស៊ូវមានបន្ទូលដោយដាក់លាក់អ្វីខ្លះ អំពីការសាងឡើងវិញនៃដំណឹងល្អរបស់ទ្រង់?
3. ចូរសង្កេតនៅក្នុងកថាភ័ណ្ឌមួយ ពីរប្បើបដែលខគម្ពីរទាំងឡាយអំពីដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ទាក់ទងទៅនឹងមាត្រានៃ សេចក្តីជំនឿទីបី និងទីបួន។
4. តើព្រះសិក្ខាបទ គឺជា “ដំណឹងល្អ” ចំពោះអ្នកដោយរប្បើបណា?
5. នៅក្នុងជីវិតផ្ទាល់របស់អ្នក តើ “ការរស់នៅតាមដំណឹងល្អ” មានន័យយ៉ាងណា?

គ ចំណេះចំណានព្រះគម្ពីរ—នីហ្វៃទី3 27:27

1. តើកិច្ចការសំខាន់របស់សាវកសាសន៍នីហ្វៃដប់ពីរនាក់ ទទួលពីព្រះអង្គសង្គ្រោះ នៅក្នុងនីហ្វៃទី3 27:24–27 មានអ្វីខ្លះ?
2. តើព្រះយេស៊ូវមានបន្ទូលឱ្យពួកគេធ្វើអ្វីខ្លះ ដើម្បីសំរេចការងាររបស់ពួកគេ?
3. ចូរសរសេរកថាភ័ណ្ឌមួយ ដោយពិពណ៌នាពីរប្បើប ដែលអ្នកព្យាយាមដើម្បីឱ្យអ្នកកាន់តែប្រែក្លាយដូចជាព្រះគ្រីស្ទ។ បញ្ចូលជា ពិសេសនូវអ្វី ដែលអ្នកបានធ្វើ និងអ្វី ដែលអ្នកនឹងធ្វើដើម្បីឱ្យបានកាន់តែប្រសើរឡើងថែមទៀត។

នីហ្វៃទី3 28

បំណងប្រាថ្នាពិសេស របស់ពួកសាវកទាំងដប់ពីរនាក់

ប្រសិនបើអ្នកអាចសុំអ្វីមួយ ដែលអ្នកប៉ងប្រាថ្នាពីព្រះអង្គសង្គ្រោះ តើរបស់នោះគឺជាអ្វី? សាវកសាសន៍នីហ្វៃដប់ពីរនាក់ ត្រូវបានផ្តល់ឱ្យនូវឱកាសនេះ។ ចូរកត់ចំណាំពីអ្វី ដែលពួកគេស្នើរសុំ។ តើអ្នកនឹងស្នើរសុំស្រដៀងគ្នា ឬក៏ខុសគ្នាពីពួកគេ?

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 28

អាយុនៃមនុស្ស (ខ. 2)—ចំនួនឆ្នាំ ដែលមនុស្សម្នាក់រស់នៅ

ក្នុងមួយពព្រិចភ្នែក (ខ. 8)—តែមួយវិនាទី

ភាពរមែងស្លាប់ (ខ. 8, 36)—មានរូបរាងកាយ ដែលអាចស្លាប់

អមតៈភាព (ខ. 8, 36)—មានរូបកាយរស់ឡើងវិញ ដែលមិនចេះស្លាប់

សាច់ឈាម (ខ. 9)—រូបកាយ ឬរូបកាយមតៈ

នឹងនៅលើផែនដី (ខ. 12)—បន្តនៅលើផែនដី

បង្រៀបបង្រៀមឱ្យចូលក្នុងសាសនាចក្រ (ខ.18)—ការផ្លាស់សាសនា

ត្រូវបែកជាពីរ (ខ. 19)—បែកជាពីរ

ត្រប់ត្រាន់ (ខ. 20)—ជ្រៅជ្រះត្រប់ត្រាន់

កូនក្មេង (ខ. 22)—កូនដើត

នីហ្វៃទី3 28:13–17, 36–40—ភាពផ្លាស់ប្រែ និងការប្រែរូប

លោកមរមន បាននិយាយថា សាវកបីនាក់ ក្នុងចំណោមសាវកសាសន៍នីហ្វៃទាំងដប់ពីរនាក់ ត្រូវបាន "ផ្លាស់ប្រែ។" នេះសំដៅទៅ លើការផ្លាស់ប្តូរជាបណ្តោះអាសន្ន ដែលមនុស្សម្នាក់ត្រូវតែមានបទពិសោធន៍ ដើម្បីឈរនៅក្នុងវត្តមានរបស់ព្រះ ហើយមិនត្រូវ បានបំផ្លាញ (សូមមើលគ និងស 67:11, ម៉ូសេ1 :11)។ ភាពផ្លាស់ប្រែ មិនគួរមានការភាន់ច្រឡំជាមួយនឹងការប្រែរូប នៃរាងកាយនោះទេ សូម្បីតែទាំងពីរនេះអាចមានឥទ្ធិពលលើរាងកាយក្នុងរបៀបស្រដៀងគ្នាក៏ដោយ។ ភាពផ្លាស់ប្រែ គឺជាការផ្លាស់ប្តូរតែមួយ ខណៈ ចំណែកឯការប្រែរូបគឺជាការផ្លាស់ប្តូរក្នុងរយៈពេលយូរក្នុងរាងកាយ ដែលត្រូវបញ្ចប់នៅពេល មនុស្សម្នាក់ឆ្លងកាត់ពី ភាពរមែងស្លាប់ទៅជាអមតៈភាព ឬក៏ដំណើររស់ឡើងវិញ (សូមមើលនីហ្វៃទី3 28:8)។ ក្នុងចំណោមអ្នកទាំងនោះ មានពេល មួយ ត្រូវបានប្រែរូប គឺលោកអេណុក និងទីក្រុងស៊ីយ៉ូន (សូមមើលម៉ូសេ7:18–23, 27) លោកអេលីយ៉ា សាវកយ៉ូហាន (គ និង ស 7) និងសាវកសាសន៍នីហ្វៃបីនាក់ (នីហ្វៃទី3 28:4–11, 15–40)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពក និងខ នៅពេលអ្នកសិក្សានីហ្វៃទី3 28។

ក្ត៊ តើអ្នកមានបំណងប្រាថ្នាអ្វីខ្លះ?

1. ចូរសរសេរពីអ្វី ដែលសាវកសាសន៍នីហ្វៃចំនួនប្រាំបួននាក់ ក្នុងចំណោមសាវកដប់ពីរនាក់ ប៉ងប្រាថ្នា នៅក្នុងនីហ្វៃទី3 28 និងធ្វើជាបញ្ជី នៃពរជ័យ ដែលព្រះអម្ចាស់បានសន្យានឹងពួកគេ។
2. ចូរសរសេរអំពីអ្វី ដែលសាវកបីនាក់ទៀតប៉ងប្រាថ្នានៅក្នុងនីហ្វៃទី3 28 និងធ្វើបញ្ជីពរជ័យ ដែលព្រះអម្ចាស់សន្យានឹងពួកគេ។
3. បើសិនជាអ្នកត្រូវបានផ្តល់សិទ្ធិឱ្យជ្រើសរើសរវាង អ្វីដែលបានផ្តល់ឱ្យទៅសាវកទាំងបួននាក់ និងសាវកបីនាក់នោះ តើអ្នកនឹង ជ្រើសរើស យកមួយណា? ហេតុអ្វី?

ខ សរសេរជាចំណោទសួរមួយ

ចូរប្រើអ្វី ដែលអ្នកបានរៀនអំពីការប្រែរូបជាទូទៅ និងសាសន៍នីហ្វៃបីនាក់ដោយជាក់លាក់ រួចសរសេរជាចំណោទសួរ "ត្រូវ ឬខុស"។ ចំណោទសួរនេះ គួរតែមានបញ្ចូលនូវសេចក្តីថ្លែងការណ៍ យ៉ាងហោចណាស់ឱ្យបានប្រាំ។ បន្ទាប់ពីសេចក្តីថ្លែងការណ៍ នីមួយៗ ចូរសរសេរចំលើយ និងខគម្ពីរត្រឹមត្រូវ ចេញអ្វី ដែលអ្នកបានរៀន។

ជំនួសឱ្យការបន្តប្រាប់នូវអ្វី ដែលបានកើតឡើងបន្ទាប់ពីការយាងមកជួបរបស់ព្រះយេស៊ូវគ្រីស្ទជាមួយនឹងពួកសាសន៍នីហ្វៃ លោក មរមន បានបញ្ចាប់នីហ្វៃទី3 ជាមួយនឹងទីបន្ទាល់ ពាក្យទូន្មាន និងការព្រមានរបស់គាត់ ចំពោះអ្នកអាននៅពេលអនាគត។ ចូរចាំថា នៅពេលអ្នកអានជំពូក 29–30 ជំពូកទាំងពីរនេះគឺ លោកមរមន បានសរសេរដោយត្រង់ឲមកកាន់ប្រជាជននៅសម័យរបស់ យើងនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី3 29

ជាការឥតប្រយោជន៍ (3)—គ្មានតម្លៃ ឬគុណសម្បត្តិ

មើលងាយ ដែលមើលងាយដល់ (ខ. 4–5, 8)—មិនគោរព បដិសេធ មិនអើពើ

ធ្វើស៊ីសស៊ូសឱ្យ . . . ចំអកដាក់ (ខ. 8)—ចំអក ឬមើលងាយ

អនុវត្ត (ខ. 9)—សម្តែង

នីហ្វៃទី3 30

អំពើសាហាយស្មន់ (ខ. 2)—អំពើបាបខាងផ្លូវភេទ

អំពើខ្ពើមឆ្អើម (ខ. 2)—អំពើបាបធ្ងន់ធ្ងរគំនិត និងសកម្មភាព ដែលធ្វើឱ្យព្រះមិនសព្វព្រះទ័យ

ការគោរពរូបព្រះ (ខ. 2)—ថ្វាយបង្គំព្រះក្លែងក្លាយ

ការផ្តាច់បាប (ខ. 2)—ការអភ័យទោសសំរាលពីកំហុស

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សានីហ្វៃទី3 29–30។

ក្ត៊ ធ្វើជាបញ្ជីមួយ

1. សូមអានអ្វី ដែលលោកមរមនបាននិយាយនៅក្នុងនីហ្វៃទី3 29:1–4,8–9 ហើយធ្វើបញ្ជីពីអ្វី ដែលយើងគួរតែដឹង ឬធ្វើ ពីព្រោះបញ្ជីប្រវត្តិនេះ ត្រូវបាននាំមកដល់ពិភពលោកនេះ។ បើសិនជាមានមូលហេតុមួយបានផ្តល់ឱ្យ នៅក្នុងខគម្ពីរទាំងនេះ អំពី ថា តើហេតុអ្វីក៏យើងគួរតែដឹង ឬធ្វើនូវរឿងទាំងនោះ ចូរសរសេរមូលហេតុនេះ បន្ទាប់ទៅនឹងអ្វី ដែលមាននៅក្នុងបញ្ជីរបស់អ្នក។
2. ចូរធ្វើការចុះបញ្ជីក្រុមមនុស្ស ដែលលោកមរមន ផ្តល់ការព្រមាន នៅក្នុងនីហ្វៃទី3 29:5–7, 30:2 ឱ្យបានច្បាស់លាស់។ ប្រសិនបើមានផលវិបាកមួយ ចំពោះការព្រមាន ដែលបាននិយាយមកនោះ ចូរសរសេរផលវិបាកនោះ បន្ទាប់ទៅនឹងអ្វី ដែលមាន នៅក្នុងបញ្ជីនោះ។
3. ចេញជំបូន្មាន និងការព្រមាន ដែលលោកបានផ្តល់ឱ្យនៅក្នុងនីហ្វៃទី3 29–30 ចូរធ្វើជាបញ្ជីពីអ្វី ដែលលោកមរមន ត្រូវបានបំផុសគំនិត ដើម្បីដឹងអំពីជំនាន់របស់យើង។

ខ តើអ្នកណាកំពុងនិយាយ?

ចូរអាននីហ្វៃទី3 30:1–2 ដោយយកចិត្តទុកដាក់។ តើពាក្យសំដីរបស់អ្នកណា ដែលមានចុះបញ្ជីនៅក្នុងខ 2 នេះ? តើហេតុអ្វី ក៏អ្នកគិតថាលោកមរមន ត្រូវបានបញ្ជាឱ្យសរសេររឿងទាំងនេះ?

នីហ្វៃទីបួន៖ គម្ពីរនីហ្វៃ

អំពីនីហ្វៃទី4

រហូតដល់ឆ្នាំ 1879 មានការចោះពាក្យ នៃព្រះគម្ពីរមរមន គម្ពីរនេះ ត្រូវបានដាក់ចំណងជើងយ៉ាងសាមញ្ញថា “គម្ពីរនីហ្វៃ កូនប្រុស របស់លីហៃ ដែលជាសាវកម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ។” អែលឌើរ ឆើរសាន់ ផ្រាត ដែលជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានអនុសាសន៍បន្ថែម នៃដើមរឿង “នីហ្វៃទីបី” ដែលត្រូវបានអនុញ្ញាតដោយ គណៈប្រធានទីមួយ។

ផ្នែកទីមួយ នៃនីហ្វៃទី4 មានពេលខ្លះ ត្រូវបានហៅថា “សម័យមាស។” សំរាប់រយៈពេល 170ឆ្នាំ ដែលប្រជាជន មានសាមគ្គីភាព និងរស់នៅក្នុងសន្តិភាព ដោយគ្មានការឈ្លោះប្រកែក ហើយពួកគេមាន “វត្ថុសព្វសារពើ ជារបស់រួមក្នុងចំណោមពួកគេ” (នីហ្វៃទី4 1:3)។ តើពួកគេអាចបង្កើតឱ្យមានពេលវេលា ដែលប្រកបដោយពរដ៏ធំ និងភាពរុងរឿងដូច្នេះបានយ៉ាងដូចម្តេច? ក្រោយមក ប្រជាជន ចាប់ផ្តើមបែកបាក់គ្នាម្តងទៀត ហើយបានធ្វើ “អំពើទុច្ចរិតសព្វបែបយ៉ាង” (ខ. 34)។ បន្ទាប់ពីបានទទួលពរដ៏ធំ ដ៏ពេល វេលា នៃសន្តិភាពនេះ តើហេតុអ្វីប្រជាជនជ្រើសរើសផ្លូវទុច្ចរិតមួយដូច្នេះទៅវិញ?

បន្ទាប់ពីពួកទុច្ចរិតត្រូវបានបំផ្លាញចោល ហើយប្រជាជនដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវបានបង្រៀន និងបំរើដោយព្រះអង្គ សង្គ្រោះ និងពួកទេវតាសួគ៌ ប្រជាជនរស់នៅក្នុងសន្តិភាព និងសេចក្តីសុចរិត អស់រយៈពេលជាច្រើនជំនាន់។ ជីវិតរបស់ពួកគេ មានភាពស្រស់ស្អើងគ្មានទៅនឹងបទពិសោធន៍ ដែលមានចំពោះប្រជាជនអេណុក ដែលត្រូវបានហៅថាស៊ីយ៉ូន (សូមមើលម៉ូសាយ 7:18)។ លោកមរមន បានសរសេរថា “ហើយគ្មានប្រជារាស្ត្រណាដែលរីករាយសប្បាយជាង” (នីហ្វៃទី4 1:16)។ នៅពេលអ្នកអាន សូមរកមើលថា តើគោលការណ៍នៃដំណឹងល្អអ្វីខ្លះ ដែលពួកគេបានរស់នៅ ដែលទាំមកនូវសុភមង្គលដូច្នេះ។

ជាអកុសល និងដាយថាហេតុ ប្រជាជន បានក្លាយទៅជាទុច្ចរិត ដូចជានៅសម័យមុនពេលព្រះយេស៊ូវគ្រីស្ទបានយាងមក។ យើងគួរតែ ពិចារណាដោយប្រុងប្រយ័ត្ន ហើយរៀនមកពីកំហុសរបស់ពួកគេបានឆ្ងើ ដែលជាលទ្ធផលនៅក្នុងការធ្លាក់ចុះ ពីសេចក្តីសុចរិត និងសុភមង្គល ទៅជាសេចក្តីទុច្ចរិត និងទុក្ខវេទនា ដែលទាំមកនូវការបំផ្លិចបំផ្លាញដល់ប្រជាជាតិនីហ្វៃ។

ការយល់ដឹងអំពីព្រះគម្ពីរ

នីហ្វៃទី4 1

វត្ថុសព្វសារពើ ជារបស់រួម (ខ. 3)—មនុស្សម្នាក់ៗ បានទទួលស្គាល់ថា អ្វីៗដែលពួកគេមាន គឺមកពីព្រះអម្ចាស់ ហើយដូច្នេះពួកគេ មានឆន្ទៈចែកចាយនូវអ្វី ដែលពួកគេមានជាមួយនឹងអ្នកដទៃ និងដើម្បីកសាងនគរព្រះ។

បានធ្វើ (ខ. 5)—ធ្វើ

មកជំនួស (ខ. 9, 19)—ដាក់ជំនួសកន្លែង

ការច្រូចក្រច្រល់ (ខ. 16)—ការរំខាន ការបះបោរ

អំពើអាសអាភាស (ខ. 16)—តណ្ហាខ្លាំងក្លា អំពើបាបខាងផ្លូវភេទ

សំឡេកចំពាក់ (ខ. 24)—ខោអាវ

វណ្ណៈ (ខ. 26)—ក្រុមសង្គម ដែលពីងផ្អែកលើលុយ ឬប្រជាប្រិយភាព

ចុះអន់ថយ (ខ. 34, 38)—ធ្លាក់ចុះបន្តិចម្តងៗ

គុបតែងខ្លួន (ខ. 41)—ការគុបតែង

លោភ (ខ. 43)—អាត្មានិយម

ធ្វើជំនួញដូញគ្រប់បែបយ៉ាង (ខ. 46)—ទិញ ឬលក់វត្ថុជាច្រើន មុខរបរ

បង្ខិតបង្ខំ (ខ. 48)—បញ្ជា

សំណល់ (ខ. 49)—កូនចៅ អ្នកនៅសល់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–ត)ខាងក្រោមនេះ នៅពេលអ្នកសិក្សានីហ្វៃទី4។

ក ប្រជារាស្ត្រ ដែលសប្បាយជាងគេបំផុត

1. នៅក្នុងនីហ្វៃទី4 1:16 មរមន បានសរសេរថា គ្មានប្រជារាស្ត្រណា ដែលអាចសប្បាយជាងប្រជារាស្ត្រ ដែលបានពិពណ៌នានៅក្នុង នីហ្វៃទី4 1:1–22 ទេ។ ចូរធ្វើបញ្ជីគោលការណ៍ឱ្យបានយ៉ាងហោចណាស់ព្រាំ នៅក្នុងខគម្ពីរទាំងនេះ ដែលអ្នកជឿថា មានឥទ្ធិពល យ៉ាងខ្លាំងដើម្បីដឹកនាំពួកគេទៅរកសុភមង្គលនេះ។
2. យោងទៅតាមនីហ្វៃទី4 1:15 តើមូលហេតុតែមួយ នៃការឈ្លោះប្រកែក ដែលត្រូវបានបំបាត់ចោលនោះជាអ្វី? ចូរពន្យល់ថា ហេតុអ្វីក៏អ្នកគិតថា គុណសម្បត្តិរបស់មនុស្ស អាចធ្វើឱ្យមានភាពខុសគ្នាកើតឡើង។

២ ជីកនាំការសម្ភាសន៍មួយ

ចូរនឹកគិតថា មានក្រុមមនុស្សក្មេងៗ មកពីជំនាន់ ដែលបានពិពណ៌នានៅក្នុងនីហ្វៃទី4 1:1–22 អាចត្រូវបានធ្វើការសម្ភាសន៍ នៅក្នុងជំនាន់របស់យើង។ ចូរសរសេរសំនួរចំនួនបី ដែលអ្នកគិតថា មនុស្សក្នុងជំនាន់របស់យើង ចង់សួរដល់ពួកគេ។ បន្ទាប់មក សរសេរចំលើយ ដែលអ្នកគិតថា មនុស្សវ័យក្មេងទាំងនោះ នឹងផ្តល់មកឱ្យ យោងទៅតាមអ្វី ដែលអ្នកអាននៅក្នុងនីហ្វៃទី4។

៣ ជណ្តើរ ដែលដើរចុះពីលើមកក្រោម

1. រ៉ៃលេខើរ ស្ពែនស៊ើរ ដបុលយូ ឃិមបឹល ជាសមាជិកនៃក្រុមសាវកទាំងដប់ពីរនាក់ បានបង្រៀនថាៈ “អំពើបាប ដូចជាការធ្វើ ជំណើរមួយ ដែលចាប់ផ្តើមពីដំហានទីមួយ” (*The Miracle of Forgiveness* [1969],214)។ នៅក្នុងនីហ្វៃទី4 សង្គម របស់នីហ្វៃ បានរស់នៅក្នុងការគោរពប្រតិបត្តិតាមបទបញ្ញត្តិរបស់ព្រះ សំរាប់ពាក់កណ្តាលដំពូកដំបូង ប៉ុន្តែទីបញ្ចប់ ពួកគេបានក្លាយទៅជាទុច្ចរិតយ៉ាងខ្លាំងក្លា។ នៅក្នុងស្បៃវត្ថោសរសេររបស់អ្នក ចូរគូរជណ្តើរមួយ ដែលដើរចុះពីលើមកក្រោម។ គួរតែមានពី ត្រាំទៅត្រាំបីកាំ។ នៅកាំលើបំផុត ចូរសរសេរពីអ្វី ដែលនីហ្វៃទី4 បានបង្ហាញថា កាំទីមួយ ដែលប្រជាជនឈានទោះ គឺដើរចុះ ទៅក្រោម ហើយធ្វើបញ្ជីខគម្ពីរពីអ្វី ដែលអ្នកបានរៀន។ ចូរបន្តដាក់ឈ្មោះកាំជណ្តើរនីមួយៗ ជាមួយនឹងអ្វី ដែលនីហ្វៃទី4 បង្រៀន ដែលជាដំហានដើរចុះក្រោមផ្សេងៗទៀត ដែលទាំប្រជាជនឃ្លាតឆ្ងាយពីប្រភេទ នៃជីវិត ដែលព្រះអម្ចាស់ចង់ឱ្យពួកគេរស់នៅ នោះ។



2. នៅទីបញ្ចប់ នៃនីហ្វៃទី4 មានមនុស្សពិចគួរចណាស់នៅក្នុងសង្គមពួកគេ ដែលអាចចាត់ទុកថា ជាមនុស្សសុចរិត។ នៅជិត កាំជណ្តើរនីមួយៗ នៅលើឱយ៉ាក្រាមរបស់អ្នក ចូរសរសេរសង្ខេបពីអ្វី ដែលអ្នកគិតថា មនុស្សសុចរិតអាចធ្វើ ដើម្បីនៅតែ ជាប្រជាជនសុចរិត នៅពេលមនុស្សដទៃទៀតនៅក្នុងសង្គម ចោះដំហានចុះមកក្រោម។
3. តើអ្នកគិតថា វានឹងមានអារម្មណ៍យ៉ាងណា ចំពោះមនុស្សដែលរស់នៅក្នុងសេចក្តីពិតតែពីរបីនាក់ នៃការបង្រៀន របស់ព្រះយេស៊ូវគ្រីស្ទ រហូតដល់បញ្ចប់នីហ្វៃទី 4? តើការប្រឈមមុខអ្វី ដែលអ្នកគិតថា មនុស្សសុចរិតនិងទទួលរង?

គម្ពីរមរមន

អ្នកនិពន្ធជាម្ចាស់ស្បៃវត្ថោ

បន្ទាប់ពីការប្រមូលផ្តុំ និងការសរសេរស្បៃវត្ថោទាំងអស់រួចហើយ យើងឥឡូវហៅថា ព្រះគម្ពីរមរមន ព្យាការីមរមនបាន សរសេរដាំដំណើរឈ្មោះមួយ នៃសម័យរបស់គាត់។ ស្បៃវត្ថោតូចមួយនេះ គឺត្រូវបានហៅថា “ព្រះគម្ពីរមរមន” ទោះបី ជាព្រះគម្ពីរតូចនេះ គឺមាននៅក្នុងព្រះគម្ពីរធំ ដែលត្រូវហៅថា បទគម្ពីរមរមន។ លោកមរមន ត្រូវបានសំលាប់ នៅពេលមួយ បន្ទាប់ពីលោកបានសរសេរពីអ្វី ដែលមាននៅក្នុងមរមន 7។ កូនរបស់លោកម៉រ៉ូណៃ បានបញ្ចប់បញ្ជីប្រវត្តិដែលចាប់ផ្តើមដោយឪពុករបស់គាត់ (សូមមើលមរមន 8–9)។



“ធ្វើល្អកាន់តែច្រើន”

នៅក្នុងការខំប្រឹងប្រែង ដើម្បីកែតំរូវកំហុសមួយ នៅក្នុងការបកប្រែរបស់មនុស្សខ្លះៗ នៃពាក្យ*មរមន* ព្យាការីយ៉ូសែបស្ម៊ីធ បានសរសេរសំបុត្រមួយច្បាប់ ទៅកាន់អ្នកចោះពុម្ពខាង *ពេលវេលានិងរដូវកាល* ដែលជាការចោះពុម្ពនៅសាសនាចក្រ កាលពីដំនាន់មុន។ នៅក្នុងសំបុត្រនោះ លោកមានប្រសាសន៍ថាៈ

“តាមរយៈក្រដាសផ្សព្វផ្សាយរបស់អ្នក ខ្ញុំសូមកែតំហុស . . .

“តំហុសដែលខ្ញុំនិយាយនោះ គឺអត្ថន័យនៃពាក្យថា ‘មរមន’។ ពាក្យនេះបានសរសេរថា មានប្រភពមកពីពាក្យ *មរម្ម* ដែលជាភាសាក្រិក។ នេះមិនមែនជាការពិតទេ។ វាគ្មានភាសាក្រិក ឬអក្សរឡាតាំងនៅលើផ្ទាំងចំណារទេ ដែលក្នុងនាមព្រះ គុណព្រះអម្ចាស់ខ្ញុំបានបកប្រែព្រះគម្ពីរមរមន . . .។

“ពាក្យថាមរមន តាមន័យរបស់ពាក្យ មានន័យថា ធ្វើល្អកាន់តែច្រើន” (*History of the Church 5:399–400)*។

មរមន=ធ្វើល្អកាន់តែច្រើន

ការនិយាយរបស់អ្នក ដែលមិនមែនជាសមាជិក នៃសាសនាចក្រ បានហៅពួកយើងថា “មរមន” ប្រធានគរដីន ប៊ី ហ៊ីងឃ្លី បានបង្រៀនដល់ សមាជិកសាសនាចក្រទាំងឡាយថា ពិរិធីមួយ ដើម្បីត្រលប់ឈ្មោះនេះ ទៅជាពាក្យសរសើរវិញ។

គាត់មានប្រសាសន៍ថា:

“ហើយដូច្នេះ នៅពេលខ្លះ ខ្ញុំតូចចិត្តថា មនុស្សមិនបានហៅឈ្មោះសាសនាចក្រនេះឱ្យបានសមរម្យ តែខ្ញុំសប្បាយថា ការដាក់ឈ្មោះ នេះ ដែលពួកគេប្រើនេះ គឺជាការផ្តល់កិត្តិយសមួយដ៏អស្ចារ្យ ដែលបានធ្វើឡើងដោយបុរសដ៏ពិសេសម្នាក់ និងបទគម្ពីរដែលបាន ផ្តល់ជា ទីបន្ទាល់គ្មានអ្វីប្រៀប ផ្ទឹមបានអំពីព្រះព្រោសលោះនៃពិភពលោក។

“អ្នកណាក៏ដោយ ដែលបានមកស្គាល់បុរសមរមន តាមរយៈការអាន និងការពិចារណាពាក្យរបស់គាត់ អ្នកណាក៏ដោយ ដែលអាន នៅក្នុងទ្រព្យសម្បត្តិប្រវត្តិសាស្ត្រដ៏មានតម្លៃនេះ ដែលត្រូវបានប្រមូលផ្តុំឡើង និងរក្សាទុកនៅក្នុងរង្វាស់ដ៏ធំរបស់គាត់ នឹងបានដឹង ថាលោក*មរមន* គឺមិនមែនជាឈ្មោះអាក្រក់ទេ ប៉ុន្តែឈ្មោះនេះតំណាងឱ្យសេចក្តីល្អដ៏វិសេសបំផុត—សេចក្តីល្អ ដែលជារបស់ព្រះ។ នេះ គឺជាអ្នកបកប្រែនៅដំទាប់ថ្មី អំពីបញ្ជីប្រវត្តិសម័យបុរាណនេះ ដែលបានអះអាងថា តាមរយៈការអានព្រះគម្ពីរមរមន បុគ្គលម្នាក់ឮអាចចូលទៅជិតព្រះបានដោយសារធ្វើតាមដំណឹងល្អ នៃគម្ពីរនេះដាង គម្ពីរដទៃទាំងអស់។

“ទាំងអស់នេះ បានដាក់មកលើយើង នៃសាសនាចក្រនេះ និងដំទាប់នេះ ទូវតំណែងមួយ ឬតំរូវការនៃការទទួលខុសត្រូវ ដើម្បីជឿង ថា អ្វីដែលយើងនិយាយ គឺដូចជាលោកមរមន យើងត្រូវតែរស់នៅ ដើម្បីឱ្យតំរូវរបស់ពួកយើងបានពង្រីកការយល់ដឹងថា *លោក មរមន* មានន័យនៅក្នុងរបៀបដ៏ពិតត្រាកដមួយគឺ ធ្វើល្អកាន់តែច្រើន” (ក្នុង Conference Report ខែតុលា ឆ្នាំ 1990, 70 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ1990, 52–53)។

នៅពេលអ្នកអានអំពីលោកមរមន នៅក្នុងដំពូកពីរបីនេះ ចូរគិតអំពីរបៀប ដែលអ្នកអាចធ្វើតាមតំរូវរបស់គាត់ ហើយឱ្យបាន ឬមាន “សេចក្តីល្អកាន់តែច្រើន” នៅក្នុងជីវិតរបស់អ្នក។

*លោកមរមន គឺជាបុរសអស្ចារ្យម្នាក់ សូម្បីតែស្ថិតនៅក្នុងវ័យយុវជន។ និយាយទៅកាន់យុវជននៃសាសនាចក្រ ប្រធាន ស្ពែនស៊ើរ ដបុលយូ យ៉ាមបីលមានប្រសាសន៍ថា: “អ្នកដែលជាយុវជនទាំងឡាយ មិនចាំបាច់រង់ចាំដើម្បីក្លាយទៅជាមនុស្សអស្ចារ្យម្នាក់ទេ។ អ្នកបានក្លាយទៅជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យ យុវជនដ៏រឹងមាំ ជាដៃគូដ៏ល្អ និងសប្បាយ មានទំនុកចិត្តទៅលើអ្នកដឹកនាំ នៃសាសនាចក្រ។ អ្នកមិនត្រូវការរង់ចាំរហូតដល់ថ្ងៃស្អែកទេ” (នៅក្នុង Conference Report ខែមេសា ឆ្នាំ1976, 71 ឬ Ensign ខែឧសភា ឆ្នាំ1976, 47)។ ប្រធានគរដីន ប៊ី ហ៊ីងឃ្លី បានផ្តល់ដំបូន្មានដល់យុវជន និងយុវនារី “ឱ្យមានជំនឿទៅក្នុង សមត្ថភាពរបស់ខ្លួន ដើម្បីរៀន និងធ្វើអ្វីមួយ ដែលមានទៅក្នុងជីវិតរបស់អ្នក។ ធ្វើអ្វីដែលត្រឹមត្រូវ ហើយឆ្ពោះទៅមុខ” (*Teachings of Gordon B. Hinckley, 715)*។

នៅពេលអ្នកអានគម្ពីរមរមន1 ចូរកត់ចំណាំថា តើលោកមានអាយុប៉ុន្មាន លើយតើលោកនិយាយអ្វីខ្លះអំពីអាយុរបស់លោក។ ចូរគិតដងដែរអំពីអ្វីអ្នកអានទៅក្នុងផ្នែកចុងក្រោយ នៃនីហ្វៃទី4 អំពីប្រភេទសង្គម ដែលលោកមរមនបានចំរើនឡើង។ គំរូ របស់លោក នៃយុវវ័យនៃសេចក្តីសុចរិតនៅកណ្តាលសេចក្តីទុច្ចរិតដ៏ធំ គឺជាមេរៀន ដែលប្រកបដោយអានុភាពមួយដូចជាអ្វី ដែលលោកបានប្រែក្រលែប្រដៅ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន1

ត្រឹមត្រូវ (ខ. 2, 15)—អាចគិតដោយល្អិតល្អន់អំពីរឿងសំខាន់ គំនិតខាងវិញ្ញាណ

សង្កេត (ខ. 2)—រៀន យល់ដឹង

ចម្លាក់, ឆ្លាក់ (ខ. 3–4)—ការសរសេរសរសេរនៅលើលោហៈធាតុ

ពោះបង់ចោលចំណងរបស់ពួកគេ (ខ. 12)—ពោះបង់ចោលផែនការរបស់ពួកគេ

ពាសពេញ (ខ. 13)—មានឥទ្ធិពលខ្លាំងបំផុត

ខិតខំ (ខ. 16)—ប៉ង ព្យាយាម

មានរបៀបមន្តអាគម (ខ. 19)—ប៉ងដើម្បីឱ្យមានវិវរណៈក្លែងក្លាយមកពីប្រភពអាក្រក់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាមរមន1។

ក ផលវិបាកទាំងឡាយ

ពាក្យ *ភីរ្ភោះ* មានសារៈសំខាន់ ដើម្បីកត់សំគាល់នៅក្នុងបទគម្ពីរ។ ជារឿយៗ បានផ្តួយដល់យើងស្គាល់ពីសកម្មភាព និងផលវិបាក របស់ពួកគេ ទាំងល្អ និងអាក្រក់។

1. ចូរប្រើអ្វី ដែលអ្នកអានទៅក្នុងមរមន 1:13–14 រួចធ្វើឌីយ៉ាក្រាមមួយ ស្រដៀងទៅនឹងអ្វីដូចខាងក្រោមនេះ ហើយចង្អុល បង្ហាញពី ផលវិបាកទាំងឡាយ នៃបទពិសោធន៍ និងសកម្មភាពរបស់សាសន៍នីហ្វៃ ដែលនាំ មកនូវផលវិបាកទាំងនោះ។

2. ឧបមាថាមានសាសន៍នីហ្វៃ នៃជំនាន់របស់លោកមរមន បានឃើញឌីយ៉ាក្រាមរបស់អ្នក ឬអានខទាំងនោះ ដែលមានគោលលទ្ធិ ទាំងឡាយ បានពន្យល់ដល់ពួកគេ ហើយបន្តាប់មកឆ្លើយតបដោយនិយាយថា "ដូច្នេះ?" ចូរសរសេរការឆ្លើយតប ចំពោះមនុស្ស ដូច្នោះ ដើម្បីជួយពួកគេឱ្យយល់ដឹងថា តើផលវិបាកទាំងនោះមានសំខាន់ប៉ុណ្ណា។ ចូរបញ្ចូលនូវឧទាហរណ៍ដាក់លាក់ ដែលធ្វើឱ្យ ជីវិតរបស់អ្នកមានភាពខុសប្លែក ពីព្រោះតែអ្នកទទួលពរជ័យទាំងឡាយ ដែលលោកមរមនបាន និយាយមកនោះ។

យើងអានទៅក្នុងមរមន 1 អំពីផលវិបាកខាងវិញ្ញាណ នៃសេចក្តីទុច្ចរិតរបស់ពួកសាសន៍នីហ្វៃ។ នៅក្នុងមរមន2 យើងរៀនអំពី ការធ្លាក់ទៅក្នុងកំហុសខ្លះៗ និងផលវិបាកទាំងឡាយរបស់ពួកគេ ដែលមានមកតាមក្រោយនោះ។ នៅពេលខ្លះ ការមានរឿង អាក្រក់កើតឡើងចំពោះយើង អាចធ្វើឱ្យយើងមានចិត្តរាបសារ ហើយដឹកនាំយើងឱ្យមើលទៅលើជីវិតរបស់យើងកាន់តែខ្លាំងឡើង និងធ្វើឱ្យគំរូវការមានការផ្លាស់ប្តូរ។ នៅពេលអ្នកអានមរមន2 ចូរកត់ចំណាំពីរបៀប ដែលពួកសាសន៍នីហ្វៃ នៅជំនាន់របស់លោក មរមន ឆ្លើយតបចំពោះការបរាជ័យ សោកនាដកម្ម និងទុក្ខព្រួយ ដែលជាលទ្ធផលមកពីសកម្មភាពរបស់ពួកគេ។ តើអ្នកអាចរៀន អ្វីខ្លះ ពីគំរូរបស់ពួកគេ? តើអ្នកអាចរៀនអ្វីខ្លះមកពីគំរូរបស់លោកមរមននៅក្នុងជំពូកនេះ?

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន2

មាឌធំ (ខ. 1)—ទំងន់

ការកាប់សម្លាប់ (ខ. 8)—របួស ឬសាកសប់ ការសម្លាប់រង្គាល

ការច្រូចបូកច្របល់ដ៏ពេញទំហឹងមួយ (ខ. 8)—គំរូដាបន្តបន្ទាប់ ទំហំ

ការខ្ជិលសោក និងទុក្ខព្រួយ (ខ. 11, 12)—ក្រៀមក្រំ ទួញយំ សេចក្តីទុក្ខព្រួយដែលតាប់ព្រះទ័យព្រះ

អសារឥតការ (ខ. 13)—គ្មានគោលបំណង

សេចក្តីក្លាហាន (ខ. 24)—ខិតខំយ៉ាងខ្លាំង កម្លាំង

ចិត្តសោកសង្រេង (ខ. 14)—ការបន្ទាបខ្លួន ទុក្ខព្រួយដ៏ខ្លាំង

វិញ្ញាណទន់ទាប (ខ. 14)—បំណងនៅខាងក្នុង ដើម្បីប្រែចិត្ត ហើយធ្វើតាមព្រះទ័យរបស់ព្រះ

ត្រូវកាប់រំលំ (ខ. 15)—សំលាប់នៅក្នុងសង្គ្រាម

អំពើគួរខ្ពើមឆ្អើមទាំងឡាយ (ខ. 18, 27)—អំពើបាបយ៉ាងធ្ងន់ធ្ងរ គំនិត និងសកម្មភាព ដែលធ្វើឱ្យទាស់ព្រះទ័យរបស់ព្រះ

គ្រោះអាសន្ន (ខ. 27)—សោកនាដកម្ម គ្រោះមហន្តរាយ

មរមន2 ៖11–14—"សេចក្តីទុក្ខសោករបស់អ្នកជាប់ទោស" ឬ "សេចក្តីទុក្ខព្រួយ. . . . នាំទៅកាន់សេចក្តីប្រែចិត្ត"

ប្រធានស្ពែនស៊ើ ដប៊ុលយូ គិមប៊ឺល បានបង្រៀនថា "ជាញឹកញាប់ណាស់ ដែលមនុស្សគិតថាពួកគេបានធ្វើការប្រែចិត្ត ហើយមាន ភាពសក្តិសម សំរាប់ការអភ័យទោសចំពោះអ្វីៗ ដែលពួកគេបានធ្វើ បានបង្ហាញពីទុក្ខព្រួយ ឬស្តាយក្រោយចំពោះអ្វីដែលអាក្រក់ បានកើតឡើង" (*Teachings of Spencer W. Kimball* ពិនិត្យផ្សេងផ្តាត់ដោយ Edward L. Kimball [1982], 87)។ ការពិពណ៌នា របស់លោកមរមននៅក្នុងមរមន 2:11–14 ជួយយើងឱ្យយល់ថា មានតែតាមរយៈទុក្ខព្រួយតែប៉ុណ្ណោះ "ដែលនាំ ទៅកាន់សេចក្តីប្រែចិត្ត" នាំទៅកាន់ការផ្លាស់ប្តូរដែលធ្វើឱ្យយើងបានស្អាត ហើយជំនួសសេចក្តីទុក្ខព្រួយ ទៅជាសុភមង្គលវិញ។ នៅក្នុង "សេចក្តីទុក្ខព្រួយដែលតាប់ព្រះហឫទ័យដល់ព្រះ" ដ៏ជ្រាលជ្រៅនេះ (សូមមើលកូរិនថូសទី 2 7:10) គឺជាការស្តែងចេញពិតមួយ ដែលជាសកម្មភាពទុច្ចរិតរបស់យើង តាមការពិតមានការប្រឆាំងនឹងព្រះ (សូមមើលមរមន 2:15) ហើយដែលយើងបានទាំទៅកាន់ការរងទុក្ខរបស់អ្នកដទៃទៀត—រួមមានទាំងព្រះអង្គសង្គ្រោះ (សូមមើលម៉ូសាយ 14:5, គ និងស 19:16–19)។ "សេចក្តីទុក្ខព្រួយ. . . . ដែលនាំទៅកាន់សេចក្តីប្រែចិត្ត" មានន័យថាយើងមានចំណងធ្វើការផ្លាស់ប្តូរ។

មរមន 2:15—"ថ្ងៃនៃព្រះគុណសំរាប់ពួកគេ បានកន្លងផុតទៅ"

ប្រធានយ៉ូសែប ហ៊ីលឌិង ស្ម៊ីធ ជាសមាជិកនៃក្រុមសាវកទាំងដប់ពីរនាក់ បានពន្យល់ថា "វាអាចទៅរួច ដើម្បីឱ្យមនុស្សទៅ ឆ្ងាយនៅក្នុងទិងងឹត តាមរយៈការបះបោរ និងអំពើទុច្ចរិត ដែលវិញ្ញាណនៃការប្រែចិត្ត បានចាកចេញពីពួកគេ . . .។ ហើយពួកគេ ចេញទៅហួសពីអំណាចនៃការប្រែចិត្ត" (*Doctrince of Salvation* 2:194 សូមមើលផងដែរ នៅហេលេមិន 13:38)។

យើងអាចរៀនពីចរិកលក្ខណៈរបស់លោកមរមនបានយ៉ាងច្រើន ពីរបៀប ដែលលោកបន្តជួយដល់ប្រជាជនរបស់លោក បន្ទាប់ពីលោកដឹងថា "ថ្ងៃនៃព្រះគុណនេះ បានកន្លងហួសទៅ។"

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាមរមន 2។

ក មូលហេតុចំពោះសេចក្តីទុក្ខព្រួយ

1. យោងទៅតាមមរមន 2:10–15 តើហេតុអ្វីពួកសាសន៍នីហ្វៃមានសេចក្តីទុក្ខព្រួយ? បន្ទាប់ពីអ្នកធ្វើបញ្ជីអំពីមូលហេតុនីមួយៗ ហើយ ចូរធ្វើការកត់ចំណាំអំពីខ ឬខគម្ពីរទាំងឡាយ ដែលអ្នកបានរកឃើញនោះ។

2. យោងទៅតាមមរមន 2:10–15, 18–19, 25–27 តើហេតុអ្វីលោកមរមនមានសេចក្តីព្រួយ? បន្ទាប់ពីអ្នកធ្វើបញ្ជីអំពី មូលហេតុនីមួយៗ ហើយ ចូរធ្វើការកត់ចំណាំអំពីខ ឬខគម្ពីរទាំងឡាយដែលអ្នកបានរកឃើញនោះ។

3. តើសេចក្តីទុក្ខព្រួយរបស់សាសន៍នីហៃ និងទុក្ខព្រួយរបស់លោកមរមនមានភាពខុសគ្នាអ្វីខ្លះ?

4. ចូរពន្យល់អំពីរឃ្យែប ដែលវគ្គគម្ពីរនីមួយៗនៅខាងក្រោមនេះ មានជាប់ទាក់ទងជាមួយនឹងសេចក្តីទុក្ខព្រួយរបស់ពួកសាសន៍ នីហៃ សេចក្តីទុក្ខព្រួយរបស់លោកមរមន ឬជាប់ទាក់ទងជាមួយនឹងសេចក្តីទុក្ខព្រួយទាំងពីរ៖ អាលម៉ា 41:10, 42:29, ម៉ូរ៉ូណៃ 10:22, ម៉ូសេ 7:28–40។

នៅក្នុងមរមន 3 យើងបានរៀនយ៉ាងច្រើនអំពីសេចក្តីមេត្តាករុណារបស់ព្រះ និងសេចក្តីអស្ចារ្យរបស់លោកមរមន នៅពេល អ្នកពិចារណាថា ព្រះអម្ចាស់បានផ្តល់ឱកាសដល់ពួកសាសន៍នីហៃ ដែលទុច្ចរិតម្តងទៀត ដើម្បីធ្វើការប្រែចិត្ត។ ព្រះអម្ចាស់ បានជួយដល់ពួកគេ នៅក្នុងសង្គ្រាមរបស់ពួកគេប្រឆាំងនឹងពួកសាសន៍លេមិនផងដែរ។ ចំពោះព្យាការី អេសេគាល នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះអម្ចាស់មានបន្ទូលថា “តើអញមានសេចក្តីអំណរដោយមនុស្សទុច្ចរិតស្លាប់ទៅឬ? . . . តើមិនមែនអ ដោយគេបែរចេញពីផ្លូវរបស់ខ្លួនវិលមកឱ្យបានរស់នៅវិញទេឬអី?” (អេសេគាល 18:23)។ ថ្វីបើព្រះអម្ចាស់មានព្រះទ័យចង់ឱ្យ មនុស្សទាំងអស់ធ្វើការប្រែចិត្តយ៉ាងខ្លាំងប៉ុណ្ណាក៏ដោយ ក៏ទ្រង់មិនបង្ខំយើងដែរ ហើយច្បាប់នៃយុត្តិធម៌នឹងធ្វើឱ្យស្កប់។ នៅពេល អ្នកអានមរមន 3 សូមយកចិត្តទុកដាក់កត់ចំណាំទូវសេកម្មភាព និងអាកប្បកិរិយា ដែលបំបែកពួកសាសន៍ នីហៃពី ព្រះអម្ចាស់។ ជាអកុសល មានមនុស្សជាច្រើននៅសព្វថ្ងៃ បានធ្វើឱ្យមានកំហុសទាំងឡាយដូចគ្នានេះផងដែរ។ វាហាក់ដូច ជាលោកមរមន ចង់ឱ្យយើងរៀនមកពីភាពត្រៀមក្រំនេះ ពីរឿងនៃការបំផ្លិចបំផ្លាញរបស់សាសន៍នីហៃដោយផ្តាល់តាំងពីលោកបានសរសេរ យ៉ាងច្បាស់លាស់ មកដល់យើងសព្វថ្ងៃនេះនៅក្នុងផ្នែកចុងក្រោយនៃដំពូកនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 3

ជាការឥតប្រយោជន៍ (ខ. 3)—មិនអាចប្រើបាន

សំបុត្រ (ខ. 4)—សំបុត្រ

ជាជាច់ខាត (ខ. 11)—ចប់សព្វគ្រប់

បីដង (ខ. 13)—បីដង

ការសងសឹក (ខ. 15)—យុត្តិធម៌ ដែលមានភាពកាចសាហាវ ទារុណកម្ម

មួយគត់ (ខ. 16)—មិនចូលរួម

សម្តែង (ខ. 16, 20)—ធ្វើឱ្យដឹង

ចាប់ផ្តើម (ខ. 17)—ចាប់ផ្តើម

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាមរមន 3។

ភ សម្លេង ដែលស្រែកចេញពីធូលីដី

នៅពេលអ្នកអានទៅទំព័រចុងក្រោយ នៃព្រះគម្ពីរមរមន មានកន្លែងជាច្រើន ដែលហាក់ដូចជាថា លោកមរមន និងលោកម៉ូរ៉ូណៃ បានដឹងយ៉ាងច្បាស់អំពីសម័យរបស់ពួកយើង ដូចជាសម័យរបស់គាត់ផ្ទាល់។ ការនិយាយចំឮមកកាន់យើងនៅក្នុងមរមន 3:17 លោកមរមនមានប្រសាន៍ថា “ហេតុដូច្នេះហើយ . . .” ឬម្យ៉ាងវិញទៀតថា “ពីព្រោះតែរឿងទាំងនេះ ដែលឥឡូវអ្នកបានដឹងខ្ញុំនឹង ត្រាប់ដល់អ្នករឿងនេះ . . .”

1. ចូរធ្វើបញ្ជីសេចក្តីពិតទាំងឡាយ ដែលលោកមរមនធ្វើទីបន្ទាល់ នៅក្នុងមរមន 3:17–22។

2. ចូរសរសេរពីរឃ្យែប ដោយការយល់ដឹងពីសេចក្តីពិតទាំងនេះ នឹងជួយដល់អ្នក ដើម្បីការពារពីការមានកំហុស ដែលទាំឱ្យមហន្តរាយម្តងហើយម្តងទៀត របស់ពួកសាសន៍នីហៃ។

នៅក្នុងមរមន 3 យើងអានថា លោកមរមន បានបដិសេធដើម្បីធ្វើជាមេបញ្ជាការកងទ័ពពួកសាសន៍នីហៃ ពីព្រោះតែចិត្តរបស់ពួក គេរឹងរូសហេតុនេះហើយគេសប្បាយចិត្តក្នុងការខ្ចាយឈាមគ្មានមិនចេះចប់សោះ។ លោកមរមនបន្តទៀតថា ទោះជាយ៉ាងណាក៏ ដោយត្រូវរក្សា និងធ្វើបញ្ជីប្រវត្តិនៃប្រជាជនរបស់គាត់។ នៅពេលអ្នកអានមរមន 4 សូមរកមើលរាល់ការផ្លាស់ប្តូរដែលមាននៅ ក្នុងអាកប្បកិរិយា ឬជោគជ័យនៅក្នុងសង្គ្រាមរបស់ពួកសាសន៍នីហៃ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 4

ចរាចល័យ (ខ. 4)—ចរាចល័យ

បានរុញច្រាន (ខ. 8)—បដិសេធចំណាងរបស់ពួកគេ

នៅតែបន្ត (ខ. 10)—បន្តដោយខ្នាប់ខ្លួន

សាកសព (ខ. 11)—សាកសពការសម្លាប់រង្គាល

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សាមរមន 4។

ក្ស សរសេរជាចំណោទសំនួរមួយ

ចូរសរសេរចំណោទសំនួរខ្លីមួយ ដោយមានទាំងអ្វី ដែលអ្នកគិតថា ជាគំនិត ឬព្រឹត្តិការណ៍ ចំនួនបី ទៅប្រាំដ៏សំខាន់បំផុត នៅក្នុង មរមន 4។ អ្នកអាចសរសេរជាចំណោទសំនួរ "ខុស ឬត្រូវ" ឬជាសំនួរទាំងឡាយណា ដែលមានចំលើយខ្លីៗ។ សូមបញ្ចូល នូវចំលើយជាគន្លឹះ ដែលមានចំលើយនីមួយៗរកបាន នៅក្នុងខគម្ពីរមួយ ឬច្រើននោះ។

ខ បដិសេធ មិនព្រមប្រែចិត្ត

នៅក្នុងមរមន 4:10–18 ចូរធ្វើការគូសចំណាំខគម្ពីរទាំងនោះ ដែលអ្នកគិតថា បានពិពណិនាអំពីអ្វី ពេលដែលបានកើតឡើង ចំពោះពួកសាសន៍នីហ្វៃ ពីព្រោះពួកគេបានបដិសេធមិនព្រមប្រែចិត្ត។ ចូរសរសេរអំពីរបៀប ដែលអ្នកគិតថា ពួកសាសន៍នីហ្វៃ មានអារម្មណ៍ជាយ៉ាងណានៅកំឡុងពេលនោះ ហើយតើហេតុអ្វី។

មរមន 5
គោលបំណង
នៃបញ្ជីប្រវត្តិរបស់លោកមរមន

ជំណើររឿងនៃព្រឹត្តិការណ៍របស់លោកមរមន កំឡុងជីវិតរបស់លោកពោរពេញទៅដោយសេចក្តីទុក្ខព្រួយ និងអស់សង្ឃឹម ហើយជាអកុសលពីព្រោះតែអំពើទុច្ចរិតរបស់ពួកគេជីវិតរបស់ពួកសាសន៍នីហ្វៃ មិនមានការរីកចំរើននោះទេ។ លោកមរមន បានចំណាយពេលនៅក្នុងមរមន 5 ដើម្បីពន្យល់ពីអ្វី ដែលលោកបានគិតអំពីប្រជាជននៅក្នុងថ្ងៃចុងក្រោយ គួរតែរៀនមកពីជំណើរ រឿងនៃការវិនាសនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 5

សេចក្តីទុក្ខវេទនា (ខ. 1)—បញ្ហា និងទុក្ខព្រួយ

រក្សា (ខ. 4)—រក្សា កាន់ យាម ការពារ

កើតទុក្ខ (ខ. 8)—ទារុណកម្ម

ឥតប្រយោជន៍ (ខ. 9)—ឆ្មានអ្វី

សេចក្តីសង្ខេប (ខ. 9)—ទស្សនះខ្លីៗ

ត្រោះកាច (ខ. 11)—សោកនាដកម្ម ត្រោះ

គោលបំណង (ខ. 14)—គោលបំណង

ពូជ (ខ. 15)—កូនចៅ

ត្ងរខ្ពើមឆ្អើម (ខ. 15)—ស្អប់ ខ្ពើមឆ្អើម ស្អប់ខ្ពើម

អង្កាម (ខ. 16, 18)—សំបកត្រាប់ស្រូវ ខាងក្រៅស្រាល

ភេត្រា (ខ. 18)—ទូក

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សាមរមន 5។

ក្ស គោលបំណងនៃព្រះគម្ពីរមរមន

1. នៅក្នុងមរមន 5:14–15 លោកមរមន បានផ្តល់មូលហេតុជាច្រើនថា ហេតុអ្វីបានជាព្រះគម្ពីរមរមនទឹងមកដល់នៅក្នុង ជំនាន់របស់យើង។ ចូរធ្វើបញ្ជីគោលបំណងទាំងនោះនៅក្នុងសៀវភៅសរសេររបស់អ្នក។
2. ចំពោះបញ្ជីរបស់អ្នក ចូរបន្ថែមនូវគោលបំណងទាំងឡាយ ដែលមាននៅក្នុងនីហ្វៃទី1 13:40, នីហ្វៃទី2 3:12 គោលលទ្ធិ និងសេចក្តីសញ្ញា 3:19–20, 10:48–52, 62–63, 20:11–12។

ខ "ពួកសាសន៍ដទៃជាទីស្រឡាញ់ . . ."

លោកមរមនដឹងថា ប្រជាជនសាសន៍ដទៃនៅក្នុងថ្ងៃចុងក្រោយ នឹងទទួលបានពាក្យសំដីរបស់គាត់។ លោកបានសរសេរយ៉ាងជាក់ លាក់ចំពោះពួកគេ ដែលជាផ្នែកដ៏ធំមួយរបស់មរមន 5:9–24។ ចូរធ្វើការសង្ខេបសារលិខិតរបស់លោកមរមនសំរាប់ពួកសាសន៍ ដទៃ ដោយការសរសេរសំបុត្រមួយច្បាប់ជាពាក្យសំដីរបស់អ្នកផ្ទាល់ ដែលត្រូវបាននិយាយ "ដល់ពួកសាសន៍ដទៃនៅក្នុងថ្ងៃចុងក្រោយ។" នៅពេលអ្នកសរសេរ ចូរធ្វើការកំណត់ចំណាំថា លោកមរមន បានសរសេរ*អំពី* ពួកសាសន៍ដទៃក៏ដូចជា*ចំពោះ* ពួក សាសន៍ដទៃ។

មរមន 6
"ការបំផ្លិចបំផ្លាញប្រជាជន"

រយៈពេលច្រើនជាងហុកសិបឆ្នាំបានកន្លងផុតទៅ រវាងការសរសេរនៅក្នុងមរមន 1 និង6។ លោកមរមនបានជីកនាំកងទ័ពសាសន៍ នីហ្វៃអស់រយៈពេលជាងហាសិបឆ្នាំ។ នៅពេលអ្នកបានអាន ទោះជាយ៉ាងណាក៏ដោយ ពួកសាសន៍នីហ្វៃ បានបដិសេធ ដើម្បីធ្វើការ ផ្លាស់ប្តូរនៅក្នុងជីវិតរបស់ពួកគេ ដែលនឹងអនុញ្ញាតឱ្យពួកគេទទួលជំនួយពីព្រះអម្ចាស់ ហើយសង្គ្រោះពួកគេឱ្យរួចផុតពីការ បំផ្លិចបំផ្លាញ។ មរមន 6 បានផ្តល់ជាដំណើររឿងមួយអំពីការធ្វើសង្គ្រាមចុងក្រោយ ដោយប្រជាជនសាសន៍នីហ្វៃ—ដែលជាប្រជាជាតិមួយ ដែលបានចាប់ផ្តើមច្រើនជាងពីរបួនរយឆ្នាំមុន ជាប្រជាជាតិមួយដែលមានសេចក្តីសញ្ញាដ៏ពិសេស មកពី ព្រះអម្ចាស់ និងជាប្រជាជាតិមួយដែលមានកិត្តិយសដោយការយាងមកជួបរបស់បុត្រារស់ឡើងវិញនៃព្រះ។ នៅពេលអ្នកអាន អំពីសេចក្តីទុក្ខព្រួយរបស់លោកមរមន ចូរពិចារណាថា តើពាក្យសំដីរបស់លោក ស្រដៀងគ្នាទៅនឹងបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលទ្រង់មានបន្ទូលថា “ខ្ញុំ យេរូសាឡិម ក្រុងយេរូសាឡិមអើយ . . . តើប៉ុន្មានដងហើយ ដែលអញចង់ប្រមូលកូនឯងទាំង ប៉ុន្មានដូចជាមេមាន់ក្រុងកូនវាឱ្យជ្រកក្រោមស្លាបតែឯងមិនព្រមទេ!” (ម៉ាថាយ 23:37)។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 6

ទុក (ខ. 6)—អនុញ្ញាត ឃល់ព្រម

អោយរលួយ (ខ. 15)—ស្មុយរលួយ

ប្រេះបែកដោយឈឺចាប់ (ខ.16)—បែកជាពីរដោយអារម្មណ៍ឈឺចាប់

អមតភាព (ខ.21)—រូបកាយរស់ឡើងវិញ ដែលនឹងរស់នៅជារៀងរហូតតទៅ

មរមន 6—ថេរវេលានៃខ្សែជីវិតរបស់លោកមរមន



ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាមរមន 6។

ក ធ្វើការប្រៀបធៀបមួយ

នៅពេលយើងអានអំពីការបំផ្លិចបំផ្លាញរបស់ប្រជាជនមួយ ដែលបែរចេញពីសេចក្តីសុចរិតរបស់ពួកគេទៅរកសេចក្តីទុច្ចរិតយ៉ាង ខ្លាំង យើងត្រូវតែដឹងដងដែរថា វាគឺជារឿងមួយរបស់បុរសម្នាក់ដែលរស់នៅដោយសុចរិតអស់រយៈពេលច្រើនជាងហុកសិបឆ្នាំ នៅកណ្តាលសេចក្តីទុច្ចរិតដ៏ខ្លាំងក្លា។ បើយើងមើលកាន់តែច្បាស់នឹងអាចជួយដល់យើងមានសេចក្តីអំណរគុណកាន់តែច្រើន ពីរបៀបលោកមរមនមានលក្ខណៈដូចជាព្រះគ្រីស្ទ ដូចបានផ្តល់ជាឧទាហរណ៍មួយ នៃរបៀបដើម្បីធ្វើការសំរេចចិត្តនៅក្នុង សម័យរបស់យើងនេះ។

1. ចូរចែកទំព័រស្បៃរតោសរសេររបស់អ្នកមួយសន្លឹកទៅជាកូឡោនពីរ។ ចូរដាក់ឈ្មោះនៅក្នុងកូឡោនមួយថា “ពួកសាសន៍នីហ្វៃ” ហើយសរសេរឱ្យខ្លីនៅពីក្រោម ដែលអ្នកប្រៀបធៀបពីសេចក្តីយោងដូចខាងក្រោមនេះ អំពីពួកសាសន៍នីហ្វៃក្នុងជំនាន់របស់លោក មរមន មរមន 1:13–14, 16–17, 19, 2:10–15, 18, 26, 3:9–10, 13–14, 4:8, 10–12, 5:2, 15–18, 6:7។
2. ដាក់ឈ្មោះនៅក្នុងកូឡោនទីពីរនៅលើទំព័រថា “លោកមរមន” ហើយសរសេរឱ្យខ្លីនៅពីក្រោមដែលអ្នកបានប្រៀបធៀបមក ពី សេចក្តីយោងដូចខាងក្រោមអំពីលោកមរមន មរមន 1:1–2, 5, 15–17, 2:1–2, 9, 12–15, 19, 23–24, 27, 3:1–3, 11–14, 16–22, 5:1–2, 8–11, 13, 6:2–4, 6, 16–22។ ចូរព្យាយាមយល់អំពីអ្វី បញ្ហាក់អំពីលោកមរមននៅក្នុងសេចក្តីយោងខ្លះៗ ដើម្បីកំណត់អំពីអ្វី ដែលពួកគេបង្ហាញអំពីចរិកលក្ខណៈរបស់លោក។ ឧទាហរណ៍ ចូរពិចារណាអំពីអ្វី ដែល លោក បានធ្វើការប្រៀបធៀបជាមួយនឹងអ្វី ដែលលោកអាចធ្វើនៅក្នុងស្ថានភាពមួយ។ ឬ ចូរពិចារណាអំពីសកម្មភាពរបស់លោក នៅក្នុងពន្លឺនៃប្រភេទមនុស្ស ដែលលោកបានរស់នៅ និងជីកនាំនោះ។
3. ចូរសរសេរកថាក៏ណ្តួយអំពី មូលហេតុដែលលោកមរមនអាចបានចាត់ទុកថាជាមនុស្សម្នាក់ក្នុងចំណោមមនុស្ស ដែលមានលក្ខណៈដូចជាព្រះគ្រីស្ទបំផុតនៅក្នុងគម្ពីរ។

មរមន 7

ទីបន្ទាល់របស់លោកមរមន ចំពោះប្រជាជនរបស់លោក

យើងអាននៅក្នុងមរមន 6 ស្តីពីសង្គ្រាម និការងបំផ្លិចបំផ្លាញដ៏គួរឱ្យខ្លាច ដែលលោកមរមនផ្តាល់បានត្រូវរបួស។ មរមន 7 គឺជាសារលិខិតរបស់លោកមរមន “ចំពោះសំណល់នៃប្រជាជននេះ ដែលបានរួចជីវិត” (ខ. 1) ទាំងជំនាន់របស់លោក និងជំនាន់ចុងក្រោយ។ ចាប់តាំងពីកូនប្រុសរបស់លោកមរមន ដែលជាលោកម៉រ៉ូណៃ បានសរសេរមរមន 8 ហើយប្រាប់ដល់យើង អំពីសេចក្តីស្លាប់របស់លោកមរមន នេះគឺជាទីបន្ទាល់ចុងក្រោយដែលលោកមរមនបានសរសេរនៅក្នុងគម្ពីរនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 7

បញ្ជីនេះ (ខ. 9)—ព្រះគម្ពីរមរមន

បញ្ជីនោះ (ខ.9)—ព្រះគម្ពីរប៊ីប

កើតឡើង (ខ.9)—បានធ្វើ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាមរមន 7។

ក អ្វី ឬហេតុអ្វី

នៅក្នុងទីបន្ទាល់ចុងក្រោយរបស់លោកចំពោះកូនចៅនៃពួកសាសន៍ឌីលៃ និងសាសន៍លេមិន លោកមរមនបានសរសេរពីអ្វី ដែល លោកចង់ឱ្យពួកគេដឹង និងធ្វើ។ នៅលើក្បាលទំព័រនៅក្នុងស្បៀវភៅសរសេររបស់អ្នក ចូរធ្វើបញ្ជីមកពីមរមន 7 អំពីអ្វី ដែលលោក ចង់ឱ្យប្រជាជនបានដឹង។ នៅចុងទំព័រ ចូរធ្វើបញ្ជីពីអ្វី ដែលលោកចង់ឱ្យពួកគេធ្វើ។ បន្ទាប់ពីធ្វើបញ្ជីទាំងពីរនេះ ចូរធ្វើការពន្យល់ដោយសង្ខេបថា ហេតុអ្វីក៏អ្នកគិតថា លោកចង់ឱ្យពួកគេដឹង ឬធ្វើដូច្នោះ។

ខ ពាក្យចុងក្រោយរបស់លោកមរមន

មរមន1–7 គឺជាពាក្យចុងក្រោយ ដែលលោកមរមនបានសរសេរនៅលើផ្ទាំងចំណារ។ ចូរសរសេរកថាក័ណ្ឌមួយអំពីអារម្មណ៍ របស់អ្នកអំពីលោកមរមន និងអ្វី ដែលលោកបានសរសេរដាច់ខាងណា។

ការសរសេររបស់កូនប្រុសរបស់លោកមរមន មរ៉ូណៃចាប់ផ្តើមនៅក្នុងមរមន 8។ លោកសរសេរថា ឪពុករបស់លោកបានស្លាប់ នៅក្នុងសង្គ្រាម ហើយ ដែលលោក មរ៉ូណៃ ត្រូវបានទុកចោលឱ្យនៅតែម្នាក់ឯង។ ផ្ទៃកដែលនៅសល់នៅក្នុងជំពូក លោកមរ៉ូណៃ បានសរសេរអំពីការមកដល់នៃព្រះគម្ពីរមរមន នៅក្នុងថ្ងៃចុងក្រោយ ដោយអំណាចរបស់ព្រះ។ ឪពុករបស់លោក បានបញ្ជាឱ្យលោក សរសេរនៅលើផ្ទៃករបស់វា (សូមមើលមរមន 8:1) ហើយលោកបានចុះបញ្ជីផ្ទៃកដែលនៅសល់ មកពីទស្សនៈនិមិត្ត ដែលព្រះអង្គសង្គ្រោះបានបង្ហាញដល់លោកអំពីថ្ងៃចុងក្រោយ (សូមមើលខ. 34–41)។

លោកមរ៉ូណៃដឹងថា គ្មានទណាម្នាក់នៅក្នុងជំនាន់របស់លោក នឹងអានបញ្ជីប្រវត្តិ ហើយថា លោកសរសេរសំរាប់ជំនាន់របស់ យើង។ ចូរកត់ចំណាំថាមរ៉ូណៃ និងព្យាការីផ្សេងទៀតនៅក្នុងព្រះគម្ពីរមរមន បានមើលឃើញពីជំនាន់របស់យើង ប្រធានអែសរ៉ា ថាប់ ប៊ែនសិន បានផ្តល់យោបល់ថា: "បើសិនជាពួកគេមើលឃើញពីជំនាន់របស់យើង ហើយបានជ្រើសរើសរឿងទាំងនោះ ដែល មានតម្លៃបំផុតសំរាប់យើង តើនេះយើងគួរតែសិក្សាអំពីព្រះគម្ពីរមរមនដល់ប៉ុណ្ណាទៀតទៅ? យើងគួរតែបន្តសួរដល់ខ្លួនឯង 'តើហេតុអ្វីបានជាព្រះអម្ចាស់បំផុសគំនិតដល់លោកមរមន (ឬលោកមរ៉ូណៃ ឬអាលម៉ា) ដើម្បីបញ្ចូលការណ៍នោះនៅក្នុងបញ្ជី របស់លោកដូច្នេះ? តើមេរៀន ដែលខ្ញុំអាចរៀនមកពីការណ៍នោះ បានជួយឱ្យខ្ញុំរស់នៅក្នុងជំនាន់ និងយុគសម័យនេះអ្វីខ្លះ?" (នៅក្នុង Conference Report ខែតុលា ឆ្នាំ1986, 5 ឬ Ensign ខែវិច្ឆិកា ឆ្នាំ1986, 6)។ សូមសួរសំនួរទាំងនេះ នៅពេល អ្នកអានជំពូកនេះ ហើយបន្តរហូតដល់ចប់ព្រះគម្ពីរមរមន។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 8

ទៅឯណាទៀត (ខ.4)—កន្លែង

គោលចំណាងទុក (ខ.5)—គោលចំណាងរបស់វា

សាច់ញាតិ (ខ.5)—គ្រួសារ

ខ្ចាត់ព្រាត់ (ខ.15)—បែកខ្ញែក

ឃោរឃៅ (ខ.19)—យ៉ាងឆាប់ គ្មានបារម្ភ ដោយមិនអើពើ

ការសងសឹក (ខ.20, 40–41)—កំហឹងទារុណកម្ម

ក្រខ្វក់ (ខ.28)—មិនស្អាត មិនបរិសុទ្ធ ពុករលួយ

ព្យុះសង្ឃរា (ខ.29)—ព្យុះយ៉ាងខ្លាំង

ចំហាយផ្សែង (ខ.29)—ពពក

ផ្សែងៗ (ខ.30)—ផ្សែងគ្មានជាច្រើន

ប្រមាត់ល្វីងជូរចត់ (ខ.31)—សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" សំរាប់អាលម៉ា 36:18 (ទំព័រ125)

ចំណងនៃអំពើទុច្ចរិត (ខ.31)—ជាឈ្លើយនៃអំពើបាប

ខូច (ខ.33)—ពុករលួយ មិនគោរពប្រតិបត្តិ

រឹងទទឹង (ខ.33)—អំនួត

ផ្លាស់ប្រែ (ខ.33)—ផ្លាស់ប្តូរ ពុករលួយ

សំឈ្បែកបំពាក់ (ខ.36–37)—សំឈ្បែកបំពាក់

កលល្បិច (ខ.36)—ទីង ស្តប់

ចូលចិត្ត (ខ.37)—ការគុបតែងដ៏ហួសប្រមាណ

អំពើអបាយមុខ (ខ.38)—ពុករលួយ ឬបំផ្លិចបំផ្លាញ

សងសឹក (ខ.41)—ធ្វើការសងសឹក

មរមន 8:7—ការបំផ្លាញពួកសាសន៍នីហ្វៃទាំងស្រុង

បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទ យាងមកជួបពួកគេ គ្មានទណាម្នាក់ត្រូវហៅថា "ជាសាសន៍នីហ្វៃ" ឬក៏ "សាសន៍លេមិន" ទេ ប្រជាជន ទាំងអស់មានសាមគ្គីភាពនឹងគ្នានៅក្នុងទ្រង់។ ក្រោយមក ប្រជាជនចាប់ផ្តើមបែកខ្ញែកខ្លួនពួកគេទៅជាក្រុមឰម្ខាងទៀត ហើយហៅ ខ្លួនឯងថា ពួកសាសន៍លេមិន ឬពួកសាសន៍នីហ្វៃ ។យោងតាមការជឿ និងទំនៀមទំលាប់របស់ពួកគេ ដែលមិនចាំបាច់ថាពីព្រោះតែ ពួកគេមកពីពូជអំបូរណាទេ។ ហេតុដូច្នេះហើយ នៅពេលយើងអានថាពួកសាសន៍នីហ្វៃ ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង។ នោះគួរ តែមានកូនចៅរបស់នីហ្វៃ សែម យ៉ាកុប និងយ៉ូសែប នៅក្នុងចំណោមពួកសាសន៍លេមិនដែលមិនត្រូវបានបំផ្លិចបំផ្លាញដូចជាមនុស្ស ម្នាក់ឡើយ។



ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) នៅខាងក្រោមនេះ នៅពេលអ្នកសិក្សាមរមន 8។

ក ការអានអំពីដំបូន្មាន

ផ្អែកទៅលើអ៊ូ ដែលលោកម៉ូរ៉ូណៃបានសរសេរនៅក្នុងមរមន 8:12, 17–19, 21, 23, 34–35 ចូរធ្វើបញ្ជីមួយ នៃ "ការណែនាំ និងដំបូន្មានសំរាប់អ្នកអានព្រះគម្ពីរមរមន។"

ខ ពិពណ៌នាអំពីសម័យកាល

1. នៅក្នុងមរមន 8:26–32 ម៉ូរ៉ូណៃ បានពិពណ៌នាអំពីសម័យកាលនៅក្នុងព្រះគម្ពីរមរមន ដែលនឹងមកនៅក្នុងពិភពលោក។ ចូរធ្វើបញ្ជីកាលៈទេសៈយ៉ាងហោចណាស់ឱ្យបានដប់ ដែលលោកម៉ូរ៉ូណៃបានទិយាយថា នឹងមាននៅអំឡុងពេលនោះ។
2. តើអ៊ូខ្លះ ធ្វើឱ្យអ្នករំតើបបំផុត អំពីការព្យាករណ៍របស់លោកម៉ូរ៉ូណៃអំពីសម័យរបស់យើងនេះ?

គ ការឆ្លើយតបចំពោះលោកម៉ូរ៉ូណៃ

1. នៅក្នុងមរមន 8:34–35 លោកម៉ូរ៉ូណៃបានធ្វើទីបន្ទាល់ថា លោកបានឃើញពីជំនាន់របស់យើង។ ផ្អែកទៅលើអ៊ូ ដែលយើងបានអាននៅក្នុងខ. 36–41 តើអ៊ូ ដែលមើលទៅហាក់ដូចជា ការព្រួយបារម្ភបំផុតចំពោះលោក?
2. ចូរស្វែងរក និងធ្វើបញ្ជីរាល់សំនួរទាំងអស់ ដែលលោកម៉ូរ៉ូណៃបានសួរនៅក្នុងមរមន 8:36–41។ បន្ទាប់មកសរសេរចំលើយថា អ្នកគិតថាជាតំណាងឱ្យចរិតលក្ខណៈរបស់លោកិយសំខាន់បំផុតសព្វថ្ងៃ។
3. ចូរសរសេរសំបុត្រមួយច្បាប់ដោយសង្ខេប បើសិនជាអ្នកត្រូវសរសេរត្រលប់ទៅលោកម៉ូរ៉ូណៃវិញ។ ចូរពន្យល់ទៅដល់លោក ពីអ៊ូ ដែលអ្នកកំពុងធ្វើដោយផ្តាល់អំពីការព្រួយបារម្ភ ដែលលោកបានបញ្ជាក់នៅក្នុងមរមន 8:36–41។

មរមន 9

"ខ្ញុំដឹងថា អ្នករាល់គ្នានឹងឮពាក្យរបស់ខ្ញុំ"

នៅពេលអ្នកអាននៅក្នុងមរមន 8 លោកម៉ូរ៉ូណៃ បានឃើញពីជំនាន់របស់យើង ហើយដឹងពីពេលវេលា ដែលពាក្យព្យាការរបស់ លោកនឹងបានសំរេច។ នៅក្នុងមរមន 9 លោកបានយកអ៊ូ ដែលលោកបានគិតគឺជាឱកាសចុងក្រោយតែមួយគត់ ដើម្បីទិយាយ ទៅកាន់ប្រជាជនដែលមិនជឿ នៅក្នុងជំនាន់របស់យើង (សូមមើលម៉ូរ៉ូណៃ 1:1)។ ទោះជាយ៉ាងណាក៏ដោយ អ្នកទាំងឡាយ ដែលជឿ អាចរៀនច្រើនមកពីអ៊ូ ដែលលោកបានបង្រៀន និងរបៀបដែលលោកបានបង្រៀន។

ការយល់ដឹងអំពីព្រះគម្ពីរ

មរមន 9

ការធ្វើទោស (ខ. 2)—ពេលវេលានៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ

ត្រូវញាំញី (ខ. 3)—ទារុណកម្ម រងទុក្ខ

ឥតរលត់ (ខ. 5)—មិនអាចពន្លត់

ការប្រែប្រួល ដែលប្រែប្រួល (ខ. 9, 10)—បានផ្លាស់ប្តូរ

ខាងសាច់ឈាម (ខ. 13)—ខាងរាងកាយ មនុស្សជាតិ

ឈប់ (ខ. 15, 19, 20)—ឈប់ បញ្ចប់

បានធ្វើ (ខ. 16–19)—បានធ្វើ

ពួកសិស្សរបស់ទ្រង់ដែលនៅលើផែនដី (ខ. 22)—ពួកសិស្សនីហ្វៃបីនាក់ដែលបានផ្លាស់ប្រែ ហើយនៅបន្តធ្វើកិច្ចការរបស់ពួកគេ នៅលើផែនដី

បញ្ជាក់ (ខ. 25)—បង្ហាញ

មើលងាយ (ខ. 26–27)—ស្អប់

ការសាកល្បង (ខ. 28)—ការសាកល្បងនៅក្នុងជីវិតរមែងស្លាប់

ដែលសំរាប់យកមកបំរើការសំរើបរបស់អ្នកឡើយ (ខ. 28)—បំពេញតាមចំណង់ខាងរាងកាយរបស់អ្នក ឬខាងលោកិយ

ត្រូវបានកែប្រែ (ខ. 32–33)—បានផ្លាស់ប្តូរ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពក ឬខ នៅពេលអ្នកសិក្សាមរមន 9។

ក ផ្តល់ដំបូន្មានសំរាប់មនុស្សជាក់លាក់

យ៉ាងហោចណាស់លោកមរមន បាននិយាយទៅដល់មនុស្សបួនក្រុមនៅក្នុងមរមន 9។ ចូរសង្ខេបសារលិខិតរបស់លោកសំរាប់ះ

1. អ្នកទាំងឡាយណា "ដែលពុំជឿដល់ព្រះគ្រីស្ត" (ខ. 1–6)។
2. អ្នកទាំងឡាយណា "ដែលបដិសេធវិវរណៈទាំងឡាយនៃព្រះទៀត" (ខ. 7–14)។
3. អ្នកទាំងឡាយណា ដែលពុំជឿដល់ព្រះអាចធ្វើអព្ភូតហេតុ (ខ. 15–25)។
4. អ្នកទាំងអស់គ្នា "ជាអ្នកមើលងាយដល់កិច្ចការនៃព្រះអម្ចាស់" (ខ. 26–31)។

ខ គោលលទ្ធិ នៃផែនការរបស់ព្រះ

គ្មានវគ្គគម្ពីរមួយណា នៅក្នុងផែនការសង្គ្រោះរបស់ព្រះ ត្រូវបានពន្យល់យ៉ាងលំអិត និងបានបង្ហាញអំពីទំនាក់ទំនងមួយ នៃធាតុ ទាំងអស់របស់ផែនការចំពោះគ្នាទៅវិញទៅមកនោះទេ។ គោលលទ្ធិ នៃផែនការមានទៅពាសពេញគម្ពីរទាំងអស់ ដែលអ្នក ទាំងឡាយ ព្យាយាមសិក្សាព្រះគម្ពីរអាចរកឃើញ ហើយអនុវត្តគោលលទ្ធិទាំងនោះ។ តំរូវការនៃការខិតខំប្រឹងប្រែងធ្វើឱ្យ ការរៀនសូត្រ កាន់តែមានអត្ថន័យ និងងាយចងចាំ។ មរមន 9 មានគោលលទ្ធិសំខាន់ឲជាច្រើន ដែលទាក់ទងទៅនឹង "ផែនការ នៃសុភមង្គលដ៏មហិមា។" នៅក្នុងមរមន 9 ចូរស្វែងរកនូវអ្វី ដែលអ្នកគិតថាជាគោលលទ្ធិសំខាន់ចំនួនប្រាំ ដែលទាក់ទងទៅនឹង ផែនការ។ សូមសរសេរគោលលទ្ធិទាំងនោះ នៅក្នុងស្បៀវភៅសរសេររបស់អ្នក ព្រមជាមួយនឹងការពន្យល់ដោយសង្ខេបមួយ អំពីសារៈសំខាន់នៃគោលលទ្ធិនេះចំពោះផែនការទាំងមូល។

គម្ពីរអេធើរ



តើអេធើរជានរណា?

អេធើរ គឺជាព្យាការីចុងក្រោយ និងជាអ្នកថែរក្សាបញ្ជីប្រវត្តិរបស់ប្រជាជនយ៉ារេឌ (សូមមើលអេធើរ 15:33–34)។ ដំណើរ រឿងរបស់លោកដែលស្តីអំពីការកើនឡើងនិងធ្លាក់ចុះរបស់ប្រជាជនយ៉ារេឌ គឺត្រូវបានចុះបញ្ជីនៅលើផ្ទាំង ចំនួនម្ពៃបួនសន្លឹក ហើយដែលបានរកឃើញដោយប្រជាជនរបស់ស្តេចលិមហៃ (សូមមើលម៉ូសាយ 8:7–11)។ ជាយថាហេតុ ស្តេចម៉ូសាយ បានធ្វើការបកប្រែពីដំណើររឿង ហើយបានធ្វើឱ្យទ្រង់ និងប្រជារាស្ត្រមានសេចក្តីទុក្ខសោកយ៉ាងខ្លាំង (សូមមើលម៉ូសាយ 28:18)។ នៅពេលម៉ូរ៉ូណៃ ដើរត្រាច់ចរមិនដឹងអំពីដែនដី លោកបានសង្ខេបបញ្ជីប្រវត្តិ របស់សាសន៍យ៉ារេឌ ហើយបញ្ចូល បញ្ជីនេះជាមួយនឹងបញ្ជីដទៃទៀត នៃព្រះគម្ពីរមរមន ពីព្រោះឱពុករបស់លោក មរមន បាននិយាយថា "មនុស្សទាំងអស់ ត្រូវដឹងនូវរឿងទាំងឡាយ ដែលបាន សរសេរនៅក្នុង ដំណើររឿងនេះ" (ម៉ូសាយ 28:19)។

តើពួកសាសន៍យ៉ារេឌជាអ្នកណា?

ព្រឹត្តការណ៍ទាំងឡាយមានទាក់ទងនៅក្នុងគម្ពីរអេធើរ ចាប់ផ្តើមនៅជំនាន់នៃប៉មនៃក្រុងបាបិល (ប្រហែលជា 2200 ម.គ.ស) នៅពេលព្រះអម្ចាស់ បំភាន់ភាសាទាំងឡាយ។ ព្រះអម្ចាស់ ប្រទានពរដល់យ៉ារេឌ និងបងប្រុសរបស់លោក និងគ្រួសាររបស់ពួកគេ ដើម្បីរួចផុតពីការបំភាន់ភាសា ហើយបាននាំពួកគេទៅកាន់ទ្វីបអាមេរិក។ ពួកគេបានក្លាយទៅជាពួកសាសន៍យ៉ារេឌ។ នៅទីនោះ ពួកគេមានការរីកចំរើន និងទទួលពរដ៏យពីព្រះអម្ចាស់ ដូចជាប្រជាជនជំរើសរបស់ទ្រង់ដូច្នេះដែរ។ ទោះជាយ៉ាងណាក្តី រឿងរបស់ ពួកសាសន៍យ៉ារេឌ ត្រូវបានបញ្ចប់នៅក្នុងលក្ខណៈស្រដៀងគ្នាយ៉ាងច្រើន ទៅនឹងពួកសាសន៍នីហ្វៃនៅ 2600 ឆ្នាំក្រោយមក។ អំនួត ការរួមគំនិតស្វាត់កំបាំង និងការបដិសេធពាក្យរបស់ព្យាការី បណ្តាលឱ្យប្រជាជាតិទាំងពីរនេះ ចាកចេញពីព្រះ ហើយត្រូវបានបំផ្លាញទាំងស្រុង។

តើខ្ញុំអាចរៀនអ្វីខ្លះ មកពីដំណើររឿងនេះ?

គម្ពីរអេធើរមានដំណើររឿងនៃសង្គ្រាម ការបះបោរ និងការបំផ្លិចបំផ្លាញជាច្រើន នៅក្នុងចំណោមប្រជាជនយ៉ារេឌ។ ទោះជាយ៉ាង ណាក៏ដោយ ក្នុងរវាងសេចក្តីទុច្ចរិតដ៏ធំនេះ ក៏មានការផ្លាស់ប្តូរ ដំណើររឿង នៃប្រជាជន ដែលអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវ ត្រីស្ត ហើយទទួលបានអព្ភូតហេតុដ៏អស្ចារ្យជាច្រើនមកពីព្រះអម្ចាស់។ គោលលទ្ធិសំខាន់ឲជាច្រើន ត្រូវបានបង្រៀនផងដែរ នៅក្នុង ទំព័រព្រះគម្ពីរ។ នៅពេលសមាជិកម្នាក់នៃសាសនាចក្ររស់នៅក្នុងថ្ងៃចុងក្រោយ អ្នកប្រហែលជាឃើញថាខ្លួនរបស់អ្នកត្រូវហ៊ុំព័ទ្ធ ទៅដោយឥទ្ធិពលអាក្រក់។ មេរៀនទាំងឡាយមពីគម្ពីរអេធើរនឹងជួយដល់អ្នកឱ្យនៅតែរឹងមាំ និងបរិសុទ្ធ។ សូមស្លរដល់ខ្លួនឯងពីអ្វីដែលអ្នកអាចរៀនមកពីមនុស្សដ៏ស្មោះត្រង់ ដូចជាបងប្រុសយ៉ារេឌ អេធើរ និងអ្នកផ្សេងទៀត។

អេធើរ 1

ពួកសាសន៍យ៉ារេឌនៅឯប៉ែម នៃក្រុងបាបិល

តើអ្នកធ្លាប់មានគ្រាមួយ ដែលត្រូវការជំនួយជាពិសេសមកពីព្រះអម្ចាស់ឬទេ—ជាពេលដែលអ្នក ត្រូវការពរជ័យ ឬកម្លាំងបន្ថែមពីលើ កំលាំងដែលខ្លួនអ្នកមាននោះ? មានក្រុមគ្រួសារចំនួនពីរគ្រួសាររស់នៅក្នុងដំនាន់ នៃប៉ែមក្រុងបាបិល ត្រូវការជំនួយពិសេសមកពីព្រះ អម្ចាស់។ នៅពេលអ្នកអានអេធើរ 1 សូមរកមើលពរជ័យពិសេស ដែលពួកគេត្រូវការ និងសូមរកមើលថា តើពួកគេមានគុណសម្បត្តិគ្រប់គ្រាន់ សំរាប់ពរជ័យនោះដោយរបៀបណា។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 1

បានកើត (ខ. 3–4)—បានកើតឡើង

ស្បថនៅក្នុងសេចក្តីខ្ញាល់ (ខ. 33)—បានសន្យានៅក្នុងសេចក្តីខ្ញាល់របស់ទ្រង់

បំភាន់ (ខ. 33–37)—ធ្វើឱ្យភាន់ច្រឡំ

នាំមុខ (ខ. 42)—ដឹកនាំ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពក និងខ នៅពេលអ្នកសិក្សាអេធើរ 1។

ក សរសេរការសង្ខេបមួយ

អេធើរ 1:2 សំដៅទៅលើ "ផ្តាំឯចំនួនម្ភៃបួនសន្លឹក។" សូមរំលឹកអំពីរូបភាព "ប្រភពសំខាន់សំរាប់ផ្តាំឯព្រះគម្ពីរមរមន" (ទំព័រ 12)សារឡើងវិញ និងបទគម្ពីរខាងក្រោមនេះ ហើយសរសេរការសង្ខេបមួយពីអ្វី ដែលអ្នកបានរៀនអំពីបញ្ជីប្រវត្តិនេះ៖ ម៉ូសាយ 8:9, 21:27, 22:14, 28:11, អាលម៉ា 37:21–32។

ខ ការដោះស្រាយបញ្ហាជាមួយនឹងជំនួយមកពីព្រះអម្ចាស់

ចូរចម្លងតារាងខាងក្រោមនេះ ដាក់ចូលទៅក្នុងស្បៀវភៅសរសេររបស់អ្នក។ អានអេធើរ 1:33–43 ហើយឆ្លើយសំនួរទីមួយៗ ដោយប្រើទូរអ៊ូ ដែលអ្នករៀនមកពីខគម្ពីរ ដែលបានរាយបញ្ជី។

តើបញ្ហាជាអ្វីខ្លះ?	តើធ្វើសកម្មភាពអ្វីខ្លះ?	តើព្រះអម្ចាស់ប្រទានពរដល់ពួកគេដោយរបៀបណា?
ខ. 33–34	ខ. 35	ខ. 35
ខ. 36	ខ. 37	ខ. 37
ខ.38	ខ. 39–40	ខ. 41–43

អេធើរ 2

ពួកសាសន៍យ៉ារេឌសង់កេត្រា



ពួកសាសន៍យ៉ារេឌ បានធ្វើដំណើរឆ្លងកាត់ទឹកដាច្រើន នៅពេលពួកគេត្រូវបានដឹកនាំទៅកាន់ដែនដីសន្យា (សូមមើលអេធើរ 2:6–7)។ ព្រះអម្ចាស់ដឹងថា ដំណើររបស់ពួកគេឆ្លងកាត់សមុទ្រច្បាស់ជាមានការលំបាក ហើយក៏បានផ្តល់ការណែនាំជាពិសេសដល់ ពួកគេអំពីរបៀបសង់ទូក ដែលនឹងជួយឱ្យពួកគេធ្វើដំណើរដោយសុវត្ថិភាព។ នៅពេលអ្នកអានអេធើរ 2 ចូរធ្វើ ការប្រៀបធៀបពីដំណើររបស់ពួកគេទៅកាន់ដែនដីសន្យាមកនឹងជីវិតរបស់អ្នក នៅពេលអ្នករីកចំរើនទៅកាន់ឧតរសេឡេស្ទាល។ អែលឌើរ ឌី. ហ៊ីងឃ្លី ដែលពេលនោះគាត់ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ បានបង្រៀនថា ការធ្វើដំណើរនៅក្នុង ជីវិតរបស់យើង នឹងមានការលំបាកផងដែរ៖

"ខ្ញុំ បានជួបនឹងមនុស្សជាច្រើន ដែលតែងតែរអ៊ូរទាំអំពីបទ្ទុក នៃការទទួលខុសត្រូវរបស់ពួកគេ។ ជាការពិតណាស់ សម្ពាធទាំង ឡាយ គឺធំណាស់។ មានកិច្ចការជាច្រើន ហើយច្រើនអនេក ដើម្បីធ្វើ . . .។ ចូរធ្វើការផ្លាស់ប្តូរការគិតរបស់អ្នក។ ជំណឹងល្អគឺជា ជំណឹងដ៏ល្អ។ មានមនុស្សលោក ដើម្បីឱ្យគេអាចមានសេចក្តីអំណរ។ សប្បាយឡើង! ចូរទុកឱ្យ

សុភមង្គលនោះបានភ្លឺចែងចាំង តាមរយៈ ទឹកមុខ របស់អ្នក ហើយនិយាយតាមរយៈទិបន្ទាល់របស់អ្នក . . .។

“ខ្ញុំចូលចិត្តពាក្យទាំងនេះរបស់លោកដែនខិន លយដ៏ ចូន . . .។

“អ្នកណា ដែលនឹកស្រមៃថាសុភមង្គល គឺជារឿងធម្មតា នោះគឺកំពុងតែចំណាយពេលវេលាដ៏តប្រមោជន៍យ៉ាងច្រើនរត់ចុះឡើង ស្រែកថាខ្លួនត្រូវគេប្លន់ហើយ។

‘ចូរដាក់ កុំទំលាក់។ សាច់គោភាគច្រើន ស្ងួត។ កុមារភាគច្រើនធំឡើងប្រែក្លាយបានត្រឹមតែជាមនុស្ស។ ដោគដ័យនៃអាពាហ៍ពិពាហ៍ភាគច្រើន គំរូវិញ្ញាណ មានការអធ្យាស្រ័យនៅក្នុងកំរិតខ្ពស់មួយ។ ការងារភាគច្រើន ជារឿយៗ មានការ មិនចូលចិត្តច្រើនជាងតាមបែបផ្សេងគ្នា។

‘ជីវិតគឺដូចជាផ្លូវសំរាប់ធ្វើដំណើរកាលពីអតីតកាល—គឺមានការពន្យាពេល,មានផ្លូវខ្វាត់ខ្វែង មានផ្សែង មានធូលី មានជាប់ដេះ និងមានការរញ្ជួយនៅលាយឡំគ្នា ហើយវាមានភាពស្រស់ស្អាតតែនៅក្នុងខណៈពេល ដែលមើលពីចំងាយ និងមានចិត្តរីករាយ ចំពោះសន្ទុះល្បឿន ដែលស្ទុះទៅមុខយ៉ាងខ្លាំងប៉ុណ្ណោះ។

‘មានល្បិចមួយ គឺត្រូវថ្លែងអំណរគុណព្រះអម្ចាស់សំរាប់ការអនុញ្ញាតឲ្យអ្នកមានមធ្យោបាយធ្វើដំណើរ’ (Deseret News ថ្ងៃទី 12 ខែមិថុនា ឆ្នាំ1973)” (Four Imperatives for Religious Educations *[address to religious educators, ថ្ងៃទី 15 ខែ វិច្ឆិកា ឆ្នាំ1978], 4)*។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 2

ដាក់អន្ទាក់ (ខ. 2)—អន្ទាក់

ដែលបកប្រែថា (ខ. 3)—ដែលមានន័យថា

តំបន់ (ខ. 5)—តំបន់

គេត្រា (ខ. 6, 16, 18)—ទូក

ទុកឱ្យ (ខ. 7, 22)—អនុញ្ញាត

បានរក្សាទុក (ខ. 7)—បានសង្គ្រោះការពារ

បានបន្ទោសថ្នាក់ថ្នម (ខ. 14)—ស្តីបន្ទោស កែតំរូវ

ចុងស្រួច (ខ. 17)—ចំនុច

ត្រូវបក (ខ. 23)—ធ្វើឱ្យខ្ទេច

អេធើរ 2:13—“ម៉ូរីអានគុមើរ”

“នៅអំឡុងពេលកំពុងធ្វើការតាំងលំនៅនៅក្នុងទីក្រុងខើតឡង់ រែលខើរ រ៉ែណុល ខាហូន គាត់មានកូនប្រុសមួយ កើតនាពេលនោះ ។ នៅថ្ងៃមួយ ពេលប្រធានយ៉ូសែបស្ម៊ីធ ដើរកាត់មុខទ្វាររបស់គាត់ គាត់បានហៅព្យាការីចូលលេង ហើយសុំឱ្យលោកប្រទានពរ និងដាក់ឈ្មោះឱ្យ កូនតូចរបស់គាត់។ លោកយ៉ូសែបក៏បានធ្វើតាមសំណូមពរ ហើយដាក់ឈ្មោះដល់ក្មេងប្រុសនោះថា ម៉ាហូនរី ម៉ូរីអានគុមើរ។ នៅពេលលោកបានបញ្ចប់ការប្រសិទ្ធិពរ លោកដាក់កូនតូចនៅលើត្រែ ហើយងាកទៅរកលោករែលខើរ ខាហូន រួចលោកមានប្រសាសន៍ថា ឈ្មោះដែលខ្ញុំបានដាក់ឱ្យកូនប្រុសរបស់អ្នក គឺជាឈ្មោះរបស់បងប្រុសរបស់យ៉ារេឌ ព្រះអម្ចាស់បានទើបតែបង្ហាញ (បើកបង្ហាញ) មកដល់ខ្ញុំ” (“Questions and Answers,” *Improvement Era* ខែកក្កដា ឆ្នាំ1905, 705)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក—គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សាអេធើរ 2។

ក ឆ្លើយតបចំពោះសំនួរមួយ

ចូរនឹកគិតថាមានមិត្តម្នាក់មិនមែនជាសមាជិក នៃសាសនាចក្រ មកសួរអ្នកថាតើពាក្យ “ដែនដីសន្យា” (អេធើរ 2:9) មានន័យ យ៉ាងណា។ ចូរប្រើអេធើរ 2:8–12 ហើយសរសេរពីអ្វី ដែលអ្នកនឹងនិយាយដើម្បីជួយឱ្យមិត្តរបស់អ្នកយល់អត្ថន័យមួយ ក្នុងចំណោមអត្ថន័យទាំងឡាយនៃឃ្លានេះ ដែលមានទាក់ទងទៅនឹងដែនដី នៅក្នុងខគម្ពីរទាំងនេះ។

ខ ចូរសរសេរ សេចក្តីថ្លែងការណ៍ “ហើយដូច្នេះយើងឃើញថា”

បន្ទាប់ពីអានអេធើរ 2:13–16 ចូរគិតអំពីមេរៀនមួយ ដែលជំណើរឡើងនេះបង្រៀន ហើយសរសេរសេចក្តីថ្លែងការណ៍ “ហើយដូច្នេះយើងឃើញថា” ដែលសង្ខេបពីអ្វី ដែលព្រះអម្ចាស់ចង់ឱ្យយើងរៀនមកពីបទពិសោធន៍នេះ។

គ គូររូបភាពមួយ

1. ចូរអំលើក អេធើរ 2:16–25 សារឡើងវិញ ហើយគូររូបភេត្រាមួយរបស់ពួកសាសន៍យ៉ារេឌ ទៅតាមគំនិតដែលអ្នកយល់ឃើញ ពីទំរង់រូបរាង្គរបស់វា។ ការគូររូបរបស់អ្នកគួរតែបង្ហាញថា តើភេត្រានោះមានជំណើរការទៅដោយដូចម្តេច ហើយថាតើហេតុអ្វីក៏ការ ច្នៃម៉ូដរបស់ពួកគេទទួលបានដោគដ័យទេវិញ។
2. សូមប្រើអេធើរ 2:1–7, 6:1–4 ដើម្បីធ្វើជាបញ្ជីមួយពីអ្វី ដែលពួកសាសន៍យ៉ារេឌយកទៅដាមួយពួកគេដាក់នៅក្នុងភេត្រា របស់ពួកគេ។

*បន្ទាប់ពីអ្នកស្លាប់ តើចរិតលក្ខណៈអ្វីខ្លះ ដែលអ្នកចង់ឱ្យមនុស្សធ្វើមកលើអ្នកនៅពេលពួកគេគិតអំពីជីវិតរបស់អ្នកនោះ? បងប្រុសយ៉ារេឌ បានដឹងអំពីជំនឿរបស់គាត់។ ដោការពិតណាស់ ពីព្រោះតែជំនឿរបស់គាត់ គាត់បានឃើញព្រះយេស៊ូវគ្រីស្ទ កាលពីជីវិតមុនជីវិតនេះ។ អែលខើរ ដែក្លូ អរ ហូលែន ជាសមាជិកម្នាក់នៅក្នុងក្រុមសាវកដប់ពីរនាក់ បានពន្យល់ថា នៅពេល ព្រះគ្រីស្ទមានបន្ទូល “ហើយយើងមិនដែលបង្ហាញរូបដល់មនុស្ស ដែលយើងបានបង្កើតឡើងទេ” (អេធើរ 3:15) ទ្រង់ “មាន បន្ទូលទៅកាន់បងប្រុសយ៉ារេឌថា យើងមិនដែលបង្ហាញរូបដល់មនុស្ស តាមលក្ខណៈនេះ មិនមែនមានមកតាមចិត្តរបស់យើងទេ បើសិនជាកើតមានឡើងមកនោះ គឺតាមជំនឿរបស់អ្នកដែលឃើញនោះប៉ុណ្ណោះ។ ក៏ដូចជាច្បាប់មួយអញ្ចឹង ព្យាការី គឺ ត្រូវបាន អញ្ជើញឱ្យចូលទៅក្នុង វត្តមានរបស់ព្រះអម្ចាស់ . . .។ កាលពីមុនព្រះអម្ចាស់ ព្រះអង្គទ្រង់ បានភ្ជាប់ជំនឿដែលមិនធ្លាប់មាន មកពីមុន ជាមួយនឹងទស្សនៈ និមិត្តដែលមិនធ្លាប់មាននេះ” (Christ and the New Covenant, *23)*។ នៅពេលអ្នកសិក្សា អេធើរ 3 ចូរស្វែងរកមើល អ្វីៗផ្សេងទៀត ដែលអ្នកអាចរៀនអំពីអំណាច នៃសេចក្តីជំនឿ មកពីបងប្រុសរបស់យ៉ារេឌ។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 3

រំលាយ (ខ. 1, 3)—ដុតកំដៅ ហើយរលាយ

ត្រូវហ៊ុំព័ទ្ធ (ខ. 2)—ព័ទ្ធជុំវិញ គ្របដណ្តប់

គ្រាំគ្រេង (ខ. 3)—ញុះយ៉ាងខ្លាំង

រាំងនន (ខ. 6, 9–20)—រាំងននបិទបាំង ឬគ្រៀងរារាំង

រាយ (ខ. 8)—រាយ

ត្សូងពីរដុំ (ខ. 23, 28)—យូរីម និងធូមីម

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សាអេធើរ 3។

ក ចូរអានរកមើលចំលើយ

ចូរឆ្លើយសំនួរខាងក្រោមនេះ នៅពេលអ្នកសិក្សាអេធើរ 3:1–8:

1. តើហេតុអ្វីបងរបស់យ៉ារេឌធ្វើឱ្យថ្មមានពន្លឺ?
2. តើហេតុអ្វីបងរបស់យ៉ារេឌគិតថាព្រះអម្ចាស់នឹងកើតសេចក្តីខ្លាល់?
3. តើបងរបស់យ៉ារេឌអធិស្ឋានសុំអ្វី?

ខ តើអ្នកបានរៀនអ្វីខ្លះ?

នៅក្នុងអេធើរ 3 បងរបស់យ៉ារេឌ បានរៀនយ៉ាងច្រើនអំពីព្រះយេស៊ូវគ្រីស្ទ "ជាពន្លឺ និងជាជីវិតហើយជាសេចក្តីពិតនៃលោកិយ" (អេធើរ 4:12)។ សូមរំលឹកអេធើរ 3 សារឡើងវិញ ហើយធ្វើបញ្ជីនៃសេចក្តីពិតយ៉ាងហោចណាស់ឱ្យបានដប់ ដែលអ្នករៀនអំពី ព្រះអង្គសង្គ្រោះ។

អេធើរ 4

ប្រែចិត្ត ហើយមករកព្រះគ្រីស្ទ

អ្នកប្រហែលជានឹកឃើញថា ផ្នែកមួយ នៃផ្នាំងចំណារមាស ដែលញ្យាការីយ៉ូសែប ស្មីធ បានទទួលនោះគឺវាមានផ្សាភ្ជាប់ទុក។ តើអ្នកធ្លាប់មានការងឿងឆ្ងល់ថាមានអ្វី ផ្ទុកនៅក្នុងបញ្ជីប្រវត្តិពិសិដ្ឋនោះឬទេ? នៅក្នុងអេធើរ 4 លោកមូរ៉ឺណៃ បានធ្វើការពន្យល់ខ្លះព្ធ អំពីបញ្ជីរៀង នៃបញ្ជីប្រវត្តិនេះ។ នៅពេលអ្នកអាន សូមរកមើលចំលើយសំរាប់ឆ្លើយសំនួរដូចតទៅនេះ: តើហេតុអ្វីបានជាយើងឥតមានបញ្ជីប្រវត្តិនៃបងរបស់យ៉ារេឌ មកធ្វើការសិក្សា? តើអ្វីខ្លះ ដែលត្រូវតែកើតឡើងមុនពេល ដែលបញ្ជីប្រវត្តិរបស់គាត់នឹងបើកឡើងនោះ? តើយើងម្នាក់ព្ធតំរូវឱ្យមានអ្វីខ្លះ?

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 4

សម្តែងត្រូវដឹង (ខ. 2, 4, 14, 16)—បើកបង្ហាញ

ចុះអន់ថយ (ខ. 3)—ធ្លាក់ចុះបន្តិចម្តងព្ធ

ប្រដាប់បកប្រែ (ខ. 5)—យូរីម និងធូមីម

ត្រូវបណ្តាសា (ខ. 8)—បណ្តាសាទារុណកម្ម

ហែក (ខ. 15)—ហែកបើកចេញ

បានចាប់ផ្តើម (ខ. 17)—ចាប់ផ្តើម

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងសកម្មភាព ខ ឬ គ នៅពេលអ្នកសិក្សាអេធើរ 4។

ក ពន្យល់ពីអ្វី ដែលគាត់នឹងនិយាយ

មកពីអ្វី ដែលយើងបានរៀននៅក្នុង អេធើរ 4:1–6 ចូរសរសេរពីអ្វី ដែលអ្នកគិតថាលោកមូរ៉ឺណៃនឹងឆ្លើយសំនួរដូចខាងក្រោម នេះ:

1. តើហេតុអ្វី បានជាអ្នកចាំបាច់ត្រូវលាក់បញ្ជីប្រវត្តិ និងប្រដាប់បកប្រែដូច្នេះទៅវិញ?
2. តើអ្វីខ្លះ ដែលត្រូវតែកើតឡើង មុនពេលបញ្ជីប្រវត្តិនឹងត្រូវបានបើកបង្ហាញ?
3. តើនៅក្នុងបញ្ជីប្រវត្តិដែលអ្នកអានមានអ្វីខ្លះ?

២ សរសេរជានិយមន័យ

សូមអានអេធើរ 4:11–12 ហើយសរសេរនិយមន័យនៃពាក្យ*ល្ហ* នៅពេលពាក្យនេះប្រើនៅក្នុងខគម្ពីរទាំងឡាយនោះ។

៣ សរសេរប្រយោគមួយដោយសង្ខេប

ចូរប្រើពាក្យនីមួយៗ ដែលមកពីអេធើរ 4:13–19 ដូចតទៅនេះ ព្រមទាំងសរសេរប្រយោគពីរបីដែលបង្ហាញពីគំនិតចំបងនៅក្នុង វគ្គនេះ *សាសន៍ដដែ* បង្ហាញឱ្យឃើញ *ហែក* *ត្រូវលាតត្រដាងបានចាប់ផ្តើម* *ត្រូវបានដំកើង*។

អេធើរ 5
ការសន្យាមួយ
របស់សាក្សីបីនាក់

អេធើរ 5 គឺជាសារលិខិតមួយមកពីលោកម្ចាំណៃចំពោះអ្នកបកប្រែព្រះគម្ពីរមរមននៅថ្ងៃអនាគត—ព្យាការីយ៉ូសែប ស្មីធ។ ចូរ នឹកគិតថា តើព្យាការីយ៉ូសែប ស្មីធមានអារម្មណ៍ជាយ៉ាងណា នៅពេលលោកបានរៀននៅក្នុងជំពូកនេះថា នឹងមានសាក្សីដទៃបីនាក់ ទៀត ឃើញផ្ទាំងចំណារមាស។ តើមានអ្វីខ្លះទៀតអំពីសារលិខិតរបស់លោកម្ចាំណៃ ដែលអ្នកគិតថានឹងមានការចាប់អារម្មណ៍ជា ពិសេសចំពោះលោក?

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 5

មានឯកសិទ្ធិ (ខ. 2)—គាប់ចិត្ត ពរជ័យ ជំរើស

យ៉ាងច្បាស់ (ខ. 3)—ដោយគ្មានការសង្ស័យ

ត្រូវបានបញ្ជាក់ (ខ. 4)—ជាតស្ពុតាងអះអាងថាពិត


Be it known unto all nations, kindred,
whom this work shall com... That we, the
and our Lord Jesus C... seen the
which is a record of ... Nephi
brethren, and also of ... Jared
which hath been spo... kn
lated ... and ... for
wher... w of ... the
that ... the eng... which
bee... by the power of God
with ... erness, that an angel of
he b... id before ... eyes, that
and the ... ngs ther... know
the Father, and our ... Christ,
these things are true ... velous
voice of the Lord ... t we
fore, to be obedient ... dmen
these things And we ... we ar
garments of the blood of ... en, and be
seat of Christ and shall dwell with him
honor be to the Father, and to the Son,

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងខ នៅពេលអ្នកសិក្សាអេធើរ 5។

៣ សរសេរទីបន្ទាល់របស់អ្នក

សូមអានអេធើរ 5:3 ហើយកត់សំគាល់ទៅលើពាក្យ *យ៉ាងច្បាស់*។

1. សូមអាន "ទីបន្ទាល់របស់សាក្សីបីនាក់" នៅក្នុងគំរបខាងមុខនៃព្រះគម្ពីរមរមន។ តើមានអ្វីកើតឡើង ដែលធ្វើឱ្យពួកគេអាច "ដឹងយ៉ាងច្បាស់" ថាបញ្ជីប្រវត្តិសាសន៍នីហ្វៃជាសេចក្តីពិត។
2. សូមសរសេរបទពិសោធន៍មួយ ដែលអ្នកមានជាមួយនឹងព្រះគម្ពីរមរមន ដែលជួយឱ្យអ្នកដឹងថាព្រះគម្ពីរមរមនពិត។

២ ពន្យល់ពីមូលហេតុ

បន្ទាប់ពីអានអេធើរ 5:4–6 រួចពន្យល់ថាហេតុអ្វីក៏អ្នកគិតថាព្រះអម្ចាស់នឹងតំរូវឱ្យមាន និងហៅសាក្សីដើម្បីធ្វើទីបន្ទាល់អំពី សេចក្តីពិតដ៏ពេញលេញរបស់ព្រះគម្ពីរមរមន។

អេធើរ 6

ពួកសាសន៍យ៉ារេឌឆ្លងកាត់សមុទ្រ

តើវាជាគ្រោះថ្នាក់ និងគួរឱ្យភ័យខ្លាចយ៉ាងណាទៅ ចំពោះការធ្វើដំណើរ របស់ពួកសាសន៍យ៉ារេឌ ដែលត្រូវតែមាននៅពេលឆ្លងកាត់ សមុទ្រនោះ! ចូរកត់ចំណាំពីរបៀប ដែលព្រះអម្ចាស់បានជួយ និងកំសាន្តចិត្តពួកគេ។ មានពេលខ្លះបន្ទាប់ពីការមកដល់ របស់ ពួកគេនៅដែនជ័យសន្យា ប្រជាជនក៏មានសេចក្តីក្រាក្នាទៅលើអ៊ីព្រ ដែលវាបានធ្វើឱ្យបងរបស់យ៉ារេឌ មានការព្រួយបារម្ភយ៉ាងខ្លាំង បំផុត។ នៅពេលអ្នកអាន ចូរគិតថាហេតុអ្វីក៏ពួកគេសុំទូរអ៊ីដែលពួកគេបានធ្វើ ដោយដឹងពីអារម្មណ៍របស់អ្នកដឹកនាំរបស់ពួកគេមាន នៅពេលគាត់បានធ្វើ។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 6

ចិញ្ចឹមជីវិត (ខ. 4)—មានជីវិតរស់នៅ

ដោយទីពឹង (ខ. 4)—ដោយតាំងចិត្ត ដោយទុកចិត្ត

ព្យុះដ៏ធំ (ខ. 6)—ព្យុះយ៉ាងខ្លាំង

ជិត (ខ. 7)—ទឹកមិនអាចជ្រាបចូលបាន

ត្រូវហ៊ុំព័ទ្ធ (ខ. 7)—នៅជុំវិញ គ្របដណ្តប់

ប្បែតប្បែន (ខ. 10)—គ្រោះថ្នាក់អន្តរាយ

ព្រួយជាខ្លាំង (ខ. 23)—ការរំខានយ៉ាងខ្លាំង

បង្ខំ (ខ. 25)—បង្ខិតបង្ខំ បង្ខាប់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព និង១ នៅពេលអ្នកសិក្សាអេធើរ 6។

ក សរសេរចូលទៅក្នុងស្បៃវែកំណត់ហេតុ

សូមអានអេធើរ 6:1–11 ហើយទឹកគិតថា ជាអ្នកដំណើរម្នាក់នៅលើគ្រាមួយរបស់ពួកសាសន៍យ៉ារេឌ។

1. ចូរសរសេរចូលទៅក្នុងកំណត់ហេតុមួយ ដែលអ្នកគិតថាអាចជាសំខាន់នៅថ្ងៃណាមួយ។ ចូរពិចារណាពីពត៌មានដែលមានបន្ថែម អំពីស្ថានភាពរបស់គ្រា ស្ថានភាពនៃការធ្វើដំណើរ ខណៈដែលមានភាពត័ឃរន្ធត់ និងពេលសប្បាយរីករាយ។
2. ចូរធ្វើការប្រៀបធ្យេបអំពីការលំបាកទាំងឡាយ ដែលពួកគេជួបប្រទះ ទៅនឹងការលំបាកដែលអ្នកជួបប្រទះ ក្នុងអំឡុងដំណើរ ជីវិតរបស់អ្នក។ សូមសរសេរអំពីអ៊ី ដែលផ្តល់ “ពន្លឺ” ឱ្យអ្នកនៅក្នុងជីវិត ហើយតើជីវិតរបស់អ្នកបានទទួលពរដ៏ធំ ដោយសារពន្លឺ នោះតាមរបៀបណា។



ខ បង្កើតសេចក្តីថ្លែងការណ៍មួយទៅដល់សារពត៌មានមួយ

ចូរនឹកគិតអំពីអ្នករាយការណ៍តាមទូរទស្សន៍ សម្ភាសន៍យ៉ារេឌ និងគ្រួសាររបស់គាត់អំពីចំណង របស់ប្រជាជន ដើម្បីមានស្តេចមួយ អង្គ។ ដកស្រង់មកពីអ៊ី ដែលអ្នករៀបនៅក្នុងអេធើរ 6:22–30 ចូរសរសេរការឆ្លើយតបមួយ ដែលអ្នកគិតថា មនុស្សនៅខាង ក្រោមនេះ អាចផ្តល់ឱ្យ ដើម្បីឆ្លើយនឹងសំនួរ៖

- បងរបស់យ៉ារេឌ៖ “តើហេតុអ្វីបានជាអ្នកប្រឆាំងជំទាស់ក្នុងការមានស្តេចមួយអង្គដូច្នេះ?”
- យ៉ារេឌ៖ “តើអ្នកមានអារម្មណ៍យ៉ាងណា អំពីគំនិតដែលឱ្យមានស្តេចនោះ?”
- ពេកាកៈ “តើអ្នកមានការឆ្លើយតបយ៉ាងដូចម្តេច ទៅនឹងការតែងតាំង ដែលឱ្យអ្នកទៅធ្វើជាស្តេច?”
- អ៊ូរៃហាៈ “តើហេតុអ្វីបានជាអ្នកទទួលយកការតែតាំងដើម្បីធ្វើជាស្តេច?”

អេធើរ 7

កូនប្រុសទាំងឡាយរបស់អ៊ូរៃហា

ពាក្យទូន្មានរបស់បងរបស់យ៉ារេឌជំទាស់នឹងការមានស្តេចគឺជាការបំផុសគំនិត ដូចមានបង្ហាញទៅក្នុងការដណ្តើម និងឈ្លក់វង្វេង នឹងអំណាច ដែលបណ្តាលឱ្យមានកើតឡើងតាមរជ្ជកាលរបស់ស្តេចនានា។ កូនចៅរបស់អ៊ូរៃហ្គ

ឲ្យាំងនឹងគ្នាដើម្បីត្រួតត្រា អាណាចក្រ។ សេចក្តីទុច្ចរិតនេះមានទៅក្នុងកន្លែងដែលមានតំណែងខ្ពស់ ដែលនាំទៅរកសេចក្តីទុច្ចរិតក្នុងចំណោមប្រជាជន។ នៅពេលអ្នកអានអេធើរ 7 ចូរធ្វើការកត់ចំណាំពីអ្វី ដែលទៅទីបញ្ចប់បានធ្វើឱ្យប្រជាជនធ្វើការកែប្រែចិត្ត។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 7

អនុវត្ត (ខ. 1, 11, 24–25, 27)—ធ្វើឱ្យកើតមានឡើង

រំលាយ (ខ. 9)—រំលាយរើ

ផេប្រមាថ (ខ. 24)—និយាយប្រមាថ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពក នៅពេលអ្នកសិក្សាអេធើរ 7។

ក្ត៌ តើអ្នកណាជា អ្នកណា?

សូមសិក្សាអេធើរ 7:1–8:7 ដោយយកចិត្តទុកដាក់ ហើយថតចម្លងតារាងពង្សាវតានៅខាងក្រោមចូលក្នុងស្បៀវភៅសរសេរ របស់អ្នក។



1. ចូរបំពេញនៅផ្នែកដែលមានចន្លោះក្នុងតារាង។
2. ចូរគូសរង្វង់ត្រង់ឈ្មោះរបស់អ្នកទាំងអស់ណា ដែលបានបំរើជាស្តេច។
3. ចូរសរសេរអក្សរ "ស" សំរាប់អ្នកទាំងឡាយណា ដែលសុចរិត ហើយអក្សរ "ទ" សំរាប់អ្នកណា ដែលទុច្ចរិត។
4. ចូរឆ្លើយសំនួរតទៅនេះអំពីតារាងរបស់អ្នកៈ
   ក. តើការណ៍នេះបង្ហាញថា ការព្យាការណ៍របស់បងរបស់យ៉ារេខនៅក្នុងអេធើរ 6:23 បានសំរេចដោយរបៀបណា?
   ខ. តើសមាជិកណាម្នាក់នៅក្នុងត្រួសារនេះ ដែលធ្វើឱ្យអ្នកចាប់អារម្មណ៍ជាងគេ? ហេតុអ្វី?

អេធើរ 8
ការរួមគំនិតស្វាត់កំបាំង ចាប់ផ្តើមមានឡើង

បញ្ហាបន្តមានទៅពេលពួកអ្នកដឹកនាំសាសន៍យ៉ារេខឲ្យាំងគ្នាដើម្បីអំណាចនិងទ្រព្យសម្បត្តិ។ ប៉ុន្តែនៅក្នុងអេធើរ 8 បញ្ហាកើត ឡើងកាន់តែអាក្រក់ទៅៗ។ សូមពិនិត្យមើលការណែនាំនៃមនុស្សអាក្រក់ ដែលផ្ទយបំផ្លាញជនជាតិយ៉ារេខទាំងស្រុង។ លោក មូរ៉ូណៃបានបញ្ចប់ជំពូកនេះជាមួយនឹងការព្រមានយ៉ាងខ្លាំងមួយចំពោះអ្នកអានទៅពេលអនាគតទាំងអស់។ តើការព្រមាន របស់លោកនេះ អនុវត្តចំពោះអ្នកបានយ៉ាងដូចម្តេច?

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 8

អ្នកជំនាញ (ខ. 8)—អ្នកឆ្លាត

គិតរក (ខ. 8)—បង្កើត អភិវឌ្ឍន៍

សម្រស់ល្អណាស់ (ខ. 9)—ស្រស់ស្អាត

ស្បថនឹង (ខ. 13–14)—សន្យា

ខ្ទះខ្ទាយ (ខ. 14)—ព្រាប់

ស្បថ (ខ. 15–16, 20)—សន្យា

ជ៏គួរឱ្យស្អប់ខ្ពើម (ខ. 18)—គួរឱ្យខ្លាចបំផ្លិចបំផ្លាញ

ការសងសឹក (ខ. 22, 24)—ទារុណកម្ម

បានបញ្ឆោត (ខ. 25)—បោកបន្លំ

អេធើរ 9:9–22—ការរួមគំនិតស្វាត់កំបាំង

ការរួមគំនិតស្វាត់កំបាំងមួយ គឺជាក្រុមនៃមនុស្សអាក្រក់មួយក្រុម ដែលរួបរួមគ្នាដោយសម្ងាត់ដើម្បីភូតកុហក បោកបញ្ឆោត លួច សំលាប់ ឬធ្វើអ្វីឲ្យ ដែលចំបាច់ដើម្បីទទួលបានភាពស្តុកស្តម ទ្រព្យសម្បត្តិ ឬអំណាច (សូមមើលហេលមិន 7:21, 8:26–28)។ ការរួមគំនិតស្វាត់កំបាំងទីមួយគឺរវាងសាតាំង និងកាអីន ដែលសំលាប់បងប្រុសរបស់ខ្លួន អេបិល (សូមមើលម៉ូសេ 5:28–32)។ អំពើរួមគំនិតស្វាត់កំបាំង នាំទៅរកការបំផ្លិចបំផ្លាញរបស់ប្រជាជនទៅក្នុងជំនាន់របស់លោកណូអេ និងពួកសាសន៍យ៉ារេខ និងពួក សាសន៍នីហ្ចៃទាំងស្រុង (សូមមើលអេធើរ 8:21)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពក នៅពេលអ្នកសិក្សាអេធើរ 8។

ក្ត៌ សំលេងនៃការព្រមានមួយ

សូមសរសេរការព្រមាន ដែលអ្នកនឹងផ្តល់នៅក្នុងស្ថានភាពដូចខាងក្រោមនេះៈ

1. អ្នក គឺជាមន្ត្រីប៉ូលីសស៊ើបអង្កេតម្នាក់ ហើយរកឃើញផែនការណ៍របស់អ៉ីតីស (សូមមើលអេធើរ 8:4–12)។ សូមសរសេររបាយការណ៍ដើម្បីព្រមានដល់អ្នកដឹកនាំរបស់អ្នកអំពីផែនការណ៍ស្វាត់កំបាំងនេះ។
2. អ្នកត្រូវបានចាត់មកពី ព្យាការីដើម្បីឡើងនិយាយ ចូរប្រើអេធើរ 8:20–26 ជាអត្ថបទរបស់អ្នក។ សូមសរសេរ កថាក៉ណ្ឌមួយ ដែលពិពណិនាអំពីការព្រមាន ដែលអ្នកគិតថាសមាជិកនៅក្នុងសាសនាចក្រសព្វថ្ងៃនេះត្រូវការ។

អេធើរ 9

ឥទ្ធិពលរបស់អ្នកទាំងឡាយដែលស្វែងរកអំណាច និងផលប្រយោជន៍

អេធើរ 9 បានបង្ហាញទាំងសង្គម ដែលល្អបំផុត និងអាក្រក់បំផុតរបស់ពួកសាសន៍យ៉ារេឌ។ នៅក្នុងជំពូកនេះអ្នកនឹងអានអំពី ស្តេច ទុច្ចរិត និងស្តេចសុចរិត ក៏នឹងប្រុសដែលមានភាពស្មោះត្រង់ និងក៏នឹងប្រុសដែលប្រឆាំងជំទាស់ទីឱពុករបស់ពួកគេ។ នៅពេលអ្នក អាន សូមរកមើលពីរបៀប ដែលប្រជាជន និងស្តេចមានការផ្លាស់ប្តូរ នៅពេលសេចក្តីទុច្ចរិតកើនឡើង។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 9

ចាប់ពីទីនោះ (ខ. 3)—ទីកន្លែងនោះ

បានទ្រព្យ (ខ. 11)—មានទ្រព្យ

គូរីឡុម និងគូមុម (ខ. 19)—វាមិនច្បាស់ថាតើសត្វប្រភេទនេះរូបរាងយ៉ាងដូចម្តេចនោះទេ

ឱបក្រសោប (ខ. 26)—ព្រមទទួលយក

អំណត់អត់ (ខ. 30)—ត្រោះអត់ឃ្លានឬរាំងស្ងួត

ត្រូវឃាំងផ្លូវទុក (ខ. 33)—ឃាំងទុក

បានបរិភោគ (ខ. 34)—ល្មោតបរិភោគ

មានកម្លាំងឡើងវិញ (ខ. 35)—បានកម្លាំងមកវិញ

អេធើរ 9—តើអ្នកណា ជាអ្នកណា នៅក្នុងអេធើរ 9?

នៅខាងក្រោមនេះគឺជាបន្ទាត់ពេលវេលា ដើម្បីជួយអ្នកយល់ពីលក្ខណៈចរិត និងព្រឹត្តិការណ៍ជាច្រើននៅក្នុងអេធើរ 9។

សេចក្តីទុច្ចរិតមិនអាចទាំមកនូវសុភមង្គល



ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាអេធើរ 9។

ក រៀបចំរបាយការណ៍

ចូរប្រើអេធើរ 9:1–9 សូមសរសេរអំពីអ្វីដែលទីមរ៉ា ប្រហែលជានឹងនិយាយនៅក្នុងរបាយការណ៍របស់គាត់ ទៅកាន់អូមើរ អំពីអ្វី ដែលកើតឡើងនៅក្នុងអាណាចក្រ។

អេធើរ 10

ស្តេចរបស់សាសន៍យ៉ារេឌ

ពួកសាសន៍យ៉ារេឌហាក់ដូចជាមិនបានរៀនមកពីបទពិសោធន៍របស់ពួកគេកាលពីមុនមកសោះ។ ពួកគេនៅតែធ្វើអំពើបាបដដែល ជាដដែលម្តងហើយម្តងទៀត។ នៅពេលអ្នកអានអេធើរ 10 ចូរពិចារណាថាតើភាពចំរុងចំរើនអ្វីខ្លះ ដែលពួកគេត្រូវធ្វើជាមួយ នឹងបញ្ហារបស់ពួកសាសន៍យ៉ារេឌ។ តើមេរៀនអ្វី ដែលលោកម៉រ៉ូណៃចង់ឱ្យយើងយល់ ចេញពីដំណើររឿងរបស់លោក ដែលស្តី អំពីស្តេច សាសន៍យ៉ារេឌជាច្រើននោះ?

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 10

ពិបាក (ខ. 5)—ការលំបាក

ទ្រាំទ្រ (ខ. 5)—ស៊ូទ្រាំ រំកអំរែក

ទុក្ខវេទនា (ខ. 7)—ធ្វើទោស ដាក់បន្ទុក បណ្តាលឱ្យមានសេចក្តីលំបាកវេទនា ឬអំពើអាក្រក់

ផ្លាញ (ខ. 22)—ធ្វើជំនួញ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ខ និងសកម្មភាព ក ឬគ នៅពេលអ្នកសិក្សាអេធើរ 10។

ក សរសេរការណែនាំមួយ

សូមរំលឹកអេធើរ 10:1–8 សារឡើងវិញ ហើយសរសេរកថាក៏ណ្តួយខ្លី ដែលណែនាំអំពី សែស និងបុត្រារបស់ទ្រង់ រ៉ាពឡាគិស ដោយសង្ខេប។ ចូរចងចាំថាការណែនាំមួយ គួរតែមានគូសចំណាំពីអ្វី ដែលប្រជាជនបានធ្វើ និងពន្លឺដាអ្វីខ្លះ ដែលពួកគេបាន បង្កើតឡើង ក្នុងនាមជាអ្នកដឹកនាំនោះ។

ខ ធ្វើការជំនុំជំរះ

1. នៅក្នុងស្បៃវែកាសរសេររបស់អ្នក ចូរសរសេរឈ្មោះនៃអ្នកដឹកនាំសាសន៍យ៉ារេឌដប់ពីរនាក់ នៅក្នុងអេធើរ 10:9–34។
2. នៅជិតនឹង ឈ្មោះនីមួយៗ ចូរសរសេរថាតើអ្នកដឹកនាំបានគោរពបទបញ្ញត្តិ ឬក៏មិនគោរពបទបញ្ញត្តិ ឬក៏អ្នកមិនដឹងច្បាស់។

ក ពន្យល់ពីឃ្លាមួយ

លោកម៉ូរីណា បានសរសេរនៅក្នុងអេធើរ 10:28 ថា "គ្មានប្រជាជនណា ដែលមានពរជាងពួកគេ។"

1. តើនរណា ដែលលោកនិយាយអំពីនោះ?

2. តើអ្នកគិតថា លោកម៉ូរីណាមានគោលចំណងអ្វី នៅក្នុងការធ្វើសេចក្តីថ្លែងការណ៍នេះ?

ព្យាការីរបស់ព្រះ ត្រូវបានហៅឱ្យប្រកាសអំពីការប្រែចិត្ត។ អ្នកទាំងឡាយណា ដែលធ្វើតាមព្យាការី យើញថាទ្រង់នឹងរក្សាតាម បន្ទូលរបស់ទ្រង់ ហើយ ពួកគេនឹងទទួលពរជ័យ ដូចដែលទ្រង់បានសន្យា។ អ្នកទាំងឡាយណាដែល មិនធ្វើតាមព្យាការី ត្រូវកាត់ ចេញពីពរជ័យទាំងឡាយ (សូមមើល គ និង ស 1:14)។ ព្យាការីទាំងឡាយ បានព្រមានដល់ពួកសាសន៍យ៉ារេឌជាច្រើនដង ឱ្យប្រែ ចិត្ត។ នៅក្នុងជំនាន់របស់យើង ក៏ដូចជានៅជំនាន់មុនដែរ ការព្រមាន របស់ពួកគេទៅកាន់ពួកទុច្ចរិតឱ្យធ្វើការប្រែចិត្ត ហើយ មករកព្រះអម្ចាស់។ បើសិនពួកគេមិនធ្វើការប្រែចិត្ត នោះការបំផ្លិចបំផ្លាញនឹងរង់ចាំពួកគេ។ នៅ ពេលអ្នកអានអំពីរបៀប ដែលពួកសាសន៍យ៉ារេឌត្រូវបំផ្លាញសង្គមរបស់ពួកគេ ចូរគិតអំពីមេរៀនអ្វី ដែលអ្នកអាចរៀនមកពីកំហុសរបស់ពួកគេនោះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 11

គ្រោះដ៏ធំ (ខ. 6)—គ្រោះអាសន្ន ទុក្ខវេទនា

ជម្ងឺអាសន្នរោគ (ខ. 7)—ជម្ងឺឆ្លងរាលដាល

ឱ្យអស់ (ខ. 12)—ទាំងស្រុង

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬខ នៅពេលអ្នកសិក្សាអេធើរ 11។

ក សរសេរអំពីការពន្យល់

សូមរំលឹកអេធើរ 11:1–5, 13–23 សារឡើងវិញ ហើយឆ្លើយសំនួរនៅខាងក្រោមនេះ

1. តើហេតុអ្វីពួកសាសន៍យ៉ារេឌ បដិសេធព្យាការី ហើយស្វែងរកសំឡាប់ពួកគេ?

2. តើអ្នកគិតថាប្រជាជនអាចបដិសេធព្យាការីសព្វថ្ងៃដោយវិធីណា?

3. តើហេតុអ្វីអ្នកគិតថាវាគឺជាការសំខាន់ដើម្បីធ្វើតាមពាក្យទូន្មានរបស់ព្យាការី?

ខ ពន្យល់អំពីឌីយ៉ាក្រាម

ចូរពិចារណាអំពីឌីយ៉ាក្រាមនៅខាងក្រោមនេះ នៅពេលអ្នកសិក្សាអេធើរ 11:5–12។



1. ចូរធ្វើការកត់សំគាល់អំពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងសេចក្តីយោងនីមួយៗ ដែលបានផ្តល់ឱ្យ។

2. ចូរពន្យល់អំពីរបៀប ដែលក្រាហ្វិកបង្ហាញពីអ្វី ដែលកើតឡើងនៅក្នុងជនជាតិយ៉ារេឌ។

តើជំនឿ នៅក្នុងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទជាអ្វី? តើសេចក្តីជំនឿអាច រីកចំរើននៅក្នុងជីវិតរបស់អ្នកបានដោយវិធីណា? តើការរីកចំរើននៅក្នុង សេចក្តីជំនឿរបស់អ្នក ផ្តល់ឱ្យអ្នកនូវអំណាចដើម្បីឱ្យពរដល់ជីវិតអ្នកដទៃបាន យ៉ាងដូចម្តេច? តើមាន ឧទាហរណ៍អ្វីខ្លះ ដែលថាជំនឿគឺជាអំណាច? តើ ព្រះជួយយើងឱ្យកើនសេចក្តីជំនឿដោយរបៀបណា? តើការរីកចំរើន នៅក្នុង សេចក្តីជំនឿរបស់អ្នក នៅក្នុងព្រះផ្តល់ឱ្យអ្នកនូវអំណាច ដើម្បីឱ្យពរដល់ជីវិត អ្នកជិតៃបានយ៉ាងដូចម្តេចទៅ? លោកម៉ូរីណា បានផ្តល់ចំលើយ ចំពោះសំនួរ ទាំងនេះ និងសំនួរសំខាន់ដទៃទៀត ដូចលោកបានបង្រៀនមកពីបទពិសោធន៍ របស់លោក អំពីសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 12

អាចទ្រាំបាន (ខ. 2)—ឈប់ ស្ងាត់ស្ងើរ

បរិបូរណ៍ (ខ. 4)—បានធ្វើយ៉ាងច្រើន

បានទទួល (ខ. 8–9)—ទទួល

នាំឱ្យមាន (ខ. 14–16, 18)—បានធ្វើឱ្យ

សេចក្តីសប្បុរស (ខ. 28, 34–37)—សេចក្តីស្រឡាញ់ដ៏សុទ្ធសាតនៃព្រះគ្រីស្ទ

ធ្វើបន្ទាល់ (ខ. 41)—ទីបន្ទាល់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) នៅពេលអ្នកសិក្សាអេធើរ 12។

ក ចំណេះចំណានបទគម្ពីរ—អេធើរ 12:6

ចូរនឹកគិតថាអ្នកទទួលសំបុត្រមួយច្បាប់មកពីមិត្តភក្តិម្នាក់ ដែលកំពុងស្វែងយល់ពីសាសនាចក្រ ហើយមានការសង្ស័យអំពី ជំណើរ រឿង របស់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីទស្សនៈនិមិត្តដំបូង

ហើយសួរអ្នកតស៊ូតាងថា ដំណើរឿងនេះពិតឬទេ។ ចូរប្រើអេធើរ 12:4–9 ចូរសរសេរសំបុត្រ ឆ្លាប់ជាមួយនឹងការឆ្លើយតបរបស់អ្នក។

២ បង្កើតជាបញ្ជីមួយ

សូមអានអេធើរ 12:10–22។

1. ចូរធ្វើបញ្ជីឧទាហរណ៍នៃអព្ភូតហេតុ ឬភាពអស្ចារ្យទាំងឡាយ ដែលលោកម៉ូរ៉ូណាបានទាញ យកមូលហេតុមកសំអាង ដើម្បីបង្រៀន អំពីសេចក្តីជំនឿ។
2. ចូរជ្រើសរើសយកអព្ភូតហេតុមួយ នៃអព្ភូតហេតុទាំងឡាយ ហើយសរសេរត្រាប់ថា តើទីកន្លែង ណាមួយនៃព្រះគម្ពីរ ដែលអ្នកអាចរក បញ្ជីប្រវត្តិ នៃអព្ភូតហេតុនោះ។
3. តាមសំដីរបស់អ្នកថ្នាល់ ចូរធ្វើការសង្កេតគំនិតចំបង ដែលលោកម៉ូរ៉ូណាបានបង្រៀនជាមួយនឹង ឧទាហរណ៍ទាំងនោះ។

© 1991 Garry L. Kapp

© 1991 Garry L. Kapp

๓ ចំណេះចំណានបទគម្ពីរ—អេធើរ 12:27

ចូរនឹកគិតថាអ្នកត្រូវបានសុំឱ្យបង្រៀនមេរៀនមួយទៅក្នុងអេធើរ 12:27–29។ ចូរសរសេរ ឧទាហរណ៍មួយ ដែលបង្ហាញពី របៀប ដែលបទគម្ពីរនេះអាចអនុវត្តចំពោះបទពិសោធន៍ទាសម័យ ទំនើបបាន។

មាត្រានៃសេចក្តីជំនឿទីដប់ បានទិយាយថា យើងជឿថា "សិយ៉ូន (ក្រុង យេរូសាឡិមថ្មី)នឹងត្រូវស្ថាបនាឡើងនៅលើទ្វីប អាមេរិក។" តើអ្នកធ្លាប់ មានការងឿងឆ្ងល់ទេថា តើរឿងនេះមានន័យយ៉ាងណា តើសិយ៉ូននឹង ស្ថាបនានៅកន្លែងណា ឬតើនរណានឹងស្ថាបនាសិយ៉ូន? ការព្យាករណ៍នេះ មានសារៈសំខាន់ដ៏អស្ចារ្យ ចំពោះព្រឹត្តិការណ៍ទាំងឡាយ មុនការយាងមក ជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ។ នៅពេលអ្នកអានអេធើរ 13 ចូររកមើលពីការបង្រៀនអ្វីខ្លះ អំពីក្រុងយេរូសាឡិម។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 13

បានស្រេក (ខ. 2)—ដកចេញ ថយក្រោយ ថយចុះ

សំណល់ (ខ. 6)—អ្នកទាំងឡាយណា ដែលនៅសល់ អ្នកនៅមាន

ត្រូវបំភាន់ (ខ. 8)—ប្រឡំ ធ្វើឱ្យច្រឡំ ធ្វើឱ្យអន់ចិត្ត

ក្រហែង (ខ. 13)—ប្រហោង រូង

ឃោត់ (ខ. 31)—ស្ទាក់ស្ទើរ រារាំង បញ្ឈប់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាអេធើរ 13។

ក សរសេរសព្វវចនាធិប្បាយអត្ថបទមួយ

អ្នកបានសុំឱ្យសរសេរអត្ថបទមួយសំរាប់សព្វវចនាធិប្បាយរបស់កុមារ។ ប្រធានបទដែលអ្នកត្រូវសរសេរ គឺទីក្រុងយេរូសាឡិមថ្មី។ សូមប្រើ អេធើរ 13:1–12 ដើម្បីជួយអ្នកសរសេរអត្ថបទមួយ ដែលមាន រហូតដល់ទៅហាសិបពាក្យ ហើយការសរសេរ នោះគឺសំរាប់ កុមារអាយុរុងប៉មួយឆ្នាំអាចយល់បាន។

ខ សរសេរអនុក្រមនៃការសរសេរចូលក្នុងកំណត់ហេតុ

© Garry E. Smith

សូមអានអេធើរ 13:13–22 ហើយសរសេរ ប្បែបសរសេរចូលក្នុងកំណត់ហេតុចំនួនបួន យ៉ាងខ្លី ឧបមាថា អ្នកកំពុងចែកចាយអំពី កន្លែង លាក់ខ្លួនជូនគ្នាទីងអេធើរ។ ការសរសេរចូលទៅ ក្នុងកំណត់ហេតុរបស់អ្នក គួរតែនិយាយអំពីពេល វេលានៃការលាក់ខ្លួន របស់អេធើរផង។

អេធើរ 14

ពេលវេលានៃសង្គ្រាម និងការបំផ្លិចបំផ្លាញដ៏ធំ

តើពួកសាសន៍យ៉ារេឌអាចក្លាយទៅជាយោរយៅ និងទុច្ចរិតច្រើនជាងកាលដែលពួកគេឆ្លាប់ធ្លាប់ពីមុនមកនោះទេ? នៅពេលអ្នកអាន អេធើរ 14 ចូរគិតអំពីមូលហេតុដែលលោកម៉ូរីណាបានចុះបញ្ជីអំពីសេចក្តីទុច្ចរិតយ៉ាងខ្លាំងរបស់ពួកសាសន៍យ៉ារេឌ។ តើហេតុអ្វី បានជារឿងនេះក្លាយទៅជាមេរៀនសំខាន់ក្នុងព្រះគម្ពីរមរមន?

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 14

កាន់ជាប់ ខ. 2)—កាន់យ៉ាងតឹង

ពន្លឺជុំវិញ (ខ. 5)—វាយប្រហារជាបន្តបន្ទាប់ ឡោមពន្លឺ

រាយលើ (ខ. 22)—ខ្ចាត់ព្រាត់

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាអេធើរ 14។

ក កត់សំគាល់អំពីចរិកលក្ខណៈ

អេធើរ 14:1–17 បានប្រាប់អំពីអ្នកដឹកនាំរបស់យ៉ារេឌបួននាក់ ថែមពីលើកាឌីអានទុមើរ។

1. ចូរធ្វើបញ្ជីឈ្មោះរបស់មនុស្សទាំងបួននាក់នេះ។
2. ចូរពន្យល់អំពីអ្វី ដែលបានកើតឡើងចំពោះអ្នកដឹកនាំទាំងបួននាក់នេះ និងកាឌីអានទុមើរ។

ខ បញ្ជូនរបាយការណ៍ពត៌មាន

អ្នកគឺជាអ្នករាយការណ៍នៅក្នុងទីលានប្រយុទ្ធម្នាក់ មានភារកិច្ចសំរាប់បញ្ជូនរបាយការណ៍ពត៌មានទៅកាន់អ្នកទាំងឡាយណា ដែលមិនទាក់ទងនៅក្នុងសង្គ្រាម។ សូមរំលឹកអេធើរ 14:18–31 សារឡើងវិញ ហើយសរសេររបាយការណ៍ដោយសង្ខេបចំនួនបី ទៅកាន់អ្នកចោះពុម្ព ដែលជួយឱ្យអ្នកអានយល់ដឹងពីអ្វី ដែលបានកើតឡើងនៅក្នុងសង្គ្រាមច្បាំងគ្នាឯងរបស់សាសន៍យ៉ារេឌ។

អេធើរ 15

ទីបញ្ចប់របស់សង្គមសាសន៍យ៉ារេឌ

ទីបញ្ចប់បានមកដល់សំរាប់ពួកសាសន៍យ៉ារេឌ។ តើមានឧណាម្នាក់នៅរស់ឬទេ? តើមានអ្វីកើតឡើងចំពោះព្យាការីអេធើរ? នៅ ពេលអ្នកអានការពិពណ៌នារបស់លោកម៉ូរីណាអំពីការបំផ្លិចបំផ្លាញនៃពួកសាសន៍យ៉ារេឌ ចូរចងចាំថា ពួកសាសន៍នីហ្វៃក៏បានទាំមក នូវការបំផ្លិចបំផ្លាញមកលើខ្លួនពួកគេតាមរបៀបស្រដៀងគ្នានេះដែរ។ តើលោកម៉ូរីណា អាចនៅចងចាំពីអ្វីខ្លះពេលលោកសរ សេរអំពីពួកសាសន៍យ៉ារេឌ? ចូរគិតអំពីមេរៀនទាំងឡាយដែលយើងត្រូវតែរៀនមកពីសម័យដ៏អស្ចារ្យ នៃសាសន៍ទាំងនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

អេធើរ 15

ដ៏សព្វគ្រប់ (ខ. 3)—យ៉ាងលំអិតទាំងអស់

ការទ្ធញសោក (ខ. 16)—ការយំការទ្ធញយំ

ពុះជ្រែក (ខ. 16–17)—ចាក់ទំលុះ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–គ) ខាងក្រោមនេះ នៅពេលអ្នកសិក្សាអេធើរ 15។

ក សរសេរសំបុត្រមួយច្បាប់

សូមរំលឹកអេធើរ 15 ៈ1–12 សារឡើងវិញ ហើយសរសេរសំបុត្រមួយច្បាប់ ដែលអ្នកគិតថាកូរីអានទុមើរ ប្រហែលជាសរសេរ ទៅកាន់គ្រួសាររបស់គាត់។

ខ ពន្យល់ពីមូលហេតុ

សូមអានអេធើរ 15:19 ដោយយកចិត្តទុកដាក់ ហើយសរសេរកថាកំណត់មួយ ដែលមានពន្យល់ថាហេតុអ្វីបានជាស្ថានភាព ដែល បានកត់ត្រាទុកក្នុងអេធើរ 15:13–22 អាក្រក់យ៉ាងដូច្នេះចំពោះពួកសាសន៍យ៉ារេឌ។

គ តើមេរៀនជាអ្វី?

បន្ទាប់ពីអ្នកអានអេធើរ 15:19 ចូរសរសេរអំពីអ្វី ដែលអ្នកគិតថា ជាមេរៀន ដែលលោកម៉ូរីណាចង់ឱ្យយើងរៀនមកពីប្រជាជន សាសន៍យ៉ារេឌ (សូមមើលនៅអោមណៃ 1:20–22 ផងដែរ)។

គម្ពីរមរ៉ូណៃ



ទីបន្ទាល់របស់លោកមរ៉ូណៃ ដូចជាសញ្ញាឧទាននៅក្នុងប្រយោគ វាសមរម្យណាស់សំរាប់នៅ ទីបញ្ចប់នៃព្រះគម្ពីរមរមន។ ព្រះអម្ចាស់ប្រទានដល់លោកមរ៉ូណៃ នូវទស្សនៈដ៏អស្ចារ្យមួយនៃសម័យ របស់យើង។ ការនិយាយមកកាន់ពួកយើង លោកមរ៉ូណៃធ្វើទីបន្ទាល់ថា "មើលចុះ ខ្ញុំនិយាយទៅ កាន់អ្នករាល់គ្នា ហាក់បីដូចជាអ្នករាល់គ្នានៅទីនេះ ប៉ុន្តែអ្នករាល់គ្នាពុំនៅ ទីនេះឡើយ ប៉ុន្តែមើល ចុះព្រះយេស៊ូវគ្រីស្ត ទ្រង់បង្ហាញអ្នករាល់គ្នាដល់ខ្ញុំ ហើយខ្ញុំដឹងនូវអ្វី ដែលអ្នករាល់គ្នាធ្វើ" (មរមន 8:35)។ ការផ្តល់នូវការព្យារកណ៍ទុកជាមុន វាគឺជា ការដ៏សំខាន់ដើម្បីដឹងកាន់តែច្រើនអំពី លោកមរ៉ូណៃ និងសារលិខិត របស់លោក។

តើលោកមរ៉ូណៃ គឺជានរណា?

អែលឌើរ ម៉ាក អី ភីទើសិន ជាសមាជិកម្នាក់ នៃក្រុមសាវកដប់ពីរនាក់ បានពន្យល់ថាលោកមរ៉ូណៃ "រស់នៅក្នុងអាមេរិក ប្រហែលជាដប់ប្រាំរយឆ្នាំកន្លងទៅ ហើយគឺជាព្យាការីរបស់ព្រះនៅជំនាន់ នោះ។ លោក និងឱពុករបស់លោក មរមន គឺជាអ្នក ប្រវត្តិសាស្ត្រ នៃប្រជាជន ដែលទទួលមរតក ដែនដីនេះកាលពីមុន។ ពួកគេសរសេរពីប្រវត្តិសាស្ត្រនៃប្រជាជនរបស់សាសន៍ ពួកគេ ឆ្លាក់នៅលើ ផ្ទាំងចំណារមាស ដើម្បីកុំឱ្យបាត់បង់តាមពេលវេលា ចំពោះបញ្ជីប្រវត្តិនោះ គឺមានសារៈសំខាន់ យ៉ាងពិតប្រាកដនៅក្នុង ថ្ងៃចុងក្រោយនេះ" (នៅក្នុង Conference Report ខែតុលា ឆ្នាំ 1983, 41, ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 1983, 29)។

លោកមរ៉ូណៃ កប់ទុកបញ្ជីពិសិដ្ឋនៅក្នុងភ្នំកូម៉ូរ៉ា ប្រហែលជានៅក្នុងឆ្នាំ 421 ត.ស។ ទីនោះផ្ទាំង ចំណារនៅរហូតដល់ថ្ងៃទី22 ខែកញ្ញា ឆ្នាំ 1827 នៅពេលលោកមរ៉ូណៃ ដែលជាទេវតាមួយអង្ត ក្រោមកាតពូកិចរបស់ព្រះអម្ចាស់ បាននាំយកផ្ទាំងចំណារទៅ ឱ្យព្យាការីយ៉ូសែប ស្មីធ សំរាប់ធ្វើ ការបកប្រែ (សូមមើលប្រវត្តិ—លោកយ៉ូសែប ស្មីធ 1:59)។

តើហេតុអ្វីខ្ញុំគួរតែអានគម្ពីរមរ៉ូណៃដូច្នេះ?

លោកមរ៉ូណៃ បញ្ចប់គម្ពីររបស់លោកជាមួយនឹងការអញ្ជើញឱ្យមនុស្សទាំងអស់ "មកឯព្រះគ្រីស្ត" (មរ៉ូណៃ 10:32)។ នៅក្នុង ជំពូកទាំងនេះ អ្នកនឹងយើញនូវការបង្រៀនរបស់លោកមរ៉ូណៃអំពីរ ប្យៀប ដើម្បីធ្វើដូច្នោះ។ ចំពោះអ្នកស្វែងរកសេចក្តីពិតស្មោះ ត្រង់ លោកពន្យល់ពីវិធីដើម្បីវិនិច្ឆ័យ រវាងល្អ និងអាក្រក់ (សូមមើលមរ៉ូណៃ 10:4–5)។ លោក បានបញ្ចូលពីសារៈសំខាន់លំអិត ដើម្បីជួយសំគាល់ពីទីសំគាល់ ហើយការអនុវត្តន៍ទាំងឡាយ នៃសាសនាច្រកពិតរបស់ព្រះយេស៊ូ គ្រីស្ត (សូមមើល មរ៉ូណៃ 1–6, 8:10–12, 10:8–18)។ លោកមរ៉ូណៃ ធ្វើទីបន្ទាល់ថា មានតែ តាមព្រះយេស៊ូវគ្រីស្ត ប៉ុណ្ណោះ ដែលយើងអាចត្រូវបានញែកចេញ ហើយបានល្អតគេខ្ចោះ។ សារលិខិតដ៏ជ្រាលជ្រៅនេះ គឺជាការបញ្ចប់ដ៏សក្តិសមចំពោះសារលិខិត នៃព្រះគម្ពីរមរមន ដើម្បី ផ្តល់ទំនុក ចិត្តចំពោះមនុស្សគ្រប់រូបថា "ព្រះយេស៊ូវ គឺជាព្រះគ្រីស្ត ជាព្រះដ៏នៅអស់កល្បជានិច្ច" (ទំព័រចំណងជើងនៃព្រះគម្ពីរមរមន)។

ចូរនឹកស្រមៃថា អ្នកនៅតែម្នាក់ឯង។ អ្នកគ្មានផ្ទះសម្បែងទេ មិត្តភក្តិ និង ត្រូសាររបស់អ្នកត្រូវសំលាប់អស់ ហើយអ្នកដែល សំលាប់ពួកគេ ទាំងនោះ តាមរកយកជីវិតរបស់អ្នកទៀត។ នេះគឺជាស្ថានភាពរបស់លោកមរ៉ូណៃ នៅ ពេលលោកបញ្ចប់នៅក្នុង បញ្ជីប្រវត្តិរបស់ឱពុកលោក។ ទោះបីជាលោក គិតថាលោកមិនមានពេលវេលាច្រើនដើម្បីសរសេរក៏ដោយក៏លោកយកចិត្តទុក ដាក់ដើម្បីបន្ថែមនូវអ្វី ដែលលោកគិតថានឹងមានតម្លៃសំរាប់ជំនាន់នៅពេល អនាគត។ នៅពេលអ្នកអានមរ៉ូណៃ 1–3 សូមរក មើលគោលលទ្ធិ និងពិធីការ នៃដំណឹងល្អ និងគោលលទ្ធិ នៃកិច្ចការសាសនាចក្រសំខាន់ព្ចទាំងឡាយ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរ៉ូណៃ 1

បន្ទាប់ពីបានធ្វើសេចក្តីសង្ខេបចប់ហើយ (ខ. 1)—បញ្ចប់ដោយ ទស្សនៈយ៉ាងខ្លី

ដែលផ្ទុយ (ខ. 4)—ខុសពី ផ្ទុយទៅនឹង

មរ៉ូណៃ 2

ពួកសិស្ស (ខ. 1)—
អ្នកដឹកនាំសាសនាចក្រដប់ពីរនាក់ នៅក្នុង ចំណោមពួកសាសន៍នីហ្វៃ

មរ៉ូណៃ 3

តែងតាំង (ខ. 1, 3–4)—ប្រគល់សិទ្ធិ អំណាចបព្ចជិតភាពទៅឱ្យ

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាពពីរ នៃសកម្មភាព (ក–ត) ខាងក្រោមនេះ នៅពេលអ្នកសិក្សាមរ៉ូណៃ 1–3។

ក សរសេរលិខិតថ្លែងអំណរគុណ

សូមរំលឹកមូរ៉ៃណា 1 សារឡើងវិញ ហើយសរសេរលិខិតថ្លែងអំណរគុណមួយទៅកាន់លោកមូរ៉ៃណា ដែលជាពិសេសកត់សំគាល់ទៅ លើការប្រឈមមុខទាំងឡាយ ដែលលោកបានជួបប្រទះ និងអំណរគុណរបស់អ្នកសំរាប់ការងាររបស់លោក។

ខ ពន្យល់ទៅកាន់អ្នកមិនមែនជាសមាជិក

ឧបមាថា អ្នកមានមិត្តម្នាក់ដែលមិនមែនជាសមាជិក មកចូលរួមការប្រជុំពិធីប្រសិទ្ធិពរនំប៉ុង និងទឹកជាមួយអ្នក ហើយយើញមនុស្សម្នាក់ ទទួលព្រះវិញ្ញាណបរិសុទ្ធ ជាសមាជិកនៃសាសនាចក្រ។ សូមប្រើមូរ៉ៃណា 2 សរសេរពីអ្វី ដែលអ្នកនឹងនិយាយ ទៅកាន់មិត្តរបស់អ្នក អំពីពិធីការនេះ និងអំណាចដែលព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានប្រគល់ឱ្យ។

គ បង្កើតទំរង់គំនិតមួយ

ប៊ីស្សប ឬប្រធានសាខារបស់អ្នក បានសុំឱ្យអ្នកបង្រៀនយុវជនម្នាក់អំពីបញ្ចជិតភាពអើរ៉ុន ដោយប្រើមូរ៉ៃណា 3។ ចូរសរសេរ ទំរង់គំនិតមួយពីអ្វី ដែលអ្នកនឹងបង្រៀន។

អែលឌើរដេវីឌ ប៊ី ហេត ជាសមាជិកនៃក្រុមសាវកដប់ពីរនាក់ មានប្រសាសន៍ថាះ "បទពិសោធន៍ការថ្វាយបង្គំដែលមានតម្លៃបំផុត របស់យើងនៅក្នុងការប្រជុំពិធីប្រសិទ្ធិពរនំប៉ុង និងទឹក គឺជាពិធីការពិសិដ្ឋនៃការប្រសិទ្ធិពរនំប៉ុងនិងទឹក ពីព្រោះពិធីនេះផ្តល់ឱកាស ដើម្បីផ្តោតគំនិត និងចិត្តរបស់យើងទៅលើព្រះអង្គសង្ត្រោះ និងពលិកម្មរបស់ទ្រង់" (ក្នុង Conference Report ខែកញ្ញា –តុលា ឆ្នាំ1989, 75 ឬ Ensign ខែវិច្ឆិកា ឆ្នាំ1989, 61)។ វាជាការសមស្របដែលលោកមូរ៉ៃណទទួលអារម្មណ៍ដើម្បីបញ្ចូល ពាក្យអធិដ្ឋានប្រសិទ្ធិពរនំប៉ុង និងទឹកនៅក្នុងបញ្ជីប្រវត្តិរបស់លោកនេះ។

ការយល់ដឹងអំពីព្រះគម្ពីរ

មូរ៉ូណៃ 4

ប្រគល់ (ខ. 1)—ការរៀបចំ និងបំរើតាមផ្លូវការ

ញែកចេញជាបរិសុទ្ធ (ខ. 3)—ធ្វើឱ្យបរិសុទ្ធ បរិសុទ្ធ

មូរ៉ូណៃ 5

មូរ៉ូណៃ 5:1—ពិធីប្រសិទ្ធិពរនំប៉ុង និងទឹក

ការនិយាយទៅកាន់យុវជន នៃសាសនាចក្រ អែលឌើរ រ៉ូប៊ឺត ឌី ហល ជាសមាជិកម្នាក់នៃក្រុមសាវកដប់ពីរនាក់ មានប្រសាសន៍ ថាះ

"អ្នកដែលជាយុវជន ថ្នាក់ឌីកិន ត្រូ និងពួកសង្ឃះ តើអ្នកមានភាពសក្តិសម ដើម្បីធ្វើជាអធិបតីនៅក្នុងការរៀបចំ ចែក និង ប្រសិទ្ធិពរនៃពិធីការប្រសិទ្ធិពរនំប៉ុង និងទឹកឬទេ? កិច្ចការទាំងនេះ គឺជាការទទួលខុសត្រូវដ៏ពិសិដ្ឋ។ នំប៉ុង និងទឹក គឺជាតំណាង ទាំងឡាយអំពីសាច់ និងព្រះលោហិតនៃព្រះអង្គសង្ត្រោះ នំប៉ុង និងទឹកនេះ តំណាងឱ្យពលិកម្មដង្វាយធួនរបស់ទ្រង់។

"ចូរគិតអំពីរៀងនោះមួយភ្លែតសិន។ ពិធីប្រសិទ្ធិពរនំប៉ុង និងទឹក ដែលអ្នកប្រាវព្ធនៅរាល់សប្តាហ៍ គឺជាការចងចាំពីដង្វាយធួន របស់ព្រះយេស៊ូវគ្រីស្ទ។ ជាអំណោយដ៏មហិមា នៃដង្វាយធួន យកឈ្នះលើសេចក្តីស្លាប់ខាងរាងកាយ ដោយគ្មានលក្ខខ័ណ្ឌ ហើយមិនកំណត់ ពីព្រោះអំណោយនេះគឺសំរាប់មនុស្សគ្រប់រូប ដែលបានរស់នៅ ឬនឹងរស់នៅក្នុងជីវិតរមែងស្លាប់នេះ។ តាមរយះដង្វាយធួន យើងទាំងអស់គ្នា ត្រូវបានរំដោះឱ្យរួចពីការធ្លាក់នៃលោកអ័ដាម ហើយនឹងត្រូវបានរស់ឡើងវិញ។

"ទោះជាយ៉ាងណាក៏ដោយ សំរាប់ពរជ័យដ៏ពេញលេញនៃដង្វាយធួន ដើម្បីមានឥទ្ធិពលនៅក្នុងជីវិតរបស់យើង ហើយអនុញ្ញាត ឱ្យយើងត្រឡប់ទៅរស់នៅជាមួយនឹងព្រះវរបិតាសួគិរបស់យើងវិញ យើងត្រូវតែប្រែចិត្តពីបាបកម្មរបស់យើង ហើយស្មោះត្រង់ នៅក្នុងការគោរពតាមបទបញ្ញត្តិរបស់ព្រះ។ ដូច្នេះ ពរជ័យលោះបាប នៃការប្រែចិត្ត និងការអភ័យទោស គឺជាផ្នែកដ៏សំខាន់ នៃដង្វាយធួន ប៉ុន្តែការប្រែចិត្ត និងការអភ័យទោស គឺជាលក្ខខ័ណ្ឌទៅលើសេចក្តីស្មោះត្រង់របស់យើង នៅក្នុងការគោរពតាម បទបញ្ញត្តិ និងគោលលទ្ធិទាំងឡាយរបស់ព្រះ។

"មែនហើយ ព្រះអម្ចាស់នឹងប្រទានពរដល់អ្នកកាន់បញ្ចជិតភាពអើរ៉ុនដែលមានភាពសក្តិសមទាំងឡាយ ដែលជាអ្នកប្រសិទ្ធិពរ និងចែកការប្រសិទ្ធិពរ នំប៉ុង និងទឹក ចំពោះសមាជិកស្មោះត្រង់នៃសាសនាចក្រនៅក្នុងការចងចាំទ្រង់ដល់ប៉ុណ្ណាទៅទៀត! ហើយតើទ្រង់ប្រទានពរដល់ អ្នកទាំងឡាយណា ដែលទទួលទាននៃការប្រសិទ្ធិពរនំប៉ុង និងទឹកដោយសក្តិសមជាយ៉ាងណាទៅហ្ន៍!" (ក្នុង Conference Report ខែមេសា ឆ្នាំ1996, 50 ឬ *Ensign* ខែឧសភា ឆ្នាំ1996, 35–36)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក នៅពេលអ្នកសិក្សាមូរ៉ូណៃ 4–5។

ក ការចងចាំពីសេចក្តីសញ្ញា

នៅពេលយើងទទួលទាន ពិធីនៃការប្រសិទ្ធិពរនំប៉ុង និងទឹក យើងធ្វើសេចក្តីសញ្ញាសារជាថ្មី ដែលយើងបានធ្វើនៅកាលពីពិធីបុណ្យ ជ្រមុជទឹក។ សូមអានពាក្យអធិដ្ឋានប្រសិទ្ធិពរនំប៉ុង និងទឹកដោយយកចិត្តទុកដាក់ នៅក្នុងមូរ៉ូណៃ 4:3 និង5 :2 ហើយបន្ទាប់មក ឆ្លើយសំនួរដូចខាងក្រោមនេះ:

1. តើអ្នកបានសន្យាជាមួយព្រះអ្វីខ្លះ នៅពេលអ្នកទទួលទាន ពិធីនៃការប្រសិទ្ធិពរនំប៉ុង និងទឹក?
2. តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់សន្យា ជាមួយអ្នកទាំងឡាយណាដែលរក្សាសេចក្តីសញ្ញារបស់ពួកគេ?
3. តើគោលដៅអ្វី ដែលអ្នកដាក់ដើម្បីជួយអ្នកឱ្យរក្សាសេចក្តីសញ្ញា ដែលអ្នកបានធ្វើសារជាថ្មីអំឡុងពេលពិធីប្រសិទ្ធិពរនំប៉ុង និងទឹកជាអ្វី?

មរ៉ូណៃ 6

សាសនាចក្រគួរបានរួមប្រជុំគ្នាជាញឹកញាប់

តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកមិនអាចធ្វើអ្វីមួយ ដែលសំខាន់បំផុតនៅក្នុងសាសនាចក្រ ពីព្រោះតែអ្នកនៅក្មេងឬទេ? លោកមរ៉ូណៃបានផ្តល់ការណែនាំជាមូលដ្ឋានខ្លះៗ ទៅដល់មនុស្សទាំងក្មេង និងចាស់អំពីភាពជាសមាជិករបស់ពួកគេ នៅក្នុងសាសនាចក្រ។ នៅពេលអ្នកអានមរ៉ូណៃ 6 សូមសួរដល់ខ្លួនរបស់អ្នកនូវសំនួរដូចតទៅនេះ៖ តើខ្ញុំបានធ្វើអ្វីខ្លះ ដើម្បីជួយចិញ្ចឹម បំប៉ាច់ក្រួសារ និងមិត្តភក្តិរបស់អ្នកដោយ “ព្រះបន្ទូលដ៏ល្អនៃព្រះ”? តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យការ ប្រជុំសាសនាចក្រទាំងឡាយ កាន់តែមានការជំរុញខាងផ្នែកវិញ្ញាណ?

ការយល់ដឹងអំពីព្រះគម្ពីរ

មរ៉ូណៃ 6

ទាំមកនូវលទ្ធផល (ខ. 1)—កិច្ចការដែលចេញផលផ្លែ

មានចិត្តសង្រេង (ខ. 2)—កែប្រែចិត្ត

បានមកសណ្ឋិតលើ (ខ. 4)—ផ្លាស់ប្តូរ

ចិញ្ចឹមបីបាច់ (ខ. 4)—ចិញ្ចឹម

ព្រះគុណ (ខ. 4)—ដង្វាយធួន និងចរិកលក្ខណៈ អាកប្បកិរិយា គុណសម្បត្តិ

ត្រូវលុបចេញ (ខ. 7)—ផ្លាស់ប្តូរទីលប់ចោល

ដោយស្មោះអស់ពីចិត្ត (ខ. 8)—ដោយអស់ពីផ្នងចិត្ត

ឱ្យជំបូន្មាន (ខ. 9)—លើកទឹកចិត្ត ជំរុញ

ប្លងសួង (ខ. 9)—សុំពរជ័យដោយរាបទាប

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក ឬ ខ នៅពេលអ្នកសិក្សាមរ៉ូណៃ 6។

ក ពន្យល់ទៅកាន់មិត្តភក្តិ

មិត្តរបស់អ្នកបានសរសេរសំបុត្រមួយច្បាប់ដោយពន្យល់ថា ទាងចង់ចូលរួមនៅក្នុងសាសនាចក្រ។ សូមអានមរ៉ូណៃ 6:1–4 ហើយ សរសេរសំបុត្រមួយច្បាប់ទៅទាងវិញដោយពន្យល់ថាៈ

1. តំរូវការទាំងឡាយសំរាប់ធ្វើពិធីបុណ្យជ្រមុជទឹក។
2. អ្វីដែលព្រះអង្គាស់សង្ឃឹមទុកពីទាង បន្ទាប់ពីទាងទទួលបុណ្យជ្រមុជទឹក។
3. ជំនួយ ដែលទាងនឹងទទួលមកពីសមាជិកដទៃទៀត បន្ទាប់ពីទាងទទួលបុណ្យជ្រមុជទឹក។

ខ ជួបសម្ភាសជាមួយនឹងអ្នកដឹកនាំសាសនាចក្រម្នាក់

ចូរធ្វើការសម្ភាសន៍អ្នកដឹកនាំម្នាក់នៅក្នុងវួដ ឬសាខា ឬសមាជិកគ្រួសាររបស់អ្នក ហើយសរសេរពីការពន្យល់របស់ពួកគេ ទូវឃ្លាដូចខាងក្រោមមកពីមរ៉ូណៃ 6:5–9ៈ

1. “ពិគ្រោះគ្នាទៅវិញទៅមកអំពីសុខុមាលភាពនៃព្រលឹងពួកគេ” (ខ. 5)
2. “គោរពយ៉ាងគឺងរឹងថា កុំឱ្យមានអំពើទុច្ចរិតនៅក្នុងចំណោមពួកគេ” (ខ. 7)
3. “កាត់ទោសទៅខាងមុខពួកអែលម៉ើរ” (ខ. 7)
4. “ពួកគេនឹងបានទទួលការអភ័យទោស” (ខ. 8)
5. “ការប្រជុំទាំងឡាយត្រូវបានដឹកនាំ . . . តាមរបៀបការងារនៃព្រះវិញ្ញាណ” (ខ. 9)

មរ៉ូណៃ 7

ព្រះវិញ្ញាណនៃព្រះគ្រីស្ទ នោះត្រូវបានប្រទានដល់មនុស្សគ្រប់រូប

តើអ្នកនឹងយកចិត្តទុកដាក់ស្តាប់ប៉ុណ្ណា បើសិនជាព្យាការីនិយាយទៅកុំង្វវដ ឬសាខារបស់អ្នក? ព្យាការីមរមន បាននិយាយទៅកាន់ ប្រជាជនរបស់លោកនៅក្នុងកន្លែងថ្វាយបង្គំរបស់ពួកគេមួយ ហើយលោកមរ៉ូណៃ បានបញ្ចូលសារដំណឹងយ៉ាងច្រើននោះ នៅក្នុង មរ៉ូណៃ 7។ សូមរកមើលពីអ្វីដែលលោកមរមនបង្រៀនអំពីការអធិដ្ឋាន អំពីរបៀបដើម្បីដឹងពីភាពខុសគ្នារវាងល្អ និងអាក្រក់ និងអំពីអ្វីដែលធ្វើឱ្យអព្ភូតហេតុកើតឡើង។ ចូរពិចារណាពីអ្វីដែលលោកនិយាយអំពីសេចក្តីសប្បុរស ហើយហេតុអ្វីបានជា សេចក្តីសប្បុរសគឺជាការចាំបាច់សំរាប់ជីវិតអស់កល្បជានិច្ច។

ដង្វាយធួន គឺជាទង្វើនៃសេចក្តីសប្បុរសដ៏អស្ចារ្យបំផុតរបស់ព្រះគ្រីស្ទ។

ការយល់ដឹងអំពីព្រះគម្ពីរ

មរ៉ូណៃ 7

ដោយទើសទាល់ (ខ. 8)—មិនស្ម័គ្រចិត្ត ដោយស្ទាក់ស្ទើរ

ញុះញង់ (ខ. 12–13)—អួសទាញ ល្បួង

សូមអង្វរ (ខ. 19)—សុំ អង្វរ

មកបង្ហាញឱ្យដឹង (ខ. 22)—ឱ្យដឹង

ផ្សេងៗ (ខ. 24)—ខុសគ្នាយ៉ាងច្រើន

តវ៉ា (ខ. 28)—និយាយទៅក្នុងទាមទៃ

នៅសល់ (ខ. 32)—ដែលនៅសល់

សម (ខ. 33)—ចាំបាច់

តែងតែអត់ធ្មត់ (ខ. 45)—គឺជាការអត់ធ្មត់ដោយគ្មានការរអូរទាំ

ពុំរកប្រយោជន៍ផ្ទាល់ខ្លួន (ខ. 45)—ដាក់ព្រះ និងអ្នកដទៃទីមួយ

មរ៉ូណៃ 7:6–9—តើចំណង់របស់អ្នកបរិសុទ្ធឬទេ?

អែលម៉ើរ ដាល់លិន អេច អូកស៍ ជាសមាជិកម្នាក់ នៃក្រុមសាវកដប់ពីរទាក់ បានបង្រៀនថាៈ

"យើងមិនត្រឹមតែធ្វើ អ្វីដែលត្រូវប៉ុណ្ណោះទេ។ យើងត្រូវតែធ្វើសកម្មភាពសំរាប់មូលហេតុត្រឹមត្រូវផងដែរ។ ពាក្យទំនើបថា គឺជាចំណង់ល្អ។ បទគម្ពីរទាំងឡាយ ជារឿយៗតូសបញ្ជាក់ពីអាកប្បកិរិយានៃគំនិតដ៏សមរម្យជាមួយនឹងពាក្យ *ដោយស្មោះអស់ពី ចិត្ត ឬដោយអស់ពីចិត្ត*។

"បទគម្ពីរបានបញ្ជាក់កាន់តែច្បាស់ថា ព្រះដឹងអំពីចំណង់ទាំងឡាយរបស់យើង និងជំនុំជំរះទៅតាមសកម្មភាពរបស់យើង។ បើសិនជាយើងមិនធ្វើសកម្មភាពសំរាប់មូលហេតុត្រឹមត្រូវនោះទេ សកម្មភាពរបស់យើង នឹងរាប់ជាសេចក្តីសុចរិត" (*Pure in Heart* [ឆ្នាំ1988],15)។

មរ៉ូណៃ 7:45–47—តើសេចក្តីសប្បុរសគឺជាអ្វី?

អែលឌើរ ស៊ី ម៉ាក់ខាលវែល ដែលជាសមាជិកម្នាក់នៃក្រុមចិតសិបនាក់មានប្រសាសន៍ថាះ "សេចក្តីសប្បុរសគឺមិនមែនត្រាន់តែ ជាគំនិត ឬគោលលទ្ធិមួយនោះទេ វាក៏មិនត្រាន់តែជាពាក្យ ដើម្បីពិពណិនាពីសកម្មភាព ឬអាកប្បកិរិយាទាំងឡាយដែរ។ បែបហ្នឹង វាគឺជាលក្ខខ័ណ្ឌនៅផ្នែកខាងក្នុង ដែលត្រូវតែអភិវឌ្ឍ និងមានបទពិសោធន៍ដើម្បីអាចយល់ដឹងបាន។ យើងគឺជាម្ចាស់នៃសេចក្តី សុចរិត នៅពេលសេចក្តីសប្បុរសគឺជាផ្នែកមួយនៃនិស្ស័យរបស់យើង។ មនុស្សដែលមានសេចក្តីសប្បុរស មានសេចក្តីស្រឡាញ់ ចំពោះព្រះអង្គសង្គ្រោះ បានទទួលសេចក្តីស្រឡាញ់របស់ទ្រង់ និងស្រឡាញ់អ្នកដទៃដូចទ្រង់បានធ្វើ" (ក្នុង Conference Report ខែតុលា ឆ្នាំ1992, 40 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ1992, 30)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព យ និងសកម្មភាពពីរដទៃទៀតនៃសកម្មភាព (ក–គ) នៅពេលអ្នកសិក្សាមរ៉ូណៃ 7។

ក បំពេញនៅក្នុងប្រយោគ

ចូរប្រើមរ៉ូណៃ 7:1–11 បំពេញនៅក្នុងប្រយោគដែលមិនទាន់ចប់ពេញលេញនៅខាងក្រោមនេះ

1. លោកមរមនត្រិះរិះចង់ឱ្យមនុស្សក្លាយទៅជាសមាជិកស្មោះត្រង់របស់សាសនាចក្រ ពីព្រោះ . . .
2. ការអធិដ្ឋានដែលមិនអស់ពីចិត្ត គឺគ្មានប្រយោជន៍ទេ ពីព្រោះ . . .

ខ ការទន្ទេញខគម្ពីរ—មរ៉ូណៃ 7:16–17

ប្រធាន អែសរ៉ា ថាព្ធ ប៉ែនសឹន មានប្រសាសន៍ថាះ ចូរយើងប្រើមាត្រដ្ឋានរបស់ "លោកមរមន" ដើម្បីវិនិច្ឆ័យអ្វីដែលយើងអាន តន្ត្រី ដែលយើងស្តាប់ ការកំសាន្តដែលយើងមើល គំនិតដែលយើងគិត។ ចូរយើងក្លាយកាន់ឱ្យដូចជាព្រះគ្រីស្ត (ក្នុង Conference Report ខែមេសា ឆ្នាំ1986, 100 ឬ *Ensign* ខែឧសភា ឆ្នាំ1986, 78)។ សូមអានមរ៉ូណៃ 7:12–19 ហើយសរសេរពីរប្យេប ដែលអ្នកអាចប្រាប់បើសិនជាមានអ្វីល្អ ឬអាក្រក់នោះ។

គ សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស

ចូរតូសចំណាំពាក្យ *សេចក្តីជំនឿ សេចក្តីសង្ឃឹម* និង*សេចក្តីសប្បុរស* រាល់ពេលដែលយើញពាក្យទាំងនេះមាននៅក្នុងមរ៉ូណៃ 7:21–48, អេធើរ 12:3–36 និងមរ៉ូណៃ 10:20–23។ សូមសរសេរដោយសង្ខេបពីអ្វី ដែលអ្នករៀនអំពី សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស។

ឃ ការទន្ទេញខគម្ពីរ—មរ៉ូណៃ 7:45

ចូរធ្វើគម្រោងនិយាយ 3–5 នាទីនៅលើប្រធានបទសេចក្តីសប្បុរស ហើយបន្ថែមពីរប្យេបទាំងឡាយ ដែលយើងអាចក្លាយ ដូចជាព្រះអង្គសង្គ្រោះ នៅក្នុងជីវិតសាមញ្ញ និងប្រចាំថ្ងៃរបស់យើង។ សូមប្រើមរ៉ូណៃ 7:45–48 សេចក្តីថ្លែងការណ៍របស់ អែលឌើរ ខាតវែល នៅក្នុងវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ" ហើយឱ្យឧទាហណ៍ នៃរប្យេបមួយ ដែលអាចបង្ហាញពីសេចក្តីស្រឡាញ់ដ៏សុទ្ធសាតរបស់ព្រះគ្រីស្ត។

មរ៉ូណៃ 8

ពិធីបុណ្យជ្រមុជទឹក និងកុមារតូចៗ

តើអ្នកដឹងថាហេតុអ្វីបានជាកុមារតូចៗ មិនទទួលបុណ្យជ្រមុជទឹក រហូតដល់ពួកគេមានអាយុប្រាំបីឆ្នាំឬទេ? លោកមរមន បាន ពន្យល់ពីមូលហេតុនៅក្នុងសំបុត្រទៅកាន់កូនប្រុសរបស់លោកមរ៉ូណៃ។ លោកមរ៉ូណៃ បន្ថែមការណែនាំដ៏សំខាន់នោះនៅ ក្នុងបញ្ជីប្រវត្តិពិសិដ្ឋរបស់លោក។ ចូរពិចារណាអំពីការបង្រៀនរបស់លោកមរ៉ូណៃ ហើយរកមើលពីរប្យេបដែលការបង្រៀនទាំងនោះធ្វើទីបន្ទាល់អំពី អំណាចនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត។

ការយល់ដឹងអំពីព្រះគម្ពីរ

មរ៉ូណៃ 8

សំបុត្រ (ខ. 1, 6)—សំបុត្រ

ការឈ្លោះប្រកែក (ខ. 4–5)—ការជជែក វិវាទ

ដ៏ធំ (ខ. 6)—ធ្ងន់ធ្ងរ ជាក់ស្តែង

មនុស្សជា (ខ. 8)—សុខភាពល្អ

ការចំអកឡកឡឺយដ៏ខ្លាំង (ខ. 9, 23)—សកម្មភាពមិនគោរពយ៉ាងខ្លាំង

ដ៏លំអៀង (ខ. 12, 18)—មិនយុត្តិធម៌ ភាពលំអៀង

ចេះរើសមុខមនុស្ស (ខ. 12)—មនុស្សម្នាក់ដែលមិនប្រព្រឹត្តចំពោះមនុស្សត្រប់រូបដោយយុត្តិធម៌

នៅក្នុងប្រមាត់ល្វីងជូរចត់ (ខ. 14)—សូមមើលវគ្គ "ការយល់ដឹងអំពីព្រះគម្ពីរ សំរាប់អាលម៉ា 36:18 (ទំព័រ 00)

ជាឥតប្រយោជន៍ (ខ. 20)—គិតថាគ្មានអំណាច គិតដូចជាគ្មានតម្លៃ

មរ៉ូណៃ 8:8—"នៅក្នុងយើង ច្បាប់កាត់ស្បែក ក៏ត្រូវបោះបង់ចោលដែរ"

មរ៉ូណៃ 8:8–24—ពិធីបុណ្យជ្រមុជទឹករបស់កុមារតូចៗ

នៅក្នុងឆ្នាំ1830 ព្យាការីយ៉ូសែប ស្មឹធ បានរៀនថា "កុមារតូចៗ គឺត្រូវបានរំដោះតាំងមកពីការចាប់ផ្តើមនៃលោកីយមកម្លេះ" តាមរយះព្រះគ្រីស្ត។ ពួកគេគ្មានអំពើបាប ដូច្នេះអំណាច គឺមិនត្រូវបានឱ្យសាតាំងដើម្បីល្បួងកូនក្មេងតូចៗបានទេ រហូតដល់ ពួកគេចាប់ផ្តើមក្លាយទៅជារាប់ថាមានទោសនៅចំពោះមុខយើង (សូមមើល គ និង ស 29:46–47)។ មួយឆ្នាំក្រោយមក នៅក្នុងឆ្នាំ 1831 ព្រះអម្ចាស់បានបើកបង្ហាញចំពោះព្យាការីថា កុមារតូចៗចាត់ទុកថារាប់ជាមានទោសបាន គឺនៅពេលមានអាយុ ប្រាំបីឆ្នាំ (សូមមើល គ និង ស 68:25–27)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាមូ៉រ៉ៃណៃ 8។

ក្ត៉ តើអ្នកអាចនិយាយអ្វីខ្លះ?

អ្នកជិតខាងរបស់អ្នក មិនមែនជាសមាជិកនៃសាសនាចក្រ។ ក្វនតូចរបស់ពួកគេទើបនឹងកើតស្រាប់តែត្រូវស្លាប់។ សូមរំលឹក មូ៉រ៉ៃណៃ 8:5–22 សារឡើងវិញ ហើយសរសេរសំបុត្រនៃការកំសាន្តចិត្តមួយច្បាប់ដោយផ្អែកទៅលើការបង្រៀនរបស់លោក មូ៉រ៉ៃណៃ។ សូមបញ្ចូលទាំងការពន្យល់របស់ លោកមូ៉រ៉ៃណៃថា ហេតុអ្វីក៏កុមារតូចៗមិនចាំបាច់ធ្វើបុណ្យជ្រមុជទឹក។

ខ ធ្វើឱ្យបទគម្ពីរទាក់ទងទៅនឹងរឿងមួយ

សូមអានមូ៉រ៉ៃណៃ 8:25–26 ហើយធ្វើបញ្ជីគោលការណ៍ទាំងឡាយ ដែលបានបង្ហាញនៅក្នុងរឿងដូចខាងក្រោមនេះ

ថូម៉ាស បានទទួលបុណ្យជ្រមុជទឹកកាលពីយប់មិញ។ គាត់មានអាយុ ដប់ប្រាំបួនឆ្នាំ ហើយជាលើកទីមួយរបស់គាត់បានញអំពី សាសនាចក្រមកពីមិត្តភក្តិម្នាក់នៅមហាវិទ្យាល័យ។ បន្ទាប់ពីអ្នកផ្សពូផ្សាយសាសនាបង្រៀនគាត់ គាត់ឈប់ផឹកកាហ្វេ តែ និង ស្រាបៀរទៀត។ គាត់សប្បាយចិត្តមកព្រះវិហារ ហើយមានមិត្តភក្តិថ្មីៗ។ មិត្តចាស់របស់គាត់និយាយថាគាត់បានផ្លាស់ប្តូរហើយ—ថាគាត់កាន់តែមានការខ្មាស់អៀន ហើយចេះគិត កាន់តែពេញវ័យ ប៉ុន្តែឈប់សប្បាយទៀតហើយ។ ថូម៉ាស សំឡឹងមើលទៅមុខ ដើម្បីឱ្យជីវិតរបស់គាត់ស្ថិតនៅក្នុងព្រះវិហារ។ គាត់សង្ឃឹមថាទៅបេសកកម្មឱ្យបានឆាប់ ពេលគាត់ក្លាយទៅជាសមាជិកនៃ សាសនាចក្របានមួយឆ្នាំ ដូច្នេះគាត់អាចជួយអ្នកដទៃឱ្យស្វែងរកអ្វីដែលគាត់បានរកឃើញនោះ។

ក្នុងរយៈពេលដ៏ខ្លី បន្ទាប់ពីមកដល់ដែនដីសន្យា លោកលីហៃ បានធ្វើការព្យាកណ៍ចំពោះប្រជាជនរបស់លោកថា "បន្ទាប់ពីពួកគេ បានទទួលពរជ័យជាច្រើនពីព្រះហស្តនៃព្រះអម្ចាស" បើសិនជាពួកគេ "មិនទទួលស្គាល់ព្រះដ៏បរិសុទ្ធនៃពួកសាសន៍អ៊ីស្រាអែល ជាព្រះមេស៊ីដ៏ពិត ជាព្រះប្រោសលោះរបស់គេ និងជាព្រះរបស់គេឡើយ មើលចុះ សេចក្តីជំនុំជំរះរបស់ទ្រង់ ដែលប្រកបដោយ សេចក្តីយុត្តិធម៌នឹងធ្លាក់មកលើពួកគេ" (នីហ្វៃទី2 1:10)។ លោកនិយាយថាព្រះនឹង "ដកយកដែនដីជាកេរ្តិ៍អាករគេមកវិញ ហើយទ្រង់នឹងធ្វើឱ្យពួកគេខ្ចាត់ខ្ចាយហើយរងទុក្ខ" ហើយនោះនឹងមាន "ការខ្ចាយឈាមនឹងការធ្វើទោសដ៏ធំនៅក្នុងចំណោមពួកគេ" (ខ. 11–12)។ នៅពេលអ្នកអានសំបុត្ររបស់លោកមរមន ទៅកាន់ក្វនប្រុសរបស់លោក មូ៉រ៉ៃណៃ សូមរកមើលមូលហេតុទាំង ឡាយថា ហេតុអ្វីបានជាការព្យាករណ៍របស់លោកលីហៃត្រូវជិតបានសំរេច។ តើមេរៀនអ្វីខ្លះ មកពីមូ៉រ៉ៃណៃ 9 អាចជួយអ្នកឱ្យតស៊ូ នឹងសេចក្តីទុច្ចរិតនៅក្នុងលោកីយសព្វថ្ងៃនេះ?

ការយល់ដឹងអំពីព្រះគម្ពីរ

មូ៉រ៉ៃណៃ 9

ដោយក្តីទុក្ខព្រួយ (ខ. 1)—ពិបាកពិពណិនា ឈឺចាប់នៅក្នុងព្រលឹង

តស៊ូ (ខ. 4)—ធ្វើការពុះពារ

រោងឧបោសថតផ្ត (ខ. 6)—រូបកាយរមែងស្លាប់

អំពើគួរខ្ពើមឆ្អើម (ខ. 9, 13, 15)—សេចក្តីទុច្ចរិតដ៏ធ្ងន់ធ្ងរ អាក្រក់

មានអារ្យធម៌ (ខ. 12)—គោរពប្រតិបត្តិសុភាពរាបសារ

ចន្លោះរវាង (ខ. 17)—រវាង

អន់ថយ (ខ. 18)—ភាពពុករលួយ

អំពើខូចអាក្រក់ (ខ. 19)—អាក្រក់ភាពពុករលួយ

កើតទុក្ខ (ខ. 25)—ទុក្ខព្រួយ ទួញយំ

មូ៉រ៉ៃណៃ 9:9—តើហេតុអ្វីបានជាច្បាប់ព្រហ្មចារីយភាពមានសារៈសំខាន់ដូច្នេះ?

អែលឌើរ រីឆាត ជី ស្គត ជាសមាជិកម្នាក់នៃក្រុមសាវកដប់ពីរនាក់ បានបង្រៀនថាះ "អំពើអសីលធម៌ខាងផ្លូវភេទ រាវាំងមិន ឱ្យមានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធជាមួយនឹងការលើកដំកើងភាពភ្លឺស្វាង និងសមត្ថភាពដោយអំណាចទាំងឡាយ។ វាបណ្តាលឱ្យមានអំណាចខាងរាងកាយ និងការដាស់ឱ្យមានវេទនាអារម្មណ៍។ តាមពេលវេលា ការណ៍នោះបង្កើតឡើងនូវ ការស្រេកឃ្លានដែលមិនអាចរលត់បាត់ទៅបាន ដែលជំរុញឱ្យអ្នកជំទាស់កាន់តែធ្វើអំពើបាបធ្ងន់ធ្ងរឡើងៗ។ វាធ្វើឱ្យមានភាព អត្មានិយម ហើយអាចបង្កើតជាសកម្មភាពឈ្លានពាន ដូចជា អំពើតិរិច្ឆានការពន្លូតក្វន ការបំពានលើផ្លូវភេទ និងបទឧក្រិដ្ឋ ឃោរឃៅ។ ការដាស់សតិដូច្នេះ អាចនាំទៅរកសកម្មភាពការរួមភេទដូចគ្នា ហើយសកម្មភាពនេះ គឺអាក្រក់ ហើយខុសទាំងស្រុង" (ក្នុង Conference Report ខែតុលា ឆ្នាំ1994, 50–51 ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ1994, 38)។

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និង ខ នៅពេលអ្នកសិក្សាមូ៉រ៉ៃណៃ 9។

ក្ត៉ ផ្តល់ភស្តុតាង

នៅក្នុងមូ៉រ៉ៃណៃ 9:4 លោកមរមនខ្លាចថា ព្រះវិញ្ញាណនៃព្រះ ចាកចោលពួកសាសន៍នីហ្វៃ។

1. សូមរំលឹក មូ៉រ៉ៃណៃ 9:1– 20 ហើយសរសេរឃ្លា ដែលបង្ហាញថាការសង្កេតរបស់លោកមរមន គឺជាការត្រឹមត្រូវ។
2. សូមអានខ. 21–26 ហើយសរសេរកថាក័ណ្ឌមួយដែលអ្នកជឿដោយខ្លីអំពីអារម្មណ៍របស់លោកមរមន។
3. ឆ្លើយតបចំពោះសំនួររបស់លោកមរមនសួរដល់ក្វនប្រុសរបស់លោកនៅក្នុងខ. 13–14។
4. ចូរពិពណិនាអំពីអ្វីដែលអ្នកគិតថាជាអត្ថន័យនៃ "ការអាណិត" (ខ. 20)។ តើមានភស្តុតាងនៃស្ថានភាពនេះអ្វីខ្លះ ដែលអ្នកឃើញមានទៅសព្វថ្ងៃនេះ?

២ ផ្តល់គំនិតរបស់អ្នក

សូមអានមូ៉រ៉ណៃ 9:9 ហើយពន្យល់ថា ហេតុអ្វីបានជាអ្នកណ្យើថា ព្រហ្មចារីយភាព និងគុណធម៌ គឺជា "វត្ថុគួរឱ្យស្រឡាញ់ និងមានតម្លៃលើសអ្វីព្យទាំងអស់។"

មូ៉រ៉ណៃ

នៅក្នុងការចាប់ផ្តើមនៃឆ្នាំសិក្សាសាលារៀន ដោយអ្នកបានចាប់ផ្តើមសិក្សាព្រះគម្ពីរ មរមនជារៀងរាល់ថ្ងៃ ដែលធ្វើ ទីបន្ទាល់ អំពីព្រះយេស៊ូវគ្រីស្ទ និងអំពីផែនការនៃ សេចក្តីសង្គ្រោះ។ ឥឡូវនេះវាដល់ពេល ដើម្បីធ្វើការវិភាគពី អារម្មណ៍ និង ទីបន្ទាល់របស់ អ្នកអំពីព្រះគម្ពីរមរមន។ ទីបន្ទាល់របស់អ្នកគួរតែរឹងមាំ ជាងមុន ពីព្រោះអ្នកបានអនុវត្ត គោលការណ៍នៃសេចក្តី សង្គ្រោះជាច្រើន ដែលមានបង្រៀននៅក្នុងព្រះគម្ពីរមរមននេះ។

ការអានរបស់អ្នកនៅក្នុងជំពូកចុងក្រោយនៃព្រះគម្ពីរមរមន គួរតែមិនមែនជា ពេលចុងក្រោយ ដែលអ្នកអាន និងសិក្សានៅក្នុង ព្រះគម្ពីរដ៏ពិសិដ្ឋនេះទេ។ សូមធ្វើឱ្យការសិក្សានៃព្រះគម្ពីរនេះបន្តមាននៅក្នុងរាកជីវិត នោះនឹងអាច ជួយអ្នកឱ្យ "មកឯព្រះគ្រីស្ទ" ហើយឱ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់" (មូ៉រ៉ណៃ 10:32)។

ការយល់ដឹងអំពីព្រះគម្ពីរ

មូ៉រ៉ណៃ 10

សេចក្តីទូន្មាន ទូន្មាន (ខ.2–4)—ការលើកទឹកចិត្ត ការដាស់តឿន

ជាច្រើនដង (ខ. 17)—ដាច់ដោយឡែក

សេចក្តីអស់សង្ឃឹម (ខ. 22)—អស់សង្ឃឹម

ហួចហៅ (ខ. 28)—ផ្សាយ សំលេងចាក់ចុចក្នុងចិត្ត

ត្រូវបំភាន់ (ខ. 31)—បានបំបែកចេញពីគ្នា

ការសិក្សាព្រះគម្ពីរ

ចូរធ្វើសកម្មភាព ក និងសកម្មភាពមួយក្នុងសកម្មភាព (ខ–យ) នៅពេលអ្នកសិក្សាមូ៉រ៉ណៃ 10។

ក ការទន្ទេញខគម្ពីរ—មូ៉រ៉ណៃ 10:4–5

1. សូមអាន មូ៉រ៉ណៃ 10:3–7 ហើយធ្វើបញ្ជីពីអ្វី ដែលយើងគួរតែធ្វើ ដើម្បី "ដឹងនូវសេចក្តីពិតនៃ ការណ៍ត្រប់យ៉ាង។"
2. សូមសរសេរនៅក្នុងកំណត់ហេតុមួយ ដែលមានបញ្ជូល (1) ទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរ មរមន (2) រប្យៀបដើម្បីធ្វើតាម សេចក្តីទូន្មាន ដែលមាននៅក្នុងខគម្ពីរទាំងនោះ បានជួយធ្វើ ឱ្យទីបន្ទាល់របស់អ្នករីកចំរើនឡើង និង(3) រប្យៀបដែលទីបន្ទាល់ របស់អ្នកបានផ្លាស់ប្តូរ នៅពេលអ្នកសិក្សាព្រះគម្ពីរមរមននៅក្នុងឆ្នាំនេះ នៅក្នុងថ្នាក់សិក្ខាសាលា។

ខ សំគាល់អំពីអំណោយទានព្រះវិញ្ញាណបរិសុទ្ធ

នៅក្នុងមូ៉រ៉ណៃ 10:8–19 អ្នកនឹងរកឃើញឧទាហរណ៍ទាំងឡាយអំពីព្រះវិញ្ញាណបរិសុទ្ធ។

1. នៅក្នុងស្យៀវភៅសរសេររបស់អ្នក ចូរធ្វើការកត់សំគាល់អំពីអំណោយទានទាំងឡាយ ដែលលោកមូ៉រ៉ណៃបាននិយាយ។
2. ហេតុអ្វីក៏អ្នកគិតថា អំណោយទានទាំងឡាយរបស់ព្រះ ត្រូវបានប្រគល់មកឱ្យមនុស្សដូច្នេះ?
3. ចូរពន្យល់អំពីរប្យៀបថាការមានអំណោយទានទាំងនេះ អាចជួយអ្នកត្រួសាររបស់អ្នក និងបំរើ អ្នកដទៃទៀតជាយ៉ាងណា។

គ បញ្ជាប់ប្រយោគ

ចូរប្រើអ្វី ដែលអ្នករៀននៅក្នុងមូ៉រ៉ណៃ 10:24–29 មកបំពេញនៅក្នុងប្រយោគខាងក្រោមនេះ

1. វេទនាដល់អ្នកណាដែលស្លាប់នៅក្នុងបាបរបស់ខ្លួន ពីព្រោះ . . .
2. មនុស្សត្រប់គ្នានឹងស្គាល់សេចក្តីពិត នៅពេល . . .
3. វាជារឿងដែលអាចធ្វើទៅបានដើម្បីស្គាល់ពីសេចក្តីពិត ពីព្រោះតែ . . .

ឃ រំលឹកពីបទពិសោធន៍មួយ

ចូរគិតអំពីបទពិសោធន៍ទាំងឡាយរបស់អ្នកនៅក្នុងថ្នាក់សិក្ខាសាលាឆ្នាំនេះ ហើយឆ្លើយនឹងសំនួរ អំពីមូ៉រ៉ណៃ 10:32–34 ដូចខាងក្រោមនេះ

1. ខ. 32ៈ តើមានបទពិសោធន៍មួយណា ដែលបានជួយដល់អ្នក "មកឯព្រះគ្រីស្ទ" ហើយ "លះបង់ចោលនូវអស់ទាំងអំពើដែលពុំ បរិសុទ្ធ"?

2. ខ. 33៖ តើមេរៀនណាមួយ ដែលអ្នកអាចរំលឹកចាំពីការសិក្សានៅក្នុងឆ្នាំនេះ ដែលជួយអ្នកធ្វើការសំរេចចិត្តចង់ឱ្យបាន “បរិសុទ្ធ ដោយគ្មានប្រឡាក់” នោះ?
3. ខ. 34៖ តើព្យាការីក្នុងព្រះគម្ពីរមរមនផ្សេងទៀតណាខ្លះ ដែលបានបង្រៀនអំពីគោលលទ្ធិដូចគ្នានឹងលោកម៉ូរ៉ូណាបានបង្រៀន នៅក្នុងខនេះ? (សូមមើល យ៉ាកុប 6៖13)។

ឥកន្លែងដែលអាចរកបាននៅក្នុងព្រះគម្ពីរមរមន
(មានការដាក់ឧបាមួយគ្នានៅទិញនៅមក)

ទំនាក់ទំនងទីកន្លែងអាចរកបាននៅក្នុងព្រះគម្ពីរមរមនពីងផ្នែកលើភស្តុតាងនៅខាងក្នុងនោះ។ គ្មានការដាក់បន្ថែម
ត្រូវធ្វើឡើង ដើម្បីសំគាល់ពីចំណុចនៅលើផែនទីនេះ ជាមួយនឹងទីតាំងដែលនៅមានក្នុងភូមិសាស្ត្រណានោះទេ។
រៀបចំឡើងដោយ លោក ដានីយែ៉ល អេច ហូតឡូ ហើយត្រូវបានប្រើប្រាស់តាមការអនុញ្ញត្តរបស់លោក។



អ្បបចំណាយ
ប្រព័ន្ធអប់រំនៃសាសនាចក្រ
© 1989 ដោយ
Intellectual Reserve Inc.
រក្សាសិទ្ធិគ្រប់យ៉ាង

សារសាធារណៈ

ព្រះយេស៊ូគ្រីស្ទ

នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02341 87258 0
34187 258